បណ្ឌិតសភាចារ្យ ខ្លុត ធីតា

# គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស
# ច្បាប់មនុ
# The Laws of Manu



រាជបណ្ឌិត្យសភាកម្ពុជា

ព.ស.២៥៦០ គ.ស.២០១៦

សៀវភៅលេខ VOL.XXV (24) រក្សាសិទ្ធិ

# មាតិកា


-អារម្ភកថាអ្នកបកប្រែ........................................................................................ ii
-ពាក្យសរសេរកាត់............................................................................................ iii
I -សេចក្តីផ្តើម.................................................................................................. ១
II-............................................................................................................... ២៦
III-.............................................................................................................. ៨០
ជំពូក ១ ច្បាប់មនុ........................................................................................... ៩៥
ជំពូក ២ ខ្លឹមសារច្បាប់មនុ................................................................................. ១១៥
ជំពូក ៣ ខ្លឹមសារច្បាប់មនុ................................................................................. ១៤៥
ជំពូក ៤ ខ្លឹមសារច្បាប់មនុ................................................................................. ១៧៩
ជំពូក ៥ ខ្លឹមសារច្បាប់មនុ................................................................................. ២០៧
ជំពូក ៦ ខ្លឹមសារច្បាប់មនុ................................................................................. ២២៦
ជំពូក ៧ ខ្លឹមសារច្បាប់មនុ................................................................................. ២៣៨
ជំពូក ៨ ខ្លឹមសារច្បាប់មនុ................................................................................. ២៦៤
-ច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌៈ នីតិវិធី..................................................................... ២៧៤
ជំពូក ៩.......................................................................................................... ៣១៦
-ករណីយកិច្ចរបស់ព្រះរាជា ( DUTIES OF A KING )........................................................ ៣៥៨
-គ្រាអាសន្ន ចម្រុះវណ្ណៈ......................................................................................... ៣៦៨
ជំពូក ១០........................................................................................................ ៣៦៨
-មុខរបរតាមវណ្ណៈ............................................................................................. ៣៧៩
ជំពូក ១១ ការធ្វើតបៈ ការបរិច្ចាគ និងការបូជាយញ្ញ........................................................ ៣៨៨
-ការចាត់ថ្នាក់បទល្មើស.......................................................................................... ៣៩៦
-ការដេញចេញពីសាសនា និងការឲ្យចូលក្នុងសាសនាវិញ.................................................. ៤១៤
ជំពូក ១២........................................................................................................ ៤២៣
-សេចក្តីសង្ខេប.................................................................................................. ៤៤៣
-ឧបសម្ព័ន្ធ........................................................................................................ ៤៤៤

ទីស្ដីការគណៈរដ្ឋមន្ត្រី
រាជបណ្ឌិត្យសភាកម្ពុជា

Royal Academy of Cambodia
Académie Royale du Cambodge

# អារម្ភកថាអ្នកបកប្រែ

អាស្រ័យដោយខ្ញុំជាអ្នកស្រាវជ្រាវផ្នែក «ទស្សនវិជ្ជាច្បាប់និងទស្សនវិជ្ជាព្រះពុទ្ធសាសនា» ក្រោយពីខ្ញុំបានឃើញឯកសារនេះ ខ្ញុំយល់ថាពិតជាសំខាន់ណាស់ទោះជាមិនងាយអាន មិនងាយយល់ឱ្យបានជ្រៅជ្រះក៏ដោយបើប្រៀបទៅនឹងពេលដែលខ្ញុំធ្លាប់ស្រាវជ្រាវរយៈពេល២៦ឆ្នាំ គឺពីឆ្នាំ១៩៩០ (តាំងពីនិស្សិតបណ្ឌិតនិងជាបណ្ឌិតនៅទីក្រុងហាណូយ ប្រទេសវៀតណាមខាងជើង ទីក្រុងកូឡំបូ ប្រទេសស្រីលង្កា នៅបណ្ណាល័យមួយចំនួនទៀតដូចជា ៖ ប្រទេសឥណ្ឌានិងនៅបណ្ណាល័យជាតិ បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យវត្តឧណ្ណាឡោមបណ្ណាល័យរណសិរ្សជាតិ បណ្ណាល័យអាមេរិក បារាំង ថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន សាំងហ្គាពួរ ប្រេស៊ីលគុយបា ក្រុងប៉េកាំង ក្រុងក្វាំងស៊ី ក្រុងជីវជាំង ក្រុងចានស៊ី ក្រុងយូណាន ក្រុងសៀងហៃ។ល។) ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ឫសគល់នៅក្នុងសៀវភៅនេះច្រើនដែរ។ បច្ចុប្បន្នរួមទាំងខ្ញុំជាអ្នកធ្វើការក្នុងការងារ (ទីប្រឹក្សាផ្ទាល់សម្ដេច អគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា) និងជាមន្ត្រីស្រាវជ្រាវពាក្យច្បាប់ ព្រមទាំងជាអតីតនិស្សិតថ្នាក់មធ្យមពុទ្ធិកៈមហាវិទ្យាល័យ ដោយគិតតាំងពីឆ្នាំ១៩៦៣ ទៀតផង។

ខ្ញុំបានគិតទៀតថា សៀវភៅច្បាប់មនុនេះ អ្នកសិក្សាច្បាប់ទាំងឡាយអ្នកស្រាវជ្រាវមិនថាថ្នាក់ណាឬថ្នាក់ណាទេ ឱ្យតែព្យាយាមអានសាចុះសាឡើងឱ្យបានពីរ ឬបីចប់នោះ គឺពិតជាយល់អំពីខ្លឹមសារនៃច្បាប់ហើយក៏អាចចេះរួមរស់ជាមួយគ្នាដោយរីករាយគ្រប់ច្បាប់ទាំងអស់ ថែមទាំងអាចកាត់បន្ថយបានច្រើននូវចម្ងល់ឥតព្រំដែនអំពីប្រវត្តិច្បាប់របស់ យើងទាំងអស់គ្នាបានផងដែរ។ មានន័យថា អ្វីដែលយើងចង់បាននោះៗបានបង្ហាញនៅក្នុងអត្ថបទនេះអស់ហើយៗរួមទាំងចម្លើយទៀតផង ពីព្រោះសៀវភៅនេះ ជាឫសគល់ពាក្យសម្ដីក៏ដូចជាឫសគល់ច្បាប់លើកពិភពលោក។ មានន័យថា មុននឹងមកដល់សម័យបច្ចេកវិទ្យារីកចម្រើន ប្រទេសលើលោកទាំងឡាយ គេចមិនផុតពីការស្រាវជ្រាវរកឫសដើមរបស់ខ្លួន ទាំងជាតិពន្ធុមនុស្ស ទាំងអ្វីៗដែលជាតម្រូវការរបស់មនុស្សសម័យដើមផងដែរ ក្នុងនោះរួមទាំងច្បាប់ធម្មជាតិជាកត្តាចម្បង។ ម្ល៉ោះហើយពួកខ្ញុំជាព្រឹទ្ធាចារ្យចាំបាច់ត្រូវខិតខំធ្វើយ៉ាងណា ដើម្បីស្រាវជ្រាវមរតកបុរាណៗ សម្រាប់បង្ហាញផ្លូវខ្លះៗតាមតែអាចធ្វើទៅបានដល់អ្នកជំនាន់ក្រោយជាចាំបាច់។

ម្យ៉ាងទៀតខ្ញុំសូមជម្រាបបញ្ជាក់ជាថ្មីម្ដងទៀតថា ក្នុងការប្រែសម្រួលពីភាសា អង់គ្លេសមកជាភាសាជាតិយើងតែងតែមានការឆ្នៃពាក្យពេចន៍ ឃ្លាប្រយោគខ្លះជាធម្មតា ប៉ុន្តែទោះជាយ៉ាងណាក៏ខ្ញុំឥតមានថែមថយសាច់រឿង ឬពន្លើសពាក្យសម្ដីទេ មានតែកាត់បន្ថយខ្លះ ព្រោះកន្លែងខ្លះបាលី និងសំស្ក្រឹតច្រើនពេកនាំឱ្យអ្នកមិនធ្លាប់រៀនពិបាកអាន ពិបាកយល់។

ហេតុនេះសូមមិត្តអ្នកអាន អ្នកស្រាវជ្រាវមេត្តាយោគយល់ខ្ញុំផង។

**សូមឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធអស់លោកដែលបានចែកស្ថានទៅ ហើយៗរួមទាំងលោកឪពុកអ្នកម្ដាយ និងក្រុមគ្រួសាររបស់ខ្ញុំដែលបានបាត់បង់ជីវិតនៅសម័យប៉ុលពត ក៏ដូចជាសម័យមុននិងក្រោយប៉ុលពតផងដែរ។**

ខ្ញុំរង់ចាំទទួលនូវមតិរិះគន់និងកែលម្អ
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៦

**បណ្ឌិតសភាចារ្យ ខ្លូត ធីតា**

- ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
- ប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន
- ទទួលបន្ទុកការងារធម្មការ និងសាសនា
- អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

# ពាក្យសរសេរកាត់

គ .= គោត្តមីយ ធម៌សាស្ត្រ; ព .= ពោធាយនីយ ធម៌សាស្ត្រៈ អាប .= អាបស្តម្ពីយ ធម៌សាស្ត្រៈ វ .= វាសិស្ថិ ធម៌សាស្ត្រៈ ; វិ .= វិស្ណុ-ស្មិតិ ; យា .= យាញ្ញវល្កីយ ធម៌សាស្ត្រៈ ; បរ .= បរាសរស្មិតិ ; មា .ស្រ .= មានវៈ-ស្រាទ្ធកល្ប ៦០ .សេចក្តីណែនាំ ទំ)-៦៣(; អា .គ្ឫ .= អាស្វលាយនគ្ឫហ្យ-សូត្រ ; សា .គ្ឫ .= សាង្ខាយន គ្ឫហ្យ-សូត្រ ; មៃ .ឧប .= មៃត្រាយណីយព្រាហ្មណោបនិស័ទ ; ឥសា .ឧប .= ឥសាវាស្យោបនិស័ទ ; ស.ឧប .= សំហិតោបនិស័ទ ; និរ .= និរុក្ត ; មហ .= មហាភារតៈ ; វ .ប .= វិស្ណុ-បុរាណ តាមអត្ថបទបកប្រែរបស់លោក Wilson ដែលបានផ្ទៀងផ្ទាត់ដោយបណ្ឌិត F. E. Hall ។

# សេចក្តីផ្តើម

I

ការបកប្រែគម្ពីរធម៌សាស្ត្រៈក្នុងគម្ពីរលេខ២ និងលេខ១៤ ជាការងារដ៏ពិបាកស្មុគស្មាញ ដូចជាបញ្ហាប្រវត្តិសាស្ត្រដែរ។ យ៉ាងណាក៏ដោយ ក៏គម្ពីរនេះមានសភាពស្មុគស្មាញតិចជាងគម្ពីរទាំងឡាយ ដែលជាគម្ពីរច្បាប់ពាក្យកាព្យ ហើយជាពិសេសគម្ពីរច្បាប់មនុ ឬអាចនិយាយឱ្យកាន់តែជាក់ច្បាស់ជាងនេះទៅទៀត គឺអត្ថបទរបស់ *ភ្រិគុ* (Bhrigu) នៃវិទ្យាស្ថានច្បាប់ពិសិដ្ឋដែលល្បីល្បាញដោយច្បាប់មនុ។ សូម្បីតែសម្ភារៈស្រាវជ្រាវរាវរកប្រវត្តិគម្ពីរធម៌សាស្ត្រៈនេះ មានតិចតួចស្ដួចស្ដើង និងមានខ្លះនៅលាយឡំនឹងប្រពៃណី ដែលជាទូទៅស្ថិតក្នុងចំណោមអ្នកសិក្សា ប៉ុន្តែមានប្រភពមិនច្បាស់លាស់ក៏ដោយ ក៏ឯកសារនេះមិនត្រឹមតែមិននិយាយបំផ្លើសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានភាពត្រូវគ្នាទាំងស្រុងជាមួយនឹងហេតុការណ៍ ដែលគេបានដឹងពីប្រភពប្រវត្តិសាស្ត្រជាក់លាក់ផង។ ជាងនេះទៅទៀត នេះគឺជាចំណុចដ៏សំខាន់បំផុត ទោះបីអត្ថបទធម៌សាស្ត្រៈ មិនសុទ្ធតែរក្សាបាននូវភាពបរិសុទ្ធឥតខ្ចោះក្តីក៏អត្ថបទទាំងឡាយរក្សាបាននូវលក្ខណៈដើមច្បាស់លាស់របស់វាដែរ។ អត្ថបទនេះទៀតសោត មិនចង់បង្ហាញនូវអ្វីៗឱ្យលើសពីសេចក្តីរៀបរាប់ផ្នែកសីលធម៌ធម្មតា ដោយផ្អែកលើការបង្រៀនគម្ពីរវេទ នានា ស្តីអំពីសេចក្តីសម្រេចរបស់អ្នកទាំងឡាយដែលមានចំណេះដឹងផ្នែកច្បាប់ និងស្តីពីទំនៀមទម្លាប់របស់ពួកអារ្យជនដែលមានគុណធម៌ខ្ពស់។ នៅក្នុងករណីមួយចំនួន អ្នកនិពន្ធគម្ពីរនេះនិយាយរៀបរាប់ច្រើនជាពាក្យសាមញ្ញធម្មតាឱ្យបានច្រើន។ ដូច្នេះ*អាបស្តម្ពៈ* (Āpastamba) ទូញសោកដដែលៗ រៀបរាប់អំពីអំពើបាប និងចំណុចខ្សោយរបស់មនុស្សនៅសម័យក្រោយៗមកទៀត ហើយព្រះគោត្តម បានក្រើនរំលឹកអំពីការគ្រាប់តាមអំពើខុសប្រក្រតីរបស់មនុស្សជំនាន់ដើម ដែលភាពមហាល្បីល្បាញជួយរក្សាពួកគេឱ្យរួចផុតពីការរលំរលាយ។ សូម្បីគ្រាន់តែពិនិត្យមើលទិដ្ឋភាពសើៗ យើងនៅតែមានការ ដឹងគុណចំពោះអ្វីៗដែលជាគោលបំណងដើមនៃគម្ពីរធម៌សូត្រនេះ។ គ្មាននរណាអាចមន្ទិលសង្ស័យនៅពេលនេះថា គម្ពីរទាំងឡាយជាស្នាដៃនិពន្ធ សរសេរដោយផ្ទាល់ដៃរបស់គ្រូអាចារ្យនៃសាលាវេទ សម្រាប់ណែនាំប្រៀនប្រដៅសិស្សគណរបស់ខ្លួនថា ដំបូងគម្ពីរទាំងនេះ ត្រូវរៀបរៀងឡើងសម្រាប់មជ្ឈដ្ឋានមនុស្សជាក់លាក់ និងថាក្រោយមក គម្ពីរទាំងឡាយនេះត្រូវបានទទួលស្គាល់ជាប្រភពច្បាប់ពិសិដ្ឋ ដែលអាចអនុវត្តបានសម្រាប់ពួកអារ្យជនទាំងអស់។ ការពិតនេះត្រូវបានទទួលស្គាល់ទាំងស្រុងពីសំណាក់ប្រពៃណីហិណ្ឌូ ថ្វីបើក្នុងករណីដែលធម៌សូត្រនានា លែងក្លាយជាកម្មសិទ្ធិរបស់សាលាវេទផ្ដាច់មុខក៏ដោយ។

ម្យ៉ាងវិញទៀត កម្រងក្បួនច្បាប់ពាក្យកាព្យ ពោរពេញទៅដោយប្រពៃណីបែបសន្មតជាក់ស្តែងតាមរយៈរឿងព្រេងវេទកថា ដែលអាចកើតឡើងព្រោងព្រាតដោយឯងៗផង ដោយហេតុថាដើមកំណើតពិតប្រាកដ គេអាចភ្លេចបាត់ទៅហើយក៏ថាបាន ឬគេអាចប្រឌិតឡើងដោយចេតនា ដើម្បីសបញ្ជាក់ថា ស្នាដៃទាំងអស់នេះមានអំណាចអាទិទេព ហេតុនេះទើបតម្រូវឱ្យមានការគោរព ដោយគ្មានពាក្យនឹងថ្លាថ្លែងពីសំណាក់ពួកអារ្យជនទាំងអស់។ នៃ! អ្វីៗទៀតជាច្រើន ដូចជារឿងព្រេងឬជា ផ្នែក

នៃរឿងព្រេង ដែលគេបានយកទៅដាក់បញ្ចូលក្នុងអត្ថបទនេះ ហើយធ្វើឱ្យលក្ខណៈពិតប្រាកដនៃគម្ពីរស្ម្រិតិនេះមានភាពស្រពេចស្រពិល។ វិសេសភាពទាំងអស់នេះ ត្រូវបានកត់សម្គាល់ជាពិសេស នៅក្នុងមាណាវៈធម៌សាស្ត្រៈ ដែលជំពូកទី១ទាំងមូល ជាជំពូកឧទ្ទិសចំពោះគោលបំណង បង្ហាញអំពី វិសាលភាពគួរឱ្យទុកចិត្តបាននៃសៀវភៅនេះ និងរៀបរាប់អំពីដើមកំណើតព្រះអាទិទេព ព្រមទាំង របៀបដែលព្រះអាទិទេពលាតត្រដាងគម្ពីរនេះបង្ហាញមនុស្សលោក។ ពាក្យកាព្យផ្ដើមនៃគម្ពីរនេះ ដំណាលអំពីរបៀបដែលពួកមហាបណ្ឌិតបានជួបព្រះ អាទិទេព**មនុ** ជាអ្នកជំនាន់ក្រោយរបស់ព្រះព្រហ្ម ដែលមានអត្ថិភាពនៅឡើយ ហើយស្នើសុំព្រះអង្គ បកស្រាយរៀបរាប់អំពីច្បាប់ដ៏ពិសិដ្ឋនេះ។ មនុទ្រង់យល់ស្របតាមសំណើរបស់មហាបណ្ឌិត និងពិពណ៌នាប្រាប់ពួកគាត់អំពីការបង្កើត ព្រមទាំងអំពីដើមកំណើតផ្ទាល់របស់ទ្រង់មកពីព្រះព្រហ្ម។ បន្ទាប់ពីថ្លាថ្លែងថា ព្រះអង្គបានសិក្សាចេះដឹងនៅ "វិទ្យាស្ថានច្បាប់ពិសិដ្ឋ" ដែលទ្រង់ខ្លួនឯងជាអ្នកបង្កើត ហើយថាព្រះអង្គបានបង្រៀនក្បួនតម្រានេះ ដល់បណ្ឌិតចំនួន ១០រូប ដែលព្រះអង្គបានបង្កើតឡើងនៅដើមដំបូង ទ្រង់ផ្ទេរស្នាដៃតម្រាដែលកំពុងបរិយាយនេះ ដល់ភ្រិគុ (Bhrigu) ជាកូនប្រុសមួយក្នុងចំណោមកូនប្រុសទាំង ១០ ដែលកើតចេញពីហឫទ័យរបស់ទ្រង់ផ្ទាល់។ អ្នកជំនាន់ក្រោយនេះ ចាប់ផ្ដើមភារកិច្ចរបស់ខ្លួន ក្នុងនាមជាអ្នកអធិប្បាយ រៀបរាប់អំពីការបង្កើតគម្ពីរមនុនេះ។ មុនដំបូង គាត់បង្រៀនទ្រឹស្ដីស្ដីពីម័នវន្តរៈ (Manvantaras) ចំនួន ៧ យោគ និងវិធីចែកពេលវេលាផ្សេងៗទៀត។ បន្ទាប់មក គាត់បានពិពណ៌នាយ៉ាងសង្ខេបអំពី ករណីយកិច្ចរបស់វណ្ណៈសំខាន់ៗចំនួនបួន រួចហើយបន្តពោលសរសេរពីព្រះព្រហ្ម និងវិទ្យាស្ថានមនុ និងបញ្ចប់ដោយការរៀបរាប់ឈ្មោះមាតិកានៃជំពូកទាំង១២នៃស្នាដៃនេះ ដែលគាត់សន្យាធ្វើអធិប្បាយ លាតត្រដាងយ៉ាងច្បាស់លាស់ដូចដែលគាត់បានទទួលពីព្រះអាទិទេព។ នៅក្នុងជំពូកបន្តបន្ទាប់ យើងឃើញមានការសរសេរជាញឹកញយរៀបរាប់ពីស្ថានភាពដែលអ្នកទី១ បានពិពណ៌នា។ នៅក្នុងវគ្គប្រមាណជា ៤០វគ្គ យើងឃើញមានការដាក់បញ្ចូលប្រធានបទថ្មីមួយ ដោយពាក្យកាព្យប្រារព្ធគួរឱ្យជក់ចិត្ត ដែលមានឃ្លាដូចជា "បញ្ហាយ៉ាងនេះ និងយ៉ាងនោះ យើងនឹងពន្យល់ប្រាប់ឯង ឥឡូវចូរឯងចាំស្ដាប់ចុះ" ឬ "យើងនឹងបន្តប្រកាសថា"។

អ្នកទី២ (ជំពូក៥ កាព្យលេខ១-៣ និងជំពូក ១២ លេខ១-២) មហាបណ្ឌិតទាំងនោះ ខិតខំស្ដាប់ នៅពេលមានការរំខានបទអធិប្បាយរបស់ភ្រិគុ និងសម្ដែងចិត្តចេតនាចង់ទទួលការណែនាំពីចំណុចសំខាន់ៗ និងអំពីព្រឹត្តិការណ៍ដែលព្រះភ្រិគុ ត្រូវបានបំពេញនាទីជាអ្នកពិពណ៌នាជាថ្មីម្ដងទៀតផង។ ជាងនេះទៅទៀត នៅក្នុងពាក្យកាព្យមួយចំនួន (សូមមើល ៖ សូមមើលលិបិក្រម s.v. មនុ) ព្រះមនុជាពិសេសត្រូវចាត់ជាអ្នកនិពន្ធ វិធានក្បួនច្បាប់ជាច្រើន និងជំពូកទី២ កាព្យលេខ ៧ ស្ដីពីអំណាចនៃការបង្រៀនរបស់ព្រះមនុ ត្រូវអះអាងប្រកបដោយវោហារសាស្ត្រគួរឱ្យជក់ចិត្តថា "ដោយហេតុថាព្រះអង្គជាព្រះសព្វញ្ញុញាណ"។ នៅក្នុងវគ្គពីរទៀតយ៉ាងណាក៏ដោយ ព្រះមនុ ទំនងជាមានលក្ខណៈច្រើនបែបច្រើនយ៉ាង។ ជំពូកទី៧ លេខ៤២ តាមការរៀបរាប់ឈ្មោះ ទ្រង់ស្ថិតក្នុងចំណោមមហារាជ្យ ដែល

បានទទួលអធិបតេយ្យភាពពីការគោរពបូជារបស់ខ្លួន ហើយជំពូកទី១២ លេខ ១២៣ ទ្រង់មានលក្ខណៈជាព្រាហ្មណ៍ដ៏កំពូល។

ការរៀបរាប់ពីដើមកំណើតនៃគម្ពីរមនុស្ម្រិតិនេះ នឹងមានការកែសម្រួលតិចតួចពីសំណាក់អ្នកដែលសុខចិត្តទទួលយកកំណាព្យ ដែលមាននៅក្នុងពាក្យប្រារព្ធស្ម្រិតិ យោងតាមអត្ថកថាចារ្យនានា ដូចជា គោវិន្ទរាគៈ នារាយណៈ និងរាឃវានន្ទៈ ព្រមទាំងយោងតាមសំណៅកាស្មៀរ និងសំណៅរស្នាដៃសិល្បៈមួយចំនួនទៀត។ ដោយសារកំណាព្យនេះ មានការបួងសួងរបស់ពួកព្រហ្មញ្ញដ៏មានអាយុ និងការសន្យាបកស្រាយច្បាប់ ដែលព្រះមនុបានបង្រៀនពាក្យកាព្យ ដូចលោកគោវិន្ទរាគៈ (សូមមើលកំណត់សម្គាល់ស្តីពីសៀវភៅមនុ ជំពូក១ លេខ ១) បានចង្អុលបង្ហាញថា "សិស្សគណមួយចំនួនរបស់លោកគ្រូភ្រិគុនិទានរៀបរាប់ស្នាដៃ ដែលបានប្រទានឱ្យលោក តាមរយៈខ្សែស្រឡាយគ្រូដែលមិនអាចផ្តាច់បាន។" អនុលោមតាមកំណាព្យនេះ ហេតុនេះយើងមានបទផ្តើមបីផ្នែកជំនួសឱ្យសេចក្តីផ្តើមពីរ ហើយគម្ពីរមនុស្ម្រិតិរបស់យើងមិនមានពាក្យពេចន៍ដើមរបស់ព្រះគ្រូភ្រិគុទេ ប៉ុន្តែការពិនិត្យអត្ថបទតាមសំណៅដៃនៃសំណេររបស់លោក ដូចជាគម្ពីរនេះត្រូវបានប្រគល់បន្តគ្នា ក្នុងចំណោមសិស្សគណរបស់លោក។ ពាក្យកាព្យបន្ថែមនេះ ទំនងជាចង់ធ្វើឱ្យសាច់រឿងកាន់តែគួរឱ្យទុកចិត្តឡើង។

ការកត់សម្គាល់ ដែលអ្នកអធិប្បាយធ្វើការពិពណ៌នានេះមានតិចតួច ហើយសូម្បីសេចក្តីសង្កេត នោះមានន័យជួយបង្កើនភាពជឿជាក់ក៏ដោយ ក៏យ៉ាងហោចណាស់មានសេចក្តីសង្កេតខ្លះ ធ្វើឱ្យអាប់ឱនដល់គម្ពីរនេះទៅវិញ។ លោកមេធាតិថិ បញ្ជាក់នៅក្នុងសេចក្តីសម្គាល់របស់ខ្លួនអំពីគម្ពីរមនុ ជំពូកទី១ លេខ ១ ថា "ព្រះប្រាគាបតិមនុ ជាបុគ្គលពិសេស ល្អឥតខ្ចោះ ក្នុងការសិក្សាអំពីសាខាវេទជាច្រើនតាមចំណេះដឹងអត្ថរស អត្ថន័យ និងចំណេះដឹងក្នុងការប្រតិបត្តិ( សីលរបស់ខ្លួន) ដែលបានតាមរយៈ ប្រពៃណីដ៏ពិសិដ្ឋ ដែលបានផ្ទេរជាបន្តបន្ទាប់ឱ្យអ្នកជំនាន់ ក្រោយយ៉ាងទៀងទាត់។ គោវិន្ទរាគៈយល់ស្របយ៉ាងខ្លាំង និងនិយាយថា មនុ គឺជា "មហាបណ្ឌិតមួយរូប ដែលមានឈ្មោះដ៏មានអត្ថន័យនៅក្នុងគម្ពីរវេទទាំងមូល ដែលអ្នកចេះដឹងគ្រប់រូបសុទ្ធតែបានដឹងបានស្គាល់គ្រប់គ្នាតាមរយៈ ប្រពៃណីដែលបានផ្ទេរឱ្យបច្ឆាជន កូនចៅជំនាន់ក្រោយយ៉ាងទៀងទាត់ និងដែលបានទទួលអំណាចបង្កើតលោក រក្សាលោក និងបំផ្លាញលោក"។ អាចនិយាយបានម្យ៉ាងទៀតថា **កុល្លូកៈ** ថ្វីបើលោកសុខ ចិត្តជឿតាមនិរុត្តិសាស្ត្រ និងការបកស្រាយពន្យល់អំពីព្រះនាមរបស់មនុ ដែលកើតចេញពី **មនុស្ស** "ដើម្បីយល់ដឹងពីអត្ថន័យវេទ" និងថ្វីបើលោកព្រមទទួលយកសារជាតិមនុស្សនៅក្នុងសាស្ត្រារបស់ខ្លួនក៏ដោយ ក៏មានចំណុចខ្លះផ្សេងគ្នាពីការពិពណ៌នារបស់មនុស្សយើងដែរ។ យោងតាមជំពូកទី១២ កាព្យលេខ១២៣ លោកថ្លែងពីគម្ពីរមនុ ថាជាការចុះចាប់កំណើត ឬជាអវតានៃព្រលឹងវិញ្ញាណដ៏កំពូល។ លើសពីនេះ លោកមេធាតិថិនិងកុល្លូកៈ លើកហេតុផល នៅក្នុងកំណត់សម្គាល់របស់ខ្លួនអំពី កំណាព្យដដែលនៅក្នុងវគ្គផ្សេងៗពី**ស្រុតិ** (ឬស្លូតិ៍) និងស្ម្រិតិ ដែលទំនងជាបង្ហាញពីអានុភាពរបស់គម្ពីរ មនុស្ម្រិតិ។ លោកទាំងពីរដកស្រង់ពាក្យផ្សេងៗ ចេញពីខ្លឹមសារគម្ពីរវេទដ៏ល្បីល្បាញ ដែលប្រកាសថា" អ្វីៗដែលព្រះមនុបាននិយាយ គឺជាឱសថ"។ លោកមេធាតិថិ បន្ថែមតែឃ្លាកាព្យនិរនាមមួយប៉ុណ្ណោះ

ដើម្បីឱ្យមានន័យថា "គម្ពីរវេទត្រូវបានប្រកាសឡើងដោយមហាបណ្ឌិត ប៉ុន្តែស្មារតៈ ឬជំនឿពីបុរមបុរាណ ត្រូវប្រកាសដោយព្រះមនុ" (ភាសាសំស្ក្រឹត)។ កុល្លូកៈ បន្ថែមពីរវគ្គទៀត មួយវគ្គបានពីព្រះព្រិហស្បតិ ស្រ្មិតិ ដែលប្រទានគម្ពីរសាស្ត្រាមនុ ឱ្យដល់ដៃមនុស្សគ្រប់វណ្ណៈទាំងអស់ដូចគ្នា និងមួយវគ្គទៀតបានពីព្រះមហាភារតៈ ដែលប្រកាសថា "គម្ពីរបុរាណៈ ច្បាប់មនុ គម្ពីរវេទ ស្នាដៃឱសថទាំងឡាយ មិនត្រូវជំទាស់ ឬបដិសេធ ដោយហេតុផលផ្ទុយនោះទេ។" អ្នកអធិប្បាយទាំងពីរនាក់នេះ ក៏បានអះអាងថា ការប្រៀនប្រដៅរបស់គម្ពីរមនុ មានភាពខ្ពង់ខ្ពស់ជាងគេនៅក្នុងវគ្គពីរផ្សេងទៀតនៃគម្ពីរវេទ គម្ពីរបូរាណៈ គម្ពីរឥតិហាសៈ និងគម្ពីរស្រ្មិតិជាដើម។ ទីបញ្ចប់ តាមកំណត់សម្គាល់ នៅក្នុងគម្ពីរមនុ ជំពូក ១ លេខ ៥៨ ពួកគេពិភាក្សាសំណួរ ថាតើគេអាចហៅថាគម្ពីរ *ស្រ្មិតិ* ជាគម្ពីរមោណវៈ ធម៌សាស្ត្រៈ ដូចម្ដេចកើត សូម្បីមាននិយាយនៅក្នុងស្នាដៃនោះក៏ដោយ ក៏ពួកព្រាហ្មណ៍គឺជាអ្នកនិពន្ធពិតប្រាកដនៃស្នាដៃនេះ។ មេធាតិថិ បានធ្វើការបកស្រាយពីរយ៉ាង ទី១ លោកអះអាងថា ពួកព្រាហ្មណ៍ បានបង្កើតតែ"ពាក្យទូន្មាននិងការហាមប្រាមយ៉ាងច្រើន"ចំណែកឯស្នាដៃនេះផ្ទាល់ ជាស្នាដៃនិពន្ធរបស់ព្រះមនុ។ បន្ទាប់មកលោកនិយាយថា យោងតាមស្នាដៃផ្សេងៗទៀត គេអាចហៅសាស្ត្រានេះជារបស់ព្រះមនុបាន ថ្វីបើដំបូងពួកព្រាហ្មណ៍ជាអ្នកនិពន្ធក៏ដោយ។ តាមសក្ខីកម្មអំណះអំណាងនេះ លោកចង្អុលបង្ហាញន័យឧបមាប្រៀបដូចទន្លេគង្គា (Ganges) ដែលសូម្បីមានប្រភពនៅគ្រប់កន្លែង ដូចជានៅឯស្ថានសួគ៌ា ក៏ត្រូវគេហៅថា**ហៃមាវតី** ពីព្រោះដំបូងគេឃើញមាននៅហិមាវ័ត ឬហិមាល័យ និងរហូតដល់ឋាន កាឋកៈ សាខា ដែលទោះបីបានសិក្សា និងទទួលការប្រៀនប្រដៅពីសំណាក់គ្រូអាចារ្យជាច្រើន ក៏នៅជាប់ឈ្មោះ ជា *កឋៈ* ដែរ។ ជាការសន្និដ្ឋាន លោកបន្ថែមថា "នារទៈ ក៏មានកំណត់ត្រាដែរថា ស្នាដៃដែលមានកំណាព្យរាប់រយពាន់វគ្គ ត្រូវបាននិពន្ធដោយពួកប្រាគាបតិ (ព្រាហ្មណ៍) ស្នាដៃនេះ ត្រូវបន្តភ្ជាប់មកជាមួយគម្ពីរមនុ និងគម្ពីរផ្សេងៗទៀត (អក្សរសំស្ក្រឹត) ។" កុល្លូកៈ ដែលបានធ្វើការសង្ខេបមិនពេញលេញខ្លះអំពីការពិភាក្សារបស់មេធាតិថិសំអាងលើវគ្គដដែលជារបស់នារទៈ និងផ្អែកលើមូលដ្ឋាននេះ ការបកស្រាយរបស់លោកផ្ទាល់នៅក្នុងជំពូកទី១ លេខ៥៨ ដែលមានន័យថា ពួកព្រាហ្មណ៍ជាអ្នកទី១ ដែលបានតាក់តែងគម្ពីរច្បាប់ និងគម្ពីរមនុ ដែលគេបានសង្ខេបខ្លឹមសាររបស់វាតាមភាសារបស់លោកផ្ទាល់ ហើយលោកក៏បានយកទម្រង់នេះទៅបង្រៀនសិស្សគណរបស់លោក។

តាមដែលខ្ញុំដឹង ទាំងអស់នេះគឺជាសេចក្ដីអធិប្បាយស្ដីពីគម្ពីរមនុ និងប្រវត្តិរបស់ **មានវៈធម៌សាស្ត្រៈ** និងកំណត់សម្គាល់នានា ក៏មានសារជាតុសំខាន់ៗទាំងអស់ ដែលត្រូវលើកយកមកពិភាក្សាជាបន្តបន្ទាប់អំពីប្រធានបទដដែល ដែលយើងអាចជួបប្រទះនៅកន្លែងផ្សេងៗ (មើលឧទាហរណ៍ សំណេរដែលបកប្រែនៅក្នុងអត្ថបទអក្សរសិល្ប៍សំស្ក្រឹត បូរាណរបស់សាស្ត្រាចារ្យ Max Muller ទំព័រ ៨៧-៩៤) ។ ដោយសារអត្ថបទទាំងនេះទំនងមានសារៈសំខាន់ដូចគ្នាចំពោះ ពួកហិណ្ឌូដែលពិចារណាចំណោទបញ្ហាស្ដីពីដើមកំណើតរបស់មនុស្រ្មិតិ ដោយក្រសែភ្នែកជំនឿអត្ថបទនេះ មានតម្លៃតិចតួចសម្រាប់អ្នកសិក្សាប្រវត្តិសាស្ត្រ ដែលនៅក្រោមឥទ្ធិពលលទ្ធិព្រហ្មញ្ញសាសនា។ សេចក្ដីអះអាងស្ដីពីបុគ្គលមនុ អាចចាត់ជាសម្ភារៈ ដ៏ល្អបំផុត សម្រាប់ការសិក្សាស្រាវជ្រាវអំពីទេវកថាវិទ្យា។ សេចក្ដីអះអាង ដែលមានការត្រួត

ពិនិត្យយថាភាព និងប្រភពគួរឱ្យទុកចិត្តនៃគម្ពីរមនុស្រ្មិតិមិនរឹងមាំទាល់តែសោះ។ ចំពោះគម្ពីរវេទ ដែលអ្នកអធិប្បាយលើកហេតុផលយ៉ាងច្រើន គឺជាការនិយាយនូវសម្រង់សម្ដីមិនត្រឹមត្រូវ។ វេទ មាន គម្ពីរផ្សេងគ្នាចំនួន ៤ ក្នុងនោះមានគម្ពីរ សំហិតា ៣ និងគម្ពីរព្រាហ្មណ៍១(សៀវភៅកាថកៈ ជំពូក១១លេខ ៥(ទំនងជាដកស្រង់ឡើងដោយមេធាតិថិ) គម្ពីរម៉ៃត្រាយនីយា សំហិតា ជំពូក ១ លេខ ១,៥ គម្ពីរតៃតិរីយា ជំពូក ២ លេខ ២,១០ និងគម្ពីរតានទ្យៈ ព្រាហ្មណ៍ ជំពូក ២៣ លេខ១៦, ៧ (ដែលដកស្រង់ដោយ កុល្លូកៈ)។)។ ក៏ប៉ុន្តែស្នាដៃ នេះសំអាងលើគម្ពីរទាំង៤ តួយ៉ាងទី១ សំដៅដល់វេទមន្តដែលមាននិយាយឬបង្ហាញនៅក្នុងគម្ពីរមនុ។ ទោះជាយ៉ាងណាក៏ដោយ តាមសម្ដីអះអាងទាំងមូលនៃការប្រៀនប្រដៅរបស់គម្ពីរមនុ គឺរៀបរាប់ក្នុង ន័យទូទៅប្រហែលជាសំអាងថា សុភាសិតជាច្រើនដែលចាត់ជាបិតារបស់មនុស្សជាតិ ត្រូវគេស្គាល់ តាមអ្នកនិពន្ធនៃស្នាដៃគម្ពីរវេទទាំង៤ ហើយទំនងជាមិនគួរឱ្យជឿថាភាសិតច្បាប់ត្រូវដាក់បញ្ចូលក្នុង ចំណោមគម្ពីរ (ខ្ញុំមិនសន្និដ្ឋានតាមសាស្ត្រាចារ្យ Max Muller តើគម្ពីរអ្វីខ្លះ អាចបង្រៀនដល់យើងនៅឥណ្ឌា? ទំព័រ ៣៦៤ ថាស្នាដៃ ច្បាប់ ដូចជាគម្ពីរមនុ ត្រូវគេស្គាល់ ថាជាអ្នកនិពន្ធគម្ពីរទាំង៤ សូមមើលទំព័រខាងក្រោម ទំព័រ៦០។) ទាំងនោះ។ ប៉ុន្តែសម្មតិកម្មរបស់លោកមេធាតិថិ និងកុល្លូកៈ ដែលគម្ពីរមនុស្រ្មិតិរបស់យើង មានន័យ តាមការដកស្រង់តម្រូវឱ្យមានសក្ខីកម្មពិសេសដ៏រឹងមាំ ពីព្រោះភាសារបស់វានិងផ្នែកទ្រឹស្ដី មានន័យ ស្របតាមសម័យកាលវេទ។

ការពិត គ្មានសក្ខីកម្មបង្ហាញបែបនេះទេ ហើយទំនងជាមិនអាចទេថា គេសុទ្ធតែអាចផ្ដល់ការ បញ្ជាក់ច្បាស់លាស់ជានិច្ចបានទេ។ ការស្រង់សម្ដីដែលអ្នកអធិប្បាយបានស្រង់ចេញ ពីស្នាដៃរបស់ មហាភារតៈ និងពីព្រិហស្បតិ ស្រ្មិតិ ព្រមទាំងអំណះអំណាងរបស់ពួកគេដែលមានមូលដ្ឋាន ត្រឹមត្រូវ នៅក្នុងគម្ពីរបុរាណៈនិងគម្ពីរស្រ្មិតិជាច្រើនជាញឹកញយត្រូវ ចាត់ជាប្រភពគួរឱ្យទុកចិត្តបានចំពោះ ច្បាប់ ដ៏ពិសិដ្ឋនេះមានសារៈសំខាន់កាន់តែខ្លាំង។ ពិតប្រាកដណាស់ថា ស្នាដៃទាំងពីរដែលលោកកុល្លូ កៈបានលើកឡើង សំដៅលើធម៌សាស្រ្តៈដែលជាច្បាប់មនុ ហើយកំណត់សម្គាល់ដដែលនេះ គោរព តាមបានយ៉ាងត្រឹមត្រូវតាមខ្លឹមសារនៃគម្ពីរបុរាណនិងស្រ្មិតិ ដែលតាមការរៀបរាប់ឈ្មោះអ្នកនិពន្ធធម៌ សាស្រ្តៈ គេដាក់ឈ្មោះព្រះមនុ នៅដើមបញ្ជីទាំងនោះ។ សូម្បីតែសក្ខីកម្មនេះមិនសូវច្បាស់លាស់ ដោយហេតុថាភាពចំណាស់នៃស្នាដៃជាច្រើនដែលមានឈ្មោះមនុ គួរឱ្យសង្ស័យក៏ដោយ ក៏គេជឿជាក់ ថា មានការពិនិត្យសំណៅសរសេរដោយដៃជាច្រើននៃច្បាប់មនុនៅមាននៅឡើយ ហើយគេអាច បង្ហាញឱ្យឃើញការពិតបាន។ ហេតុនេះ ការសំអាងលើ**មនុស្រ្មិតិ** តាមគម្ពីរបុរាណឬស្រ្មិតិ មិនស បញ្ជាក់ច្បាស់សម្រាប់ស្រ្មិតិរបស់ភ្រិគុ ប្រសិនបើនៅពេលជាមួយគ្នានោះ គេមិនបានចង្អុលបង្ហាញ ច្បាស់ថា គម្ពីរក្រោយមានន័យពិតប្រាកដនិងថា ស្នាដៃដែលមានខ្លឹមសារពិតប្រាកដទាមទារឱ្យមានការ ពិចារណាពីសម័យបុរាណ។

តាមការបកស្រាយចំណុចនេះពេលនេះ គេអាចកត់សម្គាល់បានយ៉ាងពេញលេញថា ព្រិហ-ស្បតិ ស្រ្មិតិ ដែលកុល្លូកៈ លើកហេតុផលជាសក្ខីភាព ជាស្នាដៃបុរាណ ប៉ុន្តែក្រោយមកទៀត នៅដើម សករាជរបស់យើង ដោយសារមានការកំណត់និយមន័យនៃប្រាក់ទីនារៈមាស ជាកាក់របស់ឥណ្ឌា ដែលយកលំនាំតាមចំនួនលេខទេនារី(West និង Buhler, ទស្សនាវដ្ដី ទំព័រ ៤៨ បោះពុម្ពលើកទី៣) របស់រ៉ូម៉ាំង។ ចំណុច

ខាងក្រោមបន្តបន្ទាប់យើងនឹងនិយាយ កាន់តែច្រើនអំពីគម្ពីរមនុនិងគម្ពីរមហាភារតៈ។ ការស្រង់សម្ដីរបស់មេធាតិថិពីនារាយណៈ ជាអកុសលខ្លាំងណាស់ ពីព្រោះវាមិនច្បាស់លាស់ ហើយការប្រើពាក្យពេចន៍របៀបនេះ ដើម្បីបិទបាំងនូវភាពមិនស្របគ្នាយ៉ាងច្រើន ដែលមាននៅក្នុងសាច់រឿងមានវៈ ធម៌សាស្ត្រៈ និងនារទៈ ស្មឹតិ។

សេចក្ដីណែនាំដូចមាននៅក្នុងគម្ពីរក្រោយនេះ ជាពាក្យសម្រាយធម្មតាមិនបញ្ជាក់ថា គម្ពីរច្បាប់ដើមដែលមានកាព្យរាប់រយពាន់ លោកប្រាគាបតិបានតាក់តែងឡើងនិងភ្ជាប់គម្ពីរមនុ ជាមួយគម្ពីរដទៃទៀត ប៉ុន្តែពោលដោយងាយៗថា អ្នកនិពន្ធគម្ពីរនេះគឺមនុ ប្រាគាបតិ ហើយថានារទៈ និងសុមតិ ជាកូនប្រុសរបស់ភ្រិគុ បានសរសេរសង្ខេបគម្ពីរ(មើលJolly, Narada,ទំព័រ២ និងបាឋកថា Tagore ឆ្នាំ ១៨៨៣ ទំព័រ ៤៦។ ការប៉ាន់ស្មានរបស់ខ្ញុំ ថា ការរៀបរាប់នារទៈ ដែលជារបស់អសហាយៈ មិនមែនជារបស់ស្មឹតិទេ (West និង Buhler ទំព័រ ៤៩) គឺគ្មានហេតុផលទេ។) ។ អត្ថបទរបស់នារទៈ ដែលភ្ជាប់សេចក្ដីសរុប អំពីការអធិប្បាយរបស់អសហាយៈ ដោយកល្យានភត្តៈ មានឈ្មោះបណ្ឌិតម្នាក់ទៀត គឺមារកន្ទេយៈ ដែលបានព្យាយាមដោយផ្ទាល់ សិក្សាពីស្នាដៃដ៏ធំធេងរបស់មនុ ប្រាគាបតិ។ មួយណាក៏ដោយ ក្នុងចំណោមអត្ថបទទាំងពីរនេះ អាចមានមួយជាច្បាប់ដើម ពិតមែនហើយថា ការបង្ហាញរបស់មេធាតិថិ អំពីអំណះអំណាងរបស់នារទៈ គឺមិនច្បាស់លាស់ទេ និងថាអត្ថបទក្រោយនេះ ខុសគ្នាយ៉ាងច្រើនពីសាច់រឿងនៅក្នុង *មនុស្មឹតិ* របស់យើង ដែលអះអាងថា នេះជាស្នាដៃដើមដែលព្រាហ្មណ៍បាននិពន្ធឡើង ហើយព្រះមនុ បានលាតត្រដាងដល់ ភ្រិគុ ដែលពន្យល់រឿងនេះដល់មហាបណ្ឌិតទាំងឡាយ "យ៉ាងច្បាស់តាមអ្វីៗ ដែលលោកបានទទួល"។ ហេតុនេះសាច់រឿងរបស់នារទៈ ធ្វើឱ្យបាត់ជំនឿដល់សេចក្ដីលម្អិតដែលមាននៅក្នុងមានវៈធម៌សាស្ត្រៈ។ យកល្អបំផុតគេអាចដកស្រង់សម្ដីបានក្នុងករណីគ្រាន់តែបង្ហាញអត្ថភាពនៃជំនឿទូទៅថា ព្រះមនុជាអ្នកប្រទានច្បាប់ទី១សម្រាប់ប្រទេសឥណ្ឌា។ ពាក្យសម្ដីទាំងអស់នេះ នឹងគ្រប់គ្រាន់អាចបង្ហាញបានថា សេចក្ដីថ្លែងហេតុ ដែលអ្នកអត្ថាធិប្បាយឥណ្ឌាបានលើកឡើងស្ដីពីដើមកំណើតនិងប្រវត្តិគម្ពីរមនុស្មឹតិ មិនសមនឹងធ្វើជាមូលដ្ឋានសម្រាប់ការពិភាក្សាល្អិតល្អន់អំពីចំណោទបញ្ហាទាំងអស់នេះទេ និងថាដូចនេះ អំណះអំណាងទាំងឡាយ គួរតែទុកដោយឡែក ជូនអ្នកសិក្សាភាសាសំស្ក្រឹតសម័យទំនើប ដែលបានសរសេរពាក់ព័ន្ធនឹងប្រធានបទនេះធ្វើការសិក្សាបន្ត។ ក្នុងន័យនេះ ទ្រឹស្ដីក្រោយនេះ ទំនងជាគ្មានប្រយោជន៍ក្នុងការរៀបរាប់ឈ្មោះអ្នកទាំងឡាយ នៅមុនទស្សនៈយល់ឃើញរបស់លោកសាស្ត្រា Max Muller ដែលគេអាចទទួលយកបានជាទូទៅនាពេលនេះ ដែលគម្ពីរមនុស្មឹតិរបស់យើងត្រូវពឹងផ្អែកលើ ឬតាមពិតជាការតែងឡើងវិញនូវធម៌សូត្របុរាណ។ ប៉ុន្តែសម្មតិកម្មរបស់លោកដ៏ល្បីល្បាញ ហើយរកឃើញក្រោយដែលបញ្ជាក់ពីបញ្ហានេះខ្ញុំគិតថាជាសេចក្ដីផ្ដើម ច្បាប់មនុ ដែលមិនពេញលេញ ដោយមិនបានបញ្ជាក់ឡើងវិញទាំងស្រុងអំពីអំណះអំណាងរបស់គាត់ និងការគាំទ្របន្ថែមពីសំណាក់អ្នកដទៃទេ។ លោកសាស្ត្រាចារ្យ Max Muller បានបកស្រាយពន្យល់អំពីដើមកំណើតគម្ពីរមនុស្មឹតិនេះ ដោយពឹងផ្អែកលើការពិនិត្យពិចារណា ដែលអាចមានខ្លឹមសារសង្ខេបខាងក្រោម(អានលិខិតរបស់លោក ផ្ញើជូនលោក Morley ដែលគេបានបោះពុម្ពឡើងវិញ នៅក្នុងគម្ពីរពិសិដ្ឋបូព៌ាប្រទេស សៀវភៅ លេខ២ ទំព័រ៩-១១ និង អក្សរសិល្ប៍Hist. Anc. Sansk. Lit. ទំព័រ ១៣៣-

១៣៤។ សូមធៀបនឹងទស្សនៈប្រៀបធៀប បកស្រាយដោយឯករាជ្យរបស់លោកសាស្ត្រាចារ្យ Weber និង Stender ទស្សនាវដ្តី Indiche Studien, សៀវភៅលេខ ១ ទំព័រ ៦៩, ១៤៣,៣៤៣-៤) ។ ការដាំបណ្តុះជាប្រព័ន្ធនូវ វិទ្យាសាស្ត្រដ៏ពិសិដ្ឋរបស់ពួកព្រាហ្មណ៍ ចាប់ផ្តើមកកើតឡើង ហើយអស់ពេលជាយូរណាស់ ប្រសិនបើមជ្ឈមណ្ឌលវិទ្យាសាស្ត្រនៅ**សូត្រករណៈ**បុរាណជាសាលាដែលបាន ប្រមូលចងក្រងលទ្ធិទ្រឹស្តីដែលនៅរាយប៉ាយដាច់ពីគ្នា នៅក្នុងស្នាដៃវេទដ៏ចំណាស់ជាលើកដំបូង ហើយបានរៀបចំជាស្នាដៃសម្រាប់ប្រៀនប្រដៅដោយផ្ទាល់មាត់ជាព្រះសូត្រ ឬជាកម្រងសុភាសិត។ សាលាទាំងអស់នេះ បានសាបព្រោះមុខវិជ្ជានានា ក្រៅពីពិធីសាសនា វេយ្យាករណ៍ សទ្ទសាស្ត្រ និងអង្គវេទដទៃទៀត ដែលជាច្បាប់ពិសិដ្ឋផងដែរ។ ក្រោយមកទៀត ដាក់បញ្ចូលមិនត្រឹមតែសិក្ខាបទ សម្រាប់ករណីយកម្មសីលធម៌ របស់ពួកអារ្យទាំងអស់ប៉ុណ្ណោះទេ ថែមទាំងជាវិធានពិសេសស្តីពីការប្រព្រឹត្តរបស់ព្រះមហាក្សត្រិយ៍ និងរដ្ឋបាលយុត្តិធម៌ផង។ ព្រះសូត្រអភិប្រាយស្តីពីច្បាប់ មានប្រធានបទច្រើន ដែលមាននៅក្នុងកំណាព្យ *ស្ម្រិតិ* ដែលជាស្នាដៃរបស់មនុយាញ្ញាវាក្យៈ និងមហាបណ្ឌិតដទៃទៀត។ ថ្វីបើធម៌សូត្រតែមួយ ជាអាបស្តមពីយៈ ជាក់ស្តែងនៅមានទំនាក់ទំនងនឹងសុភាសិតស្តីអំពីពិធីសាសនា និង មុខវិជ្ជាពិសិដ្ឋផ្សេងៗទៀត ក៏អត្ថិភាពនៃព្រះធម៌សូត្ររបស់ព្រះគោត្តម ព្រះវសិស្ឋៈ និងព្រះវិស្ណុ ដែលទំនងជាតែងជាព្រះសូត្របង្ហាញថា ដើមឡើយគម្ពីរទាំងនេះមានច្រើនជាងនេះទៅទៀត។ ប្រពៃណីដ៏ល្អឥតខ្ចោះរបស់សាលាមិមំសាដែលបានប្រកាសថា សាលាវេទឬករណៈនីមួយៗដើមដំបូងមានស្នាដៃពិសេសស្តីពីធម៌បញ្ជាក់គាំទ្រសម្មតិកម្មនេះ។ ពេលដែលធម៌សូត្រមានអាយុកាលដ៏ចំណាស់ច្រើនចាប់ពី៦០០-២០០ គ្រិស្តសករាជ គម្ពីរកំណាព្យសម្រិត មិនអាចមានអាយុកាលចំណាស់ដូចនេះទេដោយហេតុថា វាមានទម្រង់ទំនើបច្រើនជាពិសេសរឹកថាអនុស្តុភស្លោក ដែលគេបានសរសេរឡើង មិនមែនសម្រាប់ការតែង និពន្ធបន្តក្នុងសម័យសូត្រ។ ព្រោះថាកំណាព្យស្ម្រិតិ កើតក្រោយធម៌សូត្រ ផ្អែកលើ ព្រឹត្តិការណ៍នេះ គេនិយាយយ៉ាងសមហេតុផលថា ស្នាដៃនីមួយៗ គឺផ្អែកលើធម៌សូត្រពិសេសមួយ។ មានវៈ ធម៌សូត្រ ជាពិសេស គេអាចចាត់ទុកជាការតាក់តែងឡើងវិញ និងជាកាព្យសាស្ត្រស្តីពីធម៌សូត្ររបស់មានវៈសូត្រករណៈ ជាផ្នែកមួយរបស់សាលាម៉ៃត្រាយនីយៈដែលប្រកាន់យកតែសេចក្តី អំពីវេទតាមបែប*យ្លេកយាគុរ*។

តាមការពិចារណាពីសភាពចំណេះដឹងរបស់យើងពាក់ព័ន្ធនឹងអក្សរសិល្ប៍វេទ ៣០ឆ្នាំកន្លងមក សេចក្តីថ្លែងសម្មតិកម្មនេះ គឺពិតជាជំហានដ៏ក្លាហានមួយ។ ការពិតដែលត្រូវសំអាង គឺមានតិចតួច ហើយបំណងចងភ្ជាប់ទៅនឹងការសន្មតនេះ នៅអាចមានការជំទាស់ជាច្រើន។ គ្មានភស្តុតាង ឬគេមិនអាចរកសក្ខីកម្ម បញ្ជាក់ថា ព្រះសូត្ររបស់ព្រះគោត្តមព្រះវសិស្ឋៈនិងព្រះវិស្ណុដើមឡើយ ជាសំណេរដៃរបស់សាលាវេទ មិនមែនជាក្រមដែលប្រកាសឱ្យប្រើជាផ្លូវការ សម្រាប់ការណែនាំរបស់ពួកអារ្យជនដូចប្រពៃណីហិណ្ឌូ ដែលយើងបានស្គាល់ឬដឹងឮនោះទេ។ សម្មតិកម្មគឺថា គេបានពឹងផ្អែកលើការប្រៀបធៀបទម្រង់និងខ្លឹមសារ ជាមួយនឹងគម្ពីរអាបស្តមពីយៈ ធម៌សូត្រ។ យើងមិនឃើញមានសញ្ញាណាមួយពាក់ព័ន្ធនឹងមានវៈធម៌សូត្រ ហើយក៏គ្មានឃើញការជាប់ពាក់ព័ន្ធរវាងមានវៈធម៌សូត្រ និងសាលាមានវៈដែរ លើកលែងតែចំណងជើងរបស់អត្ថបទប៉ុណ្ណោះ។ ការអះអាងដែលថាពួកព្រាហ្មណ៍

បានប្រែក្លាយព្រះសូត្រពីមុនៗ ជាពិសេសធម៌សូត្រ ឱ្យទៅជាស្នាដៃកំណាព្យ ដែលសរសេរជាស្លោក រីកថា មិនបានបន្សល់ទុកសេចក្ដីសំអាងណាមួយ ហើយក៏គ្មានមូលហេតុ ដែលអាចបកស្រាយពន្យល់ពីការការប្រែដ៏ធំធេងនេះទេ។ ដោយសារការចាប់ផ្ដើមទប់ទល់នឹងចំណុចខ្សោយទាំងអស់ ដែលគេមិនអាចបដិសេធបាន សម្មតិកម្មរបស់សាស្ត្រាចារ្យ Max Muller មានចំណុចដ៏រឹងមាំពីរ ដែលអាចធានាបានភាពសមស្របអាចទទួលយកបានពីសំណាក់អ្នក សិក្សាភាសាសំស្ក្រឹតនៅសាលាប្រវត្តិសាស្ត្រទាំងអស់តាំងពីដំបូង។ ចំណុចទី១ បានជំនួសទ្រឹស្ដីហេតុផលស្ដីពីការវិវត្តប្រវត្តិសាស្ត្រ សម្រាប់រឿងព្រេងប្លែកៗតាមប្រពៃណីហិណ្ឌូ និងសម្រាប់ភាពមិនច្បាស់លាស់គ្មានពន្លឺ ដែលបញ្ជាក់ការគិតគូរទស្សន៍ទាយពីមុនៗរបស់អ្នកប្រាជ្ញអឺរ៉ុប ស្ដីពីដើមកំណើតក្រមច្បាប់របស់ឥណ្ឌា តាមការឱ្យឈ្មោះជាទូទៅ។ ចំណុចទី២ ពោរពេញដោយហេតុការណ៍ជាច្រើន ដែលការស្រាវជ្រាវដំបូងនៃអក្សរសិល្ប៍វេទបានផ្ដល់នូវពន្លឺខ្លះៗ និងដែលជាទូទៅជំរុញឱ្យអ្នកសិក្សាហ្មត់ចត់ទាំងអស់មានជំនឿថា ការសាបព្រោះជាប្រព័ន្ធនូវក្បួនសាស្ត្រាឥណ្ឌាទាំងអស់ បានចាប់ផ្ដើមនៅក្នុងសាលាវេទ។ ព្រឹត្តិការណ៍បន្តបន្ទាប់បានសបញ្ជាក់ថា សាស្ត្រាចារ្យ Max Muller ជាមនុស្សត្រឹមត្រូវ ដែលផ្អែកលើទស្សនៈគំនិតពីរឈានមុខគេ និងថាអ្នកសិក្សាសំស្ក្រឹតជំនាន់ក្រោយរូបលោក ពិតជាដើរតាមទស្សនៈរបស់លោក ជាជាងប្រើកំហឹងចំពោះកំហុសឆ្គងបន្តិចបន្តួច។ ការបង្ហាញភស្តុតាងជាបន្តបន្ទាប់ដោយសន្សឹមៗ ប៉ុន្តែជាប់ជាប្រចាំ បានផ្ដល់នូវពន្លឺសម្រាប់ចំណុចខ្វះខាតជាច្រើន តាមរយៈការអង្កេតជាប់ជានិច្ច។ ពេលនេះយើងបានដឹងថាស្នាដៃតម្រាសូត្ររបស់សាលាផ្សេងៗទៀត ក្រៅពីសាលា អាបស្ដម្ពីយៈបានដាក់បញ្ចូល ឬនៅតែរាប់បញ្ចូលអភិប្រាយស្ដីពីច្បាប់ពិសិដ្ឋដដែល។ ធម៌សូត្ររបស់សាលា **ពោធាយនិយៈ** ជាច្បាប់សូត្រករណៈដ៏ចំណាស់ជាងគេរបស់តៃត្តិរីយៈវេទ ត្រូវបានគេរកឃើញ។ សូម្បីតែទំនាក់ទំនងរវាងផ្នែកជាច្រើននៃតួសេចក្ដីដ៏វែងរបស់ព្រះសូត្រ គេបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្ដី ក៏គេមិនអាចទទួលស្គាល់បានថា គេធ្លាប់បានភ្ជាប់វាជាមួយនឹងគ្រឹហ្យសូត្រ(គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស សៀវភៅលេខ ១៤ ទំព័រ xxxi) ។ ការរកឃើញកម្រងហិរណ្យកេសិសូត្រទាំងមូលបានបង្ហាញថា ក្បួនតម្រាទាំងអស់នេះរួមមានធម៌សូត្រដែលតួយ៉ាងនេះគេបានយកពីអាបស្ដម្ពីយៈពីមុន(គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស សៀវភៅលេខ ២ ទំព័រ xxiii) ។ អាថ៌កំបាំងដែលនៅជុំវិញជំហរធម៌សាស្ត្រៈរបស់ព្រះគោត្តម វិស្ណុ និងវសិស្ឋៈ ត្រូវបានជម្រះយ៉ាងច្បាស់។ ចំពោះការអះអាងថា *ឫសី* ពីបុរាណបានតែងស្នាដៃទាំងនេះ ដើម្បីសេចក្ដីសុខរបស់មនុស្សជាតិយើង នៅពេលបច្ចុប្បន្ន អាចមិនយល់ស្របតាមប្រពៃណីខ្លះ ដែលគេធ្លាប់ បានសិក្សាពីដំបូង និងទទួលស្គាល់ជាប្រភពគួរឱ្យទុកចិត្ត ដោយសារមានសាលាសំខាន់ៗ ដោយប្រកាន់យកតាមសមវេទ, ប្លេកយគុរវេទ និងឫគវេទ(គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស សៀវភៅលេខ ២ ទំព័រ xlv-xlviii, សៀវភៅលេខ ៧ ទំព័រ x-xvi, សៀវភៅលេខ ១៤ ទំព័រ xl-xlv) ។ សក្ខីកម្ម ខាងក្នុងបញ្ជាក់ពីប្រពៃណីនេះ គេបានរកឃើញក្នុងករណីព្រះធម៌សាស្ត្រៈរបស់ព្រះគោត្តម និងវិស្ណុស្ម្រិតិ ឬអាចនិយាយត្រឹមត្រូវជាងនេះទៀតគឺរបស់កាឋកៈសូត្រ។ ការរកឃើញក្បួនតម្រាខាងក្រោយនេះមានសារៈសំខាន់មហាសាលពីព្រោះ វាជួយបង្កើតសច្ចភាពទាំងស្រុងនៃសម្មតិកម្ម ស្របតាមទ្រឹស្ដីរបស់សាស្ត្រាចារ្យ Max Muller

ថា នៅក្រោយសម័យវេទពួកព្រាហ្មណ៍មិនបានស្ទាក់ស្ទើរ ក្នុងការកែប្រែលក្ខណៈរបស់សៀវភៅអប់រំ សម័យបុរាណ ដើម្បីសម្រួលចងក្រងជាក្រមច្បាប់ជាទូទៅ តាមរយៈនៃការបំបែកវាចេញពីស្រូតៈ និង គ្រីហ្យសូត្រ ឬ តាមរយៈបន្ថែមបញ្ហាខាងក្រៅ ដែលតាមក្រសែភ្នែករបស់ពួកហិណ្ឌូ ដែលកាន់វិន័យ ចាស់ ត្រូវតែបង្កើនមនោសញ្ចេតនាគោរពយ៉ាងខ្លាំងចំពោះគម្ពីរទាំងនោះ។ ជាពិសេស ករណីរបស់ គម្ពីរវិស្ណុស្រ្មិតិ មានការចាប់អារម្មណ៍ខ្លាំងបំផុត។ ការចាប់ផ្តើមនិងបញ្ចប់ស្នាដៃ បញ្ជាក់យ៉ាងច្បាស់អំពី ការបើកអាថ៌កំបាំងរបស់ព្រះអាទិទេពវិស្ណុ។ ការគោរពបូជា និងទស្សនវិជ្ជារបស់ព្រះវិស្ណុ វៃស្ណវៈ ត្រូវគេ សូត្របួងសួងក្នុងពិធីផ្សេងៗនិងពេលចាប់ផ្តើមកិច្ចពិភាក្សា សូម្បីភាពផ្សេងគ្នាផ្នែករចនាបថនៃជំពូកផ្តើ មសេចក្តីនិងបញ្ចប់សេចក្តី មានសបញ្ជាក់ច្បាស់ថា ជំពូកទាំងនោះមានការបន្ថែមនៅពេលក្រោយៗ មក ហើយប្រពៃណីដ៏គួរឱ្យជឿជាក់បំផុតរបស់បណ្ឌិតបុណៈ និងប៉ៃណែរ ជាការកើតឡើងនូវអត្ថបទដ៏ ពិសិដ្ឋដែលយើងស្គាល់ថាជាគាថាកាថកៈ ព្រមទាំងភាពដូចគ្នាច្រើននឹងខ្លឹមសារគាថា កាថកៈ គ្រីហ្យ សូត្រ ជួយបញ្ជាក់ច្បាស់បំផុតថា ស្នាដៃនេះ គឺជាការតាក់តែងឡើងវិញនូវគាថា កាថកៈ ធម៌សាស្រ្តៈ (សម្រង់សម្តីស្រ្មិតិមគារីរបស់គោវិន្ទរាគ តពី ១៣$^b$,១.៨ (កម្រងការិយាល័យរបស់ឥណ្ឌា លេខ ១៧៣៦) មានមួយ ចំណែកតូចនៃស្នាដៃនេះ។ បើពិចារណាពីការលាងបាបចំពោះឃាតកម្មរបស់ព្រាហ្មណ៍ ដែលមានចែងនៅក្នុងច្បាប់មនុ ជំពូក ១១ កាព្យលេខ៧៤ លោកគោវិន្ទរាគ និយាយថា ("... សំស្រ្តឹត")។ សម្រង់សម្តីនេះ បង្ហាញថា ធម៌សូត្រនៃគាថាស្តី ពីអំពើលាងបាបប្លែកៗ ដោយបញ្ចប់ដោយសេចក្តីស្លាប់ ដែលមានចែងនៅក្នុងគម្ពីរច្បាប់បូរាណទាំងអស់ តែគេលុបចោលក្នុង គម្ពីរវិស្ណុស្រ្មិតិ។) ដោយវៃស្ណវៈ។ ដូច្នេះ ក្នុងករណីនេះយើងទទួលបានការបញ្ជាក់ពីការពិតសឹងតែទាំង ស្រុង ដែលការប្រែក្លាយពីធម៌សូត្រនៃមានវៈ ទៅជាក្រមប្រាគាបតិមនុ ដូចបានបង្ហាញ មានការសន្មត ជាមុន លើកលែងតែម្យ៉ាងគត់ គឺការជំនួសស្លោកវីរកថាជាកាព្យ ពាក្យរាយ។ យោងតាមចំណុចចុង ក្រោយនេះ ការស្វែងយល់បន្ថែមពីអក្សរសិល្ប៍ស្រ្មិតិត្រូវធ្វើ ការប្រៀបធៀបជាច្រើន។ តាមតួយ៉ាង បញ្ជាក់ចំណុចនេះ ឥឡូវនេះយើងអាចទាញហេតុផលសំអាងត្រង់វគ្គខ្លះ នៃព្រីហាតសង្ខៈ ធម៌សាស្រ្តៈ ដែលតាមការដកស្រង់បង្ហាញថា ដំបូងត្រូវតែមានពាក្យសម្រាយហើយនិងពាក្យកាព្យ ចំណែកឯគម្ពីរ ដែលមានបញ្ជាក់ពីសូត្រ និងអនុស្តភៈ ក្នុងជំពូកតែមួយ និងសុទ្ធតែជាស្លោកនៅក្នុងជំពូកផ្សេងៗ(West និង Buhler, ទស្សនាវដ្តីសភា ទំព័រ៤០ បោះពុម្ពលើកទី៣)។ លើសពីនេះ មានស្នាដៃជាច្រើន ដូចជាអាស្វឡា-យណៈ ស្រ្មិតិ និង សោណកៈ ស្រ្មិតិ ជាការបញ្ជាក់ច្បាស់ពីគ្រីហ្យសូត្រដូចគ្នាដោយបន្ថែម ឬ មិន បន្ថែមនូវបញ្ហាខាងក្រៅ(West និង Buhler, តាមសម្រង់ ទំព័រ ៥១) ។ ជារួមក្នុងចំណោមអំណះអំណាងទូទៅ ទាំងអស់ ស្តីពីប្រភពដើមនៃកំណាព្យស្រ្មិតិ ដែលលោកសាស្រ្តាចារ្យ Max Muller ដែលមានអំណះ អំណាងឈានមុខគេតែម្នាក់គិតថា ក្នុងអំឡុងសម័យសូត្រ ៦០០-២០០ឆ្នាំ មុនគ្រិស្តសករាជ ហើយ ស្នាដៃជាលាយលក្ខណ៍អក្សរនៅក្នុងកំណាព្យវីរកថាជាបន្តបន្ទាប់គេមិនបានដឹង និងមិនអាចបញ្ជាក់អំ ណះអំណាងបានពេញលេញទាំងស្រុង។ ការកំណត់អំពីការផលិតព្រះសូត្រអាចនិយាយបាននៅ ចន្លោះឆ្នាំ៦០០-២០០ មុន គ.ស. ហើយវត្តមានសំណេរដៃជាកំណាព្យអប់រំ គេឃើញមានតាំងពីយូរ មុននេះមកហើយ(Goldstucker, មានវកល្បសូត្រ ទំព័រ៧៨)។ ពេលនេះសក្ខីភាពបង្ហាញច្បាស់ថាការប្រើខ្នាត វាស់វីរភាពសម្រាប់ស្នាដៃបែប នេះមិនមែនចាប់ផ្តើមបានភ្លាមៗ និងតាមកាលកំណត់ជាក់លាក់បាន

ទេ។ តែយ៉ាងណាក៏ដោយ ភាពច្បាស់លាស់គឺថា ការប្រើសុភាសិត ពាក្យរាយ កើតមានមុនសុភាសិតពាក្យកាព្យ។ តាមករណីដែលយើងបានដឹងអស់ ព្រះសូត្រ ក្រៅពីកំណាព្យសំគ្រាហ វារត្តកៈ នាំមុខក្រុមសៀវភៅអប់រំនីមួយៗ និងវិសេសភាពដាច់គេបំផុតនៃរចនាបថ សូត្រ មាននៅក្នុងសំណេរដែជាពាក្យកាព្យ ( West និង Buhler, តាមសម្រង់ ទំព័រ៤២, ៤៤ ) ។ បើនិយាយពីសេចក្ដីសន្និដ្ឋាន ដែលជាពិសេសប៉ះពាល់ដល់មានវៈ ធម៌សាស្ត្រៈ អត្ថិភាពដើមនៃមានវៈសូត្រ ដែលជាពាក្យរាយលាយពាក្យកាព្យ តាមក្បួនកាព្យសាស្ត្រជាច្រើន បានកើតចេញពីរបកគំហើញសម្រង់សម្ដីមួយចំនួននៅក្នុងវសិស្ថៈធម៌សូត្រ ហើយមាតិការបស់វាបង្ហាញថា ស្នាដៃដែលគេបានស្គាល់ឈ្មោះអ្នកនិពន្ធតាមក្បួនតម្រាក្រោយៗ មានទំនាក់ទំនងជិតស្និទ្ធជាមួយ នឹងច្បាប់មនុស្រ្មិតិរបស់យើងនេះតែម្ដង។ ចំពោះទំនាក់ទំនងធម៌សូត្រនេះ និងបន្ទាប់មកមនុស្រ្មិតិ ជាមួយសូត្រករណៈនៃ មានវៈ លទ្ធផលនៃការសិក្សាស្រាវជ្រាវក្រោយនេះ មិនមានលក្ខណៈគួរជាទីពេញចិត្តដូចគ្នាទេ។ ការរកឃើញឡើងវិញនូវសំណេរមានវៈមិនត្រឹមតែមិនផ្ដល់ការពិតណាមួយសម្រាប់បញ្ជាក់ពីទំនាក់ទំនងដូចបានលើកឡើងប៉ុណ្ណោះទេ តែផ្ទុយទៅវិញថែមទាំងបានបង្កើនភាពស្មុគស្មាញពីព្រោះ ហាក់ដូចជាថា លទ្ធិមានវៈ គ្រិហ្យសូត្រ ខុសគ្នាច្រើនពីលទ្ធិរបស់មានវៈ ធម៌សាស្ត្រៈរបស់យើងនេះទេ។ ទាំងអស់នេះ បានជួយបញ្ជាក់ពីការបង្ហាញសក្ខីភាព នៃសម្មតិកម្មរបស់សាស្ត្រាចារ្យ Max Muller ថា គេរកឃើញភាពដូចគ្នារវាងវិស្ណុស្រ្មិតិ ជាផ្ទៀងផ្ទាត់សំណេរដែទំនើបនៃគាថា កាថកៈធម៌សូត្រ និងគម្ពីរមនុស្រ្មិតិ រវាងកាថកៈ និងមានវៈគ្រិហ្យ ធម៌សូត្រ និងរវាងកាថកៈ និងមានវៈសំហិតា ហើយថា ហេតុនេះ ប្រភពដើមវេទនៃមនុស្រ្មិតិ គេអាចសន្និដ្ឋានថា ជាកម្មសិទ្ធិរបស់សាលាមានវៈ( សាស្ត្រាចារ្យ Jolly, គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស, លេខ ៧ ទំព័រ xxvi-xxvii និង បណ្ឌិត Dr. von Bradke ទស្សនាវដ្ដី អាល្លឺម៉ង់ ឬ Soc. លេខ ៣២ទំព័រ ៤៣៨-៤៤១ )។ អ្វីដែលយើងបានដឹងបញ្ជាក់ច្បាស់ថា កម្លាំងពិតប្រាកដនៃអំណះអំណាង នេះដូចលោកបណ្ឌិត Dr. von Bradke បានចង្អុលបង្ហាញការពិតតាមការពិតថា តម្រាវិស្ណុ-ស្រ្មិតិ មិនមែនជាគាថា កាថកធម៌សូត្រដើមទេ។ ប៉ុន្តែដើម្បីច្រានចោលបញ្ហានេះព្រមទាំងផ្អែកតាមព្រឹត្តិការណ៍នេះជាបញ្ហាដ៏ហួសវិស័យមួយ។ ចំពោះការចុះសម្រុងគ្នារវាង *ស្រ្មិតិ* របស់ព្រះមនុ និងវិស្ណុ ក្ដោបលើប្រធានបទជាច្រើន ដែលក្រោយមកគ្មានសញ្ញាបង្ហាញពីការតែងឡើងវិញទេ ហើយអាចមានហេតុផលបង្ហាញពីធម៌សូត្រដើម ដោយស្មោះត្រង់បំផុត។ ទោះជាយ៉ាងនេះក្ដី ការពិចារណាទាំងស្រុងអំពីចំណុចនេះ ជាប្រការជៀសមិនផុត។ មុនពេលយើងធ្វើរបៀបនេះបានយ៉ាងណាក៏ដោយ ដំបូងបង្អស់យើងគួរតែបន្ថែមលើអំណះអំណាងរបស់សាស្ត្រា Max Muller ចំពោះអាយុកាលបុរាណ នៃមនុស្រ្មិតិរបស់យើង តាមរយៈការពិភាក្សាខ្លឹមសារខ្លះៗរបស់តម្រានេះ ដែលបង្ហាញច្បាស់ពីភាព ស្របគ្នាជាមួយនឹងតួសេចក្ដីដ៏វែងនៃអក្សរសិល្ប៍ច្បាប់ចំណាស់ជាង ជាពិសេសជាមួយនឹងធម៌សូត្រ ហើយទី២ យើងគួរពិនិត្យមើលឡើងវិញ និងថែមបង្គ្រប់សក្ខីភាពសម្រាប់អត្ថិភាពពីមុននៃមាវនៈធម៌សូត្រនិងផ្អែកលើគម្ពីរច្បាប់មុនៗដែលជាកំណាព្យ។

ក្នុងចំណោមផ្នែកនានានៃតម្រាមនុ-ស្រ្មិតិ ដែលបង្ហាញថាអំណះអំណាងរបស់អ្នកនិពន្ធនេះខុសមិនមែនជានីតិករទី១ និងដែលបង្ហាញថា អ្នកនិពន្ធមានអ្នកជំនាន់ក្រោយជាច្រើន គេត្រូវចាត់

ថ្នាក់សេចក្តីបញ្ជាក់នេះ ស្ថិតក្នុងលំដាប់ទី១ ស្តីពីបដិវាទកម្ម និងសេចក្តីសម្រេចដ៏ចម្រូងចម្រាស់ស្តីពី ចំណុចមួយចំនួននៃពិធីសាសនានិងច្បាប់។ ករណីបែបនេះពិតជារឿងកម្រណាស់។ ដូច្នេះការសង្កេត របស់ "អ្នកខ្លះ" ស្តីពីលំដាប់លំដោយនៃពិធីជាច្រើន នៅស្រាទ្ធ(Srāddha)(ការខ្វែងគំនិតគ្នាដូចនេះ មាន នៅក្នុងសង្ខាយនៈ គ្រីហ្យ សូត្រ សៀវភៅលេខ ៤ ចំណុច ១, ១០) និងការជូននំអ្នក ចែកឋានទៅ មាននិយាយ នៅក្នុងគម្ពីរមនុ ជំពូក ៣ លេខ២២៦១។ ការពិភាក្សារបស់បណ្ឌិត សម័យបុរាណដែលប្រដូចបញ្ហានោះ យ៉ាងច្បាស់លាស់ទៅនឹងធម៌សូត្រ(ពិសេសសូមអានសៀវភៅលេខ ១៧ ចំណុច ៦-៩ ដែលជាកំណាព្យមួយក្នុង ចំណោមកំណាព្យជាច្រើននៃតម្រាមនុស្រ្មិតិ)មាននៅក្នុងជំពូក៩កាព្យលេខ៣១-៥៥ ដែលនិយាយពីចំណោទ បញ្ហាទំនាស់ដ៏វែងអន្លាយថា តើកូនប្រុសក្លែចប្រពន្ធដោយសារមានអ្នកថ្មីទេ ប៉ុន្តែដោយមានការយល់ ព្រមពីស្វាមី ជាបិតាពីធម្មជាតិ ឬជា "ម្ចាស់នៃព្រលឹងវិញ្ញាណ"។ ក្នុង ជំពូកដដែលនេះ អះអាងដូចគ្នា នឹងព្រះធម៌សូត្ររបស់ព្រះគោត្តម(ព្រះគោត្តម, ជំពូក ១៨ លេខ ៨) ថា "អ្នកខ្លះ" ហ៊ានបើកឱកាសបង្កើត កូនប្រុសទី២ ជាមួយស្ត្រីមេ ម៉ាយដែលព្រមព្រៀងគ្នាជាមុន។ ច្បាប់មនុ ជំពូក ១០ លេខ ៧០-៧១ ដែលយើងខិតខំរកការសម្រេច ដូចអ្នកខ្លះអះអាង អំពីបញ្ហាថាតើគ្រាប់ពូជមានសារៈសំខាន់ជាង ឬ ដូចខ្លះទៀតថា ដីសំខាន់ជាង ឬដូចមួយក្រុមទៀតថា គ្រាប់ពូជ និងដីមានសារៈសំខាន់ស្មើគ្នា ហើយ ជំពូក ១១ លេខ ៤៥ គេប្រាប់យើងថា បណ្ឌិត ពោលគឺបណ្ឌិតទាំងអស់ មានជំនឿជឿជាក់អំពីភាព ស័ក្តិសិទ្ធិនៃការលាងបាប សម្រាប់លាងជម្រះនូវបទល្មើសដោយអចេតនា រីឯអ្នកខ្លះប្រកាសថា ពួកគេ ថែមទាំងជួយរំដោះទោសកំហុសរបស់អ្នកដែលបានប្រព្រឹត្តអំពើបាបដោយចេតនាផង។ ចំណុចចុង ក្រោយនេះ គេធ្វើការពិភាក្សាយ៉ាងច្បាស់លាស់ដូចគ្នាទៅនឹងគម្ពីរគោត្តម កាព្យលេខ១៩។ ក្នុងករណី ផ្សេងទៀត អ្នកនិពន្ធនិយាយមិនសូវច្បាស់ទេ។ អ្នកនិពន្ធគ្រាន់តែដាក់ទស្សនៈគំនិតខ្វែងគ្នាទាំងសង ខាង ដោយមិនបានវែកញែកថា ទស្សនៈទាំងនោះមានប្រភពជាក់លាក់ផ្សេងគ្នាទេ ដូច្នេះហើយគាត់ សឹងតែធ្វើឱ្យមានការយល់ច្រឡំថាអ្នកអត្ថាធិប្បាយលើកឡើងជាន័យពិតប្រាកដដូចគាត់ដែរ។ ហេតុ នេះចូរយើងអានសៀវភៅមនុ ជំពូក២ លេខ១៤៥ ថា គ្រូអាចារ្យគួរឱ្យគោរពតិចជាងឪពុកនិងម្តាយ ចំណែកឯកំណាព្យបន្តបន្ទាប់បង្រៀនយ៉ាងច្បាស់អំពីលទ្ធិផ្ទុយនេះ។ អ្នកអធិប្បាយមានការរាវែកច្រើន ដោយសារបដិវាទកម្មនេះ។ ក៏ប៉ុន្តែប្រសិនបើយើងងាកទៅមើលសៀវភៅគោត្តមជំពូក២ លេខ ៥០-៥១ ដែលនិយាយថា "គ្រូអាចារ្យជាចម្បងក្នុងចំណោមគុរុ(Gurus)ទាំងអស់ ខ្លះនិយាយថា ម្តាយ ស្ថិតនៅក្នុងឋានៈទី១។ ប្រាកដណាស់ថា តម្រាមនុ-ស្រ្មិតិ នៅក្នុងកំណាព្យទី១ ផ្តល់នូវមតិរបស់ មនុស្ស មួយចំនួនអំពីគម្ពីរគោត្តមថា បុរវបក្សៈ និងលើកតួយ៉ាងដូចខាងក្រោម ដើម្បីបញ្ជាក់ការពិតពី ភាពមិនត្រូវរបស់វា។ ករណីប្រហែលគ្នានេះ កើតមាននៅក្នុងសៀវភៅមនុជំពូក៣ លេខ២៣-២៥ ដែលបានរៀបរាប់ទស្សនៈយោបល់ចំនួនបី ស្តីអំពីការដែលអាចអនុញ្ញាតឱ្យរៀបពិធីអាពាហ៍ពិពាហ៍ បានដែលចំណុចចុងក្រោយជាទស្សនៈរបស់ព្រះសិទ្ធន្ត ឬរបស់អ្នកនិពន្ធផ្ទាល់។

គេអាចតវ៉ាបានថា សេចក្តីខ្លឹមសារទាំងអស់ ដែលជាការពង្រីកបន្ថែម មិនបានបង្ខំឱ្យយើងជឿ ថា សេចក្តីនោះជាច្បាប់ពិតប្រាកដ ជាគម្ពីរដែលមានតាំងពីមុនគម្ពីរមនុ-ស្រ្មិតិទេ។ ប្រសិនបើគម្ពីរ

នោះផ្ទាល់គេអាចបកស្រាយគ្មានអ្វីក្រៅពីថា បញ្ហាអង្គច្បាប់និងពិធីសាសនាមានការគិតគូរពីសំណាក់អ្នកសិក្សារៀនសូត្រតាំងពីយូរណាស់មកហើយ។ ប៉ុន្តែឧបាយដោះខ្លួននេះមិនអាចធ្វើទៅរួចទេ ដោយហេតុថា នៅក្នុងកំណាព្យផ្សេងៗទៀត យើងរកឃើញការសារភាពយ៉ាងច្បាស់ថា អ្នកនិពន្ធគម្ពីរមនុ-ស្រ្មិតិបានស្គាល់ធម៌សាស្រ្តៈ។ សេចក្តីទាំង ៣ និយាយមិនច្បាស់លាស់អំពីអត្ថិភាពតាមន័យទូទៅ។ ទី១ តាមនិយមន័យនៃពាក្យ មានពាក្យ *ស្រុតិ* និង *ស្រ្មិតិ*សៀវភៅមនុ ជំពូក២ លេខ១០ ថា "ប៉ុន្តែតាមពាក្យ *ស្រុតិ* (ការបកស្រាយ) មានន័យថា វេទ និងពាក្យ *ស្រ្មិតិ* (ប្រពៃណី) ជាគោលការណ៍ច្បាប់ពិសិដ្ឋ"។ នៅក្នុងអត្ថបទពាក្យចុងក្រោយ ធម៌សាស្រ្តៈ ជាពាក្យឯកវចនៈ។ ប៉ុន្តែគេយល់ច្បាស់ ពីព្រោះពាក្យ កុល្លូកៈ(ភាសាសំស្រ្កឹត) និងនារាយណៈ(ភាសាសំស្រ្កឹត) បញ្ជាក់ពីន័យសមូហភាព។ សំណេរមួយទៀតនៃគម្ពីរច្បាប់ គេឃើញមាននៅក្នុងសៀវភៅមនុ ជំពូក១២ លេខ១១ ដែលធម៌បាថក "អ្នកដែលសូត្រ (គោលការណ៍)ច្បាប់ពិសិដ្ឋ" ត្រូវមានឈ្មោះក្នុងចំណោមសមាជិកបរិស័ទឬសន្និបាត ដែលមានសិទ្ធិដោះស្រាយបញ្ហាស្មុគស្មាញនៅក្នុងច្បាប់។ អ្នកអធិប្បាយឯកភាពគ្នាជាឯកច្ឆ័ន្ទក្នុងការបកស្រាយធម៌តាមន័យត្រង់ "ច្បាប់ពិសិដ្ឋ" តាម "គោលការណ៍ច្បាប់ពិសិដ្ឋ" ឬ "ស្រ្មិតិនៃមនុ និងគម្ពីរផ្សេងៗ" ហើយតាមពិតការកំណត់ន័យនៃពាក្យនេះក្រៅពីន័យ "គម្ពីរច្បាប់"( Medh. (ភាសាសំស្រ្កឹត) ...Kull. ..., Nadh.....។ សារសំខាន់ទាំងស្រុងនៃសេចក្តីនេះ នឹងបង្ហាញជូនខាងក្រោយទំព័រ iii) មិនអាចធ្វើទៅបានទេ។ សេចក្តីទី៣ បញ្ជាក់ច្បាស់បំផុតថា គេប្រើពាក្យធម៌សាស្រ្តៈជាពហុវចនៈ។ នៅក្នុងវគ្គស្តីពីពិធីយញ្ញបូជាសពសៀវភៅមនុ ជំពូក៣ កាព្យលេខ ២៣២ថា "តាមពិធីយញ្ញជាកិត្តិយសគេត្រូវតែឱ្យ (ភ្ញៀវកិត្តិយសរបស់ខ្លួន) បានស្តាប់ឮវេទគោលការណ៍ច្បាប់ពិសិដ្ឋ (ធម៌សាស្រ្តាណី)"ជាដើម(សូមមើលសាស្រ្តាចារ្យ Stenzler ក្នុងសៀវភៅ Indische Studien,ភាគ ១ ទំព័រ ២៤៥ និងបណ្ឌិត Johiinntgen,ទស្សនាវដ្តី DasGesetzbuchdesManu, ទំព័រ ៧៦) ។ ហេតុនេះវត្តមាននៃគម្ពីរច្បាប់ជាច្រើនកាលពីសម័យមុនៗ ត្រូវគេទទួលស្គាល់ជាធម្មតា។ លក្ខណៈគោលការណ៍នៃច្បាប់ពិសិដ្ឋ ដែលគេស្គាល់ជាអ្នកនិពន្ធច្បាប់មនុរបស់យើង គេអាចលើកអំណះអំណាងពីប្រភពផ្សេងៗទៀត ដែលបង្ហាញពីភាពស្របគ្នានឹងអង្គវេទ(សូមមើលអត្ថបទដកស្រង់របស់សាស្រ្តាចារ្យ Stenzler និងបណ្ឌិត Johannstgen ទំព័រ៧៤) ។ សៀវភៅមនុ ជំពូក២ លេខ១៤១ និង ជំពូក៤ លេខ ៩៨ គេលើកឡើងពីវិទ្យាសាស្រ្តជំនួយទាំងនេះតាមវិធីទូទៅ។ ចាប់ពីគម្ពីរមនុ ជំពូក៣ លេខ ៨៥ ដែលនិយាយថា ពួកព្រាហ្មណ៍ ដែលចេះចាំអង្គយញ្ញទាំង៦ រៀបចំពិធីតាមស្រាទ្ធៈ លៀងអាហារពេលល្ងាច យើងដឹងថា ចំនួនតាមដែលអ្នកនិពន្ធរបស់យើងបានបង្ហាញមិនខុសពីចំនួនដែលមាននិយាយនៅក្នុងស្នាដៃវេទទាំងអស់ទេ។ លើសពីនេះឈ្មោះរបស់អង្គធម៌ទី១ កល្ប មានក្នុងជំពូក ៣ លេខ១៨៥ និងការនិយាយពី*ណៃរុក្ត* ក្នុងចំណោមសមាជិកបរិស័ទ សបញ្ជាក់ថា គេក៏បានដឹងពី*ណៃរុក្ត* ជាទី៤។ តាមការបញ្ជាក់ចុងក្រោយ និងអង្គ ៤ ទៀត ដែលអ្នកនិពន្ធមនុ ស្រ្មិតិ ក៏បានដឹងតាមគ្រប់ភវនីយភាព (ដំណើរគួរឱ្យជឿ) ទាំងអស់ថា យើងមិនគិតគូរភ្លាមៗទេ។ ប៉ុន្តែទី១ កល្ប មានចំណាប់អារម្មណ៍ច្រើនណាស់ចំពោះគោលបំណងរបស់យើង។ ដូចដែលគេបានដឹងច្បាស់ហើយពាក្យនេះសំដៅជារួមដល់សូត្ររបស់សាលាវេទ ដែលបង្រៀនពីការអនុវត្តពិធីយញ្ញស្រូត ជាពិធីសាសនាដែលរៀបរាប់ជាពិសេសនៅក្នុងស្រុតិ។ ដូច្នេះទាំងស្រូត-សុត្រា ព្រមទាំងសូត្រ-ករណៈ ពិតជាមានមុនគម្ពីរ

មនុ-ស្រ្មិតិ។ ឥឡូវនេះសូមចងចាំក្នុងចិត្តថា យោងតាមប្រពៃណីហិណ្ឌូ ដូចបានបង្ហាញខាងដើម សូត្រ-ករណៈ ពីមុនមានធម៌-សូត្រ និងថា នៅក្នុងកល្បមួយចំនួនធម៌-សូត្រ មានទំនាក់ទំនងជិតស្និទ្ធ ជាមួយនឹងស្រូត-សុត្រៈ។ គួរឱ្យជឿជាក់បំផុតថា មានវៈធម៌សាស្រ្តៈ គឺមានក្រោយពីគម្ពីរធម៌សូត្រមួយ ចំនួន។ សេចក្តីសន្និដ្ឋាននេះ នឹងលម្អិតបន្ថែមទៀតតាមរយៈសេចក្តីបញ្ជាក់ នានានៃមនុ-ស្រ្មិតិ ដែល អ្នកនិពន្ធបានស្រង់យកទស្សនៈយោបល់របស់អ្នកនិពន្ធជំនាន់មុនម្នាក់ៗ។ សៀវភៅមនុ ជំពូក៣ លេខ ១៦ យើងអានថា "យោងតាម *អត្រិ* និង (គោត្តម) និយាយថា កូនប្រុសរបស់ឧតថ្យៈ(ទម្រង់ ឧតថ្យៈ ជាការបង្ហូចគម្ពីរឧកថ្យវេទ និងបង្ហាញពីការជំនួសព្យញ្ជនៈដែលមានសូរនៅក្នុងក្រអូមមាត់ ដែលមានជាធម្មតានៅ ក្នុងគ្រាមភាសាប្រាគ្រិត។ ដូច្នេះវាមានតម្លៃពិតប្រាកដមួយ ជាសក្ខីកម្មបន្ថែមសម្រាប់បញ្ជាក់ពីដើមកំណើតក្រោយសម័យ វេទនៃគម្ពីរមនុ-ស្រ្មិតិ។) ដែលរៀបការជាមួយស្រ្តីសូទ្រៈម្នាក់ ជាមនុស្សក្រៅសង្គម យោងតាមសោណកៈ ស្តីពីកំណើតរបស់កូនប្រុសនិងយោងតាមភ្រិគុ អ្នកដែលមានបងប្អូន(ប្រុស) ពីស្រ្តីសូទ្រៈ ប៉ុណ្ណោះ"។ ផ្អែកលើការបកស្រាយខាងលើនេះ ដែលអ្នកអត្ថាធិប្បាយភាគច្រើនបានប្រកាន់យក និងបញ្ជាក់ទទួល ស្គាល់ដោយសេចក្តីបញ្ជាក់ដូចគ្នានៃធម៌សាស្រ្តៈពាក្យកាព្យរបស់ឧសនៈ(ឧស. ធម៌សាស្រ្ត លេខ ៣, ... ភាសាសំស្រ្កឹត។ សូម្បីការថ្លែងរបស់ឧសណៈពាក់ព័ន្ធនឹងយោបល់អ្នកច្បាប់បូរាណ មិន យល់ស្របតាមការថ្លែងរបស់គម្ពីរ មនុ-ស្រ្មិតិ លើកលែងតែករណីសោណកៈ ក៏ការថ្លែងនោះគ្មានសារៈសំខាន់ទេ ពីព្រោះវាបង្ហាញពីភាពផ្សេងគ្នានៃយោបល់ ស្តីពីហេតុបច្ច័យនៃអាពាហ៍ពិពាហ៍ជាមួយពួកសូទ្រៈ។ សូមមើលមេរៀនតាហ្គ័រ របស់Jolly ទំព័រ៥៣ផង) អ្នកនិពន្ធផ្តល់ ទស្សនៈយោបល់លើកឧទាហរណ៍ បញ្ជាក់យោបល់ពាក់ព័ន្ធនឹងប្រភពគួរឱ្យទុកចិត្តបានចំនួន៤ដែល មានអាយុកាលចាស់ជាង ហើយយោបល់ទាំងអស់ទទួលបានការជឿជាក់ពីប្រពៃណីហិណ្ឌូ ដោយមាន ការលាតត្រដាងអាចកំបាំងនៃគម្ពីរច្បាប់នានា។ យើងនៅតែមានស្រ្មិតិជាច្រើន ដែលជាគម្ពីររបស់អត្រិ សោណកៈ និងគោត្តម ព្រមទាំងគេនិយាយថាគម្ពីរមួយជារបស់ភ្រិគុ។ លើកលែងតែគម្ពីរភាសិតគោត មីយៈសាស្រ្ត ស្នាដៃទាំងអស់នេះជាស្នាដៃទំនើប មួយចំនួនជាការពិនិត្យសំណៅដៃ ជាកំណាព្យនៃ សូត្រមុនៗ និងមួយចំនួនមានប្រភពគួរឱ្យសង្ស័យណាស់។ ហេតុនេះ គេមិនអាចនិយាយបានថា គម្ពីរ មនុ មិនអាចសំដៅដល់គម្ពីរធម៌សាស្រ្តៈដែលមានស្រាប់ណាមួយទេ ដូចជារបស់អត្រិ, សោណកៈ និង ភ្រិគុ ហើយតាមការពិត យោបល់ដែលគេដកស្រង់ទាំងនោះ មិនអាចមានសញ្ញាបញ្ជាក់នៅក្នុងស្នាដៃ នោះទេ។ ប៉ុន្តែបើសិនជាយើងងាកទៅមើលតម្រាសូត្ររបស់គោត្តម យើងនឹងរកឃើញមានក្នុង ចំណោមមនុស្សទាំងនោះ ដែលធ្វើឲ្យប៉ះពាល់ដល់ភ្ញៀវនៅឯពិធីស្រាទ្ធៈលាងអាហារពេលល្ងាច និង ដែលនៅក្រៅសហគមន៍របស់អ្នកមានគុណធម៌ជាសូទ្រាបតិ ក្នុងន័យត្រង់គឺ "ប្តីរបស់ស្រ្តីសូទ្រៈ" (គោត្តម ជំពូក ១៥ លេខ ១៨, គម្ពីរពិសិដ្ឋបូព៌ាប្រទេស ភាគ ២ ទំព័រ ២៥៥។)។ ទោះជាយ៉ាងណាក៏ដោយសារៈ សំខាន់ពិតប្រាកដនៃពាក្យផ្សំនេះ ទំនងជាដូចលោកហរទេតស្នើថា "អ្នកដែលមានភរិយាឬធម្មបត្នី ប៉ុណ្ណោះជាសូទ្រៈ"។ ជាក់ស្តែងសៀវភៅមនុ ជំពូក៣ លេខ ១៧-១៩ ហាក់ដូចជាបង្ហាញថា យោបល់ របស់កូនប្រុសឧតថ្យៈ គឺដូចគ្នា វាទំនងជាមិនមានន័យដូចគ្នាទាល់តែសោះថា មនុ-ស្រ្មិតិ ពិតជាដក ស្រង់ព្រះសូត្ររបស់គោត្តម ដែលមាននៅពេលនោះទេ។ សេចក្តីសំណាងមួយទៀតចំពោះសូត្រដែល បាត់ មាននៅក្នុងសៀវភៅមនុ ជំពូក៦ កាព្យលេខ២១ ដែលនិយាយពីតាបសនៅក្នុងព្រៃថា "អូ! គាត់

អាចរស់នៅអាស្រ័យដោយផ្កាឈើ ឫសឈើ និងផ្លែឈើជាប្រចាំប៉ុណ្ណោះ... ដោយព្យាយាមគោរពតាមវិធានសីលធម៌របស់វិខណៈ។" ភាសាសំស្ក្រឹតដើមនៃប្រយោគគុណស័ព្ទ គឺ "វៃខាណសមតេ ស្ថិតៈ" ហើយមានន័យត្រង់ថា "ដោយប្រកាន់យកមតិយោបល់របស់វៃខាណសៈ"។ អ្នកអធិប្បាយលើកលែងតែនារាយណៈ បានប្រកាសជាឯកច្ឆ័ន្ទថា ពាក្យ *វៃខាណសៈ* នៅទីនេះ សំដៅដល់សាស្ត្រ ឫសូត្រដែលបានប្រកាសឱ្យប្រើដោយវៃខាណសៈ និងពិពណ៌នាយ៉ាងច្រើនពីករណីយកិច្ចរបស់តាបសឫសី (មេធ .... សំស្ក្រឹត)។ ភាពត្រឹមត្រូវនៃមតិយោបល់នេះ ហាក់ដូចជាច្បាស់លាស់ណាស់សម្រាប់រូប។ ចំពោះពាក្យ *មតៈ* "មតិ" តាមកំណាព្យក្នុងគម្ពីរមនុ តម្រូវថា ផ្នែកខាងដើមនៃសមាសនាម គួរសំដៅដល់មនុស្សក៏បាន សាលាក៏បាន ឬ ស្នាដៃក៏បាន។ ប្រសិនបើយើងចាត់ទុកវៃខាណសៈ ក្នុងន័យជាឥសីនៅក្នុងព្រៃនោះយើងមានការបកប្រែដ៏គ្មានន័យ "ឥសីអាចរស់នៅអាស្រ័យដោយផ្កាឈើជាដើមដោយយកតាមមតិយោបល់របស់តាបសឥសី"។ ហេតុនេះ ការបកប្រែវៃខាណសៈ តាមអ្នកអត្ថាធិប្បាយ ក្នុងន័យវៃខាណសៈសាស្ត្រ និងការយោងទៅលើស្នាដៃណាមួយដែលប្រៀនប្រដៅពីករណីយកិច្ចរបស់ឥសី ជាការចាំបាច់ណាស់។ វត្តមាននៃស្នាដៃបែបនេះ ត្រូវបានបញ្ជាក់មិនត្រឹមតែដោយអ្នកអធិប្បាយគម្ពីរមនុប៉ុណ្ណោះទេ ថែមទាំងដោយអ្នកនិពន្ធសម័យបុរាណ និងសម័យទំនើបដទៃទៀតផង។ ពោធាយនៈសរសេរបញ្ជាក់រឿងនេះយ៉ាងច្បាស់លាស់(ពោធ្ទៈ សៀវភៅធម៌ៈ ជំពូក២ កាព្យលេខ ១១, ១៤ និង គម្ពីរពិសិដ្ឋបូព៌ាប្រទេស ភាគ ១៤ ទំព័រ ២៥៩) និងទំនងជាសង្ខេបយ៉ាងខ្លីអំពីខ្លឹមសាររបស់វា ក្នុងជំពូកទី៣នៃប្រស្នាទី៣ នៅក្នុងធម៌សាស្ត្រៈរបស់គាត់។ ហរទត្តៈ អ្នកអត្ថាធិប្បាយអាបស្តម្ភៈនិងគោត្តម ក៏ហាក់ដូចជាបានបញ្ជាក់ច្បាស់។ នៅក្នុងកំណត់សម្គាល់របស់គាត់ស្តីពីសៀវភៅគោត្តម ជំពូក៣ លេខ២ គាត់បញ្ជាក់ពីប្រភពនៃវៃខាណសៈ ជាឥសីរស់នៅក្នុងព្រៃដោយនិយាយថា "គេហៅវានប្រស្ថជាវៃខា-ណសៈ ពីព្រោះគាត់រស់នៅតាមវិន័យសីលធម៌ ដែលប្រកាសឱ្យប្រើជាផ្លូវការដោយវៃខាណសៈ" និងបន្ថែម "ដោយហេតុថា(បណ្ឌិត)បានបង្រៀនពីវិន័យនោះ"(សំស្ក្រឹត)។ ប្រសិនបើសេចក្តីថ្លែងនោះ ពួកបណ្ឌិត ឥណ្ឌាបានធ្វើឱ្យខ្ញុំមានទំនុកទុកចិត្តយ៉ាងខ្លាំង ម្យ៉ាងទៀតយើងក៏សង្ឃឹមចំពោះការស្តារឡើងវិញនូវស្នាដៃនៅពេលនេះបាន។ នេះពិតជាគម្ពីរបុរាណដ៏យូរលង់មួយ ដោយហេតុថាន័យទី២នៃពាក្យវៃខាណសៈឥសី ដែលអាចនិយាយបានតាមការលើកឡើងរបស់*ហរទត្តៈ(*ពាក្យ ទ្រិទ្ធិ នៅក្នុងវៃខាណសៈ ទំនងជា សទិសន័យនៃពាក្យ ដែលមាននៅក្នុងអាក្រិតិ-គណៈ អនុសតិកាទិ, បាន. ជំពូក ៧ កាព្យលេខ ៣, ២០*)* នៅក្នុងធម៌-សូត្រៈដ៏ចំណាស់ជាងគេ។ យោងតាមព្រឹត្តិការណ៍ទាំងអស់នេះគេមិនអាចសន្មតបានថា វាមានទំនាក់ទំនងណាមួយជាមួយនឹងវៃខាណសៈសូត្រករណៈ ជាអនុផ្នែកនៃតៃត្តិរីយៈ ដែលទំនងជាសាលាដ៏ក្មេងខ្ចីមួយក្នុងចំណោមសាលានានា ដែលប្រកាន់ខ្ជាប់នូវប្លែកយគុំវេទ(មើលសាស្ត្រាចារ្យ Max Muller, សកាសង្ស, អក្សរសិល្ប៍, ទំព័រ ១៩៩ និងសាស្ត្រាចារ្យ Weber ទស្សនាវដ្តី Indische Studien លេខ ១ ទំព័រ ៨៣។ ផ្នែកមួយនៃវៃខាណសៈ ស្រោត-សូត្រ មានជាប្រតិចារឹកទំនើប ជាកម្មសិទ្ធិរបស់សាកលវិទ្យាល័យបំបៃ និងរាជបណ្ណាល័យមូនិច ដែលសាស្ត្រាចារ្យ Hang បានមកពីគម្ពីរបេពទា។)។ ប៉ុន្តែច្បាស់ណាស់ថាគម្ពីរវៃ ខាណសៈសូត្របុរាណ ដែល ជាផ្នែកមួយដ៏សំខាន់នៃគម្ពីរពិសិដ្ឋ ដែលមានមុនគម្ពីរមនុ-ស្មិតិរបស់យើងទៅទៀត។

ការសំអាងមួយចំពោះមតិយោបល់របស់មនុស្សម្នាក់ ដែលជាអ្នកនិពន្ធដ៏មានកេរ្តិ៍ឈ្មោះទៅលើស្នាដៃធម៌សូត្រ ត្រូវគេរកឃើញនៅក្នុងសៀវភៅមនុ ជំពូក៨ លេខ១៤០ ដែលមានចែងអំពីអត្រា ការប្រាក់ស្របច្បាប់សម្រាប់កម្ចីដែលមានការធានា គឺថា "អ្នកផ្តល់កម្ចីលុយអាចបង្កើនដើមទុនរបស់ខ្លួនតាមរយៈការប្រាក់ដែលអនុញ្ញាតដោយវសិស្ថៈ និងយកចំណែកប្រចាំខែ ៨០ លើ១០០"។ បើសិនយើងងាកទៅមើលវសិស្ថៈ ធម៌សាស្ត្រៈ ដូចយើងបានអានសៀវភៅជំពូក ៣ កាព្យលេខ៥១(សៀវភៅពិសិដ្ឋរបស់បូព៌ាប្រទេស លេខ១៤ ទំព័រ១៦ និងយោងតាមការបោះពុម្ពផ្សាយរបស់បណ្ឌិត Fuhrer វស. ជំពូក៣ កាព្យលេខ ៥០។)ថា "ផ្តល់ការប្រាក់ឱ្យអ្នកផ្តល់កម្ចីលុយ តាមការប្រកាសរបស់វសិស្ថៈ ចំនួនមាសៈ (អាចយកជារៀងរាល់ខែ) សម្រាប់លុយចំនួន ២០ កាហាបណៈ។ សូម្បីការប្រើពាក្យមនុ-ស្រ្មិតិ ខុសគ្នាពីពាក្យដែលគេបានប្រើនៅក្នុងវសិស្ថៈ ធម៌សាស្ត្រៈ ក៏ន័យនៃពាក្យទាំងពីរគឺដូចគ្នា។ ៨០ភាគរយ គឺស្មើ ១ភាគបួនរយ ហើយគេទទួលបានអត្រាស្មើគ្នាប្រសិនបើគេយក៥មាសៈសម្រាប់លុយ២០ កាហាបណៈពោលគឺសម្រាប់លុយ៤០០មាសៈ (គគន្និថៈក្នុងកម្រងអត្ថបទជំពូក១ លេខ២៥ ផ្តល់នូវការគណនាខុសគ្នាបន្តិច។ ក៏ប៉ុន្តែន័យទូទៅនៅដដែល។ ខ្ញុំយកតាមក្រិស្តបណ្ឌិត និង ហរទត្តៈ ស្តីពីគម្ពីរគោត្តម ជំពូក១២ កាព្យលេខ២៩។)។

ដូចនេះ គម្ពីរច្បាប់ទាំងពីរ ពិតជាសំដៅលើវិធានតែមួយរបស់វសិស្ថៈ។ ក៏ប៉ុន្តែភាពត្រឹមត្រូវនៃការពិចារណាបន្ថែមថា អ្នកនិពន្ធគម្ពីរមនុ-ស្រ្មិតិដែលប្រើវសិស្ថៈ ធម៌សាស្ត្រៈ មិនងាយស្រួលនឹងបង្ហាញថា ជាការដកស្រង់ដូចខាងដើមទេ។ សម្រាប់គម្ពីរវសៈជំពូក៣ កាព្យលេខ៥១ ផ្ទាល់ ជាការដកស្រង់ ដែលគេស្គាល់ដោយសារពាក្យចុងក្រោយ ឥតិ (មិនបានបកប្រែ)និងឃ្លា "ឥឡូវពួកគេក៏ដកស្រង់ថា" ដែលមានបុព្វបទសូត្រ ៤៨។ ដូច្នេះ គេអាចអះអាងថា ការស្រុះស្រួលគ្នានៃពាក្យទាំងពីរមិនបានផ្តល់នូវអំណះអំណាងរឹងមាំចំពោះបច្ឆាគតភាពនៃមនុ-ស្រ្មិតិ ដែលមានឈ្មោះ វសិស្ថៈ ផ្ទុយទៅវិញ វាប្រហែលជាគ្រាន់តែបង្ហាញពីភាពចំណុះគ្នានៃស្នាដៃទាំងពីរលើប្រភពរួមមួយ ពីព្រោះវាផ្អែកលើស្នាដៃចំណាស់ជាង ឬប្រពៃណីនៅក្នុងសាលាព្រហ្មញ្ញបច្ចុប្បន្ន។ ការបដិសេធបែបនេះ សឹងតែជាការត្រឹមត្រូវតាមច្បាប់ទាំងស្រុង ប៉ុន្តែខ្ញុំគិតថា ក្នុងពេលបច្ចុប្បន្ននេះ វាត្រូវបិទបាំងដោយព្រឹត្តិការណ៍ចម្លែកៗមួយចំនួន។ ផ្តើមចេញពីប្រពៃណីហិណ្ឌូដូចបានរៀបរាប់ខាងលើដែលគោវិន្ទស្វាមិនៈ(សូមមើលខាងលើទំព័រxx.) បានរក្សាទុកយើងបានដឹងថាវសិស្ថៈធម៌សាស្ត្រៈដើមឡើយជារបស់សាលាឫគវេទដែលសំអាងលើដំណោះស្រាយច្បាប់របស់ពួកគេ ផ្អែកលើឫសិវសិស្ថៈវេទដ៏ល្បីល្បាញ។ វិធានស្តីពីការកំណត់ការប្រាក់ប្រចាំខែចំពោះកម្ចីដែល មានការធានាចំនួន១/៤ ភាគរយ ក៏មាននៅក្នុងធម៌សូត្ររបស់គោត្តម ជំពូក១២ កាព្យលេខ២៩ ជាស្នាដៃដូចដែលបានបង្ហាញនៅកន្លែងផ្សេងៗ(គម្ពីរពិសិដ្ឋបូព៌ាប្រទេស លេខ ១១ ទំព័រ liii, liv) មានចំណាស់ជាង វសិស្ថៈ-ស្រ្មិតិ។ ប៉ុន្តែមិនមែនមាននៅក្នុងស្នាដៃនោះហើយក៏គ្មាននៅក្នុងស្នាដៃដទៃដែរ(មើលឪ.ទា.យញ្ញ.ជំពូក២ កាព្យលេខ៣៧និងអត្ថបទរបស់ព្រិហស្បតិនិងវ្យាសៈដែលគេដកស្រង់នៅក្នុងកម្រងអត្ថបទ ជំពូក១ លេខ ២៦-២៧) ជាការបញ្ជាក់យ៉ាងច្បាស់បន្ថែមលើវសិស្ថៈ។ ហេតុនេះគេសឹងតែអាចនិយាយបានថា ការបន្ថែមនេះត្រូវធ្វើឡើង ដោយអ្នកទាំងឡាយដែលបានសន្មតក្នុងច្បាប់របស់ពួកគេ ថាជាវសិស្ថៈ និងដែលចាប់អារម្មណ៍លើ ការបញ្ជាក់ពីការប្រឌិតសុភាសិត

ច្បាប់ដ៏សំខាន់សម្រាប់ព្រលឹងវិញ្ញាណរបស់ពួកគេ។ ប្រសិនបើគម្ពីរ ច្បាប់របស់ពួកគេផ្ដល់នូវវិធាន ជាទម្រង់ការដកស្រង់ ពួកគេទំនងជាមិនចង់បង្ហាញថា កំណាព្យពីមុនដែលសំអាងហេតុផលលើវសិស្ថៈមាន ប៉ុន្តែថាវិធាន ជាវិធានបុរាណ ហើយត្រូវស្រង់ចេញពីគម្ពីរ ច្បាប់ ឬពីប្រពៃណីនៃការអប់រំរបស់ពួកព្រាហ្មណ៍។ តាមការបកស្រាយនេះ ការនិយាយពីឈ្មោះ វសិស្ថៈនៅក្នុងសៀវភៅមនុ ជំពូក៨កាព្យលេខ ១៤០ នៅតែជាការបញ្ជាក់ថា អ្នកនិពន្ធសៀវភៅនេះ បានដឹងនិងសំដៅលើវសិស្ថៈធម៌សាស្ត្រ។

ផ្នែកទាំងអស់នេះ មានចំនួនច្រើនពេក មិនអាចបរិយាយបន្ថែមនៅពេលក្រោយទេ ហើយតាមពិតគ្មានព្រឹត្តិការណ៍ជាប់ពាក់ព័ន្ធនឹងវគ្គណាមួយដែលអាចធ្វើការសន្មតបែបនេះបានទេ។ ដូច្នេះ យើងត្រូវទទួលស្គាល់ថាផ្នែកទាំងនោះបង្ហាញច្បាស់ថា ការអះអាងរបស់គម្ពីរមនុ-ស្ម្រិតិខុសពីទីតាំងទី១ក្នុងចំណោមគម្ពីរច្បាប់របស់ឥណ្ឌាដែលមាននៅក្នុងជំពូកទី១ និងថាវាមានការគាំទ្រខ្លាំងចំពោះទស្សនៈនេះ ដែលស្របតាមដំណាក់កាលក្រោយមកទៀតនៃច្បាប់មនុ-ស្ម្រិតិ ដែលមានការអភិវឌ្ឍ ផ្នែកអក្សរសាស្ត្រ ជាងធម៌សូត្រ។

បើយោងតាមចំណុចទី២ នៃសេចក្ដីបន្ថែមនេះ យើងអាចពិចារណាលម្អិតឡើងវិញអំពីសេចក្ដីនៃវសិស្ថៈស្ម្រិតិ ដែលបញ្ជាក់ការពិតពីអត្ថិភាពដើមនៃមានវៈ ធម៌សូត្រ និងដែលតាមនីតិវិធីពិភាក្សា បានកំណត់អាទិភាពវសិស្ថៈស្ម្រិតិ ជាងច្បាប់មនុរបស់យើងដ៏មានសារៈសំខាន់ពិសេស។ សេចក្ដីដ៏សំខាន់ មាននៅក្នុងវសិស្ថៈជំពូក ៤ កាព្យលេខ ៥-៨(..ភាសាសំស្ក្រឹត) ដែលមានសេចក្ដីថា ៖

៥. មានវៈ (សូត្រចែងថា) "មានតែនៅពេលគោរពដល់ពួកព្រាហ្មណ៍ និងព្រះអាទិទេពទេ ឬពេលផ្ដល់កិត្តិយសដល់ភ្ញៀវទេ ទើបគេធ្វើបាបសត្វបាន។"

៦."នៅពេលផ្ដល់ទឹកឃ្មុំ(ឱ្យភ្ញៀវ) នៅក្នុងពិធីបូជានិងពិធីសាសនា ជាកិត្តិយសរបស់មនុស្ស ប៉ុន្តែក្នុងឱកាសនេះប៉ុណ្ណោះ ទើបគេអាចធ្វើការសម្លាប់សត្វបានស្របតាម(វិធាន)ច្បាប់មនុ។"

៧. គេមិនអាចទទួលបានសាច់សត្វ ដោយគ្មានការបង្កគ្រោះដល់ជីវិតសត្វនោះទេ ហើយការប៉ះពាល់អាយុជីវិតសត្វមិនបានទទួលពរជ័យពីឋានសួគ៌ទេ ដូច្នេះ (បណ្ឌិតប្រកាសថា) អ្នកសម្លាប់(សត្វព្រៃ)សម្រាប់ពិធីបូជា មិនមែនជាឃាតករទេ (តាមន័យធម្មតារបស់ពាក្យនេះ)។"

៨. "ឥឡូវ គេក៏អាចចម្អិនគោឈ្មោល ឬពពែពេញជំទង់សម្រាប់ពួកព្រាហ្មណ៍ ឬភ្ញៀវក្សត្រិយ៍ ហើយពួកគេផ្ដល់បដិសណ្ឋារកិច្ចដល់មនុស្សតាមរបៀបនេះ។"

ដូចបានជម្រាបជូននៅក្នុងសេចក្ដីផ្ដើមវសិស្ថៈ(គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស លេខ ១៤ ទំព័រxviii-xix) ព្រះសូត្រទាំងបួន ត្រូវគេដកស្រង់ទាំងអស់ ដោយសារឥតិបរិវាស័ព្ទ "ដូច្នេះ" មាននៅចុងជំពូក៤ កាព្យលេខ៨ និងដោយសារភាពដូចគ្នានៃសូត្រ ៦ ជាមួយនឹងគម្ពីរមនុ ជំពូក៥ កាព្យលេខ៤១ ព្រមទាំងភាពដូចគ្នាយ៉ាងខ្លាំងនៃសូត្រ៧ ជាមួយនឹងមនុ ជំពូក៥ កាព្យលេខ ៤៨ បង្ហាញថា សេចក្ដីសម្រង់នោះ មិនមែនចប់ដោយសូត្រ ៥ទេ។ ប្រសិនបើយើងទទួលយកការបកស្រាយនេះ យើងរៀបចំសេចក្ដីរបស់យើងតាមធម៌-សូត្រ។ ទី១ ជាក្បួនពាក្យសម្រាយបន្ទាប់មកមានកំណាព្យបញ្ជាក់បន្ថែម និងចុងក្រោយផ្នែកវេទ ដែលជាការសម្របតាមរបស់ក្បួននិងកំណាព្យ។ គេបញ្ជាក់បន្ថែមថាការបកស្រាយសេ

ចក្តីតាមក្រិស្ណៈ បណ្ឌិតធម្មាធិការិន នៅក្នុងសេចក្តីអធិប្បាយរបស់លោកក្នុងតម្រាវសិស្ថៈ ស្របតាមការពន្យល់ខាងលើទាក់ទងនឹងពាក្យ មានវៈថា "មានវៈ(សូត្រៈ)" គឺសំដៅដល់"ទស្សនៈយោបល់របស់មនុ" (មនុមតំ) គេមិនអាចលើកឡើង ដោយហេតុផលជាច្រើន។ ទី១ ការប្រើពាក្យរបស់អត្ថបទសូត្រ ៥ ទំនងជាការសម្រង់សេចក្តីត្រឹមត្រូវ មិនមែនជាការសង្ខេបគំនិតរបស់មនុតាមវសិស្ថៈទេ។ រឿងនេះច្បាស់លាស់ថា ប្រសិនបើយើងប្រៀបធៀបវសិស្ថៈ កាព្យលេខ១៧ ដែលជាក្បួនតម្រាមនុពិតប្រាកដទៅនឹងមានវៈ ធម្មៈ ជំពូក៧ កាព្យលេខ ២០៣ និងជំពូក៨ កាព្យលេខ ៤១ តាមពាក្យរបស់វសិស្ថៈ គឺថា "មនុបានប្រកាសថា ច្បាប់(ផ្សេងៗ)របស់ប្រទេសនានា វណ្ណៈនិងគ្រួសារ ត្រូវតែគោរពដោយគ្មានក្បួនតម្រា ជាអត្ថបទជាក់ស្តែងទេ(.ភាសាសំស្ក្រឹត..)។ ទី២ភាពខុសគ្នាយ៉ាងច្រើនរវាងសេចក្តីដទៃទៀតជាច្រើន ដែលស្រង់ដោយ វសិស្ថៈ ថាជារបស់គម្ពីរមនុ និងវគ្គផ្សេងៗនៃអត្ថបទមនុ-ស្ម្រិតិ តាមដែលយើងបានយល់ គឺតម្រាក្រោយនេះ សំដៅដល់វសិស្ថៈ ធម៌សាស្ត្រៈមិនអាចឱ្យយើងសន្មត តាមក្រិស្ណៈបណ្ឌិតថា វសិស្ថៈ បានដឹង និងសំដៅដល់តម្រាមនុរបស់យើង។

ដូច្នេះ ប្រសិនបើត្រូវយល់ថា គេធ្វើសម្រង់សេចក្តីរបស់វសិស្ថៈ ចេញពីមានវៈ ធម៌សាស្ត្រៈ ការព្រមព្រៀងនៃលទ្ធិ សម្រាប់ការបង្រៀនតាមសេចក្តីសម្រង់ និងផ្នែកមួយនៃអត្ថបទតាមតម្រាមនុ ស្ម្រិតិរបស់យើង បង្ហាញបន្ថែមថា ធម៌សូត្រនេះ ត្រូវតែជាគម្ពីរច្បាប់ពាក្យកាព្យនាំមុខគេរបស់យើង។ ការពិនិត្យពិចារណាសម្រង់សេចក្តីផ្សេងៗនៃតម្រាមនុ ដែលមាននៅក្នុងវសិស្ថៈស្ម្រិតិ នឹងសបញ្ជាក់ថាការព្រមព្រៀងនេះ សូម្បីសឹងតែដូចគ្នាបេះបិទក៏ដោយ ក៏មិនទាំងស្រុងដែរ។ ភាពដូចគ្នាផ្នែកទស្សនៈដែលវសិស្ថៈជំពូក១ លេខ១៧ សំអាងហេតុផលលើតម្រាមនុតាមខ្លឹមសារសៀវភៅមនុជំពូក ៣ លេខ ៤១ ត្រូវបានលើកយកមកបញ្ជាក់រួចហើយ។ សៀវភៅវសិស្ថៈជំពូក៣ កាព្យលេខ២ គេស្រង់សេចក្តីមានវៈស្លោក ដែលមានន័យត្រង់ស្របតាមសៀវភៅមនុ ជំពូក ២ កាព្យលេខ ១៦៨។ កំណត់សម្គាល់ដូចគ្នា អាចមាននៅក្នុងសម្រង់សៀវភៅវសិស្ថៈជំពូក ២០ កាព្យលេខ ១៨ ដែលមាននៅក្នុងតម្រាមនុជំពូក១១ លេខ១៥២។ វគ្គមួយទៀត វស.ជំពូក ១៣ កាព្យលេខ ១៦ មានភាពខុសគ្នាផ្នែកសំណេរជាច្រើន។ យោងតាមវសិស្ថៈ កំណាព្យរបស់មនុ គឺៈ"បើមានផ្លែឈើ ឬទឹក ឬល្ង ឬអាហារ ឬអ្វីក៏ដោយសម្រាប់ជា(អំណោយ)ក្នុងពិធីស្រាទ្ធៈ សូមកុំឱ្យគេគ្រាន់តែទទួលយក ចូរសូត្រវេទ ព្រោះមានការប្រកាសនៅក្នុងស្ម្រិតិថា ដៃរបស់ព្រាហ្មណ៍ គឺជាមាត់របស់គេ" ចំណែកឯយើង អានតម្រាមនុ ជំពូក ៤ កាព្យលេខ១១៧ "បើមានសត្វ ឬអ្វីដែលគ្មានជីវិត អ្វីក៏ដោយឱ្យតែជា (អំណោយ) ក្នុងពិធីស្រាទ្ធៈ ចូរកុំឱ្យគេគ្រាន់តែទទួលសូមឱ្យសូត្រវេទផង ព្រោះនៅក្នុងស្ម្រិតិប្រកាសថា ដៃរបស់ព្រាហ្មណ៍ជាមាត់របស់គេ(វស....ភាសាសំស្ក្រឹត...) ។" សម្រង់ចុងក្រោយ ដែលមានក្នុងគម្ពីរ វស.ជំពូក ១៩ កាព្យលេខ ៣៧ និងយោងទៅលើ*សុល្កៈ*(ការលើកលែង)ពន្ធនិងអាករ("មិនមែនអាករ (ត្រូវបង់)តាមចំនួនតិចជាង ១ កាហាបណៈ គឺគ្មានការយកពន្ធលើកការចិញ្ចឹមជីវិតដោយវិស័យសិល្បៈ និងលើទារក មិនយកលើអ្នកនាំសារ និងមិនយកលើអ្វី ដែលបានពីការដើរសុំ មិនយកលើទ្រព្យដែលលស់ពីអំពើប្លន់ មិនយកលើស្រោត្រិយៈ មិនយកទៅលើតាបសឬសី និងមិនយកលលើគ្រឿងបូជាទេ។") មាននៅក្នុងចង្វាក់បទត្រិស្តុព ដូចនេះមិនអាចមានកន្លែងនៅក្នុងមនុ-ស្ម្រិតិរបស់យើងទេ។ ប៉ុន្តែគួរឱ្យកត់សម្គាល់ថា ចំណុចចុងក្រោយនេះសូម្បី មិនមានកាព្យអានុស្តុព

ពាក់ព័ន្ធក្តី និងថាខ្លឹមសារនៃសម្រង់ មិនស្របគ្នានឹងការបង្រៀនរបស់តម្រា មនុរបស់យើង។ ចំណុចចុងក្រោយនេះ លើកឡើងពីការលើកលែងពន្ធចំពោះបរិមាណតិចជាងមួយកាហាបណៈ ដែលត្រូវគ្នានឹងជំពូក១០ កាព្យលេខ១២០។ មានន័យថាស្របគ្នានឹងលទ្ធិរបស់មនុថា ស្រោត្រិយៈឫសីទេយ្យទាន និងវត្ថុបូជាមិនត្រូវជាប់ពន្ធទេ។ ក៏ប៉ុន្តែមិនមានការបញ្ជាក់ថា ទារកអ្នកនាំសារ និងរដ្ឋទូត ឬទ្រព្យរបស់ពាណិជ្ជករដែលសល់ពីចោរប្លន់ គួរតែរួចផុតពីការបង់ពន្ធ។ ចំពោះអ្វីៗសម្រាប់ចិញ្ចឹមជីវិតដោយវិស័យសិល្បៈ តម្រាមនុរបស់យើងជំពូក៧ កាព្យលេខ ១៣៨ និងជំពូក១០ កាព្យលេខ ១២០ ដូចអ្នកនិពន្ធបុរាណផ្សេងទៀតទូន្មានថា សិល្បករត្រូវផលិតស្នាដៃមួយក្នុងមួយខែសម្រាប់ព្រះមហាក្សត្រិយ៍។ ទោះបីកិច្ចការនេះត្រូវស្របតាមបរិមាណពន្ធ ការពិតគេអាចបញ្ជាក់ថា វិធានមនុ មិនផ្ទុយគ្នាទាំងស្រុងនឹងអ្វីដែលស្រង់ដោយវសិស្ថៈទេ។ ក្រៅពីសេចក្តីទាំងអស់នេះ មានកំណាព្យខ្លះទៀត(វស.ជំពូក ១១ កាព្យលេខ ២៣, ជំពូក១២ លេខ១៦, ជំពូក ២៣ លេខ ៤៣, ជំពូក ២៦ លេខ ៨) ដែលមានឃ្លាដ៏ល្បីល្បាញ "មនុអព្រាវីត ដូច្នេះ មនុ បាននិយាយថា" ហើយចាត់ មនុ ជាប្រភពគួរឱ្យទុកចិត្តសម្រាប់ក្បួនច្បាប់ប្រៀនប្រដៅ។ ចំពោះសេចក្តីសំអាងទាំងអស់នេះ ខ្ញុំហាក់ដូចជាមិនអាចនិយាយថា គេបានស្រង់វាចេញពីតម្រាមានវៈធម៌សូត្រៈទេ។ យើងនឹងពិចារណាតទៅទៀតនៅខាងក្រោម(មើលទំព័រ lviii) ចាប់ពីសម័យដើមបំផុត មនុតាមទេវកថាជាបិតារបស់មនុស្សជាតិ ត្រូវចាត់ទុកជាអ្នកបង្កើតសណ្តាប់ធ្នាប់សង្គម និងសីលធម៌ និងថាគេចាត់ទុកព្រះអង្គជាបុគ្គលទី១ ដែលបានទូន្មានប្រៀនប្រដៅឬបើកបង្ហាញពិធីសាសនា និងភាសិតច្បាប់។ ដូចនេះគេមានជំនឿថា កំណាព្យទាំង៤នេះ មិនមានន័យអ្វី ក្រៅពីការបង្ហាញនូវជំនឿថា លទ្ធិរបស់ខ្លួនសុទ្ធតែសំអាងលើបុព្វបុរសទី១ របស់មនុស្ស(ន័យនៃឃ្លាកំណាព្យ ដែលមាននៅក្នុងសម្រង់ពីមានវៈសូត្រ ទំនងជាដូចគ្នា។) ។ បុព្វបុរស៣ជំបូងក្នុងចំណោមអ្នកទាំងឡាយ ផ្ទុយគ្នាផងនិងមិនទំនាស់គ្នាផង នៅក្នុងតម្រាមនុ-ស្ម្រិតិរបស់យើង។ ទីបួន ស្របគ្នាផ្នែកសារជាតុជាមួយនឹងតម្រាមនុជំពូក១១ កាព្យលេខ២៦០-២៦១។ ប៉ុន្តែមាននៅក្នុងជំពូកទី១ប្រហែលជាមិនត្រឹមត្រូវ ឬយ៉ាងហោចណាស់ក៏មានការថែមថយដែរ។ ទស្សនៈយោបល់អ្វីក៏ដោយ ដែលមាននៅក្នុងសេចក្តីទាំងអស់នេះជាការចោទថា មានវៈធម៌សូត្រ ដែលគេស្គាល់ថាជារបស់វសិស្ថៈ ដូចគ្នាច្រើន តែមិនដូចគ្នានឹងតម្រាមនុរបស់យើងមិនចាំបាច់មានការកែសម្រួលទេ។

ប្រសិនបើយើងខិតខំរកតម្រុយផ្សេងៗរបស់ព្រះសូត្រ ដែលវសិស្ថៈបានដកស្រង់មកនោះ គឺអាចនិយាយបានថា គម្ពីរគោត្តម ថ្លែងបញ្ជាក់ទស្សនៈយោបល់របស់មនុ ជំពូក២១ កាព្យលេខ៧នោះ។ ធម៌-សូត្ររបស់ព្រះអង្គ ក៏មានចំណាស់ជាងស្ម្រិតិរបស់វសិស្ថៈ និងកើតមុនយូរលង់ជាងមនុស្ម្រិតិរបស់យើងផង។ ប៉ុន្តែលទ្ធភាពដែលព្រះគោត្តមមិនសំអាងលើក្បួនតម្រាមានវៈ ធម៌សូត្រ តែសំអាងលើភាសិត ដែលមានទូទៅនៅក្នុងតម្រា មនុ បែបទេវកថា មិនត្រូវបានប្រានចោលទាំងស្រុងទេ។ គម្ពីរគោត្តមនិយាយថា "មនុ(ប្រកាសថា) បញ្ញត្តិ៣ ជំបូង(ស្តីពីបទឧក្រិដ្ឋ ការសម្លាប់ព្រាហ្មណ៍ដោយចេតនា ការសេពសុរា និងការរំលោភបំពានគ្រែរបស់គុរុ) មិនអាចរួចផុតពីការដាក់ទោសបានទេ (...(សំស្ក្រឹត)..II. យោបល់ដដែល មាននៅក្នុងគម្ពីរមហាភារតៈ ជំពូក ១២ លេខ ១៦៥, ៣៤ ប៉ុន្តែមិនមែនមាននៅក្នុង

គម្ពីរមនុទេ។)។ ការប្រើពាក្យសូត្រៈបង្ហាញថា វាមិនមែនជាការដកស្រង់ទេតែជាការសង្ខេបមតិយោបល់របស់មនុ។ មនុ-ស្រ្មិតិជំពូក១១ កាព្យលេខ៩០ ប្រៀនប្រដៅលទ្ធិដូចគ្នាស្ដីពីការសម្លាប់ព្រាហ្មណ៍ដោយចេតនា ព្រមទាំងការសេពសុរាដោយចេតនា ហើយបើតាមការពន្យល់របស់ខ្ញុំអំពីជំពូក១១ កាព្យលេខ ១៤៧ត្រូវបានទទួលយក។ ក្នុងន័យនេះបទល្មើសទី៣ មិនមែនជាសម្ដីផ្ទាល់ទេ។ ក៏ប៉ុន្តែការលុបលាងទោសដែលមានចែងក្នុងជំពូក១១ លេខ១០៤-១០៥ ស្មើនឹងទោសប្រហារជីវិត។ ហេតុនេះមនុ-ស្រ្មិតិរបស់យើងក៏ដូចគ្នាជាក់ស្ដែងប្រកាសបទឧក្រិដ្ឋ មិនអាចលុបលាងបានក្នុងមួយជីវិតរបស់អ្នកប្រព្រឹត្ត។ ដើមកំណើតធម៌-សូត្រៈ ដូចនេះ គេអាចសន្មតជាវិធាន ដែលព្រះគោត្តមសន្មតថា ជារបស់ព្រះមនុ។ តែយ៉ាងណាក៏ដោយ ដោយសារមានព្រឹត្តិការណ៍ ដែលបានរៀបរាប់ខាងលើ គេមិនអាចចាត់ទុកសេចក្ដីរបស់ព្រះគោត្តម ថាជាទឡ្ហីករណ៍ល្អឥតខ្ចោះស្ដីពីវត្តមានដើមរបស់តម្រាមានវៈធម៌សូត្រទេ។

ក្នុងចំណោមធម៌សូត្រដទៃទៀត(សំដៅដល់សេចក្ដីនៃសៀវភៅអាបស្តពៈ ជំពូក២ លេខ ៦១, ១ ដែលចាត់ទុកព្រះមនុជាអ្នកបង្កើតស្រាទ្ធៈ មើលទំព័រ lixខាងក្រោម) មានតែផ្នែកដែលជារបស់ឧសនៈ ដែលទំនងជាដកស្រង់ សូត្ររបស់ព្រះមនុ។ នៅដើមជំពូកទី១(ខ្ញុំសរសេរផ្ដើមស្នាដៃទាំងមូល "...ភាសាសំស្រ្កឹត..."។ នេះជាសំណេរពីរ ហើយសំណេរទី៣ អាន...(សំស្រ្កឹត) និងបន្តថា(សំស្រ្កឹត)។ ការធ្វើសេចក្ដីនេះឱ្យដូចដើមវិញទាំងអស់ គឺមិនអាចទៅរួចទេ។ សម្រង់សេចក្ដីចុងក្រោយ គឺ..(សំស្រ្កឹត)។) យើងឃើញមានសេចក្ដីវិការៈ ដែលមានសម្រង់ពាក្យរាយស្របតាមសំណេរដៃពីររបស់ខ្ញុំជាគម្ពីរមនុ ប៉ុន្តែ តាមសៀវភៅទី៣ជារបស់សុមន្តុ។ ដោយសារសំណៅ ក្រោយនេះយ៉ាងណាក៏ដោយក៏មិនសូវជាត្រឹមត្រូវជាងសំណៅពីរផ្សេងទៀត ហើយដោយសារសូត្ររបស់សុមន្តុគេមិនបានដឹងប្រភពផ្សេងទៀត នោះការអានសៀវភៅពីរដំបូងទំនងជាជក់ចិត្តជាង។ ខ្លឹមសារសេចក្ដីស្រង់ ដែលហាក់ដូចជារៀបរាប់អំពីការស្លាប់របស់ទារក ជនចំណាកស្រុក អ្នកដែលមិនរក្សាអគ្គិពិសិដ្ឋ អ្នកដែលស្លាប់ខ្លួនដោយសារគ្រោះឡើក្ស ឬដោយការដុតខ្លួនឯងទាំងរស់ និងអ្នកដែលស្លាប់ក្នុងសមរភូមិ គេមិនចាំបាច់កំណត់រយៈពេលនៃភាពមិនបរិសុទ្ធមានន័យថាស្របតាមការប្រៀនប្រដៅរបស់តម្រាមនុ-ស្រ្មិតិរបស់យើង ជំពូក៥ កាព្យលេខ ៧៨ ៨៩ ៩៤ និង ៩៨។

ជាងនេះទៅទៀត គម្ពីរមួយក្នុងចំណោមគម្ពីរវេទនានាមានពិធីសាសនាសង្ខាយនៈគ្រិហ្យសូត្រៈដែលអាចសំដៅដល់មានវៈ ធម៌សូត្រ។ ស្នាដៃនេះស្រង់កំណាព្យ មនុ ជំពូក៥ លេខ៤១ ដូចបានដែលបង្ហាញខាងលើ ក៏មាននៅក្នុងធម៌សូត្រ ព្រមទាំងស្លោកមនុ-ស្រ្មិតិរបស់ដទៃទៀតជា ច្រើន ដែលមួយផ្នែកជាកំណែល្អប្រសើរ( Oldenberg, សង្ខ. គ្រិ.ស. ក្នុង IndischeStudien លេខ ១៥ ទំព័រ II) ។ ដូចគ្រិយ្យ-សូត្រ ក៏មានវិធានស្របគ្នាជាច្រើនជាមួយនឹងមនុ អាចមានន័យថា អ្នកនិពន្ធស្នាដៃអាចផ្អែកលើប្រភពដើមនៃស្នាដៃក្រោយនេះ។ ប៉ុន្តែពីមុន គេអាចមានទំនុកចិត្តខ្លាំងទៅលើចំណុចនេះ ពោលគឺថា ចំណោទបញ្ហាស្មុគស្មាញខ្លះ ពាក់ព័ន្ធនឹងលក្ខណៈសំខាន់នៃអត្ថបទសង្ខយនៈ គួរតែច្បាស់លាស់ជាងមុនចាប់ពីពេលនេះទៅ។ សំខាន់ជាងនេះទៀត សេចក្ដីនៅក្នុងស្នាដៃចុងក្រោយជាសក្ខីកម្មដែលកាមន្ទនីយៈនីតិសារៈបានផ្ដល់ ដែលគេស្រង់ទស្សនៈយោបល់ពីរជងនៃមានវាសៈនិងយោបល់របស់មនុ ប៉ុន្តែប្រានចោលទស្សនៈយោបល់គ្រូរបស់អ្នកនិពន្ធលោក កានក្យ កោទិល្យៈ។ ក្នុងករណីមួយ គឺថា លទ្ធិរបស់មានវាសៈ

ស្របនឹងការប្រៀនប្រដៅ នៃតម្រាមនុ-ស្ម្រិតិរបស់យើង។ យើងរិះរកន័យតាមការពិភាក្សាស្ដីពីចំនួនប្រាគិតិសមាសធាតុសំខាន់ៗនៃមន្ទលៈឬមជ្ឈដ្ឋាននយោបាយដែលព្រះមហាក្សត្រិយ៍ត្រូវយកព្រះទ័យទុកដាក់ កាម. នីត. ជំពូក ៧ លេខ ២៤-២៥ ថា "ចំពោះ(សំណួរ)នេះ មានវៈ កត់ត្រាថា សមាសធាតុសំខាន់៥សេនាបតីនិងមន្ត្រីខ្ញុំរាជការដទៃទៀតជាសមាជិករបស់ក្សត្រិយ៍១២អង្គ។ប៉ុន្តែ(ក្សត្រិយ៍) ១២ ព្រះអង្គតាំងពីដើមមក និងសេនាបតី និងខ្ញុំរាជការដទៃទៀត មានចំនួន ៧២ (ជាចំនួននិងទម្រង់)ជាក្រុមសមាសធាតុសំខាន់ៗទាំងស្រុង(..ភាសាសំស្ក្រឹត...។ខ្ញុំអានតាមសេចក្ដីអធិប្បាយ ...(សំស្ក្រឹត) ជំនួសឃ្លាគ្មានន័យ...(សំស្ក្រឹត)នៃអត្ថបទនេះ។)។ តម្រាមនុ-ស្ម្រិតិរបស់យើងជំពូក៧ កាព្យលេខ ១៥៥-១៥៦ ថ្លែងថា ក្សត្រិយ៍១២ព្រះអង្គ ជាកម្មសិទ្ធិរបស់មន្ទលៈ និងថែមកាព្យលេខ ១៥៧ "សេនាបតីព្រះរាជាណាចក្របន្ទាយរតនាគារនិងកងទ័ព ជាក្រុមសមាសធាតុសំខាន់៥ ទៀត ពីព្រោះសមាសធាតុទាំងនេះ មានទំនាក់ទំនងនឹងក្សត្រិយ៍ម្នាក់ៗ (១២ ព្រះអង្គ) ដូចនេះគណៈទាំងមូល (មាន) ជារួម(អាចថា) ៧២ (ផ្នែកសំខាន់ៗ)"។ វគ្គពីរផ្សេងទៀត ខុសពីគ្នា។ យោងតាមតម្រាកាមន្ទកិ ជំពូក២ លេខ៣ មានវៈបង្រៀនថា វិទ្យាសាស្ត្រ ដែលព្រះមហាក្សត្រិយ៍ត្រូវសិក្សា មានតែបីប៉ុណ្ណោះ គឺគម្ពីរវេទ ៣ ទ្រឹស្ដីស្ដីពីវិជ្ជាជីវៈ និងពាណិជ្ជកម្ម និងវិទ្យាសាស្ត្រគ្រប់គ្រងរាជរដ្ឋាភិបាល "ពីព្រោះវិទ្យាសាស្ត្រ ប្រើគ្រាមភាសាឬហេតុផលគឺជាផ្នែករងមួយក្នុងចំណោមផ្នែកទាំងបី(នៃចំណេះដឹងវេទ(សំស្ក្រឹត))"ចំណែកឯច្បាប់មនុ ជំពូក ៣ លេខ ៤៣ រៀបរាប់មែកធាងចំណេះដឹងចំនួនប្រាំ ឬយ៉ាងហោចណាស់ចំនួនបួន ប្រសិនបើការពន្យល់របស់មេធាទិថិឬនារាយណៈអំពីពាក្យ *អាត្មវិទ្យា* ដែលប្រែថាជា "ចំណេះដឹងរបស់ព្រលឹងវិញ្ញាណ(កំពូល)" ត្រូវគេទទួលយកបាន(បើយោងតាមការបកស្រាយរបស់មេធាទិថិ និងនារាយណៈ សូមមើលកំណត់សម្គាល់បកប្រែ។ ខ្ញុំនឹងបន្ថែមថា កាម. នីត. ជំពូក ២ លេខ ៧ ...(សំស្ក្រឹត) "វិទ្យាសាស្ត្រភាសា (ជា) ន័យទទួលស្គាល់ទាំងស្រុងនូវព្រលឹង ឬអត្តា" ស្របតាមការបកស្រាយរបស់នារាយណៈ និងថា វាទំនងជាប្រសើរជាង បើខ្ញុំដាក់ន័យក្រោយនេះទៅក្នុងអត្ថបទ។) ។ ជាថ្មីម្ដងទៀត យើងឃើញតម្រាកាមន្ទកិ ជំពូក ១ លេខ ៦៧ ថា ព្រះមនុបានកំណត់ចំនួនសេនាបតី (អាមាត្យ) ដែលព្រះមហាក្សត្រិយ៍ ត្រូវតែងតាំងឱ្យគ្រប់ ១២។ ប៉ុន្តែយោងតាមតម្រាមនុ ជំពូក ៧ លេខ ៥៤ គេតម្រូវឱ្យមានមិនលើសពី ៧ ឬ ៨ទេ។ សម្រង់ទាំងអស់នេះ សបញ្ជាក់ថា កាមន្ទកិ បានចេះការងាររបស់មនុ ដែលមានសិក្ខាវិន័យ ស្ដីពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ហើយតាមទិដ្ឋភាពខ្លះស្របគ្នានឹងជំពូកទី៧ នៃតម្រាមនុ-ស្ម្រិតិរបស់យើង។ ប្រសិនបើខ្ញុំសន្និដ្ឋានថា នេះពិតជាមានវៈធម៌សូត្រដើមនោះគឺដោយសារ កាមន្ទកិ និយាយពីរដងដល់ចំណុចនេះ ដោយឈ្មោះថា មានវសៈ ក្នុងន័យត្រង់ថា "អ្នកទាំងឡាយដែលសិក្សាស្នាដៃរបស់ព្រះមនុ" ឬត្រូវបកប្រែច្រើនថា "ការប្រៀនប្រដៅរបស់មានវៈ"។ នេះជាការអនុវត្តជាទូទៅបំផុតរបស់អ្នកនិពន្ធឥណ្ឌាច្រើនយោងរបៀបនេះដល់គម្ពីរដែលកំណត់តាមការបង្រៀនសំខាន់ៗ។ ប៉ុន្តែខ្ញុំដឹងថាគ្មានករណីដែលលទ្ធិរបស់មានវៈ ធម៌សាស្ត្រៈឬពីស្នាដៃផ្សេង ដែលព្រះប្រទានសម្រាប់ពួកអារ្យ័នទាំងអស់ ហើយគេចាត់ជាប្រភពគួរឱ្យទុកចិត្តបំផុត ត្រូវគេស្រង់សេចក្ដីដូចគ្នា ឬតាមរបៀបដូចគ្នា។ ដូចកាមន្ទកិ បញ្ជាក់ស្រាប់វាមិនផ្ទុយពីសិក្ខាវិន័យដែលព្រះមនុបានប្រៀនប្រដៅ ជាមួយនឹងសិក្ខាវិន័យរបស់គ្រូអាចារ្យដទៃទៀត ហើយបន្ទាប់មកប្រានចោលសិក្ខាវិន័យទាំងអស់នោះទេ (ដូចបណ្ណាធិការដែលមានចំណេះដឹងខ្ពស់ ពី

នីតិសារៈ (អារម្ភកថា ទំព័រ ២) អះអាងថា អ្នកនិពន្ធតម្រានេះ ជាអ្នកពុទ្ធនិយម គេអាចសន្មតថា អ្នកនិពន្ធក្រោយឱ្យតម្លៃតម្រាមនុតិចតួច ពីព្រោះគាត់ប្រកាន់យកនិកាយពាហិយៈ។ ប៉ុន្តែគួរកត់ សម្គាល់ថា គ្មានទឡ្ហីករណ៍សម្រាប់បញ្ជាក់អំណះអំណាងខាងលើទេ ហើយស្នាដៃនេះ គ្មានសញ្ញាពាក់ព័ន្ធនឹងពុទ្ធសាសនាទេ។)។ ប្រសិនបើអ្នកនិពន្ធហិណ្ឌូសរសេរពីច្បាប់ចាំបាច់ត្រូវទុកទស្សនៈយោបល់របស់មនុ ដោយឡែកគាត់ក៏នឹងទុកចោលដោយស្ងាត់ស្ងៀម ឬគាត់ប្រែសេចក្ដីដែលមានស្របតាមគោលការណ៍នៃតម្រាស្រ្មិតិមួយចំនួនទៀត ដែលស្របតាមការយល់ឃើញរបស់គាត់។ ហេតុនេះ គ្មានអ្វីគួរឱ្យមន្ទិលថា សេចក្ដីសំអាងរបស់កាមន្ទកិ សំដៅដល់ស្នាដៃរបស់ព្រះមនុ ដែលសូម្បីមានការគោរពច្រើនក៏ដោយ ក៏គ្មានជំហរដូចគ្នានឹងការបកស្រាយច្បាប់មនុរបស់ក្រិគុដែរ។ ម្យ៉ាងវិញទៀត តម្រាមនុរបស់ កាមន្ទកិ ប្រាកដជាកម្មសិទ្ធិនៃការប្រៀនប្រដៅណាមួយ ហើយនោះជាករណីស្របគ្នានឹងមានវៈធម៌សូត្រ។ ការពិតដែលធម៌សូត្រល្បីៗទាំងអស់ មានការពិពណ៌នាលម្អិតទំនងជាស្ដីអំពី ករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ស្របគ្នាល្អជាមួយនឹងសម្មតិកម្មនេះ ហើយមានព្រឹត្តិការណ៍ថា កាមន្ទកិ នីតិសារៈ ពិតជាស្នាដៃបុរាណដែលតាក់ តែងឡើងតាំងពីយូរមុនដើមសករាជរបស់យើងផង ឬយ៉ាងហោចណាស់ ការកែសម្រួលចុងក្រោយនៃគម្ពីរបុរាណដូច្នេះ (ស្នាដៃនេះ អះអាងថាជាការតាក់តែងរបស់សិស្សសេនាបតីដ៏ល្បីឈ្មោះគន្ទ្រគុបតៈ កានក្យ កោតិល្យ ឬកោតល្យៈ ដែលមានមួយផ្នែកឧទ្ទិសដល់មង្គលាករណៈ និងដែលជាញឹកញយ ត្រូវគេចាត់ទុកជាគុរុ ឬគ្រូ។ សូម្បីគ្មានសក្ខីកម្មច្បាស់លាស់សម្រាប់បញ្ជាក់អំណះអំណាងនេះទេ ក៏គ្មានការបដិសេធបញ្ហានេះដែរ។ ដើម្បីគាំទ្រសំអាងនេះ ដោយបញ្ជាក់ការពិតថាឈ្មោះអ្នកនិពន្ធ គឺជាមនុស្សវណ្ណៈខ្ពស់លំដាប់ទី២។ ក្នុងចំណោមអ្នកនិពន្ធសម័យបូរាណ ការចុះហត្ថលេខាលើសៀវភៅរបស់ខ្លួន ដោយដាក់នាមត្រកូល សឹងតែជាទូទៅ។ ក្រោយមក ក៏ទំនងជាលែងមានហើយ។ អ្នកអធិប្បាយតម្រាមនុ ដ៏យូរលង់ជាងគេ គឺមេធាទិថិ ធ្វើការដកស្រង់នីតិសារៈ។)។ ទាំងនេះជាសញ្ញាណជាក់លាក់ស្ដីពី អត្ថិភាពតាំងពីដើមនៃមានវៈ ធម៌សូត្រ ដែលខ្ញុំអាចរកបាន។ អាចនិយាយបានថា ស្នាដៃដដែលនេះ ក៏និយាយសំដៅដល់កំណាព្យមួយចំនួននៃបវ៌ន (មហាវគ្គ) ទី១២ និងទី១៣ នៃមហាភារតៈ។ ប៉ុន្តែបញ្ហានេះ ក៏ដូចជាអ្វីដែលយើងនឹងបានឃើញខាងក្រោយ ពោរពេញទៅដោយបញ្ហាស្មុគស្មាញយ៉ាងច្រើន ហើយដំណោះស្រាយទំនងជាមានមន្ទិលខ្លះ។ ក្នុងចំណោមសេចក្ដីនៃវគ្គខ្លះដែលបានពិភាក្សាខាងដើម គ្មានវគ្គណាមួយមានសារសំខាន់ដូចការដកស្រង់របស់វសិស្ថៈទេ។ យ៉ាងណាក៏ដោយ ក្រៅពីនេះក៏មានការផ្ដល់ទស្សនៈគំនិតកាន់តែច្បាស់អំពីប្រធានបទជាច្រើនរួមទាំងស្នាដៃចុងក្រោយ ហើយពួកគេគាំទ្រសេចក្ដីសន្និដ្ឋានរបស់អ្នកមុនៗថា មានវៈ ធម៌សូត្រ ដូចគ្នានឹងតម្រាមនុ-ស្រ្មិតិរបស់យើងយ៉ាងច្រើន។

ការអង្កេតបញ្ហាពាក់ព័ន្ធនឹងចំណុចចុងក្រោយ បើមានសំណួរថាតើគេអាចរកឃើញមានដានទំនាក់ទំនងនៃតម្រាមនុ-ស្រ្មិតិរបស់យើង ជាមួយនឹងសំណេរនៃការប្រៀនប្រដៅរបស់មានវៈឬទេ ចាប់ពីពេលនេះទៅ យើងនឹងសំអាងលើអំណះអំណាងខាងលើ។ ការពិតសេចក្ដីនេះសំដៅដល់ការប្រៀបធៀប មានវៈគ្រិហ្យសូត្រ ជាមួយនឹងធម៌សាស្រ្តៈ ដោយហេតុថាស្នាដៃទាំងពីរជារឿយៗ និយាយពីប្រធានបទដូចគ្នា។ នៅពេលប្រៀបធៀបផ្នែកពាក់ព័ន្ធនៃស្នាដៃទាំងពីរសាស្រ្តាចារ្យJolly (ស្ដីពីវិស្គុធម៌សូត្រ និងកាថកៈ, ស្នាដៃរបស់រាជបណ្ឌិត្យសភាផវរី, ឆ្នាំ១៨៧៩, លេខ២, ទំព័រ ៨២។) គ្មានការយល់ស្របពិសេសណាមួយជាមួយនឹងអាយុកាល ដែលរៀបរាប់ពីការប្រតិបត្តិសង្ខារនៅក្នុងពិធីអាពាហ៍ពិពាហ៍ និងសិក្ខាវិ

ន័យសម្រាប់ការប្រតិបត្តិរបស់សិស្ស និងស្នាតកៈ។ គាត់មិនអាចរកឃើញពាក្យពេចន៍បច្ចេកទេសប្លែកៗណាមួយនៅក្នុងតម្រាមនុ-ស្រ្មិតិ និងឃ្លាដែលប្រើនៅក្នុងគ្រិហ្យសូត្រៈ រីឯភាពដូចគ្នាច្រើននៅក្នុងមន្រ្តគាថានៃពិធីវៃស្យនិងក្នុងចំណុចពីរបីទៀតដែលមិនទាន់មានការសម្រេចចុងក្រោយអំពី ការព្រមព្រៀងគ្នាតែមួយនៃគ្រិហ្យសូត្រៈដទៃ។ ការពិនិត្យបច្ច័យឡើងវិញ របស់បណ្ឌិត Dr. von Bradke អំពីបញ្ហានេះ(ទស្សនាវដ្តីរបស់សង្គមបូព៌ាអាលីម៉ង់, លេខ៣២, ទំព័រ៤៣៨) មិនទាន់បានផលផ្សេងនៅឡើយទេ។ ខ្ញុំអាចត្រឹមតែធ្វើជាសាក្សីសម្រាប់ភាពត្រឹមត្រូវទូទៅនៃសម្តីទាំងអស់នេះ។ សូម្បីគេអាចបង្ហាញសេចក្តីខ្លះ ដែលលោកសាស្រ្តាចារ្យ jolly(ក្នុងចំណោមសិក្ខាវិន័យ ដែលស្របគ្នាជាពិសេស ខ្ញុំអាចលើកយកចំណុចមួយចេញពីវគ្គសេចក្តីផ្តួចផ្តើម មាន. គ្រី. សូ. ជំពូក ២ លេខ ២២(ចប់), "បន្ទាប់មកគាត់ត្រូវតែដើរចេញទៅសុំ ទី១ ម្តាយរបស់គាត់ និងស្រ្តីដទៃទៀត ដែលជាមិត្ត ឬដែលនៅជិតខាង ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។" សូត្រទាំងនេះ ស្រដៀងគ្នានឹងតម្រាមនុ ជំពូក ២ លេខ ៥០ "សូមឱ្យគាត់ ទី១ ដើរសុំអាហារពីម្តាយរបស់គាត់ ឬពីបងប្អូនស្រីរបស់គាត់ ឬមីងបង្កើតរបស់គាត់ ឬពីស្រ្តីខ្លះទៀត ដែល មិនធ្វើឱ្យគាត់ខូចឈ្មោះ (ដោយការបដិសេធ)។" ខ្ញុំមិនដឹងច្បាស់ថា សិក្ខាវិន័យនេះ មាននៅក្នុងស្រ្មិតិផ្សេងទៀតទេ។) មិនបានលើកឡើង ដែលគ្រិហ្យសូត្រសឱ្យឃើញពីភាពដូចគ្នាពិសេសជាមួយ ស្រ្មិតិ, ភាពខុសគ្នាច្រើននៅក្នុងវគ្គផ្សេងទៀត(ក្នុងចំណោមភាពខុសគ្នាច្រើននោះ ខ្ញុំនឹងលើកយកចំណុចខ្លះ ដែលមាននៅក្នុងវគ្គស្តីពីពិធីអាពាហ៍ពិពាហ៍។ មនុ ស្រ្មិតិ ជំពូក ៣ លេខ ២០-៣៤ រៀបរាប់គំរូចំនួន ៨ ដ៏ល្បីល្បាញ ដែលស្រ្តីអាចទទួលបានពីគ្រួសាររបស់នាង។ មានវៈ គ្រីហ្យ សូត្រ ជំពូក ១ លេខ ៧-៨ មានតែពិធី ២ ប៉ុណ្ណោះ គឺ ពិធីព្រាហ្មណ៍ និងពិធីសោល្កៈ។ ពិធីក្រោយ ដែលស្របគ្នានឹងពិធី អាសុរៈ ឬមនុស្សៈ នៃស្រ្មិតិផ្សេងទៀត និងដាក់ទណ្ឌកម្មដល់ការដាវកូនក្រមុំ ពីឪពុកម្តាយរបស់នាង។) ការមិនស្របគ្នានៅក្នុងសិក្ខាវិន័យ(ការមិនស្របគ្នាសិក្ខាវិន័យពិសេស គួរឱ្យកត់សម្គាល់បាននៅក្នុងជំពូកស្តីពីការសិក្សាវេទ និងការបញ្ឈប់ការសិក្សាវេទ។ មានសិក្ខាវិន័យទូទៅ ឧ.ទា. ស្តីពីការចាប់ផ្តើម, ប្រវែង, និងការបញ្ចប់ពាក្យអប់រំ ដែលគេឃើញមានផងដែរនៅក្នុងស្រ្មិតិ ផ្សេងទៀត ស្របគ្នានឹងស្នាដៃទាំងពីរ។ ក៏ប៉ុន្តែគ្មានការរៀបរាប់ពិសេសណាមួយ ដោយមានវៈ គ្រីហ្យ សូត្រៈ នៅពេលនោះ ហើយពិធីដែលគេត្រូវរៀនអំពីវគ្គពិសេសនៃមៃត្រាយនីយសំហិតាអាចរកតម្រុយឃើញនៅក្នុងតម្រាមនុ-ស្រ្មិតិ។)និងការគ្មានមន្រ្តី ដូចគ្នានឹងការបង្រៀនរបស់មៃត្រាយនីយ មានវៈនៅមនុ-ស្រ្មិតិ មិនអាចឱ្យយើងចាត់ទុកវាថាជាកត្តាកំណត់សម្រាប់ដោះស្រាយចំណោទបញ្ហានេះ។ ម្យ៉ាងវិញទៀត លទ្ធផលអវិជ្ជមាននេះ មិនបានប្រានចោលលទ្ធភាពថា ទំនាក់ទំនងដែលបានលើកឡើងរវាងប្រភពដើមនៃមនុ-ស្រ្មិតិ និងការបង្រៀនរបស់មានវៈយ៉ាងណាក៏ដោយអាចមាន។ ឧទាហរណ៍នៃហៃរន្យកេសៈ និងមាធ្យាំទិនៈបង្ហាញថា សូត្ររបស់សាលាណាមួយ មិនសុទ្ធតែតាក់តែងឡើងដោយគ្រូម្នាក់ និងគ្រូដដែលទេ តែជួនកាល ត្រូវតាក់តែងឡើងតាមផ្នែក ដោយអ្នកនិពន្ធផ្សេងគ្នា។ ក្នុងករណីមាធ្យាំទិនៈអ្នកនិពន្ធស្រោតសូត្រ គឺជាកាត្យាយនៈ ចំណែកឯគ្រិហ្យសូត្រៈ មានឈ្មោះបារស្ករៈ។ ក្នុងករណីហៃរន្យកេសៈ សូម្បីធម៌ សូត្រៈ ត្រូវគេសន្មតថា ជារបស់ហិរន្យកេសិន សត្យាសាធៈក៏ដោយ ក៏តាមតថភាពជាក់ស្តែង វាជាស្នាដៃរបស់អាស្តមពៈ ហើយខុសគ្នាទាំងពីរ ផ្នែកភាសារបស់វានិងអត្ថន័យរបស់វាគឺខុសគ្នាច្រើន ពីគ្រិហ្យសូត្រ(គម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស លេខ ២ ទំព័រxxiii) ។ មួយវិញទៀត ហៃរន្យកេសៈ កាយនសូត្រ ត្រូវគេដូរ ដោយសារស្លាកសញ្ញារបស់វា បង្ហាញច្បាស់ ដោយភារ ទ្វាគៈ។ ដូចនេះ គេនៅតែអាចនិយាយបានថា មានវៈ ធម៌សូត្រពីបុរាណត្រូវចាត់ជាកម្មសិទ្ធិពិសេសរបស់មានវៈ តែ មិនមែននិពន្ធដោយគ្រូតែមួយដូចគ្រីហ្យ

សូត្រ ឬថាសូម្បីស្នាដៃទាំងពីរនេះ មានអ្នកនិពន្ធតែមួយក្តី ក៏សម្ភារៈសម្រាប់តែងនិពន្ធត្រូវប្រើប្រភពផ្សេងគ្នាដែរ។ ថ្វីបើការសន្មតជួយបកស្រាយពីភាពខុសគ្នារវាងស្នាដៃទាំងពីរក្តី។ ប្រសិនបើយើងពេលនេះអាចបង្ហាញថា ស្នាដៃខ្លះទៀតដែលជារបស់មានវៈករណៈ ស្តែងឱ្យឃើញនូវភាពដូចគ្នាពិសេសនឹងមនុ-ស្រ្មិតិ ជាការយល់ថា ដើមកំណើតនៃស្នាដៃក្រោយនេះ ជាកម្មសិទ្ធិទី១របស់សាលា ដែលអាចនៅតែមានការគាំទ្រនោះ។ ការពិនិត្យមើលជាថ្មីនូវអភិប្រាយនានាដែលគេសិក្សានិងអះអាងថាជារបស់មានវៈ បានញុាំងឱ្យខ្ញុំជឿជាក់ថា ការភ្ជាប់ទំនាក់ទំនងបែបនេះ ពិតជាមាននៅក្នុងចំណោមនោះ។ នេះជាស្រាទ្ធ កល្បៈ ជាការរៀបរាប់ពី ពិធីបូជាសពធម្មតា ដែលមានវៈគ្រីហ្យសូត្រ មិនបានលម្អិត ប៉ុន្តែមានផ្នែកខ្លះ និយាយពីពិធីរីតិ៍ អស្តកា (ជំពូក២ លេខ៨-៩)។ ប្រសិនបើសាស្ត្រាចារ្យ Jolly និងបណ្ឌិត von Bradke មិនបានពិចារណាអភិប្រាយនេះ នោះហេតុផលគឺថា វាមិនមាននៅក្នុងកម្រងមានវៈសូត្ររបស់សាស្ត្រា Haug ហើយក្រោយមកមានអត្ថបទតែមួយគត់ ដែលសិស្សអឺរ៉ុបអាចអានបាន។ តាមសំណៅស្នាដៃអប់រំរបស់មានវៈដែលខ្ញុំមាន វានៅលំដាប់បន្ទាប់ពីប្រវរាធ្យាយៈ(ការសរសេររបស់ខ្ញុំស្តីពីមានវៈ ករណៈ ដែលត្រូវបោះផ្សាយឡើងវិញនៅឆ្នាំ ១៨៦៤-៦៥ នៅណាសិក ក្រៅពីសំហិតា និងឧបនិសាទដែលចាត់ទុកជាកណ្ឌទី៥ រាប់បញ្ចូលនូវផ្នែកទាំងអស់នៃស្រោត-សូត្រៈ ដែលគេស្គាល់តាមស្នាដៃរបស់ សាស្ត្រាចារ្យ Haug ព្រមទាំងកុមារៈ ឬកុមារិលៈ ភាស្យៈ និងផ្នែកវ្រីត្តិ របស់មិស្រៈ ពាក្រិស្ណៈ ព្រមទាំងគ្រីហ្យ សូត្រៈ ជាមួយនឹងភាស្យៈ, បូរាណក្យៈ របស់ភាត្តៈ អស្តាវក្រ (មិនមែនរបស់កុមារិលៈ ដូចខ្ញុំបានស្មាននៅក្នុងទស្សនាវដ្តីលោកខាងលិច និង Buhler ទំព័រ ៤៦ ចំណុច ក. នោះទេ) និងស្រាធកល្បៈ។) ។ វាមានបួនកណ្ឌខ្លីៗ។ កណ្ឌទី១ ចាប់ផ្តើមដោយពាក្យ "ឥឡូវនេះ យើងនឹងពន្យល់ពីតម្រាវិធានសម្រាប់ពិធីបូជាសព" និងសម្រាយសេចក្តីដូចតទៅៈ ការអញ្ជើញព្រាហ្មណ៍ដែលមានសមត្ថភាពការទទួលបដិសណ្ឋារកិច្ចរបស់ពួកគេ ដោយអាយ្យៈនៅក្នុងផ្ទះរបស់ម្ចាស់ពិធីការ បន់ស្រន់បួងសួងសុំវិស្វេទេវៈ និងវិញ្ញាណក្ខន្ធអ្នកស្លាប់ទៅ ដើម្បីឱ្យមកសណ្ឋិតក្នុងពិធី និងការប្រទានព្រះអគ្គី ដល់ព្រះសោមៈយមៈ និងព្រះអគ្និ។ មន្តគាថា ដែលគេត្រូវប្រើ បើមិនទាំងអស់ក៏ហាក់ដូចជាយ៉ាងហោចភាគច្រើន ត្រូវគេដកចេញពីមៃ ត្រាយនីសំហិតា។ ផ្នែកនេះបង្ហាញថាសឹងតែគ្មានការស្របគ្នានឹងតម្រាមនុ-ស្រ្មិតិ លើកលែងតែនៅក្នុងសិក្ខាវិន័យ ដែលគេដឹងថាក៏បានមកពីធម៌-សូត្រដ៏ទៃទៀត ដែលបញ្ញត្តិពីការទទួលជប់លៀងភ្ញៀវពីរនាក់នៅក្នុងពិធី ដោយកិត្តិយសទេពតា និងភ្ញៀវបីនាក់ នៅពេលបូជាដល់វិញ្ញាណក្ខន្ធឬភ្ញៀវម្នាក់ ក្នុងឱកាសផ្សេងទៀតព្រមទាំងតាមចំនួននិងទេពតាប្រទានអគ្គី នៅមុនពេលចាប់ផ្តើមស្រាទ្ធៈ (មនុ ជំពូក៣ លេខ១២៣, ២១១)។ ប៉ុន្តែកណ្ឌទី២ ដែលមានការពិពណ៌នាពីពិធីស្រាទ្ធៈ ផ្តើមដោយកំណាព្យពីរបី កំណាព្យទី១សឹងតែមានន័យត្រង់ (សំស្ក្រឹត) ដូចគ្នា នឹងតម្រាមនុ ជំពូក៣ លេខ២៧៤។ ភាពខុសគ្នាដ៏សំខាន់តែម្យ៉ាងគត់ គឺថា នៅចុងបញ្ចប់ពាក្យ "នៅក្នុងរដូវវស្សា និងក្នុងមាគ៌ា(ទាំងអស់)" យកពីតម្រាមនុ "ពេលដែលស្រមោលដំរី ជះទៅខាងកើត"។ គេត្រូវកត់សម្គាល់ថា សូម្បីវិស្ណុ ជំពូក៧៨ លេខ៥២-៥៣ និងវសិស្ថៈ ជំពូក១១ លេខ៤០ មានឃ្លាដែលមានអ្នកសូត្រធម៌ ឧទ្ទិសព្រលឹងវិញ្ញាណក្ខន្ធដូចគ្នាក្តី ក៏ការប្រើពាក្យពេចន៍របស់តម្រាពីរនេះ ខុសគ្នាច្រើនពីពាក្យរបស់ស្រាទ្ធកល្បៈ និង មនុ-ស្រ្មិតិ។ កំណាព្យទី២ មានភាពដូចគ្នាតិចតួចនឹងមនុ កាព្យលេខ២០២ ពីព្រោះកំណាព្យនេះប្រកាសថា ទឹកដែលផ្តល់ថ្វាយក្នុង

ភាជន៍មាស ប្រាក់ឬឧត្តម្បរៈ "គ្មានថ្ងៃសាបសូន្យទេ"។ ចំណែកពាក្យសម្រាយខាងក្រោម មានចំណុចដូចគ្នាខ្លះនឹងសិក្ខាវិន័យរបស់មនុ។ គួរឱ្យចម្លែកណាស់ ផ្នែកនេះរៀបរាប់ថា គេត្រូវជូននំដល់អ្នកចែកឋាន បន្ទាប់ពីភ្ញៀវទាំងឡាយបានទទួលទានអាហាររួចរាល់។ នេះជាទំនៀមទម្លាប់ដែលតម្រាមនុ ជំពូក៣ លេខ២៦១ មាននិយាយ"ខ្លះ"ដែរ។ ផ្នែកនេះខុសគ្នាពីស្លោក(..(សំស្រ្កឹត)...) មួយចំនួន តែចំណុចក្រោយដូចគ្នាសឹងទាំងអស់នឹងតម្រាមនុ ជំពូក៣ លេខ២៨៣។ ចំណុចខុសគ្នាចម្បង គឺថា នៅបន្ទាត់ទី១ ពាក្យស្រាទ្ធ "សំដៅដល់ស្រាទ្ធៈ" គឺជំនួសឱ្យស្នាត្វា "បន្ទាប់ការងូតទឹករបស់គាត់"។ អត្ថបទសមាហិតាទី២ "ដោយផ្តោត ចិត្ត" ជំនួសទ្វិគោត្តមៈ "ពាក្យព្រាហ្មណ៍" គេឃើញមាននៅក្នុងគម្ពីរមនុ នៅភាគខាងត្បូង។ ផ្នែកបន្ទាប់ ដែលគ្មានលេខសម្គាល់ពេញជាកណ្ឌទី ៣ទេ ប៉ុន្តែជាចំគ្នា ជាអភ្យុទយៈ ឬវ្រិទ្ធិ ស្រាទ្ធៈ ជាពិធីឧទ្ទិសដល់អ្នកស្លាប់ ដែលគេត្រូវផ្តល់ឱកាសរីករាយគ្រប់យ៉ាងដូចជាពិធីអបអរថ្ងៃកំណើតរបស់កូនប្រុស អាពាហ៍ពិពាហ៍ជាដើម(..(សំស្រ្កឹត)...)។ល។ តាមតម្រាមនុ លើកឡើងពីស្រាទ្ធៈនេះច្រើនប្រភេទ មានតែនៅក្នុងជំពូក៣ កាព្យលេខ ២៥៤ ខ្លឹមសារនៃកណ្ឌនេះ មិនខុស ពី*ស្មិតិ* ទេ។ ប៉ុន្តែក្នុងចំណោមស្លោកជាច្រើននៃកណ្ឌនេះ ឃ្លាមួយមានពាក្យពេចន៍ដូចគ្នានឹងមនុជំពូក៩លេខ១៨៦ ក(..(សំស្រ្កឹត) ...)។ ផ្នែកទី៤ និងផ្នែកចុងក្រោយនៃកល្បៈ ដែលបង្ហាញជាបរិសិស្តៈ ជាសេចក្តីបន្ថែម មានវិធានបន្ថែមស្តីពីពេលវេលា ដែលគេអាចធ្វើពិធីស្រាទ្ធៈ ជារបៀបដែលធានាដល់ការបួងសួងពិសេស ហើយអ្នកដែលចូលរួមនៅក្នុងឱកាសបែបនេះ។ ផ្នែកនេះ ជាពិសេសមានឃ្លាកាព្យចំនួន ៧(A....សំស្រ្កឹត...។ នៅក្នុងកំណាព្យពាក់ព័ន្ធនៃតម្រាមនុ, មេធ. និងគោ. អាន...ជំនួសកុលូកៈ។ ឃ្លាទី៥ និងទី៦ ត្រូវអ្នក ចម្លង ខុសកន្លែង។) ដូចគ្នា ឬសឹងតែដូចគ្នានឹងវគ្គមនុ-ស្មិតិជំពូក ៣ លេខ ៨២, ១២៥-១២៦, ១៤៥, ១៨៥ និង ១៨៦ រីឯកំណាព្យមួយទៀតដែលបង្រៀនថា ពួកព្រាហ្មណ៍ដែលគេអញ្ជើញចូលរួមនិងម្ចាស់ពិធីយញ្ញត្រូវរក្សាភាពបរិសុទ្ធ "ពីព្រោះវិញ្ញាណក្ខន្ធរបស់អ្នកស្លាប់នៅជាមួយពួកគេ(...(សំស្រ្កឹត)...)"ស្របគ្នានឹងតម្រាមនុ ជំពូក៣ លេខ១៨៩។ ស្លោកពីរក្នុងចំណោមប្រាំពីរដែលទាក់ទងនឹងមនុ ជំពូក៣ លេខ១២៥-១២៦ ក៏មាននៅក្នុងវសិស្ថៈ និងពោធាយនៈធម៌សាស្រ្តៈ។ ស្លោកដទៃទៀតគ្មានសញ្ញានៅក្នុងសូត្របុរាណទេ។

កំណត់សម្គាល់ទាំងអស់នេះ សបញ្ជាក់ថា មានវៈស្រាទ្ធកល្បៈ ក៏ដូចជាសំណេរដៃជាច្រើនរបស់សាលាវេទដែរ មានស្នាដៃជាច្រើនដែលទំនងជាត្រូវនិពន្ធក្នុងសម័យកាលផ្សេងគ្នាជាបន្តបន្ទាប់។ សូម្បីអភិប្រាយទាំងមូល ទំនងជាកើតក្រោយគ្រីហ្យសូត្រៈ និងត្រូវគេបន្ថែម ដើម្បីបន្ថែមសិក្ខាវិន័យខ្លីៗ ស្តីពីពិធីឧទ្ទិស។ ប៉ុន្តែទោះបីមានការអនុញ្ញាតទាំងនេះក៏ដោយ ក៏ការពិតដែលថា វាមានកំណាព្យជាច្រើនផ្នែក ឬទាំងមូល ស្របគ្នានឹងតម្រាមនុ-ស្មិតិ រក្សាបានសារៈសំខាន់របស់ខ្លួនសម្រាប់ចំណុចដែលកំពុងពិចារណា។ ប្រសិនបើអ្នកគាំទ្រការអប់រំរបស់មានវៈយល់ថា ចាំបាច់ត្រូវរៀបចំបទអភិ-ប្រាយស្តីពីប្រធានបទ ដូចជាស្រាទ្ធៈ ការពិតគេផ្អែកលើមូលដ្ឋាននៃការទម្លាប់ប្រើប្រាស់ និងការប្រៀនប្រដៅរបស់សាលាខ្លួន។ ដូច្នេះគេអាចសន្មតថា ឃ្លាកាព្យ ដែលគេដាក់បញ្ចូលនៅក្នុងស្នាដៃក្រោយៗ ហើយគេមិនគួរមិនជឿថា ឃ្លាកាព្យទាំងឡាយអាចមាននៅក្នុងស្នាដៃសំណេរមួយរបស់ខ្លួនទេ។ ជាង

នេះទៀត ដោយសារតម្រាមនុ-ស្រ្មិតិ ផ្អែកលើមានវៈ ធម៌សូត្រ ហើយក្រោយមកបានកើតចេញពីកំណាព្យជាច្រើន ជាការបកស្រាយដ៏សាមញ្ញបំផុតអំពីភាពត្រូវគ្នាខ្លះៗ រវាងស្រាទ្ធ កល្បៈ និងស្រ្មិតិ គឺថា កាព្យទាំងពីរនេះផ្អែកលើប្រភពតែមួយ គឺមានវៈធម៌សូត្រ។ ប្រសិនបើដូច្នោះមែនកំណាព្យ ក្រោយត្រូវតែជាប្រភពគួរឱ្យទុកចិត្តបានរបស់មានវៈ និងជាកម្មសិទ្ធិពិសេសរបស់ពួកគេ។ សូម្បីចំណងទាក់ទងជាច្រើនក្នុងអំណះអំណាងជាបន្តបន្ទាប់ ត្រូវតែមានសម្មតិកម្មគួរឱ្យស្តាយថា ខ្ញុំហាក់ដូចជាពិសេសបើគិតពីរបកគំហើញបញ្ជាក់ខាងលើរបស់សាស្រ្តាចារ្យ Jolly និងបណ្ឌិត von Schroder ស្តីពីទំនាក់ទំនងគម្ពីររបស់សាលាកាថកៈ ជាមួយនឹងគម្ពីររបស់មៃត្រាយនិយៈមានវៈ និងរបស់វិស្ណុ-ស្រ្មិតិជាមួយនឹងមនុ-ស្រ្មិតិ គូសបញ្ជាក់យ៉ាងរឹងមាំថា សម្មតិកម្មរបស់សាស្រ្តាចារ្យ Max Muller ចំណុចនេះជាការឧបមាដ៏ប៉ិនប្រសប់មួយ។

ជារួម ខ្ញុំអាចវែកញែកបានថា ព្រឹត្តិការណ៍ពីរទៀត ដែលជាការស្របគ្នាមួយរវាងមៃត្រាយនៈព្រាហ្មណោបរិស័ទ និងមនុ-ស្រ្មិតិ ព្រមទាំងការនិយម ដែលស្នាដៃក្រោយមានច្រើននៅឥណ្ឌាភាគខាងជើងប៉ែកខាងលិច តាមការពិពណ៌នារបស់ប្រទេសនានា ដែលមានទំនៀមទម្លាប់បរិសុទ្ធរបស់ពួកអារ្យ៉ន ក៏អាចបង្ហាញទំនាក់ទំនងតម្រាមនុ-ស្រ្មិតិ និងប្រភពដើមរបស់វាជាមួយនឹងសាលាមានវៈ។ នៅក្នុងគម្ពីរឧបនិស័ទ ជំពូក៦ លេខ៣៧ យើងឃើញសម្រង់ ជាសុភាសិតដែលគេស្គាល់ជាទូទៅ ជាពាក្យកាព្យ ដែលមាននៅក្នុងតម្រាមនុ ជំពូក៣ កាព្យលេខ៧៦។ កំណាព្យពីរទៀត តម្រាមនុ ជំពូក៦ លេខ៧៦-៧៧ មានសារជាតុស្របគ្នាមៃត្រ. ឧប. ជំពូក៣ កាព្យលេខ៤(គម្ពីរពិសិដ្ឋរបស់បូព៌ា លេខ ១៥ ទំព័រ ២៩៨ កំណត់សម្គាល់ ១។) និងសេចក្តីខ្លះទៀតនៃ តម្រាមនុ ស្តីពីអាត្ម័ន និងលទ្ធផលនៃគុណ ឬគុណសម្បត្តិនានា មានចំណុចស្របគ្នាច្រើននឹងលទ្ធិ ដែលប្រៀនប្រដៅក្នុងគម្ពីរឧបនិស័ទ(មើលចំណុចខាងក្រោម, ទំព័រ lxxiii) ។ តាមការពិនិត្យពិច័យយ៉ាងយកចិត្តទុកដាក់ ការប្រដូចទាំងអស់នេះ យ៉ាងណាក៏ដោយ មិនមានសារៈសំខាន់អ្វីច្រើនទេ។ ដូចគ្នានឹងទស្សនៈគំនិតដែលត្រូវបង្ហាញក្នុងមនុ ជំពូក ៣ លេខ ៧៦ ទំនងជាមានសញ្ញានៅក្នុងវគ្គវេទ ដែលស្រង់នៅក្នុងវសិស្ថៈ ធម៌សូត្រៈ។ ការប្រៀបធៀបតួអង្គមនុស្ស ទៅនឹងការស្នាក់នៅមិនបរិសុទ្ធ (មនុ ជំពូក៦ លេខ៧៦-៧៧) ក៏មានផងដែរនៅក្នុងស្នាដៃតាមបែបពុទ្ធសាសនា(គម្ពីរធម្មបទ លេខ ១៤៧-១៥០, Johanntgen, រាជកិច្ចស្តីពីមនុ ទំព័រ ៩៣) ។ គោលលទ្ធិទស្សនវិជ្ជាសំខាន់ៗ ពាក់ព័ន្ធទីបំផុតជាផ្នែកមួយនៃតម្រាមនុ-ស្រ្មិតិ ដែលទំនងជាមិនមានអាយុកាលចំណាស់ទេ(មើលខាងក្រោម ទំព័រ lxix) ហើយសាលាទស្សនវិជ្ជាជាច្រើនបានប្រកាន់យក។ បើនិយាយពីសេចក្តីនៅក្នុងជំពូកទី២ នៃគម្ពីរមនុ ដែលឧទ្ទិសដល់វត្ថុសក្តិសិទ្ធិនៅតាមតំបន់នានារវាងទ្រិសទ្វតី និងសរស្វតី និងរវាងទន្លេយមុនា និងគង្គា តាមការពិចារណា(ការដកស្រង់ទាំងស្រុង ទំព័រ ១០៩-១១០) របស់បណ្ឌិត Johanntgen អាចបញ្ជាក់បានថា ទីតាំងសាលា ដែលបង្កើតមានវៈ ធម៌សូត្រៈស្ថិតនៅតំបន់ទាំងនោះ។ ប្រសិនបើមានការជាក់ច្បាស់វាស៊ីគ្នានឹងហេតុការណ៍ ដែលគេបានដឹងទីតាំងដើមរបស់មានវៈ។ ចំណុចក្រោយនេះជានិកាយខាងជើងឆៀងខាងលិច និងពង្រីកខ្លួនពីជ្រលងភ្នំ មយូរា រហូតដល់គុតរដ្ឋ តាមការអះអាងរបស់មហានវៈ(គម្ពីរពិសិដ្ឋបូព៌ា ទំព័រ xxxi និង L, Von Schroder, Maitrayani Samb. លេខ ១ ទំព័រ xxiv-xxviii។ សាលាមានវៈ នៅតែមានអត្ថិភាពនៅសតវត្សក្រោយមកទៀត និងនៅ

ខណ្ឌទេសៈ។) ។ ជាអកុសលទោះជាយ៉ាងណាក៏ដោយ ធម៌-សូត្ររបស់ វសិស្ឋៈ និងពោធាយនៈ មាន សេចក្ដីដូចគ្នាសឹងតែទាំងស្រុង ដូចមនុ ហេតុនេះកំណាព្យក្រោយនេះទំនងជាគ្មានន័យអ្វីក្រៅពីថា មានវៈ ដូចគ្នានឹងសាលាវេទជាច្រើនទៀត ចាត់ទុកឥណ្ឌាខាងជើងប៉ែកវិន្ធ្យៈ និងជាពិសេសតំបន់ដែល នៅតាមដងទន្លេពិសិដ្ឋ ជាលំនៅដ្ឋានពិតប្រាកដរបស់ពួកព្រាហ្មណ៍ និងភាពបរិសុទ្ធរបស់អារ្យ៉ន។

## II

ចំណែកឯការពិភាក្សាខាងដើមបានបង្ហាញថា មានវៈធម៌-សូត្ររបស់យើង ផ្អែកលើមានវៈ ធម៌សូត្រ ដែលទំនងជាកម្មសិទ្ធិផ្ដាច់មុខរបស់សាលាមៃត្រាយនៈមានវៈ យើងពេលនេះត្រូវពិចារណា ចំណោទបញ្ហាខ្លះ ពាក់ព័ន្ធនឹងការផ្លាស់ប្ដូរតម្រាសូត្រៈដើមនៅមូលដ្ឋាន ទៅជាគម្ពីរច្បាប់ស្ដីពីស្វាមីភក្តិ របស់ពួកអារ្យ៉ន ហើយដែលពួកគេទទួលស្គាល់ជាទូទៅ។ បញ្ហាដែលពេលនេះគេបានដោះស្រាយ ហើយ ឬយ៉ាងហោចណាស់គេចង់ដោះស្រាយ គឺមានដូចតទៅ៖ ១.តើមានព្រឹត្តិការណ៍អ្វីដែលនាំឱ្យ មានការចងក្រងមានវៈធម៌សាស្ត្រៈជាទូទៅជំនួសសំណេរដែរបស់សាលាវេទទៅវិញ? ២.ហេតុអ្វីក៏ មានជំហរមួយដ៏លេចធ្លោសម្រាប់*ស្ម្រិតិ* ដែលយកតាមលំនាំថ្មីដូចនេះ?។ ៣.តើការផ្លាស់ប្ដូរនោះ មាន ផលប៉ះពាល់យ៉ាងណា? និង ៤.តើវាទំនងជាកើតឡើងនៅពេលណា?។

ថ្វីបើគ្មានព័ត៌មានប្រវត្តិសាស្ត្រទាំងស្រុង និងគ្មានប្រពៃណីដ៏គួរឱ្យទុកចិត្ត ដើម្បីបញ្ជាក់ឱ្យ បានក្បោះក្បាយទាំងស្រុងក្នុងការឆ្លើយសំណួរទី១ក៏ដោយ ក៏ខ្ញុំគិតថាគេមិនអាចទទួលយកមូល ហេតុ ទូទៅ ដែលនាំឱ្យមានការបង្កើតថ្នាក់សិក្សា*ស្ម្រិតិ* ទី២បន្ទាប់ពីមានវៈធម៌សាស្ត្រៈដែរ(ស្ដីពីថ្នាក់សិក្សាផ្សេងៗ នៃស្ម្រិតិទី២ សូមមើល West និង Buhler, ទស្សនាវដ្ដី Digest ទំព័រ ៣២ បោះពុម្ពលើកទី៣) ។ ប្រយោគនេះ សម្រាប់ខ្ញុំ គឺជាការបង្កើតសាលាច្បាប់ពិសេស ដែលឯករាជ្យដាច់ពីសាខាវេទណាមួយ និងដែលបាន ជំនួសករណៈវេទ រហូតដល់មានការបង្រៀនច្បាប់ពិសិដ្ឋផង។ សក្ខីកម្មបង្ហាញច្បាស់ថា សាលាវេទ ដំបូងមានលក្ខណៈជាប្រព័ន្ធ និងមានវិទ្យាសាស្ត្រចំនួន៦ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយ នឹង វេទ ត្រូវគេហៅថាជាអង្គឬអវយវៈរបស់វា ជាក់ស្ដែងហាក់ដូចជាគ្មានសម្ភារៈសម្រាប់មុខវិជ្ជា នីមួយៗ ហើយវិធីសាស្ត្របង្រៀន មានភាពប្រសើរឡើង មានបញ្ហាជាច្រើន ដែលគេត្រូវសិក្សា និងការពិបាកឱ្យ សាលាវេទនានាទទួលបានឋានៈ ខ្ពស់ជាមជ្ឈមណ្ឌលសម្រាប់ជីវិតបញ្ញវន្តរបស់ពួកអារ្យ៉ន ហើយ បណ្ដាលឱ្យមានការបង្កើតសាលាវិទ្យាសាស្ត្រថ្មីៗ ដែលមានការកំណត់ការបង្រៀន មានមុខវិជ្ជារៀន តឹងរ៉ឹង និងដ៏ឆ្លាតវៃ។ នៅតាមសាលាវេទ ចំណេះដឹងត្រឹមត្រូវ និងពិតប្រាកដនៃអត្ថបទពិសិដ្ឋ ការពិត គឺជាមុខវិជ្ជាទី១។ ដើម្បីទទួលបានចំណេះដឹងនោះ សិស្សានុសិស្សត្រូវសិក្សាមិនត្រឹមតែអត្ថបទ សំហិតានៃមន្ត្រគាថា និងព្រាហ្មណៈប៉ុណ្ណោះទេ តែថែមទាំងបទៈក្រម និងទំនងជាបាឋៈពិបាកៗ ឬការ សូត្រឱ្យចាំមាត់ផង។ កិច្ចការនេះពិតជាត្រូវការពេលវេលាច្រើនហើយត្រូវសិក្សាឱ្យគ្រប់ទាំង១២វគ្គ ដែលមានរយៈពេលបួនខែកន្លះ ឬប្រាំខែកន្លះ ដែលស្ម្រិតិ កំណត់ពេលមធ្យមសម្រាប់ការសិក្សា ដើម្បី ទទួលបានចំណេះដឹងវេទមួយ(មើលគម្ពីរមនុ ជំពូក ៣ លេខ ១ និងជំពូក ៤ លេខ ៩៥ ព្រមទាំងវគ្គផ្សេងៗ ដែល មានសម្រង់ក្នុងកំណត់សម្គាល់)។ ដរាបណាដែលអង្គ មានអភិប្រាយសាមញ្ញខ្លីៗនោះ គេអាចងាយចងចាំ

វាបាន និងគ្រប់គ្រងបានខ្លឹមសាររបស់វាក្នុង១២វគ្គដែលមានរយៈពេល១៤ទៅ១៦សប្តាហ៍ពីខែបុស្ស (Pausha) ដល់ខែវិសាខ(Vaisakha)(មើលមនុ ជំពូក៤ លេខ ៩៨ និងវគ្គដូចគ្នា ដែលស្រង់ក្នុងកំណត់សម្គាល់។ យោងតាមស្មិតិមួយចំនួន គេអាចសិក្សាអង្គ នៅពេលណាមួយក្នុងវគ្គសិក្សា (វគ. ជំពូក ១៣ លេខ ៧)) ។ ប៉ុន្តែពេលដែល កល្បៈ ឬក្បួនវិធី តែម្យ៉ាង បានចម្រើនក្លាយជាសូត្ររបស់ពោធាយនីយៈ និងអបស្តបពិយៈ ចំណែកឯវេយ្យាករណ៍ដែលវិវត្តក្លាយជាប្រព័ន្ធមួយ ដូចគ្នានឹងប្រព័ន្ធបាណិនិ វាជាបញ្ហាដែលមិនអាចទៅរួចទេ សម្រាប់មនុស្សម្នាក់ ដើម្បីចងចាំ និងយល់ឱ្យបានទាំងស្រុងនូវអត្ថបទពិសិដ្ឋទាំងនេះ រួមទាំងមុខវិជ្ជាបន្ថែមនានា ពិសេសដោយសារចំនួនមុខវិជ្ជាបន្ថែមនេះ មានចំនួនច្រើនតាំងពីដើមមកតាមការបន្ថែមរបស់ន្យាយៈ ឬបូរវាមីមំសា ជាសិល្បៈបកស្រាយសិក្ខាវិន័យវេទ(ស្តីពីអត្ថិភាពដើមនៃបូរវា មីមំសា សូមមើលគម្ពីរពិសិដ្ឋបូព៌ាប្រទេស លេខ ២ ទំព័រ xxvii និងកាព្យស្តីពីគោលការណ៍បរិស័ទ ដែលគេស្រង់នៅក្នុង ពោធ. ជំពូក ១ លេខ១, ៨ និង វស. ជំពូក ៣ លេខ ២០) ។ សមាជិកសាលាវេទ ពេលនោះត្រូវប្រឈមមុខនឹងជម្រើសពីរ។ ពួកគេក៏អាចខិតខំទន្ទេញឱ្យចាំអត្ថបទវេទទាំងអស់នៅក្នុងសាខារបស់វា រួមទាំងអង្គ ដោយចង់ដឹងនូវអ្វីដែលពួកគេបានសិក្សាក៏បាន ឬពួកគេត្រូវកម្រិតចំនួនបទអភិប្រាយ ដែលពួកគេបានសិក្សាចាំមាត់ ចំណែកឯពួកគេត្រូវតែចេះឱ្យអស់នូវអ្វីដែលពួកគេបានសិក្សា។ អ្នកទាំងឡាយណាដែលប្រកាន់យកការសិក្សាតាមទម្រង់ដើម ក្លាយជាបណ្ណាល័យរស់ តែមិនអាចមានប្រយោជន៍ ជាក់ស្តែងក្នុងការសិក្សារបស់ពួកគេទេ។ អ្នកណាដែលប្រកាន់យកជម្រើសទី២ អាចក្លាយជាកំពូលអ្នកប្រាជ្ញ នៅក្នុងវិទ្យាសាស្ត្រក្បួនតម្រាពិធីយញ្ញ វេយ្យាករណ៍ ច្បាប់ ឬតារាសាស្ត្រ ប៉ុន្តែពួកគេមិនអាចប្រកួតប្រជែងជាមួយអ្នកដទៃ ដែលចេះចាំស្ទាត់មាត់អំពីគម្ពីរពិសិដ្ឋ។ ដូច្នេះ សាលាវេទ លែងក្លាយជាមជ្ឈមណ្ឌល សម្រាប់បញ្ញវន្ត និងត្រូវជំនួសដោយសាលាវិទ្យាសាស្ត្រពិសេសៗ។

ស្ថានភាពសិក្សាបច្ចុប្បន្ននៅប្រទេសឥណ្ឌាបង្ហាញច្បាស់ថា ការប្រែប្រួលនេះពិតជាកើតមានដូចបានរៀបរាប់ ហើយមានសេចក្តីបញ្ជាក់ផ្ទាល់នៅក្នុងគម្ពីរអត្ថបទបុរាណ ព្រមទាំងលក្ខខណ្ឌរបស់ពួកគេ អនុញ្ញាតឱ្យយើងដឹងបានពីដំណាក់កាលផ្សេងៗ ដែលមានការពាក់ព័ន្ធ។ តំណាងពិតប្រាកដសម័យទំនើបនូវករណៈបុរាណគឺជាវៃទិ ជាមនុស្សដែលភាគច្រើនមានសប្បុរធម៌លះបង់នូវ ថាមពលរបស់ខ្លួនទាំងស្រុង ដើម្បីមានចំណេះដឹងរត់មាត់ ចាំអស់អត្ថបទពិសិដ្ឋ និងអង្គរបស់សាខា ព្រមទាំងស្នាដៃមួយចំនួនទៀត ដែលមានទំនាក់ទំនងទោះតិច ឬច្រើនជាមួយនឹងវេទ។ ពួកវៃទិត្រឹមត្រូវបំផុតនៃសាលាអាស្វលាយនៈ ចេះដឹងឫគវេទ ស្របតាមសំហិតា បទៈ ក្រម គាថានិងយនៈ បាថៈ ឯតរេយៈព្រាហ្មណ៍ និងប្រាតិសាខ្យ និងសិក្សា នីរុត្តរបស់យាស្កៈ, វេយ្យាករណ៍របស់បាណីនិ, ប្រតិទិនវេទ ឬយោតិសៈ ជាអភិប្រាយពាក្យកាព្យ ដែលហៅថាខន្ទៈ, ធម៌សាស្ត្រៈរបស់យាញ្ញវល្ក្យៈ ជាផ្នែកនៃមហាភារតៈ និងសូត្រទស្សនវិជ្ជារបស់កាណាទៈ,គាមិនី និង ពាទរាយនៈ។ ក្នុងន័យប្រហាក់ប្រហែលគ្នានេះដែរ វៃទិរបស់សាលាយាគូ សាមន និង អថារ៉ៃ អាចសូត្រស្នាដៃទាំងមូលតាមសាខានីមួយៗយ៉ាងល្អ ឬមិនសូវល្អ ព្រមទាំគម្ពីរមិនមែនវេទ(ស្តីពីភាពចាំបាច់សម្រាប់វៃទិ សិក្សាសៀវភៅក្រៅពីវេទ សូមមើល វស. ជំពូក ២៧ កាព្យលេខ៦) មួយចំនួនទៀត។ ប៉ុន្តែការរំពឹងរង់ចាំការបកស្រាយសេចក្តីរបស់ពួកគេ គឺជារឿងឥតប្រយោជន៍។ វៃទិ មិនមែនជាអ្នកអាជីព ដែលអាចធ្វើការបូជាធំស្របតាមស្រោតសូត្រ បកស្រាយ

ប្រព័ន្ធស្មុគស្មាញនៃវេយ្យាករណ៍បាណីនិ ឬសម្រេចពីចំណុចពិបាកៗនៃច្បាប់ស្របតាមធម៌-សូត្រ ឬស្ម្រិតិទី២ ដែលគាត់ចេះចាំរត់មាត់នោះទេ។ ក្នុងគោលបំណងនេះ គេត្រូវទៅសិក្សាថ្នាក់ខុសៗគ្នា។ ការធ្វើពិធីស្រោតដ៏ធំ ស្ថិតក្នុងដៃរបស់ស្រោតិយៈ ឬស្រោតី ដែលប្រជុំដោយចេះចាំចំណេះដឹងល្អិតល្អន់នូវអត្ថបទពិសិដ្ឋនៃសាខា យល់អត្ថន័យទាំងស្រុងនៃ ស្រោត-សូត្រ និងមានក្រិយា ឬសំណេរដៃ ដែលរៀបរាប់ពីប្រយោគៈ។ ស្រោតិ ព្រមទាំងជំនួយការ ការងាររបស់គាត់ ដែលគេហៅថាយញ្ញិកៈ ឬ ភត្តគី ដែលចេះដឹងគ្រឹហ្យសូត្រ និងរៀបចំពិធីតាមទម្លាប់អ្នកស្រុក ទំនងជាតំណាងឱ្យសាលាវេទទាំងពីរ។ យ៉ាងណាក៏ដោយ ពួកគេគ្មានចំណេះគ្រប់អង្គ ធម៌គ្រប់យ៉ាងទេ តែពួកគេពេញចិត្តនឹងការសិក្សាពីកល្បៈឬផ្នែករបស់វា ហើយទំនងជាសិក្ខា(ស្តីពីស្ថានភាពបច្ចុប្បន្ននៃសាលាវេទ និងការសិក្សាវេទ សូមមើល Haug, និយាយពីព្រាហ្មណ៍ និងការស្លាប់របស់ព្រាហ្មណ៍, ទំព័រ៤៧ និងឯកសារផ្ញើចផ្ទង់របស់ R.G. បណ្ឌាការ, "វេទនៅឥណ្ឌា" (ឥណ. បូ. ជំពូក៣ លេខ ១៣២)។ ផ្តើម ពីការសង្កេតផ្ទាល់ខ្លួន ខ្ញុំអាចបន្ថែមលើសេចក្តីរបស់សាស្ត្រាចារ្យបណ្ឌាការថា វេទិនៃសត្តយាគុវេទ ក៏ត្រូវគេឃើញនៅឥណ្ឌា ភាគខាងជើង។ ខ្ញុំក៏បានឮពីវេទិរបស់សាមៈវេទ ក្នុងចំណោមបវតិយៈនៅបញ្ចាប និងអថវវៈវេទ នៅភ្នាក់ងារកេណ្ដាលរបស់ឥណ្ឌា។) ។ ចំណេះដឹងពិតប្រាកដក្នុងអង្គធម៌ដែលមានធរមានដទៃទៀត វេយ្យាករណ៍ ច្បាប់ និងតារាសាស្ត្រ គេឃើញមានតែនៅក្នុងចំណោមបណ្ឌិត ដែលមានភារកិច្ចសិក្សាពីវេទ តាមរយៈការខិតខំសូត្រ ទន្ទេញចាំមាត់ពីផ្នែកសំខាន់ៗខ្លះដូចជាចម្រៀងបាវមានីនៅក្នុងឫគវេទឬសាតទ្រិយៈនៃយាគុវេទ ឬតាមការកំណត់ការសិក្សាត្រឹមកំណាព្យពីរបី ដែលមាននៅក្នុងព្រាហ្មយញ្ញ និងសំធ្យាវន្ទនៈ (បណ្ឌាការ, សម្រង់ដដែល, ទំព័រកំណត់សម្គាល់ ១៣២)។ គោលបំណងចម្បងរបស់ពួកគេ គឺដើម្បីបន្សុតកម្មមុខវិជ្ជាពិសេសមួយ ឬច្រើន តាមដែលពួកគេអាចសិក្សាបាន ដោយមិនចាំបាច់ចូលសាលាវេទណាមួយ។ ហេតុនេះ សូម្បីបណ្ឌិតដែលលះបង់ខ្លួនដើម្បីច្បាប់ពិសិដ្ឋអាចជាសិស្សសាលាវេទរបស់ពោធ្យាយនៈ ឬអាស្តមពៈក៏ដោយ ក៏គេមិនចាត់ទុកធម៌សូត្ររបស់ពោធ្យាយនៈ ឬអាស្តមពៈ ជាចំណុចចាប់ផ្តើមនៃការសិក្សារបស់ខ្លួនដែរ។ ផ្ទុយទៅវិញ ជាញឹកញយគឺថា គេគ្មានចំណេះដឹងពីធម៌-សូត្រពីសាលាទេ លើកលែងតែវគ្គខ្លះដែលមានសម្រង់នៅក្នុងបទអត្ថាធិប្បាយ និងការពន្យល់ខ្លះៗប៉ុណ្ណោះ។ ប្រសិនបើគេអានស្នាដៃទាំងមូល គេនឹងយកចិត្តទុកដាក់តែនៅពេលណាមានសម្ដីជាច្រើនចេញពីមាត់របស់បណ្ឌិតបុរាណ។ គេនឹងមិនឱ្យតម្លៃវាជាប្រភពមួយខ្ពស់ជាង ស្ម្រិតិដទៃទេ ប៉ុន្តែបកស្រាយវាទៅតាមសិក្ខាវិន័យនៃធម៌សូត្រទី២ នៃគម្ពីរមនុ ឬ យញ្ញវល្ក្យៈ។ ការបង្ហាញដ៏ត្រឹមត្រូវក្នុងរឿងនេះ មាននៅក្នុងការបកស្រាយពោជាយនៈរបស់សាយនៈ-មាធវៈ នៅក្នុងវ្យវហារមាធវៈរបស់គាត់ ជាអភិប្រាយស្តីពីច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ដោយអធិប្បាយបន្ថែមលើស្ម្រិតិរបស់បរាសរៈ។ សូម្បីគាត់ប្រាប់យើងដោយផ្ទាល់ នៅក្នុងសេចក្តីផ្តើមរបស់បរាសរ-ស្ម្រិតិ-វ្យាខ្យា (បរាសរ-ស្ម្រិតិ-វ្យាខ្យា, ទំព័រ ៣, វគ្គ ៧ (បោះពុម្ពនៅកាល់គុតា)) ក៏ដោយ ថាគាត់ជាសិស្សរបស់សាលាពោជាយនៈហើយសូម្បីគាត់បានសរសេរសេចក្តីអធិប្បាយស្តីពីសូត្ររបស់ពោជាយនៈក៏ដោយក៏គាត់ពឹងផ្អែកលើច្បាប់ស្នងមរតកមិនមែនពឹងលើធម៌ សូត្ររបស់ ពោជាយនៈទេ តែពឹងលើការអធិប្បាយយញ្ញវល្ក្យៈរបស់វិញ្ញានេស្វរៈ។ គាត់ដកស្រង់ពោជាយនៈតែបីកន្លែងប៉ុណ្ណោះ(Bwnell,ទាយវិភាគៈ,ទំព័រ ៩, ៣៩, ៤១)

។ ដរាបណាមានការគិតគូរពីច្បាប់ សាយណៈយល់ពីទ្រឹស្តីនៃច្បាប់ពិសេស នៅក្នុងសម័យនិងប្រទេសរបស់គាត់ ដោយមិនចាំបាច់យោងនឹងមេរៀនរបស់ករណៈវេទរបស់គាត់ទេ។

ការធ្លាក់ចុះនៃករណៈវេទនេះ តាមរយៈសាលាពិសេស ដែលសាបព្រោះវិទ្យាសាស្ត្រដ៏សំខាន់បំផុតនៃអង្គធម៌ មិនមាននៅសម័យទំនើបទេ។ បើក្រឡេកមើលអតីតកាលដ៏យូរលង់ មុនពេលចាប់ផ្តើមសម័យប្រវត្តិសាស្ត្ររបស់ឥណ្ឌា យើងឃើញមានការចង្អុលបង្ហាញជាច្រើននៅក្នុងគម្ពីរបុរាណដែលញ៉ាំងឱ្យយើងធ្វើសេចក្តីសន្និដ្ឋាននេះ។ ដូច្នេះ នីរុក្តៈរបស់យាស្កៈ ជាស្នាដៃមួយដែលជាស្នាដៃដ៏បរមបុរាណស្រង់វៃយាករណៈ អ្នកវេយ្យាករណ៍ និងអ្នកសិក្សាអត្ថបទនីរុក្តៈ នរុត្តិសាស្ត្រ និងពួកយញ្ញិកៈ អ្នកធ្វើពិធីសាសនាដាក់ចេញនូវទស្សនៈយោបល់ជំទាស់របស់ពួកគេ(នីរុក្តៈ ជំពូក១ លេខ១២, ជំពូក៧ លេខ ៤ និងជំពូក១៣ លេខ៩) ។ ប្រសិនបើសាលាទាំងអស់នេះ មានបញ្ហាពាក់ព័ន្ធនឹងអត្ថបទសិក្សាឬវេយ្យាករណ៍ គេមានគំនិតថា ប្រធានបទដែលពួកគេបានបង្រៀន លែងត្រូវអប់រំដោយមនុស្សដដែលដូចសាខាជំនួយនៃចំណេះដឹងវេទ ប៉ុន្តែថាសាខានីមួយៗបានទទួលការអភិវឌ្ឍដោយឡែកពីគ្នានៅក្នុងសាលាពិសេសមួយក្នុងនាមជាវិទ្យាសាស្ត្រឯករាជ្យ។ ស្ថានភាពជាក់ស្តែងដែលមាននៅក្នុងអង្គធម៌ផ្សេងៗស្របគ្នាទាំងស្រុងនឹងករណៈនេះតាំងពីដើមឡើយមកម្ល៉េះ។ ពីព្រោះគ្មានសាលាណាមួយក្នុងចំណោមសាលាទាំងអស់នោះ នៅសល់សៀវភៅ សិក្សាមានសំណេរដៃរបស់ខ្លួនផ្ទាល់ស្តីពីវេយ្យាករណ៍ ឬតារាសាស្ត្រទេ។ អស្តាធ្យាយីរបស់បាណិនិ ជាតំណាងតែមួយគត់នៃថ្នាក់សិក្សាវ្យាករណៈអង្គធម៌ ហើយមានការទទួលស្គាល់ដូចគ្នាពីសំណាក់អ្នកគាំទ្រវេទទាំងអស់។ ប៉ុន្តែវេយ្យាករណ៍ ដែលបង្រៀនដោយបាណិនិ លែងមានសំណៅដើមសរសេរដោយដៃស្តីពីវេទវិទ្យា វាជាវិទ្យាសាស្ត្រឯករាជ្យដែលដាក់ចេញនូវច្បាប់ អាចអនុវត្តបានចំពោះភាសា សំស្ក្រឹតទាំងស្រុង និងចាត់ទុកជាអ្វី ដែលយើងពេលនេះហៅថាសំស្ក្រឹតបែបបុរាណ ជាស្តង់ដារសម្រាប់ ការនិយាយរបស់ពួកអារ្យ៉ន ជាទម្រង់វេទដែលខុសពីធម្មតា។ តាមការដកស្រង់ជាច្រើនរបស់គ្រូអាចារ្យ សាលាពីដើមៗ និងសាលាពីមុនៗ នៅក្នុងស្នាដៃផ្ទាល់របស់បាណិនិ ក្នុងប្រាតិសាខ្យៈ និងក្នុងនិរុត្តរបស់យាស្កៈ បង្ហាញច្បាស់ពីស្នាដៃបុរាណជាច្រើនដែលមានតាំងពីមុនអស្តាធ្យាយី ហើយស្នាដៃក្រោយនេះ ជាការរីកចម្រើនចុងក្រោយក្នុងការអភិវឌ្ឍវិទ្យាសាស្ត្រដ៏យូរលង់(មើល Max Muller,ប្រវត្តិអក្សរសាស្ត្រសំស្ក្រឹតបុរាណ ទំព័រ១៥០ ដែលភាគច្រើននិយាយយ៉ាងត្រឹមត្រូវថា ពួកហិណ្ឌូ មិនគួរតែនិយាយបាណិន្យាទ្យា វៃយាករណាទេ តែគួរនិយាយពីបាណិន្យន្តៈ) ។ ស្នាដៃដែលបាត់បង់ ទៅយ៉ាងច្រើន ទំនងជាបានចាត់ទុកជាជំហរទស្សនៈ ដូចគ្នានឹងស្នាដៃរបស់បាណិនិដែរ។ ប៉ុន្តែគេអាចសន្និដ្ឋានដោយសមហេតុផលថា ស្នាដៃដំបូងបំផុត ក្នុងចំណោមស្នាដៃទាំងឡាយដែលបានបង្រៀនយ៉ាងច្រើន ឬផ្តាច់មុខផង ចំពោះសិក្ខាវិន័យ ដែលជាអត្ថបទវេទ សិក្សាដោយករណៈជាច្រើន ដែលជាស្នាដៃរបស់អ្នកនិពន្ធ។ ដំណាក់កាលស្រាវជ្រាវវេយ្យាករណ៍នេះ យ៉ាងណាក្តី ក៏ជាប់ពាក់ព័ន្ធនឹងអតីតកាលដ៏យូរលង់។ វេយ្យាករណ៍ឥណ្ឌា ដូចយើងបានដឹងពីដំបូងហើយ គឺលែងស្របនឹងបំណងប្រាថ្នាទាំងមូលនៃការសិក្សាពីវេទហើយ ប៉ុន្តែស្នាដៃ សូម្បីនៅតែនិយាយពីវេទក៏ដោយ ក៏មានគោលបំណងផ្ទាល់របស់វាដែរ។

វិទ្យាសាស្ត្រស្តីពីនក្ខត្តយោគ នៅតែមានទំនាក់ទំនងច្រើនជាមួយនឹងសាលាវេទ។ សញ្ញាណទាំងអស់ដែលជាអង្គធម៌ពិតប្រាកដ មាននៅក្នុងអភិប្រាយតិចតួច ដែលផ្តល់ឈ្មោះគោត្រទិសៈ ដែលនៅមានសល់បន្តិចបន្តួចតាមការពិនិត្យសំណេរដៃចំនួនពីរផ្សេងគ្នា មួយជារបស់ឫគវេទ និងមួយជារបស់យគុរវេទ។ ស្នាដៃដទៃទាំងអស់ពាក់ព័ន្ធប្រធានបទនេះ សូម្បីជាស្នាដៃបុរាណដូចជាគារគី សំហិតាព្រមទាំងវសិស្ត សំហិតា និងសិទ្ធាន្ត បង្ហាញថាគ្មានជាប់ពាក់ព័ន្ធនឹងវេទ ឬសាលាវេទទេ លើកលែងតែថា ឋានៈអ្នកនិពន្ធត្រូវគេផ្តល់ហេតុផលថាជា ឫសី ឬអ្នកជំនាន់ក្រោយ នៃគ្រួសាររបស់ឫសី។ បើនិយាយពីច្បាប់ពិសិដ្ឋ ការពិតដែលថាមែកជាងចុងក្រោយនៃសាខាវេទ ដូចជាអស្តាមពីយៈ និងហៃរណ្យកេសៈមានធម៌សូត្រជាដើម សបញ្ជាក់ថា មុខវិជ្ជានេះបានបង្កើតជាផ្នែកនៃមេរៀន នៅក្នុងសាលាវេទតាំងពីយូរមកហើយ។ ប៉ុន្តែអ្នកវេយ្យាករណ៍ដ៏បុរាណបំផុតម្នាក់ នៅសម័យប្រវត្តិសាស្ត្រឥណ្ឌាបតញ្ជលិបង្ហាញតម្រុយថា នៅសម័យរបស់គាត់ធម៌ត្រូវគេបង្រៀនមិនមែនត្រឹមតែនៅក្នុងសាលាវេទទេ តែថែមទាំងមានបង្រៀននៅតាមសាលាជំនាញនានាផង។ អាចនិយាយបានក្នុងន័យម្យ៉ាងថា គាត់សំដៅដល់ធម៌-សូត្រ(មើលកំណត់សម្គាល់ស្តីពីបាណិនិ ជំពូក ១ លេខ ១, ៤៧) ម្យ៉ាងទៀតគាត់បង្រៀនពីការបង្កើតពាក្យជំនាញ *ធម៌វិទ្យា* ដែលបញ្ជាក់ពីអ្នកដែលសិក្សា ឬចេះធម៌វិទ្យា ជាវិទ្យាសាស្ត្រច្បាប់ពិសិដ្ឋ(មើលកំណត់សម្គាល់ស្តីពីបាណិនិ ជំពូក ៤ លេខ ២, ៦០ (ភាគ ២ ទំព័រ២៤៨ Kielhorn)។ ខ្ញុំយល់ស្របតាមបណ្ឌិត Kielhorn ដែលចារឹកពាក្យ "វិទ្យាការញ្ញក្សត្រ ធម៌ត្រិបុរវា" ជាសម្តីរបស់បតញ្ជលិ មិនមែនជាវាត្តិរបស់កាត្យាយនៈ ទេ។) ។ ទំនងជាថាពាក្យ *ធម៌សាស្ត្រ* ជាគោលការណ៍ច្បាប់ពិសិដ្ឋ ដែលពេលខ្លះមាននៅក្នុងភាស្យ(មើលកាត្យាយនវាត្តិកៈ៣៩ ស្តីពីបាណិនិជំពូក១លេខ៣, ៦៤ និងក្រោយមកជា សម្តីរបស់បតញ្ជលិ (Kielhorn,Mah. លេខ ១ ទំព័រ ២៤១)) របស់គាត់ ក៏អាចសំដៅដល់តម្រាសរសេរដោយដៃសម្រាប់សិក្សាតាមសាលាជំនាញ ដែលខុសគ្នាពីធម៌-សូត្រ។ ប៉ុន្តែមិនអាចសន្និដ្ឋានទាំងស្រុងថា គេក៏អាចហៅធម៌-សូត្រ ជាធម៌សាស្ត្របាន ពីព្រោះវាប្រៀនប្រដៅច្បាប់ពិសិដ្ឋ។ ប្រសិនបើយើងងាកទៅមើលសម័យដើម យើងនឹងបានឃើញមានសាលាច្បាប់ឯកទេស ដែលសឱ្យឃើញច្បាស់នៅក្នុងធម៌-សូត្រមួយចំនួនដែរ។ សេចក្តីដែលបញ្ជាក់ច្បាស់បំផុតត្រង់ចំណុចនេះ គឺជាវគ្គទាំងឡាយ ដែលរៀបរាប់ការបង្កើតបរិស័ទ ឬសភាប្រជុំអ្នកមានចំណេះដឹង ដែលមានសិទ្ធិសម្រេច រឿងក្តីពាក់ព័ន្ធនឹងចំណោទច្បាប់។ តាមដែលយើងបានអាន វសិស្ត ជំពូក៣ លេខ២០ និងពោធាយនៈ ជំពូក១ លេខ១, ៨ ថា "មនុស្ស៤នាក់ ដែលម្នាក់ៗសុទ្ធតែចេះគម្ពីរវេទមួយ ក្នុងចំណោមគម្ពីរទាំងបួន ជាសិស្សរបស់មិមំសា ជាអ្នកដែលចេះអង្គធម៌ ជាអ្នកចេះសូត្រ(ស្នាដៃស្តីពី)ច្បាប់ពិសិដ្ឋ (ធម៌បាឋកៈ) និងព្រាហ្មណ៍៣នាក់ ដែលមានឋានៈ(៣ផ្សេងគ្នា) (បង្កើត)ជាសភាមួយ ដែលមានសមាជិកយ៉ាងហោច១០នាក់(មើលសៀវភៅមនុជំពូក ១២, លេខ ៣ និងចំណុចខាងលើទំព័រxxv) ។" ដូច្នេះគេហៅអ្នកសូត្រ ឬអ្នកបង្រៀនច្បាប់ពិសិដ្ឋ ថាជាអ្នកចេះអង្គធម៌។ ដូចស្នាដៃពីរ ដែលមានពាក្យកាព្យ គឺជាធម៌សូត្រដែលជាផ្នែកកល្បៈនៃអង្គ សបញ្ជាក់ច្បាស់ថា អ្នកបង្រៀនច្បាប់ពិសិដ្ឋ ពិតជាមនុស្សម្នាក់ ដែលបូជាខ្លួនទាំងស្រុងដើម្បីសិក្សាមុខវិជ្ជានោះ និងចេះច្រើនលើសពីធម៌-សូត្រមួយទៅទៀត។ ហេតុនេះគេអាចយល់ស្របថា សាលាច្បាប់ឯកទេស ពិតជាកើតមាននៅពេលដែលគេតាក់តែងធម៌-សូត្រទាំងពីរនេះ(សារសំខាន់នៃសម្រង់សម្តីនៅតែមានឥទ្ធិពលខ្លាំង

បើយើងប្រៀបធៀបសិក្ខាវិន័យរបស់គោតម (ជំពូក ២៨ លេខ ៤៩) ដែលមានភាពផ្សេងគ្នាច្រើនថា "វគ្គនោះប្រកាសថា សភា (បរិស័ទ ត្រូវតែមាន)យ៉ាងហោចណាស់១០នាក់ (សមាជិក) គឺ ៤នាក់ដែលបានសិក្សាចេះចប់គម្ពីរវេទទាំង ៤ មានបីនាក់មានឋានៈបី ដែលចេះគោលច្បាប់បីផ្សេងគ្នា។" ព្រះគោតមមានពុទ្ធដីកាថា គ្មាននរណាមួយបូជាចំពោះការសិក្សាច្បាប់ពិសិដ្ឋទេ។ ព្រះអង្គត្រូវការមនុស្សបីនាក់ ដែលចេះ ព្រះធម៌សូត្របីផ្សេងគ្នា។ ព្រះអង្គ និងអាបស្តមពៈ ដឹងច្បាស់ទាំងស្រុងអំពីជំពូកផ្សេងៗនៃតម្រា សិក្ខាវិន័យរបស់ព្រះអង្គ ហើយជាពិសេសសំដៅដល់សិស្សគណរបស់ទ្រង់ (គោត. ជំពូក ១៦ លេខ ៤៩, អាប. ជំពូក ១ លេខ ៣, ជំពូក ២ លេខ ៣៨) ក្នុងករណីពាក់ព័ន្ធនឹងការបង្រៀននៃសាលាដទៃទៀត ដែលមានពាក្យទូទៅ*ស្មិតិ* ជាប្រភពដើមគួរឱ្យទុកចិត្តបាន ដោយហេតុថាគ្រូ ជាសិស្ថៈកាន់វិន័យចាស់ (គោត.ជំពូក ១ លេខ៣; អាប.ជំពូក ១ លេខ ១, ២; វស.ជំពូក ១ លេខ ៤; ពោធ ជំពូក ១ លេខ១, ៣)) ។ គេក៏អាចនិយាយបានថា សាលាឯកទេសនេះបានយកចិត្តទុកដាក់តាក់តែងមេរៀនរបស់ខ្លួនផ្ទាល់ដែលខុសពីធម៌-សូត្រ។ ដើម្បីគាំទ្រទស្សនៈ យោបល់នេះ គេអាចលើកសំអាងការដកស្រង់កំណាព្យនៅពោធាយនៈជំពូក២ លេខ៤,១៤-១៥បាន ព្រោះវាហាក់ដូចជាយកចេញពីមួយស្នាដៃនៅក្នុងអនុស្តុភៈ-ស្លោក(គម្ពីរពិសិដ្ឋបូព៌ា លេខ ១៤ ទំព័រxli) ។ សូម្បីការបញ្ជាក់របស់អត្ថបទពោធាយនៈមិនច្បាស់លាស់មិនអាចឱ្យយើងមានសំអាងរឹងមាំលើសេចក្តីនេះក៏ដោយ ក៏គេមិនអាចបដិសេធបានថា ការរៀបចំបង្កើតសាលាឯកទេស ត្រូវតែដើរតាមការតាក់តែងសំណេរមេរៀន សម្រាប់ការប្រើប្រាស់របស់ខ្លួនក្នុងរយៈពេលដ៏ខ្លី។ ការពិតបញ្ជាក់ច្បាស់ថា ស្ថាបនិករបស់សាលា មាននៅក្នុងធម៌-សូត្រ បើគិតជាចំនួនបើវិនិច្ឆ័យតាមសម្រង់សម្ពីពិតជាមានសម្ភារៈជាច្រើន ដែលគេអាចពឹងផ្អែកលើសម្រាប់ការអង្កេតរបស់ខ្លួន។ ប៉ុន្តែការវិនិច្ឆ័យមុខវិជ្ជាវិទ្យាសាស្ត្រមួយដោយទស្សនៈគំនិតថ្មី ជាការលើកទឹកចិត្តដល់ការបង្កើតសំណេរស្នាដៃថ្មី ហើយសាលាឯកទេសច្បាប់ក៏មានហេតុផលផ្សេងៗទៀតសម្រាប់រៀបចំវគ្គសិក្សាឱ្យបានល្អ។ សំណេរច្បាប់ដើមជាធម៌សូត្រ ជាទូទៅមានប្រធានបទច្រើន និយាយអំពីករណីយកិច្ចផ្នែកសីលធម៌របស់ពួកអារ្យ៉ន ការរៀបចំសិក្ខាវិន័យរបស់ខ្លួនជារឿយៗគ្មានលក្ខណៈជាប្រព័ន្ធទេ ហើយការប្រតិបត្តិនីតិវិធីច្បាប់ ច្បាប់រដ្ឋប្បវេណីនិងព្រហ្មទណ្ឌ ដោយលើកលែងចំណាងជើងតែមួយ គឺទាយកវិភាគៈ ពេលគឺច្បាប់ស្នងមរតក និងការចែកមរតក ដែលមិនសមរម្យទាល់តែសោះ។ ចំពោះចំណងជើងផ្សេងទៀត ធម៌-សូត្រ មិនបានផ្តល់អ្វីក្រៅពីតម្រុយបន្តិចបន្តួច ដែលចង់បង្ហាញពីគោលការណ៍ទូទៅទេ ប៉ុន្តែវាមិនមានលក្ខណៈជាប្រព័ន្ធទេហើយតែងតែបង្ហាញពីចំណុចខ្វះខាតដ៏គួរឱ្យខ្មាស់អៀន ។ ផ្តើមចេញពីជំហរទស្សនៈរបស់សាលាវេទ ការពិចារណាបញ្ហាទាំងអស់នេះឱ្យកាន់តែលម្អិត និងមានរបៀបរៀបរយ ការពិតមិនជាប់ពាក់ព័ន្ធគ្នាទេ ពីព្រោះគោលបំណងចម្បងរបស់វា ត្រូវចង្អុលបង្ហាញផ្លូវដើម្បីទទួលបានគុណធម៌ផ្នែកព្រលឹងវិញ្ញាណ និងដើម្បីការពារសិស្សគណរបស់ខ្លួន កុំឱ្យប្រព្រឹត្តបាបកម្ម។ សូម្បីសមាជិករបស់សាលាខ្លះ អាចត្រូវគេរំលឹក និងត្រូវកំណត់វាសនាជាក់ស្តែងសម្រាប់ជាតិក្រោយ ឱ្យក្លាយជាអ្នកច្បាប់ពិតប្រាកដ ជាធម្មាធិការីពេលគឺជាអ្នកប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រិយ៍ និងជាប្រធានឬចៅក្រម ដើម្បីដោះស្រាយបញ្ហាច្បាប់រវាងមនុស្សនិងមនុស្សតាមគោលការណ៍ទូទៅខ្លះ ដែលពួកគេបានសិក្សា ក្នុងអំឡុងពេលវគ្គសិក្សារបស់ពួកគេផ្តល់តាមតម្រូវការរបស់ខ្លួន។ សម្រាប់សេចក្តីលម្អិត គឺអាស្រ័យទៅតាមច្បាប់ទំនៀមទម្លាប់ ដែលតាមការបង្ហាញរបស់ធម៌-សូត្រ មានតាំងពីសម័យបុរាណ ព្រមទាំងមានអំណាចកាន់តែខ្លាំងនៅប្រទេសឥណ្ឌា ជាងនៅសម័យ

យើង។ បើពេលច្បាប់ពិសិដ្ឋក្លាយជាមុខវិជ្ជាវិទ្យាសាស្ត្រ ដោយឡែកមួយ ដែលមនុស្សត្រូវលះបង់ថាមពលទាំងអស់ ឬការព្យាយាមបំផុត ករណីនេះមានលក្ខណៈផ្សេងគ្នា។ យ៉ាងណាក៏ដោយអ្នកឯកទេសមានជំនឿច្រើនអំពីសារៈសំខាន់ ដ៏ធំធេងនៃផ្នែកសីលធម៌របស់ធម្មក្តី ក៏ពួកគេមិនអាចបិទភ្នែកមើលមិនឃើញចំណុចខ្វះខាតនៃគម្ពីរអត្ថបទដើម ហើយពួកគេចាំបាច់ត្រូវរកដំណោះស្រាយ។ ដើម្បីឱ្យមានប្រសិទ្ធភាពចំពោះបញ្ហានេះ មានការរៀបចំវគ្គសិក្សាពីរសម្រាប់ពួកគេ។ ពួកគេក៏រៀបចំស្នាដៃដែលមានស្រាប់ពីមុនឡើងវិញក៏បាន ឬតាក់តែងស្នាដៃថ្មីទាំងស្រុងក៏បាន។ តាមនិន្នាការសាកលដែលអាចសង្កេតមើលបានតាមរយៈអក្សរសាស្ត្រពិសិដ្ឋទាំងអស់របស់ឥណ្ឌា ពួកគេមានចំណូលចិត្តចំពោះស្នាដៃពីមុន ហើយលទ្ធផលនៃស្នាដៃរបស់ពួកគេគឺជាថ្នាក់សិក្សាស្ម្រិតិទីពីរជាតំណាងដែល នៅរស់រានជីវិតដ៏សំខាន់ ដែលធម៌សាស្ត្រៈរបស់ព្រះមនុ និងយាជ្ញវល្ក្យៈ។ ស្នាដៃទាំងអស់នេះ លាតត្រដាងពីប្រភពដើមរបស់វា តាមរយៈកំណត់សម្គាល់ដូចខាងក្រោម។ ស្នាដៃទាំងឡាយ ជាកម្មសិទ្ធិផ្តាច់មុខរបស់សាលាច្បាប់ឯកទេស ហើយវាមានប្រធានបទច្បាប់ជាប្រព័ន្ធ និងកាន់តែពេញលេញជាងមុន ទន្ទឹមនឹងនេះគេក៏សង្កេតឃើញមានតម្រុយនៃការតាក់ តែងពីដើមទោះច្បាស់លាស់ក្តីឬមិនច្បាស់លាស់ក្តី ក៏មានពាក់ព័ន្ធនឹងសាលាវេទដែរ។ តម្រុយទាំងនេះ មិនពាក់ព័ន្ធនឹងសញ្ញានៃឥទ្ធិពលនិកាយសាសនា ឬសញ្ញានៃការតាក់តែងឡើងដូចជា ទស្សនាវដ្តីសម័យក្រោយជាច្រើនតាមព្រះរាជបញ្ញា។ ទីបំផុត សញ្ញាទាំងឡាយបង្ហាញពីសេចក្តីសម្គាល់ពិតប្រាកដជាសៀវភៅរបស់សាលារៀន។ ប្រសិនបើយើងពិនិត្យមើលតម្រាមនុ-ស្ម្រិតិ របស់យើង ដោយពិនិត្យពិច្ច័យចំណុចទាំងអស់នេះ យើងអាចបង្ហាញទំនាក់ទំនងនៃស្នាដៃវេទសម័យដើមខាងលើ និងការពិតថា ចាប់ពីពេលដែលយើងមានព័ត៌មានស្តីពីអត្ថិភាពរបស់វា តាមការរក្សារបស់បណ្ឌិតដែលធ្វើពលិកម្មយ៉ាងខ្លាំង ចំពោះការសិក្សាច្បាប់គឺជាសិស្សរបស់ធម៌សាស្ត្រៈ។ នោះជាការសិក្សាប្រធានបទច្បាប់ដែលមានលក្ខណៈជាប្រព័ន្ធ និងកាន់តែពេញលេញឡើងជាងធម៌-សូត្រ ជាពិសេស ខិតខំបង្កើនល្បឿនកត់សម្គាល់ខ្លីៗចំពោះប្រធានបទនានា នៅក្នុងស្នាដៃក្រោយៗយ៉ាងច្បាស់លាស់។ នេះជាការបញ្ជាក់ច្បាស់ពីភាពឆ្លាតវៃថា ការរៀបរាប់ពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ រួមទាំងរដ្ឋបាលយុត្តិធម៌ និងច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ស៊ីកន្លែងអស់មួយភាគបីនៃស្នាដៃទាំងមូល។ ចំពោះជំពូកទី ៧-៩ មានកំណាព្យមិនតិចជាង ៩៨២ វគ្គ រីឯចំនួនវគ្គសរុប មាន ២ ៦៨៥វគ្គ(អំពីអត្រាដូចគ្នា ៣៦៧:១០០៩ គេឃើញមាននៅក្នុងស្ម្រិតិរបស់យាជ្ញវល្ក្យៈ) ។ គ្មានគម្ពីរច្បាប់បុរាណណា មានអត្ថបទលើសពីមួយភាគប្រាំសម្រាប់បញ្ហាដូចនេះទេ(ដូច្នេះនៅក្នុងគោតមិយៈ អត្ថបទ ៧ទំព័រ ក្នុងចំណោម៣៤ គឺសុទ្ធតែនិយាយពីបញ្ហាច្បាប់, នៅក្នុងវាសិស្ថៈ ១២ទំព័រ ក្នុង ចំណោម ៨១, នៅក្នុងអាស្តមពិយៈ មាន ១០ទំព័រក្នុងចំណោម ៩៨ និងក្នុងពោធាយនីយៈ ប្រហែល៧ទំព័រ ក្នុងចំណោម ១១៥។) ។ សេរីភាពរបស់ មនុ-ស្ម្រិតិ រួចផុតទាំងស្រុងពីឥទ្ធិពលសាសនាទាំងអស់។ គឺគ្មានចំណុចណាមួយប្រៀនប្រដៅពីការប្រតិបត្តិរីតិ៍ ដទៃក្រៅពីពិធីរីតិ៍នានា ដែលបានរៀបរាប់នៅក្នុងសំណេរវេទទេ ហើយគ្មានកន្លែងណាមួយបណ្តុះគំនិតពីការគោរពអាទិទេពណាមួយក្នុងនិកាយបូរាណិកផ្តាច់មុខទេ ពីព្រោះយើងឃើញមានការណែនាំ ឧទាហរណ៍ក្នុងវិស្ណុ-ស្ម្រិតិ។ ម្យ៉ាងទៀតគ្មានតម្រុយណាមួយថា វាត្រូវគេសរសេរឡើងតាមព្រះរាជបញ្ញារបស់ព្រះមហាក្សត្រិយ៍ ឬលោកនាយ ក្នុង

បំណាងរក្សាទុកជាកម្រងច្បាប់ពិសិដ្ឋ។ ទីបំផុតសញ្ញាសម្គាល់បញ្ជាក់ពីសៀវភៅរបស់សាលាមួយសម្រាប់អប់រំពួកអារ្យ៉ន់ទាំងអស់ មិនអាចមានកំហុសឆ្គងបានទេ។ គេប្រាប់យើងឱ្យដឹងពីមនុ ជំពូក១ លេខ ១០៣ ថា "ព្រាហ្មណ៍អ្នកសិក្សាត្រូវយកចិត្តទុក ដាក់សិក្សា (គោលការណ៍) ទាំងអស់នេះ ហើយត្រូវអប់រំសិស្សគណរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមគោលការណ៍" ប៉ុន្តែថា "គ្មានអ្នកផ្សេង (ធ្វើរឿងនេះទេ)"។ ការសួរថា តើសិស្សគណដែលមានសិទ្ធិសិក្សាស្នាដៃនេះជានរណា ត្រូវបកស្រាយនៅក្នុងជំពូក២ លេខ១៦។ នៅទីនោះ មាននិយាយថា "អ្នកដែលអនុវត្តវិធី ដោយចាប់ផ្ដើមជាមួយនឹងគាភាធានៈ និងបញ្ចប់ដោយអន្ត្យេស្តិ ត្រូវបំបួសដោយមានការសូត្រតម្រាពិសិដ្ឋមានសិទ្ធិសិក្សាគម្ពីរនេះ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គ្មានអ្នកផ្សេងពីនេះទេ"។ ហេតុនេះពួកព្រាហ្មណ៍ត្រូវបង្រៀនសាស្ត្រា ហើយពួកអារ្យ៉ន់អាចរៀនសាស្ត្រានេះបាន។ វាមានលក្ខណៈស្របគ្នានឹងសៀវភៅសិក្សា ប្រសិនបើផលស្រុតិ ឬការថ្លែងសរសើរដែលបានពីការសិក្សាតម្រាមនុ ជំពូក១២ លេខ១២៦ អះអាងថា មនុស្សកើតពីរដង ដែលអាចសូត្រ "គោលការណ៍តម្រាទាំងអស់នេះ តែងតែមានសច្ចធម៌ក្នុងការប្រព្រឹត្ត និងសម្រេចបានលក្ខខណ្ឌ អ្វីក៏បាន(បន្ទាប់ពីស្លាប់) តាមសេចក្ដីប្រាថ្នា"។ កម្មវត្ថុទី១ ដែលសិស្សអាចទទួលបាន គឺការរីកចម្រើនផ្ទាល់ខ្លួន និងសុភមង្គលទី២ បន្ទាប់ពីការចែកឋានទៅ(ស្រ្មិតិទី២ទៀត ឌ.ទា. តម្រាយាញ្ញវល្ក្យ (ជំពូក ៣ លេខ ៣៣០-៣៣៤) ផ្តល់សេចក្តីលម្អិតកាន់តែច្រើនអំពីការផ្តល់ រង្វាន់ដែលត្រូវទទួលបាន។ ប៉ុន្តែជាសារជាតុ ពួកគេតែងតែយល់ស្របតាមតម្រាមនុ។) ។ ប្រសិនបើយើងទទួលយកសេចក្ដីសន្និដ្ឋាន ដែលមាននៅក្នុងការពិភាក្សាមុនៗថា សាលាច្បាប់ឯកទេស បានបង្កើតផ្នែកស្រ្មិតិទី២ បុរាណបំផុត លើកដំបូង ដោយផ្អែកលើមូលដ្ឋានធម៌-សូត្រពីដើម និងថា សាលាមួយក្នុងចំណោមសាលាទាំងអស់ ដែលយ៉ាងណាក៏ដោយ មិនអាចបញ្ជាក់បន្ថែមទៀតបាន បានប្រែក្លាយមានវៈ ធម៌-សូត្រ ឱ្យទៅជាកំណាព្យស្រ្មិតិរបស់យើង(មតិយោបល់ ដែលខ្ញុំបានបង្រៀនដំបូងនៅក្នុងបទឧទ្ទេសនាមរបស់ខ្ញុំស្ដីពីច្បាប់ហិណ្ឌូបានថ្លែងនៅក្នុងសាកលវិទ្យាល័យ វីយែន ក្នុងរដូវរងា ឆ្នាំ១៨៨១-៨២ ត្រូវបានយល់ព្រមទទួលយកដោយសាស្ត្រាចារ្យ J. Jolly, Tagore Lectures, ទំព័រ ៤១ និងបទឧទ្ទេសនាមទី២ នៅនេះ ទីនោះ ព្រមទាំងទំព័រ ៣៤៧ (ចុងចប់)) យើងក៏ទទួលបានចម្លើយគួរជាទីពេញចិត្តសម្រាប់សំណួរពីរផ្សេងទៀត។ ទី១ គេអាចពន្យល់បានទេថា ហេតុអ្វីស្នាដៃក្រោយនេះ មានទំនាក់ទំនងតិចតួចនឹងលទ្ធិពិសេស និងការប្រើប្រាស់មានវៈ។ បើតាមសាស្ត្រាចារ្យ E.Hopkins យល់ថា(ក្បួនពិចារណារបស់សង្គមបូព៌ាអាមេរិក ខែតុលា ឆ្នាំ១៨៨៣ ទំព័រ xix) អ្នកគាំទ្រសាលាមានវៈវេទ បានធ្វើការកែសម្រួលធម៌-សូត្ររបស់ខ្លួន ពួកគេមិនដែលភ្លេចនិយាយពីពិធីនានា ដូចជាពិធីសម្រាប់ចាប់ផ្ដើមការសិក្សាផ្នែកពិសេសនៃសំហិតា(មើលខាងលើ ទំព័រxxxix កំណត់ចំណាំលេខ ៥) យោងតាមគ្រឹហ្យសូត្ររបស់ខ្លួន ហើយជាងនេះទៅទៀត ពួកគេនឹងឈរសូត្រមន្ត្ររបស់មៃត្រាយណីសាខា។ ជាថ្មីម្ដងទៀត ប្រសិនបើភារកិច្ចនេះក្លាយជាភារកិច្ចរបស់ សមាជិកសាលាវេទផ្សេង យើងគួរតែរកចំណុចខ្លះ ដែលនិយាយពីផលប្រយោជន៍ពិសេសសម្រាប់ពួកគេ។ ការគ្មានសញ្ញាសម្គាល់ជាក់លាក់នៃសាលាវេទ ដែលមានក្នុងមនុ-ស្រ្មិតិ គេអាចបកស្រាយតាមសម្មតិកម្មថា អ្នកដែលមិនចាប់អារម្មណ៍ពីភាពផ្សេងគ្នានៃសំណេរ និងដែលយកចិត្តទុកដាក់ដល់សិក្ខាវិន័យទាំងឡាយ ដែលពួកគេគិតថាសំខាន់សម្រាប់ពួកអារ្យ៉ន់ទាំងអស់។ ទី២ មតិយោបល់ដែលបានបង្ហាញខាងលើ ផ្តល់ចម្លើយចំពោះ

សំណួរហេតុអ្វីតម្រាមនុ-ស្រ្មិតិ ក៏ដូចជាស្នាដៃផ្សេងទៀតរបស់ថ្នាក់សិក្សា សង្កត់ធ្ងន់ពីស្វាមីភ័ក្តិរបស់ពួកហិណ្ឌូទាំងអស់។ ប្រាកដណាស់ថា គ្រប់សាលា ច្បាប់ ឯកទេស ពិតជាអះអាងថា បើការងាររបស់សាលាមិនឥតប្រយោជន៍ក្នុងការប្រើលទ្ធិទូទៅ និងសិក្ខា វិន័យរបស់ខ្លួនសម្រាប់មនុស្សជាតិទាំងអស់។ ប្រសិនបើពេលនេះ យើងងាកទៅមើលចំណុចទី២ ហេតុផលអ្វីបណ្តាលឱ្យមានសាលាច្បាប់ឯកទេស ដើម្បីជ្រើសរើសមានវៈធម៌សូត្រដ៏ត្រឹមត្រូវ ក្នុងចំណោមស្នាដៃប្រហាក់ប្រហែលជាច្រើន សម្រាប់ជាមូលដ្ឋាននៃការសិក្សារបស់ពួកគេ និងដើម្បីតាក់តែងឡើងវិញ ហើយចម្លើយមិនជាពិបាករកទេ។ ហេតុផលសម្រាប់ការជ្រើសរើសនេះ និងជាការគោរពដ៏ខ្ពង់ខ្ពស់ចំពោះមនុ-ស្រ្មិតិ និងហិណ្ឌូ ការពិតតាមទេវកថាតាំងដើមរៀងរាបមក បានប្រមូលផ្តុំឈ្មោះ តម្រាមនុ និងនៅសម័យរីកចម្រើន មានការអភិវឌ្ឍកាន់តែច្រើនឡើង និងបង្កើតបានជាប្រព័ន្ធមួយ។

នៅក្នុងទេវវិទ្យាវេទ មនុ ឬមនុស្ស ដូចដែលគេឱ្យឈ្មោះនៅក្នុងឫគ-វេទ គឺជាវីរជនក្នុងរឿងកថានៃអំបូរមនុស្ស និងដោយសារធម្មជាតិរបស់ទ្រង់មានលក្ខណៈជាអាទិទេពផង និងជាមនុស្សផង។ ក្នុងនាមជាអាទិទេព គេចាត់ទុកព្រះអង្គជាបុត្ររបស់អាទិត្យា វិវស្វត និងរបស់"ស្ត្រីសម្បុរល្អ" ជាភរិយារបស់វិស្វត ឈ្មោះសរណ្យូ ដែលជាឋានរបស់នាង(វាលខិល្យ ជំពូក ៤ លេខ ១, អថាវ វេទ ជំពូក ៨ លេខ១០, ២៤, សត. ព្រាហ្ម.ជំពូក១៣ លេខ ៤, ៣,៣ និង និរុកត្ត ជំពូក១២ លេខ ១០) ឬជាបងប្អូនរបស់ព្រះស្វយំភូ ជាព្រាហ្មណ៍ដែល មានអត្ថិភាពដោយខ្លួនឯង(មើលស្លោកវេទ ដែលដកស្រង់ដោយនិរុត្តជំពូក ៣ លេខ ៤ និយាយពីអ្វីដែលនឹងលម្អិតច្រើននៅខាងក្រោម។ អំណះអំណាងទី៣ តម្រាវ្យាលខិយ ជំពូក៣ លេខ ១, ធ្វើឱ្យទ្រង់ក្លាយជាបុត្ររបស់សំវរនេះ ដែលដូចគ្នានឹងឫសី មាននិយាយនៅក្នុងឫស. ជំពូក៥ លេខ ៣៣, ១០) ។ តាមគុណសម្បត្តិដូចគ្នានេះ ព្រះអង្គ ត្រូវគេអធិដ្ឋាននៅក្នុងពិធីយញ្ញ ជាប្រគាបតិ ជាព្រះជាម្ចាស់របស់សត្វលោក(តៃ.សំហ. ជំពូក៣ លេខ ២, ៨, ១; ជំពូក៤ លេខ ១,៩,១, វាគ.សំហ.ជំពូក ១១ លេខ ៦៦, មៃត្រ.សំហ. ជំពូក ២ លេខ ៧,៧) និង ក្នុងចម្រៀងសរសេរព្រះអាទិទេពរបស់កុត្យាយនៈ ដែលត្រូវស្រង់នៅក្នុងមៃត្រាយន ព្រាហ្មណោបនិស័ទ (លេខ ៥, ចំណុច ១) ព្រះអង្គត្រូវគេស្គាល់ថា ជាព្រាហ្មណ៍ ជាអាត្ម័នដ៏កំពូល(សៀវភៅនេះ អាន *អណាំ* អាហារ។ ប៉ុន្តែសំណេររបស់សាស្ត្រចារ្យ Max Muller សរសេរបានត្រឹមត្រូវ គឺ មនុ (មើលS.B.E.XV,ទំព័រ ៣០៣ សម្គាល់)។ សំណេររបស់ខ្ញុំសរសេរមនុ។) ។ នៅក្នុងទេវកថាដែលចងក្រងជាប្រព័ន្ធរបស់នីរុក្ត គាត់ហាក់ដូចជា ទេពតាមួយ ដែលរស់នៅឰដ៏ឋានសួគ៌(នីរុក្ត ជំពូក ១២ លេខ ៣៣-៣៤) ។ លក្ខណៈសម្បត្តិជាមនុស្សរបស់ទ្រង់បានស្តែងចេញជាញឹកញយ។ គេដាក់ឈ្មោះទ្រង់នៅក្នុងគម្ពីរ ឫគ-វេទ ជាមួយនឹងបណ្ឌិតដទៃទៀតតាំងពីបុរាណយូរលង់(គម្ពីរ RV. ជំពូក ១ លេខ ៨០, ១៦) ។ គម្ពីរតៃត្តិរិយ សំហិតា បានចាត់ទ្រង់ជាព្រះបិតារបស់គ្រួសារមួយ ដែលបែងចែកទ្រព្យសម្បត្តិឱ្យបុត្ររបស់ទ្រង់(គម្ពីរ តៃត្ត. សំហ. ជំពូក ៣លេខ១,៩,៤)ហើយសតបថ-ព្រាហ្មណ៍បង្ហាញចំណងជើងមួយស្តីពីទ្រង់ ដោយមានសេចក្តីសបញ្ជាក់ថា ទ្រង់មានទម្លាប់ធ្វើការប្រចាំថ្ងៃដូចមនុស្សធម្មតា(សត.ព្រា. ជំពូក ១ លេខ ៨, ១; គម្ពីរពិសិដ្ឋបូព៌ា លេខ ១២ទំព័រ២១៦ "នៅពេលព្រឹក ពួកគេយកទឹកថ្វាយ*មនុ* ដើម្បីជម្រះពោលគឺពួកគេយកទឹក សម្រាប់ឱ្យទ្រង់លាងដៃ"។) ។

ឋានៈរបស់*មនុ* ជាបុព្វបុរសរបស់មនុស្សជាតិ តាមធម្មតា មានបង្ហាញក្នុងន័យទូទៅប៉ុណ្ណោះ។ នៅក្នុងគម្ពីរឫគ-វេទ គេហៅទ្រង់ដដែលថា "លោកឪពុកមនុ"(គម្ពីរ RV.ជំពូក ១ លេខ ៨០, ១៦; ជំពូក ១

លេខ ១២៤, ២; ជំពូក ២ លេខ ៣៣,១៣ &c) ។ នៅក្នុងអត្ថបទផ្សេងទៀត យើង ឃើញមានការបញ្ជាក់ជារឿយៗថា "កុលសម្ព័ន្ធ ៥" ឬ "សត្វលោកចាប់កំណើតទាំងអស់នេះ" ឬ "អំបូររបស់មនុស្ស" គឺជាកូនចៅបង្កើតរបស់ទ្រង់(គម្ពីរ RV.ជំពូក ៣ លេខ ២៤, ៣; គម្ពីរ តៃត្ត. សំ. ជំពូក ៣ លេខ ៥,១,៣; ជំពូក ៣ លេខ ៤,២២, ២៧) ។ ប៉ុន្តែនៅក្នុងរឿងនិទានដ៏ល្បីល្បាញស្តីពីទឹកជំនន់ ដែលនិទានដោយសតបថ-ព្រាហ្មណ៍(គម្ពីរពិសិដ្ឋបូព៌ា លេខ ១២ ទំព័រ ២១៦-២១៩) ថា យើងមានលក្ខណៈសក្តិសមនឹងឱ្យទ្រង់បង្កើតពូជពង្សមនុស្ស។ យោងតាមប្រសាសន៍របស់ព្រាហ្មណ៍នោះ *មនុ* តែម្នាក់គត់ ត្រូវបានសង្គ្រោះដោយសារជំបូន្មានរបស់ត្រី ឱ្យរួចផុតពីមហាគ្រោះទឹកជំនន់ ដែលបំផ្លាញសត្វលោកទាំងអស់។ ដោយមានសញ្ចេតនាជាកូនចៅ ទ្រង់បានធ្វើការគោរពបូជា និងកាន់វត្តប្រតិបត្តិយ៉ាងតឹងរ៉ឹង។ ក្នុងអំឡុងពេលនេះ ទ្រង់បានធ្វើពិធីបាក-ពញ្ញ។ ការបូជារបស់ទ្រង់ ខិតខំបង្កើតស្ត្រីមួយរូប ឈ្មោះ *ឥតា* ឬ *ឥឡា* ជាការបង្កើតមនុស្ស តាមរយៈពិធី *ឥតា* និងតាមរយៈការបួងសួង។ សូម្បីមានការបួងសួងពី *មិត្រ* និង *វរុណៈ* ដើម្បីក្លាយជារបស់ពួកគេ នាងបានទទួលស្គាល់ខ្លួននាងថាជាបុត្រីរបស់ *មនុ* និងរស់នៅជាមួយទ្រង់។ ពាក្យ "នៅជាមួយនាង" ព្រាហ្មណ៍ សន្មតដោយពាក្យមិនសូវច្បាស់លាស់ថា "ទ្រង់បានបន្តធ្វើការគោរពបូជា និងកាន់វត្តប្រតិបត្តិតឹងរ៉ឹង។ តាមរយៈនាង ទ្រង់បានបង្កើតពូជនេះឡើង ដែលគេហៅថាពូជ *មនុ*"។ សូម្បីរឿងនិទាននេះ ត្រូវគេនិយាយបញ្ចិតបញ្ចៀងដល់ព្រាហ្មណ៍ម្នាក់ទៀត និងមាននិយាយឡើងវិញនៅក្នុងស្នាដៃសំស្ក្រឹតក្រោយៗក៏ដោយ ក៏មានការគួរឱ្យសង្ស័យថាតើគេមានកំណែដើមសម្រាប់បង្កើតមនុស្សតាមរយៈព្រះមនុឬទេ។ ទំនងជាគេអាចនិយាយបានថា ទេវកថាពីមុនៗសំអាងថា ទ្រង់មិនបានបង្កើតជាលើកទី២ទេ តែជាការបង្កើតលើកទី១ ឬជាការបង្កើតពូជមនុស្ស។

ក្នុងនាមជាបិតារបស់មនុស្សជាតិ ជាធម្មតា គេចាត់ទុកព្រះមនុ ជាស្ថាបនិកសណ្តាប់ធ្នាប់សង្គមនិងសីលធម៌ ជាអ្នកគ្រប់គ្រងមនុស្ស និងជាឫសី ដែលបានទទួលអត្ថបទគម្ពីរពិសិដ្ឋ ជាអ្នក បង្កើតពិធីរីតសម្រាប់ការបូជា និងជាអ្នកនិពន្ធភាសិតច្បាប់។ ហេតុនេះ យើងរកឃើញវគ្គ ដែលបញ្ជាក់ថា ទ្រង់គឺជាព្រះមហាក្សត្រិយ៍(មើលឧទាហរណ៍ សតបថ ព្រាហ្មណ៍ ជំពូក ១៣ លេខ ៤,៣,៣, និង RV. ជំពូក ១ លេខ ១១២, ៨។ ក្នុងវគ្គក្រោយនេះ ជាគុណស័ព្ទ វរជន កំណត់លក្ខណៈព្រះមនុ ជាខត្តិយាបុគ្គល។) ដែលមាននិយាយពីការឡើងគ្រងរាជ្យសម្បត្តិរបស់ទ្រង់ ឬធ្វើឱ្យទ្រង់ក្លាយជាបុព្វការីព្រះមហាក្សត្រ។ ដូច្នេះ មន្ត្រីមឥណ្ឌាសោមា វរុណ យម និងមនុនិងក្នុងចំណោមព្រះមហាក្សត្រិយ៍ គេហៅព្រះសត្យាតៈ ថាជាបុត្រារបស់ព្រះមនុ ចំណែក ឯបុរូរវៈ ជាកូនចៅរបស់បុត្រីព្រះមនុ ឥតា ឬ ឥឡា(RV. ជំពូក ១ លេខ ៣១; ជំពូក ១០ លេខ ៩៥, និង Sat. Br. ជំពូក ១១ លេខ ៥, ១,១។ ក្នុងវគ្គទី១ ខ្ញុំបកស្រាយ *មនវេ* ក្នុងន័យ *មានកាយៈ*។) ។ នៅពេលក្រោយមកទៀត ទស្សនៈគំនិតបុរាណ ដែលចាត់ទុកមនុ ជាស្តេចទី១របស់មនុស្ស និងជាបុព្វបុរសរបស់ព្រះមហាក្សត្រិយ៍ទាំងឡាយ បានមកយកអត្តិភាពរបស់ទ្រង់ជាប្រមុខនៃទេវតា និងសន្តតិវង្សក្នុងប្រវត្តិសាស្ត្រមួយ។ ផ្តើមចេញពីទ្រង់ អ្នកជំនាន់ទី២ *ឥកស្វាកុ* ជាបឋមក្សត្រិយ៍នៃវង្សព្រះសូរិយា និង ព្រះមហាក្សត្រិយ៍ *កលុក្យ* និង *កោឡៈ តាមប្រវត្តិសាស្ត្រ* ហៅព្រះមនុ ជាស្ថាបនិកខ្សែស្រឡាយរបស់ពួកទ្រង់។

គម្ពីរវេទបាននិយាយបញ្ជិតបញ្ចៀងឬសរសេរយ៉ាងច្បាស់ជាញឹកញាប់ថា ព្រះមនុជាអ្នកបង្កើតពិធីបូជា(វីត៏)។ ឫគវេទ មានវគ្គជាច្រើន(សូមមើល Bergaigne, *គម្ពីរសាសនាវេទ* ជំពូក ១ លេខ ៦២-៧០ ដែលខ្ញុំហាក់ដូចជាថា សេចក្ដីដ៏ពិបាកបំផុត ត្រូវបានបកស្រាយយ៉ាងច្បាស់ច្រើននៅក្នុងការបកប្រែរបស់ពួកវេទផ្សេងទៀត ដែលប្រើពាក្យ មនុ ដោយសេរីក្នុងន័យថា មនុស្ស។) ដែលនិយាយពីការបូជារបស់ព្រះមនុ ពីការបូជាព្រះ អគ្គី របស់ទ្រង់ ឬបួងសួងព្រះអាទិទេពទទួលយកតង្វាយបូជារបស់ឫសី ឱ្យដូចជាទ្រង់ទទួលយកការ បូជារបស់មនុ។ សម្ដីអះអាងដូចគ្នានេះ ត្រូវបានលើកឡើងម្ដងទៀតនៅក្នុងគម្ពីរយគុរវេទ(មើលឧទាហរណ៍ *តៃត. សំហ.* ជំពូក ១ លេខ៧, ១, ៣, ជំពូក២ លេខ ៥, ៩, ១, ជំពូក ៣ លេខ ៣,២,១ ជំពូក ៤ លេខ ៤,១០,៥) និង សតបថ ព្រាហ្មណ៍ (លេខ ១,៥, ១-៧) និយាយយ៉ាងច្បាស់ថា "តាមពិត មនុ បានធ្វើពិធីបូជា តាំងពីការចាប់ផ្ដើម ដោយយកត្រាប់តាមការបូជារបស់កូនចៅនេះ (របស់ទ្រង់ពេលនេះ)"។ ដោយបន្ថែមលើការបូជាអគ្គី គេក៏និយាយថា ព្រះមនុ បានបង្កើតស្រាទ្ធ ឬពិធីបូជាសព។ ខ្លឹមសារចម្បង ដែលមាននៅក្នុងចំណុចនេះ ក៏មាននៅក្នុងធម៌សូត្ររបស់អាបស្តមព ជំពូក ២ លេខ ១៨, ១ ដែលនិយាយថា ព្រះអាទិទេពបានយាងទៅឋានសួគ៌ ដើម្បីអបអរជូនពរពិធីបូជាយញ្ញរបស់ពួកគេ ហើយថា ព្រះមនុ ដោយមើលឃើញមនុស្សនៅខាងក្រោយទ្រង់ "បានបង្ហាញពិធីដែលមានប្រើពាក្យស្រាទ្ធ"។ យ៉ាងណាមិញ សេចក្ដីនេះ គេមិនបានលើកយកមកធ្វើជាសេចក្ដីសម្រង់ទេ ទម្រង់រចនាបថរបស់វាបង្ហាញច្បាស់ថា គេបានខ្ចីវាពីព្រាហ្មណ៍ ឬថា វាជាការសង្ខេបនៃរឿងមួយដ៏វែងដែលមាននៅក្នុងស្នាដៃមួយ (បើសាស្ត្រាចារ្យ Max Muller*តើឥណ្ឌាអាចបង្រៀនយើងបានទេ?* ទំព័រ ២៣៤-២៣៥ និង ៣៦៥ គិតថាសេចក្ដីរបស់អាបស្តត ក្បត់មនសិការ នៃដើមកំណើតក្រោយមករបស់ពិធីស្រាទ្ធ។ ខ្ញុំមិនអាចយកតាមលោកស្រាស្ត្រាចារ្យបានទេ។ ខ្ញុំចង់និយាយថា គេអាចបកស្រាយពិសិដ្ឋភាព និងភាពស័ក្ដិសិទ្ធិនៃពិធីយញ្ញបូជាសព និងមូលហេតុ ដែលពួកគេធានាឡើងឋានសួគ៌សម្រាប់អ្នកគោរពបូជា និងដូនតានដែលបានគោរពបូជា។ តាមសេចក្ដីផ្ដើម របស់ព្រាហ្មណ៍នៅក្នុងគម្ពីរវេទ ដែលជាផ្នែកមួយនៃគម្ពីរមនុ ជាបទផ្ដើមសម្រាប់ពិពណ៌នាអំពីយញ្ញពិធីដ៏ច្រើន។ ដោយហេតុថាស្រាទ្ធ គិតគូរពីមនុស្ស ជាពិសេស ជាបិតារបស់មនុស្សជាតិ តំណាងដ៏ត្រឹមត្រូវជាអ្នកបង្កើតមនុស្សជាតិ។) ។ នេះទំនងជារឿងនិទានដែលថា "មនុ បុត្ររបស់ព្រះសូរិយា" មាននៅក្នុងរឿង មហាភារតៈ(មហា. ជំពូក ១២ លេខ ១២១, ២៩) ជាពាក្យស្រាទ្ធវេទ ដែលគេអាចប្រែជា "អាទិទេពស្រាទ្ធ"ក៏បាន ឬប្រសើរជាងនេះទៅទៀតថា "ទ្រង់ជាព្រះអាទិទេពឈ្មោះស្រាទ្ធ ពោលគឺម្ចាស់ពិធីស្រាទ្ធ"ក៏បាន។ ដោយមានទំនាក់ទំនងជិតស្និទ្ធ នឹងឋានៈរបស់ព្រះមនុ ជាអ្នកបង្កើតពិធីយញ្ញ ជារឿងនិទានសម័យបុរាណដូចបានជម្រាបជូនខាងលើ ដែលចាត់ទុកទ្រង់ជាបិតារបស់ *ឥដា* ហើយផ្ដើមចេញពីទស្សនៈគំនិតដដែលនេះ ទំនងជាពង្រីករឿងព្រេងស្ដីពីឧសភរាជ្យរបស់ទ្រង់ ដែលមានសំឡេងអាចបំផ្លាញពួកយក្ស និងនិយាយពីពិធីយញ្ញរបស់ភរិយាទ្រង់ ព្រះនាងមាណាវី(គម្ពីរពិសិដ្ឋបូព៌ាលេខ១២ ទំព័រ២៩-៣០ និងមើលវគ្គនានា និងសេចក្ដីដកស្រង់នៅក្នុងកំណត់សម្គាល់លេខ I) ។

គេពោលសរសើរព្រះមនុ ដោយសារការលាតត្រដាងមន្ត្រ ដូចបានជម្រាបជូនខាងលើ(មើលជំពូក១៦) ក្នុងកំណត់សម្គាល់ស្ដីពីវគ្គនៅក្នុងអត្ថបទ ៣នៃយគុរវេទ និង តន្យា-ព្រាហ្មណ៍។ យ៉ាងណាមិញ ស្នាដៃដ៏ចំណាស់ជាងនេះ គ្មានកន្លែងជាការឧទ្ទិសដល់ទ្រង់ទាំងស្រុងទេ ប៉ុន្តែមានតែកំណាព្យមួយចំនួនតូច ប៉ុណ្ណោះ។ នេះជាករណីដូចគ្នា នៅក្នុងលិបិក្រមនៃសៀវភៅ *ឫសី* ជាគម្ពីរ-ស យគុរវេទ រីឯសាវា នុក្រមនីនៃគម្ពីរឫគវេទ សំអាងលើសូក្តទាំង ៥ ជំពូក ៨ កាព្យលេខ ២៧-៣១ ដើម្បីបញ្ជាក់ពី មនុ វៃវស្វត ព្រមទាំងកាព្យពីរ បីឃ្លា និយាយពីមនុ អាប្សវៈ និងមនុ សំវរណៈ។ សេចក្ដីដ៏គួរឱ្យចាប់

អារម្មណ៍ នៅខាងដើមវគ្គចុងក្រោយនៃគម្ពីរខាន្ទូឃ្យូបនិស័ទ(គម្ពីរពិសិដ្ឋបូព៌ា លេខ ១ ទំព័រ ១៤៤) បញ្ជាក់ឱ្យយើងដឹងថា ព្រាហ្ម(ហិរណ្យគាភ) បានប្រាប់អាថ៌កំបាំងស្នាដៃនោះដល់ប្រគាបតិ (កាស្យប) បន្ទាប់មកប្រគាបតិ បានប្រាប់តដល់ព្រះមនុ ហើយព្រះមនុ បានប្រាប់រឿងនេះដល់មនុស្សជាតិ។ រឿងព្រេងនិទាននេះ បង្ហាញច្បាស់ថា សាលាវេទសម័យបុរាណមានជំនឿថា ព្រះបានបង្រៀនកំណាព្យនិងចម្រៀងស្លុតីពីរបីនោះ។ ចំណុចនេះ ក៏អាចជួយឱ្យយើងយល់កាន់តែប្រសើរឡើងនូវឃ្លានៃគម្ពីរវេទទាំង ៤ ដែលបានដកស្រង់ថា "អ្វីដែលព្រះមនុបាននិយាយគឺជាឱសថ"។ ដូចបានសបញ្ជាក់ខាងដើមហើយការអះអាង ដែលមាននៅក្នុងប្រយោគនេះមានន័យទូទៅ រហូតដល់យើងមានការសង្ស័យពីវត្តមានពាក្យសម្ដីជាច្រើនរបស់មនុ ស្ដីពីប្រធានបទសាសនា។ ថ្វីបើគម្ពីរខាន្ទូឃ្យូបនិស័ទ ទំនងជាមិនបរមបុរាណ ដូចគម្ពីរសំហិតារបស់ យគុរវេទ ឬដូចតាណ្ឌ្យៈក៏ដោយ ដូច្នេះទោះបីសន្មតថា សេចក្ដីនេះត្រូវបានគេនិយាយបែបនេះ នៅពេលក្រោយ ជាការប្រថុយប្រថានខ្លាំងក្ដី ក៏ជាគំនិតដែលមនុ បានដើរតួជាអ្នកសម្រុះសម្រួលរវាងព្រាហ្មណ៍និងមនុស្សជាតិ ហើយថាទ្រង់បានបង្រៀនពីរបៀបរួចរំដោះចុងក្រោយ អាចមិនធ្លាប់មានទេពីដើមមក ហើយអាចជាបុព្វហេតុមួយក្នុងចំណោមបុព្វហេតុនានាដែលក្លាយជាការសន្និដ្ឋានទូទៅខ្លាំងពេក។ សេចក្ដីដូចគ្នានេះ ទំនងជាផ្ដល់សក្ខីភាពផងដែរអំពីវត្តមានដើមនៃជំនឿ ដែលមនុបានដោះស្រាយបញ្ហាធម៌ដំបូងដូចបានបង្ហាញខាងដើម ហើយជាហេតុនាំឱ្យមានការពង្រីកចេញពីទស្សនាទានដែលធ្វើឲ្យទ្រង់ក្លាយជា ស្ថាបនិកនៃសណ្ដាប់ធ្នាប់សីលធម៌និងសង្គមនៅក្នុងពិភពលោក។ គម្ពីរ សំហិតា និងព្រាហ្មណ៍ ដែលបានបោះពុម្ពផ្សាយតាមដែលខ្ញុំដឹងរហូតមកដល់ពេលនេះ មានអំណះអំណាងមិនច្បាស់លាស់អំពីប្រធានបទនេះ។ ក៏ប៉ុន្តែការសរសេរបញ្ហានេះ ហាក់ដូចជាមាននៅក្នុងសេចក្ដីនៃគម្ពីរតៃត្តិរីយសំហិតា ដែលប្រកាសជាផ្លូវការថា ព្រះមនុបានចែកមរតករបស់ទ្រង់ដល់បុត្រាទាំងឡាយរបស់ព្រះអង្គ។ យ៉ាងហោចណាស់ *ពោធាយនៈ*(គម្ពីរពិសិដ្ឋបូព៌ា លេខ ១៤ ទំព័រ២២៤) បាននិយាយក្នុងន័យនេះ ដោយហេតុថា លោកដាក់សេចក្ដីនេះនៅខាងដើមសិក្ខាវិន័យរបស់លោក ស្ដីពីការស្នងមរតក។ ការផ្ដល់សក្ខីភាពផ្ទាល់ដ៏ចំណាស់ជាងអំពីចំណុចនេះ គឺស្លោកដែលមានស្រង់នៅក្នុងគម្ពីរនីរុក្តជំពូក៣ លេខ៤ របស់យាស្កៈ ដែលសរសេរថា "យោងតាមច្បាប់ពិសិដ្ឋ ការទទួលមរតក ប្រព្រឹត្តទៅដោយគ្មានការបែងចែកផ្សេងគ្នាសម្រាប់កូនទាំងពីរភេទ ពោលគឺព្រះមនុ កូនកើតឯង (ស្វាយំភូ) បានប្រកាសនៅពេលចាប់ផ្ដើមបង្កើតដំបូង"(ខ្ញុំមិនយល់ស្រប តាមការយល់ឃើញរបស់សាស្ត្រាចារ្យ von Roth (នីរុក្ត សម្គាល់ ទំព័រ២៤-២៦) ពាក់ព័ន្ធនឹងភាពពិតនៃកំណាព្យនេះ និងការពិភាក្សាច្បាប់ទាំងមូលនៅក្នុងវគ្គ ៤-៦ នៃគម្ពីរនីរុក្ត ទី ៣ ។ ពេលនេះ យើងដឹងថា ទស្សនៈរបស់អ្នកនិពន្ធបូរាណ ស្ដីពីការស្នងមរតករបស់កូនស្រី មានភាពខុសគ្នាឆ្ងាយណាស់។ ហេតុនេះការពិភាក្សាដោយចៃដន្យអំពី ចំណោទបញ្ហាដ៏ក្ដៅនេះ នៅក្នុងគម្ពីរនីរុក្ត មិនបាច់បង្កើនការសង្ស័យទេ។ ការអធិប្បាយបន្ថែមខាងក្រៅ កើតមានជាទូទៅនៅក្នុងស្នាដៃវេទផ្សេងទៀត។ ការលំបាកដោយសារពាក្យផ្សំ ឬស្លោកាក្យាំ នៅក្នុងពាក្យផ្ដើមកាព្យនឹងរលាយបាត់ ប្រសិនបើតាមលោកសាស្ត្រាចារ្យ von Roth គិតថាជាទ្វន្ទ្វៈគឺមិនមែនជាកម្មធារយៈទេ។) ។ អត្ថបទបង្ហាញសំនៀងវេទ ជាការប្រើដែលទំនងជាមានកំណត់សម្រាប់សំហិតានិងព្រាហ្មណ៍។ ដោយសារគេហៅកំណាព្យថាជាស្លោកគេមិនអាចបង្កើតស្នាដៃមួយចេញពីស្នាដៃដើមទេ។ ស្នាដៃនេះទំនងជារបស់ព្រាហ្មណ៍មួយ ដែលបាត់ការ

សង្កត់សំឡេងទៅហើយ។ នោះមិនមែនជាផ្នែកមួយនៃមានវៈធម៌សូត្រ គឺមិនត្រឹមតែមិនយកតាមសំនៀងដើមប៉ុណ្ណោះទេ តែថែមទាំង មិនយកតាមខ្លឹមសារដើមទៀតផង។ លទ្ធិស្នាដៃនេះ មិនស្របនឹងលទ្ធិរបស់មនុ-ស្រ្មិតិ ដែលតាមផ្នែកជាច្រើននិយាយពីច្បាប់ស្នងមរតក គេចាត់ថាជាតំណាងនៃធម៌សូត្រដ៏ត្រឹមត្រូវ។ យ៉ាងណាមិញ គម្ពីរមនុ ជំពូក៩ លេខ១២១-១៣៩ នៅតែសង្កត់ធ្ងន់ទៅលើសិទ្ធិរបស់កូនស្រីដែលបានកំណត់ ហើយការពិតគឺសិទ្ធិរបស់កូនស្រីទាំងអស់ដែលគ្មានបងប្អូនប្រុស ដើម្បីស្នងមរតកពីសៃខាងឪពុកក៏ដោយ ក៏លោកគ្មានចែងច្បាប់នេះនៅកន្លែងផ្សេង ដែលយោងតាមយាស្កៈត្រូវបានបង្រៀននៅក្នុងកំណាព្យរបស់យើងថា កូនស្រីក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវទទួលបានចំណែកស្មើគ្នាជាមួយកូនប្រុស។ សម្រាប់កូនស្រី ដែលមានបងប្អូនប្រុស *មនុ* ឱ្យបែងចែកមួយភាគបួននៃចំណែក។

នៅក្នុងធម៌-សូត្រ កំណាព្យ ដែលមានឃ្លា "ហេតុនេះ *មនុ* បាននិយាយៈមនុអប្រាវីត"ឬដែលមានដូចគ្នានេះ មានលើកឡើងជាញឹកញាប់។ សេចក្តីរបស់វសិស្ឋៈ និងសង្ខាយនៈ ត្រូវបានពិភាក្សានៅលើរួចហើយ។ យើងឃើញមានកំណាព្យពីរនៅក្នុងធម៌សូត្ររបស់ពោជាយនៈ (ជំពូក៤ លេខ១, ១៣,២,១៥) និងលេខមួយចំនួននៅក្នុងធម៌សាស្ត្រៈសុភាសិតរបស់*ឧសនៈ(*ពាក្យឧបមារបៀបនេះ កើតមានជាពិសេសនៅក្នុងស្រាទ្ធកល្ប ជំពូកទី ៤ ...សំស្រ្កឹត.. និងជំពូកទី៦ ...សំស្រ្កឹត...*)* ។ មហាភារតៈ(ក្បួនពិចារណារបស់អង្គការសង្គមបូព៌ាអាមេរិក ខែតុលា ឆ្នាំ១៨៨៣ ទំព័រ១៩)នៅក្នុងមនុ-ស្រ្មិតិនារទ-ស្រ្មិតិ(J. Jolly,*មេរៀនតាហ្គ័រ* ទំព័រ៤៦) និងនៅក្នុងសៀវភៅ ច្បាប់ទី២ ដទៃទៀតក៏កើតមានជាទូទៅដែរ។ តាមលោកសាស្ត្រាចារ្យ Hopkins (តាមការស្រង់សម្តី)បានគូសបញ្ជាក់ថា អត្ថន័យពិតប្រាកដរបស់វា គឺគ្មានអ្វីក្រៅពីថា គេចាត់ជាសិក្ខាវិន័យបន្ថែមលើសិក្ខាវិន័យបុរាណមិនអាចប្រកែកបាន។ ដូច្នេះ ជួនកាលគេប្រើវា សម្រាប់ទាក់ទាញការបង្រៀនគម្ពីរវេទ(ធៀបនឹងឧទាហរណ៍ វាស. ជំពូក ១៧ លេខ ១០-១១ និងមនុ ជំពូក ៩ លេខ ១៨២-៣) និងការបង្រៀនរបស់ប្រជាបតិ។ បុព្វហេតុនៃការទទួលយកជារបស់ខ្លួន គឺមិនមានមានវៈធម៌ៈសូត្រ ឬសាស្ត្រៈទេ តែជាជំនឿលើការបង្ហាញរបស់ព្រះមនុ ត្រូវបានបញ្ជាក់ដោយការខ្វែងគំនិតយ៉ាងខ្លាំងអំពីលទ្ធិ ដែលជាបិតារបស់មនុស្សជាតិ ពីមួយទៅមួយ និងពីការបង្រៀនរបស់មនុ-ស្រ្មិតិ។

រឿងនិទាននិងការចាប់កំណើតទេវកថាទាំងអស់នេះ គ្រប់គ្រាន់នឹងសបញ្ជាក់ច្បាស់ពីមូលហេតុ ដែលសាលាច្បាប់ពិសេសគួរតែផ្តោតលើមានវៈធម៌សូត្រ និងគួរតែចាត់ទុកជាចំណូលចិត្តចំពោះស្នាដៃប្រហាក់ប្រហែលគ្នា ជាមូលដ្ឋាននៃសៀវភៅសិក្សារបស់ពួកគេ។ សូម្បីតែអ្នកនិពន្ធសូត្រដែលតាមប្រពៃណីរបស់មានវៈ(អ្វី ដែលខ្ញុំអាចលើកហេតុផលបានពាក់ព័ន្ធនឹងប្រពៃណីរបស់មានវ មិនឃើញមានកំណាព្យមង្គលាករណៈ ដែលត្រូវកំណត់ជាមុននូវសៀវភៅអត្ថាធិប្បាយពីរបស់អាស្តាវក្រ ស្តីពីគ្រឹហ្យ-សូត្រ។ នៅក្នុងការផ្តើមប្រថមបុរុសភាស្យ គាត់និយាយ យោងតាមសំណេរដៃរបស់សាស្ត្រាចារ្យ Haug(ព្រះរាជបណ្ណាលMunich*សំណេរដៃសំស្រ្កឹត* លេខ៥១) ថា...សំស្រ្កឹត...។ អត្ថបទរបស់ខ្ញុំបានលុបចោលពាក្យបួងសួងរបស់ភាស្យការៈ និងមានវា-កាយៈ និងអានតាមបន្ទាត់ចុងក្រោយ...សំស្រ្កឹត...។ ទ្វិតីយ បុរ-សភាស្យ តាមសំណេររបស់ខ្ញុំ គឺ...សំស្រ្កឹត...។ នៅក្នុងជួរទី១នៃកាព្យទី២ ខ្ញុំសូមអានថា ...សំស្រ្កឹត... និងប្រែថា "ដូចព្រះតេជព្រះគុណ មានវាកាយ បានសរសេរ (សូត្រ)នេះ ដោយសរស្វតិ (អត្ថាធិប្បាយ) ហៅថា បូរាណៈ ដែលត្រូវនិពន្ធដោយអស្វាវក្រ ទេវ បន្ទាប់ពីគាត់ពេញចិត្តនឹងសរស្វតិ ដែលត្រូវចំណាយពេល១០០ឆ្នាំ (លោកកាល) នៅដូរវិធ្លាក់សន្សើម"។ កំណាព្យទាំងនេះ ទំនងជាបញ្ជាក់ថា យោងតាមប្រពៃណីរបស់មានវ

តាមប្រវត្តិគឺមានវាកាយៈឬមនវាកាយៈបានសរសេរគ្រឹហ្យ-សូត្រ ដែលហៅថាព្រះធម្មតាមការនិយមរបស់ទេវតាសរស្វតិ។) ជួនកាលគេហៅថា *មនវាកាយៈ* ហើយជួនកាលថា *មានវាកាយៈ* តាមពិត ជាតួអង្គប្រវត្តិសាស្ត្រ ដែលហៅឈ្មោះតាមបុព្វបុរសរបស់មនុស្ស និងត្រូវគេចាត់ទុកយកលំនាំតាមការអប់រំរបស់គាត់ផ្ទាល់តែមានការច្របូកច្របល់រវាងរូបគាត់ និងឈ្មោះស្ងួនក្នុងទេវកថា របស់គាត់ដោយជៀសមិនរួច។ សូម្បី *អាស្តព* ដែលតាំងខ្លួនជាក្រៃភពដ៏មានបាបកម្ម មិនបានគេចផុតពីដោគវាសនាធ្លាក់ខ្លួនទៅជាពាក់កណ្តាលអាទិទេពដែលអ្នកនិពន្ធហៅថា *មហាភារតៈ(*មើល មហ. ជំពូក ១៣ លេខ ៦៦, ១២*)* និង*បូរណៈ*។ មនុដែលតែងបទអភិប្រាយស្តីពីច្បាប់ពិសិដ្ឋដែល មានភាពជាក់ស្តែងច្រើនគឺប្រាកដជាអាទិទេពកិត្តិយស។ ដរាបណាគេបង្ហាញអត្តសញ្ញាណរបស់អ្នកនិពន្ធព្រះសូត្រ ជាបិតារបស់មនុស្សជាតិ បញ្ហាគឺថាមនុ-ស្រ្មិតិបានទទួលឋានៈពិសេសហើយចាត់ជាសិទ្ធិអំណាចមហាសាលស្របតាមច្បាប់ពិសិដ្ឋ។

រឿងព្រេងខាងដើម មិនតម្រូវឱ្យយើងមានការងារផ្សេងទេ។ រឿងទាំងឡាយបកស្រាយអំពីដើមកំណើតនៃអំណះអំណាង ហាក់ដូចជាផ្ទុយគ្នានៅក្នុងស្រ្មិតិដែលនិយាយពីព្រះមនុ។ ពេលព្រះមនុ នៅទីនោះ តំណាងអ្នកជំនាន់ក្រោយរបស់ព្រាហ្មនស្វយំភូ និងប្រគាបតិ ដែលជាអ្នកបង្កើតដ៏ល្បីល្បាញ ឬដូចជាព្រាហ្មនដ៏កំពូល(អត្តសញ្ញាណដូចគ្នា គឺមាននៅក្នុងគម្ពីរ មហ. ជំពូក ១ លេខ ១, ៣២) ហើយអាចនិយាយម្យ៉ាងទៀតថាជាឫសី និងជាព្រះមហាក្សត្រិយ៍នាសម័យ បុរាណដ៏យូរលង់បំផុត ពេលនេះគឺជាក់ច្បាស់ណាស់ថា ការទស្សនាទានទាំងអស់នេះ ត្រូវបានផ្អែកលើសំណេរគម្ពីរវេទ និងថាភាពផ្សេងគ្នាជាក់ស្តែងបានកើតចេញពីទស្សនៈគំនិតសំខាន់ម័៦ ដែលធ្វើឱ្យមនុស្សដំបូង និងបុព្វបុរស ក្លាយជាសភាវៈពាក់កណ្តាលអាទិទេព និងពាក់កណ្តាលមនុស្ស ជាជំនួយក្នុងការបង្កើតនិងជាស្ថាបនិក នៃសណ្តាប់ធ្នាប់សីលតម្លៃ និងសង្គមសម្រាប់មនុស្ស។ សមាសធាតុមួយចំនួនទៀតនៃទេវកថាស្តីពីព្រះមនុ ដូចមាននិទាននៅក្នុងស្រ្មិតិ ទំនងជាការវិវត្តនៃទស្សនៈគំនិតវេទយ៉ាងជាក់ច្បាស់។ ដូច្នេះ ការសម្រុះសម្រួលនៃវិរាគឧភតោ នៅក្នុងពង្សាវលីរបស់ព្រះមនុ (ជំពូក១ កាព្យលេខ ៣២-៣៣) ត្រូវបានប្រាប់ជាមុននៅក្នុងវគ្គនៃគម្ពីរអេថាវ-វេទដ៏គួរឱ្យចង់ដឹង គឺជំពូក ៨ លេខ ១០ ដែលមាននិយាយពីវីរភេទស្រី ថា"ជាការចាប់ផ្តើមនៃពិភពលោកទាំងមូល" និងបានទទួលពរជ័យក្លាយជាវណ្ណៈសត្វលោកផ្សេងៗ។ យោងតាមកាព្យលេខ២៤ ថា "ព្រះមនុ បុត្ររបស់វិវស្វត គឺជាកូនរបស់ព្រះនាង(សម្តីនេះនិយាយទំនងជាសំដៅដល់ហេតុការណ៍ដែលមេគោឥណ្ឌាមិនអាចឱ្យគេសម្លាប់វាទេលើកលែងតែមានកូនរបស់វានៅក្បែរ។) នៅពេលប្រិថីវៃន្យ បឺតទឹកដោះពីរុក្ខជាតិកសិកម្ម និងរុក្ខជាតិធញ្ញជាតិរបស់នាង។" ហេតុនេះហាក់ដូចជាថា វិរាគ ដែលដើរតួជាចំណែកមួយនៅក្នុងទ្រឹស្តីបង្កើតលោករបស់វេទ មានទំនាក់ទំនងនឹងព្រះមនុនៅក្នុងទ្រឹស្តីស្រាប់។ ម្យ៉ាងទៀត ការយកមនុចំនួន៧ ឬច្រើនជាង ដើម្បីជំនួសមនុមួយ ទំនងជាមានហេតុផលរបស់វា ដោយហេតុថាវចនានុក្រម ភីធីស្បឹក (ពាក្យមនុ)បានលើកឡើងនូវទ្រឹស្តីបង្កើត ជាច្រើន ដែលមាននៅក្នុងអត្ថបទកំណាព្យនានា។ គេក៏មិនអាចបញ្ជាក់បានថា សាលាវេទមានជំនឿថា កាត្យាយនៈ ដែលបាននិពន្ធ សាវានុក្រម និកានៃគម្ពីរឫគវេទ មាននៅក្នុងមនុផ្សេងៗជាច្រើនទៀត។ ទីបំផុត ការប្រមូលផ្តុំមហាបណ្ឌិត១០រូប ដែលព្រះមនុ ស្វយំភូ បានបង្កើតឡើង និងបន្ទាប់មកមានភា

រៈបង្កើតមនុដទៃទៀត (ជំពូក១ លេខ៣៤-៣៦) ហើយក្នុងការបង្កើតនោះស្ថិតនៅលើសេចក្ដីជាច្រើន ដូចសេចក្ដីដែលអាបស្តមពៈ ជំពូក២ លេខ២៤, ៣-៦, ១៣ ដែលមាននិយាយពីការបំផ្លាញជាបន្តបន្ទាប់។ "ការបង្កើតនេះ ត្រូវបានប្រកាសថាជាស្នាដៃរបស់ប្រគាបតិ និងរបស់បណ្ឌិតនានា"។ ក៏ប៉ុន្តែការវិវត្តទាំងស្រុងនៃទេវកថាមនុ ស្ថិតនៅលើសាលាបូរាណិកៈនិងអែតិហាសិកៈហើយយើងរកឃើញនៅក្នុងគម្ពីរបុរាណនិងមហាភារតៈ មានរឿងព្រេងជាច្រើន ដែលមានលក្ខណៈដូចគ្នា ឬទាក់ទងគ្នាជិតស្និទ្ធទៅនឹងសេចក្ដី ដែលមាននិយាយនៅក្នុងស្ម្រិតិ(មើលH.H.Wilson,*វិស្ណុ-បូរាណ* លេខ ១ ទំព័រ ១០៤-៥ (ដែលផ្ទៀងផ្ទាត់ដោយ Hall) និងមើលសាស្ត្រាចារ្យHopkins,*ព្រឹត្តិប័ត្ររបស់សង្គមបូព៌ាអាមេរិក* លេខ ១១ ទំព័រ ២៤៧-២៥៦)។ បញ្ហាទី៣ ដើម្បីបង្ហាញពីរបៀបប្រែមានវៈធម៌-សូត្រ ទៅជាមនុ-ស្ម្រិតិ ដោយរបៀបបញ្ជាក់ឱ្យឃើញមានភាពស្មុគស្មាញច្រើនណាស់ និងផ្ដល់នូវដំណោះស្រាយស្មានៗប៉ុណ្ណោះ។ យើងគួរតែពិចារណា ទៅលើសំណួរបី។ ទី១ តើគម្ពីរមនុ-ស្ម្រិតិចំណែកណាជាចំណែកបុរាណ ហើយផ្នែកណាជាការបន្ថែមនៅពេលក្រោយ? ទី២ តើការបន្ថែមនោះចាប់ផ្ដើមពីត្រង់ចំណុចណា? និងទី៣ តើការបន្ថែមនោះមានតែមួយលើក ឬមានជាបន្តបន្ទាប់មកទៀត?។ ដោយមានបំណងចង់ញែកឱ្យច្បាស់រវាងសមាសធាតុចាស់ និងថ្មីនៅក្នុងគម្ពីរមនុ-ស្ម្រិតិគេបានណែនាំយើង វៀរលែងតែចំណុចណា ដែលយើងមានការដកស្រង់សេចក្ដីពីធម៌-សូត្របុរាណ ដោយមានភាពដូចគ្នា នឹងធម៌-សូត្រដទៃៗទៀត។ ពីព្រោះគេអាចលើកជាភាសិតទូទៅមួយថា សិក្ខាវិន័យនិងសម្ដីផ្សេងទៀតនៃមនុរបស់យើង ដែលមានឋានៈស្មើគ្នាដោយគ្មានការសង្ស័យ ជាមួយនឹងផ្នែកនៃសូត្ររបស់ គោតម ពោធាយន អាបស្តព និងវសិស្ត ទំនងជាកើតមាននៅក្នុងមានវៈធម៌សូត្រផងដែរ។ ការពិតការលើកលែងតែមួយគត់អាចនិយាយបាន ថ្វីដ្បិតតែធម៌-សូត្របង្ហាញពីប្រភេទដូចគ្នាដែលអាចញែកបានច្បាស់ក៏ដោយ ក៏គេមិនអាចញែកឱ្យបានលម្អិតដែរ។ ការលើកលែងមួយផ្ដោតខ្លាំងទៅលើប្រធានបទមួយនិងប្រធានបទផ្សេង ជាងប្រធានបទផ្សេងៗ។ ហេតុនេះអាចនិយាយបានថា មានពេលខ្លះសិក្ខាវិន័យដែលមាននៅក្នុងធម៌-សូត្រ មិនមាននៅក្នុងមានវៈ-សូត្រទេ ប៉ុន្តែត្រូវគេបន្ថែមនៅពេលមានការកែប្រែវា។ យើងក៏អាចប្រើប្រាស់វិស្ណុ-ស្ម្រិតិ សម្រាប់គោលបំណងដូចគ្នានេះក្នុងកម្រិតមួយបានដែរ។ ក៏ប៉ុន្តែគេត្រូវឱ្យមានការប្រុងប្រយ័ត្នកាន់តែខ្លាំង ដោយហេតុថាស្នាដៃនេះសូម្បីជាទូទៅជាតំណាងនៃកាថកៈ ធម៌សូត្រក៏ដោយ ក៏មានលាយឡំនូវសមាសធាតុទំនើបៗដែរ។ ម្យ៉ាងវិញទៀតសិក្ខាវិន័យនិងការពិភាក្សាទាំងនោះ ដែលយើងមិនអាចរកឃើញនៅក្នុងព្រះសូត្របុរាណណាមួយ យ៉ាងហោចណាស់ក៏គួរឱ្យសង្ស័យ និងទាមទារឱ្យមានការពិភាក្សាដោយប្រុងប្រយ័ត្ន។ ការសម្រេចចុងក្រោយ បើតាមសេចក្ដីបែបនេះ ត្រូវបានចាត់ជាការបន្ថែម ប្រាកដជាពឹងផ្អែកលើព្រឹត្តិការណ៍ជាប់ពាក់ព័ន្ធជាច្រើន។ ភ័ស្តុតាងដ៏មានសុវត្ថិភាពបំផុតគឺអាស្រ័យលើលក្ខណៈទស្សនៈគំនិតដែលគេបញ្ចេញទាំងស្រុង។ ប្រសិនបើសក្ខីកម្មទាំងនេះមានលក្ខណៈចម្លែកខុសពីព្រះសូត្រ ឬអត្ថបទវេទទាំងស្រុង នោះគេអាចប្រានបោលដោយមានទំនុកចិត្តថាជាការថែមថយ។ ដំណោះស្រាយដ៏ល្អ ក៏ពឹងផ្អែកលើការដាក់ និងរបៀបដែលគេដាក់សេចក្ដីបន្ថែមឱ្យស្របទៅនឹងបរិបទ។ ទោះជាយ៉ាងដូចនេះក្ដីករណីជាច្រើននៅតែមានការសង្ស័យនៅឡើយ។

ប្រសិនបើយើងពិនិត្យអត្ថបទរបស់មនុ ស្របតាមគោលការណ៍ទាំងនេះ លទ្ធផលកាន់តែសំខាន់គឺថា ជំពូកទី១ទាំងមូល ពិតជាត្រូវគេបន្ថែមនៅពេលក្រោយ។ គ្មានធម៌-សូត្រណា ចាប់ផ្តើមដោយពណ៌នាពីដើមកំណើតផ្ទាល់របស់ខ្លួន ដោយរៀបរាប់ពីការបង្កើតនោះទេ។ អត្ថបទដើមដែលមិនស៊ីគ្នានឹងធម៌-សូត្រ ត្រូវបានគេបន្ថែម ដើម្បីបង្ហាញប្រភពគួរឱ្យជឿជាក់សម្រាប់កំណែថ្មី។ កំណែក្រោយនេះត្រូវគេថែមពីព្រោះទេវកថា ដែលពាក់ព័ន្ធនឹងព្រះមនុមានឱកាសល្អ ដើម្បីបង្ហាញពីវិសាលភាពដ៏ធំធេងនៃស្នាដៃ នេះបើតាមសម្តីរបស់មេធាតិថិ។ តារាងមាតិកា ដូចមាននៅចុងបញ្ចប់នៃជំពូកទី១ តាមពិតក៏មិនស៊ីគ្នានឹងព្រះសូត្រដើមដែរ។ យ៉ាងណាមិញ ជំពូកទី២-៦ ហាក់ដូចជាមានភាពស្មោះត្រង់សមល្មមនឹងបង្ហាញខ្លឹមសារណែងណងពាក់ព័ន្ធ នឹងមានវៈធម៌សូត្រ។ គេសង្កេតឃើញ សិក្ខាវិន័យស្ទើរតែទាំងអស់ មាននៅក្នុងធម៌សូត្រដទៃទៀត និងនៅក្នុងវិស្ណុស្មិតិ ហើយកំណាព្យជាង បីភាគបួន ជាសុភាសិត និងកំណាព្យគម្ពីរច្បាប់បុរាណ។ យ៉ាងណាក៏ដោយ គេកម្រនឹងឃើញមានស្នាដៃបង្កើតថ្មីណាស់។ ក្រៅពីកំណាព្យសម្រាប់ភ្ជាប់សាច់រឿងពីប្រធានបទមួយ ទៅប្រធានបទមួយ(កំណាព្យទាំងនេះ ទំនងជាបង្ហាញអនុផ្នែកនៃអាធ្យាយ ជាកន្និកា ឬខណ្ឌនៃសូត្រពីមុន) ទៀត ការថែមថយខ្លះមានតិច ហើយការថែមថយខ្លះមានច្រើន។ ការបន្ថែមក្រោយនេះ មាននៅក្នុងជំពូកទី២ កាព្យលេខ ១-២ និងលេខ៨៨-១០០។ វគ្គទី១ រៀបរាប់ដើមកំណើតនៃសកម្មភាពតាមបែបទស្សនវិជ្ជា (១-៥) ដូចជាមិនឃើញមាននៅក្នុងគម្ពីរច្បាប់ពីដើមណាមួយទេ។ ជាងនេះទៅទៀត កាព្យ (លេខ៦) និយាយពីប្រភពច្បាប់ពិសិដ្ឋ ដែលមិនចាំបាច់បញ្ជាក់ពីជំពូក៥ លេខ១២ទេ និងមានការសង្ស័យពីពណ៌នាពីរដងនូវប្រភពទី៣នៃច្បាប់នេះ ដោយប្រើពាក្យវេវចនៈស័ព្ទ សីលនិងអាការៈ(មើលកំណត់សម្គាល់សម្រាប់ការបកប្រែ)។ ខ្លឹមសារកំណាព្យក្រៅពីនេះការសរសើរមនុស្មិតិ(v. ៧) ការណែនាំភាពខុសគ្នានៃប្រភព គួរឱ្យជឿជាក់ (v. ៨) ការប្រកាសផ្តល់រង្វាន់ស្តីពីការស្តាប់ឱវាទតាមអត្ថបទអធិប្បាយ (v. ៩) និយមន័យនៃពាក្យ *ស្រុតិ* និង*ស្មិតិ* និងការប្រកាសពីប្រភពពិតរបស់វា ហាក់ដូចជាមានការពង្រីកបន្ថែមយ៉ាងច្រើន នៅពេលក្រោយៗមកទៀត។ វគ្គទី២ (vv.៨៨-១០០) ដែលរៀបរាប់ម្តងមួយៗ អំពីអង្គវិញ្ញាណ និងអំពើ ព្រមទាំងបង្រៀនអំពីភាពចាំបាច់ត្រូវគ្រប់គ្រងអង្គវិញ្ញាណទាំងឡាយដោយផ្អាកអត្ថបទដោយ មិនចាំបាច់ហើយគ្មាននិយាយពីអ្វីជាក់លាស់សោះ។ ក្នុងចំណោមការបន្ថែមតិចតួចនៅក្នុងជំពូកនេះ vv. ១៣, ១៦, ២៧, ២៨, ១៤២, ១៤៣, ២១៣-២១៥, ២២១ និង ២៣៩ យើងគួរតែពិចារណាឱ្យបានត្រឹមត្រូវ។ ហាក់ដូចជាមានន័យថា វគ្គស្តីពីសារៈសំខាន់នៃព្យាង្គ *ឱម* នៅក្នុងវ្យាហ្រ្ឫតិ និងសាវិត្រី (vv.៧៦-៨៧) ព្រមទាំងវគ្គស្តីពីសេចក្តីគោរព និងការឱនលំទោនដែលតម្រូវឱ្យព្រាហ្មណ៍ត្រូវប្រកាន់យក (vv. ១៦០-១៦៣) និងវគ្គស្តីពីការគោរពឪពុកម្តាយ និងគ្រូបាអាចារ្យ (vv. ២២៥-២៣៧) ត្រូវបានពង្រីកថែម ថ្វីបើក្នុងករណីមួយៗ មានអ្វីម្យ៉ាងនៅក្នុងធម៌សូត្រ។ នៅក្នុងជំពូកទី ៣ ជាជំពួកមួយដ៏វែង (ពីvv.១៩២-២០១) ដែលបង្ហាញយ៉ាងច្បាស់ថា មានការសរសេរបន្ថែមដោយដៃនៅពេល ក្រោយ។ សម្រាប់ជាការចំណាត់ថ្នាក់វិញ្ញាណក្ខន្ធបុព្វបុរស នៅក្នុងវគ្គនេះ មានទម្រង់ផ្សេងពីអក្សរនៅក្នុងគម្ពីរវេទ។ ច្បាស់លាស់ជាងនេះទៅទៀតគឺការពិភាក្សាអំពីករណីយកិច្ចនៃការរួមសង្វាសរវាងស្វាមី ភរិយា

(ឃ.៤៦-៥០) និយាយអំពីកិត្តិយសដោយសារស្ត្រី (ឃ.៥៥-៦០) អំពីភាពខ្ពង់ខ្ពស់នៃបញ្ញារបស់មេគ្រួសារ (ឃ.៧៩-៨០) និងនិយាយអំពីលទ្ធផលនៃការអញ្ជើញបាបជន និងអ្នកប្រព្រឹត្តអំពើអាក្រក់ចំពោះស្រាទ្ធ (ឃ.១៦៩-១៨២)។ ទំនងជាការពិតថា សូត្រពីបុរាណ មានតម្រុយស្ដីពីប្រធានបទទាំងនេះខ្លះដែរ ប៉ុន្តែមិនគួរឱ្យជឿសោះថា អត្ថបទរបស់យើងហេតុអ្វី ក៏គួរតែសរសេរយ៉ាងលម្អិត។ វគ្គស្ដីពីគ្រួសារ ទំនងជាគេដាក់ខុសកន្លែង។ កាព្យភាគច្រើនគួរតែស្ថិតនៅត្រង់ចំណុចសាកច្ឆាអំពីសារសំខាន់ដោយប្រៀបនៃលំដាប់លំដោយនៅចុងជំពូកទី៥។ នៅក្នុងជំពូកទី ៤ ផ្នែកទី១ស្ដីពីមធ្យោបាយចិញ្ចឹមជីវិតរបស់ពួកព្រាហ្មណ៍ (ឃ. ១-២៤) គួរឱ្យមានមន្ទិលសង្ស័យខ្លាំងណាស់។ ការពិត ពេលខ្លះធម៌សូត្រ ឧទាហរណ៍ វសិស្ឋជំពូក ១២ លេខ ២-៤ កំណត់ជាមុន នូវតម្រុយសង្ខេបស្ដីពីវិធីប្រព្រឹត្តរបស់ស្នាតក ចំពោះសិក្ខាវិន័យស្ដីពីឥរិយាបថរបស់ខ្លួន។ ប៉ុន្តែពួកគេ មិននិយាយអំពីការចាត់ថ្នាក់រៀបរាប់លម្អិតអំពីមធ្យោបាយចិញ្ចឹមជីវិត រីត៏ អម្រិត ម្រិតប្រម្រិតនិងស្វាវ្រិត្តិ(ឃ.៥,៦)ដែលសូម្បីមានជាទូទៅនៅក្នុងគម្ពីរបុរាណៈនិងស្នាដៃក្រោយៗដទៃទៀតក្ដីក៏ គេមិនបានស្គាល់នៅក្នុងអក្សរសាស្ត្រវេទទេ។ ម្យ៉ាងទៀតដូចជាសិក្ខាវិន័យរបស់វសិស្ឋ ដែលរៀបរាប់ឈ្មោះមនុស្សដែលចិញ្ចឹមស្នាតកៈ មានបន្ថែមទៀតនៅ(ជំពូក៤លេខ៣៣-៣៤) យើងមិនគួរមិនជឿថា វគ្គនេះទាំងមូលដែលមានកាព្យចំនួន ២៤ ដំបូង គឺជាការបន្ថែមក្រោយ។ កាន់តែច្បាស់លាស់ជាងនេះទៀត បញ្ញាដដែលនេះ មាននិយាយនៅក្នុង ឃ. ៨៥-៩១ ដែលពិពណ៌នាអំពើទោសៈបង្កើតជាបទល្មើស ដូចជាការទទួលអំណោយពីអ្នកដណ្ដើមអំណាចពីស្ដេច និងមនុស្សអាក្រក់ផ្សេងទៀត និងរាប់ឈ្មោះឋាននរក២១ ដែលជាកន្លែងទទួលអ្នកប្រព្រឹត្តល្មើស។ ពីព្រោះប្រាកដណាស់ថា សូម្បីសូត្រ ការៈ ត្រូវមានចំណាត់ថ្នាក់ទិដ្ឋភាពនៃការដាក់ទោស ការរៀបរាប់ឈ្មោះនេះមិនគួរដាក់នៅចំណុចនេះទេ ប៉ុន្តែដូចជានៅក្នុងគម្ពីរវិស្ណុស្រ្មិតិ នៅដើមវគ្គនេះស្ដីពីបទឧក្រិដ្ឋ និងអនុតាបៈ (ការលាងបាប)។ ការបន្ថែមគួរឱ្យជឿបាន មាននៅចំណុច ឃ. លេខ១៧២-១៧៤ និយាយពីផលនៃអំពើបាប ចំណុច ឃ. ១៨០-១៨៥ ស្ដីពីមូលហេតុដែលគេគួរតែលើកកម្ពស់តម្លៃព្រលឹងវិញ្ញាណ។ ទីបញ្ចប់ផ្នែកស្ដីពីការជូនអំណោយ និងការទទួលអំណោយ (ឃ.១៨៦-១៩៧) ហាក់ដូចជាបញ្ចូលសមាសធាតុទំនើបមិនត្រឹមត្រូវ។ ជំពូកចំនួនពីរបន្ទាប់ទៀតមានសេចក្ដីគួរឱ្យសង្ស័យតិចតួច។ យ៉ាងណាមិញបុព្វកថាសម្រាប់វគ្គនេះ ស្ដីពីអាហារដែលគេហាមឃាត់ ជំពូក៥ លេខ១-៤, កាព្យលេខ១៩-២១ ដែលពិពណ៌នាការលាងបាប ដោយការទទួលទានផ្សិត ខ្ទឹមបារាំង គុយឆាយជាដើម ប្រាកដជាត្រូវបានគេជំទាស់។ ដោយសារខ្លឹមសារដើម ជាក្របខណ្ឌរបស់មនុស្ស ដែលគេបានដាក់នៅក្នុងសូត្រពីដើម ហើយសំណេរក្រោយគួរតែមាននៅក្នុងជំពូក១១។ សេចក្ដីសម្រេចនៅក្នុងវសិស្ឋជំពូក៤ ចំណុច ៥-៨ បញ្ជាក់កាន់តែច្បាស់ទៀតថា សិក្ខាវិន័យ ស្ដីពីការអនុញ្ញាតឱ្យទទួលទានសាច់ ត្រូវបានគេកែនិងពង្រីកថែមច្រើន ឱ្យស្របតាមការស្អប់ខ្ពើមកាន់តែខ្លាំងចំពោះអ្នកសត្វឃាត (អ្នកសម្លាប់សត្វ)។ ផ្នែកចុងក្រោយនៃជំពូកដដែល ស្ដីពី ករណីយកិច្ចរបស់ស្ត្រីទំនងជាមានវាសនាដូចគ្នា។ តួយ៉ាងវសិស្ឋធម៌សាស្ត្របង្ហាញថា សូត្រការៈមួយចំនួនពីមុន បរិយាយអំពីករណីយកិច្ចរបស់ស្ត្រីនៅក្នុងផ្នែកពីរដោយឡែកពីគ្នា(មើល វស. ជំពូក ៥ និង ១៧ លេខ ៥៥-៨០) ។

ប៉ុន្តែចំណុចនេះសឱ្យឃើញផងដែរថា ករណីយកិច្ចនេះ មិនរៀបរាប់ពីរដង ដូចជាគម្ពីរមនុស្ម្រិតិរបស់យើងទេ។ គួរបញ្ជាក់បានថា សូម្បីនៅចំណុចនេះក្តី ឬនៅក្នុងការចាប់ផ្តើមជំពូកទី៩ក្តី អ្នកនិពន្ធកំណែថ្មីមិនចាំបាច់សរសេរកំណាព្យដដែលនេះឡើងវិញទេ។ នៅក្នុងជំពូកទី៦ មានសាច់រឿងតែមួយប៉ុណ្ណោះ ចំណុច vv. ៦១-៨១ ដែលសរសេរពន្លាតវែងជាងធម៌សូត្រ។ គ្មានធម៌សូត្រណា មួយសរសេរលម្អិតអំពីការធ្វើសមាធិ ដែលតាបសឥសីត្រូវតែប្រតិបត្តិ ដើម្បីទទួលបានការសង្គ្រោះ។ ប្រធានបទធម្មតាបានធ្វើឱ្យអ្នកបង្កើតស្ម្រិតិថ្មី ចង់ពង្រីកសេចក្តីពន្យល់ខ្លីៗនៃច្បាប់ដើម។ ករណីជំពូកបីបន្ទាប់ គឺជំពូកទី៧-៩ ដែលបរិយាយពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ និងច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ មានភាពខុសគ្នាឆ្ងាយណាស់។ ផ្នែកទាំងអស់នេះ ទំនងជាមានភាពដូចគ្នាតិចតួចនឹងផ្នែកពាក់ព័ន្ធនៃ ស្នាដៃដើម។ ក្នុងចំណោមកាព្យចំនួន២២៦ល្បះ នៃជំពូកទី៧ មានតែកំណាព្យតែ៥៤ប៉ុណ្ណោះ ដែលមានសេចក្តីស្របធម៌សូត្រ និងវិស្ណុស្ម្រិតិ។ ប្រសិនបើគេយកចិត្តទុកដាក់ចំពោះសិក្ខាវិន័យពាក់ព័ន្ធនឹងករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ដែលមាននៅក្នុងធម៌សូត្ររបស់គោតម អាស្តម្ព និងវសិស្ថ ព្រមទាំងចំពោះសេចក្តីសំអាងលើមតិយោបល់របស់មានវៈ និងមនុ ដែលមាននៅក្នុងកាមន្ទកីយ នីតិសារ(មើលចំណុចខាងលើ ទំព័រ៣៦) ហាក់ដូចជាថា ខ្លឹមសារនៅក្នុងផ្នែកមានវៈធម៌សូត្រនេះ មិនខុសគ្នាច្រើនពីខ្លឹមសារ ជំពូកទី៣ នៃគម្ពីរវិស្ណុ ហើយជំពូកនោះនិយាយប្រហែលពីរភាគបីនៃអធ្យាយទី៧ នៅក្នុងមនុស្ម្រិតិ របស់យើង ត្រូវបានគេបន្ថែមនៅពេលគេតែងគម្ពីរនោះឡើងវិញ។ យោងតាមជំពូកទី៨ និងកំណាព្យ ២២៤ដំបូងនៃជំពូកទី៩ ដែលបរិយាយពីសិក្ខាវិន័យ ដែលមាន១៨ចំណងជើងច្បាប់ អ្នកតែងអត្ថបទឡើងវិញ ហាក់ដូចជាមានសភាពសកម្មដូចគ្នា។ យើងពិតសំអាងហេតុផលរបស់គាត់ ក្នុងការរៀបចំជាប្រព័ន្ធនូវសិក្ខាច្បាប់វិន័យ ដែលគ្មាននៅក្នុងគម្ពីរធម៌សូត្របុរាណណាមួយទេ ហើយថែមទាំងគ្មាននៅក្នុងវិស្ណុស្ម្រិតិផង។ គាត់ទំនងជាទទួលខុសត្រូវផងដែរចំពោះកំណាព្យជាងពាក់កណ្តាលនៃជំពូកទាំងនេះ។ នៅអធ្យាយទី ៨មានតែសិក្ខាវិន័យចំនួនបីភាគប្រាំពីរប៉ុណ្ណោះ ដែលគេឃើញមាននៅក្នុងធម៌សូត្រ ឬវិស្ណុ-ស្ម្រិតិ ដែលក្រោយមក រហូតដល់ពេលមាននិយាយប្រធានបទទាំងអស់នេះ អាចជាតំណាងដ៏ត្រឹមត្រូវនៃគាថក ធម៌សូត្រ(តាមសេចក្តីសន្និដ្ឋាននេះបង្ហាញថាគ្មានការរៀបចំជាប្រព័ន្ធនៅក្នុងគម្ពីរវិស្ណុ ជំពូក ៣-៥) ។ ចំណងជើងពីរក្នុងចំណោមចំណងជើងនានានៃគម្ពីរមនុ ទាក់ទងនឹងផ្នែកនានា(សិក្ខាវិន័យរបស់មនុ សម្រាប់ប្រធានបទនេះ ទំនងជាគេបានខ្ចីពីស្រោតសូត្រ ដែលតាមធម្មតាគេរៀបរាប់ពីការរួមចំណែក ចេញថ្លៃបូជា។) និងការធ្វើអំណោយមិនមាននិយាយនៅក្នុងស្នាដៃពីមុនៗទេ ហើយសិក្ខាវិន័យក្នុងពេល មានទុពលភាពទី៣នៃការជាវនិងលក់ មិនមានភាពដូចគ្នានឹងសិក្ខាវិន័យរបស់ព្រះវិស្ណុទេ។ នៅក្នុងជំពូកទី៩ ប្រធានបទសំខាន់ ដែលបរិយាយពីប្រធាន ករណីយកិច្ចរបស់ស្វាមីនិងភរិយា ត្រូវបានលើកយកមកនិយាយ ឬយ៉ាងហោចណាស់មាននៅក្នុងសូត្រនានា។ ប៉ុន្តែព្រះសូត្រក្រោយៗ និយាយពីចំណុចនេះនៅកន្លែងផ្សេង និងមានសេចក្តីលម្អិតកាន់តែច្បាស់។ សេចក្តីអធិប្បាយក្នុងការបកប្រែ សបញ្ជាក់ថា កំណាព្យរបស់មនុ តែមួយភាគបួនប៉ុណ្ណោះ ទើបមាននិយាយស្របគ្នានឹងគ្រូអាចារ្យសម័យដើម។ ផ្នែកស្តីពីការទទួលមរតក ហាក់ដូចជាអាចមានតិចតួច

ពីព្រោះចាប់ពីកាព្យល្បះ៨០ ក្រៅពីទី១៧០ ស្របគ្នានឹងការបង្រៀនរបស់សូត្រ ដូចនេះក្នុងចំណោមកំណាព្យនោះ ខ្លឹមសារដែលគ្មាននៅក្នុងស្នាដៃពីមុន មានតែល្បះ ១១ប៉ុណ្ណោះ គឺ vv. ១០៨-១១០, ១២៨-១២៩, ១៣៣, ១៣៨, ១៤៧, ១៨៤, ២១៥ និង ២១៧ មានចំណុចគួរឲ្យសង្ស័យ ឬមានការថែមថយយ៉ាងច្បាស់លាស់។ ស្នាដៃក្រោយភាគច្រើន មាននិយាយបញ្ហាច្រំដែលដ៏ធ្ងាំធ្ងងនៅកន្លែងផ្សេងទៀត ហើយល្បះ v. ២១៧ មានបន្ថែមវិន័យមួយ ដែលមិនស្របគ្នានឹងស្មារតីនៃផ្នែកផ្សេងទៀត។ កំណាព្យខ្លះទៀតដែលគួរឱ្យសង្ស័យពិតជាមានការបន្ថែម។ ក៏ប៉ុន្តែខ្លឹមសាររបស់កំណាព្យស្របគ្នានឹងស្មារតីធម៌សូត្រ និងមានការលុបចោល តាមការស្នើខាងលើនោះទ្រឹស្តីស្តីពីការទទួល និងការបែងចែកមរតករបស់មនុ មានភាពរលូនដោយផ្ទាល់។ ការយល់ឃើញដែលមាននៅក្នុងចំណងជើងទី៨០ ស្តីពីការលេងល្បែងនិងការភ្នាល់ មានចំណុចស្របគ្នានឹងទស្សនៈគំនិតរបស់ គោតម និងពោធាយនដែលទាំងពីរព្រះអង្គមិនឯកភាពនឹងការអនុវត្តទាំងនេះទេ។ កំណាព្យដើមរៀបរាប់ឈ្មោះអ្នកលេងល្បែងក្នុងនោះមានបុរស ដែលធ្វើឱ្យខូចការសេពគប់តាមស្រាទ្ធ ហើយកំណាព្យក្រោយរាប់ឈ្មោះការលេងល្បែង ដែលជាអំពើឧក្រិដ្ឋធ្វើឱ្យមនុស្សបាត់ភាពបរិសុទ្ធ។ ថ្វីបើអបស្តម្ពនិងវិស្ណុមិនសូវមានគោលការណ៍តឹងរ៉ឹងនិងអនុញ្ញាត ឱ្យលេងល្បែងក្រោមការត្រួតពិនិត្យពីមន្រ្តី ពោលគឺពីប៉ូលិស ឬដាក់ទោសតែចំពោះអំពើបោកប្រាស់ប៉ុណ្ណោះ (វិស្ណុ ជំពូក៥ លេខ១៣៤-១៣៥)ក្តី ក៏ការប្រៀនប្រដៅនៅក្នុងស្មិតិរបស់យើងយ៉ាងណាមិញ ទំនងជាមានតាំងពីបុរាណ។ ប៉ុន្តែផ្នែកនេះ ត្រូវបានគេពង្រីកបន្ថែមនូវសិក្ខាវិន័យផ្សេងៗ និងរៀបរាប់ពីលទ្ធផលមិនល្អនៃការលេងល្បែងភ្នាល់"កាលពីជំនាន់មុន"ពោលគឺជាផលដែលត្រូវទទួលដោយវាសនា នៃយុធិស្ថិរៈ និងនលៈ។ កំណាព្យ ១០៦ល្បះចុងក្រោយនៃជំពូកទី៩ ដែលស្របតាមតារាងមាតិកាក្នុងជំពូកទី១ បង្រៀនពីការដក (មនុស្សពាល) បន្លា (កន្តកោទ្ធារណ) ស្របគ្នានឹងផ្នែកប្រកីរណក ឬសិក្ខាវិន័យផ្សេងៗនៃយាញ្ញវល្ក្យ និងនារទៈ ។ ផ្នែកនេះហាក់ដូចជាពង្រីកចេញពីសិក្ខាវិន័យនានា នៅក្នុងមានវៈធម៌សូត្រដែលមិន ស៊ីគ្នានឹងប្រព័ន្ធមាតិកា១៨។ ក៏ប៉ុន្តែដោយសារកំណាព្យមួយចំនួនតូចប៉ុណ្ណោះ ដែលស្របនឹងសិក្ខានៃធម៌សូត្រ ចំណែកកំណាព្យពីដើមទំនងជាមានតិច។ ផ្នែកជាច្រើននៃមាតិកា ត្រូវគេសរសេរដដែលៗ ហើយត្រូវអ្នកនិពន្ធកំណែថ្មីដាក់បន្ថែម។

សិក្ខាបទនិយាយពីពេលទុក្ខព្រួយ ដែលមាននៅក្នុងជំពូកទី១០ ខុសគ្នាច្រើនពីសិក្ខាវិន័យធម៌សូត្រ ព្រោះពួកគេក៏មានបញ្ចូលទ្រឹស្តីពីដើមកំណើតវណ្ណៈចម្រុះ។ ស្នាដៃពីមុន បរិយាយប្រធានបទនេះ ដោយទាក់ទងនឹងច្បាប់អាពាហ៍ពិពាហ៍ផង ឬច្បាប់ស្នងមរតកផង។ បើនិយាយពីភាពមិនស្មើគ្នាដែលព្រះសូត្របង្ហាញពីការរៀបចំប្រធានបទនានា យ៉ាងណាមិញទំនងជាមិនមែនមិនអាចទេថា មានវៈធម៌សូត្រ បានដាក់ផ្នែកនេះ និយាយវណ្ណៈលាយឡំគ្នានៅមុនអាបទធម្មៈ និងថាអ្នកនិពន្ធអត្ថបទពាក្យកាព្យបានភ្ជាប់បញ្ហាទាំងពីរនៅក្នុងជំពូកមួយ និងដាក់ចំណងជើងរួមមួយ។ ក៏ប៉ុន្តែគ្មានអ្វីគួរឱ្យសង្ស័យសោះថា ការបរិយាយប្រធានបទក្នុងស្នាដៃដើមពិតជាខុសគ្នាច្រើនពីប្រធានបទដែលមាន នៅក្នុងចំណុច vv.១-៧៤។ ធម៌សូត្រទាំងឡាយរៀបរាប់វណ្ណៈមួយផង និងវណ្ណៈលាយឡំគ្នាផង ដោយប

ង្ហាញយ៉ាងខ្លីៗពីដើមកំណើតវណ្ណៈ ហើយជួនកាលរៀបរាប់អំពីទម្រង់ជីវិតរបស់ពួកគេផង។ ពួកគេក៏មានបន្ថែមពាក្យកាព្យខ្លះ ឬសិក្ខាវិន័យទាក់ទងនឹងការប្រែប្រួលដែលមាននៅក្នុងជំនាន់ក្រោយៗ ព្រមទាំងនិយាយអំពីរបៀបប្រព្រឹត្តរបស់មនុស្សវណ្ណៈទាប។ យ៉ាងណាមិញមនុស្ម្រិតិរបស់យើង សរសេរបានលម្អិតច្រើន និងរៀបរាប់ឈ្មោះល្អៗថ្មីៗជាច្រើន ដែលសូត្រមិននិយាយសោះ។ ការបន្ថែមទាំងអស់នេះ ហាក់ដូចជាបានពង្រីកផ្នែកដើមដល់បីដង។ សិក្ខាវិន័យខាងក្រោម ចំណុច vv. ៧៥-១០០ ស្ដីពីមុខរបររបស់វណ្ណៈនានា និងរបៀបរបបចិញ្ចឹមជីវិតរបស់ពួកគេក្នុងពេលមានទុក្ខព្រួយ ជាទូទៅស្របគ្នានឹងសូត្រ ហើយហាក់ដូចជាមានការកែបន្តិចបន្តួច។ ប៉ុន្តែសេចក្ដីអធិប្បាយបន្ថែមស្ដីពី ប្រធានបទដូចគ្នាចំណុច vv. ១០១-១៣១ ទំនងជាគេបន្ថែម នៅពេលសរសេរស្នាដៃនោះឡើងវិញ។ សិក្ខាវិន័យបុរាណមួយចំនួន ដែលពួកគេបន្ថែមមួយផ្នែក និយាយបញ្ច្រាប្រំដែល ដែលបានពិភាក្សារួចហើយ (ឧទាហរណ៍ចំណុចvv.១១៣-១៣១) ហើយផ្នែកខ្លះបានដាក់ខុសកន្លែង (ឧ.ទា.ចំណុច vv. ១១១, ១១៥-១១៧, ១១៩)(លក្ខណៈបង្ហាញការកែប្រែយ៉ាងច្រើន ដែលមានពីជំពូកទី ៧-១០ មានការសរសេរអំពីរឿងនិទានដ៏ល្បីនៅគម្ពីរបុរាណ និងមហាភារតៈ និងសូមមើលចំណុចខាងក្រោមផង)។

ជំពូកទី១១ ជាថ្មីម្ដងទៀត ក៏ដូចជាជំពូកទី២-៦ អាចតំណាងពិតប្រាកដនៃផ្នែកមានវៈធម៌សូត្រពាក់ព័ន្ធ។ ចំណុចនេះយើងយល់ថាសិក្ខាវិន័យភាគច្រើនស្របគ្នានឹងសិក្ខាវិន័យនៅក្នុងធម៌សូត្រ និងវស្តុស្ម្រិតិ។ ភាពត្រូវគ្នានឹងស្នាដៃក្រោយនេះ គឺដូចគ្នា ហើយជាពិសេសត្រង់ចំណុចស្ដីពីការចាត់ថ្នាក់បទឧក្រិដ្ឋ ការរាប់ឈ្មោះជំងឺ ដែលបណ្ដាលមកពីការប្រព្រឹត្តបទល្មើសកាលពីជាតិមុន និងមានសរសេរលម្អិតច្រើនពាក់ព័ន្ធនឹងការលាងបាប។ ការចង់ដឹងពីការអនុវត្តតាមស្នាដៃចាស់ គឺការភ្ជាប់សិក្ខាវិន័យស្ដីពីអំណោយ និងការអនុវត្តការបូជា ចំណុច vv. ១-៤៣ ជាមួយនឹងផ្នែកស្ដីពីការលាងបាប។ ការសុំទោសដែលអ្នកអធិប្បាយបានលើកឡើងដោយសមទំនងនេះ(មើលសេចក្ដីអធិប្បាយគម្ពីរជំពូក ១១ លេខ ១) គឺ "ខ្ញុំបារម្ភ" មិនគ្រប់គ្រាន់នឹងបរិយាយសេចក្ដីបានទេ។ ហាក់ដូចជាចង់និយាយថា ដូចមាននៅក្នុងជំពូកខាងដើមគេ បានភ្ជាប់ផ្នែកពីរផ្សេងគ្នានៃច្បាប់ដើមទៅជាអធ្យាយតែមួយ។ស្របតាមទស្សនៈយោបល់នេះគេអាចគូសបញ្ជាក់ ថា ធម៌សូត្ររបស់គោតមជំពូក១៨ លេខ ២៨-៣២ សិក្ខាវិន័យមួយចំនួន ដែលស្របគ្នានឹងគម្ពីរមនុ ជំពូក១១លេខ១-២៣នៅខាងដើមប្រាយស្ថិត្តិកាណ្ឌ។សេចក្ដីរបស់មហាភារតៈដែលយើងនឹងពិភាក្សាខាងក្រោម ឆ្លុះបញ្ចាំងច្បាស់ពីការប្រាប់បញ្ចូលដូចគ្នានឹងស្ម្រិតិរបស់យើងដែរ។

ជំពូកទី១២ ចុងក្រោយ ភាគច្រើននិយាយអំពីអ្នកនិពន្ធអត្ថបទពាក្យកាព្យ។ មាតិការបស់វាមួយផ្នែកមិនស្របនឹងធម៌សូត្រទេ ហើយមួយផ្នែកនិយាយជាន់គ្នា។ ការចាត់ថ្នាក់អំពើនិងអត្ថិភាព ដូចជាសាត្វិក រាគិស និងតាំមសៈ គឺដូចមានការកែប្រែតាមគុណសម្បត្តិបីនៃអំពើល្អ គឺសកម្មភាព និងភាពងងឹត មិនមាននៅគម្ពីរច្បាប់ពីមុនទេ។ ការចាត់ថ្នាក់នេះ ពឹងផ្អែកលើទ្រឹស្ដីដែលគេបង្រៀននៅក្នុងប្រព័ន្ធសំខ្យៈ យោគៈ វេទ័ន្តៈ និងសំណេរខ្លះមាននៅក្នុងមៃត្រាយណព្រហ្មណោបនិស័ទ(មៃត្រ. ឧប. ជំពូក ៣ លេខ ៣,៥,៦ និងធៀបនឹងមនុ ជំពូក ១២ លេខ ៣២-៣៣)។ យ៉ាងណាមិញ សេចក្ដីលម្អិតដូចគ្នាឬ

ស្រដៀងគ្នា ស្របគ្នានឹងបុរាណ មហាភារតៈនិងស្មិតិ ពាក្យកាព្យមួយចំនួនទៀត ដែលបញ្ចូលគំនិតទស្សនវិជ្ជាជាមួយនឹងច្បាប់ពិសិដ្ឋ។ ការពិភាក្សាបន្តបន្ទាប់ស្តីពីកម្ម វិបាក ផលនៃអំពើបាប ដែលត្រូវទទួលនៅជាតិខាងមុខ ចំណុច vv. ៥១-៨១ ត្រូវគេដាក់ខុសកន្លែង។ ជាក់ស្តែងវាគួរតែនៅត្រង់ចំណុចចាប់ផ្តើមវគ្គស្តីពីការលាងបាប ដែលព្រះវិស្ណុនិងយាញ្ញាវល្ក្យ មាន ព្រះសូត្រ និងពាក្យកាព្យពាក់ព័ន្ធជាច្រើន។ ដូចយើងឃើញមានក្នុងទីតាំងខុសគ្នា នៅក្នុងមនុស្មិតិ គេទំនងជាបន្ថែមនៅពេលសរសេរស្នាដៃនោះឡើងវិញ។ ផ្នែកស្តីពីមធ្យោបាយ ដើម្បីសម្រេចបរមសុខដ៏កំពូល ចំណុច vv. ៨២-១០៤ សំដៅទៅរកសំណួរ ដែលបានពិភាក្សារួចហើយនៅជំពូកទី៤ និង ទី៦ ហើយមិនបានបន្ថែមអ្វីថ្មីនោះទេ។ ការបរិយាយដ៏វែងនៅចុង vv. ១១៦-១២៦ បានបង្កើតជាផ្នែកនៃធម៌សូត្រ ដោយហេតុថាជាថ្មីម្តងទៀតការរៀបរាប់នេះសំដៅដល់ទេវកថា ពាក់ព័ន្ធនឹងដើមកំណើតនៃសាស្ត្រៈដែលនិទានច្រើន ដោយមិនត្រឹមត្រូវនៅក្នុងជំពូកទី១។ ក៏ប៉ុន្តែសាច់រឿងមួយផ្នែកតូចស្តីពីរបៀបដោះស្រាយអង្គច្បាប់ដ៏គួរឱ្យសង្ស័យ ចំណុច vv. ១០៥-១១៥ ទំនងជាមានស្រាប់នៅក្នុងស្នាដៃច្បាប់ដើម។ សម្រាប់ជាសេចក្តីសន្និដ្ឋានបង្ហាញពីភាពស្របគ្នានឹងក្បួនច្បាប់នៃធម៌សូត្រ និងព្រឹត្តិការណ៍ដែលគោតម ក៏ដាក់សូត្រត្រូវគ្នា នៅខាងចុងនៃស្នាដៃរបស់គាត់។

ដូចនេះប្រសិនបើគេអាចនិយាយបានថា មាតិកាពាក្យកាព្យជាងពាក់កណ្តាលនៅក្នុងមនុស្មិតិរបស់យើងមិនអាចបានមកពីមានវៈធម៌សូត្របុរាណទេ យើងពេលនេះត្រូវប្រឈមមុខនឹងចំណោទបញ្ហាថាតើចាប់ពីកន្លែងណា ដែលមានការបន្ថែមយ៉ាងច្រើន។ គន្លឹះសម្រាប់ការដោះស្រាយបញ្ហានេះ បង្កើតឱ្យមានទំនាក់ទំនងពិសេសនៃមនុស្មិតិ ជាមួយនឹងមហាភារតៈ ដែលពិតជាស្នាដៃពាក្យកាព្យដ៏ចំណាស់បំផុតនៅក្នុងអក្សរសាស្ត្រឥណ្ឌា និងជាឃ្លាំងមួយដ៏ធំផ្ទុកនូវទម្រង់ដើមបំផុតនៃទេវកថា និងលទ្ធិទ្រឹស្តីក្រោយសម័យវេទ។ ទំនាក់ទំនងដែលមាននៅក្នុងស្នាដៃទាំងពីរនេះ និងសារៈសំខាន់របស់វាចំពោះប្រវត្តិវិទ្យាស្ថានមនុ ត្រូវបានទទួលស្គាល់ដោយអ្នកភាសាវិទូសំស្ក្រឹត ភាគច្រើន ដែលបានយកចិត្តទុកដាក់ចំពោះការពិនិត្យមើលដើមកំណើតនៃ *ស្មិតិ* ទី២។ ជាច្រើនឆ្នាំកន្លងមកសាស្ត្រាចារ្យ Weber( ប្រវត្តិអក្សរសាស្ត្រឥណ្ឌា ទំព័រ៣៧៩ និងធៀបជាមួយសាស្ត្រាចារ្យ Stenzler ក្នុងការសិក្សាអំពីឥណ្ឌា លេខ១ ទំព័រ ២៤៥ ) បានគូសបញ្ជាក់ថា មហាភារតៈ មានមិនត្រឹមតែការ ដកស្រង់មួយចំនួនចេញពីមនុ សម្រង់ខ្លះដែលគេឃើញមានភាពខុសគ្នាក៏មាន ឬមិនខុសគ្នាក៏ដោយនៅក្នុង ស្មិតិ ដែលមានស្រាប់ ចំណែកឯសម្រង់ខ្លះគ្មានប្រភពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកំណាព្យជាច្រើនមិនមាននៅក្នុងគម្ពីរ មនុ ដែលយ៉ាងណាក៏ដោយ ត្រូវគេដាក់បញ្ចូលក្នុងធម៌សាស្ត្រៈ។ គាត់បានទាញសេចក្តីសន្និដ្ឋានចេញពីហេតុការណ៍នានា ដែលមនុស្មិតិ មិនអាចមានតាមទម្រង់បច្ចុប្បន្នរបស់វា ថែមទាំងតាមសម័យកាលដែលជាកម្មសិទ្ធិស្នាដៃក្រោយរបស់មហាភារតៈទេ ហើយថាអ្នកនិពន្ធ ឬអ្នកសរសេរស្នាដៃក្រោយៗ ពិតជាបានដឹងនិងប្រើប្រាស់ការពិនិត្យកែសម្រួលគម្ពីរច្បាប់ពីមុនៗរបស់មនុ។ លោក Rao Saheb V.N. Mandlik( មយុខៈ និងយាញ្ញាវល្ក្យ *សេចក្តីណែនាំអំពីយញ្ញ* ទំព័រ xlvii ) ដែលមានជំនឿលើអ្នកកែសម្រួលក្រោយបានធ្វើសេចក្តីសន្និដ្ឋានមួយ ទៅលើស្នាដៃពីមុនៗ ដោយផ្អែកលើភាពស្របគ្នានៃស្លោកជាច្រើន ជា

ពិសេសនៅក្នុងបវ័នទី ១២ និងទី១៣ នៃមហាវីរកថា ដែលមានកំណាព្យមនុស្រ្មិតិ។ ដោយសារលោកសាស្រ្តាចារ្យ Hopkins( ក្បួនតម្រារបស់សង្គមបូព៌ាអាមេរិក ខែតុលា ឆ្នាំ១៨៨៣ ទំព័រxix–xx, និងព្រឹត្តិបត្រសង្គមបូព៌ាអាមេរិក លេខ ១១ ទំព័រ ២៥៧វគ្គបន្ត ) បានធ្វើការវិភាគយ៉ាងប្រុងប្រយ័ត្នអំពីសេចក្តីដកស្រង់ពីមនុ ដែលមាននៅក្នុងមហាភារតៈ។ យោងតាមលោកសាស្រ្តាចារ្យលេខសម្រង់គឺ៣៣ ក្នុងនោមានចំនួន១៧ អាចមានប្រភព, ៥ ជាសម្រង់ពាក្យសម្តី ក្រៅពីនេះ មានភាពស្របគ្នាតែផ្នែកលទ្ធិប៉ុណ្ណោះ។ ការបកស្រាយរបស់លោកចំពោះការដកសម្រង់ដែលគ្មានប្រភព គឺមិនមានន័យថា សេចក្តីដកស្រង់នោះ ត្រូវគេដកចេញពីអត្ថបទដើមនៃមនុស្រ្មិតិទេ ប៉ុន្តែគឺថា ពាក្យភាសិតមិនលាយលក្ខណ៍អក្សរបស់មនុ សាយភាយជាទូទៅ ភាសិតខ្លះត្រូវគេប្របាច់បញ្ចូលជាមួយធម៌សូត្ររបស់មហាភារតៈ នៅពេលមានការកែសម្រួលឡើងវិញ ចំណែកឯភាសិតខ្លះទៀតមិនមានទេ។ គាត់ក៏កត់សម្គាល់ឃើញហេតុការណ៍ថា មនុសម្រិត របស់យើង មានពាក្យកាព្យជាច្រើនដែលមាននៅក្នុងមហាភារតៈ ដោយមិនមាននៅក្នុងមនុទេ ព្រមទាំងមានភាសិតខ្លះមានប្រភពផ្សេងទៅវិញ។ ភាពខុសគ្នាទាំងអស់នៅក្នុងស្នាដៃរបស់អ្នកជំនាន់មុន បង្ហាញយ៉ាងច្បាស់ថា មហាភារតៈគឺជាការរំពឹងមួយ សម្រាប់ផ្តល់ជំនួយខ្លះជាដំណោះស្រាយបញ្ហារបស់យើង។ ក៏ប៉ុន្តែពួកគេក៏ចង្អុលបង្ហាញថា ការប្រើប្រាស់ហេតុការណ៍ដែលមានស្រាប់ គួរមានការប្រុងប្រយ័ត្នខ្លះ។

ក្នុងការស្រាវជ្រាវរកទំនាក់ទំនងនៃស្នាដៃពីរ និងការពឹងផ្អែកលើប្រវត្តិនៃអត្ថបទមនុរបស់យើង ចំណុចទី១ដែលត្រូវស្វែងរក គឺថាតើមហាភារតៈពិតជានិយាយពីសៀវភៅច្បាប់របស់មនុ ហើយតើស្នាដៃនេះដូចគ្នានឹងធម៌សូត្រសម័យដើមក៏មាន ឬដូចគ្នានឹងស្រ្មិតិដែលមានស្រាប់ក៏មាន ឬក៏មានភាពខុសគ្នាទាំងពីរ។ យោងតាមអ្វីដែលបាននិយាយខាងលើ ពាក់ព័ន្ធនឹងជំនឿពីដើមដែលសំអាងលើការយល់ព្រមរបស់ស្ថាប័នសង្គម និងសាសនាចំពោះបិតាមនុស្សជាតិ និងអត្ថន័យពិតប្រាកដនៃឃ្លា "ដូចនេះ ព្រះមនុបានបញ្ចេញព្រះបន្ទូល"។ ជាក់ស្តែងគឺថា សាស្រ្តាចារ្យ Hopkins បានវែកញែកយ៉ាងត្រឹមត្រូវ ឱ្យដាច់ពីគ្នារវាងភាសិតរបស់មនុស្តីពីបញ្ហាសាសនានិងនីតិ និងសៀវភៅច្បាប់របស់គាត់ ហើយថាគាត់យល់ត្រូវក្នុងការមិនទទួលស្គាល់សម្តីរៀបរាប់ឈ្មោះរបស់មនុ ដែលសំអាងលើស្រ្មិតិរបស់គាត់ទេ។ ហេតុដូចនេះចំនួនវគ្គដែលមានប្រយោជន៍សម្រាប់ការប្រៀបធៀប ត្រូវបានកម្រិតតឹងរ៉ឹងណាស់។ វគ្គទាំងឡាយ ដែលលើកឡើងលម្អិតពីសាស្រ្តារបស់មនុ ពិតជាភ័ស្តុតាងមិនអាចប្រកែកបាន។ ការវាយតម្លៃសេចក្តីផ្សេងទៀត ត្រូវពឹងផ្អែកលើព្រឹត្តិការណ៍ពាក់ព័ន្ធ។ ការដកស្រង់ស្នាដៃពីមុនមិនមានច្រើននៅក្នុងមហាភារតៈទេ។ យ៉ាងណាមិញ សម្រង់ខ្លះមាននៅក្នុងបវ័នទី១២ និងទី១៣ ហើយពួកគេបង្ហាញយ៉ាងច្បាស់ថា អ្នកនិពន្ធសៀវភៅទាំងអស់នេះបានដឹងថា មានវៈធម៌សូត្រ មិនដូចគ្នាទេ ប៉ុន្តែមានទំនាក់ទំនងជិតស្និទ្ធជាមួយស្រ្មិតិរបស់យើង។ ដូច្នេះ យើងអាន មហ. ជំពូក ១២ លេខ ៥៦, ២៣-២៥ ដែលរៀបរាប់អំពីអំណាចរបស់មហាភារតៈ "ព្រះមនុ ដែលប្រកាន់ខ្ជាប់នូវគោលការណ៍សីលធម៌ដ៏ខ្ពង់ខ្ពស់ ឱ! ស្តេចនៃព្រះមហាក្សត្រ បានច្រៀងស្លោកពីរនៅក្នុងច្បាប់របស់ទ្រង់ (ស្វេសុ ធម៌េសុ) ឱ ជាកូនចៅរបស់គុរុ ឯងគួរចងចាំក្នុងចិត្តរបស់ឯង(២៣)។ ភ្លើងចេញមកពីទឹក

ក្សត្រិយ៍ចេញពីព្រាហ្មណ៍ ដែកចេញពីថ្ម អំណាចទាំងអស់ដែលអាចកម្ចាយអង្គទាំងបី គ្មានប្រសិទ្ធភាពទេ នៅពេលគេបង្កើតវាឡើង(២៤)។ ពេលដែកវាយថ្ម ពេលភ្លើងជួបទឹក ពេលក្សត្រិយ៍សម្តែងអរិភាពចំពោះព្រាហ្មណ៍ នោះគូប្រយុទ្ធទាំងបីនេះនឹងវិនាសហើយ។" ក្រៅពីនេះ មហ. ជំពូក ១៣ លេខ ៤៦, ៣០-៣៦ ក្នុងការពិភាក្សាអំពីបុព្វសិទ្ធិភរិយាព្រាហ្មណីនៃព្រាហ្មណៈ ដែលយើងបានដឹងជាមនុស្សតែម្នាក់គត់ដែលមានសិទ្ធិយកចិត្តទុកដាក់ស្វាមីរបស់នាង និងជួយស្វាមីក្នុងការបំពេញករណីយកិច្ចសាសនារបស់គាត់។ ជាសន្និដ្ឋានគឺថា "ហើយតាមគោលការណ៍ទាំងអស់ ដែលព្រះមនុបានប្រកាស (មនុនាភិហិតំ សាស្ត្រំ) ឱ មហារាជ ដែលបន្តសែស្រឡាយពីគុរុ គឺផ្អែកលើច្បាប់ អមតៈដូចគ្នា(៣៥)។ ពេលនេះ បើ(មនុស្ស) ដែលគ្មានសេចក្តីស្រឡាញ់ ដើរតួផ្សេងទាំងស្រុង ឱ!យុធិស្ថិរៈ ជាមនុស្ស (គួរឲ្យស្អប់) ជាកាណ្ឌាល (ចេញពី)ព្រាហ្មណៈ(វណ្ណៈ ៣៦)។" គ្មានអ្វីច្បាស់ជាងសេចក្តីទាំងពីរនេះទៀតទេ។ សម្រង់ទី២ និយាយយ៉ាងច្បាស់អំពីសាស្ត្រដែលមនុបានប្រកាសសម្តែងឱ្យដឹង ហើយសម្រង់ទី១នៃធម្មារបស់មនុ ជាពាក្យពហុវចនៈ ដែលមានន័យជាទូទៅសំដៅដល់សៀវភៅស្តីពីច្បាប់ពិសិដ្ឋ។ ម្យ៉ាងទៀត សម្រង់ទី២ ពិតជាបកស្រាយនូវគម្ពីរមនុ ជំពូក ៩ លេខ ៨៧ និងចម្លងបន្ទាត់ទី២របស់មនុ ឱ្យទៅជាអក្សរចារឹក។ ក្នុងចំណោមពាក្យកាព្យពីរឃ្លះ ដែលស្រង់នៅក្នុងសម្រង់ទី១ ឃ្លះមួយស្របនឹងគម្ពីរមនុ ជំពូក ៩ លេខ ៣២១ ប៉ុន្តែឃ្លះមួយទៀត មិនអាចរកប្រភពឃើញទេ។ ចំណែកឯសម្រង់ទាំងពីរនេះ ហាក់ដូចជាបង្ហាញទំនាក់ទំនងជាប់ពាក់ព័ន្ធច្រើន រវាងមានវៈសាស្ត្ររបស់មហាភារតៈ និងស្ម្រិតិរបស់យើង ទី៣ ស្រង់ចេញពីរាគធម្មរបស់មនុប្រាកេតស ពោលគឺស្រង់ពីផ្នែកស្តីពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ដែលជារបស់មានវៈ(សូម្បីតែខ្ញុំមិនបដិសេធថា ការបង្ហាញអំណះអំណាងខ្លះអាចជាការស្មានមួយដែលថា រាគធម្មរបស់មនុប្រាកេតស ជាស្នាដៃមួយផ្សេងពីសាស្ត្រដែលមាននៅក្នុងសម្រង់ខាងដើម ព្រោះថាការដាក់ពាក្យប្រាកេតស នៅទីនេះ ត្រូវគេបន្ថែមទៅលើឈ្មោះរបស់មនុ ហើយដោយសារនៅក្នុងមហ. ជំពូក ១២ លេខ ៣៨, ២ យើងរកឃើញមនុប្រាកេតស ជាឈ្មោះអ្នកនិពន្ធ រាគសាស្ត្រ នៅជាមួយព្រឹហស្បតិ និងឧសនៈ ដែលអាចជាស្នាដៃនីតិសាស្ត្រ ខ្ញុំមិនទាន់ហ៊ានថាមិនជឿនោះទេ។ ចំពោះរឿងព្រេងស្តីពីដើមកំណើតរបស់អ្នកផ្តល់ច្បាប់នេះ មនុមានភាពខុសគ្នានៅក្នុងមហាភារតៈ។ នៅក្នុងវគ្គផ្សេងទៀត ជួនកាលគេ ហៅ *មនុ* ថាស្វាយម្ភូវៈ ហើយជួនកាល (ឧ.ទា. ជំពូក ១២ លេខ ៣៩៤, ៥១)ថា *វៃវស្វតៈ*។ ជាងនេះទៅទៀត នីតិសាស្ត្រមួយផ្សេងរបស់*មនុ* មិនត្រូវគេដកស្រង់នៅកន្លែងផ្សេងទេ។ ម្យ៉ាងទៀត ផ្នែកស្តីពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ មានចំណងជើង*រាគធម្មៈ* នៅគ្រប់សៀវភៅច្បាប់ និងការអត្ថាធិប្បាយមនុស្ម្រិតិរបស់យើង និយាយឈ្មោះនេះនៅជំពូកទី៧។) មានចំណុចមិន ស្របគ្នាយ៉ាងច្រើន។

យើងអាន មហ.ជំពូក ១២ លេខ ៥៧, ៤៣-៤៥ថា "*មនុប្រាកេតសៈ* សូត្រ(សំណៅដើម មានពាក្យ *ឧទាហ្រិតោ* ដែលមានន័យមិនច្បាស់ ហើយក៏អាចមានន័យ "ដកស្រង់"។)កំណាព្យពីរឃ្លះខាងក្រោម នៅក្នុងនីតិសម្រាប់ព្រះមហាក្សត្រិយ៍ ចូរស្តាប់កំណាព្យដោយយកចិត្តទុកដាក់ ឱ បពិត ព្រះមហាក្សត្រិយ៍!(៤៣)។ មនុស្សគួរតែបោះចោលដូចជានាវាដែលកំពុងលិចចុះក្នុងសមុទ្រ ចំពោះគ្រូបង្រៀនដែលមិនព្រមបង្ហាត់បង្រៀន អាចារ្យដែលមិនចេះសូត្រគម្ពីរវេទ ស្តេចដែលអាចផ្តល់ការការពារ ភរិយាបង្ករឿង អ្នកគង្វាលដែលចូលចិត្តនៅតែក្នុងភូមិ និងជាងកាត់សក់ដែលចូលចិត្តតែនៅក្នុងព្រៃ"។ គ្មានកំណាព្យណាមួយក្នុងចំណោមកំណាព្យទាំងអស់នេះ មាននៅក្នុងសៀវភៅមនុរបស់យើងទេ សូម្បីកំណាព្យក្រោយនេះហ៊ានរិះគន់ស្តេច ដែលមិនការពារប្រជារាស្ត្ររបស់ទ្រង់ (ជំពូក៧ លេខ១៤៣-១៤៤)។

បើយើងត្រឡប់ទៅមើលសេចក្ដីនៅក្នុង*មនុ* គឺមិនមែននៅក្នុងសាស្ត្រៈទេ ដែលចាត់ជាប្រភពមួយដ៏គួរឱ្យជឿជាក់ ដែលខ្ញុំដឹងថាជាប្រភពតែមួយគត់ ដែលគេអាចជឿថាមានសំអាងសៀវភៅច្បាប់មួយ។ នៅក្នុងសកុន្តលូបាខ្យាន សៀវភៅ មហ.ជំពូក១ លេខ ៧៣, ៨-១៣ ព្រះរាជាទុស្សន្ត ព្យាយាមបញ្ចុះបញ្ចូលអ្នកដែលមានចិត្តស្នាក់ស្នើរចង់ជំទាស់ នឹងការសព្វព្រះរាជហឫទ័យរបស់ទ្រង់ឱ្យយល់ចូលក្នុងសមាគមគាន្ធាវៈតាមរយៈការពិភាក្សាច្បាប់អាពាហ៍ពិពាហ៍។ ព្រះអង្គដំបូងមានព្រះបន្ទូលសង្ខេបអំពីចំនួនពិធីអាពាហ៍ពិពាហ៍ (v.៨a) និងឈ្មោះពិធី(vv. ៨b-៩a) តាមរបៀបដូចគ្នានឹងគម្ពីរមនុ ហើយបន្ទាប់មកថា "ចូរសិក្សាក្នុងចំណោមពិធីសាសនាទាំងអស់នោះ(វ៉ីតី) ពីព្រោះមនុ ស្វាម្ភូវ បានប្រកាសតាំងពីដើមកថា ពិធីបួនដំបូង ជាពិធីស្របច្បាប់ ហើយពួកព្រាហ្មណៈគួរតែទទួលប្រតិបត្តិ។ ដឹងទេ ឱ ជាពិធីដែលគ្មានកំហុសសោះ ហើយប្រាំមួយទៀត ស្របតាមលំដាប់របស់វា សុទ្ធតែត្រឹមត្រូវតាមច្បាប់សម្រាប់មហាក្សត្រិយ៍(៩b-១០)។ ក៏ប៉ុន្តែរាក្សសៈក៏តម្រូវឱ្យមនុស្សពួកវណ្ណៈ ខត្តិយវង្សគោរព ហើយពិធីអាសុរៈគឺសម្រាប់ពួកវៃស្យៈនិងសូទ្រៈ។ ប៉ុន្តែក្នុងចំណោមពិធី៥(ចុង ក្រោយ) មានពិធី៣ គេប្រកាសថាស្របច្បាប់ ហើយ២មិនស្របច្បាប់ (v.១១)។ (ពិធី) បៃសាកៈនិងអាសូរៈគេមិនដែលប្រើទេ។ យោងតាមក្បួនច្បាប់នេះ (អាពាហ៍ពិពាហ៍) គេត្រូវតែគោរព នេះជាមាគ៌ាករណីយកិច្ច (v.១២)។ សូមកុំសួរអំពីភាពស្របច្បាប់នៃ(ពិធី)គាន្ធាវ និងរាក្សសៈសម្រាប់មហាក្សត្រិយ៍។ មិនចាំបាច់សង្ស័យទេ គេអាចប្រើពិធីទាំងនេះ ដោយឡែកពីគ្នាក៏បាន ឬលាយបញ្ចូល គ្នាក៏បាន" (v.១៣)។

ភាពស្របគ្នាពាក្យសម្ដីបន្ថែមនៃវគ្គនេះ ម្យ៉ាងស្របជាមួយនឹងសៀវភៅមនុ ជំពូក ៣ លេខ ២០-២៦ និងភាពផ្សេងគ្នាទាំងស្រុងពីផ្នែកលទ្ធិ ធ្វើឱ្យខ្ញុំអាចគិតបានថា វាជាការបកស្រាយ ឬការកែសម្រួលផ្នែកមួយនៃមានវៈធម៌សាស្ត្រៈ ដែលដូចគ្នាច្រើន តែមិនសូវដូចគ្នានឹងអត្ថបទដែលមានស្រាប់នោះទេ។ កាព្យលេខ ៨b-៩b មានន័យត្រង់ស្របនឹងសៀវភៅមនុជំពូក ៣ លេខ ២១ និង vv. ១១b-១៣ ស្រដៀងគ្នានឹងមនុ ជំពូក ៣ លេខ ២៥-២៦។ ប៉ុន្តែយ៉ាងណាមិញ vv. ៩b-១១a សូម្បីវាមានភាពដូចគ្នានឹង មនុជំពូក ៣ លេខ ២៣-២៤ក្ដី ក៏មានភាពខុសគ្នាច្រើនផ្នែកលទ្ធិ។ ព្រោះថា មនុប្រកាស(v. ២៣)ថា ពិធី៦ដំបូង មានលក្ខណៈត្រឹមត្រូវតាមច្បាប់សម្រាប់ពួកព្រាហ្មណៈ ពិធី ៤ បន្ទាប់សម្រាប់ពួកក្សត្រិយ៍ ហើយ ៤ ដដែលនេះ លើកលែងតែពិធីរាក្សសៈ គឺសម្រាប់ពួកសូទ្រៈ និងវៃស្យៈ ចំណែកឯ v. ២៤ និយាយថា ពិធី ៤ដំបូង ជាការផ្ដែផ្ដាំ និងថា ពិធីរាក្សសៈ អនុញ្ញាតសម្រាប់តែពួកក្សត្រិយ៍ ហើយពិធីអាសុរៈ សម្រាប់វណ្ណៈពីរទាបបំផុត។ ម្យ៉ាងវិញទៀត យោងតាមមហាភារតៈ ព្រះមនុអនុញ្ញាតឱ្យមានពិធី ៤ដំបូង សម្រាប់ពួកព្រាហ្មណៈ និង ៦ដំបូងសម្រាប់ពួកក្សត្រិយ៍។ សម្រាប់ពួកក្សត្រិយ៍ ព្រះមនុក៏អនុញ្ញាតឱ្យធ្វើពិធីទី៧ គឺរាក្សសៈ ហើយបានកំណត់ឱ្យពួកវៃស្យៈ និងសូទ្រៈ ត្រូវជាវកូនក្រមុំរបស់ពួកគេ គឺធ្វើពិធីអាសុរៈ។ ការបកស្រាយដែលគួរឱ្យជឿបាននូវចំណុចផ្ទុយគ្នានេះ ញ៉ាំងឱ្យខ្ញុំ ហាក់ដូចជាអាចសន្មតបានថា អត្ថបទរបស់មនុ ដែលគេស្គាល់ថាជារបស់អ្នកនិពន្ធឧបាខ្យានៈ ខុសគ្នាបន្តិចបន្តួចពីអត្ថបទ ដែលយើងឃើញបច្ចុប្បន្ន។

វគ្គមួយទៀត កាន់តែគួរឱ្យសង្ស័យ។ មហ. ជំពូក ១៣ លេខ ៦១, ៣៤-៣៥ គេបានរៀបរាប់មតិនានា ស្របតាមសំណួរថា ព្រះមហាក្សត្រិយ៍មានចំណែកទោសធំយ៉ាងណា ចំពោះការមិនបានផ្តល់ការការពារ និងការគ្រប់គ្រងប្រជារាស្ត្រឱ្យបានត្រឹមត្រូវ(...សំស្រ្កឹត...)។យោងតាមការប្រៀនប្រដៅរបស់មនុ ការសម្រេចគឺថាអ្នកដឹកនាំដែលធ្វេសប្រហែសត្រូវទទួលទោសទម្ងន់ទោសថ្នាក់ទីបួន។ ពាក្យប្រៀនប្រដៅ ដែលមាននៅក្នុងវគ្គផ្សេងៗទៀតរបស់មហាភារតៈ ផ្ទុយពីការបង្រៀននៅក្នុងមនុស្រ្មិតិរបស់យើងព្រមទាំងនៅក្នុងធម៌សូត្រពីមុន ដែលផ្នែកទី៦ នៃអំពើបាប ដែលអ្នកក្រោមឱវាទបានប្រព្រឹត្តត្រូវដាក់ទោសទៅលើចៅហ្វាយនាយរបស់ពួកគេ។ ព្រឹត្តិការណ៍ដែលមានមតិផ្ទុយជាច្រើន អាចត្រូវគេប្រើជាអំណះអំណាងនៅទីនេះផងដែរថា គេយោងទៅលើសៀវភៅច្បាប់មួយរបស់ព្រះមនុដែរ។ បើមានដូច្នោះមែន សេចក្តីនោះនឹងស្តែងឱ្យឃើញនូវភាពខុសគ្នា គួរឱ្យកត់សម្គាល់មួយទៀតរវាងអត្ថបទចាស់និងអត្ថបទថ្មី។ ប៉ុន្តែតាមការគិតរបស់ខ្ញុំ មូលហេតុគឺដោយសារការបង្រៀនរបស់ព្រះមនុ យើងស្របនឹងធម៌សូត្រ ដែលហាក់ដូចជាអ្នកនិពន្ធមហាភារតៈអះអាងត្រង់ចំណុចនេះ ដូចជាក្នុងករណីផ្សេងដែរថា ជាការហៅឈ្មោះព្រាវសំដៅឈ្មោះរបស់មនុគ្រាន់តែ ដើម្បីបន្ថែមទម្ងន់ទៅលើមតិយោបល់ណាមួយរបស់គេប៉ុណ្ណោះ។

មានវគ្គពីរដ៏វែងនៅក្នុងមហាភារតៈដែលសំអាងទៅលើគម្ពីរមនុ។ ក្នុងករណីមួយស្តែងឱ្យឃើញច្បាស់ណាស់ថា គ្មានទំនាក់ទំនងជាមួយនឹងស្រ្មិតិរបស់យើងទេ។ ការសន្ទនាបែបទស្សនវិជ្ជារវាងព្រះមនុ និងព្រះព្រិហស្បតិ ដែលមានច្រើនវគ្គពី២០០-២០៦នៅក្នុង មហ.ជំពូក១២ មិនមានពាក្យប្រៀនប្រដៅផ្សេងគ្នា ហើយក៏គ្មានពាក្យកាព្យណាមួយស្របគ្នានឹងមានវៈធម៌សាស្រ្តៈទេ។ ផ្ទុយទៅវិញការសន្ទនានេះ មានទំនោរទៅរកគោលជំនឿរបស់ព្រះវៃស្ណវៈ។ បើនិយាយពីវគ្គទី២ មហ.ជំពូក ១២ លេខ ៣៦, ៣-៥០ ចំណុចសង្ស័យមានតិចបំផុត។ មានរឿង "និទានបុរាណ"មួយ (បុរាណៈឥតិហាសៈ) ដែលពណ៌នាអំពីរបៀបដែលព្រះមនុបានលាតត្រដាងច្បាប់តាំងពីដើម រហូតដល់ពួកបណ្ឌិត និយាយពីអាហារ និងក្បួនច្បាប់ផ្សេងៗមួយចំនួន ពាក់ព័ន្ធនឹងអ្នកទទួលអំណោយដ៏សមគួរការសិក្សាពីវេទ និងការលាងបាប។ សម្តីរបស់ព្រះមនុ មានកាព្យ ៤៥ល្បះ ក្នុងមាន ២ល្បះស្របគ្នាទាំងស្រុង ហើយ៥ ស្របគ្នាជាមួយនឹងស្លោកនៃស្រ្មិតិរបស់យើង(មហ. ជំពូក ១២ លេខ ៣៦, ២៧ = មនុ ជំពូក ៤ លេខ ២១៨, គឺ បាទទី១ នៃកាព្យ ២៨a = បាទទី១ នៃមនុ ជំពូក ៤ លេខ២២០; កាព្យ ២៨b= មនុ ជំពូក ៤ លេខ ២១៧; បាទទី១ នៃកាព្យ ២៩a = បាទទី១ នៃមនុ ជំពូក៤ លេខ២១០b; កាព្យ ៤៦ = មនុ ជំពូក ២ លេខ ១៥៧; កាព្យ ៤៧a = មនុ ជំពូក ២ លេខ ១៥៨a។) ។ ក៏ប៉ុន្តែ កាព្យមួយក្នុងចំណោមកាព្យដែលដូចគ្នាទាំងស្រុង (v. ៤៦) ក៏មាននៅក្នុងធម៌សូត្រពីរ ហេតុនេះជារបស់ច្បាប់ បុរាណរបស់សាលាវេទ។ ដ្បិតតែកាព្យដទៃទៀត គ្មានប្រភពនៅក្នុងស្នាដៃពីមុនក្តី ក៏ខ្ញុំគិតថាមានភាពដូចគ្នាខ្លះ គឺថា មហាភារតៈអាចជាកាព្យមនុ ដែលពេលនេះមាននៅក្នុងស្រ្មិតិរបស់យើង ជាជាងថា អ្នកនិពន្ធបានដកស្រង់វា ជាផ្នែកមួយទាំងមូលចេញពីមានវៈសាស្រ្តៈ។

អ្វីក៏ដោយឱ្យតែជាការបកស្រាយត្រឹមត្រូវនូវសម្តីរបស់មនុ ក្នុងសេចក្តីទាំងអស់នេះ ប្រាកដជាមិនអាចប្រកែកបានទេថា អ្នកនិពន្ធបវ៌ទី ១ ទី១២ និងទី១៣ នៃមហាភារតៈ ពិតជាចេះ មានវធម៌

សាស្ត្រៈដែលមានទំនាក់ទំនងច្រើនជាមួយគ្នាប៉ុន្តែ មិនដូចគ្នានឹងអត្ថបទដែលមានស្រាប់ទេ។ ហេតុដូច្នេះ អត្ថបទក្រោយ ដូចលោកសាស្ត្រាចារ្យ Weber បានគូសបញ្ជាក់ស្រាប់ ត្រូវក្រោយមក គេចាត់ជា "ផ្នែកចុងក្រោយនៃវីរកថា"។ សម្រាប់ខ្ញុំ សេចក្ដីសន្និដ្ឋានក្រោយនេះ ដែលមានសញ្ញាណមួយចំនួន នៅក្នុងស្មិតិ មានចំណុចស្របគ្នាជាមួយនឹងមហាភារតៈ។ ការព្រមានពាក់ព័ន្ធនឹងផលវិបាកនៃការលេងល្បែង មនុ ជំពូក ៩ លេខ ២២៧ ប្រាកដជាសន្មតជាមុននូវការចេះចាំរឿងព្រេងរបស់គុរុ និងបាណ្ឌវៈ។ ពេលដែលចំណុចនោះបញ្ជាក់ថា "នៅក្នុងកប្បពីមុន ការប្រព្រឹត្តអបាយមុខល្បែង ជាការបង្កើតអរិភាពយ៉ាងខ្លាំង" អំណះអំណាងនេះអាចចង្អុលបង្ហាញតែតួយ៉ាងទី១ ស្ដីពីការប្រយុទ្ធគ្នារវាងយុធិស្ថិរ និងទុរ្យូធន ដែលជាការបង្កឱ្យមានសង្គ្រាមដ៏ធំមួយភ្លាម។ ដូចអ្នកអត្ថាធិប្បាយខ្លះគិតថាចំណុចនេះក៏អាចមានន័យសំដៅដល់ជោគវាសនារបស់ស្ដេចនាលៈ ប៉ុន្តែអាចមានន័យទី២ថាសង្គ្រាមមិនមែនបណ្ដាលមកពីការលេងល្បែងរបស់ទ្រង់ទេ។ សំខាន់ជាងន័យនេះទៅទៀត ការពិតគឺថា នៅក្នុងជំពូកទី ៧-១០ នៃមនុស្មិតិ រឿងព្រេងជាច្រើន ត្រូវបានដកស្រង់ដើម្បីបង្ហាញ ឬគាំទ្រក្បួនច្បាប់ដែលដូចអ្នកអធិប្បាយអះអាងដដែលៗថា(១មើលសេចក្ដីអធិប្បាយជំពូក ៧ លេខ ៤១, ជំពូក ៨ លេខ ១១០, ជំពូក ៩ លេខ ២៣, ១២៩, ៣១៤-៣១៥ និងបន្តបន្ទាប់) ដកចេញពីមហាភារតៈ ហើយថានៅក្នុងករណីមួយដែលគេបានអះអាងនៅកាព្យមួយនៃមនុ (ជំពូក៩ លេខ៣១៤) ទំនងជាដូចគ្នានឹងជំពូកដដែលនៃមហាភារតៈ។

ជំហរមិនប្រាកដនៃស្នាដៃពីរនេះ អាចញ៉ាំងឱ្យយើងសន្មតតាម រ៉ៅ សាហិប វ.ន. មណ្ឌលិក ថា មហាភារតៈ មានឥទ្ធិពលផ្ទាល់ទៅលើការពិនិត្យកែសម្រួលចុងក្រោយនៃមនុស្មិតិ ហើយថា អ្នកនិពន្ធអត្ថបទក្រោយនេះ សម្របតាមស្នាដៃដើមនូវកំណាព្យដូចគ្នាជាច្រើន ដែលនៅក្នុងមហាភារតៈ មិនសំអាងដល់មនុទេ។

ការធ្វើសម្មតិកម្មដោយផ្អែកស្មិតិទៅលើទេវកថា គឺជាការពិនិត្យយ៉ាងប្រុងប្រយ័ត្ននូវសេចក្ដីពាក់ព័ន្ធ ដែលនាំឱ្យមានលទ្ធផលផ្សេងគ្នា ដោយសារតែសម្មតិកម្មនោះចាត់ទុកជារបស់ខ្លួននូវមាត្រាដ្ឋានអនុស្តុភ នៅក្នុងស្នាដៃក្រោយ។ បើពិនិត្យមើលបវ៌នទី៣ ទី១២ និងទី១៣ នៃមហាភារតៈ ខ្ញុំបានសម្រេចរកឱ្យឃើញនូវកាព្យចំនួន ២៦០ល្បះឬផ្នែកនៃល្បះ ដែលមិនមែនជារបស់មនុ ដោយធៀបនឹងស្លោករបស់មនុស្មិតិ។ តួលេខដែលពាក់ព័ន្ធប្រមាណជាមួយភាគប្រាំនៃស្នាដៃក្រោយ នឹងត្រូវបំប៉ោងយ៉ាងខ្លាំង តាមរយៈការប្រៀបធៀបផ្នែកដទៃទៀតទាំងអស់នៃវីរកថា ហើយអាចនិយាយថាសូម្បីនៅក្នុងបវ៌នដែលមានចំណុចដូចគ្នាខ្លះ ក៏អាចគេចផុតពីការកត់សម្គាល់របស់ខ្ញុំ។ ចំនួនល្បះដែលត្រូវប្រៀបធៀបគឺមានច្រើន ដូច្នេះកំហុសឆ្គងងាយស្រួលនឹងកើតមានណាស់ ក៏ប៉ុន្តែការវែកញែកពិតជាគ្រប់គ្រាន់សម្រាប់ការបង្ហាញទំនាក់ទំនងរវាងស្នាដៃទាំងពីរ។ សេចក្ដីពាក់ព័ន្ធខុសគ្នាយ៉ាងច្រើនពីបាទមួយឬពីបន្ទាត់មួយ ទៅ២០ផ្នែក រហូតដល់៤០ល្បះ។ ចំណុចកាន់តែច្រើន ដែលស្របគ្នា គឺជាការកម្រណាស់ថា កំណាព្យ៦ ទៅ ៧ល្បះ ស្ថិតក្នុងលំដាប់ជាមួយគ្នាក្នុងស្នាដៃទាំងពីរ ហើយមិនកម្រទេថា ស្លោកដូចគ្នាជាច្រើន ត្រូវកាត់ដោយការបរិយាយពង្រីកល្បះមួយទៅជាពីរ ឬដោយបង្រួញល្បះ

ពីរឱ្យទៅជាមួយ។ ម្យ៉ាងវិញទៀត គោលបំណងដែលរកល្បះ ឬបន្ទាត់ដូចគ្នា ជួនកាលមានការប្រែប្រួល ហើយពេលខ្លះការអានដោយឡែកពីគ្នា ធ្វើឱ្យអារម្មណ៍អានប្រែប្រួលទាំងស្រុង។ ការអានផ្សេងគ្នាមានចំនួនច្រើនហួសហើយការអានមួយដ៏ល្អជួនកាលមាននៅក្នុងស្នាដៃមហាភារតៈហើយជួនកាលនៅក្នុងអត្ថបទមនុ។ បើសិនជាយើងជាប់ជំពាក់ក្នុងការវិភាគឱ្យកាន់តែលម្អិតអំពីចំនួនវគ្គពាក់ព័ន្ធមានករណីបីដែលក្នុងមួយជំពូក ឬពីរជំពូកជាប់គ្នា មានល្បះពី២០ ទៅ៤០ ដែលមាននៅក្នុងអត្ថបទមនុ។ មហ. ជំពូក ១២ លេខ២៣២-២៣៣ មានការរៀបរាប់យ៉ាងច្រើន របស់ក្រិគុអំពីការបង្កើត ហើយល្បះមួយចំនួនក្នុងនោះ បញ្ជាក់ថា ថ្លែងដោយព្រះមនុផ្ទាល់ អំពីប្រធានបទដូចគ្នា ឧ.ទា. មនុ ជំពូក ១ លេខ ១៨b, ២០, ២៨-២៩, ៦៤-៧៨, ៨១-៨៦។

យ៉ាងណាមិញ មហ.ជំពូក ១៣ លេខ ៤៨, ១៤-៤៤ ផ្តល់និយមន័យរបស់មនុអំពី និងក្បួនច្បាប់ពាក់ព័ន្ធនឹងវណ្ណៈលាយឡំ ហើយមានកំណាព្យជំពូក ១០លេខ ២៧-៣២, ៣៣a, ៣៤-៣៧, ៣៨a, ៣៩-៤០,៥០,៥២b, ៥០-៦០ និង៦២ ដែលមានការប្រែប្រួលខ្លាំង ហើយស្លោក ដែលប្រដូចនឹងមនុ ជំពូក ១០ លេខ ៤២-៤៣ ឃើញមាននៅក្នុងមហ. ជំពូក១៣ លេខ ៣៣, ២១-២២ និង ៣៥, ១៧-១៨។

ទីបំផុត មហ.ជំពូក ១២ លេខ ១៦៥ ដែលរៀបរាប់អំពីអំណោយ ការបូជា និងការលាងបាបមានលំនាំដូចគ្នានឹងជំពូកទី១១ នៃមនុបង្ហាញច្រើនបំផុតនៅចំណុចផ្តើមល្បះបន្តបន្ទាប់ ដែលខ្លះមានអត្ថបទ ផ្សេងគ្នា គឺជំពូក ១១ លេខ ២b, ៣b, ៤a, ៧, ១១-១៧, ២០, ២២b, ២៣a, ២៧a, ២៩-៣១, ៣៤-៤០, ៩១b, ១០៥, ១៥០, ១៧៧b, ១៨១, ២០៧ ជាដើម។ ន័យទូទៅនៃស្លោកមួយចំនួនទៀត មិនមានពាក្យពេចន៍ស្របគ្នាពិតប្រាកដ ហើយជំពូកដដែលនៃ មហ. ក៏មាន vv. ៣១a និង ៣២a, បីភាគបួននៃមនុ ជំពូក ២ លេខ ២៣៨ និង v. ៦៨a ពាក់កណ្តាលទី១ នៃមនុ ជំពូក ៣ លេខ ១៧២។ យើងត្រូវរកក្នុងទំហំដូចគ្នានៅអត្ថបទមនុ ជំពូក ១១ លេខ ៤៤, ៧៤, ៧៦a, ៧៧, ៨៤ ដោយធៀបនឹងមហ. ជំពូក ១២ លេខ ៣៤, ២; ៣៥, ៤-៦; ២៦៣, ៤៥b-៤៦a។ ក្នុងចំណោមវគ្គពាក់ព័ន្ធជាច្រើនទៀត ចំណុចខាងក្រោម ជាចំណុចដែលគួរឱ្យកត់សម្គាល់ជាងគេ។ ផ្នែកនៃការពិភាក្សាអំពីការគោរពចំពោះឪពុកម្តាយ និងគ្រូអាចារ្យ មនុ ជំពូក ២ លេខ ២២៩-២៣៤ មាននៅក្នុងមហ. ជំពូក ១២ លេខ១០៨, ៥-១២។ ក្បួនច្បាប់ស្តីពីការចេញថ្លៃនៅពេលរៀបអាពាហ៍ពិពាហ៍ អាសៈ និងការគោរពចំពោះស្ត្រី មាននៅក្នុងមហ. ជំពូក ១៣ លេខ ៤៥, ២០; ៤៦; ១-៧ ហើយល្បះខ្លះ មនុ ជំពូក ៣ លេខ ១៣៤-១៣៥, ១៤០-១៤២, ១៥៨-១៥៩, ១៧២, ១៨០-១៨១, ១៨៤-១៨៥, ចាប់ពីផ្នែកស្តីពីស្រាទ្ធ មហ. ជំពូក ៣ លេខ ៩០ ព្រមទាំងផ្នែកនានានៃជំពូក ៣ លេខ ២៦៧-២៧៤ នៅដើមមហ. ជំពូក ១៣ លេខ ៨៨។ ការព្រមានកុំឱ្យឈ្លោះគ្នាជាមួយសាច់ញាតិ មនុ ជំពូក៤ លេខ ១៧៩-១៨៥ ត្រូវនិយាយដដែលនៅក្នុងមហ.ជំពូក១២ លេខ ២៤៤; ១៤ b-២១a។ ច្បាប់ទម្លាប់មួយចំនួន ដែលអាចអនុវត្តបានសម្រាប់តាបសឥសី មនុ ជំពូក៦ លេខ ៤២-៤៨, ៥៧b, ៥៨a បង្ហាញម្តងទៀតនៅដើមមហ. ជំពូក១២ លេខ ២៤៦ និង ២៧៩ ចំណែកឯ មនុ

ជំពូក ៦ លេខ ៤៩ ត្រូវមើលនៅមហ. ជំពូក១២ លេខ ៣៣១, ៣០។ ការពណ៌នាយ៉ាងខ្លី អំពីរដ្ឋបាលរដ្ឋ មនុ ជំពូក ៧ លេខ ១១៥-១២២ ត្រូវសរសេរដោយពាក្យពេចន៍ស្ទើរតែដូចគ្នានឹងមហ. ជំពូក ១២ លេខ ៨៧, ៣-១១a និងជំពូកដដែល ក៏មានវិន័យស្ដីពីការយកពន្ធ សឹងតែដូចគ្នានឹងមនុ ជំពូក ៧ លេខ ១២៧ និង ១៣៩a។ វគ្គពាក់ព័ន្ធដទៃទៀត នៅសងខាងល្បះបីបន្ទាត់ និងក្រោម ស្លោកមួយ ហើយត្រូវពង្រីករហូតដល់ ១២ជំពូកនៃមនុ។ ផ្នែកមហាភារតៈ ដែលយើងឃើញមាន គឺជំពូក៣ លេខ ៩៤, ១៨០; ជំពូក ១២ លេខ ១៥, ២៤៤-២៤៥, ២៦៥; ជំពូក ១៣ លេខ ៤៥-៤៦, ៩០, ១០៤-១០៥, ១១៥, ១៥២(ការបង្ហាញជាទូទៅទាំងអស់នេះ មិនអាចធ្វើទៅបាន។ បញ្ជីល្បះកាព្យនៃមនុស្ម្រិតិ ដែលមាននៅក្នុងមហ. នឹងមាននៅក្នុងសេចក្ដីបន្ថែម។) ។

ដើម្បីបញ្ចប់ការពណ៌នាអំពីទំនាក់ទំនងនៅក្នុងស្នាដៃពីរនេះ យើងនឹងពិចារណាទាំងស្រុងនូវវគ្គមួយក្នុងចំណោមវគ្គពាក់ព័ន្ធបីដែលវែងជាងគេ ហើយអធិប្បាយខ្លីៗដោយប្រុងប្រយ័ត្ននូវចំណុចពាក់ព័ន្ធ និងចំណុចផ្សេងគ្នាទាំងពីរនេះ។ ចំណុចដ៏សមគួរបំផុតសម្រាប់ការប្រៀបធៀបបែបនេះ គឺត្រូវចាប់ផ្ដើមពីគម្ពីរមនុទី១។ ពីព្រោះគម្ពីរក្រោយ ពិតជាមានអ្នកកែសម្រួលបន្ថែមអត្ថបទកំណាព្យហើយ ការរៀបរាប់ពីការបង្កើតមានបញ្ហាជាច្រើនដែលបានធ្វើឲ្យអ្នកអត្ថាធិប្បាយឈឺក្បាលយ៉ាងខ្លាំង។ ការដោះស្រាយបញ្ហាលំបាកខ្លះក្នុងការលំបាកទាំងឡាយ ត្រូវផ្អែកលើវគ្គពាក់ព័ន្ធនៃមហាភារតៈ។ វគ្គនេះ មានរៀបរាប់ពីពិភពលោក ដែលលោកវ្យាសៈក្រិស្ណ-ទ្វៃបាយន ប្រាស្រ័យទាក់ទងជាមួយនឹងកូនប្រុស របស់គាត់ឈ្មោះ សុក ដែលភិស្មៈ ដំណាលប្រាប់យុធិស្ថិរៈ។

## ការប្រៀបធៀប

| **មហាភារតៈ ជំពូក ៣ លេខ ២៣២** | **មនុ ជំពូក ១** |
|---|---|
| ១១. វ្យាសៈ និយាយៈ ក្នុងការចាប់ផ្ដើម មានព្រាហ្មណ៍ ដោយគ្មានការផ្ដើម ឬការបញ្ចប់ មិនចាប់កំណើត មានពន្លឺ រួចផុតពីការវិនាស គ្មានការប្រែប្រួល អមតៈ មិនអាចយល់បានដោយការឱ្យហេតុផល ដោយគេមិនអាចដឹងទាំងស្រុងបានទេ។ | |
| ១២. ១៥ និមេសៈ (ព្រិចភ្នែក) ១កាស្ថា(និយាយពីភាពខុសគ្នារវាងការគណនាពីរ មើល Wilson, វិស្ណុបុរាណ ជំពូក១លេខ៤៧(ពិនិត្យកែសម្រួលដោយHall)) តែ ៣០ កាស្ថា គេគួរតែរាប់ថា១កលាម្យ៉ាងទៀត ៣០កលា និងចំនួននោះ ដែលស្មើមួយភាគដប់នៃកលា ត្រូវស្មើ ១ មុហូត | |
| ១៣. ៣០មុហូត ស្មើ ១ថ្ងៃ និង១យប់ ជាចំនួនមួយដែលពួកបណ្ឌិតបានកំណត់, ១ខែ ត្រូវគេរាប់ (មាន) ៣០ថ្ងៃ និងយប់ ហើយ ១ឆ្នាំ មាន ១២ខែ។ | |

| | |
|---|---|
| ១៤. ប៉ុន្តែចំនួនដែលគេដឹងតាមការគណនា ជាការធ្វើដំណើរពីរនៃព្រះអាទិត្យ ម្តងទៅខាងត្បូង និងម្តងទៅខាងជើងគឺមួយឆ្នាំ(កាព្យដែលបង់លេខ១៤នៅក្នុងសៀវភៅបោះពុម្ពនៅប៉ុំបៃ មានតែមួយបន្ទាប់ប៉ុណ្ណោះ។)។ | ៦៤. ១៨ និមេស(ការព្រិចភ្នែក ស្មើ ១កាស្ថា), ៣០ កាស្ថា គឺ១កលា, ៣០កលា ស្មើ ១មុហូត ហើយច្រើនមុហូត ស្មើ ១ថ្ងៃ និងមួយយប់។ |
| ១៥. ព្រះអាទិត្យ បែងចែកថ្ងៃ និងយប់សម្រាប់ពិភពរបស់មនុស្ស,(ការអានមហាភារតៈមានុសលោកិកេសម្រាប់មានុសដៃកិកេ ទំនងជាប្រសើរជាង។) យប់(ត្រូវគិតថា) សម្រាប់ការឈប់ សម្រាករបស់សត្វលោក ហើយថ្ងៃសម្រាប់ការខំព្យាយាម។ | ៦៥. ព្រះអាទិត្យ បែងចែកថ្ងៃ និងយប់សម្រាប់ ទាំងមនុស្ស ទាំងទេវៈ, ពេលយប់(គេគិតថា) សម្រាប់ការឈប់ សម្រាករបស់សត្វលោក ហើយថ្ងៃ សម្រាប់ការខំព្យាយាម។ |
| ១៦. មួយខែ គឺមួយថ្ងៃ និងមួយយប់សម្រាប់ព្រលឹងវិញ្ញាណទាំងឡាយ តែការបែងចែកវា (មានដូចតទៅ): ភ្លឺ (ពីរសប្តាហ៍) ជាថ្ងៃរបស់ពួកគេសម្រាប់ការប្រឹងប្រែងយ៉ាងសកម្ម, ងងឹត (ពីរសប្តាហ៍) ជាយប់សម្រាប់ពួកគេដេក។ | ៦៦. មួយខែ គឺមួយថ្ងៃ និងមួយយប់សម្រាប់ព្រលឹងវិញ្ញាណទាំងឡាយ តែការបែងចែកជា១៤ថ្ងៃ។ ងងឹត (១៤ថ្ងៃ)ជាថ្ងៃសម្រាប់ពួកគេប្រឹងប្រែងយ៉ាងសកម្ម, ភ្លឺ(១៤ថ្ងៃ)ជាយប់សម្រាប់ពួកគេដេក។ |
| ១៧. មួយឆ្នាំ គឺមួយថ្ងៃ មួយយប់របស់ទេវតា។ ការបែងចែកគឺ (មាន): កន្លះឆ្នាំ ដែលព្រះអាទិត្យដើរទៅទិសខាងជើង គឺជាពេលថ្ងៃ ហើយពេលព្រះអាទិត្យដើរទៅទិសខាងត្បូង គឺយប់។ | ៦៧. មួយឆ្នាំ គឺមួយថ្ងៃ មួយយប់របស់ទេវតា។ ការបែងចែកគឺ (មាន): កន្លះឆ្នាំ ដែលព្រះអាទិត្យដើរទៅទិសខាងជើង គឺជាពេលថ្ងៃ ហើយពេលព្រះអាទិត្យដើរទៅទិសខាងត្បូង គឺយប់។ |
| ១៨. ការរាប់ចំនួនឆ្នាំ (មាន)នៃថ្ងៃ និងយប់សម្រាប់មនុស្សដែលបាននិយាយខាងលើ ខ្ញុំនឹងប្រកាសថាជា (រយៈពេល) ថ្ងៃ និងយប់របស់ព្រាហ្ម។ | ៦៨.តែពេលនេះស្តាប់ឮ (ការពណ៌នា) សង្ខេបអំពីរយៈពេលយប់និងថ្ងៃរបស់ព្រាហ្មណ៍ និងអាយុកាលជាច្រើន(នៃលោក)ស្របតាមលំដាប់លំដោយរបស់វា។ |
| ១៩. ខ្ញុំនឹងប្រកាសដាច់ពីគ្នា និងតាមលំដាប់ចំនួនឆ្នាំសរុបក្នុងក្រិត,ត្រេតា, ទ្វាបរ និងអាយុកាលិ(ការពិតមួយបង្ហាញច្បាស់ថា ថ្វីដ្បិតតែមានភាពខុសគ្នាច្រើន រវាងស្នាដៃពីរនេះក៏ដោយ ក៏ស្នាដៃទាំងពីរមានទំនាក់ទំនងទៅវិញទៅមកនៅផ្នែកចាប់ផ្តើមដំបូង។)។ | |
| ២០. ពួកគេប្រកាសថា អាយុក្រិត (មាន)បួនពាន់ឆ្នាំ (របស់ទេវតា);ដំណើរព្រះអាទិត្យអស្តង្គត មានចំនួនរាប់រយ ហើយដំណើរព្រះអាទិត្យរះ មានចំនួនស្មើគ្នា។ | ៦៩. ពួកគេប្រកាសថា អាយុក្រិត (មាន) បួនពាន់ឆ្នាំ (របស់ទេវតា); ដំណើរព្រះអាទិត្យអស្តង្គត មានចំនួនរាប់រយ ហើយដំណើរព្រះអាទិត្យរះ មានចំនួនស្មើគ្នា។ |
| ២១. ក្នុងអាយុកាល៣(ទៀត) ពេលព្រះអាទិត្យលិច និងពេលព្រះអាទិត្យរះ រាប់ពាន់ និងរាប់រយ ត្រូវបន្ថយមួយភាគបួន(ក្នុងពេលមួយៗ)(ការអាននៃមនុចំពោះពាក្យ*សសំធ្យាំសេសុ ក* ថា*សំធ្យាំសេសុ តតះ* ទំនងជាស្រួលអានជាង តែអេកាបាយេន របស់គាត់ ហាក់ដូចជាអន់ជាង | ៧០. ក្នុងអាយុកាល៣(ទៀត) ពេលព្រះអាទិត្យលិច និងពេលព្រះអាទិត្យរះ រាប់ពាន់ និងរាប់រយ ត្រូវបន្ថយមួយភាគបួន(ក្នុងពេលមួយៗ)។ |

| | |
|---|---|
| អេកបាទេនរបស់មហាភារតៈ។ ) ។ | |
| ២២. ទាំងនេះ គាំទ្រពិភពលោកជាអមតៈ ជានិច្ចនិរន្តរ៍ នេះគេចាត់ទុកជាព្រាហ្មណ៍អមតៈ ដែលចេះដឹងពីព្រាហ្មណ៍។ | |
| ២៣. តាមអាយុកាលក្រិត ធម៌មានជើង ៤ និងចំនួនទាំងស្រុង (ដូច្នេះគឺ)សច្ចៈ; ហើយមិនកេងចំណេញ ដែលផ្ទុយពីសច្ចៈ (ស្មារតីយុត្តិធម៌) នាំឱ្យកើនឡើងនូវភាពមិនត្រឹមត្រូវនោះទេ(នីលកន្ថៈ បកស្រាយអាគម ក្នុងកំណាព្យនេះ និងពាក្យបន្ទាប់ តាម "គោលជំនឿ"។ ខ្ញុំបកប្រែពាក្យនេះថា ដោយ "កេងចំណេញ" ស្របតាមការបកប្រែនៅក្នុងគម្ពីរមនុ ប៉ុន្តែមានចេតនាទទួលស្គាល់ថា ការប្រែដទៃទៀតអាចធ្វើទៅបាននៅក្នុងស្នាដៃទាំងពីរនេះ ហើយថាន័យគឺអាច "និងមិនមែនដោយគោលជំនឿមិនត្រឹមត្រូវ ដែលផ្ទុយពីគោល (ធម៌)ដែលត្រូវ សំអាងទេ"(មហ.) "និងមិនមែនគោលជំនឿមិនត្រឹមត្រូវ ត្រូវរីកសាយក្នុងចំណោមមនុស្សទេ" (មនុ)។) ។ | ៨១. តាមអាយុកាលក្រិត ធម៌មានជើង ៤ និងចំនួនទាំងស្រុង(ដូច្នេះគឺ)សច្ចៈ;ហើយមិនកេងចំណេញ ធ្វើឱ្យមនុស្សកាន់តែច្រើនមានភាពមិនត្រឹមត្រូវនោះទេ។ |
| ២៤.ក្នុងអាយុ(កាល៣)ទៀតដោយហេតុផលចំណេញ (មិនត្រឹមត្រូវ)ធម៌ត្រូវគេធ្វើឱ្យខូចជើងមួយជាបន្តទៀត ហើយភាពមិនត្រឹមត្រូវ កើនឡើងតាមរយៈ ចោរកម្ម ការភូតកុហក និងការក្លែងបន្លំជាដើម។ | ៨២. ក្នុងអាយុ (កាល៣) ទៀត ដោយហេតុផលចំណេញ(មិនត្រឹមត្រូវ) ធម៌ត្រូវគេធ្វើឱ្យខូចជើងមួយជាបន្តទៀតហើយភាពមិនត្រឹមត្រូវកើនឡើងតាមរយៈ (ការកើតមានជាទូទៅ) ចោរកម្ម ការភូតកុហក និងការក្លែងបន្លំ គុណធម៌(ដែលមនុស្សទទួលបាន) ត្រូវថយចុះមួយភាគបួន(ក្នុងគុណធម៌មួយៗ)។ |
| ២៥. (មនុស្សគឺ)រួចផុតពីជំងឺ សម្រេចបំណងទាំងអស់របស់ខ្លួន និងរស់នៅដល់បួនរយឆ្នាំតាមកាលក្រិត; តែតាម(កាល)ក្រិត (និងកាលខាងក្រោម) អាយុរបស់មនុស្ស ត្រូវបន្ថយមួយភាគបួនក្នុងកាលមួយៗ(ការអានក្រិតេ ត្រេតាយុគេ ត្វេតាយុគេ ត្វេតាំ ជំនួសពាក្យក្រិតេ ត្រេតាទិសុហ្យេសាំ គឺគេលែងប្រើទៅហើយ។) | ៨៣. (មនុស្សគឺ) រួចផុតពីជំងឺ សម្រេចបំណងទាំងអស់របស់ខ្លួន និងរស់នៅដល់បួនរយឆ្នាំតាមកាលក្រិត; តែតាម(កាល)ក្រិត (និងកាលខាងក្រោម) អាយុរបស់មនុស្ស ត្រូវបន្ថយមួយភាគបួន។ |
| ២៦. ហើយគោលជំនឿវេទចុះខ្សោយ ដូចយើងដឹងស្រាប់ តាមកាលបន្តបន្ទាប់នីមួយៗ ព្រមទាំងជីវិតរស់នៅ (របស់មនុស្ស ) ពរជ័យរបស់ពួកគេ (អាសិសៈ) និងរង្វាន់ដែលវេទផ្តល់ឱ្យ (អត្ថបទសំស្ក្រឹតនៃស្លោកពីរស្របគ្នាច្រើនជាងការបកប្រែនេះ។ ហាក់ដូចជាគ្មានស្លោកណាមួយ ជាកំណែដើម ដែលទំនងជាប្រកាសថា អាយុកាលរបស់មនុស្ស ការជូនពរជ័យ និងរង្វាន់ដល់អំពើរបស់ពួកគេ | ៨៤. ជីវិតមនុស្ស ដែលបានរៀបរាប់នៅក្នុងគម្ពីរវេទ ផលដែលគេចង់បាន(អាសិសៈ) ពីពិធីបូជា និងអំណាច (អភិធម្មជាតិ) នៃរូប (ព្រលឹងវិញ្ញាណ) ជាផ្លែផ្កា ដែលចែកតាមសមាមាត្រក្នុងចំណោមមនុស្សស្របតាម(លក្ខណៈរបស់)អាយុកាល។ |

| | |
|---|---|
| ដូចជាពួកគេបានដឹងនៅក្នុងវេទ មានការបន្ថយអាយុកាលនីមួយៗតាមលំដាប់។ កំណែមួយទៀត ដែលដូចគ្នាបំផុតនឹងអត្ថបទរបស់មនុ មានមហ.ជំពូក៣លេខ២០០, ១១៥។) ។ | |
| ២៧. សំណុំករណីយកិច្ច (ដែលគេកំណត់) សម្រាប់មនុស្ស តាមអាយុកាលក្រិត ខុសគ្នាពីករណីយកិច្ចក្នុងត្រេតា និងទ្វាបរ និងមួយទៀតក្នុងអាយុកលិ តាមសមាមាត្រ ដូច្នេះអាយុ (ទាំងនោះ) ថយចុះតាមគម្លាតរយៈពេល។ | ៨៥. សំណុំករណីយកិច្ច (ដែលគេកំណត់) សម្រាប់មនុស្ស តាមអាយុកាលក្រិត ខុសគ្នាពីករណីយកិច្ចក្នុងត្រេតា និងទ្វាបរ និងមួយទៀតក្នុងអាយុកលិ តាមសមាមាត្រដូច្នេះអាយុ(ទាំងនោះ)ថយចុះតាមគម្លាតរយៈពេល។ |
| ២៨. តាមអាយុក្រិត ថៅហ្វាយ (គុណធម៌ គឺការប្រតិបត្តិនូវ) តបកម្ម តាមត្រេតា ចំណេះដឹង(ល្អប្រពៃ) គឺល្អឥតខ្ចោះបំផុត តាមទ្វាបរ ថៅហ្វាយពេញចិត្តធ្វើពលិកម្ម (បំផុត) តាមកលិ គិតតែការរួចរំដោះតែម្យ៉ាង។ | ៨៦. តាមអាយុក្រិត ថៅហ្វាយ (គុណធម៌) ត្រូវតែពេញចិត្ត(ធ្វើ)តបកម្ម តាមត្រេតា គិតពីចំណេះដឹង (ល្អប្រពៃ) តាមទ្វាបរ (ការអនុវត្ត)ពលិកម្ម តាមកលិ គិតតែការរួចរដោះតែម្យ៉ាង។ |
| ២៩.បណ្ឌិតដឹង (កាល) ដប់ពីរពាន់ឆ្នាំ (អាទិទេព) (ដែលត្រូវយល់ដោយ)ពាក្យអាយុកាល (របស់ទេវតា) កាល (ពេល) ដែលត្រូវគុណនឹងមួយពាន់ គឺត្រូវមួយរបស់ព្រហ្ម។<br>៣០. (ដឹងថា) ស្មើនឹងមួយយប់(របស់ព្រហ្ម)(ទាំងមហ. ទាំងមនុ មានករណីវិកត្តិ *ពត្រិម* ដែលមិនស្របនឹងកិរិយាស័ព្ទខាងដើម *ញេយំ* (មនុ) ឧក្សេតេ(មហ.)។ ហាក់ដូចជាមានការកែសម្រួលល្បះដើម ដែលពាក្យទំនងជា *អាហុ* ដែលមានវិកត្តិរបស់វា។ ទោះបីគេដូរកិរិយាស័ព្ទក៏ដោយ ក៏គេភ្លេចដូចពាក្យពាក់ព័ន្ធបន្តទៀតដែរ។) ។ នៅ ដើម(ថ្ងៃ)នោះ ព្រះអង្គដែលចក្រវាឡញ្ញួលចុងក្រោយបន្ទាប់ពីឈានចូលសមាធិយ៉ាងជ្រៅ។ | ៧១-៧២. ដូចនេះ ដប់ពីរពាន់ឆ្នាំ ដែលបាននិយាយខាងលើ ជា៤អាយុខែសរុប(របស់មនុស្ស) ត្រូវនឹងមួយអាយុខែរបស់ទេវតា។ ប៉ុន្តែដឹងថា មួយពាន់ អាយុខែទេវតា (គឺ)មួយថ្ងៃរបស់ព្រហ្ម និងថាមួយយប់របស់ព្រហ្ម មានរយៈពេលដូចគ្នា។ |
| ៣១. អ្នក ដែលដឹងថា ថ្ងៃរបស់ព្រហ្ម ចប់បន្ទាប់ពី (ការបញ្ចប់នូវ) អាយុខែមួយពាន់ឆ្នាំ (របស់ទេពតា) និងថាយប់របស់ព្រហ្មមានអាយុខែមួយពាន់ឆ្នាំ គឺ (ពិតជា) មនុស្សដឹង(រយៈពេល)ថ្ងៃ និងយប់បាន។ | ៧៣. អ្នកដែលដឹងថា ថ្ងៃពិសិដ្ឋរបស់ព្រហ្ម តាមពិតចប់បន្ទាប់ពី(ការបញ្ចប់នូវ)អាយុមួយពាន់ឆ្នាំ(របស់ទេពតា) និងថា យប់របស់ព្រហ្មមានពេលវែង តាមនោះ គឺ(ពិតជា)មនុស្សដឹង(រយៈពេល)ថ្ងៃ និងយប់បាន។ |
| ៣២. បើព្រហ្មបិតថេរ ដឹងខ្លួនដល់យប់ចុងក្រោយរបស់ព្រះអង្គ ព្រះអង្គកែខែខ្លួនឯង និងបង្កើតកម្លាំងធម្មជាតិ (ហៅថា)មហារូប(និង)ចេញពីចិត្តដ៏អាថ៌កំបាំង។ | |
| | |
| **មហាភារតៈ ជំពូក ២ លេខ២៣៣**<br>១.ព្រហ្មដ៏មានពន្លឺចែងចាំងជាគ្រាប់ពូជដែលកើតចេញ | |

| | |
|---|---|
| ពីកម្លាំងធម្មជាតិមួយ កើតនូវរូបពីរផ្នែក គឺមានចលនា និងគ្មានចលនា។ | |
| ២. ដឹងខ្លួននៅពេលចាប់ផ្ដើមថ្ងៃរបស់ព្រះអង្គ ព្រះអង្គបង្កើតពិភពលោកដោយអវិជ្ជា ជាកម្លាំងធម្មជាតិទី១ (ដែលហៅថា)មហារូប (បន្ទាប់មក)បង្កើតយ៉ាងឆាប់រហ័សនូវចិត្តដ៏អាចកំបាំង | |
| ៣. ហើយឈ្មោះ(ចិត្ត)ត្រចះត្រចង់នៅទីនេះ ដែលដើរទៅឆ្ងាយកាន់ផ្លូវជាច្រើន និងមានធម្មជាតិប្រាថ្នា និងសង្ស័យ បង្កើតការជាប់ជំពាក់ចិត្តប្រាំពីរ។ | |
| ៤. ចិត្តដែលជំរុញដោយការប្រាថ្នា ដើម្បីបង្កើតធ្វើការប្រែរូបរបស់វា ដូច្នេះអាកាសក៏កើតឡើង វាស្តែងមកថា សំឡេងជាលក្ខណៈរបស់ចិត្តក្រោយនេះ។ | ៧៥. ចិត្តដែលជំរុញដោយការប្រាថ្នា ដើម្បីបង្កើតធ្វើការប្រែរូបរបស់វា ដូច្នេះអាកាសក៏កើតឡើង វាស្តែងមកថា សំឡេងជាលក្ខណៈរបស់ចិត្តក្រោយនេះ។ |
| ៥. ប៉ុន្តែចេញពីអាកាស ចិត្តប្រែរូប កើតនូវខ្យល់បរិសុទ្ធដ៏ខ្លាំង គោងនូវគន្ធទាំងអស់ ផស្សៈ គឺជាលក្ខណៈរបស់វា។ | ៧៦. ប៉ុន្តែចេញពីអាកាស ចិត្តប្រែរូប កើតនូវខ្យល់បរិសុទ្ធដ៏ខ្លាំងគោងនូវគន្ធទាំងអស់នោះគឺជា លក្ខណៈរបស់ផស្សៈ។ |
| ៦. បន្ទាប់ពីខ្យល់ ចិត្តប្រែរូប បណ្តាលមកពីពន្លឺដ៏ត្រចះត្រចង់ដែលបង្ហាញច្បាស់និងពណ៌ស។នោះជាលក្ខណៈរបស់ពណ៌ | ៧៧. បន្ទាប់ពីខ្យល់ ចិត្តប្រែរូប បណ្តាលមកពីពន្លឺដ៏ត្រចះត្រចង់ដែលបង្ហាញច្បាស់ និងកម្ចាត់ភាពងងឹត។ នោះជាលក្ខណៈរបស់ពណ៌។ |
| ៧. ហើយចេញពីពន្លឺ ចិត្តប្រែ(ជា)ទឹក ដែលមានរសជាតិ; ចេញពីទឹក គឺក្លិន និងដី; នោះគេថាជាការបង្កើត(ពួកវា)ទាំងអស់។ | ៧៨. ហើយចេញពីពន្លឺ ចិត្តប្រែ (បង្កើតជា)ទឹកដែលជាលក្ខណៈរសជាតិ; ចេញពីទឹក គឺដី ដែលមានលក្ខ-ណៈជាក្លិន; នោះ គឺការបង្កើតក៏ចាប់ផ្តើម។ |
| ៨. លក្ខណៈរបស់ (ធាតុ) នីមួយៗរៀបរាប់ខាងដើមបង្កើតឱ្យមានមួយបន្ត ហើយកន្លែងណាក៏ដោយ ដែលធាតុនីមួយៗ (តាមលំដាប់) ស្ថិតនៅសូម្បីអីចឹងក្តី គេដឹងថាមានលក្ខណៈជាច្រើន(ទីតាំងកំណាព្យនេះនៅក្នុងមហាភារតៈ ជាការស្មាន មានការសន្និដ្ឋានសម្រាប់ការបកប្រែថា ទីតាំងត្រឹមត្រូវនៃមនុ ជំពូក ១ ចំណុចលេខ ២០ នៅបន្ទាប់កំណាព្យ ៧៨ ដែលគួរឱ្យជឿបំផុត។) ។ | ២០. ក្នុងចំណោមនោះ (ធាតុ)នីមួយៗបន្ទាប់ មានលក្ខណៈធាតុពីមុន ហើយកន្លែងណា (តាមលំដាប់) ធាតុនីមួយៗស្ថិតនៅ សូម្បីអញ្ចឹងក្តី ក៏មានលក្ខណៈជាច្រើន។ |
| ៩. បើធាតុខ្លះ ដែលដឹងក្លិនក្នុងទឹក តាមរយៈការចង់បានការយកចិត្តទុកដាក់ ទុកជា(លក្ខណៈទឹក) គេពិតជាដឹងថា វាជារបស់ធាតុដីតែម្យ៉ាងទេ (និងថាជា) កើតឡើងឯងៗនៅក្នុងទឹក និងខ្យល់។ | |
| ១០. អាត្ម័នទាំង ៧ប្រភេទ(យោងតាមនីលកន្ថៈ អាត្ម័នប្រាំពីរ ដែលហៅខាងលើ កាព្យ ៣នោះ ជាធាតុបង្កើតចិត្ត៧ | |

| | |
|---|---|
| មាន មហត អហំការ និងធាតុល្អិតសុខុម ៥។) ដែលមាន អានុភាព ផ្សេង គ្នា នោះ មិនអាចបង្កើតសភាវៈនីមួយៗ ដោយគ្មានការ ផ្សំផ្គុំទាំងស្រុងទេ។ | |
| ១១. មហាអាត្មនទាំងអស់ ដែលផ្សំនិងបញ្ចូលគ្នា ទៅវិញទៅមកជាមួយធាតុផ្សេងមួយៗ បង្កើតជារូប តពីនេះគេនិយាយពីបុរុស [ពោលគឺ អ្នកដែល(ឧសៈ)ជាការការពារ(បុរ)] | |
| ១២. តាមបច្ច័យនៃធាតុដែលផ្គុំនឹង (ស្រយន) រូប (សរីរៈ) ក្លាយជាលក្ខណៈធម្មជាតិ ផ្ដល់នូវទម្រង់ (ច្បាស់លាស់) និងមាន(អង្គផ្សំ) ១៦(ធាតុផ្សំ ១៦ យោងតាមនីលកន្ថៈ មានធាតុធម្មជាតិ ៥ និងសរីរៈ ១១។) ។ នោះធាតុធំៗ(នីលកន្ថៈ ចាត់ទុកមហាន្តិ ភូតានិ "មហាធាតុរូប" ក្នុងន័យជា "ធាតុល្អិតសុខុម និងមហាធាតុ មហត្តត្វ" (ភូតានិ សូខ្សានិ មហាន្តិ មហត្តត្វានិ)) ផ្សំជាមួយកម្ម (កម្មល្អ និងកម្ម អាក្រក់)។ | ១៨b. នោះមហាធាតុរូប ផ្សំជាមួយមុខងាររបស់វា (កម្ម័ន)(ល្បះនេះ ជាតួយ៉ាងមួយល្អ ដែលបង្ហាញរបៀបបង្កើតពាក្យដូចគ្នាតាមប្រពៃណីអប់រំសម័យបុរាណ ដើម្បីគោលបំណងផ្សេងៗ។) ។ |
| ១៣.ដោយជាប់មកជាមួយកម្ម័ន នូវធាតុទាំងអស់ នោះអ្នកបង្កើតទី១ បង្កើតសត្វលោកដែលត្រូវបង្កើត (ផ្សំនឹងកម្ម័ន) ដើម្បីដើរតាមក្រឹត្យក្រមដ៏តឹងរ៉ឹង ហើយសត្វលោកហៅកម្ម័ន ថាជាព្រះបង្កើតសត្វលោក ដែលត្រូវបង្កើតឡើង។ | |
| ១៤.តាមពិតព្រះបង្កើតសត្វលោកទាំងឡាយ ទាំងគ្មានចលនា និងមានចលនា បន្ទាប់មកព្រះព្រហ្មបង្កើតព្រះអាទិទេព បណ្ឌិត បុព្វបុរស និងមនុស្ស, | |
| ១៥. ពិភពលោក ទន្លេ សមុទ្រ ចំណែកផែនដី ភ្នំ ដើមឈើ មនុស្ស កិន្នរ រក្សៈ បក្សាបក្សី សត្វផ្សាំង និងសត្វព្រៃ និងពស់ សត្វមិនស្លាប់ និងសត្វស្លាប់ ទាំងមានចលនា និងគ្មានចលនា។ | |
| ១៦. ផ្លូវបដិបត្តិអ្វីក៏ដោយ ដែលពួកគេបានប្រកាន់យកតាមការបង្កើតពីមុន សូម្បីអំពើដែលពួកគេប្រកាន់យកតែម្យ៉ាង ក្នុងការបង្កើតអំពើនីមួយៗបន្តទៀត។ | ២៨. ប៉ុន្តែចំពោះផ្លូវបដិបត្តិអ្វីក៏ដោយ ព្រះអង្គដំបូងបំផុតបានកំណត់(ប្រភេទសត្វលោក)នីមួយៗ ហើយបន្ទាប់មកវាបានបង្កើតបន្តបន្ទាប់តាមប្រភេទនីមួយៗដោយឯងៗ។ |
| ១៧. សត្វលោកទាំងឡាយ ក្លាយជាពិសពល់ ឬគ្មានពិសពល់ ស្លូតបូត ឬឃោរឃៅ មានគុណធម៌ ឬបាបសច្ចៈ ឬក្លែងក្លាយ យោងទៅតាមធម្មជាតិដែលព្រះ | ២៩. អ្វីក៏ដោយ ដែលព្រះបានកំណត់សម្រាប់សភាវៈមួយៗ តាមការបង្កើត(ឡើងដំបូង) នូវភាពពិសពល់ ឬគ្មានពិស ស្លូតបូតឬឃោរឃៅ មានគុណធម៌ឬមាន |

| | |
|---|---|
| បានបង្កើតពួកវា (ដំបូង) ហេតុនេះ (ដំណើរនៃការប្រព្រឹត្ត មួយ)នោះ តម្រូវតាមសភាវៈមួយៗ។ | បាប សច្ចៈឬក្លែងក្លាយ ដែល(ក្រោយមក)តោងភ្ជាប់នឹងសភាវៈនោះដោយឯកឯង។ |

និទានដទៃទៀតរបស់ព្រាសៈ ដែលបន្តកាព្យដល់២៦ល្បះ អាចត្រូវគេលុបចោល ដោយហេតុថាល្បះបន្តបន្ទាប់មានចំណុចពាក់ព័ន្ធតិចតួចជាមួយនឹង*ស្ម្រិតិ* របស់យើង។ យ៉ាងណាមិញ យើងត្រូវកត់សម្គាល់ថា យោងតាមល្បះ២៥-២៦ ថា "ព្រះបានកំណត់ឈ្មោះ និងលក្ខខណ្ឌសម្រាប់សត្វលោករបស់ទ្រង់ ស្របទៅតាមពាក្យវេទ"។ ទស្សនៈគំនិតនេះ ស្របគ្នានឹងគម្ពីរមនុ ជំពូក លេខ ២១ ប៉ុន្តែការប្រើពាក្យនៃសេចក្តីទាំងពីរ មានភាពខុសគ្នាច្រើន។

មេរៀនដែលយើងទទួលបាន តាមរយៈការលាតត្រដាងការពិតក្នុងការពិភាក្សាខាងលើ គឺជាមេរៀនពីរយ៉ាង។ ទី១ ការពិតបង្ហាញច្បាស់ថា បណ្ណាធិការកំណាព្យមនុស្ម្រិតិរបស់យើង មិនបានប្រើមហាភារតៈទេ ប៉ុន្តែថាអ្នកនិពន្ធស្នាដៃទាំងពីរ បានប្រើប្រាស់សម្ភារៈតែមួយ។ ទី២ ការពិតទំនងជាថា សម្ភារៈដែលស្នាដៃទាំងពីរអាស្រ័យលើ មិនមែនជាបទអភិប្រាយជាប្រព័ន្ធស្តីពីច្បាប់ និងទស្សនវិជ្ជា ប៉ុន្តែភាសិតគតិបណ្ឌិតផ្សាយការអប់រំទស្សនវិជ្ជា និងច្បាប់តាមទម្រង់ជាចង្វាក់កាព្យ។ ចំណុចទី១ ជាសក្ខីកម្មបញ្ជាក់ច្បាស់សម្រាប់ខ្ញុំថា គេមិនចាំបាច់ប្រើប្រាស់ពាក្យពេចន៍មិនបានការច្រើនទៀតទេ។ តាមសេចក្តីសន្និដ្ឋានទី២ ខ្ញុំសូមគូសបញ្ជាក់ថា ភាពផ្សេងគ្នាពិតជាកើតមាននៅក្នុងស្លោកពាក់ព័ន្ធតាមរយៈកថានៅក្នុងបន្ទាត់ និងបាទក្នុងកាព្យ ដែលន័យទូទៅមានភាពផ្សេងគ្នា និងដោយមានភាពដូចគ្នាមិនច្បាស់លាស់ទាំងស្រុងផ្នែកពាក្យពេចន៍ និងគំនិតដែលអាចសង្កេតឃើញនៅក្នុងផ្នែកដទៃទៀត។ ខ្ញុំអាចបញ្ជាក់បន្ថែមថា សម្មតិកម្មនៃការអប់រំវិស័យនីមួយៗ ដែលមានជាក្រុមភាសិត ពាក្យកាព្យ ឃើញមានមូលដ្ឋានយ៉ាងល្អ។

ដូចបានអះអាងម្តងហើយម្តងទៀតថា សៀវភៅសិក្សារបស់សាលាវេទបុរាណសូត្រនិងឧបនិស័ទ មានភាពណែងណាងនៃកាព្យអនុស្តុភ ដែលមិនអាចមិនពិចារណាបាន ដែលជួនកាលមានទម្រង់ដូចគ្នាឬខុសគ្នាខ្លះដែរ។ ដូច្នេះគ្មានអ្វីគ្រាន់តែជាការរំពឹងថា គ្រូបង្រៀននៃសាលាឯកទេស គួរតែបន្តតាមមាគ៌ារបស់អ្នកជំនាន់មុនរបស់ពួកគេ ហើយគួរតែបង្កើនទុន "ស្រ្បុធ្វេសេត" របស់ពួកគេ រហូតដល់ប្រធានបទច្បាប់ និងទស្សនវិជ្ជាទាំងអស់ និងការប្រមូលកំណាព្យដែលដាច់ៗពីគ្នាទាំងអស់ ដោយធ្វើឱ្យមានភាពងាយស្រួល និងចង់បំលែងក្បួនសុភាសិតបុរាណនានា ទៅជាបទអភិប្រាយពាក្យកាព្យ

(ភាពគួរឱ្យជឿជាក់ ឬអត្ថិភាពនៃពាក្យស័ព្ទកំណាព្យសុភាសិត នឹងកាន់តែច្បាស់លាស់ បើសិនគេអាចពិនិត្យមើលការប្រៀបធៀបចំណែកបុរាណ ពីដើមជាមួយនឹងមហាភារតៈ និងកំណាព្យស្ម្រិតិ ព្រមទាំងពិចារណាលម្អិតអំពីស្នាដៃអំណាន ពុទ្ធសាសនាពីដើម។ សូម្បីបញ្ហាស្មុគស្មាញ និងទំហំធំធេងនៃការកិច្ចបែបនេះ ជាឧបសគ្គរាំងសេចក្តីផ្តើមនេះ ខ្ញុំមិនអាច មិនបញ្ចូលនូវតម្រុយទូទៅខ្លះបានទេ។ *បុរាណៈ* មានចំណុចច្រើន ដែលដូចគ្នា ឬស្រដៀងគ្នានឹងខ្លឹមសារនៃមហាភារតៈ និងមនុ ហើយក្នុងករណីជាច្រើន គេមិនអាចសន្មតបានថា កំណាព្យស្របគ្នានោះ ត្រូវគេខ្ចីពីស្នាដៃក្រោយទេ។ *បុរណៈ* ដែលមួយចំនួន ដូចជាពាក្យ*វាយុ* (Vāyu)សូម្បីជាទម្រង់បច្ចុប្បន្នក្តី ក៏សំដៅដល់សម័យបូរាណយូរលង់ដែរ ជាការចងក្រង តាមក្រុមនិកាយ សាសនានូវទេវកថាទស្សនវិជ្ជា ប្រវត្តិ និងនីតិពិសិដ្ឋ ដើម្បីការប្រើប្រាស់ដូចពេលនេះ សម្រាប់បង្រៀន ដល់វណ្ណៈដែលគ្មានអក្សរប្រើ រួមទាំងការបែងចែក វណ្ណៈសូទ្រៈ ដាច់ពីវណ្ណៈខ្ពស់ ដែលគេហៅថា សក្ខូទ្រៈ។ តាមធម្មតាគឺថា អ្នកនិពន្ធអត្ថបទទាំងនោះ គួរតែមានចំណែកនៃកំណាព្យគតិបណ្ឌិត នៃសាលាទស្សនវិជ្ជានិងច្បាប់។ ការប្រៀបធៀបអំពីអត្ថបទពុទ្ធសាសនាពីដើម មានលក្ខណៈជាការអប់រំពិសេស ពីព្រោះអ្នកកាន់ពុទ្ធសាសនាមានសាលាទស្សនវិជ្ជាឯកទេសមួយ ហើយដោយសារស្នាដៃដ៏ចំណាស់ជាងគេរបស់ពួកគេ ទោះបីភាគច្រើនជាពាក្យរាយក្តី ក៏មានស្លោកជាច្រើន ក្នុងនោះ មួយចំនួនធំជាជាធម្មបទ មានភាពដូចគ្នានឹងកំណាព្យរបស់មហាភារតៈ និងរបស់មនុផងក៏មាន។ ស្លោកទាំងឡាយហាក់ដូចជាឃ្លាំងស្តុកនៃកាព្យសុភាសិតបូរាណ និងបន្ថែមនូវពុទ្ធភាសិតថ្មីៗយ៉ាង

ច្រើន។) ។ ដូចនេះ ចម្លើយដែលយើងមានកាតព្វកិច្ចត្រូវឆ្លើយនឹង សំណួរថាតើអ្នកត្រួតពិនិត្យ មនុស្ម្រិតិរបស់យើង មានបន្ថែមសម្ភារៈរបស់គាត់ពីចំណុចណា មានចំណុចស្របគ្នាយ៉ាងច្រើនជាមួយនឹងសម្មតិកម្មរបស់សាស្ត្រាចារ្យ Hopkins ដែលដូចបានជម្រាបជូនខាងដើម ចាត់ទុកគម្ពីរច្បាប់ ជាបណ្តុំនៃមានវធម៌សូត្រ និងភាសិតផ្សេងៗ ដែលថាព្រះ*មនុ* ជាបិតារបស់មនុស្សជាតិ។ ការដាក់ដែនកំណត់ក្រោយមកទៀត ខ្ញុំហាក់ដូចជាក្លៀនយោបល់ ពីព្រោះក្នុងចំណោមផ្នែកស្របគ្នាជាច្រើន ដែលមាននៅក្នុងមហាភារតៈតាមការប្រៀបធៀបខ្លះ មានលក្ខណៈជាប្រគាបតិ និងដោយសារហិណ្ឌូ ដែលមានជំនឿយ៉ាងខ្លាំងអំពីសច្ចៈនៃជំនឿ ដែលព្រះមនុបានបង្រៀនដំបូងបំផុតអំពីច្បាប់ពិសិដ្ឋ មានការស្ទាក់ស្ទើរក្នុងការអាងហេតុផលនោះ ដែលថាបណ្ឌិតហាក់ដូចជាពិនិត្យថាភាពសុភាសិតទាំងអស់ សូម្បីបណ្ឌិតជទែអះអាងពីប្រភពផ្សេងគ្នាក៏ដោយ។

ចម្លើយចំពោះសំណួរបន្ទាប់ ថាតើការផ្លាស់ប្តូរមានវៈធម៌សូត្រ មានសំអាងហេតុបច្ច័យនៅពេលមួយឬបន្តិចម្តងៗ និងថាតើការពិនិត្យសំណៅដើមរបស់ក្រិគុ ត្រូវគេចាត់ជាលទ្ធផលផ្ទាល់ ឬជាផលបន្តបន្ទាប់នៃសូត្រ ខ្ញុំគិតថា តោងតែមានចម្លើយ ដូចជាការសន្និដ្ឋានយ៉ាងប៉ិនប្រសប់នៅក្នុងការពិភាក្សាខាងដើម ក្នុងន័យកជម្រើសទី១។ មិនយូរប៉ុន្មានហាក់ដូចជាថា មានយោបល់ផ្ទុយមួយ។ ប៉ុន្តែពេលគេពិនិត្យពិច្ច័យឱ្យកាន់តែហ្មត់ចត់នូវការពិតដែលការមើលឃើញដំបូងចង់ទាញសេចក្តីសន្និដ្ឋានថា មនុសំហិតារបស់ក្រិគុ បង្កើតទំនាក់ទំនងចុងក្រោយជាចំណងទាក់ទងនៃកាព្យមនុស្ម្រិតិដ៏វែងនោះគេកាន់ តែមើលឃើញថា ការពិតមានសារៈសំខាន់តិចតួចឬគ្មានសារៈសំខាន់សោះ។ យ៉ាងណាមិញអំណះអំណាងទាំងនោះ ដែលនិយាយគាំទ្រអត្ថបទរបស់យើង បើមិនមែនអត្ថបទទី១ យ៉ាងហោចណាស់ក៏ជាបំណងមួយក្នុងចំណោមបំណងខាងដើមៗ តាមការកែប្រែគម្ពីរសិក្សាវេទ ទៅជាសៀវភៅច្បាប់ឯកទេស មានដំណើរដូចគ្នាក្នុងការអនុវត្ត និងបង្កើតចំនួន។ ចំណុចនានា ដែលបានលើកយកមកបង្ហាញតាមលំដាប់លំដោយដើម្បីសបញ្ជាក់ថា អត្ថបទដែលមានស្រាប់របស់មនុ ត្រូវបានទទួលនូវការតាក់តែងឡើងវិញច្រើនលើកច្រើនសា ពោលគឺទី១ មានបដិវាទកម្មយ៉ាងច្រើនទី២ មានសេចក្តីថ្លែងយ៉ាងច្បាស់អំពីប្រពៃណីហិណ្ឌូ ក្នុងបុព្វកថានាទស្ម្រិតិ ទី៣ ការដកស្រង់ពីព្រិហតមនុ និងវ្រិទ្ធមនុឃើញមាននៅក្នុងព្រឹត្តិបត្រច្បាប់នៅយុគកណ្តាល និងទី៤ សេចក្តីសម្រង់ដែលគ្មានប្រភព ឬមានប្រភពខ្លះ ពីធម៌សាស្ត្ររបស់មនុ ឃើញមាននៅក្នុងស្នាដៃសំស្ក្រឹតពីដើមៗ។ អត្ថិភាពនៃការពិតទាំងអស់នេះ ពិតជាមានមិនអាចប្រកែកបាន។ ប៉ុន្តែមិនពិបាកទេក្នុងការបង្ហាញថា ការពិតខ្លះ គ្មានប្រយោជន៍សម្រាប់ធ្វើជាអំណះអំណាងទេ ហើយការពិតខ្លះដែលទាមទារឱ្យមានការបកស្រាយ ប្រសើរជាងមុន នឹងនាំឱ្យមានសេចក្តីសន្និដ្ឋានផ្សេងៗ។ ហេតុនេះ ក្នុងការថ្លឹងថ្លែងតម្លៃនៃអំណះអំណាង ដែលមានសេចក្តីផ្ទុយគ្នា គេត្រូវចងចាំក្នុងចិត្តនូវព្រឹត្តិការណ៍ពីរ ដែលភាគច្រើនគេមិនបានរៀបរាប់ ៖ ទី១គឺថា នេះជាទម្លាប់ធម្មតារបស់អ្នកនិពន្ធឥណ្ឌា ដើម្បីលើកឡើងនូវយោបល់ដែលនាំឱ្យមានទំនាស់គំនិតដោយដាក់នូវប្រភពដ៏គួរឱ្យជឿបានដែលមានទម្ងន់ដូចគ្នានិងអាចជាជម្រើស ឬលើកឡើងនូវក្បួនច្បាប់សំខាន់ៗប្រចាំសម័យកាល ច្បាប់ជាទំនៀមទម្លាប់ និងស្ថាប័នសង្គម ហើយបន្ទាប់មកសម្តែង នូវការ

ជំទាស់នឹងក្បួនតម្រាទាំងនោះ ហើយទី២ គឺថា ដូចស្ម្រិតិរបស់យើង ក្នុងករណីណាក៏ដោយ ជាការរៀបចំឡើងវិញនូវព្រះសូត្រពីមុនៗ ដែលហេតុការណ៍តែមួយក៏គ្រប់គ្រាន់នឹងបង្ហាញពីភាពផ្សេងគ្នាខាងគំនិតបាន។ ដូចបានបង្ហាញខាងលើ(មើលទំព័រខាងលើ) ហើយថា សេចក្ដីផ្សេងគ្នាខ្លះ ដូចជាវគ្គស្ដីពីឋានៈរបស់ម្ដាយ និងគ្រូតាមលំដាប់ ឬស្ដីអំពីការអនុញ្ញាតឱ្យធ្វើពិធីអាពាហ៍ពិពាហ៍មួយចំនួន បង្ហាញនូវយោបល់ផ្ទុយគ្នា ដែលមាននៅក្នុងធម៌សូត្រផងដែរ។ មនុស្ម្រិតិ បោះពុម្ពជាថ្មីនូវទស្សនៈគំនិតពីបុរាណប៉ុណ្ណោះ ប៉ុន្តែលុបចោលនូវពាក្យកាព្យចាចែងអំពីហេតុផល ដើម្បីបញ្ជាក់ពីប្រភពនិងការអប់រំផ្សេងគ្នា។ ក្នុងករណីផ្សេងទៀត យើងមានការស្ទាក់ស្ទើររវាងការបកស្រាយពីរ។ តួយ៉ាង ប្រសិនបើយើងយល់ថា អត្ថបទរបស់យើងនៅក្នុងវគ្គទី៣ និងទី៩(មនុ ជំពូក ៣ លេខ ២៥, ៥១-៥៤ និងជំពូក ៩ លេខ ៩៨-១០០) រិះគន់យ៉ាងខ្លាំងចំពោះពិធីអាពាហ៍ពិពាហ៍អាសុរៈ និងក្នុងវគ្គទី៨ និងទី៩ ជាក្បួនតម្រាដែលសន្មតជាមុននូវភាពស្របច្បាប់នៃការលក់ ឬការជាវកូនក្រមុំ យើងអាចសន្មតបានថា ពាក្យសម្ដីទី១ គឺយោងតាមអត្ថបទកំណាព្យរបស់បណ្ណាធិការនិងថាសម្ដីទី២ ជាលទ្ធិធម៌សូត្រ ដែលហួសសម័យជាង។ ស្របតាមការសន្មតនេះគេអាចសំអាងថា មានវះគ្រីហ្យសូត្រ អនុញ្ញាតទាំងស្ទាក់ស្ទើរចំពោះការជាវកូនក្រមុំ(មើលទំព័រខាងលើ) ។ ប៉ុន្តែគេក៏អាចនិយាយថាធម៌សូត្រខ្លួនឯងមានទាំងការថ្កោលទោសទំនៀមទម្លាប់និងច្បាប់ទម្លាប់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍។ ភាពខុសគ្នាបែបនេះក៏កើតមាននៅក្នុងសូត្រដទៃទៀតដែរ។ ដូច្នេះអាបស្ដម្ភ ហាមឃាត់យ៉ាងច្បាស់ នៅក្នុងផ្នែកធម៌របស់គាត់ស្ដីពីការលក់និងការឱ្យកូន និងការបង្កើតកូនប្រុសក្សេត្រគៈ(អាប. ធ. ស. ជំពូក ២ លេខ ១៣, ១១; ១៧, ២)។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងស្រោត សូត្ររបស់គាត់ ជំពូក ១ លេខ ៩, ៧ គាត់បង្កើតវិធាន ដែលបង្ហាញវិធីរៀបចំពិធីបិណ្ឌបិត្រិយញ្ញរបស់កូនប្រុស ដែលមានឪពុកពីរ (ទ្វិបិតា)។ មនុស្សបែបនេះ អាចតែជាក្សេត្រគៈ ជាទ្វ្យាមុស្យាយន ទត្តកៈ ឬបុត្រិកាបុត្រប៉ុណ្ណោះ។ ប្រសិនបើគេនៅចាំក្នុងចិត្តថា ពោធាយនៈដែលស្នាដៃរបស់ខ្លួនផ្អែកលើសូត្ររបស់អាបស្ដម្ភ អាចមានការច្របាច់បញ្ចូល ដែលសមាជិកវិទ្យាវំសៈរបស់គាត់ក្រោយមកបដិសេធ នោះការបកស្រាយជាក់ស្ដែងនូវភាពផ្សេងគ្នា គឺថាអាបស្ដម្ភ ថ្វីដ្បិតគាត់មិនព្រមទទួលយកក្រៅពីបុត្រឱរសក៏ដោយ ក៏មិនហ៊ានប្រថុយប្ដូរការបញ្ញត្តិ ដែលគាត់ឃើញមាននៅក្នុងស្រោតសូត្រពីមុនៗនោះទេ។ ទំនងដូចគ្នានេះដែរ ការសន្មតថា អ្នកនិពន្ធមានវះធម៌សូត្រ ទោះបីមានការថ្កោលទោសពិធីអាពាហ៍ពិពាហ៍អាសុរៈក៏ដោយ ក៏មិនចង់លុបចោលក្បួនច្បាប់ស្ដីពីការលក់ គឺមិនអាចធ្វើបានទេ។ ការបកស្រាយតាមរបៀបទី១ ហាក់ដូចជាការប្រសើរជាង។ ចំពោះការហាមឃាត់ពិធីអាសុរ មាននៅក្នុងសេចក្ដីសម្រង់ ដែលឃើញមាននៅក្នុងសកុន្តលូបាខ្យាយ ហើយអត្ថបទក្រោយនេះ ដូចដែលយើងឃើញមាននៅពេលបច្ចុប្បន្នទំនងជាសំដៅដល់មានវះធម៌សូត្រ។ ផ្ដើមពីចំណុចនេះខ្ញុំគិតថា យ៉ាងហោចណាស់ កំណត់សម្គាល់នៅក្នុងមនុ ជំពូក៣លេខ២៦ ពិតជាមាននៅក្នុងអត្ថបទពីបុរាណ។ ការនិយាយឡើងវិញអំពីសញ្ចេតនាដដែលនេះ គេអាចបន្ថែមនៅពេលមានការសរសេរឡើងវិញ។ តួយ៉ាងដ៏ល្បីមួយទៀតអំពីបដិវាទកម្ម មនុ វគ្គ ៩ លេខ ៥៨-៧០ ដែលដំបូងមានការអនុញ្ញាតតែងតាំងស្ត្រីមេម៉ាយម្នាក់ ហើយបន្ទាប់មកហាមឃាត់ទៅវិញ ទំនងជាត្រូវគេបកស្រាយតាមរបៀបដូច

គ្នានេះ។ នៅចំណុចត្រង់នេះ ប្រសិនបើខ្ញុំយល់ផ្សេងពីសាស្ត្រាចារ្យ Jolly(មេរៀនតាហ្គ័រ ទំព័រ ៤៨, ៦១) និងអ្នកដទៃទៀត ដែលសំអាងលើការហាមឃាត់ចំពោះការបន្ថែមបន្ថយធម៌សូត្រ។ ហើយបើខ្ញុំប្រកាន់យកតាមទស្សនៈរបស់ព្រិហស្បតិ និងអ្នកអធិប្បាយឥណ្ឌាខ្លះទៀត ហេតុផលរបស់ខ្ញុំគឺថា ដូចសេចក្តីថ្លែងផ្ទុយគ្នាអំពីធម៌សូត្របង្ហាញស្រាប់ បែបបទរបស់និយោគ មិនត្រូវបានគេទទួលស្គាល់ជាទូទៅសូម្បីកាលពីសម័យបុរាណ និងថា និពន្ធការៈយុគកណ្តាល ជាញឹកញយប្រកាន់យកវិធីសាស្ត្របង្រៀនប្លែកៗរបស់ព្រះមនុ។ វិធីសាស្ត្រទាំងឡាយ ក៏រៀបរាប់អំពីទំនៀមទម្លាប់ផ្សេងៗពីមុនៗ បន្ទាប់មកបន្ថែមសម្តីថា បញ្ហាដែលបានបង្រៀន ត្រូវបានហាមឃាត់នៅសម័យកលិ។ ក្នុងចំណោមករណីជាក់ស្តែងដែលបដិវាទកម្មកើតឡើង ដោយការបន្ថែមបន្ថយរបស់អ្នកអធិប្បាយ ខ្ញុំអាចនិយាយពីសិក្ខាវិន័យថា មនុ ជំពូក៤ លេខ២២២ ពណ៌នាអំពីការលាងបាបចំពោះការទទួលយកអាហារដោយខុសច្បាប់ដែលខុសគ្នាពីច្បាប់ទម្លាប់នៅក្នុងជំពូក១១លេខ ១៥៣។ គេពិតជាចាត់ទុកវគ្គមុននេះ ថាមិនត្រឹមត្រូវទេ ដោយសារវាមាននៅក្នុងជំពូកមួយ ដែលគ្មាននិយាយពីការលាងបាបទេ។ ជាក់ស្តែងគឺថាគេមិនអាចប្រើឧទាហរណ៍ដែលទើបបានលើកឡើង និងតួយ៉ាងផ្សេងទៀត ដែល*ស្ម្រិតិ* របស់យើងបង្ហាញនូវច្បាប់ទម្លាប់បុរាណពីរផ្ទុយគ្នា ឬជាសិក្ខាវិន័យទំនើប ដែលផ្ទុយពីសិក្ខាវិន័យបុរាណ ធ្វើជាអំណះអំណាងថា មានវៈធម៌សូត្រ មានការថែមថយច្រើនលើសពីម្តង។ ក្នុងព្រឹត្តិការណ៍ទាំងអស់នេះ គេអាចពឹងផ្អែកលើបដិវាទកម្មទាំងឡាយដែលមាននៅក្នុងផ្នែកនៃអត្ថបទរបស់យើង ដែលគេចាត់ជាផ្នែកទំនើបបន្ថែមទៅលើធម៌សូត្រពីមុន និងដើម្បីអះអាង ឧទាហរណ៍ ភាពខុសគ្នានៅការពណ៌នា ពីរអំពីការបង្កើត(មើលបណ្ឌិត Johanntgen *ទស្សនាវដ្ដីវដ្ត ស្តីពីមនុ* ទំព័រ ១៥) គឺមនុ ជំពូក១ លេខ ៧-៥៨ និង ៦២-៨៦ សបង្ហាញថា ជំពូកទី១ មានទម្រង់បច្ចុប្បន្ន ជារបស់អ្នកនិពន្ធពីរផ្សេងគ្នា។ ទម្រង់បង្ហាញហេតុផលបែបនេះ ប្រាកដជាត្រឹមត្រូវ ប្រសិនបើការបន្ថែមទៅលើធម៌សូត្រ ជាការតាក់តែងឡើងតាមច្បាប់ដើមដោយឯករាជ្យនោះ។ ក៏ប៉ុន្តែដូចការពិភាក្សាខាងដើមស្តីពីប្រភពនៃបញ្ហាបន្ថែមនេះ បានបង្ហាញថា ជំពូកទី១ ជាការចងក្រងនូវការចងចាំកំណាព្យពីដើមៗ ដែលពិតជាមានផ្នែកជាច្រើន និងអាចជាការរៀបរាប់ទាំងស្រុងដោយមិនប្រាកដប្រជាផង។ កំណាព្យផ្ទុយគ្នា អាចត្រូវគេរៀបចំដាក់បញ្ចូលគ្នា ដូចមេធាតិថិ ហាក់ដូចជាបានផ្តល់យោបល់ គ្រាន់តែដោយសារវាពិតជា ឬត្រូវជាការបកស្រាយសេចក្តីវេទ ឬគេអាចសម្រួលវាជាមួយនឹងកាព្យផ្សេង តាមរយៈវិធីសាស្ត្រដ៏ប៉ិនប្រសប់ក្នុងការបកស្រាយរបស់អ្នកសិក្សាឥណ្ឌា ដែលជាមហាគ្រូនានា។

បើគិតពីអំណះអំណាងទី២ សម្តីអះអាងរបស់នារទស្ម្រិតិ(មើលទំព័រខាងលើ និងមេរៀនរបស់ចូលី, តាហ្គ័រ ទំព័រ៥៧) ដែលថាមនុបានតាក់តែងធម៌ សូត្រជាកំណាព្យចំនួន ១០០,០០០កាព្យ ដែលរៀបចំជា ១០៨០ជំពូកដែលបន្ទាប់មកនារទបំព្រួញមកត្រឹម១២,០០០កាព្យ,មារកន្ដេយបន្ថយមកត្រឹម ៨០០០ កាព្យ ហើយកូនរបស់ភ្រិគុ ឈ្មោះសុមតិ បំព្រួញមកត្រឹម ៤,០០០កាព្យ គឺជាដំណើរមួយថា ថ្វីបើមានការបំភ្លើសជាក់ស្តែងក៏ដោយ ក៏គេអាចចាត់ថាមានមូលដ្ឋាននៃការពិត និងជាការសំខាន់ចំពោះប្រវត្តិគម្ពីរច្បាប់របស់មនុ។ ការបំព្រួញស្នាដៃធំៗ(កំណែថ្មីពីររបស់នារទ លើកឡើងនូវតួយ៉ាងមួយដ៏គួរឱ្យចាប់ចិត្ត; សូម

មើល Jolly អត្ថបទដដែល ទំព័រ ៥៧) ជាទូទៅជាការពង្រីកស្នាដៃខ្លីៗ ឱ្យទៅជាអត្ថបទអក្សរសិល្ប៍។ ទោះជាយ៉ាងនេះក៏ដោយសម្ដីអះ អាងដែលរៀបរាប់នៅខាងលើ ដែលយើងអាចធ្វើតេស្ដបាន ពិតជាមិនត្រឹមត្រូវទេថា អត្ថបទរបស់នារទស្ដីពីច្បាប់របស់មនុ មានលក្ខណៈចំណាស់ជាងអត្ថបទរបស់សុមតិ ភារគវ ឬភ្រិគុ។ គេបានត្រឡប់ទីតាំងពិតប្រាកដនៃស្នាដៃទាំងពីរ។ វ្យវហារមាត្រិការបស់នារទ សឱ្យឃើញនូវការវិវត្តរីកចម្រើននៃទ្រឹស្ដីវិនិច្ឆ័យជាងសំហិតារបស់ភ្រិគុ និងមានបញ្ហាដែលបង្ហាញយ៉ាងប្រាកដប្រជាថាមិនអាចជាស្នាដៃដែលមានចំណាស់ជាងសតវត្សទី៤ឬទី៥នៅក្នុងសម័យយើងនេះទេ(WestនិងBuhler *ព្រឹត្តិបត្រ* ទំព័រ ៤៨-៥០ បោះពុម្ពលើកទី៣ សៀវភៅមេរៀនតាហ្គ័រ របស់ Jolly, ទំព័រ ៥៦: បុព្វកថាស្នាដៃ បកប្រែរបស់នារទ ទំព័រxv-xvii)។ដោយសារការធ្វើតេស្ដមិនបានជោគជ័យគេមិនអាចប្រើអំណះអំណាងរបស់នារទ សម្រាប់ការកំណត់លំដាប់អំពីការតាក់តែងអត្ថបទច្បាប់នានារបស់មនុ។ ទំនងជាគួរឱ្យជឿថា គេបានកំណត់ក្របខណ្ឌអំណះអំណាងដើម្បីលើកកម្ពស់ សារៈសំខាន់នៃនារទស្ម្រិតិស្ដីពីគំរូរឿងប្រឌិតសុទ្ធសាធនិយាយ អំពីដើមកំណើតធម៌ ដូចមានរៀបរាប់នៅក្នុងមហាភារតៈ ជំពូក១២ លេខ៥៩, ២២ និង៨០ បន្តបន្ទាប់ ដែលយើងបានដឹងថា ព្រហ្មន ដោយមានជំនួយពីអាទិទេព ដំបូងបានបង្កើតធម៌សាស្ត្រៈ ចំនួន១០០, ០០០ជំពូក ដែលត្រូវបានសង្ខេបឱ្យខ្លីដោយសំការៈនៅត្រឹម១០,០០០ជំពូក,ដោយឥន្ទ្រត្រឹម៥,០០០ ជំពូក, ដោយព្រិហស្បតិត្រឹម ៣,០០០ជំពូក និងដោយកាវ្យ ត្រឹម១,០០០អជ្ឈាយៈ។ ពាក់ព័ន្ធនឹងភាព ត្រឹមត្រូវនៃរឿងរបស់នារទ យើងក៏សំអាងលើសេចក្ដីបញ្ជាក់ពោរាណិក ស្របតាមការកែសម្រួលច្បាប់មនុ លើកដំបូងដោយភ្រិគុ, ទី២ ដោយនារទ, ទី៣ ដោយព្រិហស្បតិ និងទី៤ ដោយអង្គិរៈ(មណ្ឌលិក, *វ្យវហារមយុខ និងយញ្ញ* ទំព័រxlvii;មេរៀនតាហ្គ័រ របស់ Jolly, ទំព័រ ៤៤) ។

អំណះអំណាងទី៣ដែលកើតចេញពីហេតុការណ៍ថា និពន្ធកថានិងវិចារណកថាសម័យកណ្ដាលស្រង់សេចក្ដីពីព្រិហត (មហា) មនុ និងគម្ពីរមនុពីដើម នៅតែមិនសូវមានតម្លៃដដែល។ សាស្ត្រាចារ្យ Jolly បានបញ្ជាក់អះអាងជាចុងក្រោយនៅក្នុងការពិភាក្សារបស់គាត់អំពីសម្រង់សេចក្ដី ពីស្នាដៃទាំងឡាយ ដែលក្រោយមក គឺមិនមែនមុនអត្ថបទមនុដែលមានស្រាប់នេះទេ ពីព្រោះសិក្ខាវិន័យខ្លះនៃសម្រង់នោះ ប្រហាក់ប្រហែលនឹងការបង្រៀនរបស់យាញវល្ក្យ និងនារទ ចំណែកឯចំណុចផ្សេង ទៀតផ្ទុយពីមនុរបស់យើងត្រង់ចំណុច ដែលគាត់ប្រកាន់យកទស្សនៈយោបល់បុរាណ។ ម្យ៉ាងទៀត វគ្គមួយនៅក្នុងមនុវ្រិទ្ធ ដែលសាស្ត្រាចារ្យ Max Muller បានចាប់អារម្មណ៍មុនគេ(ឥណ្ឌា, តើគេអាចបង្រៀនអ្វីដល់យើង? ទំព័រ ៣៦៦) ទំនងជាមានសញ្ញាស្របគ្នានឹងហោរាសាស្ត្រក្រិក។ ខ្ញុំអាចយល់ស្របតាមសេចក្ដីសន្និដ្ឋានរបស់សាស្ត្រាចារ្យJolly ប៉ុណ្ណោះ និងបន្ថែមថា ការប្រៀបធៀបសេចក្ដីសម្រង់ពីព្រិហតមនុ និងវ្រិទ្ធមនុ ជាមួយនឹងសំហិតារបស់ភ្រិគុ ញ៉ាំងឱ្យមានចំណាប់អារម្មណ៍ថា បើតាមពិតចំណងជើងសំដៅលើស្នាដៃទាំងពីរ គឺមិនមែនសំដៅស្នាដៃតែមួយ នោះស្នាដៃទាំងពីរត្រូវគេពង្រីកនៅពេលមានកំណែក្រោយនេះ(ដើម្បីឱ្យអ្នកអានអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯង អំពីចំណុចនេះបាន ខ្ញុំសូមបន្ថែមបញ្ជីសម្រង់ ដែលខ្ញុំបានរកឃើញ។ បញ្ជីនោះស្រង់ពីព្រិហតមនុ *១. អត្ថបទព្រឹត្តិបត្រ* វគ្គ ២ លេខ៣, ២៦;*២. ព្រឹត្តិបត្រ* វគ្គ៥លេខ៤២៨ = *គី . ដៃ.* វគ្គ ១១ លេខ ៦, ៣៤; *៣. ទត្ត. មីម.* វគ្គ២ លេខ ៨; *៤. មយ.* វគ្គ ៤ លេខ៥, ៥៣; រហូតដល់សម្រង់ចេញពីវ្រិទ្ធមនុ *១. អត្ថបទ ព្រឹត្តិបត្រ* វគ្គ៣ លេខ ១, ៦៩; *២. ព្រឹត្តិ.* វគ្គ ៣ លេខ១, ៨៣; = *មយ.* វគ្គ១១ លេខ ៥ = *វិ. កិន្ត.* ទំព័រ ៩៩;

*៣. ព្រឹត្តិបត្រ* វគ្គ ៣ លេខ១, ៨៦ = *វិ. កិន្ត.* ទំព័រ ៨៩; *៤. ព្រឹត្តិ.* វគ្គ ៣ លេខ១, ៩០ =*មយ.* វគ្គ ១១ លេខ ៥ = *វិ. កិន្ត.* ទំព័រ ១០០; *៥. ព្រឹត្តិ. វគ្គ* ៣ លេខ១, ៩៣ = *វិ. កិន្ត.* ទំព័រ ១០៣; *៦. ព្រឹត្តិ. វគ្គ ៥* លេខ១៦២ = *វិ. កិន្ត.* ទំព័រ ២៧២ = *វេទ.* ទំព័រ២១, = *គី. ដាយ.* វគ្គ៩ លេខ ១៧ (ដែលសន្មតជាព្រិហត ម.); *៧. ព្រឹត្តិ.* វគ្គ៥ លេខ៤០៨ = *សម្រិ. កណ្ឌ.* វគ្គ ១១ លេខ១, ១៥ = *សរ. វិល.* លេខ ៥០៤ = *វេទ.*ទំព័រ ៣៣, ៤០ = *វីៈ* វគ្គ៣ លេខ១, ២ = *គី. ដៃ.* វគ្គ១១ លេខ១, ៧និង *វិ. កិន្ត.* ទំព័រ ២៨៩ (ដែលសន្មតជាព្រិហត ម.);*៨. មិត.* វគ្គ២ លេខ៥,៦ = *វិ. កិន្ត.* ទំព័រ ២៨៩ និងវេទ. ទំព័រ៣៧ (ដែលសន្មតជាព្រិហត ម.); *៩. វិ. កិន្ត* ទំព័រ១២៦-៧; *១០. វិ. កិន្ត.* ទំព័រ១៨០; *១១. វេទ.* ទំព័រ ៥០; *១២.វេទ.* ទំព័រ ២៨ ដែលដាក់ស្តែងហាក់ដូចជាស្រង់ចេញពី មនុ វគ្គ៩ លេខ ២០៦។) ។ ដូច្នេះហាក់ដូចជាថា មានការពិនិត្យសំណៅដើម ក្រោយមនុស្រ្មិតិរបស់យើង ហើយសម្រង់ដែលមានប្រភពខ្លះ ឬគ្មានប្រភព ខ្លះចេញពីធម៌សាស្រ្តៈរបស់មនុ នៅក្នុងវគ្រេសុគី(Weber *Indiche Streifen,* លេខ ១ ទំព័រ ១៩០, ១៩២, ១៩៨) របស់អស្វឃោសៈ និងពីមនុ ក្នុងព្រិហត សំហិតា(Kern *ព្រិហត សំហិតា* ជំពូក ៧៤ កាព្យ ៧-១៥ និងបុព្វកថា ទំព័រ៤៣) របស់វរាហមិហិរៈមានសារៈសំខាន់មិនច្រើនទេ។ បើនិយាយពីសេចក្តីបញ្ជាក់របស់វរាហមិហិរគួរកត់សម្គាល់អនុលោម តាមឥន្ទិករបស់អល្លីរូនី គឺថា សំហិតាហោរាសាស្រ្តពីរ ដែលហៅតាមមនុ មានសតវត្សទី១១ ក្រោយគ្រិស្តសករាជ ជាស្នាដៃតូចជាង ដែលសង្ខេបដោយអ្នកនិពន្ធជាមនុស្ស លោកដ៏ល្បីល្បាញបំផុត (អល្លីរូនី *ឥន្ទីកៈ* វគ្គ ១៤ និងសូមមើល Kern *ស្នាដៃដដែល* ទំព័រ ៤២ ដែលគេអាចឃើញមាននៅក្នុងមានវី សំហិតា។ អល្លីរូនី និយាយថា ចំណងជើងស្នាដៃទាំងពីរ គឺមានសៈ (មានវី?) និងថា ស្នាដៃមួយខ្លី ត្រូវបាននិពន្ធដោយ PNKL ជាអ្នកស្រុកដើមនៅឥណ្ឌាភាគខាងត្បូង។ ការបកស្រាយទាំងអស់ ធ្វើឱ្យខ្ញុំមានអារម្មណ៍ដឹងគុណចំពោះសមានចិត្តល្អរបស់សាស្រ្តាចារ្យ Sachau ជាបណ្ណាធិការដ៏មានចំណេះដឹង និងជាអ្នកបកប្រែស្នាដៃដ៏សំខាន់របស់អល្លីរូនី។) ។ ហេតុនេះ វរាហមិហិរអាចសរសេរកំណាព្យរបស់គាត់ផ្អែកលើចរិតលក្ខណៈរបស់ស្រ្តី ដែលមាននៅក្នុងស្នាដៃក្រោយនេះ។ នៅក្នុងសេចក្តីសម្រង់ទាំងពីរ ស្លោកដែលមិនមាននៅក្នុង*ស្រ្មិតិ*របស់យើង មានលក្ខណៈទំនើបច្រើន។ យ៉ាងណាមិញ ករណីនេះមានលក្ខណៈខុសពីសម្រង់ដែលយកចេញពីគម្ពីរមនុ ដែលដូចបានបង្ហាញខាងដើមមាននៅក្នុងមហាភារតៈ។ យើងត្រូវបង្ខំចិត្តនិយាយថា អត្ថបទស្រ្មិតិដែលមានស្រាប់របស់យើងមានអាយុកាលក្មេងខ្ចីជាងវីរកថា។ ដូចនេះ ប្រសិនបើសៀវភៅច្បាប់ក្រោយនេះ មិនមែនជាធម៌សូត្របុរាណ យើងក៏ត្រូវតែយល់ស្របតាមអត្ថិភាពនៃអត្ថបទកែសម្រួលលើកទី២ ដែលមានមុនសំហិតារបស់ក្រិគុ។ ដំណោះស្រាយបញ្ហានេះ គឺមានការពិបាកណាស់ ដោយសារការដកស្រង់ខ្លីពេក។ ក៏ប៉ុន្តែ បើពិចារណាសាច់រឿងទាំងអស់ ខ្ញុំសូមសន្មតថា អ្នកនិពន្ធ ឬស្មេរមហាភារតៈ បានចេះដឹងតែធម៌សូត្រប៉ុណ្ណោះ។ លក្ខណៈនៃកំណាព្យមួយ ហើយពាក់កណ្តាល ដែលត្រូវដកស្រង់សូត្រដោយផ្ទាល់មាត់ ព្រមទាំងសេចក្តីបកស្រាយនៅក្នុងសកុន្ត លូបាខ្យាន ស្របគ្នាល្អជាមួយនឹងសម្មតិកម្មនេះ ពីព្រោះមានវៈធម៌សូត្រ ដូចដែលយើងបានឃើញស្រាប់នោះពិតជាមានស្លោកជាច្រើន។ ម្យ៉ាងទៀតការពិតបញ្ជាក់បន្ថែមថា មហាភារតៈមិនមានការខុសប្លែកគ្នាក្នុងការរៀបចំ ឬគ្រាន់តែគ្មានការរៀបចំច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌឱ្យផ្សេងគ្នាពីធម៌សូត្រ។ យ៉ាងណាមិញ វីរកថាមានកំណាព្យជាច្រើននិយាយអំពីប្រធានបទទាំងអស់នេះ ហើយគ្មានកន្លែងណាមួយមានភាពស្របគ្នានឹងចំណងជើង ១៨ នៃច្បាប់ដែលមានលក្ខណៈជាស្រ្មិតិទី២ ជាសៀវភៅក្បួនច្បាប់របស់សាលាឯកទេស។ មួយវិញទៀត យើងអាចរំលឹកថា មហាភារតៈមិនបាននិយាយពីធម៌សូត្រទេ និងថា ទិដ្ឋភាពទូទៅស្តីពីដើមកំណើតនៃច្បាប់

ពិសិដ្ឋនេះ ត្រូវគ្នានឹងទិដ្ឋភាពដែលមាននៅក្នុងសៀវភៅច្បាប់ក្រោយៗ។ មានន័យថាពាក្យប្រៀនប្រដៅផ្នែកសីលធម៌ និងច្បាប់ ត្រូវបានលាតត្រដាង ដើម្បីជាប្រយោជន៍សម្រាប់អម្បូរមនុស្សដំបូងបំផុតដោយព្រហ្ម៊ន បង្ហាញដល់ឫសីជាច្រើនតាមទេវកថា ហើយពួកឫសីបាននាំយកពាក្យប្រៀនប្រដៅនោះមកអប់រំដល់មនុស្សជាតិ។ ទោះជាយ៉ាងនេះក៏ដោយ យើងឃើញមានការបដិសេធ ដែលមិនមែនមិនសមហេតុផលថា នៅពេលដែលមហាភារតៈត្រូវបានតាក់តែងឡើង គេបានភ្លេចប្រភពដើមពិតប្រាកដនៃសូត្រពីដើមបាត់ទៅហើយ ចំណែកឯអត្ថបទនៅមិនទាន់មានការកែប្រែឱ្យខុសពីច្បាប់ដើមនៅឡើយទេ។ អ្វីៗដែលបានជម្រាបជូនខាងដើមអំពីការ កើនឡើងនូវសាលាច្បាប់ឯកទេស និងការពិត ដែលយើងបានដឹងពាក់ព័ន្ធនឹងការកែប្រែតាមទម្លាប់ ចំពោះព្រះសូត្ររបស់ព្រះគោតម និងវសិស្ថ បង្កើតនូវសម្មតិកម្មជាបណ្ដោះអាសន្នមួយ ដែលមិនមែនសុទ្ធតែមិនគួរឱ្យជឿទាំងអស់ដែរ។ យ៉ាងណាមិញប្រសិនបើគេគិតថា មិនអាចបដិសេធលទ្ធភាពតាក់តែងកំណាព្យមានវសូត្រ មុននឹងកំណត់ថា ភ្រិគុជាអ្នកនិពន្ធយ៉ាងហោចណាស់គេអាចនិយាយថាគ្មានការរៀបចំសម្រួលផ្នែកវោហារតាមចំណងជើងនានា។

ដូច្នេះក្នុងពេលដែលគ្មានសក្ខីកម្មចំពោះយោបល់ដែលថា មនុស្ម្រិតិផ្នែកទំនើប ត្រូវបានបន្ថែមបន្តិចម្ដងៗពីពេលមួយទៅពេលមួយ ឬថា អត្ថបទបច្ចុប្បន្នជាពន្លឺចុងក្រោយមួយជាប់ពាក់ព័ន្ធនឹងអត្ថបទកំណាព្យកែសម្រួល មានចំណុចជាច្រើន ដែលហាក់ដូចជាបង្ហាញថា មនុសំហិតា ជាបំណងមួយដំបូងបង្អស់ ក្នុងការកែសម្រួលធម៌សូត្រ។ អំណះអំណាងដ៏សំខាន់បំផុតចំពោះការប្រៀបធៀប កាលបរិច្ឆេទដំបូងរបស់អត្ថបទ មានភាពមិនពេញលេញនិងភាពផ្ទាំផ្ទួងនៃវិធានស្ដីពី នីតិវិធីដំណើរការតុលាការ និងស្ដីពីច្បាប់រដ្ឋប្បវេណី(មើលប្រធានបទនេះ និងការពិភាក្សាខាងក្រោម Weber, *ប្រវត្តិអក្សរសាស្ត្រឥណ្ឌា* ទំព័រ ២៧៩-២៨១; Stenzler *យញ្ញវល្ក្យ* ទំព័រvii-x;ព្រឹត្តិបត្ររបស់អាល្លឺម៉ង់ ឫសង្គម លេខ ៩ ស្ដីពីបទពិសោធន៍មិនល្អរបស់ឥណ្ឌា និងមេរៀនតាហ្គ័រ របស់ Jolly, ទំព័រ៤៥-៤៩) ។ ប្រសិនបើយើងប្រៀបធៀបសិក្ខាវិន័យទាំងអស់នេះជាមួយនឹងសិក្ខាវិន័យធម៌សូត្រនិងជាមួយនឹងសិក្ខាវិន័យកំណាព្យស្ម្រិតិដទៃទៀតសិក្ខាវិន័យទាំងឡាយច្បាស់លាស់ជាងធម៌សូត្របន្តិច ប៉ុន្តែមានតម្លៃទាបជាងច្រើនស្ម្រិតិ។ គិតតាមនីតិក្រម *មនុស្ម្រិតិ* ផ្ដោតខ្លាំងទៅលើផ្នែកសីលធម៌នៃករណីយកិច្ចសម្រាប់ចៅក្រម និងអ្នកពាក់ព័ន្ធផ្សេងទៀត ជាងការផ្ដោតទៅលើផ្នែកបច្ចេកទេស ដែលពណ៌នាយ៉ាងច្បាស់លាស់ និងលម្អិតជាងនៅក្នុងធម៌សាស្ត្រៈ នៃយញ្ញវល្ក្យ និងនារទ។ ក្នុងន័យនេះធម៌សូត្រនេះ ជាពិសេសហាក់ដូចជាមិនបានរៀបរាប់ក្បោះក្បាយ ជាលាយលក្ខណ៍អក្សរអំពីទុក្ខសោក និងភ័ស្តុតាងឯកសារព្រមទាំង មានការសង្ខេបនូវពាក្យសម្ដីអំពីបទពិសោធន៍មិនល្អ។ ក្នុងចំណោមសៀវភៅច្បាប់បុរាណទាំងឡាយ សៀវភៅវសិស្ថធម៌សាស្ត្រៈ ជាសៀវភៅតែមួយគត់ ដែលមាននិយាយអំពីឯកសារលាយលក្ខណ៍អក្សរ និងរាប់ឈ្មោះឯកសារនោះជំពូក១៦ លេខ ១៤-១៥ ជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានាក្នុងការបង្ហាញ តឹកតាងស្របច្បាប់។ នៅក្នុងធម៌សូត្រដទៃទៀត គ្មានសក្ខីកម្មបង្ហាញថា អ្នកនិពន្ធធម៌សូត្រនោះ មានសិល្បៈក្នុងការតែងនិពន្ធទេ។ ខ្ញុំបានគូសបញ្ជាក់រួចហើយនៅក្នុងសេចក្ដីផ្ដើមនៃការបកប្រែស្នាដៃ វសិស្ថ(គម្ពីរពិសិដ្ឋបូព៌ាប្រទេស លេខ១៦ ទំព័រ xxvi) របស់ខ្ញុំថា អ្វីដែលគេលុបចោលនេះទំនងជាត្រូវបានបកស្រាយពន្យល់ មិនមែនដោយការសន្មតថានៅសម័យគោតមទេ។ គេមិនបានដឹងឬប្រើប្រាស់តិចតួចនូវសំណេ

រពោជាយនៈ និងអាបស្តម្ភនៅប្រទេសឥណ្ឌា ប៉ុន្តែយើងបានពន្យល់តាមរយៈការពិចារណាថា លក្ខណៈទូទៅនៃធម៌សូត្រ ដែលយកចិត្តទុកដាក់ជាពិសេសចំពោះផ្នែកសិល្បឹតម្លៃរបស់ច្បាប់ មិនទាមទារឱ្យមានការណែនាំបញ្ហានានាដែលទំនងជាមាននៅក្នុងទំនៀមទម្លាប់របស់ប្រទេស ឬជាអាថ៌សាស្ត្រ។ គេអាចគិតអំពីការកើតមាននូវសំណេរក្នុងអំឡុង សម័យពីមុនៗ និងពីតម្លៃនៃការបកស្រាយរបស់ខ្ញុំ គេអាចយល់បានយ៉ាងច្បាស់ថា មនុសំហិតារបស់ ភ្រិគុ ស្ថិតក្នុងសម័យដែលសិល្បៈតែងនិពន្ធ ត្រូវបានគេទទួលស្គាល់និងអនុវត្តជាទូទៅ។ ជាលើកដំបូង យើងរកឃើញសេចក្តីបញ្ជាក់ច្បាស់លាស់ពីរចំពោះឯកសារសំណេរថា "អ្វីៗត្រូវគេសរសេរដោយបង្ខំ" (លិខិត វគ្គ ៨ លេខ ១៦៨) និងព្រះរាជបញ្ញត្តិ (សាសន ជំពូក៩ លេខ ២៣២)។ ទី២ យើងឃើញមានពាក្យ *និពន្ធ* "កត់ត្រា" នៅក្នុងវគ្គមួយ (ជំពូក ៨ លេខ២៥៥) ដែលបរិបទបង្ហាញច្បាស់ថានេះជាការសរសេរបន្ថែម។ នៅពេលមានពាក្យនេះនៅចំណុចនោះ ក្នុងរឿងទំនាស់ ព្រំប្រទល់ ព្រះមហាក្សត្រិយ៍ត្រូវកត់ត្រាព្រំប្រទល់ស្របតាមការថ្លែងជាឯកច្ឆ័ន្ទរបស់សាក្សីរួមទាំងឈ្មោះរបស់ពួកគេ ហើយការគិតថាតើព្រះអង្គអាចធ្វើដូច្នេះបាន ដោយគ្មានឯកសារលាយលក្ខណ៍អក្សរ ដែលចាំបាច់ត្រូវមានអំណាចផ្លូវច្បាប់សម្រាប់ពេលអនាគតយ៉ាងណានោះ គឺជាបញ្ហាមួយពិបាកយល់។ ការប្រើពាក្យ កិរិយាស័ព្ទ និពន្ធអាចញ៉ាំងឱ្យមានជំនឿថែមទៀតថា មេធាទិថិ មិនមែនខុសទាំងស្រុងទេ នៅពេលគាត់បកស្រាយ (ជំពូក៣ លេខ ៧៦) សមាសពាក្យ *អនិពន្ធ* គឺ "អ្នកដែលគេចាត់តាំង (ឱ្យធ្វើជាសាក្សីកិច្ចការណាមួយ)" ដោយ "បុគ្គលម្នាក់ដែលមិនអាច (ធ្វើជាសាក្សីនៅក្នុងឯកសារនោះបាន)" និងសំដៅដល់វិធានសម្រាប់រឿងក្តីកម្ចី និងកិច្ចពាណិជ្ជកម្មផ្សេងៗទៀត។ ទី៣ មានពាក្យ *ករណៈ* (ជំពូក៨ លេខ៥៤និង១៥៤) ដែលសូម្បីមិនសូវច្បាស់លាស់ក៏ដោយក៏ដូចជាសំដៅដល់ការប្រើប្រាស់ ការធានាជាលាយលក្ខណ៍អក្សរចំពោះកម្ចី។ វគ្គខាងដើម ប្រកាសថា "បំណុល ដែលត្រូវបញ្ជាក់ភ័ស្តុតាងដោយ *ករណៈ*" (ករណេន វិភាវិតំ) ត្រូវតែសងវិញ ហើយអ្នកអត្ថកថា បកស្រាយពាក្យ *ករណៈ* មានន័យថា "កិច្ចធានាជាលាយលក្ខណ៍អក្សរសាក្សី ជាដើម"។ ដូច្នេះយើងអាចបកប្រែពាក្យនេះថា "ភ័ស្តុតាងត្រឹមត្រូវ"។ កាព្យ១៥៤ បង្គាប់ថា កូនបំណុល "ដែលមិនអាចសងបំណុល (តាមពេលកំណត់) ចង់ធ្វើកិច្ចសន្យាថ្មី អាចធ្វើ *ករណំ* ជាថ្មី (ន័យត្រង់គឺ ធ្វើថ្មី) (ករណំ បរិវៃតយិត(ការអាន *ការណំ* របស់លោក ននួន គឺជាការភាន់ច្រឡំ; សូមមើលទំព័រខាងក្រោម))។ អ្នកអត្ថកថាពីររូប កុល្លូកៈ និងរាឃវៈ ប្រើពាក្យនេះ នៅចំណុចនេះក្នុងន័យ "កិច្ចធានាជាលាយលក្ខណ៍អក្សរ" ចំណែកឯងអ្នកមុនៗ មានគោវិន្ទ នារាយណៈ និងទំនងជាមេធាទិថិផងដែរ បកស្រាយពាក្យនេះថា "ការធានា" នឹងធ្វើឡើងដោយមានការយល់ព្រមនៅចំពោះមុខសាក្សី។ ផ្តើមចេញពីការបកស្រាយនិងការប្រើប្រាស់ពាក្យ *ករណៈ* នៅក្នុងស្នាដៃច្បាប់ដទៃទៀត ហាក់ដូចជាសបញ្ជាក់ថា *ករណៈ* គេក៏អាចលើកជាសេចក្តីសំអាងជាសាក្សី សម្រាប់សម្គាល់អ្នកនិពន្ធរបស់យើងតាមសិល្បៈតែងនិពន្ធ។ ដើម្បីសន្និដ្ឋានថា ស្នាដៃនេះពិតជា ត្រូវបានប្រើប្រាស់យ៉ាងច្រើននៅក្នុងផ្នែកពាក់ព័ន្ធការធ្វើធុរកិច្ច ចុងក្រោយបំផុតច្បាប់ទម្លាប់របស់មនុត្រូវកែសម្រួលឱ្យស្របតាមសភាពអារ្យធម៌ទាំងស្រុង។ កិច្ចពាណិជ្ជកម្មដែលមានការអភិវឌ្ឍខ្លាំងតាមផ្លូវគោក និងផ្លូវសមុទ្រ (ជំពូក ៨ លេខ ១៥៦-១៥៧) ដែលផ្អែកលើករណីយកិច្ចសិល្បឹតម្លៃ(ជំពូក

៨ លេខ ៤០១-៤០៣) វត្តមាននៃបញ្ញើតម្លៃផ្លូវការ ដែលត្រូវធ្វើឡើងជាថ្មីតាមពេលកំណត់(ជំពូក ៨ លេខ ៤០១-៤០៣) ប្រព័ន្ធស្មុគស្មាញនៃការគណនាការប្រាក់ ក្នុងនោះយើងរកឃើញការប្រាក់រួម(ជំពូក៨ លេខ ៤០១-៤០៣) និងការបង្កើតឱ្យមាននិក្ខេប(ជំពូក ៨ លេខ ១៦៥) ពិតជាមិនអាចធ្វើទៅបាន ដោយគ្មានឯកសារលាយ លក្ខណ៍អក្សរទេ។ ការពិតទាំងអស់នេះសម្រាប់ខ្ញុំហាក់ដូចជាសបញ្ជាក់យ៉ាងច្បាស់ថា សូម្បីវគ្គទាំងអស់ ដែលលើកមកសំអាងខាងលើ ដែលរៀបរាប់ច្បាស់ជាឯកសារលាយលក្ខណ៍អក្សរ អាចបញ្ជាក់ថា ជាការថែមថយក្រោយហើយទិដ្ឋភាពទូទៅនៃចំណោទបញ្ហានេះនៅដដែលដោយគ្មានការកែប្រែ។ អនុលោម តាមព្រឹត្តិការណ៍ទាំងអស់នេះ បើសិនជាវិធានច្បាប់របស់មនុ ស្តីពីភ័ស្តុតាងគ្មានអ្វីជាក់លាក់ ស្តីពីការអនុញ្ញាតឱ្យមានឯកសារ ហើយបើសិនជា *មនុ* យល់ស្របក្នុងរឿងនេះ ជាពិសេសតាមធម៌សូត្រ និងខុសគ្នាឆ្ងាយពីធម៌សាស្ត្រៈរបស់យាញ្ញវល្ក្យនិងនារទព្រមទាំងកំណាព្យ*ស្ម្រិតិ* ដទៃទៀត។ ការលុបចោលនេះ មានសារៈសំខាន់ណាស់ សម្រាប់ជំហរគោលប្រវត្តិសំហិតា។ ថ្វីដ្បិតតែយើងបកស្រាយបញ្ហានេះ ទៅតាមការសង្កេតរបស់បណ្ណាធិការក្តីឬដោយសម្មតិកម្មថា *មនុ* បានទុកការកំណត់តម្លៃឯកសារលាយលក្ខណ៍អក្សរនេះ អាស្រ័យលើទម្លាប់ ឬសាស្ត្រមួយទៀតក្តី ក៏អាចបង្ហាញថា គាត់បានដឹងអំពីធម៌សូត្រតែមួយឬដឹងដោយធម៌សូត្រនានា និងកំណាព្យស្ម្រិតិនេះមិនរាប់បញ្ចូលនូវផ្នែកស្តីពីឯកសារទេ។ ប្រាកដណាស់គាត់ជាអ្នកប្រកាន់ខ្ជាប់នូវសាលាច្បាប់តាមឯកទេស និងដោយផ្អែកលើស្នាដៃរបស់គាត់ទាំង ស្រុងគាត់នឹងមិនបំភ្លេចចោលនូវចំណុចសំខាន់ដូច្នេះទេ ប្រសិនបើគាត់បានចេះដឹងពីសៀវភៅច្បាប់ដូច ជាយាញ្ញវល្ក្យស្ម្រិតិ។

ការលុបចោលបញ្ហាលម្អិតស្តីពីបទពិសោធន៍នានា ជាព័ត៌មានដែលមិនសូវសំខាន់។ គម្ពីរមនុ ជំពូក៨ លេខ ១០៩-១១៦ ពណ៌នាតែអំពីការចាត់ចែងពិធីសច្ចាប្រណិធានយ៉ាងក្បោះក្បាយច្រើន និងនិយាយពីការវិនិច្ឆ័យយ៉ាងប្រញាប់ប្រញាល់ដោយប្រើភ្លើងនិងទឹក។ ក្នុងចំណោមធម៌សូត្រនានា មានតែសូត្រ អាបស្តម្ពីយ (ជំពូក២ លេខ ២៩, ៦)ប៉ុណ្ណោះ ដែលណែនាំអំពីការប្រើសក្ខីកម្ម បែបអាទិទេព (ទេវៈ) ឬការពិសោធន៍តាមរបៀបទូទៅ ដោយគ្មានបន្ថែមអ្វីពិសេសទេ។ សៀវភៅច្បាប់ទី២ របស់យាញ្ញវល្ក្យ និងនារទ រៀបរាប់ពីការពិសោធន៍ ៥ ប្រភេទ ហើយសៀវភៅទី២នេះ លម្អិតជាងសៀវភៅទី១ អំពីវិធីដែលគេត្រូវធ្វើពិសោធ។ សូម្បីវិស្ណុស្ម្រិតិ ក៏យល់ស្របតាមវិធីទាំងអស់នេះ ហើយផ្នែកកំណាព្យ ស្ម្រិតិដែលបាត់បង្ហាញថា ស្នាដៃក្រោយភាគច្រើន មានផ្នែកដែលនិយាយដូចគ្នានឹងវិធីរបស់យាញ្ញវល្ក្យ និងនារទ។ តាមយោបល់របស់ខ្ញុំ ការយល់ឃើញដោយសំអាងលើចំណុច មិនបាននិយាយរបស់គោតម និងវសិស្ឋ ជាកំហុសមួយ គឺថា នៅសម័យបុរាណនៅឥណ្ឌា គេមិនបានដឹងពីការពិសោធន៍នេះទេ។ ប្រភពនៃការអនុវត្តបែបនេះ ដែលធ្លាប់មានពីមុន តាមរូបភាពជាច្រើនក្នុងចំណោមអម្បូរ ឥណ្ឌូ-អឺរ៉ុប ត្រូវបានគេរកឃើញ ដូចការរំពឹងទុកនៅក្នុងស្នាដៃវេទនានា។ ប្រសិនបើអ្នកនិពន្ធធម៌សូត្រ បំភ្លេចចោលវិធីនេះ ឬគ្រាន់តែបង្ហាញថា ការបកស្រាយដ៏ត្រឹមត្រូវអំពីហេតុការណ៍នេះ ក៏ដើម្បីថាពួកគេបានចាត់ទុកប្រធានបទនេះ មិនសូវសំខាន់ ដើម្បីសរសេរលម្អិត ហើយក៏ទុកការអនុវត្តវិធីនេះទៅតាមទម្លាប់ទៅចុះ។ អ្នកនិពន្ធស្ម្រិតិទី២ តាមពិតខ្វល់ខ្វាយចង់បំពេញចន្លោះខ្វះខាត ដែលអ្នក

ជំនាន់មុនបានបន្សល់ទុក។ ក៏ប៉ុន្តែពួកគេគ្មានអ្វីក្រៅតែពីយកទំនៀមទម្លាប់នៅតាមភូមិស្រុកនានា មកចងក្រងជាប្រព័ន្ធមួយ ដែលមានលក្ខណៈកាន់តែពេញលេញឡើងៗបន្តិចម្តងៗ។ យោងតាមព្រឹត្តិការណ៍បែបនេះ ហេតុការណ៍ដែលថាក្បួនច្បាប់របស់មនុ ស្ថិតនៅចំចំណុចកណ្តាល ក្បួនច្បាប់នៃធម៌សូត្រ និងនៃសៀវភៅកំណាព្យច្បាប់ ជាអំណះអំណាងមួយសម្រាប់ផ្តល់ឋានៈទី១ ដល់សំហិតារបស់គាត់។ តាមរបៀបដោះស្រាយច្បាប់រដ្ឋប្បវេណីនិងព្រហ្មទណ្ឌ កម្រិតទាបនៃមនុ ស្មិតិជាងធម៌សាស្ត្រៈដទៃដែលស្ថិតក្នុងថ្នាក់ជាមួយគ្នា ព្រមទាំងទាបជាងធម៌សាស្ត្រៈរបស់យាញ្ញវល្ក្យ ដែលមានមានចំនួនកាព្យតិចជាងស្តីពីវ្យវហារៈ ស្តែងឱ្យឃើញដោយខ្លួនឯងតាមរបៀបផ្សេងៗ។ ទោះបីមានបំណងក្នុងចំណាត់ថ្នាក់តាមបែបវិទ្យាសាស្ត្រនូវក្បួនច្បាប់នានា តាមចំណងជើងមួយចំនួនក៏ដោយ ក៏ការរៀបចំផ្នែកទាំងអស់នេះសឱ្យឃើញនូវភាពមិនរៀបរយ និងគ្មានសណ្តាប់ធ្នាប់។ មានការនិយាយពីរដងនៅចុងជំពូកទី ៨ និងទី៩។ យើងឃើញមានការប្រមូលផ្តុំក្បួនច្បាប់ផ្សេងៗ ដែលតាមការប្រៀបស្នាដៃរបស់យាញ្ញវល្ក្យ និងនារទ បង្ហាញថា យើងងាយស្រួលនឹងធៀបតាមមាតិកា ឬផ្នែកមាតិកាដទៃទៀតចំនួន១៨។ ក្នុងចំណោមតែមួយ ជួនកាលក្បួនច្បាប់ ត្រូវគេរៀបចំយ៉ាងគ្មានរបៀបរៀបរយ។ ជាពិសេសយើងអាចមើលឃើញភាពមិនរៀបរយនេះ នៅក្នុងជំពូកស្តីពីការស្នងមរតក ដើម្បីលើកឧទាហរណ៍ជាក់ស្តែងបំផុតអំពីកង្វះការយកចិត្តទុកដាក់ គឺល្បះដែលបន្ថែមសិទ្ធិរបស់ម្តាយនិងជីដូន អាចទទួលមរតកពីកូន ឬចៅ ដែលបានចែកឋានទៅមុន ត្រូវដាក់មិនត្រូវកន្លែងបានល្អ ដូច្នេះគេមិនអាចស្មានដឹងទីកន្លែងណាដែលជាវគ្គស្តីពីទាយាទ ដែលអ្នកនិពន្ធចង់និយាយនោះទេ។ ដូចបានបញ្ជាក់ខាងលើ បណ្ណាធិការពិនិត្យធម៌សូត្របុរាណ ទំនងជាបានបញ្ចូលកាព្យនេះ។ ប្រសិនបើគាត់យកចិត្តទុកដាក់ចំពោះភាពមានរបៀបរបប និងភាពងាយយល់ នោះគាត់មិនគួរពេញចិត្តនឹងការពោលភាសិតដែលមនុស្សទាំងអស់ពិតជាទទួលបានមរតកទេ ប៉ុន្តែគាត់គួរតែចង្អុលបង្ហាញកន្លែងឬវគ្គណាពាក់ព័ន្ធនឹងវគ្គមុនស្តីពីទាយាទ ដែលត្រូវកាត់ផ្តាច់ដើម្បីបន្ថែមខ្លឹមសារមួយចំនួន។ ការដាក់ជាប្រចាំនូវការអប់រំផ្នែកសីលធម៌ បញ្ចូលជាមួយក្បួនច្បាប់ និងការផ្តល់ឱវាទអំពីយន្តការវិនិច្ឆ័យដ៏ហួសសម័យ ដែលជាទូទៅជាដំណាក់កាលដើមនៃការអភិវឌ្ឍច្បាប់ ក៏មានសារៈសំខាន់ណាស់ដែរ។ ថ្វីបើករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ក្នុងការការពារអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ និងការទប់ស្កាត់ជនកំណាច ត្រូវបានបកស្រាយយ៉ាង ពេញលេញនៅក្នុងជំពូកទី៧ក៏ដោយ ក៏ប៉ុន្តែនៅផ្នែកស្តីពីចោរកម្ម (ជំពូក៨ លេខ ៣០២-៣១១) ស្តីពីអំពើហិង្សា (ជំពូក ៨ លេខ ៣៨៣-៣៨៧) និងស្តីពីការផិតក្បត់(ជំពូក ៨ លេខ ៣៨៦-៣៨៧) អ្នកនិពន្ធសរសេរយ៉ាងវែងអន្លាយម្តងហើយម្តងទៀត អំពីភាពចាំបាច់នៃការរួចផុតពីបទល្មើសបែបនេះ។ ក្នុងករណីទី២ វិធានច្បាប់ជាក់លាក់ ដែលចែងពីការដាក់ទោសបទឧក្រិដ្ឋប្រព្រឹត្តសាហស (អំពើហិង្សា) ត្រូវបំភ្លេចចោល ឬត្រូវលុបចោល ដោយសារមានការកែសម្រួលនៅចុងជំពូកទី៩។ ទាំងយាញ្ញវល្ក្យនិងនារទ គិតថាចំណុចនេះមិនមានការចាំបាច់លើកឡើងម្តងទៀតអំពីកាតព្វកិច្ចផ្នែកសីលធម៌របស់ព្រះ មហាក្សត្រិយ៍ បន្ទាប់ពីចង្អុលបង្ហាញម្តងរួច ហើយ។ លោកទាំងពីរ ក៏ចៀសមិននិយាយអំពីឧបាយកលប្លែកៗ ដែលមនុ ណែនាំ (ជំពូក៨ លេខ ១៨២-១៨៤) សម្រាប់ការធ្វើសេចក្តី

សម្រេចវិវាទគួរឱ្យសង្ស័យ ពាក់ព័ន្ធនឹងបញ្ញើ។ ចំណុចដ៏សំខាន់មួយទៀត គឺថាវិធានច្បាប់របស់មនុស្ម្រឹតី ពីចំណងជើងខ្លះ មិនមានភាពពេញលេញច្រើនទេ ហើយនិយាយត្រូវរឿងតែមួយ ដែលមិនងាយស្រួលក្នុងការធ្វើសន្និដ្ឋានគោលការណ៍ទូទៅទេ។ ដូច្នេះ ក្នុងការចាត់ទុកជាការសង ឬការមិនព្រមសងនូវអំណោយ មនុ (ជំពូក ៨ លេខ ២១២-២១៣) កំណត់ពាក្យសម្ដីរបស់គាត់ត្រឹមតង្វាយជំនឿសាសនា ដែលមិនអាចអនុវត្តតាមរបៀប ដែលមានចែងនេះទេ។ យាញ្ញវល្ក្យ (ជំពូក២ លេខ១៧៥-១៧៧) ដាក់ចំណងជើងនេះ យ៉ាងហោចណាស់សម្រាប់គោលការណ៍ទូទៅមួយចំនួន ដែលបង្ហាញនូវអ្វីដែលចាំបាច់សម្រាប់ភាពត្រឹមត្រូវនៃតង្វាយ ចំណែកឯលោកនារទ(អត្ថបទបកប្រែរបស់សាស្ត្រាចារ្យ Jolly ទំព័រ ៥៩-៦០) ធ្វើការបរិយាយពេញលេញ និងជាប្រព័ន្ធនូវច្បាប់ទាំងមូលស្ដីពីតង្វាយ។ ការវិវត្តបន្តិចម្ដងៗដូចគ្នានេះ អាចពិនិត្យមើលបានតាមចំណងជើងផ្សេងទៀត ជាពិសេសពាក់ព័ន្ធនឹងអ្នកចូលហ៊ុន និងវិការនៃកិច្ចសន្យាលក់និងទិញ វិធានច្បាប់ក្រោមចំណងជើងក្រោយ ដែលមនុ ដាក់ត្រូវកន្លែងរបស់វាមួយផ្នែក ហើយមួយផ្នែកមាននៅក្នុងសិក្ខាវិន័យផ្សេងៗ នៅចុងជំពូកទី៨។ ចុងក្រោយចំណុចទី៣ ដែលគួរកត់សម្គាល់នៅទីនេះគឺការពិតដែលថាការកំណត់និយមន័យច្បាប់គឺសឹងតែគ្មានទាំងស្រុងនៅក្នុងមនុស្ម្រឹតិ តែមានច្រើននៅក្នុងស្នាដៃរបស់យាញ្ញវល្ក្យ និងមានជានិច្ចនៅក្នុងស្នាដៃរបស់នារទ ព្រមទាំងថាវិធានច្បាប់មួយៗ ជាច្រើនដែលមានទូទៅសម្រាប់មនុ និងយាញ្ញវល្ក្យឬមនុ យាញ្ញវល្ក្យ និងនារទ ត្រូវបានគេរៀបចំនៅក្នុងស្នាដៃក្រោយៗ ឱ្យកាន់តែមានភាពច្បាស់លាស់ជាងស្នាដៃពីមុន(ប្រៀបធៀប ឧ.ទា. វិធានច្បាប់ស្ដីពីអត្រាការប្រាក់ស្របច្បាប់ *មនុ* វគ្គ ៣ លេខ ១៤០-១៤២ និងយាញ្ញ វគ្គ២ លេខ៣៨) ។ ភាពអន់ជាងរបស់មនុស្ម្រឹតិនៅក្នុងចំណុចទាំងអស់នេះ អាចត្រូវបកស្រាយដោយការសន្មតថា គេបានតាក់តែងមនុស្ម្រឹតិនៅពេលមួយ ដែលមានវិធីតែងនិពន្ធច្បាប់ជាប្រព័ន្ធតែមិនទាន់មានភាពសុក្រឹតខ្ពស់នៅឡើយ ចំណែកភាពប្រសើរជាងនៃកំណាព្យស្ម្រឹតិដទៃ អាចញ៉ាំងឱ្យសន្និដ្ឋានថា ស្ម្រឹតិនោះស្ថិតនៅជំនាន់ក្រោយៗមកទៀត ដែលសាលាច្បាប់ឯកទេសមានការរីកចម្រើនខ្លាំងក្នុងការបកស្រាយលម្អិតអំពីទ្រឹស្ដីរបស់ខ្លួន។ សម្រាប់ខ្ញុំហាក់ដូចជាថាការអះអាងនេះ ជាអំណះអំណាងដ៏មានទម្ងន់បំផុត ដែលគេអាចយកធ្វើជាមូលដ្ឋានដ៏រឹងមាំសម្រាប់ឱ្យពួកអឺរ៉ុប និងអ្នកសំស្ក្រឹតតណ្ឌា ទាំងអស់មានជំនឿជាទូទៅចំពោះអាទិភាពនៃគម្ពីរមនុរបស់យើង ជាងសៀវភៅ ច្បាប់ទី២ផ្សេងៗទៀតទាំងអស់។ ទោះជានៅកន្លែងណាក៏ដោយ ក៏យើងអាចរកឃើញប្រភពយ៉ាងច្រើននៅក្នុងប្រវត្តិវិទ្យាសាស្ត្រព្រាហ្មណ៍ពិសេសមួយ ដូចជាតួយ៉ាងក្នុងការសិក្សាវេយ្យាករណ៍ យើងរកឃើញថា អ្នកនិពន្ធក្រោយៗ ទោះបីចេញពីសាលានិងមានគោលជំនឿផ្សេងគ្នាក៏ដោយ ហើយទោះបីមានគោលលទ្ធិជាក់ស្ដែងផ្សេងគ្នាក៏ដោយ ក៏ចៀសមិនរួចពីការប្រើវិធីរបស់បុព្វការីខ្លួនក្នុងការអភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើង។ ជំហានថយក្រោយ ជាតួយ៉ាងដែលហាក់ដូចជាមាននៅក្នុងសៀវភៅមេរៀនរបស់សាលាវេទ(ប្រៀបធៀប ឧ.ទា. ករណីរបស់គោតម និងពោធាយនិយធម៌សូត្រ ដែលស្នាដៃទី២ និងស្នាដៃក្រោយៗមានកម្រិតទាបជាងវិធីសាស្ត្រ ដែលមានពីមុន។) ហើយចាប់ពីពេលនេះទៅលែងមានទៀតហើយ(បើគេបដិសេធថា វិស្ណុស្ម្រឹតិ សូម្បីមានអាយុកាលក្មេងខ្ចីជាងធម៌សាស្ត្ររបស់មនុ និងយាញ្ញវល្ក្យក៏ដោយ ក៏មានការខ្វះ ខាតក្នុងការរៀបចំជាប្រព័ន្ធនូវវិធានច្បាប់ស្ដីពីច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ចម្លើយគឺថា អ្នកត្រួតពិនិត្យស្នាដៃនេះ ទំនងជាអ្នកកាន់និយាយវៃ្លរ មិនមែនជាអ្នកចេញពីសាលាច្បាប់ដែលសិក្សាផ្នែកឯកទេសនោះទេ។) ។

អំណះអំណាងទាំងអស់ ដែលមានឬអាចមានហេតុផលបញ្ជាក់ពីភាពចំណាស់នៃមនុស្ម្រិតិរបស់យើង គឺមិនសូវមានភាពប្រាកដប្រជាទេ។ បើសិនជាគេនិយាយថា ស្នាដៃនេះមានគោលជំនឿហួសសម័យ (តួយ៉ាងមួយដ៏ជាក់ច្បាស់បំផុតក្នុងចំណោមតួយ៉ាងនានា គឺគោលលទ្ធិរបស់មនុ ស្តីពីការទទួលមរតករបស់ស្ត្រីពីមរតករបស់បុរស ដែលការបដិសេធកិរិយា ត្រូវគ្នានឹងការប្រៀនប្រដៅរបស់ធម៌សូត្រ(មេរៀនរបស់ Jolly, Tagore ទំព័រ៤៨)។ ការអះអាងរបស់សាស្រ្តាចារ្យ Hopkins (វណ្ណៈ យោងតាមបណ្ឌិតរូបនេះ ទំព័រ១០៨) ថា បុព្វសិទ្ធិរបស់ពួកព្រាហ្មណ៍ មានច្រើនស្របតាមពិធីយញ្ញ ជាងតាមការយល់ឃើញរបស់មនុ។ ហាក់ដូចជាធ្វើខ្ញុំភាន់ច្រឡំ ហើយផ្អែកយ៉ាងខ្លាំងទៅលើការបកស្រាយដែលមិនអាចទទួលយកបាននូវសេចក្តីមួយចំនួនរបស់*មនុ*។ តាមយោបល់របស់ខ្ញុំ ទំនាក់ទំនងទៅវិញទៅមករវាងវណ្ណៈនិងវណ្ណៈ ដូចបានរៀបរាប់នៅក្នុងគម្ពីរច្បាប់ពីរ មិនអាចឱ្យគេលើកយកមកបង្ហាញអំពីអាទិភាពរបស់ស្នាដៃជាងស្នាដៃមួយទៀតបានទេ។)ដែលមិនមាននៅក្នុងសៀវភៅច្បាប់ទី២ផ្សេងទៀតនោះគឺជាការពិតមែនហើយ។ ប៉ុន្តែការពិចារណាពីអាយុកាលនៃស្នាដៃមានចំណុចគួរឱ្យសង្ស័យច្រើនដោយសារផ្អែកលើប្រធានបទផ្សេងៗ មនុគឺជាស្ម្រិតិនាំមុខគេ ក្នុងចំណោមស្ម្រិតិដទៃទៀត(ឧ.ទា.នៅក្នុងគោលលទ្ធិពាក់ព័ន្ធនឹងនិយោគ) និងដោយសារជាទូទៅការអភិវឌ្ឍគោលលទ្ធិជាក់ស្តែងហាក់ដូចជាគ្មាននិរន្តរភាព និងភាពប្រាកដប្រជា។ អំណះអំណាងទាំងឡាយនៅតែមិនមានមូលដ្ឋានជាក់លាក់ ផ្អែកលើភាសារបស់ មនុស្ម្រិតិ ដែលមិននិយាយពីតារាសាស្រ្តក្រិកឬការប្រើពាក្យក្រិក និងចំណុចប្រហាក់ប្រហែល។ ដូចយើងបានវែកញែកអំពីការតាក់ តែងឡើងវិញនូវគម្ពីរបុរាណ និងដូចអ្នកត្រួតពិនិត្យអត្ថបទ បានប្រើកំណាព្យបុរាណល្អៗជាច្រើនក្នុងការបកស្រាយសំណៅដៃរបស់គាត់ គេគ្រាន់តែរំពឹងថា យើងនឹងឃើញមានទម្រង់ និងឃ្លាបុរាណខ្លះ។ ប៉ុន្តែប្រាកដណាស់ថា ទម្រង់និងឃ្លាទាំងនោះ មិនបានសបញ្ជាក់ពីអ្វីដែលពាក់ព័ន្ធនឹងសម័យកាលចងក្រងទេ ពីព្រោះការសម្រេចថាករណីនីមួយៗនៃផ្នែកសំខាន់ៗ របស់វាមានលក្ខណៈហួសសម័យឬទេ គឺមិនអាចធ្វើទៅរួចទេ។ ដោយគិតថា សេចក្តីសំអាងដទៃមិន មាននិយាយ ក៏ស្មើគ្នានឹងមានការពិតដែរ។ សូម្បីយើងផ្តល់ភាពត្រឹមត្រូវដល់ការពោលអះអាងថា គម្ពីរមនុរបស់យើងមិននិយាយពីលំដាប់ផ្កាយព្រះគ្រោះរបស់ក្រិក ពីចក្ររាសី ពីហោរាសាស្ត្រដ៏ត្រឹមត្រូវ និងពីទីណារៈ ល្ខោន និងនាណកៈរបស់ក្រិក ឬជនជាតិស៊ីថ្យា ចំណែកឯគម្ពីរច្បាប់ទី២ផ្សេងទៀតថែងអំពីការដាក់បញ្ចូលពីខាងក្រៅមួយឬច្រើនពោលគឺ ពិតជាអាចមានការលុបចោលខ្លះមិនលែង។ គេអាចប្រើចំណុចទាំងអស់នេះដោយគ្មានអ្វីក្រៅពីដើម្បីបង្ហាញថា គ្មានអ្វីនៅក្នុងអត្ថបទគម្ពីរមនុ ដែលបង្ខំឱ្យយើងដាក់វានៅសម័យកាលនេះ ឬក្រោយសម័យកាលចន្លោះឆ្នាំ៣០០-៥០០ក្រោយគ.ស.ក្នុងអំឡុងដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើឥណ្ឌា។ចំណុចនានាមានសារៈសំខាន់ពិតប្រាកដជាជំនួយបន្ថែមទៅលើ សម្តីសំអាងដ៏ចម្បងដែលកើតចេញពីការបង្កើតវិធីសាស្រ្តមិនសូវត្រឹមត្រូវ ឬការបរិយាយច្បាប់នេះជាផ្លូវការ។ ក៏ប៉ុន្តែបើពិចារណាឱ្យគ្រប់ជ្រុងជ្រោយ ដូចបាននិយាយនៅក្នុងការពិភាក្សាខាងដើមខ្ញុំគិតថា ការនិយាយនេះមិនច្រើនពេកទេ។ គ្មានឧបសគ្គអ្វីទេនិងហេតុផលខ្លះ សម្រាប់ទទួលយកសម្តីអះអាងនេះថាជាការពិតដែលមាននៅក្នុងមនុស្ម្រិតិផ្ទាល់ និងដែលមានការគាំទ្រពីប្រពៃណីដែលមាននៅក្នុងស្កន្ទបុរាណ ដែលសំហិតារបស់ក្រិគុ(ការបកស្រាយច្បាស់លាស់និងប្រាកដប្រជាអំពីបញ្ហាមូលហេតុ ដែលថាប្រពៃណីហិណ្ឌូសំអាងលើការប្រកាសជាផ្លូវការនូវច្បាប់របស់*មនុ* ដល់ក្រិគុ រហូតមកដល់ពេលនេះ គ្មានតម្រុយបញ្ជាក់ពីប្រភពបានទេ។ ទំនាក់ទំនងរបស់ក្រិគុ ជាមួយនឹង *មនុ* គឺដូចបានសរសេរនៅក្នុងអត្ថបទថា គាត់គឺជាបុត្រមួយរូបដែលប្រសូត្រចេញពីចិត្ត ឬបិតារបស់

មនុស្សជាតិ។ យ៉ាងណាមិញ របៀបនិទានរឿងព្រេងស្តីពីដើមកំណើតរបស់គាត់ មិនធម្មតាទេ។ នៅក្នុងមហាភារតៈជំពូក ១២ លេខ ១៨៣-១៩២ យើងរកឃើញ "ពាក្យ ធម៌សាស្ត្រខ្លីមួយ" ដែលត្រូវភ្រិគុ បានប្រាប់ទៅដល់ភរទ្វាគ។ ពាក្យនេះ មានពាក្យពណ៌នាបន្ថែមអំពី ការបង្កើត ប៉ុន្តែមិនបាននិយាយពី*មនុ* ទេ។ ព្រោះថា ពាក្យភ្រិគុ ហាក់ដូចជាមាននៅកន្លែងផ្សេងទៀត ជាអ្នកនិពន្ធធម៌សាស្ត្រ គេពិតជាអាចនិយាយបានថា រឿងនិទាននោះអាចផ្អែកលើកេរ្តិ៍ឈ្មោះល្បីល្បាញរបស់ភ្រិគុ ក្នុងនាមជានីតិករ និងជា កូនចៅរបស់ព្រះ *មនុ*។) ជាស្នាដៃសរសេរឡើងវិញដំបូង និងចំណាស់បំផុតអំពីធម៌សាស្ត្រៈ ដែលគេចាត់ទុកថាជារបស់ព្រះមនុដែលក្រោយមកមានការពិតបញ្ជាក់នៅក្នុងផ្នែកដំបូងនៃសេចក្តីផ្តើម ពិតជាមានលក្ខណៈដូចគ្នានឹងមានវធម៌សូត្រមែន។ សូម្បីតែគេចាត់ទុកការតាក់តែងឡើងវិញនេះជាស្នាដៃរបស់មនុស្សម្នាក់ ក៏គេមិនអាចប្រានចោលលទ្ធភាពដែលថា អាចមានការបន្ថែម ឬកែពាក្យកាព្យនៅពេលនោះទេ។ ការអភិរក្សឱ្យនៅដូចដើមឥតខ្ចោះនូវស្នាដៃរបស់ឥណ្ឌា ដែលត្រូវបានគេធ្វើការសិក្សាយ៉ាងច្រើន គឺជារឿងមួយហួសវិស័យ ពិបាកនឹងជឿនិងមានការខ្វែងគំនិតគ្នាក្នុងចំណោមស្មេរជាច្រើន ដូចពាក្យកាព្យមួយចំនួនបញ្ជាក់ថា អ្នកខ្លះដែលមានឈ្មោះនៅក្នុងអត្ថបទរបស់យើងអាចក្លាយជាការសង្ស័យសម្រាប់អ្នកនិពន្ធផ្សេងៗ ក៏ប៉ុន្តែចំនួនស្លោក ដែលគួរឱ្យសង្ស័យពិតប្រាកដមានតិចតួចហើយមិនដល់រាប់សិបស្លោកផង( កាព្យជាច្រើនទៀត មានមួយផ្នែក នៅក្នុងភាស្សរបស់មេធាទិថិ និងមួយផ្នែកនៅក្នុងបទអត្ថាធិប្បាយរបស់នន្ទនៈ។ ប៉ុន្តែ សូមមើលខាងទំព័រខាងក្រោមៗទៀត ដែលមានបង្ហាញថា ការលុបចោលសេចក្តីខ្លះនៅក្នុងស្នាដៃទាំងពីរនេះ មានមិនតិចទេ ) ។

ការពិភាក្សាខាងដើមក៏បានកំណត់ពីជំហរពាក់ព័ន្ធនឹងមនុស្មិតិរបស់យើងនៅក្នុងអក្សរ សាស្ត្រព្រហ្មញ្ញ ហេតុនេះក៏បើកផ្លូវឱ្យមានការពិចារណាអំពីបញ្ហាដែលនៅសេសសល់ ហើយបញ្ហាអាច នឹងកើតមាននៅពេលធ្វើការប្រែមានវៈធម៌សូត្រឱ្យទៅជាគម្ពីរកំណាព្យច្បាប់។ ការចាប់ផ្តើមសម្រាប់ការតាក់តែងសំហិតារបស់ភ្រិគុ គឺយុគសម័យមហាភារតៈ ហើយពេលបញ្ចប់គឺជាសម័យកំណាព្យ *ស្មិតិ* របស់យាញ្ញវល្ក្យនិងនារទៈ។ សូម្បីនៅពេលបច្ចុប្បន្នយើងមិនមានជំហរការពារអ្វីដែលជាចំណុចវិជ្ជមានពាក់ព័ន្ធនឹងពេលវេលាសរសេរមហាភារតៈ ជាពិសេសនៅបវនៃទី១២ និងទី១៣ទេ ហើយសូម្បីកាលបរិច្ឆេទនៃធម៌សាស្ត្រៈរបស់យាញ្ញវល្ក្យ ក៏គួរឱ្យសង្ស័យច្រើន តែការពិតខ្លះ ដែលយើងបានដឹងអំពី នារទស្មិតិ មិនមែនគ្មានសារៈសំខាន់សម្រាប់ការកំណត់ទិដ្ឋភាពចម្លើយចំពោះសំណួរដ៏ពិបាក ដែលបានលើកឡើងនៅពេលនេះទេ។ ទាំងសាស្ត្រាចារ្យ Jolly និង Muller( Jolly, *មេរៀនតាហ្គ័រ* ទំព័រ ៥៦; West និង Buhler*ព្រឹត្តិបត្រ* ទំព័រ៤៨។ សម្រាប់អំណះអំណាងដែលលើកហេតុផលនៅទីនោះ ខ្ញុំថែមពាក្យ *ពាណៈ* មិត្តរបស់ស្រីហាសសហវឌ្ឍនៈ (ឆ្នាំ៦០៦-៧ -៦៤៨ គ.ស) ជាការសរសេរឱ្យច្បាស់បន្តិចចំពោះនារទិយ ធម៌សាស្ត្រ នៅក្នុងកាទំពរី ទំព័រ ៩១,១,១៣ (ការបោះពុម្ពរបស់Peterson) ដែលគាត់ហៅរាជវាំងថា *នារទិយំ ឥវាន័យមានរាគធមំ* "ទំនងជាដូចគ្នានឹង *នារទិយ* (ធម៌សាស្ត្រ) ព្រោះនៅទីនោះករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ត្រូវបានបង្រៀន (តាមការប្រព្រឹត្តរបស់អ្នកដឹកនាំ) ដូចជាគេបង្រៀន(តាមសៀវភៅច្បាប់)ដែរ។") បានពិភាក្សានាពេលថ្មីៗ អំពីសារៈសំខាន់ក្នុងការបញ្ជាក់អំពី *ទីនារៈ* ឬ *ទេនរី* នៅក្នុងកំណែដ៏ត្រឹមត្រូវនិងយ៉ាងវែងរបស់នារទនិងអំពីព្រឹត្តិការណ៍ ដែលថា *អសហាយ* ជាអត្ថកថាចារ្យដើមដំបូងបំផុតរបស់ *មនុ* មេធាទិថិ បានបកស្រាយពន្យល់ និងបានឈានដល់ការធ្វើសេចក្តីសន្និដ្ឋានប្រហាក់ប្រហែលគ្នាថានារទស្មិតិ មានអាយុកាលមុនបន្តិចក៏បាន ឬក្រោយពាក់កណ្តាលមួយឆ្នាំដំបូងក្នុងសករាជរបស់យើង។ បើសិនជាដូច្នោះមែនសំហិតារបស់ភ្រិគុ តាមការ

ពិចារណាលើសេចក្ដីសំអាងដែលបានលើកឡើង គឺកើតឡើងមិនត្រឹមតែនៅមុនប៉ុណ្ណោះទេ តែថែមទាំងមុនយូរលង់ទៀតផង ហើយការអះអាងថា ស្នាដៃនេះពិតជាកើតមានយ៉ាងហោចណាស់នៅសតវត្សទី២ នៃសករាជរបស់យើងមិនមែនគ្មានការជានាទេ។ ការពិចារណាក្រោយៗទៀត ក៏ប្រាកដជាមានតាមរយៈរបកគំហើញ ដែលយើងត្រូវតែទទួលយកសេចក្ដីអត្ថាធិប្បាយពីមុនៗ និងយ៉ាងហោចណាស់ពីវាត្តិកៈ ឬការិកាពីបុរាណដែលសំអាងលើអត្ថបទរបស់ *មនុ* ដែលយើងបានស្គាល់។ ដោយសារមានបទអត្ថាធិប្បាយនានា មេធាទិថិ អ្នកនិពន្ធមនុភាស្សៈ គឺជាសក្ខីភាពច្បាស់លាស់ និងដ៏មានតម្លៃបំផុត។ អ្នកនិពន្ធដែលទំនងជាបានសរសេរនៅសតវត្សទី៩ ក្រោយគ្រិស្ដសករាជ ជាញឹកញយណាស់ដកស្រង់មតិយោបល់ និងអំណាននានាដែលបានបញ្ជាក់ ឬអះអាងដោយបុព្វការីរបស់គាត់ និងបង្ហាញនូវចំនួនការបកស្រាយផ្ទុយគ្នា ដែលជួនកាលគាត់លើកហេតុផលសំអាងលើសេចក្ដីនៃអត្ថបទ ដែលនៅសម័យគាត់មានបទអត្ថាធិប្បាយយ៉ាងច្រើនស្ដីពីមនុស្ម្រិតិ។ ដូច្នេះក្នុងចំណោមអ្នកទាំងឡាយដែលត្រូវបានស្រង់សម្ដី គាត់ដាក់ឈ្មោះអ្នកខ្លះដោយពាក្យ *ពូរ្វ* និង *ចិរំតន* ។ ពូរ្វ ដែលមានន័យថា "ពីមុន"ផង និង "ពីបុរាណ"ផង គឺជាពាក្យដែលមានន័យមិនច្បាស់លាស់។ គេអាចប្រើពាក្យនេះសំដៅដល់មនុស្សទាំងអស់ ដែលបានសរសេរពីមុនអ្នកនិពន្ធ ទោះបីជាញឹកញាប់គេប្រើពាក្យនេះ ដើម្បីនិយាយពីអ្នកទាំងឡាយ ដែលរស់នៅច្រើនសតវត្សកន្លងមកហើយ។ ពាក្យ *ចិរំតន* "ពីមុនឬពីបុរាណយូរលង់" ជាពាក្យមានទម្ងន់ជាង ហើយយោងតាមការប្រើប្រាស់របស់អ្នកនិពន្ធឥណ្ឌា សំដៅដល់បុព្វការីតាំងពីបុរាណយូរលង់។ ដូចលោកមេធាទិថិ ដែលសរសេរនៅសតវត្សទី៩ បានដឹងពីបទអត្ថាធិប្បាយនានាដែលគាត់ត្រូវបង្ខំកំណត់ពេលវេលាថា បុរាណយូរលង់នោះគ្រាន់តែជាការប៉ាន់ស្មានដ៏សមរម្យប៉ុណ្ណោះ។ បើយើងសន្មតថា ស្នាដៃដំបូងមាននៅសម័យគាត់ចាប់ពីបីរយឆ្នាំ ទៅបួនរយឆ្នាំ។ ប៉ុន្តែបើតាមការបកស្រាយអំពីអត្ថបទរបស់យើងមាននៅសតវត្សទី៦ឬទី៥ក៏ដោយការតាក់តែងអត្ថបទពិតស្ថិតនៅសម័យ កន្លងមកយូរហើយ។ ដោយសារការបកស្រាយផ្សេងគ្នាជារឿយៗនូវចំណោទបញ្ហាពាក់ព័ន្ធនឹងខ្លឹមសារដ៏ពិបាកយល់ ដែលលោកមេធាទិថិ សំអាងហេតុផលពីបុព្វការីរបស់គាត់គួសបញ្ជាក់ថា សូម្បីស្នាដៃខ្លះដ៏ចំណាស់បំផុត ត្រូវញែកឱ្យដាច់ពីគ្នាពីភាពខុសគ្នាច្រើន ពីអ្នកបកស្រាយមនុសំហិតា ឃើញមានភាពខុសគ្នាយ៉ាងខ្លាំង ដែលអត្ថន័យពិតប្រាកដនៃអត្ថបទនោះត្រូវគេបំភ្លេចចោល។

គុណូបការនៃរបកគំហើញ ដែលកំណាព្យធម៌សាស្ត្រៈមួយដែលបាត់បង់ក្នុងចំណោមកំណាព្យជាច្រើនទៀត គឺព្រិហស្បតិស្ម្រិតិ ជាវាត្តិកៈមួយស្ដីពីអត្ថបទមនុរបស់យើង ជារបស់សាស្ត្រាចារ្យ Jolly ដែលការសង្កេតយ៉ាងយកចិត្តទុកដាក់នូវផ្នែកនានានៃសៀវភៅច្បាប់ដែលបាត់នោះ មានចុះផ្សាយនៅក្នុងព្រឹត្តិប័ត្រសម័យទំនើប មានសារជាតុបំភ្លឺយ៉ាងច្រើនអំពីផ្នែកដ៏ពិបាកពាក់ព័ន្ធនឹងប្រវត្តិអក្សរសាស្ត្រច្បាប់ឥណ្ឌា។ លោកបង្ហាញថា(មើលសៀវភៅមេរៀនតាហ្គ័រទំព័រ៦០-៦២) ព្រិហស្បតិ មិនត្រឹមតែបែងចែកស្ម្រិតិរបស់មនុ ជាថ្នាក់ទីមួយក្នុង ចំណោមសៀវភៅច្បាប់ទាំងអស់ទេ ថែមទាំងថា គាត់បកស្រាយធ្វើឱ្យសាមញ្ញ និងជួនកាលកែសម្រួល ក្រឹត្យក្រមរបស់វាទៅតាមផ្នែកនានានៃវ្យវហារ។ ចំណុចពិសេសដែលព្រិហស្បតិបានស្រង់ចេញពីមនុ ហាក់ដូចជាបញ្ជាក់ច្បាស់ថា អត្ថបទដែលគាត់ចេះចាំ មិនខុសគ្នា

ពីអ្វីដែលយើងចេះចាំទេ។ គាត់បកស្រាយដូចសាស្ត្រចារ្យ Jolly គូសបញ្ជាក់នូវពាក្យប្លែកៗ ដែលមាននៅក្នុងមនុ ជំពូក៨ លេខ ៤៩ តាម ទម្រង់ផ្សេងៗ ដែលម្ចាស់បំណុលអាចទទួលបំណុល ព្រមទាំងសំនួនពាក្យ *អស្វាមិន* ដែលមាននៅក្នុងចំណងជើងច្បាប់ ហៅថា *អស្វាមិវិក្រយ* ។ គាត់អះអាងបន្តថា មនុ ជំពូក៩ លេខ ៥៧-៦៨ ដំបូងប្រៀនប្រដៅ ហើយក្រោយមកហាមឃាត់ការបតិបត្តិនិយោគ តាមខ្ញុំដឹង ក៏ផ្តល់នូវការបកស្រាយត្រឹម ត្រូវអំពីការខ្វែងគំនិតគ្នានេះ។ គាត់ក៏កត់សម្គាល់ឃើញថា មនុជំពូក ៩ លេខ២២១-២២៨ ហាមឃាត់ការលេងល្បែងដែលអ្នកនិពន្ធច្បាប់ដទៃ អនុញ្ញាតដោយមានការត្រួតពិនិត្យត្រឹមត្រូវ ហើយគាត់កែសម្រួល វិធានក្រឹត្យក្រមរបស់មនុស្តីពីភាពមិនអាចញែកដាច់ការស្លៀកពាក់និងវត្ថុដទៃទៀត ដែលមានរៀបរាប់ឈ្មោះនៅវគ្គ៩ លេខ២១៩។ ការខ្វែងគំនិតគ្នាយ៉ាងច្បាស់នៅក្នុងវិធានក្រឹត្យក្រមរបស់ព្រិហស្បតិ ស្របតាមបុត្រជំនួយ( Jolly, *មេរៀនតាហ្គ័*ទំព័រ ១៥៨) បញ្ជាក់ច្បាស់ថា គាត់បានចេះដឹង និងទទួលយកការប្រៀនប្រដៅរបស់មនុស្តីពីប្រធានបទនេះ។ គាត់ប្រកាសថា អ្នកជំនួសកូនស្របច្បាប់របស់តួអង្គ ត្រូវហាមឃាត់នៅក្នុង*កលិយុគ* តែមិនព្រមទទួលយកសិទ្ធិរបស់បុត្រិកា ឬបុត្រីតែងតាំង ដែលភាគច្រើនស្ថិតក្នុងចំណោមអ្នកជំនួស។ បញ្ហាលំបាកនេះត្រូវបានដោះស្រាយយ៉ាងងាយស្រួល ប្រសិនបើគេចងចាំក្នុងចិត្តថា មនុ ក្រៅពីគម្ពីរ ច្បាប់បុរាណដទៃទៀត មិនចាត់ជាបុត្រិកា ក្នុងចំណោមបុត្រជំនួសដទៃទៀតទេ។ គាត់ញែកបុត្រី នៅជំពូក៩ លេខ១២៧-១៤០ ពីគោណបុត្រនៅជំពូក៩ លេខ១៥៨-១៨១ និងទទួចទារសិទ្ធិរបស់នាងយ៉ាងខ្លាំង ក្នុងពេលដែលគាត់ដាក់កម្រិតដល់អ្នកដទៃទៀត។ ការរៀបរាប់តួយ៉ាងនានា ដែលព្រិហស្បតិ បានលើកឡើងអធិប្បាយបន្ថែម ឬរំគាយន័យវិធានក្រឹត្យក្រមរបស់មនុ ដែលតាមខ្ញុំគិត គេអាចពង្រីកបន្ថែមទៀត ហើយខ្ញុំហាក់ដូចជាថា ការប្រៀបធៀបកំណាព្យទាំងអស់របស់គាត់ ដែលមាននៅក្នុងព្រឹត្តិប័ត្ររបស់ Colebrooke ជាមួយនឹងគម្ពីរមនុ ផ្តល់នូវការចាប់អារម្មណ៍មួយថា ស្នាដៃរបស់ព្រិហស្បតិ គឺឆ្លងកាត់ការត្រួតពិនិត្យកែសម្រួល និងពង្រីកសេចក្តីរបស់ក្រិគុសំហិតា ឬដើម្បីប្រើប្រាស់សំនួនវោហារស័ព្ទឥណ្ឌា គឺមនុវាត្តិក ឬមនុការិកា។ សាស្ត្រាចារ្យ Jolly ទីបំផុតបានគូសបញ្ជាក់ថា សក្ខីកម្មនេះ ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងមនុ និងព្រិហស្បតិ ស្របគ្នា និងផ្តល់ទម្ងន់ខ្លះទៅលើប្រពៃណី ដែលមាននៅក្នុងស្កន្ទបុរាណ ស្របតាមទៅនឹងអ្វីដែលព្រិហស្បតិបានសរសេរការបកស្រាយបីផ្នែកក្នុងចំណោមកំណែទាំងបួនផ្នែកនៃធម៌សាស្ត្រៈរបស់មនុ។ សម័យកាលស្រ្មិតិរបស់ព្រិហស្បតិ ត្រូវបានកំណត់ដោយនិយមន័យតម្លៃនាយុគទីណាមោស និងដោយការស្រង់សេចក្តីពីអ្វីដែលមានរួចហើយនៅក្នុងបទអត្ថាធិប្បាយ និងនិពន្ធដ៏ចំណាស់បំផុត ចាប់ពីសតវត្សទី៩ ក្រោយគ្រិស្តសករាជមក។ តាំងពីសម័យក្រោយមក គេបានចាត់ជាស្នាដៃដែលមានប្រភពពីអាទិទេព ត្រូវលាតត្រដាងដោយគ្រូទេវតា។ ដូចនេះការសន្មតរបស់សាស្ត្រាចារ្យ Jolly ដែលថាស្នាដៃនោះពិតជាមានអាយុកាលពីរយឆ្នាំ ឬបី រយឆ្នាំមុន មិនមែនយូរលង់ពេកទេ ប៉ុន្តែតាមយោបល់របស់ខ្ញុំ មិនថ្មីពេកទេ។ ប៉ុន្តែសូម្បីបើព្រិហស្បតិ ស្រ្មិតិ មានកាលបរិច្ឆេទប្រមាណ ៦០០ ឆ្នាំក្រោយគ.ស អំណះអំណាងស្តីពីប្រភពដ៏គួរឱ្យទុកចិត្តនៃការបង្រៀនរបស់មនុ បង្ហាញថា កំណែរបស់យើងនៅសម័យក្រោយ ពិតជាមានតាំងពីច្រើនសតវត្ស មកហើយ។

ចំណុចបីដែលត្រូវពិភាក្សានៅទីនេះ តាមយោបល់របស់ខ្ញុំ គឺជាចំណុចតែមួយដែលពិតជា មានប្រយោជន៍សម្រាប់កំណត់កាលបរិច្ឆេទក្រោយៗនៃមនុស្រ្មិតិ។ ការពិតដទៃទៀតទាំងអស់ដែលខ្ញុំ បានដឹង ដែលពាក់ព័ន្ធនឹងចំណោទបញ្ហាមិនមានតម្លៃទេ ដោយសារមានកង្វះខាតណាមួយ។ ដូច្នេះប្រសិនបើយើងយល់ថា កំណាព្យធម៌សាស្រ្តៈមួយទៀត កាត្យាយនស្រ្មិតិ ដែលហាក់ដូចជាស្ថិតក្នុងសម័យជាមួយនឹងព្រិហស្បតិស្រ្មិតិ ដកស្រង់ម្តងហើយម្តងទៀតនូវគោលលទ្ធិរបស់មនុ ឬភ្រិគុ ដែលមាននៅក្នុងអត្ថបទរបស់យើង យ៉ាងណាមិញការសន្មតដ៏ទុកចិត្តបំផុតតាមកុល្លូកនៅក្នុងមនុជំពូក៨ លេខ ៣៥០ ថាអ្នកនិពន្ធនេះ បានចេះដឹង និងបកស្រាយអត្ថបទរបស់យើង គឺមិនអាចធ្វើទៅបានទេ។ ព្រោះដូចលោកសាស្រ្តាចារ្យ Jolly បានបង្ហាញស្រាប់(Jolly, *មេរៀនតាហ្គ័រ*ទំព័រ ៦១, ១១, ២២ និង២៤ ព្រិហស្បតិ ត្រូវបានគេបោះពុម្ពពីរលើក ដោយមានកំហុសឆ្គងត្រង់ កាត្យាយន។) ថាមានករណីដទៃទៀត ដែលនៅក្នុងការបង្រៀនរបស់កាត្យាយន បានមកពីភ្រិគុ ឬមនុ ខុសពីយោបល់ដែលបានលើកឡើងពីមុននៅក្នុងស្រ្មិតិរបស់យើង។ តាមពិតយើងអាចនិយាយថា អ្នកនិពន្ធដែលកំណត់យកឈ្មោះកាត្យាយន អាចមានការខុសភ្លាត់ ឬអាចចេះដឹងមនុសម្រិត ឬភ្រិគុស្រ្មិតិជាច្រើន និងបាននិយាយយោងស្នាដៃផ្សេងៗនៅកន្លែងនានា។ ប៉ុន្តែដោយមានលទ្ធភាពគ្រប់បែបយ៉ាងដូច្នេះគេមិនអាចនិយាយថា ការយោងរបស់គាត់ប្រើប្រាស់អំណះអំណាងប្រាកដប្រជាមួយ។ ជាថ្មីម្តងទៀតគេបានគូសបញ្ជាក់ថា អ្នកនិពន្ធភាវិស្យបុរាណ សរសេរយ៉ាងច្រើននៅជំពូកបីដំបូងនៃសៀវភៅមនុរបស់យើង ដែលគាត់ក៏ប្រើឈ្មោះនេះ ហើយគ្មាននរណាមួយ ដែលប្រៀបធៀបអត្ថបទទាំងពីរនេះដោយយកចិត្តទុកដាក់ អាចមានការ ថានរណាជាអ្នកខ្ចីទេ ដោយសារ*បុរាណ* ដាក់ជំនួសអំណានងាយស្រួលជាប្រចាំសម្រាប់អំណានពិបាកៗ និងបន្ថែមពាក្យកាព្យពន្យល់ជាច្រើន។ ក្រៅពីនេះនារាយណៈ ព្រមទាំងកុល្លូក(មើលឧ.ទា. កំណត់សម្គាល់របស់គាត់អំពីគម្ពីរមនុ ជំពូក១១ លេខ១០១ និងសៀវភៅរបស់នារាយណជំពូក១១ លេខ១៣១) ស្រង់កំណាព្យរបស់ភាវិស្យបុរាណ ចេញពីផ្នែកមួយនិយាយពីការលាងបាបដែលមិនមាននៅក្នុងសំណៅដៃផ្សេងដែលទំនង ជាបកស្រាយច្បាស់អំពីអត្ថបទសំហិតារបស់យើង។ យ៉ាងណាមិញ ទាំងអស់នេះ យើងមិនអាចកំណត់កាលបរិច្ឆេទនៃបុរាណសូម្បីតាមការប៉ាន់ប្រមាណនៅពេលនេះក៏ដោយ។ សាស្រ្តាចារ្យ H.H. Wilson ដែលមានយោបល់ដ៏មានន័យអំពីសៀវភៅនេះ ប្រកាសថា គេមិនអាចអះអាងពី ភាពចំណាស់យូរលង់ ហើយហាក់ដូចជាផលិតផលមួយនៃសតវត្សទី៩ឬទី១០។ របកគំហើញរបស់សាស្រ្តាចារ្យ Aufrecht ដែលថា មត្សយបុរាណ ដែលនិយាយអំពីភាវិស្យបុរាណ នៅកំណាព្យ ១៤,៥០០ល្បះ ដាក់ស្តែងមានផ្នែកជាច្រើនដែលបានខ្ចីមកពីស្នាដៃក្រោយ ដែលរក្សាបានតាមសំណៅដៃ ធ្វើឲ្យការប៉ាន់ស្មានរបស់សាស្រ្តាចារ្យ Wilson មិនអាចជឿបាន។ ចំពោះមត្សយបុរាណត្រូវគេចាត់ជាស្នាដៃសាសនបញ្ញត្តិ ទំនងជាមាននៅ១០០០ឆ្នាំក្រោយគ្រិស្តសករាជ និងត្រូវប្រើដោយអល្បីរូនី សម្រាប់ស្នាដៃរបស់គាត់ និយាយពីឥណ្ឌា(ខ្ញុំដឹងគុណចំណេះដឹងពីការពិត ដោយសារចិត្តសប្បុរសរបស់សាស្រ្តាចារ្យ Sachau)។ ហេតុនេះសូម្បីហាក់ដូចជាថា ភាវិស្យបុរាណ មានចំណាស់ជាងការសន្មតរបស់សាស្រ្តាចារ្យ Wilson ក៏

ទិន្នន័យដែលទទួលបាន មានភាពមិនច្បាស់ លាស់សម្រាប់ការពិចារណាអំពីសម័យកាលនៃមនុស្មិតិរបស់យើងទេ។

លទ្ធផលមិនគួរឱ្យពេញចិត្តសម្រាប់យើង មានដូចគ្នាក្នុងការពិនិត្យសម្រង់ពីមនុស្មិតិ ដែលឃើញមាននៅក្នុងស្នាដៃសំស្ក្រឹតនានា។ សម្រង់ដែលគេមិនអាចប្រកែកបានទាំងស្រុងតែម្តង គឺមិនមានទេ ហើយសម្រង់ទាំងឡាយភាគច្រើន មាននៅក្នុងស្នាដៃសម័យថ្មី ឧ.ទា. នៅក្នុងយសស្តិលករបស់កំណាព្យសោមវេទ ឱគំពរ គៃណ ឆ្នាំ៩៥៩ នៅក្នុងសារីរកភាស្សរបស់សង្ករាគាយ ឆ្នាំ៨០៤ គ្រិស្តសករាជ និងនៅក្នុងអមរកោសោទឃាទន របស់ក្សីរស្វាមិន(Aufrecht, *ព្រឹត្តិបត្ររបស់អាល្លឺម៉ង់* ចេញលេខ២៨ ទំព័រ ១០៧។ កាលបរិច្ឆេទរបស់អ្នកនិពន្ធនេះ ដែលធ្លាប់ប្រើដូចនឹងគ្រូបង្រៀនគាយាបីទ របស់កាស្មីរ (ឆ្នាំ៧៧៩-៨១៣ ក្រោយ គ.ស) ហាក់ដូចជាស្របតាមគ្នា នឹងការស្រាវជ្រាវក្រោយៗ។)។ ករណីផ្សេងទៀតដែលយើងរកឃើញកំណាព្យនានាដែលមនុសំហិតា ស្រង់ចេញពីស្នាដៃបុរាណ ជាការយោងដែលមានភាពស្រពេចស្រពិល ឬដោយសារព្រឹត្តិការណ៍ ដែលសេចក្តីដូចគ្នាក៏មាននៅក្នុងស្នាដៃដទៃ។ ហេតុនេះ យើងរកឃើញមនុជំពូក៨ លេខ ៤១៦ មានភាពខុសគ្នាផ្នែកកិរិយាស័ព្ទបន្តិចបន្តួច នៅចុងបន្ទាត់ទី១(មើលសៀវភៅទី៣ ទំព័រ៥៨ ការបោះពុម្ពរបស់សាស្ត្រាចារ្យ Kielhorn។ ខ្ញុំអាចបន្ថែមថា ស្នាដៃដដែលស្តីពីបាណីនិ ជំពូក ២ លេខ ៣,៣៥ (សៀវភៅលេខ១ ទំព័រ ៤៥៧, Kielhorn) ស្រង់កំណាព្យមួយទៀត ជួរទី១ ដែលស្របនឹងមនុ ជំពូក៤ លេខ ១៥១a ចំណែកឯងជួរទី២ ខុសគ្នាទាំងស្រុង។ ក្នុងករណីនេះផងដែរ មហាភារតៈ ជំពូក១៣ លេខ ១០៤, ៨២ មានកំណាព្យ មួយដូចគ្នាបេះបិទនឹងកំណាព្យរបស់មនុ។) នៅក្នុងសពរភាស្ស ស្តីពីមីម. សូ. ជំពូក៦ លេខ១,១២។ សូម្បីស្នាដៃក្រោយនេះ មិនមានកាលបរិច្ឆេទប្រាកដប្រជាក៏ដោយ ក៏យើងដឹងថា ស្នាដៃនេះកើតមុនតន្រវាត្តិករបស់កុមារិលភត្ត ហើយរចនាបថរបស់វា ដែលដូចគ្នានឹងមហាភារតៈរបស់បតញ្ញលិ អាចនិយាយបានថា អ្នកនិពន្ធស្នាដៃនេះ បានរស់នៅមិនមែនក្រោយការចាប់ផ្តើមសករាជរបស់យើងច្រើនទេ។ ហេតុនេះ សក្ខីកម្មបញ្ជាក់ពេលវេលានេះ មានការចាប់អារម្មណ៍ខ្លាំងបំផុត ដោយហេតុថាវាមានភាពច្បាស់លាស់ណាស់។ ជាអកុសល ភាស្ស បញ្ចូលពាក្យកាព្យ *ឯវំក* ស្មិតិ "ដូច្នេះហើយគាត់កត់ត្រា ឬនិយាយនៅក្នុងស្មិតិ" ដោយគ្មានបញ្ជាក់ច្បាស់ពីអ្នកនិពន្ធទេ។ ដោយសារគោលលទ្ធិនៃកំណាព្យ ដែលប្រកាសភរិយា កូនប្រុសនិងទាសករ មិនអាចគ្រប់គ្រង និងមិនអាចទទួលកម្មសិទ្ធិទ្រព្យសម្បត្តិបានទេ ទោះបីមានចែងខុសគ្នាក៏ដោយ ក៏នៅក្នុងនារទស្មិតិ វិវាទបទ ជំពូក៥ លេខ ៣៩ អាចមានន័យថា សពរៈ បានស្រង់សេចក្តីពីស្នាដៃផ្សេង មិនមែនពីមនុស្មិតិទេ។ ជាថ្មីម្តងទៀត ទោះបីបតញ្ញលិនៅក្នុងវ្យាករណមហាភាស្ស ស្តីពី បាណិនិ ជំពូក៦ លេខ ១,៨៤ លើកហេតុ ផលសំអាងលើមនុ ជំពូក២ លេខ ១២០ ដោយគ្មាន កែប្រែ(សូមមើលសៀវភៅបោះពុម្ពលេខ៣ ទំព័រ៥៨ របស់សាស្ត្រាចារ្យ Kielhorn ។ ខ្ញុំអាចនបន្ថែមថា ស្នាដៃដដែលស្តីពីបាណិនិ ជំពូក២ លេខ ៣,៣៥ (សៀវភៅទី១ ទំព័រ៤៥៧, Kielhorn) ស្រង់ពាក្យកាព្យមួយទៀត នៅបន្ទាត់ទី១ ដែលស្របគ្នានឹងមនុជំពូក៤ លេខ ១៥១a រីឯបន្ទាត់ទី២ ខុសគ្នាទាំងស្រុង។ ក្នុងករណីនេះ មហាភារតៈ ជំពូក ១៣ លេខ ១០៤,៨២ មានកំណាព្យ ដែលដូចគ្នានឹងកំណាព្យរបស់មនុ។) ក៏ដោយ ក៏ការសន្និដ្ឋានថា គាត់ស្រង់ពីអត្ថបទមនុរបស់យើង គឺជាការប្រថុយប្រថានហួសហេតុ។ ចំពោះមហាភារតៈ (ជំពូក១៣ លេខ ១០៤, ៦៤b-៦៥a) មានពាក្យដូចគ្នាបេះបិទ។

សំខាន់ជាងនេះទៅទៀត មាននិយាយយោងទៅច្បាប់មនុ ដែលឃើញមាននៅក្នុងស្នាដៃជាច្រើននាសម័យបុរាណ និងនៅក្នុងសិលាចារឹក។ តាមការពិត បើតាមការបញ្ជាក់ក្នុងអត្ថបទផ្ទាល់ មិនមានច្រើនទេ។ ក៏ប៉ុន្តែបើពិចារណាពីភាពស្របគ្នានឹងលទ្ធផលនៃអំណះអំណាងសំខាន់បី យើងឃើញថា វាពិតជាមានការយល់ស្របនៅពេលក្រោយៗមកទៀត។ ករណីច្បាស់បំផុត ទំនងជាមាននៅក្នុងកិរាតាគុនីយ របស់ភារវិ ជាកវីមួយរូប ដែលមានកេរ្តិ៍ឈ្មោះល្បី ដោយមានសិលាចារឹកនៅអៃហូលេ ជាសក្ខីកម្មបង្ហាញស្រាប់ ដោយមានបញ្ជាក់កាលបរិច្ឆេទឆ្នាំ ៦៣៤ ក្រោយគ.ស. ដែលហេតុនេះហើយមិនមានជីវិតរស់នៅបានយូរជាងដើមសតវត្សទី៦ទេ តែអាចមានអាយុច្រើនជាងនេះ។ គាត់ធ្វើជា (កិរ. ជំពូក១ លេខ៩) ចារបុរសរបស់យុធិស្ថិរៈ និយាយថា "គាត់ (ទុរិយោធន) បង្ក្រាបបានសត្រូវ(ផ្ទៃក្នុង) ចំនួន ៦នាក់ មានបំណងដើរចូលមកតាមផ្លូវ ដែលព្រះមនុបានប្រៀនប្រដៅ ដែលពិបាកនឹងស្រាយ ហើយដែលជម្នះបាននូវសេចក្តីខ្ជិលច្រអូស(ទាំងអស់) ទាំងថ្ងៃនិងយប់ គាត់ប្រកាន់ខ្ជាប់ការបែងចែក (ព្រះរាជករណីយកិច្ច) ស្តែងឱ្យឃើញនូវថាមពលកាន់តែខ្លាំងស្របតាមនីតិ។" ពេលសម្លឹងមើលដំបូងហាក់ដូចជាថា សេចក្តីនេះ គ្មានអ្វីក្រៅពីការសម្តែងនូវជំនឿបុរាណ ដែលព្រះមនុបានរៀបចំនូវករណីយកិច្ចសម្រាប់មនុស្សជាតិ ហើយក្នុងចំណោមករណីយកិច្ចទាំងនោះ ក៏មានព្រះរាជករណីយកិច្ចសម្រាប់ព្រះមហាក្សត្រិយ៍ដែរ។ ប៉ុន្តែបើយើងនៅចាំបានថាការពិចារណាដែលមេធាទិថិ បានលើកឡើងពាក់ព័ន្ធនឹងបទអត្ថាធិប្បាយពីបុរាណ និងការពិចារណារបស់ព្រិហស្បតិស្ម្រិតិ គេអាចនិយាយថា ភារវិសំដៅដល់ជំពូកទី៧ នៃកំណែមនុស្ម្រិតិរបស់ភ្រិគុ ដែលថ្លែងពីវិន័យ សេចក្តីគោរព ឬការគ្រប់គ្រងខ្លួនឯង ពោលគឺការគ្រប់គ្រងសត្រូវខាងក្នុងទាំង៦ គុណសម្បត្តិដ៏ចម្បងមួយក្នុងចំណោមគុណសម្បត្តិនានា ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ព្រះមហាក្សត្រិយ៍ ហើយដែលរៀបរាប់យ៉ាងយកចិត្តទុក និង ដោយលម្អិតអំពីការងារឃ្លាំមើលសត្រូវនីមួយៗទាំងយប់ទាំងថ្ងៃ។ ការលើកឡើងមិនសូវច្បាស់លាស់ដទៃទៀត មាននិយាយអំពីការផ្តល់ដីធ្លី។ ចំណុចនេះមាននិយាយច្រើននៅក្នុងសេចក្តីផ្តើមនៃសិលាចារឹកនៅ*វលភិ* របស់ធ្រុវសេនទី១ គុហសេន និងធរសេនទី២ ដែលខ្ញុំបានធ្វើចំណាប់អារម្មណ៍កន្លង មកហើយ(មើល West និង Buhler *ព្រឹត្តិបត្រ* ទំព័រ ៤៦ និងឯកសារចុះនាមចារឹក ស្តីពីការសិក្សាវត្ថុបុរាណឥណ្ឌា សៀវភៅលេខ ៤ ទំព័រ ១០៥; លេខ ៥, ២៨; លេខ៦, ១១; លេខ ៧, ៦៧, ៦៩, ៧១; លេខ ៨, ៣០២។ សម្រាប់សេចក្តីផ្សេងទៀត មើល Hopkins *ព្រឹត្តិបត្រ* របស់អង្គការសង្គមបូព៌ាប្រទេសរបស់អាមេរិក លេខ ១១ ទំព័រ ២៤៣-២៤៦។) ។ សិលាចារឹកចំណាស់ជាងគេ មានកាលបរិច្ឆេទ សំវ័ត ២០៧ ពោលគឺមិនហួសពីឆ្នាំ ៥២៦(នេះជាការសន្មតថាសម័យបន្ទះលោហៈវលភី ចាប់ផ្តើមនៅឆ្នាំ៣១៩ គ.ស ជាកាលបរិច្ឆេទថ្មីបំផុត ដែលគេមិនធ្លាប់ឃើញពីមុនមកទេ។) គ.ស ទេ។ សិលាចារឹកនោះមានរៀបរាប់អំពីទ្រោនសីហ មហារាគទី១របស់វលភី និងបុព្វការី ផ្ទាល់របស់ទ្រុវសេនទី១ ថា "ដូចជាធម៌រាគ (យុធិស្ថិរ) លោកបានគោរពដូចជាច្បាប់របស់លោកនូវវិធាននិងបទប្បញ្ញត្តិទាំងឡាយ ដែលព្រះមនុនិង(បណ្ឌិត)ដទៃទៀតបានបង្រៀន។" ដោយបកស្រាយក្នុងន័យយ៉ាងតឹងរ៉ឹងសេចក្តីនេះ គ្មាននិយាយអ្វីក្រៅពីខ្លឹមសារនៅក្នុងសៀវភៅច្បាប់នានា នៅសម័យទ្រោនសីហ ដែលជាស្នាដៃមួយសំខាន់។ ក៏ប៉ុន្តែបើពិចារណាពីអ្វីដែលយើងបានចេះដឹងពី ប្រភពផ្សេងៗយើងមិនគួរមិនជឿថា វានិយាយយោងទៅដល់សំហិតារបស់យើង ដែលត្រូវបានទទួលស្គាល់ដោយព្រិហស្ប

តិ ដែលជាប្រភពដ៏គួរឱ្យជឿជាក់យ៉ាងសម្បើមមួយ។ នេះជាអ្វីដែលខ្ញុំអាចធ្វើ សេចក្តីសន្និដ្ឋានបាន ដើម្បីដាក់ដែនកំណត់កម្រិតទាបសម្រាប់មនុស្សិតិ។ ប៉ុន្តែការពិតដែលបាន បញ្ជាក់ជូននៅទីនេះ ខ្ញុំគិតថា គ្រប់គ្រាន់នឹងអាចសន្និដ្ឋានថា ស្នាដៃដូចដែលយើងបានចេះចាំនេះ មានអាយុកាលតាំងពីសតវត្ស ទី២ ក្រោយគ្រិស្តសករាជ។ ចំពោះចម្លើយសម្រាប់សំណួរថាតើមនុសម្រិតរបស់យើងអាចមានអាយុកាលទៅក្រោយ ហួសពីនេះច្រើនទេ ហើយថយក្រោយយូរប៉ុនណានោះ យើងមានទិន្នន័យតិចតួចណាស់នៅពេលបច្ចុប្បន្ននេះ។ កាលបច្ចាភាពពីបវ័នទី១២និង១៣ របស់មហាភារតៈបង្រៀនយើង ដូចបានបញ្ជាក់ ជូនស្រាប់ហើយ គឺគ្មានអ្វីជាក់លាក់ទេ។ ប៉ុន្តែមានសេចក្តីមួយនៅក្នុងជំពូកទី១០ លេខ vv.៤៣-៤៤ ដែលជារឿយៗគេសន្មតថាមានន័យ និងទំនងជាមានខ្លឹមសារជាតម្រុយស្តីពីការកំណត់កម្រិតទាប។ ក្នុងវគ្គនោះ មានរៀបរាប់ពីពួកកាំពោគ យវនសកៈ និងបហ្លវ ក្នុងចំណោមពូជសាសន៍ដែលមានដើមកំណើតពីពួកក្សត្រិយ៍ ត្រូវអាប់ឱនទៅតាមលក្ខខណ្ឌរបស់ពួកសូទ្រៈ ដោយសារអំពើធ្វេសប្រហែសរបស់ពួកព្រាហ្មណ៍(កាព្យឈ្មោះនេះ ក៏មានឈ្មោះ*គីរៈ* ដែលពីមុនគេគិតថាមានតម្លៃជាគោលកំណត់កាលប្បវត្តិ។ ការស្រាវជ្រាវសម័យក្រោយៗ បានបង្ហាញច្បាស់ពីមតិនេះ ថា គេមិនអាចការពារបានទេ។ មើល A. von Gutschmid *ព្រឹត្តិបត្រ* អង្គការបូព៌ា ប្រទេស របស់អាល្លឺម៉ង់ លេខ៣៤ ទំព័រ២០២-២០៨; Max Muller *តើឥណ្ឌាអាចបង្រៀនអ្វីដល់យើង?* ទំព័រ ១៣១; ឫគវេទ លេខ ៤ ទំព័រ ii) ។ ដូចគេបានរៀបរាប់*យវន* ជាមួយនឹង កាំពោគឬកាពុលី តាមរៀបដូចគ្នានៅក្នុងព្រះរាជបញ្ញត្តិរបស់ស្តេច អសោក(មើល ឧ.ទា. ព្រះរាជបញ្ញត្តិសិលាទី៥ ដែលយោន-កំពោគ-គំធារ ឬគំធាល ត្រូវគេចាត់ទុកជាអ្នកជិតខាងរបស់ស្តេចអសលោកជាទីកន្លែងដ៏ឆ្ងាយបំផុតលើកដំបូង។) គេមានជំនឿថាប្រជានុរាស្ត្រក្រិករបស់អ្នកបន្តវេន Alexander និងជាពិសេសគេសំដៅដល់ពួកក្រិកនៅអាស៊ីកណ្តាលនាសម័យបុរាណ។ ចំណុចនេះព្រមទាំងការនិយាយពីពួកសកៈ(Sakas)(ការលើកឡើងពីពួកសកៈ ដំបូងបំផុត ទំនងជាមាននៅក្នុងវាត្តិក របស់កាត្យាយន ស្តីពីបាណៈ វគ្គ៦ លេខ ១,៩៤ ដែលពាក្យ*សកន្ធុ* ត្រូវបានបកស្រាយថាកើតចេញពីពាក្យ*សកៈ + អន្ធុ*។ យោងតាមការបកស្រាយតាមប្រពៃណី សមាសពាក្យ នេះមានន័យថា "ភាពសុខស្រួលរបស់ស្តេចសកៈ"។) ឬពួកស៊ីថៀ (Scythians) នឹងបង្ហាញថា ស្លោកនេះគ្មានហេតុផល ត្រូវគេសរសេរនៅមុនសតវត្សទី៣ គ.ស ទេ។ ការកំណត់នេះ នឹងត្រូវនិយាយឱ្យខ្លីថែមទៀត ប្រសិនបើការលើកឡើងពី*បហ្លវ* គឺហួសពីការសង្ស័យ ហើយបើការទាញហេតុផលតាមមិត្តបញ្ញវន្តរបស់ខ្ញុំ លោកសាស្ត្រាចារ្យ Noldeke(Weber, *ប្រវត្តិអក្សរសាស្ត្រឥណ្ឌា* ទំព័រ ១៨៧-៨ កំណត់សម្គាល់ ២០១a) ស្តីពីអាយុកាលនៃពាក្យនេះ មានភាពប្រាកដប្រជាណាស់។ *បហ្លវ* ហើយយោងតាមសក្ខីភាពស្របគ្នារបស់អ្នកជំនាញបូព៌ាប្រទេសដ៏ល្បីល្បាញបានឱ្យដឹងថា ពាក្យ*បហ្លវ* គំរូដើមរបស់អ៊ីរ៉ង់គឺជាការកែពីពាក្យ *បាថវ* ជាឈ្មោះដើមរបស់ពួកបាសៀន(ពាក្យ *អូល្សៅសិន, បាថវ* និង *បហ្លវ, មាទ, និងមះ* (Monatsberichte de Berliner Akademie, ឆ្នាំ១៨៧៧) និង Noldeke *ព្រឹត្តិបត្រ* របស់អង្គការបូព៌ាប្រទេសរបស់អាល្លឺម៉ង់ សៀវភៅលេខ៣១ទំព័រ៥៥៧) ។ ដោយផ្អែកលើហេតុការណ៍ថា ការផ្លាស់ប្តូរពាក្យ *ថ* (*th*) របស់អ៊ីរ៉ង់ទៅពាក្យ *ហ* (*h*) ដំបូង អាចរកប្រភពឃើញនៅក្នុងឈ្មោះមេហឺដាត ដែលតាស៊ីទុសបានលើកឡើង និងនៅក្នុងពាក្យ *មៀរ៉ូ*(Miiro) ពោលគឺពាក្យ *មិហិរ* ស្តីពីកាក់របស់ *កនិស្ក* (Kanishka) ឬ *កនីកិ* (Kanerki)( Sallet, *Die Nachfalger Alexanders de Gr.* ទំព័រ ១៩៧) លោកសាស្ត្រាចារ្យ Noldeke សន្និដ្ឋានថា ទម្រង់ *បហ្លវ* មិនអាចមានដើមកំណើត

ក្នុងចំណោមពួកអ៊ីរ៉ង់ នៅមុនសតវត្សទី១ ក្រោយគ្រិស្តសករាជទេ និងថាគេមិនអាចយកពាក្យនេះមកប្រើនៅឥណ្ឌា មុនសតវត្សទី២ នៃសករាជរបស់យើងទេ។ ប្រសិនបើការពិចារណានេះមិនអាចប្រកែកបាន ការកំណត់ពេលមនុស្ម្រិតិយូរជាងគឺត្រូវគ្នានឹងពេលកំណត់ក្រោយៗ។ ក៏ប៉ុន្តែតាមការពិចារណាថ្លឹងថ្លែង គ្រប់ជ្រុងជ្រោយពីឈ្មោះរបស់សាស្ត្រាចារ្យ Noldeke ខ្ញុំសូមសារភាពថា ការពិចារណានេះហាក់ដូចជាប្រថុយប្រថានណាស់សម្រាប់ខ្ញុំ។ ពីព្រោះថា ទី១ មូលដ្ឋានទ្រឹស្តីរបស់គាត់មានលក្ខណៈចង្អៀតពេក ទី២ ការពិតផ្ទាល់របស់គាត់មួយ គឺមិនស្របគ្នានឹងការអះអាងរបស់គាត់ទេ។ យ៉ាងណាមិញថ្មីៗនេះ យើងអាចកំណត់ឆ្នាំឱ្យពាក្យ *កនិស្ក* គាត់មិនអាចថាកើតឡើងហួសពីបីភាគបួននៃសតវត្សទី១ គ.ស.ទេ។ *កនិស្ក* មិនមែនជាភាសាបាថៀទេ ហើយសំនួនវោហាររបស់គាត់ ទំនងជាសំដៅទៅលើតំបន់ភាគខាងជើងនៃប្រទេសឥណ្ឌា។ ហេតុនេះ ហាក់ដូចជាថា ទម្រង់ពាក្យអ៊ីរ៉ង់ ដោយមានការសម្រួលសូរពី *th* (ធឹ) ទៅ*h* (ហ)មានប្រើជាទូទៅនៅប្រទេសឥណ្ឌា រហូតដល់ចុងសតវត្សទី១។ ម្យ៉ាងវិញទៀត ពាក្យ *បហ្លវ* មាននៅក្នុងសិលាចារឹកគៀនារ របស់រុទ្រទាម័ន(ឥណ្ឌា *Ant.* សៀវភៅលេខ ៧ ទំព័រ ២៦១។ អនុសេនីយ៍របស់រុទ្រទាម័ន នៅគៀនារ គឺជា *បហ្លវ កុលៃប* (ខូរែប?) ជាកូនប្រុសរបស់សុវិសាខា។) ដែលត្រូវធ្លាក់យ៉ាងខ្លីមុនឆ្នាំ ៧២ នៃសម័យក្សត្រាបៈខាងលិច ហើយពេលនេះរបកគំហើញដ៏សំខាន់របស់លោក Fleet បង្ហាញសក្ខីកម្មមិនអាចប្រកែកបាន គឺជាអ្វីដែលគេហៅថាវិក្រមសំវ័ត ឬ និយាយឱ្យត្រឹមត្រូវជាងនេះគឺ*សំវ័ត*របស់មាលវេសៈ លោកម្ចាស់មាលវៈដែលចាប់ផ្តើមនៅឆ្នាំ៥៧មុនគ.ស។ ហេតុនេះ សិលាចារឹករបស់រុទ្រទាម័ននេះកំណត់ កាលបរិច្ឆេទឆ្នាំ២១-២២ ក្រោយគ.ស ហើយប្រាកដណាស់ថាពាក្យ *បហ្លវ* ត្រូវបានប្រើនៅឥណ្ឌា នៅដើមសតវត្សទី១ គ.ស។ ព្រឹត្តិការណ៍ទាំងនេះ មិនអាចឲ្យយើងទទួលស្គាល់ការពិចារណារបស់សាស្ត្រាចារ្យ Noldeke ពីទម្រង់បន្ទន់សូររបស់អ៊ីរ៉ង់។ ប៉ុន្តែការសរសេរពាក្យ *បហ្លវ* នេះ សបញ្ជាក់ថា ពាក្យកាព្យរបស់*មនុ* មិនអាចត្រូវតាក់តែងឡើងនៅមុនដើមសតវត្សទី១ មុនគ.ស.ទេ។ សន្តតិវង្សបាថៀរបស់*អាសស៊ីដេ* ត្រូវបានបង្កើតឡើងនៅពាក់កណ្តាលសតវត្សទី៣ មុនគ.ស. ហើយយោងតាមអ្នកនិពន្ធសម័យបុរាណមួយចំនួនបានឱ្យដឹងថា មេដឹកនាំទី៦ នៃខត្តិយវង្សនេះ ឈ្មោះ មិថ្រដេត (Mithradetes) ទី១ បានចូលឈ្លានពានប្រទេសឥណ្ឌា ប្រហែលពាក់កណ្តាលសតវត្សទី២(Lassen, *Indische Alterumskunde,* សៀវភៅទី ២ ទំព័រ៣៣៤) ។ សំនួនវោហាររបស់អាសាក់ ថេអូ និងអាសាក់ឱកែអូ ដែលធ្លាប់ប្រើភាសា *ប្រក្រិត* និងអក្ខរក្រមរបស់ឥណ្ឌាខាងជើង យើងឃើញមាននៅបញ្ជាបហើយស្ថិតនៅសម័យដំណាលគ្នា ឬនៅសម័យក្រោយមកបន្តិច(Sallet, *Die Nachfalger Alexanders des Gr.* ទំព័រ៥១, ១៥៦-១៥៧) ។ ដូចពួកព្រាហ្មណ៍ ធ្លាប់បានប្រើសម្រាប់ទំនាក់ទំនងជាមួយប្រជាជាតិបរទេស ជាទីតាំងមួយនៅក្នុងប្រព័ន្ធជាតិពន្ធុរបស់ពួកគេ គេអាចនិយាយថា ទំនងជានៅដើមសតវត្សទី១ មុនគ.ស ដើមកំណើតឥណ្ឌាទំនងជាត្រូវបង្កើតឱ្យមានពួក*បហ្លវ*។ ប៉ុន្តែសូម្បីការបន្ថយកាលយូរលង់នៃមនុស្ម្រិតិ តាមយោបល់របស់ខ្ញុំ គឺគ្មាន សុវត្ថិភាពទេ។ សូម្បីមានសក្ខីកម្មអំពីភាពត្រឹមត្រូវនៃមនុជំពូក១០ លេខ ៤៣-៤៤ គ្រប់ជ្រុងជ្រោយ និងថ្វីបើការបកប្រែផ្សេងៗចំពោះពាក្យ *បហ្លវ* របស់លោកគោវិន្ទ ទំនងជាមិនគួរឲ្យជឿក៏ដោយ(អត្ថកថាចារ្យ និងអ្នកពិនិត្យសំណៅដៃ សរសេរកំណាព្យពីរល្បះ។ បើសំណៅដៃរបស់មេធាទិថិ អាន *បហ្នវ* សម្រាប់ពាក្យ *លៈហ្លវ* ដែលជាកំហុសរបស់បុព្វជិត ដែលកើតចេញពីភាពដូចគ្នានៃទេវនាគរី

លៈ និង នៈ ដែលគេមានជំនឿច្រើន។ មេរៀនរបស់គោវិន្ទ ពាក្យ *បហ្លវ* គឺមិនគួរឱ្យជឿ ព្រោះអម្បូរផ្សេងទៀត ដែលមាននិយាយនៅជួរទី២នៃឈ្មោះ៤៤ ស្ថិតនៅភាគខាងជើងនៃប្រទេសឥណ្ឌា ចំណែកឯពួក *បហ្លវ* តាមដែលយើងចេះចាំ គឺសំដៅដល់ពួកអ្នកនៅភាគខាងត្បូង។)ក៏ប៉ុន្តែបង្កើតឱ្យមានការសង្ស័យចំពោះអំណានក្រោយៗ។ វគ្គប្រហាក់ប្រហែលគ្នានឹងកំណាព្យ ពីររបស់មនុ ឃើញមាននៅក្នុងសៀវភៅមហាភារតៈ ទី១៣ លេខ៣៣, ២១-២៣a និងទី១៣ លេខ ៣៥, ១៧-១៨ ដែលមានរៀបរាប់សែស្រឡាយក្សត្រិយ៍ ដែលអាប់ឱនកេរ្តិ៍ឈ្មោះ និងបុព្វហេតុនៃការអាប់ឱនកិត្តិយសនេះ ត្រូវបានបញ្ជាក់ដោយពាក្យដូចឬប្រហាក់ប្រហែលគ្នា។ វគ្គទាំងពីររៀបរាប់ឈ្មោះ*យវនៈ* និង *សកៈ* ។ ប៉ុន្តែគ្មានពាក្យ មួយណានិយាយពីពួក *បហ្លវ* ទេ។ ហេតុនេះគួរឱ្យសង្ស័យថា បើកំណែដើមនៃស្លោកទាំងនេះ ពិតជាមានឈ្មោះក្រោយនេះមែន។ ជាងនេះទៅទៀតមិនមែនមិនអាចទេថា ការបញ្ចូលពាក្យ មិនមែនដោយ សារអ្នកតាក់តែងមានវេធម៌សូត្រឡើងវិញទេ តែក្រោយមកបានវិវត្តឃើតៗដោយឯកឯងតាមនាមឈ្មោះខ្លះទៀត។ បណ្ឌិតឥណ្ឌាមិនមានជំនាញខ្លាំងផ្នែកជាតិពន្ធុវិទ្យា និងប្រវត្តិសាស្ត្រ ហើយមានទម្លាប់មិនយកចិត្តទុកដាក់ចំពោះនាមឈ្មោះរបស់មនុស្ស និងប្រទេសដែលពួកគេកែប្រែជារឿយៗ ឬប្រើពាក្យមួយទៀតជំនួសនៅក្នុងស្នាដៃរបស់ពួកគេ។ ហេតុនេះខ្ញុំគ្មានសេចក្តីក្លាហាន សង្ខេបចំណុចចាប់ផ្តើមមកត្រឹមជាង១០០ឆ្នាំ តាមកម្លាំងពាក្យតែមួយដែលមាននៅក្នុងពាក្យកាព្យ ដែលដើមឡើយ មានទម្រង់ផ្សេងគ្នានោះទេ។ ខ្ញុំគិតថា ការពឹងផ្អែកច្រើនលើសំណេររបស់យវន, កាំពោគ និងសកៈ និងការកំណត់ពេលយូរលង់នៃស្នាដៃនេះប្រហែលជានៅដើមសតវត្សទី២ ក្រោយគ្រិស្តសករាជឬនៅមុននោះបន្តិចហាក់ដូចជាមានសុវត្ថិភាព។ ការប៉ាន់ស្មានអំពីអាយុកាលភ្រិគុសំហិតា ដែលមាននៅសតវត្សទី២ ក្រោយគ្រិស្តសករាជ និងហាក់ដូចជាត្រូវគេតាក់តែងឡើងនៅចន្លោះកាលបរិច្ឆេទនេះនិងសតវត្សទី២ មុនគ្រិស្តសករាជ ស្របគ្នាយ៉ាងខ្លាំងនឹងទស្សនៈរបស់សាស្ត្រាចារ្យ Cowell (Elphinstone, *ប្រវត្តិសាស្ត្រប្រទេសឥណ្ឌា* ទំព័រ ២៤៩ (បោះពុម្ពឆ្នាំ ១៨៧៤)) និងលោក Talboys Wheeler(*ប្រវត្តិសាស្ត្រប្រទេសឥណ្ឌា* ភាគ២ ទំព័រ៤២២) ។ វាខុសគ្នាយ៉ាងច្រើនពីការកំណត់ដែលបញ្ជាក់ចុងក្រោយ ដោយសាស្ត្រាចារ្យ Max Muller ដែលចាត់ទុកស្នាដៃ *មនុ* របស់យើង ថាកើតក្រោយសតវត្សទី៤ ព្រោះហាក់ដូចជាថា វគ្គមួយដែលដកស្រង់ពី វ្រិទ្ធមនុ ដែលជាបុព្វការីនៃសំហិតារបស់យើងមានរៀបរាប់សញ្ញាទាំង១២ នៃចក្ររាសី។ ខ្ញុំគិតថាវាមិនបានបង្ហាញច្បាស់នូវរាល់ស្នាដៃទាំងឡាយដែលរៀបរាប់ពី*រាសី*ប្រាកដជានៅសម័យក្រោយ ដែលហោរាសាស្ត្រ និងតារាសាស្ត្ររបស់ផ្តូលេមី (Ptolemy) ត្រូវបាននាំចូលមកប្រើនៅប្រទេសឥណ្ឌា។ ប៉ុន្តែបើមិននិយាយពីការជំទាស់នេះ មតិយោបល់របស់លោកសាស្ត្រាចារ្យ Max Muller សម្រាប់ខ្ញុំ ហាក់មិនអាចការពារបានទេ ដោយហេតុថាយោងតាមការ ស្រាវជ្រាវរបស់សាស្ត្រាចារ្យ Jolly និងរបស់ខ្ញុំផ្ទាល់ វ្រិទ្ធ ឬព្រិហ័តមនុ ដែលត្រូវដកស្រង់នៅព្រឹត្តិបត្រ និងបទអត្ថាធិប្បាយនានា មិនមានអាយុកាលមុននេះទេ តែអាចក្រោយសំហិតារបស់ភ្រិគុ។ ទោះជាគេ គិតអ្វីក៏ដោយ ដែលពាក់ព័ន្ធការលម្អិតអំពីការពិចារណា និងសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ក៏ខ្ញុំមានជំនឿថា បឋមវិធាននៃទ្រឹស្តីច្បាប់នៅក្នុងសំហិតារបស់យើងតាមការប្រៀបធៀបយាញ្ញវល្ក្យ និងនារទ (សតវត្សទី៤ ឬ ទី៥ ក្រោយ គ.ស.) នូវការពិតដែលថាព្រិហស្បតិស្ម្រិតិនៅសតវត្សទី៦ ឬទី៧ គឺជាវាត្តិក និយាយអំពីអត្ថបទរបស់យើង និងការអះអាងរបស់មេធាទិថិ ថា

គាត់បានចេះចាំបទអត្ថាធិប្បាយនៅ សតវត្សទី៩ តាំងពីបុរាណយូរលង់ ជំរុញឱ្យយើងចាត់ថ្នាក់នៅមុនកាលកំណត់ ដែលលើកឡើងដោយសាស្ត្រាចារ្យ Max Muller។

## III.

ពេលនេះ ដល់ពេលដែលខ្ញុំត្រូវបរិយាយអំពីសម្ភារៈ ដែលត្រូវធ្វើការបកប្រែ និងអំពីរបៀបប្រើប្រាស់សម្ភារៈនោះ។ ក្នុងចំណោមស្នាដៃសំស្ក្រឹតនានា បទអត្ថាធិប្បាយរបស់មេធាទិថិ គោវិន្ទរាគ, សារ-ញនារាយណ, កុល្លូកភត្ត, រាឃវានន្ទ និងនន្ទនាកាយ ព្រមទាំងតិប្បណអនាមិក ដែលមាននៅក្នុងសំណៅដៃកាស្មៀររបស់មនុសំហិតា គឺជាប្រភពឯកសារដែលខ្ញុំបានពឹងផ្អែកជាចម្បង។ ក្នុងចំណោមអត្ថបទបកប្រែមុនៗ ស្នាដៃបកប្រែដ៏ល្បីរបស់ Sir William Jones និងអត្ថបទបកប្រែពន្យល់ជាភាសាអាល្លឺម៉ង់(ដែលបោះពុម្ពផ្សាយនៅ Zeitschrift Fur Vergleichende Rechtswislenschaft ភាគ ៣) របស់សាស្ត្រាចារ្យ J. Jolly ជំពូកទី៨ និងទី៩ លេខ ១-១០២ ត្រូវបានប្រើប្រាស់យ៉ាងប្រុងប្រយ័ត្ន។ ជួនកាលអត្ថបទបោះពុម្ពដ៏ល្បីល្បាញរបស់លោក Loiseleur Deslongchamps, អត្ថបទ បកប្រែជាភាសាអង់គ្លេសនៃជំពូក ១-៣ លេខ ៣៣ របស់តារាកន្ទ ក្រក្រវ៉ាតិ (កុច្ចេបុត្តី)(ខ្ញុំបានប្រើប្រាស់សំណៅរបស់បណ្ណាល័យការិយាល័យឥណ្ឌាលេខ១៩-២៧,១៧។ សាស្ត្រាចារ្យ Goldstucker ឱ្យឈ្មោះអ្នកនិពន្ធ ស្តីពីភាពទន់ខ្សោយ ទំព័រ ៥, កំណត់សម្គាល់។) និងអត្ថបទ បកប្រែមារាឋិរបស់គនាទ័នវាសុទេវ គុរគា(ត្រូវបោះពុម្ពជាមួយអត្ថបទគម្ពីរមនុ នៅលើទំព័រសារព័ត៌មាននៀណយសាគារ, បុំប៉ៃ ឆ្នាំ១៨៧៧) ត្រូវបានលើកយកមកពិគ្រោះផងដែរ។ សៀវភៅរបស់លោក Sir G.C. Haughton និងអត្ថបទបោះពុម្ពឡើងវិញនានារបស់ឥណ្ឌាត្រូវទុកដោយឡែក ដោយសារឯកសារទាំងនោះភាគច្រើនជាអត្ថបទអំណានដដែលរបស់កុល្លក ឬជាកម្រងអត្ថបទបកប្រែ ដែលមិនបានបង្ហាញប្រភពឱ្យបានច្បាស់ លាស់គ្រប់គ្រាន់។

ក្នុងចំណោមបទអត្ថាធិប្បាយជាភាសាសំស្ក្រឹតស្តីពីមនុស្ម្រិតិដ៏មានចំណាស់ជាងគេគឺពោរពេញដោយភាស្សយ៉ាងច្រើនរបស់ភត្ត មេធាទិថិ ជាបុត្ររបស់ភត្ត វិរស្វាមិន។ ដូចនឹងចំណងជើងរបស់វាភាស្ស បង្ហាញថា សៀវភៅនេះ មិនមែនជាសេចក្តីពន្យល់ ដែលបកស្រាយគ្រប់ពាក្យទាំងអស់ នៅក្នុងអត្ថបទនោះទេ។ គោលបំណងសៀវភៅនេះគឺសំដៅបង្ហាញន័យទូទៅនៃពាក្យភាសិតរបស់ព្រះមនុដើម្បីបំភ្លឺសេចក្តីពិបាកស្មុគស្មាញពិតប្រាកដ និងដើម្បីបកស្រាយចំណុចសង្ស័យទាំងអស់តាមរយៈការពិគ្រោះ ពិភាក្សាទាំងស្រុងជាមួយនឹងអត្ថបទបកប្រែនានានិងទស្សនៈយល់ឃើញរបស់អ្នកដទៃទៀត។ ក្នុងការអនុវត្តផែនការនេះ លោកមេធាទិថិ បើកបង្ហាញនូវចំណេះដឹងមហាសាល និងសមត្ថភាពដែលយើងមិនអាចពណ៌នាបាន។ លោកយកចិត្តទុកដាក់ប្រើប្រាស់បទអត្ថាធិប្បាយបុរាណយ៉ាងច្រើនស្តីពីគម្ពីរមនុ និងបង្ហាញនូវការចេះដឹងសាស្ត្រៈ ដែលចាំបាច់សម្រាប់ការបកស្រាយអត្ថបទរបស់លោកប្រកបដោយភាពជោគជ័យ ស្របតាមអក្សរសាស្ត្រវេទ វេយ្យាករណ៍ មិមាំសា ធម្មសូត្រ(មេធាទិថិ ដកស្រង់ធម៌សូត្រទូទៅ និងគោតម, ពោធាយន, អាបស្តម្ភ, និងវសិស្ត ព្រមទាំងស្នាដៃដែលបាត់បង់មួយចំនួន ទៀត។ ក្នុងចំណោមធម៌សូត្រដែលបាត់ទៅ ដែលគាត់លើកយកមកប្រើ មានកាត្យាយនិយសូត្រដែលដកស្រង់មនុ ជំពូក ៨ លេខ ២១៥ ដែលហាក់ដូចជាបរិយាយច្បាប់រដ្ឋប្បវេណីយ៉ាងលម្អិ ហើយទំនងច្បាប់ដើមនៃកំណាព្យកាត្យាយនិយស្ម្រិតិ ដែលព្រឹត្តិបត្រជាច្រើន យកធ្វើជាប្រភពច្បាប់ដកស្រង់។) និង*ស្ម្រិតិ* វេទន្ត និងមហាភារតៈ។ទន្ទឹមនឹងនេះលោក

ជៀសវាងមិនឱ្យមានកំហុសទូទៅរបស់អ្នកអត្ថកថាចារ្យសំស្រ្កឹត ជាភាពបរិបូណ៌ហួសហេតុក្នុងការដកស្រង់ ដែលមានតែប្រធានបទត្រូវពិចារណាប៉ុណ្ណោះ។ ម្យ៉ាងទៀត លោកជាញឹកញយបន្ថែមតម្លៃនៃការបកស្រាយរបស់ខ្លួន តាមរយៈការចង្អុលបង្ហាញវិធានច្បាប់របស់មនុដោយលើកឧទាហរណ៍ចេញពីជីវិតរស់នៅប្រចាំថ្ងៃជាចំណុច មួយដែលអ្នកនិពន្ធហិណ្ឌូភាគច្រើនពាក់ព័ន្ធនឹងច្បាប់និងប្រធានបទដូចគ្នាមិនបានចាប់អារម្មណ៍ទាល់តែសោះ។ ទីបំផុត លោកបានប្រកាន់ជំហរកាន់តែឯករាជ្យច្រើនឡើង ជារឿយៗចំពោះអ្នកនិពន្ធរបស់ខ្លួនជាងអ្នកអត្ថាធិប្បាយ ដែលហ៊ានកាត់ស្មានច្រើន។ ហេតុនេះលោកមិនរួញរាក្នុងការប្រកាសថា ឈ្មោះ កាព្យជាច្រើន គឺជាអថាវាទ ដែលគ្មានអំណាចផ្លូវច្បាប់ និងថាពាក្យនីមួយៗជាច្រើន ត្រូវគេសៀតញាត់បញ្ចូល គ្រាន់តែជា *វ្រិត្តបុរណាថី* "ដើម្បីបង្កើតឃ្លាកាព្យប៉ុណ្ណោះ"។ ម្យ៉ាងវិញទៀត ចំណុចខ្សោយដ៏ធំរបស់លោក ដែលគេពិបាកនឹងរកឃើញ និងដែលផ្អែកលើបទវិចារណកថា(មើលកំណាព្យបញ្ចប់បទអត្ថាធិប្បាយរបស់កុល្លូក។ សេចក្តីថ្លែងរបស់លោក Sir W. Jones ដែលស្នាដៃរបស់មេធាទិថិ ត្រូវសរសេរ "ពន្លាតឱ្យវែង និងមិនស្មើគ្នា" (អារម្ភកថានៃអត្ថបទបកប្រែ ទំព័រ xvii របស់លោក St. Grady) ទំនងជាផ្អែកលើ សំដីរបស់កុល្លូកនេះឯង។) របស់ **កុល្លូក** ដែលញាំងឱ្យលោកលើកឡើងនូវសេចក្តីសង្កេត "ដ៏មានតម្លៃផងនិងគ្មានតម្លៃផង" មានការមិនពេញចិត្តក្នុងការសម្រេចសេចក្តីបកប្រែដែលមានទំនាស់ ហើយជួនកាលយោបល់របស់គាត់ ត្រូវគេចាត់ជាយោបល់ដែលមានភាពមិនស្របគ្នាដែរ។ ដំណើរប្រែប្រួលនេះហាក់ដូចជាត្រូវបានបញ្ជាក់ដោយសេចក្តីមួយចំនួន ដែលអត្ថបទមានន័យមិនច្បាស់លាស់ ឬស្រពេចស្រពិលខ្លាំង។ ក៏ប៉ុន្តែ ជាទូទៅកត្តានេះទំនងជា ដោយសារមានការគោរពហួសហេតុចំពោះទស្សនៈយោបល់របស់អ្នកជំនាន់មុនរបស់លោក ដែលយ៉ាងហោចណាស់បទអត្ថាធិប្បាយខ្លះ មានសម័យកាលចំណាស់ខ្លាំង និងមានកិត្តិស័ព្ទល្បីច្រើន ឬដែលលោកមានហេតុផលផ្ទាល់ខ្លួនត្រូវតែគោរព។ ផ្អែកលើកាលៈទេសៈជាច្រើន លោកលើកឡើងនូវការបកស្រាយជាក់លាក់ដូចជាការពន្យល់របស់បូរប្បកិរិតនពោលគឺរបស់អ្នកអត្ថាធិប្បាយពីបុរាណ។ ដូចនេះលោកពិនិត្យសង្កេតផ្អែកលើគម្ពីរមនុជំពូក៤ លេខ២២៣ថា "ប៉ុន្តែការអត្ថាធិប្បាយខាងលើ គឺជាយោបល់របស់ចាស់បុរាណ; ហេតុនេះយើងក៏អះអាងដូច្នេះដែរ"។ ក្នុងករណីមួយទៀត នៅពេលបកស្រាយគម្ពីរមនុ ជំពូក៩លេខ១៤១ និង១៤៧ លោកកត់សម្គាល់ថាការបកប្រែរបស់លោក ជាការបកប្រែរបស់ឧបាធ្យាយ ពោលគឺការបកប្រែរបស់គ្រូរបស់លោកផ្ទាល់ ដោយសារលោកបានចេះដឹងមនុសំហិតា ពីគ្រូរបស់លោក។ ដោយសារមានការមិនពេញចិត្ត ទើបការពិចារណារកការសម្រេច អាចអាស្រ័យលើអ្នកពិចារណាការអត្ថាធិប្បាយ ជាការបកស្រាយអត្ថបទឱ្យបានច្បាស់លាស់ និងមានប្រកពគួរឱ្យទុកចិត្តបាន ប៉ុន្តែមិនមែនមិនមានប្រយោជន៍នោះទេ។ ភាពសម្បូរបែបរបស់លោកក្នុងការដកស្រង់ទស្សនៈយោបល់របស់បុព្វការីលោក ញាំងឱ្យស្នាដៃរបស់លោក មានសារៈសំខាន់ក្រៃលែង សម្រាប់អ្នកសិក្សាប្រវត្តិមនុស្ម្រិតិ និងច្បាប់របស់ហិណ្ឌូ។ ភាស្យ បង្ហាញសក្ខីកម្មយ៉ាងច្បាស់លាស់ថា អត្ថបទរបស់មនុ ត្រូវបានតាក់តែងឡើងច្រើនសតវត្សក្លាយជាកម្មវត្ថុសិក្សាយ៉ាងស៊ីជម្រៅ និងថា កំណាព្យជាច្រើននៃស្នាដៃនេះ បានក្លាយជាកម្មវត្ថុនៃការបកប្រែផ្សេងៗយ៉ាងទូលំទូលាយ។ ជាងនេះទៅទៀត ភាស្យសបញ្ជាក់ថា អត្ថបទអំណានជាច្រើនសុទ្ធតែល្អៗ។ ទីបំផុតការប្រៀបធៀបសេចក្តីអត្ថាធិប្បាយក្រោយៗដែលនៅមានរហូតមកដល់ពេលនេះ

សឱ្យឃើញច្បាស់ថា បទអត្ថាធិប្បាយជាទូទៅផ្អែកលើមនុភាស្យ និងថាសូម្បីមតិយោបល់ និងការអានផ្សេងគ្នា ជាញឹកញយកើតចេញពីស្នាដៃមុនៗ។ អនុលោមតាមព្រឹត្តិការណ៍ទាំងនេះ បញ្ហាស្ដីពីកាលបរិច្ឆេទរបស់ មេធា ទិថិ មានសារៈសំខាន់ខ្លាំងណាស់។ ចំណុចគួរឱ្យសោកស្ដាយគឺថា ដូចក្នុងករណីជាច្រើនទៀតដែលយើងមិនមានព័ត៌មានពាក់ព័ន្ធ នឹងប្រវត្តិដ៏គួរឱ្យជឿជាក់ណាមួយទេ ប៉ុន្តែចាំបាច់ត្រូវផ្អែកលើសក្ខីកម្ម ព្រឹត្តិការណ៍ ដូចដែលយើងអាចប្រមូលបានសម្រង់ផ្ទាល់របស់មេធាទិថិ និងសម្រង់របស់អ្នកនិពន្ធដទៃទៀត ដែលស្រង់ចេញពីភាស្យ។ ប្រសិនបើយើងយកតាមអំណះអំណាងក្រោយនេះ ការកំណត់សម័យកាលក្នុងការតាក់តែងស្នាដៃរបស់មេធាទិថិ ត្រូវកំណត់ទៅតាមការបញ្ជាក់របស់ *វិញ្ញានេស្វរៈ* នៅក្នុងការបកស្រាយរបស់គាត់អំពីគម្ពីរមនុជំពូក៩លេខ១៨១។ វិញ្ញានេស្វរៈបានសរសេរបទអត្ថាធិប្បាយរបស់ខ្លួនស្ដីពីយាញ្ញវល្ក្យ នៅក្នុង រជ្ជកាលស្ដេច កាលុក្យ, វិក្រមាទិត្យទី VI ដែលគ្រងរាជ្យនៅដែន កល្យាណ ពីសកសំវ័ត ៩៩៧-១០៤៨ ឬ១០៧៣-១១២៦-៧ ក្រោយ គ.ស(មើលព្រឹត្តិបត្រ Bo.Br.Roy.As.Soc.លេខ ៩ ទំព័រ ១៣៤-១៣៨ និង West និង Buhler *ព្រឹត្តិបត្រច្បាប់ហិណ្ឌូ* ទំព័រ ១៥-១៧ បោះពុម្ពលើកទី៣)។ ក្បួនលើក សេចក្ដីយោងរបស់វិញ្ញានេស្វរៈ សបញ្ជាក់ថា នៅសម័យរបស់គាត់ ភាស្យមានកេរ្តិ៍ឈ្មោះយ៉ាងខ្លាំង។ ដូច្នេះគេអាចសន្និដ្ឋានថា ពេលនោះមិនមែនជាកាលបរិច្ឆេទថ្មីៗទេ។ ចំពោះសេចក្ដីសន្និដ្ឋាន ដូចគ្នានេះ ក៏បញ្ជាក់សេចក្ដីអត្ថាធិប្បាយរបស់កុល្លូក អំពីគម្ពីរមនុ ជំពូក៨ លេខ ១៨៤ ដែលតាមសម្ដីរៀបរាប់កំណាព្យឈ្មោះ១៨១-១៨៤ គេបានដាក់ឈ្មោះ*មេធាទិថិ* នៅពីមុខឈ្មោះ*ភោគភគ*។ តាមការរៀបរាប់ឈ្មោះបុព្វការីរបស់ខ្លួន អ្នកអត្ថកថាចារ្យទាំងឡាយ ជាធម្មតាប្រកាន់ភ្ជាប់នូវសណ្ដាប់ធ្នាប់ ធម្មជាតិ និងដាក់ឈ្មោះណាចំណាស់ជាងគេ នៅមុនគេអាចនិយាយបានថា *កុល្លូក* ចង់បង្ហាញថា មេធាទិថិនៅពីមុខ*ភោគភគ*។ ជាថ្មីម្ដងទៀត ហាក់ដូចជាថា បើឈ្មោះក្រោយនេះ មានលក្ខណៈដូចគ្នានឹងព្រះពហុសូត្រ ដែលបានគ្រប់គ្រងនៅធារា ក្នុងអំឡុងពាក់កណ្ដាលទី១ នៃសតវត្សទី១១ ក្រោយគ.ស. មានន័យថា មេធាទិថិ មិនអាចសរសេរនៅក្រោយសតវត្សទី១០ទេ។ ដោយសារសម័យកាលយូរលង់សម្រាប់ការតាក់តែងភាស្យខ្ញុំធ្លាប់បាននិយាយ ពីមុនហើយ(West និង Buhler, *ព្រឹត្តិបត្រ ទំព័រ* v បោះពុម្ពលើកទី១) ថា មេធាទិថិដកស្រង់កុមារិលៈ និង សង្ការកាយជាប្រភពគួរឱ្យទុកចិត្តយ៉ាងខ្លាំងចំពោះមីមាំសានិងវេទាន្ត។ ប្រភពខាងដើមនេះត្រូវបានរាប់ឈ្មោះ នៅក្នុងកំណត់សម្គាល់ស្ដីពីមនុជំពូក១ លេខ ៣ និងនៅក្នុងចំណងជើងធម្មតា ភគ្គបាទា "ព្រះថេរភគ្គ" នៅក្នុងវគ្គអត្ថាធិប្បាយអំពីគម្ពីរមុនជំពូក២ លេខ៨១។ បើគិតតាមសង្ការកាយខ្ញុំយល់ថា ការយល់ដឹងរបស់មេធាទិថិចំពោះសំណេររបស់លោក មិនមែនប្រាកដប្រជាដូចដែលខ្ញុំធ្លាប់បានគិតពីមុនមកទេ។ នៅក្នុងសំណៅឯកសាររបស់ខ្ញុំផ្ទាល់ ជាប្រតិចរិតនៃការចងចាំរបស់បុណជំរុញឱ្យមេធាទិថិ ដកស្រង់សារីរកភាស្យ។ សំណេរដែចំណាស់ជាង និងប្រសើរជាងរបស់ការិយាល័យឥណ្ឌា អានថា *សារីក* ដែលទំនងជាមានន័យយោងទៅសារីរកសូត្រ(គម្ពីរមនុ ជំពូក១២ លេខ ១៩) ។ អនុលោមតាមព្រឹត្តិការណ៍ទាំងអស់នេះ យើងមិនអាចអះអាងតទៀតថា ភាស្យកើតក្រោយស្នាដៃរបស់ ពួកមហាវេទន្ត ដែលបានសរសេរនៅដើមសតវត្សទី៩ក្រោយគ.ស។ ឥឡូវនេះ យើងមានតែអត្ថបទ ដកស្រង់ពីកុមារិល ដែលមានកាលបរិច្ឆេទមុន ដែលមិនសូវច្បាស់លាស់។ យើងដឹងថា កុមារិល មានមុនសង្ការាកាយ(មើលកំណត់សម្គាល់របស់សាស្ត្រាចារ្យ Cowell

ចំពោះសំណេររបស់ Colebrooke វគ្គ ១ ទំព័រ ៣២៣) ប៉ុន្តែទំហំពេលវេលាដែលនៅចន្លោះស្នាដៃទាំងពីរហូតមកដល់ពេលនេះ នៅមិនទាន់បានបញ្ជាក់ច្បាស់ទេ។ លោក Colebrooke,បណ្ឌិត Burnell និងសាស្ត្រាចារ្យ Max Muller មាន ហេតុផលផ្សេងៗពីគ្នាថា គាត់បានរស់នៅក្នុងសតវត្សទី៧ ឬមិនមែនក្រោយឆ្នាំ ៧00 គ.ស(មើលសាស្ត្រាចារ្យ Max Muller *តើឥណ្ឌាអាចបង្រៀនអ្វីខ្លះដល់យើង?* ទំព័រ ៣០៨ កំណត់សម្គាល់) ទេ។ សូម្បីដូចគ្នានឹងអត្ថបទដកស្រង់របស់គាត់ក៏ដោយ ក៏មេធាទិថិអាចសរសេរនៅមុនសតវត្សទី៩ក្រោយគ.ស.ខ្ញុំនៅតែប្រកាន់ខ្ជាប់នូវទស្សនៈយោបល់របស់ខ្ញុំពីមុនមកដដែល។ ដោយសារការពិចារណាឱ្យកាន់តែជិតដល់អំពីភាស្យ បានបើកបង្ហាញនូវចំណុចមួយចំនួនទៀត ដែលគាំទ្រដល់យោបល់របស់ខ្ញុំ។ មេធាទិថិដកស្រង់ម្តងហើយម្តងទៀតនូវសៀវភៅច្បាប់ពាក្យកាព្យរបស់យាញ្ញវល្ក្យ, នារទ និងបរាសរ ព្រមទាំងកំណែរបស់កាថកធម៌សូត្រ ដែលគេស្គាល់ថាជាវិស្ណុស្រ្មិតិ ហើយទាំងអស់នេះជាសាសនប្បញ្ញត្តិ។ យ៉ាងណាមិញគ្មានស្នាដៃណាមួយ អះអាងពីអាយុកាលចំណាស់ខ្លាំងទេ ជាពិសេសវិស្ណុ ស្រ្មិតិ ដែលរៀបរាប់ឈ្មោះថ្ងៃប្រចាំសប្តាហ៍របស់ក្រិក មិនអាចមានចំណាស់ជាងសតវត្សទី៥ ឬទី៦ ក្រោយគ.ស.ទេ។ ប្រសិនបើមេធាទិថិគិតថាជាស្នាដៃទូន្មានមួយដែលប្រទានដោយ ព្រះវិស្ណុក៏ដោយ ក៏យើងមានហេតុផលសន្និដ្ឋានថា ចន្លោះពេលឃ្លាតគ្នា គឺស្ថិតនៅចន្លោះកាលបរិច្ឆេទ នៃការនិពន្ធស្នាដៃ និងសម័យកាលផ្ទាល់របស់អ្នកនិពន្ធ។ហាក់ដូចជាមានន័យថា វិស្ណុស្រ្មិតិ ទំនងជាត្រូវនិពន្ធនៅកាស្មៀរ ដែលតាមការរកឃើញបច្ចុប្បន្ន ក៏ជាស្រុកកំណើតរបស់មេធាទិថិផង។ លទ្ធផលកាន់តែច្បាស់លាស់ ពាក់ព័ន្ធនឹងកាលបរិច្ឆេទរបស់មេធាទិថិសម្រាប់ខ្ញុំ គឺបារម្ភថា មិនអាចកំណត់បាននៅពេលបច្ចុប្បន្ន។សេចក្តីសំអាងរបស់គាត់ទៅលើស្នាដៃផ្សេងទៀត ដូចជាវាក្យប្រទីបជាបទអភិប្រាយ វិមិស្រ(មនុ ជំពូក១២ លេខ ១១៨. ........សំស្ក្រឹត...............។ សាស្ត្រាចារ្យ Kielhorn ប្រាប់ខ្ញុំថា ឈ្មោះកំណាព្យនេះមិនមាននៅក្នុងវាក្យបទីយ ដែលជួនកាលហៅថា វាក្យប្រទីប), អភិធានកូស(មនុ ជំពូក៩ លេខ ១១៨ លេខ១៨៥-៦ពាក្យដែលត្រូវដកស្រង់គឺ ...សំស្ក្រឹត...) របស់បិង្គល ស្តីពីមាត្រាសាស្ត្រ(មនុ ជំពូក៩ លេខ៤២ ...សំស្ក្រឹត...; បិង្គលជំពូក៨ លេខ ១; មើល Weber *Indische Studien,* ជំពូក៨ លេខ ១៤៧) ជាស្នាដៃរបស់អ្នកនិពន្ធបុរាណនិយាយអំពីសំខ្យាវិទ្យាសិនជាដើមគឺស្ថិតនៅលើស្ថានភាពចំណេះដឹងរបស់យើងពាក់ព័ន្ធនឹងប្រវត្តិអក្សរសាស្ត្រសំស្ក្រឹត ដែលមិនសូវសំខាន់ខ្លាំងទេ។ យ៉ាងណាមិញ ភាស្យ ផ្តល់នូវព័ត៌មានលម្អិតចំនួនពីរ គួរឱ្យចាប់អារម្មណ៍ ពាក់ព័ន្ធនឹងប្រវត្តិផ្ទាល់ខ្លួនរបស់មេធាទិថិ។ ទី១ យើងដឹងថា លោកបានសរសេរ អភិប្រាយពាក្យកាព្យស្តីពីច្បាប់ ពិសិដ្ឋ ដែលគេហៅថា *ស្រ្មិតិវិវេក*។ ទី២ ហាក់ដូចជាថា ជ្រលងភ្នំកាស្មៀរ ដែលបានបង្កើតអ្នកនិពន្ធឥណ្ឌាជាច្រើន ជាប្រទេសកំណើតរបស់លោក។ *ស្រ្មិតិវិវេក* ត្រូវសរសេរ ជាច្រើនដងនៅក្នុងភាស្យជាស្នាដៃដ៏ធំមួយ ដែលពិភាក្សាយ៉ាងក្បោះក្បាយ អំពីបញ្ហាច្បាប់ដ៏ស្មុគស្មាញ(មើល ឧ.ទា.បទអត្ថា.ជំពូក២លេខ៦...សំស្ក្រឹត... និងក្នុងសៀវភៅដដែល...សំស្ក្រឹត....។)។បើនិយាយពីចំណុចផ្សេងទៀតនៅក្នុងភាស្យនេះ មិនបានសរសេរដោយផ្ទាល់អំពីទីកន្លែងកំណើតរបស់លោកមេធាទិថិទេ។ ក៏ប៉ុន្តែអ្នកនិពន្ធជារឿយៗសរសេរអំពីកាស្មៀរ ច្បាប់ សាខា វេទរបស់កាស្មៀរ ព្រមទាំងអំពីភាសារបស់តំបន់នេះ ដែលយើងអាចសន្និដ្ឋានថា កាស្មៀរជាប្រទេស កំណើតរបស់លោកពិតប្រាកដ។ ដូច្នេះ តាមការពន្យល់

ពាក្យ *ស្វារស្ត្រ* មានន័យថា "នៅក្នុងអាណា ចក្ររបស់លោកផ្ទាល់" (មនុ ជំពូក៧ លេខ៣២) និង ពាក្យ *គនបទះ* "ប្រទេស ឬខេត្ត" (មនុ ជំពូក៨ លេខ ៤១) លោកប្រើឈ្មោះកាស្មៀរ ធ្វើជាការលោត ត្រដាងតួយ៉ាងមួយ(ជំពូក ៧ លេខ ២២ ...សំស្ក្រឹត... និងជំពូក៨ លេខ៤១ ...សំស្ក្រឹត...។) ។ ជាថ្មីម្តងទៀត ក្នុង ការលើកឧទាហរណ៍ឯកាធិបតេយ្យរបស់ព្រះរាជា តាមការពិនិត្យគម្ពីរមនុ ជំពូក៨ លេខ៣៩៩ លោក ថ្លែងយ៉ាងត្រឹមត្រូវថាការលក់ល្មៀតគឺជាសិទ្ធិផ្តាច់មុខរបស់ស្តេចនៅកាស្មៀរ។ ជាងនេះទៅទៀតសរសេរ ច្រើនលើកច្រើនសាអំពីគាថកសាខានៃគម្ពីរ យគុរវេទ ពួកស្បែកខ្មៅ ដែលមានតែនៅកាស្មៀរ តាំងពី យូរលង់មកហើយ ហើយនៅពេលព្យាយាមបង្ហាញសក្ខីកម្មនៅក្នុងសេចក្តីពន្យល់អំពីមនុ ជំពូក១ លេខ ៥៨ ថា មានវេធម៌សាស្រ្តៈ ត្រូវគេហៅចំពោះ គម្ពីរមនុ ទោះបីជំបូងលោក ហិរណគភ បានបង្រៀនលើក ដំបូងក៏ដោយ ក៏លោកលើកតួយ៉ាងឧបមា ដូចជាគាថក ដែលត្រូវសិក្សានិងបង្រៀន ដោយអ្នកជទៃជា ច្រើនទៀតក្តី ក៏ហៅឈ្មោះថាគាថាដែរ។ ការបង្ហាញបែបនេះ កម្រមានណាស់សម្រាប់អ្នកដទៃ លើក លែងតែសិស្សគណរបស់គាថកសាខា។ ទីបំផុត សេចក្តីសម្គាល់របស់លោក ជាកត្តាកំណត់ក្នុងការ អធិប្បាយគម្ពីរមនុ ជំពូក៤ លេខ៥៩ ដែលលោកនិយាយថា ឥន្ទធនូ រំលឹកឡើងវិញដល់កាស្មៀរ វិន-ខាយា(...សំស្ក្រឹត...។ ខ្ញុំពិតជាត្រូវអធិប្បាយថា ឯកសារមេរៀនរបស់សាស្ត្រាចារ្យ Jolly, Tagore ទំព័រ ៦ ផ្តល់យោបល់ យល់ឃើញផ្សេងគ្នា និងចាត់ទុកមេធាទិថិ ជាអ្នកស្រុកភាគខាងត្បូង។ ហេតុផលរបស់លោក អំពីការបញ្ចប់ *ស្វាមិន* ក្នុង នាម ឈ្មោះបិតារបស់មេធាទិថិ គឺ វិរស្វាមិន និងការយកចិត្តទុកដាក់របស់អ្នកនិពន្ធបុរាណនៅភាគខាងត្បូងចំពោះភាស្យ នេះ ហាក់ដូចជាមិនមានទម្ងន់គ្រប់គ្រាន់សម្រាប់រូបខ្ញុំទេ។ ព្រោះដូចឈ្មោះអ្នកកាស្មៀរ *ក្សីរស្វាមិន* និងពួកស្វាមិនជាច្រើន បង្ហាញស្រាប់ថា ឈ្មោះនេះ យ៉ាងហោចណាស់ មិនត្រូវបានកំណត់សម្រាប់អ្នកស្រុកខាងត្បូងទេ។ លើសពីនេះ ការរាប់ អានគ្នារវាងកាស្មៀរ និងឥណ្ឌាភាគខាងត្បូង នៅសម័យបិល្ហណៈ និងហសទេវ ពន្យល់អំពីការណែនាំស្នាដៃរបស់កាស្មៀរ ចំពោះ កំណត់សម្គាល់របស់បណ្ឌិតអ្នកស្រុកភាគខាងត្បូង។) ។

បើនិយាយពីប្រវត្តិអត្ថបទនៃបទ អត្ថាធិប្បាយរបស់លោកមេធាទិថិ លោក Colebrooke ថ្លែង នៅក្នុងបុព្វកថា ព្រឹត្តិបត្រ ទំព័រ xv (ការបោះពុម្ពរបស់ Madras)ថា"ភាស្យ" ដែលបានបាត់បង់ខ្លះ ទៅ ហើយនោះត្រូវបានសរសេរបញ្ចប់ដោយស្មេរជទៃ នៅក្នុងជំណាក់របស់មទនបាលព្រះអង្គម្ចាស់ទីយៈ។ អំណះអំណាងនេះទំនងជាផ្អែកលើប្រកពល្បះ តាមខ្នាតសាទុលវិក្រីទិត ដែលឃើញមានច្រើនសំណៅ ច្បាប់នៅចុងបញ្ចប់នៃជំពូកជាច្រើន ដែលនិយាយថា "ភាស្យ ដែលត្រូវបន្ថែមបន្ថយ ព្រះអង្គម្ចាស់ មទ នបាល បុត្រារបស់សាហារណៈ បាននាំយកស្នាដៃពីប្រទេសមួយទៀត ហើយបានធ្វើគីរន្ទទ្វារៈ ឬស្ថាប នាការខូចខាតឡើងវិញ ដោយដកសំណៅខ្លះចេញពីនោះ"( Jolly, *មេរៀនតាហ្គ័រ* ទំព័រ ៧ ដែលគាត់បានរក ឃើញកំណាព្យត្រឹមត្រូវខ្លះ ទោះតិចឬច្រើន ក៏មាននៅក្នុងសំណៅដៃ បុរាណចំនួន ៧ ពីផ្នែកនានានៅក្នុងប្រទេសឥណ្ឌា។ តាមយោបល់របស់ខ្ញុំ គេគួរអានថាៈ ...សំស្ក្រឹត...។ ខ្ញុំយល់ផ្សេងពី សាស្ត្រាចារ្យ Jolly នៅចុងបាទទី២ ដែលគាត់អានតាម សំណៅរបស់បេណៃរថា...សំស្ក្រឹត...និងនៅចុងបាទទី៣ ដែលគាត់ប្តូរការអានពាក្យ...សំស្ក្រឹត...។)។ តាមការប្រើពាក្យ កាព្យ ខ្ញុំអាចយល់ស្របតាមសាស្ត្រាចារ្យ Jolly (ដូចអាគតដ្ឋានទាំងស្រុង) ថា មេធាទិថិ មិនបង្កឱ្យ មានការតាក់តែងឡើងវិញនូវផ្នែកណាមួយនៃភាស្យទេ ប៉ុន្តែគ្រាន់តែបំពេញចន្លោះខ្វះខាតនៃសំណៅ ដៃបណ្ណាល័យរបស់គាត់ ដែលបានពីការទិញនៅតំបន់ផ្សេងៗនៅឥណ្ឌា។ កន្លែងដែលបង្កើតគីរន្ទទ្វារៈ នេះ គឺ កាស្ថានៅជិតដែលី។ ដោយសារល្បះនោះចែងថា មទនៈ ជាបុត្ររបស់សហារណសឱ្យឃើញថា

បុគ្គលនេះ ដូចគ្នានឹងមទនៈឬនាយមទនបាល ជាម្ចាស់វិស្វេស្វរភគ្គ ដែលបាននិពន្ធសុពោធិនី ស្តីពីមិតាក្សរានិងប្រយោគឬមទនបារិគាត។ វិស្វេស្វរៈនៅក្នុងសេចក្តីផ្តើមស្នាដៃក្រោយនេះជាផ្នែកមួយនៃពង្សាវលីលោកម្ចាស់របស់គាត់( Aufrecht, *Cat. សំស្ក្រឹត* សំណៅដៃនៅបណ្ណាល័យ Bodleian ទំព័រ ២៧៤ ) និងអះអាងថា មទនៈ ជាកម្មសិទ្ធិរបស់គ្រួសារប្រធានតំបន់កាស្ថា និងជាបុត្រទី២របស់គ្រួសារ*សាធារណៈ*មួយ។ អាចកាត់យល់បានថានៅក្នុងកំណាព្យដកស្រង់ខាងលើសហារណៈទម្រង់បាក្រឹត ត្រូវបានប្រើជំនួស *សាធារណៈ* ក្នុងហេតុផលកាព្យឃ្លោង។ លោក Colebrooke បានកំណត់មទនៈនេះ ដូចគ្នានឹងអ្នកនិពន្ធ ដែលមានសទិសនាមនឹងមទនវិន្ទុ ដែលកំណត់កាលបរិច្ឆេទ វិក្រមសំវ័ត១៤៣១ ឬ ១៣៧៥ ក្រោយគ.ស. ហើយលោកសវាធិការិ ឯកភាពពីការបង្ហាញពីភាពដូចគ្នា ដោយប្រាប់យើងថាមទនវិន្ទុមានពង្សាវលីមទន( *មេរៀនតាហ្គ័រ*ឆ្នាំ១៨៨០ ទំព័រ ៣៨៩។ លោក សវាធិការិ ចង់អានកាលបរិច្ឆេទ ព្រហ្ម (១) គគ័ត (៣) យុគ(៤) ឥន្ទុ(១) (មាឃ សុទិ ៦ ថ្ងៃច័ន្ទ) ថា ១២៣១។ លោក គិតថា យុគ ក៏អាចបង្ហាញតួលេខ ២ និងថា ការអានវិក្រមសំវ័ត ១២៣១ ជាការចាំបាច់ ពីព្រោះបារិគាត ត្រូវបានដកស្រង់ដោយកណ្ឌេស្វរៈ ដែលបាននិពន្ធនៅសតវត្សទី១៣។ យ៉ាងណា មិញ លោកក៏បានយល់ច្រឡំ ដោយសារការគណនាតារាសាស្ត្របង្ហាញថា មាឃ សុទិ ៦ នៃវិក្រមសំវ័ត ១៤៣១ ត្រូវនឹងថ្ងៃច័ន្ទ (ខែមករា ទី៨ ១៣៧៥) ចំណែកឯថ្ងៃដដែលនេះ ឆ្នាំ១២៣១ គឺថ្ងៃព្រហស្បតិ៍។ ហេតុនេះ បារិគាតដែលត្រូវដកស្រង់ដោយកណ្ឌេស្វរគឺជាស្នាដៃផ្សេងទៀតនិយាយពីច្បាប់។ ចំណាងជើងនេះមិនមែនមិនធម្មតានោះទេ។) ជាមួយគ្នានឹងបារិគាត។ ហេតុនេះ "ការស្តាបនាភាស្សនេះឱ្យដូចដើមវិញ" ពិតជាបានអនុវត្តប្រហែលប្រាំរយឆ្នាំមកហើយ។

យ៉ាងណាមិញ ហាក់ដូចជាថា សកម្មភាពនេះមិនធ្វើឱ្យហ្មត់ចត់ ឬអាចនិយាយថាប្រសិទ្ធភាពរបស់វាមិនស្ថិតថេរទេ។ ចំពោះសំណៅអត្ថាធិប្បាយទាំងអស់របស់មេធាទិថិ ដែលខ្ញុំបានឃើញ ឬធ្លាប់បានប្រើជាទូទៅទោះតិច ឬច្រើន សុទ្ធតែរងនូវការពុកផុយទាំងអស់ ហើយនៅក្នុងផ្នែកខ្លះ ជាពិសេសនៅជំពូកទី៨ និងទី៩ ព្រមទាំងនៅចុងជំពូកទី១២ មានស្ថានភាពផ្សេងទៅវិញ។ ផ្នែកក្រោយនេះ ស្ថិតក្នុងភាពប្រឫកប្រឫសណាស់ ផ្នែកខ្លះដាច់បាត់ និងផ្នែកខ្លះទៀតត្រួតគ្នា។ នៅជំពូកទី៨ និងទី៩ ល្បះកំណាព្យជាច្រើនបានបាត់ ទោះបីមានសក្ខីកម្មបង្ហាញយោង ដែលផ្អែកលើយោងផ្សេងទៀត ឬផ្អែកលើកំណត់សម្គាល់របស់កុល្លូក ថាលោកមេធាទិថិ ពិតជាបានបកស្រាយកំណាព្យដែលបាត់នោះ។ សូម្បីផ្នែកអត្ថាធិប្បាយនៅមានរូបរាងនៅឡើយក្តី ក៏ការពុកផុយជារឿយៗមានសភាពធ្ងន់ធ្ងរ ហើយអត្ថន័យមានការសង្ស័យជាញឹកញយឬគ្រាន់តែជាការស្មានប៉ុណ្ណោះ។ ក្នុងព្រឹត្តិការណ៍ទាំងអស់នេះខ្ញុំមានជំនឿថា ការជាប់ជំពាក់ខ្លាំងពេកចំពោះចំណុចខ្វះខាតនៃកំណាព្យ ដែលស្ថិតក្នុងភាស្ស សុទ្ធសាធគឺមិនមែនជាការឆ្លាតវៃទេ។ មុននឹងយើងអាចឈានទៅធ្វើការសម្រេចពាក់ព័ន្ធនឹងស្ថានភាពពិតប្រាកដ នៃមនុស្ម្រិតិ នៅសម័យលោកមេធាទិថិខ្ញុំគិតថា យើងតោងមានសំណៅដៃនៃស្នាដៃរបស់លោក ដែលគ្រាន់បើជាងនេះ។ មន្ត្រីទទួលបន្ទុកស្រាវជ្រាវសំណេរដៃសំស្ក្រឹតនៅប្រទេសឥណ្ឌា អាចខិតខំធ្វើការងារយ៉ាងច្រើនដោយផ្អែកលើប្រវត្តិច្បាប់ឥណ្ឌា បើពួកគេផ្តោតការខិតខំរបស់ពួកគេ ដើម្បីរកឱ្យបានសំណៅសំណេរដៃដែលនៅល្អពិតប្រាកដ ហេតុនេះបើអ្នកស្រាវជ្រាវមានសមត្ថភាពអាចបោះផ្សាយសៀវភៅដ៏គួរឱ្យទុកចិត្តនោះ។ សំណៅដែលត្រូវប្រើសម្រាប់សរសេរកំណត់សម្គាល់នៃអត្ថបទ បកប្រែរបស់ខ្ញុំ គឺខ្ញុំ

ផ្អែកភាគច្រើនបំផុតលើជំពូកទី១-៦ និងទី១០-១២ ដែលជាសំណេរបុរាណនៅឆ្នាំ១៨៦៤ និងសំណៅនានារបស់បណ្ណាល័យការិយាល័យឥណ្ឌា លេខ.៩៣៤-៩៣៥, ១៤០៧-១៤០៩, ១៥៥១-១៥៥២។ សំណៅទាំងអស់នេះ ងាកទៅផ្អែកលើសំណៅក្បួនច្បាប់ដើម ដែលបានទទួលពីសំណៅស្ថាបនាឡើងវិញរបស់លោកមទនៈហើយសំណៅល្អប្រសើរបំផុតគឺមាននៅក្នុងបណ្ណាល័យការិយាល័យឥណ្ឌា លេខ. ១៥៥១-១៥៥២ ដែលមានកាលបរិច្ឆេទសំរ័តៃ ១៦៤៨ មាគ សីស សុទិ ៣, សូមវាសិរេ ឬថ្ងៃចន្ទ ទី១៨ ខែវិច្ឆិកា ឆ្នាំ១៥៩១ ក្រោយ គ.ស(សម្រាប់ការគណនានេះ និងការគណនាកាលបរិច្ឆេទផ្សេង ខ្ញុំត្រូវអរគុណបណ្ឌិត Schram ជាគ្រូបង្រៀនឯកជន ផ្នែកប្រវត្តិវិទ្យាតារាសាស្ត្រ នៅសាកលវិទ្យាល័យវីយែន។)។

ក្រោយមក បន្ទាប់មនុភាស្យ តែទំនងជានៅចន្លោះពេលផ្សេងគ្នាច្រើន មាននមនុទីកា នៃគោវិន្ទរាគបុត្ររបស់ភត្តមាធវ។ កាលបរិច្ឆេទពិតប្រាកដរបស់អ្នកនិពន្ធនេះហាក់ដូចជាមិនអាចដឹងបានច្បាស់លាស់ទេ។ លោកជាមនុស្សប្រយ័ត្នប្រយែងអំពីខ្លួនឯង និងបុព្វការីរបស់លោកណាស់ ហើយដកមិនត្រឹមតែស្នាដៃមួយដែលនិយាយពីច្បាប់ទេ លើកលែងតែស្រ្មិតិមញ្ជរី ឬស្រ្មិតិមញ្ជរិបញ្ចិកា ដែលជាកម្រងក្បួនច្បាប់ស្តីពីការលាងបាប(ការអត្ថាធិប្បាយអំពីមនុ ជំពូក៣ លេខ ២៤៧ និង ២៤៨; សូមមើលកុល្លូកស្តីពីមនុ ជំពូក៤ លេខ ២១២ផង។ សំណៅ ស្នាដៃនេះ ដែលនិពន្ធនៅអស្វិន ពទិស នៅក្នុងអំឡុងរជ្ជកាលមហារាណ ឧទយសិង្ហ ត្រូវបានរក្សាទុកនៅក្នុងបណ្ណាល័យការិយាល័យឥណ្ឌា លេខ. ១៧៣៦។ លោក Colebrooke បានគិតថា កាលបរិច្ឆេទនេះ ត្រូវសំអាងលើសករាជ វិក្រម ហើយ អ្នកបណ្ណាធិការសំណៅចម្លងជាច្រើន ដែលបោះផ្សាយដោយអង្គការសង្គមសិក្សាអក្សរបុរាណ លេខ៣ កើតមានជាបន្តបន្ទាប់ពីរូបលោក។ ប៉ុន្តែគ្មានអ្វីគួរឱ្យសង្ស័យទេថា ព្រះអង្គម្ចាស់ ដែលបាននិយាយនៅក្នុងផ្នែកព័ត៌មានអំពីការបោះពុម្ព គឺជាមហារាណ ឧទយសិង្ហ ក្នុងសៃស្រឡាយមេវាទ ដែលបានឡើងសោយរាជ្យនៅឆ្នាំ១៥៤១ ក្រោយគ.ស.។ ដូចនេះ កាល បរិច្ឆេទនៃសំណៅនេះ សំដៅដល់សករាជ សកៈ និងត្រូវនឹងឆ្នាំ ១៥៤៥ ក្រោយគ.ស.។ ស្រ្មិតិ មញ្ជរី គ្មានសម្រង់ដែលដកស្រង់ពីគម្ពីរច្បាប់ដទៃ ក្រៅពីស្រ្មិតិទេ។ ឈ្មោះបិតារបស់គោវិន្ទរាគ គឺភត្ត មាធវ មានចុះនាមចារឹកនៅក្នុងផ្នែកជាច្រើន ជាញឹកញយ។) ដែលមានប្រភពចេញពីធម៌សាស្ត្រៈនានា។ យ៉ាងណាក៏ដោយ គេអាចរកហេតុផលអំពីការកំណត់អាយុកាលយូរលង់ជាងនេះ ពីកំណត់សម្គាល់របស់កុល្លូកដែលនិយាយពីមនុ ជំពូក៨ លេខ១៨៤ ចាប់ពីនោះមកហាក់ដូចជាថា គោវិន្ទរាគ ស្ថិតក្នុងសម័យកាល ក្រោយភោគនៃរាជ្យធានា (ពាក់កណ្តាលទី១ នៃសតវត្សទី១១)។ ការកំណត់អាយុកាលទាបជាងនេះ ត្រូវបញ្ជាក់ដោយសំណេរឈ្មោះរបស់លោក នៅក្នុងទាយភាគនៃគីមូតវាហន(Colebrooke *ទាយ.* ជំពូក១១ លេខ ៣១ ដែលមានចារឹកឈ្មោះរបស់គោវិន្ទ បន្ទាប់ពីឈ្មោះរបស់ភគរាគ។) និងនៅក្នុងស្នាដៃរបស់សូលបាណី ស្តីពីការលាងបាប(Aufrecht, *Cat. សំណៅសំស្ក្រឹត* នៃបណ្ណាល័យ Bodleian ទំព័រ ២៨៣a) ។ ខ្ញុំអាចយល់ស្របតាមសាស្ត្រាចារ្យ Jolly ក្នុងករណីដែលលោកគិតថា គាត់បានរស់នៅក្នុងសតវត្សទី១២ ឬទី១៣(Jolly, *មេរៀនតាហ្គ័*ទំព័រ៩) ។ ការបញ្ចប់ឈ្មោះគោវិន្ទរាគបានញ៉ាំងឱ្យអ្នកសិក្សាស្រាវជ្រាវជាច្រើនសន្និដ្ឋានថាគាត់ជាព្រះអង្គម្ចាស់ ហើយ គេអាចយល់ពីគាត់ តាមរយៈគោវិន្ទ កន្ទ្រ នៃ ដែនដីបេណៃ (ជានគរពារានសីពីដើម) ឬ តាមរយៈព្រះមហាក្សត្រិយ៍ ដែលមានសូរដូច ព្រះនាម កានូគ។ ប៉ុន្តែបុត្ររបស់ភត្ត អាចជាព្រហ្មណ៍ប៉ុណ្ណោះ ហើយគេមិនត្រូវភ្លេចថា គោវិន្ទរាគ គឺ ស្មើគ្នានឹងគោវិន្ទ្រៅ ជាឈ្មោះសាមញ្ញមួយក្នុងចំណោមមរាថា ព្រហ្មណ៍។

មនុទីកា ជាឃ្លាវាចាមួយយ៉ាងខ្លីនៃអត្ថបទមនុ តែមានន័យមិនច្បាស់លាស់("មិនច្បាស់លាស់" ជាគុណស័ព្ទ ដែលលោក Sir W. Jones ប្រើនៅក្នុងអារម្ភកថាអត្ថបទបកប្រែគម្ពីរមនុ ទំព័រ xvii (St. Grady)។ ការស្មាននេះទំនងជាកើតចេញពីពាក្យសម្ដីរបស់កុល្លូក ក្នុងកំណាព្យបញ្ចប់បទអត្ថាធិប្បាយរបស់លោក ...សំស្ក្រឹត... ។ នេះគ្រាន់តែជាអ្វីដែលគេគិតថាជាស្នាដៃលួចចម្លងដ៏អសោច ដែលគេចង់លើកតម្លើង។) ។ ជាទូទៅ វាជា ការសង្ខេបភាស្យរបស់មេធាទិថិ ដែលគោវិន្ទបានលើកឡើងនូវអ្វីដែលហាក់ដូចជាមានតម្លៃបំផុតសម្រាប់រូបលោក។ លោកបានបដិសេធចោលនូវការបកស្រាយតាមអំពើចិត្តជាច្រើននៃបុព្វការីរបស់ លោក ព្រមទាំងការសរសេរយ៉ាងច្រើនរបស់ខ្លួន ប្រកបដោយបដិវាទកម្មអំពីចំណុចស្មុគស្មាញនៃច្បាប់ ចំណែកឯលោកបានសរសេរសង្ខេបការបកស្រាយផ្សេងៗយ៉ាងខ្លី។ លោកបានបន្ថែមការពន្យល់អំពី ពាក្យទាំងនោះ ដែលលោកមេធាទិថិមិនបាននិយាយ ហើយជួនកាលលោកក៏លើកឡើងនូវយោបល់ ដែលមិនមានប្រភពនៅក្នុងស្នាដៃមុនៗ ដែលអាចជាស្នាដៃរបស់ខ្លួនក៏បាន ឬបានមកពីប្រភពនានា ដែលយើងមិនអាចរកបានក្តី។ ក៏ប៉ុន្តែនៅក្នុងករណីបែបនេះ លោកកម្រនឹងមានសំណាងល្អ និងនាំឲ្យ មានលទ្ធផល ដែលអ្នកជំនាន់ក្រោយរបស់គាត់ គឺលោកកុល្លូក សើចចំអក ដោយមិនមែនគ្មានហេតុ ផលអ្វីនោះទេ។ ដូច្នេះតាមការសង្កេតរបស់គាត់ស្តីពីមនុជំពូក៣ លេខ៥០ ដែលអត្ថបទនិយាយថា បុរស ដែលកម្រិតការរួមសង្វាសជាមួយសហព័ទ្ធក្នុងកម្រិតអប្បបរមា មានភាពបរិសុទ្ធដូចគ្នានឹងអ្នកសិក្សា "ដែលអាចរស់នៅតាមទោះក្នុងស្ថានភាពណាក៏ដោយ" ហើយគោវិន្ទ ចាប់យកពាក្យចុងក្រោយ ដែលមានន័យចង្អៀតពេក និងបំភ្លឺឱ្យហិណ្ឌូបានយល់ពីគោលលទ្ធិចម្លែកៗ ដែលគម្ពីរមនុមានបំណង អនុញ្ញាតឱ្យពួកឥសី ដែលមានកូនចៅស្លាប់អស់ អាចត្រឡប់ទៅកាន់ជីវិតសហព័ទ្ធឡើងវិញ និងអាចជួសជុលការបាត់បង់របស់ពួកគេ ឱ្យប្រសើរឡើងវិញ។ ការភាន់ច្រឡំស្រពេចស្រពិលខ្លះទៀត ត្រូវបាន សាស្ត្រាចារ្យ Jolly គូសបញ្ជាក់នៅក្នុងមេរៀនតាហ្គ័ររបស់លោក ទំព័រ៩ កំណត់សម្គាល់ចំណុច១។ យ៉ាងណាមិញ លក្ខណៈពិសេសផ្សេងទាំងអស់នេះមិនធ្វើឱ្យបាត់បង់ច្រើននូវសារប្រយោជន៍របស់មនុទីកាទេ។ ស្នាដៃមិនត្រឹមតែមុនដំបូងគេបំផុតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការបកស្រាយអត្ថបទមនុបានយ៉ាងពេញលេញបំផុតផង។ជារឿយៗស្នាដៃនេះជួយឱ្យអ្នកសិក្សាអាចស្វែងយល់នូវព្រៃប្រស្នា ទាំងមូលនៃភាស្យ និងមានការបកស្រាយដ៏មានតម្លៃជាច្រើន នូវពាក្យពេចន៍ទាំងឡាយដែលលោក មេធាទិថិ មិនបានពន្យល់។ សំណៅសរសេរដៃដែលប្រើសម្រាប់ការអធិប្បាយនេះ ជាសំណៅតែមួយគត់ ដែលខ្លួនខ្ញុំផ្ទាល់បានទទួលពីរដ្ឋាភិបាលទីក្រុងប៊ុំបៃ(បណ្ណាល័យមហាវិទ្យាល័យដេកង់កម្រងឯកសារឆ្នាំ១៨៧៩-១៨៨០លេខ២៣៩)។សៀវភៅនេះ មានសភាពលក្ខណៈល្អធម្មតា មានអត្ថបទទាំងមូលនិងមានអត្ថាធិប្បាយផងលើកលែងតែចំណុចជំពូក៩ លេខ៧១-៣៣៦។ ស្នាដៃនេះត្រូវបាននិពន្ធនៅស្តមភតីថ ឬនៅកាំប៉ៃ ទំនងជា ២៥០-៣០០ ឆ្នាំកន្លងមកហើយ។

ទីតាំងកាលប្បវត្តិនៃបទអត្ថាធិប្បាយក្រោយៗនៅក្នុងបញ្ជីរបស់យើង មន្វាថវិវ្វិតិ ឬមន្វាថនិពន្ធរបស់សវ៌ញ-នារាយណ ត្រូវបានកំណត់ដូចលោកសាស្ត្រាចារ្យ Jolly ធ្លាប់បានគូសបញ្ជាក់ដំបូង នៅក្នុងសេចក្តីណែនាំបទអត្ថាធិប្បាយរបស់រាឃវានន្ទ(Jolly, *មេរៀនតាហ្គ័រ* ទំព័រ ១១; វគ្គនេះ ត្រូវបានបោះពុម្ពនៅក្នុងសៀវភៅកាតុឡុកតញ្ជ័រ របស់បណ្ឌិត Burnell ទំព័រ១២៦) ។ អ្នកនិពន្ធក្រោយនេះ និយាយត្រង់ចំណុចនោះ

ថា "គាត់បានដឹង (មតិយោបល់នេះ) ដែលមានការទទួលស្គាល់ពីកុល្លូក និងនារាយណៈ និងបានដឹងពីយោបល់ដែលមាននៅក្នុងបេះដូងរបស់គោវិន្ទ និងមេធាទិថិ"។ ដូចសក្ខីកម្មបង្ហាញថា នៅក្នុងក្រុមទី២ អ្នកនិពន្ធក្រោយនេះ ធ្លាប់ត្រូវបានគេដាក់ក្នុងក្រុមទី១ ហើយការសន្និដ្ឋានថា គេបានកំណត់លំដាប់ដូចគ្នានឹងពីរក្រុមដំបូង និងថារាឃវានន្ទ ដែលប្រើប្រាស់គោលការណ៍ឧត្តរោត្តរគរីយស្ទ ពោលគឺការដាក់ឈ្មោះបុគ្គលដែលសំខាន់ជាងនៅក្រោយ មានបំណងចង់ឱ្យអ្នកអាន អានវគ្គទាំងមូលថយក្រោយ (របៀបរាយឈ្មោះក្រុមមនុស្សតៗគ្នា ឬអំណះអំណាង ក៏ឃើញមាននៅក្នុងស្នាដៃសំស្ក្រឹតពីមុនៗមកខ្លះដែរ; សូមមើល ឧ. ទា. វសិស្ថ ជំពូក ១៣ លេខ៥៨) គឺមិនមែនមិនសមហេតុផលទេ។ ដើម្បីជាការគាំទ្រយើងក៏ថ្លែងពីការពិតថា នារាយណៈ ដកស្រង់គោវិន្ទរាគស្តីពីមនុ ជំពូក៨ លេខ១២៣។ ដើម្បីកំណត់កាលបរិច្ឆេទ ដែលនារាយណៈបានសរសេរនោះ យើងត្រូវតែពឹងផ្អែកយ៉ាងសំខាន់លើពាក្យសម្រង់មួយចំនួន។ ទស្សនៈយោបល់របស់គាត់ ស្តីពី ច្បាប់ ដំបូងឡើយត្រូវបានដកស្រង់ពាក្យ ដោយកមឡាករ ដែលបាននិពន្ធនៅដើមសតវត្សទី១៧ (Aufrecht, *សៀវភៅកាតាឡុក* ភាសាសំស្ក្រឹត បណ្ណាល័យ Bodliean ទំព័រ២៧៥)។ ក៏ប៉ុន្តែគោលការណ៍នាមនិធាន របស់នារាយណសវញ្ញ ត្រូវបានលោករាយមុកុត សរសេរនៅក្នុងបទអត្ថាធិប្បាយរបស់លោក ស្តីពីអមរកោស ដែលត្រូវនិពន្ធនៅឆ្នាំ១៤៣១ (មើលការវិភាគរបស់សាស្ត្រាចារ្យ Aufrecht នៅក្នុងព្រឹត្តិបត្រអង្គការចុងបូព៌ារបស់អាល្លឺម៉ង់ លេខ២៨ ទំព័រ១១៤) ក្រោយគ.ស។ រហូតមកដល់ពេលនេះ សំណៅដៃរបស់មនវាថវិវ្វិត្តិ (សំណៅដៃនេះ ដែលត្រូវបានប្រើសម្រាប់អត្ថាធិប្បាយក្នុងអត្ថបទបកប្រែនេះ គឺជាសំណៅមួយនៅមានសភាពល្អ ដែលមានអត្ថាធិប្បាយសុទ្ធ។ បន្ទាប់ពីលេខ ១-៨ ត្រូវកណ្តុរ ស៊ីអស់ពាក់កណ្តាល។ ចាប់ពីលេខ ១៩២-៣ បានបាត់ទៅហើយ។)ដែលគេរកឃើញ (សៀវភៅកម្រងរបស់មហាវិទ្យាល័យដេកង់ឆ្នាំ១៨៧៩-១៨៨០ លេខ២៣៨) មាននៅចុងនៃអធ្យាយទី ៨ កាលបរិច្ឆេទ សំ១៥៤៤ កែត្រ ពទិ៩ រវៅ ដែលត្រូវនឹងថ្ងៃអាទិត្យទី២៧ ខែមីនា ១៤៧៩ ក្រោយគ.ស។ ហេតុដូច្នេះ មានន័យថា នារាយណៈ មិនអាចនិពន្ធក្រោយពាក់កណ្តាលចុងក្រោយនៃសតវត្សទី១៤ទេ។ ហាក់ដូចជាគាត់មានអាយុចាស់ជាងនោះបន្តិច។

មនវាថវិវ្វិត្តិ មិនមែនជាអត្ថាធិប្បាយបន្ត ដែលបកស្រាយគ្រប់ពាក្យទាំងអស់នៃអត្ថបទទេ។ វាជាការបំភ្លឺសេចក្តី និងពាក្យស្មុគស្មាញនានា។ គេបានសរសេរ មនវាថវិវ្វិត្តិនេះ ក្នុងបំណងដ៏មុតមាំ កែសម្រួលស្នាដៃរបស់អ្នកនិពន្ធមុនៗ ឱ្យដូចដើមឡើងវិញ។ នៅចុងជំពូកទី១ ទី៦ និងទី៨ យើងឃើញមានកំណាព្យដែលហាក់ដូចជារបស់នារាយណៈ ដែលនិយាយថា "បទអត្ថាធិប្បាយអំពីមនុស្រ្មិតិនេះ ដែលនិពន្ធដោយនារាយណៈ សវវញ្ញ ដ៏ចំណាន ជាការពិពណ៌នាយ៉ាងច្រើន ដូចជាការបកស្រាយដ៏គួរឱ្យធុញ (..សំស្ក្រឹត... ។ ដូចនេះ នៅចុងជំពូកទី១ និងនៅក្នុងវគ្គពីរផ្សេងទៀត អក្សរ សរសេរខុសទម្រង់។) ។ ជាថ្មីម្តងទៀត នៅចុងជំពូកទី៤ យើងអាន "ចូរអ្នកយកចិត្តទុកដាក់ចំពោះពាក្យល្អៗ របស់នារាយណសវញ្ញ ដែលពោលអះអាងអត្ថន័យត្រឹមត្រូវនៃគម្ពីរមនុ និងច្រានចោលការអត្ថាធិប្បាយមិនត្រឹមត្រូវ" ( ...សំស្ក្រឹត ... ។ កំណាព្យអួតបីទៀត មាននៅចុង ទី១ នៅក្នុងជំពូក ៣ .....សំស្ក្រឹត..., ទី២ ជំពូកទី៥ ...សំស្ក្រឹត...និង ទី៣ ជំពូកទី៩ ...សំស្ក្រឹត..)។ តាមពាក្យសម្តីទាំងអស់នេះនារាយណស្តែងឱ្យឃើញនូវការព្រួយបារម្ភក្នុងការបកស្រាយឱ្យផ្សេងពីសេចក្តីបកស្រាយរបស់មេធាទិថិនិងគោវិន្ទ។ ជួនកាលគាត់សម្រេចបំណងនេះ ដោយងាកទៅមើលនូវទស្សនៈយោបល់ ដែលលោកមេធាទិថិអះអាង និងបដិសេធប៉ុន្តែជារឿយៗការបកស្រាយ

របស់គាត់ត្រូវដកស្រង់ចេញពីបទអត្ថាធិប្បាយ ដែលយើងមិនអាចរកប្រភពបានក៏មាន ឬបង្ហាញនូវទស្សនៈយោបល់ដែលគាត់បង្កើតឡើងដោយឯកឯងក៏សឹងមាន។ រាល់ការបកស្រាយពិសេសរបស់គាត់គួរតែយើងយកចិត្តទុកដាក់ឱ្យមែនទែន។ ក្នុងករណីជាច្រើន ការបកស្រាយនោះ មានលក្ខណៈ ប្រសើរជាងការបកស្រាយរបស់អ្នកផ្សេង ហេតុនេះហើយយើងកម្រនឹងឃើញមាននៅក្នុងការបកប្រែ ណាស់។ នារាយណហាក់ដូចជាមិនត្រឹមតែតែងកំណាព្យយ៉ាងស៊ីជម្រៅនៅក្នុងច្បាប់ពិសិដ្ឋប៉ុណ្ណោះទេ ថែមទាំងមានចំណេះដឹងអំពីសាស្ត្រៈជាច្រើនទៀតផង។ ដូចយើងបានសិក្សាអំពីការអត្ថាធិប្បាយ របស់គាត់អំពីមនុ ជំពូក៥ លេខ ៥៦, ៨០, ១០៤ វគ្គ១១ លេខ ៧២ដែរ គាត់ក៏បាននិពន្ធស្នាដៃពីរទៀត ស្តីពីធម្មកាមធេនុទិបិកា និងសុទ្ធិទិបិកា។ កោសៈរបស់គាត់ យើងបាននិយាយនៅខាងលើរួច ហើយ។ ការអត្ថាធិប្បាយរបស់គាត់ ក្នុងផ្នែកមហាភារតៈ ឧ.ទា.អំពីឧទ្យោគបវ៌ន អំពីស្វរគារោហណ បវ៌ន( Weber, *សៀវភៅកាតាឡុកអាល្លឺម៉ង់* លេខ ៣៤៤, ៣៩៩; Aufrecht *សៀវភៅកាតាឡុក* បណ្ណាល័យបូលីនៀន ទំព័រ២ ) និងអំពីសនត្សុគារីយ នៅមានរហូតមក( Telang, *គម្ពីរពិសិដ្ឋបូព៌ាប្រទេស* ភាគ ៨ ទំព័រ ១៤៨ ) ។

ស្នាដៃទី៤ នៅក្នុងបញ្ជីរបស់យើង មន្វាថ-មុក្តាវលិ របស់កុល្លូកភត្ត បុត្ររបស់ទិវាករភត្ត ត្រូវគេចាត់ជាស្នាដៃដ៏ល្បីល្បាញមួយ រហូតដល់ពេលថ្មីៗនេះក្លាយជាសៀវភៅណែនាំដ៏គួរឱ្យទុកចិត្តបំផុតសម្រាប់អធិប្បាយគម្ពីរមនុ។ នៅក្នុងកាព្យផ្តើមបទអត្ថាធិប្បាយរបស់គាត់ កុល្លូកប្រាប់យើងឱ្យដឹងថាគាត់គឺជាគោទ ឬជាអ្នកស្រុកបឹងហ្គាលិ ពីកំណើតឪពុករបស់គាត់រស់នៅស្រុកនន្ទនៈ ដែនវរេន្ទ្រី( នៅក្នុងនាមចារឹកនៃជំពូកទី១៣ កន្លែងនេះ ត្រូវគេហៅថា ដែនវារេន្ទ្រនន្ទន។ ស្រុកវរេន្ទ្រ ស្ថិតនៅចន្លោះទីនាជបុរ និង ទន្លេកាំង យោងតាមលោក Cunningham របាយការណ៍កាលប្បវត្តិ ជំពូក ១៥ សន្លឹកទី១ និងទំព័រ ៤០។ ) និងថា គាត់បាននិពន្ធស្នាដៃរបស់គាត់នៅបេណែ ( ពារានសី )ដោយមានជំនួយពីបណ្ឌិតខ្លះទៀត។ បើនិយាយពីសម័យកាលរបស់គាត់ យើងគ្រាន់តែដឹងថា នារាយណសរវញ្ញ និងអ្នកអត្ថាធិប្បាយម្នាក់ទៀត លោកធរណីធរ( មើលកាព្យបញ្ចប់នៅចុងជំពូកទី១២ ) ស្ថិតនៅចន្លោះឈ្មោះលោកនិងគោវិន្ទរាគ និងថា រឃុនន្ទន ដែលបាននិពន្ធនៅដើមសតវត្សទី១៦ជាអ្នកនិពន្ធដំបូងបង្អស់ដែលដកស្រង់ឈ្មោះគាត់( Aufrecht,សម្រង់ដដែលទំព័រ ៣៩១ ) ។ ហេតុនេះ គាត់ទំនងជា បានរស់នៅក្នុងសតវត្សទី១៥។

ដូចលោកសាស្ត្រាចារ្យ Jolly ធ្លាប់បានទទួលស្គាល់មុនគេ ( DieJllristischen Ablchnitte aus dem Gesetzbucbe desManu,ទំព័រ ៣,desSeparatabdrucks;មេរៀនតាហ្គ័រ ទំព័រ១០ ) មន្វាថមុក្តាវលិ ជាសៀវភៅដែលត្រូវធ្វើឲ្យប្រសើរឡើងវិញតិចជាងមនុតីការបស់គោវិន្ទរាគ។ ថ្វីបើមានភាពគ្រោតគ្រាត ដែលកុល្លូកប្រើពាក្យរិះគន់ម្តងហើយម្តងទៀតចំពោះបុព្វការីរបស់គាត់ គាត់មិនបានមាក់ងាយក្នុងការចម្លងផ្នែកភាគច្រើននៃមនុតីកាជួនកាលប្រើពាក្យដូចគ្នា ហើយជួនកាលចម្លងចេញមិនបានពេញលេញទាំងស្រុងទេ ដែលជាហេតុធ្វើឱ្យកន្លែងដែលបាត់នោះ មានន័យមិនច្បាស់លាស់។ ម្យ៉ាងទៀត សូម្បីកន្លែងដែលប្រើពាក្យអធិប្បាយពីរផ្សេងគ្នាក៏ឥទ្ធិពលរបស់គោវិន្ទអាចឱ្យគេមើលឃើញកាន់តែច្បាស់។ ក្នុងព្រឹត្តិការណ៍ទាំងនេះ តម្លៃមុក្តាវលិ ចាប់តាំងពីមានការចម្លងមនុតីកាឡើងវិញ គឺមិនមានច្រើនទេ សូម្បីគេមិនអាចបដិសេធបានថាក្នុងករណីខ្លះ ពាក្យសម្តីឬការរិះគន់របស់កុល្លូក ដោយការជឿជាក់ចំពោះស្នាដៃពីមុនៗមានប្រយោជន៍យ៉ាងណាក៏ដោយ។ កេរ្តិ៍ដ៏ល្បីរបស់វានៅឥណ្ឌា និងវត្តមានរបស់វាជារឿយៗនៅតាម

បណ្ណាល័យរបស់មេធាវីពលរដ្ឋ នៅគ្រប់តំបន់នៃឧបទ្វីបអាចជាការបកស្រាយដោយការពិតថា ស្នាដៃនេះត្រូវបាននិពន្ធ និងទទួលបានជំនឿទុកចិត្តនៅបេណៃ (ពារានសី) ដែលជាទីក្រុងតាំងពីបុរាណយូរលង់ មានមជ្ឈមណ្ឌលអក្សរសាស្ត្រដ៏សំខាន់បំផុត និងជាប្រភពដ៏ចម្បងសម្រាប់បណ្ឌិតទាំងឡាយទទួលបានការផ្គត់ផ្គង់សៀវភៅគម្ពីររបស់ពួកគេ។ ដើម្បីធ្វើការពន្យល់ ខ្ញុំមិនបានប្រើប្រាស់សំណៅសំណេរដៃរបស់មុក្តាវលិទេ ប៉ុន្តែប្រើសៀវភៅបោះពុម្ពពីរក្បាល ជាការបោះពុម្ពឡើងវិញរបស់ គីពានន្ទនៅរោងពុម្ពកាល់គុត្តាពីមុន និងការបោះពុម្ពដែលប្រើសីលាលេខនៅបុំបៃសកសំវ័ត១៧៨០។ ការបោះពុម្ពក្រោយនេះ មានលក្ខណៈល្អប្រសើរជាងច្រើន ប៉ុន្តែដូចគ្នានឹងការបោះពុម្ពផ្សេងទៀតទាំងអស់ដែលខ្ញុំធ្លាប់បានឃើញ នៅតែមានចំណុចគួរឱ្យរិះគន់ច្រើន។ មានវគ្គជាច្រើននៅក្នុងអត្ថបទ ដែលមិនស្របគ្នានឹងការអធិប្បាយ។

នៅក្នុងមន្ទាថមុក្តាវលិ មានមន្ទាថកន្ទ្រិកា ដែលសរសេរដោយរាឃវានន្ទ សរស្វតី ជាឥសី នៅសាលាសំការាកាយ និងជាសិស្សរបស់វិស្វេស្វរ ភគវត្បាតមួយ។ ទោះបីអ្នកនិពន្ធអះអាងដូចបញ្ជាក់ខាងលើថា គាត់បានប្រើបទអត្ថាធិប្បាយពីមុនចំនួនបួនក៏ដោយ ក៏គាត់ភាគច្រើនប្រកាន់យកតាមទស្សនៈយោបល់របស់កុល្លូកដែរ។ ជាការកម្រគឺថា គាត់ចូលចិត្តការបកស្រាយរបស់នារាយណ ឬលើកនូវយោបល់របស់គោវិន្ទ និងមេធាទិថិ ដែលកុល្លូកធ្លាប់បានជំទាស់ ឬមិនយកចិត្តទុកដាក់។ ការអត្ថាធិប្បាយរបស់គាត់អំពីផ្នែកទស្សនវិជ្ជានៅក្នុងអត្ថបទ យ៉ាងណាមិញ មានលក្ខណៈឯករាជ្យបំផុត ហើយគាត់បកស្រាយចំណុចទាំងនោះ តាមរបៀបមួយស្របគ្នានឹងគោលលទ្ធិវេទន្តរបស់សាលាគាត់។ កន្ទ្រិកា វិចារណកថាបន្តបន្ទាប់ ដែលបកស្រាយគ្រប់ពាក្យរបស់មនុ ប៉ុន្តែក្រៅពីការសង្ខេបន័យទូទៅច្រើនតែផ្តោតលើពាក្យ និងឃ្លាពិបាកៗ។ ស្នាដៃនេះហាក់ដូចជាស្នាដៃទំនើប ដែលមានកាលបរិច្ឆេទ ពីសតវត្សទី១៦ ឬដើមសតវត្សទី១៧(បំណងរបស់លោក LoiseleurDeslongchamps(Lois deManon,ទំព័រxvi)ដើម្បីស្គាល់ឲ្យច្បាស់ឈ្មោះរាឃវិនន្ទ ជាមួយនឹង រាឃុនន្ទន ភត្តាកាយនៃសតវត្សទី១៦ ជាការស្មានទាំងខកចិត្ត។ សម្រាប់ខ្ញុំហាក់ដូចជាថាអ្នកនិពន្ធកន្ទ្រិកា គឺដូចគ្នាបេះបិទ នឹងឥសីរាឃវានន្ទ សិស្សគណរបស់អទ្វានន្ទ សិស្សរបស់វិស្វេស្វរ ដែលបណ្ឌិត F.E. Hall *សៀវភៅកាតាឡុក* ទំព័រ ៦, ៩១ថាជាអ្នកនិពន្ធផ្នែកសាំខ្យា និងទស្សនវិជ្ជាវេទន្ត។) ។ ខ្ញុំមិនបានឃើញពាក្យដកស្រង់ពីឈ្មោះនៅក្នុងគម្ពីរច្បាប់ដទៃទេ។ សំណេរដៃដ៏ល្បីល្បាញយ៉ាងចំណាស់ជាងគេ ជាស្នាដៃដែលអង្គេកេទិលបាននាំមកពីគុគរាត និងបានតម្កល់នៅបណ្ណាល័យជាតិនៅទីក្រុងប៉ារីស (Devanagad49, fonds d'Anquetil, លេខ ១៦)។ កាលបរិច្ឆេទរបស់វា សំវ័ត ១៧០៦ វសេ កាត្តិក ពទិ ១០ សោមទិនេត្រូវគ្នាតាមការគណនារបស់បណ្ឌិត Schram គឺថ្ងៃចន្ទ ទី២៩ ខែវិច្ឆិកា ឆ្នាំ១៦៤៩។ សំណេរដៃដ៏ចំណាស់មួយទៀតនិយាយពីកាលបរិច្ឆេទដូចគ្នា ត្រូវលោក Burnell បញ្ជាក់នៅក្នុងសៀវភៅកាតាឡុក Tanjore ទំព័រ ១២៦។ ចំពោះការអត្ថាធិប្បាយនេះ ខ្ញុំបានប្រើប្រាស់សំណៅប៉ារីស ដែលរដ្ឋាភិបាលបារាំងមានសមានចិត្តល្អ អនុញ្ញាតឱ្យខ្ញុំខ្ចី រហូតដល់គម្ពីរមនុជំពូក៩ លេខ១៨៧។ ស្នាដៃនេះ មានទាំងបទអត្ថាធិប្បាយនិងទាំងអត្ថបទដែលពីមុនមាននៅជំពូក១លេខ៤៥-៧៨។ចំពោះផ្នែកដទៃទៀតខ្ញុំបានពិគ្រោះសំណៅពីមុនៗ តែជាសំណៅដែលមានការខូចខាតច្រើននៃកម្រងរបស់មហាវិទ្យាល័យ ដេកង់ឆ្នាំ១៨៨២-១៨៨៣ ដែលសាស្ត្រាចារ្យ Bhandirkar បានបង្កើតឡើងសម្រាប់រដ្ឋាភិបាលក្រុងបុំបៃ។

យោងតាមសំណៅនេះ ឈ្មោះអត្ថាធិប្បាយទី៦ ជាសៀវភៅមទ្រ មនុវ្យាខ្យាន ដែលខ្ញុំបានសូមខ្ចី ពីឌីវាន ពហាឌុរ រាឃនាស្រៅ ប៉ុន្តែបើតាមបណ្ឌិត Burnell ថាជាសៀវភៅកាតាឡុក តាញ៉រ ទំព័រ ១២៦ វគ្គនន្ទិនី។ អ្នកនិពន្ធអត្ថបទនេះ ហៅខ្លួនឯងថា នន្ទន (នន្ទនាកាយ យោងតាមបណ្ឌិត Burnell) ជាកូនប្រុសរបស់លក្ស្មណៈ ជាសមាជិករបស់ភារទ្វាគគោត្រ និងមិត្តសម្លាញ់របស់វីរមល្ល ដ៏ល្បីល្បាញ(ព័ត៌មានអំពីការបោះពុម្ពជំពូកទី១២ សរសេរថា ...សំស្ក្រឹត....មានន័យថា វីរមល្ល ទំនងជាព្រះអង្គម្ចាស់ ឬអ្នកដឹកនាំ ហើយការនិយាយពីឈ្មោះទ្រង់ ជាយថាហេតុជួយបញ្ជាក់ពីសម័យកាលរបស់នន្ទន។ ផ្នែកទី៣នៃឈ្មោះក្រោយនេះមាននៅក្នុងការបោះពុម្ពមទ្រ នូវព្រឹត្តិបត្ររបស់ Colebrooke ទំព័រ xv ចុះលេខ ៦ ដែលអ្នកបោះពុម្ពអត្ថាធិប្បាយអំពីគម្ពីរមនុនន្ទនគ្ឫត (?) របស់នន្ទនរាគ។) ។ គ្រប់ទិដ្ឋភាពទាំងអស់បង្ហាញថា គាត់ជាអ្នកស្រុកដើមកំណើតឥណ្ឌានៅភាគខាងត្បូង។ ដោយសារហេតុថា ស្នាដៃរបស់គាត់ តាមដែលខ្ញុំដឹង មានតែនៅឥណ្ឌាភាគខាងត្បូងទេ សំណៅដៃនៅតំបន់នេះមានតែនៅសម័យក្រោមការដឹកនាំរបស់មទ្រ ហើយសាស្ត្រាចារ្យJolly (អត្ថបទដកស្រង់ ដដែលទំព័រ ១២) បានរកឃើញថា អំណានជាច្រើនរបស់គាត់ មានលក្ខណៈពិសេស ដូចគ្នានឹងការអានរបស់ ដែលមាននៅក្នុងសំណោរមនុស្រ្មិតិ ភាគខាងត្បូង។ តាមដែលខ្ញុំបានដឹង ឈ្មោះរបស់គាត់ មិនមាននៅក្នុងសេចក្តីអត្ថាធិប្បាយណាមួយ ឬស្នាដៃច្បាប់ណាមួយទេ។ មានន័យថា ស្នាដៃគាត់ស្ថិតក្នុងសម័យទំនើប ឬទស្សនៈយោបល់របស់គាត់ មិនបានទទួលការគោរពរាប់អានច្រើន។ ស្នាដៃរបស់លោក រាឃុនាស្រៅ ត្រូវចុះកាលបរិច្ឆេទ សកសំរែត ១៧២៤ មាឃ សុទិប្រតិប័ទ ឬ គ.ស.១៨០៣។ មនុវ្យាខ្យាន ជាអត្ថបទអត្ថាធិប្បាយបែបខ្លី ដែលភាគច្រើននិយាយដដែលៗ និងពន្យល់ពាក្យ ឬឃ្លាមួយចំនួនតូចនៅក្នុងអត្ថបទ។ អត្ថាធិប្បាយនេះបាត់កាព្យជាច្រើន ដែលចាំបាច់ទាមទារនូវការស្រាយបំភ្លឺ នៅត្រង់ពាក្យយ៉ាងខ្លី *ស្បស្តៈ* "ទទេ" និងរំលងផ្នែកផ្សេងទៀត ដោយគ្មានកំណត់សម្គាល់អ្វីសោះ។ សូម្បីតែគ្មានសម្រង់ឈ្មោះក៏ដោយ ក៏ការបកស្រាយភាគច្រើន បានប្រកាន់យកគោលការណ៍បន្ទយ៉ាងត្រឹមត្រូវផ្តើមពីអត្ថាធិប្បាយខាងដើម ដែលក្នុងនោះយើងអាចគិតយល់នូវបញ្ជីប្អូនដំបូង។ ក្នុងចំណោមនេះ តារាងបញ្ជីត្រឹមត្រូវបំផុត គឺមន្វាថវិវ្ទិតិ។ សេចក្តីអត្ថាធិប្បាយអត្ថបទបកប្រែនេះ បង្ហាញនូវករណីជាច្រើនដែល "នារនិងនន្ទ" បង្កើតក្រុមផ្សេងគ្នា និងនិយាយពីចំណុចសំខាន់គាំទ្រទស្សនៈ យោបល់ ដែលជំទាស់នឹងទស្សនៈរបស់មេធាទិថិ គោវិន្ទ និងកុល្លូក។ ប៉ុន្តែក៏មានសេចក្តីផ្សេងទៀត ពាក់ព័ន្ធនឹងការបង្ហាញចំណុចណា ដែលនន្ទនៈស្របគ្នានឹងទស្សនៈរបស់មេធាទិថិតែម្យ៉ាងក៏មាន ឬ ស្របនឹងទស្សនៈដទៃ ដែលមេធាទិថិបានដកស្រង់ក៏មាន ស្របនឹងទស្សនៈរបស់កុល្លូកក៏បាន ឬគោវិន្ទៈ ក៏បាន។ ទីបញ្ចប់ គាត់ធ្វើការរៀបរាប់ករណីជាច្រើន ដែលមិនអាចរកប្រភពនៅកន្លែងផ្សេង ហើយ សេចក្តីអធិប្បាយខ្លះ ជាពិសេសផ្នែកដែលនិយាយអំពីទស្សនវិជ្ជា គួរឲ្យយកចិត្តទុកដាក់។ អត្ថបទដែលនន្ទនៈរៀបរាប់តាមនោះ មិនខុសគ្នាតិចតួចពីសម្តីធម្មតាទេ។ អត្ថបទនេះ ក្រៅពីអត្ថបទជាច្រើនទៀត ជាអត្ថបទដ៏សំខាន់ ទោះមានការលុបបាត់ខ្លះ ការបន្ថែមខ្លះក្តី និងការបាត់ការលើកដាក់សំឡេងកាព្យទាំងមូលក៏ដោយ។ អត្ថបទជាច្រើនរបស់នន្ទនៈ មានប្រភពពីមេធាទិថិនារាយណ និងអ្នកនិពន្ធបុរាណផ្សេងៗទៀត ដែលយោងតាមប្រភពទាំងនោះ ឬយ៉ាងហោចណាស់ ក៏រៀបរាប់ពីអត្ថិភាពប្រភពទាំងនោះដែរ។ បើនិយាយពីអ្នកនិពន្ធដែលនន្ទនៈបានលើកឡើង ភាគច្រើន

ហាក់ដូចជាមានខ្វះខ្លះ ឬស្មានខ្លះ ហើយជួនកាលមានការខកចិត្តយ៉ាងខ្លាំង។ ការលើកដាក់សំឡេង ដែលមាននៅត្រង់វគ្គនានា ស្តីពីលំដាប់លំដោយ ដែលអ្នកអត្ថាធិប្បាយដទៃទៀតឯកភាពគ្នា ជួនកាលហាក់ដូចជាគ្មានប្រភពដែលគួរឱ្យទុកចិត្តជាងការស្មានរបស់នន្ទនៈទេ។ ដូចនេះ ប្រសិនបើគាត់ដាក់ មនុ ជំពូក១ លេខ ២៧ នៅក្រោយកាព្យ ១៩ និងជំពូក១០ លេខ១៤ ក្រោយកាព្យ ៦ ហើយបន្ថែមក្នុងកាព្យនីមួយៗថា "បើអ្នកខ្លះអានកាព្យនោះបន្ត គឺថា កាព្យនោះប្រាកដជាមានការភាន់ច្រឡំ របស់អ្នកចម្លងអត្ថបទ" ខ្ញុំអាចយល់បាននៅត្រង់សម្តីបញ្ជាក់ថា មានការប៉ិនប្រសប់ក្នុងការបន្ថែមលើអត្ថបទបុរាណ។ តាមខ្ញុំគិត កាព្យដែលនន្ទនៈបន្ថែមនោះ គឺជាការថែមថយទាំងស្រុង ក្នុងនោះការថែមថយខ្លះទំនងជាមានតាំងពីមុនមក ព្រោះវាមាននៅក្នុងសំណៅដៃនៅភាគខាងត្បូង និងសំណៅរបស់កាស្មៀរ។ បើនិយាយពីកន្លែងលុបបាត់ លោកនន្ទនៈជួនកាលយកតាមសំណៅរបស់អ្នកអត្ថាធិប្បាយណាមួយ ឬអ្នកអត្ថាធិប្បាយជាច្រើនទៀត។ ក្នុងករណីខ្លះទៀត លោកយកតាមសំណៅដៃរបស់ភាគខាងត្បូងប៉ុណ្ណោះ តែក្នុងករណីផ្សេងទៀត លោកប្រកាន់យកជំហរខ្លួនលោកតែម្តង។ ចំណុចលុបបាត់ប្រភេទចុងក្រោយ មនុជំពូក ៥ លេខ ៦១ ដូចបានគូសបញ្ជាក់នៅក្នុងកំណត់សម្គាល់រួចហើយ គឺដោយសារមានចន្លោះខ្វះខាតជាយថាហេតុនៅក្នុងសំណៅដៃ ដែលលោកនន្ទនៈបានប្រើប្រាស់។ បើនិយាយពីករណីជាច្រើនទៀត គួរឱ្យកត់សម្គាល់ថា សំណៅពីររបស់មនុវ្យាខ្យាន ដែលអ្នកប្រាជ្ញអឺរ៉ុបបានពិនិត្យពិច័យ គឺសំណៅរបស់លោក រាឃុនាស្រៅ និងបណ្ឌិត Burnell (ជំពូក ៨-៩ បច្ចុប្បន្នមាននៅក្នុងបណ្ណាល័យ ការិយាល័យឥណ្ឌា) មានលក្ខណៈខុសគ្នាយ៉ាងច្រើន។ ហេតុនេះ សំណៅរបស់បណ្ឌិត Burnell បាត់ជំពូកទី៨ នេះបើយោងតាមការផ្ទៀងផ្ទាត់របស់សាស្ត្រាចារ្យ Jolly កាព្យ ៨, ១១, ១៤, ៧៤, ៨១, ១០៣, ២២៧-២២៨, ២៣១, ៣៣២, ចំណែកឯសំណៅរបស់លោក រាឃុនា ស្រៅ មានកាព្យទាំង អស់នេះ លើកលែងតែកាព្យ ៨, ២២៨ និង ២៣១ ថែមទាំងបានអធិប្បាយអំពីជំពូក ២ លេខ ១៤, ៨១, ១០៣, ២២៧ផង។ ភាពខុសគ្នារវាងសំណៅទាំងពីរនេះ ហាក់ដូចជា ត្រូវផ្អែកលើការអានអត្ថបទគម្ពីរ មនុ និងទាមទារឱ្យមានការបកស្រាយផងដែរ។ យ៉ាងណាមិញ យើងមិនពិបាកនឹងផ្តល់យោបល់ដាក់លាក់អំពីចំណុចទាំងអស់នេះទេ ព្រោះថាសំណៅរបស់លោក រាឃុនា ស្រៅ ជួនកាលបង្ហាញតែប្រតីកៈ របស់កាព្យប៉ុណ្ណោះ ហើយជារឿយៗមានការកែប្រែច្រើន ដូចនេះ អត្ថន័យខ្លឹមសារអាចយល់បាន លុះត្រាតែមានការកែតម្រូវអក្ខរាវិរុទ្ធតាមការស្មាន។

យោងតាមព្រឹត្តិការណ៍ទាំងអស់នេះ ការផ្តោតខ្លាំងពេកតែទៅលើអត្ថបទត្រូវប្រែ ដែលបានពីមនុវ្យាខ្យាន ដោយគ្មានជំនួយពីប្រភពអត្ថាធិប្បាយដទៃទៀត នឹងមិនមានព័ត៌មានគ្រប់គ្រាន់ទេ។

ទីបណៈអនាមិក ឬកម្រងអត្ថាធិប្បាយពន្យល់តែម្យ៉ាងនៅក្នុងសំណេរលើសំបកឈើបីច(កម្រងរបស់មហាវិទ្យាល័យដេកង់ ឆ្នាំ១៨៧៦-១៨៧៧ លេខ ៣៥៥។) នៅកាស្មៀរ មានសារសំខាន់តិចតួចណាស់។ សំណេរនេះហាក់ដូចជាមានប្រភពដើម សបញ្ជាក់ដោយការអត្ថាធិប្បាយខ្លះៗពីសំណាក់បណ្ឌិត ដែលមានចំណេះដឹងខ្ពស់មួយចំនួន ដែលក្រោយមកពួកគេ បានចម្លងចេញជាអត្ថបទ ហើយបានដាក់នូវកាព្យដែលត្រូវយោង។ សាស្ត្រាចារ្យ Jolly(មេរៀនតាហ្គ័រ ទំព័រ១១) បានគូសបញ្ជាក់ថា ក្នុងករណីមួយសំ

ណោរនេះមានលក្ខណៈស្របគ្នានឹងគោវិន្ទរាគ និងម្យ៉ាងវិញទៀត តួយ៉ាងគេអាចបន្ថែមអត្ថាធិប្បាយអំពីគម្ពីរមនុជំពូក១ លេខ៥២បាន។ មានករណីខ្លះទៀត (សូមមើលឧ.ទា. ការបកស្រាយរបស់ឌីមភៈ មនុជំពូក៥ លេខ៩១) ដែលអត្ថាធិប្បាយរបស់កាស្មៀរ ត្រូវគ្នានឹងការបក ស្រាយដែលគួរឱ្យចង់ស្វែងយល់របស់នន្ទន(មើល ឧ.ទា. កំណត់សម្គាល់អំពីមនុជំពូក ១ លេខ ២; ជំពូក ៣ លេខ១៩, ៧៣, ១៩៥) ។ ប៉ុន្តែខ្ញុំយល់ថា ជាការប្រថុយប្រថានណាស់ចំពោះការ ធ្វើសេចក្ដីសន្និដ្ឋានអំពីប្រភពរបស់ *ទីបណៈ* ដោយផ្អែកលើឧទាហរណ៍ទាំងនេះ។ សំណៅរកាស្មៀរ ដែលត្រូវបានសរសេរ និងកែសម្រួលយ៉ាងផ្ចិតផ្ចង់នោះ ត្រូវខូចដាច់ដាចនៅផ្នែកខាងចុង អស់ប្រហែល មួយភាគបីនៅគ្រប់រាប់សិបទំព័រចុងក្រោយ។ ការដាច់បាត់មាននៅត្រង់ចំណុចមនុ ជំពូក១១ លេខ ២១៨ដល់ជំពូក១២ លេខ ១២៦។

មតិយោបល់ខាងលើស្ដីពីឯកសារដែលខ្ញុំបានលើកយកមកបង្ហាញ សូម្បីមានសារៈសំខាន់មិនអាចប្រកែកបានក៏ដោយ ក៏ឯកសារទាំងនោះមិនអាចមានការកែប្រែទាំងស្រុងក្នុងការអធិប្បាយអត្ថបទនៃគម្ពីរមនុទេ។ តាមការពិនិត្យអត្ថបទសំណៅដៃរបស់លោក កុល្លូក គឺជាសំណៅតែមួយដែលយើងអាចរកបានទាំងស្រុង និងជាសំណៅដ៏គួរឱ្យទុកចិត្តគ្រាន់បើ ខ្ញុំមិនអាចរកឯកសារផ្សេងក្រៅពីឯកសារនេះ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបកប្រែរបស់ខ្ញុំបាន។ ហេតុផលជាក់ស្ដែង ជាពិសេសក៏ជាការពិចារណា ដែលសាធារណជនឥណ្ឌា បានជាប់ចិត្តនឹងអត្ថបទរបស់កុល្លូក និងដែលសេចក្ដីសំអាងជាច្រើនក្នុងការបកប្រែគម្ពីរច្បាប់ហិណ្ឌូ ច្រើនដៅទៅរកគម្ពីរមនុរបស់កុល្លូក នេះជាការពិចារណាមួយដែលប្រកាន់យកគោលការណ៍ដែលមានការនិយមច្រើន។ ហេតុនេះខ្ញុំបានព្យាយាមរក្សាទុកកាព្យ ទាំងអស់ដែលកុល្លូកបានបកស្រាយ ទោះបីទម្ងន់នៃប្រភពនេះមិនគួរឱ្យទុកចិត្តទាំងស្រុងក៏ដោយ ហើយខ្ញុំបានរក្សាទុកនៅក្នុងអត្ថបទនេះ នូវកាព្យណាដែលលោកបានលុបចោល។ ក្នុងករណីខាងដើម ឈ្មោះរបស់អ្នកអធិប្បាយដែលមានយោបល់ផ្ទុយគ្នា ត្រូវបានលើកក្នុងសេចក្ដីអត្ថាធិប្បាយដែលការបកប្រែរបស់អ្នកអធិប្បាយដទៃទៀត នូវកំណាព្យបន្ថែមដែលគួរឱ្យជឿជាក់បំផុត និងមានសារៈសំខាន់ នឹងមានបង្ហាញជូន(ខ្ញុំអាចបន្ថែមបានថា ខ្ញុំមិនយកចិត្តទុកដាក់ចំពោះកាព្យ ដែលការនិពន្ធនាយុគសម័យកណ្ដាល ស្រង់ពាក្យថា *របស់មនុ* តែមិនអាចរកឃើញនៅក្នុងអត្ថបទពិនិត្យសំណៅដៃ ដែលមានការគាំទ្រពីអ្នកអធិប្បាយនានាទេ។ តាមយោបល់របស់ខ្ញុំកាព្យទាំងអស់នេះ សុទ្ធតែមិនត្រឹមត្រូវទេ។ ក្នុងករណីភាគច្រើន យើងត្រូវតែគិតគូរអំពីការស្រង់ពាក្យមិនត្រឹមត្រូវ ដែលកើត ឡើងដោយការធ្វេសប្រហែសរបស់និពន្ធការៈ ដែលមានភាពត្រឹមត្រូវ តិចដូចអ្នកនិពន្ធផ្នែកវិទ្យាសាស្ត្រផ្សេងៗរបស់ឥណ្ឌា ឬដូចអ្នកនិពន្ធសម័យកណ្ដាល ដែលផ្ដោតលើទស្សនវិជ្ជាបុរាណ។ ពួកគេបានដកស្រង់ភាគច្រើនតាមរយៈការចងចាំរបស់ខ្លួន ប្រសិនបើគ្មានជម្រើសផ្សេង។)។ ជាងនេះទៀត ខ្ញុំបានប្រកាន់យកតាមការរៀបចំកាព្យរបស់កុល្លូកៈ លើកលែង ក្នុងករណីខ្លះ ដែលកុល្លូកៈមានកំហុសជាក់ស្ដែង ហើយការលើកដាក់សំឡេងមិនបង្កឱ្យមានការលំបាកច្រើនទេ។ ម្យ៉ាងវិញទៀត ខ្ញុំបានព្យាយាមកុំឱ្យមានការភាន់ច្រឡំយ៉ាងច្បាស់លាស់ ក្នុងការអានអត្ថបទ ដែលភាគច្រើនមិនមែនកើតឡើងដោយសារកុល្លូកៈខ្លួនឯងទេ តែដោយសារអ្នកបោះពុម្ពអត្ថបទរបស់គាត់។ សេចក្ដីអធិប្បាយសបញ្ជាក់នូវអ្វី ដែលមានការកែប្រែនិងបង្ហាញពីប្រភពដ៏គួរទុកចិត្ត។ ទីបំផុតខ្ញុំបានបន្ថែមនូវជម្រើសសម្រាប់អត្ថបទអំណានសំខាន់ៗដែលមាននៅក្នុងបទអត្ថា ធិប្បាយដទៃទៀតដែរ។

បើនិយាយពីការបកប្រែនេះ របៀបពិចារណារបស់ខ្ញុំ មានលក្ខណៈខុសគ្នាបន្តិច។ ទោះបីខ្ញុំចង់យកលំនាំតាមអត្ថបទអត្ថាធិប្បាយរបស់កុល្លូកៈតែម្យ៉ាង និងបង្ហាញការបកប្រែរបស់អ្នកអធិប្បាយផ្សេងទៀតនៅក្នុងសេចក្ដីពន្យល់ក៏ដោយ ក៏ខ្ញុំយល់ថាមិនអាចទៅរួចទេ។ កម្រាស់សៀវភៅរបស់ខ្ញុំ នឹងមានទំហំធំ ហើយនៅក្នុងវគ្គជាច្រើន ខ្ញុំត្រូវតែបង្ខំចិត្តលើកយកការបកប្រែនោះមកដាក់ក្នុងអត្ថបទដែលនាំឱ្យមានការភាន់ច្រឡំជាក់ស្ដែង។ ដើម្បីជៀសផុតនូវបញ្ហាលំបាកទាំងអស់នេះ ជាទូទៅលើកលែងតែវគ្គណាដែលមានការសង្ស័យ ទើបខ្ញុំបកប្រែទៅតាមការពិពណ៌នាដែលសមហេតុផលបំផុតសម្រាប់រូបខ្ញុំ ហើយខ្ញុំបានលើកឡើងនូវការបកស្រាយនានាដែលគួរឱ្យកត់សម្គាល់ នៅក្នុងសេចក្ដីអធិប្បាយ។ នៅក្នុងកាព្យជាច្រើនដែលន័យពិតប្រាដកបរស់អត្ថបទមានមន្ទិលច្រើន ខ្ញុំមិនអាចទៅហួសពីការបកប្រែន័យត្រង់របស់ពាក្យក្នុងគម្ពីរមនុ ដែលហាក់ដូចជាច្បាប់ដើម គេអាចបកប្រែតាមរបៀបផ្សេងបាន។ ក្នុងករណីបែបនេះ ការអធិប្បាយបង្ហាញការបកប្រែនានាទាំងអស់ ដែលមាននៅក្នុងសេចក្ដីអត្ថាធិប្បាយ។ នៅក្នុងកាព្យមួយចំនួនតូច ការបកស្រាយរបស់អ្នកអត្ថាធិប្បាយ បានលើកហេតុផលសមគួរដែលមានរៀបរាប់ក្នុងអត្ថបទនេះ។ ការបកស្រាយរបស់ខ្ញុំមានទំហំខុសគ្នាច្រើន ដោយសារការចាប់អារម្មណ៍ ឬបញ្ហាលំបាកដែលមានក្នុងអត្ថបទ។ ដូចនេះ ការសង្ខេបទស្សនៈយោបល់របស់អ្នកអត្ថាធិប្បាយទាំងឡាយតាមចំណងជើងសំខាន់ៗ ជាក់ស្ដែងនៃច្បាប់ហិណ្ឌូគម្ពីរមនុជំពូក៩លេខ១-២១៩ មានលក្ខណៈពេញលេញតាមសំណៅដើម ដែលខ្ញុំអាចយល់ន័យបាន។ គោលទស្សនវិជ្ជាលំបាកៗស្ទើរតែទាំងអស់នៅជំពូក ១ និងជំពូក១២ ជាដើម មានការបកស្រាយយ៉ាងច្បាស់។ ក៏ប៉ុន្តែការស្រង់ពាក្យពីបទអត្ថាធិប្បាយនានាអំពីផ្នែកមុនៗ ដែលនិយាយអំពីករណីយកិច្ចរបស់សិស្សគណ មេគ្រួសារស្នាតកៈជាដើម គឺជាពាក្យស្រង់ខ្លីៗ ដើម្បីគ្រាន់តែជាការឈ្វេងយល់ ត្រឹមត្រូវនូវកាព្យជាច្រើន ត្រូវការបង្ហាញវគ្គស្របគ្នាខ្លះ ដែលមាននៅក្នុងស្ម្រិតិបុរាណដទៃទៀត។ ក្នុងចំណោមស្ម្រិតិផ្សេងៗនោះ មានបកប្រែក្នុងជំពូក ២, ៧ និង ១៤ នៃសៀវភៅភាគនេះ ត្រូវបានគេដកស្រង់នៅគ្រប់កន្លែង។ បើសិនជាគេមិនបានរាប់បញ្ចូលនារទៈ ហេតុផលគឺថា សៀវភៅបកប្រែថ្មី ដែលសាស្ត្រាចារ្យ Jolly នឹងបោះផ្សាយក្នុងពេលឆាប់ៗ នឹងធ្វើឱ្យការយោងនោះលែងមានប្រយោជន៍ នេះបើយោងតាមសម្ភារៈឯកសារ ដែលគេបានរកឃើញនៅពេលថ្មីៗ។ ការស្រង់សេចក្ដីពីសៀវភៅមនុ ដែលមាននៅក្នុងអត្ថបទបកប្រែច្បាប់ហិណ្ឌូ ត្រូវបានចងក្រងដាក់ក្នុងសេចក្ដីបន្ថែមនៅខាងចុងសៀវភៅ សម្រាប់ជួយសម្រួលដល់ការប្រើប្រាស់របស់អ្នកច្បាប់។ បើនិយាយពីទំនាក់ទំនងអត្ថបទបកប្រែរបស់ខ្ញុំជាមួយនឹងអត្ថបទរបស់អ្នកបកប្រែពីមុនៗ ខ្ញុំពិតជាជំពាក់គុណច្រើនចំពោះកំពូលស្នាដៃរបស់លោក Sir William Jones ដែលសូម្បីសិក្សាអំពីនិរុត្តិវិទ្យាសំស្ក្រឹត មានការរីកចម្រើនក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយនេះក្ដី ក៏នៅតែមានតម្លៃមហាសាលដដែល។ ខ្ញុំក៏ត្រូវមានកាតព្វកិច្ចធ្វើការបកប្រែភាសាអាល្លឺម៉ង់ នៅជំពូកទី៨ និងកាព្យ vv.១-១០២ នៃជំពូកទី៩ របស់សាស្ត្រាចារ្យ Jolly ដែលជាឯកសារបង្អែករបស់ខ្ញុំ។ បើគ្មានឯកសារយោង ដូចជាសៀវភៅបកប្រែ ដែលបោះផ្សាយថ្មីៗ ដោយបណ្ឌិត Burnell និង Hopkins នោះហេតុផលគឺថា ការបោះពុម្ពសៀវភៅរបស់ខ្ញុំ កើតឡើងមុនវត្តមានឯកសារនោះទៅទៀត។

ជាសេចក្តីសន្និដ្ឋាន ខ្ញុំពិតជាថ្លែងអំណរគុណចំពោះសហការីជាច្រើន ជាពិសេសចំពោះសាស្ត្រាចារ្យ Jolly និង Kielhorn ចំពោះការជួយបកប្រែសេចក្តីតាមរបៀបផ្សេងៗ ព្រមទាំងអរគុណចំពោះបណ្ឌិត R. Rost ប្រធានបណ្ណាល័យផ្នែកការិយាល័យឥណ្ឌា លោក K.M. Chatfield នាយកផ្នែកសិក្សាសាធារណៈ នៅបុំបៃ, ចំពោះនាយកបណ្ណាល័យជាតិរបស់បារាំង និងចំពោះឌីវាន បាហាឌុរ រាឃុណាថ រ៉ៅ នៅ Mylapur រដ្ឋ Madras ចំពោះការអនុញ្ញាតឱ្យខ្ចីសំណៅដៃដោយសេរី។

# ច្បាប់មនុ

⊛⊛⊛

## ជំពូក ១

១- មហាបណ្ឌិត បានចូលទៅជិតព្រះមនុ ដែលកំពុងអង្គុយដោយចិត្តមូល ហើយបន្ទាប់ពីបានសម្តែងគារវកិច្ចយ៉ាងសមគួរចំពោះព្រះអង្គ ព្រមទាំងបាននិយាយថា៖

២- "សូមបន្ទាបខ្លួនចុះ ព្រះអាទិទេព ដើម្បីថ្លែងឱ្យពួកយើងខ្ញុំបានជ្រាបច្បាស់ និងតាមលំដាប់លំដោយ នូវច្បាប់ពិសិដ្ឋសម្រាប់វណ្ណៈនីមួយៗ (វណ្ណៈសំខាន់ទាំងបួន) និងអំពីវណ្ណៈកណ្តាល។

៣- "ដើម្បីទ្រង់ ឱព្រះជាម្ចាស់ មានតែទ្រង់ទេយល់យ៉ាងច្បាស់បំផុតនូវទស្សនៈគំនិតទូទៅ (ពោលគឺ) ពិធីរីតិ៍ និងមានចំណេះដឹងអំពីព្រលឹងវិញ្ញាណ (ទូន្មាន) នូវបទប្បញ្ញត្តិទាំងអស់របស់ព្រះស្វយំភូ (ស្វយំភូ) ដែលគ្មាននរណាអាចដឹង និងអាចយល់ដល់ទីជម្រៅបាន។"

---

I. ១. កុល្ល. គិតថា ប្រតិបូគ្យ 'បន្ទាប់ពីបានគោរព' ក៏អាចមានន័យ 'បន្ទាប់ការគោរពគ្នាទៅវិញទៅមក' ហើយលោកភ្ជាប់ ផ្សេងពីយោបល់របស់អ្នកអត្ថាធិប្បាយដទៃ 'ដោយត្រឹមត្រូវ' ជាមួយនឹងពាក្យ 'បានថ្លែង'។ គោវ. នារ. រាឃ. និង ក. ព្រមទាំងសំណៅដៃនានា (លោក Loiseleur I ទំព័រ ៣១៣ និង Bikaner Cat. ទំព័រ ៤១៩) ចាប់ផ្តើមសំហិតា ដោយកាព្យដូចខាងក្រោម ដោយលុបពាក្យ មេធ. កុល្ល. និងនន្ទ. ថាៈ'បន្ទាប់ពីបានគោរពព្រាហ្មណ៍ស្វយំភូ' ដែលមានអំណាចគ្មានដែនកំណត់ ខ្ញុំសូមប្រកាសច្បាប់អមតៈទាំងឡាយ ដែលព្រះបានប្រកាសឲ្យប្រើ។'

២. បន្ទាប់ពីកាព្យនេះ លោកនន្ទ. បញ្ចូលថែមបួនបន្ទាត់ក្រោយ ដែលយើងឃើញមាននៅក្នុង កុល្ល. ថា: (ក) 'ដើមកំណើតសត្វលោកទាំងអស់ ដែលចាប់កំណើតក្នុងគភ៌ ដែលចាប់កំណើតក្នុងស៊ុត ដែលចាប់កំណើតញើស(exudations) និងដែលកើតពីពន្លកគ្រាប់ពូជ (germinating seeds) និងការវាសគ្រាប់ពូជ' (ខ) 'វិធានទំនៀមទម្លាប់ និងពិធីសាសនាទាំងអស់ ដែលត្រូវគោរព សំដៅរៀបរាប់ជាទូទៅ ស្របទៅតាមសម័យកាល និងភាពសមស្របរបស់វា។'

៣. 'បទប្បញ្ញត្តិរបស់ព្រះស្វយំភូ' ពោលគឺ 'គម្ពីរវេទ' (តាម កុល្ល. នារ. និងរាឃ.) ឬ 'វេទ ឬវិធានបញ្ញត្តិ (វិធិ) មាននៅក្នុង វេទ' (មេធ.) ឬ 'គោលការណ៍' (គោវ.)។ អកិន្ត្យ 'ដែលគេមិនអាចដឹងបាន' ពោលគឺ 'វិសាលភាព ដែលគេមិនអាចដឹងបាន' (កុល្ល. និងរាឃ.) ឬ 'ដែលគេមិនអាចដឹងបាន និយាយអំពីជម្រៅចំណេះដឹង' (គោវ.) ឬ 'អត្ថន័យ ដែលគេមិនអាចដឹងបាន ដោយការឱ្យហេតុផល' (នារ.) ឬ 'ដែលមិនអាចយល់ន័យបាន' (មេធ.) ឬ 'ពិបាកយល់' (នន្ទ.)។ *អប្រមេយ* 'ដែលមិនអាចមើលយល់បាន' ពោលគឺ 'ដែលមិនអាចយល់បាន ដោយគ្មានជំនួយពីមីមាំសា និងវិធីផ្តល់ហេតុផលដទៃទៀត' (តាម កុល្ល.) ឬ 'ដែលមិនអាចមើលយល់បាន តាមវិសាលភាពរបស់វា' (គោវ., នន្ទ.) ឬ 'ដែលមិនអាចមើលយល់បាន តាមវិសាលភាពរបស់វា ឬ ដែលមិនអាចយល់បានដោយផ្ទាល់ តែគេត្រូវយល់ថាជាមូលដ្ឋាននៃស្មិតិ' (មេធ.) ឬ ដែលពិបាកយល់' (រាឃ.)។ កុល្ល. និង រាឃ. បកស្រាយពន្យល់ កាយតត្វាថ តាម 'គំនិតទូទៅ ពោលគឺជា ពិធីសាសនា និងធម្មជាតិព្រលឹងវិញ្ញាណ;' មេធ. គោវ. និងនន្ទ. តាម 'សេចក្តីពិត គឺ រីតិ៍។' នន្ទ. ចាត់ទុកពាក្យ *សាវស្យ* 'ទាំងមូល' ហាក់ដូចផ្អែកលើ 'បទប្បញ្ញត្តិ' ហើយតាមន័យ 'ដែលបានបញ្ញត្តិអំពីសត្វលោកទាំងអស់។'

តាមសេចក្តីអធិប្បាយកាព្យ ១១ លោកមេធ. នៅតែផ្តល់ការបកស្រាយកាព្យនេះ ក្នុងន័យម្យ៉ាង ស្របទៅតាមអ្វីដែលគេអាចបកប្រែថាៈ'សម្រាប់ទ្រង់ ឱ ព្រះម្ចាស់ថ្លៃអើយ មានតែទ្រង់ទេ យល់ដឹងបំផុតអំពីធម្មជាតិ និងកម្មវត្ថុនៃផលិតផល ដែលកើតមាននៅក្នុងចក្រវាឡនេះ ដែលគ្មាននរណាអាចគិតដល់ជម្រៅនៃភាពអស្ចារ្យរបស់វា និងដែលគ្មាននរណាអាចយល់បានទេ។' កាព្យនេះ ជារបស់អ្នកអធិប្បាយ 'ផ្សេង' ដែលបកស្រាយអំពីការបង្កើតទាំងស្រុង ដោយផ្អែកលើគោលការណ៍សំខាន់របស់ព្រះមនុ ដ៏បរិសុទ្ធ។

៤- ព្រះអង្គ ដែលមានអំណាចគ្មានដែនកំណត់ ដោយហេតុថាត្រូវបានចោទសួរពីមហាបណ្ឌិតដែលមានឧត្តមគតិខ្ពង់ខ្ពស់ បានផ្តល់កិត្តិយសដ៏សមគួរដល់ពួកបណ្ឌិត ហើយបានឆ្លើយថា ‘ចូរស្តាប់ចុះ’។

៥- (ចក្រវាឡ) នេះស្ថិតក្នុងស្រមោលអន្ធការ ខ្វះការយល់ដឹង គ្មានសញ្ញាវែកញែក មិនអាចចាក់ធ្លុះដោយការឱ្យហេតុផល ដែលមិនអាចចេះដឹងបាន ដែលលិចលង់ទាំងស្រុង ដូចជានៅក្នុងដំណេកយ៉ាងលង់លក់។

៦- ពេលនោះ ព្រះអាទិពេទកើតឯង (ស្វយំភូ ព្រះអង្គឯង) ដែលគេមិនអាចមើលឃើញ (តែ)ធ្វើឲ្យ (អ្វីទាំងអស់)នេះ ក្លាយជាកម្លាំងធម្មជាតិដ៏មហិមា និងអ្វីៗផ្សេងទៀត ដែលគេអាចមើលឃើញ បានស្តែងឡើងនូវអំណាច(បង្កើត)ដោយគ្មាននរណាមួយអាចរារាំងបាន ដោយកម្ចាត់បង់នូវភាពងងឹតអន្ធការ។

---

៥. ការជំណាលពីការរៀបរាប់អំពីការបង្កើត ដែលមាននៅក្នុងកាព្យ ៥-១៣ មាន ដូចសម្តីរបស់បណ្ឌិត Muir (អត្ថបទសំស្ក្រឹត សៀវភៅលេខ៤ ទំព័រ ២៦) ភាពដូចគ្នាខ្លះនឹងការរៀបរាប់ ដែលមាននៅក្នុងវគ្គមួយចំនួននៃសតបថព្រាហ្មណ៍ ជាពិសេសសៀវភៅលេខ ១១ កាព្យ ១, ៦, ១ បន្តបន្ទាប់ ហើយទំនងជាមាននៅក្នុងស្នាដៃវេទមួយចំនួនថា ‘ដោយលាយឡំនឹងគោលលទ្ធិទំនើបៗកាន់តែច្រើន’។ តាមការបកស្រាយការប្រើពាក្យកាព្យ ៥ លោកមេធ. និងកុល្លូ. សំដៅដល់វគ្គ ដូចជាសៀវភៅ ឫគ. Rv. ភាគ ១០, កាព្យលេខ ១២៩, ៣ និង សៀវភៅតៃតិរីយ-ព្រាហ្មណ៍ ភាគ ២ កាព្យលេខ ៨, ៩, ៤។ សាយណៈ ក៏ស្រង់កាព្យនេះ ដាក់ក្នុងអភិប្រាយរបស់គាត់នៅវគ្គបន្ទាប់។

អ្នកអធិប្បាយ មេធ. និងគោវ. បកស្រាយការពិតថា ព្រះមនុ ដោយមានការស្នើសុំ បរិយាយច្បាប់ ធ្វើការរៀបរាប់អំពីការបង្កើត តាមរយៈការសន្មតថា ទ្រង់មានបំណងចង់បង្ហាញនូវស្នាដៃដែលមានវិសាលភាពដ៏ធំធេងមួយ និងសារសំខាន់នៃការសិក្សា ដោយហេតុថា ការបង្កើតសត្វលោកផ្សេងៗ អាស្រ័យលើគុណធម៌ និងបាបធម៌។ ផ្ទុយទៅវិញ លោកកុល្លូ. ព្យាយាមបង្ហាញការពិតថា ការជំណាលអំពីការបង្កើត ដែលសឱ្យឃើញពីចំណេះដឹងនៃព្រលឹងវិញ្ញាណដ៏កំពូល គឺជាផ្នែកមួយនៃច្បាប់ពិសិដ្ឋ ហើយហេតុនេះទំនងអាចរកឃើញនៅនេះ។ អ្នកអធិប្បាយទាំងអស់ លើកលែងតែលោក រាឃ. បកស្រាយពាក្យ *តមះ* ‘ភាពងងឹត’ ដោយ ‘ដែលមានឫសជាអនិច្ចំ’ ដែលបកស្រាយលម្អិតអំពីសុភាសិតរបស់ព្រះមនុ តាមន័យរបស់សាលាវេទន្ត មានន័យស្មើនឹងអវិជ្ជា ‘ភាពល្ងង់ខ្លៅ’។ ការបកស្រាយពាក្យគុណនាមទាំងបួន ដែលបង្ហាញតាមពាក្យផ្សេងគ្នា នូវភាពមិនអាចយល់បានពាក្យ *មូលប្រក្រតិ* មានការអធិប្បាយផ្សេងគ្នា៦ បែប។ ហេតុផលសមទំនងបំផុត ទំនងជាយោបល់របស់កុល្លូកៈ ដែលសន្មតថា ពាក្យបួននេះ សំដៅដល់ភាពមិនអាចមានចំណេះដឹងយល់ *ប្រក្រតិ* តាមន័យបី ខាងក្រោម សៀវភៅលេខ ១២ កាព្យ ១០៥ និង ‘ដោយការឱ្យហេតុផល’ (តកៈ)។ គាត់ពន្យល់ពាក្យ *អប្រញាតៈ* ‘ដែលមិនអាចយល់បាន’ ដោយ ‘ដែលមិនអាចដឹងន័យបាន’; ពាក្យ *អលក្សណៈ* ‘ដែលខ្វះសញ្ញា’ ដោយ ‘ដែលមិនអាច ពិចារណាបាន’; *អវិញ្ញេយ* ‘ដែលមិនអាចយល់ដឹងបាន’ ដោយ ‘ដែលមិនអាចកំណត់ន័យ ដោយពាក្យ ឫសម្តីគួរឱ្យជឿជាក់ បាន’។

៦. ការបកប្រែខាងលើ យកលំនាំតាមលោកគោវ. នារ. និងកុល្លូ.។ អ្នកអភិប្រាយបីនាក់ផ្សេងទៀត ប្រើមហាភូតាទិវ្រិតៅគាស ជាសណ្តានពាក្យសមាស។ តាមការសន្មតនេះ ការបកប្រែមានលំនាំដូចតទៅ៖ ‘ពេលនោះ ព្រះស្វយំភូ (ព្រះអង្គខ្លួនទ្រង់) ដែលគេមិនអាចមើលឃើញបាន (តែ) ធ្វើឱ្យគេអាចមើលឃើញ (ចក្រវាឡ) នេះបានបានស្តែងឡើងថា អំណាច (បង្កើត)របស់ព្រះអង្គ’ បង្កើតកម្លាំងធម្មជាតិដ៏អស្ចារ្យ និងអ្វីៗទាំងអស់ ហើយព្រះអង្គកម្ចាត់បង់ភាពងងឹត។’

‘ពេលនោះ’ ពោលគឺនៅចុងសម័យកាលហិនហោច។ អវ្យក្តៈ ‘(ខ្លួនឯង) ដែលមិនអាចមើលឃើញ’ ពោលគឺ ‘ដែលគេមិនអាចចេះ លើកលែងតែពួកយោគិន’ (តាមលោក មេធ.) ឬ ‘ដែលមិនអាចយល់បានដោយន័យខាងក្រៅ’ (គោវ., កុល្លូ., នារ.) ឬ ‘ដែលគេមិនអាចដឹង លើកលែងតាមឯកសារឧបនិស័ទ’ (រាឃ.) ឬ ‘ដែលពិបាកយល់ដឹង’ (នន្ទ.)។ លោក មេធ.

ចូលចិត្តអានអវ្យក្តំ ‘(ចក្រវាឡ័) ដែលគេមិនអាចមើលឃើញនេះ’។ ‘កម្លាំងធម្មជាតិដ៏អស្ចារ្យ និងអ្វីៗទាំងអស់’ ពោលគឺ ‘គោលការណ៍ដទៃទៀត មហាគោលសីលធម៌ជាដើម’ (មេធ., គោវ., នារ., កុល្ល., នន្ទ.) ឬ ‘គោលការណ៍អត្តទត្តភាព’ (រាឃ.)។ ‘បានស្តែងឡើង’ ពោលគឺ ‘សន្មតជាតួអង្គ ដែលមានឆន្ទៈសេរីផ្ទាល់ខ្លួន មិនចំណុះឱ្យកម្មរបស់ខ្លួន គឺអំពើរបស់ទ្រង់ ស្ថិតក្នុងអត្ថិភាពពីមុន’ (មេធ., គោវ., នន្ទ.) ឬ ‘ប្រែជាអាចវិនិច្ឆ័យបាន’ (វ្យក្តៈ) (នារ.) ឬ ‘ដែលត្រៀមបង្កើតឡើងស្រេច’ (កាយោន្មុខ) (តាមរាឃ.)។ លោកគោវ. បកស្រាយពាក្យ *វ្រត្តៅគាស* ‘ដោយមានអំណាច ដែលគ្មាននរណាអាចរារាំងបាន’ ដោយ ‘ដែលទទួលបាននូវអំណាច’ (ប្រាប្តំ បលំ យេន)។ លោកកុល្ល. បកស្រាយ *តមោនុទខ* ថា ‘ដោយកម្ចាត់បង់នូវភាពងងឹត(ពោលគឺដោយធ្វើឱ្យវិនាស)’ ដោយ ‘ដែលផ្តល់នូវកម្លាំងចិត្ត ឱ្យមានការវិវត្តពីខាងក្នុង’ ហើយលោករាឃ. បកស្រាយតាមរបៀបស្រដៀងគ្នានេះដែរ។

អ្នកអធិប្បាយដែលលោកមេធ. លើតួយ៉ាងយោបល់នៅក្នុងកាព្យ ១១ បានបកស្រាយកាព្យនេះ ជាការពណ៌នាអំពីការ វិវត្តដោយខ្លួនឯង ដែល *ប្រក្ឫតិ* សម្តែងទៅតាមសាំខ្យៈ។ ពួកគេបានចាត់ទុក *ស្វយំភូ* ថា ‘ការកើតឯង’ ក្នុងន័យ ‘ដែលប្រែប្រួលតាមចិត្តចង់របស់ខ្លួនផ្ទាល់;’ ‘អាទិទេព’ក្នុងន័យថា មានអំណាចពេញលេញដើម្បីបំពេញកិច្ចការរបស់ខ្លួន’ (ស្វវ្យាបារៈ ឥស្វរៈ)។ ការពិត ពាក្យផ្សេងទៀតមិនមានការលំបាកខ្លាំងទេ។

៧. ‘ដោយប្រើសព្វនាមពីរ អស់លោក “ទ្រង់ដែល” គាត់ប្រាប់អំពីព្រលឹងវិញ្ញាណដ៏កំពូល ដែលចេះដឹងលោកទាំងមូល នៅក្នុងគម្ពីរវេទ ច្បាប់បុរាណ ឥតិហាសៈ ជាដើម’(កុល្ល. ស្របគ្នានឹងមេធ.)។ សព្វនាមខាងក្រោយ មានបំណងក្រៅពីការ បកស្រាយអំពីអតិន្ទ្រិយគ្រាហ្យៈ ‘ដែលគេអាចដឹងបាន ដោយសារសរីរាង្គខាងក្នុង (ឬចិត្តតែម្យ៉ាងប៉ុណ្ណោះ’ ដែលគោវ., កុល្ល. និង នន្ទ. ចូលចិត្តប្រើពាក្យមួយទៀត ‘ដែលហួសពីការដឹងរបស់ញាណ ដែលគេមិនអាចដឹងដោយចំណេះដឹងយោគៈ តែមួយទេ’។ នារ. និងរាឃ. ក៏យល់ផ្សេងពីការបកប្រែខាងលើ។ ‘ដែលល្អិតសុខុម’ ពោលគឺ ‘ដែលហួសពីសញ្ញាសំគាល់ ទាំងអស់ ដូចជាតូច និងធំ’ (មេធ.) ឬ ‘ដែលគេមិនអាចដឹងបានដោយញាណខាងក្រៅ’ (កុល្ល.) ឬ ‘ដែលគេអាចដឹងបាន ដោយការយល់ដ៏ល្អិតសុខុមប៉ុណ្ណោះ’ (គោវ.) ឬ ‘ដែលគ្មានអវយវៈ ឬគ្រឿងគ្រៅ’ (រាឃ.)។ នន្ទ. បញ្ជាក់ដោយប្រើវិសេស ស័ព្ទទូទៅ *កំពូលព្រលឹងវិញ្ញាណ* ‘តូចជាងល្អិត’ (កាថ. ឧប. ភាគ២ លេខ ២០; ភគវទគីតា ភាគ៨ លេខ៩)។ អវ្យក្តៈ ‘ដែលមិនអាចយល់ដឹងបាន’ ត្រូវបានកុល្ល. បកប្រែដើម្បីសំដៅដល់ ‘ដែលខ្វះនូវអវយវៈ ឬផ្នែកនានា’។ សាវ៌ភូតមយៈ ‘ដែលមានសត្វលោកទាំងអស់’ យោងតាមមេធ. មានន័យផងដែរថា ‘ដែលទ្រង់យល់នូវចិត្តគំនិតរបស់សត្វលោកទាំងអស់’ ឬ ‘ដែលស្របគ្នានឹង *អទ្វៃត វេទន្ត* សត្វលោកទាំងអស់ ជាការកែប្រែឡើងដោយបំភ័ន្តរបស់ព្រះអង្គ’។ មតិចុងខាងក្រោយនេះ ទំនងជាមតិមួយ ដែលមានការឯកភាពជាច្រើនពីសំណាក់អ្នកនិពន្ធផ្សេងៗ។ ‘ដែលបញ្ចេញពន្លឺ’ ពោល ‘ដែលសន្មតថា ជាតួកាយដែលគេអាចមើលឃើញ’ក៏បាន ឬ ‘ដែលមានពន្លឺដោយឯកឯង’ (តាមមេធ.) ‘ដែលសន្មតជាតួកាយ’ (គោវ.) ‘ដែលស្តែងឡើងនូវទម្រង់ប្រែរូបផ្សេងៗ ជារូបដ៏មហិមាជាដើម’(កុល្ល.)ឬ ‘ដែលហាក់ដូចជាអាចមើលឃើញ’ (នន្ទ.)។

---

៧- ព្រះអង្គ ដែលគេអាចដឹងបានតាមរយៈសរីរាង្គខាងក្នុង(ប៉ុណ្ណោះ) ដែលល្អិតសុខុម ដែលគេមិន អាចមើលឃើញ និង អមតៈ ដែលមានគ្រប់លក្ខណៈសត្វលោកទាំងអស់ ហើយដែលគេមិនអាច យល់បាន បានស្តែងឡើងនូវ (ឆន្ទៈ)ផ្ទាល់របស់ទ្រង់។

៨- ព្រះអង្គ ដោយមានបំណងបង្កើតសត្វលោកជាច្រើនប្រភេទចេញពីរូបកាយរបស់ព្រះអង្គផ្ទាល់ ដំបូងមានព្រះហឫទ័យបង្កើតទឹក ហើយបានដាក់ពូជបោះទៅក្នុងទឹកទៅ។

៩- (ពូជ)នោះ បានក្លាយជាស៊ុតមាស មានពន្លឺចែងចាំងបីដូចព្រះអាទិត្យ ហើយនៅក្នុង(ស៊ុត)នោះ ព្រះអង្គខ្លួនឯង បានកើតជាព្រហ្ម ជាបុព្វបុរសនៃពិភពលោកទាំងមូល។

១០-ទឹកនោះ ត្រូវគេហៅថា *នារៈ* (ពីព្រោះ) តាមពិត ទឹកជាកូនរបស់ព្រះនារៈ ដោយហេតុថា ទឹកជានិវេសនដ្ឋានទីមួយរបស់ទ្រង់(អយនៈ)ចាប់ពីពេលនោះគេហៅព្រះនាមព្រះអង្គថា ព្រះនារាយណ៍

១១- ផ្តើមពីដើមហេតុ (ទី១) ដែលគេមើលមិនឃើញ អមតៈ ទាំងពិត ទាំងមិនពិត ត្រូវបានបង្កើត *បុរសៈ*(បុរស)នោះ ដែលមានកិត្តិនាមល្បីនៅក្នុងលោកនេះ(យោងតាមការហៅឈ្មោះព្រហ្មន)។

---

៧. ក្រៅពីនោះ វគ្គនានាដែលដកស្រង់តាមកាព្យ ៥ ប្រៀបធៀបរឿង *ប៉ៅរាណិក* ស្តីពីស៊ុតលោកី របស់លោក Wilson *វិស្ណុបុរាណ* ខ្សែទី ១ ទំព័រ ៣៩-៤០ (បោះពុម្ពដោយ Hall)។ ពាក្យ 'ព្រះអង្គ' គឺយោងតាមលោក មេធ. និងរាឃ.។ ពាក្យ 'ហិរណ្យគាភៈ' យោងតាមអ្នកអធិប្បាយផ្សេងទៀត គឺស្មើនឹង 'កំពូលព្រលឹងវិញ្ញាណ'។ លោក មេធ. សំអាងទៅលើគម្ពីរឫគវេទ ខ្សែទី១០ លេខ១២១, ១។ យោងតាមមេធ. (កាព្យ១១) អ្នកដែលបានយល់នូវសេចក្តីទាំងស្រុង អាស្រ័យលើប្រក្ឫតិ ដែលគ្មានប្រាជ្ញា បានបកស្រាយអភិធ្យាយ 'ដោយមានគំនិតមួយ' ដើម្បីចង្អុលប្រាប់ 'ដែលឯករាជ្យពីអំពើខាងក្រៅទាំងអស់ ហាក់ដូចជាមនុស្សធ្វើអំពើមួយ តាមគំនិតមួយប៉ុណ្ណោះ។' ពួកគេក៏បានអះអាងថា ទឹកត្រូវបានបង្កើតឡើងជាកម្លាំងធម្មជាតិ ទី១ ប៉ុន្តែមិនមែនជាកំពូលធម្មជាតិ និងគោលការណ៍ដទៃទេ។ ផ្ទុយទៅវិញ កុល្ល. យល់សំនួនវោហារដែលប្រើក្នុងកាព្យនេះ ជាទឡ្ហីករណ៍បង្ហាញថា មនុជាអ្នកអនុវត្តវេទន្តដែលមិនមែនជាទ្វិនិយម។

៩. លោកមេធ., កុល្ល និងរាឃវៈ ប្រើវិសេសស័ព្ទ 'ពណ៌មាស' ក្នុងន័យធៀប ហើយមានគំនិតចង់បង្ហាញន័យនៃគំនិតស្តីពីភាពបរិសុទ្ធ ដូចលោករាឃ. ក៏ចង់សំដៅដល់ភាពភ្លឺថ្លាខាងបញ្ញា។ ជំនួសឱ្យឃ្លា 'ព្រះអង្គខ្លួនឯង បានកើតជាព្រហ្មន (ភេទបុំលិង្គ)' ការបកប្រែអាចនិយាយថា 'ព្រះព្រហ្ម បានកើតដោយឯកឯង'។ លោក មេធ. ផ្តល់ការបកស្រាយទាំងពីរនេះ។ អ្នកអធិប្បាយផ្សេងទៀតទទួលយកន័យ ដែលមាននៅក្នុងអត្ថបទនោះ។ ជាទូទៅ សត្វលោកដែលត្រូវបង្កើត គឺសំដៅដល់អ្វីៗទាំងអស់ វៀលែងតែលោក រាឃ., ហិរណ្យគាភៈ។ រាឃ. ក្នុងនាមជាវេទន្តិនដ៏ហ្មត់ចត់មួយរូប គិតថា វាគឺជា *វិរាត*។ អ្នកអធិប្បាយទាំងអស់ គូសបញ្ជាក់ថា ពាក្យ *បិតាមហៈ* 'បុព្វបុរស' ក្នុងន័យត្រង់គឺ ជីដូនជីតា ជាឈ្មោះទូទៅរបស់ព្រះព្រហ្មន (បុំលិង្គ)។

១០. ការបកស្រាយលេងពាក្យចំពោះឈ្មោះនារាយណ៍របស់ព្រះព្រហ្ម មានភាគច្រើននៅក្នុងគម្ពីរបុរាណ សូមមើលលោក Wilson *វិស្ណុបុរាណ* ខ្សែទី១ ទំព័រ៥៦ (បោះពុម្ពដោយ Hall)។ ទាំងលោកមេធ. ទាំងលោកគោវ. ហាក់ដូចជាអាន *អាបោ នារៈ* 'ទឹកត្រូវគេហៅថា *នារៈ*' ។ នារៈ គឺជាឈ្មោះមួយទៀតរបស់កំពូលអាត្មន។

១១. អ្នកអធិប្បាយទាំងអស់ វៀលែងតែលោក រាឃ. ដែលមានការបកស្រាយខុសឆ្ងាយ សុទ្ធតែយល់ថា 'ដើមហេតុ (ទី១)' ជាកំពូលអាត្មន។ សទសទាត្មកៈ 'ដែលទាំងពិត ទាំងមិនពិត' យោងតាមលោកមេធ. គោវ. និងកុល្ល.ថា 'ដែលមានអត្ថិភាព ឬពិត ពីព្រោះគេអាចស្គាល់ព្រះអង្គតាមរយៈគម្ពីរវេទ និងវេទន្ត តែគ្មានអត្ថិភាព ឬមិនពិត តាមធាតុពិត ដោយហេតុថា គេមិនអាចយល់ដឹងពីព្រះអង្គតាមរយៈញាណបានទេ'។ ការបកស្រាយរបស់លោក នន្ទ. ថា 'ដែលទាំងពិតមានបច្ច័យគ្រប់គ្រាន់ និងទាំងមិនពិត ជាផល ជារូប និងជាអ្វីៗទាំងអស់' យ៉ាងណាក៏ដោយ ហាក់ដូចជាការបកស្រាយសមទំនង មានការនិយមចូលចិត្តច្រើន។ គាត់និយាយថា *ស័ទ ឥតិការណំ អស័ទ ឥតិ ប្រក្ឫតិត្យាទិ កាយំ* ។ បើនិយាយពីពាក្យក្នុងគម្ពីរវេទបុរាណ ពាក្យ *បុរសៈ* គឺ 'ប្រុស' ឬ 'ព្រលឹង' សូមមើល Miur, *អត្ថបទសំស្ក្រឹត* ភាគ ៥ ទំព័រ ៣៦៧-៣៧៧។

១២- ព្រះអាទិទេព បានអាស្រ័យនៅក្នុងស៊ុតនោះ ក្នុងអំឡុងមួយឆ្នាំពេញ បន្ទាប់មកព្រះអង្គ ដោយព្រះហឫទ័យផ្ទាល់របស់ទ្រង់ (តែម្យ៉ាង) បានចែកព្រះកាយទ្រង់ជាពីរកំណាត់;

១៣- ហើយក្រៅពីពីរកំណាត់នោះ ព្រះអង្គបានបង្កើតឋានសួគ៌និងឋាននរក នៅចន្លោះឋានទាំងពីរ មានឋានកណ្ដាល មានជើងមេឃទិសប្រាំបី និងមានកន្លែងអាស្រ័យជាអមតៈនៅក្នុងទឹក។

១៤- ផ្ដើមចេញពីព្រះអង្គផ្ទាល់ (អាត្ម័នៈ) ព្រះអង្គក៏បានបញ្ចេញព្រះហឫទ័យ ដែលមានទាំងពិត និងមិនពិត ហាក់ដូចជាចេញពីតួចិត្ត ដែលមានមុខងារដឹងដោយខ្លួនឯង (ហើយគឺ)ជាព្រះជាម្ចាស់;

១៥- លើសពីនេះ កំពូលញាណ ព្រលឹងវិញ្ញាណនិង(ផល)ទាំងអស់ ត្រូវមានលក្ខណៈសម្បត្តិបី ហើយតាមលំដាប់នៃលក្ខណៈសម្បត្តិនោះ មានអវយវៈប្រាំ ដែលមានគ្រឿងវិញ្ញាណ។

---

១២. លោកកុល្ល. បកស្រាយពាក្យ 'ក្នុងមួយឆ្នាំ' គឺសំដៅ 'មួយឆ្នាំរបស់ព្រហ្ម'។ ប៉ុន្តែលោកមេធ. និងគោវ. ដែលនិយាយថា មួយឆ្នាំមនុស្ស គឺស្របទៅតាមគម្ពីរ *សតបថ-ព្រាហ្មណ៍* ភាគ៩ លេខ ១, ៦, ២។

១៣. លេខ '៨' បានពីការថែមទិសតូចបួន,'ទិសកណ្ដាល' គឺទិសឦសាន និងទិសអាគ្នេយ៍ ជាដើម។

១៤-១៥. អ្នកអធិប្បាយ ផ្ដល់ការបកស្រាយពីរផ្សេងគ្នាទាំងស្រុងចំពោះកាព្យដ៏ពិបាកទាំងពីរនេះ។ យោងតាមលោក មេធ., គោវ., កុល្ល. និងរាឃ. ពួកគេរៀបរាប់អំពីការបង្កើត *តត្វៈ* គោលការណ៍នៃប្រព័ន្ធសំខ្យៈ គោលការណ៍បីដំបូង ដែលគេបានដាក់តាមលំដាប់ប្រាស់ គឺមហ៍ត អហំការៈ និងមនៈ។ ថ្វីបើគម្ពីរមនុ ចែងច្បាស់ (នៅកាព្យលេខ ១៤)ថា អ្នកបង្កើតបានបង្កើតនូវមនៈ (ដែលមនៈ គឺសំដៅដល់អវយវៈខាងក្នុង) ចេញពីអាត្ម័ន (ពោលគឺយោងតាមមេធ. និងគោវ. ចេញពី 'ប្រធានៈ' ដែលជារូបផ្ទាល់របស់ទ្រង់ [តត្រូជានាទ អត្ម័នៈ ស្វស្វារូបាត, លោកមេធ.] ឬយោងតាមគោវ., កុល្ល. និង រាឃ. គឺ 'ចេញពីបរមាត្ម័ន' ជាកំពូលអាត្ម័ន ឬយោងតាមការបកស្រាយម្យ៉ាងទៀតរបស់លោករាឃ. 'ចេញពីព្រះអង្គផ្ទាល់' [ស្វស្មាត/គីវស្យ ភោគាចំ វា])ថា ទ្រង់បានបង្កើត *អហំការៈ* ចិត្តសួនតួ ចេញពី *មនៈ* ហើយថា បន្ទាប់មក ទ្រង់បានបង្កើតមហាន្តំ អាត្មានំ 'មហាអាត្ម័ន ដួងព្រលឹង' (ពោលគឺ យោងតាមលោកមេធ. ពាក្យ *មហ៍ត* ដែលហៅថាព្រលឹង ព្រោះហាក់ដូចជាព្រលឹង ដែលមាននៅក្នុងរាង្គកាយទាំងអស់ ឬយោងតាមលោក កុល្ល. មហ៍ត ដែលហៅថាព្រលឹង ដោយសារវាកើតចេញពីព្រលឹង ឬមានប្រយោជន៍សម្រាប់ព្រលឹង) យ៉ាងណាមិញពួកគេគិតថា គេពិតជាយល់ថា មហ៍ត ត្រូវបានបង្កើតឡើងដំបូងក្លាយជា*អហំការៈ* និងបន្ទាប់មកចេញពី អហំការ ក្លាយជា *មនៈ*។ ពាក្យបន្ទាប់ សាវាណិ ត្រិគុណានិ 'ផលទាំងអស់ ដែលប្រែប្រួលដោយសារលក្ខណៈសម្បត្តិបីយ៉ាង' ពួកគេសំដៅដល់ផលទាំងអស់ ឬខ្សែបន្ទាត់ ហើយត្រូវគេហៅឈ្មោះនេះចាប់ពីពេលនេះទៅ។ ហេតុនេះ ពួកគេត្រូវលុបពាក្យ *កៈ* 'និង' នៅចុងកាព្យលេខ ១៥a ហើយលោករាឃ. បញ្ជាក់ច្បាស់ថា ពាក្យ *កៈ* នៅចំណុចនោះ ប្រាប់ពីការបញ្ជាក់បន្ថែមទៅលើពាក្យខាងដើម (កការោ វធារណាថៈ)។ ចុងក្រោយលោកគោវ. កុល្ល. និងរាឃ. មានមតិថា ពាក្យ *កៈ* ទីបី 'និង' នៅចុងកាព្យ ១៥b សបញ្ជាក់ថា សរីរាង្គធ្វើចលនា និងកម្លាំងធម្មជាតិដ៏ប្រពៃ ត្រូវបានគេបន្ថែម ស្របតាមគោលការណ៍សំខ្យៈ រីឯលោកមេធ. យល់ថា មានន័យសម្រាប់តែកម្លាំងធម្មជាតិដ៏ប្រពៃម្យ៉ាងប៉ុណ្ណោះ។ លោកនន្ទ. ហើយដើម្បីវិនិច្ឆ័យតាមផ្នែកនៃបទអត្ថាធិប្បាយរបស់គាត់ នារ. ក៏ផ្ដល់ការបកស្រាយមួយផ្សេងគ្នាប្រឡះ។ យោងតាមយោបល់របស់ពួកគាត់ មនៈ ដែលត្រូវបានបង្កើតឡើងដំបូង ជាឈ្មោះមួយទៀត សម្រាប់គោលការណ៍ដែលជា ទូទៅហៅថា មហ៍ត។ តាមសក្ខីកម្មនៃអំណះអំណាងនេះ នន្ទ.លើកតួយ៉ាងសេចក្ដីមួយមកបញ្ជាក់ ចេញមកពីគម្ពីរបុរាណ ដែលលោកមេធ. ស្រង់ពាក្យកាព្យលេខ ៧៤ ដែលគេចាត់ទុកពាក្យ *មនៈ* ជាវេវចនស័ព្ទនឹងពាក្យមហ៍ត (សូមមើល Cowell *សាវធាសនៈ សំគ្រាហៈ* ទំព័រ ២២២ កំណត់សម្គាល់ ១)។ ពួកគេបន្តចាត់ទុក មហាន្តំ អាត្មានំ ជា 'មហាអាត្ម័ន ដួងព្រលឹង' ដើម្បីបញ្ជាក់ពីមនៈ ឬសរីរាង្គខាងក្នុង [មហាន្តំ]*កៈ* មនោ នាម តត្វំ អាត្មានំ អាត្មានោ គីវស្យាវគ្គេទកត្វាទ វ្យបទេសៈ, លោករាឃ.)។ តាមសំនួនវោហារ *សាំណិ ត្រិគុណិនិ* លោក នន្ទ. ហាក់ដូចជាយល់ថាជាកម្លាំងធម្មជាតិដ៏ល្អិតសុខុម (តន្មា

១៦- ប៉ុន្តែដោយផ្សំនឹងចុណ្ណភាគទាំង ៦ ដែលមានអំណាចឥតព្រំដែន ដោយចុណ្ណភាគរបស់ទ្រង់ផ្ទាល់ ព្រះអង្គបានបង្កើតសត្វលោកទាំងអស់។

១៧- ដោយសារចុណ្ណភាគតូចល្អិតទាំង ៦(ប្រភេទ) ដែលបង្កើតជាទម្រង់ (របស់អ្នកបង្កើត) កើតជា (អា-ស្រិ) (សត្វលោក)ទាំងអស់នេះ ហេតុនេះពួកបណ្ឌិតហៅទម្រង់របស់ព្រះអង្គថា *សរីរៈ* (រូបកាយ)។

---

ត្រា) ហើយលោកក៏មានជំនឿថា ពាក្យ *ក:* នៅចុងកាព្យ ១៥៦ បង្ហាញថាជាសរីរាង្គមានចលនា។ កម្មវត្ថុនៃកាព្យទាំងពីរ យោងតាមលោកនន្ទ. គឺមិនបានរៀបរាប់តាមលំដាប់ដាក់ស្តែងនៃការបង្កើតសត្វលោកទេ តែចង់បង្ហាញថា បច្ច័យសម្ភារៈសម្រាប់ការកើតសត្វលោកទាំងអស់ មានចំណែកចេញពីរូបកាយរបស់អ្នកបង្កើត របស់មហ័ត, អហំការៈ, មនៈ, តន្មាត្រា និងគ្រឿងវិញ្ញាណ និងសកម្មភាព (កម្ម) ដែលពាក់ព័ន្ធនឹងវា (អនេន ស្លោកទ្វយេនៃត័ទ ឧតំ ភវតិ / អាត្មី យានំ មហាទ ហំការមនត្តន្មាត្រញានកមេអត្រិយាណាំ អាំសះ សវភូតោបាទានំ ឥតិ //)។ ហាក់ដូចជាថា យោបល់របស់លោកនន្ទ. និង នារ. តាមការបកស្រាយអំពីពាក្យមនៈ (កាព្យ ១៤) គឺត្រឹមត្រូវ ប៉ុន្តែគេអាចសង្ស័យ យោងតាមពាក្យនៅក្នុងកាព្យ ១៥ *មហាន អាត្មា* និង *សវាណិ ត្រិគុណានិ* ថាតើពួកគេមានសំណាងល្អដូចគ្នាឬទេ។ ការបកស្រាយរបស់អ្នកអធិប្បាយបួន នាក់ដំបូងហាក់ដូចជាមិនត្រូវទាំងស្រុងទេ។ ជាការសន្និដ្ឋាន អាចបញ្ជាក់បានថា លោកនន្ទ. ក៏ផ្តល់ការបកស្រាយ ដែលអាចទទួលយក បានបំផុតអំពីវិសេសស័ព្ទ *មនៈ, ទសទាត្មកំ* ដែលគាត់និយាយសំដៅដល់ 'ដែលហាក់ដូចជាធម្មជាតិមានចលនា និងការវិវត្ត' (ប្រកួតិវិក្វត្យាត្មកំ) និង *ឥស្វរ* 'ព្រះជាម្ចាស់' 'ដែលញ៉ាំងឱ្យអ្វីៗមានចលនា' (សវកាមប្រវតកំ)។

១៦. ការបកប្រែតាមលំនាំលោក នន្ទ., រាឃ, និងវិញ្ញាណាភិក្សុ (*សាំខ្យសារ:* ទំព័រ ១៩ បោះពុម្ពដោយ Hall) ដែលឯកភាពថា កាព្យនេះ និយាយពីរូបកាយដ៏ប្រណិត ឬជារៀមច្បងរបស់សត្វលោកនីមួយៗ ដែលកើតចេញពីព្រះកាយដ៏ល្អិតសុខុមរបស់អ្នកបង្កើត និងព្រលឹងនីមួយៗ ដែលចេញពីវិញ្ញាណរបស់ទ្រង់។ ពួកគេពន្យល់ *អាត្មមាត្រាសុ* ដោយន័យថា អបរិក្ខិន្នស្បៃកស្យាត្មីន ឧបាធិវាស័ទ អវយវៃតៃប្រតីយមានេសុ អាត្មសុ (លោករាឃ.), ស្វគីវាំសេសុ (លោកនន្ទ.) និង ស្វាំសកេតនេសុ (លោកវិញ្ញ.)។ ក៏ប៉ុន្តែពួកគេយល់ផ្សេងគ្នាចំពោះន័យនៃ 'ចុណ្ណភាគទាំង ៦'។ អង្គធាតុតូចល្អិត 'ទាំង ៦' យោងតាមលោករាឃ. និងវិញ្ញ. ជា 'ញាណ ៦' ពោលគឺ គ្រឿងវិញ្ញាណ ៥ និងចិត្ត ១ (ដែលមានទំនាក់ទំនងគ្នា បង្ហាញរូបកាយដ៏ប្រពៃទាំងស្រុងតាមលោកវិញ្ញ.) ហើយយោងតាមលោកនន្ទ. ថា ក្រុម *តត្វៈ* ចំនួន ៦ ដែលគាត់មានជំនឿ មានបង្ហាញនៅក្នុងកាព្យពីរខាងដើម មានទី១ មហាត្មន ទី២ អញ្ញ ទី៣ ចិត្ត ទី៤ កម្លាំងធម្មជាតិដ៏ប្រណិត ឬជារៀមច្បង ទី៥-៦ គ្រឿងវិញ្ញាណ និងអំពើ។

ម្យ៉ាងទៀត លោកមេធ., គោវ. និងកុល្ល. គិតថាកាព្យនេះ 'ដោយផ្សំនឹងចុណ្ណភាគតូចៗទាំង ៦ (ដូចជាចិត្តអញនិយម និងកម្លាំងធម្មជាតិដ៏ប្រណិត៥) ដែលមានអំណាចគ្មានដែនកំណត់ ជាមួយនឹងចុណ្ណភាគនៃធាតុ (ប្រែប្រួល) ដូចគ្នា (ពោលគឺវិវឌ្ឍចេញពីធាតុ ៦ដូចគ្នា [តាមគោវ., កុល្ល.] ជាធាតុគ្រោតគ្រាត ដែលកើតចេញពី *តន្មាត្រា* និងសរីរាង្គដែលកើតចេញពីចិត្តអញនិយម[តាមលោកមេធ.]) ទ្រង់បានកំណត់រូបរាងសត្វលោកទាំងអស់'។ ហាក់ដូចជាថា ការបកស្រាយរបស់នន្ទ. ត្រូវនឹងការពិតច្រើន យ៉ាងណាមិញដូចបានបញ្ជាក់ខាងលើ ដោយបង្ហាញថា ចុណ្ណភាគ ៦ ឬប្រភេទធាតុផ្សំ មាននិយាយនៅក្នុងកាព្យខាងដើម មិនមែនជាការគួរឱ្យពេញចិត្តទាំងស្រុងទេ។ ក៏ប៉ុន្តែនៅគ្រប់ព្រឹត្តិការណ៍ទាំងអស់ គាត់បានយល់ថា សំនួនពាក្យ 'ទាំង ៦នោះ' ប្រាកដជាសំដៅដល់ការរៀបរាប់នៅក្នុងកាព្យពីរខាងដើមស្រាប់។

១៧. ការបកប្រែនេះ ជាថ្មីម្តងទៀត យកលំនាំតាម នន្ទ. ដែលលោកនារ. ហាក់ដូចជាបានឯកភាពតាមដែរ។ គាត់និយាយ 'ដោយសារចុណ្ណភាគទាំង ៦(ប្រភេទ) នៃរូបរបស់ទ្រង់ ពោលគឺធាតុផ្សំ៦ របស់រាងកាយព្រះព្រហ្ម ដែលបានបញ្ជាក់ខាងលើ មហ័ត និងអ្វីៗទាំងអស់ គឺមានទាំងអស់នេះ ជាសត្វលោកទាំងអស់ដែលមាននៅក្នុងកាព្យខាងដើមនិយាយពីចំនួនោះ ជា (ស្រយណាត) ពួកគេហៅរូបកាយរបស់ព្រះព្រហ្មនោះ ថា សរីរៈ។ អត្ថន័យគឺថា កាយរបស់ហិរណ្យគាគៈ ត្រូវគេហៅសរីរៈ ពីព្រោះវាមាន (ស្រយតិ)ក្នុងសត្វលោកទាំងអស់ តាមផ្នែករបស់កាយ ដែលជាបច្ច័យរូប(របស់វា) ក៏ប៉ុន្តែវាមិនត្រូវបានបំផ្លាញ (សីរ្យតេ) ដូចកាយរបស់មនុស្សធម្មតាទេ។' ដូចនេះ លោកនន្ទ. គិតថា ការបកស្រាយលេងពាក្យ ចំពោះពាក្យ *សរីរៈ* ចេញពីពាក្យ *ស័ទ អាស្រិ* ឬ *ស្រិ* ត្រូវគេដាក់តាមលំដាប់ ដើម្បីបង្ហាញថា និរុត្តិសាស្ត្រ(ដើមកំណើត

ពាក្យ)ផ្សេងទៀត ដែលមានប្រភពចេញពី *ស្រី* 'ដើម្បីវិនាស' មិនអាចអនុវត្តបានសម្រាប់កាយរបស់ ព្រហ្មន់ ទេ។ លោកមេធ. គោវ. និងកុល្ល. យល់កាព្យនេះខុសពីគ្នាឆ្ងាយណាស់។ ពួកគេឯកភាពគ្នា ដោយសន្មតថា កាយ ត្រូវហៅ *សរីរៈ* ពីព្រោះ ធាតុផ្សំ ៦ ដូចបានរៀបរាប់ ផ្សំផ្គុំ ឬបង្កើតបានកម្លាំងធម្មជាតិ និងសរីរាង្គទាំងមូលឡើង។ លោកមេធ. អាន *តានីមនិ* សម្រាប់ពាក្យ *តស្យេមានិ* ហើយបើតាមការបកស្រាយរបស់គាត់ ពាក្យប្រែប្រាកដជា 'ដោយសារចុណ្ណភាគតូចៗ ៦ (ប្រភេទ) សម្រាប់បង្កើតរូបកាយ ផ្សំផ្គុំគ្នា (ដែលក្លាយជាបច្ច័យ) ឬបង្កើតបានទាំងនេះ (ពោលគឺ ដោយសារមានអញ សរីរាង្គ ដែលបាននិយាយពីមុន និងធាតុផ្សំដ៏សុខុម ផ្សំបានជាធាតុពេញលេញ ដែលអាចនិយាយពីចំណុចនេះទៅ) ហេតុនេះ ពួកបណ្ឌិតហៅកាយ ដែលមានទម្រង់មើលឃើញនឹងភ្នែក(ប្រធាន)នោះ ជាសរីរៈ។' លោកកុល្ល. ដែលអាន *តស្យៈ* ខុសពីការ ការបកប្រែនេះ តែក្នុងករណីថា គាត់ប្រើពាក្យ *តស្យៈ* សំដៅដល់ព្រហ្មន់។ លោករាឃ. ចុងក្រោយគេ យោងតាមការបកស្រាយរបស់គាត់អំពីពាក្យ 'ទាំង ៦នោះ' ផ្តល់ន័យថា 'ដោយសារចុណ្ណភាគដ៏ប្រណិត ៦ ដែលបង្កើតជាទម្រង់ដ៏តូចល្អិតនោះ (ហិរណ្យគាភៈ ពោលគឺចិត្ត និងអ្វីៗទៀត) ផ្សំបានជានេះ (រូបកាយទាំងមូល តាមប្រាថ្នា) ហេតុនេះ ពួកបណ្ឌិតហៅទម្រង់ដែលមើលឃើញនោះ (រូបនៃព្រលឹងនីមួយៗ) ថា *សរីរៈ*។' ដូច្នេះ គាត់យល់ស្រប តាមលោក មេធ., គោវ. និងកុល្ល. ថា គាត់ក៏ឱ្យន័យកាព្យនោះថា កាយទូទៅដែរ។

១៨- នោះធាតុសំខាន់ៗ ផ្សំផ្គុំតាមមុខងាររបស់វានិងចិត្ត តាមផ្នែកតូចរបស់វា ជាអ្នកបង្កើតទម្រង់ រូបសត្វលោកទាំងអស់ ជាធាតុមិនវិនាស។

១៩- ប៉ុន្តែផ្តើមចេញពីកាយ (ដែលផ្គុំ)ចុណ្ណភាគនៃ*បុរសៈ* ដ៏មានឥទ្ធិពលទាំងប្រាំពីរនេះ កើតឡើងនូវ(លោកិយ)នេះ ជារបស់វិនាស ដែលកើតចេញពីអ្វីដែលមិនវិនាស។

---

១៨. អ្នកអធិប្បាយ ធ្វើការបកប្រែកាព្យនេះ ផ្សេងគ្នា ៥បែប គឺ ១-លោកមេធ.ថា 'នោះ (ពោល *ប្រធាន* គឺ) អ្នកបង្កើតសត្វលោកទាំងអស់ និងអ្វីដែលមិនវិនាស ពីព្រោះទាំងនេះ (ដូចជា)ធាតុផ្សំទាំងអស់ ដែលមានមុខងាររបស់វា (ហើយនៅមុខពួកវា) ចិត្ត ដែលមានចុណ្ណភាគល្អិតសុខុមរបស់វា (ពោល ធាតុសុខុម ជាបញ្ញា ចិត្តសួនតួ និងសរីរាង្គ) ផ្សំផ្គុំគ្នា' ២-លោកគោវ. និងកុល្ល. ថា 'ផ្តើមពីនោះ (ពោលគឺ ព្រហ្មន់ ដែលមានទម្រង់ធាតុផ្សំប្រណិត និងមានចិត្តអាត្មា និយម ត្រូវបានបង្កើតជាធាតុទាំងមូលរួមទាំងមានមុខងាររបស់វា និងចិត្ត ដែលជាអ្នកបង្កើតសត្វលោកទាំងអស់ តាមផ្នែកតូចៗរបស់វា(ដែលមិនវិនាស) (ពោលគឺផលរបស់វា គំនិតល្អ និងអាក្រក់ ការសប្បាយនិងការឈឺចាប់ជាដើម ជាលោកិយដែលកើតចេញពីអំពើល្អ និងអំពើអាក្រក់ ដែលមានប្រភពនៅក្នុងចិត្ត) និងធាតុដែលមិនវិនាស។' ៣-លោករាឃ. ថា 'នោះ (ពោលគឺតួកាយទាំងមូល) ធាតុទាំងមូលផ្សំផ្គុំ (ជាអ្នកបង្កើត [ឬបង្កើត]) និងចិត្តដែលជាអ្នកតាក់តែងសត្វលោកទាំងអស់ និងមិនវិនាស រួមទាំងមានអំពើ (ពោលគឺ អំពើកុសលជាដើម) និងមាន (សរីរាង្គសំខាន់ៗ) អវយវៈដៃជើង។' ៤-លោកនន្ទ. ថា '(ហេតុថា) នោះ (កាយរបស់ហិរណ្យគាភៈ) សូម្បីតាមផ្នែកតូចៗនៃកាយនេះ ក៏វាបង្កើតបានសត្វលោកទាំងអស់ តែមិនវិនាស (ទោះដូច្នេះក្តី) លក្ខណៈធម្មជាតិដ៏មហិមា (ចិត្តប្រកាន់ ចិត្ត ត្រិគុណៈ ធាតុវេទនា និងសង្ខារ) និងចិត្ត (គឺ ប្រភពចម្បង ហៅថាដួងអាត្ម័ន) ដែលមានសង្ខារ (ពោលជាវិញ្ញាណមួយ) ផ្សំផ្គុំជាមួយគ្នា។' ៥-ការបកស្រាយរបស់លោកនារ. ត្រូវបានថែមថយខ្លះ តែហាក់ដូចជាមានន័យថា 'នោះ (ពោលគឺកាយដ៏ល្អិត) ជាតុផ្សំទាំងមូល (ដែលបង្កើតកាយទាំងមូល) ផ្គុំជាមួយ *កម៌ន* (គឺកុសល និងអកុសល) និងចិត្ត (ដែលជា)អ្នកបង្កើតសត្វលោកទាំងអស់ និងមិនវិនាសរួមជាមួយនឹង (មុខងាររបស់វា ចំណេះដឹង ចំណង់ ទោសៈ ជាដើម ដែលតាមធាតុពិតរបស់វា គឺ)ផ្នែកតូចៗ។'

សម្រាប់ខ្ញុំ ហាក់ដូចជាថា គ្មានការបកស្រាយណាមួយក្នុងចំណោមការបកស្រាយទាំងឡាយខាងលើ អាចទទួលយកបានទាំងស្រុងនោះទេ។ ខ្ញុំយល់ស្របតាមលោកនារ. ក្នុងការគិតថា ពាក្យ '**នោះ**' សំដៅដល់កាយដ៏ល្អិត និងថា កាព្យរៀបរាប់អំពីដើមកំណើតនៃកាយទាំងមូល ដោយសារការផ្សំផ្គុំគ្នាកម្លាំងធម្មជាតតិ ពោលគឺជាធាតុសំខាន់ៗ និងមនៈ ជាមួយនឹងកាយដ៏ល្អិតៗ។ ប្រសិនបើ*មហាន្តិ ភូតានិ* ជាធាតុមហាភូតរូប យ៉ាងណាមិញយើងចាំបាច់ត្រូវយល់បានតាមរយៈ *កម្មភិះ* 'មុខងាររបស់វា' ដែលតាមសម្តីរបស់លោកមេធ. និងកុល្ល. គឺ 'មុខងារ ដែលទ្រទ្រង់ធាតុដី ដែលវិវត្តទៅបែកធ្លាយ ឬបង្កើត

ជាភ្លើង ជាដើម។' ដោយពាក្យ *មនៈ* ខ្ញុំយល់នៅទីនេះ សំដៅដល់សរីរាង្គខាងក្នុង ដែលបង្កើតចំណងទំនាក់ទំនងរវាងញាណទាំងមូល ឬកាយទាំងមូល ហើយវិញ្ញាណនីមួយៗ ដូច្នេះហើយគេអាចនិយាយពីការបង្កើតទម្រង់ ឬចេញគំរូសម្រាប់សត្វលោកទាំងអស់។ ព្រោះថាលក្ខណៈធម្មជាតិរបស់វា ជាបរមាណូ។ ការភ្ជាប់ *អវយវៃ សូក្សៃ* ជាមួយនឹង *សវេកូតក្ខូត* និងការចាត់ទុកជាអវយវៈ ក៏បានតាមការស្នើរបស់លោកកុល្ល. គឺជាការចាំបាច់ ឬអាចសន្មតថា ធាតុថាមពល ចិត្តជាច្រើន ត្រូវបានសំអាង ស្របតាមករណីបុគ្គលនីមួយៗ។

១៩. ចំពោះការបកស្រាយសំនួនវោហារ 'បុរុសៈ ៧' អ្នកអធិប្បាយនិយាយច្រើនត្រឹម '៦' នៅក្នុងកាព្យ ១៦។ លោកមេធ., គោវ. និងកុល្ល. ថែម 'ដួងព្រលឹង' ឬមហ័ត ទៅលើការរៀបរាប់ពីមុនៗ 'អត្តទត្តភាព និងធាតុដ៏ប្រណិត ៥' ចំណែកឯលោកនារ. និងនន្ទ. បន្ថែម 'ចំណែកនៃអាត្ម័ន' (កាព្យ ១៦) ទៅលើធាតុទាំងអស់ ដែលពួកគាត់យល់ថា មាន '៦'។ចំណុចនេះទំនងជាការកំណត់ន័យរបស់លោករាឃ. ដែលនិយាយ *បុរុសាណំ មនអាទិបុរុសាន្តានំ សប្តានាំ* 'របស់បុរុស ពោលគឺ នៃធាតុ ៧ ដែលក្នុងនោះទីមួយ គឺចិត្ត ហើយចុងក្រោយគឺ បុរុស។' អ្នកអធិប្បាយទាំងអស់ យល់ស្របថា ពាក្យបុរុស 'បុរសឬព្រលឹង' ត្រូវប្រកាន់នូវគោលការណ៍តាមន័យធៀប ប៉ុន្តែពួកគេផ្តល់ហេតុផលផ្សេងចំពោះការពិតថា 'ដោយសារវាគឺ ដើមព្រលឹង' បុរុស (តាមមេធ.) ឬ 'ដោយសារវាត្រូវបានកើតឡើងដោយបុរុស ជាអាត្ម័ន' (តាមកុល្ល.)។ លោកនារ. យល់ថាពាក្យ 'និង' ជាអវ្យយាត ហើយនិយាយថា 'និងដែលចេញពីធាតុមិនវិនាស ពោលគឺចេញពីប្រក្ឫតិ។' 'ធាតុវិនាស' តាមពិតសំដៅដល់ 'កាយទាំងមូល'។

២០- ក្នុងចំណោមធាតុទាំងឡាយ (ធាតុ)សម្រេចនីមួយៗ មានលក្ខណៈសម្បត្តិពីធាតុដើម ហើយកន្លែងណាក៏ដោយ ដែល(តាមលំដាប់)ធាតុនីមួយៗស្ថិតនៅ វាត្រូវតែមានលក្ខណៈសម្បត្តិជាច្រើនដែរ។

២១- ប៉ុន្តែក្នុងការចាប់ផ្តើម ព្រះអង្គបានកំណត់ឈ្មោះ អំពើនិងលក្ខខណ្ឌជាច្រើនសម្រាប់(សត្វលោកដែលត្រូវបង្កើត)ទាំងអស់ ថែមទាំងស្របទៅតាមពាក្យវេទ។

---

២០. កាព្យនេះ ប្រាប់អំពីគោលលទ្ធិថា ធាតុទី១ អាកាស (អាកាសៈ) មានលក្ខណៈសម្បត្តិមួយ ពេញលេញទាំងស្រុង, បន្ទាប់ ធាតុទី២ ខ្យល់ មានភាពពេញលេញ និងជាក់ស្តែង, ទី៣ ធាតុភ្លើង ឬពន្លឺ ជាធាតុទី៣ជាដើម ហើយសូមមើល *សាំខ្យសារៈ* ទំព័រ ១៨ ផង។ លោកនន្ទ. ដាក់កាព្យ ២៧ មុនកាព្យនេះ ហើយអះអាងថា 'ប្រសិនបើគេអានកាព្យ ៧ល្បះក្រោយនេះជាបន្តបន្ទាប់ នោះគេពិតជារកឃើញការភាន់ច្រឡំរបស់អ្នកវាយអត្ថបទ'។ សូម្បីកាព្យ ២០ និង ២៧ មិនស៊ីសង្វាក់គ្នាជាមួយនឹងអ្វីដែលមានខាងដើមនិងបន្ទាប់ទេ ខ្ញុំគិតថា យើងមិនអាចទទួលយកសំណើរបស់នន្ទ. ដែលខ្ញុំបារម្ភនោះ គ្មានអ្វីសំអាងសោះ ប៉ុន្តែជាការកាត់ស្មានមួយដ៏ឆ្លាតវៃចំពោះប្រភពគួរឱ្យជឿជាក់ពីសំណាក់អ្នកអធិប្បាយដទៃទៀតទាំងអស់។ ប្រសិនបើអាចប្តូរទីតាំងកាព្យនោះបាន ខ្ញុំសូមស្នើឱ្យដាក់កាព្យ ២៧ នៅចំណុចនេះ ហើយដាក់កាព្យ(២០)នេះ នៅក្រោយកាព្យ ៧៨ វិញ។

២២- ទ្រង់ ព្រះជាម្ចាស់ ក៏បានបង្កើតថ្នាក់របស់ទេពតា ដែលបានទទួលនូវជីវិត និងដែលមានលក្ខណៈធម្មជាតិរបស់ខ្លួន ជាសង្ខារ ជាថ្នាក់ដ៏សុខុម គឺ *សាធ្យៈ* និងធ្វើពិធីបូជាយញ្ញជានិច្ច។

២៣- ប៉ុន្តែផ្តើមចេញពីភ្លើង ខ្យល់ និងព្រះអាទិត្យ ព្រះអង្គបានបង្កើតគម្ពីរវេទដ៏អមតៈ ៣ គឺ ឫគវេទ, យគុវេទ, និងសាមវេទ សម្រាប់ការប្រតិបត្តិយញ្ញឱ្យបានត្រឹមត្រូវ។

២៤- ពេលនិងការចែកពេល, វិមានព្រះចន្ទនិងផ្កាយព្រះគ្រោះទាំងឡាយ, ទន្លេ សមុទ្រ ភ្នំ ដីវាលរាបនិងដីរដិបរដុប

២៥- ការប្រតិបត្តិតឹង ការនិយាយ ចំណង់ និងកំហឹង ព្រះអង្គទំនងជាបានបង្កើតរឿងទាំងអស់នេះឡើង ដោយសារព្រះអង្គចង់ឱ្យសត្វលោកទាំងអស់មានអត្ថិភាព។

២៦- លើសពីនេះ ដើម្បីញែកអំពើទាំងឡាយឱ្យដាច់ពីគ្នា ព្រះអង្គបានញែកកុសល ដាច់ពីអកុសល ហើយព្រះអង្គបានញ៉ាំងឱ្យសត្វលោក ត្រូវទទួលរងនូវអំពើទាំងពីរ (បដិបក្ខនឹងគ្នា) ដូចជាការឈឺចាប់ និងសេចក្ដីរីករាយជាដើម។

២៧- ប៉ុន្តែជាមួយនឹងចុណ្ណភាគដ៏តូចដែលវិនាសនៃ(ធាតុ)ទាំង ៥ ដូចបានជម្រាបជូនហើយ (ពិភពលោក)ទាំងមូលនេះ ត្រូវមានរូបរាង តាមលក្ខខណ្ឌត្រឹមត្រូវ។

---

២២. អ្នកអធិប្បាយនានា យល់ផ្សេងគ្នាច្រើនចំពោះការបកស្រាយកាព្យនេះ។ លោកមេធ. ស្នើ 'ហើយព្រះជាម្ចាស់ បានបង្កើត (ឡើងនូវ) មនុស្ស ដែលត្រូវធ្វើពិធីបូជាយញ្ញ (ដ៏ច្រើន)របស់ទេពតា ជាថ្នាក់ដ៏សុខុមរបស់សាធ្យៈ និងពិធីយញ្ញដែលលក្ខណៈធម្មជាតិរបស់ទ្រង់ គឺធ្វើពិធីយញ្ញជាប់លាប់ជានិច្ច។' 'ចំណុចផ្សេងទៀត' ដែលគាត់ គោវ. និងកុល្ល. បានលើកឡើង ដាក់បញ្ចូល '**និង**' នៅចន្លោះ *កម្មាត្ម័នាំ* និង *ប្រាណិនាំ* ហើយពន្យល់ថា 'ព្រះអង្គបានបង្កើតទេពតាជាច្រើនដែលមានលក្ខណៈជាអ្នកប្រតិបត្តិពិធីយញ្ញ និងដែលទទួលបាននូវជីវិត'។ ដោយសារទេពតាដែលមានលក្ខណៈ ជាអ្នកបូជាយញ្ញនោះ' ពួកគាត់យល់អំពីឧបករណ៍គ្មានជីវិត ដែលត្រូវប្រើក្នុងពិធីយញ្ញប៉ុន្តែជាញឹកញយមាននិយាយនៅក្នុងគម្ពីរវេទ ថាជាទេវៈ ចំណែកឯទេពតា ដែលបានទទួលជីវិត គេហៅថា ឥន្ទ្រ ជាដើម។ លោកមេធ. ព្រមទាំងលោកនារ. ដែលហាក់ដូចជាបានយល់ស្របដែរនោះ និយាយថា 'ហើយព្រះជាម្ចាស់បានបង្កើតសត្វលោក ផ្ដល់ជីវិតឱ្យយើង ទេពតាជាច្រើនដែលមិនអាចមើលឃើញ ដែលដោយសារកម្មរបស់ពួកគេ បានឡើងទៅឋានទេវៈរបស់ខ្លួន ឬដែលចិញ្ចឹមជីវិតដោយអាស្រ័យតង្វាយបូជានានា'។ គ្មានការពិចារណាណាមួយ មានប្រយោជន៍ច្រើនោះទេ។ ក៏ប៉ុន្តែអាចនិយាយបានថា *កម័ន* សំដៅដល់ 'ពិធីបូជាយញ្ញ' ហើយគេអាចបកប្រែ *កមាត្មនាំ* ថា 'ដែលមានលក្ខណៈ ជាយញ្ញ' ឬ 'ដែលមានទេវភាព អាស្រ័យលើការប្រត្តិបត្តិពិធីយញ្ញ'។ បើនិយាយពី សាធ្យៈ សូមមើល Wilson *វិស្ណុ-បុរាណ* ខ្សែ ២ ទំព័រ២២ (បោះពុម្ពដោយ Hall)។

២៦. ផ្នែកបដិបក្ខនឹងគ្នាដទៃទៀត មានចំណង់និងកំហឹង ការប្រកាន់ខ្ជាប់យ៉ាងខ្លាំងនិងទោសៈ ការឃ្លាននិងការស្រេកទុក្ខព្រួយនិងមាយា ជាដើម (តាមកុល្ល.)។

២៧. 'ចុណ្ណភាគវិនាសដ៏តូចល្អិតនៃ(ធាតុ) ៥' យោងតាមលោកមេធ., គោវ. និងកុល្ល. គឺជាធាតុដ៏ប្រណិត ឬរៀមច្បងដែល គេអាចហៅថា 'ដែលងាយវិនាសទៅបាន' ពីព្រោះចុណ្ណភាគទាំងឡាយ ត្រូវប្រែប្រួលទៅជាធាតុទាំងស្រុង។ លោករាឃ. បកស្រាយគុណស័ព្ទ 'ដែលងាយវិនាសទៅបាន' ដោយបន្ថែមថា 'ដោយសារធាតុទាំងឡាយត្រូវបានបង្កើតឡើង'។ អ្នកអធិប្បាយធ្វើការពន្យល់ផ្សេងគ្នា ដើម្បីរៀបរាប់អំពីការបន្ថែមនៅក្នុងកាព្យនេះ ដែលធ្វើឱ្យដាច់ភាពស៊ីសង្វាក់នៃអត្ថបទ។ លោកមេធ. គិតថា វាជាការសង្ខេប។ លោកគោវ. និងកុល្ល. អះអាងថា អត្ថន័យគឺចង់កាត់បន្ថយការសង្ស័យថាតើការបង្កើតចិត្តគំនិតរបស់ព្រហ្មន៍ អាស្រ័យដោយហេតុបច្ច័យ មិនមែនដោយសារជំនួយពី 'ប្រកពព្រះ'ទេហើយលោកនារ. ពោលថា ក្នុងន័យនេះ គឺថា អាត្មម មិនអមតៈនោះទេ។ នន្ទ. ដូចបានបញ្ជាក់ខាងលើស្រាប់នៅក្នុងកាព្យ ២០ ដាក់កាព្យនោះ នៅជាប់ផ្ទាល់នឹងកាព្យ ១៩។

២៨- ប៉ុន្តែចំពោះដំណើរប្រព្រឹត្តតាមរបៀបណាក៏ដោយ ព្រះជាម្ចាស់មុនដំបូងបានបង្កើត(ប្រភេទសត្វលោក)នីមួយៗ ហើយសត្វលោកនីមួយៗនោះបានបន្តពូជតាមអម្បូរមួយៗជាបន្តបន្ទាប់។

២៩- អ្វីដែលទ្រង់បានកំណត់ឱ្យដល់អម្បូរមួយៗ នៅពេលបង្កើត(ដំបូង) គឺភាពពិសពុល ឬភាពមិនបង្កការឈឺចាប់, ភាពរាបសា ឬភាពឃោរឃៅ, បុណ្យ ឬបាប, ភាពទៀងត្រង់ ឬភាពមិនទៀងត្រង់ដែលជាប់មកជាមួយដោយឯកឯង។

៣០- ដោយសារមានការផ្លាស់ប្ដូររដូវកាល រដូវនីមួយៗដែលមានដំណើរផ្ទាល់របស់វា មានលក្ខណៈសម្គាល់ច្បាស់លាស់របស់វា ថែមទាំងជាសភាវៈមានរូបកាយ (បន្តកំណើតជាថ្មី) តាមដំណើរ (ដែលបានកំណត់)របស់វា។

៣១- ប៉ុន្តែដើម្បីភាពចុំចើ្រងរបស់ពិភពលោក ទ្រង់បានញ៉ាំងឱ្យមានពួកព្រាហ្មណ៍ ក្សត្រិយ៍ វៃស្យៈ និងសូទ្រៈ ដែលចេញមកពីព្រះឱស្ឋ ហត្ថា ភ្លៅ និងព្រះបាទរបស់ទ្រង់។

៣២- ដោយបែងចែកចេញពីរូបកាយរបស់ទ្រង់ផ្ទាល់ ព្រះជាម្ចាស់បានក្លាយជាប្រុសពាក់កណ្ដាល និងស្រីពាក់កណ្ដាល ហើយជាមួយនឹង (ធាតុស្រី)នោះ ព្រះអង្គបានបង្កើត*វិរាគ*។

៣៣- ប៉ុន្តែស្គាល់ខ្ញុំ ឱ! ពិតជាពិសិដ្ឋបំផុត ក្នុងចំណោមសត្វដែលចាប់កំណើតពីរដង គឺជាបង្កើត (ពិភពលោក)ទាំងមូលនេះដែលជាតុប្រុស *វិរាគ* បង្កើតខ្លួនឯង បន្ទាប់ពីបានធ្វើតបធម៌យ៉ាងតឹងរ៉ឹងមក។

៣៤- ពេលនោះ ខ្ញុំ ដោយមានបំណងចង់បង្កើតសត្វលោកដែលត្រូវបានបង្កើតនោះ បានខំធ្វើវត្តបដិបត្តិធម៌យ៉ាងលំបាកលំបិនណាស់ (ហេតុនោះ)ហើយបានញ៉ាំងឱ្យមហាបណ្ឌិត ១០រូប ជាគ្រូរបស់សត្វលោកដែលត្រូវបានបង្កើតទាំងឡាយនោះ មាន

៣៥- មរីគិ, អត្រិ, អង្គិរៈ, បុលស្ត្យ, បុល្យហ, ក្រតុ, ប្រកេត្ស, វសិស្ឋ, ភ្រិគុ និងនារទ។

៣៦- ពួកគេបានបង្កើត*មនុ* ៧ ផ្សេងទៀត ដែលមានបញ្ញាញាណអស្ចារ្យ ទេពតា និងជាន់ថ្នាក់របស់ទេពតា និងមហាបណ្ឌិតទាំងឡាយ ដែលមានអំណាចគ្មានដែនកំណត់,

---

៣១. លោកនារ. បកស្រាយពាក្យ *លោកវិវ្រិទ្ធ្យាថំ* 'ដើម្បីភាពចុំចើ្រងរបស់ពិភពលោក' ដោយ *វាណៃលោករក្សណសំ វាធនាថំ* 'ដើម្បីការពារពិភពលោក ដោយការចែកវណ្ណៈ និងដើម្បីធ្វើឲ្យពិភពលោករីកចម្រើន'។ លោកមេធ., គោវ. និងកុល្ល. ដែលបកប្រែន្សោមពាក្យ 'ដើម្បីឱ្យ (សត្វលោកទាំងឡាយនៅក្នុង)ពិភពលោក អាចបង្កើតកូនពូនជាចៅ' សំដៅដល់គុណប្រយោជន៍ ដែលទទួលបានពីការប្រតិបត្តិយញ្ញរបស់គ្រួសារ ខ្សែ៣ កាព្យ ៧៦។ នន្ទ. មានប្រសាសន៍ យោងតាមន័យរបស់កាព្យ 'ឥឡូវទ្រង់និយាយអំពីការបង្កើតទេពនិករ ដែលមានវណ្ណៈបួន។' ពាក់ព័ន្ធនឹងដើមកំណើតនៃវណ្ណៈទាំងឡាយ សូមមើលគម្ពីរឫគវេទ ខ្សែ ១០ កាព្យ ៩០, ១២។

៣២-៣៣. 'បានបង្កើត' គឺ 'បានញ៉ាំងឱ្យកើត' (មេធ., កុល្ល.) មើល Wilson, *វិស្ណុ-បុរាណ* ខ្សែ ១ ទំព័រ ១០៤ កំណត់សម្គាល់ ២ (បោះពុម្ពដោយ Hall)។

៣៤-៣៥. មើល Wilson *វិស្ណុ-បុរាណ* ខ្សែ ១ ទំព័រ ១០០ កំណត់សម្គាល់ ២ (បោះពុម្ពដោយ Hall)។

៣៦. 'មនុ' គឺ 'អ្នកបង្កើតនៅក្នុង មនវន្តរ ជាច្រើន' (លោកមេធ., គោវ., កុល្ល., រាឃ.)។ 'ទេពតាទាំងឡាយ' គឺ 'ទេពតាទាំងឡាយ ដែលមិនមែនបង្កើតឡើងដោយព្រហ្មន៍' (កាព្យ ២២ មេធ., កុល្ល.); ពាក្យ ទេវនិកាយាន 'ជាន់ថ្នាក់របស់ពួកទេពតា' (នន្ទ.,នារ.) យោងតាមមេធ.,កុល្ល. និងរាឃ. មានន័យ 'ឋានរបស់ទេពតា'(ទេវស្ថានានិ)។ រាឃ. ក៏ឱ្យន័យថា 'បរិវារបស់ទេពតា'។

៣៧- យក្ស (បរិវាររបស់កុបេរៈ គេហៅថាពួកសភាវៈអាក្រក់) រក្សសៈ និងបិសាចៈ, គន្ធវ៌ៈ(ឬពួកតន្ត្រីកររបស់ទេពតា}, អប្សរ (ពួកអ្នករបាំរបស់ទេពតា}, អសុរៈ (គេហៅទេពតាពស់) នាគនិង សាបៈ (សំដៅដល់ទេពតាបក្សី) សុបាណៈ និងឋានជាច្រើនទៀតរបស់សភាវអាក្រក់,

៣៨- ផ្លេកបន្ទោរ ផ្គររន្ទះ និងពពក, (រោហិតៈ)មិនគ្រប់លក្ខណៈ និងឥន្ទធនូដ៏ល្អផូរផង់ អាចម៍ផ្កាយធ្លាក់ចុះ សំឡេងអភិធម្មជាតិ ផ្កាយដុះកន្ទុយ និងពន្លឺពីឋានសួគ៌ជាច្រើនប្រភេទ,

៣៩- កិន្នរ (ដែលមានមុខសេះ) ពានរ មច្ឆា បក្សាបក្សីជាច្រើនប្រភេទ សត្វពាហនៈ ក្តាន់រមាំង មនុស្សម្នា និងពួកសត្វព្រៃដែលមានធ្មេញពីរជួរ ស៊ីសាច់ជាអាហារ,

៤០- ដង្កូវតូចធំ និងសត្វល្អិតនានា មានខ្ទួត ចៃ រុយ សត្វល្អិតចង្រៃ សត្វល្អិតទិច និងចឹកខាំទាំងអស់ និង អ្វីៗដែលគ្មានចលនាជាច្រើនប្រភេទ។

៤១- ដូចនេះគឺជាការ(បង្កើត)ទាំងស្រុង ទាំងអ្វីដែលគ្មានចលនា ទាំងអ្វីដែលមានចលនា ដែលបង្កើតឡើងដោយសភាវៈដែលមានឧត្តមគតិខ្ពស់ ដោយសារការអនុវត្តតបធម៌ និងតាមបញ្ជារបស់ខ្ញុំ (សភាវៈនីមួយៗ) ត្រូវអនុលោមតាមអំពើរបស់ខ្លួន។

៤២- ប៉ុន្តែអំពើអ្វីក៏ដោយ ត្រូវបានបញ្ជាក់(ទៅតាម)សភាវៈសត្វលោកទាំងអស់នោះ មានដូចខាងក្រោម ដែលខ្ញុំនឹងប្រកាសយ៉ាងត្រឹមត្រូវឱ្យអ្នកទាំងឡាយបានដឹង ព្រមទាំងរបៀបចាប់កំណើតរបស់ សភាវៈទាំងនោះផង។

៤៣- សត្វពាហនៈ ក្តាន់រមាំង សត្វព្រៃដែលមានធ្មេញពីរជួរ ស៊ីសាច់ជាអាហារ ពួករក្សសៈ បិសាកៈ និងពួកមនុស្សម្នា ត្រូវចាប់កំណើតនៅក្នុងគភ៌។

៤៤- ពួកសត្វដែលចាប់កំណើតក្នុងស៊ុត មានពួកបក្សាបក្សី ពស់ ក្រពើ មច្ឆា អណ្តើក កន្ធាយ ព្រមទាំង (សត្វ)ប្រហាក់ប្រហែល ដែលរស់នៅលើគោក និងក្នុងទឹក។

៤៥- ពួកសត្វដែលមានកំណើតពីសំណើមក្តៅ មានពពួកសត្វល្អិតទិច ចឹក និងខាំ ចៃ រុយ សត្វចង្រៃ និងសត្វល្អិតផ្សេងៗទៀត ដែលស្ថិតក្នុងប្រភេទនោះ ត្រូវបានកើតឡើងដោយសារកម្តៅ។

៤៦- រុក្ខជាតិទាំងអស់ ដែលដុះចេញពីគ្រាប់ពូជ ឬរំអិល រីកដុះចេញពីពន្លក; រុក្ខជាតិដែលដុះតែមួយរដូវ (ជារុក្ខជាតិទាំងឡាយ) ដែលមានផ្កានិងផ្លែច្រើន ងាប់ទៅវិញ បន្ទាប់ពីផ្លែរបស់វាទុំ;

៤៧- (ដើមឈើទាំងឡាយ) ដែលមានផ្លែ ដោយគ្មានផ្កា ត្រូវគេហៅថា *វនស្បតិ* (ទេវតាព្រៃឈើ) ប៉ុន្តែដើមឈើទាំងឡាយ ដែលមានផ្កានិងផ្លែ ត្រូវគេហៅ *វ្រក្សៈ*។

---

៣៧. ឋានជាច្រើនរបស់ព្រលឹងបុព្វបុរស មានរៀបរាប់នៅខាងក្រោម ខ្សែទី ៣ កាព្យ ១៩៤-១៩៩។

៣៨. រោហិតៈ ត្រូវបានសំដៅដល់ឥន្ទធនូមិនគ្រប់លក្ខណៈដែលទំនងជាត្រង់ភ្លឹង តាមការឱ្យឈ្មោះរបស់ គោវ.គឺជា *សស្រ្តុត្បាត*។

៤៦. ខ្ញុំអានតាមលោក មេធ., គោវ., នន្ទ. និងកុល្ល. ថា *តរវៈ* ជំនួយឲ្យ *ស្តាវៈ* ដែលមាននៅក្នុងសៀវភៅពុម្ព ហើយប្រែពាក្យនេះតាមបរិបទតម្រូវថា 'រុក្ខជាតិ'។

៤៧. ការប្រែរបស់ខ្ញុំ ពាក្យ *ឧភយតៈ* 'ទាំងពីរ' គឺផ្អែកតាមការអធិប្បាយរបស់គោវ. *'វ្រក្សៈ បុនះ បុស្បផាលេនូភយេនាបិ យត្តាភវន្តិ'* ដែលលោកនារ. និងនន្ទ. យល់ស្របតាម។ យ៉ាងណាមិញ លោកខាងក្រោយសុំឱ្យអាន 'ឧភយថា'។

៤៨- ប៉ុន្តែរុក្ខជាតិនានាដែលមានមែកសាខាច្រើន ដុះចេញឫសមួយឬច្រើន ប្រភេទស្មៅផ្សេងៗ រុក្ខ-ជាតិវល្លិ និងរុក្ខជាតិឡើងទ្រើង សុទ្ធតែដុះចេញពីពូជ ឬពីការផ្សាំមែក។

៤៩- (វត្ថុជាតិ)ទាំងអស់ ដែលពោរពេញដោយភាពងងឹតច្រើនបែបយ៉ាង បណ្ដាលមកពីអំពើរបស់ខ្លួន (តាមអត្ថិភាពពីមុន) មានស្មារតីខាងក្នុង និងដឹងសប្បាយរីករាយ និងដឹងការឈឺចាប់។

៥០- លក្ខខណ្ឌ(ផ្សេងៗ) ដែលសភាវៈបែបនេះ តែងទទួលរងនូវវដ្ដនៃការប្រែប្រួល ទុក្ខទោមនស្ស ក្នុងជាតិកំណើតនិងការស្លាប់ ត្រូវបានបញ្ជាក់ដោយចាប់ផ្ដើមពី (លក្ខខណ្ឌរបស់)ព្រហ្មន៍ និងបញ្ចប់ដោយ(លក្ខខណ្ឌរបស់) (សភាវៈគ្មានចលនាដែលទើបបាននិយាយរួចហើយ) ទាំងអស់នេះ។

៥១- បើអំណាចរបស់ទ្រង់មិនអាចឱ្យគេយល់បាន ហេតុនេះទើបព្រះអង្គបានបង្កើតចក្រវាល និងរូបខ្ញុំ ព្រះអង្គបាត់ខ្លួនទៅវិញដោយព្រះអង្គឯង ដោយបាត់មួយប្រវត្តិកាលម្ដងហើយម្ដងទៀត ដោយហេតុផលផ្សេងៗ។

៥២- នៅពេលទេវអង្គនោះភ្ញាក់ឡើង ពេលនោះពិភពលោកនេះរញ្ជួយ; ពេលទ្រង់ដេកលង់លក់យ៉ាងស្ងៀមស្ងាត់ ពេលនោះចក្រវាឡនេះចាប់ផ្ដើមលង់លក់ទៅដែរ។

៥៣- ប៉ុន្តែនៅពេលព្រះអង្គសម្រាកក្នុងដំណេកដ៏ស្ងប់ សត្វមានជីវិត ដែលធម្មជាតិរបស់ខ្លួន ជាអំពើ លែងធ្វើអំពើរបស់ខ្លួន ហើយចិត្តចាប់ផ្ដើមឈប់គិត។

៥៤- នៅពេលពួកគេដក់ចិត្តមួយរំពេចនឹងដួងព្រលឹងនោះទាំងស្រុង ពេលនោះព្រះអង្គ ដែលជាព្រលឹងនៃសភាវទាំងអស់ ដេកលង់លក់យ៉ាងសុខស្រួល ដោយគ្មានកង្វល់ និងជាប់ជំពាក់អ្វីទាំងអស់។

---

៤៩. ʻភាពងងឹតច្រើនបែបយ៉ាងʼ មើលចំណុចខាងក្រោម ខ្សែ១២ កាព្យ ៤២។

៥០. ភូតៈ ʻសភាវកើតឡើងʼ តាមលោកគោវ. និងកុល្ល. មានន័យ ក្សេត្រញ្ញ ʻព្រលឹងដែលមានរូបʼ។ យោងតាមលោកគោវ. និងនារ.យល់ថា ពាក្យ និត្យំ ʻតែងតែʼ ត្រូវរៀបរាប់ដោយពាក្យ *យោរេ* ʻដែលរងទុក្ខគួរខ្លាចʼ។ យ៉ាងណាមិញ លោកនារ. គិតថា និត្យេ ʻក្នុងសភាពនិច្ចំនេះʼដែលលោកនន្ទ.ក៏យល់ថាងាយស្រួលអានជាង។

៥១. ʻបានបាត់ខ្លួនដោយអង្គឯងʼ គឺ ʻព្រះអង្គបានចេញពីព្រះកាយរបស់ទ្រង់ តាមព្រះហឫទ័យរបស់ទ្រង់ផ្ទាល់ʼ (លោកមេធ., គោវ., កុល្ល.)។ ʻមួយប្រវត្តិកាលដោយលក្ខខណ្ឌផ្សេងៗʼ គឺ ʻសម័យកាលនៃការបង្កើត ដោយពេលវិនាសទៅវិញʼ (មេធ., គោវ., កុល្ល.)។

៥២. ជំនួសឱ្យពាក្យឧបមា និមីលតិ ʻបិទព្រះនេត្រ ចាប់ផ្ដើមលង់ដំណេកʼ លោកគោវ. និងកុល្ល. អាន ប្រលីយតេ ʻគឺលង់ចិត្តគំនិតʼ។

៥៣. សរីរណៈ ʻសភាវមានរូបʼ យោងតាមលោកមេធ., គោវ. និងកុល្ល. មានន័យ ʻព្រលឹងដែលស្ថិតក្នុងរូបʼ។ ករមាត្មានះ ʻដែលមានធម្មជាតិជាអំពើʼ ពោលគឺ ដែលទទួលផលតាមអំពើ (នន្ទ., នារ.) យោងតាមមេធ., គោវ., និងកុល្ល. មានន័យថា ʻដែលដោយសារអំពើរបស់ខ្លួន បានក្លាយជាចំណងទំនាក់ទំនងមួយʼ។

៥៤. យោងតាមគោវ. និងកុល្ល. កាព្យនេះរៀបរាប់ពាក្យ មហាប្រល័យ ជាការវិនាសដ៏ខ្លាំងក្លា ឬរលាយទាំងស្រុង នៅខាងចុងកល្ប ចំណែកឯពាក្យ អន្តរាយប្រលយ គឺការវិនាសភ្លាមៗ ឬបំផ្លាញមិនទាំងស្រុង។ លោកមេធ. ពន្យល់ថា ʻព្រះអង្គដែលជាព្រលឹងរបស់សត្វលោកទាំងអស់ʼ ដោយពាក្យសំខ្យ ជាប្រធាន ʻជាដើមហេតុចម្បង ឬជាធម្មជាតិʼ ចំណែកឯលោកគោវ. និងកុល្ល. យល់សំនួនវោហារនេះ ព្រមទាំង មហាត្មន ថាជា ʻដួងព្រលឹង ឬព្រះអាទិទេពʼ របស់វេទន្ត។

៥៥- នៅពេល(ព្រលឹង)នេះបានទទួលនូវភាពងងឹត ព្រលឹងនឹងទ្រាំនៅជាមួយសរីរៈ(វិញ្ញាណ) អស់មួយរយៈពេលវែង ប៉ុន្តែមិនបានបំពេញនាទីរបស់ខ្លួនទេ បន្ទាប់មកព្រលឹងដើរចេញពីតួរូប។

៥៦- នៅពេលគ្របដណ្ដប់ដោយចុណ្ណភាគតូចៗ(ប៉ុណ្ណោះ) ព្រលឹងចូលទៅក្នុងគ្រាប់ពូជបន្លែ ឬសត្វ បន្ទាប់មកវាក៏សម្របរួមរស់(ជាមួយរូបប្រឌិតមួយ) បង្កើតបានជាតួរូប(ថ្មី)មួយ។

៥៧- ដូច្នេះ ព្រះអង្គ ទ្រង់មិនស្លាប់ ដោយ(គ្រាន់តែប្ដូរផ្លាស់)ម្ដងភ្ញាក់ ម្ដងដេកលក់ រស់ឡើងវិញភ្លាមៗ ហើយវិនាសផ្ដាច់បង់ (ធម្មជាតិ សត្វលោក)មានចលនា និងគ្មានចលនាទាំងមូលនេះ។

៥៨- ប៉ុន្តែព្រះអង្គ បន្ទាប់ពីបានផ្សំផ្គុំបង្កើតគោលការណ៍(នៃច្បាប់ពិសិដ្ឋ) បានបង្រៀនសិក្ខាវិន័យនោះដោយផ្ទាល់ ដល់រូបទូលបង្គំម្នាក់គត់ នៅគ្រាដំបូង តមកទូលបង្គំខ្ញុំ (បានបង្រៀនគោលការណ៍ច្បាប់ទាំងនោះ)ដល់ មរីគិ និងបណ្ឌិតដទៃទៀត។

៥៩- ភ្រិគុ នេះឯង នឹងនិទានរៀបរាប់ឡើងវិញទាំងស្រុងដល់អ្នកទាំងឡាយ នូវគោលការណ៍ទាំងនេះ ដោយហេតុថាបណ្ឌិតនោះបានសិក្សាទាំងស្រុងពីទូលបង្គំ។

៦០- បន្ទាប់មកមហាបណ្ឌិតភ្រិគុនោះដូចដែលត្រូវបានបញ្ជាក់ដោយព្រះមនុបានថ្លែងសម្ដែង ហឫទ័យរីករាយដល់ពួកបណ្ឌិតទាំងអស់នោះថា ‘ចូរស្ដាប់ចុះ!’

---

៥៥-៥៦. អ្នកអធិប្បាយធ្វើការបកស្រាយកាព្យទាំងពីរនេះ តាមបីរបៀបផ្សេងគ្នា។ លោកមេធ., គោវ. និងកុល្ល. ដែលតាមការបកស្រាយខាងដើម គិតថា អយំ ‘(ព្រលឹង)នេះ’ សំដៅដល់ព្រលឹងនីមួយៗ និងថាកាព្យទាំងពីរនោះ រៀបរាប់ដោយឯកឯងនូវអ្វីដែលកើតឡើងចំពោះព្រលឹងនៅពេលស្លាប់រូប ដែលព្រលឹងមួយៗស្ថិតនៅនោះ។ ទី១ ពួកគាត់និយាយថា ព្រលឹងចូលក្នុងភាពងងឹត ពោលគឺ ចំណេះដឹង (ញាណ) លែងដំណើរការ ហើយសូម្បីពេលខ្លះ ទំនាក់ទំនងរបស់ព្រលឹងជាមួយនឹងសរីរាង្គនៅមានក៏ដោយ ក៏ព្រលឹងលែងដំណើរការដកដង្ហើមជាដើម។ បន្ទាប់មក ព្រលឹងបានចាកចេញពីរូបកាយចាស់នោះ។ ពេលនោះព្រលឹងត្រូវបង្កប់នៅក្នុងធាតុកាយដំបូង ដែលមានធាតុផ្សំប្រាំបី ជាសង្ខតធាតុដំបូង (ភូតៈ) និងសរីរៈ (ឥន្ទ្រីយ៍) ចិត្ត (មនៈ) បញ្ញា(ពោធិ) ការចងចាំកម្មពីអតីតកាល(វាសនា) កុសល ឬអកុសល(ករម័ន ឬកម្ម) ខ្យល់សម្ព័ន្ធជីវិត(វាយុ) និងអវិទ្យា ឬអវិជ្ជា។ ក្នុងលក្ខខណ្ឌនេះ ព្រលឹងចូលក្នុងគ្រាប់ពូជរុក្ខជាតិមួយចំនួន ឬភ្រូណារបស់សត្វខ្លះ ហើយបន្ទាប់មកបង្កបង្កើតជារូបកាយមួយថ្មីទាំងស្រុង។ ចំណែកលោកនារ. យល់ថា កាព្យទី១នេះ ធ្វើការពិពណ៌នាអំពីជោគវាសនានៃព្រលឹងនីមួយៗ ក្នុងអំឡុងពេលមិនដឹងខ្លួន (មុរខា) និងទី២ សំដៅដល់ដំណើរ ប្រែប្រួលនៃព្រលឹងបន្ទាប់ពីស្លាប់។ យោងតាមការសន្មតនេះ កាព្យ៥៦ ត្រូវតែប្រែដូចតទៅៈ ‘សភាវៈអាត្មម (ព្រលឹង) ចូលក្នុងពូជបន្លែ ឬសត្វ ហើយផ្សំផ្គុំ(ជាមួយនឹងរូបដំបូង) ចាកចេញពីតួកាយ(ពីមុន)។’ លោកនន្ទ. ចុងក្រោយ យល់តាមពាក្យ អយំ ‘(ព្រលឹង)នេះ’ អ្នកបង្កើត (ភគវ័ន) ហើយគិតថា កាព្យទី១ រៀបរាប់អំពីចរិយារបស់ទ្រង់ក្នុងពេលវិនាស រីឯកាព្យទី២ សំដៅដល់ការកកើតជាថ្មី។ គាត់និយាយថា ‘នៅពេលទ្រង់បានចូលក្នុងភាពងងឹត’ គឺជាធម្មជាតិ ឬ ដំណើរវិវត្តពីខាងក្នុង ‘ហើយបានស្ថិតនៅទីនោះអស់ពេលយ៉ាងយូរ’ គឺនៅយូររហូតដល់ពេលវិនាសចុងក្រោយ ‘បន្ទាប់មកត្រូវជ្រកនៅក្នុងសរីរៈព្រលឹងមានរូបរាង្គ ដែលអាចមើលឃើញបាន’ ពោលគឺព្រលឹងស្តែងឡើងជារូបសត្វលោក។ កំណត់សម្គាល់របស់គាត់នៅកាព្យ ៥៦ ដែលគាត់អានពាក្យ *សំសូស្តៅ* សម្រាប់ពាក្យ *សំសូស្តះ* ជាកាព្យខ្លីពេក ដែលពិបាកនឹងធ្វើការបកប្រែឱ្យបានច្បាស់លាស់បាន។

៥៨. ‘យោងតាមសិក្ខាវិន័យ’ ពោលគឺ ‘ដោយមានពិធីសាសនាជំនួស ដែលបង្គាប់នៅក្នុងសាស្ត្រ’ (លោកកុល្ល.) ឬ ‘ដោយមានចេតនាត្រឹមត្រូវ ដោយយកចិត្តទុកដាក់’ (លោកមេធ., គោវ.)។

៦១- មនុដ៏មានឫទ្ធិអំណាច មានឧត្តមគតិខ្ពស់ចំនួន ៦នាក់ទៀតដែលស្ថិតក្នុងអម្បូរមនុនេះជាកូនចៅជំនាន់ក្រោយរបស់ព្រះកើតឯង(ស្វយំភូ) និងដែលបានបង្កើតសភាវៈមានជីវិតដោយឡែកៗពីគ្នា,

៦២- (គឺ) ស្វារោកិស, ឱត្តមិ, តាមស, រេវតៈ, កាក្សុសៈ ដែលមានពន្លឺដ៏អស្ចារ្យ និងបុត្ររបស់វិវស្វ័ត។

៦៣- មនុជ៏រុងរឿងទាំងប្រាំពីរនេះទីមួយក្នុងចំណោមនោះគឺស្វាយំភូវៈបានបង្កើតនិងការពារ(សត្វលោក) មានចលនា និងគ្មានចលនាទាំងមូល សភាវៈមួយៗ ក្នុងសម័យកាល (ដែលគេកំណត់)។

៦៤- ១៨ និមេសៈ (មួយពព្រិចភ្នែក គឺ ១ កាស្ថា) ៣០កាស្ថា ស្មើ ១ កលា, ៣០ កលា ស្មើ ១ មុហូតៈ ហើយច្រើន (មុហូតៈ) ស្មើ ១ ថ្ងៃ និង១យប់។

៦៥- ព្រះអាទិត្យចែកថ្ងៃនិងយប់ ទាំងមនុស្សនិងទេពតា យប់(ដែលសំដៅដល់)សម្រាប់ការឈប់សម្រាករបស់សត្វលោកដែលត្រូវបានបង្កើតឡើង ហើយពេលថ្ងៃសម្រាប់ការខំប្រឹងប្រែង។

៦៦- មួយខែ គឺមួយថ្ងៃមួយយប់របស់អមនុស្ស ប៉ុន្តែការបែងចែកនេះ គឺស្មើនឹងពីរសប្តាហ៍។ ងងឹត (រយៈពេលពីរសប្តាហ៍) ជាពេលថ្ងៃរបស់ពួកអមនុស្សសម្រាប់ការព្យាយាមយ៉ាងសកម្ម ពេលភ្លឺ (រយៈពេលពីរសប្តាហ៍) ជាពេលយប់សម្រាប់ពួកអមនុស្សដេក។

៦៧- មួយឆ្នាំ គឺមួយថ្ងៃមួយយប់របស់ទេពតា ហើយការបែងចែកថ្ងៃនិងយប់របស់ពួកទេពតា គឺ(មានដូចជា): កន្លះឆ្នាំ ក្នុងពេលដែលព្រះអាទិត្យធ្វើដំណើរទៅទិសខាងជើង គឺជាពេលថ្ងៃ ហើយកន្លះឆ្នាំ ក្នុងពេលដែលព្រះអាទិត្យដើរទៅទិសខាងត្បូង ជាពេលយប់។

៦៨- ប៉ុន្តែឥឡូវបានដឹងពីព័ត៌មានសង្ខេប (រៀបរាប់អំពី)អំឡុងពេលយប់ និងថ្ងៃរបស់ព្រហ្ម និងរបស់អាយុខែជាច្រើន (នៅក្នុងពិភពលោក យុគ) តាមលំដាប់លំដោយរបស់វា។

៦៩- ពួកគេប្រកាសថា អាយុខែក្ឫតៈ (មាន) បួនពាន់ឆ្នាំ(របស់ទេពតា) ហើយចន្លោះពេលព្រះអាទិត្យអស្តង្គត មុនព្រះអាទិត្យរះ មានចំនួនរាប់រយឆ្នាំ រីឯចន្លោះពេលព្រះអាទិត្យរះដល់ព្រះអាទិត្យលិច មានចំនួនឆ្នាំស្មើគ្នា។

៧០- តាមអាយុខែបីផ្សេងទៀត នៅចន្លោះពេលព្រះអាទិត្យរះ និងពេលព្រះអាទិត្យលិច ពាន់ និងរយឆ្នាំ ត្រូវរាប់ថយក្រោយមួយ(ម្តងៗ)។

៧១- ដប់ពីរពាន់(ឆ្នាំ)នេះ ដូចដែលបាននិយាយរួចហើយជារួមស្មើបួនអាយុខែ(មនុស្ស) ត្រូវស្មើនឹងមួយអាយុខែរបស់ទេវតា។

---

៦១. ‘ដែលស្ថិតក្នុងអម្បូរមនុ ស្វាយំភូវៈ នេះ’ ពោលគឺ ‘ដែលកើតក្នុងអម្បូរឬគ្រួសារដូចគ្នា ពីព្រោះពួកគេទាំងអស់ ត្រូវបានព្រះព្រហ្មបង្កើតឡើងភ្លាមៗ ដូច្នេះហើយទើបស្ថិតក្នុងអម្បូរមួយ’ (តាមលោកមេធ.)។

៦៤. ដូចពាក្យ *តាវតៈ* ‘ច្រើនដូច’ មាននៅក្នុងទុតិយាវិភត្តិ លោកមេធ., គោវ. និងកុល្លូ. យល់ពាក្យ វិទ្យាត ថា ‘គេគួរតែដឹងក្លាយជា...’។ ប៉ុន្តែលោកនារ. ទំនងជាយល់ត្រូវក្នុងការសន្មតជា វិភត្តិវ្យត្យយៈ ពោលគឺថា អ្នកនិពន្ធបានប្រើទុតិយាវិភត្តិនេះ ពីព្រោះវិភត្តិទី១ មិនត្រូវគ្នានឹងជើងកាព្យ។ លោកនន្ទ. ដែលគ្រាន់តែប្រើពាក្យ ‘តាវន្តៈ’ ជំនួសពាក្យ ‘តវតៈ’ ហាក់ដូចជាបានប្រកាន់យកយោបល់ដូចគ្នា។

៦៦. ដូចនេះ ព្រះច័ន្ទជាអ្នកកំណត់ពេលសម្រាប់ពួកអមនុស្ស។

៦៩-៧១. មើល Wilson, *វិស្ណុ-បុរាណ* ខ្សែ ១ ទំព័រ ៤៩-៥០ (បោះពុម្ពដោយ Hall)។

៧២- ប៉ុន្តែត្រូវដឹងថា អាយុសរុបមួយពាន់ឆ្នាំរបស់ទេវតា (ត្រូវនឹង)មួយថ្ងៃរបស់ព្រហ្ម និងថាមួយយប់របស់ព្រហ្ម មានរយៈពេលស្មើគ្នា។

៧៣- អ្នកដែល (មានតែអ្នកដែល)ដឹងថា ថ្ងៃដ៏ពិសិដ្ឋរបស់ព្រហ្ម តាមពិត ចប់ត្រឹម (ការបញ្ចប់)អាយុមួយរយឆ្នាំ(របស់ទេវតា) ហើយថា យប់របស់ព្រហ្ម មានរយៈពេលវែងជាង (តាមពិត) ត្រូវវែងជាងរយៈពេលយប់ និងថ្ងៃរបស់មនុស្ស។

៧៤- នៅពេលចប់ថ្ងៃនិងយប់នោះ ទ្រង់ដែលកំពុងលង់ដំណេក ភ្ញាក់ឡើង ហើយបន្ទាប់ពីភ្ញាក់ដឹងខ្លួនបង្កើតមនោ ដែលមានទាំងពិតផង និងមិនពិតផង។

៧៥- ចិត្ត (មនោ) ដែលរងនូវបំណងប្រាថ្នាបង្កើត(របស់ព្រហ្ម) បំពេញការងារនិមិត្ត ដោយការប្រែខ្លួនរបស់វាផ្ទាល់ បន្ទាប់មកអាកាសត្រូវបានបង្កើតឡើង ហើយពួកគេប្រកាសថា សំឡេងជាគុណសម្បត្តិរបស់អាកាស។

៧៦- ប៉ុន្តែចេញពីអាកាស ដែលចេះប្រែរូបរបស់វា ញ៉ាំងឱ្យមានខ្យល់បរិសុទ្ធដ៏មានឥទ្ធិពល ជាយាននាំគន្ធពិដោរគ្រប់បែបយ៉ាង ហើយគន្ធពិដោរនោះ មានលក្ខណៈសម្គាល់ដោយការប៉ះខ្ទប់។

៧៧- បន្ទាប់ពីមានខ្យល់ ដែលចេះប្រែខ្លួនរបស់វា បន្តបង្កើតឱ្យមានពន្លឺត្រចះត្រចង់ ដែលបំភ្លឺ និងកម្ចាត់បង់ភាពងងឹត ហើយខ្យល់ញ៉ាំងឱ្យមានលក្ខណៈសម្គាល់នូវពណ៌

៧៨- ហើយផ្ដើមចេញពីពន្លឺដែលចេះប្រែខ្លួនរបស់វា (ត្រូវបានកើតជា)ទឹក ដែលជាសមុដ្ឋានរបស់រសជាតិ, ផ្ដើមចេញពីទឹក មានដី ដែលជាសមុដ្ឋាននៃក្លិន ពោលគឺដំណើរបែបនេះ ជាការចាប់ផ្ដើមបង្កបង្កើតសត្វលោក។

៧៩- អាយុរបស់ទេវតាដូចបាននិយាយពីមុន (ឬ) ដប់ពីរពាន់ (ឆ្នាំរបស់ទេវតា) ដែលត្រូវគុណនឹងចិតសិបមួយ(បង្កើតបានអ្វីម្យ៉ាង)នៅទីនេះ ត្រូវគេឱ្យឈ្មោះថា សម័យកាលរបស់មនុ(មន្វន្តរៈ)។

---

៧៣. អនុលោមតាមអ្នកអធិប្បាយនានា ពាក្យ បុណ្យ 'ពិសិដ្ឋ' ត្រូវបានប្រើ ដើម្បីបញ្ជាក់ថា ចំណេះដឹងអំពីសម័យកាលនៃថ្ងៃរបស់ព្រហ្ម គឺជា 'រង្វាន់ដ៏ប្រសើរ'។

៧៤. អ្នកអធិប្បាយបានផ្ដល់ការបកស្រាយពីរយ៉ាងចំពោះកាព្យពាក់កណ្ដាលទី ២ នោះ។ ក៏អាចមានន័យថា ព្រះព្រហ្ម នៅពេលភ្ញាក់ពីដំណេក ទី១ បង្កើតនូវកំពូលគោលការណ៍(មហ័ត) ដែលនៅទីនោះ ក៏ដូចជានៅកន្លែងដទៃ ត្រូវគេហៅថា មនៈ 'ចិត្ត' ឬថា ទ្រង់កំណត់ (ស្រិគតិ)សរីរៈខាងក្នុង ឬចិត្ត(មនៈ)ផ្ទាល់របស់ព្រះអង្គ ដែលដល់ពេលវិនាសភ្លាម (អវាន្តរៈ ឬ អន្តរាលប្រលយ) នៅតែមានអត្ថិភាព ដើម្បីបង្កើតលោកដដែល។ លោកមេធ. និងកុល្លូ. ធ្វើការបកស្រាយទាំងពីរ ហើយពេញចិត្តការបកស្រាយទី១ជាង។ គោវ. ធ្វើការបកស្រាយទី២តែម្យ៉ាង ចំណែកឯនារ. និងនន្ទ. ប្រកាន់យកការបកស្រាយទី១។ អ្នកខាងក្រោយនេះ ចាត់ទុក *មនៈ* ជាការបញ្ជាក់នូវគោលការណ៍បី មហាត្ម័ន អត្តា និងចិត្ត ហើយបកស្រាយសទសទាត្មកំ 'ដែលមានទាំងពិតផង និងមិនពិតផង' ដូចមាននៅក្នុងកាព្យ ១៤ ដោយពាក្យ ប្រក្ឫតិវិក្ឫត្យាត្មកំ 'ដែលមានទាំងប្រែប្រួលផង និងវិនាសនៅខាងចុងផង'។

៧៥. 'ពីពេលនោះមក' គឺ 'ចាប់ពីចិត្ត ប្រែជាអត្តា' នារ. (ស្រដៀងគ្នានឹងការយល់របស់កុល្លូ.) ឬ 'ចេញពីព្រះព្រហ្ម'។

៧៦. ដូចតម្រាសាំខ្យ (សាំខ្យការិកា កាព្យ២៥) ផ្សំជាបឋមធាតុដែលផ្ដើមចេញពីអត្តានោះ លោកមេធ. យល់ថា ពាក្យទី១នៃកាព្យនេះ មានន័យ 'ប៉ុន្តែផ្ដើមចេញពីអត្តា ដែលចេះប្រែរូបរបស់វា ខ្យល់កើតឡើងបន្ទាប់ពីអាកាស'។ តាមពិតលោកប្រកាន់យកគន្លឹះបកស្រាយដូចគ្នាក្នុងកាព្យបីខាងក្រោម។

៨០- មន្វន្តរៈ ការកើតនិងការវិនាស (នៃលោកគឺ) រាប់មិនអស់ ហើយដោយមានការទ្រទ្រង់ ព្រោះព្រះព្រហ្មបង្កើតលោកនេះឡើងវិញម្ដងហើយម្ដងទៀត។

៨១- តាមអាយុក្ឫតៈ ធម៌ មានឫសគល់បួនពេញលេញទាំងស្រុង ហើយ(នោះគឺជា)សច្ចធម៌; ហើយគ្មានចំណេញអ្វីសម្រាប់មនុស្ស ដែលខ្វះភាពត្រឹមត្រូវនោះទេ។

៨២- តាម(អាយុកាលបី)ផ្សេងទៀត ដោយហេតុតែប្រយោជន៍(មិនត្រឹមត្រូវ) (អាគមៈ) ធម៌ត្រូវបាត់បង់នូវឫសកែវមួយជាបន្តបន្ទាប់ ហើយដោយការលួច(ជាទូទៅ) ការកុហក និងការបោកប្រាស់កុសល (ដែលមនុស្សត្រូវទទួលបាន) ត្រូវបានកាត់បន្ថយមួយភាគបួន(ក្នុងផ្នែកកុសលមួយៗ)។

៨៣- (មនុស្សគឺ) រួចផុតពីជំងឺ សម្រេចបាននូវបំណងរបស់ខ្លួនទាំងអស់ និងរស់នៅបួនរយឆ្នាំ ក្នុងកាលក្ឫត ប៉ុន្តែក្នុងត្រេតា និង (ក្នុងកាលនីមួយៗ) កាលបន្ត ជីវិតមនុស្សត្រូវខែចុះមួយភាគបួន។

---

៧៨. 'នៅក្នុងការចាប់ផ្តើម' ពោលគឺ 'បន្ទាប់ពីការវិនាសទាំងស្រុង' (មហាប្រលយ) (កុល្លូ.) ហើយ 'បន្ទាប់ពីការវិនាសភ្លាម'(គោវ., នារ.); 'មុនពេលកកើតស៊ុតលោកិយ' (នន្ទ.)។

៨១. ហេតុផលដែលនិយាយពី ធម៌ 'យុត្តិធម៌ ឬច្បាប់' ជាកតុស្បាត ត្រូវបានបកស្រាយពន្យល់ ដូចលោកកុល្លូ.គូសបញ្ជាក់ដោយគម្ពីរមនុ ខ្សែ៨ កាព្យ១៦។ បើនិយាយពីសារសំខាន់នៃអាថ៌កំបាំងដ៏ជ្រាលជ្រៅ ដែលចាត់ទុក ធម៌ ជាសត្វដែលមានជើងបួន មតិយោបល់ខាងក្រោយ ត្រូវបានលើកឡើងច្រើន គឺទី១. ជើងបួនតំណាងបុព្វជិតសំខាន់បួន នៅក្នុងពិធីយញ្ញ (មេធ.) ទី២. ឬវណ្ណៈសំខាន់បួន (មេធ., នន្ទ.) ទី៣. ឬបច្ច័យដ៏ចម្បងបួនក្នុងការទទួលបានកុសល គឺការធ្វើតបធម៌ ចំណេះដឹង ការបូជាយញ្ញ និងចិត្តសប្បុរស សូមមើលខាងក្រោម កាព្យ ៨៦ (មេធ., នារ., កុល្លូ.) ទី៤. ឬចុងក្រោយ វាក្យស័ព្ទបួនប្រភេទ ដែលមាននិយាយនៅក្នុងគម្ពីរឫគវេទ ខ្សែ១ កាព្យ១៦៤, ៤៦ (មេធ.)។ អ្នកអធិប្បាយទាំងអស់ យល់ស្របតាមការបញ្ជាក់ថា សច្ចធម៌ សូម្បីមាននៅក្នុងធម៌ក៏ដោយ មាននិយាយជាពិសេស ដើម្បីបង្ហាញពីសារសំខាន់ដ៏មហិមារបស់វា។ លោកនន្ទ. អានពាក្យចុងក្រោយ *នាធរមោ នាគមៈ គស្ចិន* និងពន្យល់ថា 'មិនមែនអកុសល និងមិនមែនច្បាប់ពិសិដ្ឋ សាស្ត្រណាមួយរត់ទៅរកមនុស្សទេ ពោលគឺគ្មានគោលការណ៍ច្បាប់មានសារសំខាន់ចាំបាច់ទេ'។

៨២. មេធ. បកស្រាយកាព្យមួយកំណាត់ដំបូងផ្សេងគ្នា 'នៅក្នុងកាលបីផ្សេងទៀត ធម៌ ច្បាប់ពិសិដ្ឋ(បានមក)ពីវិជ្ជាពិសិដ្ឋ (អាគម) ពោលគឺវេទ បង្កើតបានជាជើងមួយ បន្ទាប់មកជើងម្ខាងទៀត ជើងមួយក្នុងសម័យកាលមួយ គឺវិនាសទៅវិញ (បន្តិចម្តង) ពីព្រោះអំណាចរបស់មនុស្សក្នុងការសិក្សា និងចងចាំអត្ថបទពិសិដ្ឋ ធ្លាក់ចុះជាលំដាប់'។ លោកគោវ. និយាយថា 'ប៉ុន្តែនៅក្នុងត្រេតា ធម៌ ច្បាប់ពិសិដ្ឋ (ដែលកើត)ពីវិជ្ជាពិសិដ្ឋ (អាគមៈ) សាស្ត្រ ពោលគឺការបតិបត្តិ យញ្ញ ជាដើម ត្រូវបានកើតឡើង គឺត្រូវវិនាសទៅវិញតាមលំដាប់ មួយភាគបួនតាមសម័យនីមួយៗ ដោយសារអំពើចោរកម្ម (ជាទូទៅ) ការភូតកុហក និងការបោកប្រាស់។' លោកនន្ទ. ចុងក្រោយនៅតែយល់ផ្សេងថា 'នៅក្នុងសម័យកាលបីផ្សេងទៀត គឺត្រេត និងកាលដទៃទៀត ធម៌ (គុណធម៌ ឬយុត្តិធម៌ ត្រូវបានកំណត់) ដោយសារវិជ្ជាពិសិដ្ឋ (អាគមៈ)' សាស្ត្រ ប៉ុន្តែធម៌នេះ ត្រូវបានវិនាសទៅវិញមួយភាគបួនក្នុងមួយសម័យកាល ហើយ 'ការវិនាសធម៌នេះ' ជាសញ្ញាបង្ហាញអត្ថន័យនៃ 'ការធ្លាក់ចុះការតាំងចិត្តប្រតិបត្តិធម៌'។' ការបកប្រែយកលំនាំតាមលោកកុល្លូ., នារ. និងរាឃ។

៨៣. ដើម្បីសម្រួលសេចក្តីនេះ ដែលនិយាយអំពីអាយុខែរបស់មនុស្សតាមកាលក្ឫត តាមវគ្គផ្សេងៗនៃគម្ពីរមហាភារតៈ និងបុរាណៈ ដែលនាំឱ្យមានវីរជន និងបណ្ឌិតមួយចំនួន មានជីវិតច្រើនពាន់ឆ្នាំ អ្នកអធិប្បាយបកស្រាយវគ្គរបស់យើង ក្នុងន័យថា បួនរយឆ្នាំ ជារយៈពេលធម្មតានៃជីវិត ដែលយ៉ាងណាក៏ដោយ ក៏អាចបន្តរស់នៅបាន តាមរយៈការកាន់វគ្គប្រតិបត្តិតបធម៌។ ពួកគេបន្តអះអាងថា នៅក្នុងវគ្គ*ភាថក* ៣៤, ៥ ដែលកំណត់មួយរយឆ្នាំ ជារយៈពេលរស់របស់មនុស្ស តួលេខត្រូវបានប្រើក្នុងន័យ 'ច្រើន'។

៨៤- ជីវិតមនុស្សដែលមាននិយាយនៅក្នុងគម្ពីរវេទ លទ្ធផលជាទីប្រាថ្នាដែលបានពីពិធីយញ្ញនិងអំណាច (អភិធម្មជាតិ)នៃ(ព្រលឹង)ក្នុងរូប ជាផ្លែផ្កា ដែលត្រូវចែករំលែកដ៏ត្រឹមត្រូវក្នុងចំណោមមនុស្ស ស្របតាម (លក្ខណៈ)នៃអាយុកាល។

៨៥- សំណុំភារកិច្ច (ត្រូវបានពណ៌នា)សម្រាប់មនុស្សក្នុងកាលក្ឫត ខុសគ្នាពីភារកិច្ចក្នុងត្រេតា និងក្នុងទ្វាបរៈ និង(ម្យ៉ាងទៀត)ភារកិច្ចមួយ(សំណុំ)ទៀតក្នុងកាលិ ស្របតាមកាល(ទាំងនោះ) ដែលខែចុះអាយុកាល។

៨៦- នៅក្នុងកាលក្ឫត (គុណធម៌)ដ៏ប្រសើរ ត្រូវបានបង្ហាញតាម(ការប្រតិបត្តិ)តបធម៌ដ៏តឹងរ៉ឹង ក្នុងកាលត្រេតា ចំណេះដឹង(ទេវៈ) នៅក្នុងទ្វាបរៈ (ការប្រតិបត្តិ)តបធម៌ដ៏តឹងរ៉ឹង ក្នុងកាលិ មានតែសប្បុរសធម៌ម្យ៉ាងប៉ុណ្ណោះ។

៨៧- ប៉ុន្តែដើម្បីការពារចក្រវាឡនេះ ព្រះអង្គដ៏ភ្លឺចិញ្ចែងចិញ្ចាចបំផុត បានកំណត់នូវ(ភារកិច្ចនិង)មុខរបរផ្សេងៗសម្រាប់អ្នកទាំងឡាយ ដែលកើតចេញពីព្រះឱស្ឋ ព្រះហស្ត ភ្លៅ និងព្រះបាទរបស់ទ្រង់។

៨៨- សម្រាប់ពួកព្រាហ្មណ៍ ព្រះអង្គបានប្រទានការងារបង្រៀន និងរៀន(គម្ពីរវេទ) ធ្វើពលិកម្មដើម្បីប្រយោជន៍ផ្ទាល់ខ្លួន និងសម្រាប់អ្នកដទៃ ឱ្យនិងទទួល(ទាន)។

៨៩- ក្សត្រិយ៍ ព្រះអង្គបានដាក់បញ្ជាឱ្យការពារប្រជារាស្ត្រ ចែកអំណោយ ធ្វើពិធីបូជាយញ្ញ សិក្សា(គម្ពីរវេទ) និងវៀរចាកការតោងស្អិតនឹងតម្រេកតណ្ហា;

៩០- វៃស្យៈ ទទួលភារកិច្ចចិញ្ចឹមសត្វពាហនៈ ឱ្យអំណោយ បូជាយញ្ញ សិក្សា(គម្ពីរវេទ) ធ្វើពាណិជ្ជកម្ម ចងការប្រាក់ និងធ្វើកសិកម្ម។

៩១- ការងារតែមួយគត់ ដែលព្រះជាម្ចាស់ប្រទានឱ្យពួកសូទ្រៈ គឺឱនលំទោន បម្រើវណ្ណៈទាំងបី (ផ្សេងទៀត)ដូចគ្នា។

៩២- មនុស្ស ត្រូវបានបញ្ជាក់ថា មានភាពបរិសុទ្ធជាងសត្វ ហេតុនេះព្រះកើតឯង (ស្វាយំភូ) បានប្រកាសផ្នែកបរិសុទ្ធបំផុតរបស់ទ្រង់ គឺព្រះឱស្ឋរបស់ទ្រង់។

៩៣- ព្រោះតែព្រាហ្មណ៍កើតចេញពីព្រះឱស្ឋរបស់ (ព្រហ្ម) ក្នុងនាមព្រះអង្គជាអ្នកមានកំណើតទី១ ដូច្នេះហើយព្រះអង្គជាម្ចាស់គម្ពីរវេទ ព្រះអង្គត្រូវតែជាម្ចាស់នៃការបង្កើតអ្វីៗទាំងអស់នេះ។

---

៨៧. សូមមើលកាព្យ ៣១ ខាងលើ។

៨៨-៩១. មើលខាងក្រោម ខ្សែ ១០ កាព្យ៧៥-៧៩, ៩៩។

៨៩. ខ្ញុំអានតាម មេធ., រាឃ. និងកុល្ល. សមាទិស័ត `ព្រះអង្គបានបញ្ជា´ សម្រាប់ពាក្យ សមាសតះ `ដោយសង្ខេប´។ លោកនន្ទ. អាន អកល្បយ័ត។

៩២. មើលខាងក្រោម ខ្សែ ៥ លេខ ១៣២។

៩៣. ធម៌តះ ប្រភុះ `ពិតជាម្ចាស់´ ត្រូវគ្នានឹងសេចក្តីពន្យល់របស់លោកនារ. និងនន្ទ។ មេធ., គោវ., កុល្ល. និងរាឃ ថា `ទ្រង់គឺជាច្បាប់ ជាម្ចាស់ ពោលគឺ ដែលមានអំណាចចេញបញ្ញត្តិតួនាទីភារកិច្ចរបស់ពួកគេ សម្រាប់ការបង្កើតទាំងស្រុង´។

៩៤- សម្រាប់ព្រះស្វយំភូ (ស្វយំភូ) ដោយបានបំពេញតបធម៌ បានបង្កើតព្រាហ្មណ៍មុនគេ ចេញពីព្រះឱស្ឋរបស់ទ្រង់ដើម្បីឱ្យគេអាចធ្វើការបូជាដល់ទេវតានិងបុព្វបុរស និងអាចរក្សាចក្រវាលនេះបាន។

៩៥- តើសភាវៈអ្វីដែលត្រូវបានបង្កើតឡើងហើយអាចប្រសើរជាងទ្រង់ តាមព្រះឱស្ឋរបស់ទ្រង់ ពួកទេវតាបន្តសោយអាហារយញ្ញ ហើយពួកអមនុស្សស៊ីសំណែន ដែលគេបូជាវិញ្ញាណក្ខន្ធ?។

៩៦- ក្នុងចំណោមសភាវៈដែលត្រូវបង្កើតឡើង សភាវៈខ្ពង់ខ្ពង់បំផុត គឺជាសភាវៈទាំងឡាយ ដែលមានជីវិត, ក្នុងចំណោមសភាវៈមានជីវិត មានសភាវៈដែលមានបញ្ញា, ក្នុងចំណោមសភាវៈមាន បញ្ញាគឺមនុស្ស, ហើយក្នុងចំណោមមនុស្ស គឺព្រាហ្មណ៍

៩៧- ក្នុងចំណោមព្រាហ្មណ៍ គឺអ្នកដែលបានសិក្សា(គម្ពីរវេទ), ក្នុងចំណោមអ្នកសិក្សាទាំងនោះ គឺអ្នកដែលទទួលស្គាល់ (ភាពចាំបាច់ និងរបៀបបដិបត្តិភារកិច្ចដែលបានបញ្ញត្តិ), ក្នុងចំណោមអ្នកដែលមានចំណេះដឹងនេះ មានអ្នកដែលបដិបត្តិចំណេះនោះ, ក្នុងចំណោមអ្នកបដិបត្តិនោះ គឺអ្នកដែលចេះព្រហ្មន។

៩៨- កំណើតពិតរបស់ព្រាហ្មណ៍ គឺជាអវតារអមតៈនៃច្បាប់ពិសិដ្ឋ ព្រោះព្រាហ្មណ៍កើតមក ដើម្បី (បដិបត្តិ) ច្បាប់ពិសិដ្ឋ និងក្លាយជាអ្នកដែលនៅជាមួយព្រហ្ម។

៩៩- ព្រាហ្មណ៍ ដែលមកចាប់កំណើត ត្រូវកើតក្នុងឋានៈខ្ពស់បំផុតនៅលើផែនដី ជានាយនៃសត្វដែលត្រូវបង្កើតទាំងអស់ ដើម្បីការពារតម្លៃរតនៈរបស់ច្បាប់។

១០០- អ្វីក៏ដោយឱ្យតែមានអត្ថិភាពក្នុងលោកិយនេះ ជាកម្មសិទ្ធិរបស់ព្រាហ្មណ៍ ហើយបើនិយាយពីឧត្តមភាពនៃជាតិកំណើតរបស់ខ្លួន គឺព្រាហ្មណ៍ តាមពិតត្រូវទទួលបានអ្វីៗទាំងអស់។

១០១- ព្រាហ្មណ៍ ទទួលទានតែអាហារផ្ទាល់របស់ខ្លួន ស្លៀកពាក់តែសម្លៀកបំពាក់របស់ខ្លួនផ្ទាល់ ប្រើប្រាស់បានតែទេយ្យវត្ថុរបស់ខ្លួនផ្ទាល់ ឯមនុស្សដទៃទៀតអាចរស់បានដោយសប្បុរសធម៌របស់ពួកព្រាហ្មណ៍។

១០២- ដើម្បីបែងចែកករណីយកិច្ចរបស់ខ្លួន និងករណីយកិច្ចរបស់(វណ្ណៈ)ដទៃ ឱ្យច្បាស់លាស់ ស្របតាមឋានៈរបស់ពួកគេ បណ្ឌិតមនុ ដែលកើតចេញពីព្រះស្វយំភូ បានតាក់តែងគោលការណ៍ (ច្បាប់ពិសិដ្ឋ)ទាំងអស់នេះ។

១០៣- ព្រាហ្មណ៍ដែលមានការចេះដឹងច្រើន ត្រូវតែសិក្សាច្បាប់ពិសិដ្ឋនេះដោយយកចិត្តទុកដាក់ ហើយគេ ត្រូវតែទូន្មានបុត្រធីតារបស់ខ្លួនឱ្យត្រឹមត្រូវតាមច្បាប់នោះ ហើយគ្មាននរណាផ្សេង (ត្រូវធ្វើកិច្ច ការនេះទេ)។

---

៩៤. ដូចលោកននួ.និយាយថា តបៈ តប្វា 'បន្ទាប់ពីបានធ្វើតបៈធម៌ដ៏តឹងរឹង' ត្រូវបានបន្ថែម ដើម្បីបង្ហាញនូវ'ការពិចារណាដ៏មហិមាក្រៃលែង' (តបៈ តប្ត្វៃ អាទារាសយៈ)។ សូមមើលកាព្យ ៣៣, ៣៤, ៤១ ខាងក្រោម។

៩៥. មេធ., នារ. និងននួ. បកស្រាយ *ក្ឫតពុទ្ធយៈ* 'ដែលទទួលស្គាល់ (ភាពចាំបាច់ និងរបៀបបំពេញករណីយកិច្ចដែលបានបញ្ញត្តិ' ដោយ 'ដែលចេះនូវអត្ថន័យនៃគម្ពីរវេទ'។ 'អ្នកទាំងឡាយណាដែលស្គាល់ព្រះព្រហ្ម' ពោលគឺ 'ចេះដឹងវិជ្ជាពិសិដ្ឋ ដែលឈានទៅរកការរួចរដោះនៅទីបំផុត'។

១០០.'ដោយសារតែឧត្តមភាពនៃដើមកំណើតរបស់ខ្លួន'ពោលគឺព្រោះតែព្រាហ្មណ៍បានកើតចេញពីព្រះឱស្ឋរបស់ព្រហ្ម។

១០៤- ព្រាហ្មណ៍ ដែលសិក្សាគោលការណ៍ទាំងអស់នេះ (និង)បដិបត្តិករណីយកិច្ច(ដែលបានបញ្ញត្តិរួចហើយ) ដោយស្មោះត្រង់ មិនត្រូវប្រឡាក់ដោយអំពើបាប ដែលកើតឡើងដោយកាយ វាចា ឬចិត្ត។

១០៥- ព្រាហ្មណ៍ជួយសង្គ្រោះមនុស្សទាំងឡាយ (ដែលខ្លួនអាចគពប្រសប់) បុព្វបុរស ៧សណ្តាន និងបច្ឆាជន ៧សណ្តាន ហើយមានតែគាត់ទេ ទើបសម (នឹងជាម្ចាស់)ផែនដីទាំងមូលនេះ។

១០៦- (ដើម្បីសិក្សាស្នាដៃ) នេះ ជាមធ្យោបាយដ៏ប្រសើរបំផុត ក្នុងការទទួលបាននូវសុខុមាលភាព វាជួយបង្កើនការយល់ដឹង វាផ្តល់នូវកិត្តិនាមនិងអាយុវែង វា(នាំឱ្យទទួលបាន) នូវពរជ័យដ៏កំពូល។

១០៧- នៅក្នុង(ស្នាដៃ)នេះ ច្បាប់ពិសិដ្ឋ ត្រូវបានអះអាងទាំងស្រុង ដូចជាលក្ខណៈសម្បត្តិល្អ និងអាក្រក់នៃអំពើ(របស់មនុស្ស) និងសិក្ខាវិន័យតាំងពីយូរលង់ (ដែលត្រូវអនុវត្ត) ដោយវណ្ណៈទាំងបួន។

១០៨- សិក្ខាវិន័យគឺជាច្បាប់ដ៏វិសេសវិសាល ទោះបីជាគេបង្រៀនវាតាមអត្ថបទដែលបានបង្ហាញក្តី ឬតាមប្រពៃណីដ៏ពិសិដ្ឋក្តី ហេតុនេះមនុស្សមានកំណើតពីរដង ដែលចេះត្រេកអរនឹងខ្លួនឯង គួរតែយកចិត្តទុកដាក់(គោរព)សិក្ខាវិន័យឱ្យបានខ្ជាប់ខ្ជួន។

១០៩- ព្រាហ្មណ៍ ដែលចាកគន្លងធម៌ពីសិក្ខាវិន័យ មិនបានទទួលផលពីវេទទេ ប៉ុន្តែព្រាហ្មណ៍ដែលដើរតាមសិក្ខាវិន័យត្រឹមត្រូវ នឹងទទួលបានរង្វាន់ទាំងស្រុង។

១១០- បណ្ឌិត ដែលបានដឹងដូច្នេះថា ច្បាប់ពិសិដ្ឋមានមូលដ្ឋានផ្អែកលើសិក្ខាវិន័យ បានចាត់ទុកការប្រព្រឹត្តអំពើល្អ ជាឫសកែវដ៏ប្រសើរបំផុតក្នុងការកាន់វត្តប្រតិបត្តិដ៏តឹងរឹងទាំងអស់។

---

១០៣. កាព្យនេះ គ្មានបំណងបដិសេធពួកក្សត្រិយ៍ និងវៃស្យៈ មិនឱ្យមានសិទ្ធិសិក្សាគម្ពីរមនុស្សសំហិតា តែគ្រាន់តែហាមមិនឱ្យបង្រៀនប៉ុណ្ណោះ។

១០៤. សំសិតវ្រតៈ 'ដែលបដិបត្តិតាមករណីយកិច្ចយ៉ាងស្មោះត្រង់' គឺអាស្រ័យលើការបកស្រាយទាំងស្រុងរបស់គោវ. ថា ទេតទថាវពោធេន សំសិតវ្រតោ វិសិស្ត យមនិយមៈ សន ដែលសឹងតែស្របគ្នានឹងការបកស្រាយរបស់លោកមេធ.។

១០៧. 'លក្ខណៈល្អ និងអាក្រក់នៃអំពើ(របស់មនុស្ស)' ពោលគឺយោងតាមលោកមេធ., គោវ., កុល្ល., និងនន្ទ. គឺ 'ផលល្អ និងផលអាក្រក់នៃអំពើ' ឬយោងតាមលោករាឃ., និងនារ. គឺ 'អំពើដែលបានកំណត់ ជាអំពើល្អ និងអំពើហាមឃាត់ ដែលជាអំពើអាក្រក់'។

១០៨. ខ្ញុំប្រែពាក្យ *អាត្មវ័ន* ថា 'ដែលចេះត្រេកអរនឹងខ្លួនឯង' ដោយប្រែតាមលោកមេធ. និងកុល្ល.។ លោកគោវ. ប្រែពាក្យនេះថា 'ដែលមានសម្បទាដ៏ប្រសើរ',លោកនារ. ថា 'ដែលមានភាពរឹងមាំ' ហើយលោករាឃ. ថា 'ដែលមានជំនឿលើជីវិតជាតិក្រោយ'។

១០៩. វេទផលំ 'ផលនៃវេទ' ពោលគឺជា 'រង្វាន់សម្រាប់ផ្តល់ជូនអំពើ ដែលបានបញ្ញត្តិដោយគម្ពីរវេទ' (មេធ., គោវ., កុល្ល. និងនារ.)

១១០. ភាគ VI ល្បះលេខ ១-៨។ 'សិក្ខាវិន័យ ឬការប្រព្រឹត្តល្អ' (អាការៈ) ដែលសរសេរនៅទីនេះ និងនៅក្នុងកាព្យខាងដើមៗ មានការប្រើប្រាស់ច្រើន ដែលបានរៀបរាប់ខ្លះៗនៅនៅក្នុងគម្ពីរវេទ ហើយខ្លះនៅក្នុងធម៌សាស្ត្រ ដូចជាការជុសខ្លួននឹងទឹកដោះខាប់ក្នុងឱកាសពិសេសនៃពិធីបូជាយញ្ញ ឬការក្រេបទឹកក្នុងពិធីមួយចំនួន។

១១១- ការបង្កើតចក្រវាឡ៏ សិក្ខាវិន័យសម្រាប់ការគោរពបូជា បទប្បញ្ញត្តិសម្រាប់ការសិក្សា និងឥរិយា-បថគោរព(ចំពោះគ្រូ) សិក្ខាវិន័យដ៏ប្រពៃបំផុតសម្រាប់ការមុជទឹក (នៅពេលត្រឡប់មកពីផ្ទះរបស់គ្រូវិញ),

១១២- (ច្បាប់) អាពាហ៍ពិពាហ៍ និងការពិពណ៌នាអំពីពិធីអាពាហ៍ពិពាហ៍(ផ្សេងៗ) វិធានសម្រាប់ការ ធ្វើពិធីយញ្ញធំៗ និង សិក្ខាវិន័យមានគ្រប់សម័យកាលសម្រាប់ពិធីបុណ្យសព,

១១៣- ការពិពណ៌នាអំពីរបៀប(ចិញ្ចឹម)ជីវិត និងតួនាទីភារកិច្ចរបស់*ស្នាតកៈ* (សិក្ខាវិន័យស្ដីអំពី) អាហារត្រឹមត្រូវតាមច្បាប់បញ្ញត្តិ និងអាហារដែលត្រូវហាមឃាត់ ការបន្សុទ្ធមនុស្ស និងវត្ថុ,

១១៤- ច្បាប់ស្ដីពីស្ត្រី,(ច្បាប់)របស់តាបស, (របៀបទទួលបាន)នូវការរួចផុតចុងក្រោយ និង(នូវ)ការ ប្រកាសបោះបង់ចោលលោកិយ៍នេះ, តួនាទីភារកិច្ចរបស់ព្រះមហាក្សត្រយ៏ និងរបៀបវិនិច្ឆ័យ រឿង ក្ដី,

១១៥- វិធានសម្រាប់ពិនិត្យសាក្សី, ច្បាប់ស្ដីពីស្វាមីនិងភរិយា, ច្បាប់ស្ដីពី(ការទទួលមរតក និង)ការ បែងចែកមរតក, (ច្បាប់ស្ដីពី)ការលេងល្បែងស៊ីសង និងការបណ្ដេញមនុស្សចង្រៃ(មនុស្សដែល បង្កទុក្ខភ័យដល់អ្នកដទៃ),

១១៦- (ច្បាប់ស្ដីពី)ការប្រព្រឹត្តរបស់វៃស្យៈ និងសូទ្រៈ, ដើមកំណើតនៃវណ្ណៈចម្រុះ, ច្បាប់សម្រាប់ វណ្ណៈទាំងអស់ ក្នុងពេលអាសន្ន និងច្បាប់ស្ដីពីការធ្វើតបៈ,

១១៧- មាគ៌ាបែកជាបីសម្រាប់ការធ្វើទេសន្ដប្រវេសន៍, ផលនៃអំពើ (ល្អ ឬអាក្រក់), (របៀបដើម្បី ទទួលបាននូវពរជ័យដ៏កំពូល និងការពិនិត្យមើលលក្ខណៈនៃអំពើល្អ និងអំពើអាក្រក់,

១១៨- ច្បាប់សម័យដើមនៃបណ្ដាប្រទេសនានា ស្ដីពីវណ្ណៈ(គតិ), ស្ដីពីគ្រួសារ និងវិធាន ស្ដីពីអ្នកដែលមានជំនឿខុសពីមនុស្សទូទៅ និងធុរកិច្ច(របស់ឈ្មួញ និងអ្នកផ្សេងៗ) ពោលគឺ (ទាំងអស់ នេះ) គឺ មនុបានប្រកាសដាក់ចេញជាគោលការណ៍ទាំងអស់។

១១៩- ដើម្បីជាការឆ្លើយនូវសំណួររបស់ខ្ញុំ ដូច*មនុ* បានប្រកាសឱ្យប្រើនូវគោលការណ៍ទាំងអស់នេះ ពីមុនមកហើយ ដូច្នេះសូម្បីតែអ្នកក៏គួរតែរៀន(កិច្ចការទាំងមូលនេះ)ពីខ្ញុំដែរ។

# ជំពូក ២

១- ចូរសិក្សានូវច្បាប់ពិសិដ្ឋដែលអ្នកចេះដឹងបានសិក្សា អនុវត្តតាម(គម្ពីរវេទ) និងដែលត្រូវយល់ព្រមទទួលដោយអ្នកមានគុណធម៌ ដែលធ្លាប់រួចរំដោះពីទោសៈ និងសេចក្ដីស្រឡាញ់ហួសហេតុ។

២- ការមានបំណងចង់បានរង្វាន់តែម្យ៉ាង គឺមិនប្រពៃទេ ប៉ុន្តែការរួចផុតពីចំណង់នោះ គឺ(គេយល់ថា) មិននៅក្នុង(ពិភពលោក)នេះទេ ពោលគឺ សេចក្ដីប្រាថ្នា ក្លាយជាមូលដ្ឋានសម្រាប់ការសិក្សាវេទ និងការប្រតិបត្តិនូវអំពើ ដែលគម្ពីរវេទបានបញ្ញត្តិ។

៣- សេចក្ដីប្រាថ្នា (ចង់បានរង្វាន់) តាមពិត មានឫសគល់របស់វានៅក្នុងគំនិតដែលថា អំពើអាចផ្ដល់រង្វាន់បានហើយដោយសារការយល់(បែបនេះ) គេត្រូវធ្វើពលិកម្ម; ការសច្ចា និងច្បាប់ដែលកំណត់ព្រំដែន សុទ្ធតែត្រូវបានបញ្ជាក់ថាជាគំនិត ដែលនឹងផ្ដល់នូវផ្លែផ្កា។

៤- មិនមែនមនុស្សម្នាក់ដែលបានធ្វើអំពើតែមួយ(ខាងក្រោម) បានអស់សេចក្ដីប្រាថ្នាទេ; ទោះបី(គេ) ធ្វើអ្វីក៏ដោយ ក៏វាគឺជា (កើតចេញពី)វិញ្ញោចនៃចំណង់ដែរ។

៥- អ្នកដែលស៊ូក្នុងការបដិបត្តិនូវ(តួនាទីបញ្ញត្តិ)ទាំងអស់នេះ ដោយត្រឹមត្រូវ មិនចេះសាបសូន្យទេ ហើយសូម្បីនៅក្នុង(ជាតិ)នេះ នឹងទទួល(ផលសម្រេច)គ្រប់សេចក្ដីប្រាថ្នាដែលគេបានប៉ងប្រាថ្នា។

៦- វេទទាំងមូល ជាប្រភព(ទី១)នៃច្បាប់ពិសិដ្ឋ បន្ទាប់មកជាប្រពៃណី និងជាអំពើប្រកបដោយគុណធម៌របស់អ្នកដែលចេះ (វេទ តមកទៀត) ព្រមទាំងជាទំនៀមទម្លាប់របស់មនុស្សពិសិដ្ឋ និង(ទីបំផុត)ជាការបំពេញខ្លួនឯង។

---

II. កាព្យ ២ អាប. ខ្សែ ១ កាព្យ ៦, ២០, ១-៤។ ពាក្យ 'គឺមិនប្រពៃ' ពីព្រោះបញ្ញត្តិបែបនេះ មិនសំដៅដល់ការរួចរដោះចុងក្រោយ តែនៅមានកំណើតថ្មី (គោវ., កុល្ល.)

៣. នន្ទ. ចាប់ផ្ដើមដោយកាព្យផ្សេងវិញ គឺ 'ការប្រាថ្នាចង់បានរង្វាន់ ជាឫសកែវនៃការសម្រេចិត្តធ្វើអំពើ' (សំកល្ប)។ ពាក្យ 'ការសច្ចា' គឺជា 'អំពើ ដែលគេប្រព្រឹត្តក្នុងមួយជីវិតទាំងមូលរបស់ខ្លួន ដូចជាអំពើរបស់ស្នាតកៈ' (ជំពូក ៤) មេធ., គោវ., នារ., ជា 'ការសច្ចារបស់សិស្ស' នន្ទ., ជា 'ច្បាប់ ដែលបញ្ញត្តិអំពីដែនកំណត់' ពោលគឺ 'វិធានហាមឃាត់ ឧទាហរណ៍ វិធានដែលហាមឃាត់ការបង្ករបួសស្នាមដល់សត្វមានជីវិត' លោកមេធ., គោវ., នារ., ជា 'វិធាន ដែលមានឥទ្ធិពលលើតាបស និងសំន្យាសិន' លោកនន្ទ.។ លោកកុល្ល. សំអាងពាក្យទាំងពីរ យោងទៅតាមជំពូក ៤។

៥. 'ដោយត្រឹមត្រូវ' ពោលគឺ 'ដោយសារបញ្ញត្តិទាំងនោះមានចែងនៅក្នុងគម្ពីរវេទ ហើយដោយគ្មានចង់បានរង្វាន់ឡើយ'។ 'សភាពមិនចេះស្លាប់' គឺជា 'ការរួចរំដោះចុងក្រោយ'។

៦. អាប. ជំពូក ១, កាព្យ ១, ១-៣; គោត. ជំពូក១, កាព្យ១-៤, ជំពូក២៨, កាព្យ ៤៨; វស. ជំពូក១, កាព្យ ៤-៦; ពោធ. ជំពូក១, កាព្យ១, ១-៦; និងយាញ្ញ. ជំពូក១, កាព្យ ៧។ *សីល*ជា'អំពើល្អ' គឺ 'ការទប់បាននូវលោភៈ និងទោសៈ' តាម មេធ., គោវ.; 'សីល ដែលមានចំណង ១៣ ដែលត្រូវប្រកាន់យក ដើម្បីបានក្លាយជាព្រាហ្មណ៍ ដូចជាមានភក្ដីភាពចំពោះ ព្រះអាទិទេព និងមាតាបិតា និងចិត្តមេត្តាជាដើម' តាមកុល្ល.; 'បញ្ញត្តិសម្រាប់មនុស្សជាច្រើន ដែលចេះវេទ មានការគោរពជាធម្មតា' នារ.; 'ជាអ្វីដែលធ្វើគេ ទទួលបានកិត្តិយសពីមនុស្ស' នន្ទ.។ '*ទំនៀមទម្លាប់*' ឧទាហរណ៍ដូចជា ការចងដៃកូនក្រមុំនឹងខ្សែអំបោះនៅពេលរៀបការ(មេធ., គោវ.) និងការដណ្ដប់សំពត់ ឬសំបកឈើ(កុល្ល.)។ ត្បិតតែអ្នកអធិប្បាយ ខិតខំបង្ហាញភាពផ្សេងគ្នារវាង*សីល* និង*អាការៈ* ក៏ដោយ ក៏អាចនិយាយថា ពាក្យទាំងពីរនៅប្រើនៅទីនេះ ពីព្រោះនៅក្នុងធម៌សូត្រមួយចំនួន ឧ.ទា. គោត.ជំពូក១ កាព្យ២, សូត្រមុន និងនៅក្នុងសូត្រក្រោយខ្លះ ក៏មាននិយាយដែរ (ឧ.ទា. វស. ជំពូក ១ កាព្យ ៥)។ 'ការពេញចិត្តខ្លួនឯង' ដូចជារបស់អ្នកមានគុណធម៌ (មេធ., គោវ.,នន្ទ.) ជាសិក្ខាវិន័យ ក្នុងករណីខ្លះ គ្មានការកំណត់ដោយអំណាចណាមួយទេ (នារ., នន្ទ.) ហើយក្នុងករណីខ្លះវាគ្រាន់តែជាជម្រើសទេ(មេធ., គោវ., កុល្ល.)។

---

៧- ច្បាប់អ្វីក៏ដោយ ដែលមនុ បានបញ្ញត្តិឡើងសម្រាប់(អ្នកណា)ក៏ដោយ សុទ្ធតែមានចែងទាំងស្រុង នៅក្នុងគម្ពីរវេទ ពោលគឺជា (បណ្ឌិត) ដែលពោរពេញដោយសព្វញ្ញុញាណ។

៨- ប៉ុន្តែអ្នកចេះដឹងបន្ទាប់ពីសិក្សាវិភាគទាំងស្រុងនូវបញ្ហាទាំងអស់នេះដោយចក្ខុពុទ្ធិ ស្របតាមប្រភព អត្ថបទជាក់លាក់ដូចបានបង្ហាញជូន គួរតែតាំងចិត្ត(ប្រតិបត្តិតាម)ករណីយកិច្ចរបស់ខ្លួន។

៩- សម្រាប់មនុស្ស ដែលគោរពច្បាប់ដែលមានចែងនៅក្នុងអត្ថបទបង្ហាញជូន និងក្នុងប្រពៃណីដ៏ ពិសិដ្ឋ ទទួលបានកិត្តិនាមល្បីក្នុង(ជាតិ)នេះ និងជាតិក្រោយសុភមង្គលតាមសេចក្ដីប្រាថ្នា។

១០- ប៉ុន្តែតាមស្រុតិ (ការលាតត្រដាង) សំដៅដល់វេទ ហើយតាមស្ម្រិតិ(ប្រពៃណី) ជាគោលការណ៍ នៃច្បាប់ពិសិដ្ឋ គឺទាំងពីរនេះ មិនត្រូវមានការសង្ស័យចំពោះបញ្ហាណាមួយឡើយ ដោយសារមាន សិក្ខាវិន័យទាំងពីរ ទើបច្បាប់ពិសិដ្ឋបញ្ចេញរស្មីល្បីរន្ទឺបាន។

១១- គ្រប់មនុស្សដែលមានកំណើតពីរដង ដែលពឹងផ្អែកលើគោលការណ៍វិចារវិទ្យា មិនគោរពប្រភព (ច្បាប់) ទាំងពីរនេះ ប្រាកដជាត្រូវមនុស្សល្អបណ្តេញចេញ ដោយចាត់ជាអ្នកគ្មានជំនឿលើអាទិ-ទេព និងជាអ្នកប្រមាថវេទ។

១២- គម្ពីរវេទ ប្រពៃណីពិសិដ្ឋ ទំនៀមទម្លាប់របស់មនុស្សល្អ និងសេចក្តីរីករាយរបស់មនុស្ស ពួកគេ មើលឃើញថា ជាក់ស្តែងមានន័យមួយយ៉ាងសម្រាប់កំណត់និយមន័យច្បាប់ពិសិដ្ឋ។

១៣- ពុទ្ធិនៃច្បាប់ពិសិដ្ឋ ត្រូវបានទៅនរណាដែលមិនងប់ងល់នឹងទ្រព្យ និងបំពេញចំណង់របស់ខ្លួន ហើយសម្រាប់អ្នកដែលស្វែងរកពុទ្ធិពីច្បាប់ពិសិដ្ឋ ប្រភពសំខាន់បំផុតគឺការបើកបង្ហាញការពិត(ស្រុតិ)។

---

៧. ខ ចុងក្រោយ មានការយល់ផ្សេងគ្នាពីសំណាក់គោវ. ដែលបកស្រាយថា 'ព្រោះតែគម្ពីរ(វេទ) ត្រូវបានបង្កើតឡើងជាក់ស្តែង មានគ្រប់ចំណេះដឹង'។ មេធ. ផ្តល់ការបកស្រាយសារជាតុដូចគ្នា។

៨.'ទាំងអស់នេះ'សំដៅដល់'សាស្ត្រ' (មេធ., គោវ., កុល្ល.); 'គោលការណ៍ទាំងអស់របស់មនុ'(តាមនារ.); 'ប្រភពឯកសារផ្សេងទាំងអស់នេះ'(នន្ទ.)។ 'ដោយចក្ខុពុទ្ធិ' គឺ 'ដោយមានជំនួយពីវេយ្យាករណ៍ ពីមីមាំសា ជាដើម'(មេធ., កុល្ល.)។

១១. 'ដែលពឹងផ្អែកលើគោលការណ៍វិចារវិទ្យា' គឺ 'ដែលពឹងផ្អែកលើគោលការណ៍ហេតុផល ដោយមិនជឿលើអាទិទេព ដូចជាគោលការណ៍របស់ពោទ្ធ និងការវាកៈ' (តាមមេធ.); 'ដែលពឹងផ្អែកលើវិធីវែកញែកហេតុផល ដែលផ្ទុយនឹងវេទទាំងស្រុង' (កុល្ល., នារ.)។

១២. ពាក់កណ្តាលដំបូងនៃកាព្យនេះមានន័យត្រង់ស្របនឹងយញ្ញ ជំពូក១ លេខ ៧។

១៣. យោងតាមអ្នកអធិប្បាយ 'មួយរូបទៀត' ដែលលោកមេធ.បានស្រង់សម្តី និងយោងតាមលោកគោវ., កុល្ល. និងនារ. ន័យរបស់កាព្យពាក់កណ្តាលដំបូង គឺ 'ដំបូន្មានសម្រាប់ការសិក្សាគម្ពីរច្បាប់ពិសិដ្ឋ គឺសម្រាប់អ្នកណា ដែលមិនតោងស្អិតនឹងសម្ភារៈលោកីយ៍ ពីព្រោះអ្នកនោះ ដែលប្រតិបត្តិ (សិក្សា, តាមនារ.)ច្បាប់ពិសិដ្ឋ ដោយគ្រាន់តែដើម្បីទទួលបានគុណប្រយោជន៍ខាងលោកីយ៍ ដូចជាទ្រព្យធន កេរ្តិ៍ឈ្មោះជាដើម មិនបានទទួលប្រយោជន៍ផ្នែក ព្រលឹងវិញ្ញាណ ពីសិក្ខាវិន័យឡើយ (ដោយហេតុថា ពួកគេនឹងមិនគោរពសិក្ខាវិន័យដោយពិតប្រាកដទេ' តាមនារ.)។ ផ្ទុយទៅវិញ លោកមេធ. គិតថា ពាក្យ *វិធីយតេ* 'ដែលត្រូវបានបញ្ញត្តិ' សំដៅដល់ 'ដែលមានហេតុផលបញ្ជាក់'។

១៤- ប៉ុន្តែពេលដែលអត្ថបទ(ស្រុតិ)ដ៏ពិសិដ្ឋពីរ មានទំនាស់នឹងគ្នា អត្ថបទទាំងពីរ ត្រូវចាត់ទុកជាច្បាប់ ពីព្រោះបណ្ឌិតបានប្រកាសអត្ថបទទាំងពីរ (ថាជា)ច្បាប់ត្រឹមត្រូវ។

១៥- (ហេតុនេះ) ពិធីយញ្ញ(អញ្ញិហូត្រ) គេអាចធ្វើ(តាមចិត្ត) នៅពេលណាក៏បាន បន្ទាប់ពីថ្ងៃរះ មុនពេលព្រះអាទិត្យរះក៏បាន ឬនៅពេលគ្មានព្រះអាទិត្យនិងគ្មានផ្កាយក៏បាន ពោលគឺចំណុចនេះ (មានចែង)នៅក្នុងអត្ថបទវេទ។

១៦- ចូរដឹងថា អ្នកដែល(រៀបចំធ្វើ)ពិធី ចាប់ផ្តើមដោយពិធីរីត៏ ក្នុងការប្រារព្ធកម្មវិធី (គាភាធាន) និង បញ្ចប់ដោយពិធីបញ្ចុះសព (អន្ត្យេស្តិ) ដែលមានកំណត់ច្បាស់ រីឯរូបមន្តពិសិដ្ឋគេត្រូវតែសូត្រ គេអាច(សិក្សា) គោលការណ៍ទាំងអស់នេះបាន ប៉ុន្តែយ៉ាងណាក៏ដោយមិនត្រូវឱ្យមានអ្នកដទៃ ទេ។

១៧- ដីដែលបង្កើតដោយអាទិទេព ស្ថិតនៅចន្លោះទន្លេដ៏ល្អផូរផង់ពីរ គឺទន្លេសរស្វតី និងទ្វសទ្វតី (ពួក បណ្ឌិត) ហៅថាព្រាហ្មាវាតៈ។

១៨- ទំនៀមទម្លាប់ ដែលបន្តអនុវត្តមកជាប្រចាំ(ចាប់តាំងពីយូរអង្វែងមកហើយ) ក្នុងចំណោមវណ្ណៈ (សំខាន់ បួន) និងពូជសាសន៍ចម្រុះក្នុងប្រទេសនោះ គេហៅថាក្រមប្រតិបត្តិសម្រាប់មនុស្សល្អ។

១៩- វាលរាបរបស់ពួកគុរុ (ដែនរបស់)ម័តស្យៈ, បញ្ចាលៈ និងសូរសេនកៈ តាមពិតទាំងអស់នេះ (បង្កើត) ដែនដីរបស់ព្រាហ្មសិ(ពួកព្រាហ្មណ៍បណ្ឌិតដែលមានឋានៈ) ជាប់ផ្ទាល់ពីព្រាហ្មាវាតៈ។

២០- ផ្ដើមចេញពីព្រាហ្មណ៍ចាប់កំណើតនៅលើដែនដីនោះ ញ៉ាំងឱ្យមនុស្សទាំងអស់នៅលើផែនដី រៀននូវទម្លាប់ជាច្រើនរបស់ពួកគេ។

២១- ដែនដី ដែលនៅចន្លោះភ្នំហិមព័តនិងភ្នំវិន្ធ្យៈ ដល់ខាងកើតប្រយាគៈ និងខាងលិចវិនសនៈ (ជាកន្លែងដែលផុតទន្លេសរស្វតិ) គេហៅថាមជ្ឈទេសៈ (ភូមិភាគកណ្ដាល)។

២២- ប៉ុន្តែ(តំបន់) នៅចន្លោះភ្នំទាំងពីរ(ជម្រាបជូនខាងលើ)នោះ ដែលលាតសន្ធឹងដល់សមុទ្រភាគ ខាងកើត និងសមុទ្រភាគខាងលិច ពួកបណ្ឌិតហៅថា *អារ្យាវតៈ* (ដែនដីរបស់ពួកអារ្យ័ន)។

---

១៥. ពាក្យ *អគ្និហូត្រ* នៅទីនេះ សំដៅដល់ការបូជាពីរយ៉ាង ទីមួយគឺជាការបូជានៅពេលព្រឹក និងការបូជាមួយទៀតនៅពេលល្ងាច។ សំនួនពាក្យ *សមយាធ្យុសិតេ* យោងតាមពាក្យសម្រាយរបស់កុល្ល. គឺ 'នៅពេលមិនឃើញពន្លឺព្រះអាទិត្យ មិនឃើញផ្កាយ' តែតាមលោកមេធ. បកស្រាយថា 'ពេលព្រលឹមអុល' (ឧសសះ កាលះ) ហើយតាមការបកស្រាយក្រោយមកទៀតរបស់លោកគោវ. ថា 'នៅពេលយប់ហៀបនឹងកន្លងផុតទៅ'។

១៦. *អ្នក*នៅទីនេះ សំដៅដល់បុរសវណ្ណៈអារ្យ័នចំនួនបី។ គេអាចធ្វើប្រសិទ្ធីឱ្យស្ត្រី និងពួកសូទ្រៈបានដែរ ប៉ុន្តែគ្មានការសូត្រមន្ត្រអ្វីទេ (ជំពូក ២ លេខ៦៦ និងជំពូក ១០ លេខ ១២៧)។

១៩. តំបន់នេះ ជាប់នឹងតំបន់ដូអាប ដែលនៅជិតនឹងដេលី រហូតដល់មថុរៈ រាជធានីសូរសេនកៈពីបុរាណ។

២១. កន្លែងដែលជាចុងបញ្ចប់នៃទន្លេសរស្វតី ជានិគមហិសារ, ប្រយាគៈ ពោលគឺអល្លហាបាដ។

២២. វស. ជំពូក ១ លេខ ៩ និង ពោធ. ជំពូក ១ លេខ២, ១០។

២៣- ដីណាដែលមានសត្វទោចខ្មៅ(ក្រៅ)ត្រាច់ចរជាធម្មតា គេត្រូវតែដឹងថា ជាកន្លែងដ៏សក្តិសម សម្រាប់ធ្វើពិធីយញ្ញ ហើយ(តំបន់)ផ្សេងពីនេះ (គឺជា)ដែនដីរបស់ពួកម្លេច្ឆៈ (មនុស្សព្រៃ)។

២៤- ចូរអ្នកដែលមានកំណើតពីរដង ស្វែងរកកន្លែងស្នាក់អាស្រ័យនៅក្នុង(តំបន់ដែលបានរៀបរាប់ខាងលើ) នោះ ប៉ុន្តែពួកសូទ្រៈ ដែលជួបគ្រោះអាសន្នក្នុងការចិញ្ចឹមជីវិត អាចស្នាក់នៅទីណាក៏បាន។

២៥- ដូច្នេះដើមកំណើតនៃច្បាប់ពិសិដ្ឋ ត្រូវបានរៀបរាប់សង្ខេបយ៉ាងច្បាស់ជូនលោកអ្នក និងដើមកំណើតនៃចក្រវាឡនេះ (ឥឡូវ)ចូររៀនអំពីករណីយកិច្ចសម្រាប់វណ្ណៈទាំងឡាយ។

២៦- ជាមួយនឹងពិធីដ៏ពិសិដ្ឋដែលមានចែងនៅក្នុងគម្ពីរវេទ អ្នកដែលមានកំណើតពីរដង ត្រូវតែប្រតិបត្តិ ពិធីនេះ តាមការយល់ឃើញ និងធ្វើពិធីប្រសិទ្ធីផ្សេងៗដើម្បីសង្គ្រោះរូបកាយ និងលាងនូវ(អំពើ បាប)នៅក្នុង(ជាតិ)នេះ និងជាតិក្រោយ។

២៧- ដោយការបូជាអគ្គីក្នុងអំឡុងមានគភ៌(របស់ម្ដាយ), ដោយគាតករម័ន (ពិធីក្រោយពេលសម្រាល កូន), ពិធី*ភោជ* (កោរសក់) និង*មោញ្ជីពន្ធនៈ* (ការចងរឹតដ៏ពិសិដ្ឋដោយស្មៅ*មុញ្ជ*) ជាដំណើរ ផលកម្ម ដែលកើតចេញពីមាតាបិតាទាំងពីរ ដែលជាមនុស្សមានកំណើតពីរដង។

២៨- ដោយការសិក្សាព្រះវេទ ដោយការតាំងសច្ចា ដោយការបូជាព្រះអគ្គី ដោយការ(សូត្រ)ធម៌ស័ក្តិសិទ្ធិ ដោយ(ការចេះ)វិទ្យាសាស្ត្រដ៏ពិសិដ្ឋដែលមានបីផ្នែក ដោយការបូជា(ថ្វាយព្រះអាទិទេព ឫសីនិងព្រលឹងដូនតា

ដោយ(ការបង្កើត)បុត្រដោយកម្លាំងមហាបូជា និងដោយពិធីសាសនា (ស្រោត) រាងកាយ(មនុស្ស)នេះ សក្តិសម(នឹងនៅជាមួយ)ព្រាហ្មណ៍។

---

២៣. វស. ជំពូក១ លេខ១៣-១៥, ពោធ. ជំពូក១ លេខ២, ១២-១៥, យញ្ញ. ជំពូក១ លេខ២។

២៥. លោកគោវ. ប្រែ ធម៌ 'ច្បាប់ពិសិដ្ឋ' ថាជា 'គុណធម៌ផ្នែកព្រលឹងវិញ្ញាណ'។

២៦-៣៥. គោត. ជំពូក៨ លេខ ១៤-២០, វិ. ជំពូក២៧ លេខ១-១២, យញ្ញ. ជំពូក១ លេខ ១០-១៣។

២៦. មេធ. ធ្វើការបកស្រាយផ្សេងចំពោះពាក្យដំបូងនេះថា 'ដោយមានពិធីដ៏ពិសិដ្ឋ ដែលមានភ្ជាប់ដោយសម្រង់អត្ថបទវេទ' ហើយលោកគោវ. គិតថា ពាក្យ 'វៃទិកៈ' អាចបកស្រាយបានក្នុងន័យទាំងពីរ។

២៧. ការបូជាអគ្គី ក្នុងអំឡុងពេលម្តាយមានគភ៌ គឺជា*ពុំសវណៈ, សីមន្តន្នយនៈ* ជាដើម; សូមមើលអាស្វ. គ្ឫហ្យសូត្រ ជំពូក ១ លេខ១៣-១៤។

២៨. 'ដោយការតាំងសច្ចា' គឺជា 'សច្ចារបស់អ្នកសិក្សា នៅពេលគេសិក្សាផ្នែកណាមួយនៃព្រះគម្ពីរវេទ ដូចជា*សាវិត្រីវ្រតៈ* (មេធ., គោវ., នារ.); 'ការបញ្ឈប់ដោយស្មគ្រចិត្ត ដូចជាការតមទឹកឃ្មុំ សាច់ជាដើម' (កុល្ល., រាឃ.; 'ការសច្ចា ដូចជាការធ្វើតបៈ*ប្រាគាបត្យ* (នន្ទ.)។ ឃ្លា 'ដោយការបូជាអគ្គី' សំដៅដល់ 'ការបូជានូវទេវហវត្ថុប្រចាំថ្ងៃ' (ជំពូក២ លេខ១០៨)។ ត្រៃវិទ្យេនៈ 'ដោយចេះនូវវិទ្យាសាស្ត្រពិសិដ្ឋ ដែលមានបីផ្នែក' គឺ'ដោយការសិក្សាអត្ថន័យនៃព្រះវេទចំនួនបី' (មេធ.,នន្ទ.); 'ដោយការតាំងសច្ចា ដើម្បីសិក្សាព្រះវេទទាំងបី ក្នុងអំឡុងពេល ៣៦ឆ្នាំ' (ជំពូក២ លេខ១; គោវ., កុល្ល., នារ., រាឃ.)។ *ឥឞ្យយា*ដោយការបូជាព្រះអាទិទេពឫសីនិងព្រលឹងដូនតា' គឺ តាមរយៈការធ្វើពិធី ដែលគេហៅថា *តាបនៈ* (មេធ., គោវ., នារ., រាឃ.), ឬ 'ដោយការធ្វើពិធីបាកយញ្ញ'(នារ., នន្ទ.)។ មេធ. ចាត់ទុកព្រាហ្មី 'សក្តិសមនឹងព្រាហ្មណ៍' ដើម្បីបញ្ជាក់ន័យ 'ដែលទាក់ទងនឹងព្រាហ្មណ៍' ប៉ុន្តែធ្វើឱ្យការបកស្រាយរបស់យើង ដែលអ្នកអធិប្បាយដទៃទាំងអស់ទទួលយកបានថាជាមតិយោបល់របស់ 'អ្នកដទៃ'។

២៩- មុននឹងកាត់ទងផ្ចិត គេត្រូវតែធ្វើគាតករម៉េន(ពិធីចាប់កំណើត) សម្រាប់(កូន)ប្រុស ហើយពេលប្រារព្ធពិធីត្រូវសូត្រធម៌ពិសិដ្ឋ ត្រូវផ្តល់អាហារមាស ទឹកឃ្មុំ និងប៊ឺដល់កូននោះ។

៣០- ប៉ុន្តែចូរ(ទុកឱ្យបិតាជាអ្នកធ្វើ ឬ) ផ្តើមហេតុរៀបចំពិធី*នាមធេយៈ* (ពិធីដាក់ឈ្មោះកូន) នៅថ្ងៃទី ១០ ឬ១២ (បន្ទាប់ពីថ្ងៃកើត) ឬនៅថ្ងៃដែលមានព្រះច័ន្ទដ៏មានជោគ ក្រោមដួងតារារះយ៉ាងត្រចះត្រចង់។

៣១- ចូរយក(ផ្នែកទី១នៃ)ឈ្មោះព្រាហ្មណ៍ (បញ្ជាក់នូវអ្វីមួយ)ជានក្ខត្តឫក្ស រីឈ្មោះរបស់ក្សត្រិយ ត្រូវមានទំនាក់ទំនងនឹងអំណាច ហើយឈ្មោះរបស់វៃស្យ ត្រូវជាប់ពាក់ព័ន្ធនឹងទ្រព្យធន តែឈ្មោះ របស់ពួកសូទ្រៈ (បង្ហាញនូវអ្វី) ដែលគួរស្អប់ខ្ពើម។

៣២- (ផ្នែកទី២នៃ)ឈ្មោះរបស់ព្រាហ្មណ៍ ត្រូវតែជា(ពាក្យ)ដែលបង្កប់នូវន័យសុភមង្គល ឈ្មោះរបស់ក្សត្រិយជា(ពាក្យ)ដែលបង្កប់នូវការការពារឈ្មោះរបស់វៃស្យ (ជាពាក្យ) ដែលបញ្ជាក់ពីការចម្រើនជឿនលឿន ហើយឈ្មោះរបស់ពួកសូទ្រៈ (ជាពាក្យ)ដែលបញ្ជាក់នូវការបម្រើ។

៣៣- ឈ្មោះរបស់ស្ត្រី ត្រូវតែងាយស្រួលអាន មិនបង្កប់នូវន័យគួរឱ្យខ្លាច មានន័យសាមញ្ញ បង្ហាញនូវភាពត្រេកត្រអាល និងនក្ខត្តឫក្ស បញ្ចប់ដោយស្រៈដែលមានខ្យល់វែង និងមានពាក្យការប្រសិទ្ធិពរជ័យ។

---

២៩. អាស្វ. គ្ឫហ្យសូត្រ ជំពូក១ លេខ១៥, ១; មានវ គ្រហ្យសូត្រ ជំពូក១ លេខ១៧, ១;បារស្ករ គ្ឫហ្យសូត្រ ជំពូក ១ លេខ១៦, ៤។ ថ្វីបើអត្ថបទនិយាយច្បាប់ថា កូនត្រូវផ្តល់អាហារមោស ទឹកឃ្មុំ និងប៊ឺក្តី ក៏វាមាននៅក្នុងគ្ឫហ្យសូត្រ ព្រមទាំងអ្នកអធិប្បាយខ្លះបញ្ជាក់ថា សារជាតុពីរចុងក្រោយប៉ុណ្ណោះ ទើបអាចផ្តល់ឱ្យកូនបាន ក្រោយពេលកូនបានប៉ះមាស ឬ ចិញ្ចៀនមាសក៏បាន។

៣០. អាស្វ. គ្ឫហ្យសូត្រ ជំពូក១ លេខ១៥, ៤-១០; បារស្ករ ជំពូក១ លេខ១៧, ១-៦។ នារ. និងនន្ទ. មានការសង្ស័យថា តើចំនួន 'ទី១០ ឬ១២'នោះ សំដៅដល់ថ្ងៃចន្ទគតិ ឬសុរិយគតិ ពីព្រោះពាក្យនេះ ជាឥត្ថីលិង្គ ហើយគេអាចថាជាពេល តិថិ (ពេលថ្ងៃ)ក៏បានឬពេលរាត្រី(ពេលយប់)ក៏បាន។ កុល្ល. ធ្វើការបកស្រាយផ្សេងអំពីកាលបរិច្ឆេទនេះថា 'បន្ទាប់ពីថ្ងៃទី១០ (ថ្ងៃចុងក្រោយនៃភាពមិនបរិសុទ្ធ នៅថ្ងៃទី១១ ឬទី១២' ដែលលោកមេធ. ក៏បាននិយាយដែរ តែបដិសេធ។ កុល្ល. គិតថា*វា* (ឬ)ទី៣ និងទី៤ ដែលនៅបន្ទាប់ពីពាក្យ *មហូត្រ* និង*នក្សត្រ* មានន័យ 'ទើបតែ' ហើយមិនបញ្ជាក់នូវជម្រើសទី៣ ទេ។

៣១-៣២. លោក K. លុប ៣១៦ និង ៣២a។ លោក នារ. និងរាឃ. គិតថា ផ្នែកទី២នៃឈ្មោះរបស់ព្រាហ្មណ៍ ត្រូវតែមាន ពាក្យ *សាម័ន* និងគ្មានពាក្យផ្សេងទេ ប៉ុន្តែមតិទូទៅរបស់អ្នកផ្សេងទៀតយល់ថា វាអាចជាពាក្យ *សាម័ន* ក៏បាន ឬពាក្យវេ វចនៈស័ព្ទផ្សេងៗក៏បាន ដែលបង្កប់នូវន័យ 'សុភមង្គល ឬទីអាស្រ័យ'។ លោកមេធ. ជំទាស់នឹងទស្សនៈខាងដើមទាំងស្រុង ហើយផ្តល់ឧទាហរណ៍អំពីការដាក់ឈ្មោះត្រឹមត្រូវ ដូចជាពាក្យ *ស្វាមិទត្ត, ភវភូតិ, ឥន្ទ្រស្វាមិន, ឥន្ទ្រាស្រមៈ, ឥន្ទ្រទត្ត* ជាដើម។

៣៣. លោកមេធ. មានយោបល់ដោយមិនកោតខ្លាច តែដោយប្រើហេតុផលថា រវាងពាក្យ 'ជោគល្អ' (មង្គល) និងពាក្យ 'ការប្រទានពរជ័យ' (អាសីវាទ) គ្មានភាពខុសគ្នាទេ ហើយថា ពាក្យចុងក្រោយ ត្រូវគេបន្ថែម ដោយគ្រាន់តែដើម្បីបង្គ្រប់ ឃ្លាកាព្យប៉ុណ្ណោះ។

៣៤- នៅក្នុងខែទី៤ គួរតែធ្វើពិធី*និស្ក្រមណៈ* សម្រាប់(ការចាកចេញពីផ្ទះលើកដំបូង)របស់ក្មេង នៅខែ ទី៦ គួរធ្វើពិធី*អន្នប្រាសនៈ* (ការផ្តល់អាហារជាតិបាយលើកដំបូង) ហើយតាមការស្ម័គ្រចិត្តអាច ធ្វើពិធីនាំគ្រោះល្អ (ផ្សេងៗទៀត) ដែលតម្រូវដោយ(ទំនៀមទម្លាប់)របស់គ្រួសារ។

៣៥- យោងតាមមេរៀននៃអត្ថបទបើកបង្ហាញអាថ៌កំបាំង គេត្រូវធ្វើពិធី*ចូឌាកម្ម័ន* (ពិធីកោរជុក) ដើម្បីទទួលបាន បុណ្យកុសលផ្នែកព្រលឹងវិញ្ញាណសម្រាប់អ្នកដែលមានកំណើតពីរដងទាំងអស់ នៅឆ្នាំទី១ ឬឆ្នាំទី៣។

៣៦- នៅឆ្នាំទី៨ បន្ទាប់ពីការចាប់កំណើត គេត្រូវតែធ្វើទទួលសមាជិកថ្មី (ឧបនាយន)របស់ព្រាហ្មណ៍ នៅឆ្នាំទី ១១ បន្ទាប់ពីចាប់កំណើត(ធ្វើពិធីនេះ)សម្រាប់ពួកក្សត្រិយ តែនៅឆ្នាំទី១២ សម្រាប់ពួក វៃស្យ។

៣៧- (ពិធីទទួលសមាជិកថ្មី)របស់ព្រាហ្មណ៍ ដែលចង់បានភាពស្ទាត់ជំនាញក្នុងការសិក្សាដ៏ពិសិដ្ឋ គួរតែធ្វើនៅ ឆ្នាំទី៥ (បន្ទាប់ពីចាប់កំណើត), (ពិធីនេះ)សម្រាប់ក្សត្រិយ ដែលចង់មានអំណាចខ្លាំង ធ្វើនៅឆ្នាំទី៦ (ហើយពិធីនេះ)សម្រាប់ពួកវៃស្យដែលចង់បាន(ជោគជ័យ)ក្នុងធុរកិច្ចរបស់ខ្លួន ធ្វើនៅឆ្នាំទី៨

៣៨- (ពេលវេលាសម្រាប់) ស្វាវិត្រី(ពិធីទទួលសមាជិកថ្មី)របស់ព្រាហ្មណ៍ មិនត្រូវឱ្យកន្លងផុតរហូត ដល់ផុតឆ្នាំ ទី១៦ (បន្ទាប់ពីកើត)ទេ សម្រាប់ក្សត្រិយរហូតដល់ផុតឆ្នាំទី២២ ហើយសម្រាប់ពួក វៃស្យ មិនត្រូវឱ្យឆ្នាំទី ២៤ទេ។

៣៩- បន្ទាប់ពី(អំឡុងពេលនោះ មនុស្សក្នុង)វណ្ណៈទាំងបី ដែលមិនបានទទួលពិធីប្រសិទ្ធីតាមកាលកំណត់ត្រឹមត្រូវ ក្លាយជាអ្នក *វ្រាត្យៈ* (មនុស្សក្រៅវណ្ណៈ) ដែលហាមមិនឱ្យចូលពិធីសាវិត្រី (ពិធីទទួលសមាជិកថ្មី) និងត្រូវពួកអារ្យ៉ងស្អប់ខ្ពើម។

---

៣៤. អាស្វ. គ្ឫហ្យសូត្រ ជំពូក១ លេខ ១៦; បារស្ករ ជំពូក១ លេខ ១៧, ៥, ១៩, ១-៦។ អនុប្រយោគចុងក្រោយ ដែល អនុញ្ញាតឱ្យធ្វើតាមទំនៀមទម្លាប់គ្រួសារនោះ បើតាមលោកមេធ., គោវ. និងកុល្ល.យល់ថា គឺពិធីប្រសិទ្ធី។

៣៥. អាស្វ. គ្ឫហ្យសូត្រ ជំពូក១ លេខ១៧, ១; បារស្ករ ជំពូក២ លេខ ១។ នារ. និងនន្ទ. បកស្រាយពាក្យ *ធម៌តះ* 'ដើម្បី បុណ្យកុសលផ្នែកព្រលឹងវិញ្ញាណ' ដោយ 'ស្របតាមច្បាប់គ្រួសារ' (មើលអាស្វ. គ្ឫហ្យសូត្រ ចំណុចដកស្រង់)។

៣៦-៣៧. អាប.ជំពូក១ លេខ១, ៥, ៨-២១; គោត. ជំពូក១ លេខ៥-១៤; វស.ជំពូក២ លេខ៣; ជំពូក១១ លេខ៤៩-៧៣; ពោធ. ជំពូក១ លេខ ៣, ៧-១២; វិ.ជំពូក២៧ លេខ ១៥-២៨; យាញ. ជំពូក១ លេខ១៤។

៣៧. ដូចអ្នកអធិប្បាយគូសបញ្ជាក់ស្រាប់ អ្នកដែលមានបំណងប្រាថ្នាដាក់លាក់ មិនមែនជាក្មេងប្រុសទេ តែជាបិតារបស់គេ។

៣៨-៤០. អាប. ជំពូក១ លេខ១, ២២-២, ១០; គោត. ជំពូក២១ លេខ ១១; វស. ជំពូក១១ លេខ៧៤-៧៩; ពោធ. ជំពូក១ លេខ១៦; វិ. ចំណុចដកស្រង់ និង ៥៤ លេខ២៦; យាញ. ជំពូក១ លេខ៣៧-៣៨។ 'អ្នកខ្លះ' ប្រើអាយតនិបាត *អា*ហេតុដល់' ហើយតាមលោកកុល្ល. ថា 'ហេតុដល់ដើម'។

៤០- ជាមួយនឹងមនុស្សបែបនេះ ប្រសិនបើពួកគេមិនត្រូវបានបន្សុទ្ធស្របតាមវិធានទេ លែងជាព្រាហ្មណ៍ ទៀតហើយ សូម្បីក្នុងគ្រាអាសន្ន បង្កើតទំនាក់ទំនងតាមរយៈព្រះវេទក៏បាន ឬតាមចំណងអាពាហ៍ ពិពាហ៍ក៏បាន។

៤១- ទុកឱ្យសិស្ស ស្របតាមលំដាប់(នៃវណ្ណៈរបស់ខ្លួន) ពាក់(សម្លៀកបំពាក់ផ្នែកខាងលើ)ស្បែកសត្វ ពណ៌ខ្មៅ ដូចជាស្បែកសត្វក្តាន់រមាំងអុចខ្មៅ និងស្បែកពពែ ហើយ(សម្លៀកបំពាក់ផ្នែកខាងក្រោយ) ធ្វើអំពីដើមក្រចៅ ធ្មៃ ឬរោមចៀម។

៤២- ខោទ្រនាប់របស់ព្រាហ្មណ៍ ត្រូវមានខ្សែបីនៃស្មៅ*មុញ្ជ* រលោង និងទន់; (ខោ)របស់ក្សត្រិយ មានខ្សែធ្នូដែលជាក្រណាត់ធ្វើអំពីសរសៃមុរ៉ា; (ខោ)របស់វៃស្យ ធ្វើអំពីអំបោះក្រចៅ។

៤៣- ប្រសិនបើគេមិនអាចរកបានស្មៅ*មុញ្ជ* (ជាដើម) (ខោរបីនេះ) អាចធ្វើពីសរសៃកុស, អស្មន្តក, និងបល្បគ ដោយមានចំណងបីផ្នត់ជាប់គ្នាតែមួយ ឬដោយមាន(ចំណង)បីឬប្រាំ ស្របតាមប្រពៃណីរបស់គ្រួសារ។

៤៤- ខ្សែសម្រាប់ពិធីបូជាយញ្ញរបស់ព្រាហ្មណ៍ត្រូវធ្វើអំពីសំឡី(ត្រូវ)គ្របាញ់ទៅខាងស្តាំ (ហើយមាន)បីសរសៃ ខ្សែរបស់ក្សត្រិយធ្វើអំពីអំបោះក្រចៅ (ហើយ)ខ្សែរបស់វៃស្យ ធ្វើអំពីអំបោះ រោមចៀម។

៤៥- ព្រាហ្មណ៍ត្រូវតែ(បដិបត្តិ)តាមច្បាប់ពិសិដ្ឋ កាន់ដំបង*ពិល្វ* ឬ*បឡាសៈ*; ក្សត្រិយកាន់ដំបង*វតៈ* ឬ*ខទិរៈ* (ហើយ)វៃស្យ កាន់*បិលុ*ឬ*ឧទុម្ពរ*។

៤៦- ដំបងរបស់ព្រាហ្មណ៍ ត្រូវតែធ្វើឱ្យមានប្រវែងស្មើនឹងចុងសក់របស់ខ្លួន ដំបងរបស់ក្សត្រិយ ត្រូវស្មើ នឹងថ្ងាសរបស់ខ្លួន (ហើយ)ដំបងរបស់វៃស្យ ស្មើនឹង(ចុង)ច្រមុះរបស់ខ្លួន។

៤៧- ចូរដាក់ដំបងទាំងអស់ឱ្យត្រង់ ដោយមិនឱ្យមានកំហុសឆ្គង ឱ្យមើលទៅស្អាត ហាក់ដូចមិនធ្វើឱ្យគេ ពិបាកភ្នែកមើល ដោយមានពណ៌ល្អផូរផង់ គ្មានស្នាមភ្លើងឆេះ។

---

៤០. 'ទំនាក់ទំនងតាមរយៈព្រះវេទ' គឺបង្រៀន ឬសិក្សាតាមព្រះវេទ គោរពបូជាព្រះវេទ ឬជ្រើសរើសព្រះវេទធ្វើជាគ្រូធំ ដោយទទួលអំណោយសាសនាពីវេទ ឬផ្តល់អំណោយដល់វេទ។ លោករាឃ. លុបកាព្យលេខ ៤០ចោល។

៤១. អាប. ជំពូក១ លេខ២, ៣៩-៣, ៩; គោត. ជំពូក១ លេខ ១៦, ២១; វស.ជំពូក ១១ លេខ៦១-៦៧; ពោធ. ជំពូក១ លេខ៣, ១៤; វិ. ជំពូក២៧ លេខ១៩-២០។ រាឃ. បកស្រាយពាក្យ *ll* 'សត្វរមាំងស្បែកអុជៗ' ថាជា 'សត្វខ្លា'។

៤២. អាប. ជំពូក១ លេខ២, ៣៣-៣៧; គោត. ជំពូក១ លេខ១៥; វស. ជំពូក១១ លេខ៥៨-៦០; ពោធ. ជំពូក១ លេខ៣, ១៣; វិ. ជំពូក២៧ លេខ១៨; យញ្ញ. ជំពូក១ លេខ២៩។ លោកមេធ. និងគោវ. គិតថា ខោរបីរបស់ពួកក្សត្រិយ មិនមានខ្សែបីផ្សេងគ្នា ដែលវិញចូលគ្នា ហើយលោកកុល្ល. មានយោបល់ដូចគ្នាទាំងស្រុង។ រាឃ. និងនារ. និយាយថា ខ្សែធ្នូតាមធម្មតា មានបីសរសៃ។

៤៣. 'ដោយខ្សែបីសរសៃវិញចូលគ្នាតែមួយ' ហាក់ដូចជាថា ខ្សែនីមួយៗខោរប ទី១គួរតែក្តួចបញ្ចូលគ្នា ហើយកំណួចខ្សែបីសរសៃ បន្ទាប់មកត្រូវវិញបញ្ចូលគ្នាជាផ្នុងមួយ។ ប៉ុន្តែ នារ. និងរាឃ. ចាត់ទុកពាក្យ *ត្រិវ្រិតា* 'ផ្នុងមួយខ្សែបីសរសៃ' ទៅវិញ ពោលគឺសំដៅទៅលើសរសៃខ្សែ។ ដូច្នេះ ពួកគេគាំទ្រការបកប្រែរបស់ Sir W. Jone ថា 'ក្នុងផ្នុងមួយ មានខ្សែបីសរសៃ'។

៤៤. អាប. ជំពូក២ លេខ ៤, ២២; គោត. ជំពូក១ លេខ៣៦; វស. ជំពូក១២ លេខ១៤; ពោធ.ជំពូក១ លេខ៥; វិស. ជំពូក២៧ លេខ១៩។

៤៥-៤៧. អាប.ជំពូក១ លេខ២, ៣៨; គោត. ជំពូក១ លេខ២២; វស. ជំពូក១១ លេខ៥២-៥៧; ពោធ.ជំពូក១ លេខ៣, ១៥; វិ. ជំពូក២៧ លេខ២២-២៤; យញ្ញ. ជំពូក១ លេខ២៩។

៤៨- បន្ទាប់ពីមានដំបងស្របតាមជម្រើសរបស់ខ្លួន បានគោរពដល់ព្រះអាទិត្យ និងដើរជុំវិញព្រះអគ្គី ដោយយកដៃស្តាំរបស់ខ្លួនទៅចាប់ដំបងរួច (កូនសិស្ស)គួរតែសុំទាន ស្របតាមវិធានបញ្ញត្តិ។

៤៩- ព្រាហ្មណ៍ដែលគេទទួលស្គាល់ជាសមាជិកថ្មី គួរតែសុំដោយចាប់ផ្តើម(ពាក្យសុំ)ញោមស្រី(ភវតិ); ក្សត្រិយ ដាក់(ពាក្យ)ស្ត្រីនៅកណ្តាល ប៉ុន្តែពួកវៃស្ស ដាក់ពាក្យស្ត្រីនៅខាងចុង(សេចក្តី)។

៥០- មុនដំបូងចូរឱ្យគេសុំអាហារពីម្តាយរបស់ខ្លួន ឬបងប្អូនស្រីរបស់ខ្លួន ឬម្តាយមីងបង្កើតរបស់ខ្លួន ឬ ពីស្ត្រី (ណាមួយ) ដែលនឹងមិនធ្វើឱ្យគេបាក់មុខ (ដោយការបដិសេធ)ក៏បាន។

៥១- បន្ទាប់ពីសុំបានអាហារច្រើនគ្រប់គ្រាន់(ពីមនុស្សជាច្រើន) និងបានប្រកាសថាគ្មានឧបាយកល បោកប្រាសគ្រូរបស់ខ្លួន ចូរឱ្យគេទទួលទានអាហារដោយបែរមុខរបស់គេទៅទិសខាងកើត ហើយបន្ទាប់មកទើបបន្សុទ្ធខ្លួនគេ ដោយការជិបទឹក។

៥២- (អាហាររបស់គេនឹងផ្តល់)នូវអាយុយឺនយូរ ប្រសិនបើគេទទួលទាន ដោយបែរមុខទៅខាងកើត, នាំមកនូវកិត្តិនាម បើគេបែរមុខទៅខាងត្បូង, នាំមកនូវវិបុលភាព បើគេបែរមុខទៅខាងលិច, នាំឱ្យមានភាពទៀងត្រង់ បើគេបែរមុខទៅកើត (គួរតែខាងជើង?)។

៥៣- ចូរឱ្យអ្នកដែលមានកំណើតពីរដង ទទួលទានអាហាររបស់ខ្លួនដោយចិត្តមូល បន្ទាប់មកធ្វើពិធី ជម្រះកាយ ហើយក្រោយពីគេបានទទួលទានអាហាររួច ចូរឱ្យសម្អាតខ្លួនដោយទឹកដោយខ្លួនឯង ដោយត្រឹមត្រូវ និងប្រោះទឹកទៅលើ(ក្បាលរបស់គេ)។

៥៤- ចូរឱ្យគេធ្វើសក្ការៈជានិច្ចចំពោះអាហាររបស់ខ្លួន ហើយទទួលទានវាដោយគ្មានការអាក់អន់ចិត្ត ពេលគេឃើញអាហារ សូមឱ្យគេរីករាយ បង្ហាញទឹកមុខពេញចិត្ត ហើយធ្វើអធិដ្ឋានថា គេតែងតែ អាចទទួលបានអាហារជានិច្ច។

៥៥- អាហារដែលគេត្រូវគោរពជានិច្ចនោះ ជួយផ្តល់កម្លាំងនិងភាពមាំមួនជាបុរស ប៉ុន្តែបើគេទទួល ទានដោយគ្មានការកោតក្រែង អាហារបំផ្លាញកត្តាទាំងពីរនេះទៅវិញ។

---

៤៨-៥៧. អាប. ជំពូក១ លេខ៣, ២៥-៤; គោត. ជំពូក២ លេខ៣៥-៤១; វស. ជំពូក១១ លេខ៦៨-៧០; ពោធ. ជំពូក១ លេខ៣, ១៦-១៨; វិ. ជំពូក២៧ លេខ២៥; យញ្ញ. ជំពូក១ លេខ៣០, ៥១-៥៧; អាប. ជំពូក១ លេខ២-៣; ៣, ១១; គោត. ជំពូក៩ លេខ ៥៩; វស. ជំពូក៣ លេខ៦៩; ជំពូក១២ លេខ១៨-២០; ពោធ. ជំពូក២ លេខ៥, ១៨, ២១-៦, ២; ១៣, ១២; វិ. ជំពូក៥៨ លេខ ៣៤-៣៥, ៤០-៤៤; យញ្ញ. ជំពូក១ លេខ២៧, ៣១, ១១២។

៥២. លោកមេធ. និងនារ. ធ្វើការបកស្រាយផ្សេងសម្រាប់ពាក្យ *រិតំ* 'ភាពទៀងត្រង់' ថាជា 'ពលិកម្ម'។

៥៣. ពាក្យ *និត្យំ* 'ជានិច្ចកាល' សបញ្ជាក់ថា វិធាននេះសំដៅដល់គ្រួសារផងដែរ (តាមលោកគោវ., កុល្លូ., នារ. នន្ទ.)។

៥៤. 'ធ្វើសក្ការៈ' គឺ 'ចាត់ទុកជាទេវភាព' (មេធ., គោវ., នន្ទ.) ឬ 'ការនៅអំពីការទទួលបានការចិញ្ចឹមជីវិត' (មេធ., គោវ., កុល្លូ.) ឬ 'សូត្រកំណាព្យសរសើរអាហារ' ឫគវេទ ជំពូក ១ លេខ ១៨៧, ១ (នារ.)។

៥៥. អ៊ូគំ 'ភាពមាំមួនជាបុរស' (គោវ., កុល្លូ.) ឬ 'ថាមពល' (នារ., នន្ទ.) ឬ 'មាឌ' (មេធ.)។

៥៦- ចូរគេកុំឱ្យនរណាមួយនូវអ្វីដែលគេបន្សល់នោះ ហើយចូរប្រយ័ត្នក្នុងការទទួលទានរវាង (អាហារ ទាំងពីរពេល) ចូរគេកុំទទួលទានហួសហេតុ និងកុំទៅកន្លែងមួយដោយមិនបានសម្អាតខ្លួនឯង (បន្ទាប់ពីទទួលទានអាហាររបស់ខ្លួន)។

៥៧- ការទទួលទានច្រើនហួសប្រមាណ នាំឱ្យអន្តរាយដល់សុខភាព កិត្តិនាម និងប៉ះពាល់ដល់(ដំណើរ ឡើង) ឋានសួគ៌ វាទប់ស្កាត់(ការទទួលបាននូវ)កុសលផ្នែកព្រលឹងវិញ្ញាណ និងញ៉ាំងឱ្យអ្នកផង មិនពេញចិត្តក្នុងហេតុផលទាំងអស់នេះ គេគួរតែប្រយ័ត្ន កុំទទួលទានអាហារហួសប្រមាណ។

៥៨- ចូរឱ្យព្រាហ្មណ៍ក្រេបទឹកចេញពីកំបង់ដៃ (ទីរថ) ដ៏ពិសិដ្ឋសម្រាប់ព្រាហ្មណ៍ជានិច្ច ឬចេញពីវត្ថុ ពិសិដ្ឋនេះសម្រាប់ *កា* (ប្រគាបតិ) ឬចេញពីវត្ថុពិសិដ្ឋ ដើម្បីព្រះអាទិទេព ហើយចូរកុំឱ្យចេញពី វត្ថុពិសិដ្ឋនេះ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធ។

៥៩- ពួកគេហៅ(ផ្នែក)គល់មេដៃ *ទីរថ* ជារបស់ពិសិដ្ឋសម្រាប់ព្រាហ្មណ៍ ថានៅគល់(កូន)ម្រាមដៃ គឺ ពិសិដ្ឋសម្រាប់ *កា* (ប្រគាបតិ) ថានៅចុង(ម្រាមដៃមេ *ទីរថ*) ជាវត្ថុពិសិដ្ឋសម្រាប់ព្រះអាទិទេព និងថានៅផ្នែកខាងក្រោម (ចន្លោះម្រាមចង្អុល និងមេដៃ *ទីរថ* នោះ) ជាវត្ថុពិសិដ្ឋសម្រាប់ឧទ្ទិសវិញ្ញាណក្ខន្ធ។

៦០- ទី១ ចូរឱ្យគេក្រេបទឹកបីដង បន្ទាប់មកជូតមាត់គេពីរដង ហើយចុងក្រោយយកដៃជ្រលក់ទឹក (ដាក់លើបង្ហើយក្បាល) (ជាអាសនៈនៃ)ព្រលឹង និងក្បាល។

៦១- គេដែលចេះដឹងច្បាប់ពិសិដ្ឋ និងស្វែងរកភាពបរិសុទ្ធ គួរតែធ្វើពិធីក្រេបទឹក មិនក្តៅ និងគ្មានពពុះ ដោយ *ទីរថ* (ដូចបានរៀបរាប់) នៅកន្លែងមួយដាច់ពីគេ ហើយបែរមុខទៅខាងកើត ឬបែរមុខ ទៅខាងជើង។

៦២- ព្រាហ្មណ៍ ត្រូវបន្សុទ្ធដោយទឹក ដែលជ្រាបចូលដល់បេះដូងរបស់គេ ក្សត្រិយបន្សុទ្ធដោយទឹក ដែលចូលដល់បំពង់-ក របស់គេ វៃស្យបន្សុទ្ធដោយទឹកដែលចូលដល់មាត់របស់គេ (ហើយ)សូទ្រៈ បន្សុទ្ធដោយទឹកដែលប៉ះត្រឹមបបូរមាត់របស់គេ។

---

**៥៦.**លោកមេធ. អាន *នាឡ្យាត អេត៌ត តថាន្តា* ហើយធ្វើការបកស្រាយពីរបែបទៀត ផ្សេងពីការបកប្រែនេះ គឺ ១-'ចូរកុំឱ្យគេទទួលទានអ្វី បន្ទាប់បញ្ឈប់ការទទួលទានរបស់គេ' ២-'ចូរកុំឱ្យគេដកដៃឆ្វេងរបស់គេចេញពីចាន'។ នន្ទ. អាន *នាឡ្យាក កៃត៌ត តថាន្តា* 'ហើយចូរកុំឱ្យគេទទួលទានសំណល់(អាហារសល់ពីអ្នកដទៃ)ក្នុងពេលទទួលទាន'។

**៥៨-៦២.** អាប. ជំពូក១ លេខ ១៥, ១-១៦; វស. ជំពូក៣ លេខ ២៦-៣៤; ពោធ. ជំពូក១ លេខ៨, ១២-២៣; វិ. ជំពូក ៦២ លេខ ១-៩; យញ្ញ. ជំពូក១ លេខ១៨-២១។

**៥៨.**ថ្វីត្បិតតែអត្ថបទនិយាយអំពីព្រាហ្មណ៍តែម្យ៉ាងក៏ដោយ ក៏វិធាននេះ តាមកំណត់សម្គាល់របស់អ្នកអធិប្បាយ សំដៅដល់ពួកអារ្យ័នផងដែរ។

**៥៩.***អង្គុលិមូលេ* 'នៅខាងដើមម្រាមកូនដៃ' (កុល្លូ., នារ., រាឃ.) បើតាម មេធ. និង នន្ទ. យល់ថា 'នៅគល់ម្រាមដៃ'។

**៦០.**'(អាសនៈនៃ)ព្រលឹង' គឺ 'បេះដូង' (ទាំងអស់គ្នាយល់ដូច្នេះ លើកលែងលោកមេធ. ដែលបន្ថែមថា 'ឬផ្ចិត')។

**៦១.**'មិនក្តៅ' ពោលគឺ 'មិនដាំ ឬដាក់ឱ្យក្តៅលើភ្លើងទេ' (មេធ., គោវ., កុល្លូ., នារ., នន្ទ.)។

៦៣- គេហៅអ្នកដែលមានកំណើតពីរដងថា *ឧបវីតិន* នៅពេលដៃស្តាំរបស់គាត់ត្រូវលើកឡើង (ហើយ ខ្សែយញ្ញ ឬអំបោះសីមាដែលរត់ខាងក្រោមដៃទៅស្ថិតលើស្មាខាងឆ្វេង); (ពេលដៃ)ឆ្វេងត្រូវលើកឡើង (ហើយខ្សែ ឬអំបោះសីមាដែលរត់ខាងក្រោមដៃទៅស្ថិតនៅលើស្មាស្តាំ គេហៅគាត់ថា) *ប្រាកីនាវីតិន* និង *និវីតិន* នៅពេលដៃទម្លាក់ចុះ(ត្រង់)ពី ក មក។

៦៤- ខោរឹបរបស់គេ ស្បែក (ដែលធ្វើជាសម្លៀកបំពាក់ខាងលើរបស់គេ) ដំបងរបស់គេ អំពោះពិធីរបស់គេ (និង) កំសៀវទឹករបស់គេ គេត្រូវតែបោះចូលក្នុងទឹក នៅពេលរបស់ទាំងនោះខូច ហើយយក របស់ផ្សេង ដែលបានមកពីការរៀបចំពិធីពិសិដ្ឋ។

៦៥- (គេហៅពិធី) *កេសាន្ត* (កាត់សក់) ត្រូវបំបួសព្រាហ្មណ៍ក្នុងអាយុ១៦ឆ្នាំ (ចាប់ពីការចាប់កំណើត) សម្រាប់ក្សត្រិយ ក្នុងអាយុ ២២ឆ្នាំ ហើយសម្រាប់វៃស្ស ក្នុងអាយុពីរ (ឆ្នាំ) ច្រើនជាង អាយុក្សត្រិយ។

៦៦- ដំណើរទាំងមូល(នៃពិធី)នេះ គេត្រូវធ្វើសម្រាប់ស្ត្រីផងដែរ ដើម្បីសង្គ្រោះរូបកាយ តាមពេលវេលា សមស្រប និងតាមលំដាប់សមស្រប ប៉ុន្តែដោយគ្មាន(ការសូត្រធម៌)ពិសិដ្ឋអ្វីទេ។

៦៧- ពិធីអាពាហ៍ពិពាហ៍ មាននិយាយថាជាពិធីវេទបែបប្រសិទ្ធីឱ្យស្ត្រី (ហើយស្មើគ្នានឹងពិធីទទួលសមាជិកថ្មី) ដែលបម្រើស្វាមី (ដែលប្រៀបដូចជា)ការស្នាក់អាស្រ័យក្នុង(ផ្ទះរបស់)គ្រូ និង កាតព្វកិច្ចគ្រួសារ (ដូចគ្នា)នឹងការគោរពព្រះអគ្គីប្រចាំថ្ងៃ។

៦៨- ដូចនេះវិធានត្រូវបានកំណត់សម្រាប់ការទទួលអ្នកកើតពីរដង ដែលបង្ហាញពីកំណើត(ថ្មី) និងធ្វើតាមបញ្ញត្តិសាសនា (ពេលនេះ)រៀននូវករណីយកិច្ច ដែលពួកគេត្រូវគោរពតាមដោយខ្លួនឯង។

៦៩- បន្ទាប់ពីបានធ្វើ(ពិធី)ទទួលសមាជិកថ្មី គ្រូត្រូវតែទី១ ប្រៀនប្រដៅ(សិស្ស) អំពីវិធានសម្រាប់បន្សុទ្ធខ្លួន អំពីការប្រព្រឹត្ត អំពីការបូជាព្រះអគ្គី និងអំពីការធ្វើអធិដ្ឋានពេលព្រះអាទិត្យលិច។

---

**៦៣.** ពោធ. ជំពូក១ លេខ៨, ៥-១០។

**៦៤.**ពោធ. ជំពូក១ លេខ៦, ៧; វិ. ជំពូក២៧ លេខ២៩។

**៦៥.** យញ្ញ. ជំពូក១ លេខ៣៦។ នេះជាពិធី ដែលគេហៅថា *គោទាន:* ; អាស្វ. គ្រួហ្យសូត្រ ជំពូក១ លេខ១៨; បារស្ករ ជំពូក២ លេខ១, ៣-៧។

**៦៦-៦៧.** អាស្វ. គ្រួហ្យសូត្រ ជំពូក១ លេខ១៦, ១៦; វិ. ជំពូក២៧ លេខ១៣-១៤; យញ្ញ. ជំពូក១ លេខ១៣។ 'ពិធីប្រសិទ្ធីព្រះវេទ' គឺ 'ពិធីសូត្រអត្ថបទពិសិដ្ឋ' (តាមនន្ទ., រាឃ.) ឬ 'ដែលមានកម្មវត្ថុសិក្សាអត្ថបទព្រះវេទ' (មេធ.,នារ.)។ ដូចនេះគេមិនចាំបាច់ធ្វើពិធីទទួលស្ត្រីជាសមាជិកថ្មីទេ។ តាមសេចក្ដីដូចគ្នានៃអាស្វ. បង្ហាញពីដំណើរការពិធី គឺគេធ្វើតែធ្វើពិធីកោរសក់តែម្យ៉ាង។

**៦៨.**'ដែលសបញ្ជាក់ពីកំណើត(ពិត)របស់ពួកគេ ពីព្រោះមនុស្ស ដែលមិនបានធ្វើពិធីនេះ គឺស្មើនឹងអ្នកដែលមិនបានចាប់កំណើត' (មេធ., គោវ.)។

**៦៩-៧៣.** គោត. ជំពូក១ លេខ៤៦-៥៦; វិ. ជំពូក៣០ លេខ៣២; យញ្ញ. ជំពូក១ លេខ១៥, ២៧។

៧០- ប៉ុន្តែ(សិស្ស) ដែលហៀបនឹងចាប់ផ្តើមការសិក្សា(ព្រះវេទ) គួរតែទទួលបានការអប់រំ បន្ទាប់ពីគេ បានក្រេបទឹក ស្របតាមគោលការណ៍(ច្បាប់ពិសិដ្ឋ) កូនសិស្សព្រាហ្មណ៍បានស្លៀកពាក់ស្អាតបាត និងបានគ្រប់គ្រងអវយវៈរបស់ខ្លួនយ៉ាងសមគួរ។

៧១- នៅពេលចាប់ផ្តើម និងពេលបញ្ចប់(មេរៀននៅក្នុង)ព្រះវេទ គេត្រូវតែឱនក្តោបជើង ទាំងពីររបស់ គ្រូខ្លួនជានិច្ច (ហើយ)គេត្រូវតែសិក្សាដោយក្តោបដៃចូលគ្នា នោះទើបគេហៅថាកូនសិស្ស ព្រាហ្មណ៍ (សំពះចំពោះព្រះវេទ)។

៧២- គេត្រូវតែដាក់ដៃខ្វែងគ្នាទៅលើ(ជើង)របស់គ្រូ និងប៉ះ(ជើង)ឆ្វេង ដោយដៃឆ្វេងរបស់ខ្លួន ប៉ះ(ជើង)ស្តាំដោយដៃស្តាំរបស់ខ្លួន។

៧៣- ប៉ុន្តែសម្រាប់កូនព្រាហ្មណ៍ ដែលហៀបនឹងចាប់ផ្តើមការសិក្សា គ្រូដោយគ្មានការនឿយហត់ ត្រូវ និយាយថាៈ ឱ ចូរសូត្រទៅ! គេគួរតែឈប់ (ពេលគ្រូនិយាយ)ថាៈ ចូរឈប់ទៅ!។

៧៤- ចូរឱ្យគេសូត្រពាក្យ ឱម ជានិច្ច នៅពេលចាប់ផ្តើមនិងពេលបញ្ចប់(មេរៀន)ព្រះវេទ (ព្រោះ) បើមិនសូត្រពាក្យ ឱមជាមុនទេ (មេរៀន)នឹងចេញឆ្ងាយពី(រូបគេ) ហើយបើមិនធ្វើតាមទេ មេរៀន នឹងគ្មានន័យអ្វីទេ។

៧៥- ដោយអង្គុយលើ(ស្លឹកស្មៅ*កុសៈ*) ដោយដាក់ចុងស្មៅទៅខាងកើត ត្រូវបន្សុទ្ធដោយ*បវិត្រ* (ស្លឹក ស្មៅ*កុសៈ*) ហើយក្រោយពីបានធ្វើពិធីសាសនា ដោយទប់ដង្ហើមបីដង(ប្រាណាយាម)គេគួរ(សូត្រ)ពាក្យ ឱម។

៧៦- ប្រជាបតិ (ព្រះនៃសព្វសត្វ) ដែលបានប្រទាន(ដាក់ស្តែង)នូវព្រះវេទបី ដែលមានសំឡេង *អេ ឧ* និង *អិម* (A, U និង M)និង(វ្យាហ្ឫតិៈ) *ភូ, ភូវៈ, ស្វៈ*។

---

**៧០.** *លាឃុវ៉ាសា* 'បានស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត' (មេធ., កុល្លូ.) ឬ 'សម្លៀកបំពាក់ ដែលមិនឆើតឆាយ' (គោវ., នារ., នន្ទ.) ពោលគឺ ដែលមានតម្លៃទាបជាងសម្លៀកបំពាក់របស់គ្រូ(រាឃ.)។

**៧១-៧២.** អាប. ជំពូក១ លេខ៥, ១៩-២៣; ពោធ. ជំពូក១ លេខ៣, ២៨; វិ. ជំពូក២៧ លេខ ១៤-១៦។

**៧៣.** នារ. និងនន្ទ. អាន *អឡេស្យមាណា តុ គុរុំ* 'ប៉ុន្តែសិស្ស ដែលមានបំណងចង់សិក្សា គួរនិយាយទៅកាន់គ្រូរបស់ខ្លួនថា លោកម្ចាស់ជាទីគោរព ហើយសូត្រមេរៀន' ចំណុចនេះស្របគ្នានឹងគោត. ជំពូក១ លេខ៤៦។ នារ.ក៏បញ្ជាក់ពីការអាន ដែលបានបកប្រែខាងលើ ដែលអ្នកអធិប្បាយផ្សេងទៀតធ្វើការបកស្រាយដែរ។

**៧៤.** អាប. ជំពូក១ លេខ១៣, ៦-៧; គោត. ជំពូក១ លេខ៥៧; វិ. ជំពូក៣០ លេខ៣៣។ លោកកុល្លូ. ប្រែពាក្យ *វិសីរ្យត្រេ* ថា 'នឹងអសារឥតការ' ស្របគ្នានឹងលោកមេធ. ដែលថា 'នឹងឥតប្រយោជន៍ចំពោះបំណងដាក់ស្តែង' ហើយយោងតាម គោវ. និងនារ. ថា 'នឹងមិនយល់មេរៀនបានត្រឹមត្រូវក្នុងពេលសិក្សាទេ'។ មេធ. បន្ថែមថា ពាក្យស័ព្ទពីរនេះ ជាពាក្យឧបមា ដែលដូចជាការចំអិនទឹកដោះ និងថា គេក៏និយាយអំពី *វិសរណៈ* គឺការធ្វើឱ្យខូចទឹកដោះចំអិន។

**៧៥.** គោត. ជំពូក១ លេខ៤៨-៥០; យញ្ញ. ជំពូក១ លេខ២៣។ ឃ្លា 'ដែលបន្សុទ្ធដោយ*បវិត្រ*' គឺ 'ដោយបានប៉ះនឹងទីតាំងខ្យល់ជីវិត ដោយស្លឹកស្មៅ*កុសៈ*(មេធ., គោវ., នារ.); សូមមើលគោត. ជំពូក១ លេខ៤៨។ មេធ. បញ្ជាក់ការបកស្រាយម្យ៉ាងទៀតអំពីពាក្យ *បវិត្រ* ដែលលោកនន្ទ.យល់ស្របដែរថា 'អត្ថបទសម្រាប់បន្សុទ្ធ'។ បើនិយាយពីពាក្យ 'ការទប់ដង្ហើប' សូមមើលវស. ជំពូក២៥ លេខ១៣; វិ. ជំពូក៥៥ លេខ៩។

**៧៦.** វិ. ជំពូក៥៥ លេខ១០។

៧៧- ជាងនេះទៀតផ្ដើមចេញពីព្រះវេទបី ប្រគាបតិ ដែលតាំងនៅឯឋានសួគ៌ដ៏ខ្ពស់បំផុត(*បរមេស្ថិន*) ដែលបានប្រទាន (ដាក់ស្ដែង) នូវកំណាព្យ *ឫក* ដ៏ពិសិដ្ឋចំពោះ*សាវិត្រ* (សាវិត្រី)ដែលចាប់ផ្ដើម ដោយពាក្យ *តទ៍* មួយជំហានម្ដង។

៧៨- ព្រាហ្មណ៍ដែលសិក្សាព្រះវេទ ដែលសូត្រពាក្យនោះទាំងពេលយប់ និង(កំណាព្យ)នោះ ដែលផ្ដើម ដោយ *វ្យាហ្វតិះ* ទទួលបានបុណ្យកុសល(ទាំងស្រុង) ដែលបានពី(ការសូត្រ)ព្រះវេទ។

៧៩- អ្នកមានកំណើតពីរដង ដែល(រាល់ថ្ងៃ)សូត្រដដែលៗនូវពាក្យទាំងបីនោះ ចំនួនមួយពាន់ដងនៅ ខាងក្រៅ(ភូមិ)បន្ទាប់ពីរយៈពេលមួយខែ នឹងត្រូវបានទទួលសេរីភាព សូម្បីមានទោសធ្ងន់ធ្ងរក្ដី ប្រៀបដូចជាពស់ចេញផុតពីសំណក។

៨០- ព្រាហ្មណ៍ ក្សត្រិយ និងវៃស្យ ដែលមិនយកចិត្តទុកដាក់(សូត្រ)កំណាព្យឫកនោះ និងការធ្វើពិធី តាមពេលកំណត់(សម្រាប់)ពួកគេទេ នឹងត្រូវអ្នកមានគុណធម៌ធ្វើការតិះដៀល។

៨១- ចូរដឹងថា *មហាវ្យាហ្វតិ* ដ៏មិនចេះសាបសូន្យទាំងបី ដែលនាំមុខដោយពាក្យ ឱម និង(បន្ត)ដោយ *សាវិត្រី* ដែលមានឫសបីជាខ្លោងទ្វារនៃព្រះវេទនិងជាទ្វារឆ្ពោះ(ទៅភ្ជាប់សម្ព័ន្ធជាមួយ)ព្រះព្រហ្ម។

៨២- អ្នកដែលរាល់ថ្ងៃ សូត្រនូវ(កំណាព្យ)នោះ ដោយមិនចេះនឿយហត់ ក្នុងអំឡុងពេលបីឆ្នាំ នឹងចូលទៅកាន់(ក្រោយពេលស្លាប់)ឋានព្រហ្មថ្នាក់ខ្ពស់បំផុត មានដំណើរដោយសេរីហាក់បីដូចជា ខ្យល់ និងឧបមាដូចជាអាកាសវេហា។

៨៣- ឯកព្យាង្គ(ឱម)នេះ ជាព្រហ្មខ្ពស់បំផុត ការទប់ដង្ហើម(បីដង) ជា(ទម្រង់)ប្រសើរបំផុតក្នុងការធ្វើ តបះ ប៉ុន្តែគ្មានអ្វីប្រសើរជាង*សាវិត្រី*ទេ គឺ សច្ចភាពប្រសើរជាងសេចក្ដីស្ងប់។

៨៤- ពិធីទាំងអស់ ដែលបញ្ញត្តិនៅក្នុងព្រះវេទ ការដុតបូជា និងពិធីយញ្ញ(ផ្សេងៗទៀត) នឹងអន្តរធានទៅ ប៉ុន្តែចូរដឹងថា ពាក្យ (ឱម) នឹងមិនសាបសូន្យទេ ហើយ(វាជា)ព្រហ្ម (និង)ព្រះនៃសព្វសត្វ (ប្រគាបតិ)។

---

**៧៧**.វិ. ជំពូក៥៥ លេខ១១១។ សាវិត្រី គឺជាកាព្យ *តត៍ សវិតុរ វរេណ្យំ* ក្នុងគម្ពីរ ឫគវេទ ជំពូក៣ លេខ៦២, ១០។

**៧៨**. វិ. ជំពូក៥៥ លេខ១១២; ពោធ. ជំពូក២ លេខ១១, ៦។

**៧៩**. វិ. ជំពូក៥៥ លេខ១១៣; ពោធ. ជំពូក៤ លេខ១, ២៩; វស. ជំពូក២៦ លេខ៤។

**៨០**. វិ. ជំពូក៥៥ លេខ១១៤។

**៨១**.វិ. ជំពូក៥៥ លេខ១១៥។ *ព្រហ្មណោ មុខំ* ន័យត្រង់ គឺ 'មាត់របស់ព្រហ្ម' ទំនងជាមានបង្កប់ពីរយ៉ាង នៅក្នុងការបកប្រែ។ លោកមេធ. កុល្លូ. និងរាឃ. ធ្វើការប្រែក្នុងន័យពីរនេះ ចំណែកឯលោកគោវ., នារ. និងនន្ទ. បកស្រាយពាក្យនេះ ក្នុងន័យតែ 'ការចាប់ផ្ដើម ឬខ្លោងទ្វារនៃព្រះវេទ' សូមមើលអាប. ជំពូក១ លេខ១៣, ៦ ផង។

**៨២**.វិ. ជំពូក៥៥ លេខ ១៦។ ៨៣. វិ. ជំពូក៥៥ លេខ១៧។

**៨៤**. វិ. ជំពូក៥៦ លេខ១៨។ 'កន្លងផុតទៅ' គឺ 'នៅបានយូរនៅមានគេគិតពីលទ្ធផលរបស់វា' (មេធ., គោវ., កុល្លូ., នារ.) 'នៅរហូតដល់រូប និងលទ្ធផលរបស់វា នៅមានគេគិតគូរ' (តាមនន្ទ.)។ ពិធីយញ្ញ នាំមកនូវតែពរជ័យឋានសួគ៌ ដែលមិនឋិតថេរ ចំណែកឯការសូត្រ ឱម ជាប្រចាំ ជួយភ្ជាប់សម្ព័ន្ធភាពជាមួយនឹងឋានព្រហ្ម។ យោងតាមមេធ., គោវ., កុល្លូ. និង រាឃ. ថា ព្រហ្មនៅទីនេះ គឺជាអលិង្គ ហើយតាមនារ. និងនន្ទ. ថាជា បុំលិង្គ។ ពាក្យ'និង (វាជា) ព្រហ្ម (និង) ប្រគាបតិ' (មេធ., គោវ., នារ., រាឃ.) ត្រូវកុល្លូ.ប្រែ'ដោយសារវាជាព្រហ្ម និងប្រគាបតិ' ដោយនន្ទ.ថា 'ហាក់ដូចជាព្រហ្ម ព្រះនៃសត្វលោក'។

៨៥- ការបូជា ដែលមានអ្នកសូត្រហឹមៗ មានភាពសក្តិសិទ្ធិដប់ដងច្រើនជាងពិធីយញ្ញ ដែលធ្វើតាមវិធាន(នៃព្រះវេទ) (អ្នកសូត្រ) ដែលមិនឮដល់(អ្នកដទៃ) បានផលលើសមួយរយដង ហើយចិត្ត(សូត្រធម៌ពិសិដ្ឋ) បានផលមួយពាន់ដង។

៨៦- *បាកយញ្ញ* បួន និងពិធីយញ្ញទាំងអស់ ដែលត្រូវបង្គាប់ដោយវិធាន(នៃព្រះវេទ) រួមបញ្ចូលគ្នាទាំង អស់ មិនមានតម្លៃស្មើមួយភាគដប់ប្រាំមួយនៃពិធីយញ្ញសូត្រធម៌ខ្សឹបៗនោះទេ។

៨៧- ប៉ុន្តែដោយគ្មានការសង្ស័យទេថា ព្រាហ្មណ៍ សម្រេចបានគោលដៅខ្ពស់បំផុត ដោយការសូត្រធម៌ ប៉ុណ្ណោះ (ទោះបី)គេធ្វើ(ពិធី)ផ្សេងក្តី ឬមិនធ្វើក្តី ក៏អ្នកដែលជាមិត្ត(សព្វសត្វទាំងអស់) ត្រូវគេ ចាត់ទុកជាព្រាហ្មណ៍(ពិត)។

៨៨- ជនមានគតិបណ្ឌិតគួរព្យាយាមទប់ស្កាត់អវយវៈ(ឥន្ទ្រីយ៍)របស់ខ្លួន ដែលចាកគន្លងធម៌ គ្មានវិន័យ ដោយលង់ក្នុងគ្រឿងវិញ្ញាណ ដូចជាអ្នកបររាជរថ បណ្តោយតាមការអូសទាញរបស់ពាជីនៃខ្លួន។

៨៩- អវយវៈទាំងដប់មួយ ដែលបណ្ឌិតពីដើមបានឱ្យឈ្មោះ ខ្ញុំនឹងរៀបរាប់ដោយផ្ទាល់ (និង)ដោយដាក់លាក់តាមលំដាប់លំដោយ គឺ:

៩០- (មានដូចជា) ត្រចៀក កាយ(ស្បែក) ភ្នែក អណ្តាត និងច្រមុះជាឥន្ទ្រីយ៍ទី៥, រន្ធគូថ ជាអវយវៈ បន្តពូជ, ដៃ និងជើង និង(គ្រឿងសម្រាប់)និយាយ ជាអវយវៈទី១០។

៩១- អវយវៈ ៥ក្នុងចំណោមអវយវៈទាំងឡាយ ត្រចៀក និងគ្រឿងវិញ្ញាណផ្សេងទៀត តាមលំដាប់របស់វា គេហៅថាជាគ្រឿងវិញ្ញាណ ហើយអវយវៈ ៥ក្នុងចំណោមអវយវៈទាំងនោះ មានអវយវៈបន្តពូជ និងអវយវៈផ្សេងទៀត ជាអវយវៈធ្វើអំពើ។

៩២- ចូរដឹងថា អវយវៈខាងក្នុង(មនៈ) ជាអវយវៈទី១១ ដែលមានលក្ខណៈសម្បត្តិសម្រាប់ទាំងពីរខាង ពេលដែលអវយវៈទី១១ ត្រូវបានបង្ក្រាប គ្រឿងវិញ្ញាណទាំង៥ បានទទួលជោគជ័យ។

---

**៨៥.**វិ ជំពូក៥៦ លេខ១៩; វស. ជំពូក២៦ លេខ៩។ តាមពិត ពាក្យពិសិដ្ឋ សំដៅដល់ ឱម, វ្យាហ្រ្ឫតិ និង គាយត្រី។

**៨៦.**វិ. ជំពូក៥៦ លេខ២០; វស. ជំពូក២៦ លេខ១០។ 'បាកយញ្ញ' គឺ 'មហាពិធីយញ្ញ ដែលគេហៅថាជាពិធីសម្រាប់ព្រះអាទិទេព បុព្វបុរស ម្រេញគង្វាល និងមនុស្ស(ជំពូក៣ លេខ៧០) ដែលមិនរាប់បញ្ចូលព្រហ្មយញ្ញទេ' (មេធ., កុល្លូ., នារ., នន្ទ.)។ គោវ. និង រាឃ. យល់ថា ពាក្យនេះ គឺសបញ្ជាក់អំពី 'ពិធីស្មាតៈ និងស្រោតៈទាំងអស់' សូមមើល Jolly ស្តីពី ព្រះវិស្ណុ សម្រង់ដដែល។

**៨៧.**វិ. ជំពូក៥៦ លេខ២១; វស. ជំពូក២៦ លេខ១១។ មៃត្រៈ 'អ្នកដែលជាមិត្តនឹង(សព្វសត្វទាំងអស់)' គឺ 'មិនមែនជាការធ្វើពិធីបូជាដល់សត្វនោះទេ'។ លោក រាឃ. ក៏បានធ្វើការបកស្រាយថា 'អ្នកដែលគោរពមិត្រ ព្រះអាទិត្យជាដើម'។ ព្រាហ្មណៈ 'ព្រាហ្មណ៍(ពិត)' គឺ 'អ្នកដែលមានទំនាក់ទំនងជាមួយព្រហ្ម''អ្នកដែលជោគជាំដោយធាតុព្រហ្ម' (កុល្លូ.);' ភាព ល្អប្រសើរបំផុតរបស់ព្រាហ្មណ៍ (លោករាឃ. ថាជា *ព្រហ្មិស្ថៈ*)។ មេធ. និង គោវ. ប្រែប្រយោគចុងក្រោយ ផ្សេង ទៅវិញថា '(ព្រះគម្ពីរវេទ) ប្រកាសថា ព្រាហ្មណ៍ (គួរជា) មិត្រសំឡាញ់ (នៃសព្វសត្វទាំងអស់)'។

**៩២.**'ដោយគុណសម្បត្តិរបស់វា' ពោលគឺ ដោយគុណសម្បត្តិ ដែលហៅថា *សង្កល្បៈ* ជាអំណាចកំណត់ ឬបង្កើតការទាក់ទាញវិញ្ញាណ។

៩៣- តាមរយៈការជាប់ជំពាក់គ្រឿងវិញ្ញាណរបស់ខ្លួន(ទៅនឹងចំណង់ត្រេកត្រអាល) មនុស្សប្រាកដជា នឹងប្រព្រឹត្តនូវកំហុស ប៉ុន្តែប្រសិនបើគេគ្រប់គ្រងគ្រឿងវិញ្ញាណនោះបានទាំងស្រុង គេពិតជានឹង ទទួលបានជោគជ័យ (អ្វីៗស្ថិតក្នុងដៃរបស់ខ្លួន)។

៩៤- ចំណង់ មិនអាចរម្ងាប់ ដោយការត្រេកត្រអាលនៃវត្ថុចំណង់នោះទេ វាមានតែចម្រើនខ្លាំងឡើង ដូចជាភ្លើង (ដែលឆេះកាន់តែខ្លាំង)ដោយការបន្ថែមប្រេងសាំងកាន់តែច្រើន។

៩៥- ប្រសិនបើមនុស្សម្នាក់ត្រូវបាននូវ (ការត្រេកត្រអាលផ្លូវកាម) ទាំងអស់នោះ ហើយមនុស្សម្នាក់ ទៀតត្រូវរួចផុតកាមតម្រេកទាំងអស់នោះការរួចផុតចំណង់ត្រេកត្រអាលទាំងអស់ល្អប្រសើរ ច្រើន ជាងការទទួលបាននូវកាមតម្រេកនោះទៅទៀត។

៩៦- (គ្រឿងវិញ្ញាណ) ទាំងឡាយ ដែលតោងស្អិតខ្លាំងទៅនឹងកាមតម្រេក មិនអាចកាត់បន្ថយបានជា ដាច់ខាតដោយការចេះប្រមាណ (នឹងចំណងរីករាយ) ឱ្យដូចជាការទប់ស្កាត់ដោយ (ការស្វែងរកនូវ) ចំណេះដឹងពិតទេ។

៩៧- មិនមែន(ការសិក្សា)ព្រះវេទ មិនមែនការរួចរំដោះ មិនមែនពិធីបូជាយញ្ញ មិនមែនការទប់ចិត្ត (ដោយខ្លួនឯង) មិនមែនការធ្វើតបៈ សុទ្ធតែផ្តល់នូវ(រង្វាន់) ដល់មនុស្សដែលមានបេះដូងមិនស្អាត (ប្រឡាក់ដោយចំណង់ត្រេកត្រអាល)ទេ។

៩៨- អ្នកនោះ អាចបានជ័យជម្នះ(បានពិតប្រាកដ)លើគ្រឿងវិញ្ញាណរបស់ខ្លួននៅពេលស្តាប់ និងប៉ះកាយសម្ផស្ស(ផស្សៈ) ហើយការឃើញនិងប៉ះក្លិន(អ្វីក៏ដោយ) មិនរីករាយ និងមិនសោកសៅនោះទេ។

៩៩- ប៉ុន្តែនៅពេលអវយវៈមួយក្នុងចំណោមអវយវៈទាំងអស់នោះគ្មានការគ្រប់គ្រង ពេលនោះ គតិបណ្ឌិតនឹងឃ្លាតឆ្ងាយពីរូបគេ សូម្បីតែទឹកស្រក់ប៉ះជើង(ទទេ)(របស់អ្នកយួរទឹក)ក៏ដោយ។

១០០- ប្រសិនបើគេរក្សានូវគ្រឿងវិញ្ញាណទាំង (ដប់) ព្រមទាំងចិត្តឱ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួន គេអាចសម្រេចបំណងទាំងអស់របស់គេបាន ដោយមិនចាំបាច់ចំណាយខ្លួនទៅ (ធ្វើ) យោគៈ ទេ។

---

**៩៣.**ទោសំ 'ទោស' (តាមនារ.) ត្រូវលោកមេធ., គោវ. និងកុល្ល. ប្រែក្នុងន័យ *ទុស្តាទុស្តំ* ទោសំ 'ជាទុក្ខ និងទោស' ហើយតាមលោករាឃ. ថា *សំសារខ្សំ* 'ទុក្ខនៃកំណើតដដែលៗ'។ 'ជោគជ័យ(ក្នុងការសម្រេចនូវបំណងរបស់ខ្លួនទាំងអស់)' គឺជា 'រង្វាន់សម្រាប់ការងារល្អ និងការធ្វើពិធីនានា' (មេធ.) ឬ 'ការរួចរដោះចុងក្រោយ' (នារ., រាឃ.) ឬ 'បំណង ទាំង អស់របស់មនុស្ស ការរួចរដោះចុងក្រោយជាដើម' (គោវ., កុល្ល.)។

**៩៦.**អសេវយា 'ដោយការវៀចោកចំណងរីករាយ' (គោវ., នារ., នន្ទ.) មានន័យស្របតាម មេធ. និងកុល្ល. ថា 'ដោយវៀរចាកពីកន្លែងជាប់ជំពាក់ចំណងរីករាយ' ពោលគឺ 'ដោយស្នាក់អាស្រ័យក្នុងព្រៃព្រឹក្សា' (មេធ.)។

**៩៩.**'គតិបណ្ឌិត' គឺ 'អំណាចគ្រប់គ្រងវិញ្ញាណ' (មេធ., គោវ., រាឃ.) ឬ 'ចំណេះដឹងអំពីសច្ចៈ)' (កុល្ល.)។ ខ្ញុំអានតាមមេធ., គោវ., នន្ទ., រាឃ., ក. និងសៀវភៅប៊ុប៉ៃ *បាទាត* ជំនួស *បាត្រាត*។ លោក Haughton បានធ្វើការបកស្រាយពាក្យឧបមែនេះយ៉ាងត្រឹមត្រូវនៅក្នុងកំណត់សម្គាល់របស់លោកចំពោះការបកប្រែរបស់ Sir W. Jones។

**១០០.**នារ. និងនន្ទ. ប្រែ *យោគតះ* ថា 'ដោយការធ្វើយោគៈ' តាមមេប្រយោគ ហើយមេធ. សរសេរៀបពាក្យដូច្នេះដែរ។

១០១- ចូរឲ្យគេឈរនៅពេលព្រឹកមិនទាន់មានពន្លឺព្រះអាទិត្យ សូត្រហ៊ឹមៗធម៌សាវិត្រី រហូតដល់ព្រះ អាទិត្យរះ ប៉ុន្តែ(ឱ្យគេសូត្រ)អង្គុយនៅពេលល្ងាច រហូតដល់គេអាចមើលឃើញតារារះច្បាស់។

១០២- អ្នកដែលឈរសូត្រធម៌ពេលព្រឹកព្រលឹមមិនទាន់មានពន្លឺព្រះអាទិត្យ (សាវិត្រី) រំដោះទោស កំហុសដែលមានកាលពីយប់(មុន) ប៉ុន្តែអ្នកដែលអង្គុយ(សូត្រធម៌) នៅពេលល្ងាច កម្ចាត់បង់ បាបកម្ម ដែលគេបានប្រព្រឹត្តនៅពេលថ្ងៃ។

១០៣- ប៉ុន្តែអ្នកដែលមិនឈរ(គោរពបូជា)នៅពេលព្រឹក មិនអង្គុយសូត្រធម៌នៅពេលរសៀល គួរត្រូវបណ្តេញចេញ ឱ្យទៅជាពួកសូទ្រៈ ដែលបាត់បង់ករណីយកិច្ច និងសិទ្ធិទាំងអស់របស់អារ្យន៍។

១០៤- អ្នកដែល(ចង់)ធ្វើពិធីសូត្រ(ធម៌)ប្រចាំថ្ងៃ សូម្បីសូត្រសាវិត្រីនៅជិតទឹក ចូលទៅនៅក្នុងព្រៃ ក៏អាចគ្រប់គ្រងឥន្ទ្រីយ៍របស់ខ្លួន និងអាចធ្វើសមាធិចិត្តរបស់ខ្លួនបាន។

១០៥- ទាំងនៅពេល(គេសិក្សា)អភិប្រាយព្រះវេទបន្ថែម និងទាំងនៅពេល(គេសូត្រធម៌)មួយផ្នែករបស់វេទប្រចាំថ្ងៃ ដោយមិនខ្វល់ពីថ្ងៃហាមឃាត់ទេ ដូចជានៅពេល(គេសូត្រដដែល)នូវអត្ថបទពិសិដ្ឋ ដែលតម្រូវឱ្យមានការបូជាអគ្គី។

១០៦- ការសូត្រធម៌ប្រចាំថ្ងៃ គ្មានថ្ងៃហាមឃាត់ទេ ព្រោះថាព្រហ្មសត្ត្រ ត្រូវបានប្រកាសហើយ (ថា ព្រាហ្មណ៍អាចធ្វើការបូជាគ្មានទីបំផុត) ហេតុនោះព្រះវេទមាននិយាយពីការបូជាព្រះអគ្គី ហើយជាការគួរឱ្យសរសើរ គឺនៅពេលដែល(បាតុភូតធម្មជាតិ ដែលតម្រូវឱ្យ)បញ្ឈប់ការសិក្សាព្រះវេទ កើតមានការឧទាន *វ៉ាស័ត*។

១០៧- សម្រាប់អ្នកដែលមានភាពបរិសុទ្ធ និងគ្រប់គ្រងឥន្ទ្រីយ៍របស់ខ្លួនបាន ក្នុងអំឡុងពេលមួយឆ្នាំ ធ្វើការសូត្រធម៌ព្រះវេទរាល់ថ្ងៃស្របតាមសិក្ខាវិន័យ (ការសូត្រធម៌ប្រចាំថ្ងៃ)នោះ ញុំាងឱ្យមានទឹកដោះគោផ្អែមនិងជូរ ទឹកដោះខាប់ក្លីថ្លានិងទឹកឃ្មុំ លំអោនចុះមក។

---

**១០១.**អាប. ជំពូក១ លេខ៣០, ៨; គោត. ជំពូក២ លេខ១០-១១; វស. ជំពូក ៨ លេខ១៦; ពោធ. ជំពូក២ លេខ៧; វិ. ជំពូក២៧ លេខ២-៣; យញ្ញ. ជំពូក១ លេខ២៤-២៥។

**១០២.**វស. ជំពូក២៦ លេខ២-៣; ពោធ. ជំពូក២ លេខ៧, ១៨, ២០។ លោកមេធ. និងគោវ. គូសបញ្ជាក់ថា គេអាចលុបលាងបានតែកំហុសតូចតាចប៉ុណ្ណោះ ផ្ទុយទៅវិញជំពូកស្ដីពីការលាងបាប នឹងគ្មានន័យ។

**១០៣.**ពោធ. ជំពូក២ លេខ ១៧, ១៥។

**១០៤.**ពោធ. ជំពូក២ លេខ១១, ៦។ 'សូម្បី' គឺ 'ប្រសិនបើគេមិនអាចសូត្រធម៌វេទផ្សេងទេ។'

**១០៥-១០៦.**អាប. ជំពូក១ លេខ១២, ១-៩; វស. ជំពូក១៣ លេខ៧។ អនុប្រយោគចុងក្រោយនៃកាព្យលេខ១០៦ មានការបកស្រាយតាមរយៈសេចក្ដី សតបថ ព្រាហ្មណ៍ ដែលត្រូវដកស្រង់ដោយអាប. ជំពូក១ លេខ១២, ៣។ *អនធ្យាយៈ* ('ការមិនសិក្សា' មានន័យ 'ហេតុនាំឱ្យមានការអាក់ខានការសិក្សា ដូចជាផ្គររន្ទះ ឬខ្យល់ព្យុះដែលកើតឡើងនូវពាក្យ ឧទានថា *វ៉ស័ត*)។

**១០៧.**វិ. ជំពូក៣០ លេខ៣៤-៣៨; យញ្ញ. ជំពូក១ លេខ៤១-៤៦។ នារ. និងនន្ទ. បកស្រាយពាក្យបួន 'ទឹកដោះផ្អែម និងជូរ ទឹកដោះខាប់ថ្លា និងទឹកឃ្មុំ' ជានិមិត្តរូបនៃវត្ថុបួនសម្រាប់អត្ថិភាពរបស់ជីវិតមនុស្ស គឺ កុសល ទ្រព្យ សេចក្ដីរីករាយ និងការរួចរដោះ។ លោកមេធ. ស្រង់ការបកប្រែនេះ ធ្វើជាមតិរបស់ 'អ្នកដទៃ'។

---

១០៨- ចូរឲ្យអាវ៉ុន ដែលត្រូវបានបញ្ចូលជាសមាជិកថ្មី ថ្វាយប្រេង(ប្រចាំថ្ងៃ)ដល់ព្រះអគ្គីពិសិដ្ឋ ដើរសុំអាហារ ដេកលើដី និងធ្វើអ្វី ដែលជាប្រយោជន៍សម្រាប់គ្រូរបស់ខ្លួន រហូតដល់(គេធ្វើពិធី) សមាវតនា (នៅពេលត្រឡប់ទៅផ្ទះវិញ)។

១០៩- យោងតាមច្បាប់ពិសិដ្ឋ (បុគ្គល)ដប់នាក់ (ជៀបជាមួយ)បុត្ររបស់គ្រូ មានអ្នកចង់ផ្ដល់ការបម្រើអ្នកដែលចង់ចែករំលែកពុទ្ធិ អ្នកដែលចង់ប្រតិបត្តិតាមច្បាប់ អ្នកដែលបរិសុទ្ធ ជាអ្នកមានទំនាក់ទំនងអាពាហ៍ពិពាហ៍ឬមិត្តភាព អ្នកដែលមានសមត្ថភាព(ផ្លូវចិត្តល្អ) អ្នកដែលមានជំនូនជាថវិកា អ្នកដែលស្មោះត្រង់និងជាសាច់ញាតិ អាចទទួលជំបូន្មាន(ព្រះវេទ)បាន។

១១០- ប្រសិនបើគេមិនបានទទួលសំណើទេ គេមិនចាំបាច់បកស្រាយ(អ្វីមួយ)ដល់នរណាម្នាក់ឡើយ ហើយមិនចាំបាច់ (គេមិនចាំបាច់ឆ្លើយ) ចំពោះអ្នកដែលសួរមិនបានត្រឹមត្រូវ; ចូរទុកឱ្យជន ដែលមាន

គតិបណ្ឌិត សូម្បីគេដឹង(ចម្លើយនោះ)ក៏ដោយ ធ្វើឫកក្នុងចំណោមមនុស្សទាំងឡាយ (ហាក់ដូចជាគេជា) មនុស្សល្ងីល្ងើ។

១១១- ក្នុងចំណោមមនុស្សពីនាក់ អ្នកដែលបកស្រាយ(អ្វីមួយ)ដោយខុសនឹងក្បួនតម្រា និងអ្នក ដែលសួរ(សំណួរ)ដោយខុសក្បួនតម្រា ម្នាក់(ឬទាំងពីរ)នឹងស្លាប់ ឬបង្កើតឱ្យមានអរិភាព (រវាងគ្នានឹងគ្នា)។

១១២- ទីណាដែលមិនអាចទទួលបាននូវកុសល និងទ្រព្យ (ដោយការបង្រៀន) និង(យ៉ាងហោច ណាស់) មិនបានទទួលការគោរពដ៏ត្រឹមត្រូវ ទីនោះពុទ្ធិដ៏ពិសិដ្ឋប្រាកដជាមិនដុះលូតលាស់ឡើយ ប្រៀបដូចគ្រាប់ពូជល្អ (ពិតជា)មិនដុះលូតលាស់នៅលើដីគ្មានជីជាតិទេ។

១១៣- សូម្បីនៅក្នុងពេលមានទុក្ខព្រួយដ៏ធ្ងន់ធ្ងរក៏ដោយ ក៏គ្រូបង្រៀនព្រះវេទ សុខចិត្តស្លាប់ជាមួយនឹង ពុទ្ធិរបស់ខ្លួន ជាជាងសាបព្រោះព្រះវេទនៅលើដីគ្មានជីជាតិ។

---

**១០៨.**អាប. ជំពូក១ លេខ៤, ១៦, ២៣, ២៥, ២៨, ៣២; គោត. ជំពូក២ លេខ៨, ៣០, ៣៥; វស. ជំពូក៧ លេខ៩, ១៥; វិ. ជំពូក២៨ លេខ៤, ៧, ៩, ១២; ពោធ. ជំពូក១, លេខ ៣, ១៦, ៤, ៤-៨; យញ្ញ. ជំពូក១ លេខ២៥។ បើនិយាយពី*សមាវេតន* សូមមើលជំពូក៣ លេខ៣-៤ ខាងក្រោម។

**១០៩.**យញ្ញ. ជំពូក១ លេខ២៨។ ធម្មតៈ 'អនុលោមតាមច្បាប់ពិសិដ្ឋ' (កុល្លុ., នន្ទ.) មានន័យ តាមលោកមេធ., គោវ., និងនារ. ថា 'ដើម្បីកុសលផ្នែកព្រលឹងវិញ្ញាណ'។

**១១០.**អាប. ជំពូក លេខ៣២, ២២-២៤; វស. ជំពូក២ លេខ១២; ពោធ. ជំពូក១ លេខ៤, ២; វិ. ជំពូក២៩ លេខ៧។ ពាក្យ *គាទៈ* 'មនុស្សល្ងីល្ងើ' តាមលោកមេធ. និងកុល្លុ. គឺ 'មនុស្សភ្លើ'។

**១១១.**វិ. ជំពូក២៩ លេខ៧។ មនុស្សដែលស្លាប់ ក្នុងករណីផ្សេង គឺអ្នកប្រមាថ។ ប្រសិនបើអ្នកទាំងពីមើលស្រាលគ្នា គេទាំងពីរនឹងស្លាប់។ *វិទ្វេសំ វាធិគច្ឆតិ* 'នឹងបង្កឱ្យមានអរិភាព(នឹងគ្នា)' តាមមេធ. និងគោវ. យល់ថា 'នឹងបង្កឱ្យមានការស្អប់ខ្ពើមគ្នា' តែតាមរាឃ. ថា 'នឹងនាំឱ្យខាតប្រយោជន៍'។

**១១២.**ពោធ. ជំពូក១ លេខ៤, ១ និង វិ. ជំពូក២៩ លេខ៨។

**១១៣.**តាមការគូសបញ្ជាក់របស់លោកមេធ. និងគោវ. កាព្យនេះសបញ្ជាក់ថា ក្នុងកាលៈទេសៈធម្មតា អ្នកចេះដឹង ប្រាកដជាបង្រៀននូវអ្វីដែលខ្លួនចេះដឹង។

១១៤- ការសិក្សាដ៏ពិសិដ្ឋបានចូលទៅជិតព្រាហ្មណ៍ហើយនិយាយទៅកាន់ព្រាហ្មណ៍ៈ ខ្ញុំជារតនៈរបស់អ្នក ចូរថែរក្សាខ្ញុំកុំឱ្យខ្ញុំធ្លាក់ទៅក្នុងដៃអ្នកប្រមាថ; (បើរក្សាបាន)ដូច្នេះ ខ្ញុំនឹងក្លាយជា កម្លាំងដ៏មហិមា'។

១១៥- 'ប៉ុន្តែចូរឱ្យខ្ញុំទៅនរណា ដែលដូចជាអ្នករក្សារតនៈរបស់អ្នកទៅឱ្យព្រាហ្មណ៍ ដែលអ្នកដឹងថា ជាអ្នកបរិសុទ្ធ យកឈ្នះលើឥន្ទ្រីយារម្មណ៍បាន មានកាយនិងចិត្តបរិសុទ្ធ និងមានការយកចិត្តទុកដាក់ខ្ពស់'។

១១៦- ប៉ុន្តែអ្នកដែលទទួលបានព្រះវេទដោយមិនបាច់មានការអនុញ្ញាតពីអ្នកដែលសូត្រធម៌វេទ គឺជាកំហុសក្នុងការលួចព្រះវេទ ហើយនឹងធ្លាក់ទៅនរក។

១១៧- (សិស្ស) ដំបូងបង្អស់ត្រូវសម្តែងការគោរពចំពោះ(គ្រូ) ដែលគេទទួលបាន(ចំណេះដឹង)ពីគាត់ ដោយជួយបម្រើកិច្ចការលោកិយ បម្រើព្រះវេទ ឬបម្រើព្រាហ្មណ៍។

១១៨- ព្រាហ្មណ៍ ដែលគ្រប់គ្រងខ្លួនឯងបានទាំងស្រុង ទោះបីគេចេះតែសាវិត្រីក៏ដោយ ក៏ប្រសើរជាង អ្នកចេះវេទទាំងបី (តែ)មិនអាចគ្រប់គ្រងខ្លួនឯងបាន ទទួលអាហារ(គ្រប់ប្រភេទ) និងលក់ (ទំនិញ)គ្រប់បែបយ៉ាងទាំងអស់។

១១៩- គេមិនត្រូវអង្គុយលើគ្រែ ឬកៅអី ដែលអ្នកខ្ពស់ជាងអង្គុយទេ ហើយអ្នកដែលអង្គុយលើគ្រែ ឬកៅអី គួរងើបឡើងទៅរក(អ្នកខ្ពស់ជាង) ហើយ(បន្ទាប់មក)គោរពគាត់។

១២០- ដើម្បីកញ្ចៀរឱ្យប្រសើរ យុវជនបង្អោនខ្លួនចុះនៅពេលមនុស្សចាស់ដើរមកជិតខ្លួន ប៉ុន្តែដោយ ងើបមើលគាត់ និងគោរពគាត់ គាត់នឹងគោរពពួកគេវិញ។

១២១- អ្នកដែលមានទម្លាប់ស្វាគមន៍និងសម្ដែងការគោរពជាប្រចាំចំពោះមនុស្សចាស់ទទួលបាននូវ(ប្រយោជន៍)បួនយ៉ាង (ពោលគឺ)អាយុវែង ពុទ្ធិច្រើន កេរ្តិ៍ឈ្មោះល្បី (និង)កម្លាំងមាំមួន។

១២២- បន្ទាប់ពី (ពាក្យ) គំនាប់វន្ទនាការ ព្រាហ្មណ៍ ដែលចេះគោរពមនុស្សចាស់ ប្រាកដជាប្រកាសឈ្មោះខ្លួនថា 'ខ្ញុំឈ្មោះ...'។

---

**១១៤-១១៥.**វស. ជំពូក២ លេខ៨-១០; វិ. ជំពូក២៩ លេខ៩-១០; និរុក្ត ជំពូក២ លេខ៤។

**១១៦.**វិ. ជំពូក៣០ លេខ៤១-៤២។

**១១៧.**អាប. ជំពូក១ លេខ១៤, ៧-៩; គោត. ជំពូក៦ លេខ១-៣, ៥; វស. ជំពូក១៣ លេខ៤១-៤៣; ពោធ. ជំពូក១ លេខ៣, ២៥-២៨; វិ. ជំពូក៣២ លេខ១-៤។ វិធាននេះ សំដៅដល់រាល់ជំនួបធម្មតាទាំងអស់។

**១១៩.**អាប. ជំពូក១ លេខ៨, ជំពូក២ លេខ១១, ១៤, ១៧; គោត. ជំពូក២ លេខ២១, ២៥។

**១២១.**អាប. ជំពូក១ លេខ៥, ១៥; ពោធ. ជំពូក១ លេខ៣, ២៦។ ជំនួសឱ្យពាក្យ *វិទ្យា* ឬ *ប្រាជ្ញា* 'ចំណេះដឹង' មេធ. អានថា *ធម្ម:* 'កុសលផ្នែកព្រលឹងវិញ្ញាណ' ហើយការអានដូចគ្នានេះ មាននៅក្នុងផ្នែកនិយាយពីមនុស្សនៅក្នុងអត្ថបទរបស់រដ្ឋាភិបាល។

**១២២.**អាប. ជំពូក១ លេខ៥, ១២; គោត. ជំពូក៦ លេខ៥; វស. ជំពូក១៣ លេខ៤៥; ពោធ. ជំពូក១ លេខ៣, ២៧; វិ. ជំពូក២៨ លេខ១៧; យញ្ញ. ជំពូក១ លេខ២៦។ 'បន្ទាប់ពីពាក្យវន្ទនាការ' គឺបន្ទាប់ពីពាក្យ *អភិវាទយេ* 'ខ្ញុំសូមគោរព' (គោវ., កុល្ល., នារ., នន្ទ.)។

១២៣- ចំពោះ(អ្នក)ទាំងឡាយណាដែលពេលប្រកាសឈ្មោះមិនយល់(ន័យនៃ)កិច្ចវន្ទនាការអ្នកមានគតិបណ្ឌិតនឹងនិយាយថា 'គឺខ្ញុំ' ហើយ(គេគួរនិយាយ)បែបនេះទៅកាន់ស្ត្រីទាំងអស់។

១២៤- ក្នុងកិច្ចស្វាគមន៍ គេគួរថ្លែងនូវពាក្យ *ផុះ* បន្ទាប់ពីឈ្មោះរបស់គេ ព្រោះបណ្ឌិតបានប្រកាសថា ធម្មជាតិនៃ *ផុះ* គឺដូចគ្នានឹងលក្ខណៈនៃឈ្មោះ(ផ្ទាល់ខ្លួនទាំងអស់)។

១២៥- ដូចនេះ ព្រាហ្មណ៍គួរទទួលបានការគោរពតបវិញ 'ឱ សុភាពបុរស! ចូរមានអាយុយឺនយូរ' និង ស្រៈ'អ' ត្រូវបន្ថែមនៅខាងចុងឈ្មោះ(របស់អ្នកដែលត្រូវនិយាយ) ហើយព្យាង្គដែលនាំមុខ ត្រូវដកឃ្លាឱ្យឃ្លាតបីដង។

១២៦- ព្រាហ្មណ៍ ដែលមិនដឹងពីទម្រង់គោរពតបវិញ មិនត្រូវបានទទួលការគោរពពីអ្នកចេះដឹងទេ ដូចគ្នានឹងសូទ្រៈ ក៏គេមិនត្រូវគោរពដែរ។

១២៧- ទុកឱ្យគេសួរទៅព្រាហ្មណ៍នៅពេលជួបព្រាហ្មណ៍ អំពី (សុខភាពរបស់គាត់ដោយពាក្យ)*កុសល:* ចំពោះក្សត្រិយ៍(ប្រើពាក្យ) *អនាមយ:,* វៃស្យ (ប្រើពាក្យ) *ក្សេម:* និងចំពោះសូទ្រៈ (ប្រើពាក្យ) *អនារោគ្យ:*។

១២៨- អ្នកដែលត្រូវបានគេបញ្ចូលសមាជិកថ្មី (ដើម្បីពិធីស្រោត) មិនត្រូវបានគេហៅចំឈ្មោះខ្លួនទេ សូម្បីគាត់មានវ័យក្មេងជាងក៏ដោយ។ អ្នកដែលចេះច្បាប់ពិសិដ្ឋ ត្រូវប្រើបរិវាស័ព្ទ(មនុស្ស) *ផុះ* ដើម្បីនិយាយ និង (សព្វនាម) *ភវ័ត* (ជាការគោរពរបស់អ្នក)។

---

**១២៣.**វស. ជំពូក១៣ លេខ៤៦ ពោលគឺ សម្រាប់អ្នកដែលមិនចេះវេយ្យាករណ៍ក៏បាន ឬដែលមិនចេះធម៌សាស្ត្រក៏បាន (មេធ.)។ លោកនន្ទ. ដាក់កាព្យនេះ នៅក្រោយកាព្យ ១២៦។

**១២៤.**វិ. ជំពូក២៨ លេខ១៧។

**១២៥.**អាប. ជំពូក លេខ៥, ១៨; វស. ជំពូក១៣ លេខ៤៦។ ការប្រែកាព្យពាក់កណ្ដាលទី២ ត្រូវផ្អែកលើការអាន '*ប៉ូវាក្យរ ប្លុតះ* ដែលនន្ទ. ឱ្យន័យ និងនារ. សន្មតថា 'មួយចំនួន'។ ន័យនេះយកលំនាំតាមការប្រែរបស់អ្នកអធិប្បាយទាំងពីរ ដែលមានសារជាតុស្របគ្នានឹងក្បួនតម្រារបស់*វសិស្ឋៈ*។ ន័យគឺថា ទេវទត្ត ត្រូវគេអានថា 'ទេវទត្តាសៈ'ហរភូតេ 'ហរភូតាស្យៈ' ជាដើម។ លោកមេធ. និងកុល្លូ. កំណត់យកសេចក្ដីថា 'និងស្រះ (ពោលគឺ)' «អ» (ជាដើម)នៅខាងចុងឈ្មោះ (ឬក្នុងករណី ពាក្យបញ្ចប់ដោយព្យញ្ជនៈ) ព្យាង្គនាំមុខនោះ ត្រូវដកឃ្លាបីដង'។ យោងតាមការប្រែ ដែលតម្រូវឱ្យអាន 'ប៉ូវាក្យរៈ ប្លុតៈ' ក្បួនតម្រារបស់ព្រះមនុ ស្របគ្នានឹងតម្រារបស់អាប. និងបាណិនិ ជំពូក៨ លេខ២, ៨៣។ ការជំទាស់ដ៏ខ្លាំងគឺថា លោក មេធ. និងកុល្លូ. ត្រូវបង្ខំ *អការៈ* 'ស្រះ អ' ក្នុងន័យស្រះដូចស្រះ អ និងយល់ស្របតាមពាក្យ *ប៉ូវាក្យរៈ* គឺពាក្យ ស្វរៈ មិនមាននៅក្នុងកាព្យទេ។ គោវ. និងរាឃ. យល់ខុសពីនេះឆ្ងាយណាស់។ អ្នកអធិប្បាយភាគច្រើនគិតថា ពាក្យ *វិប្រៈ* គឺ 'ព្រាហ្មណ៍' មានន័យបូកបញ្ចូលទាំងពួកអារ្យ័នផង ប៉ុន្តែសូមមើល អាប. ជំពូក១ លេខ១៤, ២៣។

**១២៦.**ន័យនៅក្នុងកាព្យនេះគឺថា គេមិនត្រូវស្វាគមន៍ចំពោះសូទ្រៈ តាមរបៀបដូចបានរៀបរាប់នៅក្នុងតម្រាខាងដើមទេ។

**១២៧.**អាប. ជំពូក១ លេខ២៤, ២៦-២៩។ តម្រានេះ សំដៅដល់ការជួបមិត្តភ័ក្តិ ឬសាច់ញាតិ មិនសំដៅដល់មនុស្សគ្រប់គ្នា ដែលត្រូវគោរពតបវិញទេ (គោវ.)។

**១២៨.**គោត. ជំពូក៦ លេខ១៩។ តម្រានេះសំដៅពេលចន្លោះពិធី*ទីក្សណីយេស្តិ* ឬពិធីទទួលសមាជិកថ្មី និងពិធីមុជទឹកចុងក្រោយនៅពេលបញ្ចប់ពិធី(មេធ., កុល្លូ.)។ ក្រៅពីពាក្យ *ផុះ* និង *ភតែ* គេត្រូវប្រើងារ *ទីក្សិត* ឬ *យតមានៈ*។

១២៩- ប៉ុន្តែចំពោះស្ត្រី ដែលជាភរិយារបស់បុរសម្នាក់ទៀត និងមិនជាប់សាច់ឈាមជាមួយគ្នា គេត្រូវនិយាយថា 'អ្នកស្រី' (ភវតិ) ឬ 'បងស្រី/ប្អូនស្រីជាទីស្រឡាញ់!'។

១៣០- ចំពោះពូ/អ៊ំប្រុសខាងឪពុកនិងខាងម្ដាយរបស់គេ ឪពុកក្មេក អាចារ្យពិធីការ (និងបុគ្គលជាទីគោរពនានា) គេត្រូវនិយាយថា 'ខ្ញុំគឺ...' និងងើបឡើង(ទទួលពួកគាត់) សូម្បីពួកគេមានវ័យ ក្មេង(ជាងខ្លួន)ក៏ដោយ។

១៣១- មីង/អ៊ំស្រីខាងម្ដាយ ភរិយារបស់ពូខាងម្ដាយ ម្ដាយក្មេក និងមីងខាងឪពុក គេត្រូវផ្ដល់កិត្តិយស ឱ្យដូចជាភរិយារបស់គ្រូខ្លួន គឺពួកគេគឺស្មើនឹងភរិយារបស់គ្រូខ្លួន។

១៣២- (ជើងរបស់)ភរិយានៃបង/ប្អូនប្រុសខ្លួន ប្រសិនបើគាត់មានវណ្ណៈដូចគ្នា គេត្រូវកាប់ជារៀងរាល់ថ្ងៃ ប៉ុន្តែ (ជើងរបស់)ភរិយានៃសាច់ញាតិខាងឪពុក និងម្ដាយ (ផ្សេងគ្នា) គេគ្រាន់តែថើបក្នុងពេលធ្វើដំណើរត្រឡប់មកវិញប៉ុណ្ណោះ។

១៣៣- ចំពោះបង/ប្អូនស្រីរបស់ឪពុក និងម្ដាយខ្លួន និងចំពោះបងស្រីរបស់ខ្លួនផ្ទាល់ គេត្រូវប្រណិប័តន៍ ឱ្យដូចម្ដាយរបស់ខ្លួន (ប៉ុន្តែ) ម្ដាយបង្កើត គួរគេគោរពឱ្យបានច្រើនជាង។

១៣៤- ពលរដ្ឋរួមជាតិ ត្រូវរាប់អានជាមិត្តសំឡាញ់ (ឱ្យស្មើគ្នា ទោះបីគេមាន) អាយុ១០ ឆ្នាំ(ច្រើនជាងគ្នា)ក៏ដោយអ្នកដែលមានមុខការផ្នែកវិចិត្រសិល្បៈ(ដូចគ្នា) (សូម្បីគេមាន) អាយុ៥ឆ្នាំ (ច្រើនជាងម្ខាងទៀត)ក្ដី ស្រូត្រិយៈ (សូម្បីមានអាយុ)៣ឆ្នាំ(នៅចន្លោះគ្នា)ក្ដី ប៉ុន្តែសាច់សាលោហិត គម្លាតអាយុ(បើខុសគ្នា) គឺខុសបន្តិចបន្តួចប៉ុណ្ណោះ។

១៣៥- ចូរដឹងថា ព្រាហ្មណ៍ដែលមានអាយុ ១០ឆ្នាំ និងក្សត្រិយដែលមានអាយុ ១០០ឆ្នាំ ឈរជាមួយគ្នាដូចឪពុក និងកូន ហើយរវាងអ្នកទាំងពីរ ព្រាហ្មណ៍គឺជាឪពុក។

១៣៦- ទ្រព្យ ញាតិ វ័យ (ការប្រតិបត្តិត្រឹមត្រូវតាម)ពិធីសាសនា និងទី៥ ការចេះដឹងដ៏ពិសិដ្ឋ គឺជាងារ ដែលត្រូវគោរព ប៉ុន្តែ (អំពើ) ដែលថែមខាងក្រោយឈ្មោះមួយៗមានទម្ងន់ធ្ងន់ជាង (ពាក្យនោះទៅទៀត)។

**១២៩.**វិ. ជំពូក៣២ លេខ៧។

**១៣០.**អាប. ជំពូក១ លេខ១៤, ១១; គោត. ជំពូក៦ លេខ៩; វស. ជំពូក១៣ លេខ៤១; ពោធ. ជំពូក១ លេខ៤, ៤៥; វិ. ជំពូក៣២ លេខ៤។ *គួរទ*បុគ្គលជាទីគោរព(ផ្សេងទៀត) ពោលគឺ បុគ្គលជាទីគោរព ដោយផ្អែកលើការចេះដឹង និងការធ្វើតបៈធម៌របស់ពួកគេ' (កុល្ល., រាឃ.) ឬ 'ភាពប្រសើរជាងរបស់គាត់ ដោយសារគាត់ជាអ្នកមានជាងជាដើម ឧទាហរណ៍ បុត្ររបស់ប្អូនស្រី' (មេធ.) ឬ 'ស្វាមីរបស់មីងខាងម្តាយជាដើម ប៉ុន្តែមិនមែនជាអ្នកដែលមានការចេះដឹងជាងខ្លួនទេ' (គោវ.) ឬ 'គ្រូ និងអ្នកដទៃទៀត' (នន្ទ.) ឬ 'ឋានៈបន្ទាប់ពីគ្រូ' (ឧបាធ្យាយ តាមលោកនារ.)។

**១៣១-១៣២.**គោត. ជំពូក៦ លេខ៩; អាប. ជំពូក១ លេខ១៤; វិ. ជំពូក៣២ លេខ២-៣។

**១៣៤.**អាប. ជំពូក១ លេខ១៤, ១៣; គោត. ជំពូក៦ លេខ១៤-១៧។ អ្នកដែលជាមិត្ត និងសំឡាញ់ អាចហៅគ្នាទៅវិញទៅមក ដោយពាក្យ *ផុះ, ករ៉ែ* ឬ *វយស្យ* 'មិត្តសំឡាញ់'។ការបកស្រាយកាព្យ ដែលមានខ្លឹមសារដូចគ្នា នៅក្នុងការអធិប្បាយនានា គឺផ្អែកលើសេចក្តីរបស់គោត. ចំណែកឯការប្រែហរទត្តរបស់អាប. គឺខុសគ្នាតិចតួច។

**១៣៥.**អាប. ជំពូក១ លេខ១៥, ២៥; វិ. ជំពូក៣២ លេខ១៧។

១៣៧- បុរសណាក៏ដោយក្នុងចំណោមវណ្ណៈបី(ខ្ពស់ជាងគេ) មានឋានៈខ្ពស់បំផុតក្នុងចំណោមវណ្ណៈ ទាំង៥ ទាំងចំនួននិងកម្រិត គឺបុរសនោះសមនឹងទទួលបានកិត្តិយសក្នុងចំណោមពួកគេ (និង ក៏ដូចគ្នា) សម្រាប់ពួកសូទ្រៈដែលបានឈានចូលដល់វ័យទី១០(ទសវត្សរ៏នៃជីវិតខ្លួនក៏ដោយ)។

១៣៨- ផ្លូវប្រាកដជាសម្រាប់អ្នកដើរផ្លូវ សម្រាប់អ្នកដែលមានវ័យលើសពីកៅសិបឆ្នាំ សម្រាប់អ្នកដែល មានជំងឺ សម្រាប់អ្នករែកពុននូវបន្ទុក សម្រាប់ស្ត្រី សម្រាប់ស្នាតកៈ សម្រាប់ព្រះរាជា និង សម្រាប់កូនកំលោះ។

១៣៩- ក្នុងចំណោមអ្នកទាំងនោះ ប្រសិនបើពួកគេជួបគ្នា(នៅពេលមួយ) ស្នាតកៈ និងព្រះរាជា ត្រូវតែផ្តល់កិត្តិយស(បំផុត) ហើយប្រសិនបើព្រះរាជា និងស្នាតកៈ(ជួបគ្នា) ស្នាតកៈទទួលបានការ គោរពពីព្រះរាជា។

១៤០- ពួកគេហៅព្រាហ្មណ៍ ដែលទទួលកូនសិស្ស និងបង្រៀនកូនសិស្សអំពីព្រះវេទ ព្រមទាំងកល្ប និងរហស្យ ថាជាគ្រូ (អាចារ្យ របស់សិស្ស)។

១៤១- ប៉ុន្តែអ្នកដែលបង្រៀនព្រះវេទដើម្បីតែការចិញ្ចឹមជីវិតរបស់ខ្លួន ឬបង្រៀនពីអង្គរបស់វេទ ត្រូវគេ ហៅថាគ្រូរង (ឧបជ្ឈាយ៍)។

១៤២- ព្រាហ្មណ៍ណា ដែលប្រតិបត្តិតាមសិក្ខាវិន័យ(របស់ព្រះវេទ) ពិធីសាសនា គាភធន (ពិធីចាប់កំណើត) ជាដើម និងផ្តល់អាហារ(ដល់ក្មេង) ត្រូវគេហៅថា គុរុ (ជាមហាគ្រូ)។

១៤៣- អ្នកដែលត្រូវគេជ្រើសរើស(ដោយសមគួរ) រៀបចំពិធី*អគ្ន្យាធេយ*ពិធី*បាកយញ្ញ* (និង)ពិធីស្រោត ដូចជា អគ្និស្តូម (សម្រាប់មនុស្សម្នាក់ទៀត) ត្រូវគេហៅថា អាចារ្យពិធីការ។

១៤៤- អ្នកដែលស្តាប់នូវព្រះវេទដោយស្មោះត្រង់ (សិស្ស)គួរចាត់ទុកជាឪពុក និងម្តាយរបស់ខ្លួន ហើយសិស្ស មិនត្រូវប្រមាថមើលងាយគាត់ឡើយ។

---

**១៣៦.**គោត. ជំពូក៦ លេខ ២០; វស. ជំពូក១៣ លេខ៥៦-៥៧; វិ. ជំពូក៣២ លេខ១៦; យញ្ញ. ជំពូក១ លេខ ១១៦។

**១៣៧.**គោត. ជំពូក១០; យញ្ញ. ជំពូក១ លេខ១១៦។

**១៣៨-១៣៩.**អាប. ជំពូក២ លេខ១១, ៥-៧; គោត. ជំពូក៦ លេខ២៤-២៥; វស. ជំពូក១៣ លេខ ៥៨-៦០; ពោធ. ជំពូក២ លេខ៦, ៣០; វិ. ជំពូក៦៣ លេខ៥១; យញ្ញ. ជំពូក១ លេខ១១៧។ ចំពោះការពន្យល់ពាក្យ *ស្នាតកៈ* សូមមើល ជំពូក៤ លេខ ៣១ ខាងក្រោម។

**១៤០-៤១.**អាប. ជំពូក១ លេខ១, ១៣; គោត. ជំពូក១ លេខ៩-១០; វស. ជំពូក៣ លេខ២១-២៣; វិ. ជំពូក២៩ លេខ ១-១២; យញ្ញ. ជំពូក១ លេខ៣៤-៣៥។ កល្បៈ ជាសូត្រ សំដៅលើការធ្វើពិធីផ្សេង។ រហស្យៈ ន័យត្រង់គឺ 'ចំណែកដ៏អាថ៌កំបាំង' ជាឧបនិស័ទ និងការបកស្រាយ(មេធ., គោវ., កុល្លូ., នន្ទ., រាឃ.) ឬ 'ការបកស្រាយព្រះវេទ និងអង្គដ៏អាថ៌កំបាំងបំផុត មិនមែនឧបនិស័ទទេ ពីព្រោះគេបញ្ចូលវាក្នុងន័យព្រះវេទ' (នារ.)។

**១៤២.**យញ្ញ. ជំពូក១ លេខ៣៤។ បុគ្គលដែលគេដៅដល់នោះ ជាឪពុកពីកំណើត។

**១៤៣.**វិ. ជំពូក២៩ លេខ៣; យញ្ញ. ជំពូក១ លេខ៣៥។

**១៤៤.**អាប. ជំពូក១ លេខ១, ១៤; វស. ជំពូក២ លេខ១០; វិ. ជំពូក៣០ លេខ៤៧។ 'ដោយស្មោះត្រង់' គឺក្នុងន័យថា គ្មានកំហុសក្នុងការបញ្ចេញសំឡេង ឬក្នុងអត្ថបទព្រះវេទ។

១៤៥- គ្រូ (អាកាប្យៈ) គួរឱ្យគោរពដប់ដងច្រើនជាងគ្រូ រង (ឧបជ្ឈាយ៍) គួរគោរពឪពុកមួយរយដង ច្រើនជាងគ្រូ ប៉ុន្តែគោរពម្តាយមួយពាន់ដងច្រើនជាងឪពុក។

១៤៦- ក្នុងចំណោមអ្នកដែលផ្តល់កំណើត និងអ្នកដែលផ្តល់(ចំណេះដឹងអំពី)ព្រះវេទ អ្នកផ្តល់ព្រះវេទ ជាឪពុកដ៏គួរឱ្យគោរពជាង ព្រោះជាអ្នកផ្តល់កំណើតព្រះវេទ (ជារង្វាន់)អមតៈ ទាំងសម្រាប់ ជាតិនេះ និងសម្រាប់ជាតិក្រោយ។

១៤៧- ចូរគេគិតថា (គេបានទទួល)អត្ថិភាព(ជាសត្វប៉ុណ្ណោះ ពេលដែលឪពុកម្តាយរបស់ខ្លួនផ្តល់កំណើតឱ្យខ្លួន តាមរយៈសេចក្តីស្រឡាញ់ទៅវិញទៅមក ហើយពេលដែលគេកើតចេញពីឧទរ (ម្តាយរបស់គេ)។

១៤៨- ប៉ុន្តែកំណើត ដែលគ្រូបានឱ្យនូវព្រះវេទទាំងមូល ត្រឹមត្រូវតាមច្បាប់ ផ្តល់ឱ្យគេនូវសាវិត្រី ជាការ រួចផុតពិតប្រាកដពីការកើត និងស្លាប់។

១៤៩- (សិស្ស) ត្រូវតែដឹងថា អ្នកដែលផ្តល់ប្រយោជន៍ឱ្យខ្លួននូវ(ការបង្រៀន)ព្រះវេទ ទោះតិចក្តី ច្រើនក្តី តាមគោលការណ៍ ត្រូវហៅគាត់ថាជាគុរុរបស់ខ្លួន ដោយសារផលប្រយោជន៍ (ដែលបានទទួលពីការអប់រំ) ព្រះវេទ។

១៥០- ព្រាហ្មណ៍ ដែលជាអ្នកផ្តល់កំណើត ជាព្រះវេទ ហើយគ្រូដែលមានករណីយកិច្ចដូចបានរៀបរាប់ នេះ តាមច្បាប់ ក្លាយជាឪពុករបស់មនុស្សចាស់ ទោះបីគាត់ខ្លួនឯង នៅជាកូនក្មេងក៏ដោយ។

១៥១- កវីវ័យក្មេង បុត្រារបស់អង្គិរៈ បានបង្រៀនសាច់ញាតិរបស់ខ្លួន(ដែលមានវ័យចំណាស់បីដូចជា) ឪពុក ហើយដោយសារូបគេមានចំណេះដឹង(ពិសិដ្ឋ)ច្រើនជាងសាច់ញាតិ គេបានហៅសាច់ញាតិទាំងនោះថា 'កូនប្រុសគួរឱ្យស្រឡាញ់'។

១៥២- ពួកគេដែលពោរពេញដោយការតូចចិត្ត បានសួរដល់ព្រះអាទិទេពអំពីបញ្ហានោះ ហើយព្រះអាទិទេព បន្ទាប់ពីបានប្រជុំគ្នារួចបានផ្តល់ចម្លើយថា 'ក្មេងនោះបាននិយាយទៅកាន់អ្នកដោយសមរម្យហើយ'។

---

**១៤៥.**វស. ជំពូក១៣ លេខ៤៨; យញ្ញ. ជំពូក១ លេខ៣៥។ អ្នកអធិប្បាយព្យាយាមសម្រួលអត្ថន័យកាព្យនេះ និងកាព្យក្រោយៗ ដោយសន្មតថា ទោះជាពាក្យ អាកាប្យៈ ក្នុងករណីនេះ សំដៅដល់អ្នកដែលគ្រាន់តែធ្វើពិធីទទួលសិស្សថ្មី និងបង្រៀនគាយត្រីប៉ុនហ្នឹងក្តី (មេធ., កុល្លូ.) ឬពាក្យ 'ឪពុក' សំដៅដល់ឪពុកដែលធ្វើពិធីកំណើតកូនផ្ទាល់របស់ខ្លួន និងបង្រៀនព្រះវេទដល់កូនក៏ដោយ (គោវ., នារ.)។ ក៏ប៉ុន្តែទំនងជាអាចនិយាយទៀតថា មតិផ្ទុយគ្នាទាំងពីរ ប្រកាន់ន័យម្ខាងម្នាក់ដូចនេះ ដោយសារមតិទាំងពីរ ផ្អែកលើប្រពៃណីបុរាណ សូមមើលគោត. ជំពូក២ លេខ៥០-៥១។

**១៤៦-១៤៨.**អាប. ជំពូក១ លេខ១, ១៥-១៧; គោត. ជំពូក១ លេខ៨; វស. ជំពូក២ លេខ៣-៥; វិ. ជំពូក៣០ លេខ៤៤-៤៥។ នារ. និងនន្ទ. អាន *ឧត្បាទកព្រហ្មបិត្រៈ* 'ក្នុងចំណោមឪពុកទាំងពីរ គឺអ្នកដែលផ្តល់កំណើតរូបកាយ និងអ្នកដែល (ផ្តល់កំណើត)ព្រះវេទ'។

**១៤៩.**ឥហ ន័យត្រង់គឺ 'ទីនេះ' ពេលគឺតាគោលការណ៍ទាំងនេះ (កុល្លូ.) ឬ 'នៅក្នុងជំពូកស្ដីពីកិច្ចវន្ទនាការ'(គោវ.)។ ប៉ុន្តែក៏អាចមានន័យថា 'នៅក្នុងលោកិយនេះ'។

**១៥១.**ពោធ. ជំពូក១ លេខ៣, ៤២។ ពាក្យ *សិសុ* 'វ័យក្មេង' ហាក់ដូចជាឈ្មោះ ឬងារ នៅក្នុងអត្ថបទរបស់ពោធ.។ ពាក្យ *បរិត្វហ្ស* 'ដោយសារគាត់វិសេសវិសាលលើពួកគេ'(នន្ទ.) តាមន័យរបស់មេធ., គោវ., កុល្លូ., នារ. និងរាឃ. 'ដោយនិយាយអំពីចំណេះដឹងរបស់គាត់ ដែលមានច្រើនជាងពួកគេ (ដែលជា)សិស្សរបស់គាត់'។ បិត្រីន ន័យត្រង់ជា 'បិតា' តាមនារ. ថា 'ព្រលឹងវិញ្ញាណ គឺ *អគ្និស្វាត្ត* និងន័យផ្សេងទៀត'។

១៥៣- 'ពីព្រោះ(បុរស)ដែលគ្មានចំណេះដឹង(ពិសិដ្ឋ) តាមពិតគឺជាកូនក្មេង ហើយអ្នកដែលបង្រៀន ព្រះវេទដល់គេ ជាឪពុករបស់គេ ដោយហេតុថា(ពួកបណ្ឌិត)តែងតែបាននិយាយថា«កូន» ទៅកាន់បុរសល្ងង់ និង «បិតា»ទៅកាន់គ្រូបង្រៀនព្រះវេទ។'

១៥៤- មិនយកវ័យច្រើនជាង មិនយក(សក់)ស មិនយកទ្រព្យ មិនយកសាច់ញាតិ(ដ៏មានអំណាច) (ធ្វើជាធំ) នោះទេ។ ពួកបណ្ឌិតបានបង្កើតច្បាប់នេះថា 'អ្នកដែលបានចេះដឹងអំពីព្រះវេទ ប្រកបដោយអង្គ(អនូកាន) យើងត្រូវ(ចាត់គាត់)ជាកំពូលមនុស្ស'។

១៥៥- ភាពចំណាស់ជាងរបស់ព្រាហ្មណ៍ គឺកើតចេញពីចំណេះដឹង(ពិសិដ្ឋ) ភាពចំណាស់ជាងរបស់ ក្សត្រិយកើតចេញពីភាពក្លាហាន ភាពចំណាស់ជាងរបស់វៃស្យកើតពីទ្រព្យគ្រាប់ធញ្ញជាតិ (និងទំនិញដទៃទៀត) ប៉ុន្តែភាពចំណាស់ជាងរបស់សូទ្រៈ គឺស្ថិតលើអាយុម្យ៉ាងប៉ុណ្ណោះ។

១៥៦- ដូច្នេះបុរសម្នាក់ មិនបានទទួល (ឬត្រូវបានគេ)គោរពដោយសារសក់ក្បាលស្កូវរបស់ខ្លួនទេ អ្នកដែលថ្វីបើមានវ័យក្មេងក៏ដោយ បានចំណេះដឹងអំពីព្រះវេទ អាទិទេពចាត់ទុកជាអ្នកគួរជាទីគោរព។

១៥៧- ព្រោះដូចដំរីដែលគេធ្វើពីឈើ ដូចរម៉ាំងដែលគេធ្វើពីស្បែក បីដូចព្រាហ្មណ៍ដែលគ្មានចំណេះ ដឹង ហើយបុរសទាំងបីនោះ គ្មានអ្វីក្រៅពីឈ្មោះ(របស់ពួកគេ)នោះទេ។

១៥៨- ឧបមាដូចខន្ទី(មនុស្សកម្រៀវ)មិនអាចមានកូនជាមួយស្ត្រី ហាក់បីដូចមេគោនៅជាមួយមេគោ មិនអាចផ្តល់កំណើតបាន និងឧបមាដូចអំណោយដែលគេឱ្យបុរសល្ងង់ មិនបានផលអ្វីឡើយ សូម្បីជាព្រាហ្មណ៍ក៏គ្មានប្រយោជន៍អ្វីដែរ បើគេមិន(ចេះ)ឫគវេទនោះ។

១៥៩- សត្វលោកដែលត្រូវបានបង្កើតឡើង ត្រូវទទួលការទូន្មាន (ក្នុងន័យ)ផ្តល់ការសង្គ្រោះពួកគេ ដោយមិនឱ្យពួកគេឈឺចាប់ ហើយ(គ្រូ) ដែលចង់(ដើរតាម)ច្បាប់ពិសិដ្ឋ ត្រូវតែប្រើសម្តីផ្អែម និងសុភាពរាបសា។

១៦០- តាមការពិត អ្នកដែលមានសម្តី និងគំនិតបរិសុទ្ធ ព្រមទាំងចេះរក្សាបានត្រឹមត្រូវ នឹងទទួលបានរង្វាន់ទាំងស្រុងពីវេទាន្ត។

---

**១៥៤.**ពាក្យ *អនុកានះ* (តាម កុល្លូ., នារ., នន្ទ., រាឃ.)គឺ 'អ្នកដែលបានចេះដឹងព្រះវេទ និងអង្គវេទ' ហើយតាមមេធ. និងគោវ. មានន័យថា 'អ្នកដែលបង្រៀនព្រះវេទ និងអង្គ'។

**១៥៥.**វិ. ជំពូក៣២ លេខ១៨។

**១៥៦.**នារ. និងនន្ទ. អាន *ស្ថវិរោ ភវតិ ក. ស្ថវិរោ ញេយោ* សម្រាប់ពាក្យ *វ្រទ្ធា* 'ដែលគួរគោរព'។

**១៥៧.**វស. ជំពូក៣ លេខ១១; ពោធ. ជំពូក១ លេខ១, ១០។

**១៥៨.**ពាក្យ *ឫគ* គឺជាវេទ (គោវ., នារ.)។

**១៥៩.**អាប. ជំពូក១ លេខ៨, ២៥-៣០; គោត. ជំពូក២ លេខ៤២។ កាព្យនេះ និងកាព្យបន្តបន្ទាប់ ក្នុងន័យទីមួយ សំដៅដល់ឥរិយាបថរបស់គ្រូចំពោះសិស្សគណរបស់ខ្លួន សូមមើលជំពូក៨ លេខ២៩៩-៣០០ខាងក្រោមផង។

**១៦០.**វេទាន្ត គឺជាគម្ពីរឧបនិស័ទ ហើយវង្វាន់ ក្នុងន័យនេះ គឺ 'ការរួចរដោះចុងក្រោយ' (តាមគោវ., កុល្លូ., នារ., នន្ទ., រាឃ.)។ ប៉ុន្តែលោកមេធ. ចង់ឱ្យន័យវេទាន្តថា 'ភាសិត ឬការបង្រៀនអំពីព្រះវេទ'ច្រើនជាង ហើយលោកគិតថា វង្វាន់ រាប់បញ្ចូលទាំងវង្វាន់គ្រប់បែបយ៉ាងសម្រាប់ពិធីវេទផង។

១៦១- ចូរកុំឱ្យគេ ទោះបីមានការឈឺចាប់ក៏ដោយ (និយាយពាក្យ)កាត់អ្នកដទៃរហ័សពេក; ចូរកុំឱ្យគេ ធ្វើឱ្យអ្នកដទៃឈឺចាប់ដោយគំនិត ឬអំពើ; ចូរកុំឱ្យគេនិយាយពាក្យដែលធ្វើឱ្យ(អ្នកដទៃ)ភ័យ ខ្លាចខ្លួន ព្រោះថាអំពើនោះនឹងរារាំងរូបគេ មិនឱ្យឡើងឋានសួគ៌បាន។

១៦២- ព្រាហ្មណ៍ ជានិច្ចកាលគួរតែភ័យចំពោះការគោរពបូជា ឱ្យដូចភ័យចំពោះថ្នាំពុល ហើយតាំងចិត្ត (ទទួលយក)ការប្រមាថ ឱ្យដូចជា(ការប្រាថ្នានូវ)ទឹកអម្រិត។

១៦៣- ចំពោះព្រាហ្មណ៍ដែលត្រូវគេប្រមាថ (ត្បិតតែបើអាច) ងាយនឹងមានចិត្តប្រតិកម្មក៏ដោយ ក៏អាចដាស់តឿនចិត្តបានភ្លាម ហើយនៅជាមួយអ្នកទាំងឡាយដោយសប្បាយចិត្ត ប៉ុន្តែអ្នកប្រមាថ នឹងជួបតែការវិនាសខ្លួនតែម្យ៉ាង។

១៦៤- អ្នកដែលមានកំណើតពីរដង ដែលត្រូវបានសង្គ្រោះដោយ(ការប្រើ)មធ្យោបាយនានា (ដូចបាន រៀបរាប់ខាងលើ) ដោយត្រឹមត្រូវ នឹងធ្វើតបៈធម៌កាន់តែប្រសើរឡើងបន្តិចម្តងៗ តាមបញ្ញត្តិសម្រាប់(អ្នក) សិក្សាព្រះវេទ។

១៦៥- ពួកអារ្យ៉ន ត្រូវតែសិក្សាគម្ពីរវេទទាំងមូល រួមទាំងរហស្យៈ ដោយការធ្វើតបៈធម៌ផ្សេងៗ និងការប្តេជ្ញាចិត្តនៅពេលជាមួយគ្នា ដូចបានបញ្ញត្តិដោយវិធាន(នៅក្នុងវេទ)។

១៦៦- ចូរព្រាហ្មណ៍ ដែលប្រាថ្នាធ្វើតបៈធម៌ សូត្រធម៌វេទជាប្រចាំ ពីព្រោះការសិក្សាវេទ ត្រូវគេប្រកាសនៅក្នុងនេះ (ថាជា)ការប្រតិបត្តិដ៏កំពូលសម្រាប់ព្រាហ្មណ៍។

១៦៧- តាមពិតគឺថា អ្នកមានកំណើតពីរដងត្រូវកាន់វត្តប្រតិបត្តិដ៏កំពូលរហូតដល់ទីបំផុត ដែលសូម្បីពាក់ដោយកម្រងផ្កា សូត្រធម៌វេទម្នាក់ឯងរាល់ថ្ងៃ ឱ្យអស់ពីលទ្ធភាពរបស់ខ្លួន។

១៦៨- អ្នកមានកំណើតពីរដង ដែលមិនទាន់បានសិក្សាវេទ សិក្សា(វិជ្ជាផ្លូវលោក)ផ្សេងៗទេ នឹងធ្លាក់ឱនថយភ្លាម សូម្បីក្នុងខណៈកំពុងរស់រានមានជីវិតក្តី ទៅក្នុងស្ថានភាពជាសូទ្រៈ ហើយជំនាន់ក្រោយរបស់ គេ (ក៏ដូចគ្នានឹងរូបគេដែរ)។

---

**១៦២.**កាព្យនេះ ផ្តល់ដំបូន្មានសម្រាប់សិស្ស ដែលត្រូវចេញទៅសុំការសិក្សា (មេធ.)។

**១៦៤.**'ន័យដែលបានរៀបរាប់ខាងលើ' សំដៅ 'ពិធីសាសនាផ្សេងៗ'។ ពាក្យ *វេទាធិ គមិគំ តបៈ* 'ការធ្វើតបៈ(ផ្សេងៗដូចបានរៀបរាប់) សម្រាប់(អ្នកទាំងឡាយដែលសិក្សា)ព្រះវេទ' ហើយយោងតាមនារ. និងនន្ទ. ថា 'ការធ្វើតបៈ ដែលមាននៅក្នុងការសិក្សាព្រះវេទ' និងសូមមើល អាប. ជំពូក១ លេខ១២, ១-២ផង។

**១៦៥.**'វេទទាំងមូល'គឺ 'វេទ រួមទាំងអង្គវេទ'(មេធ., នារ. និងអ្នកផ្សេង) ឬ 'សាខាវេទទាំងមូល ដែលមានមន្ត្រ និងព្រាហ្មណ៍' (មេធ., គោវ., កុល្លូ.)។ ពាក្យ 'រហស្យ' គឺ 'ឧបនិស័ទ' (មេធ., គោវ., កុល្លូ., នន្ទ.) ឬ 'ការបកស្រាយអាថ៌របស់វេទ' (នារ.)។ 'ប្រភេទតបៈធម៌ផ្សេងៗ' គឺ 'ការសុំសីល, *ក្រិច្ឆ្រៈ* ជាដើម'(មេធ., នារ., នន្ទ.) ឬ 'សិក្ខាវិន័យ សម្រាប់រឹតបន្តឹងកូនសិស្ស' (មេធ., គោវ., កុល្លូ. និងអ្នកផ្សេងៗទៀត) ឬ 'ការប្រតិបត្តិផ្ទាល់ ដូចជាការឱ្យចំណីសត្វសេះ នៅពេលគេអានអត្ថបទ *អស្វមេធៈ*(រាឃ.)។ 'ការសច្ចា' គឺ មហានាំនីវ្រតៈ ជាដើម និងសូមមើល *សាំខាយនា គួហ្យសូត្រ* ជំពូក២ លេខ ១១-១៣។

**១៦៦.**អាប. ជំពូក១ លេខ១២, ១-២; យញ្ញ. ជំពូក១ លេខ៤០។

**១៦៧.**សតបថ-ព្រាហ្មណ៍ ជំពូក១១ លេខ៥, ៧, ៤។
**១៦៨.**វស. ជំពូក៣ លេខ២; វិ. ជំពូក២៨ លេខ៣៦។

១៦៩- អនុលោមតាមការបង្គាប់នៃអត្ថបទដែលបានរៀបរាប់ កំណើតទីមួយរបស់អារ្យ័នបានពីម្ដាយ (បង្កើតរបស់ខ្លួន) ទីពីរកើតឡើងនៅពេលចងខ្សែដែលធ្វើពីស្មៅ*មុញ្ញ* និងទីបី កើតឡើងនៅ ពេលធ្វើការបញ្ចូលសមាជិកថ្មី (ដោយការធ្វើ)ពិធីស្រោតៈ។

១៧០- ក្នុងចំណោមកំណើតទាំងបី ដែលត្រូវសម្គាល់ដោយអំណាចនៃខ្សែចងដែលធ្វើពីស្មៅមុញ្ញៈ ជាកំណើតរបស់ខ្លួនដើម្បីព្រះវេទ ពោលគឺពួកគេប្រកាសថា នៅក្នុង(កំណើត)នោះ សាវិត្រី (កាព្យ) គឺជាម្ដាយរបស់ខ្លួន ហើយគ្រូ ជាឪពុករបស់ខ្លួន។

១៧១- ពួកគេហៅគ្រូជាបិតា(របស់សិស្ស) ពីព្រោះគ្រូផ្ដល់វិជ្ជាវេទ គឺព្រោះតែគ្មាននរណាអាចធ្វើពិធី (ពិសិដ្ឋ) នៅចំពោះមុខអំណាចខ្សែដែលធ្វើពីស្មៅមុញ្ញៈ បានទេ។

១៧២- (អ្នកដែលមិនបានធ្វើពិធីបញ្ចូលសមាជិកថ្មី) មិនគួរសូត្រអត្ថបទវេទ(ណាមួយ)ទេ លើកលែងតែ(អ្នកដែលគេតម្រូវសម្រាប់)ការធ្វើពិធីឧទ្ទិស ដោយហេតុថាគេស្ថិតក្នុងកម្រិតមួយស្មើនឹងពួកសូទ្រៈ មុននឹងកំណើតរបស់គេបានពីព្រះវេទ។

១៧៣- (កូនសិស្ស) ដែលត្រូវបានគេធ្វើពិធីជាសិស្សថ្មី ត្រូវទទួលការទូន្មាន ដោយការប្ដេជ្ញាចិត្ត ហើយខំសិក្សាព្រះវេទសន្សឹមៗ ដោយប្រតិបត្តិតាមសិក្ខាវិន័យដែលបានបញ្ញត្តិ។

១៧៤- ការតុបតែងកាយយ៉ាងណា អំបោះពិសិដ្ឋ ខ្សែចងចង្កេះដំបងនិងសម្លៀកបំពាក់មួយកំណាត់ក្រោមយ៉ាងដូចម្ដេច មានបញ្ញត្តិសម្រាប់(សិស្សនៅពេលធ្វើពិធីទទួល) របស់ដូចគ្នានេះ (ត្រូវគេប្រើម្ដងទៀត) នៅពេល(ធ្វើពិធី)សច្ចាប្រណិធាន។

១៧៥- ប៉ុន្តែសិស្សដែលស្នាក់នៅជាមួយគ្រូរបស់ខ្លួន ត្រូវតែប្រតិបត្តិសិក្ខាវិន័យតឹងរឹង ដូចជាការគ្រប់គ្រងឥន្ទ្រីយារម្មណ៍ទាំងអស់របស់ខ្លួនឲ្យបានសមរម្យ ដើម្បីបង្កើតគុណធម៌ផ្នែកព្រលឹងវិញ្ញាណរបស់ខ្លួន។

១៧៦- រាល់ថ្ងៃ បន្ទាប់មុជទឹកនិងសម្អាតខ្លួនរួច សិស្សត្រូវប្រទានទឹកបូជាព្រះអាទិទេព បណ្ឌិត និង បុព្វការីគោរព(រូបរបស់)ព្រះអាទិទេព និងដាក់ប្រេងចូលចង្ក្រាន(ព្រះអគ្គីពិសិដ្ឋ)។

---

**១៦៩-១៧០.**វិ. ជំពូក២៨ លេខ៣៧-៣៨; វស. ជំពូក២ លេខ៣; យញ្ញ. ជំពូក១ លេខ៣៩; ឯតរេយ-ព្រាហ្មណ៍ ជំពូក១ លេខ១; Max Muller ស្នាដៃ Hist. Anc. Sansk. Lit., ទំព័រ៣៩០។

**១៧១-១៧២.**អាប. ជំពូក២ លេខ១៥, ១៩; គោត. ជំពូក១ លេខ១០; ជំពូក២ លេខ៤-៥; វស. ជំពូក២ លេខ៤, ៦-៧; ពោធ. ជំពូក១ លេខ៣, ៦; វិ. ជំពូក២៨ លេខ៤០។

**១៧៣-១៧៤.**វិ. ជំពូក២៧ លេខ២៨។ ពាក្យ 'ការប្ដេជ្ញាចិត្ត' គឺ 'ការប្រតិបត្តិ និងសិក្ខាវិន័យ ដូចជាការប្រទានប្រេង ការហាមដេកថ្ងៃ' (កុល្លូ., នារ.) ឬ 'ការតាំងចិត្តសិក្សាព្រះវេទ គោទាន ជាដើម' (មេធ., គោវ., រាឃ.) ឬ 'ការធ្វើតបៈ ដូចជាប្រាគាបត្យ'(នន្ទ. និងនារ.)។ នៅក្នុងកាព្យទី២ លោកកុល្លូ. យល់ព្រមតាមការបកស្រាយរបស់លោកមេធ. និងគោវ. ដែរ។

**១៧៦-១៨២.**អាប. ជំពូក១ លេខ២, ១៧, ២៣-៣០; លេខ៣, ១១-២៥; លេខ៤, ១៣-២៣; គោត. ជំពូក២ លេខ៨-៩, ១២-១៧; វស. ជំពូក៧ លេខ១៥, ១៧; ពោធ. ជំពូក១ លេខ៣, ១៩-២០, ២៣-២៤; វិ. ជំពូក២៨ លេខ៤-៥, ១១, ៤៨-៥១; យញ្ញ. ជំពូក១ លេខ២៥, ៣៣។

១៧៧- ចូរឱ្យសិស្សតមទឹកឃ្មុំ សាច់ គ្រឿងក្រអូប កម្រងផ្កា សារជាតុ(ដែលប្រើសម្រាប់)បង្កើតរសជាតិ(អាហារ) ស្ត្រី សារជាតិទាំងអស់ដែលក្លាយទៅជាអាស៊ីត និងហាមបង្ករបួសស្នាមដល់សត្វមាន ជីវិត។

១៧៨- ហាមដុសខាត់(ខ្លួនគេ)ជាមួយនឹងប្រេង លាបថ្នាំភ្នែករបស់ខ្លួន ប្រើស្បែកជើង និងឆ័ត្រ (ឬក្លោះ) ហាមមានចំណង(កាមតម្រេក) កំហឹង លោភៈ ការរាំរែក ការច្រៀង និងការលេង (ឧបករណ៍តន្ត្រី)

១៧៩- ហាមលេងល្បែង ឈ្លោះប្រកែកគ្នាឥតប្រយោជន៍ និយាយដើមគេ និងភូតកុហក ហាមមើល និងប៉ះពាល់ស្ត្រី និងហាមធ្វើឱ្យអ្នកដទៃឈឺចាប់។

១៨០- ចូរឱ្យគេដេកម្នាក់ឯងជានិច្ច កុំឱ្យគេបំផ្លាញភាពជាបុរសរបស់គេ ព្រោះអ្នកដែលសុខចិត្តបំផ្លាញ បុរសភាពរបស់ខ្លួន គឺបំពានពាក្យសច្ចារបស់ខ្លួន។

១៨១- សិស្សដែលមានកំណើតពីរដង ដែលបានបំផ្លាញកម្លាំងបុរសរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងពេល ដេកត្រូវងូតទឹក គោរពព្រះអាទិត្យ ហើយបន្ទាប់មកត្រូវសូត្ររង្វង់ៗនូវកាព្យឫគវេទ (ដែលជាការ ចាប់ផ្ដើម) ចំនួនបីចប់ថា 'សូមឱ្យកម្លាំងរបស់ខ្ញុំត្រឡប់មកកាន់ខ្លួនខ្ញុំវិញ'។

១៨២- ចូរឱ្យគេកាន់ភាជន៍ដែលមានទឹកពេញទៅស្រោចផ្កា កើបអាចម៍គោ បោសដី និងបោចស្មៅ*កុសៈ* ឱ្យបានច្រើនតាមការតម្រូវ(របស់គ្រូខ្លួន) និងដើរចេញទៅ ដើរសុំអាហាររាល់ថ្ងៃ។

១៨៣- សិស្ស ដែលមានចិត្តបរិសុទ្ធ គួរតែយកអាហារពីផ្ទះរបស់អ្នកដែលខ្វះ(ចំណេះដឹងអំពី)វេទ និង ដែលមិន(ធ្វើពិធី)យញ្ញ និងដែលមានឈ្មោះល្បីក្នុងការប្រកបមុខរបរ(របស់ពួកគេដោយស្រប ច្បាប់)។

១៨៤- ចូរកុំឱ្យគេដើរសុំអាហារពីសាច់ញាតិខាងគ្រូរបស់ខ្លួន កុំសុំពីញាតិផ្ទាល់របស់ខ្លួន ឬពីញាតិខាងម្ដាយរបស់ខ្លួន ប៉ុន្តែបើគ្មានផ្ទះក្រៅញាតិទាំងអស់នេះទេ ចូរឲ្យគេទៅសុំពីផ្ទះណាមួយក្នុងចំណោម ផ្ទះដែលរាប់ឈ្មោះខាងលើ ដោយចាប់ផ្ដើមពីឈ្មោះចុងគេមុន;

---

**១៧៧.**រសាន 'សារជាតុ (ដែលគេប្រើ)សម្រាប់បន្ថែមរសជាតិអាហារ' គឺ 'ទឹករង្វ និងគ្រឿងផ្សេងៗទៀត'(នន្ទ.)។ នារ. បន្ថែមថា អ្នកផ្សេងប្រែពាក្យ *រសាន* ដើម្បីឱ្យត្រូវចុងជួនកាព្យ ថា រសៈ ឬសញ្ចេតនា។ លោកមេធ. ធ្វើការបកស្រាយដូចគ្នា និងថែមពីរទៀត គឺ (១)ម្ទេស (២)ទឹកផ្លែឈើ និងគ្រឿងកំប៉ុង ដូចជាស្ករអំពៅ។

**១៧៩.**ពាក្យ *គនវាទ* 'ជម្លោះឥតប្រយោជន៍' (មេធ., កុល្លូ., រាឃ.) ឬ 'ដើរនិយាយដើមគេ'(មេធ., នារ.)។

**១៨០.**វិ. ជំពូក២៨ លេខ៤៨។ បើនិយាយពីផលវិបាកនៃការប្រព្រឹត្តបទល្មើសបែបនេះ សូមមើលជំពូក១១ លេខ១១៩-១២៤ ខាងក្រោម។

**១៨១.**វិ. ជំពូក២៨ លេខ៥១។ កាព្យនេះ មាននៅក្នុងគម្ពីរ តៃត្ត. អារ. ជំពូក១ លេខ៣០។

**១៨២.**នន្ទ. អាន *ឧទកុមភាន* 'ភាជន៍ ដែលមានទឹកពេញ'។

**១៨៣.**ពោធ. ជំពូក១ លេខ៣, ១៨; វិ. ជំពូក២៨ លេខ៩; អាប. ជំពូក១ លេខ៣, ២៥; គោត. ជំពូក២ លេខ៣៥។

**១៨៤.**គោត. ជំពូក២ លេខ៣៧-៣៨។

១៨៥- បើមិនដូច្នោះទេ ប្រសិនបើគ្មាន(សាច់ញាតិ)ដែលមានចិត្តល្អដូចបានរៀបរាប់ខាងលើ គេអាច ដើរតាមផ្ទះ(នីមួយៗ)នៅក្នុងភូមិដោយចិត្តបរិសុទ្ធ និងរក្សាភាពស្ងៀមស្ងាត់ ប៉ុន្តែចូរជៀស ចេញពី *អភិសស្ត* (អ្នកដែលជាប់ចោទពីបទប្រព្រឹត្តបាបកម្មផ្នែកសីលធម៌)។

១៨៦- បន្ទាប់ពីបានប្រេងពិសិដ្ឋពីទីឆ្ងាយមក ចូរគេទុកវានៅកន្លែងណាមួយ តែត្រូវដាក់នៅលើដី ហើយចូរគេកុំមានការនឿយហត់ ក្នុងការបូជាព្រះអគ្គីពិសិដ្ឋទាំងនៅពេលល្ងាច និងពេលព្រឹក។

១៨៧- សិស្សដែលគ្មានជំងឺ លែងចេញទៅសុំអាហារក្នុងអំឡុងពេលប្រាំពីរថ្ងៃ(ជាប់គ្នា) និងមិនថ្វាយប្រេងចំពោះព្រះអគ្គីពិសិដ្ឋ គួរតែធ្វើតបៈជាអ្នកអវកីណិន (អ្នកដែលបានបំពានពាក្យសច្ចា របស់ខ្លួន)។

១៨៨- សិស្សដែលប្រកាន់ខ្ជាប់នូវពាក្យសត្យៈ (ក្នុងនាមជាសិស្ស) គួរចិញ្ចឹមជីវិតដោយការដើរសុំជាប្រចាំ (ប៉ុន្តែ) មិនគួរទទួលទានអាហារ(តែពីមនុស្ស)ម្នាក់ប៉ុណ្ណោះទេ ហើយការចិញ្ចឹមជីវិត របស់សិស្សដោយអាស្រ័យលើអាហារសុំ ត្រូវបានប្រកាសថា មានតម្លៃស្មើនឹងការសុំសីល។

---

**១៨៦.**'ពីទីឆ្ងាយ' គឺ 'បានពីកន្លែងមួយដាច់ស្រយាល នៅក្នុងព្រៃ ដែលគ្មានភាពសៅហ្មង'។ *វិហាយសិ* 'កន្លែងណាក៏ដោយ តែត្រូវនៅលើដី' ន័យត្រង់គឺ 'នៅក្នុងលំហ' និងមានការបកស្រាយផ្សេងៗថា 'នៅលើដំបូលផ្ទះ' (មេធ., គោវ., កុល្ល.) 'នៅលើដំបូល និងនៅលើអ្វីមួយបែបនេះ'(នារ.) 'នៅកណ្តាលវាល' (នន្ទ.) 'នៅកន្លែងបរិសុទ្ធណាមួយ លើកលែងតែ នៅនឹងដី'(រាឃ.)។ គោលបំណង តាមការពិចារណារបស់អ្នកអធិប្បាយភាគច្រើន គឺដើម្បីរក្សាកុំឱ្យខូចព្រៃ។ ប៉ុន្តែ យោងតាមអ្នកអធិប្បាយដទៃទៀត ដែលលោកមេធ. និងនន្ទ. បានដកស្រង់ ហាក់ដូចជាឯកភាពគ្នាថា វត្ថុ ត្រូវទុកបែបនេះ វត្ថុនោះអាចក្រៀមនៅកណ្តាលវាលបាន។

**១៨៧.**វិ. ជំពូក២៨ លេខ៥២; យញ្ញ. ជំពូក៣ លេខ២១៨។ តបៈសម្រាប់*អវកីណិន* មាននិយាយនៅជំពូក១១ លេខ ១១៩-១២០ ខាងក្រោម។

**១៨៨.**យញ្ញ. ជំពូក១ លេខ៣២។

**១៨៩.**យញ្ញ. ជំពូក១ លេខ៣២។ 'ដោយប្រកាន់ខ្ជាប់នូវលក្ខខណ្ឌពាក្យសត្យៈរបស់' គឺ 'មិនទទួលទានទឹកឃ្មុំ សាច់ និងផ្សេងៗ'។ *ឫសិវត៌* 'ឱ្យដូចជាឥសី' (មេធ., គោវ., នារ., នន្ទ.) ឬ 'ឱ្យដូចជាតាបស'(យតិ., កុល្ល.)។ យោងតាមគោវ., នារ. និងនន្ទ. ឃ្លាចុងក្រោយនេះ មានន័យថា សិស្សត្រូវទទួលទានបាយពេលល្ងាច (ដែលធ្វើអង្គធម្មជាតិ) ជាមួយនឹងអាហារផ្សេងដែលសមស្របសម្រាប់អ្នកបួស(មុនី) នៅផ្ទះធ្វើពិធីឧទ្ទិស ចំណែកឯលោកមេធ. និងកុល្ល. គិតថា ឃ្លាពីរនេះ ហាមទទួលទានអាហារដែលហាមប៉ុណ្ណោះ។

**១៩០.**'ភារកិច្ចនេះ' សំដៅដល់ការអនុញ្ញាតនៅកាព្យលេខ១៨៩។ យ៉ាងណាមិញ យោងតាមលោកនារ. និងអ្នកផ្សេងទៀត គិតថា កាព្យនេះលុបចោលវិន័យ ដែលមានចែងនៅក្នុងកាព្យ ១៨៨។

**១៩១.**អាប. ជំពូក១ លេខ៥, ២៧, ៤, ២៣; គោត. ជំពូក១ លេខ៥៤, ជំពូក២ លេខ២៩-៣០; វិ. ជំពូក២៨ លេខ ៦-៧; យញ្ញ. ជំពូក១ លេខ២៧។

**១៩៣.**អាប. ជំពូក១ លេខ៦, ១៨-២០។ ខ្ញុំអានតាមលោកមេធ., កុល្ល. និងរាឃ. *សុសំវ្រុតៈ* ហើយប្រែពាក្យនេះ តាមពួកគាត់ 'ស្លៀកពាក់បិទបាំងកាយរបស់ខ្លួនឱ្យស្អាតបាត'។ លោកមេធ. បកស្រាយពាក្យនេះថា 'រាំងរក្សាខ្លួនឱ្យល្អ (ក្នុងការនិយាយស្តី'។ នារ. និងកុល្ល. អាន *សមាហិតៈ* 'តម្កល់ចិត្តរបស់ខ្លួនឱ្យមូល'។ លោកគោវ. ទំនងជាអានដូចគ្នានឹងលោកនារ. ដែរ។

**១៩៤.**អាប. ជំពូក១ លេខ៤, ២២, ២៨; គោត. ជំពូក២ លេខ២១; ពោធ. ជំពូក១ លេខ៣, ២១; វិ. ជំពូក២៨ លេខ ១៣។

១៨៩- នៅពេលមានការអញ្ជើញ សិស្សអាចទទួលទានតាមសប្បាយនូវអាហាររបស់អ្នកផងនៅឯ (ពិធីសាសនា)ក្នុងកិត្តិយសរបស់អាទិទេពដោយ(យ៉ាងណាក៏ដោយ)ត្រូវប្រកាន់ខ្ជាប់នូវពាក្យសត្យៈរបស់ខ្លួន ឬនៅឯ(ពិធីឧទ្ទិស) ជាការគោរពដល់វិញ្ញាណក្ខន្ធ ដោយ(យ៉ាងណាក៏ដោយ) ត្រូវកាន់វត្តដូចជាឥសី។

១៩០- បណ្ឌិតបានបញ្ញត្តភារកិច្ចនេះសម្រាប់តែព្រាហ្មណ៍ប៉ុណ្ណោះ ក៏ប៉ុន្តែគេមិនបានបញ្ញត្តភារកិច្ច បែបនេះសម្រាប់ពួកក្សត្រិយ និងវៃស្យៈទេ។

១៩១- ទាំងនៅពេលមានបញ្ជាពីគ្រូរបស់ខ្លួន ទាំងនៅពេលគ្មានបញ្ជា(ពិសេស)ក៏ដោយ (សិស្ស)គួរដាក់ខ្លួនក្នុងការសិក្សា(ព្រះវេទ)ជានិច្ច និងជាការធ្វើអ្វីម្យ៉ាង ដែលជាការបម្រើដល់គ្រូរបស់ខ្លួនក៏បាន។

១៩២- ចេះគ្រប់គ្រងខ្លួនឯង ពាក្យសម្ដី ឥន្ទ្រីយារម្មណ៍(របស់ខ្លួន) និងចិត្តរបស់ខ្លួន ចូរសិស្សក្រោកឈរលើកដៃសំពះ ដោយសម្លឹងមើលមុខគ្រូរបស់ខ្លួន។

១៩៣- ចូរសិស្សលាដៃស្ដាំរបស់ខ្លួនជានិច្ច កាន់ឥរិយាបថត្រឹមត្រូវ និងស្លៀកពាក់ស្អាតបាត ហើយពេលគេស្លៀកពាក់រួច (ពេលឮពាក្យថា) 'ចូរអង្គុយចុះ' សិស្សគួរតែអង្គុយចុះ ដោយបែរមុខមើលគ្រូរបស់ខ្លួន។

១៩៤- នៅពេលមានវត្តមានគ្រូ ចូរសិស្សទទួលទានឱ្យតិច ស្លៀកសម្លៀកបំពាក់និងពាក់គ្រឿងតុបតែង ដែលមានតម្លៃទាប(ជាងគ្រូ) ហើយចូរសិស្សភ្ញាក់ពីដេក(មុន) និងចូលដេកក្រោយគ្រូ។

១៩៥- ចូរសិស្សកុំឆ្លើយ ឬសន្ទនាជាមួយ(គ្រូរបស់ខ្លួន) ដេករនៀលលើគ្រែ កុំអង្គុយ កុំបរិភោគ កុំឈរ ដោយបែរមុខចេញពីគ្រូ។

១៩៦- ចូរសិស្សធ្វើ(ដូច្នេះ) ក្រោកឈរ ប្រសិនបើ(គ្រូរបស់ខ្លួន)អង្គុយ ពេលគ្រូឈរ សិស្សត្រូវដើរទៅមុខគ្រូ បើគ្រូដើរទៅមុខ និងរត់សិស្សត្រូវរត់តាមគ្រូ;

១៩៧- ចូរដើរ(ទៅខាង)មុខ(គ្រូ) ប្រសិនបើមុខគ្រូបែរទៅទិសផ្សេង ចូលទៅជិតគ្រូ បើគ្រូក្រោកឈរនៅពីចម្ងាយ ប៉ុន្តែឱនគោរពគ្រូ បើគ្រូសម្រាកនៅលើគ្រែ និងបើគ្រូឈរនៅទីមួយទាបជាង។

១៩៨- ពេលគ្រូរបស់ខ្លួននៅជិត ចូរអង្គុយលើគ្រែ ឬកៅអីទាបជាង ប៉ុន្តែត្រូវនៅខាងមុខគ្រូរបស់ខ្លួន សិស្សមិនគួរអង្គុយដោយធ្វេសប្រហែសនោះទេ។

១៩៩- ចូរសិស្សកុំគ្រាន់តែហៅឈ្មោះរបស់គ្រូខ្លួន (ដោយមិនបន្ថែមងារកិត្តិយស) សូម្បីនៅពីខាងក្រោយខ្នងរបស់គ្រូក្ដី ហើយសិស្សមិនត្រូវធ្វើត្រាប់តាមដំណើរ សម្ដី និងឥរិយាបថរបស់គ្រូទេ។

---

**១៩៥-១៩៧.** អាប. ជំពូក១ លេខ៦, ៥-៩; គោត. ជំពូក២ លេខ២៥-២៨; វស. ជំពូក៧ លេខ១២; ពោធ. ជំពូក១ លេខ៣, ៣៨; វិ. ជំពូក២៨ លេខ១៨-២២។

**១៩៧.** *និទេសេ ទិស្តតៈ* 'បើគាត់ឈរនៅទីទាបជាង'(នារ., នន្ទ.)តាមមេធ., គោវ., កុល្ល. និងរាឃ.'បើគាត់ឈរនៅជិត'។

**១៩៨.** អាប. ជំពូក១ លេខ២, ២១, ៦, ១៣-១៧; គោត. ជំពូក២ លេខ១៤-១៥, ២១; វិ. ជំពូក២៨ លេខ១២, ២៣។

**១៩៩.** គោត. ជំពូក២ លេខ២៣; វិ. ជំពូក២៨ លេខ២៤-២៥។ គេត្រូវប្រើគុណស័ព្ទបន្ថែមលើឈ្មោះរបស់គ្រូ ដូចជា *ឧបាធ្យាយ, ភត្តៈ* (មេធ.), *អាការយៈ* (កុល្ល.), ឬ *ករណោ* និងពាក្យផ្សេងទៀត(នារ.)។

២០០- ទីណា(ដែលមានមនុស្ស) រិះគន់ច្រើន ឬបង្កាច់បង្ខូចកេរ្តិ៍គ្រូរបស់ខ្លួន ពេលនោះសិស្សត្រូវបិទ ត្រចៀករបស់ខ្លួន ឬដើរចេញពីទីនោះទៅកន្លែងផ្សេង។

២០១- ដោយមានការរិះគន់(គ្រូរបស់ខ្លួន)ទោះបីត្រឹមត្រូវក៏ដោយ សិស្សនឹងក្លាយជាមនុស្សឆ្កួត (នៅជាតិក្រោយ) ដោយការបង្កាច់បង្ខូចឈ្មោះគ្រូនឹងក្លាយជាឆ្កែ ហើយសិស្សដែលរស់នៅដោយសារទ្រព្យរបស់គ្រូខ្លួននឹងក្លាយជាដង្កូវ ហើយសិស្សដែលច្រណែននឹង(បុណ្យកុសលរបស់គ្រូ) នឹងក្លាយជាសត្វល្អិត។

២០២- សិស្សមិនត្រូវបម្រើ(គ្រូដោយមានអន្តរាគមន៍ពីអ្នកផ្សេងទេ) ទោះជាគាត់ឈរនៅឆ្ងាយ ទោះជាពេលគាត់គ្មានកំហឹង ទោះជាពេលគ្មានស្ត្រីនៅក្បែរ ប្រសិនបើគាត់អង្គុយលើរថ ឬលើអាសនៈ (ដែលគេរៀបចំឱ្យ) សិស្សត្រូវតែដើរចុះ បន្ទាប់មកសម្ដែងកិច្ចវន្ទនាការចំពោះ(គ្រូ)ខ្លួន។

២០៣- ចូរសិស្សកុំអង្គុយជាមួយគ្រូខ្លួន នៅខាងក្រោមខ្យល់ឬនៅពីលើខ្យល់(បាំងគ្រូ) ហើយសិស្សមិនត្រូវនិយាយអ្វី ដែលគ្រូរបស់ខ្លួនមិនអាចស្ដាប់បាននោះទេ។

២០៤- សិស្សអាចអង្គុយជាមួយគ្រូខ្លួនបាន នៅក្នុងរទេះ ដែលអូសដោយគោ សេះ ឬអូដ្ឋ នៅលើផ្ទៃរាបនៅលើកម្រាលស្មៅ ឬស្លឹកឈើ នៅលើកន្ទេល នៅលើថ្ម នៅលើកៅអីឈើ ឬនៅលើទូក។

២០៥- ប្រសិនបើគ្រូរបស់គ្រូខ្លួននៅជិត ចូរសិស្សគោរព(ចំពោះគាត់) ឱ្យដូចជាគោរពគ្រូរបស់ខ្លួនផ្ទាល់ ប៉ុន្តែចូរសិស្ស បើខ្លួនមិនបានទទួលការអនុញ្ញាតពីគ្រូរបស់ខ្លួនទេ គេមិនគួរគោរពបុគ្គលគួរជាទីសក្ការៈនៃ (គ្រួសារ) របស់គាត់ផ្ទាល់ទេ។

២០៦- បញ្ញត្តិដូចគ្នានេះត្រូវបានកំណត់សម្រាប់ការប្រព្រឹត្តជាប្រចាំរបស់សិស្ស ចំពោះគ្រូបង្រៀន (ដទៃទៀត) ក្នុងវិស័យវិទ្យាសាស្ត្រ ចំពោះញាតិសណ្តានរបស់គ្រូ (សមស្របតាមឋានៈ កិត្តិយស) ចំពោះអ្នកទាំងឡាយណា ដែលអាចទប់ចិត្តមិនប្រព្រឹត្តអំពើបាប ឬដែលអាចផ្តល់ឱវាទល្អៗដល់ខ្លួន។

២០៧- ចំពោះអ្នកដែលប្រសើរជាងខ្លួន ចូរសិស្សតែងតែគោរពឱ្យដូចជាគ្រូរបស់ខ្លួន ដូចជាចំពោះបុត្រា របស់គ្រូខ្លួន ដែលចាប់កំណើតពីម្តាយដែលមានវណ្ណៈស្មើគ្នា និងចំពោះសាច់ញាតិរបស់គ្រូ ទាំងខាងឪពុកនិងទាំងខាងម្តាយ។

---

**២០០.** វិ. ជំពូក២៨ លេខ២៦។

**២០១.** *បរិភោក្តា* 'សិស្សដែលរស់អាស្រ័យលើទ្រព្យរបស់គ្រូខ្លួន' តាមនារ. និងនន្ទ. គឺ 'សិស្សដែលទទួលទានអាហារពិសេសដែលបានពីការដើរសុំ ដោយគ្មានការអនុញ្ញាតពីគ្រូ'។ ការបកស្រាយក្រោយនេះ ត្រូវបានបន្ថែមន័យអាយតនិបាត 'បរិ' ទៅលើពាក្យ *បរិវេត្តា* និង *បរ្យាធ្យាតា*។

**២០២.** 'ទោះជាពេលគ្មានស្ត្រីនៅជិត' គឺ 'ប្រសិនបើគ្រូ កំពុងនៅជាមួយភរិយារបស់គាត់'។

**២០៣.** អាប. ជំពូក១ លេខ៦, ១៥។

**២០៤.** អាប. ជំពូក១ លេខ៧, ១២-១៣; វិ. ជំពូក២៨ លេខ២៧-២៨។

**២០៥.** អាប. ជំពូក១ លេខ៧, ២៩-៣០។

**២០៦.** អាប. ជំពូក១ លេខ៨, ២៨។

**២០៧.** អាប. ជំពូក១ លេខ៧, ២៩-៣០; ពោធ. ជំពូក១ លេខ៣, ៤៥។ ឯយេសុ 'ដែលកើតពីភរិយាដែលមានវណ្ណៈស្មើ

២០៨- កូនប្រុសរបស់គ្រូ ដែលព្រមផ្តល់ការអប់រំ (ក្នុងនាមឪពុករបស់ខ្លួន) ទោះបីមានវ័យក្មេងជាង ឬ វ័យស្មើគ្នាក្តី ឬជាសិស្ស(វិទ្យាសាស្ត្រ)សិក្សាយញ្ញ (ឬអង្គធម៌ណា)ក្តី ចូរផ្តល់កិត្តិយសឱ្យដូចជា គ្រូដែរ។

២០៩- (សិស្ស) មិនត្រូវដុសសាប៊ូអវយវៈនៃកូនប្រុសរបស់គ្រូខ្លួន មិនត្រូវជួយមុជទឹកឱ្យគេ មិនត្រូវទទួលទានចំណែកអាហាររបស់គេ និងត្រូវលាងជើងឱ្យគេទេ។

២១០- ភរិយារបស់គ្រូ ដែលមានវណ្ណៈស្មើគ្នា សិស្សត្រូវគោរពឱ្យស្មើនឹងគ្រូ ប៉ុន្តែភរិយាដែលមានវណ្ណៈ ខុសគ្នា សិស្សត្រូវផ្តល់កិត្តិយស ក្រោកឈរគោរព។

២១១- ចូរសិស្សកុំដើរតួនាទីជួយភរិយារបស់គ្រូ ក្នុងការដុសសម្អាតខ្លួនគាត់ ជួយមុជទឹកឱ្យគាត់ដុសសាប៊ូ ដៃជើងឱ្យគាត់ ឬសិតសក់ឱ្យគាត់ជាដើម។

២១២- (សិស្ស)ដែលមានអាយុគ្រប់ម្ភៃឆ្នាំ ហើយដឹងនូវអ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ មិនគួរគោរពភរិយាវ័យក្មេងរបស់គ្រូខ្លួន (ដោយឱនចាប់)ជើងរបស់គាត់ទេ។

២១៣- ធម្មជាតិរបស់ស្ត្រី តែងទាក់ចិត្តបុរសនៅក្នុងលោកិយនេះ ក្នុងហេតុផលដូច្នេះ បណ្ឌិតមិនដែលគ្មានការហាម(នៅជាមួយ)ស្ត្រីទេ។

២១៤- ព្រោះស្ត្រី អាចនាំឱ្យវង្វេងនៅក្នុងលោកិយនេះ មិនត្រឹមតែធ្វើឱ្យឆ្កួតប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យអ្នកចេះដឹង និងសិស្ស ក្លាយជាទាសករនៃតម្រេក និងទោសៈបានផងដែរ។

២១៥- អ្នកមិនគួរអង្គុយម្នាក់ឯងនៅទីមួយជាមួយម្ដាយ បងប្អូនស្រីឬកូនស្រីរបស់ខ្លួនទេ ឥន្ទ្រីយារម្មណ៍ មានអំណាចខ្លាំងណាស់ ហើយអាចធ្វើជាម្ចាស់លើអ្នកចេះដឹងបានផងដែរ។

២១៦- ប៉ុន្តែតាមសម្រួលរបស់ខ្លួន សិស្សវ័យក្មេងអាចក្រាបសំពះដល់ដីនៅពីមុខភរិយាវ័យក្មេងរបស់គ្រូ បានស្របតាមសិក្ខាវិន័យ ហើយនិយាយថា 'ខ្ញុំគឺ... (សូមគោរពអ្នកស្រីម្ចាស់)'។

---

គ្នា' គឺ វណ្ណៈព្រាហ្មណ៍ (តាមមេធ., កុល្ល., គោវ.) ហើយតាមនារ. និងនន្ទ. គឺ 'ដែលមានគុណធម៌'។ ប៉ុន្តែ ទំនងជាអាចនិយាយថា វាជាន័យត្រង់ គឺ 'ដែលជាពួកអារ្យ៉ន គឺ ដែលកើតពីភរិយានៃវណ្ណៈបីដំបូង'។ មេធ.ចូលចិត្តអំណានមួយទៀត *គុរុបុត្រេ តថាការយេ* 'សំដៅដល់បុត្ររបស់គ្រូ ដែល(ទទួលតំណែងឪពុកខ្លួនធ្វើជា)គ្រូ'។ រាឃ.យល់ស្របតាមគំនិតនេះ។

**២០៨.** អាប.ជំពូក១ លេខ៧, ៣០; វិ. ជំពូក២៨ លេខ៣១។ ការប្រែខាងលើ យកលំនាំតាមលោកមេធ., គោវ. និងនារ.។ នន្ទ. យល់ផ្សេងគ្នាបន្តិចប៉ុណ្ណោះ គឺ 'បុត្ររបស់គ្រូ ដែលព្រមផ្ដល់ការអប់រំ (នៅពេលឪពុករបស់ខ្លួនជាប់រវល់)ក្នុងពិធីយញ្ញ (ឬពិធីផ្សេងៗ) ទោះជាមានវ័យក្មេងជាង ឬអាយុដំណាលគ្នាក្ដី ឬជាសិស្សក៏ដោយ សមទទួលបានការគោរពជាដើម'។ កុល្ល. និងរាឃ. បកស្រាយផ្សេងទៅវិញថា 'បុត្ររបស់គ្រូ ទោះជាមានវ័យក្មេងជាង ឬដំណាលគ្នាក្ដី ឬជាសិស្សក្ដី ប្រសិនបើគេ(អាច)បង្រៀនព្រះវេទបាន គេសមទទួលបានកិត្តិយសដូចជាគ្រូដែរ នៅពេល(ដែលគេមានវត្តមាន)នៅឯកន្លែងប្រារព្ធពិធីយញ្ញ'។

**២០៩-២១២.** អាប. ជំពូក១ លេខ៧, ២៧; គោត. ជំពូក២ លេខ៣១-៣៤; ពោធ. ជំពូក១ លេខ៣, ៣៣-៣៧; វិ. ជំពូក២៨ លេខ៣២-៣៣; ជំពូក៣២ លេខ២, ៥-៧។

**២១៦-២១៧.** វិ. ជំពូក៣២ លេខ១៣-១៥។

២១៧- ពេលត្រឡប់ពីការធ្វើដំណើរវិញ សិស្សត្រូវតែគោរពឱនចាប់ជើងភរិយារបស់គ្រូខ្លួន និងគោរពគាត់រាល់ថ្ងៃ (តាមរបៀបដូចបាននិយាយនេះ) ដោយចាំឱ្យច្បាស់នូវករណីយកិច្ចមនុស្សល្អ។

២១៨- ឧបមាដូចជាបុរសដែលជីកដីនឹងចបជីកដើម្បីយកទឹក ក៏មានការគោរពដែរ ដូច្នេះ(សិស្ស) ដែលបានចំណេះដឹង ដែលមាននៅក្នុងខ្លួនគ្រូ ក៏ត្រូវគោរពគាត់ដែរ។

២១៩- (សិស្ស) អាចកោរសក់ក្បាលក៏បាន ឬប្រើក្រមាចងក្បាលក៏បាន ឬធ្វើជាមួកពាក់លើក្បាលក៏បាន ហើយព្រះអាទិត្យមិនត្រូវលិច ឬរះ នៅខណៈដែលសិស្ស(កំពុងដេក)នៅក្នុងភូមិទេ។

២២០- ប្រសិនបើព្រះអាទិត្យរះ ឬលិច ខណៈដែលសិស្សកំពុងដេក ហេតុនោះគឺ (សិស្សបានបំពាន) ដោយចេតនាឬដោយអចេតនា សិស្សគួរតែសុំសីលនៅថ្ងៃ(បន្ទាប់) ដោយសូត្រហឹមៗនូវ (សាវិត្រី)។

២២១- ព្រោះសិស្សដែលកំពុងដេក ខណៈដែលព្រះអាទិត្យលិច ឬរះ និងមិនបានធ្វើតបៈ(នោះ) ត្រូវមានកំហុសធ្ងន់ធ្ងរ។

២២២- ត្រូវបន្សុទ្ធដោយការក្រេបទឹក សិស្សគួរបូជារាល់ថ្ងៃក្នុងអំឡុងពេលយប់ ដោយសញ្ជឹងគិតនៅកន្លែងមួយបរិសុទ្ធ ដោយសូត្រអត្ថបទដែលបានបញ្ញត្ត ស្របតាមសិក្ខាវិន័យ។

២២៣- ប្រសិនបើស្ត្រី ឬបុរសនៃវណ្ណៈក្រោមធ្វើអ្វីម្យ៉ាង (ដែលនាំឱ្យមាន) ការសប្បាយរីករាយ ចូរសិស្សព្យាយាមប្រតិបត្តិធម៌ ព្រមទាំង (នរណាមួយដែលធ្វើអំពើ ដែលញ៉ាំងឱ្យចិត្តភ្លើតភ្លើនក្នុងតម្រេក។

២២៤- (អ្នកខ្លះប្រកាសថា) ដើមចមអំពើល្អ មាននៅក្នុងកុសលផ្នែកព្រលឹង និងទ្រព្យ (ខ្លះទៀតយល់ ថា) ស្ថិតនៅ(ការបំពេញចិត្ត)ចំណង់ និង(ការមាន)ទ្រព្យ (អ្នកខ្លះថា)ស្ថិតលើការកុសល ផ្នែកព្រលឹងតែម្យ៉ាងប៉ុណ្ណោះ ហើយ(អ្នកខ្លះនិយាយថា ការមាន)ទ្រព្យជាដើមចមអំពើល្អដូច ខាងក្រោម ប៉ុន្តែការវិនិច្ឆ័យ(ត្រឹមត្រូវ) គឺថា អំពើល្អមានកត្តាទាំងបី(នោះ)។

**២១៩.** គោត. ជំពូក១ លេខ២៧; វស. ជំពូក៧ លេខ១១; វិ. ជំពូក២៨ លេខ៤១; អាប. ជំពូក១ លេខ៣០, ៨; គោត. ជំពូក២ លេខ១០។ ជំនួសឱ្យឃ្លា 'ខណៈដែល(គេដេក)នៅក្នុងភូមិ' (តាមមេធ., កុល្លូ., រាឃ.) លោកមេធ., គោវ., នារ. និងនន្ទ. ប្រែថា 'ខណៈ(គេស្នាក់នៅ)ក្នុងភូមិ'។ ប៉ុន្តែការបកស្រាយខាងដើម ទំនងជាស្របនឹងអត្ថន័យកាព្យខាងក្រោម។
**២២០.** អាប. ជំពូក២ លេខ១២, ១៣-១៤; គោត. ជំពូក២៣ លេខ២១; វស. ជំពូក២០ លេខ៤; ពោធ. ជំពូក២ លេខ ៧, ១៦; វិ. ជំពូក២៨ លេខ៥៣។ ការប្រែពាក្យចុងក្រោយនេះ យកតាមគោវ. និងកុល្លូ. ចំណែកឯលោកមេធ., នារ. និង រាឃ. បញ្ជាក់ថា គេគួរធ្វើតបៈក្នុងអំឡុងពេល 'ថ្ងៃ (ឬយប់)បន្ទាប់' ហើយថា សិស្សដែលធ្វេសប្រហែសក្នុងការសូត្រធម៌ នៅពេលល្ងាច គួរតែរួសរាន់នៅពេលព្រលប់ និងសូត្រធម៌គាយត្រី ឡើងវិញ នៅពេលយប់។ សេចក្តីដូចគ្នានេះសបញ្ជាក់ថា ការខ្វែងគំនិតគ្នា កើតមានដោយសារការធ្វើតបៈធម៌នេះឯង។
**២២១.** វស. ជំពូក១ លេខ១៨; អាប. ជំពូក២ លេខ១២, ២២។
**២២២.** អាប. ជំពូក១ លេខ៣០, ៨; គោត. ជំពូក២ លេខ១១; ពោធ. ជំពូក២ លេខ៧; វិ. ជំពូក២៨ លេខ២។
**២២៣.** អាប. ជំពូក២ លេខ២៩, ១១។

២២៥- សិស្ស ជាពិសេសព្រាហ្មណ៍ មិនត្រូវមិនគោរពគ្រូ ឪពុក ម្តាយ និងបងប្រុសទេ ទោះបីគេត្រូវទទួលការប្រមាថធ្ងន់ធ្ងរពី(ពួកគាត់)ក៏ដោយ។

២២៦- គ្រូ ជារូបភាពតំណាងព្រាហ្មណ៍ ឪពុកជារូបភាពតំណាងប្រជាបតិ (ព្រះរបស់សត្វលោក) ម្តាយជារូបភាពតំណាងផែនដី ហើយ(បងប្រុស)ជារូបភាពតំណាងអត្តារបស់ខ្លួន។

២២៧- ទុក្ខកង្វល់ (និងការឈឺចាប់ ដែលឪពុកម្តាយបានឆ្លងកាត់នៅពេលផ្តល់កំណើតដល់កូនៗ (របស់ពួកគាត់) មិនអាចគេសងគុណរួច សូម្បីក្នុងពេលមួយឆ្នាំក៏ដោយ។

២២៨- ចូរសិស្សជានិច្ចកាលត្រូវធ្វើអ្វី ដែលឱ្យត្រូវចិត្តអ្នក (ទាំងពីរ) និងត្រូវធ្វើ (អ្វីដែលអាច) ឱ្យគ្រូរបស់ខ្លួនសប្បាយចិត្ត ហើយពេលដែលអ្នកទាំងបីនោះបានសប្បាយចិត្ត សិស្សនឹងសម្រេចបានផល (ទទួលរង្វាន់ទាំងអស់) ដែលកើតចេញពីការធ្វើតបៈធម៌។

២២៩- ការគោរពប្រណិប័តន៍ចំពោះអ្នកទាំងបី ត្រូវគេប្រកាសថាជា (ទម្រង់) ប្រសើរបំផុតនៃការធ្វើតបៈ ចូរសិស្សកុំធ្វើអំពើកុសលដទៃ ដោយគ្មានការអនុញ្ញាតពីពួកគាត់។

២៣០- ព្រោះព្រះសម្តែងថា ពួកគាត់គឺជាលោកបី ពួកគាត់ជាបញ្ញា(សំខាន់)បី ពួកគាត់ជាព្រះវេទបី ហើយពួកគាត់ជាភ្លើងពិសិដ្ឋបី។

២៣១- តាមពិត គេនិយាយថា ឪពុកជាភ្លើងគាហប្ប្យៈ ម្តាយជាទក្សិណាគ្និ ប៉ុន្តែគ្រូជាភ្លើងអាហវនីយៈ ហើយភ្លើងមនុស្សទាំងបីនេះ ជាសក្ការៈដ៏គួរឱ្យគោរពបំផុត។

២៣២- សិស្ស ដែលធ្វេសប្រហែសចំពោះអ្នកទាំងបី (សូម្បីបន្ទាប់ពីគេមាន)គ្រួសារក៏ដោយ នឹងបំពេញចិត្តលោកទាំងបី និងពន្លឺក្នុងកាយដូចអាទិទេព គេនឹងបានរីករាយនៅឯឋានសួគ៌។

២៣៣- តាមរយៈការផ្តល់កិត្តិយសដល់ម្តាយរបស់ខ្លួន សិស្សនឹងមិនអាប់ឱនឡើយក្នុងលោកិយនេះ ដោយការផ្តល់កិត្តិយសដល់ឪពុករបស់ខ្លួន នឹងបាននៅឋានកណ្តាល ប៉ុន្តែតាមរយៈការគោរពចំពោះគ្រូខ្លួន នឹងបានទៅឋានព្រហ្ម។

២៣៤- សិស្សដែលចេះផ្តល់កិត្តិយសដល់អ្នកទាំងបី ត្រូវបំពេញករណីយកិច្ចទាំងអស់ ប៉ុន្តែសម្រាប់សិស្សដែលមិនបានបំពេញភារកិច្ចជាកិត្តិយសសម្រាប់អ្នកទាំងបី រាល់ការធ្វើពិធីសាសនាទាំង អស់នឹងមិនបានផ្លែផ្កាឡើយ។

**២២៥.** អាប. ជំពូក១ លេខ១៤, ៦; វិ. ជំពូក៣១ លេខ១-៣។ លោកកុល្ល.ម្នាក់ប៉ុណ្ណោះ បានដាក់កាព្យនេះ នៅពីក្រោយកាព្យខាងក្រោម ចំណែកឯអ្នកអធិប្បាយផ្សេងទៀត ព្រមទាំងកុល្ល. ដាក់តាមលំដាប់ដូចខាងលើ។
**២២៩.** វិ. ជំពូក៣១ លេខ៦។
**២៣០.** វិ. ជំពូក៣១ លេខ៧។ 'លោកទាំងបី' គឺ 'ផែនដី ឋានកណ្ដាល និងឋានលើ', 'បញ្ញាបី' ជា 'បញ្ញាបីខាងដើម' (កុល្ល., នារ., នន្ទ.), 'បញ្ញាបីចុងក្រោយ'តាមមេធ., គោវ.)។
**២៣១.** អាប. ជំពូក១ លេខ៣, ៤៤; វិ. ជំពូក៣១ លេខ៨។
**២៣២.** វិ. ជំពូក៣១ លេខ៩។ **២៣៣.** វិ. ជំពូក៣១ លេខ១០។
**២៣៨.** អាប. ជំពូក២ លេខ២៩, ១១. 'ច្បាប់ដ៏កំពូល' គឺ 'យានសម្រាប់ការរួចរដោះទីបំផុត'(កុល្ល.); ប៉ុន្តែលោកមេធ., គោវ. និងរាឃ. ឱ្យន័យឃ្លានេះ សំដៅដល់ឱវាទក្នុងន័យលោកិយ។ ឃ្លា 'ពីគ្រួសារតូចតាច' គឺ 'ពីគ្រួសារ ដែលធ្វើប្រហែសក្នុងការធ្វើពិធីពិសិដ្ឋ'(មេធ.), (កុល្ល.)'ពីអ្នក ដែលមានឋានៈទាបជាងខ្លួន', (គោវ.) 'ពីគ្រួសារស្ទូនផ្ទាំង ឬពីវណ្ណៈទាប'។ ប៉ុន្តែទំនងជាវិធាននេះ សំដៅដល់ការរើសកូនក្រមុំតាមប្រាថ្នា សូម្បីពីគ្រួសារដែលនៅក្រៅវណ្ណៈក៏ដោយ សូមមើល វស. ជំពូក១៣ លេខ៥១-៥៣។

២៣៥- ដរាបណាអ្នកទាំងបីនៅមានជីវិត ដរាបនោះចូរសិស្សកុំធ្វើអំពើ (កុសល) ណាផ្សេង (ដោយចិត្តឯងឡើយ)ហើយចូរសិស្សបម្រើពួកគាត់ជានិច្ច ដោយធ្វើ(អ្វីដែលធ្វើឱ្យពួកគាត់រីករាយ) និងផ្ដល់ប្រយោជន៍ដល់(ពួកគាត់)។

២៣៦- សិស្សគួរជម្រាបពួកគាត់នូវអ្វីគ្រប់យ៉ាង ពោលគឺបើមានការយល់ព្រមពីពួកគាត់ សិស្សអាចធ្វើតាមគំនិត ពាក្យ ឬអំពើ ដើម្បីលោកខាងមុខ។

២៣៧- ដោយ (ការផ្ដល់កិត្តិយស) ដល់អ្នកទាំងបី អ្វីៗដែលកូនប្រុសគួរធ្វើ ត្រូវធ្វើឱ្យសម្រេចនោះហើយជាករណីយកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ហើយ(អំពើ)ផ្សេងទៀតជាករណីយកិច្ចបន្ទាប់បន្សំទេ។

២៣៨- សិស្សដែលមានសច្ចភាព អាចទទួលបានចំណេះដឹងបរិសុទ្ធ សូម្បីពីមនុស្សនៅក្នុងវណ្ណៈទាប ជាងក៏ដោយ ច្បាប់ដ៏ឧត្ដមបំផុត ក៏អាចបានពីវណ្ណៈទាបបំផុត ហើយភរិយាដ៏ប្រពៃបំផុត ក៏អាចបានពីគ្រួសារដ៏តូចតាចបំផុតដែរ។

២៣៩- សូម្បីពីពិសពុលក៏គេអាចយកទឹកអម្រិតបាន សូម្បីពីកូនក្មេងក៏អាចមានឱវាទល្អៗ សូម្បីពី សត្រូវក៏អាចមានចំណុចល្អ(គួររៀនតាម) ហើយសូម្បីពីសារធាតុសៅហ្មងក៏អាចមានជាតុមាស នៅក្នុងនោះដែរ។

២៤០- ភរិយាឧត្ដម, ចំណេះដឹង, (ការចេះដឹង)ច្បាប់, (សិក្ខាវិន័យស្ដីពី)ភាពបរិសុទ្ធ, ដំបូន្មានល្អ និង សិល្បៈនានា គេអាចទទួលបានពីមនុស្សណាក៏បាន។

២៤១- តាមបញ្ញត្តិគឺថា ក្នុងគ្រាអាសន្ន (សិស្ស)អាចសិក្សា(ព្រះវេទ)ពីអ្នក ដែលមិនមែនជាព្រាហ្មណ៍ បាន ហើយថា សិស្សគួរដើរពីក្រោយ បម្រើគ្រូ(នោះ) រហូតដល់បញ្ចប់ការសិក្សា។

២៤២- អ្នកដែលប្រាថ្នាចង់បានបរមសុខឥតឧបមា(នៅឯឋានសួគ៌) មិនគួររស់នៅក្នុង(ផ្ទះ)របស់គ្រូ ដែលមិនមែនជាព្រាហ្មណ៍អស់មួយជីវិតរបស់ខ្លួនទេ ហើយក៏មិននៅជាមួយព្រាហ្មណ៍ដែលមិន ចេះដឹងព្រះវេទ និងអង្គវេទទាំងស្រុងដែរ។

២៤៣- ប៉ុន្តែប្រសិនបើ (សិស្ស) ប្រាថ្នាចង់នៅផ្ទះរបស់គ្រូអស់មួយជីវិតរបស់ខ្លួន សិស្សត្រូវបម្រើគ្រូ ដោយយកចិត្តទុកដាក់ រហូតដល់គេបានរួចរំដោះពីរូបកាយនេះ។

២៤៤- ព្រាហ្មណ៍ដែលបម្រើគ្រូរបស់ខ្លួនរហូតដល់បាត់បង់ជីវិតខ្លួន នឹងបានទៅកាន់វិមានព្រហ្មដ៏ជាទីអមតៈភ្លាម។

២៤៥- អ្នកដែលចេះដឹងច្បាប់ពិសិដ្ឋ មិនត្រូវជូនអំណោយណាមួយឱ្យគ្រូខ្លួននៅមុន(សមាវតនៈ)ទេ ប៉ុន្តែបើមានការអនុញ្ញាតពីគ្រូខ្លួនសិស្សត្រៀមខ្លួនមុជទឹក(ចុងក្រោយ) ចូរសិស្សឱ្យ(អំណោយ)ជូនមនុស្សជាទីគោរព ស្របតាមសមត្ថភាពរបស់សិស្ស។

---

**២៤០.** ពាក្យ *ស្ត្រិយោ រត្នានិ* 'ភរិយាដ៏ឧត្តម'(កុល្ល., រាឃ.) ហើយតាមលោកមេធ. និងគោវ. ថា 'ភរិយា និងរតនវត្ថុ'។
**២៤១.** អាប. ជំពូក២ លេខ៤, ២៥; គោត. ជំពូក៧ លេខ១-៣; ពោធ. ជំពូក១ លេខ៣, ៤១-៤៣។
**២៤៣.** អាប. ជំពូក២ លេខ២១, ៦; គោត. ជំពូក៣ លេខ៥-៦; វស. ជំពូក៧ លេខ៤; ពោធ. ជំពូក២ លេខ១១, ១៣; វិ. ជំពូក២៨ លេខ៤៣; យញ្ញ. ជំពូក១ លេខ៤៩។
**២៤៥.** អាប. ជំពូក១ លេខ៧, ១៩; គោត. ជំពូក២ លេខ៤៨-៤៩; វិ. ជំពូក២៨ លេខ៤២; យញ្ញ. ជំពូក១ លេខ៥១។

២៤៦- (ដូចជា)ស្រែ, មាស, មេគោ, សេះ, ក្លស់ និងស្បែកជើង, កៅអី, គ្រាប់ធញ្ញជាតិ, (ព្រមទាំង) បន្លែបង្កា (ហើយធ្វើយ៉ាងណា)ធ្វើឱ្យគ្រូរបស់ខ្លួនសប្បាយចិត្ត,

២៤៧- (សិស្សអស់មួយជីវិត) ប្រសិនបើគ្រូខ្លួនស្លាប់ ត្រូវបម្រើបុត្ររបស់គ្រូ (ព្រោះគាត់)មានគុណសម្បត្តិល្អៗ ឬអ្នកមេម៉ាយរបស់គ្រូ ឬ សបិណ្ឌារបស់គ្រូឱ្យដូចជាគ្រូដែរ។

២៤៨- បើគ្មាននរណាម្នាក់ក្នុងចំណោមអ្នកទាំងអស់នេះនៅមានជីវិត សិស្សត្រូវបម្រើព្រះអគ្គីពិសិដ្ឋ ដោយឈរ (នៅពេលថ្ងៃ) និងអង្គុយ (នៅពេលយប់) ហើយ(ធ្វើដូច្នេះ)រហូតដល់អស់ជីវិត របស់ខ្លួន។

២៤៩- ដូចនេះ ព្រាហ្មណ៍ ដែលកន្លងបង់ជីវិតទៅក្នុងនាមជាសិស្ស ដែលមិនបានបំពានពាក្យសត្យៈរបស់ខ្លួន នឹងបានទៅកាន់ឋានខ្ពស់បំផុត(នៅជាតិក្រោយ) ហើយនឹងមិនចាប់កំណើតជាថ្មី នៅក្នុងលោកិយនេះឡើយ។

---

**២៤៦.** អ្នកអធិប្បាយភាគច្រើនបំផុត អាន *ប្រតិមាហរេត* សម្រាប់ *អាវហេត* ហើយយោងតាមអំណាននេះ ការប្រែអាចជា 'ស្រែ, មាស... សិស្សគួរផ្ដល់ជូនគ្រូ ដើម្បីធ្វើឱ្យគ្រូសប្បាយចិត្ត'។
**២៤៧.** គោត. ជំពូក៣ លេខ៧; វិ. ជំពូក២៨ លេខ៤៤-៤៥; យញ្ញ. ជំពូក១ លេខ៤៩។ បើនិយាយពីពាក្យ *សបិណ្ឌ* សូមមើលជំពូក៥ លេខ៦០ ខាងក្រោម។
**២៤៨.** គោត. ជំពូក៣ លេខ៨; វស. ជំពូក៧ លេខ៥-៦; វិ. ជំពូក២៨ លេខ៤៦; យញ្ញ. ជំពូក១ លេខ៤៩។ ពាក្យ *សរីរំ សាធយេត* 'គួរបញ្ចប់ជីវិតរបស់ខ្លួន'(មេធ., គោវ.) ហើយតាមកុល្ល. គឺ 'គួរធ្វើឱ្យវិញ្ញាណនៅជាមួយកាយរបស់ខ្លួនយ៉ាងល្អ ពោលគឺស្របគ្នានឹងព្រហ្មន៍'។ នារ. និងរាឃ. ប្រែពាក្យនេះ ប្រហាក់ប្រហែលនេះដែរ។
**២៤៩.** វិ. ជំពូក២៨ លេខ៤៩; យញ្ញ. ជំពូក១ លេខ៥០។

# ជំពូក ៣

១- ពាក្យសត្យៈ(ក្នុងការសិក្សា) ព្រះវេទទាំងបីតាមបញ្ញារបស់គ្រូ ត្រូវតែសិស្សគោរពរយៈពេល សាបសិបប្រាំមួយឆ្នាំ ឬពាក់កណ្ដាលពេលនេះ ឬមួយភាគបួន ឬរហូតដល់(សិស្ស)បានចេះដឹង ព្រះវេទត្រឹមត្រូវ។

២- (សិស្ស) ដែលបានសិក្សាព្រះវេទទាំងបីតាមលំដាប់លំដោយឬពីរ ឬសូម្បីតែមួយក៏ដោយ ដោយមិនបំពាន(សិក្ខាវិន័យ)ជាសិស្សគួរតែចាប់ផ្ដើមគ្រួសារបាន។

៣- សិស្សដែលល្បីក្នុងការ(ប្រតិបត្តិតឹងរ៉ឹងនូវ)ករណីយកិច្ចរបស់ខ្លួន និងបានទទួលមរតក, ព្រះវេទពីឪពុករបស់ខ្លួន គួរទទួលបានកិត្តិយស អង្គុយលើអាសនៈ និងទទួលបានកម្រងផ្កា ដោយមាន (វត្តមាន)មេគោ (និងអាហារលាយទឹកឃ្មុំ)។

៤- បន្ទាប់ពីស្រង់ទឹករួច ដោយមានការអនុញ្ញាតពីគ្រូរបស់ខ្លួន និងបានប្រតិបត្តិតាមសិក្ខាវិន័យ *សមាវតនៈ* (ពិធីទទួលការត្រឡប់មកផ្ទះវិញ) អ្នកមានកំណើតពីរដង គួររៀបការភរិយា ដែលមានវណ្ណៈស្មើគ្នា ដែលជាសញ្ញានៃជោគល្អ(ផ្នែករូបកាយ)។

៥- (ក្រមុំត្រកូលខ្ពស់) ដែលមិនមែនជាសបិណ្ឌា នៅខ្សែខាងម្ដាយ និងក៏មិនមែនជាគ្រួសារតែមួយ នៅខ្សែខាងឪពុក ត្រូវគេណែនាំឱ្យទៅបុរសមានកំណើតពីរដង ជាប្ដីប្រពន្ធនឹងគ្នា និងរួមរស់ជាសហព័ទ្ធនឹងគ្នា។

៦- ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយភរិយា ចូរឱ្យប្ដីត្រូវប្រយ័ត្ន ជៀសវាងគ្រួសារចំនួន គឺគ្រួសារដែលអស្ចារ្យខ្លាំងពេក ឬមានគោ សេះ ចៀម ធញ្ញជាតិ ឬទ្រព្យ (ផ្សេងៗ) ច្រើនពេក,

---

III. **១.** អាប. ជំពូក១ លេខ២, ១២-១៦; គោត. ជំពូក២ លេខ៤៥-៤៧; វស. ជំពូក៨ លេខ១; ពោធ. ជំពូក១ លេខ៣, ១-៤; វិ. ជំពូក២៨ លេខ៤២; យញ្ញ. ជំពូក១ លេខ៣៦។

ព្រះវេទទាំងបី ដែលនិយាយនៅទីនេះ មានឫគ-វេទ, យគុរ-វេទ និងសាម-វេទ។ អថវ-វេទ នៅទីនេះ ជាធម៌-សូត្រ ដ៏បុរាណបំផុតក្នុងចំណោមវេទនានា។ ពោធាយនៈ តែម្នាក់ប៉ុណ្ណោះ បានអះអាងថា ពាក្យភាពជាកូនសិស្ស មានរយៈពេលហួសពីសែសិបប្រាំបីឆ្នាំ ហើយវិធាននេះរាប់បញ្ចូលទាំងអថវ-វេទ ផង។

**២.** យញ្ញ. ជំពូក១ លេខ៥២។

**៣.** អត្ថន័យគឺថា សិស្សដែលបន្ទាប់ពីបញ្ចប់ការសិក្សារបស់ខ្លួន ក្លាយជាស្នាតកៈ គួរបានទទួលទីមួយ ពោលគឺមុនអាពាហ៍ពិពាហ៍របស់ខ្លួន គឺកិត្តិយសជាមធុបកៈ (អាប. ជំពូក២ លេខ៨, ៥-៩) ពីអ្នកដែលបានបណ្ដុះបណ្ដាលរូបគេ។ ឃ្លា 'អ្នកដែលបានទទួលមរតករបស់ខ្លួន ព្រះវេទ ពីឪពុកខ្លួន' យោងតាមអ្នកអធិប្បាយ គឺសំដៅថា តាមវិធាន ឪពុកត្រូវបង្រៀនដល់កូនប្រុសរបស់ខ្លួន។ ប៉ុន្តែដោយសារគ្រូត្រូវគេចាត់ទុកជាឪពុកផ្នែកព្រលឹងវិញ្ញាណនៃសិស្សរបស់ខ្លួន គេក៏អាចប្រែពាក្យ *បិតុះ* 'បានពីឪពុក (ផ្នែកព្រលឹងវិញ្ញាណ) របស់ខ្លួន' បានដែរ។

**៤.** គោត. ជំពូក៤ លេខ១; វស. ជំពូក៨ លេខ១; យញ្ញ. ជំពូក១ លេខ៥២។ បើនិយាយពី 'សញ្ញានៃជោគល្អផ្នែក រូបកាយ' សូមមើល *សាំខាយន,* គ្ឫហ្យ-សូត្រ ជំពូក១ លេខ៥, ១០។ សូមមើលកាព្យ ៧-១០ ខាងក្រោមផង។

**៥.** អាប. ជំពូក២ លេខ១១, ១៥-១៦; គោត. ជំពូក៤ លេខ២-៥; វស. ជំពូក៨ លេខ១-២; ពោធ. ជំពូក២ លេខ១, ៣២-៣៨; វិ. ជំពូក២៤ លេខ៩-១០; យញ្ញ. ជំពូក១ លេខ៥៣។ *អសគោត្រា ក យា បុតុះ* 'ដែលមិនស្ថិតក្នុងគ្រួសារតែមួយ ខាងឪពុក' ហើយតាមលោកមេធ. និងកុល្ល. គឺថា 'នៅចន្លោះគ្រួសារខាងឪពុក និងកូនកំលោះ គ្មានទំនាក់ទំនងសាច់ឈាមទេ'។ យ៉ាងណាមិញ ទំនងជាអាចនិយាយថា គោត្រ មានន័យពីរ គឺ *វ៉ៃទិក* និង *លោកិក* គោត្រ និងថា ក្នុងករណីជាព្រាហ្មណ៍ ការភ្ជាប់ចំណងអាពាហ៍ពិពាហ៍រវាងគ្រួសារនានា ជាប់ចំណងលោហិតពីសែពី*ឫសី* តែមួយ ហើយក្នុងជាអារ្យ៉ែនផ្សេងទៀត រវាងគ្រួសារនានាដែលមានឈ្មោះដូចគ្នា ឬ ដែលគេដឹងមានជាប់ពាក់ព័ន្ធ ត្រូវហាមឃាត់។ កុល្ល., នារ និងរាឃ. ប្រកាន់ជំហរថា *ក* ដំបូង គឺ 'និង' សបញ្ជាក់ថា អសគោត្រា សំដៅដល់សែខាងម្ដាយដែរ ហើយលោកមេធ., កុល្ល., នារ. និងរាឃ. គិតថា បើនិយាយពីពាក្យ *ក* ទី២ ពាក្យ អសបិណ្ឌា ប្រាកដជាសំដៅដល់សែខាងឪពុកដែរ ដូច្នេះគឺថា ចំណងអាពាហ៍ពិពាហ៍ជាមួយកូនស្រីនៃម្ដាយមីងខាងឪពុក ឬបច្ឆាជនខាងស្រីនៃសៃជីតាខាងឪពុក ត្រូវហាមឃាត់។ *មៃថុនេ* 'សម្រាប់ការរួមរស់ជាសហព័ទ្ធ' (មេធ., គោវ., នារ.) ហើយតាម លោកកុល្ល. និងរាឃ. គឺ 'សម្រាប់ពិធីដ៏ពិសិដ្ឋ ដែលប្ដីប្រពន្ធត្រូវធ្វើរួមគ្នា'។ នន្ទ. អាន *អមៃថុនី* 'អ្នកដែល នៅព្រហ្មចារី'។ ចំពោះពាក្យ *សបិណ្ឌ* សូមមើលជំពូក៥ លេខ៦០ ខាងក្រោម។

៧- (ដូចជា) គ្រួសារដែលមិនធ្វើពិធីពិសិដ្ឋ គ្រួសារដែលគ្មានកូនប្រុស គ្រួសារដែលមិនសិក្សាព្រះវេទ គ្រួសារ(ដែលមានសមាជិក)មានរោមក្រាស់នៅលើខ្លួន គ្រួសារដែលកើតឫសដូងបាត របេងសួត ខ្សោយពោះវៀន ឆ្កួតជ្រូក ឬកើតឃ្លង់ស និងឃ្លង់ខ្មៅ។

៨- ចូរគេកុំរៀបការជាមួយស្រីក្រមុំ(ដែលមាន)សក់ក្រហម កុំការជាមួយអ្នកដែលមានសមាជិកច្រើន កុំការជាមួយអ្នកដែលមានជំងឺ កុំការជាមួយអ្នកដែលគ្មានរោម(នៅលើ)ខ្លួនសោះ ឬមាន រោមច្រើនពេក កុំការជាមួយអ្នកដែលនិយាយច្រើន ឬ (ភ្នែក) ក្រហម,

៩- កុំការជាមួយអ្នកដែលដាក់ឈ្មោះតាមតារានិករ ដើមឈើ ឬទន្លេ កុំការជាមួយអ្នកដែលមានឈ្មោះក្នុងវណ្ណៈទាបឬដែលមានឈ្មោះជាភ្នំ កុំការជាមួយអ្នកដែលដាក់ឈ្មោះតាមសត្វស្លាប ពស់ ឬទាសករ កុំការជាមួយអ្នកដែលមានឈ្មោះគួរឱ្យខ្លាច។

១០- ចូរឱ្យគេរៀបការជាមួយស្ត្រីដែលគ្មានទុពលភាពលើរាងកាយ ដែលមានឈ្មោះល្អ មានដំណើរល្អ ដូចជាហំសៈ ឬដំរី មានរោមល្មមលើរាងកាយនិងសក់ ធ្មេញល្អិត និងអវយវៈទន់ល្វន់។

១១- ប៉ុន្តែបុរសឈ្លាត់ចត់មិនគួររៀបការជាមួយ (ស្រីក្រមុំ) ដែលគ្មានបងប្អូនប្រុស អ្នកដែលមិនមានឪពុកច្បាស់លាស់ ក្រែលោ(ឆ្លងតាមអ្នកជំនាន់មុនរបស់នាង) កូនស្រីសុំ (ហើយក្នុងករណី ក្រោយនេះ) ប្រយ័ត្ន(គេនឹងប្រព្រឹត្ត)បាបកម្ម។

១២- សម្រាប់អាពាហ៍ពិពាហ៍លើកទីមួយរបស់បុរសមានកំណើតពីរដង គួរយកប្រពន្ធដែលមានវណ្ណៈ ស្មើគ្នា ប៉ុន្តែសម្រាប់អ្នកដែលចង់(រៀបការម្តងទៀត) ចូរជ្រើសរើសស្ត្រីដែលមានវណ្ណៈក្នុងលំដាប់ជាមួយគ្នា ទើបជាការប្រសើរបំផុត។

១៣- តាមបញ្ញត្តិប្រកាសគឺថា ស្ត្រីសូទ្រៈ (អាចតែជា)ភរិយារបស់សូទ្រៈប៉ុណ្ណោះ, នាងនិងបុរសដែលស្ថិតក្នុងវណ្ណៈវៃស្យៈ អាចជាប្តីប្រពន្ធនឹងគ្នា អ្នកទាំងពីរនិងបុរសក្នុងវណ្ណៈក្សត្រិយដូចគ្នាអាចការជាមួយគ្នាបាន អ្នកទាំងបីនិងបុរសក្នុងវណ្ណៈព្រាហ្មណ៍ដូចគ្នាអាចរៀបការជាមួយគ្នាបាន។

---

**៧.** វិ. ជំពូក២៤ លេខ១១; យញ្ញ. ជំពូក១ លេខ៥៤។

**៨.** យញ្ញ. ជំពូក១ លេខ៥៣; វិ. ជំពូក២៤ លេខ១២-១៦។

**១១.** យញ្ញ. ជំពូក១ លេខ៥៣។ ឃ្លា 'ក្រែងលោ គេនឹងប្រព្រឹត្តបាបកម្ម' គឺ រៀបការជាមួយ *សគោត្រា* ឬ អ្នកដែលរស់នៅក្នុងគ្រួសារគ្មានសីលធម៌។ ការប្រែនេះយកតាមលោក កុល្ល., នារ., រាឃ. និងអ្នកផ្សេងទៀត តាមប្រសាសន៍របស់លោក មេធ.។ ប៉ុន្តែមេធ. ខ្លួនឯង បកស្រាយកាព្យផ្សេងថា 'បុរសឈ្លាត់ចង់ មិនគួររៀបការជាមួយ(ស្រីក្រមុំ) ដែលគ្មានបងប្អូនប្រុស បើគេមិនស្គាល់ឪពុកនាង (ពោលគឺស្លាប់ ឬមិនដឹង) ចូរប្រយ័ត្នបើនាងជាកូនចិញ្ចឹម' ចំណែកឯគោវ. បកស្រាយកាព្យនេះថា 'បុរសឈ្លាត់ចត់មិនគួររៀបការជាមួយ(ស្រីក្រមុំ) ដែលគ្មានបងប្អូនប្រុស ឬដែលគេមិនស្គាល់ឪពុកនាង ចូរប្រយ័ត្នបើនាងជាកូនចិញ្ចឹម'។ យោងតាមសេចក្តីក្រោយនេះ អាចនិយាយបានថា ក្នុងករណីគេមិនស្គាល់ឪពុក គឺថា នាងអាចជាប់សាច់ឈាមពាក់កណ្តាលប៉ុណ្ណោះជាមួយបងប្អូនប្រុសរបស់នាង ហើយឪពុកនាងពិតប្រាកដ ដែលគ្មានកូនអាចយកនាងមកធ្វើជាកូនចិញ្ចឹម។

**១២.** វិ. ជំពូក២៤ លេខ១-៤; ពោធ. ជំពូក១ លេខ១៦, ២-៥។

**១៣.** យញ្ញ. ជំពូក១ លេខ៥៦; វិ. ជំពូក១ លេខ២៥-២៦។

១៤- ស្ត្រីសូទ្រៈ មិនមានការរៀបរាប់សូម្បីនៅក្នុងរឿង(បុរាណ)ណាមួយ ថាជាភរិយា(ទី១)របស់ ព្រាហ្មណ៍ ឬរបស់ក្សត្រិយទេ ទោះបីពួកគេបានធ្លាក់ខ្លួនរស់នៅក្នុងគ្រាអាសន្ន(បំផុត)ក្តី។

១៥- បុរសកើតពីរដង ដែលរៀបការភរិយាដែលមានវណ្ណៈទាប(សូទ្រៈ) ដោយចិត្តពាលរបស់ខ្លួន ធ្វើ ឱ្យអាប់ឱនកិត្តិយសគ្រួសាររបស់ខ្លួនភ្លាមៗ ហើយកូនរបស់គេនឹងក្លាយជាសូទ្រៈ។

១៦- យោងតាម *អត្រិ* និង(គោតម)បុត្ររបស់ឧតថ្យ អ្នកដែលរៀបការជាមួយស្ត្រីសូទ្រៈ ក្លាយជា សូទ្រៈ យោងតាមសោនកៈ នៅពេលមានបុត្រ ហើយយោងតាមភ្រិគុ អ្នកដែលមានកូន(ប្រុស) ដែលកើតពីស្ត្រី (សូទ្រៈប៉ុណ្ណោះ)។

១៧- ព្រាហ្មណ៍ដែលយកប្រពន្ធសូទ្រៈ ឡើងលើគ្រែរបស់ខ្លួន (បន្ទាប់ពីស្លាប់) នឹងធ្លាក់នរក ប្រសិន បើគេមានកូនជាមួយនាង គេនឹងបាត់ឋានៈជាព្រាហ្មណ៍។

១៨- បុព្វបុរសនិងទេវតា នឹងមិនទទួលសោយ(ការបូជា)របស់បុរស ដែលធ្វើពិធីថ្វាយទេវតា បុព្វបុរសនិងភ្ញៀវនានាដោយជំនួយពិសេសពី (ភរិយាសូទ្រៈ) ទេ ហើយបុរស (នោះ) នឹងមិនបានឡើងឋានសួគ៌ឡើយ។

១៩- ចំពោះអ្នកដែលថើបជជក់មាត់សូទ្រៈ ដែលសៅហ្មងដោយខ្យល់ដង្ហើមរបស់នាង និងដែលមានបុត្រជាមួយនាង គេមិនអាចលុបលាងទោសបានទេ។

២០- ឥឡូវចូរស្តាប់នូវ (ការពណ៌នា) សង្ខេបអំពីពិធីអាពាហ៍ពិពាហ៍ប្រាំបីយ៉ាងខាងក្រោម សម្រាប់វណ្ណៈទាំងបួន ដែលមួយផ្នែកនាំមកនូវប្រយោជន៍ និងមួយផ្នែកនាំមកនូវអំពើបាប សម្រាប់ជាតិនេះ និងជាតិក្រោយផង។

---

**១៤.** វស. ជំពូក១ លេខ២៧; គោត. ជំពូក១៥ លេខ១៨; អាប. ជំពូក១ លេខ១៨, ៣៣។

**១៥.** វិ. ជំពូក២៥ លេខ៦។

**១៦.** ពោធ. ជំពូក២ លេខ២-៧។ ការប្រែខាងលើ យកតាមលោកមេធ., គោវ., នន្ទ. និងរាឃ.។ ប៉ុន្តែលោកកុល្ល. ប្រែអនុប្រយោគចុងក្រោយផ្សេងថា `យោងតាមភ្រិគុ នៅពេលមានកំណើតកូនប្រុស´។ តាមអត្ថបទសម្រង់របស់លោកនារ. បញ្ជាក់ថា ការប្រែនេះមានការគាំទ្រពី*ភវិស្យ បុរាណ* ដែលតាមធម្មតាបកស្រាយអត្ថបទមនុ *បុត្រស្យ បុត្រំ អាសាទ្យ សោនកៈ សូទ្រតាំ គតៈ / ភ្រិគ្វាទយោ បី អេវំ អេវ បតិតត្វំ អវាប្នុយុះ* ។ លើសពីនេះ ដូចសេចក្ដីនេះបានបង្ហាញការបកស្រាយបុរាណនៃកាព្យរបស់យើង ដែលយោងតាមនាមរបស់ឫសីនានា មិនបានបញ្ជាក់អ្នកនិពន្ធគម្ពីរច្បាប់ទេ ប៉ុន្តែមានបញ្ជាក់ពី គោត្ររបស់អ្នកបង្កើត។ លោកនារ. ប្រកាន់យកទស្សនៈនេះ ហើយលោកយល់ថា ការប្រែគួរមានន័យថា `(បុរសនៃគ្រួសារ) របស់អត្រិ ដែលរៀបការជាមួយស្ត្រីសូទ្រៈ ក្លាយជាសូទ្រ (ជាអំបូរមួយ)នៃបុត្ររបស់ឧតថ្យ ពេលមានកំណើតកូនប្រុស និងមានគោត្ររបស់សោនកៈ ឬរបស់ភ្រិគុ ដោយគ្មានកូនផ្សេងក្រៅពីសូទ្រៈទេ´។ គួរឱ្យកត់សម្គាល់ថា យោងតាម កុល្ល. ម្នាក់ឯង ខ-បី សំដៅដល់ព្រាហ្មណ៍ ក្សត្រិយ និងវៃស្យៈ តាមលំដាប់។ រាឃ. ជំទាស់ដាច់ខាតចំពោះយោបល់នេះ ហើយគាត់យល់ថា `មួយចំនួន´។

**១៨.** វស. ជំពូក១៤ លេខ១១; វិ. ជំពូក២៥ លេខ៧។

២១- ធីរបស់ឫសី(អាសៈ) ពិធីរបស់ប្រគា-បតិ(ប្រាគាបត្យ)ពិធីរបស់អសុរៈ(អាសុរៈ)ពិធីរបស់គន្ធវៈ(គាន្ធវៈ) ពិធីរបស់រាក្សសៈ(រាក្សសៈ) និងពិធីរបស់បិសាកៈ(បៃសាកៈ)។

២២- ដែលស្របច្បាប់សម្រាប់វណ្ណៈនីមួយៗ និងដែលជាកុសល ឬទោសសម្រាប់(ពិធី)មួយៗ រឿង ទាំងនេះ ខ្ញុំនឹងប្រកាសប្រាប់អ្នក ព្រមទាំងចំណុចល្អ និងអាក្រក់របស់វា ដែលពាក់ព័ន្ធនឹងកូន។

២៣- គេអាចដឹងថា ពិធីប្រាំមួយដំបូងតាមលំដាប់(ដូចខាងលើ) គឺស្របច្បាប់សម្រាប់ពួកព្រាហ្មណ៍ បួនចុងក្រោយសម្រាប់ពួកក្សត្រិយនិងបួនដដែល លើកលែងតែពិធីរក្សសៈសម្រាប់ពួកវៃស្យៈ និងសូទ្រៈ។

២៤- បណ្ឌិតអះអាងថា ពិធីបួនដំបូងគឺសម្រាប់ព្រាហ្មណ៍មួយ ពិធីរក្សសៈសម្រាប់ក្សត្រិយ និងអាសុរៈ(ពិធីរៀបការ)សម្រាប់វៃស្យ និងសូទ្រៈ។

២៥- ប៉ុន្តែតាមគោលការណ៍ច្បាប់ពិសិដ្ឋទាំងនេះ ពិធីបីក្នុងចំណោមពិធីប្រាំ(ចុងក្រោយ) ត្រូវបានប្រកាសថាស្របច្បាប់ និងពីរ ខុសច្បាប់ ហើយ(ពិធី)បៃសាកៈ និងអាសុរៈ កុំប្រើឱ្យសោះ។

២៦- សម្រាប់ពួកក្សត្រិយ ពិធីពីរដែលបានរៀបរាប់ពីមុន គាន្ធវៈ និងរាក្សសៈ ត្រូវបានអនុញ្ញាតដោយប្រពៃណីពិសិដ្ឋ ទោះជាធ្វើដោយឡែកពីគ្នាក៏បាន ឬលាយគ្នាក៏បាន។

២៧- ជំនូនរបស់កូនស្រី ក្រៅពីការតុបតែឱ្យនាង (ដោយសម្លៀកបំពាក់មានតម្លៃ) និងផ្តល់កិត្តិយសឱ្យនាងដោយ (អំណោយរតនៈ) សម្រាប់ជូនខាងប្រុសដែលបានសិក្សាព្រះវេទ និងមានចរិយាមារយាទល្អ ដែល(ឪពុក)ខ្លួនអញ្ជើញដោយផ្ទាល់ គេហៅពិធីនេះថាពិធីព្រាហ្មណ៍។

២៨- ជំនូនរបស់កូនស្រី ដែលត្រូវតុបតែដោយគ្រឿងអលង្ការជូនអាចារ្យ ដែលជាអ្នករៀបចំពិធីត្រឹមត្រូវក្នុងពេលធ្វើពិធីនោះ គេហៅពិធីនេះថា ពិធីទេវៈ។

២៩- ពេល(ឪពុក)ឱ្យទៅកូនស្រីរបស់ខ្លួននូវមេគោនិងគោឈ្មោល ឬគោពីរនឹមស្របតាមតម្រា បន្ទាប់ពីទទួលបានពីកូនកំលោះ សម្រាប់(ការអនុវត្តតាម)ច្បាប់ពិសិដ្ឋ ពិធីនេះគេឱ្យឈ្មោះថា ពិធីអាសៈ។

---

**២១-៣៤.** អាប. ជំពូក២ លេខ១១, ១៧-២១; គោត. ជំពូក៤ លេខ៦-១៥; វស. ជំពូក១ លេខ១៧-៣៥; ពោធ. ជំពូក១ លេខ២០, ១-២១, ២៣; វិ. ជំពូក២៤ លេខ១៨-២៨; យញ្ញ. ជំពូក១ លេខ១, ៥៨-៦១។

**២៣.** ហាក់ដូចជាច្បាស់ណាស់ កាព្យនេះ និងកាព្យបីបន្ទាប់ ដូច Sir W. Jones យល់ថា មានមតិខ្វែងគ្នាច្រើនស្តីពីការអនុញ្ញាតឱ្យរៀបចំពិធីអាពាហ៍ពិពាហ៍ផ្សេងៗគ្នា។ ប៉ុន្តែអ្នកអធិប្បាយព្យាយាមសម្របសម្រួលគំនិតទាំងនោះ ដោយប្រើវិធីបកស្រាយផ្សេងៗ។

**២៦.** 'ចម្រុះ' គឺនៅពេលគេពង្រាត់ស្ត្រីដោយបង្ខំពីផ្ទះឪពុករបស់នាង បន្ទាប់ពីគេដឹងជាមុនថានាងនៅជាមួយសហាយ។

**២៧.** នារ. និងរាឃ. សំដៅដល់ពាក្យ *អាកាយិត្វា* 'បន្ទាប់ពីផ្តល់កិត្តិយស' ដល់កូនកំលោះ និងទទួលយកក្នុងន័យ 'បន្ទាប់ពីផ្តល់កិត្តិយស (ឱ្យកូនកំលោះនូវអាហារលាយទឹកឃ្មុំ)'។

**២៩.** 'សម្រាប់ការ(ប្រតិបត្តិតាម)ច្បាប់ពិសិដ្ឋ' គឺ 'មិនមានចេតនាលក់កូនរបស់ខ្លួនទេ' (មេធ.) សូមមើលកាព្យលេខ៥១-៥៤ ខាងក្រោមផង។ 'យោងតាមវិធាន' គឺ 'ដោយសូត្រតាមការបញ្ញត្តិដើម្បីជាការអំណោយ' (នារ.)។

៣០- ជំនូនរបស់កូនស្រី (ដែលឪពុកនាងឱ្យ) បន្ទាប់ពីគាត់បានពោលពាក្យទៅកាន់(គូស្វាមីភរិយា) ថា 'ចូរកូនទាំងពីព្យាយាមបំពេញករណីយកិច្ចរបស់ខ្លួនរួមគ្នា' និងបានផ្តល់កិត្តិយស (ដល់កូនកំលោះ) តាមតម្រាគេហៅថាពិធីប្រាគាបត្យ។

៣១- នៅពេល (កូនកំលោះ)ទទួលកូនក្រមុំ បន្ទាប់ពីបានផ្តល់ទ្រព្យច្រើនតាមលទ្ធភាពដែលគាត់អាចផ្តល់បានទៅឱ្យញាតិសន្តានខាងប្រុស និងកូនក្រមុំផ្ទាល់ ស្របតាមឆន្ទៈផ្ទាល់របស់គាត់ គេហៅ ពិធីនោះថាពិធីអាសុរៈ។

៣២- ការរួមរស់ដោយស្ម័គ្រចិត្តរបស់កូនក្រមុំជាមួយគូស្នេហ៍របស់នាង ពិធីនេះជាពិធីគាន្ធវៈ ដែលកើតចេញពីតម្រេក និងមានការរួមសង្វាស់តាមចំណង់តម្រេក។

៣៣- ការចាប់ពង្រាត់ដោយបង្ខំនូវកូនក្រមុំពីផ្ទះរបស់នាង ខណៈនាងស្រែកយំ បន្ទាប់ពី(ញាតិសន្តានខាងប្រុសរបស់នាង)ត្រូវគេវាយដំឬសម្លាប់ និងកម្ទេច(ផ្ទះរបស់ពួកគេ)ខ្ទេចខ្ទី គេហៅពិធីនេះ ថាជាពិធីរាក្សសៈ។

៣៤- នៅពេល(បុរស)មានចិត្តមិនស្មោះត្រង់ប្រលោមក្មេងស្រីម្នាក់ ដែលកំពុងដេកស្រវឹង ឬពុល ឬមានសតិបញ្ញាមិនគ្រប់គ្រាន់ នោះជាពិធីទីប្រាំបី ជាពិធីក្រោយគេនិងជាពិធី*បិសាកៈ* (ពិធីបិសាច) ប្រកបដោយបាបកម្ម។

៣៥- ជំនូនរបស់កូនស្រីក្នុងចំណោមពួកព្រាហ្មណ៍ ត្រូវបានកំណត់ ប្រសិនបើគេធ្វើពិធីសែនទឹកជាមុន ប៉ុន្តែសម្រាប់វណ្ណៈដទៃ (គេអាចផ្អែកលើការព្រមព្រៀងគ្នាទៅវិញទៅមក។

៣៦- ឥឡូវចូរស្ដាប់ខ្ញុំសិន ម្នាលព្រាហ្មណ៍ ខណៈពេលដែលខ្ញុំប្រកាសទាំងស្រុងនូវលក្ខណៈសម្បត្តិ ដែលមនុបានលើកហេតុផលសំអាងចំពោះពិធីអាពាហ៍ពិពាហ៍នីមួយៗ។

---

**៣០.** 'បន្ទាប់ពីបានផ្តល់កិត្តិយស' គឺ 'ឱ្យទៅកូនកំលោះនូវអាហារលាយទឹកឃ្មុំ' (នារ., នន្ទ.)។

**៣១.** 'ស្របតាមឆន្ទៈផ្ទាល់របស់ខ្លួន' គឺ 'មិនស្របតាមការទូន្មាននៃច្បាប់ពិសិដ្ឋទេ ដូចជាក្នុងធ្វើពិធីអាសៈ' (មេធ., គោវ., កុល្លូ., នារ., នន្ទ.)។

**៣២.** គោវ. និងនន្ទ. ត្រង់ចំណុចនេះ លើកចំណោទបញ្ហាថាតើការផ្តល់ជំនូនតាមការរៀបរាប់ និងពិធីអាពាហ៍ពិពាហ៍ ត្រូវគេធ្វើឡើងតាមពិធីគាន្ធវៈ, រាក្សសៈ និងបៃសាកៈ ឬទេ។ ដោយផ្អែកលើសេចក្តីរបស់ទេវលៈ និងពហ្វកៈ គ្នុហ្យបរិសិស្ត (សោនកៈ) ពួកគេមានយោបល់ថា គេត្រូវតែពិធី*ហោមៈ* យ៉ាងហោចណាស់ក្នុងករណីគូស្វាមីភរិយាអារ្យ័ន។ ប៉ុន្តែពួកគេមានមតិសង្កត់ធ្ងន់លើភាសិតរបស់មនុ ជំពូក ៨ លេខ២២៦ ដែលកំណត់អំពីការប្រើ*មន្ត្រៈ* ចំពោះស្ត្រី ដែលរៀបការទាំងនៅព្រហ្មចារី នោះគេមិនចាំបាច់សូត្រធម៌អាពាហ៍ពិពាហ៍តាមបែបវេទទេ។ យោងតាមយោបល់របស់មេធ. ស្តីពីកាព្យលេខ ៣៤ ទំនងជាមានន័យថា គេអាចចែកយោបល់ទាំងនេះបាន ហើយថាអ្នកខ្លះរៀបពិធីអាពាហ៍ពិពាហ៍ដោយការសូត្រមន្ត្រៈដើម្បីជាការសុំអនុញ្ញាត ចំណែកឯខ្លះទៀតមិនព្រមទទួលស្គាល់សារសំខាន់នៃពិធីអាពាហ៍ពិពាហ៍ទេ។

**៣៥.** *ឥតរេតរកាំយយា* 'ដោយ(ការមាន)ការព្រមព្រៀងគ្នាទៅវិញទៅមក' គឺដោយឪពុកម្តាយ ហើយតាមលោកមេធ. យល់ថា 'ដោយសារបំណងប្រាថ្នាទៅវិញទៅមករបស់កូនក្រមុំ និងកូនកំលោះ'។ ប៉ុន្តែលោកក៏មានការបកស្រាយផ្សេងទៀតដែរ។ អត្ថបទនេះ ទំនងជាសំដៅដល់ប្រពៃណីទំនៀមទម្លាប់ ដូចជាពិធីបញ្ចូនផ្លែដូង ដែលធម្មតាស្របតាមសំណើរបស់ពួកក្សត្រិយ។

៣៧- បុត្ររបស់ភរិយា ដែលបានរៀបការស្របតាមពិធីព្រហ្ម ប្រសិនបើគេប្រព្រឹត្តអំពើប្រកបដោយគុណធម៌ ជួយរំដោះបាបកម្មជូនដូនតាដប់ជាតិ បច្ឆាជនដប់ជាតិ និងខ្លួនឯងបានម្តៃមួយជាតិ។

៣៨- បុត្រដែលកើតចេញពីភរិយាដែលបានរៀបការតាមពិធីទេវៈ ដូចនេះអាច (ជួយសង្គ្រោះ) ដូនតា បានប្រាំពីរជាតិនិងបច្ឆាជនប្រាំពីរជាតិ, បុត្រនៃភរិយាដែលបានរៀបការតាមពិធីអាសៈ ជួយសង្គ្រោះ (អ្នកជំនាន់មុន និងអ្នកជំនាន់ក្រោយ)បីតំណ ហើយបុត្រនៃភរិយាដែលបានរៀបការ តាមពិធី *កា* (ប្រគាបតិ) ជួយសង្គ្រោះបានប្រាំមួយជាតិ(តាមសៃនីមួយៗ)។

៣៩- ផ្តើមចេញពីអាពាហ៍ពិពាហ៍ចំនួនបួន (ដូចបានរៀបរាប់)ជាបន្តបន្ទាប់ ដែលចាប់ផ្តើមដោយពិធី ព្រហ្មជប់បុត្រ ដែលចេញរស្មីពីពុទ្ធិនៃព្រះវេទ និងផ្តល់កិត្តិយសដោយសិស្ត (មនុស្សល្អ)។

៤០- ដោយបានទទួលគុណសម្បត្តិផ្នែកសោភណភាពនិងសេចក្តីល្អ ដែលមានទ្រព្យនិងកិត្តិស័ព្ទ ទទួលបាននូវការសប្បាយរីករាយស្របតាមសេចក្តីប្រាថ្នានិងសមតាមបំណង ពួកគេនឹងមានជីវិតរស់នៅរហូតដល់អាយុមួយរយឆ្នាំ។

៤១- ប៉ុន្តែបើនិយាយពីអាពាហ៍ពិពាហ៍មិនល្អ (បួន) ទៀត នឹងផ្តល់កំណើតបុត្រដែលមានសារជាតិ ឃោរឃៅ និងជាអ្នកនិយាយគ្មានការពិត ដែលស្អប់ព្រះវេទ និងច្បាប់ពិសិដ្ឋ។

៤២- ដោយសារមានភាពមិនល្អនេះ កូនដែលកើតចេញពីអាពាហ៍ពិពាហ៍មិនល្អ គឺជាមនុស្សអាក្រក់ (ជាកូនមិនល្អ) ហេតុនេះអ្នកទាំងឡាយគួរតែជៀសវាងនូវ(ទម្រង់អាពាហ៍ពិពាហ៍)មិនល្អនេះ។

៤៣- ពិធីចងដៃត្រូវបានកំណត់ (សម្រាប់អាពាហ៍ពិពាហ៍ជាមួយ) ស្ត្រីដែលមានវណ្ណៈស្មើគ្នាហើយ ចូរយល់ថា វិធានខាងក្រោម (គឺសម្រាប់អនុវត្តចំពោះ) ការរៀបអាពាហ៍ពិពាហ៍ជាមួយស្ត្រី ដែលមានវណ្ណៈផ្សេងគ្នា។

៤៤- ចំពោះការរៀបការរបស់បុរសដែលមានវណ្ណៈខ្ពស់ជាងកូនក្រមុំត្រកូលក្សត្រិយ ត្រូវកាន់ព្រួញកូនក្រមុំវៃស្យៈត្រូវកាន់ជញ្ជួញ និងស្ត្រីសូទ្រៈត្រូវកាន់ជាយសម្លៀកបំពាក់(របស់កូនកំលោះ)។

៤៥- ចូរ(ប្តី)ចូលទៅរកប្រពន្ធរបស់ខ្លួនតាមកាលសមគួរ ដោយខិតខំបំពេញចិត្តនាង(ដែលនៅឯកា) ហើយប្តីក៏អាចធ្វើឱ្យករិយាសប្បាយចិត្ត ចូលទៅរកនាងដោយចេតនាផ្សារសាច់ផ្សារឈាម (នៅថ្ងៃណាក៏បាន) លើកលែងតែថ្ងៃ*បវ័ន*។

---

**៣៧-៤២.** វិ. ជំពូក២៤ លេខ២៩-៣២; គោត. ជំពូក៤ លេខ២៩-៣៣; ពាធ. ជំពូក១ លេខ២១, ១; អាប. ជំពូក១ លេខ១២, ៤; យញ្ញ. ជំពូក១ លេខ៥៨-៦០, ៩០។

**៣៩.** យោងតាមការបកស្រាយពាក្យ *សិល្ប:* សូមមើលជំពូក១២ លេខ១០៩ខាងក្រោម។

**៤០.** គោវ. និងកុល្ល. ឱ្យន័យគុណនាមទីមួយផ្សេងគ្នា 'ដែលបានផ្តល់នូវសោភណភាព សេចក្តីល្អ និងគុណសម្បត្តិប្រពៃដទៃទៀត'។ យោងតាមពាក្យ 'សេចក្តីល្អ'(សត្វៈ) សូមមើលជំពូក១២ លេខ៣១ខាងក្រោម។

**៤៣.** វិ. ជំពូក២៤ លេខ៥-៨; យញ្ញ. ជំពូក១ លេខ៦២។

**៤៤.** កូនកម្លោះកាន់ចុងព្រួញ ឬជញ្ជួញម្ខាងទៀត ដោយនិយាយពាក្យដូចគ្នា ក្នុងពេលកាន់ដៃកូនក្រមុំដែលមានវណ្ណៈ ស្មើគ្នា (នារ.)។

**៤៥.** យញ្ញ. ជំពូក១ លេខ៨០-៨១; អាប. ជំពូក២ លេខ១៧-១៨; គោត. ជំពូក៥ លេខ១-២; វស. ជំពូក១២ លេខ២១-

៤៦- ដប់ប្រាំមួយ(ថ្ងៃនិង)យប់ (ក្នុងមួយខែ) បន្ថែមបួនថ្ងៃទៀត ក្រៅពីថ្ងៃដែលនៅសល់ និងថ្ងៃដែលត្រូវហាម គេហៅថារដូវកាលធម្មជាតិរបស់ស្ត្រី។

៤៧- ប៉ុន្តែក្នុងចំណោមបួនថ្ងៃដំបូងនេះ ថ្ងៃទីដប់មួយនិងទីដប់បី គឺជាថ្ងៃហាមឃាត់ ហើយយប់ផ្សេងទៀតអាចរួមសង្វាសបាន។

៤៨- ការរួមសង្វាសនៅយប់ថ្ងៃគូនឹងបានកូនប្រុស ហើយយប់ថ្ងៃសេសនឹងបានកូនស្រី ដូច្នេះបុរសដែលប្រាថ្នាចង់បានកូនប្រុស គួរតែទៅប្រលោមប្រពន្ធខ្លួនតាមកាលគួរនៅ(យប់ថ្ងៃ)គូ។

៤៩- កូនប្រុស ត្រូវកើតចេញពីចំនួនកោសិកាពូជឈ្មោលច្រើនជាង កូនស្រីកើតពីចំនួនកោសិកាញីច្រើន។ ប្រសិនបើ(កោសិកាទាំងពីរ)មានចំនួនស្មើគ្នា កូនអាចខ្ទើយ ឬប្រុសនិងស្រី ប្រសិនបើ (កោសិកាទាំងពីរ)ខ្សោយ ឬមិនគ្រប់ចំនួន គឺមិនអាចផ្តល់កំណើតបានទេ។

៥០- អ្នកដែលមិនប្រតិព័ទ្ធស្ត្រីក្នុងប្រាំមួយយប់ហាមឃាត់ និងប្រាំបីយប់ផ្សេងទៀត គឺ (បីដូចជាអ្នកមានកាយចិត្តបរិសុទ្ធដូច)អ្នកសិក្សា ដែលគេអាចរស់នៅតាមរបៀបណាក៏បាន។

៥១- គ្មានឪពុកណាដែលចេះ(ច្បាប់) ត្រូវផ្តល់តម្លៃតិចបំផុតចំពោះកូនស្រីរបស់ខ្លួនទេ ព្រោះបុរសដែលមានសេចក្តីកំណាញ់ខ្លាំង មិនព្រមឱ្យតម្លៃកូនស្រី គឺជាការលក់កូនចៅរបស់ខ្លួន។

៥២- ប៉ុន្តែទំនាក់ទំនង(បុរស) ដែលរស់នៅលើចំណែកទ្រព្យរបស់ស្ត្រី (ឧ.ទា. យកមកធ្វើជារបស់ខ្លួននូវ)សត្វបម្រើ ការដឹកជញ្ជូន និងសម្លៀកបំពាក់របស់ស្ត្រី ជាការប្រព្រឹត្តបាបកម្ម ហើយនឹងធ្លាក់នរក។

៥៣- អ្នកខ្លះហៅថាគោញី និងគោឈ្មោល (ដែលឱ្យជា) 'អំណោយ'ក្នុងពិធី(រៀបការ)អាសៈ (ប៉ុន្តែ នោះជាអំពើខុសឆ្គង ព្រោះថា(ការទទួល)ថ្លៃឈ្នួល ទោះតិចក្តី ឬច្រើនក្តី ជាការលក់(កូនស្រី)។

---

២៤; វិ. ជំពូក៦៩ លេខ១; ពោធ.ជំពូក៤ លេខ១៧-១៩។ *តន្ត្រតៈ* 'ដែលចង់ធ្វើឱ្យនាងសប្បាយចិត្ត'(មេធ., កុល្លូ.) ហើយតាមនារ.យល់ថា'ដែលសុខចិត្តក្សោតាមវិធានស្តីពីបវ័ន'។ ចំពោះពាក្យ*បវ័ន* សូមមើលជំពូក៤លេខ១២៨ខាងក្រោម។

**៤៦.** យញ្ញ. ជំពូក១ លេខ៧៩។ ថ្ងៃដែលមនុស្សល្អប្រកាសថាមិនសមនឹងរួមសង្វាស គឺបួនថ្ងៃដំបូង បន្ទាប់ពីមករដូវ។

**៤៨.** យញ្ញ. ជំពូក១ លេខ៧៩។

**៥០.** 'គេអាចរស់នៅតាមរបៀបណាមួយក៏បាន' គឺ 'គេអាចរស់នៅជាមេគ្រួសារក៏បាន ឬជាតាបសរស់នៅក្នុងព្រៃក៏បាន' (កុល្លូ., នារ.)។ មេធ.គិតថា វាគ្រាន់តែជា*អាថ៌ាទ* និងមិននិយាយដល់របៀបរបបផ្សេងទេ ប៉ុន្តែនិយាយពីឃរាវាស(អ្នកមានគ្រួសារ) ចំណែកឯលោកគោវិន្ទ គិតថា កាព្យនេះក៏អនុញ្ញាតឱ្យរស់នៅជាតាបស ដែលចាកចោលកូនទាំងអស់របស់ខ្លួន អាចចូលទៅរកប្រពន្ធរបស់ខ្លួនបានពីរយប់ក្នុងមួយខែ។ កុល្លូ. រិះគន់មតិចុងក្រោយនេះដោយត្រង់ៗ។

**៥១.** អាប. ជំពូក២ លេខ១៣, ១១; វស. ជំពូក១ លេខ៣៧-៣៨; ពោធ. ជំពូក១ លេខ២១, ២-៣។

**៥២.** មេធ. ធ្វើការបកស្រាយកាព្យនេះតាមរបៀបមួយមុនគេ ដែលនារ. និងនន្ទ. គិតថាជាការបកស្រាយមួយដែលអាចទទួលយកបាន គឺ 'ប៉ុន្តែការទំនាក់ទំនង(របស់បុរស)ដែលមានចិត្តលីលា រស់នៅលើទ្រព្យដែលបានពី(ការលក់)ស្ត្រី (ឧទាហរណ៍) ជាការដឹកជញ្ជូន ឬសត្វបម្រើ និងសម្លៀកបំពាក់(សម្រាប់)ស្ត្រី ជាការប្រព្រឹត្តអំពើបាប'។ នន្ទ. និង កុល្លូ. អាន *នារី យានាទិ* 'ទាសកស្ត្រី ការដឹកជញ្ជូនជាដើម'។ ការជំទាស់ចំពោះការបកស្រាយរបស់នារ. គឺថា *នារិយានាទិ* មិនអាចមានន័យថា 'យកស្ត្រីធ្វើជាយានជំនិះ'។ ការអាន 'នារីៈ' ពិតជាការកែតម្រូវអក្ខរាតាមការស្មាន។

**៥៣.** អាប. ជំពូក២ លេខ១៣, ១២; វស. ជំពូក១ លេខ៣៦។

៥៤- ប្រសិនបើសាច់ញាតិមិនយកអំណោយដែលផ្តល់ឱ្យនោះ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននោះ មិនមែនជាការលក់ទេ (ក្នុងករណីនោះ) (អំណោយ)គ្រាន់តែជានិមិត្តរូបនៃការគោរព និងចិត្តមេត្តាចំពោះកូនក្រមុំ។

៥៥- ឪពុក បងប្អូនប្រុស ស្វាមី និងបងប្អូនប្រុសសាច់ថ្លៃដែលស្រឡាញ់សុខុមាលភាព(ផ្ទាល់ខ្លួន) ត្រូវតែផ្តល់កិត្តិយស និងផ្តល់គ្រឿងតុបតែងខ្លួនដល់ស្ត្រី។

៥៦- ទីណាមានការផ្តល់កិត្តិយសដល់ស្ត្រី ទីនោះមានការពេញចិត្តពីអាទិទេព ប៉ុន្តែទីណាដែលមិនផ្តល់កិត្តិយសដល់ស្ត្រី ការធ្វើពិធីពិសិដ្ឋនៅទីនោះនឹងមិនបានទទួលផលឡើយ។

៥៧- ទីណាដែលស្ថានភាពរបស់ស្ត្រីរស់នៅក្នុងទុក្ខព្រួយ គ្រួសារទាំងមូលនឹងវិនាសភ្លាមៗ ប៉ុន្តែគ្រួសារដែលស្ត្រីរស់នៅមិនមែនមិនសប្បាយចិត្តនោះ នឹងរុងរឿងជានិច្ច។

៥៨- ផ្ទះណាដែលស្ថានភាពស្ត្រីមិនត្រូវបានផ្តល់កិត្តិយសត្រឹមត្រូវ នឹងទទួលបានបណ្តាសា វិនាសទាំងស្រុងហាក់ដូចជារលាយដោយសារគ្រូវេទមន្ត។

៥៩- ដូច្នេះបុរស ដែលស្វែងរកសុខុមាលភាព(ផ្ទាល់ខ្លួន) គួរតែផ្តល់កិត្តិយសដល់ស្ត្រីជានិច្ច នៅថ្ងៃបុណ្យទានដោយផ្តល់(អំណោយ)គ្រឿងអលង្ការ សម្លៀកបំពាក់ និងអាហារ(ប្រណិតៗ)។

៦០- នៅក្នុងគ្រួសារដែលមានស្វាមីរីករាយនឹងភរិយារបស់ខ្លួន ហើយភរិយារីករាយនឹងស្វាមីខ្លួន សុភមង្គលប្រាកដជានឹងកើតមានជាមិនខាន។

៦១- ព្រោះថា បើភរិយាមិនពោរពេញដោយសោភណ នាងនឹងមិនអាចទាក់ទាញប្តីខ្លួនបានទេ ប៉ុន្តែបើនាងគ្មានការទាក់ទាញសម្រាប់ប្តីទេ កូននឹងមិនអាចកើតមានឡើយ។

៦២- ប្រសិនបើភរិយាមានរូបឆោមលោមល្អ ផ្ទះទាំងមូលនឹងភ្លឺចិញ្ចែងចិញ្ចាច ប៉ុន្តែប្រសិនបើនាងខ្វះនូវរូបសម្បត្តិល្អ អ្វីៗទាំងអស់នឹងប្រែទៅជាគួរឱ្យសង្វេគណាស់។

៦៣- ដោយការរៀបអាពាហ៍ពិពាហ៍កម្រិតទាប ដោយលុបចោល(ការធ្វើ)ពិធីពិសិដ្ឋ ដោយធ្វេសប្រហែសក្នុងការសិក្សាព្រះវេទ និងដោយមិនគោរពចំពោះព្រាហ្មណ៍ (មហា) គ្រួសារនឹងធ្លាក់ចុះដុនដាប។

៦៤- ដោយ(ការសង្វាត)ការងារសិប្បកម្ម ដោយការជួញដូរប្រាក់កាសដោយ(ការបង្កើត)កូនជាមួយស្ត្រីសូទ្រៈប៉ុណ្ណោះ ដោយ(ការជួញ)មេគោ សេះ និងរទេះ ដោយ(ការប្រកបរបរ)កសិកម្ម និងដោយការបម្រើព្រះមហាក្សត្រិយ,

---

**៥៥-៦០.** យញ្ញ. ជំពូក១ លេខ៨២។
**៥៨.** សំណៅមួយចំនួនរបស់លោកមេធ. លុបចោលកាព្យលេខ៥៨-៦៦។
**៥៩.** ជំនួសឱ្យពាក្យ *សត្តារសុ* (លោកគោវ. ប្រើពាក្យ *សំករសុ*) 'នៅថ្ងៃបុណ្យ' ដូចជាថ្ងៃកោមុទី, និងមហានាំនីជាដើម (គោវ., កុល្ល., រាឃ.) តែលោកនារ. និងនន្ទ. អាន *សត្តារណេ* ដែលស្របតាមពាក្យដើម ថា 'ដោយសម្តីសុភាព'។
**៦៤.** ពោធ. ជំពូក១ លេខ១០, ២៨។ នារ. និយាយថា 'ដោយ(ការចិញ្ចឹម)សត្វបម្រើ ដូចជាគោក្របី និងសេះជាដើម'។

៦៥- ដោយការបូជាចំពោះមនុស្សដែលមិនសមទទួលការបូជា និងដោយការបដិសេធការងារគ្រួសារ (ដែលល្អសម្រាប់ពេលអនាគត) ដែលមាន(ចំណេះដឹង)ព្រះវេទគ្រប់គ្រាន់ នឹងវិនាសទៅយ៉ាងឆាប់។
៦៦- ប៉ុន្តែគ្រួសារ ដែលពោរពេញដោយចំណេះដឹងព្រះវេទ ទោះបីមានទ្រព្យតិចតួចក្តី ត្រូវស្ថិតក្នុងលំដាប់ក្នុងចំណោមមហាគ្រួសារ និងមានកិត្តិនាមក្រៃលែង។
៦៧- ដោយមានព្រះអគ្គីពិសិដ្ឋ សម្រាប់បំភ្លឺក្នុងពិធីអាពាហ៍ពិពាហ៍ គ្រួសារតាមច្បាប់នឹងធ្វើពិធីគ្រួសារ និងពិធីយញ្ញ(ធំៗ)ចំនួនប្រាំ ហើយ(ដោយសារភ្លើងនោះ) គេនឹងចំអិនអាហាររបស់គេរាល់ថ្ងៃ។
៦៨- មេគ្រួសារមានផ្ទះប្រហារប្រាំ (ប្រៀបដូចជា)ជើងក្រានគ្រួសារ ត្បាល់កិន អំបោស អង្រែ និង ត្បាល់បុក, ភាជន៍ទឹក ដែលគាត់ត្រូវប្រើ (នៅពេលមានបាបកម្ម)។
៦៩- ដើម្បីលុបលាងជាបន្តបន្ទាប់នូវ (អំពើបាបដែលបានប្រព្រឹត្តដោយមធ្យោបាយ) ទាំងប្រាំនោះ មហាបណ្ឌិតបានបញ្ញត្តឱ្យមេគ្រួសារ (ធ្វើ) ពិធីបូជាយញ្ញធំៗប្រាំជារៀងរាល់ថ្ងៃ។
៧០- ការបង្រៀន (និងការសិក្សា) ជាបូជាយញ្ញ(សម្រាប់)ពួកព្រាហ្មណ៍ (ការបូជាទឹកនិងអាហារ) ដែលគេហៅ *តាបណៈ* ជាការបូជាចំពោះព្រលឹងដូនតា ការបូជាអគ្គីជាការបូជាចំពោះអាទិទេព ការធ្វើពិធីពលិជាការបូជាចំពោះភូតៈ និងការធ្វើបដិសណ្ឋារកិច្ចភ្ញៀវជាការបូជាចំពោះមនុស្ស។
៧១- អ្នកដែលប្រហែសមិនធ្វើការបូជាធំៗទាំងប្រាំនេះ ក្នុងពេលដែលខ្លួនអាច(ធ្វើបាន) នឹងជាប់នូវបាបកម្មដែល(បានប្រព្រឹត្ត)ក្នុងទីពិឃាតទាំងប្រាំទោះជាគេរស់នៅ(មានរបៀបរបប)ជាគ្រួសារជាប្រចាំក៏ដោយ។

---

**៦៥.** ពោធ. ជំពូក១ លេខ១០, ២៦។ ជំនួសពាក្យ *កុលានី អាសូ វិណស្សន្តិ* 'គ្រួសារ... វិនាសភ្លាម'(គោវ., កុល្ល.), តែលោកនារ., នន្ទ. និងរាឃ អាន *កុលានី អកុលតាំ យាន្តិ* '(មហា)គ្រួសារបាត់បង់ឋានៈរបស់ខ្លួន'។
**៦៦.** ពោធ. ជំពូក១ លេខ១០, ២៩។
**៦៧.** យញ្ញ. ជំពូក១ លេខ៩៧; គោត. ជំពូក៥ លេខ៧; វិ. ជំពូក៥៩ លេខ១; ពោធ. ជំពូក២ លេខ៤, ២២។
'ពិធីក្នុងផ្ទះ' ជា 'ពិធីសាសនាទាំងអស់ ដែលមានចែងនៅក្នុងគ្ញហ្យ-សូត្រ'។
**៦៨.** វិ. ជំពូក៥៩ លេខ១៩។ ការប្រែពាក្យ *ឧបស្ករៈ* 'អំបោស' ផ្អែកលើប្រភពឯកសាររបស់នារ. ដែលនិយាយថា *បេសណោន ឧបការតី អសុទ្ធានីតី ឧបស្ករោ វស្ករហេតុ|សំមាគនី កូយិស្តបិបីលិកាទិហឹសាហេតុ*។ អ្នកអធិប្បាយផ្សេង ហាក់ដូចជាប្រែពាក្យ ឧបស្ករៈ តាមន័យធម្មតារបស់ពាក្យថា 'ឧបករណ៍គ្រួសារ' ដូចដែលពួកគេបកស្រាយពាក្យនេះ ដោយ *កុណ្ឌកដាហាទិ* 'ឆ្នាំង កំសៀវ និងរបស់ប្រើប្រាស់'(មេធ.) កុល្ល.ថា *កុណ្ឌសំមាគន្យាទិ* 'ឆ្នាំង អំបោស និងរបស់ផ្សេងៗ', រាឃ.ថា *សំ*

*មាគន្យាទិ* 'អំបោស និងរបស់ផ្សេងៗ', កុ. ថា *ឧលូខលមុសលាទិ* 'ត្បាល់បុក និងអង្រែ និងរបស់ផ្សេងៗ'។ ប៉ុន្តែបរិបទបង្ហាញច្បាស់ថា អត្ថន័យសំដៅដល់តែឧបករណ៍មួយប៉ុណ្ណោះ។

**៦៩.** វិ. ជំពូក៥៩ លេខ២០។

**៧០.** អាប. ជំពូក១ លេខ១១, ១៥-១៣, ១; គោត.ជំពូក៥ លេខ៣, ៩; ពាធ. ជំពូក២ លេខ៥, ១២; ជំពូក២ លេខ ១១, ១-៦; វិ. ជំពូក៥៩ លេខ២១-២៥; យញ្ញ.ជំពូក១ លេខ១០២។ ដោយពាក្យ *ភូត:* គេអាចយល់ថា 'ម្រេច គង្វាល' ឬ 'សត្វមានជីវិត'។ មេធ. ប្រែពាក្យនេះតាមន័យខាងដើម។ នន្ទ. អាន *អធ្យាបនំ* និងបន្ថែម *អធ្យាយនំ អោ ធ្យាយនំ, 'អធ្យាយន:* មានន័យដូចពាក្យ *អធ្យាយន:* គឺការសិក្សា'។

៧២- ប៉ុន្តែអ្នកដែលបីបាច់វត្ថុទាំងប្រាំ អាទិទេព ភ្ញៀវរបស់ខ្លួន អ្នកដែលស្ថិតក្នុងបន្ទុកត្រូវរក្សាព្រលឹង បុព្វបុរស និងខ្លួនឯង បីដូចជាស្លាប់ ទោះជាគេនៅដកដង្ហើមក្តី។

៧៣- គេក៏អាចហៅការបូជាទាំងប្រាំ(នេះ)ថា អហុត: ហុត: ប្រហុត: ព្រាហ្មយហុត: និងប្រាសិត: បានដែរ។

៧៤- អហុត: (មិនមែនបូជាក្នុងភ្លើងទេ) គឺជាការសូត្រធំៗ(នូវធម៌វេទ), ហុត:ជាការបូជាអគ្គី (ចំពោះព្រះអាទិទេព), ប្រហុត: (ការពង្រាយការបូជានៅលើដី) ជាការបូជាបែបពលិ ដើម្បី ផ្តល់ឱ្យពួកភូត:, ព្រាហ្មយហុត: (បូជាភ្លើងរំលាយអាហារព្រាហ្មណ៍) ជាការទទួលរាក់ទាក់ (ភ្ញៀវ)ព្រាហ្មណ៍ដោយគោរព និងប្រាសិត:(អាហារ) ជាការបូជាប្រចាំថ្ងៃចំពោះព្រលឹងបុព្វបុរស ដែលគេហៅថា) *តាបណ:*។

៧៥- ចូរ(អ្នកគ្រប់គ្នា)នៅក្នុង(យ៉ាងហោចណាស់ បញ្ញត្តិទី២)នេះ សូត្រដោយខ្លួនឯងនូវព្រះវេទជា រៀងរាល់ថ្ងៃ ព្រមទាំងធ្វើការបូជាចំពោះព្រះអាទិទេព ព្រោះថា អ្នកដែលព្យាយាមក្នុងការបូជា ជួយដល់សត្វទាំងមានជីវិត និងគ្មានជីវិត។

៧៦- ការបូជាដោយបោះចូលទៅក្នុងព្រះអគ្គីតាមការកំណត់ បានទៅដល់ព្រះអាទិត្យ ចេញពីព្រះអាទិត្យក្លាយជាភ្លៀង ដោយសារភ្លៀងនាំឱ្យមានអាហារ ដោយសារមានអាហារទើបកើតមាន សត្វមានជីវិត (ញ៉ាំងឱ្យជីវិតខ្លួនរស់រានបាន)។

៧៧- ដោយសារសព្វសត្វមានជីវិតទាំងអស់រស់រានបាន ដោយមានការទំនុកបម្រុងពីខ្យល់ដូច្នេះ (សមាជិក) តាមលំដាប់ទាំងអស់ ដោយសារការឧបត្ថម្ភពីមេគ្រួសារដែរ។

៧៨- ពីព្រោះមនុស្សបីជំនាន់(ទៀត) ត្រូវបានមេគ្រួសារបីបាច់ចិញ្ចឹមរាល់ថ្ងៃ ដោយ(ការបរិច្ចាគ)នូវពុទ្ធិពិសិដ្ឋ និងអាហារដូចនេះ(ក្រុម)គ្រួសារនេះ ជាគ្រួសារដ៏ប្រពៃបំផុត។

---

**៧២.** 'អ្នកដែលខ្លួនមានកាតព្វកិច្ចត្រូវចិញ្ចឹម' គឺ 'ឪពុកម្តាយចាស់ជរាជាដើម' (មេធ., គោវ., កុល្លូ.) ឬ'សត្វដែលមិនអាចផ្តល់ពលកម្មបាន'(មេធ.) ឬ 'ភូត: ម្រេញគង្វាល ឬសត្វមានជីវិត' (នារ., រាឃ.)។ នន្ទ. អាន *ភូតានាំ* ជំនួសពាក្យ *ព្ធត្យានាំ* ហាក់ដូចជាស្របគ្នានឹងលោក នារ. និងរាឃ.។

**៧៣.** មេធ. កត់សម្គាល់ថា ពាក្យបច្ចេកទេសទាំងនេះ ត្រូវតែស្ថិតក្នុងសាខាពិសេសណាមួយនៃព្រះវេទ។ ពាក្យពីរក្នុងចំណោមពាក្យទាំងឡាយនោះ មាននៅខាងដើមគ្ឫហ្យ-សូត្ររបស់ពោធាយន: ជាគម្ពីរពិសិដ្ឋបូព៌ាប្រទេស សៀវភៅលេខ ១៤ ទំព័រ xxxi និងពាក្យបួននៅក្នុងគ្ឫហ្យ-សូត្ររបស់បាកស្តរ: ជំពូក១ លេខ៤, ១ ព្រមទាំងនៅក្នុងគម្ពីររបស់សំខាយន: ជំពូក១ លេខ៥, ១។ លោកនារ., នន្ទ. និងក. អាន *ព្រាហ្មភូត:* នៅក្នុងកាព្យនេះ និងកាព្យបន្ទាប់។

**៧៦.** វស. ជំពូក១១ លេខ១៣។

**៧៧-៧៨.** វស. ជំពូក៨ លេខ១៤-១៦; វិ. ជំពូក៥៩ លេខ២៧-២៨។

**៧៨.** មេធ. គួសបញ្ជាក់ថា កាព្យនេះសបញ្ជាក់ថា តាមធម្មតា យាវាសប៉ុណ្ណោះគឺជាគ្រូនៃព្រះវេទ មិនមែនជាតាបស ឬឥសីទេ។ ប៉ុន្តែលោកបន្ថែមថា គោលការណ៍របស់ភិក្ខុ បញ្ញត្តថា មនុស្សលំដាប់ពីខាងក្រោយនេះ ក៏បង្រៀនបានដែរ។ ដូចគ្នានឹងលោកនារ. និងនន្ទ. បញ្ជាក់ថា យាវាសតែប៉ុណ្ណោះគឺជាគ្រូ 'លើកលែងតែក្នុងគ្រាអាសន្ន'(នន្ទ.)។

៧៩- (ករណីយកិច្ចរបស់)ក្រុមគ្រួសារ ដែលមិនអាចអនុវត្តបានពីសំណាក់មនុស្សដែលមានឥន្ទ្រីយ៍ ខ្សោយ ចូរអ្នកដែលប្រាថ្នាចង់បានពរជ័យ(នៅ)ឋានសួគ៌ និងមានសុភមង្គលជានិច្ចនៅក្នុងជាតិនេះ ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាម។

៨០- អ្នកមានគតិបណ្ឌិត បុព្វបុរស អាទិទេព ភូតៈ និងភ្ញៀវ ចូរយាវាស(ធ្វើការបូជានិងបរិច្ចាគ) ហេតុនេះ អ្នកដែលចេះ(ច្បាប់) ត្រូវតែបូជាចំពោះអ្នកទាំងឡាយនោះ (នូវអ្វីដែលសមស្រប តាមពួកគេម្នាក់ៗ)។

៨១- ចូរអ្នកដើរតាមគន្លងធម៌ គោរពបណ្ឌិត ដោយការសូត្រនូវព្រះវេទ គោរពព្រះអាទិទេពដោយការ បូជាព្រះអគ្គី គោរពបុព្វបុរសដោយការបូជាអ្នកចែកឋានទៅ (ស្រាទ្ធ) គោរពមនុស្សដោយ (ការបរិច្ចាគ) អាហារ និងគោរពភូតៈ ដោយការបូជាពលិ។

៨២- ចូរអ្នកធ្វើពិធីឧទ្ទិសវិញ្ញាណក្ខន្ធរាល់ថ្ងៃដោយបូជាអាហារ ឬទឹក ឬទឹកដោះគោក៏បាន ឬមើមឈើ និងផ្លែ ហើយ(ធ្វើដូច្នេះ)ញ៉ាំងឱ្យវិញ្ញាណក្ខន្ធសប្បាយចិត្ត។

៨៣- ចូរអ្នកឱ្យអាហារសូម្បីព្រាហ្មណ៍ម្នាក់ក៏ដោយក្នុងនាមវិញ្ញាណក្ខន្ធបុព្វបុរស(តាមស្រាទ្ធ) ដែលជាកំពូល យញ្ញទាំងប្រាំ ប៉ុន្តែចូរអ្នកកុំឱ្យអាហារដល់ព្រាហ្មណ៍ណាមួយក្នុងឱកាសប្រារព្ធពិធីវៃស្វទេវ។

៨៤- តាមតម្រា(គ្ឫហ្យ-សូត្ររបស់ខ្លួន) ព្រាហ្មណ៍គួរតែផ្តល់នូវអាហារចំអិនរួច សម្រាប់បូជាដល់វៃស្វ ទេវៈ ក្នុងអគ្គីដ៏ពិសិដ្ឋនៅក្នុងគ្រួសារ ដើម្បីឧទ្ទិសដល់ពួកទេវតាដូចខាងក្រោមៈ

៨៥- ទីមួយឧទ្ទិសចំពោះព្រះអគ្និ និង(បន្ទាប់មក)ចំពោះព្រះសោមៈ បន្ទាប់មកចំពោះព្រះទាំងពីរ រួមគ្នា តមកទៀតឧទ្ទិសចំពោះទេវតាទាំងអស់ (វិស្វេ ទេវៈ) ហើយតមកទៀតឧទ្ទិសចំពោះព្រះ *ធន្វន្តរិ*

---

**៧៩.** 'ដែលមានឥន្ទ្រីយ៍ទន់ខ្សោយ' គឺ 'ដែលមិនអាចគ្រប់គ្រងឥន្ទ្រីយ៍បាន' (មេធ., គោវ., កុល្ល.)។ អត្ថបទសំណៅដៃខ្លះរបស់លោកមេធ. និងនន្ទ. អាន *អត្យន្តំ* 'ដែលហួសប្រមាណ' សម្រាប់ពាក្យ *និត្យំ* 'ជាប្រចាំ'។

**៨០.** វិ. ជំពូក៥៩ លេខ២៩។

**៨១.** យញ្ញ. ជំពូក១ លេខ១០៤។

**៨២.** វិ. ជំពូក៦៧ លេខ២៣-២៥។

**៨៣.** កម្មវត្ថុនៃផ្នែកទីពីរក្នុងកាព្យនេះ គឺហាមឃាត់ថា ព្រាហ្មណ៍ពីរប្រភេទត្រូវគេផ្តល់អាហារតាមពិធីស្រាទ្ធរាល់ថ្ងៃ ដូចជាគេធ្វើក្នុងពិធី*បាវណៈ ស្រាទ្ធ* សូមមើលកាព្យ១២៥ខាងក្រោម។ នារ. បន្ថែម *វិស្វេសាំ ទេវានាំ និត្យស្រាទ្ធេ បីណានំ នាស្តីតិ ទរសិតំ* សូមបញ្ជាក់(ចាប់ពីពេលនេះតទៅ)ថា វិស្វេទេវ មិនរីករាយចំពោះពិធីស្រាទ្ធរាល់ថ្ងៃទេ'។ មេធ., នន្ទ. និងរាឃ. អាន *កិងកិត* '(អាហារ)ណាក៏ដោយ' សម្រាប់ពាក្យ *កំកិត* '(ព្រាហ្មណ៍)ណាក៏ដោយ'។

**៨៤.** អាប. ជំពូក២ លេខ៣, ១៦; គោត. ជំពូក៥ លេខ១០; វិ. ជំពូក៦៧ លេខ៣ (សូមមើលគ្ឫហ្យ-សូត្រ ដែលសាស្ត្រាចារ្យ Jolly បានដកស្រង់នូវសេចក្តីចុងក្រោយផង)។ ពាក្យ 'ព្រាហ្មណ៍' មិនមែនមិនរាប់បញ្ចូលពួកអារ្យ៉ូនទេ (តាមមេធ., នន្ទ., កុល្ល., រាឃ.)។

**៨៥.** ការបូជានីមួយៗ ត្រូវប្រកបដោយការសូត្រមន្ត្រ ដែលមានព្រះនាមរបស់ទេវត្រឹមត្រូវ និងពាក្យ 'ស្វាហា'។

៨៦- ជាបន្តឧទ្ទិសចំពោះ*កុហូ* (ទេពធីតានៃព្រះចន្ទខ្នើត), ចំពោះ*អនុមតិ* (ទេពធីតានៃព្រះចន្ទពេញបូណ៌មី), ចំពោះប្រជាបតិ (ព្រះបង្កើតសត្វលោក), ចំពោះឋានសួគ៌និងផែនដីរួមគ្នា និងជាចុងក្រោយឧទ្ទិសចំពោះ*អគ្និ ស្វិស្តក្ឫត* (ព្រះអគ្គីដែលបង្កើតឱ្យមានអណ្តូងយញ្ញ)។

៨៧- បន្ទាប់ពីបានបូជាអាហារតាមពិធីត្រឹមត្រូវ ចូរអ្នកធ្វើថ្វាយការបូជាពលិទៅតាមទិសជុំវិញដោយចាប់ផ្ដើមពី (ទិសខាងកើត) ទៅខាងត្បូង ទៅឥន្ទ្រ យមៈ វរុណៈ សោមៈ ព្រមទាំងបរិវា (របស់ព្រះទេវៈទាំងអស់នេះ)ផង។

៨៨- ដោយនិយាយពាក្យ '(សូមបូជា)ចំពោះព្រះមរុត'អ្នកគួរតែដាក់វាយ (អាហារខ្លះ) នៅក្បែរមាត់ទ្វារ និង (ខ្លះ)នៅក្នុងទឹកដោយនិយាយថា '(សូមបូជា)ចំពោះទឹក' អ្នកគួរបោះ(ខ្លះ)ទៅលើ អង្រែ និងត្បាល់បុក ដោយនិយាយដូច្នេះថា '(សូមបូជា)ចំពោះដើមឈើ'។

៨៩- នៅជិតក្បាល(គ្រែ) អ្នកគួរធ្វើការបូជាចំពោះព្រះ *ស្រី* (លាភរាសី) និងនៅជិតខាងចុង (គ្រែរបស់ខ្លួន) ចំពោះ*ព្រះភទ្រកាលី* ហើយនៅចំកណ្ដាលផ្ទះ ចូរអ្នកដាក់*ពលិ* បូជារួមគ្នាដល់ព្រហ្មន៍ និងដល់ព្រះ *វាស្តុស្បតិ* (ទេវតាថែរក្សាផ្ទះ)។

៩០- ចូរអ្នកបោះពលិ ឡើងទៅលើ ដើម្បីបូជាដល់ទេវតាទាំងអស់ និង(ការបូជានៅពេលថ្ងៃ)សម្រាប់ម្រេញគង្វាល ដែលដើរត្រាច់ចរនៅពេលថ្ងៃ (និងនៅពេលល្ងាច) សម្រាប់ម្រេញគង្វាល ដែលដើរនៅពេលយប់។

៩១- នៅជាន់ខាងលើ ចូរអ្នកបូជាពលិ ចំពោះ*សវ៌ាត្មភូតិ* ប៉ុន្តែចូរអ្នកបោះអាហារនៅសល់(ពីការបូជាទាំងអស់នេះ)ទៅទិសទក្សិណសម្រាប់ព្រលឹងបុព្វបុរស។

៩២- ចូរអ្នកដាក់(អាហារខ្លះ)នៅនឹងដីដោយសប្បុរសសម្រាប់សត្វឆ្កែ ពួកសូទ្រៈ កណ្ឌាលៈ (ស្វប្ក) អ្នកដែលមានជំងឺដោយជាប់ទណ្ឌកម្មបាបកម្មពីមុន សត្វគោ និងសត្វល្អិត។

៩៣- ដូចនេះព្រាហ្មណ៍ណាដែលគោរពសត្វលោកទាំងអស់រាល់ថ្ងៃនោះ នឹងទទួលបានរូបស្រស់បំព្រង ដើរតាមផ្លូវត្រូវ ដ៏ត្រង់ឆ្ពោះទៅឋានដ៏ខ្ពស់បំផុត (គឺឋានព្រហ្ម)។

---

**៨៧-៩២.** អាប.ជំពូក២លេខ៣, ១២-១៥, ១៨-៤, ៩; គោត. ជំពូក៥ លេខ១១-១៧; វិ. ជំពូក៦៧ លេខ៤-២២, ២៦។
**៨៩.** ពាក្យ *ឧត្តិរសេកេ* 'នៅជិតក្បាលគ្រែ' (មេធ., នារ., នន្ទ., អ្នកដទៃទៀត) តែតាមលោក គោវ., កុល្លូ. និងរាឃ. ថា 'នៅប៉ែកខាងជើងឈៀងខាងកើតផ្ទះ ដែលជាក្បាលរបស់ *វាស្តុ-បុរសៈ* (ភូមិទេវតា) ស្ថិតនៅ'។ មេធ. និយាយថា កន្លែងនោះគេហៅថា*ទេវសរណៈ*។ ប្រភពដដែលសំដៅដល់ *បាទតៈ* 'នៅនឹងជើង' ត្រង់កន្លែងទិសនិរតីនៃអគារ ដែលពួកភូមិទេវតាថែរក្សាជើងរបស់ខ្លួន។
**៩១.** ពាក្យ *ប្ឫស្ឋវាស្តុនិ* 'នៅជាន់ខាងលើ' ឬ (បើផ្ទះនោះមានតែមួយជាន់) គឺ'នៅលើដំបូលផ្ទះ' (មេធ.) ហើយតាមគោវ. និងនារ. ក៏អាចមានន័យថា 'នៅខាងក្រោយផ្ទះ' ឬតាមនន្ទ. ថា 'នៅខាងក្រៅផ្ទះ'។ ជំនួសឱ្យពាក្យ *សវ៌ាត្មភូតិ* (របស់កុល្លូ. រាឃ.) លោកនារ. និងនន្ទ. ប្រើពាក្យ 'សវ៌ានុភូតិ', គោវ. 'សវ៌ាន្នភូតិ'។ នារ. លើកឡើងនូវអំណានផ្សេង 'សវ៌ាន្នភូតិ' ដែលហាក់ដូចជាត្រូវគ្នានឹងការបកស្រាយរបស់មេធ.ដែរ។ អាទិទេពដដែលនេះ មាននៅក្នុងសំខាយន គ្ឫហ្យ-សូត្រ ជំពូក២ លេខ១៤ ដែលសាស្ត្រាចារ្យ Oldenberg ប្រើពាក្យ *សវ៌ាន្នភូតិ* ចំណែកឯវចនានុក្រម Petersberg សរសេរថា *សវ៌ានុភូតិ* ។ ទំនងជាពាក្យមួយក្នុងអំណានពីរក្រោយនេះ ជាពាក្យដើម ប៉ុន្តែដោយគ្មានសេចក្តីបញ្ជាក់ស្របគ្នាបន្ថែម គេពិបាកនឹងនិយាយថាគួរយកមួយណាណាស់។

៩៤- ដោយបានធ្វើការបូជាពលិនេះ ទីមួយអ្នកគួរផ្តល់អាហារឱ្យភ្ញៀវរបស់ខ្លួន ហើយតាមតម្រា ចូរឱ្យទានទៅតាបស (និង)អ្នកសិក្សា។

៩៥- យាវាសដែលមានកំណើតពីរដង តាមរយៈការឱ្យទាន នឹងទទួលបាននូវរង្វាន់សេចក្តីល្អដូចគ្នានឹង(អ្នកសិក្សា)ដែលខំកាន់វត្តប្រតិបត្តិស្របតាមសិក្ខាវិន័យ ផ្តល់មេគោដល់គ្រូរបស់ខ្លួនដែរ។

៩៦- តាមតម្រា ចូរអ្នកផ្ដល់ឱ្យព្រាហ្មណ៍ ដែលចេះចាំអត្ថន័យព្រះវេទពិតប្រាកដនូវទាន(អាហារមួយចំណែកតូច) ឬទឹកមួយកំសៀវ បន្ទាប់បានផ្គត់ផ្គង់(នូវអាហារដែលមានផ្សំគ្រឿង ឬភាជន៍ផ្កា និងផ្លែឈើ)។

៩៧- ការបូជាចំពោះទេវតា និងវិញ្ញាណក្ខន្ធបុព្វបុរសពីសំណាក់បុគ្គលដែលមិនចេះ (ច្បាប់បរិច្ចាគ) គ្មានបានផលទេ ប្រសិនបើអ្នកបរិច្ចាគដ៏ល្ងង់ខ្លៅនោះ (ផ្ដល់ទានរបស់ខ្លួន)ដល់ព្រាហ្មណ៍ដែល គ្មានគុណធម៌។

៩៨- ការបូជាដល់មាត់របស់ព្រាហ្មណ៍ ដែលពោរពេញដោយចំណេះដឹងពិសិដ្ឋនិងតបធម៌ ជួយសង្គ្រោះនូវគ្រោះអកុសល និងបាបកម្មធ្ងន់ធ្ងរបាន។

៩៩- ប៉ុន្តែចូរអ្នកបូជាតាមក្បួនតម្រា ជូនភ្ញៀវដែលបានអញ្ជើញមក (តាមការព្រមព្រៀងរបស់អ្នកផ្ទាល់)នូវអាសនៈនិងទឹកព្រមទាំងអាហារដែលមានទាំង(គ្រឿងផ្សំផ្សេងៗ) ស្របតាមលទ្ធភាពរបស់ខ្លួន។

១០០- ព្រាហ្មណ៍ ដែលស្នាក់នៅដោយមិនបានទទួលការគោរព(នៅក្នុងផ្ទះ) នឹងនាំយកទៅវិញ (តាមខ្លួនរបស់គាត់)ទាំងអស់នូវគុណធម៌ផ្នែកព្រលឹងវិញ្ញាណ សូម្បីពីបុគ្គលដែលរស់នៅដោយសារគ្រាប់ពោត ឬធ្វើការបូជាភ្លើងទាំងប្រាំក៏ដោយ។

---

**៩៣.** ជំនួសឱ្យពាក្យ *តេគោមុតិៈ* 'ដែលមានរូបឆោមលោមល្អ' លោកកុល្ល. និងរាឃ. អាន *តេគោមុតិ* '(ទៅកាន់ឋាន) ដ៏ខ្ពស់បំផុត (គឺឋានព្រហ្ម)'។

**៩៤.** វិ. ជំពូក៥៩ លេខ១៤; ជំពូក៦៧ លេខ២៧; វស. ជំពូក១១ លេខ៥; ពោធ. ជំពូក២ លេខ៥, ១៥; យញ្ញ. ជំពូក១ លេខ១០៧។ ពាក្យ *ភិក្សវេ ព្រហ្មការិណេ* (តាមកុល្ល., រាឃ.) 'ឱ្យទៅតាបស និងអ្នកសិក្សា' តែតាមមេធ. (ដែលឲ្យន័យស្របគ្នានឹងទស្សនៈរបស់កុល្ល.) ថា 'ឱ្យទៅអ្នកសិក្សាដើរសូមក៏បាន' ឬ 'ឱ្យទៅតាបស ដែលបរិសុទ្ធទាំងកាយទាំងចិត្តក៏បាន'។ គោវ. ប្រកាន់យកតាមការបកស្រាយខាងដើម។ 'យោងតាមសិក្ខាវិន័យ' គឺ 'ញុំាងឱ្យគេប្រាថ្នាចង់បានសុខុមាលភាព' (មេធ., នន្ទ.)។ សូមមើលគោត. ជំពូក៥ លេខ១៨ ផង។

**៩៥.** ចំពោះ *វិធិវទ៌ គុរេ* ឬ *គុរោះ* 'យោងតាមវិធាន ចូរជូនគ្រូរបស់ខ្លួន' លោកនន្ទ.អានថា *អគោរ យថាវិធិ* 'យោងតាមវិធាន ឱ្យទៅអ្នកដែលគ្មានមេគោ'។ លោកមេធ. ក៏លើកឡើងនូវមេរៀនផ្សេងៗផងដែរ។ ពាក្យ 'វិធាន' យោងតាមគោវ. និងកុល្ល. គឺសំដៅដល់ពិធីយញ្ញ ជំពូក១ លេខ២០៤ នោះឯង។

**៩៦.** ពាក្យ *សត្កត្យ* 'ដោយផ្ដល់អាហារជាដើម'(កុល្ល., រាឃ.) តែតាមលោកមេធ. និងគោវ. ថា 'ដោយបានគោរពដល់អ្នកទទួល' (ដោយផ្ដល់នូវផ្លែឈើ និងផ្កា, សម្រាប់ គោវ.)។

**៩៧.** វស. ជំពូក៣ លេខ៨។

**៩៩-១១៨.** អាប. ជំពូក២ លេខ៤, ១១, ១៣-២០; លេខ៦, ៥-៩; គោត. ជំពូក៥ លេខ២៥-៤៥; វស. ជំពូក៨ លេខ៤-៥, ១១-១៥; ពោធ. ជំពូក២ លេខ៥, ១១-១៨; លេខ៦, ៣៦-៣៧; វិ. ជំពូក៦៧ លេខ២៨-៤៦; យញ្ញ. ជំពូក១ លេខ១០៤-១០៩, ១១២-១១៣។

---

១០១- ស្មៅ បន្ទប់(សម្រាក) ទឹក និងទីបួនពាក្យពីរោះពិសាទាំងអស់នេះ មិនអាចគ្មាននៅក្នុងផ្ទះរបស់មនុស្សល្អទេ។

១០២- ប៉ុន្តែព្រាហ្មណ៍ ដែលស្នាក់នៅតែមួយយប់ ត្រូវចាត់ទុកជាភ្ញៀវ(អតិថិ) ព្រោះថាគាត់ស្នាក់នៅ (ស្ថិតៈ) មិនយូរ(អនិត្យំ) អាចហៅគាត់ជាអតិថិ (ភ្ញៀវ)។

១០៣- គេមិនត្រូវចាត់ទុកព្រាហ្មណ៍ដែលស្នាក់នៅក្នុងភូមិជាមួយគ្នាថាជាភ្ញៀវទេ និងមិនអាចចាត់ទុកអ្នកដែលស្វែងរកការចិញ្ចឹមជីវិតតាមផ្លូវលោក សូម្បីគាត់បានមកស្នាក់នៅផ្ទះមួយដែល(មាន) ភរិយានិងដែលមានការរក្សាភ្លើងពិសិដ្ឋទេ។

១០៤- ឃរាវាសល្មីល្មើទាំងឡាយណាដែលចិញ្ចឹម (ជីវិត) ជាប្រចាំដោយពឹងផ្អែកលើអាហាររបស់អ្នកដទៃជាតិក្រោយ ដោយសារសេចក្តីថោកទាបនោះ នឹងក្លាយជាសត្វពាហនៈដែលរស់អាស្រ័យ លើការផ្តល់អាហារពីអ្នកដទៃ។

១០៥- ម្ចាស់ផ្ទះមិនត្រូវដេញភ្ញៀវ ដែលមកដល់នៅល្ងាច(ថ្ងៃលិច)ចេញពីផ្ទះទេ ទោះជាគាត់បានដល់ ពេលយប់ក្តី ឬខុសកាលក្តី ក៏គាត់មិនត្រូវស្នាក់នៅផ្ទះនោះដោយគ្មានការទទួលឱ្យបាយទឹកទេ។

១០៦- ចូរអ្នកកុំទទួលទានអាហារ(ឆ្ងាញ់) ដែលអ្នកមិនបានផ្តល់ជូនភ្ញៀវរបស់អ្នក ព្រោះថាការទទួល រាក់ទាក់ភ្ញៀវនាំឱ្យទ្រព្យសម្បត្តិ កិត្តិស័ព្ទ អាយុយឺនយូរ និងបានកុសលឡើងឋានសួគ៌។

១០៧- ចូរអ្នកផ្តល់(ដល់ភ្ញៀវ)នូវអាសនៈ បន្ទប់ គ្រែ ការជូនដំណើរពេលចាកចេញ និងគោរព (ខណៈ ពេលមានភ្ញៀវ) ចំពោះភ្ញៀវដ៏មានកិត្តិយសបំផុត ដោយប្រពៃបំផុត គោរពថ្នាក់ក្រោមបន្តិច សម្រាប់ភ្ញៀវថ្នាក់ក្រោម គោរពស្មើសម្រាប់ភ្ញៀវថ្នាក់ស្មើ។

១០៨- ប៉ុន្តែបើភ្ញៀវម្នាក់មកដល់ បន្ទាប់ពីបានបញ្ចប់ការបូជាវៃស្វ-ទេវ (ម្ចាស់ផ្ទះ)ផ្តល់អាហារដល់ភ្ញៀវ តាមលទ្ធភាពរបស់ខ្លួន (តែ)មិនត្រូវធ្វើការបូជាពលិម្តងទៀតទេ។

១០៩- ព្រាហ្មណ៍ មិនគួរដាក់ឈ្មោះគ្រួសារខ្លួន និងគោត្រ(តាមវេទ)ដើម្បីទទួលបានអាហារទេ ព្រោះថា បណ្ឌិតចាត់ទុកអ្នកដែលអួតលើកតម្កើងខ្លួនដើម្បីបានអាហារ ថាជាមនុស្សអាក្រក់ (ជាអំពើបាបធ្ងន់ធ្ងរ)។

---

**១០១.** ពាក្យ *សាំគតិកៈ* 'អ្នកដែលខំចិញ្ចឹមជីវិតរបស់ខ្លួន តាមផ្លូវលោក' គឺស្របតាមគោវ., កុល្ល. និងរាឃ. ថា 'អ្នកដែលចិញ្ចឹមខ្លួន តាមរយៈការនិទានរឿងល្អៗ ឬអស្ចារ្យ និងរឿងផ្សេងៗ'។ មេធ. បកស្រាយពាក្យទីមួយ ថា'អ្នក ដែលស្នាក់នៅក្នុងនាមជាអ្នកសិក្សា(សហាធ្យាយី)' និងពាក្យបន្ទាប់ ថា 'វៃស្យ ឬសូទ្រៈ ឬមិត្ត ដែលគប់មិត្តជាមួយអ្នករាល់គ្នា ដែល មានរឿងនិទានល្អៗ ឬអស្ចារ្យ និងរឿងផ្សេងៗ ដែលប្រើពាក្យថា *សំគតិ*។ នារ. និយាយថា *សំគតិ* មានន័យ *សម្ពន្ធៈ* 'ការចងសម្ព័ន្ធ' ហើយពាក្យ *សាំគតិកៈ* គឺ 'អ្នកដែលចងសម្ព័ន្ធនឹងគ្នា'។ ទំនងជាគេអាចប្រែពាក្យនេះថា 'ភ្ញៀវរកស៊ី ឬភ្ញៀវមកលេង'។ យោងតាមកុល្ល. និងរាឃ. អនុប្រយោគចុងក្រោយ 'ដែល(មាន)ភរិយា និងភ្លើងពិសិដ្ឋ (ត្រូវរក្សាឲ្យបាន)' បញ្ជាក់ន័យថា ឃរាវាស(អ្នកគ្រប់គ្រងផ្ទះ) ដែលមិនមែន មិនចង់ទទួលភ្ញៀវទេ។ ប៉ុន្តែលោកគោវ. និងនារ. ប្រែពាក្យនេះ ផ្សេងថា 'មិនមែនអ្នកដែលធ្វើដំណើរជាមួយភរិយារបស់ខ្លួន ឬភ្លើងរបស់ខ្លួនទេ' (*អថា យត្រ យស្យ ប្រវាសិនូ បិ ភារ្យាគ្នយោ វា សហ គច្ឆន្តិ। អេតទន្យតមំ ស្វគ្ឫហ ឧបស្ថិតំ អាគតំ អប្យចិ អតិថឹ ន វិទ្យាត।នាតិថិជាមេ ណាកយេត॥* នារ.)។

**១០៧.** គោត. ជំពូក៥ លេខ៣៨។ 'វិធាននេះ សំដៅដល់ករណីដែលមានភ្ញៀវច្រើនមកដល់ក្នុងពេលដំណាលគ្នា។' ពាក្យ *ឧបាសនំ* 'គោរព ខណៈពេលពួកគេស្នាក់នៅ' គឺ 'អង្គុយជាមួយពួកគេ និងនិយាយជាមួយពួកគេ' (មេធ.)។

**១០៨.** 'នៅពេលបញ្ចប់ការផ្តល់វៃស្វ-ទេវ' គឺ 'នៅពេលភ្ញៀវទទួលទានអាហារពេលល្ងាចហើយ'។

១១០- ប៉ុន្តែគេមិនត្រូវចាត់ទុកពួកក្សត្រិយ វៃស្យៈ សូទ្រៈ មិត្តភក្តិផ្ទាល់ខ្លួន សាច់ញាតិ និងគ្រូ (ដែល មក) ដល់ផ្ទះរបស់ព្រាហ្មណ៍ ថាជាភ្ញៀវ(អទិថិ)ទេ។

១១១- ប៉ុន្តែបើក្សត្រិយមកដល់ផ្ទះរបស់ព្រាហ្មណ៍ក្នុងនាមជាភ្ញៀវ (ម្ចាស់ផ្ទះ) អាចផ្តល់អាហារដល់គាត់ តាមចេតនារបស់ខ្លួន បន្ទាប់ពីព្រាហ្មណ៍នោះបានទទួលទានរួច។

១១២- សូម្បីតែវៃស្យៈ និងសូទ្រៈ ដែលបានមកដល់ផ្ទះរបស់អ្នក ក្នុងនាមជាភ្ញៀវ អ្នកអាចអនុញ្ញាតឲ្យទទួលទានអាហារជាមួយអ្នកបម្រើរបស់អ្នក ដោយចេះបង្ហាញនូវចិត្តមេត្តារបស់អ្នកផង។

១១៣- សូម្បីចំពោះអ្នកដទៃ មិត្តភក្តិផ្ទាល់ខ្លួនជាដើម ដែលបានមកដល់ផ្ទះរបស់អ្នក ដោយក្តីស្រឡាញ់ រាប់អានអ្នកអាចផ្តល់អាហារមានម្ហូបផ្សេងៗស្របតាមលទ្ធភាពរបស់អ្នក(ទទួលទានក្នុងពេលជាមួយ)នឹងភរិយារបស់អ្នក។

១១៤- សូម្បីនៅចំពោះមុខភ្ញៀវ អ្នកអាចផ្ដល់អាហារដោយគ្មានចិត្តស្ទាក់ស្ទើរដល់បុគ្គល ដូចជាស្ត្រី ដែលទើបរៀបការថ្មីៗ កូនក្មេង អ្នកជំងឺ និងស្ត្រីមានផ្ទៃពោះ។

១១៥- ប៉ុន្តែបុរសល្ងីល្ងើដែលទទួលទានមុន ដោយមិនបានផ្ដល់អាហារដល់ (បុគ្គល) ទាំងអស់នេះ ខណៈដែលគេទំពារអាហារដោយមិនដឹងថា (បន្ទាប់ពីស្លាប់)ខ្លួនគេនឹងត្រូវសត្វឆ្កែនិងត្មាត ហែកហួរស៊ីនោះទេ។

១១៦- បន្ទាប់ពីព្រាហ្មណ៍ ញាតិសន្តានប្រុស និងអ្នកបម្រើបានទទួលទានបាយល្ងាចរួច ម្ចាស់ផ្ទះនិងភរិយារបស់ខ្លួនអាចទទួលទាននូវអ្វីដែលសល់ពីនោះបាន។

១១៧- ដោយបានគោរពអាទិទេព បណ្ឌិត មនុស្ស បុព្វបុរស និងទេវតារក្សាផ្ទះរួចហើយ ម្ចាស់ផ្ទះគួរតែទទួលទានអ្វីដែលនៅសល់តាមក្រោយបាន។

១១៨- អ្នកដែលរៀបចំអាហារសម្រាប់តែខ្លួនឯង (តែម្យ៉ាង) មិនបានទទួលទានអ្វីក្រៅពីអំពើបាបទេ ព្រោះមានការកំណត់ថាអាហារដែលនៅសល់ពីការបូជា គួរជាអាហារសម្រាប់អ្នកមានគុណធម៌។

១១៩- ចូរអ្នកគោរពផ្ដល់អាហារលាយទឹកឃ្មុំដល់ព្រះរាជា អាចារ្យពិធីការ ស្នាតកៈ គ្រូ កូនប្រសា ឪពុកក្មេក និងពូខាងម្ដាយ (ប្រសិនបើពួកគេ)ត្រឡប់មកវិញ ក្រោយពេលមួយឆ្នាំ (ចាប់តាំងពីការមកលេងចុងក្រោយរបស់ពួកគាត់)។

---

**១១១.** 'ក្នុងនាមជាភ្ញៀវ' គឺ 'ដោយបានប្រើប្រាស់របស់ចាំបាច់របស់ខ្លួន ខណៈពេលធ្វើដំណើរ ដែលមកស្នាក់នៅក្នុងភូមិផ្សេង ឬមកដល់ក្នុងពេលទទួលទានអាហារ'(មេធ., គោវ., កុល្ល.)។

**១១២.** នារ. និយាយថា 'អ្នកអាចឱ្យពួកគេទទួលទានជាមួយអ្នកបម្រើរបស់អ្នកដូចគ្នា'។

**១១៤.** ពាក្យ *សុវាសិនិះ* 'ចំពោះស្ត្រីរៀបការថ្មីៗ' សំដៅដល់ 'កូនប្រសាស្រី និងកូនស្រី' តែអ្នកអធិប្បាយផ្សេងទៀត តាមការដកស្រង់សេចក្ដីរបស់មេធ. និងគោវ. និយាយថា 'ស្ត្រីដែលមានឪពុក ឬឪពុកក្មេកនៅរស់'។ នន្ទ. អាន *ស្វាសិនិះ* និងបកស្រាយថា 'បងប្អូនស្រី'។

**១១៩-១២០.** អាប. ជំពូក២ លេខ៨, ៥-៩; គោត. ជំពូក៥ លេខ២៧-៣០; វស. ជំពូក១១ លេខ១-២; ពោធ. ជំពូក២ លេខ៦, ៣៦-៣៧; យញ្ញ. ជំពូក១ លេខ១១០។

**១១៩.** គុរុះ 'គ្រូ' ហើយតាមនារ. ថា 'គ្រូ ឬឧបាធ្យាយ'។ ពាក្យ *ប្រិយះ* តាមគោវ., កុល្ល. និងរាឃ. មានន័យថា 'កូនប្រសាប្រុស' តែនារ. និងនន្ទ. ប្រែតាមន័យដើមថា 'មិត្ត'។

១២០- ព្រះរាជា និងស្រោត្រិយ ដែលមកដល់ពេលធ្វើការបូជា គេត្រូវផ្ដល់កិត្តិយស ដោយថ្វាយអាហារ លាយទឹកឃ្មុំ តែមិនបាច់ផ្ដល់ទេ បើគ្មានពិធីបូជា នេះគឺជាតម្រាដែលបានកំណត់។

១២១- ប៉ុន្តែភរិយាគួរតែធ្វើការតុបតែងអាហារ(ខ្លះ)នៅពេលល្ងាច សម្រាប់ការថ្វាយពលិ ដោយមិនចាំបាច់ (សូត្រ)ពាក្យពិសិដ្ឋទេ ព្រោះថា(ពិធីដែលគេហៅថា)វៃស្វទេវ ត្រូវអនុញ្ញាតឱ្យធ្វើបានទាំងពេលព្រឹក និងទាំងពេលល្ងាច។

១២២- បន្ទាប់ពីការធ្វើពិធីបិតួយញ្ញ ព្រាហ្មណ៍ ដែលរក្សាភ្លើងពិសិដ្ឋគួរបូជារាល់ខែ នៅថ្ងៃខាងខ្នើត ពិធីឧទ្ទិស (ស្រាទ្ធ ដែលគេហៅថា) *បិណ្ឌានវាហារ្យកៈ*។

១២៣- អ្នកមានគតិបណ្ឌិតហៅការឧទ្ទិសវិញ្ញាណក្ខន្ធចំពោះបុព្វបុរសថាជាពិធីអន្វាហារ្យ (ដែលផ្ដល់បន្ទាប់ពីនំដុត)ហើយគេត្រូវតែធ្វើពិធីនោះដោយប្រុងប្រយ័ត្នដោយមានសាច់(តាមការអនុញ្ញាតដូចខាងក្រោម)។

១២៤- ខ្ញុំនឹងប្រកាសអំពីការផ្ដល់នូវអ្វី និងការផ្ដល់អាហាររបៀបណាដល់ព្រាហ្មណ៍ ស្របតាម (កាលៈទេសៈ) ដែលត្រូវជៀសវាង និងអំពីអាហារប្រភេទណា (ដែលពួកគេទទួលទានពេលល្ងាច)។

១២៥- អ្នកត្រូវផ្តល់អាហារដល់(ព្រាហ្មណ៍)ពីរនាក់ក្នុងពេលថ្វាយទេវតា និងបីនាក់ក្នុងពេលបូជាបុព្វការីឬតែម្នាក់នៅពេលណាក៏បាន ហើយសូម្បីបុគ្គលមានទ្រព្យច្រើនមិនគួរអន្ទះសា (ទទួល) ភ្ញៀវមួយហ្វូងធំទេ។

---

**១២០.** យោងតាមមតិរបស់មេធ. ដែលគោវ., កុល្លូ. និងនារ. ឯកភាពតាម គឺថា វិធាននេះជាការកំណត់នៃកាព្យ ១១៩ និងមានន័យថា មនុស្សពីរនាក់ដែលដៅដល់នោះ មិនគួរទទួលអាហារលាយទឹកឃ្មុំទេ លើកលែងពេលដែលពួកគេមកដល់ចំពេលធ្វើពិធី ទោះជាមានរយៈពេលប៉ុន្មាន បន្ទាប់ពីការមកលេងចុងក្រោយរបស់ពួកគេក៏ដោយ។ យោងតាមការបកស្រាយមួយទៀតរបស់លោកមេធ., នន្ទ. និងរាឃ. ថា កាព្យនេះ មានន័យថា ព្រះរាជា និងស្រោត្រិយ ដែលមកមុនមួយឆ្នាំតាំងពីការមកលេងចុងក្រោយរបស់ពួកគេ ចំពេលធ្វើពិធីបូជា គួរទទួលបានមធុ-បាកៈ។ ពាក្យ*ស្រោត្រិយ* តាមលោកមេធ. សំដៅដល់ស្នាតកៈ ឬអាចារ្យពិធីការ និងយោងតាមការបកស្រាយរបស់អ្នកដទៃដែលគាត់បានស្រង់សេចក្តី គឺសំដៅដល់បុគ្គលទាំងអស់ ដែលបានរៀបរាប់នៅក្នុងកាព្យខាងដើម ហើយយោងតាមគោវ., កុល្លូ., នារ.និងរាឃ. សំដៅដល់ស្នាតកៈ។ ការបកស្រាយក្រោយនេះ ទំនងជាមតិត្រឹមត្រូវ ព្រោះថាស្រោត្រិយ គឺអ្នកដែលចេះពិនិត្យសំណៅគម្ពីរវេទទាំងមូល ប្រាកដជាស្នាតកៈ។ លោកមេធ. គាំទ្រការអាន *យញ្ញកាមណី ឧបស្ថិតេ*។

**១២១.** នន្ទ. លុបចោលកាព្យនេះ។

**១២២.** យញ្ញ. ជំពូក១ លេខ២១៧; គោត. ជំពូក១៥ លេខ២។ ពិធីបូជាតាមពាក្យ *បិត្វយញ្ញ* 'យញ្ញបូជាចំពោះឪពុក' ជាពិធីដែលគេឱ្យឈ្មោះថា *បិណ្ឌបិត្វយញ្ញ* ជាពិធីស្រោត (អាស្វលាយន, ស្រោត-សូត្រ ជំពូក២ លេខ៦-៧) និង *បិណ្ឌា ន្វាហារ្យកៈ* ជាឈ្មោះពិធីមួយទៀត សំដៅដល់ស្រាទ្ធប្រចាំខែ។

**១២៥.** វស. ជំពូក១១ លេខ២៧; ពោធ. ជំពូក២ លេខ១៥, ១០; វិ. ជំពូក៧៣ លេខ៣-៤; គោត. ជំពូក១៥ លេខ៨, ២១; យញ្ញ. ជំពូក១ លេខ២២៨។ ការថ្វាយទេវតា ដែលមាននិយាយក្នុងកាព្យនេះ ជាពិធីអគ្និ ឬពិធីជំនួសដែលធ្វើមុនពិធីឧទ្ទិសវិញ្ញាណក្ខន្ធបុព្វបុរស។ លោកមេធ. ប្រែផ្នែកទីមួយនៃកាព្យនេះ តាមរបៀបពិសេសថា 'អ្នកត្រូវផ្តល់អាហារដល់(ព្រាហ្មណ៍)ពីរនាក់ នៅពេលថ្វាយទេវតា និងបីនាក់ (សម្រាប់ជូនតានីមួយៗ ឬប្រាំតែម្តង) នៅពេលឧទ្ទិសដល់បុព្វបុរស ឬម្នាក់ក្នុងម្តងៗ (គឺម្នាក់ក្នុងពេលថ្វាយទេវតា និងពេលឧទ្ទិសបុព្វបុរស ម្នាក់ក្នុងពេលឧទ្ទិសបុព្វបុរសម្នាក់ ឬបីនាក់ក្នុងពេលតែមួយ'។

១២៦- ភ្ញៀវដ៏ច្រើនធ្វើឱ្យខូច(ប្រយោជន៍)ទាំងប្រាំនេះ ដូចជាការរាប់អានដោយគោរព (ពីអ្នកដែលត្រូវគេអញ្ជើញ, ភាពគួរសមនៃ) ទីកន្លែងនិងពេលវេលា ភាពបរិសុទ្ធនិង(ការជ្រើសរើសភ្ញៀវ) ព្រាហ្មណ៍ដែលមានគុណធម៌ ហេតុនេះអ្នកមិនគួរបង្កើតកម្មវិធី(ទទួល)ភ្ញៀវដ៏ច្រើនទេ។

១២៧- ពិធីនេះគឺសម្រាប់អ្នកដែលចែកឋានទៅ គេហៅថា (ការឧទ្ទិសដ៏ពិសិដ្ឋចំពោះវិញ្ញាណក្ខន្ធបុព្វបុរស និងត្រូវធ្វើ)នៅថ្ងៃខាងខ្នើត ប្រសិនបើគេយកចិត្តទុកដាក់(ធ្វើ)ពិធីនោះ (ផលនៃ)ពិធី ឧទ្ទិសដល់អ្នកចែកឋាននោះ ដែលត្រូវធ្វើស្របតាមតម្រាស្មារតៈ នឹងបានដល់អ្នកធ្វើជានិច្ច។

១២៨- ការបូជាចំពោះអាទិទេពនិងព្រលឹងបុព្វបុរស ត្រូវមានវត្តមានអ្នកឧទ្ទិសចំពោះស្រោត្រិយតែប៉ុណ្ណោះ ហើយអ្វីដែលត្រូវផ្តល់ជូនព្រាហ្មណ៍ដ៏មានកិត្តិយសបំផុត នឹងផ្តល់ផលមហាសាល។

១២៩- ចូរអ្នកផ្តល់អាហារដល់អ្នកចេះដឹងសូម្បីតែម្នាក់ នៅក្នុងពេល(ឧទ្ទិស)ចំពោះអាទិទេព និងម្នាក់នៅពេល (ឧទ្ទិសចំពោះ)ព្រលឹងបុព្វបុរស (ធ្វើដូច្នេះ) អ្នកនឹងទទួលផលយ៉ាងច្រើន ហើយនឹងមិនសូវបានផលទេ (បើអ្នកទទួល)មនុស្សជាច្រើន ដែលមិនចេះព្រះវេទ។

១៣០- ចូរអ្នកស្វះស្វែងសួរក (ជូនតា) ព្រាហ្មណ៍សែឆ្ងាយៗដែលបានសិក្សា (ពិនិត្យសំណៅ) ព្រះវេទ ទាំងស្រុង; (ប្រសិនបើមានអ្នកជំនាន់ក្រោយចេញពីពូជមានគុណធម៌) មនុស្សបែបនេះគឺជាអ្នកទទួលការ

បរិច្ចាគដ៏មានកិត្តិយសនូវអាហារដែលត្រូវបូជាចំពោះអាទិទេព ឬចំពោះព្រលឹងបុព្វបុរស គាត់គឺជា(អ្នកនាំមកនូវផលបុណ្យដ៏ច្រើនដូច) ភ្ញៀវ (អតិថិ) ដែរ។

១៣១- ទោះបីមនុស្សមួយលាននាក់ដែលមិនចេះឫគវេទ បានមកបរិភោគអាហារពេលល្ងាចក្នុងពេល (ពិធីឧទ្ទិស)ក៏ដោយ តែសូម្បីមនុស្សតែម្នាក់ដែលចេះចាំព្រះវេទ ដែលរីករាយ (នឹងការទទួលនោះ) ក៏មានតម្លៃច្រើនជាងមនុស្សទាំងនោះ (ក្នុងការផ្តល់) កុសលផ្លូវចិត្ត (ដែលនឹងបានទទួល) ដែរ។

១៣២- អាហារពិសិដ្ឋ សម្រាប់ឧទ្ទិសដល់ព្រលឹងបុព្វបុរស ឬអាទិទេព គេត្រូវជូនដល់មនុស្ស ដែលមានចំណេះដឹងពិសិដ្ឋ ព្រោះដៃប្រឡាក់ឈាម មិនអាចលាងជ្រះដោយឈាមបានទេ។

---

**១២៦.** វស. ជំពូក១១ លេខ២៨; ពោធ. ជំពូក២ លេខ១៥, ១១។

**១២៧.** គោវ. អាន *វិធិះ ក្សយេ* ជំនួស *វិធុក្សយេ* 'នៅថ្ងៃខាងខ្នើត' ហើយបកស្រាយកាព្យពាក់កណ្តាលដំបូងដូចតទៅៈ 'ពិធីដែលគេហៅ(ការឧទ្ទិស)ចំពោះព្រលឹងបុព្វបុរស (ជា)ពិធីសាសនាមួយប្រភេទ សម្រាប់ជាប្រយោជន៍ដល់អ្នកដែលបានចែកឋានទៅ (និង)ដែលគេកំណត់យកថ្ងៃខាងខ្នើត ឬក្នុងផ្ទះ ពោលគឺមេគ្រួសារត្រូវធ្វើ មិនមែនសមាជិកផ្សេងទេ'។ មេធ. ក៏លើកឡើងនូវអំណានមួយទៀត ដែលគាត់បកស្រាយសឹងតែដូចគ្នានឹងលោកគោវ. ហេតុនេះហើយទើបមានពាក្យ *វិធិះ ក្សយេ* ទោះបីសំណៅដើមអាន *តិថិក្សយេ* ក៏ដោយ។

**១២៧.** វស. ជំពូក៣ លេខ៨; គោត. ជំពូក១៥ លេខ៩។

**១៣០.** វិ. ជំពូក៨២ លេខ២។ ដូចគ្នាក្នុងករណីអាចារ្យពិធីការដែរ ការផ្ទៀងផ្ទាត់ត្រូវរាប់ដល់ដូនតាសែទីដប់ ទាំងខាងម្តាយនិងខាងឪពុក (មេធ., គោវ.)។

**១៣១.** ពាក្យ *ឫគ* គឺសំដៅ 'វេទ'។ នារ. អាន *យុក្តៈ* ជំនួស *ប្រីតៈ* វិញ 'ដែលពេញចិត្ត' និងភ្ជាប់ពាក្យនេះដោយ *ធម្មតៈ* 'ដែលមានការអញ្ជើញត្រឹមត្រូវ'។ នន្ទ. សរសេរ *វិប្រៈ* សំដៅដល់'ព្រាហ្មណ៍' ជំនួសពាក្យ *ប្រីតៈ* ។ K. ប្រើពាក្យ *ប្រិម មនុ វិប្រៈ* ជាផ្នែកនៃមនុយុក្តៈ។

១៣៣- មនុស្សច្រើនដែលសុទ្ធតែជាបុគ្គលល្ងង់ ទទួលទានអាហារក្នុងពិធីបូជាអាទិទេព ឬឧទ្ទិសដល់ព្រលឹងបុព្វបុរស ឧបមាបីដូច ដែកស្រួច លំពែង និងដុំដែកក្តៅ គឺសម្រាប់ទុកឱ្យ (អ្នកផ្តល់ អាហារ)ទទួលទាននៅជាតិក្រោយ។

១៣៤- ព្រាហ្មណ៍មួយចំនួនតាំងចិត្តពុះពារ(ស្វែងរក)ចំណេះដឹង ហើយព្រាហ្មណ៍ខ្លះ ខំធ្វើ(តបធម៌) ខ្លះខំធ្វើតបៈនិងសូត្រព្រះវេទ ហើយខ្លះទៀតខំធ្វើពិធីពិសិដ្ឋ។

១៣៥- ការបូជាចំពោះព្រលឹងបុព្វបុរស គួរប្រុងប្រយ័ត្ន ផ្តល់ជូនអ្នកណាដែលបូជាដើម្បីចំណេះដឹង ប៉ុន្តែសំណែនទេវតា យោងតាមហេតុផលដែលមាននៅក្នុង(ច្បាប់ពិសិដ្ឋ) គួរជូនដល់បុគ្គល ទាំងបួនប្រភេទ (ដូចបានជម្រាបជូនខាងលើ)។

១៣៦- ប្រសិនបើមានឪពុកដែលមិនចេះតម្រាពិសិដ្ឋ ដែលមានកូនចេះដឹងអាចផ្ទៀងផ្ទាត់ព្រះវេទ និង អង្គវេទទាំងមូលបាន និងបុត្រដែលមិនចេះតម្រាពិសិដ្ឋ ដែលមានឪពុកចេះដឹងអាចផ្ទៀងផ្ទាត់ ព្រះវេទ និងអង្គវេទទាំងមូលបាន,

១៣៧- ចូរដឹងថា អ្នកដែលមានឪពុកចេះដឹងព្រះវេទ ជាបុគ្គលគួរឱ្យគោរពជាង(ក្នុងចំណោមអ្នកទាំងពីរ)ប៉ុន្តែម្នាក់ទៀតជាបុគ្គលមានកិត្តិយសខ្ពស់ ព្រោះការគោរពគឺអាស្រ័យលើព្រះវេទ (ដែលគេ បានសិក្សា)។

១៣៨- ចូរអ្នកកុំទទួលមិត្តផ្ទាល់ខ្លួនក្នុងពិធីឧទ្ទិសវិញ្ញាណក្ខន្ធ គឺអ្នកអាចទទួលបានការពេញចិត្តដោយ ការបរិច្ចាគដ៏មានតម្លៃ(ផ្សេងទៀត); នៅក្នុងពិធីស្រាទ្ធ ចូរអ្នកជូនអាហារដល់ព្រាហ្មណ៍ ដែលអ្នកគិតថាមិនមែនជាសត្រូវ និងមិនមែនជាមិត្ត។

១៣៩- អ្នកដែលធ្វើពិធីឧទ្ទិសនិងថ្វាយទេវតាដើម្បី(ទទួលបាន)មិត្តជាសំខាន់ នឹងមិនទទួលបានផលសម្រាប់ពិធីស្រាទ្ធនិងពិធីឧទ្ទិស បន្ទាប់ពីស្លាប់នោះទេ។

១៤០- ការកំណាញ់ស្ថិតក្នុងចំណោមអ្នកមានកំណើតពីរដង ដែលគិតតែពីមិត្តភាពដោយភាពល្ងីល្ងើរបស់ខ្លួនក្នុងពេលធ្វើពិធីឧទ្ទិស នឹងមិនបានឡើងឋានសួគ៌ទេ ដោយហេតុថាគេបានធ្វើស្រាទ្ធ ដើម្បីតែមិត្តភាព។

---

**១៣៣.** នារ. គិតថា អ្នកទទួលទាន មិនមែនអ្នកផ្តល់ការជប់លៀងទេ នឹងមានទោស។ មេធ. ប្រកាន់យកការបក ស្រាយទាំងពីរ ហើយបានដាក់នៅក្នុងសំណៅបកប្រែ។ នារ.បកស្រាយ *ឫស្តិ* 'លំពែង' ជំនួសពាក្យ *ឧឌគ:* 'ដាវ'។ នន្ទ. អាន *ហុលាន* ជំនួសពាក្យ *គុឌាន* 'បាល់' ហើយនិយាយថា *ហុល* មានន័យថា 'ដាវមុខពីរ'។

**១៣៤.** 'ចំណេះដឹង' គឺ 'ចំណេះដឹងអំពីព្រលឹងវិញ្ញាណទាំងស្រុង' (មេធ., គោវ., កុល្លូ., នារ., រាឃ.)។ មេធ. និងនារ. និយាយថា តាបស ឥសី អ្នកសិក្សា និងឃរាវាស នៅក្នុងអត្ថបទនេះ គឺមានបួនផ្នែក។

**១៣៥.** វស. ជំពូក១១ លេខ១៧; ពោធ.ជំពូក២ លេខ១៤, ៣។ កាព្យនេះបញ្ជាក់ថា តាបសជាភ្ញៀវគួរឱ្យទទួលបំផុត។

**១៣៦-១៣៧.** កុល្លូ. កត់សម្គាល់ថា កម្មវត្ថុនៃកាព្យនេះ គឺដើម្បីទូន្មានថា នៅឯពិធីស្រាទ្ធ បុត្រដែលជាអ្នកចេះដឹងរបស់ឪពុកដែលជាអ្នកចេះដឹង គេត្រូវតែទទួល ប៉ុន្តែមិនអនុញ្ញាតចំពោះបុត្រល្ងង់របស់ឪពុកចេះដឹងទេ។

**១៣៨-១៤៨.** អាប. ជំពូក២ លេខ១៧, ៤-៦; គោត. ជំពូក១៥ លេខ១២-១៤; ពោធ. ជំពូក២ លេខ១៤, ៦; យញ្ញ. ជំពូក១ លេខ២២០។

១៤១- គេនិយាយថា ការឱ្យ(អាហារ)របស់អ្នកមានកំណើតពីរដងដល់ (មិត្តសំឡាញ់និងញាតិ- សន្តាន) ជាការបូជាចំពោះ *បិសាក:*; បានផលតែក្នុង(ជាតិនេះ)ប៉ុណ្ណោះ បីដូចជាមេគោខ្វាក់ ដែលនៅតែក្នុងក្រោលមួយ។

១៤២- ដូចជាអ្នកស្រែមិនអាចប្រមូលផលបាន នៅពេលគាត់បានសាបព្រោះពូជនៅលើដីគ្មានជីជាតិ សូម្បីអ្នកផ្តល់អាហារនៃពិធីយញ្ញក៏ដោយ នឹងមិនបានផលទេ បើគាត់បានផ្តល់អាហារដល់ បុគ្គលដែលមិនចេះឫគវេទ។

១៤៣- ប៉ុន្តែអំណោយដែលឱ្យស្របតាមតម្រាជូនដល់អ្នកចេះដឹង ញ៉ាំងឱ្យអ្នកជូន និងអ្នកទទួលបាន ផលទាំងក្នុង(ជាតិ)នេះ និងទាំងក្នុងជាតិក្រោយ។

១៤៤- (ប្រសិនបើគ្មានព្រាហ្មណ៍ជាអ្នកចេះដឹងនៅក្នុងទំនាក់ទំនង) អ្នកអាចគោរពមិត្ត(ល្អ) ប្រសើរ ជាងសត្រូវ ទោះបីសត្រូវមានសមត្ថភាព (ដោយការសិក្សាជាដើម) ក្តី ព្រោះអាហារយញ្ញ ដែលសត្រូវទទួលទាន គ្មានបានផលនៅជាតិក្រោយទេ។

១៤៥- ចូរអ្នក (សុខចិត្ត) លំបាកក្នុងការផ្តល់អាហារនៅក្នុងពិធីស្រាទ្ធដល់អ្នកគោរពឫគវេទ ដែលបានសិក្សាព្រះវេទទាំងស្រុង ឬអ្នកគោរពយគុវេទដែលបានសិក្សាចប់មួយសាខា ឬអ្នកចម្រៀង សាម័ន ដែលបានបញ្ចប់(ការសិក្សាអត្ថបទវេទទាំងមូល)។

១៤៦- ប្រសិនបើម្នាក់ក្នុងចំណោមអ្នកទាំងបីទទួលទានពេលល្ងាចដោយបានទទួលការគោរពសមរម្យ ក្នុងពិធីឧទ្ទិសវិញ្ញាណក្ខន្ធ នោះបុព្វបុរសរបស់គាត់ (ដែលរៀបចំអាហារ) សម្រាប់មនុស្សរហូត ដល់ប្រាំពីរនាក់នឹងរីករាយពេញចិត្តអស់ពេលយ៉ាងយូរ។

១៤៧- នេះជាតម្រាដ៏សំខាន់ (ដែលត្រូវគោរព) ក្នុងការធ្វើពិធីបូជាទេវតា និងព្រលឹងបុព្វបុរស; ចូរចាំថា មនុស្សល្អតែងតែគោរពតាមក្បួនតម្រាផ្សេងៗ។

១៤៨- អ្នកក៏អាច (ក្នុងឱកាសបែបនេះ) ទទួលជីតាខាងម្ដាយ ពូខាងម្ដាយ បុត្ររបស់បងប្អូនស្រីឪពុកក្មេករបស់ខ្លួន គ្រូរបស់ខ្លួន បុត្រារបស់កូនស្រី ប្ដីរបស់កូនស្រី ញាតិលោហិតខាងប្រុស អាចារ្យ ពិធីការផ្ទាល់របស់ខ្លួន ឬបុគ្គល ដែលអ្នកត្រូវធ្វើការបូជា។

១៤៩- ចំពោះពិធីពិសិដ្ឋសម្រាប់ថ្វាយទេវតា អ្នកដែលចេះច្បាប់ នឹងមិនស៊ើបសួរ (ល្អិតពេក) ពាក់ព័ន្ធព្រាហ្មណ៍ដែលត្រូវអញ្ជើញទេ ប៉ុន្តែនៅពេលអ្នកធ្វើពិធីដើម្បីឧទ្ទិសដល់ព្រលឹងបុព្វបុរស អ្នកត្រូវតែយកចិត្តទុកដាក់ពិនិត្យពិច័យ(គុណសម្បត្តិ និងចំនួនភាគរយភៀវ)។

---

**១៤៧.** អាប. ជំពូក២ លេខ១៧, ៨-៩។ យោងតាមមេធ., គោវ., កុល្ល. និងរាឃ. ពាក្យ *បៃសាគី* មានន័យ 'ជូនតាមរបៀបបិសាចៈ'។ ប៉ុន្តែការប្រែខាងលើនេះ ដែលយកតាមលោកនារ. និងនន្ទ. ត្រូវបានគាំទ្រដោយកាព្យបុរាណ ដែលស្រង់សេចក្ដីដោយអាបស្តម្ភ ដែលទំនងជាបានមកពីស្លោករបស់ព្រះមនុ។

**១៤៨.** ពាក្យ *បន្ធុ* 'ញាតិលោហិតខាងប្រុស' (កុល្ល., រាឃ.) តែលោកមេធ. និងគោវ. ប្រែក្នុងន័យទូលាយបំផុតថា 'ញាតិសន្តានខាងប្រុស'(សគោត្រាទិៈ)។

**១៤៩.** វិ. ជំពូក៨២ លេខ១-២។

១៥០- មនុបានប្រកាសថា ព្រាហ្មណ៍ទាំងឡាយណាដែលជាចោរ ចណ្ឌាល មនុស្សកម្រៀវ ឬអ្នកមិន ជឿថាមានអាទិទេព មិនសម(ទទួល)តង្វាយបូជាព្រះអាទិទេព និងព្រលឹងបុព្វបុរសទេ។

១៥១- នៅក្នុងពិធីស្រាទ្ធ ចូរអ្នកកុំទទួលនរណាដែលពាក់សក់ក្រង(សិស្ស), អ្នកដែលមិនបានសិក្សា (ព្រះវេទ), អ្នកដែលមានជំងឺសើស្បែក, អ្នកល្បែង, និងកុំទទួលអ្នកដែលធ្វើពិធីសម្រាប់(អ្នក បូជា)ដ៏ច្រើន។

១៥២- គេត្រូវជៀសវាងគ្រូពេទ្យ អាចារ្យវត្ត អ្នកលក់សាច់ និងអ្នកដែលចិញ្ចឹមជីវិតដោយការលក់ដូរ នៅពេលធ្វើពិធីបូជាព្រះអាទិទេព និងព្រលឹងបុព្វបុរស។

១៥៣- អ្នកបម្រើទទួលបៀវត្សរបស់ភូមិឬរបស់ព្រះរាជា អ្នកដែលខូចក្រចកឬធ្មេញខ្មៅ អ្នកដែលប្រឆាំងនឹងគ្រូរបស់ខ្លួន អ្នកដែលបានបោះបង់ចោលភ្លើងពិសិដ្ឋ និងអ្នកចងការប្រាក់;

១៥៤- អ្នកដែលខ្វះខាតក្នុងការបរិភោគ អ្នកដែលចិញ្ចឹមជីវិតដោយការចិញ្ចឹមសត្វពាហនៈ ប្អូនប្រុសដែលរៀបការ ឬបង្កាត់ភ្លើងពិសិដ្ឋមុនបង អ្នកដែលមិនធ្វើការបូជាធំៗទាំងប្រាំ សត្រូវរបស់អម្បូរ ព្រាហ្មណ៍ បងប្រុសដែលរៀបការឬបង្កាត់ភ្លើងពិសិដ្ឋក្រោយប្អូន និងអ្នកដែលជាផ្នែកមួយរបស់ ក្រុមហ៊ុន ឬសាជីវកម្ម,

១៥៥- តារា ឬអ្នកចម្រៀង អ្នកដែលបានបំពានពាក្យសត្យៈក្នុងការសិក្សា អ្នកដែលភរិយា(ប៉ុណ្ណោះឬទី១) របស់ខ្លួន ជាស្ត្រីសូទ្រៈ បុត្ររបស់ស្ត្រីដែលបានរៀបការពីរដង បុរសភ្នែកមួយ និងអ្នកដែលនៅក្នុងផ្ទះរបស់ខ្លួន(មាន)ស្រីកំណាន់;

---

**១៥០-១៨២.** អាប. ជំពូក២ លេខ១៧, ២១; គោត. ជំពូក១៥ លេខ១៦-១៩, ៣០-៣១; វស. ជំពូក១១ លេខ១៩; វិ. ជំពូក៨២ លេខ៣-៣០; យញ្ញ. ជំពូក១ លេខ២២២-២២៤។

**១៥០.** ចំពោះពាក្យ *នាស្តិកវ្ត្តិ* 'អ្នកមិនជឿថាមានអាទិទេព'។ ក្រៅពីការបកស្រាយខាងលើ លោកមេធ. ធ្វើការបកស្រាយម្យ៉ាងទៀតថា 'អ្នកដែលទទួលបានការចិញ្ចឹមខ្លួនពីអ្នកដែលមិនជឿថាមានអាទិទេព'។

**១៥១.** *អនធិយានំ* 'អ្នកដែលមិនបានសិក្សាព្រះវេទ' គឺ 'អ្នកដែលត្រូវគេទទួលជាសមាជិកថ្មី តែមិនបានសិក្សា'(កុល្ល.) ឬ 'អ្នកដែលមិនបានចេះស្ទាត់ជំនាញព្រះវេទ'(មេធ.) ឬ 'អ្នកដែលបានបោះបង់ការសិក្សា'(នារ.)។ មេធ. និងនន្ទ. អាន *ទុរ វាលំ* ចំពោះពាក្យ *ទុរបលំ*ដែលកើតជំងឺសើស្បែក' និងមេធ.បកស្រាយសម្ដីរបស់គាត់ថា 'មនុស្សក្បាលទំពែក ឬសក់ក្រហម'។ 'អ្នកដែលបូជាដល់មនុស្សដ៏ច្រើន' គឺ 'អ្នកដែលធ្វើការបូជា*អហីន*(ដែលត្រូវហាមឃាត់) ព្រោះក្នុងឱកាសនោះមានអ្នកបូជាច្រើន'(នារ.)។

**១៥៤.** *និរាក្ឫតិះ* 'អ្នកដែលធ្វេសប្រហែសក្នុងការបូជាធំៗប្រាំយ៉ាង' (មេធ., កុល្ល., រាឃ.) តែយោងតាមគោវ. មានន័យថា 'អ្នកដែលបោះបង់ព្រះវេទ (និងអ្វីៗទាំងអស់)'។ យោងតាមនារ. និងនន្ទ. ថា 'អ្នកដែលមិនសូត្រព្រះវេទតែឯង' ឬ 'ដែលមិនបានសូត្រធម៌'។ *គណាភ្យន្តរៈ* 'អ្នកដែលជាផ្នែកមួយរបស់ក្រុមហ៊ុន ឬសាជីវកម្ម' គឺ 'ក្នុងចំណោមអ្នកដែលរស់នៅដោយការធ្វើពាណិជ្ជកម្ម' (មេធ., គោវ., នារ.) តែនារ.បកស្រាយបន្ថែមថា 'មេភូមិ' ឬ 'អ្នកដឹកនាំក្រុមអ្នកដំណើរ'។ យោងតាមកុល្ល. និងរាឃ. ពាក្យនេះមានន័យថា 'អ្នកដែលបន្លំលួចលុយក្រុមហ៊ុន'។

**១៥៥.** *កុសីលវៈ* 'តួប្រុស ឬអ្នកចម្រៀង' ហើយតាមយោបល់របស់មេធ. មានន័យទូលាយ ដោយរួមទាំង 'កវីអ្នកសម្ដែង អ្នកលេងសៀក អ្នករបាំ អ្នកច្រៀងជាដើម'។ កុល្ល. យល់ច្រឡំពាក្យ *អវកីណីន* 'អ្នកដែលបានបំពានពាក្យសត្យៈក្នុងការសិក្សា' ជាតាបស ដែលមិនបរិសុទ្ធ។ តាបសបែបនេះ គេហៅថា *អរូធបតិត*។

១៥៦- អ្នកដែលបង្រៀនដើម្បីលក្ខខណ្ឌប្រាក់ឈ្នួល និងអ្នកដែលត្រូវគេបង្រៀនក្នុងលក្ខខណ្ឌនោះ អ្នកដែលបង្រៀនសិស្សសូទ្រៈ និងអ្នកដែលមានគ្រូជាសូទ្រៈ អ្នកដែលនិយាយឥតពូជ បុត្ររបស់ស្ត្រីក្បត់ស្វាមី និងបុត្ររបស់ស្ត្រីមេម៉ាយ,

១៥៧- អ្នកដែលបោះបង់ម្ដាយឪពុករបស់ខ្លួនចោល ឬគ្រូដោយគ្មានហេតុផល(គ្រប់គ្រាន់) អ្នកដែលបានចងសម្ព័ន្ធមិត្តជាមួយចណ្ឌាល តាមរយៈព្រះវេទក្ដី ឬតាមរយៈចំណងអាពាហ៍ពិពាហ៍ក្ដី,

១៥៨- អ្នកអុជអាល អ្នកទោស អ្នកដែលទទួលទានអាហារដែលបានពីកូនរបស់ស្ត្រីក្បត់ស្វាមី អ្នកលក់សោមៈ(គ្រឿងស្រវឹង) អ្នកដែលធ្វើដំណើរតាមសមុទ្រ កវី អ្នកលក់ប្រេង អ្នកទទួលសំណូក កូតតុលាការ,

១៥៩- អ្នកដែលឈ្លោះ ឬប្ដឹងផ្ដល់ជាមួយឪពុកខ្លួន អ្នកបើកផ្ទះល្បែង អ្នកស្រវឹងខ្ទប អ្នកដែលមានជំងឺ(ដោយសារការដាក់ទណ្ឌកម្មនៃអំពើឧក្រិដ្ឋកន្លងមក) ជនជាប់ចោទពីបទល្មើសដែលមានទោសដល់ស្លាប់ មនុស្សលាក់ពុត អ្នកលក់សារជាតុសម្រាប់លើករសជាតិអាហារ,

១៦០- អ្នកធ្វើធ្នូ និងព្រួញ អ្នកដែលចែចង់ប្រលោមកាមជាមួយអ្នកមេម៉ាយរបស់បងប្រុស អ្នកក្បត់មិត្ត អ្នករស់ដោយសារល្បែង អ្នកដែលសិក្សា(ព្រះវេទ)ពីកូនប្រុសរបស់ខ្លួន,

---

**១៥៦.** ពាក្យ *វាគទុស្តះ* 'អ្នកដែលនិយាយឥតពូជ' តែតាមការបកស្រាយរបស់អ្នកផ្សេង ដែលលោកមេធ. និងកុល្ល.បានដកស្រង់គឺ 'អ្នកដែលជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ'(អភិសស្ត)។

**១៥៧.** យោងតាមនារ. ពាក្យ *គុរុះ* 'គ្រូ'សំដៅដល់គ្រូអាចារ្យតែប៉ុណ្ណោះ។ មេធ. បន្ទោសការបកស្រាយនេះ ហើយប្រែពាក្យនេះថាឧបាធ្យាយ។ លោកពន្យល់ពាក្យ *កុណ្ឌាសី* 'អ្នកដែលទទួលទានអាហារកូនប្រុសរបស់ស្ត្រីក្បត់ប្ដី' ក្នុងន័យថា 'អ្នកល្មោភស៊ី ដែលស៊ីបាយអស់ហុកសិប បលៈ'។

**១៥៨.** ពាក្យ *អគារទាហិ* 'អ្នកអុជអាល' តាមការដកស្រង់កាព្យមួយរបស់នន្ទ. រាប់បញ្ចូលទាំង 'អ្នកដែលដុតខ្មោច យកលុយ'។ ពាក្យ *កូដការកៈ* 'អ្នកស៊ីសំណូកកូតតុលាការ' (គោវ., កុល្ល.) ហើយតាមមេធ. និងរាឃ. គឺ 'អ្នកផ្ដល់សក្ខីកម្មមិនពិត' តែតាមនារ. និងនន្ទ. 'នរណាក៏ដោយដែលប្រព្រឹត្តអំពើក្លែងបន្លំ' ឧ.ទា. អ្នកធ្វើវត្ថុក្លែងក្លាយ អ្នកបន្លំភ្នែកជញ្ជីង និងបន្លំខ្នាតផ្សេងៗ។ 'អ្នកខ្លះ' ដែលលោកមេធ.បានស្រង់សម្ដី ប្រែ *សោមវិក្រយិន* ថា'អ្នកដែលលក់ (កុសលធម៌ ដោយ) សោម' (ពិធីយញ្ញ)។

**១៥៩.** ៉អ្នកដែលឈ្លោះ ឬប្តឹងផ្តល់ជាមួយឪពុករបស់ខ្លួន៉ ឧ.ទា. ដែលបង្ខំឪពុកឱ្យចែកទ្រព្យគ្រួសារ(មេធ.) សូមមើល គោត. ជំពូក១៥ លេខ១៩។ ពាក្យ *កិតវៈ* ៉អ្នកបើកបនល្បែង៉ (មេធ.) ហើយតាមគោវ. និងនន្ទ. គឺ ៉អ្នកដែលយកអ្នកដទៃសម្រាប់ការលេងសើចរបស់ខ្លួន៉ តែតាមនារ.ថា ៉អ្នកលេងដើម្បីសប្បាយ៉ និងតាមនន្ទ.គឺ ៉មនុស្សទុច្ចរិត៉។ យ៉ាងណាមិញ អ្នកខ្លះទៀតអាន *កេករៈ* ៉អ្នកដែលបើកភ្នែកលែងចង់រួច៉ និងបកស្រាយពាក្យនេះថា *មទ្យបៈ* ៉អ្នកស្រវឹងខ្លប៉ (មេធ., គោវ., កុល្ល., នារ., នន្ទ., រាឃ.)។ ពាក្យ *សេៈ* ៉សារធាតុសម្រាប់លើករសជាតិអាហារ៉ ឧ.ទា. ៉ស្ពទឹកអំពៅ៉(គោវ., កុល្ល. រាឃ.) ហើយលោក(នារ.)ថា ៉ទឹករង្វ៉។ មេធ.ប្រែ *សេទៈ* ថា *សៃទៈ* ៉មេបំពុល៉។

**១៦០.** ខ្ញុំទទួលយកការបកស្រាយរបស់គោវ. និងរាឃ. *អគ្រេទិធិសូបតិ* ដែលជឿថាពាក្យនេះត្រូវគ្នានឹងពាក្យ *ទិធិសូបតិ* ដែលមានការបកស្រាយនៅក្នុងកាព្យលេខ១៧៣ ខាងក្រោម។ កុល្ល. និងនន្ទ. ប្រែពាក្យនេះថា ៉ស្វាមីរបស់ប្អូនស្រីដែលរៀបការមុនបង៉ ហើយលោកមេធ. ថាជាពាក្យផ្ទុំខុសពីធម្មតា ដែលមាន *អគ្រេទិធិសូបតិ* និង *ទិធិសូបតិ* សូមមើល គោត. ជំពូក១៥ លេខ១៦។ សូម្បីក្នុងសម្រិតខ្លះ ពាក្យ *អគ្រេទិធិសូបតិ* តាមន័យរបស់កុល្ល. ហាក់ដូចជាគេមិនអាចទទួល យកបានទេ បើពិនិត្យមើលកាព្យលេខ១៧៣ ដែលគ្មានន័យ បើគ្មានន័យដូចការប្រែពាក្យនេះទេ។ ពាក្យ *ទ្យូតវ្ឫត្តិៈ* ៉អ្នកដែលចិញ្ចឹមជីវិតដោយសារល្បែង៉ ហើយតាមមេធ.ថា ៉អ្នកដែលយកអ្នកដទៃធ្វើជាប្រយោជន៍របស់ខ្លួន៉ និងតាមគោវ., កុល្ល. និងរាឃ.ថា ៉អ្នកបើកបនល្បែង៉។ នារ. និងនន្ទ. ប្រែពាក្យនេះតាមន័យត្រង់។

១៦១- មនុស្សឆ្កួតជ្រូក អ្នកកើតជំងឺម្រេញ អ្នកកើតរោគឃ្លង់ល្ពៅ អ្នករាយការណ៍ មនុស្សឆ្កួត មនុស្សខ្វាក់ និងអ្នកដែលឈ្លោះនឹងព្រះវេទទាំងទទឹងទិស គេត្រូវជៀសវាងមនុស្សទាំងអស់ នេះ។

១៦២- អ្នកបង្វឹកដំរី គោឡើងក សេះ ឬអូដ្ឋ អ្នកដែលចិញ្ចឹមជីវិតដោយវិជ្ជាហោរាសាស្ត្រ អ្នកស្រឡាញ់ សត្វស្លាប និងអ្នកដែលបង្រៀនការប្រើប្រាស់អាវុធ,

១៦៣- អ្នកដែលបង្វែរមុខទឹក និងអ្នកដែលចូលបិទមុខទឹក ស្ថាបត្យករ អ្នកនាំសារ និងអ្នកដែលដាំរុក្ខ ជាតិ (ដើម្បីលុយ),

១៦៤- អ្នកចិញ្ចឹមឆ្កែដើម្បីកីឡា អ្នកបង្ហាត់ស្ទាំង អ្នកដែលបំផ្លាញព្រហ្មចារីស្រីក្រមុំ អ្នកដែលចូលចិត្ត ធ្វើទុក្ខបុកម្នេញសត្វមានជីវិត អ្នកដែលចិញ្ចឹមជីវិតដោយសារសូទ្រៈ និងអ្នកដែលធ្វើការបូជា ចំពោះ*គណៈ*,

១៦៥- អ្នកដែលមិនគោរពតម្រាសីលធម៌ (អ្នកគ្មានថាមពលដូច)មនុស្សកម្រៀង អ្នកដែលចូលចិត្តពឹង (អ្នកដទៃ) ជានិច្ច អ្នកដែលពឹងលើកសិកម្ម អ្នកដែលមានជើងត្រង់ដូចឈើ និងអ្នកដែល ត្រូវមនុស្សរិះគន់,

១៦៦- អ្នកគង្វាលចៀម អ្នកចិញ្ចឹមក្របី ស្វាមីរបស់ស្ត្រីរៀបការពីរដង និងអ្នកដឹកសាកសព គេត្រូវប្រយ័ត្ន ជៀសវាងមនុស្ស(ទាំងអស់នេះ)។

១៦៧- ព្រាហ្មណ៍ដែលចេះដឹង (ច្បាប់ពិសិដ្ឋ) គួរដើរចេញ(នៅក្នុងពិធី) ទាំង (ពិធីថ្វាយទេវតានិងពិធីឧទ្ទិស ព្រលឹងបុព្វបុរស) ពីមនុស្សថ្នាក់ទាបបំផុតដែលមានចរិយាឆ្គាំឆ្គង និងដែលមិនសមនឹងអង្គុយជាមួយ (នៅពេលបាយ)។

១៦៨- ឧបមាដូចជាគេ(មិនងាយនឹងធ្វើឱ្យខូចការបូជានិងពន្លត់) ភ្លើងឆេះស្មៅស្ងួត សូម្បីធ្វើជាមួយព្រាហ្មណ៍ ដែលគ្មានការចេះដឹងក៏ដោយ ក៏ប៉ុន្តែគេមិនត្រូវផ្តល់អាហារបូជាដល់គាត់ដែរ ព្រោះការផ្តល់នោះនឹងក្លាយជាផេះ។

១៦៩- ខ្ញុំនឹងប្រកាសទាំងស្រុងនូវអ្វីដែលអ្នកបរិច្ចាគនឹងទទួលបានបន្ទាប់ពីស្លាប់ ប្រសិនបើគេផ្តល់អាហារ សម្រាប់បូជាទេវតា ឬបុព្វបុរស ឱ្យមនុស្សដែលមិនសមនឹងអង្គុយជាមួយ។

---

**១៦២.** ពាក្យ *បក្សិណាំ បូសកៈ* ៉អ្នកស្រឡាញ់សត្វស្លាប៉ ហើយតាមមេធ. ថា ៉អ្នកបង្វឹកសត្វស្ទាំងសម្រាប់ប្រមាញ់៉។

**១៦៤.** អ្នកអធិប្បាយសរសេរសំណេរផ្សេង *វ្រុសលបុត្រ:* 'អ្នកដែលមានតែកូនប្រុសជាមួយភរិយាសូទ្រៈ' សំដៅដល់ 'អ្នកដែលចិញ្ចឹមជីវិតខ្លួនដោយសារសូទ្រៈ'។ នារ. និងនន្ទ. បកស្រាយពាក្យ *គណាន៑ា យាគក:* ថា 'អ្នកដែលបូជាចំពោះ*គណៈ* គឺមនុស្ស ឬក្រុមមនុស្សជាច្រើន។ យោងតាមការបកស្រាយរបស់លោកមេធ., កុល្លូ. និងរាឃ. ដែលត្រូវប្រែខាងលើ ការធ្វើពិធី*នៃាយក:* ឬ *គណេស-ហោម* (មើលយញ្ញ. ជំពូក១ លេខ២៧០-២៩៤) អាចមានពន្យល់ន័យនេះ។ ប៉ុន្តែ គេក៏ អាចគិតអំពី *គណហោម*ដែលតាមពោធ. ជំពូក៤ លេខ៨,១ គេមិនត្រូវធ្វើសម្រាប់អ្នកដទៃទេ។

**១៦៨.** យោងតាមមេធ. និងគោវ. កម្មវត្ថុកាព្យនេះ គឺសំដៅទទួលមនុស្សល្អ និងអ្នកចេះដឹង ដែលមានជំងឺផ្លូវកាយ ធ្វើជាភ្ញៀវក្នុងពិធីសាសនា ដើម្បីអបអរពិធីថ្វាយទេវតា សូមមើលវស. ជំពូក១១ លេខ២០។ កុល្លូ. គិតថា ការបង្គាប់ឱ្យជៀសវាងមនុស្សល្ងង់ ត្រូវបាននិយាយច្រើនដងនៅទីនេះ ដើម្បីបញ្ជាក់ថា ពួកគេមិនស័ក្តិសមជា'អ្នកចូលរួមពិតប្រាកដទេ'។

១៧០- តាមពិត *ភក្សសៈ* បរិភោគ(អាហារ) របស់ព្រាហ្មណ៍ដែលមិនបានគោរពពាក្យសត្យៈក្នុងការសិក្សារបស់*បរិវេត្តិ* ជាដើម និងរបស់អ្នកផ្សេងទៀត ដែលគេមិនអាចរាប់អានជាមិត្តភក្តិបាន។

១៧១- គេត្រូវចាត់ទុកគាត់ថាជា *បរិវេត្តិ* ដែលរៀបការ ឬចាប់ផ្ដើមធ្វើអគ្និហោត្រ មុនបងប្រុសរបស់ខ្លួន ហើយបងប្រុសក៏ជាបរិវេត្តិ ដែរ។

១៧២- បងប្រុសដែលរៀបការក្រោយប្អូន, ប្អូនប្រុសដែលរៀបការមុនបង, ស្ត្រីដែលគេសន្យារៀបការជាមួយ, អ្នកដែលលែងនាង និងអាចារ្យពិធីការ ជាគម្រប់ប្រាំ នឹងធ្លាក់នរកទាំងអស់។

១៧៣- អ្នកដែលប្រលោមលេងដោយកាមតម្រេកជាមួយនឹងអ្នកមេម៉ាយរបស់បងប្រុសដែលចែកឋាន ទោះបីជាគេតម្រូវឱ្យនាង(មានកូនជាមួយគាត់) ស្របតាមច្បាប់ពិសិដ្ឋក្តី ក៏គេចាត់ទុកថាជា *ទិធិសូបតិ* ដែរ។

១៧៤- បុត្រពីរប្រភេទ គឺ *កុណ្ឌ:*និង *គោលក:* ចាប់កំណើតពីភរិយារបស់បុរសផ្សេង ហើយ(អ្នកដែលកើតមកនោះ) ខណៈដែលស្វាមីនៅមានជីវិតនឹងក្លាយជា*កុណ្ឌ:* និង (អ្នកដែលកើត)បន្ទាប់ ពីមរណភាពរបស់ស្វាមី គឺ *គោលក:*។

១៧៥- ប៉ុន្តែមនុស្សទាំងពីរ ដែលកើតពីភរិយាដែលមានបុរសផ្សេងគ្នា ញ៉ាំងឱ្យអ្នកបរិច្ចាគមិនបាន (ផល) ទាំងនៅក្នុងជាតិនេះនិងជាតិក្រោយ ចំពោះការបរិច្ចាគអាហារពិសិដ្ឋដល់ទេវតា ឬ ព្រលឹងបុព្វបុរសនោះ។

១៧៦- អ្នកបរិច្ចាគល្ងង់ខ្លៅ (នូវអាហារបុណ្យ) មិនបានទទួលផល ព្រោះភ្ញៀវកិត្តិយសជាច្រើន អាចសម្លឹងមើលភ្ញៀវដែលមិនសមនឹងចូលរួមពិធី ខណៈដែលពួកគេកំពុងទទួលទាន។

១៧៧- មនុស្សខ្វាក់ដែលមានវត្តមានក្នុងពិធី ញ៉ាំងឱ្យអ្នករៀបចំ (ពិធីបុណ្យ) បាត់បង់ផលសម្រាប់ (ភ្ញៀវ) កៅសិបនាក់, មនុស្សភ្នែកម្ខាងបាត់អស់ហុកសិបនាក់, អ្នកកើតឃ្លង់ល្ពៅបាត់អស់មួយរយនាក់ និងអ្នកមានបាបដោយសារជំងឺ(ធ្ងន់ធ្ងរ) បាត់អស់មួយពាន់នាក់។

១៧៨- អ្នករៀបចំ (ពិធីស្រាទ្ធ) បាត់បង់ផល (កុសល) ដោយសារការបរិច្ចាគក្រៅពិធីបុណ្យ ព្រោះព្រាហ្មណ៍ជាច្រើន(ដែលជាភ្ញៀវ)ដែលបរិច្ចាគដល់ពួកសូទ្រៈអាចប៉ះដៃប៉ះជើងភ្ញៀវ (ក្នុងពេលទទួលទាន)។

---

**១៧០.** *អប្រែត* 'អ្នកដែលមិនបានគោរពពាក្យសត្យៈក្នុងការសិក្សា'(គោវ., កុល្លូ., រាឃ.) ហើយបើតាមមេធ. គឺ 'ដែលប្រព្រឹត្ត មិនល្អ' ហើយបើតាមនារ. គឺ 'ដែលមិនគោរពសិក្ខាវិន័យ ដែលបញ្ញត្តិសម្រាប់ស្នាកតៈជាដើម'។

**១៧១.** ជាធម្មតា មនុស្សម្នាក់ដែលបង្កាត់ភ្លើងពិសិដ្ឋនៅចំពោះមុខបងប្រុសរបស់ខ្លួន ត្រូវគេហៅថា *បរយាធាត្ន* ហើយគេហៅបងប្រុសនោះថា *បរិយ្យាហិត:*។

**១៧២.** ពោធ. ជំពូក២ លេខ១, ៣៩។

**១៧៧.** ពាក់ព័ន្ធនឹងជំងឺ ដែលជាការទទួលទណ្ឌកម្មចំពោះអំពើបាបដែលបានប្រព្រឹត្តកាលពីជាតិមុន សូមមើលជំពូក១១ លេខ៤៩ ខាងក្រោម។

**១៧៨.** ពាក្យ *អោរតិកំ* 'ដោយសារការបរិច្ចាគក្រៅពិធី' គឺ 'ព្រោះអ្នកដែលទទួលការបរិច្ចាគនៅក្រៅបរិវេណពិធីបុណ្យ' (មេធ., គោវ.) ឬ 'ព្រោះការបរិច្ចាគអាហារនៅពេលពិធីស្រាទ្ធ'(កុល្លូ., រាឃ.)។

១៧៩- ហើយប្រសិនបើព្រាហ្មណ៍ ថ្វីត្បិតតែមានការចេះដឹងព្រះវេទក៏ដោយ ទទួលអំណោយដោយ ចិត្តលោភពី(មនុស្ស)បែបនេះ គាត់នឹងវិនាសយ៉ាងឆាប់ ដូចជាភាជន៍ដីដែលមិនបានដុត ហើយត្រូវទឹក។

១៨០- (អាហារ)ដែលផ្តល់ជូនអ្នកលក់សោមៈ នឹងក្លាយជាសម្រាម (អាហារដែលផ្តល់)ឱ្យគ្រូពេទ្យ ក្លាយជាខ្ទុះនិងឈាម តែ(អាហារដែលផ្តល់)ជូនអាចារ្យវត្ត ត្រូវបាត់ទទេ ហើយ(អាហារដែល) ឱ្យអ្នកចងការប្រាក់ នឹងបាត់ឱកាស(ទៅកាន់ឋានទេវលោក)។

១៨១- អ្វីដែលគេបានបរិច្ចាគដល់ព្រាហ្មណ៍ដែលរស់នៅដោយរបរជួញដូរ ដែលមិន(សូវ)បានផល នៅក្នុងជាតិនេះ និងជាតិក្រោយ និង(ការធ្វើទាន)ដល់ព្រាហ្មណ៍ដែលកើតពីស្ត្រីរៀបការពីរដង (ញ៉ាំងផលនៃការបូជានោះ)ឱ្យក្លាយជាផេះតែម្តង។

១៨២- ប៉ុន្តែអ្នកមានគតិបណ្ឌិតប្រកាសថា អាហារដែល(គេជូន)មនុស្សអាក្រក់ដែលមិនគួរឱ្យ ដូចបានរៀបរាប់ខាងលើ (នឹងក្លាយជា)ជុំខ្លាញ់ ឈាម សាច់ ខួរឆ្អឹង និងឆ្អឹងដ៏ក្រាស់។

១៨៣- ឥឡូវចូរស្តាប់ចំណុចសំខាន់អ្វីខ្លះដែលអ្នកមានកំណើតពីរដង ធ្វើឲ្យខូចដោយសារវត្តមានរបស់ភ្ញៀវមិនសមគួរ ត្រូវបន្សុទ្ធមកវិញ និងមានការពណ៌នាទាំងស្រុងអំពីព្រាហ្មណ៍ដែលជួយសង្គ្រោះញាតិមិត្ត។

១៨៤- គេពិតជាចាត់ទុកមនុស្សទាំងនោះជាម្ចាស់បុណ្យរបស់មិត្ត ដែលភាគច្រើនចេះដឹងព្រះវេទ និង អង្គធម៌ទាំងអស់ និងដែលជាកូនចៅរបស់ *ស្រោត្រិយ*។

១៨៥- *ត្រិណាកិកេតៈ* អ្នកដែលរក្សាភ្លើងពិសិដ្ឋប្រាំ, *ត្រិសុបរណៈ* អ្នកដែលចេះតែងកាព្យអង្គប្រាំមួយ, បុត្ររបស់ស្ត្រីដែលបានរៀបការស្របតាមពិធីព្រាហ្មណ៍, អ្នកដែលច្រៀង *ជ្យេស្ឋសាម័ន*,

---

**១៧៩.** 'ផ្តើមពីមនុស្សបែបនេះ' គឺ 'ពីអ្នកដែលបូជាដល់ពួកសូទ្រៈ'។

**១៨០.** អត្ថន័យគឺថា អ្នកបរិច្ចាគ នឹងចាប់កំណើតនៅជាតិបន្ទាប់របស់ខ្លួនក្នុងចំណោមសត្វ ដែលចិញ្ចឹមជីវិតមិនស្អាត (ដូចលោកមេធ., គោវ., កុល្លូ., រាឃ. បានរៀបរាប់) ឬថា ព្រលឹងបុព្វបុរស និងទេវតានឹងមិនទទួលអាហារនោះទេ ដោយសារតែភាពសៅហ្មង(នារ.)។ *អប្រតិស្ថំ* 'រកទីឋានមិនឃើញទេ'(មេធ., គោវ., កុល្លូ., រាឃ.) ហើយនារ.និងនន្ទ. ថា 'មិនទទួលបានកិត្តិស័ព្ទ(សម្រាប់អ្នកបរិច្ចាគ)ទេ'។

**១៨២.** យោងតាមមេធ., គោវ., កុល្លូ. និងរាឃ. គេប្រាកដជាយល់ថា អ្នកធ្វើទាន នឹងកើតក្នុងជាតិបន្ទាប់ជាដង្កូវ ដែលរស់នៅក្នុងទីមិនស្អាតដូចបានជម្រាបជូនស្រាប់។

**១៨៣-១៨៦.** អាប. ជំពូក២ លេខ១៧, ២២; គោត. ជំពូក១៥ លេខ២៨, ៣១; វស. ជំពូក៣ លេខ១៩; ពោធ. ជំពូក២ លេខ១៤, ២-៣; វិ. ជំពូក៨៣; យញ្ញ. ជំពូក១ លេខ២១៩-២២១។

**១៨៥.** ចំពោះពាក្យ *ត្រិណាកិកេតៈ* សូមមើលកំណត់សម្គាល់របស់ អាប. ជំពូក២ លេខ១៧, ២២។ ពាក្យ *បញ្ចាគ្និះ* 'អ្នកដែលរក្សាភ្លើងពិសិដ្ឋប្រាំ' (មេធ., គោវ., កុល្លូ., នន្ទ., រាឃ. និងអ្នកផ្សេងទៀត) ហើយតាមមេធ. និងនារ. ថា 'អ្នក ដែលចេះដឹង *បញ្ចាគ្និវិទ្យា* បានសិក្សានៅក្នុង *ខានទោគ្យោបនិស័ទ* ជំពូក៤ លេខ១០'។ *ត្រិសុបរណៈ* តាមលោកមេធ., នារ. និងនន្ទ. មានន័យថា 'អ្នកដែលចេះដឹងអត្ថបទ តៃត្ត. អារ. ជំពូក១០ លេខ៣៨-៤០' ប៉ុន្តែតាមគោវ., កុល្លូ. និងរាឃ. ថា 'អ្នកដែលចេះដឹងឫគ-វេទមួយផ្នែក ដែលគេហៅថា *ត្រិសុបរណៈ* ឫគ-វេទ ជំពូក១១៤, ៣-៥'។'

១៨៦- អ្នកដែលដឹងច្បាស់ពីអត្ថន័យព្រះវេទ និងអ្នកដែលចេះអធិប្បាយព្រះវេទ អ្នកសិក្សាអ្នកដែលបានផ្តល់(មេគោ)មួយពាន់ និងអ្នកដែលមានអាយុមួយរយឆ្នាំ ត្រូវគេចាត់ទុកជាព្រាហ្មណ៍ ដែលជួយសង្គ្រោះញាតិមិត្ត។

១៨៧- នៅមុនថ្ងៃរៀបចំពិធីស្រាទ្ធ ឬនៅថ្ងៃធ្វើពិធី ចូរអ្នកគោរពអញ្ជើញព្រាហ្មណ៍យ៉ាងហោចណាស់ ចំនួនបីនាក់ ដូចបានរៀបរាប់ខាងលើ។

១៨៨- ព្រាហ្មណ៍ ដែលត្រូវបានអញ្ជើញចូលរួម(ពិធី) ដើម្បីជាកិត្តិយសបុព្វបុរស គួរតែគ្រប់គ្រងខ្លួន ឯងជានិច្ច និងមិនសូត្រធម៌វេទទេ ហើយអ្នកដែលធ្វើពិធីស្រាទ្ធ (ត្រូវដំណើរការកម្មវិធីតាម របៀបដដែល)។

១៨៩- ដើម្បីព្រលឹងអ្នកស្លាប់ ចូររាក់ទាក់ទទួលព្រាហ្មណ៍ដែលបានអញ្ជើញ ដើរតាមពួកគាត់ (ពេលពួកគាត់ដើរ) ដូចជាខ្យល់ និងអង្គុយជិតពួកគាត់ ពេលពួកគាត់អង្គុយ។

១៩០- ប៉ុន្តែព្រាហ្មណ៍ដែលត្រូវគេអញ្ជើញត្រឹមត្រូវ ឱ្យចូលរួមពិធី ដើម្បីជាកិត្តិយសអាទិទេព ឬវិញ្ញា-ណក្ខន្ធបុព្វបុរស ធ្វើឱ្យខក(ពេលណាត់)តាមរបៀបណាក៏ដោយ ជាកំហុស(ឧក្រិដ្ឋ) ហើយ (ក្នុងជាតិបន្ទាប់របស់គាត់) នឹងក្លាយជាសត្វជ្រូក។

១៩១- ប៉ុន្តែអ្នកដែលត្រូវគេចូលរួមពិធីស្រាទ្ធ ប្រលោមលេងជាមួយស្ត្រីសូទ្រៈ នឹងទទួលបាបកម្មទាំងអស់ដែលអ្នក(ធ្វើទាន)បានប្រព្រឹត្ត។

១៩២- ព្រលឹងបុព្វបុរសជាទេវតាបឋម គ្មានកំហឹងរក្សាខ្លួនក្នុងភាពបរិសុទ្ធ ស្អាតកាយស្អាតចិត្ត ឃ្លាតឆ្ងាយពីវិវាទ និងពោរពេញដោយមហាកុសលធម៌។

១៩៣- ឥឡូវចូរសិក្សាទាំងស្រុងពីដើមកំណើតបុព្វបុរសរបស់ខ្លួននិងពិធីអ្វីខ្លះ ដែលគួរដល់ការគោរពបូជាវិញ្ញាណក្ខន្ធពួកគាត់។

១៩៤- វណ្ណៈ(ផ្សេងៗ)របស់វិញ្ញាណក្ខន្ធជូនតា ត្រូវបានអះអាងថាជាបុត្ររបស់បណ្ឌិតទាំងអស់ *មរីកិ* និងអ្នកដទៃទៀត ដែលជាកូនចៅរបស់មនុ បុត្ររបស់ហិរណ្យគាភៈ។

---

**១៨៦.** នន្ទ. បកស្រាយ*ព្រាហ្មការី* 'អ្នកសិក្សា' ដោយ 'បុរសបរិសុទ្ធ' (សូមមើលកាព្យលេខ៥០ខាងលើ)។

**១៨៧.** អាប. ជំពូក២ លេខ១៧, ១១-១៥; វស. ជំពូក១១ លេខ១៧; យញ្ញ. ជំពូក១ លេខ២២៥។

**១៨៨.** គោត. ជំពូក១៥ លេខ២៣; យញ្ញ. ជំពូក១ លេខ២២៥។ 'គ្រប់គ្រងខ្លួនឯង' គឺ 'រក្សាភាពបរិសុទ្ធឲ្យបាន'។

**១៨៩.** 'ដូចខ្យល់' គឺ 'ដូចខ្យល់ជីវិត គឺដង្ហើម'(មេធ., គោវ., កុល្ល.)។ មេធ.គិតថា ព្រលឹងបុព្វបុរស ចូលសណ្ឋិតក្នុងខ្លួនភ្ញៀវដែលគេបានអញ្ជើញ។

**១៩០.** មេធ. បកស្រាយពាក្យ *អតិក្រាមន៍* 'ធ្វើឲ្យខកការណាត់ជួន'(គោវ., កុល្ល., នារ., រាឃ.) ដោយ 'បំពានវិធានបរិសុទ្ធ និងវិធានផ្សេង'។ មេធ.បញ្ជាក់ការបកស្រាយទីពីររបស់អ្នកដទៃ 'មិនទទួលយកការអញ្ជើញ' គឺជាការមិនសមស្រប។

**១៩១.** មេធ., គោវ., នន្ទ. និងរាឃ. ប្រែពាក្យ *វ្រសលី* 'ស្ត្រីសូទ្រៈ' ក្នុងន័យ 'ភរិយារួមសង្វាស់របស់ខ្លួន'។ ទំនងជាគេប្រើពាក្យនេះតាមន័យត្រឹមត្រូវរបស់វាហើយដូចលោកនារ.អះអាងសបញ្ជាក់ថាការរួមសង្វាស់ជាមួយភរិយាសូទ្រៈ ជាបទល្មើសធ្ងន់ធ្ងរបំផុតក្នុងករណីបែបនេះ។

**១៩៤.** ឃ្លា 'មរីកិ និងអ្នកផ្សេងទៀត' សូមមើលជំពូក១ លេខ៣៥ ខាងលើ។

១៩៥- *សោមស័ទ* បុត្ររបស់វិភាគ ត្រូវគេអះអាងថាជាបុព្វបុរសរបស់សាធ្យៈ ហើយអគ្និស-វាត្ត បុត្ររបស់*មារីកិ* មានកេរ្តិ៍ឈ្មោះល្បីក្នុងលោក (ជាបុព្វបុរស)របស់អាទិទេព។

១៩៦- ពរហិស័ទដែលកើតពីព្រះនាងអត្រិ ត្រូវគេកត់ត្រាថាជា (ព្រលឹងបុព្វបុរស) របស់ពួកទៃត្យៈ, ទានវៈ, យក្ស, គន្ធរ្វ, ទេវតាពស់, រាក្សសៈ, សុបរណ និងកឹនរ (កិន្នរ),

១៩៧- *សោមបៈ* បុត្រទាំងឡាយរបស់ព្រាហ្មណ៍, *ហវិភុគ* បុត្រទាំងឡាយរបស់ក្សត្រិយ, *អាត្យប* បុត្រទាំងឡាយរបស់វៃស្យៈ ហើយ*សុកាលិន* បុត្រទាំងឡាយរបស់សូទ្រៈ។

១៩៨- *សោមបៈ* ជាបុត្រារបស់កាវិ (ក្រិគុ), *ហវិស្មំត* កូនរបស់អង្គិរៈ, *អាត្យបៈ* កូនរបស់បុលស្ត្យ, ហើយ*សុកាលិន* (កើត)ពីវសិស្ឋៈ។

១៩៩- អ្នកគួរតែដឹងថា (វណ្ណៈដទៃ) ដូចជាអគ្និទគ្ធ, អនគ្និទគ្ធ, កាវ្យ, ពរហិស័ទ, អគ្និស្វាត្តៈ, និង សៅម្យ គឺជា (បុព្វបុរស)របស់ព្រាហ្មណ៍ប៉ុណ្ណោះ។

២០០- ប៉ុន្តែចូរដឹងដែរថានៅក្នុង(លោក)នេះ មានបុត្រានិងចៅប្រុសរាប់មិនអស់ ដែលកើតពីជួរបុព្វបុរសសំខាន់ៗ ដូចដែលបានរៀបរាប់។

២០១- ពីបុព្វបុរស បង្កើតបានពួកបណ្ឌិត, ពីអាទិទេព និងទានវៈ បង្កើតបុព្វបុរស តែពិភពលោកទាំងមូលកើតពីព្រះអាទិទេព ទាំងវត្ថុមានចលនា និងគ្មានចលនា តាមលំដាប់លំដោយ។

២០២- សូម្បីទឹកដែលធ្វើពីប្រាក់ ឬសំអិតសំអាងដោយប្រាក់សម្រាប់បូជាតាមជំនឿ (ដល់បុព្វបុរស) បង្កើតនូវ (ពរជ័យ)រាប់មិនអស់។

២០៣- សម្រាប់អ្នកមានកំណើតពីរដង ពិធីសាសនាដែលឧទ្ទិសដល់វិញ្ញាណក្ខន្ធបុព្វបុរស មានសារៈសំខាន់ជាងពិធីបូជាអាទិទេព ព្រោះថាការបូជាព្រះអាទិទេព ដែលធ្វើមុន(ពិធីស្រាទ្ធ) ត្រូវបានប្រកាសថាជាមធ្យោបាយ សម្រាប់ធ្វើឱ្យ (ពិធីក្រោយ) ប្រសើរឡើង។

---

**១៩៥.** នារ., នន្ទ. និង K. ប្រិម មនុ អាន *សោមសុតៈ* សម្រាប់ពាក្យ *សោមសទៈ*។

**១៩៩.** មេធ. និងគោវ. ដាក់ពាក្យ *អនគ្និទគ្ធ* មុន។ នារ.អានកាព្យចុងពាក់កណ្ដាលទីមួយ *ពហូន* 'ច្រើន' ជំនួសពាក្យ *តថា* ហើយនន្ទ.ប្រើពាក្យ *វហាន*។ ការប្រែនេះយកតាមការបកស្រាយរបស់គោវ., កុល្លុ., និងរាឃ.។ អ្នកអធិប្បាយបីនាក់ទៀតនិយាយថា កាព្យនេះរាប់ឈ្មោះខុសគ្នាខ្លះចំពោះវណ្ណៈជាច្រើនរបស់បុព្វបុរស ដែលបានរៀបរាប់នៅក្នុងកាព្យខាងដើម។ ប៉ុន្តែការបកស្រាយរបស់ពួកគេ មិនច្បាស់ណាស់ណាទេ ហើយពួកគេបង្ខំធ្វើមិនដឹង ឬប្តូរបរិវាសព្ទ *អេវ* ដែលស្ថិតនៅខាងក្រោយ *វិប្រាណាំ*។ កាព្យនេះទំនងជាមានការចាត់ថ្នាក់បុព្វបុរសទីពីរ ដែលខុសគ្នាពីបុព្វបុរសខាងដើម ពីព្រោះតែមានប្រពៃណីផ្សេងគ្នា។

**២០២.** ពាក្យ *អក្សយាយបកល្បតេ* 'ឱ្យ(ពរជ័យ)គ្មានទីបញ្ចប់'(គោវ., កុល្លុ.) ហើយតាមមេធ.ថា 'ញុំាងឱ្យពួកគេរីករាយជានិច្ច'។

**២០៣.** ពិធីថ្វាយព្រះអាទិទេព គឺ*វៃស្វទេវ*ដែលធ្វើមុនពិធីស្រាទ្ធៈនីមួយៗ។

២០៤- ចូរអ្នកទីមួយអញ្ជើញ(ព្រាហ្មណ៍)ម្នាក់ដើម្បីជាកិត្តិយសព្រះអាទិទេពធ្វើជាការការពារ(ការបូជាវិញ្ញាណក្ខន្ធបុព្វបុរស) ព្រោះពួករក្សាសៈចូលចិត្តបំផ្លាញពិធីយញ្ញ ដែលធ្វើដោយគ្មានការ ការពារបែបនេះ។

២០៥- ចូរអ្នកចាប់ផ្តើម(ធ្វើពិធីស្រាទ្ធ) និងបញ្ចប់ដោយ(ពិធី)បូជាអាទិទេព។ ការបូជាអាទិទេពមិន គួរចាប់ផ្តើមមុន ហើយបញ្ចប់ដោយ(ពិធី)ឧទ្ទិសវិញ្ញាណក្ខន្ធបុព្វបុរសទេ ពីព្រោះអ្នកដែលចាប់ ផ្តើមពិធីស្រាទ្ធមុន និងបញ្ចប់ដោយ(ពិធី)ឧទ្ទិសព្រលឹងបុព្វបុរស នឹងវិនាសយ៉ាងឆាប់ ព្រមជាមួយនឹងកូនចៅរបស់ខ្លួន។

២០៦- ចូរអ្នករៀបចំសំអាតកន្លែងឱ្យបរិសុទ្ធ និងបិទបាំងឱ្យដាច់ពីកន្លែងអាចម៍គោ ហើយធ្វើឱ្យមានជម្រាលទៅខាងត្បូង។

២០៧- ព្រលឹងបុព្វបុរស តែងតែរីករាយជាមួយនឹងការបូជាដែលធ្វើនៅទីវាល កន្លែងបរិសុទ្ធបែបធម្មជាតិ នៅមាត់ទន្លេ និងនៅកន្លែងដាច់ពីគេ។

២០៨- (អ្នកបូជាយញ្ញ) គួរឱ្យព្រាហ្មណ៍ (ដែលបានអញ្ជើញមក) ដែលមានធ្វើការស្រោចត្រឹមត្រូវអង្គុយនៅលើអាសនៈដែលបានរៀបចំដាច់ពីគេ លើកម្រាលស្មៅកុសៈ ដែលបានរៀបចំស្រាប់។

២០៩- បន្ទាប់ពីបានអញ្ជើញព្រាហ្មណ៍គ្មានមន្ទិលនោះ អង្គុយលើអាសនៈរួច អ្នកគួរផ្តល់កិត្តិយសជូន ពួកគាត់ដោយជូនកម្រងផ្កាក្រអូបនិងទឹកអប់ ដោយចាប់ផ្តើមពី (អ្នកណាដែលត្រូវបានអញ្ជើញមកដើម្បីជាកិត្តិយស) ព្រះអាទិទេព។

២១០- បន្ទាប់ពីបានផ្តល់ជូនពួកគាត់នូវទឹក គ្រាប់ល្ង និងកម្រាលស្មៅកុសៈ ព្រាហ្មណ៍(អ្នកបូជាយញ្ញ) គួរតែថ្វាយ(ព្រះភ្លើង)ក្នុងចង្រ្កានពិសិដ្ឋ ក្រោយពីបានការអនុញ្ញាត(ឱ្យធ្វើដូច្នោះ) ពី(ភ្ញៀវ) ព្រាហ្មណ៍ដែលចូលរួម(ទាំងអស់)។

---

**២០៤.** ការប្រែខាងលើនៃកាព្យពាក់កណ្តាលទីមួយ យកតាមលោកមេធ., គោវ. និងកុល្ល.។ យ៉ាងណាមិញ មិនមែនមិនអាចទៅរួចទេ បើយកតាមការប្រែរបស់ Sir W. Jones *ទៃវ* ជានបុំសកលិង្គ និងប្រែថា 'ចូរអ្នកធ្វើពិធីថ្វាយព្រះអាទិទេព ជាមុន ដើម្បីជាការការពារសម្រាប់(ពិធីស្រាទ្ធៈ)'។

**២០៥.** ន័យនៃកាព្យនេះ គឺថា ព្រាហ្មណ៍ដែលទទួលទានក្នុងពិធីវៃស្វទេវ ដែលធ្វើមុនពិធីស្រាទ្ធៈ ត្រូវបានគេអញ្ជើញ និងបម្រើមុន និងអញ្ជើញឱ្យទៅវិញ បន្ទាប់ពីព្រាហ្មណ៍រៀបចំឧទ្ទិសវិញ្ញាណក្ខន្ធបុព្វបុរស (មេធ., កុល្ល., នារ.)។ សូមមើលកាព្យលេខ២០៩ ខាងក្រោមផង។

**២០៦.** អាប. ជំពូក២ លេខ១៨, ១៤; គោត. ជំពូក១៥ លេខ២៥; យញ្ញ. ជំពូក១ លេខ២២៧។

**២០៧.** វិ. ជំពូក៨៥ លេខ៥៤-៦៣។ ពាក្យ *កុស្សេសុ* 'បរិសុទ្ធតាមបែបធម្មជាតិ' (មេធ., គោវ., កុល្ល., នារ.) ឬ 'ដែលស្រស់ត្រកាល' (នន្ទ., រាឃ.) 'ដូចជាព្រៃល្បោះ'(កុល្ល.)។

**២០៨.** យញ្ញ. ជំពូក១ លេខ២២៦,

**២០៩.** វិ. ជំពូក៨៣ លេខ២; យញ្ញ. ជំពូក១ លេខ២៣១។

**២១០.** វិ. ជំពូក៨៣ លេខ៥; អាប. ជំពូក២ លេខ១៧, ១៧-១៩; ពោធ. ជំពូក២ លេខ១៤, ៧; យញ្ញ. ជំពូក១ លេខ២២៩។

២១១- យោងតាមវិធាន ដោយបានធ្វើ ដំបូងជាមធ្យោបាយការពារ(ពិធីស្រាទ្ធៈ) ការបូជាព្រះ*អគ្និ*, *សោមៈ* និង*យមៈ* បន្ទាប់ពីនោះមក ចូរអ្នកបំពេញចិត្តព្រលឹងបុព្វបុរស ដោយការឧទ្ទិសអាហារ បុណ្យ។

២១២- ប៉ុន្តែប្រសិនបើគ្មានភ្លើង(ពិសិដ្ឋ)ទេ គេគួរដាក់តង្វាយនោះទៅលើដៃរបស់ព្រាហ្មណ៍ ព្រោះព្រាហ្មណ៍ដែលចេះធម៌ពិសិដ្ឋនឹងថ្លែងថា 'ភ្លើងអ្វីក៏ដោយ បើដូច្នោះគឺមានព្រាហ្មណ៍'។

២១៣- ពួកគេ(ក៏)ហៅអ្នកមានកំណើតពីរដងមុនគេ ថាជាទេវតាដើមនៃពិធីយញ្ញ ដែលគ្មានកំហឹង ពិតជាពេញចិត្តទទួលការឧទ្ទិសនេះ ហើយធ្វើឱ្យអ្នកទាំងឡាយរុងរឿង។

២១៤- បន្ទាប់ពីបានធ្វើការ (បូជា) ព្រះភ្លើង (និង) ដំណើរការពិធីទាំងមូលតាមរបៀបមួយដែលពួកគេអាចបញ្ចប់នៅទិសខាងត្បូង ចូរអ្នករលាស់ទឹកដោយដៃស្តាំរបស់ខ្លួនទៅលើកន្លែង(ដាក់នំ ចំណី)។

២១៥- ប៉ុន្តែបន្ទាប់ពីបានយកនំបីចេញពីអាហារបុណ្យដែលសល់នោះ អ្នកត្រូវដាក់វាលើ(ស្មៅកុសៈ) ដោយផ្តោតអារម្មណ៍របស់ខ្លួន បែរទៅទិសទក្សិណ តាមរបៀបដូចគ្នាដែល(អ្នកបូជា)ទឹកដែរ។

២១៦- បន្ទាប់ពីបានបូជានំទាំងនោះស្របតាមតម្រាបញ្ញត្តិដោយចិត្តបរិសុទ្ធ ចូរអ្នកជូតសំអាតដៃ ដដែលនោះជាមួយនឹង (គល់)ស្មៅកុសៈ ដើម្បី (បុព្វបុរសបីជំនាន់) ដែលទទួលយករបស់សំអាតនោះ(*លេបៈ*)។

២១៧- បន្ទាប់ពីបានក្រេបទឹកបែរមួយជុំ(ទៅទិសខាងជើង)ហើយទប់ដង្ហើមយឺតៗចំនួនបីដង(អ្នកបូជាយញ្ញ) ដែលចេះពាក្យពិសិដ្ឋ គួរគោរពដល់(ទេវតាថែរក្សានានា)រដូវកាលទាំងប្រាំមួយ និងព្រលឹងដូនតា។

---

**២១១.** រ៊ី. ជំពូក៧៣ លេខ១២; ពោធ. ជំពូក២ លេខ១៤, ៧។

**២១២.** អាស្វលាយន គួហ្យ-សូត្រ ជំពូក៤ លេខ៨, ៥-៦។ ករណីដែលត្រូវការភ្លើងពិសិដ្ឋចាំបាច់ គឺករណីក្មេង បុរសមិនទាន់រៀបការ ឬអ្នកមេម៉ាយធ្វើពិធីស្រាទ្ធៈ (មេធ., កុល្ល., នារ.)។

**២១៣.** កម្មវត្ថុកាព្យនេះចង់បង្ហាញពីមូលហេតុ ដែលគេអាចដាក់តង្វាយបូជាទៅក្នុងដៃរបស់ភ្ញៀវបាន។ គុណស័ព្ទ 'ដើម' ត្រូវបានបកស្រាយសំដៅ 'ដែលបានកើតក្នុងកល្ប នៅពេលមានការប្រារព្ធពិធីស្រាទ្ធៈ'(មេធ.) ឬ 'អ្នកទាំងឡាយដែលបន្តសន្តានឥតដាច់ ចាប់តាំងពីពេលយូរលង់មកហើយ'(គោវ., កុល្ល., រាឃ.) ឬ 'អ្នកទាំងឡាយដែលបានកើត មនុវណ្ណៈដទៃទាំងអស់'(នារ.) ឬ 'អ្នកទាំងឡាយដែលទទួលអំណោយមុនអ្នកដទៃ'(រាឃ.)។ ប៉ុន្តែលោកមេធ. ចូលចិត្តពាក្យ *បុរាតនៈ* 'តាំងពីយូរលង់' ហើយការប្រែនេះទំនងជាមាននៅក្នុងអត្ថបទរបស់នន្ទ.ដែរ។

**២១៤.** 'ដំណើរការពិធីទាំងមូល' គឺចាប់ពី 'ការស្រោចទឹក និងការរាយស្មៅកុសៈជុំវិញភ្លើងជាដើម ដែលជួយដល់ការបូជាភ្លើង'។ ពាក្យ *អបសវ្យំ* 'តាមរបៀបមួយដែលពួកគេអាចចប់នៅទិសខាងត្បូង'(ទក្សិណាសំស្ថំ) ហើយតាមនារ. ថា *ប្រាកីនាវីតេន* 'ដោយដាក់ខ្សែយញ្ញកាត់ស្មាខាងស្តាំ និងក្រោមដៃឆ្វេង'។ ពាក្យ *អបសវ្យេន ហស្តេន* 'ដោយដៃស្តាំ របស់គាត់' (មេធ., កុល្ល., រាឃ. និងអ្នកដទៃ) ហើយតាមមេធ., គោវ., នារ. និងនន្ទ. 'ចេញពី*តីរថ* នៃដៃស្តាំ ដែលសម្រាប់បូជាព្រលឹងបុព្វបុរស' (សូមមើលជំពូក២ លេខ៥៩ខាងលើ)។

**២១៦.** បុព្វបុរសបីនៅទីនេះ គឺតាទួត ឪពុកនិងជីតារបស់គាត់, សូមមើលរ៊ី. ជំពូក៧៣ លេខ២២។

**២១៧.** ពាក្យដែលត្រូវថ្លែងគឺ 'និទាឃរដូវជាទីគោរព! ជាដើម' ហើយតមកទៀត'សូមគោរពដល់អស់លោក ឱវិញ្ញាណក្ខន្ធបុព្វបុរសទាំងឡាយ'។ មុននឹងសូត្រពាក្យចុងក្រោយ អ្នកបូជាត្រូវបង្វិលខ្លួនបែរទៅខាងត្បូង។

២១៨- ចូរអ្នកចាក់ទឹកដែលនៅសល់ថ្នមៗ នៅក្បែរនំ និងដោយផ្ចង់អារម្មណ៍ ហិតក្លិននំទាំងនោះ តាមលំដាប់របស់វានៅលើ(ដី)។

២១៩- ប៉ុន្តែដោយយកនំមួយចំណែកតូចជាបន្តបន្ទាប់ អ្នកគួរផ្តល់នំនោះទៅឱ្យព្រាហ្មណ៍ ដែលកំពុងអង្គុយទទួលទាន ស្របតាមវិធាន នៅមុនពេល(អាហារល្ងាចរបស់ពួកគេ)។

២២០- ប៉ុន្តែប្រសិនបើឪពុក(របស់អ្នកបូជាយញ្ញ)នៅមានជីវិត អ្នកត្រូវតែបូជា(នំ)ជូន(បុព្វបុរស) សែឆ្ងាយចំនួនបី ឬអ្នកក៏អាចផ្តល់អាហារដល់ឪពុកខ្លួននៅក្នុងពិធីយញ្ញ ដូចជាភ្ញៀវព្រាហ្មណ៍ (ម្នាក់ដែរ)។

២២១- ប៉ុន្តែអ្នកដែលមានឪពុកខ្លួនស្លាប់ទៅហើយតែជីតារបស់ខ្លួននៅមានជីវិត គួរបន្ទាប់ពីប្រកាសឈ្មោះឪពុកខ្លួនហើយ បញ្ជាក់ពី(ឈ្មោះរបស់)ជីតាទួតរបស់ខ្លួន។

២២២- មនុ បានប្រកាសថា ជីតាអាចទទួលទានអាហារបុណ្យស្រាទ្ធៈ (ក្នុងនាមជាភ្ញៀវ)ក៏បាន ឬ (ចៅប្រុស) ដោយបានទទួលការអនុញ្ញាត អាចធ្វើពិធីតាមចំណង់របស់ខ្លួនក៏បាន។

២២៣- ក្រោយពីបានចាក់ទឹកលាយនឹងល្ង ដែលមាននៅលើកម្រាស្មៅកុសៈ ទៅក្នុងដៃរបស់(ភ្ញៀវ)រួច អ្នកគួរជូនភ្ញៀវម្នាក់នូវចំណែកនំ(ដែលបាននិយាយខាងលើ) ដោយនិយាយថា 'សូមជូនស្វធា ទាំងឡាយ!'។

២២៤- ប៉ុន្តែដោយកាន់(ភាជន៍) ដែលដាក់អាហារ ដោយដៃទាំងពីរ (អ្នកបូជាយញ្ញ) គួរតែដាក់អាហារដោយផ្ទាល់ដោយរៀបរយនៅចំពោះមុខព្រាហ្មណ៍ ដែលកំពុងភាវនាដល់ព្រលឹងបុព្វបុរស។

២២៥- *អសុរៈ* ចិត្តអាក្រក់ កញ្ឆក់យកទាំងបង្ខំនូវអាហារ ដែលមិនកាន់ដោយដៃទាំងពីរនោះទៅ។

២២៦- ចូរតាំងចិត្តឱ្យបរិសុទ្ធ និងយកចិត្តទុកដាក់ទៅលើដី ដោយប្រុងប្រយ័ត្ននូវគ្រឿងអាហារ (សម្រាប់ហូបបាយ) ដូចជាទឹកស៊ុប និងគ្រឿងទេស ទឹកដោះគោផ្អែមនិងជូ និងទឹកឃ្មុំ។

២២៧- (ព្រមទាំងប្រភេទ)អាហាររឹងនានាដែលត្រូវកិនឱ្យម៉ត់ និងអាហារទន់ អាហារមើម ផ្លែឈើ សាច់ក្លិនឈ្ងុយ និងភេសជ្ជៈក្រអូប។

---

**២១៨.** វិ. ជំពូក៧៣ លេខ២៣។ 'ទឹកដែលនៅសល់' គឺ 'ដែលមាននៅក្នុងភាជន៍ សល់ពីការក្រឡាស់ទៅលើដី' (កាព្យ ២១៤)។

**២១៩.** 'ព្រាហ្មណ៍ដែលអង្គុយលើអាសនៈទាំងនោះ' គឺ 'អ្នកដែលគេបានអញ្ជើញសម្រាប់ពិធីបុណ្យឧទ្ទិសនោះ មិនជាអ្នកដែលគេបានអញ្ជើញសម្រាប់ពិធីពីមុន សម្រាប់ថ្វាយទេវតាទេ'។ 'យោងតាមវិធាន' គឺ 'ដោយជូនតំណាងរបស់ឪពុក នូវនំមួយដុំ សម្រាប់ឧទ្ទិសដល់ព្រលឹងឪពុកជាដើម' (កុល្លូ.) ឬ 'បន្ទាប់ពីពួកគេបានក្រេបទឹកហើយជាដើម'(នារ.)។ នន្ទ. ដាក់បញ្ចូលកាព្យ២២៣ ត្រង់ចំណុចនេះ ហើយបញ្ជាក់ថា វាជាពាក្យពន្យល់ 'ស្របតាមវិធាន'។

**២២០.** វិ. ជំពូក៧៥ លេខ១, ៤។ នារ. បន្ថែមថា ករណីនេះកើតឡើងនៅពេលកូនប្រុសបានបង្កាត់ភ្លើងពិសិដ្ឋ ក្នុងកំលុងពេលឪពុកខ្លួននៅមានជីវិត ពីព្រោះពេលនោះគេត្រូវធ្វើពិធី *បិណ្ឌបិត្ឫយញ្ញ* ហើយបន្ទាប់មកធ្វើពិធី *បារវណ ស្រាទ្ធៈ*។

**២២១-២២២.** វិ. ជំពូក៧៥ លេខ៦។

**២២៣.** វិ. ជំពូក៧៣ លេខ២៣។ វិធាននេះ ជាការបន្ថែមទៅលើកាព្យលេខ២២០។ ជំនួសឱ្យពាក្យសព្វនាម គេត្រូវប្រើ ព្រលឹង (មេធ., គោវ.)។

**២២៥.** វស. ជំពូក១១ លេខ២៥; ពោធ. ជំពូក២ លេខ១៥, ៣។

២២៨- ទាំងអស់នេះ អ្នកគួរជូន(ភ្ញៀវរបស់ខ្លួន) ហើយដោយចិត្តបរិសុទ្ធ និងយកចិត្តទុកដាក់អញ្ជើញ ពួកគេជាបន្តបន្ទាប់ ដើម្បីទទួលទាន(អាហារ)មួយមុខៗ ដោយប្រកាសប្រាប់អំពីគុណសម្បត្តិ របស់អាហារនោះផង។

២២៩- ចូរអ្នកកុំសម្រក់ទឹកភ្នែក ខឹងសម្បារ ឬនិយាយពាក្យមិនពិត ហើយកុំឱ្យយកជើងទៅប៉ះម្ហូប និង កុំធ្វើឱ្យរង្គើខ្លាំង។

២៣០- ទឹកភ្នែកបញ្ជូន (អាហារ) ទៅប្រេត, កំហឹងឱ្យទៅសត្រូវខ្លួន, ពាក្យកុហកឱ្យទៅឆ្កែ, អាហារប៉ះ ជើងឱ្យទៅរក្សសៈ, ការធ្វើឱ្យរង្គើឱ្យទៅអ្នកធ្វើអំពើបាប។

២៣១- ធ្វើអ្វីក៏ដោយឱ្យតែអាចធ្វើឱ្យព្រាហ្មណ៍សប្បាយ ចូរអ្នកធ្វើទានកុំឱ្យមានចិត្តគំគួន ហើយចូរអ្នកចេះដាក់ប្រស្នាវេទ ព្រោះប្រស្នានោះត្រូវចិត្តចំពោះព្រលឹងបុព្វបុរស។

២៣២- នៅពេល(ធ្វើពិធី)ឧទ្ទិសវិញ្ញាណក្ខន្ធ អ្នកត្រូវតែឱ្យ(ភ្ញៀវរបស់ខ្លួន)ស្តាប់ព្រះវេទ គោលការណ៍ច្បាប់ពិសិដ្ឋ រឿងព្រេង រឿងនិទាន រឿងបុរាណ និងរឿងខិលៈ។

២៣៣- ដោយធ្វើខ្លួនឱ្យសប្បាយ ចូរអ្នកផ្តល់ការសប្បាយរីករាយដល់ពួកព្រាហ្មណ៍ ធ្វើឱ្យគេទទួលទានសន្សឹមៗ និងយឺតៗ(នូវមុខអាហារនីមួយៗ) ហើយអញ្ជើញ(ពួកគាត់ឲ្យទទួលទាន)ជារឿយៗ ដោយ(ជូន)អាហារ និង(សរសើរ)ពីគុណភាពអាហារផង។

២៣៤- នៅក្នុងពិធីយញ្ញ ចូរអ្នកទទួលបុត្ររបស់កូនស្រី ទោះបីគេជាកូនសិស្សក្តី ហើយចូរអ្នកដាក់កម្រាលនេប៉ាល់គ្របលើកៅអី(របស់ភ្ញៀវម្នាក់ៗ) ដោយបាចគ្រាប់ល្ងទៅលើដី។

២៣៥- វិធីឧទ្ទិសមានបីយ៉ាង(ដែលត្រូវប្រើ)នៅក្នុងពិធីស្រាទ្ធៈ បុត្ររបស់កូនស្រីមួយ កម្រាលនេប៉ាល់មួយនិង គ្រាប់ល្ង ហើយពួកគេស្នើធ្វើ(បញ្ញា)បីយ៉ាងទៀតសម្រាប់ពិធី គឺភាពស្ងប់ស្ងាត់ការទប់កំហឹង និងកុំ រហាល់ពេក។

---

**២២៩.** វិ. ជំពូក៧៩ លេខ១៩-២១; ជំពូក៨១ លេខ១; យញ្ញ. ជំពូក១ លេខ២៣៩។ លោកមេធ. បកស្រាយ*អត្វរេន* `និងមិនធ្វើឱ្យវារង្គើខ្លាំង´ ហើយអ្នកផ្សេងថា `និងមិនយកខោអាវជូតធូលី´។ នន្ទ. ដាក់កាព្យ២៣០ បន្ទាប់ពីកាព្យ២២៨។
**២៣១.** យញ្ញ. ជំពូក១ លេខ២៣៩។ ពាក្យ *ព្រហ្មោទ្យា កថៈ* `ចូរឱ្យគេដោះប្រស្នាវេទ´ ដូចជាប្រស្នាទាំងឡាយ ដែលមាន ចងក្រងនៅក្នុងអាស្វលាយន ស្រោត-សូត្រ ជំពូក១០ លេខ៩, ២ (មេធ., នន្ទ.)។ មេធ. គិតថា ពាក្យ *ព្រហ្មោទ្យៈ* ក៏អាច សំដៅដល់រឿងរ៉ាវរបស់ព្រះវេទ ដូចជារឿងរ៉ាវចម្បាំងរវាងទេវៈ និងអសុរៈ ឬរឿងសរមានិងបណិៈ ហើយគាត់លើកឡើង ជម្រើសមួយទៀត *ព្រហ្មោទ្យៈ* `ការសន្ទនាអំពីព្រហ្មន ដួងព្រលឹង´។ ការបកស្រាយក្រោយនេះបានទទួលការគាំទ្រពីគោវ., កុល្ល., នារ. និងរាឃ. ទោះបីអត្ថបទគ្រប់កន្លែងសរសេរ *ព្រហ្មោទ្យៈ* ក៏ដោយ។ ព្រោះថា ការដោះប្រស្នាព្រហ្មោទ្យ គឺជាការ កំសាន្តដ៏សប្បាយរបស់គ្រូអាចារ្យ ក្នុងពេលធ្វើពិធីយញ្ញដ៏នឿយហត់របស់ពួកគេ ប្រាកដណាស់ថាការបកស្រាយដែលមាន នៅក្នុងបកប្រែនេះ ជាការបកស្រាយដែលអាចទទួលយកបានតែមួយគត់។
**២៣២.** ពោធ. ជំពូក២ លេខ១៤, ៥; វិ. ជំពូក៧៣ លេខ១៦; យញ្ញ. ជំពូក១ លេខ២៣៩។ `ខិលៈ´ គឺ `សំណេរមុន ព្រះ វេទ ដូចជា*ស្រីសូក្ត*ជាដើម´។ `រឿងព្រេង*អាខ្យាន*និ ដូចជារឿង*សោបណៈ, មៃត្រាវរុណៈ*(មេធ., គោវ., កុល្ល., រាឃ.) ឬ `ដូចជាមាននៅក្នុងឯកសារ*ព្រាហ្មណៈ* (នារ.) ឬ `មរណភាពរបស់កំសៈ ជាដើម´(នន្ទ.)។
**២៣៥.** វស. ជំពូក១១ លេខ៣៥-៣៦។

២៣៦- អាហារទាំងអស់ត្រូវតែឱ្យក្តៅខ្លាំង ហើយ(ភ្ញៀវ)គួរទទួលទានដោយស្ងៀមស្ងាត់; (សូម្បី)ត្រូវម្ចាស់កម្ម វិធីបុណ្យអញ្ជើញក៏ដោយព្រាហ្មណ៍មិនគួរប្រកាសពីគុណភាពនៃអាហារបុណ្យ។

២៣៧- ដរាបណាអាហារនៅតែក្តៅ ដរាបណាភ្ញៀវទទួលទានដោយស្ងាត់ស្ងៀម ដរាបណាគេមិនបានប្រកាស គុណភាពអាហារ ដរាបនោះបុព្វបុរសទទួលសេពសោយ(សំណែន)។

២៣៨- អ្វីដែល(ភ្ញៀវ)បរិភោគ ដោយគ្របក្បាលរបស់ខ្លួន អ្វីដែលគេបរិភោគដោយបែរមុខទៅទិសខាងត្បូង អ្វី ដែលគេបរិភោគដោយពាក់ស្បែកជើងសង្រែក(របស់ខ្លួន) នោះជារបៀបបរិភោគ របស់ពួករាក្សសៈ។

២៣៩- កាណ្ឌាល ជ្រូកស្រុក មាន់គក ឆ្កែ ស្ត្រីមានរដូវ និងមនុស្សកម្រៀវ មិនត្រូវសម្លឹងមើល ព្រាហ្មណ៍ដែល កំពុងបរិភោគអាហារទេ។

២៤០- មួយណាក៏ដោយក្នុងចំណោមសត្វ មនុស្សទាំងអស់នេះ មើលឃើញការបូជាអគ្គី ការធ្វើទាន (ដ៏ ឧឡារិក) ការទទួលទានអាហារល្ងាច (របស់ព្រាហ្មណ៍) ឬពិធីបុណ្យឧទ្ទិសដល់អាទិទេព និងព្រលឹង បុព្វបុរស នោះនឹងមិនផ្តល់ផលតាមប្រាថ្នាទេ។

២៤១- ជ្រូកព្រៃធ្វើឱ្យ(ពិធី)គ្មានន័យ ដោយការហិតក្លិន(តង្វាយនោះ), មាន់គក ដោយហើរ ឆ្កែ ដោយសម្លឹង មើល(ការបូជា), មនុស្សវណ្ណៈទាប ដោយប៉ះពាល់(តង្វាយបូជា)។

២៤២- ប្រសិនបើមនុស្សពិការ មនុស្សភ្នែកម្ខាង មនុស្សខ្វះអវយវៈ ឬអ្នកដែលមានម្រាមដៃជើងលើស សូម្បីជា អ្នកបម្រើរបស់អ្នកធ្វើ(ពិធីស្រាទ្ធៈ) គេក៏ត្រូវឱ្យចេញពីកន្លែង(ធ្វើពិធីស្រាទ្ធៈ)នោះ។

២៤៣- គេអាច ដោយបានការអនុញ្ញាតពីព្រាហ្មណ៍ (ជាភ្ញៀវរបស់ខ្លួន) សម្តែងនូវការគោរពតាមលទ្ធភាពរបស់ ខ្លួន ជូនចំពោះព្រាហ្មណ៍(យាវាំស) ឬតាបស ដែលអញ្ជើញមកទទួលទានអាហារ។

២៤៤- ចូរគេលាយអាហារផ្សេងៗទាំងអស់ចូលគ្នា ប្រោះទឹកលើវា និងដាក់វាដោយពង្រាយនៅលើ(ស្មៅកុសៈ) ដាក់នៅលើដី នៅពីមុខ(ភ្ញៀវរបស់ខ្លួន) នៅពេលភ្ញៀវបានបញ្ចប់ការទទួលទានរបស់ពួកគេ។

---

**២៣៦.** រ៊ិ. ជំពូក៨១ លេខ១១, ២០។

**២៣៧.** រ៊ិ. ជំពូក៨១ លេខ២០; វស. ជំពូក១១ លេខ៣២។

**២៣៨.** រ៊ិ. ជំពូក៨១ លេខ១២-១៤។

**២៣៩.** អាប. ជំពូក២ លេខ១៧, ២០; គោត. ជំពូក១៥ លេខ២៤។

**២៤១.** 'មនុស្សវណ្ណៈទាប' គឺសំដៅដល់ 'ពួកសូទ្រៈ'។

**២៤២.** រ៊ិ. ជំពូក៨១ លេខ១៥-១៦។ យោងតាមលោកមេធ., គោវ. និងកុល្លុ. ពាក្យ *អបិ* 'សូម្បី' បញ្ជាក់ថា អ្នកផ្សេងតួយ៉ាងពួកសូទ្រៈ ក៏ត្រូវឱ្យចេញពីពិធីដែរ។

**២៤៣.** រ៊ិ. ជំពូក៨១ លេខ១៨។ មេធ., គោវ. និងកុល្លុ. ប្រែពាក្យទីមួយផ្សេងថា 'ជូនចំពោះព្រាហ្មណ៍ ដែលអញ្ជើញមកក្នុងនាមជាភ្ញៀវ(អតិថិ) ឬស្ទួមដទៃទៀត'។ នារ. និងរាឃ. ធ្វើការបកស្រាយដូចខាងលើដែរ។

**២៤៤.** រ៊ិ. ជំពូក៨១ លេខ២១។

២៤៥- អាហារនៅសល់(ក្នុងចាន) និងមួយចំណែកដែលពង្រាយនៅលើស្មៅកុសៈ គួរជាចំណែករបស់(កូនចៅ)អ្នកស្លាប់ ដែលមិនទាន់បានទទួលពិធីឧទ្ទិស(បូជា) និងអ្នកដែលបានបោះបង់ភរិយាថ្លៃថ្នូរ(ដោយអយុត្តិធម៌)។

២៤៦- ពួកគេប្រកាសនូវចំណែកអាហារដែលបានដាក់នៅលើដី (ក្នុងពិធីស្រាទ្ធៈ) សម្រាប់ឧទ្ទិសព្រលឹងបុព្វបុរស ថាជាចំណែករបស់អ្នកបម្រើស្មោះត្រង់ យកចិត្តទុកដាក់ក្នុងកិច្ចការខ្លួន។

២៤៧- ប៉ុន្តែមុនពេលធ្វើពិធី *សាបិណ្ឌិករណៈ* គេត្រូវរៀបចំបាយទឹកក្នុងពិធីឧទ្ទិសវិញ្ញាណក្ខន្ធដល់អារ្យ៉ន (ព្រាហ្មណ៍) ដែលបានចែកឋាន (នាពេលថ្មីៗ) ដោយមិនបាន (ធ្វើពិធីថ្វាយអាទិទេព និងផ្តល់នំតែមួយប៉ុណ្ណោះ។

២៤៨- ប៉ុន្តែបន្ទាប់ពីបានធ្វើពិធីសាបិណ្ឌិករណៈ(ដល់ឪពុកដែលបានចែកឋានទៅ) ស្របតាមច្បាប់ ពិសិដ្ឋរួចកូននោះត្រូវផ្តល់នំក្នុងពិធីនោះ (ដូចបានរៀបរាប់ខាងលើ)។

២៤៩- មនុស្សល្ងង់ដែល បន្ទាប់ពីបានទទួលទាន(អាហារល្ងាច)បុណ្យស្រាទ្ធៈ ឱ្យរបស់សល់ទៅពួកសូទ្រៈ នឹងដាំក្បាលចុះនរក*កាលសូត្រ*។

២៥០- ប្រសិនបើអ្នកទទួលទាន(អាហារ)បុណ្យស្រាទ្ធនោះ នៅថ្ងៃជាមួយគ្នា ដេកជាមួយស្ត្រីសូទ្រៈ ព្រលឹង (ជូនតា)របស់គេ នឹងស្ថិតនៅក្នុងឧច្ចារៈរបស់នាងក្នុងមួយខែនោះ។

២៥១- ដោយបានសួរសំណួរថា 'តើលោកបានទទួលទានឆ្ងាញ់ពិសាទេ?'(ទៅកាន់ភ្ញៀវរបស់ខ្លួន) ចូរគេជូនទឹកផឹកដល់ភ្ញៀវដែលមានការពេញចិត្ត និងជូនដំណើរភ្ញៀវចេញបន្ទាប់ពីពួកគេបាន ផឹកទឹករួច (ដោយពាក្យថា) 'ស្នាក់នៅទីនេះក៏បាន ឬទៅផ្ទះក៏បាន!'។

---

**២៤៥.** វស. ជំពូក១១ លេខ២៣-២៤; រ៊ិ. ជំពូក៨១ លេខ២២។ បើនិយាយពីកិច្ចបញ្ចុះសពកូន សូមមើលជំពូក៥ លេខ៦៩ខាងក្រោម។ ត្យាគិនាំ កុលយោសិតាំ 'អ្នកដែលបោះបង់ប្រពន្ធដោយអយុត្តិធម៌' (មេធ., កុល្លុ.) ហើយតាមរាឃ. និងអ្នកដទៃ ក៏អាចមានន័យតាមការដកស្រង់របស់មេធ. និងកុល្លុ. ថា 'ដែលបានបោះបង់គុរុរបស់ខ្លួន និងស្រីក្រមុំដែល មិន

ទាន់រៀបការ'; យោងតាមគោវ.ថា 'ក្នុងចំណោមស្ត្រីដែលបោះបង់គ្រួសាររបស់ខ្លួន'; យោងតាមនារ. ថា 'នៃការធ្វើអត្ត ឃាត និងស្ត្រីគ្មានកូន'។ នន្ទ. បកស្រាយពាក្យទីមួយថា 'នៃតាបស'។

**២៤៦.** វិ. ជំពូក៨១ លេខ២៣។

**២៤៧.** វិ. ជំពូក២១ លេខ២-១២, ១៩; យញ្ញ. ជំពូក១ លេខ២៥០។ សាបិណ្ឌីករណៈ 'ពិធីទទួលដ៏ឧឡារិកដល់អ្នកស្លាប់ទៅ ក្នុងចំណោមអ្នកទទួលទានការបូជាយញ្ញ' ត្រូវបានធ្វើឡើងនៅថ្ងៃទី១៣ក៏បាន ឬមួយឆ្នាំបន្ទាប់ពីស្លាប់ក៏បាន។ យោងតាមពេលប្រារព្ធពិធី គេហៅស្រាទ្ធៈថាពិធី អេកោទទិស្ត 'ដែលគេធ្វើសម្រាប់បុគ្គលម្នាក់ប៉ុណ្ណោះ'។ មេធ., គោវ., នារ., នន្ទ. និង K. អានពាក្យដំបូងរបស់កាព្យនេះថា *អាបិណ្ឌក្រិយាកមៈ* ហើយយោងតាមអត្ថបទផ្សេង ការប្រែត្រូវតែថា 'ពិធីសម្រាប់មនុស្ស មិនមែនពិធី*សបិណ្ឌ*(គឺគេត្រូវតែពិធី*អេកោទទិស្ត ស្រាទ្ធៈ*សម្រាប់អារ្យ៉ន់ដែលស្លាប់ថ្មីៗ ហើយ(ក្នុងឱកាសនោះ គេត្រូវតែធ្វើ'។

**២៥០.** មេធ., គោវ., កុល្ល. និងរាឃ. ប្រែពាក្យ *វ្រ្ឫសលី*ថា 'ស្ត្រីសូទ្រៈ'(នារ.) ក្នុងន័យថា 'ស្ត្រីល្មោភកាម' (វ្រ្ឫសស្យន្តី)។

**២៥១.** យញ្ញ. ជំពូក១ លេខ២៤២; វិ. ជំពូក៧៣ លេខ២៦-២៧។ កុល្ល. អាន *អភិ ភោ រមតាំ* 'អូ ចូរសម្រាក់ចុះ!' ហើយរាឃ.ថា *អភិតោ គំយតាំ* 'សូមអញ្ជើញទៅកន្លែងណាតាមចិត្ត'។

២៥២- (ភ្ញៀវ)ព្រាហ្មណ៍ ពេលនោះគួរឆ្លើយទៅគាត់ថា 'ចូរ*ស្វធា* នៅទីនោះចុះ!' ព្រោះថានៅក្នុង ពិធីសាសនាសម្រាប់ឧទ្ទិសវិញ្ញាណក្ខន្ធ ពាក្យ *ស្វធា* ជាពាក្យជូនពរដ៏ខ្ពង់ខ្ពស់បំផុត។

២៥៣- បន្ទាប់មក ចូរគេជម្រាប(ភ្ញៀវរបស់ខ្លួន)ដែលបានទទួលទានអាហារ អំពីអាហារដែលនៅសល់ ហើយដោយមានការអនុញ្ញាតពីព្រាហ្មណ៍ ចូរគេចាត់ចែង (អាហារនោះ) តាមតែការបង្គាប់របស់ពួកគេ។

២៥៤- នៅក្នុង(ពិធីស្រាទ្ធៈ)ដើម្បីឧទ្ទិសវិញ្ញាណក្ខន្ធ គេត្រូវប្រើពាក្យ(សួរភ្ញៀវថា តើពួកគេរីករាយឬ ទេ)*ស្វទិតំ* ; នៅក្នុងពិធីគោស្ដី-ស្រាទ្ធៈ(ប្រើពាក្យ)*សុស្រុតំ*; នៅក្នុងពិធីវ្ឫទ្ធិ-ស្រាទ្ធៈ (ប្រើពាក្យ)*សំបន្នំ* និងនៅក្នុង(ពិធី)សែនទេវតា (ប្រើពាក្យ)*រុកិតំ*។

២៥៥- ថ្ងៃរសៀល ស្មៅកុសៈ ការរៀបចំកន្លែងស្នាក់នៅសមគួរ គ្រាប់ល្ង ចិត្តទូលាយ ការរៀបចំអាហារដោយយកចិត្តទុកដាក់ និង(ការទទួល)ព្រាហ្មណ៍ភ្ញៀវកិត្តិយស គឺជាទ្រព្យពិតប្រាកដនៅក្នុងពិធីបុណ្យឧទ្ទិសវិញ្ញាណក្ខន្ធ។

២៥៦- ចូរដឹងថា ស្មៅកុសៈ(ពាក្យ)បណ្ដោះគ្រោះ អាហារបុណ្យគ្រប់ប្រភេទសម្រាប់ពេលព្រឹក និងមធ្យោបាយទាំងអស់សម្រាប់លាងបាបដូចបានរៀបរាប់ខាងលើ គឺជាការប្រសិទ្ធិពរយញ្ញដល់ព្រះអាទិទេព។

២៥៧- គេហៅអាហារដែលតាបសទទួលទានក្នុងព្រៃ ទឹកដោះគោ ទឹកសោម សាច់ដែលគ្មានរសជាតិ ហិល (ម្ទេស)និងអំបិលដែលគ្មានការផ្សែផ្សំថាជាអាហារបុណ្យ តាមលក្ខណៈរបស់វា។

២៥៨- បន្ទាប់ពីបានឱ្យព្រាហ្មណ៍(ដែលបានអញ្ជើញមក)នោះត្រឡប់ទៅវិញ ចូរគេតាំងចិត្តតាំងកាយ ឱ្យស្ងប់ស្ងាត់ និងបរិសុទ្ធ សម្លឹងទៅទិសខាងត្បូង និងសុំពរជ័យពីព្រលឹងបុព្វបុរស ថា៖

២៥៩- 'សូមឱ្យយើងខ្ញុំជួបតែមនុស្សចិត្តល្អ! សូមឱ្យយើង(មានចំណេះដឹង)វេទ និងកូនចៅ(យើង) កាន់តែច្រើន! សូមកុំឱ្យយើងខ្ញុំបាត់បង់ជំនឿ! សូមឱ្យយើងខ្ញុំបានធ្វើទាន (ដល់អ្នកខ្វះខាត) ឱ្យបានច្រើន!'

---

**២៥២.** យញ្ញ. ជំពូក១ លេខ២៤៣។ មេធ., គោវ., នន្ទ.និងរាឃ. អាន *ស្វធេត្យេវៈ* (ពេលនោះគួរឆ្លើយទៅគាត់) 'ស្វាធា!'

**២៥៤.** 'គេត្រូវសួរ' ពោលគឺ 'អ្នករៀបចំពិធីបុណ្យ ឬអ្នកដទៃទៀតដែលអញ្ជើញមក' (មេធ., គោវ.) ហើយកុល្ល.ប្រកាន់យកការបកស្រាយមួយមុន។ មេធ. និងគោវ. បកស្រាយ *គោស្ថេ* 'នៅឯគោស្ដី-ស្រាទ្ធៈ'(កុល្ល., រាឃ.) ដោយថា 'នៅក្នុងក្រោលគោ' (គោសុ តិស្ថន្តីសុ, គោគណមធ្យេ) ហើយនារ.ថា គោស្ថេ គោមណ្ឌលាចំ គោស្ថេ ព្រាហ្មណភោគនេ។ អភ្យុទយ ឬ វ្ឫទ្ធិ-ស្រាទ្ធៈ ជាពិធីដែលគេធ្វើក្នុងឱកាសសប្បាយរីករាយ ដូចជាពិធីអាពាហ៍ពិពាហ៍។

**២៥៦.** ពាក្យ *បរិត្រំ* 'ពាក្យបណ្ដោះគ្រោះ' ហើយតាមលោកនារ.ថា 'មធ្យោបាយលាងបាបផ្សេងៗ ដូចជាស្រូវបាឡេ និងទឹក'។ នន្ទ. អាន *ទរកបរិត្រំ* 'ស្លឹមស្មៅកុសៈ'។ 'មធ្យោបាយលាងបាបទាំងឡាយដូចបានរៀបរាប់ខាងលើ' គឺ 'ការរៀបចំភេសជ្ជៈជាដើម'។ នន្ទ.អាន *ហវិស្យាណី ក សត្កិត:* 'អាហារពិធី(ដែលរៀបចំ)តាមលទ្ធភាពរបស់ខ្លួន'។
**២៥៧.** ពាក្យ *អនុបស្កូតំ* 'ដែលមិនបានលាយគ្រឿងហិល(ម្ទេស)'(គោវ., នារ.), តាមនន្ទ. ថា 'ដែលមិនតុបតែង ដូចមនុស្សធ្វើជាទូទៅ', តាមកុល្ល. និងរាឃ ថា 'ដែលមិនជាប់ក្លិនអាក្រក់' ហើយតាមមេធ. ថា 'ដែលមិនមានការហាមឃាត់ដូចជាសាច់បានពីសត្តឃាតដ្ឋាន'។ 'អំបិលដែលគ្មានការតុបតែង' ជា 'អំបិលបានពីក្នុងដី ឬអំបិលបានពីសមុទ្រ' (តែនារ. ថា មិនមែនជា *ពិណៈ* ទេ)។
**២៥៩.** យញ្ញ. ជំពូក១ លេខ២២៤៥; វិ. ជំពូក៧៣ លេខ២៨។

២៦០- ដូច្នេះបន្ទាប់ពីបានបូជា(នំ) និងក្រោយពី(អ្នកឧទ្ទិស)ចប់ ចូរអ្នកឱ្យមេគោ ព្រាហ្មណ៍ ពពែ ឬ អគ្គីពិសិដ្ឋ ទទួលស៊ីនំនោះ ឬចូរអ្នកបោះវាចូលទៅក្នុងក៏បាន។

២៦១- អ្នកខ្លះធ្វើការបូជានំ បន្ទាប់ពី(អាហារពេលល្ងាច) ហើយអ្នកខ្លះ ដាក់(នំ)ឱ្យសត្វស្លាបស៊ី ឬ បោះនំចូលក្នុងភ្លើង ឬចូលក្នុងទឹក។

២៦២- ភរិយាទីមួយ (របស់អ្នកឧទ្ទិស) ដែលមានចិត្តស្មោះ និង មានបំណងបូជាវិញ្ញាណក្ខន្ធអាចទទួលនំប្រហែលពាក់កណ្ដាល (ប្រសិនបើនាងប្រាថ្នា)ចង់បានកូនប្រុស។

២៦៣- (ដូច្នេះ)នាងនឹងបង្កើតបានកូនប្រុស ដែលមានអាយុវែង កេរ្តិ៍ឈ្មោះល្បី បញ្ញាវាងវៃ សម្បូរទ្រព្យ ជាឪពុកដែលមានកូនចៅច្រើនសម្បូណ៌ទៅដោយ(គុណសម្បត្តិ)ល្អ និងត្រឹមត្រូវ។

២៦៤- ដោយបានលាងដៃរបស់ខ្លួននិងក្រេបទឹករួច ចូរអ្នករៀបចំ(អាហារ)សម្រាប់ញាតិខាងឪពុករបស់ខ្លួន ហើយដោយផ្ដល់អាហារដល់ពួកគេដោយគោរពត្រឹមត្រូវ ចូរអ្នករៀបចំអាហារជូន ញាតិខាងម្ដាយរបស់ខ្លួនផងដែរ។

២៦៥- ប៉ុន្តែអាហារនៅសល់គួរទុក(នៅកន្លែងដដែល)រហូតដល់ព្រាហ្មណ៍អញ្ជើញចេញ ហើយបន្ទាប់មកអ្នកគួរធ្វើការបូជាពលិក្នុងផ្ទះ (រាល់ថ្ងៃ) នោះជា(តម្រាកំណត់តាម)ច្បាប់ពិសិដ្ឋ។

២៦៦- ឥឡូវ ខ្ញុំនឹងប្រកាសនូវប្រភេទអាហារបុណ្យបែបណា សម្រាប់បូជាវិញ្ញាណក្ខន្ធ ស្របតាមតម្រានឹងរៀបចំបានអស់កាលដ៏យូរ ឬរហូត។

២៦៧- បុព្វបុរសរបស់មនុស្សពេញចិត្តអស់រយៈពេលមួយខែចំពោះគ្រាប់ល្ង បាយ ស្រូវបាឡេសណ្ដែក *មាសៈ* ទឹក មើម និងផ្លែឈើ ដែលអាចបូជាបានស្របតាមតម្រាបញ្ញត្តិ,

២៦៨- ពីរខែចំពោះត្រី, បីខែចំពោះសាច់សត្វអំបូរប្រើស ចៀមបួន និងតាមពិតសាច់សត្វស្លាបប្រាំ,

២៦៩- ប្រាំមួយខែ ចំពោះសាច់កូនក្ដាន់, ប្រាំពីរខែចំពោះសាច់រមាំងស្បែកអុចៗ, ប្រាំបីខែចំពោះសាច់ប្រើសស្បែកខ្មៅ ហើយប្រាំបួនខែចំពោះសាច់(ក្ដាន់ដែលមានឈ្មោះថា)*//*,

---

**២៦០.** យញ្ញ. ជំពូក១ លេខ២៥៦, 'ដូច្នេះ' គឺដូចបានពណ៌នានៅក្នុងកាព្យលេខ២១៥។
**២៦១.** ពោធ. ជំពូក២ លេខ១៤, ៩។ យោងតាមសំណៅដៃ និងអត្ថបទបោះពុម្ព ពាក្យដែលប្រែស្របតាមការបកស្រាយច្បាស់លាស់របស់លោកមេធ., កុល្ល. និង K. និងតាមការតម្រូវនៃបរិបទថា 'បន្ទាប់(អាហារពេលល្ងាច)' គឺពាក្យ *បរស្តាត*។ ដោយហេតុថា *បរស្តាត* តែងតែមានន័យថា 'មុន' គឺទំនងជាថា ការអានពិតប្រាកដរបស់អ្នកអធិប្បាយបីនាក់ ដូចគ្នានឹងការបកស្រាយរបស់រាឃ. 'បរស្តាត' ដែលមានន័យស្របតាមការបកស្រាយរបស់ពួកគេទាំងស្រុង។ នារ. និងនន្ទ. អាន

ច្បាស់ថា *បរស្តាត* ហើយបកស្រាយថា *ប្រាក* គឺ ‘មុន’។ ក៏ប៉ុន្តែការឱ្យន័យនេះ គឺមិនល្អទេ ពីព្រោះវាមានន័យថា ទំនៀមទម្លាប់ដែលនិយាយនៅទីនេះ ពិតជាខុសគ្នាពីទម្លាប់ដែលបានរៀបរាប់ខាងលើ កាព្យលេខ២១៨។

**២៦៤.** គេត្រូវធ្វើបន្ទាប់គេបានធ្វើ និងរៀបចំទុកដាក់នំរួច(មេធ., នន្ទ.)។ មេធ., គោវ., នន្ទ. អាន *បូគយេត* ‘ចូរគេគោរព’ ជំនួយឱ្យឃ្លា ‘ចូរគេផ្តល់អាហារ’។

**២៦៧-២៧២.** អាប. ជំពូក២ លេខ១៦, ២៣-១៧, ៣; គោត. ជំពូក១៥ លេខ១៥; វិ. ជំពូក៨០; យញ្ញ. ជំពូក១ លេខ ២៥៧-២៥៩។

**២៦៩.** គោវ. បញ្ជាក់ថា សត្វ រុរុ គឺជាសំបរ ឬកូនសាំបះ។

២៧០- ដប់ខែ ពួកគេពេញចិត្តសាច់ជ្រូកព្រៃ និងក្របី ប៉ុន្តែដប់មួយខែ តាមពិតពេញចិត្តសាច់ទន្សាយ និងអណ្តើក,

២៧១- មួយឆ្នាំ ពេញចិត្តទឹកដោះគោនិងបាយទឹកដោះ ហើយការពេញចិត្តរបស់ពួកគេមានដល់ដប់ពីរ ឆ្នាំចំពោះសាច់ពពែឈ្មោលរោមសវែង។

២៧២- កាលសក:(គឺបន្លែ), មហាសល្ក:(ត្រី), សាច់រមាសនិងសាច់ពពែក្រហម និងអាហារគ្រប់ប្រភេទ ដែលឥសីទទួលទាន ផ្តល់ជូនបានរហូត។

២៧៣- (អាហារ)អ្វីក៏ដោយ ដែលលាយទឹកឃ្មុំ គេផ្តល់ជូនចំនួនដប់បីថ្ងៃ នៅថ្ងៃមានព្រះច័ន្ទ នៅរដូវវស្សាក្រោមដួងតារាមេឃា ដែលផ្តល់នូវ(ការពេញចិត្ត)រហូតដែរ។

២៧៤- ‘(ព្រលឹងនិយាយថា) សូមឱ្យមនុស្សបែបនេះចាប់កំណើតក្នុងគ្រួសាររបស់យើងដែលនឹងផ្តល់ឱ្យយើងនូវបាយទឹកដោះ លាយទឹកឃ្មុំ និងប៊ឺសុទ្ធ នៅថ្ងៃទីដប់បីនៃច័ន្ទគតិ (ខែ*ភទ្របទ*) និង (នៅពេលរសៀល) ពេលស្រមោលដំរីបែរទៅខាងកើត’។

២៧៥- (មនុស្ស)ណាក៏ដោយ ដែលពោរពេញជំនឿ ធ្វើពិធីឧទ្ទិសស្របតាមតម្រាបញ្ញត្តិ ដែលនៅក្នុង លោកដទៃ(ទទួលបានរង្វាន់ជាទីពេញចិត្ត)ជានិច្ច និងមិនចេះសាបសូន្យចំពោះវិញ្ញាណក្ខន្ធ។

២៧៦- ថ្ងៃក្នុងខែងងឹតពាក់កណ្តាល ចាប់ផ្តើមពីថ្ងៃទីដប់ ប៉ុន្តែលើកលែងថ្ងៃទីដប់បួន អាចធ្វើពិធីយញ្ញ ឧទ្ទិសកុសលបាន ដូច្នេះ(គឺ)មិនមានថ្ងៃដទៃទេ។

២៧៧- អ្នកដែលធ្វើពិធីយញ្ញនៅថ្ងៃគូ(ច័ន្ទគតិ) និងក្រោមដួងតារាគួរឱ្យគយគន់នឹងទទួលបានពរជ័យទាំងអស់របស់ខ្លួន អ្នកដែលបូជាព្រលឹងបុព្វបុរសនៅថ្ងៃសេស(ច័ន្ទគតិ) និងក្រោម (ដួងតារា) មិនល្អ នឹងបានកូនប្លែកពីគេ។

---

**២៧១.** នារ. បកស្រាយ *វាទ្រីណស:* ថា ‘សត្វស្លាបដែលមានស្លាបវែង-ស ក-ខ្មៅ ក្បាលក្រហម’ តែលោកមេធ., គោវ., កុល្លូ. និងរាឃ. ប្រកាសដោយផ្អែកលើប្រកពកាព្យ ថាជាពពែ-ស។ នារ. ដកស្រង់*និគម:* មួយទៀតដើម្បីគាំទ្រយោបល់របស់គាត់ សូមមើលអាប. ជំពូក២ លេខ១៧, ៣ ដែលសត្វក្រៀល គេឲ្យឈ្មោះ *វាទ្រាណស:*។

**២៧២.** ឈ្មោះមួយទៀតរបស់តិណទេស *កាលសាក:* គឺតាមលោកមេធ.ថា *ក្រិស្ណវាសុទេវ* ហើយតាមនន្ទ.ថា *ក្រិស្ណនិម្ព*។ ពាក្យ *មហាសល្ក* ជាបង្គា។ អ្នកខ្លះតាមការអះអាងរបស់មេធ. អាន *សសល្កាន*។

**២៧៣.** វិ. ជំពូក៧៦ លេខ១; យញ្ញ. ជំពូក១ លេខ២៦០។ ថ្ងៃនៅទីនេះ គឺ *ភទ្របទ ពទិ* ១៣។

**២៧៤.** វិ. ជំពូក៧៨ លេខ៥១-៥២; វស. ជំពូក១១ លេខ៤០។ លោកគោវ. លុបកាព្យនេះចោល។ លោកមេធ. និយាយថា ‘អ្នកដទៃ’ បកស្រាយមិនសូវទំនងចំពោះពាក្យ *ប្រាក្ច្ឆាយេ កុញ្ជរស្យ* ‘នៅពេលរសៀល ពេលស្រមោលដំរី ងាកទៅខាងកើត’(កុល្លូ., នារ., រាឃ.) ថា ‘អំឡុងពេលងងឹត’។ គាត់ក៏លើកឡើងនូវពាក្យ *ប្រាក្ឆ្វាំ*។ ប៉ុន្តែ ហាក់ដូចជាច្បាស់ណាស់ថា ការបកស្រាយរបស់គាត់និងអ្នកអធិប្បាយភាគច្រើន ជាការបកស្រាយត្រឹមត្រូវ។ ច្បាស់ជាងនេះទៅទៀតគឺថា ថ្ងៃជាក់លាក់

មួយ (សូមមើល វិញ្ញានេស្វរៈ នៅក្នុងតម្រាយញ្ញ. ជំពូក១ លេខ២១៧) មានការឱ្យន័យនេះ។ ការពិតថ្ងៃច័ន្ទគតិទីដប់បី ជាថ្ងៃទីដប់បី ជាថ្ងៃកទ្របទ ព្រះច័ន្ទងងឹតពាក់កណ្ដាល ជាថ្ងៃល្អសម្រាប់ពិធីមហាលយ-ស្រាទ្ធៈ។

**២៧៦.** អាប. ជំពូក២ លេខ១៧, ៦; គោត. ជំពូក១៥ លេខ៣; យញ្ញ. ជំពូក១ លេខ២៦៣; វស. ជំពូក១១ លេខ១៦។ ហេតុផលដែលលើកលែងថ្ងៃទីដប់បួន មានបញ្ជាក់នៅក្នុង វិ. ជំពូក៧៨ និងយញ្ញ. នៅចំណុចសម្រង់សេចក្ដី។

**២៧៧.** អាប.ជំពូក២ លេខ១៧, ៨-២២; គោត.ជំពូក១៥ លេខ៥; វិ.ជំពូក៧៨ លេខ៤៨-៤៩; យញ្ញ.ជំពូក១ លេខ២៦៧។

២៧៨- ដោយហេតុថាពាក់កណ្ដាលទីពីរក្នុងខែនោះ ប្រសើរជាងពាក់កណ្ដាលទីមួយ សូម្បីនៅពេលរសៀលក៏ល្អប្រសើរ(សម្រាប់ការធ្វើ)ពិធីឧទ្ទិសកុសល ជាងនៅមុនពេលរសៀល។

២៧៩- ចូរអ្នកកុំមានការនឿយហត់ក្នុងការធ្វើ(ពិធី)តាមសមគួរ ដើម្បីគោរពព្រលឹងបុព្វបុរសស្របតាមតម្រាបញ្ញត្តិ ដោយដាក់អំបោះពិសិដ្ឋឆ្លងតាមស្មាខាងស្ដាំ ដោយចាប់ពីឆ្វេងទៅស្ដាំ (និង) ដោយកាន់ស្មៅកុសៈនៅក្នុងដៃខ្លួន រហូតដល់ចប់(ពិធីនោះ)។

២៨០- ចូរអ្នកកុំធ្វើពិធីឧទ្ទិសកុសលនៅពេលយប់ ព្រោះពេល(រាត្រី) ត្រូវគេចាត់ទុកជាពេលសម្រាប់ពួករាក្សសៈ និងកុំធ្វើនៅពេលព្រះអាទិត្យអស្ដង្គត និងកុំធ្វើនៅពេលព្រះអាទិត្យទើបនឹងរះ។

២៨១- ចូរអ្នកនៅពេលនេះបូជាអាហារបុណ្យខាងក្រោម ស្របតាមតម្រាបញ្ញត្តិខាងលើ (យ៉ាងហោចណាស់) បីដងក្នុងមួយឆ្នាំ នៅរដូវរងា រដូវក្ដៅ និងរដូវវស្សា ប៉ុន្តែនៅពេលនោះត្រូវមានមហា បូជាប្រាំ រាល់ថ្ងៃ។

២៨២- ការបូជាអគ្គីឧទ្ទិសដល់ព្រលឹងបុព្វបុរស មិនត្រូវធ្វើនៅក្នុងចង្ក្រានធម្មតាទេ ហើយព្រាហ្មណ៍ដែលរក្សាព្រះអគ្គីពិសិដ្ឋ មិន(គួរធ្វើ)ពិធីឧទ្ទិសទេ លើកតែនៅថ្ងៃព្រះច័ន្ទខាងខ្នើតម្ដងទៀត។

២៨៣- សូម្បីនៅពេលព្រាហ្មណ៍បន្ទាប់ពីងូតទឹករួច ផ្ដល់ទឹកបំពេញចិត្តព្រលឹងដូនតា នោះអ្នកនឹងទទួលបានផលទាំងស្រុងចំពោះការធ្វើពិធីស្រាទ្ធៈ(ប្រចាំថ្ងៃ)។

២៨៤- ពួកគេអញ្ជើញ(ព្រលឹង)ឪពុក *វសុ* (ព្រលឹង)ជីតា *រុទ្រ* និង(ព្រលឹង)តាទួត *អាទិត្យ* ដូច្នេះ (ចូរនិយាយថា)ព្រះវេទអមតៈ។

២៨៥- ចូរអ្នករាល់ថ្ងៃចូលរួមទទួល*វិឃស* និងទទួលទានអាហារអម្រិត (អាហារទិព្វ)ប៉ុន្តែ *វិឃស* គឺជាអាហារដែលសល់ពី(ភ្ញៀវព្រាហ្មណ៍) និងអាហារសល់ពីបុណ្យ (គេហៅ) អម្រិត។

២៨៦- ដូច្នេះ បញ្ញត្តិទាំងអស់ពាក់ព័ន្ធនឹង(មហា)ពិធីប្រាំប្រចាំថ្ងៃ ត្រូវបានប្រកាសដល់អ្នក ឥឡូវចូ ស្ដាប់បញ្ញត្តិសម្រាប់ការប្រតិបត្តិក្នុងជីវភាពរស់នៅ ឱ្យសមជាព្រាហ្មណ៍។

---

ខ្ញុំអានតាមលោកមេធ., គោវ., នន្ទ., រាឃ. និង K. បិត្រីនាក័ន ដែលពិនិត្យតាមការអធិប្បាយក៏ជាអំណានរបស់ កុល្ល.ដែរ ជំនួសពាក្យដែលគ្មានន័យ *ប្រិត្រីន សាំន* នៅក្នុងអត្ថបទបោះពុម្ព។ នន្ទ.បន្ថែមកាព្យប្រាំ និងពាក់កណ្ដាលដែលបញ្ជាក់ការ លម្អិតស្របតាមរង្វាន់ដែលទទួលបានក្នុងការធ្វើពិធីស្រាទ្ធៈ នៅថ្ងៃច័ន្ទគតិពិសេស។ វាគឺជាការថែមថយឱ្យមានន័យកាន់តែច្បាស់។

**២៧៨.** អាប. ជំពូក២ លេខ១៧, ៥។

**២៧៩.** គោវ., កុល្ល. និងរាឃ. បកស្រាយ *អបសវ្យំ* 'ដោយចាប់ផ្ដើមពីឆ្វេងទៅស្ដាំ'(នារ.) ថា 'ដោយខាងដៃ*តីថ៌*ដែលគួរគោរពដល់វិញ្ញាណក្ខន្ធ'។ មេធ. និងគោវ. គិតថា *និធនាត*រហូតដល់ចប់(ពិធីនោះ)'(កុល្ល., នារ., នន្ទ., រាឃ.) ថា 'រហូតដល់ស្លាប់'។

**២៨០.** អាប. ជំពូក២ លេខ១៧, ២៣។ **២៨៤.** យញ្ញ. ជំពូក១ លេខ២៦៨។

**២៨៥.** មេធ. និងនារ. ទំនងជាអាន *ភ្រិត្យសេសំ* 'អ្វីដែលនៅសល់ពីអ្នកបរិភោគ'។ អ្នកមុន ក៏លើកឡើងនូវអំណានអ្នកដទៃដែរ។

# ជំពូក ៤

១- បន្ទាប់ពីបានស្នាក់នៅជាមួយគ្រូក្នុងអំឡុងពេលមួយភាគបួននៃ (ជីវិតមនុស្ស) ព្រាហ្មណ៍គួររស់នៅមួយភាគបួនទីពីរ(នៃជីវិតខ្លួន)នៅក្នុងផ្ទះខ្លួន ក្រោយពីខ្លួនបានរៀបការភរិយា។

២- ព្រាហ្មណ៍ត្រូវតែស្វែងរកមធ្យោបាយចិញ្ចឹមជីវិត ដែលមិនបង្កការឈឺចាប់ ឬយ៉ាងហោចណាស់បង្កការឈឺចាប់តិចតួច(ដល់អ្នកដទៃ) និងរស់នៅតាម(របៀបនោះ) លើកលែងក្នុងគ្រាអាសន្ន។

៣- ក្នុងបំណងដើម្បីការចិញ្ចឹមជីវិតសុទ្ធសាធ ចូរអ្នកខិតខំបង្កើនទ្រព្យ ដោយការប្រកបមុខរបរគ្មានទោស (ដូចខាងក្រោម សម្រាប់វណ្ណៈរបស់ខ្លួន) ដោយមិនធ្វើឱ្យរូបកាយខ្លួនបាក់កម្លាំង(ហួស ហេតុ)។

៤- អ្នកអាចចិញ្ចឹមជីវិតដោយ*រីតៈ* (ភាពទៀងត្រង់) និង*អម្រិត* (អាហារឆ្ងាញ់) ឬដោយ*ម្រិតៈ* (មរណភាព) និងដោយ*ប្រម្រិតៈ* (អ្វីដែលនាំឱ្យជីវិតស្លាប់ច្រើន) ឬសូម្បីដោយ(ទម្រង់)ដែលហៅថា*សត្យានរីតៈ* (ភាពលាយឡំភាពទៀងត្រង់ និងបោកប្រាស់) ប៉ុន្តែមិនដែលចិញ្ចឹមជីវិតដោយ*ស្វាវ្រិត្តិ* (ទម្រង់ជីវិតសត្វសុនខ) ទេ។

៥- ដោយ *រីតៈ* គេនឹងយល់ត្រឹមតែការបេះពោត, ដោយ *អម្រិត* ជាអ្វីដែលគេឲ្យដោយមិនបាច់សួរ, ដោយ *ម្រិតៈ* ជាអាហារដែលបានពីការដើរសុំ និងការធ្វើកសិកម្ម ត្រូវគេចាត់ទុកថា *ប្រម្រិតៈ*។

៦- ប៉ុន្តែការជួញដូរ និង(ការឱ្យខ្ចីលុយ) គឺជា*សត្យានរីតៈ* សូម្បីតែវិធីនោះគេអាចចិញ្ចឹមជីវិតបានក៏ដោយ។ គេហៅការបម្រើថា *ស្វាវ្រិត្តិ* ដូចនេះគេគួរជៀសវាងការងារនេះ។

៧- គេអាចប្រមូលដាក់ជង្រុកគ្រប់គ្រាន់ក៏បាន ឬស្តុកក្នុងពាងគ្រាប់ធញ្ញជាតិក៏បាន ឬគេអាចប្រមូលអ្វីៗទុកសម្រាប់រយៈពេលបីថ្ងៃក៏បាន ឬមិនចាំបាច់ទុកបម្រុងសម្រាប់ថ្ងៃស្អែកក៏បាន។

---

ជំពូក៤ **លេខ ២.** មេធ., គោវ., កុល្លូ., នារ. និងរាឃ. អះអាងយ៉ាងច្បាស់ថា *ទ្រោហៈ* និង *អទ្រោហៈ* មិនស្មើនឹងពាក្យ *ហឹសា* (ហិង្សា) និង *អហឹសា* (អហិង្សា)ទេ ព្រោះ 'ការបង្កប្បួសស្នាមដល់សត្វមានជីវិត' ត្រូវបានហាមឃាត់ ទោះក្នុងកាលទេសៈណាក៏ដោយ។ អ្វី ដែលជាអត្ថន័យរបស់*ទ្រោហៈ* គឺជាការបង្កការឈឺចាប់ដល់អ្នកដទៃ ដោយការរុកគួនរំខាន។ ដូច្នេះ ការឱ្យន័យរបស់មនុ គឺថា យរាវាស(អ្នកគ្រប់គ្រងផ្ទះ) គួរ ប្រសិនជាអាចធ្វើបាន កុំចិញ្ចឹមជីវិតដោយការដើរសុំទាន ប៉ុន្តែអាចបេះពោតបាន។ យ៉ាងណាមិញ នន្ទ. បកស្រាយពាក្យ *ទ្រោហៈ* ដោយ*ហឹសា* ហើយកាព្យខាងក្រោម ជាការគាំទ្រយោបល់របស់គាត់។

**៣.** 'ដោយបំណងត្រឹមការចិញ្ចឹមជីវិតសុទ្ធសាធ ប៉ុន្តែមិនមែនដើម្បីផ្គត់ផ្គង់ការសប្បាយហួសហេតុសម្រាប់ខ្លួនឯងទេ'។

**៧.** យញ្ញ. ជំពូក១ លេខ១២៨។ អនុប្រយោគពីរដំបូង ត្រូវបានគេប្រែផ្សេងគ្នា។ ទីមួយ តាមលោកមេធ. ថា 'គេអាចស្តុកទុកគ្រាប់ធញ្ញជាតិ ឬទ្រព្យផ្សេងទៀត គ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារធំមួយ មានអ្នកបម្រើច្រើន និងសត្វ ក្នុងអំឡុងពេលបីឆ្នាំបាន', យោងតាមលោកគោវ. ថា 'ការស្តុកទុកធញ្ញជាតិគ្រប់សម្រាប់ដប់ពីថ្ងៃ', តាមលោកកុល្លូ. និងរាឃ. ថា 'ការស្តុកទុកពេញពាង ដែលសម្រាប់ផ្គត់ផ្គង់រយៈពេលបីឆ្នាំ ឬលើសពីបីឆ្នាំ' ហើយតាមលោកនារ. ថា 'ការស្តុកទុកសម្រាប់មួយឆ្នាំប្រាំមួយខែ ឬបីខែ'។ អនុប្រយោគទីពីរ ត្រូវលោកមេធ.ប្រែថា 'ការស្តុកទុកសម្រាប់ប្រាំមួយខែ', លោកគោវ. និងនារ. ថា

៨- ជាងនេះទៅទៀត ក្នុងចំណោមយរាវាសព្រាហ្មណ៍ទាំងបួននោះ ព្រាហ្មណ៍(ដែលមានឈ្មោះក្រោយគេ) ត្រូវគេចាត់ថាចំណានជាងគេ ហើយដោយគុណធម៌របស់គាត់នឹងទទួលបានជោគជ័យនៅលើលោកនេះកាន់តែច្រើន។

៩- មុខរបរមួយក្នុងចំណោមមុខរបរប្រាំមួយខាងក្រោម ម្នាក់ចិញ្ចឹមជីវិតដោយរបរបីម្នាក់ទៀត ដោយរបរពីរ ប៉ុន្តែទីបួនរស់នៅដោយ*ព្រាហ្មសត្រ*។

១០- អ្នកដែលចិញ្ចឹមជីវិតខ្លួនដោយការបេះគ្រាប់ធញ្ញជាតិ និងផ្លែពោត ពិតជាចង់រស់នៅលើ(ការងារ) អគ្និហោត្រជានិច្ចនិងបូជា*ឥស្តិះ* ជាប្រចាំ តាមបញ្ញត្តិក្នុងថ្ងៃស្របគ្នា និងផ្ទុយគ្នា(ជាមួយព្រះច័ន្ទ) និងនៅថ្ងៃគោមផែនដី(ថ្ងៃវែងបំផុត ឬខ្លីបំផុត)។

១១- ចូរអ្នកកុំបណ្តែតបណ្តោយតាមលោកិយ, ដើម្បីតែការចិញ្ចឹមជីវិត ចូរអ្នករស់នៅក្នុងជីវិតបរិសុទ្ធស្មោះត្រង់ ដើរឆ្ពោះទៅមុខតាមមាគ៌ាព្រាហ្មណ៍។

១២- អ្នកដែលប្រាថ្នាសុភមង្គល ត្រូវតែព្យាយាមពេញទំហឹង តាមអធ្យាស្រ័យល្អទាំងស្រុង និងគ្រប់គ្រងខ្លួនឯង ព្រោះថាសុភមង្គលមានភាពត្រជាក់រីករាយនៅនឹងឫសរបស់វា ហើយឫសនៃអភមង្គល មានទំនោរផ្ទុយគ្នា។

១៣- ព្រាហ្មណ៍ ដែលជាស្នាតកៈ និងចិញ្ចឹមជីវិតដោយទម្រង់ជីវិតណាមួយ(ដូចបានរៀបរាប់ខាងលើ) ត្រូវតែបំពេញភារកិច្ច(ខាងក្រោម) ដែលនឹងបានពរជ័យឋានសួគ៌ អាយុយឺនយូរ និងកេរ្តិ៍ឈ្មោះ។

---

'ការស្តុកសម្រាប់ពេលប្រាំមួយថ្ងៃ' ហើយលោកកុល្ល. និងរាឃ. ថា 'ការទុកគ្រប់សម្រាប់ពេលមួយឆ្នាំ'។ ចំពោះការបកស្រាយពាក្យផ្សេងទៀត *កុម្ភិធាន្យ* សូមមើលពោធ. (ចំណុចកំណត់សម្គាល់)ជំពូក១ លេខ១, ៥។ នន្ទ. អាន *ឡ្យហែហិកៈ* 'ឬគេអាចប្រមូលទុកអ្វីៗ សម្រាប់រយៈពេលពីរថ្ងៃបាន'។

**៩.** 'មុខរបរប្រាំមួយ' គឺមាន 'ការប្រមូលផលពោត, ការទទួលអំណោយដែលគេឱ្យដោយមិនបាច់សុំ, ការដើរសុំ, ការងារកសិកម្ម, ការជួញដូរ និងការបង្រៀន'(មេធ.) ឬ 'ការងារទាំងឡាយដែលបានរៀបរាប់នៅក្នុងកាព្យលេខ៥-៦'(គោវ.) ឬ 'ការងារដែលបានរៀបរាប់នៅក្នុងកាព្យលេខ ៥-៦ លើកលែងតែការបម្រើ និងការយកចំណេញពីការឱ្យលុយគេខ្ចី'(កុល្ល., រាឃ.) ឬ 'ការងារទាំងឡាយដែលបានរៀបរាប់នៅក្នុងកាព្យលេខ៥-៦ និងការងារទាំងប្រាំមួយ ដែលមានរៀបរាប់ខាងលើជំពូក១ លេខ៨៨'(នារ.), ឬ 'ការងារទាំងឡាយដែលបានរៀបរាប់ខាងលើជំពូក១ លេខ៨៨'(នន្ទ.)។ 'ចិញ្ចឹមជីវិតដោយមុខរបរបី' គឺ 'ដោយមុខរបរបីដំបូង ដែលបានរៀបរាប់នៅក្នុងកាព្យលេខ៥-៦'(មេធ.) ឬ 'ដោយការបង្រៀន ការបូជាយញ្ញ និងការទទួលអំណោយពីអ្នកដទៃ'(គោវ., កុល្ល., រាឃ., នន្ទ.), ឬ 'ដោយការបង្រៀន ការបូជាយញ្ញ និងការទទួលអំណោយ និងដោយមុខរបរបីដំបូង ដែលមាននិយាយក្នុងកាព្យលេខ៥-៦'(នារ.)។ 'ម្នាក់រស់ដោយមុខរបរពីរ' គឺ 'ដោយការប្រមូលផល និងការទទួលអំណោយស្ម័គ្រចិត្ត'(មេធ.), ឬ 'ដោយការបូជាយញ្ញ និងការបង្រៀន'(គោវ., កុល្ល., រាឃ., នន្ទ.), ឬ 'ដោយការបេះពោត និងធញ្ញជាតិណាមួយ'(នារ.)។ ពាក្យ '*ព្រាហ្មសត្រ*' គឺ 'ការប្រមូលផលពោត ឬធញ្ញជាតិណាមួយក៏បាន'(នារ.), ឬ 'ការបង្រៀន'(គោវ., កុល្ល., រាឃ., នន្ទ.)។ នៅកន្លែងណាដែលមានប្រើពាក្យ *ព្រាហ្មសត្រ* សំដៅដល់ការសូត្រធម៌វេទប្រចាំថ្ងៃ ហើយនៅទីនេះ ទំនងជាមានន័យថា 'ការបង្រៀន'។

**១០.** អគ្និហោត្រ ជាការបូជាប្រចាំថ្ងៃនៅពេលព្រឹក និងពេលល្ងាច ដល់ព្រះអគ្គី ឬចង្ក្រានពិសិដ្ឋ។ យញ្ញដែលត្រូវរៀបចំ គឺ *ទរេ-បៅណមាសៈ* និង *អាគ្រយណៈ*។

**១១.** យញ្ញ. ជំពូក១ លេខ១២៣។

**១២-១៧.** យញ្ញ. ជំពូក១ លេខ១២៩។

**១៣.** នន្ទ. ដាក់កាព្យលេខ១៥ ជាប់ពីក្រោយកាព្យលេខ១២ ផ្ទាល់។ ចំពោះពាក្យ *ស្នាតកៈ* សូមមើលកាព្យ៣១ តម្រាអាប. ជំពូក១ លេខ៣០, ១-៣ ខាងក្រោម។

១៤- ចូរអ្នកកុំនឿយហត់ក្នុងការធ្វើពិធីសាសនា ដែលតម្រូវឱ្យអ្នកធ្វើតាមព្រះវេទ ព្រោះអ្នកដែលធ្វើពិធីទាំងនោះស្របតាមលទ្ធភាពរបស់ខ្លួន នឹងទទួលបានឋានៈខ្ពស់បំផុត។

១៥- ទោះបីជាអ្នកមានក្ដីឬស្ថិតក្នុងភាពអាសន្នក្ដី ចូរអ្នកកុំស្វែងរកទ្រព្យតាមផ្លូវពួកតារា កុំប្រកបរបរណាដែលគេហាមឃាត់ ហើយកុំ(ទទួលអំណោយ)ពី(អ្នកណាក៏ដោយ)។

១៦- ចូរអ្នកកុំបាត់បង់ចំណង់(សប្បាយរីករាយ), រីករាយនឹងតម្រេកកាមអារម្មណ៍ ហើយចូរអ្នកប្រុងប្រយ័ត្នកុំងប់នឹងតម្រេកកាមអារម្មណ៍ហួសហេតុ ដោយ(ចេះពិចារណាអំពីភាពគ្មានតម្លៃរបស់វា) នៅក្នុងចិត្តរបស់អ្នក។

១៧- ចូរអ្នកជៀសវាង(មធ្យោបាយចង់បាន)ទ្រព្យទាំងអស់ ដែលធ្វើឲ្យអន្តរាយដល់ការសិក្សាព្រះវេទ (ចូររក្សាខ្លួនឯង)តាមរបៀបណាក៏ដោយ ប៉ុន្តែត្រូវតែសិក្សា ពីព្រោះ(ការបូជាចំពោះ ការសិក្សាព្រះវេទ នឹងបាននូវ)ការសម្រេចគោលបំណងរបស់ខ្លួន។

១៨- ចូរអ្នកដើរនៅ(លើដី)នេះ ដោយមានសម្លៀកបំពាក់ ចេះនិយាយស្ដី និងពិចារណាស្របតាមវ័យរបស់ខ្លួន មុខរបររបស់ខ្លួន ទ្រព្យរបស់ខ្លួន ការសិក្សាដ៏ពិសិដ្ឋរបស់ខ្លួន និងពូជអម្បូររបស់ខ្លួន។

១៩- ចូរអ្នកអានរាល់ថ្ងៃយ៉ាងផ្ចិតផ្ចង់នូវគោលការណ៍វិទ្យាសាស្ត្រទាំងឡាយណា ដែលជួយបង្កើតគតិបណ្ឌិតឆាប់រហ័ស, គោលការណ៍ទាំងឡាយដែលបង្រៀនពីការរកទ្រព្យ, គោលការណ៍ទាំងឡាយដែលមានប្រយោជន៍(សម្រាប់លោកិយ) ហើយធ្វើដូច្នេះតាម*និគមៈ*ដែលអធិប្បាយព្រះវេទ។

២០- ព្រោះថាអ្នកសិក្សាគោលការណ៍វិទ្យាសាស្ត្រទាំងស្រុងបានកាន់តែច្រើន នោះអ្នកនឹងយល់គោលការណ៍នោះទាំងមូល ហើយចំណេះដឹងមហិមារបស់អ្នកនឹងបញ្ចេញរស្មីត្រចះត្រចង់។

២១- ប្រសិនបើអ្នកអាចធ្វើ(ការបូជាបាន) ចូរអ្នកកុំធ្វេសប្រហែសនឹងពិធីបូជាចំពោះបណ្ឌិត ចំពោះព្រះអាទិទេព្យ ចំពោះភូតៈ ចំពោះមនុស្ស និងចំពោះវិញ្ញាណក្ខន្ធបុព្វបុរស។

២២- មនុស្សខ្លះ ដែលចេះដឹងបញ្ញត្តិសម្រាប់ធ្វើពិធីយញ្ញ តែងតែធ្វើមហាបូជាទាំងនេះ ដោយឥន្ទ្រីយារម្មណ៍របស់ខ្លួន ដោយគ្មានកម្លាំង (ពីខាងក្រៅណាមកបង្ខំឡើយ)។

---

**១៥.** *ប្រសង្គេនៈ* 'ដើរតាមផ្លូវរបស់ពួកតារា' ឧ.ទា 'ផ្នែកតន្ត្រី និងចម្រៀង'(មេធ., គោវ., កុល្ល., រាឃ., នន្ទ.)។ នារ. ប្រែពាក្យនេះ ថា 'ដោយចំណង់ខ្លាំងពេក'។

**១៧.** វិ. ជំពូក៧១ លេខ៤។

**១៨.** យញ្ញ. ជំពូក១ លេខ១២៣; វិ. ជំពូក៧១ លេខ៥-៦។ 'ពូជអម្បូររបស់ខ្លួន' ឧ.ទា. ចូរអ្នកពាក់សក់របស់អ្នក ស្របតាមការកំណត់របស់គ្រួសារអ្នក(វស. ជំពូក២ លេខ២១)។

**១៩.** យញ្ញ. ជំពូក១ លេខ៩៩; វិ. ជំពូក៧១ លេខ៨។ វិទ្យាសាស្ត្រនានាដែលចង់និយាយនៅទីនេះ គឺ *ឥតិហាស, បុរាណ* និង *អាថសាស្ត្រ, វេជ្ជាពេទ្យ* និង*ហោរាសាស្ត្រ*។ ពាក្យ *និគម* គឺជា *អង្គ*(តាមមេធ.)។ គោវ., កុល្ល. និងនារ. ចាត់ទុក និគមថាជាប្រភេទការងារមួយដោយឡែក គឺការបង្រៀនអត្ថន័យព្រះវេទ ដូចជា នៃគមកាណ្ឌ គម្ពីរនីរុក្តៈ។

**២២.** កាព្យនេះ និងកាព្យពីរក្រោយទៀត សំដៅដល់របៀបធ្វើពិធីយញ្ញធំៗជានិមិត្តរូប ដែលមានរៀបរាប់នៅក្នុងគម្ពីរឧបនិស័ទ។

២៣- ចូរដឹងថា (ការធ្វើពិធី) បូជាដោយវាចា និងវត្ថុសំខាន់ក្នុងជីវិតរបស់ខ្លួនផ្ដល់ (ផល) មិនចេះសាបសូន្យ អ្នកខ្លះតែងតែបូជាវត្ថុសំខាន់ក្នុងជីវិតរបស់ខ្លួនដោយវាចា ស្របតាមដង្ហើមរបស់ខ្លួន។

២៤- ព្រាហ្មណ៍ដទៃ ដែលមានចក្ខុពុទ្ធិថា ការធ្វើពិធីសាសនាទាំងនោះមានចំណេះដឹងមូលដ្ឋានរបស់វា តែងតែធ្វើពិធីនោះដោយការយល់ដឹងតែប៉ុណ្ណោះ។

២៥- ព្រាហ្មណ៍គួរធ្វើអគ្និហោត្រ នៅដើម ឬនៅចុងថ្ងៃ និងយប់ និងពិធីទរស និងបៅរណមាស(ឥស្ដិ) នៅចុងពាក់កណ្ដាលខែនីមួយៗ,

២៦- នៅពេលគ្រាប់ធញ្ញជាតិចាស់ ត្រូវធ្វើ(ពិធីអាគ្រយណ)ដោយធញ្ញជាតិថ្មី, នៅចុងរដូវ(ទាំងបី) ធ្វើពិធី(កាតុរមាស្យ), នៅគោមផែនដី ធ្វើការបូជាយញ្ញ(សត្វ), នៅចុងឆ្នាំធ្វើការបូជា*សោមៈ*។

២៧- ព្រាហ្មណ៍ ដែលរក្សាភ្លើងពិសិដ្ឋ ប្រសិនបើគេចង់រស់នៅបានយូរ មិនគួរទទួលទានធញ្ញជាតិថ្មី ឬ សាច់ ដោយមិនបានបូជាឥស្ដិ (អាគ្រយណ)នូវធញ្ញជាតិថ្មី និង(បូជាយញ្ញ)សត្វនោះទេ។

២៨- ចំពោះព្រះអគ្គីរបស់ខ្លួនមិនត្រូវគោរពដោយការបូជាធញ្ញជាតិថ្មីនិងសត្វទេ ចូររម្ងាប់អារម្មណ៍ភ្លៀវភ្លារបស់ខ្លួន (ព្រោះវាជា)ចិត្តលោភចង់បានធញ្ញជាតិនិងសាច់។

២៩- គ្មានភ្ញៀវណាត្រូវស្នាក់នៅក្នុងផ្ទះគេដោយ មិនបានទទួលការគោរពស្របតាមលទ្ធភាពរបស់គេ ដោយផ្ដល់នូវអាសនៈ អាហារ កន្លែងដេក ទឹក ឬមើមឈើ និងផ្លែឈើ។

៣០- ចូរអ្នកកុំគោរព សូម្បីដោយការស្វាគមន៍ចំពោះពួកអញ្ញទិដ្ឋ មនុស្សដែលប្រកបរបរហាមឃាត់ មនុស្សដែលរស់ដូចសត្វឆ្មា ឬមនុស្សពាល អ្នកអាងហេតុផល (ពោលបំពានព្រះវេទ) និងអ្នកដែលរស់នៅដូចសត្វក្រសារ។

៣១- អ្នកដែលបានក្លាយជាស្នាកតៈ បន្ទាប់ពីសិក្សាព្រះវេទ ឬបន្ទាប់ពីបញ្ចប់ពាក្យសត្យៈរបស់ខ្លួន (និង) ឃរាវាស(អ្នកគ្រប់គ្រងផ្ទះ) ដែលជាស្រោត្រិយ អ្នកត្រូវគោរពដោយ(ការបរិច្ចាគអាហារ) ពិសិដ្ឋដល់អាទិទេព និងព្រលឹងបុព្វបុរស ប៉ុន្តែអ្នកត្រូវជៀសវាងអ្នកផ្សេងពីនេះ។

---

**២៣.** គៅសិតកិ-ឱប. ជំពូក២ លេខ៥។

**២៤.** នន្ទ. លុបចោលកាពនេះ។

**២៥-២៧.** គោត. ជំពូក៨ លេខ១៩-២០; វស. ជំពូក១១ លេខ៤៦; វិ. ជំពូក៥៩ លេខ២-៩; ពោធ. ជំពូក២ លេខ៤, ២៣; យញ្ញ. ជំពូក១ លេខ៩៧, ១២៤-១២៥។

**៣០.** យញ្ញ. ជំពូក១ លេខ១៣០។ *បាសណ្ឌិនៈ* 'អញ្ញទិដ្ឋិ' គឺ 'ភាពជាតាបសមិនមែនជាព្រាហ្មណ៍'(*វាហ្យលិង្គិនៈ*, មេធ.) ឬ 'ជាតាបសស្លៀកពាក់សម្លៀកបំពាក់ក្រហមជាដើម'(គោវ.), ឬ 'តាបសមិនមែនជាព្រាហ្មណ៍ ដូចជាព្រះពុទ្ធ'(កុល្ល., នារ.), ឬ 'អ្នកដែលគ្មានជំនឿលើព្រះវេទ'(រាឃ.)។ ពាក្យនេះ មិនចាំបាច់សំដៅដល់អ្នកពុទ្ធនិយម និងគៃណៈ ទេ ទោះបីអ្នកក្រោយនេះ អាចត្រូវកំណត់ឈ្មោះជាមុនទេ។ លោក Kern បានធ្វើការបកស្រាយត្រឹមត្រូវចំពោះពាក្យ *បាសណ្ឌ* ឬ*បាសន្ទិន* 'អ្នកកាន់និកាយសាសនា' នៅក្នុង Jaartelling de zuidelijke Buddhisten ទំព័រ៦៧។ ចំពោះបុរសដែលប្រព្រឹត្តដូចជាសត្វឆ្មា ឬក្រសារ សូមមើលកាព្យលេខ១៩៥-១៩៦ខាងក្រោម។

**៣១.** នន្ទ. អាន *គួហំ អាគតាន*ដែលបានចូលមកកាន់ផ្ទះរបស់ខ្លួន' ជំនួសពាក្យ *គួហមេធិនៈ* 'ដែលជាអ្នកគ្រប់គ្រងផ្ទះ'។

៣២- យាវាស ត្រូវជូន(អាហារឱ្យបានច្រើន) តាមដែលខ្លួនអាចធ្វើទៅបាន ដើម្បីផ្គត់ផ្គង់ដល់អ្នកដែលមិនដាំស្លសម្រាប់ខ្លួនឯង និងដល់សត្វលោកទាំងឡាយ គឺត្រូវចែករំលែក(អាហារ) ដោយមិនគិតខ្លាច ខាត(ប្រយោជន៍ផ្ទាល់ខ្លួនឯង)ទេ។

៣៣- ស្នាតកៈ ដែលមានសេចក្តីស្រេកឃ្លានខ្លាំង អាចសុំទ្រព្យពីព្រះរាជា ពីអ្នកដែលខ្លួនគោរពបូជា និងពីកូនសិស្ស តែមិនមែនពីអ្នកដទៃទេ នេះជាវិធានកំណត់។

៣៤- ស្នាតកៈ ដែលអាច (រកអាហារបាន) មិនគួរចំណាយពេលចោលជាមួយនឹងសេចក្តីស្រេកឃ្លានទេ និងមិនគួរពាក់សម្លៀកបំពាក់ចាស់ៗ ឬគគ្រិចទេ ប្រសិនបើខ្លួនមានទ្រព្យ។

៣៥- ដោយការកាត់សក់ ក្រចក និងពុកចង្ការបស់ខ្លួន ការជម្នះបាននូវតណ្ហារបស់ខ្លួនដោយការធ្វើតបៈ ការពាក់សម្លៀកបំពាក់ស និង (ការរក្សាខ្លួន) ឱ្យបរិសុទ្ធ អ្នកគួរធ្វើការសិក្សាព្រះវេទ និង (អំពើបែបនេះដែលផ្តល់)ផលល្អដល់សុខុមាលភាពរបស់ខ្លួន។

៣៦- អ្នកគួរកាន់ដំបងឫសី ភាជន៍ដែលមានទឹកពេញ អំបោះពិសិដ្ឋ បាច់ស្មៅកុសៈ និង(ពាក់)ក្រវិលមាសដ៏ភ្លឺចិញ្ចាចពីរ។

៣៧- ចូរអ្នកកុំសម្លឹងមើលព្រះអាទិត្យ នៅពេលព្រះអាទិត្យរះ ឬលិច បាត់ពន្លឺ ឬចាំងរូបក្នុងទឹក ឬរះចំកណ្តាលមេឃ។

៣៨- ចូរអ្នកកុំជាន់ខ្សែដែលចងកូនគោ, ចូរអ្នកកុំរត់ពេលមេឃភ្លៀង ហើយចូរអ្នកកុំមើលរូបខ្លួនឯងនៅក្នុងទឹក នេះជាវិធានកំណត់។

---

**៣២.** អាប. ជំពូក២ លេខ៤, ១៤; គោត. ជំពូក៥ លេខ២២; ពោធ. ជំពូក២ លេខ៥, ២០។ 'អ្នកដែលមិនចំអិនអាហារដោយខ្លួនឯង' គឺ អ្នកសិក្សា និងតាបស។ យោងតាមគោវ. ថា *បាសណ្ឌ* ត្រូវរាប់បញ្ចូលនូវពាក្យនេះ។

**៣៣.** គោត. ជំពូក៩ លេខ៦៣-៦៤; វស. ជំពូក១២ លេខ២; យញ្ញ. ជំពូក១ លេខ១៣០។ 'ព្រះរាជា' គឺ 'ក្សត្រិយ ស្តេចដែលគ្រប់គ្រងស្របតាមសាស្ត្រ' សូមមើលកាព្យលេខ ៨៤ ខាងក្រោម។

**៣៤.** វស. ជំពូក១២ លេខ៤; វិ. ជំពូក៧១ លេខ៩; គោត. ជំពូក៩ លេខ៣; អាប. ជំពូក១ លេខ៣០, ១៣។ ពាក្យ *សក្តៈ* 'ដែលអាច(ផ្តល់អាហារ)បាន'(នារ.) ហើយតាមនន្ទ. ថា 'អ្នកដែលអាចរៀបចំអាហារពេលល្ងាច មិនគួរមានចិត្តមច្ឆរិយៈទេ'។ គោវ., កុល្ល. និង K. បកស្រាយឃ្លា 'ស្នាតកៈ ដែលជាអ្នកសមគួរ (អ្នកទទួលអំណោយ) មិនត្រូវត្រេកត្រអាលខ្លាំង (រហូតដល់ព្រះរាជរកអ្វីឱ្យមិនបាននោះទេ)' គឺ គេត្រូវចេះទប់អារម្មណ៍។ រាឃ. អាន *យុក្តៈ* ជំនួសការអាន *សក្តៈ* 'ស្នាកតៈដែលកំពុងស្រេកឃ្លាន មិនគួរអស់សង្ឃឹមទេ'។ បើប្រែតាមន័យទីពីរ វិធាននេះដូចគ្នានឹងវិធានដែលមាននៅក្នុងតម្រា អាប. ជំពូក២ លេខ២៥, ១១; គោត. ជំពូក១០ លេខ៩-១០; វិ. ជំពូក៣ លេខ៧៩។

**៣៥.** អាប. ជំពូក១ លេខ៣០, ១០-១២; គោត. ជំពូក៩ លេខ៤, ៧; យញ្ញ. ជំពូក១ លេខ១៣១; ពោធ. ជំពូក១ លេខ៥, ៧។

**៣៦.** វស. ជំពូក១២ លេខ១៤-១៧; ពោធ. ជំពូក១ លេខ៥, ៣-៥; លេខ៦, ១-៥; ជំពូក២ លេខ៦, ៧; វិ. ជំពូក៧១ លេខ១៣-១៦; យញ្ញ. ជំពូក១ លេខ១៣៣។

**៣៧.** អាប. ជំពូក១ លេខ៣១, ២០; វស. ជំពូក១២ លេខ១០; ពោធ. ជំពូក២ លេខ៦, ១០; វិ. ជំពូក៧១ លេខ១៧-២១; យញ្ញ. ជំពូក១ លេខ១៣៥។

**៣៨.** អាប. ជំពូក១ លេខ៣១, ១៥; វស. ជំពូក១២ លេខ៩; ពោធ. ជំពូក២ លេខ៦, ១៥; វិ. ជំពូក៧១ លេខ២៣; ជំពូក៧៣ លេខ៤១-៣។

៣៩- ចូរអ្នកដើរជួបដី(ខ្លះ) មេគោ វត្ថុសក្ការៈ ព្រាហ្មណ៍ ប៊ីថ្លា ទឹកឃ្មុំ ផ្លូវបំបែក និងដើមឈើល្បី ដោយបត់ស្តាំ ដើរសំដៅទៅរកវា។

៤០- ចូរអ្នក សូម្បីមានចំណង់លីលាក៏ដោយ មិនត្រូវចូលទៅជិតភរិយារបស់ខ្លួន ពេលដំណើររបស់នាងដើរមកដល់ ហើយចូរអ្នកកុំដេកជាមួយនាងក្នុងគ្រែតែមួយ។

៤១- ដើម្បីគតិបណ្ឌិត ថាមពល កម្លាំង ចក្ខុប្រសាទ និងភាពស្វាហាប់របស់មនុស្ស ដែលចូលទៅរកស្ត្រីដែលកំពុងមានរដូវ នឹងវិនាសទាំងអស់យ៉ាងពិតប្រាកដ។

៤២- ប្រសិនបើអ្នកជៀសពីនាងបានខណៈពេលនាងកំពុងស្ថិតក្នុងលក្ខខណ្ឌនោះគតិបណ្ឌិត ថាមពល កម្លាំង ចក្ខុប្រសាទ និងភាពស្វាហាប់ នឹងកើនឡើង។

៤៣- ចូរអ្នកកុំទទួលទានរួមជាមួយភរិយាខ្លួន កុំសម្លឹងមើលនាង ខណៈដែលនាងទទួលទាន កណ្តាស់ ស្វាប ឬអង្គុយតាមសម្រួលរបស់នាង។

៤៤- ព្រាហ្មណ៍ ដែលចង់បានថាមពល មិនត្រូវសម្លឹងមើល(ស្ត្រី) ដែលលាបថ្នាំភ្នែក បានខាត់ខ្លួនជាមួយនឹងប្រេង ឬមិនបិទបាំងខ្លួន ឬបង្កើត(កូន)។

៤៥- ចូរអ្នកកុំទទួលទាន ដោយស្លៀកតែខោប៉ុណ្ណោះ, ចូរអ្នកកុំមុជទឹកស្រាត, ចូរអ្នកកុំជុះនោមដាក់ផ្លូវ ផេះ ឬក្នុងទ្រុងគោ,

៤៦- និងកុំជុះដាក់ដីដែលភ្ជួររួច ក្នុងទឹក លើទីសក្ការៈបូជា លើភ្នំ លើវត្តអារាមបាក់បែក និងកុំជុះលើដំបូកស្រមោចឱ្យសោះ,

៤៧- កុំជុះដាក់ក្នុងរន្ធដែលសត្វមានជីវិតរស់នៅ កុំជុះខណៈពេលដើរឬឈរនៅលើច្រាំងទន្លេ និងកុំជុះដាក់លើកំពូលភ្នំ។

៤៨- ចូរអ្នកកុំជុះអាចម៍ ឬនោម នៅខាងមុខខ្យល់ ឬភ្លើង ឬសម្លឹងទៅរកព្រាហ្មណ៍ ព្រះអាទិត្យ ទឹក ឬមេគោ។

---

**៣៩.** គោត. ជំពូក៩ លេខ៦៦; វិ. ជំពូក៦៣ លេខ២៦-២៨; យញ្ញ. ជំពូក១ លេខ១៣៣។

**៤០-៤២.** គោត. ជំពូក៩ លេខ២៩-៣០; វស. ជំពូក១២ លេខ៧; វិ. ជំពូក៦៩ លេខ១១។

**៤២.** មេធ. និងនន្ទ. អាន *លក្ស្មី* ‘សំណាង’ ជំនួសពាក្យ *តេត:* ‘ថាមពល’។

**៤៣.** វស. ជំពូក១២ លេខ៣១; វិ. ជំពូក៦៨ លេខ៤៦; យញ្ញ. ជំពូក១ លេខ១៣១; គោត. ជំពូក៩ លេខ៣២។

**៤៤.** គោត. ជំពូក៩ លេខ៣២។

**៤៥.** អាប. ជំពូក១ លេខ៣០, ១៨; គោត. ជំពូក៩ លេខ៤០; វស. ជំពូក១២ លេខ១១; ពោធ. ជំពូក២ លេខ៦, ២៤, ៣៩; វិ. ជំពូក៦៨ លេខ១៤; ជំពូក៦៤ លេខ៥; ជំពូក៦០ លេខ១១, ១៦, ១៩; យញ្ញ. ជំពូក១ លេខ១៣១, ១៣៤។ *គោវ្រជេ* ‘នៅក្នុងទ្រុងគោ’(គោវ., កុល្លូ.) ហើយតាមមេធ. ថា ‘កន្លែងដែលគោស៊ីស្មៅ’។

**៤៦.** អាប. ជំពូក១ លេខ៣០, ១៨; គោត. ជំពូក៩ លេខ៤០; វិ. ជំពូក៦០ លេខ៤, ២១, ១០។ ‘អ្នកខ្លះលុបចោលកាព្យលេខ៤៦-៤៧’(នារ.) ហើយគេរកមិនឃើញកាព្យនោះនៅក្នុងអត្ថបទរបស់នន្ទ.ទេ។

**៤៧.** វិ. ជំពូក៦០ លេខ៩។

**៤៨.** អាប. ជំពូក១ លេខ៣០, ២០; គោត. ជំពូក២ លេខ១២; វិ. ជំពូក៦០ លេខ២២; យញ្ញ. ជំពូក១ លេខ១៣៤។ ‘ដោយមើលទៅអ្វីមួយ(ដែលត្រូវខ្យល់បក)’(មេធ., កុល្លូ.)។ មេធ. ដាក់កាព្យ៥២ បន្ទាប់ពីកាព្យនេះផ្ទាល់។

៤៩- អ្នកអាចសម្រួលខ្លួន បន្ទាប់ពីដាក់ដំបង ដុំដី ស្លឹកឈើ ស្មៅជាដើម លើ(បរិវេណនោះ) ដោយកុំនិយាយ (រក្សាខ្លួន)ឱ្យបរិសុទ្ធ ដោយមានអ្វីគ្របខ្លួននិងក្បាល។

៥០- ចូរអ្នកកុំជុះអាចម៍និងនោម នៅពេលថ្ងៃ ដោយបែរមុខទៅជើង នៅពេលយប់ដោយបែរមុខទៅខាងត្បូង ក្នុងអំឡុងមុនថ្ងៃរះនិងក្រោយថ្ងៃលិច ដោយប្រកាន់ជំហរដូចគ្នានឹងពេលថ្ងៃដែរ។

៥១- នៅក្នុងម្លប់ ឬទីងងឹត ព្រាហ្មណ៍អាចជុះបានទាំងពេលថ្ងៃ ទាំងពេលយប់ ដោយជំហរដែលខ្លួនគិតថាស្រួល ដូច្នេះបីដូចជីវិតខ្លួនកំពុងជួបគ្រោះថ្នាក់។

៥២- (មនុស្ស)ឆ្លាត ដែលជុះនោមដាក់ភ្លើង ព្រះអាទិត្យ ព្រះច័ន្ទ ទឹក ព្រាហ្មណ៍ មេគោ ឬខ្យល់ នឹងវិនាស។

៥៣- ចូរអ្នកកុំយកមាត់អ្នកផ្លុំភ្លើង, ចូរអ្នកកុំមើលស្ត្រីអាក្រាត, ចូរអ្នកកុំបោះវត្ថុមិនបរិសុទ្ធចូលក្នុងភ្លើង ហើយចូរអ្នកកុំយកភ្លើងកម្តៅជើងអ្នក។

៥៤- ចូរអ្នកកុំដាក់ភ្លើងក្រោម (គ្រែ ឬកន្លែងអង្គុយ), កុំកន្លងភ្លើង, កុំដាក់ភ្លើងនៅក្បែរជើងគ្រែ (ពេលអ្នកដេក) ហើយចូរអ្នកកុំធ្វើបាបសត្វមានជីវិត។

៥៥- ចូរអ្នកកុំទទួលទាន កុំធ្វើដំណើរ កុំដេកក្នុងអំឡុងពេលព្រះអាទិត្យអស្តង្គត, ចូរអ្នកខ្វាចដី, ចូរអ្នកកុំដោះកម្រងផ្ការបស់ខ្លួន។

៥៦- ចូរអ្នកកុំជុះនោម ឬអាចម៍ដាក់ទឹក, កុំស្តោះទឹកមាត់ កុំបោះ(ដាក់ខោអាវ) ដែលប្រឡាក់សារ-ជាតុមិនស្អាត កុំបោះរបស់មិនល្អ ឈាម និងវត្ថុពុលចូលក្នុងទឹក។

៥៧- ចូរអ្នកកុំដេកម្នាក់ឯងនៅទីរហោឋាន,ចូរអ្នកកុំដាស់(លោកនាយ)ដែលកំពុងដេក, ចូរអ្នកសន្ទនាជាមួយស្ត្រីមានរដូវ ហើយចូរអ្នកកុំចូលរួមពិធីយញ្ញ បើអ្នកត្រូវគេជ្រើស(ឱ្យធ្វើជាអាចារ្យពិធី)។

៥៨- ចូរអ្នកទុកដៃស្តាំឱ្យនៅទំនេរនៅកន្លែងដែលមានភ្លើងពិសិដ្ឋ ក្នុងទ្រុងគោ ទីដែលមានព្រាហ្មណ៍ ក្នុងពេលសូត្រព្រះវេទម្នាក់ឯង និងនៅពេលទទួលទាន។

---

**៤៩.** អាប. ជំពូក១ លេខ៣០, ១៤-១៥; គោត. ជំពូក៩ លេខ៣៧-៣៨, ៤១-៤៣; វស. ជំពូក១២ លេខ១៣; វិ. ជំពូក៦០ លេខ២-៣, ២៣។

**៥០.** អាប. ជំពូក១ លេខ៣១, ១; វិ. ជំពូក៦០ លេខ២-៣។

**៥២.** មេធ. និងនារ. លើកឡើងនូវពាក្យផ្សេង *ប្រតិកំ* 'បញ្ច្រាស់ខ្យល់', *ប្រតិសំធ្យំ* 'នៅពេលអស្តង្គត' ដែលនន្ទ. យល់ស្របតាម។

**៥៣.** អាប. ជំពូក១ លេខ១៥, ២០-២១; គោត. ជំពូក៩ លេខ៣២; វស. ជំពូក១២ លេខ២៧; វិ. ជំពូក៧១ លេខ៣២-៣៤, ៣៧; យញ្ញ. ជំពូក១ លេខ១៣៧។

**៥៤.** វិ. ជំពូក៧១ លេខ៣៦; យញ្ញ. ជំពូក១ លេខ១៣៥, ១៣៧; គោត. ជំពូក៩ លេខ៧៣។

**៥៥.** វិ. ជំពូក៦៣ លេខ៨; ជំពូក៦៨ លេខ ១២; ជំពូក៧១ លេខ៤១, ៥៥។

**៥៦.** អាប. ជំពូក១ លេខ៣០, ១៩; វិ. ជំពូក៧១ លេខ៣៥; យញ្ញ. ជំពូក១ លេខ១៣៧។

**៥៧.** គោត. ជំពូក៩ លេខ៥៤-៥៥; វស. ជំពូក១២ លេខ៤២; វិ. ជំពូក៦៣ លេខ២១; ជំពូក៧០ លេខ១៣; ជំពូក៧១ លេខ៥៨; យញ្ញ.ជំពូក១ លេខ១៣៨។

**៥៨.** ពោធ. ជំពូក២ លេខ៦, ៣៨; វិ. ជំពូក៧១ លេខ៦០។

៥៩- ចូរអ្នកកុំបញ្ឈប់មេគោដែលកំពុងបំបៅ(កូនវា), កុំប្រាប់នរណាមួយអំពីរឿងនេះ។ អ្នកឆ្លាត ប្រសិនបើឃើញឥន្ទធនូលើមេឃ មិនត្រូវចង្អុលវា ប្រាប់នរណាមួយទេ។

៦០- ចូរអ្នកកុំស្នាក់នៅក្នុងភូមិ ដែលមិនមានការគោរពច្បាប់ពិសិដ្ឋ កុំស្នាក់នៅយូរ នៅកន្លែងដែលមានជំងឺឆ្លង, ចូរអ្នកកុំធ្វើដំណើរម្នាក់ឯង កុំនៅយូរនៅលើភ្នំ។

៦១- ចូរអ្នកកុំស្នាក់នៅក្នុងប្រទេសដែលមេដឹកនាំជាសូទ្រៈ កុំនៅទីណាដែលសម្បូរដោយមនុស្សមិនត្រឹមត្រូវ កុំនៅកន្លែងរបស់អ្នកដែលមានជំនឿអញ្ញទិដ្ឋិ កុំនៅកន្លែងណាដែលមានក្រុមមនុស្សវណ្ណៈទាប។

៦២- ចូរអ្នកកុំទទួលទានអ្វីដែលបានធ្វើពីខ្លាញ់ ចូរអ្នកកុំធ្វើជាអ្នកល្មោភស៊ី ចូរអ្នកកុំទទួលទាននៅ(ព្រឹក)ព្រលឹមអុល និងនៅពេលល្ងាចជ្រៅ កុំទទួលទានអាហារនៅល្ងាច ប្រសិនបើអ្នកបានទទួលទាន(ឆ្អែត) នៅពេលព្រឹក។

៦៣- ចូរអ្នកកុំខំប្រឹងប្រែងដោយគោលបំណង ចូរអ្នកកុំផឹកទឹកក្នុងកំបង់ដៃខ្លួន ចូរអ្នកកុំបរិភោគអាហារ(ដែលនៅ)លើភ្លៅរបស់ខ្លួន ចូរអ្នកកុំបង្ហាញការចង់ដឹង(ឥតប្រយោជន៍)នោះ។

៦៤- ចូរអ្នកកុំរាំ កុំច្រៀង កុំលេងឧបករណ៍តន្ត្រី កុំទះភ្លៅ(របស់ខ្លួន) កុំសង្កៀតធ្មេញ ហើយចូរអ្នកកុំធ្វើឱ្យសំឡេងរំខានដោយមិនសមរម្យ ទោះបីអ្នកកំពុងមានកំហឹងខ្លាំងក៏ដោយ។

៦៥- ចូរអ្នកកុំលាងជើងក្នុងភាជន៍ ដែលធ្វើពីទង់ដែងស ចូរអ្នកកុំទទួលទាននៅក្នុងចាន (ដី) កំបែក ហើយកុំវាយតម្លៃដោយឃើញរូបខាងក្រៅមិនល្អ។

៦៦- ចូរអ្នកកុំប្រើស្បែកជើង សម្លៀកបំពាក់ ខ្សែពិសិដ្ឋ គ្រឿងអលង្ការ កម្រងផ្កា ឬភាជន៍ទឹក ដែលអ្នកដទៃប្រើហើយ។

---

**៥៩.** អាប. ជំពូក១ លេខ៣១, ១០, ១៨; គោត. ជំពូក៩ លេខ២៣; វស. ជំពូក១២ លេខ៣៣; ពោធ. ជំពូក២ លេខ៦, ១១, ១៧; វិ. ជំពូក៦៣ លេខ២; ជំពូក៧១ លេខ៦២។ អ្នកអធិប្បាយទាំងអស់ លើកលែងលោករាឃ. បកស្រាយពាក្យ *ធយន្តីម* 'ដែលកំពុងបំបៅ(កូនរបស់វា)' ដោយ *បិពន្តីម* 'ដែលកំពុងផឹកទឹក'(ទឹកដោះ ឬទឹក សូមមើលយញ្ញ. ជំពូក១ លេខ១៤០)។

**៦០-៦១.** អាប. ជំពូក១ លេខ១៥, ២២, ៣២, ១៨; គោត. ជំពូក៩ លេខ៦៥; ពោធ. ជំពូក២ លេខ៦, ២១, ៣១; វិ. ជំពូក៧១ លេខ៦៤-៦៨។

**៦២.** វិ. ជំពូក៦៨ លេខ២៧, ៤៨; សូមមើលជំពូក២ លេខ៥៦-៥៧ ខាងលើ។

**៦៣.** គោត. ជំពូក៩ លេខ៩, ៥០, ៥៦; ពោធ. ជំពូក២ លេខ៦, ៥; វិ. ជំពូក៧១ លេខ៦៩។

**៦៤.** អាប. ជំពូក២ លេខ២០, ១៣; វិ. ជំពូក៧១ លេខ៧០-៧១។ ពាក្យ *ន ក្ស្វេឌេត* 'ចូលអ្នកកុំសង្កៀតធ្មេញ' ហើយតាមនារ. 'ចូរអ្នកកុំស្រែកពេទី ដូចគោ', តាមនន្ទ. ថា 'ចូរអ្នកកុំផ្ទាត់ម្រាមដៃរបស់អ្នក'។ *ន សហ្វោតយេត* 'ចូរអ្នកកុំទម្រេត(ដៃជើង)' ហើយតាមនន្ទ. ថា 'អ្នកមិនគួរកាច់ម្រាមដៃ(ឱ្យលាន់ប្រឺបៗ)'។

**៦៥.** វិ. ជំពូក៦៨ លេខ២០; ជំពូក៧១ លេខ៣៩។

**៦៦.** វិ. ជំពូក៧១ លេខ៤៧។

**៦៧-៦៨.** វិ. ជំពូក៦៣ លេខ១៣-១៨។

៦៧- ចូរអ្នកកុំធ្វើដំណើរជាមួយសត្វប្រើសម្រាប់ដឹកទំនិញដែលមិនទាន់បានបង្ហឹក កុំនៅជាមួយ(សត្វ) ដែលស្រេកឃ្លាន ឬមានជំងឺ ឬដែលស្នែង ភ្នែក និងក្រចករបស់វាមានរបួស ឬកន្ទុយរបស់វាត្រូវគេធ្វើឱ្យខូចទ្រុងទ្រាយ។

៦៨- ចូរអ្នកធ្វើដំណើរជានិច្ចជាមួយ(សត្វព្រៃ)ដែលរត់មិនកើត រត់មិនលឿន ដែលមានសញ្ញានាំសំណាង និងមានពណ៌និងទម្រង់ល្អឥតខ្ចោះ ដោយកុំបង្ខំ ចាក់វានឹងជន្លួញអី។

៦៩- ព្រះអាទិត្យព្រឹកព្រលឹម ផ្សែងហុយចេញពីសាកសព(ដែលកំពុងដុត) ខូច អ្នកត្រូវតែជៀសវាងឱ្យបាន។ ចូរអ្នកកុំខាំក្រចក ឬសក់របស់អ្នក ហើយកុំខាំហែកក្រចកនឹងធ្មេញរបស់អ្នក។

៧០- ចូរអ្នកកុំបុកបំបែកដី ឬដុំដី កុំប្រើក្រចកហែកស្មៅ ហើយចូរអ្នកកុំធ្វើអ្វី ដែលឥតប្រយោជន៍ ឬដែលមិនផ្តល់ផលល្អនៅពេលអនាគត។

៧១- មនុស្សដែលប្រើក្រចកបំបែកដុំដី ស្មៅ ឬខាំក្រចក មិនយូរទេនឹងជួបនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ដូចគ្នានឹងអ្នកជូនដំណឹង និងអ្នកដែលមិនគោរព(តម្រា)សម្រាប់សំអាតកាយចិត្ត។

៧២- ចូរអ្នកកុំឈ្លោះគ្នា ចូរកុំពាក់កម្រងផ្កាលើ(សក់ក្បាល)។ ការជិះលើខ្នងមេគោ (ឬគោឈ្មោល) ទោះជារបៀបណាក៏ដោយ គឺជាអំពើគួរឱ្យស្តីបន្ទោស។

៧៣- ចូរអ្នកកុំចូលទៅកាន់ភូមិ ឬផ្ទះកំផែង លើកលែងតែចូលតាមក្លោងទ្វារ ហើយនៅពេលយប់ ចូរអ្នកនៅឱ្យឆ្ងាយពីឫសឈើ។

៧៤- ចូរអ្នកកុំលេងអាប៉ោង/ឡុកឡាក់ឱ្យសោះ កុំដោះស្បែកជើង ហើយចូរអ្នកកុំទទួលទានដោយដេកលើគ្រែ កុំហូបអ្វីដែលជាប់លើដៃ ឬលើកៅអីអង្គុយ។

---

**៦៩.** វិ. ជំពូក៧១ លេខ៤៤, ៤៦; យញ្ញ. ជំពូក១ លេខ១៣៩។ ពាក្យ *ពាលាតបៈ* 'ព្រះអាទិត្យព្រឹកព្រលឹម' ហើយតាមអំណះអំណាងរបស់នារ. និងរាឃ. ថា អ្នកខ្លះប្រែ 'ព្រះអាទិត្យក្នុងសញ្ញា *កន្យា* ឬ *វិគោ*' គឺ 'ព្រះអាទិត្យក្នុងសរទរដូវ'។ លោកនន្ទបណ្ឌិត ធ្វើការបកស្រាយដូចគ្នានេះ នៅក្នុងសេចក្តីអធិប្បាយរបស់លោក ស្តីពីព្រះវិស្ណុ។ យ៉ាងណាមិញ ការបកស្រាយនោះទំនងជាមិនត្រឹមត្រូវទេ សូមមើលសេចក្តីផ្តើម។ 'ចូរអ្នកកុំកាត់ក្រចក ឬសក់របស់អ្នក' គឺ 'កុំកាត់ដោយខ្លួនឯង តែចូរអ្នកប្រើជាងកាត់សក់ចុះ'(មេធ., គោវ.) ឬ 'មុនពេលវាដុះវែង'(កុល្លូ.) ឬ 'លើកលែងក្នុងពេលវេលាសមស្របសម្រាប់ការកាត់នោះ'(នន្ទ.)។

**៧០.** អាប. ជំពូក១ លេខ៣២, ១៨; គោត. ជំពូក៩ លេខ៥១; វិ. ជំពូក៧១ លេខ៤២-៤៣។

**៧២.** អាប. ជំពូក១ លេខ៣២, ៥; គោត. ជំពូក៩ លេខ៣២; ពោធ. ជំពូក២ លេខ៦៩។ ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ 'វិគ្ឫហ្យ' ជំនួសឱ្យ 'វិគរហ្យ' ដែលមាននៅក្នុងអត្ថបទបោះពុម្ព។ 'ចូរអ្នកកុំពាក់កម្រងផ្កាលើ(សម្លៀកបំពាក់របស់អ្នក' (មេធ.) ឬ 'ចូរអ្នកកុំដាក់កម្រងផ្កានៅខាងក្រៅ(ផ្ទះ)' ឬ 'កម្រងផ្កា ដែលមិនក្រអូប'(អ្នកដទៃ, មេធ.)។

**៧៣.** អាប. ជំពូក១ លេខ៣១, ២៣; គោត. ជំពូក៩ លេខ៣២; ពោធ. ជំពូក២ លេខ៦, ១៣; យញ្ញ. ជំពូក១ លេខ ១៤០។

**៧៤.** គោត. ជំពូក៩ លេខ៣២; វស. ជំពូក១២ លេខ៣៦; ពោធ.ជំពូក២ លេខ៦, ៦; វិ. ជំពូក៦៨ លេខ២៣; វិ. ជំពូក ៧១ លេខ៤៥; យញ្ញ. ជំពូក១ លេខ១៣៨។ 'កុំហូបអ្វី ដែលជាប់លើដៃ' គឺ 'នៅលើដៃឆ្វេងអ្នក ឬនៅក្នុងភាជន៍ នៅក្នុងដៃនោះ'(នារ.)។ ការបកស្រាយនេះ ច្បាស់លាស់ណាស់ ព្រោះពួកហិណ្ឌូ តែងតែទទួលទាននឹងម្រាមដៃខាងស្តាំ ហើយគេចាត់ទុកដៃខាងឆ្វេងជាដៃមិនស្អាត ក្នុងហេតុផលល្អៗជាច្រើន។

៧៥- ចូរអ្នកកុំទទួលទានក្រោយថ្ងៃលិចនូវអាហារណាដែលមានធញ្ញជាតិល្ង, ចូរអ្នកកុំដេកស្រាតហើយ ចូរកុំទៅកន្លែងដែលមិនបរិសុទ្ធ (បន្ទាប់ពីបាយរួច)។

៧៦- ចូរអ្នកទទួលទាននៅពេលជើងរបស់អ្នកនៅសើម(ពីពិធីមុជទឹក) ប៉ុន្តែចូរអ្នកកុំទៅដេក ទាំងជើងនៅសើម។ អ្នកដែលទទួលទានក្នុងពេលជើងរបស់ខ្លួននៅសើមនៅឡើយ នឹងបានអាយុវែង។

៧៧- ចូរអ្នកកុំចូលកន្លែងដែលពិបាកចូល ពិបាកមើលនឹងភ្នែក, ចូរអ្នកកុំមើលទឹកនោម ឬលាមក ហើយកុំឆ្លងទន្លេ (ដោយការហែលនឹងដៃ)។

៧៨- ចូរអ្នកកុំដើរលើសក់ ផេះ ឆ្អឹង អំបែងភាជន៍ គ្រាប់កប្បាស ឬចំបើងអង្កាម ប្រសិនបើអ្នកចង់បានអាយុវែង។

៧៩- ចូរអ្នកកុំស្នាក់នៅជាមួយពួកសូទ្រៈ ពួកកាណ្ឌាលៈ ពួកបុក្កសៈ ពួកមនុស្សភ្លីភ្លើ មនុស្សជិះជាន់អ្នកដទៃ មនុស្សវណ្ណៈទាប និងពួកអន្ត្យាវសាយិន។

៨០- ចូរអ្នកកុំឱ្យដំបូន្មាន អាហារសំណល់ អាហារបុណ្យ(សម្រាប់បូជាអាទិទេព) ដល់សូទ្រៈ ហើយចូរអ្នកកុំពន្យល់ច្បាប់ពិសិដ្ឋដល់(មនុស្សបែបនេះ) និងកុំបង្រៀន(គេ)ធ្វើតបៈ។

៨១- ចំពោះអ្នកដែលពន្យល់ច្បាប់ពិសិដ្ឋ(ដល់សូទ្រៈ)ឬបង្រៀនឱ្យសូទ្រៈចេះធ្វើតបៈ នឹងធ្លាក់ទៅកាន់នរក (ដែលមានឈ្មោះ)*អសំ-វ្ឫត* ជាមួយមនុស្សនោះ។

៨២- ចូរអ្នកកុំខ្វាចក្បាលរបស់អ្នកដោយដៃទាំងពីរ, ចូរអ្នកប៉ះក្បាល ពេលក្បាលមិនស្អាត និងមិនបានមុជទឹក(ត្រូវ)ក្បាល។

៨៣- ចូរអ្នកប្រយ័ត្ន(កុំខឹង)បោចសក់(របស់ខ្លួនឬសក់អ្នកដទៃ)ឬវាយក្បាលខ្លួនឯងឬក្បាលអ្នកដទៃ។ ពេលអ្នកបានមុជទឹកត្រូវក្បាលហើយ អ្នកមិនគួរយកដៃទៅលាបប្រេង លើអវយវៈណាមួយរបស់ខ្លួនទេ។

៨៤- ចូរអ្នកកុំទទួលអំណោយពីព្រះរាជា ដែលមិនបានបន្តវង្សខត្តិយ មិនមែនជាអ្នកសម្លាប់សត្វ អ្នកផលិតប្រេងនិងម្ចាស់ហាង ហើយមិនមែនជាអ្នកដែលចិញ្ចឹមជីវិតដោយចំណូលរបស់ស្រីពេស្យា។

---

**៧៥.** គោត. ជំពូក៩ លេខ៦០; វិ. ជំពូក៦៨ លេខ២៩; ជំពូក៧១ លេខ៣; សូមមើលជំពូក២ លេខ៥៦ខាងលើ។

**៧៦.** វិ. ជំពូក៦៨ លេខ៣៤; ជំពូក៧០ លេខ១។

**៧៧.** អាប. ជំពូក១ លេខ៣២, ២៦; គោត. ជំពូក៩ លេខ៣២; វស. ជំពូក១២ លេខ៤៥; ពោធ. ជំពូក២ លេខ៦, ២៦; វិ. ជំពូក៦៣ លេខ៤៦។

**៧៨.** អាប.ជំពូក២ លេខ២០, ១១; គោត. ជំពូក៩ លេខ១៥; ពោធ. ជំពូក២ លេខ៦, ១៦; យញ្ញ. ជំពូក១ លេខ១៣៩។

**៧៩.** ចំពោះពាក្យ *បុក្កសៈ* និង *អន្ត្យាវសាយិន* សូមមើលជំពូក១០ លេខ១៨, ៣៩ ខាងក្រោម។

**៨០.** អាប. ជំពូក១ លេខ៣១, ២៤; វិ. ជំពូក៧១ លេខ៤៨-៥២; វស. ជំពូក១៨ លេខ១៤។

**៨១.** វស. ជំពូក១៨ លេខ១៥។

**៨២.** វិ. ជំពូក៧១ លេខ៥៣។

**៨៣.** វិ. ជំពូក៦៤ លេខ១២។ 'ពេលអ្នកបានមុជទឹក(ត្រូវ)ក្បាលហើយ' គួរត្រូវកន្លែងផ្សេងទៀត ហើយ(តាមកុល្ល. និង រាឃ.) 'ពេលអ្នកដុសក្បាលនឹងប្រេងហើយ'។

**៨៤.** យញ្ញ. ជំពូក១ លេខ១៤០។

៨៥- ការលោបប្រេងម្តងគឺ (អាក្រក់) ស្មើនឹងសត្តឃាតដ្ឋានដប់កន្លែង, ការបើកតៀមស្រាមួយ គឺ (អាក្រក់)ស្មើនឹងការលោបប្រេងដប់ដង, ការបើកបនស្រីមួយ(អាក្រក់)ស្មើនឹងការបើកតៀមស្រាដប់, ព្រះរាជាមួយ(អាក្រក់)ស្មើនឹងបនស្រីដប់។

៨៦- ព្រះរាជា ត្រូវគេចាត់ទុក(អំពើឃោរឃៅ)ស្មើនឹងអ្នកសម្លាប់សត្វ ដែលមានកន្លែងសម្លាប់សត្វរាប់រយពាន់ ហើយការទទួលអំណោយពីស្តេច គឺជា(ឧក្រិដ្ឋ)ធ្ងន់ធ្ងរ។

៨៧- អ្នកដែលទទួលអំណោយពីព្រះរាជាលោភលន់ ដែលប្រព្រឹត្តផ្ទុយពីគោលការណ៍ (ច្បាប់ពិសិដ្ឋ) នឹងធ្លាក់នរកចំនួនម្ភៃមួយកន្លែងជាប់គ្នាដូចជា៖

៨៨- នរកតាមិស្រ, អន្ធតាមិស្រ, មហារៅរវ, រៅរវ, កាលសូត្រ, មហានរក,

៨៩- សំឃិវន, មហាវិកិ, តបន, សំប្រាតិបន, សំឃាត, សកាកោល, កុដមល, បូតិម្ឫត្តិក,

៩០- លូហសង្គ, ឫគិស, បបិន, ទន្លេ(ភ្លើង), សាល្មល, អសិបត្របន និងលោហការក។

៩១- ព្រាហ្មណ៍មានចំណេះដឹងជ្រៅជ្រះដែលដឹងថាអ្នកដែលសិក្សាព្រះវេទ និងចង់បានពរជ័យក្រោយពេលស្លាប់ មិនទទួលអំណោយពីព្រះរាជាទេ។

៩២- ចូរអ្នកកុំភ្ញាក់ឡើងក្នុង*មុហូរត* ចូរបូជាចំពោះព្រាហ្មណ៍ និងគិត (ចង់បាន) កុសលផ្នែកព្រលឹងវិញ្ញាណ និងទ្រព្យ គិតពីការបាក់កម្លាំងកាយចាប់ពីពេលនោះ និងគិតពីអត្ថន័យពិតនៃព្រះវេទ។

៩៣- ប្រសិនបើអ្នកបានក្រោកឡើង បានសម្រាលនូវភាពចាំបាច់នៃធម្មជាតិ និងប្រុងប្រយ័ត្នបន្សុទ្ធកាយចិត្តរបស់ខ្លួនចូរអ្នកឈរក្នុងអំឡុងពេលព្រឹកមិនទាន់មានពន្លឺថ្ងៃ សូត្រធម៌(គាយត្រី) ខ្សឹបៗឱ្យបានយូរ ហើយតាមពេលវេលាសមស្រប (អ្នកត្រូវតែធ្វើដូចនេះដដែល) នៅពេលល្ងាច។

៩៤- ដោយការបន្តប្រតិបត្តិធម៌ពេលព្រះអាទិត្យអស្តង្គត បណ្ឌិតបានទទួលអាយុវែង មានគតិបណ្ឌិត កិត្តិយស កេរ្តិ៍ឈ្មោះ និងមានចំណេះដឹងឥតខ្ចោះផ្នែកវេទ។

៩៥- ដោយបានប្រតិបត្តិ*ឧបាករម៍ន* ស្របតាមតម្រាបញ្ញត្តិនៅថ្ងៃ *ស្រាវណៈ* (ខែព្រះច័ន្ទពេញវង់) ឬនៅថ្ងៃពេញបូណ៌មីខែ*ប្រោស្ថបទ*(ភាទ្របទ)ព្រាហ្មណ៍គួររៀរាំងសិក្សាព្រះវេទក្នុងពេលបួនខែកន្លះ។

---

**៨៥.**យញ្ញ.ជំពូក១លេខ១៤១។មេធ.,គោវ.,នារ.និងនន្ទ.និយាយថា'ព្រះរាជាមួយអាក្រក់ស្មើនឹងស្រីពេស្យាដប់' (វេស្យា)។

**៨៨-៩០.** វិ. ជំពូក៤៣ លេខ២-២២។ នារ. និងគោវ. និយាយយ៉ាងច្បាស់ថា *នរកំ កាលសូត្រំ ក* មានន័យថា 'នរកកាលសូត្រ' ហើយនារ. ថា *វៃតរណី* ត្រូវគេយល់ថា *នទី* 'ទន្លេ' ចំណែកឯគោវ. និយាយអំពីនរក ថា *នទី* 'ទន្លេ'។ វគ្គពាក់ព័ន្ធនៅក្នុងគម្ពីរវិស្ណុ បង្ហាញថា *ទីបនទី* ត្រូវសំដៅដល់នរក។ អត្ថបទបោះពុម្ព អាន *សំហាត* ជំនួយពាក្យ *សំឃាត,* ពាក្យ *សាល្មលី* ជំនួសពាក្យ *សាល្មល*ហើយពាក្យ *លោហទារក* ដែលរាឃ.ប្រើ ក៏ជំនួសពាក្យ*លោហការក*។

**៩២.** វស. ជំពូក១២ លេខ៤៧; វិ. ជំពូក៦០ លេខ១។ កុល្ល. និងរាឃ. និយាយថា 'នៅក្នុង*មុហូរត* ដែលពិសិដ្ឋ ចំពោះព្រាហ្មី' ឬភារតី ជាទេពធីតាផ្នែកនិយាយស្តី។ ប៉ុន្តែការបកស្រាយនេះ មិនត្រឹមត្រូវទេ ព្រោះសំនួនពាក្យ *ប្រាគាបត្យ មុហូរត* មានប្រើនៅក្នុងស្ម្រិតិផ្សេងទៀត។

**៩៣.** វិ. ជំពូក៧១ លេខ៧៧។

**៩៤.** ខ្ញុំអានតាមលោកគោវ., នន្ទ. និង K. *អាប្នុវេ* 'ដែលបានទទួល' ជំនួស *អាប្នុយុះ* (មេធ., កុល្ល., នារ., រាឃ.)។

**៩៥.** អាប. ជំពូក១ លេខ៩, ១-៣, ១០, ២; គោត. ជំពូក១៦ លេខ១-២, ៤០; វស. ជំពូក១៣ លេខ១-៥; ពោធ. ជំពូក

៩៦- នៅថ្ងៃ-បុស្ស(នៃខែ*ពោស*)ឬថ្ងៃទីមួយ ខែមាឃព្រះច័ន្ទភ្លឺពាក់កណ្ដាល ព្រាហ្មណ៍គួរធ្វើ *ឧត្សរគន* នៃព្រះវេទនៅមុនថ្ងៃត្រង់។

៩៧- ដោយបានធ្វើឧត្សរគនៅខាងក្រៅ(ភូមិ) តាមបញ្ញត្តិជាគោលការណ៍(ច្បាប់ពិសិដ្ឋ) អ្នកគួរឈប់អានក្នុងអំឡុងពីរថ្ងៃពីរយប់ ឬក្នុងអំឡុងថ្ងៃ(ឧត្សរគ) និងយប់(បន្ទាប់)។

៩៨- តមកអ្នកគួរយកចិត្តទុកដាក់សូត្រព្រះវេទក្នុងរាត្រីខែភ្លឺ (ពាក់កណ្ដាលខែ) និងសិក្សាយ៉ាងត្រឹមត្រូវនូវអង្គព្រះវេទទាំងអស់ ក្នុងអំឡុងពីរសប្ដាហ៍រាត្រីខែងងឹត។

៩៩- ចូរអ្នកកុំសូត្រ(អត្ថបទ)ប្រហូកប្រហល់ កុំសូត្រក្នុងវត្តមានរបស់សូទ្រៈ ហើយចូរអ្នកកុំចូលទៅដេកម្ដងទៀត ប្រសិនបើអ្នកអស់កម្លាំងក្នុងការសូត្រព្រះវេទនៅពេលជិតភ្លឺ។

១០០- យោងតាមវិធានដែលបានប្រកាសខាងលើ ចូរអ្នកសូត្រមន្តខ្លះប្រចាំថ្ងៃ ហើយព្រាហ្មណ៍ដែលមានសេចក្ដីព្យាយាម មិនស្ថិតក្នុងគ្រោះអាសន្ន (គួរសិក្សា)គម្ពីរព្រាហ្មណ៍ និងមន្ត្រសំហិតា។

១០១- ចូរអ្នកសិក្សាអ្នកដែលមិនចូលចិត្ត(អាន)នៅក្នុងគ្រាដែលការសិក្សាព្រះវេទត្រូវបានហាមឃាត់ ហើយ(ចូរ)អ្នកដែលបង្រៀនកូនសិស្សស្របតាមវិធានដែលបានរៀបរាប់ (ចូរធ្វើចុះ)។

១០២- អ្នកទាំងឡាយដែលចេះ(ក្បួន)សូត្រ ប្រកាសថា នៅរដូវវស្សា គេត្រូវបញ្ឈប់ការសិក្សាព្រះវេទក្នុង(ឱកាស)ទាំងពីរ គឺនៅពេលយប់មានឮសូរខ្យល់ខ្លាំង និងនៅពេលថ្ងៃមានខ្យល់កួចធូលីឡើង។

១០៣- មនុ បានបញ្ជាក់ថា ពេលផ្លេកបន្ទោរ ផ្គររន្ទះ និងភ្លៀង (មកជាមួយគ្នា) ឬនៅពេលអាកាសបាតុភូតក្រហមឆ្អៅនៅគ្រប់ទិស គេត្រូវផ្អាកការសូត្រនោះ រហូតដល់ម៉ោងដដែល(នៅថ្ងៃបន្ទាប់ចាប់ពីថ្ងៃកើតព្រឹត្តិការណ៍នោះ)។

១០៤- នៅពេលគេសង្កេតមើលឃើញ(បាតុភូត)ទាំងអស់នេះ(នៅពេលយប់) បន្ទាប់ពីព្រះអគ្គីពិសិដ្ឋត្រូវបានឆេះសន្ធោសន្ធៅ (សម្រាប់ធ្វើអគ្និហោត្រ) បន្ទាប់មកគេត្រូវចេះសូត្រព្រះវេទទប់កុំឲ្យរលត់ ហើយពពកក៏រសាត់បាត់ទៅតាមកាលដ៏គួរ។

១០៥- នៅ(ពេលមាន)ឮសំឡេងអភិធម្មជាតិពីលើមេឃ រញ្ជួយផែនដី និងពេលមានព្រះអាទិត្យបាំងឆ័ត្រ បាត់ពន្លឺពីឋានសួគ៌ ចូរអ្នកដឹងថា(ការសិក្សាព្រះវេទត្រូវតែ)បញ្ឈប់រហូតដល់ម៉ោងដដែល(នៅថ្ងៃបន្ទាប់) សូម្បីតែ(បាតុភូតទាំងនេះកើតឡើង)នៅរដូវ(វស្សា)ក៏ដោយ។

---

១ លេខ១២-១៦; វិ. ជំពូក៣០ លេខ១-២, ២៤-២៥; យញ្ញ. ជំពូក១ លេខ១៤២-១៤៤។ *ឧបាករម៉ន* ជាការបើកឆ្នាំសិក្សា សាលាព្រហ្មញ្ញយ៉ាងឧឡារិកនិងពាក្យ *ឧត្សរគន* ឬ *ឧត្សរគ* គឺការបិទឆ្នាំសិក្សាសាលានេះ។ ការបរិយាយរបស់ពួកគាត់មាននៅក្នុងគ្ឫហ្យ-សូត្រ, ឧទាហរណ៍ សាង្ខាយន ជំពូក៤ លេខ៥-៦។ ថ្ងៃ*បុស្ស* ជាថ្ងៃទីប្រាំមួយនៃ ខែច័ន្ទគតិ នីមួយៗពោលគឺ ខែ *ស្រាវណ,* ខែកក្កដា-សីហា; *ភាទ្របទ* ខែសីហា-កញ្ញា; *បុស* ខែធ្នូ-មករា; *មាឃ* ខែមករា-កុម្ភៈ។

**៩៧.** ប៉ុន្តែសូមមើលកាព្យលេខ១១៩ ខាងក្រោម។

**៩៨-១២៩.** អាប. ជំពូក១ លេខ៩, ៤-១១, ៣៨; ៣២, ១២-១៥; គោត. ជំពូក១ លេខ៥៨-៦០; ជំពូក១៦ លេខ៥-៤៩; វស. ជំពូក១៣ លេខ៦-៤០; ជំពូក១៨ លេខ១៣; ពោធ. ជំពូក១ លេខ២១, ៤-២២; វិ. ជំពូក៣០ លេខ៣-៣០; យញ្ញ. ជំពូក១ លេខ១៤៤-១៥១។

**១០០.** ʽមន្ត្រ(ខ្លះ)ប្រចាំថ្ងៃʼ គឺ ʽគាយត្រី និងផ្នែកខ្លះទៀតនៃ*ឫគ*, *យុគ*, និង*សាម*.ʼ។

១០៦- ប៉ុន្តែនៅពេលមានផ្លេកបន្ទោរ និងសំឡេងផ្គរលាន់ បន្ទាប់ពីព្រះអគ្គីពិសិដ្ឋត្រូវបានឆាបឆេះឡើង ការបញ្ឈប់គួររង់ចាំរហូតដល់ពេលមានពន្លឺ (ព្រះអាទិត្យ ឬតារា) ហើយប្រសិនបើនៅតែមាន (បាតុភូតភ្លៀងដូចរៀបរាប់ខាងលើ ការអានគួរតែបញ្ឈប់) ទាំងនៅពេលថ្ងៃ ទាំងនៅពេលយប់។

១០៧- ចំពោះអ្នកដែលចង់បាននូវកំពូលបុណ្យកុសលដ៏លើសលុប ការអាក់ខានការសិក្សាព្រះវេទជាបន្តបន្ទាប់ (នៅក្នុង)ភូមិ និងទីប្រជុំជន ហើយ (ការសិក្សាព្រះវេទត្រូវតែអាក់ខាន)ជានិច្ច នៅពេល(មានក្លិនមិនល្អ)ណាមួយកើតឡើង។

១០៨- នៅក្នុងភូមិ ដែលមានសាកសព មានមនុស្ស(ដែលរស់នៅមិនតាមគន្លងធម៌ ដូចជា)ពួកសូទ្រៈ ខណៈដែលឮ(សំឡេង)កំពុងយំ និងនៅក្នុងហ្វូងមនុស្ស គេត្រូវបញ្ឈប់(ការសូត្រព្រះវេទ)។

១០៩- នៅក្នុងទឹក ក្នុងអំឡុងពេលពាក់កណ្តាលយប់ ខណៈដែលអ្នកកំពុងបន្ទោរបង់ ឬបញ្ចេញគ្រឿងសៅហ្មង និងបន្ទាប់ពីអ្នកបានទទួលទានអាហារបូជាពេលល្ងាច អ្នកមិនត្រូវ សូម្បីគិតក្នុងចិត្ត ក៏មិនគួរគិតអំពី(ពាក្យពិសិដ្ឋ)ឡើយ។

១១០- ព្រាហ្មណ៍មានការចេះដឹងច្រើន មិនគួរសូត្រព្រះវេទ ក្នុងអំឡុងបីថ្ងៃ នៅពេលគេបានទទួលការអញ្ជើញឱ្យចូលរួម(ពិធីបូជា) ឧទ្ទិសដល់បុព្វបុរស(អេកោទទិស្ត) ឬនៅពេលព្រះរាជាមានភាពមិនបរិសុទ្ធ ដោយសារកំណើត ឬមរណភាពនៅក្នុងគ្រួសារទ្រង់(សូតកៈ) ឬនៅពេលរាហូចាប់ច័ន្ទ ធ្វើឱ្យព្រះច័ន្ទបាត់រស្មី។

១១១- ដរាបណាមានក្លិន និងស្នាមប្រឡាក់(អាហារដែលគេបូជា)ដល់ព្រលឹងបុព្វបុរស នៅជាប់នឹងខ្លួនប្រាណរបស់ព្រាហ្មណ៍អ្នកចេះដឹង ដ៏រាបនោះគេមិនត្រូវសូត្រព្រះវេទទេ។

១១២- ចូរកុំសិក្សាព្រះវេទអីខណៈដែលកំពុងដេកលើគ្រែខណៈដែលអ្នកលើកជើងផុតពី(កៅអី)ខណៈដែលអ្នកអង្គុយចោងហោងបន្តឹងក្បាលជង្គង់ និងនៅពេលអ្នកបានទទួលទានសាច់ ឬអាហារដែលបានពីមនុស្សមិនបរិសុទ្ធ នៅថ្ងៃកំណើត ឬថ្ងៃមរណភាព,

១១៣- ចូរកុំសិក្សានៅពេលចុះអ័ព្ទ កុំសិក្សានៅពេលឮសូរសំឡេងព្រួញក្នុងពេលអស្តង្គត ថ្ងៃមានព្រះច័ន្ទ ដំបូង នៅថ្ងៃទីដប់បួននិងថ្ងៃទីប្រាំបី (នៃពាក់កណ្តាលខែនីមួយៗ) ហើយកុំសិក្សានៅថ្ងៃព្រះ ច័ន្ទពេញវង់។

១១៤- ថ្ងៃមានព្រះច័ន្ទដំបូងញ៉ាំងឱ្យគ្រូវិនាស, ថ្ងៃទីដប់បួនធ្វើឱ្យសិស្សវិនាស, ថ្ងៃទីប្រាំបី និងថ្ងៃព្រះច័ន្ទពេញវង់ (ធ្វើឱ្យការចេងចាំ) ព្រះវេទទាំងអស់វិនាស ដូច្នេះចូរអ្នកជៀសវាង (កុំអាន) នៅថ្ងៃទាំងនោះ។

---

**១០៥.** មេធ. លើកឡើងនូវការបកស្រាយម្យ៉ាងទៀតចំពោះពាក្យ *ត្យោទិសាំ កោបសរគនេ*ពេលពន្លឺឋានសួគ៌បង្កភាពរឹករវដល់គ្នានឹងគ្នាʼ គឺធ្វើឱ្យងងឹតដល់គ្នាទៅវិញទៅមក ហើយលោកនារ., កុល្ល. និងរាឃ. ឱ្យន័យឃ្លានេះសំដៅដល់សូរ្យគ្រាស/ច័ន្ទគ្រាស។

**១០៧.** ដោងតាមកាព្យនេះ សូមមើលជាពិសេស ពោធ. ជំពូក២ លេខ៦, ៣៣-៣៤។

**១០៩.** មេធ. លើកឡើងនូវអត្ថបទផ្សេង *ឧទយេ* នៅពេលថ្ងៃរះʼ, ពាក្យ *ឧទកេ* ʽនៅក្នុងទឹកʼ។

**១១០.** តាមពិត សូរ្យគ្រាស ក៏ត្រូវរាប់បញ្ចូលដែរ។
**១១១.** ពាក្យ *វាណៈ* 'ព្រួញ' ក៏អាចមានន័យថា 'ពិណដ៏ធំ'។

១១៥- ព្រាហ្មណ៍មិនគួរសូត្រ(ព្រះវេទ) ក្នុងកំលុងពេលមានខ្យល់ព្យុះក្តួច ខណៈពេលមេឃក្រហមខុសពីធម្មតា ពេលឆ្កែព្រៃស្រែកលូ ពេលឆ្កែព្រួស ពេលសត្វលាស្រែកកញ្ជ្រៀវ ឬពេលគេឮសំឡេងសត្វអូដ្ឋស្រែក ហើយកុំសិក្សា ខណៈពេលដែល(ខ្លួនអង្គុយជាមួយ)ក្នុងចំណោម។

១១៦- ចូរអ្នកកុំសិក្សានៅក្បែរកន្លែងកប់ខ្មោច នៅជិតភូមិ ទ្រុងគោ នៅពេលគ្មានសម្លៀកបំពាក់ខណៈពេលរួមភេទ ហើយកុំសិក្សាបន្ទាប់ពីទទួលអំណោយក្នុងពិធីយញ្ញ។

១១៧- បើជាសត្វ ឬរបស់គ្មានជីវិត អ្វីក៏ដោយដែលជា(អំណោយ)នៅឯពិធីស្រាទ្ធ ចូរអ្នកកុំសូត្រព្រះវេទ បន្ទាប់ពីបានទទួលអំណោយភ្លាម ព្រោះថាដៃរបស់ព្រាហ្មណ៍គឺជាមាត់របស់ខ្លួន។

១១៨- នៅពេលចោរប្លន់បានឡោមព័ទ្ធភូមិ និងនៅពេលមានសញ្ញាអាសន្នគ្រោះអគ្គីភ័យ ចូរអ្នកដឹងថា (ការសិក្សាព្រះវេទត្រូវ)ឈប់ រហូតដល់ម៉ោងដដែល(នៅថ្ងៃបន្ទាប់) និងនៅពេលមានប្រផ្នូលទាំងអស់។

១១៩- អ្នកត្រូវបញ្ឈប់ការសិក្សា (ព្រះវេទ) រយៈពេលបីថ្ងៃដូចបានរៀបរាប់ នៅពេល(មាន) *ឧបាករម័ន* និង *វេទោត្សគេ* និងនៅពេល *អស្តកា* និងនៅយប់ចុងក្រោយនៃរដូវកាល ទាំងយប់ទាំងថ្ងៃ។

១២០- ចូរអ្នកកុំសូត្រព្រះវេទនៅលើខ្នងសេះ លើដើមឈើ លើដំរី នៅក្នុងទូក(ឬនាវា) លើលា លើអូដ្ឋ និងកុំសិក្សានៅពេលកំពុងឈរលើដីគ្មានជីជាតិ និងនៅលើរទេះដឹកទំនិញ។

១២១- កុំសិក្សាក្នុងពេលមានទំនាស់ពាក្យសម្តី ក្នុងពេលឈ្លោះគ្នាទៅវិញទៅមក ក្នុងជំរុំ ក្នុងសមរភូមិ និងកុំសិក្សានៅពេលអ្នកទើបបានទទួលទាន ក្នុងពេលកំពុងឆ្អែតចាក់ប្រាស់ បន្ទាប់ពីក្អួត និងភើចេញក្លិនជូរ។

១២២- កុំសិក្សា ដោយមិនបានការអនុញ្ញាតពីភ្ញៀវ(ដែលកំពុងស្នាក់ក្នុងផ្ទះខ្លួន) កុំសិក្សាខណៈពេលមានខ្យល់បក់យ៉ាងខ្លាំង កុំសិក្សាខណៈពេលមានឈាមហូរចេញពីរាងកាយ កុំសិក្សានៅពេលត្រូវរបួសដោយអាវុធណាមួយ។

១២៣- ចូរអ្នកកុំសូត្រឫគ-វេទ ឬយគុ-វេទ ខណៈពេលឮសំឡេង *សាម័ន* (ភ្លេងពីរោះ), (ចូរអ្នកបញ្ឈប់ការសិក្សាព្រះវេទទាំងអស់រយៈពេលមួយថ្ងៃមួយយប់) បន្ទាប់បញ្ចប់ព្រះវេទ ឬបន្ទាប់ពីសូត្រ *អារណ្យកៈ*។

១២៤- ឫគ-វេទ ត្រូវបានប្រកាសថាជាការបូជាព្រះអាទិទេព, យុគ-វេទ គឺសម្រាប់មនុស្ស ហើយសាមវេទ សម្រាប់ពួកអមនុស្ស ហេតុនេះសំឡេងរបស់អ្នកក្រោយនេះមានភាពសៅហ្មង(ជាធម្មតា)។

---

**១១៥.** *បង្គតោ* នៅក្នុងចំណោមជាមួយគ្នា'(គោវ., កុល្លូ., នារ., អ្នកដទៃទៀត) ហើយយោងតាមមេធ., នារ. និងនន្ទ. ថា 'នៅក្នុងចំណោមសត្វឆ្កែ លា ឬអូដ្ឋ'។ នារ. បកស្រាយក្នុងន័យទីបីថា 'ក្នុងចំណោមមនុស្សអាក្រក់'(អបាង្គត្យ)។
**១១៧.** ពោលគឺជាបាបកម្មចំពោះការសូត្រព្រះវេទ បន្ទាប់ពីទទួលអំណោយក្នុងពិធីស្រាទ្ធ ដូចគ្នានឹងការសិក្សាក្រោយពីទទួលទានអាហារបុណ្យដែរ។

**១១៩.** *អស្តកា* គឺបី ឬបួនថ្ងៃសម្រាប់ពិធីអស្តកាស្រាទ្ធ ដែលអ្នកនិពន្ធផ្សេងៗប្រើខុសៗគ្នា សូមមើលស្នាដៃលោក Weber, Die Nakshatras ជំពូក២ លេខ៣៣៧។

**១២១.** នារ. ប្រែយ្លា *ន វិវាទេ ន កលហេ* ថា `កុំសិក្សាក្នុងពេលមានវិវាទបញ្ហាផ្លូវច្បាប់ និងក្នុងពេលវិវាទឈ្លោះគ្នា´។

**១២៤.** `គឺសៅហ្មង (តាមជាក់ស្តែង)´ គឺ `មិនមែនសៅហ្មងពិតប្រាកដទេ តែនៅពេលគេឮ គេមិនត្រូវសិក្សាទេ ក្នុងពេល

១២៥- ដោយដឹងច្បាស់បញ្ហានេះ អ្នកចេះដឹងមុនដំបូងរំលឹកឡើងវិញរាល់ថ្ងៃឱ្យបានត្រឹមត្រូវអំពីខ្លឹមសារនៃវេទទាំងបី ហើយបន្ទាប់មកសិក្សា(អត្ថបទ)ព្រះវេទ។

១២៦- ចូរដឹងថា (ការសិក្សាព្រះវេទត្រូវបាន)អាក់ខានមួយថ្ងៃមួយយប់ នៅពេលមានសត្វពាហនៈ កង្កែប ឆ្មា ឆ្កែ ពស់ ស្កា ឬកណ្តុរប្រែង ឆ្លងកាត់ចន្លោះ(គ្រូ និងកូនសិស្ស)។

១២៧- ចូរបុរសមានកំណើតពីរដង តែងតែប្រយ័ត្នក្នុងការអាក់ខានការសិក្សាព្រះវេទពីរ(ពេល)នៅពេលកន្លែងដែលខ្លួនសូត្រនោះមិនបរិសុទ្ធ និងនៅពេលខ្លួនឯងមិនទាន់សម្អាតកាយ។

១២៨- បុរសមានកំណើតពីរដង ដែលជាស្នាតកៈ គួររក្សាភាពបរិសុទ្ធនៅថ្ងៃព្រះច័ន្ទរះជាថ្មី នៅថ្ងៃទី៨ (ថ្ងៃច័ន្ទគតិនៃពាក់កណ្តាលខែនីមួយៗ) នៅថ្ងៃព្រះច័ន្ទពេញវង់ និងនៅថ្ងៃទីដប់បួន សូម្បី (បើថ្ងៃនោះត្រូវចំពេល(ល្អសម្រាប់ការរួមសង្វាសក៏ដោយ)។

១២៩- ចូរអ្នកកុំមុជទឹកក្រោយពេលបាយ(ហើយភ្លាម) កុំមុជទឹកនៅពេលឈឺ កុំមុជទឹកនៅកណ្តាលយប់ កុំស្លៀកពាក់ខោអាវទាំងអស់ជារឿយៗ និងកុំមុជទឹកក្នុងស្រះ ដែលខ្លួនមិនស្គាល់ច្បាស់។

១៣០- ចូរអ្នកកុំដើរដោយចេតនាជាន់លើស្រមោល(រូបព្រះអាទិទេព) គុរុ ព្រះរាជា ស្នាកតៈ គ្រូរបស់ខ្លួន សត្វសម្បុរត្នោតក្រហមព្រឿងៗ ឬអ្នកដែលបានទទួលការបង្រៀនអំពីការធ្វើពិធីស្រោតៈ (ទីក្សិត)។

១៣១- នៅកណ្តាលថ្ងៃ និងកណ្តាលយប់ បន្ទាប់ពីទទួលទានសាច់នៅពិធីបុណ្យបាយល្ងាច និងនៅចន្លោះពេលថ្ងៃលិចនិងមុនថ្ងៃរះ ចូរអ្នកកុំនៅយូរនៅលើផ្លូវបំបែក។

១៣២- ចូរអ្នកកុំដើរជាន់ដោយចេតនាលើវត្ថុអ្វី ដែលសម្រាប់សម្អាតខ្លួន លើទឹកសម្រាប់មុជ លើទឹកនោម ឬលើលាមក លើឈាម លើសំបោ និងលើអ្វីដែលគេខាកស្តោះ ឬក្អួត។

១៣៣- ចូរអ្នកកុំស្តែងនូវចេតនាពិសេសចំពោះសត្រូវ មិត្តភ័ក្តិរបស់សត្រូវ មនុស្សអាក្រក់ ចោរឬភរិយារបស់អ្នកដទៃ។

---

មានអ្វីមួយសៅហ្មង ឬមនុស្សមិនល្អ´(មេធ.)។

**១២៥.** `ខ្លឹមសារ(ព្រះវេទ)ទាំងបី´ គឺមានព្យាង្គ ឱម និង គាយត្រី សូមមើលជំពូក២ លេខ៧៦-៧៧ ខាងលើ។

**១២៨.** វិ. ជំពូក៦៩ លេខ១; វស. ជំពូក១២ លេខ២១។ យោងតាមអ្នកនិពន្ធផ្សេងទៀត ដែលមេធ.ស្រង់សម្តី បានឱ្យដឹងថា ពាក្យ *ព្រហ្មការី* ដែលត្រូវបានប្រែ `ព្រហ្មចារី´ សបញ្ជាក់ថា ស្នាតកៈ ក៏ត្រូវប្រព្រឹត្តឱ្យដូចជាកូនសិស្សផ្សេងទៀតដែរ។ មេធ. គិតទៀតថា អាចសំដៅដល់ការតមទឹកឃ្មុំ និងសាច់ផងដែរ។

**១២៩.** អាប. ជំពូក១ លេខ៣២, ៨; ពោធ. ជំពូក២ លេខ៦, ២៥; វិ. ជំពូក៦៤ លេខ៣-៤, ៦។ `មិនញ៉ើកញាប់´ គឺ `ក្នុងហេតុផលជាក់លាក់ប៉ុណ្ណោះ ដូចជាត្រូវប៉ះពាល់ដោយ*ចណ្ឌាល*។

**១៣០.** យញ្ញ. ជំពូក១ លេខ១៥២; វិ. ជំពូក៦៣ លេខ៤០។ លោកគោវ., កុល្ល., និងរាឃ. ប្រែពាក្យ *ពភ្រុ* 'សត្វពណ៌ត្នោតក្រហមព្រឿងៗ'ដោយមិនបានបកស្រាយច្បាស់ទេ។ លោកមេធ. គិតថា 'មេគោពណ៌ត្នោត' ឬ 'រុក្ខជាតិវល្លិ៍សោម'។ នន្ទ. ប្រកាន់យកការបកស្រាយខាងដើម ហើយនារ. ប្រែថា 'សត្វពណ៌ត្នោត'។

**១៣២.** វិ. ជំពូក៦៣ លេខ៤១; យញ្ញ. ជំពូក១ លេខ១៥២។ *អបស្នានំ* 'ទឹកសម្រាប់មុជ' ហើយតាមនារ. និងនន្ទ. ថា 'ទឹកសម្រាប់លាងសាកសព'។

១៣៤-ព្រោះនៅក្នុងពិភពលោកនេះ គ្មានអ្វីខាតអាយុច្រើនដូចការសន្ទនាដ៏អាមាស់ជាមួយភរិយាអ្នកដទៃនោះទេ។

១៣៥-ចូរអ្នកដែលប្រាថ្នាភាពរុងរឿង តាមពិតកុំស្អប់ក្សត្រិយ ពស់ និងព្រាហ្មណ៍អ្នកចេះដឹង ព្រោះពួកគេអន់ខ្លាំងណាស់។

១៣៦-ពីព្រោះវត្ថុទាំងបីនេះ ប្រសិនបើមិនផ្តល់ការគោរព អាចធ្វើឱ្យអ្នកវិនាសទាំងស្រុងបាន ហេតុនេះអ្នកឆ្លាតមិនត្រូវស្អប់ពួកគេ។

១៣៧-ចូរអ្នកកុំស្អប់ខ្លួនឯងចំពោះបរាជ័យក្នុងពេលកន្លងមក, ចូរអ្នកខិតខំស្វែងរកភាពប្រសើរឡើងរហូតដល់ជីវិតចុងក្រោយ ហើយកុំអស់សង្ឃឹមក្នុងការប្រឹងប្រែងនេះ។

១៣៨-ចូរអ្នកនិយាយអ្វីដែលជាការពិត, ចូរអ្នកនិយាយអ្វីដែលបង្កនូវភាពរីករាយ, ចូរអ្នកកុំនិយាយ ការពិតដែលមិនពេញចិត្តអ្នកដទៃ ហើយចូរអ្នកកុំនិយាយភូតកុហកដើម្បីបំពេញចិត្តអ្នកដទៃ នេះជាក្រឹត្យច្បាប់ដែលនៅជាធរមានជាអមតៈ។

១៣៩-(អ្វីដែល)ល្អ ចូរអ្នកស្តីថាល្អ ឬចូរអ្នកនិយាយតែពាក្យ 'ល្អ' ប៉ុណ្ណោះ ហើយចូរអ្នកកុំបង្កទំនាស់ឥតប្រយោជន៍ ឬកុំឈ្លោះទាស់ទែងជាមួយនរណាឱ្យសោះ។

១៤០- ចូរអ្នកកុំធ្វើដំណើរនៅពេលព្រឹកព្រលឹមពេក នៅពេលយប់ជ្រៅពេក នៅចំកណ្តាលថ្ងៃត្រង់ កុំធ្វើដំណើរជាមួយ(មនុស្ស)ដែលអ្នកស្គាល់ កុំធ្វើដំណើរម្នាក់ឯង និងកុំដើរជាមួយសូទ្រៈ។

១៤១- ចូរអ្នកកុំប្រមាថអ្នកដែលមានអវយវៈលើសឬមិនគ្រប់គ្រាន់ កុំប្រមាថអ្នកខ្វះចំណេះដឹង កុំប្រមាថ ចាស់ទុំ កុំមើលស្រាលអ្នកដែលគ្មានរូបសម្បត្តិល្អឬគ្មានទ្រព្យ និងកុំប្រមាថអ្នកដែលមានកំណើតតូចទាប។

១៤២-ព្រាហ្មណ៍ដែលខ្វះភាពបរិសុទ្ធ មិនត្រូវយកដៃខ្លួនទៅប៉ះមេគោ ព្រាហ្មណ៍ ឬព្រះអគ្គី ហើយបើចង់បានសុខភាពល្អ ចូរអ្នកកុំសម្លឹងមើលពន្លឺនៅលើមេឃ ខណៈដែលខ្លួនមិនបរិសុទ្ធ។

១៤៣-ប្រសិនបើអ្នកបានប៉ះរបស់ទាំងនេះ ក្នុងខណៈមិនបរិសុទ្ធ ចូរអ្នកយកដៃរបស់អ្នក ប្រោះទឹកទៅលើគ្រឿងវិញ្ញាណ អវយវៈទាំងអស់ និងផ្ចិតរបស់អ្នក។

---

**១៣៥-១៣៦.** យញ្ញ. ជំពូក១ លេខ១៥៣។

**១៣៧.** វិ. ជំពូក៧១ លេខ៧៦; យញ្ញ. ជំពូក១ លេខ១៥៣។

**១៣៨.** គោត. ជំពូក៩ លេខ៦៨; វិ. ជំពូក៧១ លេខ៧៣-៧៤; យញ្ញ. ជំពូក១ លេខ១៣២។

**១៣៩.** អាប. ជំពូក១ លេខ៣២, ១១-១៤; គោត. ជំពូក៩ លេខ១៩-២០; វិ. ជំពូក៧១ លេខ៥៧; យញ្ញ. ជំពូក១ លេខ១៣២; គោត. ជំពូក៩ លេខ៣២។ ពាក្យ 'ប៉ុណ្ណោះ' គឺ សូម្បីជាបញ្ហានោះខុសក៏ដោយ។ ខ្ញុំយកតាមការបកស្រាយរបស់

នារ. ដែលជាការប្រែត្រឹមត្រូវតែមួយគត់ គឺ *កទ្រំ វស្តុតោ យត្ខាកនំ / កទ្រំ ឥតិ អេវ វា `កទ្រំ អបិ`* (ចូរអ្នកស្តីថា) ល្អចំពោះអ្វីដែលពិតជាល្អ ឬ (ចូរអ្នកស្តីថា)ល្អ សូម្បីបញ្ហានោះមិនល្អក៏ដោយ'។

**១៤០.** ពោធ. ជំពូក២ លេខ៦, ២២-២៣; វ៉ិ. ជំពូក៦៣ លេខ៤, ៦-៧, ៩។

**១៤១.** វ៉ិ. ជំពូក៧១ លេខ៦២។

**១៤២.** យញ្ញ. ជំពូក១ លេខ១៥៥។

១៤៤- លើកលែងតែពេលឈឺ អ្នកមិនត្រូវប៉ះរន្ធប្រហោង(រូបកាយ)ដោយគ្មានហេតុផលទេ ហើយអ្នកត្រូវជៀសវាង (ប៉ះពាល់) សក់ត្រង់ (កន្លែង) ពិសិដ្ឋ។

១៤៥- ចូរអ្នកតាំងចិត្តប្រតិបត្តិតាម( ទំនៀមទម្លាប់ដែលនាំមកនូវ)ជោគល្អ និងក្បួនតម្រាក្រមសីលធម៌ យកចិត្តទុកដាក់ពីភាពបរិសុទ្ធនិងគ្រប់គ្រងឥន្ទ្រីយារម្មណ៍ទាំងអស់របស់ខ្លួន, ចូរអ្នកសូត្រ( ធម៌) ខ្សឹមៗ ហើយកុំនឿយហត់ក្នុងការបូជាព្រះអគ្គីរាល់ថ្ងៃ។

១៤៦- គ្មានគ្រោះចង្រៃណាកើតឡើងចំពោះអ្នកយកចិត្តទុកដាក់ប្រតិបត្តិទំនៀមទម្លាប់ល្អ និងក្រមសីលធម៌ ចំពោះអ្នកដែលតែងតែយកចិត្តទុកដាក់ពីភាពបរិសុទ្ធ និងអ្នកដែលសូត្រ (ធម៌ពិសិដ្ឋ) និងបូជាព្រះអគ្គីនោះទេ។

១៤៧- ចូរអ្នកកុំនឿយហត់ក្នុងការសូត្រព្រះវេទរាល់ថ្ងៃ តាមពេលវេលាសមស្រប ព្រោះបណ្ឌិតប្រកាសថាការងារនេះជាភារកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់អ្នក ហើយ( ការប្រតិបត្តិ)ដទៃទៀតទាំងអស់ ជាភារកិច្ចទីពីរប៉ុណ្ណោះ។

១៤៨- ដោយការសូត្រព្រះវេទរាល់ថ្ងៃ ដោយ( ការគោរពក្បួនតម្រា)ធ្វើកាយចិត្តឱ្យបរិសុទ្ធ ដោយការអនុវត្តតបៈធម៌ និងដោយការមិនបង្កបបួសស្នាមដល់សត្វមានជីវិត គេនឹងទទួលបាននូវញាណដែលចងចាំនូវកំណើតពីមុនៗ។

១៤៩- អ្នកដែលរលឹកឃើញការរស់នៅកន្លងមកខិតខំសូត្រព្រះវេទម្តងហើយម្តងទៀតនឹងទទួលពរជ័យគ្មានទីបំផុត ដោយការសិក្សាព្រះវេទជាប្រចាំ។

១៥០- ចូរអ្នកតែងតែបូជានៅថ្ងៃ*បវរ* ដល់*សាវិត្ត* និងដូចជាបញ្ចៀសប្រថ្នូលអាក្រក់ ហើយនៅថ្ងៃ*អស្តកា* និង *អន្វស្តក* ចូរអ្នកគោរពបូជាវិញ្ញាណក្ខន្ធបុព្វបុរសជាប្រចាំ។

១៥១- ចូរអ្នកបន្ទោរបង់តូច (និងធំ) ឱ្យឆ្ងាយពីកន្លែងស្នាក់នៅរបស់ខ្លួន ចូរ( អ្នកចោល)ទឹកដែលលាងជើងរួចឱ្យឆ្ងាយពីកន្លែងនៅ និងចោលអាហារសំណល់ និងទឹកសល់ពីមុជ ឱ្យឆ្ងាយពីកន្លែងនៅ។

១៥២- ចូរអ្នកបត់ជើងធំ តុបតែង(កាយរបស់អ្នក) មុជទឹកសម្អាតធ្មេញ លាបថ្នាំភ្នែក និងគោរពព្រះអាទិទេព នៅព្រឹកព្រលឹម។

---

**១៤៤.** វ៉ិ. ជំពូក៧១ លេខ៧៩។

**១៤៥.** វស. ជំពូក២៦ លេខ១៤។

**១៤៧.** គោត. ជំពូក៩ លេខ៧២។

**១៥០.** វ៉ិ. ជំពូក៧១ លេខ៨៦។ នន្ទ. អាន *សាវិត្រ្យា* 'ដោយ*សាវិត្រី* ចំពោះពាក្យ *សាវិត្រាន*សំដៅដល់*សាវិត្ត* ហើយនន្ទ. ផ្តល់ការបកស្រាយដូចគ្នា។

**១៥១.** អាប. ជំពូក១ លេខ៣១, ២-៣; គោត. ជំពូក៩ លេខ៣៩; យញ្ញ. ជំពូក១ លេខ១៥៣។ *អាវសថ* 'ការស្នាក់នៅរបស់អ្នក' ដែលតាមកុល្ល. ថា 'បន្ទប់សម្រាប់រក្សាព្រះអគ្គី'។ កុល្ល. បកស្រាយ *និសេកំ* 'ទឹកដែលចេញពីការមុជរបស់ខ្លួន' ដោយ 'ភាពមិនស្អាតមានច្រើន'។ គោវ. និងនន្ទ. អាន *ឧច្ឆិស្តាន្ននិសេកំ ក* និងប្រែពាក្យ *និសេក* ដោយ *ត្យាគ* 'ចាក់ចោលទៅ'។

**១៥២.** យោងតាមមេធ. អ្នកដទៃបានបកស្រាយ *មៃត្រំ* 'ការសម្អាត' ដោយ 'ការបម្រើពាក់ទាក់ល្អ' ឬ 'ការគោរពមិត្ត'។

១៥៣- ប៉ុន្តែនៅថ្ងៃ *បវ៌* ចូរអ្នកទៅទស្សនា(រូប)ព្រះអាទិទេព និងទៅសួរសុខទុក្ខព្រាហ្មណ៍ល្អៗ និងអ្នកដឹកនាំ(ប្រទេស)ព្រមទាំងគ្រូរបស់ខ្លួន ដើម្បីបានការគាំពារ។

១៥៤- ចូរអ្នកគោរពវន្ទាចំពោះមនុស្សគួរឱ្យគោរព (នៅពេលសួរសុខទុក្ខ) ចូរជូនកៅអីរបស់ខ្លួនដល់ពួកគាត់ ចូរអ្នកអង្គុយជិតពួកគាត់ដោយក្ដោបដៃចូលគ្នា ហើយនៅពេលពួកគាត់ចាកចេញ (ចូរអមដំណើរពួកគាត់) ដោយដើរពីខាងក្រោយពួកគាត់។

១៥៥- ចូរអ្នកកុំនឿយហត់ក្នុងការគោរពប្រណិបតន៍ ចំពោះអ្នកមានគុណធម៌ក្នុងមុខរបររបស់ខ្លួន ដែលស្របតាមតម្រាវិន័យទាំងស្រុង និងស្របតាមប្រពៃណីដ៏ពិសិដ្ឋ (ស្ម្រិតិ) ដែលជាឫសគល់នៃច្បាប់ពិសិដ្ឋ។

១៥៦- តាមរយៈការប្រព្រឹត្តល្អ អ្នកនឹងទទួលបានអាយុវែង តាមរយៈការប្រព្រឹត្តល្អមានកូនចៅតាមសេចក្ដីប្រាថ្នា តាមរយៈការប្រព្រឹត្តល្អ នឹងមានទ្រព្យមិនចេះសាបសូន្យ ហើយការប្រព្រឹត្តល្អជួយកំចាយ(ឥទ្ធិពល)ដែលជាសញ្ញាអាក្រក់។

១៥៧- ចំពោះអ្នកដែលប្រព្រឹត្តអាក្រក់ ត្រូវបានតិះដៀលក្នុងចំណោមមនុស្ស ទទួលវាសនាអាក្រក់ជាប្រចាំ សម្បូរជំងឺនិងអាយុខ្លី។

១៥៨- អ្នកដែលប្រព្រឹត្តតាមគន្លងគុណធម៌ មានសច្ចភាព និងរួចផុតពីការឈ្នានីស រស់នៅដល់រយឆ្នាំ ទោះបីអ្នកគ្មានភ័ព្វល្អទាំងស្រុងក៏ដោយ។

១៥៩- ចូរអ្នករវាំងកុំជៀសវាងនូវការងារដែលជោគជ័យពឹងផ្អែកលើអ្នកដទៃទាំងស្រុង ប៉ុន្តែចូរអ្នកស្វះស្វាស្វែងរកជោគជ័យ ដែលកើតចេញពីស្នាដៃរបស់ខ្លួន។

១៦០- អ្វីៗ ដែលពឹងផ្អែកលើអ្នកដទៃ (រមែងផ្ដល់នូវ)ការឈឺចាប់, អ្វីៗដែលពឹងផ្អែកលើខ្លួនឯង (ផ្ដល់នូវ) ភាពរីករាយ។ ចូរដឹងថា នេះជានិយមន័យខ្លីអំពីភាពរីករាយ និងការឈឺចាប់។

១៦១- ពេលធ្វើនូវអំពើល្អមួយដែលញ៉ាំងឱ្យបេះដូងរបស់អ្នករីករាយ ចូរអ្នកធ្វើវាដោយយកចិត្តទុកដាក់ ប៉ុន្តែចូរអ្នករវាំងប្រយ័ត្ននូវឧបសគ្គ។

១៦២- ចូរអ្នកកុំប្រមាថគ្រូដែលបានទទួលអ្នកជាសិស្ស កុំប្រមាថអ្នកដែលពន្យល់ព្រះវេទ កុំប្រមាថឪពុកម្ដាយរបស់អ្នក កុំប្រមាថគ្រូ(នានា) កុំប្រមាថមេគោ កុំប្រមាថព្រាហ្មណ៍ កុំប្រមាថអ្នកណាក៏ដោយដែលកំពុងធ្វើតបៈ។

---

**១៥៣.** អាប. ជំពូក១ លេខ៣១, ២១-២២។ លោកមេធ. លុបចោលកាព្យលេខ១៥៣-១៥៨។

**១៥៤.** ពោធ. ជំពូក២ លេខ៦, ៣៥។

**១៥៥.** វស. ជំពូក៧១ លេខ៩០; យញ្ញ. ជំពូក១ លេខ១៥៤។

**១៥៦.** វស. ជំពូក៦ លេខ៧; វិ. ជំពូក៧១ លេខ៩១។

**១៥៧.** វស. ជំពូក៦ លេខ៦។

**១៥៨.** វស. ជំពូក៦ លេខ៨; វិ. ជំពូក៧១ លេខ៩២។

**១៦១.** វិធាននេះ សំដៅដល់អំពើណាក៏ដោយ ឬករណីដែលមានជម្រើសណាមួយ សូមមើលជំពូក២ លេខ១២ខាងលើ។

**១៦២.**យញ្ញ. ជំពូក១ លេខ១៥៧-១៥៨។ *ន ហឹស្យាត* ʻចូរអ្នកកុំប្រមាថʼ(មេធ., កុល្ល., នារ., នន្ទ.) ហើយតាមគោវ. ថា

១៦៣-ចូរអ្នកជៀសវាងការមិនជឿអាទិទេពដោយបន្ទោសព្រះវេទទាំងមិនដឹងខុសត្រូវ ស្អប់ខ្ពើម មានកំហឹងទោសៈ ខ្វះភាពរាបសា ខ្វះការពេញចិត្ត និងមានភាពគ្រោតគ្រាតចំពោះព្រះអាទិទេព។

១៦៤-នៅពេលខឹង ចូរអ្នកកុំលើកដំបងចង្អុលអ្នកដទៃ កុំវាយ(នរណាមួយ)ឱ្យសោះ លើកលែងតែកូនប្រុសឬកូនសិស្ស ហើយអ្នកអាចវាយអ្នកទាំងពីរនោះបាន ដើម្បីកែលម្អពួកគេ។

១៦៥-អ្នកមានកំណើតពីរដង ដែលគ្រាន់តែបានគំរាមព្រាហ្មណ៍ ដោយចេតនា(ចង់ឱ្យគាត់)របួសផ្លូវកាយប៉ុណ្ណោះ នឹងធ្លាក់ទៅឋាននរក*តាមិស្រ* ប្រហែលមួយរយឆ្នាំ។

១៦៦-ដោយបានវាយព្រាហ្មណ៍ទាំងកំហឹង សូម្បីដោយដើមស្មៅក៏ដោយ អ្នកនឹងចាប់កំណើតក្នុងស្បូនម្ភៃមួយអត្តិភាព (ជាសភាវៈ ដែលចាប់កំណើតដើម្បីទទួលទណ្ឌកម្មនៃ) អំពើបាបរបស់ខ្លួន។

១៦៧-អ្នកដែលបានបង្ករបួសចេញឈាមពីរូបកាយរបស់ព្រាហ្មណ៍ ដែលមិនវាយប្រហារគេ នឹងទទួលរងទុក្ខមហាសែនឈឺចាប់ហួសប្រមាណ បន្ទាប់ពីស្លាប់។

១៦៨-(សត្វ)ដទៃនៅក្នុងភពបន្ទាប់នឹងបំផ្លាញអ្នកបង្កឱ្យមានការចេញឈាម ឱ្យក្លាយជាបំណែកតូចៗ ស្មើគ្នានឹងគ្រាប់ឈាមដែលហូរចេញពីដី ក្នុងអំឡុងពេលដ៏ច្រើនឆ្នាំ។

១៦៩-ហេតុនេះ មនុស្សឆ្លាត មិនគួរគំរាមកំហែងព្រាហ្មណ៍ មិនគួរវាយព្រាហ្មណ៍ សូម្បីដោយដើមស្មៅ និងមិនគួរបង្កឱ្យចេញឈាម(របស់ព្រាហ្មណ៍)ទេ។

១៧០-អ្នកដែល(រស់នៅ)ដោយមិនត្រឹមត្រូវ, អ្នកដែល(បាន)ទ្រព្យ(ដោយការនិយាយ) ភូតកុហក និងអ្នកដែលតែងតែចូលចិត្តបង្ករបួសស្នាម នឹងដែលបានទទួលសេចក្តីរីករាយនៅក្នុងលោកិយនេះឡើយ។

១៧១-ចូរអ្នក សូម្បីរងនូវការឈឺចាប់ដោយសារភាពត្រឹមត្រូវរបស់ខ្លួនក៏ដោយ ក៏មិនត្រូវប្រែចិត្តទៅប្រព្រឹត្តអំពើមិនត្រឹមត្រូវដែរ ព្រោះថាអ្នកគង់នឹងឃើញការវិនាសយ៉ាងឆាប់របស់មនុស្សអាក្រក់ដែលមិនចេះធ្វើល្អ។

១៧២-ភាពមិនត្រឹមត្រូវដែលកើតមាននៅក្នុងលោកិយនេះ មិនផ្តល់ផ្លែផ្ការបស់វាភ្លាមៗទេ ដូចជាមេគោ ប៉ុន្តែនឹងវិវត្តសន្សឹមៗ បីដូចអំពើនោះកាត់ផ្តាច់ឫសរបស់អ្នកប្រព្រឹត្តដូច្នោះដែរ។

---

ʻចូរអ្នកកុំធ្វើឱ្យពួកគេរងទុក្ខ សូម្បីពួកគេប៉ុនប៉ងយកជីវិតអ្នកក៏ដោយ ក៏អ្នកមានសិទ្ធិត្រឹមតែការពារខ្លួនʼ(សូមមើលជំពូក៣ លេខ៣៥០)។ តាមលោកមេធ. ពាក្យ *តបស្វិនៈ* មានន័យ ʻអ្នកទាំងឡាយដែលធ្វើតបៈʼ ឧ.ទា. សូម្បីអ្នកធ្វើអំពើបាបដែលធ្វើតបៈ (មេធ.) ចំណែកឯងអ្នកអធិប្បាយដទៃទៀត យល់ថាពាក្យនេះសំដៅដល់ ʻតាបស ឥសីʼ។

**១៦៣.** អាប. ជំពូក១ លេខ៣០, ២៥; វស. ជំពូក១៣, លេខ៤១; វិ. ជំពូក៧១ លេខ៨៣។ ខ្ញុំអានអ្នកអធិប្បាយទាំងអស់ជំនួសដោយពាក្យ *ទំភំ* ʻការលាក់ពុតʼហើយតាមមេធ., គោវ. និងនារ. ថា *ស្តំភំ* ʻត្រូវការភាពរមទម្យʼ ហើយតាមកុល្ល. ថា ʻត្រូវការថាមពលក្នុងការបំពេញភារកិច្ចʼ។

**១៦៤.** រ. ជំពូក៧១ លេខ៨១-៨២។ សូមមើលជំពូក៨ លេខ២៩៩-៣០០ ខាងក្រោម។

**១៦៥-១៦៧.** គោត. ជំពូក២១ លេខ២០-២១; យញ្ញ. ជំពូក១ លេខ១៥៥។

**១៧២.** 'ដូចជាមេគោ' គឺ 'ដែលផ្ដល់ប្រយោជន៍ជាទឹកដោះរបស់វាភ្លាមៗជាដើម'(គោវ., នារ., នន្ទ.)។ មេធ., កុល្ល. និង រ ឃ. ប្រែពាក្យ *គោវ* ថា 'ធរណី' គឺ 'ដែលមិនផ្ដល់ផលភ្លាមៗទេ' ប៉ុន្តែគាត់ក៏មានសរសេរដូចន័យទីមួយដែរ។ វាមិនអាចទេ ថា ពាក្យនេះត្រូវបានប្រែបានទាំងពីរយ៉ាង និងមិនអាចថា អ្នកនិពន្ធចង់ប្រើពាក្យ *សាធម្យ* ផង និង *វៃធម្យទ្រុស្តាន្ត* ផងទេ។

១៧៣- ប្រសិនបើ(ទោសមិនធ្លាក់)ទៅលើ(ជនល្មើស)ខ្លួនឯងទេ (វានឹងធ្លាក់)ទៅលើកូនរបស់គេ បើមិនធ្លាក់ទៅកូនទេ (យ៉ាងហោចណាស់)នឹងធ្លាក់លើចៅរបស់គេ ប៉ុន្តែអំពើអសីលធម៌ដែលគេ(ធ្លាប់)បានប្រព្រឹត្ត មិនដែលមិនឱ្យផលដល់អ្នកបានប្រព្រឹត្តនោះទេ។

១៧៤- គេអាចចម្រើនបានមួយភ្លែតដោយអំពើអាក្រក់ ពេលនោះគេទទួលនូវជោគវាសនាល្អ បន្ទាប់មកឈ្នះសត្រូវរបស់គេ ប៉ុន្តែ(ទីបំផុត)គេត្រូវវិនាស(ទាំងមែក និង)ឫស។

១៧៥- ចូរអ្នកតែងតែរីករាយនឹងអំពើល្អ (ប្រតិបត្តិតាម)ច្បាប់ពិសិដ្ឋ ក្រមសីលធម៌របស់ពួកអារ្យជន និងសុចរិតភាព ចូរអ្នកដាក់ទណ្ឌកម្មដល់សិស្សរបស់ខ្លួនស្របតាមច្បាប់ពិសិដ្ឋ ចូរអ្នកឱ្យគេគ្រប់គ្រងពាក្យសម្ដី ដៃ និងក្បាលរបស់គេ។

១៧៦- ចូរអ្នកជៀសវាង(ការទទួល)ទ្រព្យ និង(ការជាប់ជំពាក់)នឹងចំណង់របស់ខ្លួន ប្រសិនបើវាផ្ទុយនឹងច្បាប់ពិសិដ្ឋ ហើយសូម្បីអំពើស្របច្បាប់ដែលអាចបង្កការឈឺចាប់នៅថ្ងៃអនាគត ឬជាការប្រមាថចំពោះមនុស្សធូន់ធូរក៏ដោយ។

១៧៧- ចូរអ្នកកុំធ្វើចលនាដៃជើងឬភ្នែករបស់អ្នកដោយឥតប្រយោជន៍ កុំបត់ក្ងិកក្ងក់ កុំនិយាយឥតបានការ កុំបង្កអន្តរាយដល់អ្នកដទៃដោយអំពើ ឬដោយការគិតក៏ដោយ។

១៧៨- ចូរអ្នកដើរតាមមាគ៌ារបស់កំពូលមនុស្ស ដែលឪពុកនិងជីតារបស់អ្នកបានប្រកាន់យក ខណៈដែលអ្នកដើរតាមផ្លូវនោះ អ្នកនឹងមិនទទួលនូវគ្រោះថ្នាក់ឡើយ។

១៧៩- ពេលនៅជាមួយអាចារ្យពិធីការ ឬអ្នកបួស ជាមួយគ្រូ ជាមួយពូខាងម្ដាយ ភ្ញៀវ និងអ្នកក្នុងបន្ទុក ជាមួយទារក មនុស្សចាស់ និងមនុស្សឈឺ ជាមួយអ្នកចេះដឹង ជាមួយសាច់ញាតិខាងឪពុករបស់ខ្លួន ដែលមានទំនាក់ទំនងអាពាហ៍ពិពាហ៍ និងសាច់ញាតិខាងម្ដាយ,

១៨០- ពេលនៅជាមួយឪពុក និងម្ដាយរបស់ខ្លួន ជាមួយសាត់ញាតិជាស្ត្រី ជាមួយបងប្អូនប្រុស ជាមួយកូនប្រុសនិងភរិយា ជាមួយកូនស្រីនិងអ្នកបម្រើរបស់ខ្លួន ចូរអ្នកកុំឱ្យមានជម្លោះ។

១៨១- ប្រសិនបើអ្នកប្រយ័ត្នកុំឱ្យមានជម្លោះជាមួយមនុស្សទាំងអស់នេះ អ្នកនឹងរួចរំដោះពីបាបកម្មទាំងអស់ហើយដោយជម្នះបាននូវ(ជម្លោះ)ទាំងអស់នេះយរាវាសគ្រប់គ្រងអ្នកនូវឋានដូចខាងក្រោម។

---

**១៧៥.** គោត. ជំពូក៩ លេខ៥០, ៦៨-៦៩។

**១៧៦.** គោត. ជំពូក៩ លេខ៤៧, ៧៣; រ. ជំពូក៧១ លេខ៨៤-៨៥; យញ្ញ. ជំពូក១ លេខ១៥៦។ ដូចជាតួយ៉ាងនៃ 'អំពើស្របច្បាប់ ដែលបង្កឱ្យមានការឈឺចាប់ក្នុងពេលអនាគត' លោកមេធ. លើកហេតុផលដូចជា 'ការបរិច្ចាគទ្រព្យទាំងអស់របស់ខ្លួន'។

**១៧៧.** ផ្នែកចុងក្រោយនៃកាព្យនេះ 'កុំបង្ករបួសស្នាមដល់អ្នកដទៃជាដើម' ក៏អាចឱ្យគេប្រែបានថា 'ចូរអ្នកកុំមានចេតនាធ្វើអំពើ (ដែលគិតថា)មានរបួសដល់អ្នកដទៃ'។

**១៧៩-១៨៤.** យញ្ញ. ជំពូក១ លេខ១៥៧-១៥៨។
**១៧៩.** *វិទ្យាត់:* 'ជាមួយអ្នកចេះដឹង' អាចមានន័យ 'ជាមួយគ្រូទេព្យ'ក៏បាន។
**១៨១.** ជំនួសពាក្យ *អេវៃ គិតៃ ក* 'ដោយការខំទប់វិវាទបែបនេះ(ទាំងអស់)' (មេធ., គោវ., កុល្ល., រាឃ.) ហើយនារ. និង នន្ទ. អាន *អេវៃ គិត ក* 'ដោយបណ្ដោយខ្លួនឱ្យចុះចាញ់មនុស្សទាំងនេះ' គឺ 'ដោយសុខចិត្តទ្រាំជាមួយមនុស្សទាំងនេះ'។ អំណាននេះ ទោះបីមានអំណះអំណាងបញ្ជាក់ច្រើនក្ដី ក៏ទំនងជាគួរឱ្យទុកចិត្តជាងគេ។

១៨២- គ្រូ ជាព្រះនៃភពព្រហ្ម, ឪពុកមានអំណាចលើសភពព្រះបង្កើតលោក(ប្រគាបតិ), ភ្ញៀវគ្រប់គ្រង លើឋានព្រះឥន្ទ្រ ហើយអាចារ្យ កាន់កាប់ឋានទេវៈ។

១៨៣- សាច់ញាតិជាស្ត្រី (មានអំណាច)លើឋាន*អប្សរ*, ញាតិខាងម្ដាយមានអំណាចលើឋាន*វិស្វេ ទេវា*, ញាតិដោយចំណងអាពាហ៍ពិពាហ៍ (មានអំណាច) លើពិភពទឹក, ម្ដាយនិងពូខាងម្ដាយ (មាន អំណាច)លើផែនដី។

១៨៤- ទារក មនុស្សចាស់ អ្នកក្រនិងអ្នកឈឺ ត្រូវគេចាត់ទុកជាអ្នកដឹកនាំឋានកណ្ដាល, បងប្រុសស្មើ នឹងឪពុក, ភរិយានិងកូនរបស់ខ្លួនស្មើនឹងរូបកាយផ្ទាល់របស់ខ្លួន។

១៨៥- ទាសាទាសីរបស់អ្នកដូចជាស្រមោលរបស់អ្នក, កូនស្រីអ្នកបីដូចជាភាពផ្អែមល្ហែមបំផុត ហេតុ នេះប្រសិនបើ(នរណាម្នាក់ក្នុងចំណោម)អ្នកទាំងនេះប្រមាថអ្នក នោះអ្នកត្រូវទទួលដោយគ្មាន ការអាក់អន់ចិត្ត។

១៨៦- ថ្វីបើ(ដោយសារការសិក្សា និងភាពខ្ពង់ខ្ពស់របស់អ្នក) អ្នកអាចមានសិទ្ធិទទួលអំណោយបាន ចូរអ្នកកុំប្រកាន់ខ្ជាប់(ខ្លាំងពេក)ចំពោះ(ទម្លាប់)នោះ ព្រោះតាមរយៈការទទួលអំណោយ(ជា ច្រើន) ពន្លឺដ៏ល្អផូរផង់នៅក្នុងខ្លួនអ្នក នឹងត្រូវបាត់បង់យ៉ាងឆាប់។

១៨៧- ដោយគ្មានចំណេះដឹងពេញលេញអំពីក្បួនតម្រាដែលបានបញ្ញត្តិដោយច្បាប់ពិសិដ្ឋសម្រាប់ការ ទទួលអំណោយទេ អ្នកឆ្លាតគួរកុំទទួលយកអី សូម្បីអ្នកអាចសោកសង្រេងនឹងការចង់បានខ្លាំង ក៏ដោយ។

១៨៨- ប៉ុន្តែ(មនុស្ស)ល្ងង់ ដែលទទួលមាស ដីធ្លី សេះ មេគោ អាហារ សម្លៀកបំពាក់ គ្រាប់ល្ង (ឬ) ប៊ឺ សុទ្ធ ត្រូវក្លាយជាផេះ ដូចជា(កម្ទេច)ឈើ។

១៨៩- មាសនិងអាហារបំផ្លាញអាយុវែងរបស់ខ្លួន, ដីធ្លីនិងមេគោ(បំផ្លាញ)រូបកាយខ្លួន, សេះ(បំផ្លាញ) ចក្ខុប្រសាទ, សម្លៀកបំពាក់(បំផ្លាញ)ស្បែក, ប៊ឺសុទ្ធ(បំផ្លាញ)ថាមពល, គ្រាប់ល្ង(បំផ្លាញ)កូន ចៅរបស់ខ្លួន។

១៩០- ព្រាហ្មណ៍ដែលមិនធ្វើតបៈដ៏តឹងរ៉ឹង និងមិនសិក្សាព្រះវេទ ហើយនៅតែសប្បាយរីករាយក្នុងការ ទទួលអំណោយ នឹងធ្លាក់(នរកជាមួយអ្នកបរិច្ចាគ) បីដូច(អ្នកដែលប៉ុនប៉ងឆ្លងទន្លេ)ដោយជិះ ទូកធ្វើពីថ្ម (នឹងលិច)ក្នុងទឹកដូច្នោះដែរ។

១៩១- ហេតុនេះ(មនុស្ស)ល្ងង់នឹងមិនក្រោតក្រែងក្នុងការអំណោយណាមួយទេ ព្រោះដោយហេតុផល នៃ(អំណោយ)ដ៏តិចតួច ញ៉ាំងឱ្យមនុស្សល្ងង់ធ្លាក់(នរក) ដូចមេគោជាប់ផុងក្នុងភក់ជាដើម។

១៩២- (មនុស្ស)ដែលច្បាប់មិនគួរផ្តល់សូម្បីតែទឹកឱ្យដល់ព្រាហ្មណ៍ ដែលប្រព្រឹត្តដូចជាសត្វឆ្មា ដល់ព្រាហ្មណ៍ ដែលប្រព្រឹត្តដូចជាសត្វក្រសារ ដល់ព្រាហ្មណ៍ ដែលគ្មានចំណេះដឹងពីព្រះវេទ។

**១៨៦.** វិ. ជំពូក៥៧ លេខ៦-៧។
**១៨៧.** វិ. ជំពូក៥៧ លេខ៨។
**១៨៨.** យញ្ញ. ជំពូក១ លេខ២០១។
**១៩២.** វិ. ជំពូក៩៣ លេខ៧។

១៩៣- ទោះបី(បុគ្គល)ទាំងបីប្រភេទនេះបាននូវទ្រព្យ ស្របតាមក្បួនតម្រាកំណត់ក៏ដោយក៏ញ៉ាំងឱ្យទាំងអ្នកផ្តល់ និងអ្នកទទួលរងទុក្ខវេទនានៅជាតិក្រោយដែរ។

១៩៤- ឧបមាដូចអ្នកដែល(ប៉ង)ឆ្លងកាត់ទឹក ដោយជិះទូកថ្មនឹងលិច(ចុះក្រោម)ដូច្នេះ បរិច្ចាគដ៏ល្ងង់ និងអ្នកទទួលដ៏ល្ងីល្ងើ នឹងលិចលង់ដូចគ្នា។

១៩៥- (នរជន) ដ៏ល្មោភ ដែលលើកទង់គុណធម៌ (ដែលជា)អ្នកលាក់ពុត ជាអ្នកឆបោកអ្នកដទៃ មានចេតនាធ្វើឱ្យខូចប្រយោជន៍ (និង)អ្នកបំផ្លាញ(គុណធម៌)របស់មនុស្សទាំងអស់ គេប្រាកដជាអ្នកដែលធ្វើខ្លួនឱ្យជាសត្វឆ្មា។

១៩៦- នោះ ព្រាហ្មណ៍ណាដែលមានអារម្មណ៍គ្មានមេត្តា មានចេតនាតែម្យ៉ាងឱ្យសម្រេចបំណងផ្ទាល់ខ្លួន គ្មានសេចក្តីស្មោះត្រង់ និងធ្វើជាសុភាពក្លែងក្លាយ គឺជាមនុស្សដែលធ្វើឫកដូចសត្វក្រសារ។

១៩៧- ព្រាហ្មណ៍ណាដែលធ្វើឫកដូចសត្វក្រសារ និងព្រាហ្មណ៍ណាដែលបង្ហាញនូវលក្ខណៈ ដូចជាសត្វឆ្មានឹងទទួលផលវិបាកនៃអំពើអាក្រក់នោះ ដូចគ្នានៅ(ឋាននរក ដែលមានឈ្មោះថា) *អន្ធតាមិស្រ* ។

១៩៨- បើសិនជាអ្នកបានប្រព្រឹត្តបាបកម្មមួយ ចូរអ្នកកុំធ្វើតបៈធម៌ ក្នុងលេស (ថាជាអំពើចង់បាន)នូវគុណធម៌ខាងព្រលឹងវិញ្ញាណ (ធ្វើដូច្នេះ) ដោយលាក់បាំងអំពើបាបរបស់ខ្លួនក្រោម (លេស) នៃពាក្យសត្យ និងប្រោកប្រាសស្ត្រី និងពួកសូទ្រៈ។

១៩៩- អ្នកចេះបកស្រាយព្រះវេទនិងពាក្យសត្យ ធ្វើការតិះដៀលព្រាហ្មណ៍បែបនេះបន្ទាប់ពីស្លាប់ និងនៅក្នុង(ជាតិ) នេះ ហើយព្រាហ្មណ៍ប្រភេទនេះនឹងធ្លាក់នរក *រាក្សសៈ*។

២០០- អ្នកដែលមិនមែនជាសិស្ស ធ្វើការចិញ្ចឹមជីវិតខ្លួនដោយ (ការស្លៀកពាក់) សម្លៀកបំពាក់ជាកូនសិស្ស នឹងទទួលកំហុសរបស់សិស្ស(ទាំងអស់) ហើយចាប់កំណើតលើកក្រោយក្នុងស្បូនរបស់សត្វ។

២០១- ចូរអ្នកកុំមុជទឹកក្នុងអាងរបស់អ្នកដទៃ បើសិនជាអ្នកមុជ(របៀបនោះម្តង) អ្នកនឹងទទួលទោសមួយចំណែករបស់ម្ចាស់អាងនោះ។

**១៩៥.** វិ. ជំពូក៩៣ លេខ៨។
**១៩៦-២០០.** វិ. ជំពូក៩៣ លេខ៩-១៣។

**១៩៦.** ខ្ញុំបានប្រែពាក្យ *ពក* ឬ *វក* ថា 'សត្វក្រសារ' ដូចជាពាក្យ *ពក្លា* ដែលជាពាក្យសម័យទំនើបសំដៅសត្វនេះ ក៏គេនៅប្រើឈ្មោះសត្វក្ងពណ៌-ស និងសត្វកុក។ ប៉ុន្តែតាមកាព្យផ្សេងទៀត ដែលនិយាយពីសត្វក្រសារ ដែលដើរយ៉ាងប្រុងប្រយ័ត្ននៅក្នុងទឹក ហាក់ដូចជាវាខ្លាចឱ្យអន្តរាយដល់សត្វក្នុងទឹក ទំនងជាអាចនិយាយថា ដំណើររបស់សត្វក្រសារ ដែលគេអាចឃើញមាននៅឥណ្ឌា នៅតាមអាងនៅគ្រប់ភូមិ បង្កើតបានជាសំនួនវោហារ *ពកវ្រត* និង *ពកវ្រតិន*។

**១៩៨.** តបៈមានច្រើនប្រភេទ ឧ.ទា. *កាន្ទ្រាយណ* ឬ តបៈក្រោមពន្លឺព្រះច័ន្ទ គឺអាចប្រតិបត្តិបានសម្រាប់ទាំងប្រព្រឹត្តអំពើបាប ដើម្បីលាងបាបចំពោះអំពើឧក្រិដ្ឋក៏បាន ឬសម្រាប់អ្នកគ្មានកំហុស ដើម្បីទទួលបានកុសលផ្នែកព្រលឹងវិញ្ញាណ សូមមើលពោធ. ជំពូក៣ លេខ៨, ២៧-៣១។

**២០១.** វិ. ជំពូក៦៤ លេខ១;យញ្ញ. ជំពូក១ លេខ១៥៩; ពោធ. ជំពូក២ លេខ៥, ៦។

២០២- អ្នកដែលប្រើរទេះ គ្រែ កៅអី អណ្ដូង ឧទ្យាន ឬផ្ទះរបស់អ្នកដទៃដោយគ្មានការអនុញ្ញាត នឹងទទួលទោសមួយភាគបួននៃទោស(របស់ម្ចាស់នោះ)មិនខាន។

២០៣- ចូរអ្នកតែងតែមុជទឹកក្នុងទន្លេ ស្រះ ដែលអាទិទេពបានជីក(ដោយផ្ទាល់) ក្នុងបឹង និងប្រឡាយ ឬទឹកដែលចេញពីដី។

២០៤- មនុស្សឆ្លាត គួរបំពេញភារកិច្ចដ៏ប្រពៃៗជានិច្ច(ដែលគេហៅថា *យម*) ប៉ុន្តែកុំធ្វើកិច្ចការតូចតាច (ហៅថា *និយម*) ឱ្យសោះ ព្រោះអ្នកមិនធ្វើកិច្ចការឧត្ដុង្គឧត្ដម ហើយធ្វើតែកិច្ចការតូចតាចប៉ុណ្ណោះ នឹងក្លាយជាមនុស្សក្រៅសង្គម។

២០៥- ព្រាហ្មណ៍មិនត្រូវទទួលទាន (អាហារពេលល្ងាច) នៅឯពិធីយញ្ញដែលផ្ដល់ដោយអ្នកដែលមិនមែនជា*ស្រោត្រិយ* ដោយអ្នកដែលធ្វើយញ្ញសម្រាប់មនុស្សដ៏ច្រើន ដោយស្ត្រី ឬដោយមនុស្សកម្រៀវ។

២០៦- ពេលដែលមនុស្សទាំងនោះដាក់អាហារយញ្ញចូលក្នុងភ្លើង វាមិនផ្ដល់សំណាងសម្រាប់(បុរស)ពិសិដ្ឋ ហើយវាធ្វើឱ្យអាទិទេពមិនសប្បាយចិត្ត ហេតុនេះ ចូរអ្នកជៀសវាងអាហារនោះទៅ។

២០៧- ចូរអ្នកកុំទទួលទាន (អាហារដែលផ្ដល់) ដោយ (មនុស្ស)ស្រវឹង ខឹងសម្បារឬឈឺ, កុំទទួលទានអាហារដែលមានជាប់សក់ឬសត្វល្អិត និងកុំទទួលទានអ្វីដែលប៉ះជើងដោយចេតនា,

២០៨- កុំទទួលទានអ្វីដែលអ្នកសម្លាប់ព្រាហ្មណ៍ចេះដឹង បានសម្លឹងមើល, កុំទទួលទានអ្វីដែលប៉ះពាល់ដោយស្ត្រីមានរដូវ, កុំទទួលទានអ្វីដែលសត្វបានចឹក ឬឆ្កែបានប៉ះរួចហើយ,

២០៩- កុំទទួលទានអាហារដែលមេគោបានហិត, កុំទទួលទានអាហារណាមួយ ដែលគេបានអញ្ជើញសម្រាប់អ្នកចូលរួមទាំងអស់, កុំទទួលទានអាហារ (ដែលផ្ដល់)ដោយជនសាមញ្ញ ឬដោយស្ត្រីពេស្យា, កុំទទួលទានអ្វីដែលអ្នកចេះដឹងប្រកាសថាមិនល្អ,

២១០- កុំទទួលទានអាហារ(ដែលផ្ដល់)ដោយចោរ អ្នកតន្ត្រី ជាងឈើ អ្នកចងការប្រាក់ អ្នកដែលត្រូវចូលជាសិស្ស(ក្នុងការធ្វើយញ្ញស្រោត) ជនកំណាញ់ អ្នកដែលជាប់ខ្នោះ,

---

**២០២.**យញ្ញ. ជំពូក១ លេខ១៦០; ពោធ. ជំពូក២ លេខ៦, ២៩។

**២០៣.**វិ. ជំពូក៦៤ លេខ១៦; យញ្ញ. ជំពូក១ លេខ១៥៩។ ពាក្យ *គរត*ប្រហោងទឹក'(គោវ., នារ.) ហើយលោកកុល្ល. ដែលដកស្រង់កាព្យ *ខាន្ទោគ្យ-បរិសិស្ដ*របស់លោកនន្ទ. និងរាឃ. ថា 'កូនអូរ'។

**២០៤.**បើនិយាយពីចំណាត់ថ្នាក់ទាំងពីរនៃករណីយកិច្ច សូមមើលយញ្ញ. ជំពូក៣ លេខ៣១៣-៣១៤។ សូម្បីអ្នកនិពន្ធ ធ្វើការបកស្រាយផ្សេងគ្នាអំពី *យម* និង *និយម* ក៏ដោយ ក៏ទំនងជាអាចនិយាយថា កុល្ល. ធ្វើការសន្មតដោយត្រឹមត្រូវថា មនុចង់មានយោបល់ដូចគ្នានឹងយញ្ញ. ដែរ។

**២០៥.**នារ. សរសេរពាក្យមួយទៀត *សូទ្រេទណ*ដោយសូទ្រៈ' សំដៅដល់ 'ដោយមនុស្សកម្រៀវ'។

**២០៩.**គោវ. និងកុល្ល. លើកនូវតួយ៉ាង 'ជនសាមញ្ញ' ថាជា 'ភាពជាបងប្អូនរបស់ព្រាហ្មណ៍ដែលនៅអារាមមួយ'។

**២១០.**ខ្ញុំប្រែ *ពទ្ធស្យ និគឌស្យ ក* តាមលោកកុល្ល. ថា 'អ្នកដែលជាប់ខ្នោះ' ពីព្រោះក្នុងភាសាសំស្ក្រឹតពីដើមៗ គេប្រើកៃត្តិម្តងម្កាលសម្រាប់ផ្សំជាមួយគុណនាមដែលក្លាយពីកិរិយាសព្ទអកម្ម ហើយដោយសារពាក្យ *និគឌ* ដែលមាននៅក្នុងសំណេរប៉ែកខាងត្បូងខ្លះដែរ។

២១១- កុំទទួលអាហារពីអ្នក ដែលជាប់ចោទប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ(អភិសស្ត), មនុស្សខ្ទើយ, ស្ត្រីបរិសុទ្ធ, ឬមនុស្សលាក់ពុត និងកុំទទួល(បង្អែមអ្វីក៏ដោយ)ដែលបានប្រែទៅជាជូរ កុំទទួលទានអ្វីរក្សាទុកហួសមួយយប់ កុំទទួលទាន(អាហារ)របស់សូទ្រៈ កុំទទួលរបស់សំណល់(របស់បុរសដទៃ),

២១២- កុំទទួលទាន(អាហារដែលផ្តល់)ដោយគ្រូទេព្យ, អ្នកប្រមាញ់, មនុស្សកាចសាហាវ, អ្នកដែលទទួលទានចំណែក(អាហាររបស់អ្នកផ្សេង), កុំទទួលទានអាហាររបស់*ឧគ្រ*, កុំទទួលទានអាហារដែលគេរៀបចំសម្រាប់ស្ត្រីដែលកំពុងសម្រាលកូន, កុំទទួលទានអាហារ(ពេលល្ងាច) ដែល (ភ្ញៀវក្រោក) មុនពេលកំណត់(ហើយ)ផឹកទឹក, កុំទទួលទានអាហារ(របស់ស្ត្រី) ដែលបាត់បង់ភាពបរិសុទ្ធមិនទាន់បានដប់ថ្ងៃ,

២១៣- កុំទទួលទាន(អាហារ)ដែលគេជូនដោយគ្មានការគោរពត្រឹមត្រូវ, កុំទទួលទាន (អាហារដែលមាន) សាច់សម្រាប់ទទួលទានដោយគ្មានហេតុផលពិសិដ្ឋ, កុំទទួលទាន(អាហារដែលផ្តល់)ដោយស្ត្រីដែលគ្មាន(សាច់ញាតិ)ប្រុស, កុំទទួលទានអាហាររបស់សត្រូវ, កុំទទួលទានអាហារ(ដែលផ្តល់)ដោយលោកម្ចាស់ក្រុង, កុំទទួលទានអាហារ(របស់មនុស្សក្រៅសង្គម), កុំទទួលទានអាហារដែលនរណា ម្នាក់បានកណ្តាស់សំបោរដាក់,

២១៤- កុំទទួលទានអាហារ(ដែលផ្តល់)ដោយអ្នករាយការណ៍ ដោយអ្នកដែលមានទម្លាប់ពោលពាក្យកុហក ឬដោយអ្នកដែលជួញ(បុណ្យ)ពិធីយញ្ញ និងកុំទទួលទានអាហារ(ដែលផ្តល់)ដោយតារាសម្តែង ជាងកាត់ដេរ ឬ(មនុស្ស)មិនចេះដឹងគុណគេ,

២១៥- ដោយជាងដែក អ្នកនេសាទ អ្នកសម្តែងលើឆាក ជាងមាស អ្នកកញ្ចើល្អី ឬអ្នកជួញជូរអារុជ,

២១៦- ដោយអ្នកបង្ហាត់ឆ្កែប្រមាញ់ អ្នកលក់ស្រា អ្នកបោកគក់ អ្នកជ្រលក់ពណ៌ (មនុស្ស)គ្មានក្តីមេត្តា និងមនុស្សដែល(ជាសហព័ទ្ធ)មិនត្រឹមត្រូវតាមច្បាប់នៅក្នុងផ្ទះ,

---

**២១១.**ឃ្លា *សូទ្រស្យោត្ឆិស្តំ អេវ ក* 'កុំទទួលទាន(អាហារ)របស់សូទ្រៈ កុំទទួលសំណល់(របស់បុរសដទៃ)'(កុល្ល, នារ.) ឬ'សំណល់របស់សូទ្រៈ' ដែលត្រូវបានលើកឡើងដើម្បីសបញ្ជាក់ថាការធ្វើតបៈដ៏តឹងរ៉ឹងគេត្រូវតែធ្វើឱ្យបាន(មេធ.,រាឃ.) ឬ 'អាហារដែលសូទ្រៈបានស៊ីរួចហើយ និងបានសល់នៅក្នុងចាន'(គោវ., នន្ទ., មេធ., និងអ្នកដទៃទៀត)។ មេធ. មានសរសេរឃ្លាមួយទៀតដែរថា *ឧត្ឆិស្តំ អគុរោស តថា* 'កុំទទួលទានអាហារសំណល់របស់មនុស្សណាទាំងអស់ លើកលែងតែគ្រូ'។

**២១២.**គេបកស្រាយពាក្យ ឧគ្រ ផ្សេងគ្នាថា 'មនុស្សរបស់វណ្ណៈឧគ្រ'(មេធ., គោវ., នារ., នន្ទ., រាឃ.) ឬ 'ព្រះមហាក្សត្រិយ' (មេធ., គោវ. នៅក្នុង *មញ្ជរី* ឬ 'មនុស្សដែលប្រព្រឹត្តអំពើគួរឱ្យខ្លាច'(កុល្លូ., រាឃ.)។
**២១៣.**កុល្លូ. និងគោវ. ហាក់ដូចជាប្រែពាក្យ *នគរន្នំ* 'អាហារដែលផ្តល់ដោយលោកម្ចាស់ក្រុង' គឺជា ព្រះរាជ(តាមមេធ., នារ., រាឃ.) ក្នុងន័យថា *នគរាន្នំ* 'អាហារដែលផ្តល់ដោយទីក្រុងទាំងមូល'។
**២១៥.**យោងតាមអ្នកដទៃទៀតដែលលោកមេធ., នន្ទ. និងរាជ. បានស្រង់សម្តីថា 'តារាសម្តែង' ក៏អាចមានន័យ 'អ្នកដែលចិញ្ចឹមជីវិតដោយមធ្យោបាយមិនត្រឹមត្រូវ'។
**២១៦.**ពាក្យ*នូសំស*មនុស្សគ្មានចិត្តមេត្តា'(មេធ., គោវ., កុល្លូ., នន្ទ., រាឃ.) ក៏អាចមានន័យថា 'កវី'(មេធ., នារ., រាឃ.) ផងដែរ។

២១៧- កុំទទួលទាន(អាហារដែលផ្តល់)ដោយអ្នកដឹងថាមាន(ភរិយា)មិនស្របច្បាប់ និងដោយអ្នកត្រូវស្ត្រីដឹកមុខគ្រប់បញ្ហាទាំងអស់ ហើយកុំទទួលទានអាហារ(ដែលផ្តល់ដោយបុរស)ដែលបានប្រព្រឹត្តអំពើមិនបរិសុទ្ធ(រហូតដល់មានបាត់បង់ជីវិត) មិនទាន់បានកន្លងផុតដប់ថ្ងៃ, កុំទទួលទានអាហារដែលខ្លួនមិនចូលចិត្ត។

២១៨- អាហាររបស់ព្រះរាជា ធ្វើឱ្យបាត់ភាពស្វាហាប់របស់ខ្លួន, អាហាររបស់សូទ្រៈធ្វើឱ្យបាត់ភាពឧត្តមរបស់ខ្លួនក្នុងការសិក្សាដ៏ពិសិដ្ឋ, អាហាររបស់ជាងមាសញ៉ាំងឱ្យហិនហោចអាយុវែងរបស់អ្នក, អាហាររបស់អ្នកកាត់ស្បែក ញ៉ាំងឱ្យបាត់បង់កិត្តិនាមរបស់ខ្លួន,

២១៩- អាហាររបស់សិប្បកធ្វើឱ្យវិនាសកូនចៅរបស់អ្នក, អាហាររបស់អ្នកបោកគក់ ធ្វើឱ្យវិនាសកម្លាំង(កាយ)របស់អ្នក, អាហាររបស់ជនសាមញ្ញនិងរបស់ស្រីពេស្យាធ្វើឱ្យអ្នកបាត់បង់ឋានៈ(ខ្ពស់)។

២២០- អាហាររបស់គ្រូពេទ្យ (គឺអាក្រក់ស្មើនឹង) ខ្ទុះ, អាហាររបស់ស្ត្រីមិនបរិសុទ្ធ (ស្មើនឹង) ទឹកកាម, អាហាររបស់អ្នកចងការប្រាក់ (អាក្រក់ស្មើនឹង) លាមក ហើយអាហាររបស់ឈ្មួញលក់អាវុធ(អាក្រក់ស្មើនឹង) ធូលី។

២២១- អាហាររបស់អ្នកដទៃទៀត ដែលបានរៀបរាប់ជាបន្តបន្ទាប់ថាជាអាហារដែលមិនត្រូវទទួលទាន បណ្ឌិតប្រកាស(ថាមិនបរិសុទ្ធដូចគ្នានឹង) ស្បែក ឆ្អឹង និងសក់។

២២២- ប្រសិនបើអ្នកបាន ទទួលអាហាររបស់នរណាម្នាក់ក្នុងចំណោមអ្នកទាំងនោះដោយមិនដឹងខ្លួន (អ្នកត្រូវតែ)សុំសីលចំនួនបីថ្ងៃ; បើសិនជាអ្នកបានទទួលទានដោយចេតនា ឬ(បានលេប)ទឹកកាម លាមក ឬទឹកនោម នោះអ្នកត្រូវធ្វើតបៈ*ក្ឫច្រ្ក*។

២២៣- ព្រាហ្មណ៍ ដែលចេះ(ច្បាប់) មិនត្រូវទទួលទានអាហារចំអិន(ដែលផ្តល់)ដោយសូទ្រៈ ដែលមិនធ្វើពិធីស្រាទ្ធ ប៉ុន្តែបើគ្មានមធ្យោបាយ(ផ្សេង)ក្នុងការចិញ្ចឹមជីវិត អ្នកអាចទទួលគ្រាប់ធញ្ញជាតិឆៅ សម្រាប់មួយយប់ (និងមួយថ្ងៃ)ប៉ុណ្ណោះ។

២២៤- អាទិទេព ដោយបានពិចារណា(គុណធម៌នីមួយៗ)របស់ស្រោត្រិយដ៏កំណាញ់ និងរបស់អ្នកចងការប្រាក់ចិត្តទូលាយ បានប្រកាសអាហាររបស់អ្នកទាំងពីរ ថាមានលក្ខណៈសម្បត្តិស្មើគ្នា។

២២៥- ព្រះបង្កើតសត្វលោក(ប្រជាបតិ) បានយាងចុះមក ហើយនិយាយទៅកាន់ពួកគេថា 'កុំនិយាយថាស្មើគ្នា គឺមិនស្មើគ្នាទេ។ អាហាររបស់(អ្នកចងការប្រាក់)ចិត្តទូលាយ ត្រូវបរិសុទ្ធដោយជំនឿ ហើយ(អាហាររបស់បុរស)ម្នាក់ទៀត ត្រូវកខ្វក់ដោយការគ្មានជំនឿ'។

**២២០.** ពោលគឺវាញ៉ាំងឱ្យអ្នកមានកំណើតជាថ្មីជាសត្វ ដែលស៊ីខ្ទុះ ឬសារធាតុមិនស្អាតដទៃទៀត(គោវ.)។
**២២២.** គោត. ជំពូក២៣ លេខ២៣-២៤។ ចំពោះពាក្យ *តបៈក្ឫច្ឆ្រ* សូមមើលជំពូក១១ លេខ២១១ខាងក្រោម។
**២២៤.** នារ.ប្រែពាក្យ *អស្រាទ្ធិនៈ* 'ដែលមិនធ្វើពិធីស្រាទ្ធៈ' ដោយថា 'ដែលគ្មានជំនឿ' ហើយនន្ទ. សរសេរ *អស្រទ្ធិនៈ*។
**២២៤-២២៥.** ពោធ. ជំពូក១ លេខ១០, ៥; វស. ជំពូក១៤ លេខ១៧។

២២៦- ចូរអ្នកកុំនឿយហត់ ជានិច្ចកាលត្រូវធ្វើការបូជាយញ្ញ និងធ្វើការងារសប្បុរសធម៌ដោយជំនឿ ព្រោះថាការបូជានិងការងារសប្បុរសធម៌ដែលធ្វើដោយជំនឿ និងដោយលុយដែលរកបានដោយស្របច្បាប់(នឹងផ្តល់)ផលគ្មានទីបញ្ចប់។

២២៧- ចូរអ្នកធ្វើជារឿយៗតាមលទ្ធភាពរបស់ខ្លួនដោយចិត្តអំណរ ធ្វើកិច្ចការសប្បុរស ដោយការបូជាយញ្ញផង និងដោយការងារសប្បុរសធម៌ផង ប្រសិនបើអ្នកស្វែងរកអ្នកទទួល(ការបរិច្ចាគរបស់ខ្លួន)បានត្រឹមត្រូវ។

២២៨- ប្រសិនបើគេសុំអ្នក ចូរអ្នកផ្តល់នូវអ្វីម្យ៉ាងជានិច្ច សូម្បីតិចតួចក្តី ដោយមិនបង្ហាញពីការមិនពេញចិត្ត ព្រោះអ្នកទទួលដ៏សមគួរ នឹង(ទំនងជា)អ្នកដែលជួយសង្គ្រោះ(បាប)ទាំងអស់ពីរូបអ្នក។

២២៩- អ្នកឱ្យទឹកទទួលបានការបំពេញនូវ(ការស្រេកឃ្លានរបស់អ្នក) អ្នកឱ្យអាហារទទួលបានសុកមង្គលមិនចេះសាបសូន្យ អ្នកឱ្យគ្រាប់ល្ងនឹងមានកូនតាមប្រាថ្នា អ្នកឱ្យចង្កៀងនឹងមានភ្នែកភ្លឺថ្លាបំផុត។

២៣០-អ្នកឱ្យដីធ្លីនឹងមានដីច្រើន អ្នកឱ្យមាសនឹងមានអាយុវែង អ្នកឱ្យផ្ទះនឹងទទួលបានភូមិគ្រឹះដ៏ប្រណិតបំផុត អ្នកឱ្យប្រាក់ (រូប្យ) នឹងមានរូបសម្បត្តិល្អផូរផង់។

២៣១-អ្នកឱ្យសម្លៀកបំពាក់ នឹងបានកន្លែងមួយនៅឋានព្រះច័ន្ទ អ្នកឱ្យសេះ(អស្វ)នឹងបានកន្លែងមួយនៅឋានអស្វិន អ្នកឱ្យគោឈ្មោលនឹងទទួលបានសំណាងល្អមហាសាល អ្នកឱ្យមេគោ នឹងបានកន្លែងមួយនៅឋានព្រះអាទិត្យ,

២៣២-អ្នកឱ្យរទេះឬគ្រែនឹងបានភរិយា អ្នកឱ្យការការពារនឹងមានអំណាចដ៏កំពូល អ្នកឱ្យគ្រាប់ធញ្ញជាតិនឹងបានពរជ័យរហូត អ្នកឱ្យព្រះវេទ(ព្រហ្ម័ន)នឹងបានទៅកាន់ឋានព្រហ្ម,

២៣៣- ការឱ្យព្រះវេទ ប្រពៃលើសអំណោយដទៃទៀតទាំងអស់ ដូចជាការឱ្យទឹក អាហារ មេគោ ដីធ្លី សម្លៀកបំពាក់ ល្ង មាស និងប៊ីសុទ្ធ។

២៣៤-(អ្នក)ជូនអំណោយណាក៏ដោយក្នុងចេតនាបែបណា អ្នកនឹងសោយ(ផលជាតិក្រោយ)ដោយចេតនាដូចគ្នា ស្របតាម(ផល)នៃអំពើនោះ។

២៣៥- ទាំងអ្នកដែលទទួល(អំណោយ)ដោយគោរព និងទាំងអ្នកជូនអំណោយដោយគោរព នឹងឡើងឋានសួគ៌ ក្នុងករណីផ្ទុយទៅវិញ(ពួកគេទាំងពីរនឹងធ្លាក់)នរក។

២៣៦-ចូរអ្នកកុំមានមោទនភាពនឹងការធ្វើតបៈរបស់ខ្លួន ចូរអ្នកកុំនិយាយកុហកបន្ទាប់ពីអ្នកបានធ្វើការបូជាយញ្ញ ចូរអ្នកកុំនិយាយអាក្រក់ពីព្រាហ្មណ៍ ទោះបីអ្នកត្រូវទទួលទណ្ឌកម្ម (ពីពួកគេ) ក្តី ហើយពេលអ្នកបានជូន(អំណោយ) ចូរអ្នកកុំអួតពីការជូននោះអី។

---

**២២៦-២២៧.** គោវ. ពន្យល់តែកាព្យលេខ២២៦a និង២២៧b ប៉ុណ្ណោះ។
**២២៦-២៣៥.** វស. ជំពូក៣០; វិ. ជំពូក៩១-៩២; យញ្ញ. ជំពូក១ លេខ២០១, ២០៣-២១២។
**២៣៤.** មេធ., គោវ., នារ. និងរាឃ. ប្រែកាព្យនេះខុសៗពីគ្នា។ `(អ្នក)ជូនអំណោយមួយដោយចិត្តបែបចិត្ត អ្នកនឹងទទួលបាន(ផលបន្ទាប់ពីស្លាប់)ដោយចិត្តបែបនោះដូចគ្នា´។ នន្ទ. លុបកាព្យនេះចោល។ លោក K. យកតាមការបកស្រាយរបស់កុល្លូ. ដែលលោកមេធ.ក៏សរសេរបែបនេះដូចគ្នា។

២៣៧-ដោយការភូតកុហកពិធីយញ្ញនឹងទៅជាឥតប្រយោជន៍, ដោយការពេញចិត្តខ្លួនឯង (ផលនៃ)ការធ្វើតបៈនឹងត្រូវបាត់, បាត់ផលអាយុវែងដោយការនិយាយអាក្រក់ពីព្រាហ្មណ៍និងបាត់(ផល)នៃការបរិច្ចាគដោយការនិយាយអួត។

២៣៨-ដោយការមិនបង្កការឈឺចាប់សត្វណាមួយ ចូរអ្នកខំពង្រីកគុណធម៌ផ្នែកព្រលឹងសន្សឹមៗ ដើម្បី (ទទួលបាន) កុសលជាប់ខ្លួនទៅជាតិក្រោយ ឧបមាដូចជាស្រមោច-ស (ខំលើក) ដំបូករបស់វាបន្តិចម្តងៗដូច្នោះដែរ។

២៣៩-សម្រាប់ជាតិបន្ទាប់ អ្នកមិនអាចទៅជាមួយឪពុក ម្តាយ ប្រពន្ធ កូន សាច់ញាតិបានទាំងអស់ ហើយមានតែកុសលផ្លូវចិត្តប៉ុណ្ណោះ(ដែលទៅជាមួយអ្នក)។

២៤០- ម្នាក់ៗ ត្រូវចាប់កំណើតរៀងៗខ្លួន ការស្លាប់ទៅតែម្នាក់ឯង ការសោយផលបុណ្យកុសលតែម្នាក់ឯង ហើយការទទួលទណ្ឌកម្មនៃអំពើបាបក៏ម្នាក់ឯង។

២៤១- ការចាកចោលរូបស្ពូកស្ពឹងលើដី បីដូចជាគល់ឈើ ឬដុំដី សាច់ញាតិបែកផ្លូវគ្នាទីកាន់ទិសផ្សេងៗគ្នា ប៉ុន្តែកុសលផ្លូវចិត្តនឹងទៅជាមួយ(ព្រលឹង)។

២៤២- ដូច្នេះចូរអ្នកខំពង្រីកកុសលផ្លូវចិត្តសន្សឹមៗដើម្បី(ជាទ្រព្យជាប់)តាមខ្លួន(បន្ទាប់ពីស្លាប់) ព្រោះមានតែបុណ្យកុសលទេជាទ្រព្យជាប់ខ្លួនអ្នក ជួយអ្នកឆ្លងកាត់ទីងងឹតមួយទៅកាន់ភពមួយបាន។

២៤៣-(ទ្រព្យជាប់ខ្លួន)នាំមនុស្សដែលធ្វើពលិកម្មចំពោះករណីយកិច្ច និងគេចផុតពីបាបកម្មរបស់ខ្លួន ដោយការធ្វើតបៈទៅកាន់ជាតិបន្ទាប់យ៉ាងឆាប់រហ័ស ដោយមានរូបកាយភ្លឺចែងចាំងនិងសម្លៀកបំពាក់បរិសុទ្ធស្រាលដូចខ្យល់។

២៤៤- ចូរអ្នកដែលប្រាថ្នាចង់លើកតម្កើងឋានៈខ្លួន ជានិច្ចកាលចូរសេពគប់ជាមួយ (កល្យាណមិត្ត) ដ៏ឧត្តុង្គឧត្តមបំផុត ហើយជៀសចេញពីមិត្តថោកទាបទាំងអស់។

២៤៥- ព្រាហ្មណ៍ ដែលសេពគប់ជាមួយកល្យាណមិត្តដ៏ប្រពៃបំផុត និងគេចចេញពីមិត្តថោកទាបទាំងអស់ជានិច្ច (ខ្លួនគេ)នឹងល្បីល្បាញបំផុត ហើយបើប្រព្រឹត្តផ្ទុយពីនេះ គេនឹងក្លាយជាសូទ្រៈ។

២៤៦-អ្នកដែលមានការព្យាយាម សុភាពរាបសា (និង) អត់ធ្មត់ មិនសេពគប់មិត្តដែលមានចរិតកាចសាហាវ និងមិនបង្កអន្តរាយ(ដល់សត្វមានជីវិត) នឹងទទួលបានពរឡើងឋានសួគ៌ ប្រសិនបើគេរស់នៅតាមរបៀបនោះ ដោយការគ្រប់គ្រងឥន្ទ្រីយារម្មណ៍ខ្លួន និងមានចិត្តសប្បុរសជាប្រចាំ។

២៤៧- អ្នកអាចទទួលយកពី(មនុស្ស)ណាក៏បាន នូវប្រេង ទឹក មើមឈើ ផ្លែឈើ អាហារដែលគេជូនដោយមិនបាច់សុំនិងទឹកឃ្មុំ អំណោយបែបនេះ(ជាការឱ្យស្របតាម)ការសន្យាផ្តល់ការគាំពារ។

២៤៨- ព្រះបង្កើតសត្វលោក(ប្រជាបតិ) បានប្រកាសថា គេអាចទទួលវត្ថុទានដែល (អ្នកជូន)បរិច្ចាគ និងឱ្យដោយគ្មានចង់បានអ្វី សូម្បីពីអ្នកប្រព្រឹត្តអំពើបាបក៏បាន ព្រោះថា(ការបរិច្ចាគនោះ)បានធ្វើឡើងដោយគ្មានការ(សុំ ឬ) បានសន្យាទុកជាមុនទេ។

**២៤៧.** អាប. ជំពូក១ លេខ១៨, ១; គោត. ជំពូក១៧ លេខ៥; វស. ជំពូក១៤ លេខ១២; វិ. ជំពូក៥៧ លេខ១១។

**២៤៨.** អាប.ជំពូក១ លេខ១០, ១២-១៤; វស. ជំពូក១៤ លេខ១៦; វិ. ជំពូក៥៧ លេខ១១; យញ្ញ.ជំពូក១ លេខ២១៥។

២៤៩- ក្នុងអំឡុងពេលដប់ប្រាំឆ្នាំ វិញ្ញាណក្ខន្ធមិនទទួលទាន(អាហារ)របស់មនុស្សដែលមើលងាយ(ការឱ្យទានដោយសុទ្ធចិត្ត) ហើយព្រះអគ្គីក៏មិនទទួលការបូជារបស់គេ(ចំពោះអាទិទេព)ដែរ។

២៥០- គ្រែ ផ្ទះ ស្មៅកុសៈ ទឹកអប់ ទឹក ផ្កា គ្រឿងអលង្ការ ទឹកដោះជូរ គ្រាប់ធញ្ញជាតិ ត្រី ទឹកដោះផ្អែម សាច់ និងបន្លែ ចូរអ្នកកុំបដិសេធ (ប្រសិនបើគេឱ្យរបស់នោះដោយស្ម័គ្រចិត្ត)។

២៥១- អ្នកដែលប្រាថ្នាចង់ជួយសម្រាលបន្ទុកគុរុរបស់ខ្លួន និងអ្នកដែលខ្លួនត្រូវចិញ្ចឹម ឬចង់បូជាព្រះអាទិទេពនិងជូនដល់ភ្ញៀវ អាចទទួល(អំណោយ)ពីអ្នកណាក៏បាន ប៉ុន្តែអ្នកមិនត្រូវបំពេញចិត្ត(ការស្រេកឃ្លានផ្ទាល់)របស់ខ្លួន នឹង(អំណោយ)បែបនោះទេ។

២៥២- ប៉ុន្តែបើសិនជាគុរុស្លាប់ ឬបើសិនជាគាត់នៅរស់បែកពីពួកគេនៅក្នុងផ្ទះ (ផ្សេង) ចូរគាត់ទទួលយក(អំណោយ)បានតែពីមនុស្សល្អប៉ុណ្ណោះ នៅពេលគាត់ត្រូវការការចិញ្ចឹមជីវិត។

២៥៣- កម្មករភ្ជួររាស់របស់ខ្លួន មិត្តសំឡាញ់របស់គ្រួសារខ្លួន អ្នកមើលមេគោរបស់ខ្លួន ទាសាទាសីរបស់ខ្លួននិងជាងកាត់សក់របស់ខ្លួន ជាមនុស្សក្នុងចំណោមសូទ្រៈ ដែលអាចទទួលទានអាហារនោះបាន ដូចជា(អ្នកក្រ)ដែលបរិច្ចាគខ្លួន(ធ្វើជាទាសកររបស់គេ)ដែរ។

២៥៤- គេចង់ធ្វើតាមចរិតរបស់គេ តាមការងារ និងតាមរបៀបដែលគេចង់បម្រើ សូម្បីដូច្នេះក្តី(ទាសករស្ម័គ្រចិត្ត)ត្រូវបរិច្ចាគដោយខ្លួនឯង។

២៥៥- អ្នកដែលរៀបរាប់ដោយខ្លួនឯងប្រាប់(អ្នកដែល)មានគុណធម៌ដោយផ្ទុយពីការពិត ជាមនុស្សមានបាបធ្ងន់បំផុតនៅក្នុងលោកនេះ ពោលគឺគេជាចោរ ដែលលួចខ្លួនរបស់គេផ្ទាល់។

២៥៦- ទាំងអស់នេះ(មានលក្ខណៈរបស់វា)ដែលកំណត់ដោយពាក្យសម្តីសម្តីជាដើមចមរបស់វា ហើយដោយសារសម្តី ទើបពួកគេប្រព្រឹត្តទៅបាន ប៉ុន្តែអ្នកដែលគ្មានសេចក្តីស្មោះត្រង់ គោរពតាមពាក្យសម្តី គឺគ្មានការស្មោះត្រង់ក្នុងរឿងអ្វីទាំងអស់។

២៥៧- យោងតាមច្បាប់ នៅពេលអ្នកបានសងបំណុលរបស់ខ្លួនចំពោះមហាបណ្ឌិត វិញ្ញាណក្ខន្ធ និងចំពោះអាទិទេព ចូរអ្នកធ្វើអ្វីៗដើម្បីកូនប្រុសអ្នក ហើយស្នាក់(នៅក្នុងផ្ទះរបស់អ្នក) ដោយមិនខ្វល់ពីបញ្ហាលោកិយទាំងអស់។

មេធ., គោវ. និងនារ. ប្រែ *អប្រកោទិតាំ* ‘ដែលគេមិនបានសុំ ឬសន្យា’ ក្នុងន័យថា ‘ដែលមិនបានសន្យាប៉ុណ្ណោះ ហើយលោកនន្ទ. ដែលសរសេរ *អប្រវេទិតាំ* ក៏ប្រែដូច្នេះដែរ។

**២៤៩.** អាប. ជំពូក១ លេខ១៩, ១-៤; វស. ជំពូក១៤ លេខ១៨; វិ. ជំពូក៥៧ លេខ១២។
**២៥០.** គោត. ជំពូក១៧ លេខ៥; វស. ជំពូក១៤ លេខ១២; វិ. ជំពូក៥៧ លេខ១១; យញ្ញ. ជំពូក១ លេខ២១៤។
**២៥១.** អាប. ជំពូក១ លេខ៧, ២០; គោត. ជំពូក១៧ លេខ៤; វស. ជំពូក១៤ លេខ១៣; វិ. ជំពូក៥៧ លេខ១៣; យញ្ញ. ជំពូក១ លេខ២១៦។
**២៥១.** វិ. ជំពូក៥៧ លេខ១៥។
**២៥៣.** អាប. ជំពូក១ លេខ១៨, ១៤; គោត. ជំពូក១៧ លេខ៥-៦; វិ. ជំពូក៥៧ លេខ១៦។
**២៥៥.** ពោលគឺ ដោយការបដិសេធខ្លួនជានរណាពិតប្រាកដ គេនឹងបំផ្លាញអត្តសញ្ញាណផ្ទាល់របស់ខ្លួន។
**២៥៧.** ចំពោះបំណុលបី សូមមើលវស. ជំពូក១១ លេខ៤៨។ កាព្យនេះ និងកាព្យបន្ទាប់ តាមលោកមេធ. គឺរៀបរាប់អំពីប្រភេទ*សំឡាស*ធម្មតា។

២៥៨- ចូរអ្នកភាវនាម្នាក់ឯងជាប្រចាំដោយនៅដាច់ពីគេ ដើម្បីជាប្រយោជន៍ដល់ព្រលឹងរបស់ខ្លួន ពីព្រោះអ្នកភាវនាម្នាក់ឯងនឹងទទួលបានពរជ័យដ៏កំពូល។

២៥៩- ដូច្នេះដោយបានប្រកាសថា មធ្យោបាយដែលយរាវាសព្រាហ្មណ៍ត្រូវប្រើប្រាស់ដើម្បីចិញ្ចឹមជីវិតជានិច្ច និងសេចក្តីសង្ខេបអំពីបញ្ញត្តិសម្រាប់ស្នាតកៈដែលជួយបង្កើនពិសិដ្ឋភាព និងជាការគួរឱ្យសរសើរ។

២៦០- ព្រាហ្មណ៍ ដែលមានការចេះដឹងក្នុងច្បាប់វេទ បានប្រតិបត្តិខ្លួនតាមរបៀបនេះ និងព្យាយាមដុតបំផ្លាញអំពើបាបរបស់ខ្លួនរាល់ថ្ងៃ នឹងបានទៅកាន់ឋានព្រហ្ម។

**២៦០.** វស. ជំពូក៨ លេខ១៧; ពោធ. ជំពូក២ លេខ៣, ១; គោត. ជំពូក៩ លេខ៧៤។

# ជំពូក ៥

១- បណ្ឌិត ដោយបានស្តាប់ករណីយកិច្ចរបស់ស្នាតក ដូច្នេះក៏បានប្រកាស និយាយទៅកាន់ភ្រិគុ ដែលមានអាត្មន៍ដ៏កំពូល មានកំណើតចេញពីព្រះអគ្គីថា៖

២- 'តើសេចក្តីស្លាប់អាចមានអំណាចលើព្រាហ្មណ៍ ដែលចេះវិទ្យាសាស្ត្រពិសិដ្ឋ ព្រះវេទ(និង)ដែលបំពេញករណីយកិច្ចរបស់ខ្លួន តាមបញ្ញត្តិដែលព្រះជាម្ចាស់បានបរិយាយ យ៉ាងដូចម្តេច?'។

៣- ភ្រិគុដ៏ត្រឹមត្រូវ បុត្ររបស់មនុ (ដូច្នេះ)បានឆ្លើយប្រាប់មហាបណ្ឌិតថា៖ 'ចូរ (ក្នុងការដាក់ទណ្ឌកម្មនូវ)អ្វីដែលជាកំហុស សេចក្តីស្លាប់ជាការកាត់បន្ថយអាយុរបស់ព្រាហ្មណ៍បាន!'។

៤- 'ដោយការមិនខំសិក្សាព្រះវេទ ដោយការមិនព្រមធ្វើតាមតម្រាប្រតិបត្តិ ដោយការធ្វេសប្រហែស (ក្នុងការបំពេញករណីយកិច្ច) និងដោយមានកំហុស(ដែលបានទទួលទាន)អាហារហាមឃាត់ សេចក្តីស្លាប់មានបំណងបន្ថយអាយុរបស់ព្រាហ្មណ៍បាន'។

៥- ខ្ទឹមស គុយឆាយ និងខ្ទឹមបារាំង ផ្សិត និង(រុក្ខជាតិទាំងអស់) ដែលដុះចេញពី(សារធាតុ)មិនស្អាត មិនសក្តិសមនឹងឱ្យអ្នកមានកំណើតពីរដងទទួលទានទេ។

---

**ជំពូក៥. លេខ១.** មេធ., គោវ. និងរាឃ. បញ្ជាក់យ៉ាងត្រឹមត្រូវថា ភ្រិគុ ទោះបីមានជំពូក១ លេខ៣១ខាងលើក្តី ក៏គេនិយាយថា គាត់ត្រូវបានបង្កើតដោយមនុ ដូច្នេះហើយបានជាគេដាក់ឈ្មោះ*មានវ* ដូចជំពូក៥ លេខ៣ខាងក្រោម ត្រូវតែហៅនៅទីនេះថាកូនចៅរបស់ព្រះអគ្គី ស្របតាមសេចក្តីផ្សេងទៀតនៃព្រះវេទ និងមហាភារត។
**២.** ពោលគឺ 'តើពួកគេអាចត្រូវបាត់បង់អាយុវែង មួយរយឆ្នាំ ដោយរបៀបណា ដោយចែកទឱ្យមនុស្សនៅក្នុងព្រះវេទឬ ?' (គោវ., កុល្ល.)។

**៥-២៥.** អាប. ជំពូក១ លេខ១៧, ១៨-៣៩; គោត. ជំពូក១៧ លេខ២២-៣៦; វស. ជំពូក១៤ លេខ៣៣-៤៨; ពោធ. ជំពូក១ លេខ១២, ១-១៥; វិ. ជំពូក៥១ លេខ៣-៦, ២១-៤២; យញ្ញ. ជំពូក១ លេខ១៦៩-១៧៨។ ពាក្យ *សេលុ* ជា ទឹកផ្កា Cordia Myxa។

៦- អ្នកគួរយកចិត្តទុកដាក់ ជៀសវាងសារធាតុក្រហមដែលចេញពីដើមឈើ និង(ទឹកផ្លែឈើ) ដែលចេញពីការកាត់ សេលុ (ចេញពីផ្លែឈើ) និងទឹកដោះខាប់របស់មេគោ (ដែលចេញបន្ទាប់ពីវាកើតកូន)។

៧- បាយដែលដាំលាយជាមួយល្ង បាយស្រូវសាឡីដែលលាយជាមួយប៊ឺ ទឹកដោះ និងស្ករ បាយលាយទឹកដោះ និងនំម្សៅដែលមិនបានចំអិនសម្រាប់ពិធីយញ្ញ សាច់ដែលមិនបានត្រូវទឹកនៅពេលគេសូត្រធម៌ពិសិដ្ឋ អាហារដែលបូជាអាទិទេព និងអាហារបូជាយញ្ញ,

៨- ទឹកដោះមេគោ (ឬសត្វញីផ្សេងទៀត) ក្នុងរយៈពេលដប់ថ្ងៃ បន្ទាប់ពីវាបង្កើតកូន ទឹកដោះរបស់អូដ្ឋ របស់សត្វដែលមានក្រចកមួយ របស់ចៀម របស់មេគោដែលកំពុងរកឈ្មោល ឬទឹកដោះរបស់សត្វដែលគ្មានកូន,

៩- (ទឹកដោះ)សត្វព្រៃទាំងអស់ លើកលែងតែគោ-ក្របី ទឹកដោះស្ត្រី និង(សារធាតុ)ទាំងអស់ដែលប្រែជាជូរ គេត្រូវតែជៀសវាង។

១០- ក្នុងចំណោម(របស់ដែលប្រែ)ជាជូរ មានទឹកដោះគោជូរ និង(អាហារ)ទាំងអស់ដែលបានចំអិនគេអាចទទួលទានបាន ដូចជាអ្វីៗដែលគេចម្រាញ់ចេញពីផ្កា មើមឈើ និងផ្លែឈើសុទ្ធ។

១១- ចូរអ្នកជៀសវាងសត្វស្លាបដែលស៊ីសាច់ជាអាហារ និងសត្វស្លាបដែលរស់នៅក្នុងភូមិ និងសត្វដែលមានក្រចកមួយដែលគេមិនអនុញ្ញាត(ឱ្យទទួលទាន)ជាពិសេសនិងសត្វស្លាប*តិត្តិភ* (Parra Jacana)

១២- ចាបស្រុក សត្វប្លាវ សត្វហំស ទាព្រាហ្មណី មាន់គកស្រុក សត្វក្រៀលក្រសារ សត្វរាត្តុទាល សត្វត្រសេះ សេក និងសត្វទៀវ,

១៣- សត្វទាំងឡាយដែលចិញ្ចឹមជីវិតដោយប្រើចំពុះរបស់វា សត្វស្លាបមានជើងជាប់ស្បែកសំបុកពីងពាង សត្វកោយស្តិ សត្វដែលប្រើម្រាមជើងខ្វាច សត្វដែលមុជទឹកចាប់ត្រីធ្វើចំណី សត្វស្លាប ស៊ីសាច់នៅតាមផ្ទះសត្តឃាត និងសាច់ដែលគេហាលចោល,

១៤- សត្វ*ពក* និងសត្វក្រៀល*ពលាកា* សត្វក្អែកធំ សត្វ*ខញ្ជរិតក* (សត្វ)ដែលស៊ីត្រី ជ្រូកស្រុក និងត្រីគ្រប់ប្រភេទ។

---

**៧.** 'អាហារដែលបូជាអាទិទេព' គេឱ្យឈ្មោះថា *នៃវេទ្យ*។ អាហារនេះ និងអាហារបូជាយញ្ញ ជាអាហារសម្រាប់បូជាព្រះអគ្គី គេមិនត្រូវទទួលទាននៅមុនពេលធ្វើពិធីទេ បន្ទាប់មកអាហារដែលនៅសល់គេអាចទទួលទានបាន(មេធ., គោវ., កុល្លូ.)។

**៨.** *សន្ទិនី* 'មេគោកំពុងរកឈ្មោល' (កុល្លូ., នារ., រាឃ.) ហើយតាមមេធ. និងគោវ. ថា 'គោដែលឱ្យទឹកដោះម្តង ក្នុងមួយថ្ងៃប៉ុណ្ណោះ' ហើយតាមនន្ទ. និង K. ថា 'មេគោដែលជាប់ជាកូន'។

**១១.** ការអនុញ្ញាតឱ្យទទួលទានសត្វដែលមានក្រចកមួយ តាមការកត់សម្គាល់របស់អ្នកនិពន្ធ មិនមាននិយាយនៅក្នុងតម្រាស្រ្មិតិទេ។ សំនួនវោហារនេះសំដៅដល់ករណីដែលព្រះវេទបញ្ញត្តិអំពីសត្វសេះជាដើម ដែលត្រូវគេសម្លាប់និងទទួលទាននៅក្នុងពិធីយញ្ញ។

**១២.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ *វេត្ទវាល* ជំនួសពាក្យ *វេត្ទវាល* ដែលមាននៅក្នុងអត្ថបទបោះពុម្ព។ *វេត្ទវាល* តាមលោកវិញ្ញានេស្វរៈ ថា សត្វស្លាបព្រៃ ហើយតាមនារ. ថា សត្វស្លាបទឹក។
**១៤.** ចំពោះពាក្យ *វកៈ* ឬ *ពកៈ*សូមមើលជំពូក៤ លេខ១៩៦ ខាងលើ។

១៥- អ្នកដែលទទួលទានសាច់(សត្វ)ណាមួយ ត្រូវគេហៅថាអ្នកស៊ីសាច់សត្វ(សត្វលោកណាមួយ) អ្នកដែលស៊ីត្រី គឺអ្នកស៊ីត្រី(គ្រប់ប្រភេទ) ហេតុនេះចូរអ្នកជៀសវាងសាច់ត្រី។

១៦- (ប៉ុន្តែត្រីដែលឈ្មោះថា)*បាឋីនៈ* និង *រោហិត* គេអាចទទួលទានបាន ប្រសិនបើប្រើសម្រាប់បូជាថ្វាយអាទិទេព ឬវិញ្ញាណក្ខន្ធបុព្វបុរស (គេអាចទទួលទានបាន)ដូចជា*រាជីវ, សឹហតុណ្ឌ* និង *សសល្ក* នៅក្នុង(ឱកាស)ទាំងអស់នោះ។

១៧- ចូរអ្នកកុំទទួលទានសត្វព្រៃនិងសត្វស្លាបដែលនៅឆ្ងាយពីគេ ឬដែលគេមិនស្គាល់ ទោះបីសត្វទាំងនោះអាចស្ថិតក្នុង(ប្រភេទសត្វ)ដែលអាចទទួលទានបានក៏ដោយ និងកុំទទួលទាន(សត្វ)ដែលមានម្រាមជើងប្រាំ។

១៨- សត្វពង្រូល កាំប្រមា ទន្សង រមាស អណ្តើក និងទន្សាយស្លឹក ជាសត្វដែលគេទទួលទានបាន ព្រមទាំង(សត្វស្រុក)ទាំងអស់ដែលមានធ្មេញនៅត្រង់ថ្គាមប៉ុណ្ណោះ លើកលែងសត្វអូដ្ឋ។

១៩- អ្នកមានកំណើតពីរដង ដែលទទួលទានផ្សិត ជ្រូកស្រុក ខ្ទឹមស មាន់គកស្រុក ខ្ទឹមបារាំង ឬដើមគូឆាយ ដោយចេតនា នឹងក្លាយមនុស្សក្រៅសង្គម។

២០- អ្នកដែលទទួលទាន (របស់ណាមួយ) ក្នុងចំណោមរបស់ទាំងប្រាំមួយនេះដោយអចេតនា នឹងត្រូវធ្វើ*សាំតបន* (ក្ឫច្ឆ្រៈ) ឬតបះក្រោមពន្លឺព្រះច័ន្ទ(ចាន្ទ្រាយណ)ជាតាបស ក្នុងករណី (អ្នកបានទទួលទានអាហារហាមឃាត់)ណាមួយ អ្នកនឹងត្រូវសុំសីលចំនួនមួយថ្ងៃ(មួយយប់)។

២១- មួយឆ្នាំម្តង ព្រាហ្មណ៍ត្រូវធ្វើតបះក្ឫច្ឆ្រៈ ដើម្បីលាងបាបក្នុងការទទួលទាន(អាហារហាមឃាត់) ដោយអចេតនា ប៉ុន្តែបើ(ទទួលទានអាហារហាមឃាត់)ដោយចេតនា គេត្រូវធ្វើតបះពិសេសដូចបានរៀបរាប់។

២២- សត្វព្រៃ និងសត្វស្លាប (ដែលអាចទទួលទានបាន) ព្រាហ្មណ៍អាចសម្លាប់ដើម្បីពិធីយញ្ញបាន និងដើម្បីផ្គត់ផ្គង់អ្នកទាំងឡាយដែលខ្លួនមានកាតព្វកិច្ចត្រូវចិញ្ចឹម ព្រោះ *អគស្ត្យ* បានធ្វើដូច្នេះយូរណាស់មកហើយ។

២៣- ដោយពី(សម័យ)បុរាណ នំពិធីយញ្ញត្រូវគេធ្វើ (ពីសាច់) សត្វព្រៃនិងសត្វស្លាប ដែលអាចទទួលទានបាន ក្នុងពេលមានពិធីយញ្ញរបស់ព្រាហ្មណ៍ និងក្សត្រិយ។

២៤- អាហាររឹង ឬទន់ដែលស្របច្បាប់ទាំងអស់ គេអាចទទួលទានបាន ទោះបីជាសល់យូរ (បន្ទាប់ពីលាយសារធាតុ)ខ្លាញ់ហើយក្តី ដូចនេះអាចទទួលទានអាហារសល់ពីពិធីយញ្ញបាន។

២៥- ប៉ុន្តែការរៀបចំអាហារស្រូវបាឡេនិងស្រូវសាឡី ព្រមទាំងអាហារទឹកដោះ អ្នកមានកំណើតពីរដងអាចទទួលទានបាន ដោយមិនចាំបាច់លាយជាមួយ(សារជាតិ)ខ្លាញ់ទេ ព្រោះថាអាហារនោះអាចទុកបានយូរផង។

---

**១៦.** នារ. ប្រែពាក្យ *អេកចរាន*សត្វដែលនៅទីស្ងាត់ដាច់ពីគេ' ដោយថា 'សត្វដែលនៅក្នុងហ្វូង' (សំយការិណៈ)។

**២០.** ចំពោះ*សាំតបន ក្ឫច្ឆ្រៈ* និងការធ្វើតបៈក្រោមពន្លឺខែរបស់តាបស មើលជំពូក១១ លេខ២១៣ និង២១៩ ខាងក្រោម។
**២១.** ចំពោះការធ្វើតបៈក្ឫច្ឆ្រៈ សូមមើលជំពូក១១ លេខ២១២ ខាងក្រោម។
**២២.** វស. ជំពូក១៤ លេខ១៥។

២៦- ដូច្នេះដោយបានរៀបរាប់ទាំងស្រុង អំពីអាហារដែលអាចទទួលទានបាន និងដែលហាមឃាត់សម្រាប់អ្នកមានកំណើតពីរដង ពេលនេះ ខ្ញុំនឹងថ្លែងអំពីវិធាន/ក្បួនសម្រាប់ការទទួលទាន និងការជៀសវាងសាច់។

២៧- អ្នកអាចទទួលទានសាច់ នៅពេលសាច់ត្រូវក្រលាស់ត្រូវទឹកមន្រ្ត ខណៈពេលគេសូត្រមន្រ្ត នៅពេលព្រាហ្មណ៍ចង់(ធ្វើបែបនោះ) នៅពេលអ្នកចូលរួម(ក្នុងពិធីបុណ្យ) ស្របតាមច្បាប់ និងនៅពេលជីវិតរបស់ខ្លួនកំពុងស្ថិតក្នុងគ្រោះថ្នាក់។

២៨- ព្រះជាម្ចាស់(ប្រជាបតិ) បានបង្កើត (ពិភពលោកទាំងមូល) នេះ ឱ្យមានចំណីអាហារសម្រាប់ទ្រទ្រង់អាយុជីវិត ហើយទាំងវត្ថុមានចលនានិងគ្មានចលនា (សុទ្ធតែមាន)អាហារទ្រទ្រង់ជីវិត។

២៩- អ្វីដែលគ្មានចលនាជាអាហាររបស់សត្វដែលចលនា,(សត្វ)ដែលគ្មានធ្មេញ (ជាអាហារ) របស់សត្វដែលមានធ្មេញ, សត្វដែលគ្មានដៃ ជាអាហាររបស់សត្វដែលមានដៃ ហើយសត្វកំសាកជាអាហាររបស់សត្វអង់អាច។

៣០- អ្នកស៊ីគេ ដែលប្រហារចំណីសម្រាប់ជាអាហាររបស់ខ្លួនប្រចាំថ្ងៃ មិនប្រព្រឹត្តបាបកម្មឡើយ ព្រោះអ្នកបង្កើតរូបគេមក បានបង្កើតទាំងអ្នកស៊ីគេនិងអ្នកដែលត្រូវគេស៊ី (ក្នុងបំណងពិសេសទាំងអស់នេះ)។

៣១- 'ការប្រើប្រាស់សាច់(គឺសមរម្យ)សម្រាប់ពិធីយញ្ញ' អាទិទេពបានប្រកាសបង្កើតវិធាននេះឡើង ប៉ុន្តែការបន្ត(ប្រើប្រាស់វា)ក្នុង(ឱកាស)ផ្សេងទៀត ត្រូវតែសមស្របនឹងពិធីពក្យសៈ។

៣២- អ្នកដែលស៊ីសាច់ នៅពេលគេបូជាព្រះអាទិទេព និងវិញ្ញាណក្ខន្ធបុព្វបុរស មិនប្រព្រឹត្តអំពើបាបទេ ទោះបីគេបានទិញ ឬសម្លាប់(សត្វនោះ)ដោយខ្លួនឯងក៏ដោយ ឬបានទទួលវាជាអំណោយពីអ្នកដទៃក្តី។

៣៣- អ្នកមានកំណើតពីរដង ដែលចេះច្បាប់ មិនត្រូវទទួលទានសាច់ទេ លើកលែងតែស្របតាមច្បាប់ ព្រោះបើសិនគេបានទទួលទានសាច់ដោយខុសច្បាប់ គេនឹងមិនអាចសង្គ្រោះខ្លួនឯងបាន និងត្រូវ(សត្វរងគ្រោះ)របស់គេនោះនឹងស៊ីគេវិញនៅជាតិក្រោយ។

៣៤- បន្ទាប់ពីស្លាប់ ទោសរបស់អ្នកដែលសម្លាប់សត្វក្តាន់ដើម្បីរកចំណេញ មិនមែនជាទោស(ធ្ងន់) ដូចទោសរបស់អ្នកដែលស៊ីសាច់ ដែលមិនសម្រាប់បំណងពិសិដ្ឋ។

៣៥- ប៉ុន្តែអ្នកដែលចូលរួមដោយត្រឹមត្រូវ (ធ្វើជាអធិបតី ឬទទួលទានក្នុងពិធីពិសិដ្ឋ) បដិសេធមិនទទួលទានសាច់ ជាតិក្រោយនឹងក្លាយជាសត្វរហូតដល់ម្ភៃមួយអត្តិភាព។

---

**២៧-៥៦.** វស. ជំពូក៤ លេខ៥-៨; វិ. ជំពូក៥១ លេខ៥៩-៧៨; យញ្ញ. ជំពូក១ លេខ១៧៨-១៨១។
**២៧.** សាច់ ត្រូវទឹកមន្រ្ត ក្នុងពិធីយញ្ញស្រោត។
**៣៤.** 'នៃអ្នកដែលសម្លាប់ក្តាន់ដើម្បីរកចំណេញ' គឺជាអ្នកប្រមាញ់អាជីព ឬពួកវណ្ណៈថ្នាក់ក្រោយដទៃទៀត។

**៣៥.** វស. ជំពូក១១ លេខ៣៤។

៣៦- ព្រាហ្មណ៍មិនត្រូវទទួលទាន(សាច់)សត្វដែលមិនទាន់បានប្រសិទ្ធីដោយមន្ត្រ ប៉ុន្តែដោយគោរពតាមច្បាប់បុរាណ គេអាចទទួលទានវាបាន ដោយការប្រសិទ្ធីធម៌ព្រះវេទ។

៣៧- ប្រសិនបើគេមានចំណង់ខ្លាំង(ចង់ទទួលទានសាច់) គេអាចធ្វើបីសុទ្ធជារូបសត្វ ឬម្សៅ (ហើយទទួលទានវាបាន) ប៉ុន្តែចូរអ្នកកុំរកវិធីប្រហារសត្វ ដោយគ្មានហេតុផល(ត្រឹមត្រូវតាមច្បាប់)។

៣៨- រោមសត្វព្រៃដែលស្លាប់ទៅមានចំនួនច្រើនប៉ុនណា ការពិតអ្នកដែលបានសម្លាប់វាដោយគ្មានហេតុផលស្របច្បាប់នឹងទទួលរងនូវសេចក្ដីស្លាប់ប៉ុណ្ណោះដងដោយហិង្សាក្នុងកំណើតអនាគត។

៣៩- ព្រះស្វយំភូ (ស្វ័យអត្ថិភាព)បានបង្កើតសត្វដោយផ្ទាល់ ដើម្បីពិធីយញ្ញ, ពិធីយញ្ញ (ត្រូវបានបង្កើតឡើង)ជាប្រយោជន៍នៃ(ពិភពលោក)ទាំងមូល ហេតុនេះការសម្លាប់(សត្វព្រៃ) សម្រាប់ពិធីយញ្ញ គឺមិនមែនជាការសម្លាប់ (ដូចន័យពាក្យធម្មតា)នោះទេ។

៤០- តិណាទេស ដើមឈើ សត្វពាហនៈ សត្វស្លាប និងសត្វដទៃទៀត ដែលត្រូវគេប្រហារសម្រាប់ពិធីយញ្ញ ទទួល(ចាប់កំណើត)ខ្ពស់ជាងមុន។

៤១- ក្នុងការផ្ដល់អាហារលាយទឹកឃ្មុំ(ជូនភ្ញៀវ) ក្នុងពិធីយញ្ញ និងពិធីសាសនានានាដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធ ប៉ុន្តែសម្រាប់តែក្នុងឱកាសទាំងអស់នេះប៉ុណ្ណោះទើបគេអាចសម្លាប់សត្វបាន ហើយនោះជា(វិធាន)ដែលមនុបានប្រកាសឡើង។

៤២- អ្នកមានកំណើតពីរដងដែលមានការយល់ដឹងអត្ថន័យពិតនៃព្រះវេទ សម្លាប់សត្វក្នុងបំណងទាំងអស់នេះ ញុំាងឱ្យទាំងខ្លួនគាត់និងសត្វឡើងទៅកាន់ឋានមួយដ៏សុខក្រៃលែង។

៤៣- អ្នកមានកំណើតពីរដង ដែលមានចិត្តប្រកបដោយគុណធម៌ ថ្វីបើគេរស់នៅក្នុងផ្ទះ(របស់ខ្លួនផ្ទាល់)ក៏ដោយ នៅជាមួយគ្រូក៏ដោយ ឬនៅក្នុងព្រៃក៏ដោយ ទោះបីក្នុងគ្រាអាសន្នក្ដីក៏មិនត្រូវបង្កទុក្ខលំបាក (ដល់សត្វលោក) ណាមួយដែលព្រះវេទមិនបានអនុញ្ញាតទេ។

៤៤- ចូរដឹងថា ការបង្ករបួសស្នាមដល់សត្វមានចលនា និងសត្វគ្មានចលនា ដែលព្រះវេទបានបញ្ញត្តិសម្រាប់ឱកាសមួយចំនួន គឺមិនមែនជាការបង្កអន្តរាយទាល់តែសោះ ព្រោះច្បាប់ពិសិដ្ឋកើតចេញពីព្រះវេទ។

៤៥- អ្នកដែលបង្ករបួសស្នាមដល់សត្វដែលគ្មានទោស ដោយបំពេញសេចក្ដីរីករាយផ្ទាល់ខ្លួន កុំស្វែងរកការសប្បាយនោះ ទាំងសត្វរស់ និងទាំងសត្វងាប់។

៤៦- អ្នកដែលមិនរកវិធីបង្កឱ្យរងទុក្ខ និងស្លាប់ដល់សត្វមានជីវិត (ប៉ុន្តែ) ប្រាថ្នាធ្វើល្អដល់សត្វលោកទាំងអស់នឹងទទួលពរជ័យគ្មានទីបញ្ចប់។

---

**៣៧.** *សង្គេ* 'បើ(អ្នកមាន)បំណងចង់(សាច់)យ៉ាងខ្លាំង'(កុល្ល., រាឃ.) ហើយតាមមេធ. និង K. ថា 'បើឱកាស(តម្រូវឱ្យសម្លាប់សត្វក្នុងពិធីមិនមែនវេទ' និងយោងតាមគោវ. 'ក្នុងករណី(អ្នកទទួលរងនូវ)ការវាយប្រហារពីព្រលឹងបិសាច(ភូតៈនិងផ្សេងទៀត' ហើយយោងតាមនន្ទ. 'ក្នុងឱកាសការជួបជុំគ្នា'។ រាឃ. ចាត់ទុកយោបល់របស់មេធ. ថាជាការបកស្រាយបន្ថែមតាមចិត្ត ហើយនារ.បានជំទាស់ការប្រែរបស់គោវ.។ ការបកស្រាយផ្ទាល់របស់គាត់ចំពោះពាក្យ *សង្គេ ត្យន្តេកាយាំ* ជាការភាន់ច្រឡំ ប៉ុន្តែទំនងជាចង់សំដៅដល់ *អឃ្យន្តេក្វាយាំ* ដូច្នេះហើយគាត់យល់ស្របតាមមតិរបស់កុល្ល.។

**៤៦.** ផ្នែកខាងក្រោយនៃកាព្យនេះ គេក៏អាចប្រែថា 'នឹងទទួលបានពរជ័យគ្មានទីបញ្ចប់ ព្រោះគេជាមនុស្សដែលមានចិត្តប្រោសប្រណីសត្វលោកទាំងអស់'(គោវ.)។

៤៧- អ្នកដែលមិនបង្កអន្តរាយដល់(សត្វលោក)ណាមួយ អាចសម្រេចបានដោយស្រួលនូវអ្វីដែលគេចង់បាននូវអ្វីដែលគេកំពុងធ្វើ និងនូវអ្វីដែលគេដាក់ចិត្តធ្វើ។

៤៨- គេមិនអាចបានសាច់ ដោយគ្មានការបង្កអន្តរាយដល់សត្វមានជីវិត ហើយការបង្កអន្តរាយដល់សត្វលោកជាឧបសគ្គរារាំង (ការទទួលបាន) ពរជ័យឡើងឋានសួគ៌ ហេតុនេះចូរអ្នកជៀសវាង (ការប្រើប្រាស់)សាច់ឱ្យបាន។

៤៩- ដោយបានពិចារណាច្បាស់លាស់អំពីប្រភពសាច់ (ដែលគួរឱ្យខ្ពើម) និង(ភាពឃោរឃៅក្នុង) ការឃុំឃាំង និងសម្លាប់ជីវិតសត្វ ចូរអ្នកកុំទទួលទានសាច់តែម្តង។

៥០- អ្នកដែលមិនខ្វល់ពីវិធាន(ខាងលើ) មិនទទួលទានសាច់ដូចជាបិសាច នឹងក្លាយជាមនុស្សល្អ ហើយនឹងមិនមានជំងឺផ្សេងៗទេ។

៥១- អ្នកដែលផ្តល់ឱកាស(ដល់អ្នកសម្លាប់សត្វ) អ្នកដែលកាប់ចិញ្ច្រាំសាច់ អ្នកដែលសម្លាប់សត្វ អ្នកដែលទិញ ឬលក់(សាច់) អ្នកដែលចំអិនសត្វ អ្នកដែលយកសាច់ធ្វើជាអាហារ និងអ្នកដែលទទួលអាហារ (សុទ្ធតែត្រូវគេចាត់ទុកថាជា) អ្នកសម្លាប់(សត្វ)ទាំងអស់។

៥២- តែបាបកម្មមិនធ្ងន់ធ្ងរជាង (អ្នក) ដែល ទោះបីមិនមានការបូជាអាទិទេពឬវិញ្ញាណក្ខន្ធក្តី ក៏នៅតែខំបង្កើន(គំនរ)សាច់របស់ខ្លួន ដោយការយកសាច់ពី(សត្វ)ដទៃៗទៀត។

៥៣- អ្នកដែលធ្វើពិធីបូជាយញ្ញសេះរាល់ឆ្នាំក្នុងអំឡុងពេលមួយរយឆ្នាំ និងអ្នកដែលតមហូបសាច់ទាំងស្រុង នឹងទទួលបានផលដូចគ្នាចំពោះ(អំពើ)កុសលរបស់ពួកគេ។

៥៤- ដោយការចិញ្ចឹមជីវិតអាស្រ័យលើផ្លែឈើនិងមើមឈើសុទ្ធ និងដោយការបរិភោគអាហារសមស្របសម្រាប់តាបស(នៅក្នុងព្រៃ) គេមិនបានទទួលផលកុសល(ច្រើន) ដូចជាអ្នកជៀសវាង (ការប្រើប្រាស់) សាច់ទាំងស្រុងទេ។

៥៥- '*មេ ហេ* (ការទទួលទាន*មំសៈ* នឹងវិនាសនៅ(ជាតិ)ក្រោយ ដូចជាសាច់ដែលខ្ញុំទទួលទានក្នុង (ជាតិនេះ) ហើយបណ្ឌិតប្រកាសប្រាប់ន័យពិតប្រាកដនៃពាក្យ សាច់ ថា (មំសៈ)។

៥៦- ការទទួលទានសាច់ការ(ផឹក)គ្រឿងស្រវឹងនិងការរួមសង្វាស់ មិនមែនជាអំពើបាបទេ ព្រោះអំពើនោះជាដំណើរធម្មជាតិរបស់សត្វលោក ប៉ុន្តែការតម នឹងផ្តល់បុណ្យកុសលមហាសាល។

៥៧- ពេលនេះ ខ្ញុំនឹងបកស្រាយតាមលំដាប់លំដោយអំពីការសម្អាតសាកសព និងការបន្សុទ្ធអ្វីសម្រាប់វណ្ណៈទាំងបួន។

៥៨- នៅពេល(កុមារ)ស្លាប់ កុមារនោះមានធ្មេញឬកុមារដែលនៅមិនទាន់មានធ្មេញ បានទទួល (ពិធីកោរជក់)ការកោរសក់(*ចូឌាករណ*)ឬ(ពិធីបញ្ចូលសមាជិកថ្មី) សាច់ញាតិទាំងអស់(នឹង) សៅហ្មង និងនៅថ្ងៃកំណើត(របស់ក្មេង) (វិធាន)ដដែលនេះត្រូវបានបញ្ញត្តិ។

---

**៥៣.** *មនុស្សន្ទានិ* 'អាហារដែលសមស្របសម្រាប់តាបស(ក្នុងព្រៃ)' គឺ 'ស្រូវធម្មជាតិ និងភោគផលអនុផលព្រៃឈើផ្សេងៗ'។

**៥៦.** 'មិនមានបាបទេ' ពោលគឺក្នុងការធ្វើអំពើទាំងនេះ នៅពេលដែលច្បាប់អនុញ្ញាត។

**៥៨-១០៤.** អាប. ជំពូក១ លេខ១៥, ១៨; ជំពូក២ លេខ១៥, ២-១១; គោត. ជំពូក១៤; វស. ជំពូក៤ លេខ១៦-៣៧; ពោធ. ជំពូក១ លេខ១១, ១-៨, ១៧-២៣, ២៧-៣២; វិ. ជំពូក២២; យញ្ញ. ជំពូក៣ លេខ១-៣០។

៥៩- តាមបញ្ញត្តិគឺ(ថា)ក្នុងចំណោម*សបិណ្ឌ*ភាពមិនបរិសុទ្ធ(ការកាន់ទុក្ខ)នៅពេលស្លាប់ (គួរមាន) រយៈពេលដប់ថ្ងៃ (ឬ)រហូតដល់ពេលគេរើសឆ្អឹង (ឬ)បីថ្ងៃ ឬមួយថ្ងៃប៉ុណ្ណោះ។

៦០- ក៏ប៉ុន្តែខ្សែញាតិ*សបិណ្ឌ* ឈប់រាប់ត្រឹមអ្នកទីប្រាំពីរ (ឡើងទៅលើ និងចុះក្រោម) ខ្សែ*សមានូទក* ប្រសិនបើដើមកំណើត(ធម្មតា) និង(អត្ថិភាពរបស់គ្រួសារទូទៅ) ឈ្មោះ(លែងត្រូវ)គេស្គាល់ទៀតហើយ។

៦១- ដោយសារភាពមិនបរិសុទ្ធក្នុងពេលមានមរណភាពត្រូវបញ្ញត្តិសម្រាប់*សបិណ្ឌ* (ទាំងអស់)ដូច្នេះ ហើយគេគួរ (កំណត់យក) ការចាប់កំណើត អាស្រ័យលើអ្នកដែលចង់បានភាពបរិសុទ្ធទាំងស្រុង។

៦២- (ឬខណៈដែល)ភាពមិនបរិសុទ្ធក្នុងពេលមានមរណភាព គឺទូទៅសម្រាប់*(សបិណ្ឌ)* ទាំងអស់ ដែលបានចាប់កំណើតជាមួយឪពុកម្ដាយប៉ុណ្ណោះ (ឬ)គួរសម្រាប់តែម្ដាយប៉ុណ្ណោះ ហើយឪពុកគួរតែបរិសុទ្ធ ដោយការងូតទឹក,

៦៣- ប៉ុន្តែបុរស ដោយបានចំណាយកម្លាំងរបស់ខ្លួន គ្រាន់តែបន្សុទ្ធកាយចិត្តដោយការមុជទឹក ហើយ បន្ទាប់ពីផ្ដល់កំណើតកូន (ជាមួយស្ត្រីដែលរៀបការលើកទីពីរ) គេគួរតែសម្អាតភាពមិនបរិសុទ្ធក្នុងអំឡុងបីថ្ងៃ។

---

**៥៨.** មេធ. និងគោវ. ពន្យល់ពាក្យ *អនុគាតេ* ដែលប្រែដោយស្រួលថា 'មុនមានធ្មេញ' ជាការសន្មតជាមុនថា 'ក្មេងដែលមានអាយុតិចជាងក្មេងដែលមានធ្មេញ' (*គាតទន្តាទ ពាលតរ ឥតិ ស្មរន្តិ*) ហើយនារ. និងរាឃ. យល់ស្របតាមការបកប្រែនេះ។ ប៉ុន្តែលោកកុល្ល. ហាក់ដូចជាប្រែក្នុងន័យថា 'ក្រោយពេលដុះធ្មេញ' ហើយនន្ទ. បកស្រាយឃ្លានេះថា 'ក្មេងដែលបានកើតម្ដងទៀត គឺត្រូវបានគេធ្វើពិធីបញ្ចូលជាសមាជិកថ្មី'។ គោវ., នារ., កុល្ល. និងរាឃ. គិតថា តាមពាក្យទីពីរ *ច* 'ឬ' និងពាក្យ 'ដែលមានពិធីបញ្ចូលជាសមាជិកថ្មី' គេត្រូវតែយល់បាន។

**៥៩.** ឆ្អឹងរបស់ព្រាហ្មណ៍ត្រូវរើស(ប្រមូល)នៅថ្ងៃទីបួន សូមមើល វិ. ជំពូក១៩ លេខ១០។ អ្នកនិពន្ធទាំងឡាយមានយោបល់ថា រយៈពេលនៃភាពមិនបរិសុទ្ធ យោងតាមមេរៀនបញ្ជាក់នៅក្នុងស្ម្រិតិផ្សេងទៀត គឺអាស្រ័យលើឋានៈរបស់អ្នកកាន់ទុក្ខ និងថា មនុស្សដែលចេះមន្ត្រតែក្នុងមួយសាខាប៉ុណ្ណោះ នឹងមិនបរិសុទ្ធក្នុងអំឡុងបួនថ្ងៃ អ្នកដែលចេះសាខាទាំងមូល (ឬវេទចំនួនពីរ) ក្នុងអំឡុងបីថ្ងៃ អ្នកដែលចេះវេទ (ឬវេទចំនួនបី) និងរក្សាភ្លើងបី ឬភ្លើងពិសិដ្ឋប្រាំ ក្នុងអំឡុងមួយថ្ងៃ។ ប៉ុន្តែ លោកមេធ. ប្រែតាមរបៀបមួយទៀត យោងតាមរយៈពេលទាំងបួន ត្រូវស្របទៅតាមវ័យទាំងបួនរបស់សាកសព ដែលបានបញ្ជាក់នៅក្នុងកាព្យខាងដើម។ យោងតាមទស្សនៈនេះ *សបិណ្ឌ* គួរកាន់ទុក្ខចំពោះមនុស្សដែលបានបញ្ចូលជាសមាជិកថ្មីហើយ ចំនួនដប់ថ្ងៃ ចំពោះអ្នកដែលបានធ្វើពិធីកោរជុក ចំនួនបួនថ្ងៃជាដើម។ ប៉ុន្តែសូមមើលកាព្យលេខ៦៧។

**៦១-៦២.** មេធ. និងគោវ. ប្រើតែកាព្យមួយ ជំនួសឱ្យកាព្យពីរគឺ *គននេ បី អេវំ ស្យាន មាតាបិត្រោស តុ សូតកំ / សូតកំ មាតុ អេវា ស្យាទ ឧបស្ប្រិស្យ បិតា សុខិះ//* 'ថ្វីបើដូច្នេះក្តី ក៏គេគួរកំណត់យកការចាប់កំណើត ឬភាពមិនបរិសុទ្ធគួរមានតែចំពោះឪពុកម្ដាយប៉ុណ្ណោះ ឬក៏គួរតែមានចំពោះម្ដាយប៉ុណ្ណោះ ហើយឪពុក (គួរមាន)ភាពបរិសុទ្ធដោយការមុជទឹក។' លោកនន្ទ. លុបចោលកាព្យលេខ៦១ពាក់កណ្ដាលដំបូង ហើយភ្ជាប់ពាក់កណ្ដាលទីពីរនៃកាព្យ៦១ ជាមួយនឹងឃ្លាពាក់

កណ្ដាលទីពីរនៃកាព្យ៦២។ គាត់បន្តធ្វើបែបនេះរហូតដល់កាព្យលេខ៦៥ ត្រង់ចំណុចពាក់កណ្ដាលទីពីរ។ ហេតុនេះ ការបកស្រាយកាព្យជាបន្តបន្ទាប់របស់គាត់ ពិតជាមិនមានប្រយោជន៍អ្វីទេ។

**៦៣.** ការប្រែខាងលើ យកតាមគោវ., កុល្ល., នារ. និងរាឃ.។ មេធ. យល់ផ្សេងពីគេ។

៦៤- អ្នកដែលបានប៉ះពាល់សាកសព ត្រូវបានទទួលភាពបរិសុទ្ធបន្ទាប់ពីមួយថ្ងៃមួយយប់ (ដោយថែមលើ) រយៈពេលបីថ្ងៃ ហើយអ្នកដែលធ្វើការចាក់ទឹកសែនបានបរិសុទ្ធ បន្ទាប់ពីបីថ្ងៃ។

៦៥- សិស្សដែលធ្វើពិធី*បិត្ធមេធ* ចំពោះគ្រូរបស់ខ្លួនដែលបានចែកឋានទៅ ក៏បានបរិសុទ្ធ បន្ទាប់ពីដប់ថ្ងៃ ដូចគ្នានឹងអ្នកដែលសែងសាកសពយក(ទៅបញ្ចុះ)ដូចគ្នា។

៦៦- ២ (ស្ត្រី) ត្រូវបានបន្សុទ្ធពីការរលូតកូន ក្នុងរយៈពេលច្រើន(ថ្ងៃនិង)យប់ ស្មើនឹងខែ(ដែលបានពពោះកន្លងផុតទៅ) ហើយស្ត្រីមានរដូវ នឹងបានបរិសុទ្ធដោយការមុជទឹក បន្ទាប់ពីឈាមរដូវបានឈប់ធ្លាក់។

៦៧- (នៅថ្ងៃមរណភាព) របស់ក្មេងដែលមិនទាន់បានធ្វើពិធីកោរជុក (*ចូឌាករម័ន*) នោះការធ្វើ (សបិណ្ឌ) ត្រូវចាត់ទុកថាអាចបរិសុទ្ធបានក្នុងរយៈពេលមួយ(ថ្ងៃនិង)មួយយប់ ហើយ(ចំពោះការស្លាប់)របស់ក្មេងដែលបានធ្វើពិធីកោរជុកហើយ (ប៉ុន្តែមិនទាន់បានធ្វើពិធីបញ្ចូលជាសមាជិកថ្មី ច្បាប់) កំណត់(ថា) ការបន្សុទ្ធកាយចិត្ត (កើតឡើង)បន្ទាប់ពីបីថ្ងៃ។

៦៨- ក្មេងដែលបានស្លាប់មុនគម្រប់ពីរខួប សាច់ញាតិគួរតែយកចេញពី(ភូមិ) ដោយតុបតែងដោយផ្កាភ្ញី រួចកប់សពនោះ)នៅក្នុងដីបរិសុទ្ធ ដោយមិនចាំបាច់ប្រមូលឆ្អឹង(តាមក្រោយ)ទេ។

៦៩- (ក្មេង)បែបនេះ គេមិនគួរបូជាដោយភ្លើងទេ ហើយគេមិនគួរបូជាទឹកដល់សពដែរ ដោយទុកចោល ទុកចោលដូចជា (កំណាត់) ឈើនៅក្នុងព្រៃ(សាច់ញាតិ) គួររក្សាភាពមិនបរិសុទ្ធ ក្នុងអំឡុងពេលបីថ្ងៃប៉ុណ្ណោះ។

៧០- សាច់ញាតិមិនគួរបូជាទឹកដល់ (ក្មេង) ដែលមិនទាន់មានអាយុដល់ឆ្នាំទីបីទេ ប៉ុន្តែបើក្មេងនោះមានធ្មេញឬបានធ្វើពិធីដាក់ឈ្មោះ(នាមករ)ហើយ (ការបូជាទឹកគឺ)ស្រេចតែនឹងចិត្ត។

៧១- បើសិស្សរួមថ្នាក់បានទទួលមរណភាពតម្រា*ស្មិតិ* បញ្ញត្តិភាពមិនបរិសុទ្ធគឺមួយថ្ងៃ ហើយការធ្វើពិធីបន្សុទ្ធដោយ*សមានោទក* ត្រូវបានប្រកាស(ឱ្យធ្វើបាន)បន្ទាប់ពីរយៈពេលបី (ថ្ងៃនិង)យប់។

---

**៦៤.** យោងតាមគោវ. និងនារ. តម្រាវិធាននេះសំដៅដល់ព្រាហ្មណ៍ណា ដែលសែងសាកសពទៅបូជា ដើម្បីបានលុយ ហើយបើយោងតាមកុល្ល. និងរាឃ. សំដៅដល់*សបិណ្ឌ* ដែលប៉ះពាល់សាកសព ដោយមិនគាប់ចិត្ត។ មេធ. គិតថា កាព្យនេះសំដៅដល់អ្នកទាំងអស់ដែលប៉ះពាល់ ឬសែងសាកសព ទោះជាដោយក្ដីស្រឡាញ់ក្ដៅ ឬដើម្បីបានលុយក្ដី។ រាឃ. គិតថា អត្ថបទលើកឡើងអំពីភាពមិនបរិសុទ្ធដែលមានដំណាក់កាលបីផ្សេងគ្នា គឺមួយថ្ងៃ បីថ្ងៃ និងដប់ថ្ងៃ។

**៦៥.** *បិត្ធមេធ* គឺជា *អន្ត្យេស្តិ* (តាមមេធ., គោវ., កុល្ល., រាឃ.) ឬជា ‘ពិធីបុណ្យខ្មោចទាំងមូល’(តាមអ្នកដទៃ និងមេធ.)។

**៦៦.** ដូច្នេះ យោងតាមកុល្ល., នារ. និងរាឃ. គិតថា តម្រាវិធាននេះសំដៅដល់ការរលូតកូន ដែលកើតឡើងក្នុងអំឡុងពេលប្រាំមួយខែនៃការមានគភ៌ និងថា ចាប់ពីខែទីប្រាំពីរ ទោះជាទាករនោះរស់ ឬមិនរស់ក៏ដោយ អំឡុងពេលមិនបរិសុទ្ធ គេត្រូវតែគិតទាំងស្រុង។ ជាងនេះទៅទៀត លោកនារ. អះអាងថា នៅក្នុងខែទីមួយនិងខែទីពីរ ភាពមិនបរិសុទ្ធគួរតែមានរយៈពេលបីថ្ងៃ។ *សាធ្វី* ‘ប្រែជាបរិសុទ្ធ’ គឺ ‘សមស្របនឹងការធ្វើពិធីពិសិដ្ឋ’(គោវ.)។ នារ. ប្រែពាក្យនេះក្នុងន័យថា ‘បរិសុទ្ធ’។

**៦៧.** នន្ទ. ដាក់បញ្ចូលកាព្យលេខ៧៨ បន្ទាប់ពីកាព្យ៦៦តែម្តង។

៧២- (ចំពោះមរណភាព) របស់ស្ត្រី(ដែលបានភ្ជាប់ពាក្យប៉ុន្តែ)មិនទាន់បានរៀបការ (កូនកំលោះនិងសាច់ញាតិរបស់ខ្លួន ត្រូវបន្សុទ្ធកាយចិត្តបន្ទាប់ពីរយៈពេលបីថ្ងៃ ហើយញាតិខាងឪពុកនឹងបរិសុទ្ធស្របតាមវិធានដូចគ្នា។

៧៣- ចូរ(អ្នកកាន់ទុក្ខ)ទទួលទានអាហារដោយគ្មានជាតិអំបិលក្លែងក្លាយ មុជទឹកក្នុងរយៈពេលបីថ្ងៃ តមសាច់ និងដេកដោយឡែកពីគ្នានៅលើដី។

៧៤- វិធានខាងលើស្តីពីភាពមិនបរិសុទ្ធ នៅពេលមានមរណភាព ត្រូវបានបញ្ញត្តិ (ក្នុងករណីដែលញាតិសន្តានប្រុសនៅមានជីវិត)នៅក្បែរ(សាកសព) ញាតិ(សបិណ្ឌ)និងញាតិ(សមានោទក) ត្រូវតែដឹងនូវវិធានខាងក្រោម (ដើម្បីអនុវត្តក្នុងករណីដែលសពនៅ)ឆ្ងាយពី(ពួកគេ)។

៧៥- អ្នកដែលអាចដឹងថា(មានសាច់ញាតិ)រស់នៅប្រទេសឆ្ងាយបានទទួលមរណភាព មុនពេលដប់ថ្ងៃ (បន្ទាប់ពីថ្ងៃមរណភាពនោះបានកន្លងផុតទៅ) គួរកាន់ទុក្ខរយៈពេលដែលសល់ពីដប់ (ថ្ងៃនិង) យប់ប៉ុណ្ណោះ។

៧៦- ប្រសិនបើពេលដប់ថ្ងៃបានកន្លងផុតទៅ គេគួរតែកាន់ទុក្ខក្នុងកំលុងពេលបី(ថ្ងៃនិង)យប់ ប៉ុន្តែបើមួយឆ្នាំបានកន្លងផុតទៅ (ចាប់តាំងពីថ្ងៃទទួលមរណភាព) គេនឹងបានបរិសុទ្ធឡើងវិញដោយគ្រាន់តែធ្វើពិធីមុជទឹកប៉ុណ្ណោះ។

៧៧- បុរសដែលបានដឹងពីមរណភាពសាច់ញាតិ(សបិណ្ឌ) ឬពីការប្រសូត្របុត្រា បន្ទាប់ពីដប់ថ្ងៃ(នៃការកាន់ទុក្ខបានកន្លងផុតទៅ) នឹងបានបរិសុទ្ធដោយការមុជទឹក ទាំងសម្លៀកបំពាក់របស់ខ្លួន។

៧៨- បើទារក(ដែលមិនទាន់មានធ្មេញ) ឬ(សាច់ញាតិធំពេញវ័យដែល) មិនមែនជា*សបិណ្ឌ* ទទួលមរណភាពនៅទីឆ្ងាយ គេនឹងបានបរិសុទ្ធភ្លាមបន្ទាប់ពីការមុជទាំងសម្លៀកបំពាក់របស់ខ្លួន។

៧៩- បើនៅក្នុងរយៈពេលដប់ថ្ងៃ(នៃភាពមិនបរិសុទ្ធ)មានការប្រសូត្រឬមរណភាព ព្រាហ្មណ៍គួររក្សាភាពមិនបរិសុទ្ធរហូតដល់កន្លងផុតរយៈពេលដប់ថ្ងៃ(ដំបូង)។

៨០- ពួកគេប្រកាសថា ពេលដែលមានគ្រូ (អាចារ្យ) ទទួលមរណភាព ភាពមិនបរិសុទ្ធ (មាន) រយៈពេលបីថ្ងៃ បើបុត្រាឬភរិយារបស់ (គ្រូទទួលមរណភាព ភាពមិនបរិសុទ្ធមាន) រយៈពេលមួយថ្ងៃមួយយប់ នេះជា(តម្រាវិធាន)ដែលបានកំណត់។

៨១- សម្រាប់*ស្រោត្រិយ* ដែលរស់នៅជាមួយ(គាត់ ដោយមិនជាប់ជំពាក់ចិត្តខ្លាំង) បុរសគួរមានភាពមិនបរិសុទ្ធរយៈពេលបីថ្ងៃ ចំពោះពូខាងម្តាយ កូនសិស្ស អាចារ្យពិធីការ ឬញាតិខាងម្តាយ (ភាពមិនបរិសុទ្ធមាន)ពេលមួយយប់ ដោយថែមមួយថ្ងៃមុននិងក្រោយ។

---

**៧២.** 'យោងតាមតម្រាវិធានដូចគ្នា' គឺ 'យោងតាមវិធានដែលមានចែងនៅក្នុងកាព្យ៦៧'(មេធ., គោវ., នន្ទ.) ឬ 'ដូចគ្នានឹងសាច់ញាតិខាងប្តីដែរ គឺ បន្ទាប់ពីបីថ្ងៃ' (កុល្លូ., នារ., រាឃ.)។

**៧៣.** នន្ទ. អាន *អទ្ធាំ* (ងូតទឹក) 'ប្រចាំថ្ងៃ' ជំនួសដោយ 'ក្នុងអំឡុងបីថ្ងៃ'។

**៨១.** *ឧបសំបន្នេ* 'ដែលរស់នៅជាមួយ(គាត់ ដោយជាប់ចិត្តខ្លាំង' តាមលោកមេធ.អាចមានន័យថា 'ដែលស្អាតស្អំ'។ តាម នារ. មានន័យថា 'ដែលជាអ្នកជិតខាង'។

៨២- បើសិនជាព្រះរាជានៅក្នុងអាណាចក្ររបស់ខ្លួនទទួលមរណភាព (គេគួរតែរក្សាភាពមិនបរិសុទ្ធ) ឱ្យបានយូររហូតដល់ពន្លឺ(ព្រះអាទិត្យ ឬផ្កាយរះ) ប៉ុន្តែចំពោះ(មិត្តជិតស្និទ្ធ) ដែលមិនមែនជាស្រោតិយ(ការរក្សាភាពមិនបរិសុទ្ធ មានរយៈពេល)ពេញមួយថ្ងៃ ដូចគ្នាចំពោះគុរុ ដែលចេះព្រះវេទ និងអង្គវេទដែរ។

៨៣- ព្រាហ្មណ៍គួរតែបរិសុទ្ធបន្ទាប់ពីដប់ថ្ងៃ, ក្សត្រិយបន្ទាប់ពីដប់ពីរថ្ងៃ, វៃស្យ បន្ទាប់ពីដប់ប្រាំថ្ងៃ និងសូទ្រៈ ត្រូវបរិសុទ្ធបន្ទាប់ពីមួយខែ។

៨៤- ចូរអ្នកកុំពង្រីករយៈពេលមិនបរិសុទ្ធ(ដោយមិនចាំបាច់) កុំបញ្ឈប់ពិធីយញ្ញបូជាព្រះអគ្គីពិសិដ្ឋ ព្រោះអ្នកដែលធ្វើពិធី (អគ្និហោត្រ) នឹងមិនមែនមិនបរិសុទ្ធនោះទេ ទោះបី (អ្នកជា) ញាតិ (សបិណ្ឌ)ក៏ដោយ។

៨៥- ពេលដែលអ្នកបានប៉ះពាល់*ចណ្ឌាល* ស្ត្រីមានរដូវ មនុស្សក្រៅវណ្ណៈ ស្ត្រីសម្រាលកូន សាកសព ឬ អ្នកដែលបានប៉ះ(សាកសព) អ្នកនឹងបរិសុទ្ធដោយការមុជទឹក។

៨៦- អ្នកដែលបានធ្វើឱ្យខ្លួនបរិសុទ្ធដោយការក្រេបទឹក គួរសូត្រពាក្យពិសិដ្ឋឱ្យជាប់ ពេលមើល(អ្វី ឬបុគ្គល)មិនបរិសុទ្ធ សំដៅដល់(កាព្យ)*សូរ្យ* និង*បាវមានី*។

៨៧- ព្រាហ្មណ៍ដែលបានប៉ះឆ្អឹងមនុស្សដែលនៅមានជាប់ជាតិខ្លាញ់ នឹងបានបរិសុទ្ធដោយការមុជទឹក បើសិនជាឆ្អឹងមិនមានជាប់ខ្លាញ់ ដោយគ្រាន់តែក្រេបទឹកនិងដោយការប៉ះមេគោ (តាមក្រោយ) ឬសម្លឹងមើលព្រះអាទិត្យ។

---

**៨២.** *អនូការេ គថា គុរោ* 'ដូចជាសម្រាប់គុរុ ដែលចេះព្រះវេទ និងអង្គវេទ' គឺ 'ដូចអ្នកដែលត្រូវបានរៀបរាប់ខាងលើ ជំពូក ២ លេខ១៤៩'(គោវ., កុល្លូ., រាឃ.)។ នារ. ប្រែពាក្យពីរនេះផ្សេងពីគ្នា។ មេធ. ភ្ជាប់ពាក្យ *អនូការេ* ជាមួយនឹង *អស្រោតិយេ* និងគិតថា បុរស គឺសំដៅដល់អ្នកដែលមិនចេះព្រះវេទ ប៉ុន្តែចេះអង្គវេទ។ គាត់ក៏បង្ហាញការបកស្រាយដូច បញ្ជាក់ជូនខាងលើស្រាប់។ នន្ទ.ជាចុងក្រោយអាន *អនូការេ គថា គុរោ* 'ដូចជាសម្រាប់អ្នកដែលចេះព្រះវេទ និងអង្គ តែមិនមែនជាគុរុ'។
**៨៤.** យោងតាមមេធ. ន័យនៃអនុប្រយោគទីមួយគឺថា បើមានជម្រើសរវាងរយៈពេលខ្លីជាង ឬវែងជាងនៃកាន់ទុក្ខ អ្នកកាន់ទុក្ខមិនត្រូវជ្រើសរើសយករយៈពេលវែងជាង ដើម្បីជៀសវាងមិនបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួនទេ។ គាត់បន្ថែមថា អ្នកនិពន្ធ ដទៃគិតថាជាការក្រើនរំលឹក កុំឱ្យពន្យាពេលពិធីមុជទឹក ដែលត្រូវធ្វើនៅពេលផុតរយៈពេលកាន់ទុក្ខ។ អ្នកនិពន្ធខ្លះទៀត ផ្តល់ការបកស្រាយតាមបែបទីមួយប៉ុណ្ណោះ។ អនុប្រយោគទីពីរ ដែលសំដៅដល់ការបន្តបូជាស្រោត អគ្និហោត្រ តាមលោកមេធ., គោវ. និងនន្ទ. មានន័យថា អគ្និហោត្រិន ដែលកំពុងកាន់ទុក្ខ មិនគួរធ្វើការបូជាដោយខ្លួនឯងទេ ប៉ុន្តែឱ្យអ្នកដទៃ ដែលជាសាច់ញាតិជិតដិតរបស់ខ្លួន ធ្វើជំនួសខ្លួនបាន។ កុល្លូ. នារ. និងរាឃ. គិតថា អ្នកធ្វើពិធីផ្ទាល់ក៏អាចធ្វើការបូជាបាន។ នន្ទ. បកស្រាយ *សនាភ្យះ* 'សបិណ្ឌ' (គោវ., កុល្លូ., នារ., រាឃ.) ដោយ *សហោទរះ* 'បងប្អូនប្រុសសុទ្ធសាធ'។
**៨៥.** *តត្សប្រិស្ថិនំ* 'អ្នកដែលបានប៉ះ(សាកសព)'(មេធ., គោវ., កុល្លូ., រាឃ.) ហើយតាមមេធ., នារ. និងនន្ទ. ថា 'អ្នកដែលបានប៉ះរបស់ណាមួយដូចបានរៀបរាប់ពីមុន មាន*ចណ្ឌាល* ជាដើម'។
**៨៦.** 'អ្នកដែលបានបន្សុទ្ធខ្លួនឯង' គឺ 'នៅមុនពេលអ្នកចាប់ផ្តើមបូជាព្រះអាទិទេព ឬវិញ្ញាណក្ខន្ធ'(មេធ., កុល្លូ., នារ.,រាឃ. និងអ្នកដទៃ)។ '(វត្ថុ ឬបុគ្គល)មិនបរិសុទ្ធ' គឺ 'អ្វីៗដែលបានរៀបរាប់ខាងលើ'។ មេធ. និងគោវ. ប្រែកាព្យនេះបែបផ្សេងថា 'អ្នកដែលមើលបុគ្គលមិនបរិសុទ្ធ ដូចបានរៀបរាប់ខាងលើ ចូរអ្នកក្រេបទឹក និងសូត្រធម៌ ទើបអាចបន្សុទ្ធបានជាដើម'។ ពាក្យដែលសំដៅដល់*សូរ្យ* ឃើញមាននៅក្នុងឫគ-វេទ ជំពូក១ លេខ៥០ ផ្នែកទីមួយ និងបាវមានី ក្នុង*មណ្ឌាល* ជំពូក៩។

៨៨- អ្នកដែលបានធ្វើពិធីសច្ចា មិនគួរចាក់ទឹកបូជា(ដល់សព)ទេ រហូតដល់ពេលបញ្ចប់ពិធីសច្ចាទាំងស្រុង ប៉ុន្តែពេលដែលអ្នកបានបូជាទឹកបន្ទាប់បញ្ចប់ពិធីនោះ អ្នកនឹងបានបរិសុទ្ធក្នុងរយៈពេលបីថ្ងៃប៉ុណ្ណោះ។

៨៩- ការបូជាទឹកមិនគួរធ្វើចំពោះអ្នកដែល (មិនប្រតិបត្តិពិធីបញ្ញត្តិ និងអាចនិយាយថា) ចំពោះអ្នកដែលមានកំណើតឥតប្រយោជន៍ ចំពោះអ្នកដែលមានកំណត់ដោយសារការលាយឡំនៃវណ្ណៈដែលមិនត្រឹមត្រូវតាមច្បាប់ ចំពោះអ្នកដែលប្រព្រឹត្តដូចជាតាបស (ដែលមានទិដ្ឋអញ្ញនិយម) និងចំពោះអ្នកដែលបានធ្វើអត្តឃាត,

៩០- ចំពោះស្ត្រីដែលបានរួមដំណេកជាមួយអ្នកតាំងខ្លួនជាតាបស ស្ត្រីដែលតាមរយៈកាមតណ្ហា អាចរស់នៅ (ជាមួយបុរសច្រើន) ស្ត្រីដែលបានរំលូតកូន ស្ត្រីដែលបានសម្លាប់ប្តីរបស់ខ្លួន ឬស្ត្រីដែលសេពគ្រឿងស្រវឹង។

៩១- សិស្សមិនត្រូវបំពានពាក្យសត្យរបស់ខ្លួន ដោយហ៊ានសែងសពគ្រូខ្លួនដែលចែកឋាន(អាចារ្យ), ឧបាធ្យាយ(គ្រូរង) ឪពុកម្តាយ ឬគុរុរបស់ខ្លួនផ្ទាល់ ទៅ(កាន់កន្លែងបូជាសព្វ)ទេ។

៩២- ចូរអ្នកសែងសាកសពសូទ្រៈ តាមក្លោងទ្វារខាងត្បូងក្រុង ប៉ុន្តែ(សពរបស់)អ្នកមានកំណើតពីរបើធ្វើឱ្យបានត្រឹមត្រូវ ត្រូវសែងតាម(ទ្វារ)ខាងលិច ខាងជើង ឬខាងកើត។

៩៣- ផលកម្មនៃភាពមិនបរិសុទ្ធនឹងធ្លាក់ទៅលើព្រះរាជា និងអ្នកដែលបានចូលរួមធ្វើពាក្យសត្យ ឬរបស់*សត្រ* ពីព្រោះ(អ្នកទីមួយ) ត្រូវអង្គុយលើរាជបល្ល័ង្កព្រះឥន្ទ្រ និង(ពីរអ្នកចុងក្រោយគឺជា) អ្នកបរិសុទ្ធដូចជាព្រាហ្មណ៍។

៩៤- ចំពោះព្រះរាជា ដែលស្ថិតលើបល្ល័ង្កនៃចិត្តអធ្យាស្រ័យ ការបានភាពបរិសុទ្ធភ្លាមដូចបានបញ្ញត្តិ ហើយហេតុផលគឺថា ទ្រង់គង់នៅលើ(បល្ល័ង្កនោះ) ដើម្បីការពារប្រជារាស្ត្រ(របស់ទ្រង់)។

---

៨៨. វិធានបញ្ជាក់អំពីសិស្ស ដែលមិនត្រូវធ្វើពិធីចុងក្រោយចំពោះសាច់ញាតិសព ក្នុងអំឡុងពេលខ្លួនជាសិស្សទេ លើកលែងតែម្តាយរបស់ខ្លួន(មេធ.) ឬលើកលែងម្តាយនិងឪពុករបស់ខ្លួន(គោវ.) ឬលើកលែងឪពុកម្តាយខ្លួននិងគ្រូរបស់ខ្លួន សូមមើលកាព្យលេខ៩១ ខាងក្រោម(កុល្លូ., រាឃ.)។ យោងតាម K. ថា អ្នកដទៃគិតថា វិធាននេះសំដៅដល់អ្នកដែលធ្វើតបៈក្រោមពន្លឺព្រះច័ន្ទ ឬពិធីប្រណិធានដទៃទៀត។

៨៩. 'ចំពោះអ្នកដែល(មិនប្រតិបត្តិពិធីបញ្ញត្តិ និងអាចនិយាយថាសម្រាប់អ្នក) ដែលមានកំណើតឥតប្រយោជន៍'(គោវ., កុល្លូ., នន្ទ., រាឃ.) ពោលគឺ 'ចំពោះអ្នកដែលមិនបានកាន់សិក្ខាបទវិន័យអ្វីសោះអស់មួយឆ្នាំ'(មេធ.) ឬ 'ចំពោះខន្ទី(មនុស្សកម្រៀវ)'(នារ.)។ ពាក្យ *សំករគា* 'ដែលមានកំណើតដោយល្បាយវណ្ណៈមិនស្របច្បាប់' រួមមានអ្នកដែលកើតពីម្តាយក្នុងវណ្ណៈខ្ពស់ជាងនិងឪពុកក្នុងវណ្ណៈទាបជាង, បុត្រារបស់មេម៉ាយដែលមិនស្គាល់ឪពុក និងដែលកើតពីអំពើផិតក្បត់ស្វាមី(មេធ., គោវ., នន្ទ.)។ 'ការតាំងខ្លួនជាតាបស (ជាអ្នកអញ្ញទិដ្ឋ)' គឺ *កាបាលិក* អ្នកស្លៀកពាក់ពណ៌ក្រហមជាដើម(មេធ.)។ នារ. និងរាឃ. ប្រែពាក្យនេះសំដៅដល់តាបសប្រកាន់វិន័យចាស់។

៩០. *បាសណ្ឌ* 'និកាយអញ្ញទិដ្ឋ' ជា *កាបាលិក* អ្នកដែលស្លៀកពាក់ពណ៌ក្រហម(មេធ.) ឬ 'និកាយ*ពុទ្ធ* ជាដើម'(នារ.)។

៩១. 'គុរុ' គឺជា 'អ្នកដែលបកស្រាយព្រះវេទ'(នារ., កុល្លូ.) ឬ 'អ្នកដែលមានរៀបរាប់ឈ្មោះខាងលើ ក្នុងជំពូក២ លេខ១៤៩'(មេធ., គោវ.)។

៩២. ពោលគឺ *វៃស្យៈ* សែងតាមក្លោងទ្វារខាងលិច ក្សត្រិយតាមទ្វារខាងជើង និងព្រាហ្មណ៍តាមទ្វារខាងកើត(មេធ., គោវ., កុល្លូ., នន្ទ., រាឃ.)។

៩៥- (វិធានដដែលត្រូវអនុវត្តចំពោះញាតិសន្តានប្រុស) នៃអ្នកដែលបានចូលប្រឡូកក្នុងកុប្បកម្ម ឬសមរភូមិ, (របស់អ្នកដែលត្រូវបានសម្លាប់) ដោយរន្ទះបាញ់ ឬដោយព្រះរាជា និង (របស់អ្នកដែលស្លាប់ក្នុងការប្រយុទ្ធ) ដើម្បីគោមេនិងព្រាហ្មណ៍ និងអនុវត្តចំពោះអ្នកដែលព្រះរាជាចង់ (ផ្តល់ភាពបរិសុទ្ធឱ្យ)។

៩៦- ព្រះរាជាជាការចាប់កំណើតពីអវតារអ្នកថែរក្សាទាំងប្រាំបីនៃចក្រវាល មានព្រះច័ន្ទ ព្រះអគ្គី ព្រះអាទិត្យ ព្រះពាយ ព្រះឥន្ទ្រ ព្រះធន និងព្រះគង្គា (កុពេរ និងវរុណ) និងព្រះយមៈ។

៩៧- ដោយហេតុថាព្រះរាជាមានជាតុនៃព្រះចក្រវាល (ទាំងអស់នោះ) គ្មានជាតុសៅហ្មងណាអាចប៉ះពាល់ទ្រង់បានទេ ព្រោះភាពបរិសុទ្ធនិងភាពមិនបរិសុទ្ធរបស់មនុស្សត្រូវបានបង្កើត និងបំផ្លាញទៅវិញដោយព្រះនៃចក្រវាល (ទាំងអស់នោះ)។

៩៨- ដោយសារអ្នកដែលស្លាប់ក្នុងសមរភូមិក្នុងពេលកាន់អាវុធក្នុងដៃ ស្របតាមច្បាប់ក្សត្រិយ ពិធី (ស្រោត) ត្រូវធ្វើឱ្យបានភ្លាម ហើយនេះជារយៈពេលកាន់ទុក្ខ (សម្រាប់មរណភាពរបស់គាត់) នេះគឺវិធានដែលបានកំណត់។

៩៩- (នៅចុងបញ្ចប់នៃរយៈពេលកាន់ទុក្ខ) ព្រាហ្មណ៍ដែលបានធ្វើពិធីយញ្ញចាំបាច់ នឹងបានបរិសុទ្ធដោយការប៉ះទឹក ក្សត្រិយដោយការប៉ះសត្វដែលជាយានជំនិះរបស់ទ្រង់ និងអាវុធរបស់ទ្រង់ វៃស្យដោយការប៉ះជន្លួញរបស់ខ្លួន ឬខ្សែកន្ទុះ(គោឈ្មោលរបស់ខ្លួន) ហើយសូទ្រៈដោយការប៉ះឈើច្រត់របស់ខ្លួន។

---

**៩៣.** ៶ការសច្ចា៎ គឺ ៶ភាពជាកូនសិស្ស(នារ.) ព្រមទាំងជាការធ្វើតបក្រោមពន្លឺច័ន្ទជាដើម៎(មេធ., គោវ., កុល្ល.) ហើយពាក្យ *សត្ត្រ* គឺ ៶ពិធីយញ្ញមួយដ៏វែង ដូចជា*គវាមយន*។ *ព្រហ្មភូតា* ៶បរិសុទ្ធដូចព្រហ្ម៎(កុល្ល., នារ., រាឃ.) តែតាមមេធ. គឺថា ៶ពួកគេបានសម្រេចភាពជាព្រហ្ម៎។

**៩៥.** នន្ទ.និង K. បកស្រាយពាក្យ *ទិម្ភៈ* ៶នៅក្នុងភាពរឹករវ៎ សំដៅដល់ ៶ដោយទារក៎។ ៶ដែលព្រះរាជាចង់(ឱ្យបានបរិសុទ្ធ)៎ គឺ ៶បរិវារ និងនាហ្មឺនកុង្សីយ៍របស់ទ្រង់ ដែលទ្រង់ត្រូវការសម្រាប់ព្រះរាជកិច្ចរបស់ទ្រង់៎។ នារ. ដាក់បញ្ចូលអនុប្រយោគមួយទៀត ៶(ញាតិខាងប្រុសរបស់អ្នកដែលត្រូវគេសម្លាប់) ដោយព្រាហ្មណ៍ ពោលគឺ ដោយការសែកមន្តគាថា៎។ ប៉ុន្តែខ្ញុំ មិនយល់ពីរបៀបប្រើពាក្យឱ្យសមស្របនឹងកាព្យនេះទេ។

**៩៦.** សូមមើលជំពូក៧ លេខ៤ ខាងក្រោម។

**៩៧.** មេធ. អាន *លោកេសប្រភវាប្យយោ* និងកាព្យផ្នែកកំណាត់ទីពីរ ដូចនេះត្រូវប្រែថា ៶ភាពបរិសុទ្ធ និងភាពមិនបរិសុទ្ធមានឥទ្ធិពលលើអារម្មណ៍មនុស្ស វាត្រូវបានបង្កើត និងធ្វើឱ្យបាត់ទៅវិញ ដោយអ្នកថែរក្សាលោក៎។ នារ., នន្ទ., និង K. អាន *លោកេសប្រភវោ ហី អយំ* ៶ប៉ុន្តែទ្រង់ ព្រះរាជាចាប់កំណើតពីអ្នកការពារលោក៎។ នារ. សរសេរអំណានថា *លោកេសប្រភវេ ប្យយៈ* ៶សម្រាប់ទ្រង់ដែលមានកំណើតពីអ្នកការពារពិភពលោក (ភាពបរិសុទ្ធ និងភាពមិនបរិសុទ្ធ) មិនមានទេ៎។

**៩៨.** យោងតាមលោកមេធ.ថា អ្នកខ្លះអះអាងថា វិធាននេះសំដៅដល់តែអ្នកដែលស្លាប់ក្នុងសមរភូមិប៉ុណ្ណោះ មិនសំដៅដល់អ្នកដែលស្លាប់ដោយសាររបួសរបស់ខ្លួននៅពេលក្រោយមកទេ។ *យញ្ញៈ* ៶ពិធីយញ្ញ(ស្រោត)៎(មេធ., កុល្ល., រាឃ.) ហើយតាមនារ.ថា ៶ពិធីបុណ្យសព៎។

**៩៩.** ៶ការប៉ះទឹក៎ គឺ ៶ការមុជទឹក៎(មេធ., កុល្ល., នារ.) ហើយគោវ. ថា ៶ការលាងដៃរបស់ខ្លួន៎។

១០០- ដូច្នេះការធ្វើឱ្យបរិសុទ្ធ (នៅពេលមានមរណភាពរបស់) សបិណ្ឌ ត្រូវបានបកស្រាយដល់អ្នកទាំងឡាយថា ឱ ប្រពៃណាស់ អ្នកមានកំណើតពីរដង; ឥឡូវនេះចូរស្តាប់អំពីរបៀបដែលមនុស្សបានភាពបរិសុទ្ធនៅពេលមានមរណភាព (សាច់ញាតិដែល) មិនមែនជាសបិណ្ឌ។

១០១- ព្រាហ្មណ៍ ដោយបានសែងសាកសពព្រាហ្មណ៍ដែលមិនមែនជាសបិណ្ឌ (បើគាត់ហាក់ដូចជា) ញាតិ(ជិតស្និទ្ធ)ឬជាញាតិខ្សែកិតខាងម្តាយរបស់ខ្លួន នឹងបានបរិសុទ្ធបន្ទាប់ពីបីថ្ងៃក្រោយ;

១០២- ប៉ុន្តែបើសិនជាអ្នកទទួលទានអាហាររបស់ (សបិណ្ឌរបស់សព) អ្នកនឹងបានបរិសុទ្ធក្នុងពេលដប់ថ្ងៃ(តែ)ក្នុងពេលមួយថ្ងៃ បើសិនជាអ្នកមិនបានទទួលទានអាហាររបស់ពួកគេ មិនបានស្នាក់ក្នុងផ្ទះរបស់ពួកគេ។

១០៣- ដោយបានដើរតាមសពដោយស្ម័គ្រចិត្ត ទោះបី(សពរបស់)ញាតិខាងឪពុកក្តី ឬ(របស់)ជនចម្លែកក្តី អ្នកនឹងបានបរិសុទ្ធដោយការមុជទឹកទាំងសម្លៀកបំពាក់របស់ខ្លួន ដោយការប៉ះភ្លើង និងទទួលទានប៊ឺសុទ្ធ។

១០៤- ចូរអ្នកកុំឱ្យពួកសូទ្រៈសែងសាកសពព្រាហ្មណ៍ បើសិនមានមនុស្សក្នុងវណ្ណៈដូចគ្នាអាចជួយបាន ព្រោះថាការបូជាភ្លើង ដែលមានភាពសៅហ្មងដោយការប៉ះរបស់សូទ្រៈ ជាឧបសគ្គរាំងផ្លូវ(របស់សាកសពឡើង) ឋានសួគ៌។

១០៥- ពុទ្ធិ(របស់ព្រាហ្មណ៍អំពី)ការធ្វើតបៈ ព្រះអគ្គី អាហារ(ពិសិដ្ឋ) ផែនដី (ការទប់)គ្រឿងវិញ្ញាណខាងក្នុងទឹក ការពង្រាយ(អាចម៍មេគោ) ខ្យល់ យញ្ញពិសិដ្ឋ ព្រះអាទិត្យ និងពេលវេលា គឺជាអ្នកធ្វើឱ្យបរិសុទ្ធនៃរាងកាយ(សត្វលោក)។

១០៦- ក្នុងចំណោមវិធីធ្វើឱ្យបរិសុទ្ធទាំងអស់ ភាពបរិសុទ្ធក្នុង(ការទទួល)ទ្រព្យ ត្រូវបានប្រកាសថាជាវិធីប្រសើរបំផុត ព្រោះអ្នកដែលបានទ្រព្យដោយបាតដៃស្អាតស្អំ ជាអ្នកបរិសុទ្ធ គឺមិនមែនអ្នកដែលធ្វើឱ្យខ្លួនបរិសុទ្ធដោយសារដី និងទឹកនោះទេ។

១០៧- អ្នកចេះដឹង ត្រូវបានបន្សុទ្ធដោយអារម្មណ៍អនុគ្រោះ អ្នកដែលបានប្រព្រឹត្តទង្វើហាមឃាត់ ដ៏ច្រើន អ្នកធ្វើអំពើបាបជាសម្ងាត់ (បានបរិសុទ្ធ)ដោយការសូត្រហឹមៗនូវ(ពាក្យពិសិដ្ឋ) និងអ្នកដែលចេះដឹងព្រះវេទល្អបំផុត (បរិសុទ្ធ)ដោយការធ្វើតបៈ។

---

**១០១.** (នារ.)ថា 'សំដៅដល់សាច់ញាតិខាងម្តាយខ្លួន និង(សគោត្រខាងឪពុកខ្លួន)ឬញាតិតាមចំណងអាពាហ៍ពិពាហ៍'។

**១០២.** ក្នុងករណីអ្នកស្នាក់នៅក្នុងផ្ទះអ្នកកាន់ទុក្ខ អ្នកនឹងបាត់ភាពបរិសុទ្ធរយៈពេលបីថ្ងៃ(គោវ., កុល្លូ., រាឃ., K.)។

**១០៤.** យោងតាមនារ. វិធាននេះសំដៅជាពិសេសដល់ព្រាហ្មណ៍ ហើយតាមមេធ. និងកុល្លូ. ថាសំដៅដល់ពួកអារ្យ៉ន់ទាំងអស់។ ការដុតសាកសព ត្រូវគេហៅជាពាក្យសម្រាយថា ការបូជាអគ្គី។

**១០៥.** វិ. ជំពូក២២ លេខ៨៨; យញ្ញ. ជំពូក៣ លេខ៣១; ពោធ. ជំពូក១ លេខ៨, ៥២។ (នារ.)សរសេរថា *មនះ ក្សមាក្សះ* (?) *និយមយុក្តំ មនោ គីវស្យ*។ អ្នកនិពន្ធខ្លះទៀត ប្រែ *មនះ* ថា 'មនោ ឬវិញ្ញាណខាងក្នុង' ក្នុងន័យថា 'បេះដូងសង្គ្រោះ'។

**១០៦.** វិ. ជំពូក២២ លេខ៨៩; យញ្ញ. ជំពូក៣ លេខ៣២។

**១០៧.** វិ. ជំពូក២២ លេខ៩០; យញ្ញ. ជំពូក៣ លេខ៣៣។

១០៨- ដោយដីនិងទឹកត្រូវបានធ្វើឱ្យបរិសុទ្ធនូវអ្វីដែលគួរតែបរិសុទ្ធ, ទន្លេ(បរិសុទ្ធ)ដោយចរន្តទឹក ស្ត្រីដែលមានគំនិតមិនបរិសុទ្ធដោយការមករដូវ, ព្រាហ្មណ៍(មិនបរិសុទ្ធ)ដោយការបោះបង់លោក(សំន្យាស)។

១០៩- សាកសពត្រូវសម្អាតដោយទឹក, វិញ្ញាណខាងក្នុងត្រូវបន្សុទ្ធដោយភាពសច្ចៈ, ព្រលឹងនីមួយៗត្រូវបរិសុទ្ធដោយការសិក្សានិងការធ្វើតបៈដ៏ពិសិដ្ឋ, បញ្ញវន្ត (បរិសុទ្ធ) ដោយចំណេះដឹងពិតប្រាកដ។

១១០- ដូច្នេះ វិធានដ៏ច្បាស់លាស់សម្រាប់ការធ្វើឱ្យកាយបរិសុទ្ធ ត្រូវបានប្រកាសជូនអ្នករាល់គ្នាហើយ ឥឡូវចូរស្តាប់ការវិនិច្ឆ័យ(ច្បាប់)ស្តីពីការធ្វើឱ្យបរិសុទ្ធវត្ថុ(គ្មានជីវិត)ផ្សេងៗ។

១១១- បណ្ឌិតលោកកំណត់ថា (វត្ថុ)ទាំងអស់ដែលធ្វើពីលោហៈ ត្បូងនិងអ្វីៗដែលធ្វើពីថ្ម ត្រូវលាងសម្អាតបានដោយផេះ ដី និងទឹក។

១១២- ភាជន៍មាស ដែលគ្មានស្នាមប្រឡាក់ នឹងស្អាតដោយសារទឹកតែម្យ៉ាង ដោយហេតុថាអ្វីដែលមាននៅក្នុងទឹក មានដូចជា (ខ្យងនិងផ្កាថ្ម), អ្វីដែលគេធ្វើពីថ្ម និង(ភាជន៍)ប្រាក់ មិនត្រូវឆ្លាក់ក្បាច់ទេ។

១១៣- ដោយមានការលាយទឹកនិងភ្លើង បានញ៉ាំងឱ្យមាសនិងប្រាក់មានពន្លឺចែងចាំង ដូច្នេះវត្ថុទាំងពីរត្រូវសម្អាតបានល្អដោយ(សារធាតុ)ដែលជាប្រភពនៃកំណើតរបស់វា។

១១៤- ស្ពាន់ ដែក ទង់ដែង សំណប៉ាហាំង ស័ង្កសី និងសំណ ត្រូវសម្អាត បានតាមសភាពសមស្រប (សម្រាប់ករណីនីមួយៗ) ដោយ(សារធាតុ)ទឹកក្បុង អាស៊ីត ឬទឹក។

១១៥- ការសម្អាតដែលបានរៀបរាប់(ប្រភេទ)វត្ថុរាវទាំងអស់ គឺដោយការដាក់ស្មៅ*កុសៈ* ពីរដើមអូសកាត់វត្ថុរាវនោះ,ចំពោះវត្ថុរឹងដោយការស្រោច(ទឹកដាក់វា),ចំពោះ(វត្ថុ)ដែលធ្វើពីឈើ ដោយការធ្វើឱ្យវាមានរូបរាងឡើង។

---

**១០៨.** វិ. ជំពូក២២ លេខ៩១; វស. ជំពូក៣ លេខ៥៨; យញ្ញ. ជំពូក៣ លេខ៣២។

**១០៩.** វិ. ជំពូក២២ លេខ៩២; វស. ជំពូក៣ លេខ៦០; យញ្ញ. ជំពូក៣ លេខ៣៣-៣៤។

**១១០.** វិ. ជំពូក២២ លេខ៩៣។

**១១១-១២៦.** អាប. ជំពូក១ លេខ១៧, ៨-១៣; ជំពូក២ លេខ៣, ៩; គោត. ជំពូក១ លេខ២៩-៣៤; វស. ជំពូក៣ លេខ៤៤-៥៧, ៥៩, ៦១-៦៣; ពោធ. ជំពូក១ លេខ៨, ៣២-៥៣,៩, ១-៤, ៧-១២, ១០, ១-៩; ១៣, ១១-១៤, ១៩; វិ. ជំពូក២៣ លេខ២-៤៦, ៥៦; យញ្ញ. ជំពូក១ លេខ១៨២-១៩០។

**១១២.** *អនុបស្ក្រិតំ* 'ដែលមិនលម្អដោយក្បាច់' តាមមេធ. និងនន្ទ. ក៏អាចមានន័យថា 'ដែលសៅហ្មងខ្លាំង'។ មេធ. និងនារ. បន្ថែមថា ពាក្យចុងក្រោយនេះ សំដៅដល់វត្ថុផ្សេងៗដែលបានរៀបរាប់នៅក្នុងកាព្យ។

**១១៣.** មេធ., គោវ. និងកុល្លូ. ស្រង់សេចក្តីព្រះវេទ ដែលបង្ហាញប្រភពមាសចេញពីព្រះអគ្និ និងទេពធីតា*វរុណានី*។

**១១៥.** ពាក្យ *ឧត្បវនំ* ឬ *ឧត្លវនំ* (គោវ., កុល្លូ., រាឃ.) ថា 'ដោយដាក់ស្មៅកុសៈពីរដើមកាត់វត្ថុនោះ' ហើយតាមមេធ. អ្នកនិពន្ធផ្សេងទៀត និង K. ថា 'ការសម្អាតដោយការចាក់វាចូលទៅក្នុងភាជន៍មួយទៀត ដែលមានវត្ថុរាវស្អាតក្នុងប្រភេទ ដូចគ្នា'។ តាមនារ.ថា 'ការត្រងដោយក្រណាត់'។ 'វត្ថុរឹង' គឺ 'គ្រែ កៅអី និងវត្ថុផ្សេងទៀត'។

១១៦-ក្នុងពិធីយញ្ញ ការសម្អាត(ពែង*សោម* ដែលគេហៅថា)*កមសៈ* និង *គ្រហ* និងការសម្អាតភាជន៍បុណ្យ(ផ្សេងទៀតធ្វើឡើង) ដោយការយកដៃជុស(វា)ហើយ(បន្ទាប់មក)ប្រើទឹកលាងសម្អាត(វា)។

១១៧-*ករុ* និង (ស្លាបព្រា ដែលគេហៅថា) *ស្រុក* និង*ស្រុវ* គេត្រូវសម្អាតដោយទឹកក្តៅ ដូចគ្នានឹង(ដាវឈើ ដែលគេហៅ)*ស្ប្យៈ* ចង្អេរអុំស្រូវ(សូរប) រទេះ(សម្រាប់ដឹកធញ្ញជាតិ) អង្រែ និងត្បាល់។

១១៨-វិធីសម្អាតគ្រាប់ធញ្ញជាតិ និងសម្លៀកបំពាក់ក្នុងបរិមាណច្រើន គឺត្រូវចាក់ទឹកដាក់វា ប៉ុន្តែការសម្អាតក្នុងបរិមាណតិច ត្រូវធ្វើដោយការលាងវា។

១១៩-ស្បែក និង(វត្ថុ)ដែលធ្វើពីបន្ទះផ្តៅ គេត្រូវសម្អាតដូចគ្នានឹងសម្លៀកបំពាក់ដែរ ហើយបន្លែ មើមឈើ និងផ្លែឈើ (សម្អាត)ដូចគ្រាប់ធញ្ញជាតិ;

១២០- សូត្រ និងវត្ថុដែលធ្វើពីឡែន (សម្អាត)ដោយដីក្បុង; ក្បួយ(សម្អាត)ដោយ(ផ្លែ)*អរិដ្ឋ* ដែលបុកបំបែករួច; *អំសុបត្ត* ដោយផ្លែ*ពេល;* ក្រណាត់និលិន ដោយ(ម្សៅ)ស្ពៃលឿង។

១២១-បុរស ដែលចេះ(ច្បាប់) ត្រូវសម្អាតសម្បកស័ង្ខ ស្នែង ឆ្អឹង និងភ្លុក ដូចក្រណាត់លិនិន ឬដោយទឹកលាយជាមួយនោមមេគោ។

១២២-ស្មៅ ឈើ និងចំបើង នឹងស្អាតដោយការស្រោចទឹកដាក់, ផ្ទះ(ស្អាត)ដោយសារការបោស និងដោយការលាប(អាចម៍គោ ឬកំបោរ), (ភាជន៍)ដី ដោយការដុតជាលើកទីពីរ។

១២៣-ភាជន៍ដី ដែលប្រឡាក់ដោយជាតិគ្រឿងស្រវឹង ទឹកនោម លាមក ទឹកមាត់ ខ្ទុះ ឬឈាម គេមិនអាចសម្អាត ដោយការដុតម្តងទៀតទេ។

១២៤- ការសម្អាតដី (អាចធ្វើ)ដោយវិធីប្រាំយ៉ាង(ដូចខាងក្រោម) ដោយការបោស ការលាប(អាចម៍គោ)ដោយការប្រោះ(ទឹកនោមឬទឹកដោះមេគោ) ដោយការយកទៅបោះចោល និងដោយឱ្យមេគោដេក(ពីលើមួយយប់មួយថ្ងៃ)។

១២៥-(អាហារ) ដែលត្រូវសត្វស្លាបចិក ត្រូវមេគោហិត ត្រូវប៉ះ(នឹងជើង) ត្រូវគេកណ្តាស់ដាក់ ឬមានជាប់សក់ ឬសត្វល្អិត នឹងបរិសុទ្ធ ដោយសារការបាចដី(ពីលើវា)។

---

**១១៩.** *វៃទលានំ* 'វត្ថុ ដែលធ្វើពីបន្ទះផ្តៅ'(កុល្លូ., K., រាឃ., នារ., នន្ទ.) ហើយតាមលោកមេធ. និងគោវ. ថា 'ដែលធ្វើពីសម្បកឈើជាដើម'។ មេធ. កត់សម្គាល់ថា វិធាននេះ និងវិធានដទៃទៀត ដែលមាននិយាយអំពីសម្បកជាដើម ក៏សំដៅដល់វត្ថុដែលធ្វើពីរបស់បែបនេះ ឧ.ទា. ស្បែកជើង។

**១២០.** *អរិដ្ឋ* គឺម្សៅសបិណ្ឌៈ ឈើដែលមានផ្លែតូចពពុះដូចសាប៊ូ។ តាមគោវ., នន្ទ. និងនារ. ពាក្យ *អំសុបត្ត* គឺ 'ក្រណាត់ដែលធ្វើពីសម្បកឈើស្តើងៗ' ហើយយោងតាមកុល្ល. និងរាឃ. ថា 'សម្លៀកបំពាក់ខាងលើសម្រាប់ស្ត្រី(សារី) ដែលធ្វើពីក្រណាត់ប្រណិត'(បត្តសាតក, បត្តសាតី)។

**១២៥.** 'ដោយសត្វស្លាប' គឺ 'ដោយសត្វសេក ជាដើម មិនមែនដោយសត្វក្អែក ត្មាត និងសត្វមិនស្អាតផ្សេងទៀត ទេ'(មេធ., គោវ., កុល្ល.)។ *អវធូតំ* 'ដែលប៉ះ(ជើង)'(កុល្ល., រាឃ.) ហើយតាមមេធ.និងគោវ. ថា 'ដែលប្រើមាត់ផ្លុំដាក់' ឬ 'ដែលប្រឡាក់ធូលីកន្ទប', តាមនារ. ថា 'ដែលត្រូវខ្យល់បើុង (ធ្វើប៉ះ) ក្រណាត់ ជើងជាដើម' និងតាមនន្ទ. ថា 'ដែលកខ្វក់ដោយប៉ះអំបោស ឬដីហុយ ដោយសារស្លាបសត្វបក់'។

១២៦-ជរាបណាក្លិន (អាក្រក់) មិនបាត់ពី (វត្ថុ) ដែលប្រឡាក់ដោយសារធាតុមិនស្អាត ហើយស្នាមប្រឡាក់នោះ(មិនបាត់) ពេលនោះគេត្រូវប្រើដីនិងទឹក ក្នុងសម្អាតវត្ថុ(គ្មានចលនា)។

១២៧-អាទិទេពបានប្រកាសវត្ថុបី ដែលបរិសុទ្ធសម្រាប់ព្រាហ្មណ៍ គឺវត្ថុ(ដែល)មិនឃើញស្នាមប្រឡាក់ អ្វីដែលត្រូវលាងទឹក និងអ្វីដែលត្រូវបានសរសើរ(ថាស្អាត) ដោយសម្ដី(របស់ព្រាហ្មណ៍)។

១២៨-ទឹក (ដែលមានចំនួន) គ្រប់គ្រាន់ដើម្បីសម្រន់ការស្រេករបស់មេគោ ដែលមានក្លិន ពណ៌ និងរសជាតិ(ល្អ) និងមិនលាយដោយសារធាតុមិនស្អាត គឺស្អាតល្អ ប្រសិនបើគេយកទឹកនោះពីកន្លែង (ស្អាត)។

១២៩-ដៃរបស់សិប្បករ ត្រូវស្អាតជានិច្ច ដូច្នេះ(ទំនិញដែលអាចលក់បានទាំងអស់) ត្រូវដាក់លក់នៅទីផ្សារ ហើយអាហារដែលបានពីការសុំ ដែលសិស្សកាន់ (ក្នុងដៃរបស់គេ) គឺសមស្របសម្រាប់ការប្រើប្រាស់ជានិច្ច ហើយនោះគឺជាវិធានដែលបានបញ្ញត្តិ។

១៣០-មាត់របស់ស្ត្រី តែងតែបរិសុទ្ធ ដូចជាសត្វស្លាប ដែលវាបង្កឱ្យផ្លែឈើជ្រុះ; កូនគោបរិសុទ្ធ ពេលសប្បាយបឺតទឹកដោះ ហើយឆ្កែ សប្បាយនៅពេលវាចាប់បានក្ដាន់។

១៣១-មនុ បានប្រកាសថា សាច់(សត្វ)ដែលឆ្កែសម្លាប់ គឺបរិសុទ្ធ ដូចជា(សាច់សត្វព្រៃ) ដែលសម្លាប់ដោយ(សត្វ)ស៊ីសាច់ជាអាហារ ឬដោយមនុស្សក្នុងវណ្ណៈទាប(ទស្យុ) ដូចជាចណ្ឌាលជាដើម។

១៣២-ប្រហោង(ក្នុងរាងកាយ)ទាំងអស់ ដែលស្ថិតនៅលើផ្ចិត គឺបរិសុទ្ធ (ប៉ុន្តែ) ប្រហោងដែលនៅខាងក្រោមផ្ចិត គឺមិនបរិសុទ្ធ ព្រមទាំងសំណល់ដែលចេញពីកាយ។

១៣៣- រុយ ដំណក់ទឹក ស្រមោល មេគោ សេះ កាំរស្មីព្រះអាទិត្យ ធូលី ដី ខ្យល់ និងភ្លើង អ្នកត្រូវដឹងថាជារបស់បរិសុទ្ធ អាចប៉ះបាន។

១៣៤-ដើម្បីសម្អាត(សរីរាង្គ)ដោយការបន្ទោរបង់លាមកនិងទឹកនោម គេត្រូវប្រើដីនិងទឹក ព្រោះគេអាចត្រូវការវា ដូចក្នុងការសម្អាត(អ្វីដែលចាប់)វត្ថុមិនស្អាតចំនួនដប់ពីរនៅក្នុងរាងកាយ។

---

**១២៧.** វស. ជំពូក១៤ លេខ២៤; ពោធ. ជំពូក១ លេខ៩; វិ. ជំពូក២៣ លេខ៤៧; យញ្ញ. ជំពូក១ លេខ១៩១។ ដោយឯកភាពតាមមតិរបស់អ្នកនិពន្ធនានា ខ្ញុំប្រែពាក្យ *បរិត្រាណិ* ថា 'បរិសុទ្ធ'។ ប៉ុន្តែពាក្យនេះក៏មានន័យថា 'មធ្យោបាយសម្រាប់សម្អាត' ដែលខ្ញុំបានប្រែនៅក្នុងសេចក្ដីប្រហាក់ប្រហែល។ ន័យទូទៅនៅរក្សាដដែល។

**១២៨.** វស. ជំពូក៣ លេខ៣៥-៣៦, ៤៧; ពោធ. ជំពូក១ លេខ៩, ១០; វិ. ជំពូក២៣ លេខ៤៣; យញ្ញ. ជំពូក១ លេខ១៩២។

**១២៩.** ពោធ. ជំពូក១ លេខ៩, ១; វិ. ជំពូក២៣ លេខ៤៨។

**១៣០.** ពោធ. ជំពូក១ លេខ៩, ២; វិ. ជំពូក២៣ លេខ៤៩; យញ្ញ. ជំពូក១ លេខ១៩៣។

**១៣១.** វស. ជំពូក៣ លេខ៤៥; វិ. ជំពូក២៣ លេខ៥០; យញ្ញ. ជំពូក១ លេខ១៩២។

**១៣២.** វិ. ជំពូក២៣ លេខ៥១; យញ្ញ. ជំពូក១ លេខ១៩៤។

**១៣៣.** វិ. ជំពូក២៣ លេខ៥១; យញ្ញ. ជំពូក១ លេខ១៩៣។ 'ដំណក់ទឹក' គឺ 'ដូចជាអាចដឹងបានដោយផស្សៈ'(មេធ., គោវ.) ឬ 'ដូចជាចេញពីមាត់ គឺទឹកមាត់'(កុល្ល., រាឃ., នារ.)។ រាឃ. បន្ថែមថា 'និងមានខ្សែទឹកជាប់ៗគ្នា'។

**១៣៤.** អាប. ជំពូក១ លេខ១៦, ១៥; គោត. ជំពូក១ លេខ៤៣; វស. ជំពូក៦ លេខ១៤; យញ្ញ. ជំពូក១ លេខ១៧។ 'ព្រោះគេត្រូវការវា' គឺ 'សម្រាប់សម្អាតវត្ថុមិនស្អាតប្រាំមួយយ៉ាងដំបូង ដែលមានរៀបរាប់នៅក្នុងកាព្យបន្ទាប់ ដូចជាគេអាចត្រូវការទឹកនិងដីច្រើនដូចគ្នា ហើយវត្ថុមិនស្អាតប្រាំមួយចុងក្រោយ ត្រូវការតែទឹកប៉ុណ្ណោះ'(គោវ., កុល្ល., នារ., រាឃ.)។

១៣៥-ការចេញខ្លាញ់ ទឹកកាម ឈាម (សារធាតុខ្លាញ់នៅក្នុង) ខួរក្បាល ទឹកនោម លាមក សំបោ អាចម៍ត្រចៀក ស្លេស្ម ទឹកភ្នែក អាចម៍ភ្នែក និងញើស ជាវត្ថុមិនស្អាតចំនួនដប់ពីរនៅក្នុង(ខ្លួន) មនុស្ស។

១៣៦-អ្នកដែលចង់ស្អាត ត្រូវសម្អាតសរីរាង្គដោយ(ប្រើ)ដី (សម្អាត)ទ្វារចំនួនបីដង (សម្អាត)ដៃឆ្វេងឱ្យបានដប់ដង និងសម្អាត(ដៃ)ទាំងពីរឱ្យបានប្រាំពីរដង។

១៣៧-ឃរាវាស ត្រូវធ្វើការសម្អាតរបៀបនេះ ហើយ(ការសម្អាត)នឹងបង្កើនទ្វេដងសម្រាប់សិស្ស បីដងសម្រាប់ឥសី ប៉ុន្តែបួនដងសម្រាប់តាបស។

១៣៨-នៅពេលអ្នកបន្ទោរបង់លាមក ឬនោម ចូរអ្នកលាងទឹកទ្វារនោះ បន្ទាប់ពីផឹកទឹក ដូចជានៅពេលអ្នកទៅសូត្រព្រះវេទ ហើយតែងតែសម្អាតមុនពេលទទួលទានអាហារ។

១៣៩-ចូរអ្នកដែលចង់ឱ្យកាយស្អាត ទីមួយផឹកទឹកឱ្យបានបីដង បន្ទាប់មកជូតមាត់ឱ្យបានពីរដង ប៉ុន្តែស្ត្រីនិងសូទ្រៈ (នឹងធ្វើអំពើនីមួយៗ)តែម្តងប៉ុណ្ណោះ។

១៤០- សូទ្រៈ ដែលរស់នៅតាមតម្រាច្បាប់ នឹងកោរសក់(របស់ខ្លួន)ក្នុងមួយខែ; វិធីសម្អាតរបស់ពួកគេ (នឹងធ្វើ)ដូចគ្នានឹងការសម្អាតរបស់វៃស្យៈ ហើយអាហាររបស់ពួកគេ ជាសំណល់ពីអាហាររបស់ពួកអារ្យ័ន។

១៤១-ដំណក់ (ទឹក) ចេញពីមាត់ ដែលមិនធ្លាក់លើដៃជើង មិនធ្វើឱ្យ(មនុស្ស)មិនស្អាតទេ និងពុកមាត់មិនចូលមាត់ ហើយគ្មានអ្វីគ្មានធ្មេញ។

១៤២-ដំណក់ ដែលស្រក់លើជើងរបស់អ្នកដែលផ្តល់ទឹកឱ្យអ្នកដទៃផឹក គេមិនត្រូវចាត់ទុកថា(ជាទឹក) ដែលបានដងមកពីលើដីទេ ពោលគឺដំណក់ទឹកនោះមិនធ្វើឱ្យគេកខ្វក់ទេ។

១៤៣-អ្នកដែល ក្នុងពេលកាន់អ្វីមួយតាមរបៀបណាមួយ ប៉ះនឹង(វត្ថុ ឬមនុស្ស)មិនបរិសុទ្ធ នឹងបានបរិសុទ្ធវិញ បើសិនជាគេធ្វើការស្រោចទឹក ដោយមិនចាំបាច់ដាក់វត្ថុនោះចុះទេ។

---

**១៣៦.** វស. ជំពូក៦ លេខ១៨; វិ. ជំពូក៦០ លេខ២៥។

**១៣៧.** វស. ជំពូក៦ លេខ១៩; វិ. ជំពូក៦០ លេខ២៦។

**១៣៨.** គោត. ជំពូក១ លេខ៣៦; ពោធ. ជំពូក១ លេខ៨, ២៦; វិ. ជំពូក៦២ លេខ៨។ 'រន្ធ' គឺក្នុងក្បាល(គោវ.) ព្រមទាំងផ្ចិត បេះដូង និងបង្ហើយក្បាល(នារ., កុល្លូ.)។

**១៣៩.** អាប. ជំពូក១ លេខ១៦, ៣-៨; គោត. ជំពូក១ លេខ៣៦; វស. ជំពូក៣ លេខ២៧-២៨; ពោធ. ជំពូក១ លេខ៨, ២០-២២; វិ. ជំពូក៦២ លេខ៦-៨; យញ្ញ. ជំពូក១ លេខ២០។

**១៤០.** អាប. ជំពូក២ លេខ៣, ៤-៦។ 'ដែលរស់នៅតាមតម្រាច្បាប់' គឺ 'ដែលសមស្របជាអារ្យ័ន'(មេធ., គោវ., កុល្លូ., រាឃ.)។ នន្ទ. គិតថា *មាសិកំ វបនំ កាយំ* 'នឹងកោរមួយខែម្តង' មានន័យថា 'នឹងធ្វើស្រាទ្ធរាល់ខែ'។

**១៤១.** អាប. ជំពូក១ លេខ១៦, ១៣; គោត. ជំពូក១ លេខ៣៨-៤១; វស. ជំពូក៣ លេខ៣៧, ៤០-៤១; ពោធ. ជំពូក ១ លេខ៨, ២៣-២៥; វិ. ជំពូក២៣ លេខ៥៣; យញ្ញ. ជំពូក១ លេខ១៩៥។ ខ្ញុំអានតាមលោកមេធ., គោវ., នារ., នន្ទ. និង K. *អង្គំ ន យន្តិ យា* ជំនួសឃ្លា *អង្គេ បតន្តិ* 'ដែលធ្លាក់លើដៃជើង' ជាសំណោររបស់កុល្លូ. និងរាឃ.។

**១៤២.** វស. ជំពូក៣ លេខ៤២; វិ. ជំពូក២៣ លេខ៥៤។

**១៤៣.** គោត. ជំពូក១ លេខ២៨; វស. ជំពូក៣ លេខ៤៣; ពោធ. ជំពូក១ លេខ៨, ២៧-២៩; វិ. ជំពូក២៣ លេខ៥៥។

១៤៤- អ្នកដែលបានក្អួតឬចង្អោរគួរមុជទឹក ហើយបន្ទាប់ពីទទួលទានបឺសុទ្ធ ប៉ុន្តែប្រសិនបើ (ការចង្អោរនោះកើតឡើង)ក្រោយពីការទទួលទានរួច ចូរអ្នកគ្រាន់តែផឹកទឹកប៉ុណ្ណោះ ហើយការមុជទឹកត្រូវកំណត់សម្រាប់អ្នកដែលបានរួមភេទជាមួយស្ត្រី។

១៤៥- ថ្វីបើអ្នកអាចស្អាតបាត (រួចហើយ) ក៏ដោយ ចូរអ្នកផឹកទឹកបន្ទាប់ពីដេក កណ្តាស់ទទួលទានក្អួត និយាយមិនពិត ហើយផឹកទឹក ដូចជានៅពេលអ្នកទៅសិក្សាព្រះវេទ។

១៤៦- ដូច្នេះវិធានសម្អាតខ្លួនសម្រាប់បុរសគ្រប់វណ្ណៈ និងវិធានសម្រាប់សម្អាត(វត្ថុ)គ្មានចលនា ត្រូវបានប្រកាសប្រាប់អ្នកទាំងស្រុងៈ ឥឡូវចូរស្តាប់ករណីយកិច្ចរបស់ស្ត្រី។

១៤៧- គ្មានអ្វីដែលត្រូវធ្វើតែឯងដោយក្មេងស្រី ស្ត្រីវ័យក្មេង ឬសូម្បីមនុស្សចាស់ក្តី ទោះជានៅក្នុងផ្ទះរបស់ខ្លួនផ្ទាល់ក៏ដោយ។

១៤៨- ក្នុងវ័យកុមារភាពស្ត្រីត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុកនាង ក្នុងវ័យយុវភាពនៅក្រោម ស្វាមីរបស់ខ្លួន ពេលម្ចាស់របស់នាងស្លាប់ស្ថិតក្រោមកូនប្រុសនាង ហើយស្ត្រីមិនត្រូវនៅដាច់ ឯករាជ្យតែឯងទេ។

១៤៩- នាងមិនត្រូវរកវិធីនៅបែកពីឪពុក ស្វាមី ឬកូនប្រុសរបស់ខ្លួនទេ ដោយសារការចាកចេញពីពួកគេនាងនឹងញ៉ាំងឱ្យគេមើលងាយគ្រួសារ(របស់នាងផ្ទាល់ និងរបស់ស្វាមីនាង)ទាំងសងខាង។

១៥០- នាងត្រូវតែរីករាយ ឆ្លាតវាងវៃជានិច្ចក្នុង (ការចាត់ចែង) កិច្ចការផ្ទះរបស់នាង យកចិត្តទុកដាក់សម្អាតសម្ភារៈផ្ទះបាយ និងសន្សំសំចៃក្នុងការចំណាយ។

១៥១- អ្នកដែលឪពុកនាងអនុញ្ញាតឱ្យមើលនាង ឬបងប្អូនប្រុសរបស់នាង ដែលមានការអនុញ្ញាតពីឪពុកនាងត្រូវគោរពដរាបណាគេនៅមានជីវិត ហើយពេលគេស្លាប់នាងមិនត្រូវប្រមាថ (អនុស្សាវរីយ៍របស់គេ) ទេ។

១៥២- ដើម្បីជានាទូវភ័ព្វវាសនាល្អចំពោះ (កូនក្រមុំ) ការសូត្រពាក្យប្រសិទ្ធពរ (ស្វស្ត្យយន) និងការបូជាព្រះបង្កើតសត្វលោក (ប្រជាបតិ) ត្រូវធ្វើនៅពេលរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពិធីភ្ជាប់ពាក្យ (ដែលធ្វើដោយឪពុកឬអាណាព្យាបាល) គឺជាដើមហេតុនៃការគ្រប់គ្រង (របស់ប្តីចំពោះភរិយារបស់ខ្លួន)។

---

**១៤៥.** អាប. ជំពូក១ លេខ១៦, ១៤; គោត. ជំពូក១ លេខ៣៧; វិ. ជំពូក២២ លេខ៧៥; យញ្ញ. ជំពូក១ លេខ១៩៦។ យោងតាមមេធ. ថា អ្នកខ្លះឱ្យន័យកាព្យនេះ ថា ការក្រេបទឹកម្តងហើយម្តងទៀត។

**១៤៧-១៤៩.** សូមមើលជំពូក៩ លេខ២-៣ខាងក្រោម; វិ. ជំពូក២៦ លេខ១២-១៣; យញ្ញ. ជំពូក១ លេខ៨៥-៨៦។

**១៤៥.** វិ. ជំពូក២៦ លេខ៤-៦; យញ្ញ. ជំពូក១ លេខ៨៣។

**១៥១.** វិ. ជំពូក២៦ លេខ១៤; យញ្ញ. ជំពូក១ លេខ៦៣។

**១៥២.** *ស្វស្ត្យយន*ការសូត្រពាក្យប្រសិទ្ធពរ' គឺ 'ក្នុងពាក្យនោះសំដៅបញ្ចៀសប្រផ្នូលអាក្រក់'(គោវ., កុល្ល.); ឬ 'បុណ្យាហវាកន និងផ្សេងៗទៀត'(នារ.); ឬ 'ការសូត្រពាក្យនៅមុនពេលការបូជាភ្លើងពេលរៀបការ'(រាឃ., នន្ទ.)។ មេធ. ភ្ជាប់ពាក្យនេះជាមួយ *យញ្ញៈ* ហើយពន្យល់ថា 'ការធ្វើដូច្នោះអាចផ្តល់នូវសេចក្តីសុខ'។ មេធ. បកស្រាយសំនួនវោហារនេះថា 'ការបូជាព្រះប្រជាបតិ' ដោយបញ្ជាក់ថា 'ពិធីខ្លះ'មានកំណត់អំពីការបូជានៅក្នុងពិធីរៀបការ ដោយកាព្យថា *ប្រជាបតេ នត្វទ អេវានៃ្យះ( ? ត្វទេតានី* សូមមើលគម្ពីរឫគ-វេទ ជំពូក១០ លេខ១២១, ១០) និងថា ការបូជាអាទិទេពផ្សេងទៀត ត្រូវ

១៥៣- ស្វាមីដែលបានរៀបការជាមួយនាង ដោយមានពាក្យពិសិដ្ឋ តែងតែផ្តល់សុភមង្គលដល់ភរិយារបស់ខ្លួន ទាំងក្នុងកាលដ៏គួរ ទាំងក្នុងកាលមិនគួរ ទាំងក្នុងជាតិនេះ និងទាំងក្នុងជាតិក្រោយ។

១៥៤- ប្ដីត្បិតតែមិនសូវមានបុណ្យកុសល ឬដោយការស្វែងរកការសប្បាយ (នៅកន្លែងផ្សេង) ឬគ្មានគុណសម្បត្តិល្អក៏ដោយ (ក៏)ភរិយាដែលមានស្វាមីភក្តិ ត្រូវតែគោរពស្វាមីឱ្យដូចជាព្រះ។

១៥៥- ការកើតឡើងនូវការមិនបូជា ការមិនប្ដេជ្ញា ការមិនសុំសីលរបស់ស្ត្រី ក៏ជាចំណែកមួយ(ពាក់ព័ន្ធនឹងស្វាមីរបស់នាងដែរ)ប្រសិនបើភរិយាគោរពស្វាមីខ្លួន នាងនឹងបានឡើងឋានសួគ៌ (ក្នុងហេតុផលនេះម្យ៉ាង)។

១៥៦- ភរិយាស្មោះត្រង់ ដែលចង់រស់នៅជាមួយស្វាមីខ្លួន (នៅជាតិក្រោយ) មិនត្រូវធ្វើអ្វីដែលធ្វើឱ្យបុរស ដែលបានចាប់ដៃនាងនោះពិបាកចិត្តទេ ទោះបីជាគាត់នៅរស់ ឬស្លាប់ក៏ដោយ។

១៥៧- ដោយសេចក្តីអនុគ្រោះរបស់នាង ចូរនាងរក្សារូបកាយនាងឱ្យស្គម ដោយ(រស់អាស្រ័យនឹង)ផ្កាមើមឈើនិងផ្លែឈើដ៏បរិសុទ្ធ ប៉ុន្តែនាងមិនត្រូវហៅឈ្មោះបុរសដទៃបន្ទាប់ពីស្វាមីនាងបាន ស្លាប់ទៅទេ។

១៥៨- ចូរនាងព្យាយាមអត់ធ្មត់(ចំពោះការពិបាក) គ្រប់គ្រងខ្លួនឱ្យបាន និងរក្សាភាពបរិសុទ្ធ ហើយខំ(បំពេញ)ករណីយកិច្ចដ៏ប្រពៃបំផុត(ក្នុងនាមជា)ភរិយាដែលមានស្វាមីមួយប៉ុណ្ណោះ រហូតដល់ទីបំផុតនៃជីវិត។

១៥៩- ព្រាហ្មណ៍ច្រើនពាន់នាក់ដែលនៅបរិសុទ្ធពីយុវភាពរបស់ខ្លួនបានឡើងឋានសួគ៌ ដោយមិនចាំបាច់មានការប្រកួតប្រជែងទេ។

១៦០- ភរិយាល្អ ដែលបន្ទាប់ពីមរណភាពរបស់ស្វាមីនាង នៅតែបន្តរក្សាភាពបរិសុទ្ធ នឹងឡើងឋានសួគ៌ទោះបីនាងគ្មានកូនប្រុសក្តី បីដូចជាបុរសបរិសុទ្ធទាំងអស់នោះដែរ។

១៦១- ប៉ុន្តែស្ត្រីដែលមានបំណងចង់មានកូន ដោយបំពានករណីយកិច្ចខ្លួនដែលមានចំពោះ (សព) ស្វាមីរបស់ខ្លួន នាំឱ្យនាងមានភាពអាម៉ាស់នៅក្នុងជាតិនេះ និងបាត់បង់ឱកាសនៅជាមួយប្តីនាង(នៅឯឋានសួគ៌)។

១៦២- ការមានកូនជាមួយបុរសម្នាក់ទៀត នៅទីនេះ មិនចាត់ទុក(ថាស្របច្បាប់)ទេ ហើយការបង្កើតកូន(ដែលផ្តល់កំណើតដោយភរិយាជាមួយបុរសម្នាក់ទៀត(មិនស្ថិតលើអ្នកបង្កើត)និងមិនមែនជាស្វាមីទីពីរ សម្រាប់ស្ត្រីល្អទាល់តែសោះឡើយ។

---

ប្រើសំនួនវោហារនេះ។ នារ. គិតថា មនុដែលប្រើពាក្យ*ប្រគាបតិ* ជាអាទិទេពការពារកូនក្រមុំ ហេតុដូច្នេះគេហៅការបូជាក្នុងពេលអាពាហ៍ពិពាហ៍ ថា 'ការបូជាចំពោះព្រះប្រគាបតិ'។

**១៥៥.** វិ. ជំពូក២៦ លេខ១៥; យញ្ញ. ជំពូក១ លេខ៧៧។

**១៥៦-១៦៦.** សូមមើលជំពូក៩ លេខ៦៤-៦៨ខាងក្រោម; យញ្ញ. ជំពូក១ លេខ៧៥, ៨៧។

**១៥៧.** មេធ. ឆ្លៀតយកឱកាសនេះ ជំទាស់យ៉ាងខ្លាំងចំពោះការអនុវត្តទម្លាប់ឱ្យស្ត្រីមេម៉ាយដុតខ្លួនតាមសពស្វាមីខ្លួន។

**១៥៩.** គោវ. និងកុល្លូ. គិតថា កាព្យនេះ សំដៅដល់*វាលខិល្យ ឫសី*។

**១៦០.** វិ. ជំពូក២៦ លេខ៧។

**១៦២.** មេធ., នារ. និងនន្ទ. ប្រែកាព្យនេះផ្នែកទីមួយផ្សេងថា 'ការបង្កើតកូនដោយបុរសម្នាក់ទៀត មិនមែនអាស្រ័យលើ

១៦៣-ស្ត្រីដែលរួមរស់ជាមួយបុរសដែលមានវណ្ណៈខ្ពស់ជាង ដោយលះបង់ប្តីផ្ទាល់ខ្លួនដែលមានវណ្ណៈទាបជាង នឹងត្រូវគេមើលងាយនៅក្នុងលោកិយនេះ ហើយត្រូវគេឱ្យឈ្មោះថាស្ត្រីរៀបការពីរដង (បរបូរវា)។

១៦៤-ដោយការបំពានករណីយកិច្ចរបស់ខ្លួនចំពោះស្វាមីនាង ភរិយាត្រូវរស់នៅយ៉ាងអាម៉ាស់ក្នុងជាតិនេះ (បន្ទាប់ពីស្លាប់) នាងចាប់កំណើតក្នុងពោះឆ្កែព្រៃ និងត្រូវហែកហួរដោយជំងឺ (ជាទណ្ឌកម្មសម្រាប់) អំពើបាបរបស់នាង។

១៦៥-ស្ត្រីដែលចេះគ្រប់គ្រងចិត្តគំនិត ពាក្យសម្តីនិងអំពើរបស់ខ្លួនបាន មិនមើលស្រាលម្ចាស់របស់នាង (បន្ទាប់ពីស្លាប់)នឹងរស់នៅជាមួយស្វាមីនាង(នៅឋានសួគ៌) ហើយគេហៅថា កល្យាណ (ភរិយា)។

១៦៦-ក្នុងការផ្តល់រង្វាន់ចំពោះអំពើបែបនេះ ស្ត្រីដែលចេះគ្រប់គ្រងចិត្តគំនិត សម្តីសំដៅ និងសកម្មភាពរបស់ខ្លួន នឹងទទួលបានកិត្តិនាមខ្ពស់បំផុតនៅក្នុងជាតិនេះ ហើយនៅក្នុងជាតិក្រោយ នឹងនៅជាប់ជាមួយស្វាមី។

១៦៧-បុរសមានកំណើតពីរ ដែលបានចេះច្បាប់ពិសិដ្ឋ នឹងបូជាភរិយាដែលមានវណ្ណៈស្មើគ្នា ដែលបានស្លាប់មុនខ្លួន ដោយបានប្រើភ្លើងពិសិដ្ឋ *អគ្និហោត្រ* និងដោយមានធ្វើពិធីសាសនាផង។

១៦៨-ដោយបានធ្វើដូច្នេះក្នុងពិធីបុណ្យសព ដែលមានការបូជាភ្លើងពិសិដ្ឋដល់ភរិយាខ្លួនដែលចែកឋានមុនខ្លួន គេអាចរៀបការម្តងទៀតបាន និងអាចបង្កាត់(ភ្លើងនោះ)ម្តងទៀតបាន។

១៦៩- (ដោយការរស់នៅ)ស្របតាមតម្រាវិន័យ(ពីបុរាណ) គេមិនត្រូវធ្វេសប្រហែសពិធីយញ្ញ(ធំៗ) ចំនួនប្រាំ ហើយបន្ទាប់ពីមានភរិយា គេត្រូវស្នាក់នៅក្នុងផ្ទះរបស់ខ្លួនផ្ទាល់ ក្នុងដំណាក់កាលទីពីរនៃជីវិតរបស់ខ្លួន។

---

(ម្តាយ)ទេ៎។ លោកគោវ. និងកុល្ល. ផ្តល់ការបកស្រាយផ្សេង។

**១៦៥.** មេធ. លុបចោលកាព្យលេខ១៦៥-១៦៦។

**១៦៧-១៦៨.** យញ្ញ. ជំពូក១ លេខ៨៨។

---

# ជំពូក ៦

១- ដូចនេះ បុរសមានកំណើតពីរដង ដែលបានរស់នៅតាមច្បាប់ តាមទម្លាប់របស់ឃរាវាស ដោយមានការតាំងចិត្តអង់អាច និងរក្សាឥន្ទ្រីយារម្មណ៍របស់ខ្លួនបានត្រឹមត្រូវអាចរស់នៅក្នុងព្រៃ (ដើម្បីប្រតិបត្តិតម្រាវិន័យខាងក្រោម)យ៉ាងត្រឹមត្រូវ។

២- នៅពេលឃរាវាសឃើញ(ស្បែក)របស់ខ្លួនជ្រួញនិង(សក់ខ្លួន)ឡើងស ហើយចៅប្រុសរបស់ខ្លួនគេក៏អាចអាស្រ័យនៅក្នុងព្រៃបាន។

៣- ដោយបោះបង់ចោលអាហារទាំងអស់ដែលបានពីការធ្វើស្រែចម្ការ និងកម្មសិទ្ធិផ្ទាល់ខ្លួនទាំងអស់ អ្នកអាចចាកចេញទៅនៅក្នុងព្រៃ ដោយឱ្យភរិយាខ្លួននៅជាមួយកូនប្រុសក៏បានឬឱ្យនាងទៅជាមួយខ្លួនក៏បាន។

៤- ដោយយកតាមខ្លួននូវភ្លើងពិសិដ្ឋនិងប្រដាប់ប្រដាចាំបាច់ក្នុងផ្ទះ(សម្រាប់ពិធីយញ្ញ) អ្នកអាចធ្វើដំណើរចេញពីភូមិចូលក្នុងព្រៃ រួចស្នាក់នៅទីនោះដោយខំគ្រប់គ្រងវិញ្ញាណរបស់ខ្លួនឱ្យបានត្រឹមត្រូវ។

៥- ចូរអ្នកធ្វើពិធីយញ្ញធំៗប្រាំស្របតាមតម្រាវិន័យ ដោយមានអាហារបរិសុទ្ធផ្សេងៗសម្រាប់ជូនតាបសក៏បាន ឬដោយតិណជាតិ មើមឈើ និងផ្លែឈើក៏បាន។

៦- ចូរអ្នកពាក់ក្រណាត់ធ្វើពីស្បែកឬក្រណាត់ដាច់ដាច ចូរអ្នកមុជទឹកនៅពេលល្ងាច ឬនៅពេលព្រឹក ហើយចូរអ្នកពាក់សក់ជាកម្រងលើ(ក្បាលរបស់ខ្លួន) (កុំកាត់)រោមលើកខ្លួន ពុកចង្កា និងក្រចកដៃខ្លួនឱ្យសោះ។

---

**ជំពូក៦ លេខ១-៣២.** អាប. ជំពូក២ លេខ១៨-២៣, ២; គោត. ជំពូក៣ លេខ២៦-៣៥; វស. ជំពូក៦ លេខ១៩-២០; ជំពូក៩; ពោធ.ជំពូក២ លេខ១១, ១៤-១៥; ជំពូក៣ លេខ១៨-៤, ២២; វិ. ជំពូក៩៤-៩៥; យញ្ញ.ជំពូក៣ លេខ៤៥-៥៥។

**១.** *និយតៈ* 'ដោយមានការតាំងចិត្តដាច់ខាត'(គោវ., កុល្ល.) តាមលោកនារ. ថា 'ដែលប្តេជ្ញាចំពោះករណីយកិច្ចដ៏តឹងរ៉ឹង ការធ្វើតបៈ ការសូត្រព្រះវេទជាដើម'។ កុល្ល. ភ្ជាប់ពាក្យ *យថាវទ* 'ដោយប្រតិបត្តិត្រឹមត្រូវ'ជាដើម(គោវ., នារ.) ជាមួយនឹង 'ដោយរក្សាឥន្ទ្រីយារម្មណ៍របស់ខ្លួនត្រឹមត្រូវ'។

**២.** មេធ. កត់សម្គាល់ជាពិសេសថា *សិស្ត* តវ៉ានឹងភាពចាំបាច់ថា អ្នកដែលចិញ្ចឹមជីវិតក្នុងព្រៃ ត្រូវមានកូនប្រុស និងចៅប្រុស និងថា ហេតុនេះ *អបត្យ* 'កូនចៅ' ជាពាក្យដែលគេប្រែក្នុងន័យដ៏ចង្អៀត។ នារ. ប្រកាន់ជំហរថា កាព្យនេះផ្តល់មូលដ្ឋានបីផ្សេងគ្នា ដោយរាប់បញ្ចូលដល់លំដាប់ទីបី ចំណែកឯមេធ. គិតថា លក្ខខណ្ឌទាំងបីត្រូវគិតបញ្ចូលគ្នា។ តែអ្នកខ្លះទៀត តាមការលើកឡើងរបស់មេធ. ប្រែកាព្យនេះ ដោយរៀបរាប់ពីការឈានចូលដល់វ័យចាស់ ដែលផ្តល់សិទ្ធិឱ្យយាវាសចូលតាំងសីលជាឥសីបាន។

**៣.** 'ប្រសិនបើភរិយាខ្លួនចង់ទៅជាមួយខ្លួន នាងអាចទៅបាន។ ប៉ុន្តែអ្នកខ្លះថា គាត់ត្រូវទុកភរិយារបស់គាត់ឱ្យផ្ទះ បើសិនជានាងនៅក្មេង តែគួរយកនាងទៅតាម បើនាងចាស់'(មេធ.)។

**៦.** *ចីរ* 'ក្រណាត់ដាច់ដាច'(លោកមេធ., គោវ., កុល្ល. សរសេរ *ស្លេខណ្ឌ*) ក៏អាចមានន័យ 'សម្លៀកបំពាក់ដែលធ្វើពីសម្បកឈើ ស្មៅកុសៈ ឬសម្លៀកបំពាក់ប្រភេទនេះ'(គោវ., នារ., រាឃ.)។

៧- ចូរអ្នកធ្វើការបូជា*ពលិ* ដោយអាហារដូចជារបស់ខ្លួនទទួលទាន និងដាក់ទានតាមលទ្ធភាពរបស់ខ្លួន ចូរអ្នកគោរពអ្នកដែលមករស់នៅក្នុងភាពជាឥសី ដោយដាក់ទានដូចជាទឹកមើមឈើ និងផ្លែឈើ។

៨- ចូរអ្នកឧស្សាហ៍ព្យាយាមសូត្រព្រះវេទម្នាក់ឯងជានិច្ច ចូរអ្នកអត់ធន់នឹងការពិបាក រាប់អាន(ចំពោះអ្វីៗទាំងអស់) ប្រមូលអារម្មណ៍ឱ្យមូល ឱ្យមានសេរីភាពជានិច្ច ហើយកុំធ្វើជាអ្នកទទួលអំណោយ និងមានចិត្តមេត្តាចំពោះសព្វសត្វទាំងអស់។

៩- ចូរអ្នកបូជាអគ្និហោត្រ ដោយភ្លើងពិសិដ្ឋបី ស្របតាមតម្រាច្បាប់ កុំភ្លេចធ្វើពិធីយញ្ញសម្រាប់ ព្រះច័ន្ទរះថ្មី និងព្រះច័ន្ទពេញវង់ តាមពេលវេលាសមស្រប។

១០- ចូរអ្នកធ្វើពិធី(បូជា) *នក្សត្រេស្តិ, អាគ្រយណា* និង *ចាតុរមាស្យ* ផង ព្រមទាំងធ្វើពិធី *តុរាយណា* ក៏ដូចជា *ទាក្សាយណា* តាមលំដាប់ត្រឹមត្រូវដែរ។

១១- ដោយមានធញ្ញជាតិសុទ្ធស្អាតល្អដែលដុះនៅរដូវផ្ការីកនិងរដូវត្រជាក់ ហើយដែលរកបានដោយខ្លួនឯង សម្រាប់តាបស ចូរអ្នករៀបចំធ្វើនំពិធីយញ្ញ (បុរោដាស) និង(ចរុ) ម្ហូបចម្អិនឱ្យបានច្រើន តាមតម្រាច្បាប់ណែនាំ។

១២- បន្ទាប់ពីបានបូជាអាហារយញ្ញដ៏បរិសុទ្ធបំផុតទាំងអស់នោះ រួមមានផលអនុផលព្រៃឈើ អ្នកអាចប្រើចំណីអាហារដែលនៅសល់សម្រាប់ខ្លួនឯង (ដោយលាយជាមួយ) អំបិលដែលខ្លួនបានត្រៀមទុក។

១៣- ចូរអ្នកទទួលទានបន្លែដែលដុះលើដីស្ងួតឬក្នុងទឹក ផ្កា មើមឈើ និងផ្លែឈើ ផលអនុផលនៃដើមឈើបរិសុទ្ធ និងប្រេងដែលចម្រាញ់ចេញពីផ្លែឈើព្រៃ។

---

៨. *ទាន្តះ* 'អត់ធន់នឹងការលំបាក' តាមមេធ. និងនារ. មានន័យថា 'រួចផុតពីការជាប់ជំពាក់'។ គោវ. អានត្រង់ចំណុចផ្ដើមពាក់កណ្ដាលទីពីរនៃកាព្យថា *ត្យក្តទ្វន្ទោ និសំ ទាតា* 'ចូរអ្នកកុំយកចិត្តទុកដាក់ភាពផ្ទុយគ្នា ចូរអ្នកមានសេរីភាព និងមានមេត្តាចំពោះសព្វសត្វទាំងអស់ជានិច្ច'។

៩. *យោគតះ* 'តាមពេលវេលាសមស្រប'(កុល្លូ., រាឃ.) ហើយតាមមេធ. និងគោវ. ថា 'តាមការតម្រូវរបស់តម្រាច្បាប់' និងតាមនារ. ថា 'ដោយព្យាយាម'។

**១០.** មេធ. អាន *ទសេស្តិ* សម្រាប់ពាក្យ *ឫក្សេស្តិ* 'គឺ នក្សត្រេស្តិ'។ ខ្ញុំអានតាមមេធ., នារ., នន្ទ. និងរាឃ. គឺ *តុរាយណា* (សូមមើល*សំ្ង.* ស្រោត-សូត្រ ជំពូក៤ លេខ១១) ជំនួសពាក្យ *ឧត្តរាយណា*ពិធីយញ្ញក្នុងរដ្ឋរដូវរងារ (ថ្ងៃដែលមាន រយៈពេលខ្លីបំផុត)' តាមការឱ្យន័យរបស់គោវ., កុល្លូ. និង K.។ អ្នកទីមួយ ក៏អានបានល្អជាងកុល្លូ. និង K. ថា *ទក្សិណាយនំ* 'ពិធីយញ្ញនារដូវក្ដៅដែលមានថ្ងៃយូរជាងគេ' ជំនួសពាក្យ *ទក្សស្យាយណំ* 'ទាក្សាយណ'។ *នក្សត្រេស្តិ* ជាពិធីយញ្ញស្រោតដែលបូជាចំពោះវិមានព្រះច័ន្ទ។ ចំពោះភាពផ្សេងគ្នានៃ *ទសបូណាមាស* ដែលគេហៅ *ទាក្សាយណា* សូមមើល អាស្វ. ស្រោត-សូត្រ ជំពូក២ លេខ១៤។

**១២.** យោងតាមកុល្លូ. ឥសី ត្រូវដើររកអំពិលពី *ឱសរ* ជាផេះប្រៃ ហើយតាមនារ. អ្នកត្រូវចេះត្រៀមអំបិលដែលបានពី *ក្សារ* 'ជាសារធាតុអំបិល ឬក្បុងប្រៃ' ដែលបានដើមឈើមជាដើម។

១៤- ចូរអ្នកកុំប្រើទឹកឃ្មុំ សាច់ និងផ្សិត ដែលដុះលើដី (ឬកន្លែងផ្សេង បន្លែ ដែលគេហៅ) *ភូត្រិណា* និង *សិគ្រុក* និងផ្លែ *ស្លេស្មានតក*។

១៥- ចូរអ្នកបោះចោលអាហារសម្រាប់តាបសក្នុងខែ *អាស្វិន* ដែលអ្នករកបានពីមុន ដូចជាខោអាវរហែក និងបន្លែ មើមឈើ និងផ្លែឈើរបស់ខ្លួន។

១៦- ចូរអ្នកកុំទទួលទានអ្វី (ដែលដាំលើដី) ភ្ជួររាស់ ទោះបីអាចមាននរណាម្នាក់បោះពូជចោលក៏ដោយ ចូរកុំទទួលទានមើមនិងផ្លែដែលដាំក្នុងភូមិ សូម្បី (អ្នកអាច) រងទុក្ខ (ដោយការស្រេកឃ្លាន) ក៏ដោយ។

១៧- អ្នកអាចទទួលទានអ្វីដែលបានចម្អិនដោយភ្លើងក៏បាន ឬអ្វីដែលបានទុំតាមកាលកំណត់ក៏បាន ហើយអ្នកក៏អាចប្រើថ្មសម្រាប់បុក កិន ឬធ្មេញរបស់ខ្លួន អាចធ្វើជាត្បាលរបស់អ្នកបាន។

១៨- អ្នកអាចសម្អាត(ភាជន៍របស់ខ្លួនសម្រាប់ដាក់អាហារ)ភ្លាមបន្ទាប់ពីការទទួលទានប្រចាំថ្ងៃក៏បាន ឬគរទុកដល់មួយខែក៏បាន ឬប្រមូលទុកអ្វីៗ សម្រាប់គ្រប់ប្រាំមួយខែ ឬមួយឆ្នាំក៏បាន។

១៩- ដោយបានប្រមូលទុកអាហារតាមលទ្ធភាពរបស់ខ្លួន អ្នកអាចទទួលតែនៅពេលយប់ក៏បាន ឬនៅពេលថ្ងៃក៏បាន ឬបួនដងក្នុងមួយថ្ងៃក៏បាន ឬប្រាំបីដងក៏បាន។

២០- ហើយអ្នកអាចរស់នៅស្របតាមតម្រាវិន័យតបៈក្រោមពន្លឺព្រះច័ន្ទ (ចន្ទ្រាយណ ដោយទទួលទានអស់បរិមាណអាហាររបស់ខ្លួនរាល់ថ្ងៃ)ក្នុងខែភ្លឺ(ពាក់កណ្ដាលខែ) និង(បង្កើនចំណីអាហារវិញ) នៅខែងងឹត (ពាក់កណ្ដាលខែ) ឬអ្នកអាចទទួលទាននៅថ្ងៃចុងក្រោយ រយៈពេលពីរសប្ដាហ៍ម្ដង គឺ(ទទួលទានបបរាវ)ម្ដងក្នុងមួយថ្ងៃប៉ុណ្ណោះក៏បាន។

២១- ឬអ្នកអាចរស់អាស្រ័យលើផ្កា មើមឈើ និងផ្លែឈើទុំតាមកាលកំណត់ និងជ្រុះដោយឯកឯង តែម្យ៉ាងជាប្រចាំ ដោយប្រតិបត្តិតាមតម្រាវិន័យ(គោលការណ៍) *វិខន*។

---

**១៤.** *ភូត្រិណ* គឺជាអម្បូរភូតគាម (Andropogon Schoenanthu)*សិគ្រុក* ហើយតាមនារ. ដូចគ្នានឹង *សោភនាញ្ជន* ជារំដេង រមៀត ស្លឹកឈើដែលគេប្រើធ្វើជាបន្លែជាដើម។ យោងតាមមេធ. បន្លែទាំងពីរនេះ គេស្គាល់ទូទៅក្នុងចំណោម*ពាហិក* នៅតំបន់*បញ្ជាប* ហើយតាមគោវ., កុល្ល., រាឃ. ថា វត្ថុដំបូងមាននៅ *មាល្វា*។ *ស្លេស្មានតក* គឺ ជាផ្កាមួយប្រភេទ ឈ្មោះ Cordia Myxa ។ តាមលោកមេធ. *ភូមានិ*បន្លែណា ដែលដាំ ឬដុះចេញពីដី' ត្រូវគេប្រែដោយពាក្យផ្សេងៗគ្នា ហើយកំណត់ជារុក្ខជាតិ ដែលគេស្គាល់តាមអ្នកកាត់ឈើ ឈ្មោះ*គោតិហ្សិកា* ថាជាប្រភេទរុក្ខជាតិតិណទេស (Phlomnis ឬ Premna Esculenta)។ គោវ., នារ. និងកុល្ល. ប្រើពាក្យផ្ទុំដូចខាងលើ ហើយពីនោក់ក្រោយនេះប្រកាសថា នោះជាផ្សិត ដែលដុះនៅនឹងដើមឈើ ត្រូវគេហាមឃាត់។

**១៦.** 'ថ្វីបើអ្នកអាចស្ថិតក្នុងគ្រាអាសន្នក៏ដោយ' គឺ 'ហែកហួរដោយសេចក្ដីស្រេកឃ្លាន'(គោវ., កុល្ល.) ឬ'ឈើថ្នាត់'(នារ.)។

**១៨.** 'អ្នកអាចសម្អាត(ភាជន៍ដាក់អាហាររបស់ខ្លួន)ភ្លាម បន្ទាប់ការទទួលអាហារប្រចាំថ្ងៃរបស់ខ្លួនក៏បាន'(នារ.) មានន័យ 'អ្នកអាចប្រមូលគរទុកសម្រាប់មួយថ្ងៃក៏បាន'។ របៀបចិញ្ចឹមជីវិតនេះ ពិតជាដូចគ្នានឹងការចិញ្ចឹមជីវិត ដែល*ពោធាយន* ជំពូក ៣ លេខ២, ១១ ហៅថា *សំប្រក្សាលនី ឫតិ*។

**២១.** អ្នកនិពន្ធទាំងអស់ លើកលែងតែលោកនារ. បញ្ជាក់ច្បាស់ថា អត្ថបទនេះសំដៅដល់សូត្រពិសេស ដែលរៀបរាប់អំពីឥសី វិខន ដែលបានពិចារណាតម្រាវិធានសម្រាប់តាបស។ លោកមេធ. បន្ថែមថា តាបសត្រូវសិក្សាការងារអនុវត្តផ្សេងៗទៀតពីការងារឥសីនោះ។

២២- ចូរអ្នករមៀលលើដីក៏បាន ឬឈរចុងម្រាមជើងនៅពេលថ្ងៃក៏បាន (ឬ)ចូរអ្នកផ្លាស់ប្ដូរ ម្ដងឈរម្ដងអង្គុយក៏បាន ហើយដោយដើរទៅរកទឹកក្នុងព្រៃ (ដើម្បីមុជទឹក) នាពេល*សវន* (ពេលព្រះអាទិត្យរះ កណ្ដាលថ្ងៃត្រង់ និងពេលព្រះអាទិត្យលិច)។

២៣- នៅរដូវក្ដៅ ចូរអ្នកអាំងខ្លួននឹងកម្ដៅភ្លើងប្រាំ ក្នុងរដូវវស្សា ចូររស់នៅកណ្ដាលវាល ហើយនៅរដូវរងា ចូរស្លៀកខោអាវសើម (ធ្វើដូច្នេះ)ជួយបង្កើន(ភាពហ្មឺងម៉ាត់ក្នុងការធ្វើ)តបៈរបស់ខ្លួន។

២៤- នៅពេលអ្នកមុជទឹកក្នុងពេល *សវន* បី (គឺពេលថ្ងៃរះ កណ្ដាលថ្ងៃត្រង់ និងថ្ងៃលិច) ចូរអ្នកបូជាទឹកចំពោះវិញ្ញាណក្ខន្ធបុព្វបុរសនិងអាទិទេព ហើយចូរអ្នកហាលថ្ងៃរូបកាយរបស់អ្នក ដោយខំអនុវត្តការធ្វើតបៈកាន់តែខ្លាំងក្លាឡើងៗ។

២៥- ដោយបានរក្សាភ្លើងពិសិដ្ឋបីនៅក្នុងខ្លួន ស្របតាមតម្រាវិធានបញ្ញត្តិ ចូលអ្នករស់នៅដោយគ្មានភ្លើង ដោយគ្មានផ្ទះ រក្សាភាពស្ងប់ស្ងាត់ទាំងស្រុង ដោយរស់អាស្រ័យមើមឈើ និងផ្លែឈើ,

២៦- ដោយមិនព្យាយាម(ផ្គត់ផ្គត់)របស់ដែលផ្ដល់សេចក្ដីរីករាយ មិនសេពកាម ដោយដេកលើដីទទេ ដោយមិនចាំបាច់ខ្វល់ពីជម្រក ដោយដេកលើឫសឈើជាដើម។

២៧- ចូរអ្នកទទួលទេយ្យទាន (ត្រឹមតែគ្រប់គ្រាន់) សម្រាប់ទ្រទ្រង់ជីវិតពីព្រាហ្មណ៍ (ដែលរស់នៅដូចជា) តាបស ឬទទួលឃរាវាសអ្នកមានកំណើតពីរជេងផ្សេងៗ ដែលស្នាក់នៅក្នុងព្រៃ។

២៨- ឬ (តាបស) ដែលស្នាក់នៅក្នុងព្រៃ អាចយក(អាហារ)ពីភូមិ ដោយបានទទួលវាដាក់ក្នុងចានទាប(ដែលធ្វើពីស្លឹកឈើ) ក៏បានឬដាក់ក្នុងដៃ (ទទេរបស់ខ្លួនក៏បានឬដាក់ក្នុងចានដីកំបែកក៏បាន ហើយអាចទទួលទានប្រាំបីម៉ាត់។

២៩- ការបដិបត្តិទាំងនេះនិងការបដិបត្តិដទៃទៀត គឺសម្រាប់ឱ្យព្រាហ្មណ៍ដែលស្នាក់នៅក្នុងព្រៃអនុវត្តដោយយកចិត្តទុកដាក់និងដើម្បីសម្រេចបាននូវ (ការឯកភាព) ជាមួយនឹងកំពូលអាត្ម័នទាំងស្រុង (អ្នកត្រូវតែសិក្សា)អត្ថបទពិសិដ្ឋនានា ដែលមាននៅក្នុងគម្ពីរឧបនិស័ទ,

៣០- (ព្រមទាំងពិធីសាសនានិងអត្ថបទទាំងនោះ) ដែលបណ្ឌិត (ឫសី) និងឃរាវាសព្រាហ្មណ៍ធ្លាប់បានអនុវត្តនិងសិក្សា ដើម្បីបង្កើនពុទ្ធិរបស់ខ្លួន(ពាក់ព័ន្ធព្រហ្មញ្ញ) និងការធ្វើតបៈធម៌របស់ខ្លួននិងដើម្បីសង្គ្រោះរូបកាយខ្លួន;

---

**២៣**. 'ភ្លើងប្រាំ' គឺ 'ភ្លើងបួន និងព្រះអាទិត្យពីខាងលើមួយ'។

**២៤**. គោវ. និយាយថា ការធ្វើតបៈខ្លាំងក្លាទាំងនេះ ជាការបដិបត្តិ ដែលមានរៀបរាប់នៅក្នុង*វៃខន សាស្ត្រ*។ មេធ. លើកឡើងនូវតួយ៉ាងថា ដោយឈរដាក់ដៃឡើងលើ ការតមអាហារមួយខែ និង*ទ្វាទសរាត្រ*។

**២៥**. 'យោងតាមតម្រាវិធាននេះ' គឺ 'ដោយការលេបផេះជាដើម'(មេធ., គោវ., កុល្លូ.) ជាគំរូ ដែលគេត្រូវសិក្សា ពី*ស្រាវណក* [ស្រាមណក សូត្រ] (មេធ.) ឬដោយការសូត្រ'យា តេ អគ្នេ យញ្ញិយា' តៃត្ត. សំហ. ជំពូក២ លេខ៥, ៨, ៨ (នារ.)។

**២៩**. ពាក្យ *អាត្មសំសិទ្ធយេ*ដើម្បីសម្រេច(ការឯកភាព)ជាមួយនឹងកំពូលអាត្ម័ន' ក៏អាចមានន័យថា 'ដើម្បីធ្វើឱ្យខ្លួន ឬព្រលឹងរបស់ខ្លួន បានល្អឥតខ្ចោះ'។ នារ. ផ្ដល់នូវឫសពាក្យត្រឹមត្រូវនៃគម្ពីរឧបនិស័ទ ដោយបកស្រាយ *ឧបនិសណ្ណា យោក្យត ឥតិ ឧបនិស័ត* គឺ 'ឧបនិស័ទ មានន័យជា(អត្ថបទ) ដែលគេសម្រាប់សូត្រ (ខណៈកូនសិស្ស) អង្គុយជិត (គ្រូ)'។

**៣០**. គោវ. និងកុល្លូ. បំបែកពាក្យពីរ'ឃរាវាសព្រាហ្មណ៍'ដាច់ពីគ្នា។ អ្នកទី១ បកស្រាយព្រាហ្មណ៍ថា ជាឫសី ហើយអ្នកទី

៣១- ឬចូរអ្នកដើរដោយចិត្តដឹងទាំងស្រុង ហើយទៅឱ្យត្រង់ទៅកាន់ទិសខាងជើងឈៀងខាងកើតដោយអាស្រ័យលើទឹកនិងខ្យល់ រហូតដល់កាយរបស់ខ្លួនសម្រាកស្ងៀម។

៣២- ដោយបានរួចផុតពីកាយខ្លួន ដោយការប្រតិបត្តិតាមវិធីមួយក្នុងចំណោមវិធីទាំងនោះ ដែលមហាបណ្ឌិតធ្លាប់បានប្រតិបត្តិរួចហើយ ព្រាហ្មណ៍មានចំណង់បានពិភពព្រហ្ម រួចផុតពីទុក្ខព្រួយ និង ការភ័យខ្លាច។

៣៣- ប៉ុន្តែដោយបានឆ្លងផុតដំណាក់កាលទីបីនៃ (ដំណើរជីវិតធម្មតារបស់មនុស្ស) ការអ្នកអាចរស់នៅដូចតាបស ក្នុងដំណាក់កាលទីបួននៃជីវិត បន្ទាប់ពីការបោះបង់ចោលការជាប់ជំពាក់ សម្ភារៈលោកិយ។

៣៤- អ្នកដែល បន្ទាប់ពីឆ្លងផុតពីកម្រិតមួយដល់កម្រិតមួយ បន្ទាប់ពីបានបូជាយញ្ញ និងយកឈ្នះវិញ្ញាណរបស់ខ្លួនក្លាយជាតាបស ដែលនឿយហត់នឹង(ការឱ្យ)ទាន និងការបូជាអាហារ នឹងទទួលពរជ័យបន្ទាប់ពីស្លាប់។

៣៥- ពេលអ្នកបានសងបំណុលបីហើយ ចូរអ្នកតម្រង់ចិត្តខ្លួន សំដៅ(ការសម្រេច)ការរួចរំដោះចុងក្រោយ អ្នកដែលស្វែងរកការរួចរំដោះ ដោយមិនបានសង(បំណុលរបស់ខ្លួន) ធ្លាក់ចុះក្រោម។

៣៦- ដោយបានសិក្សាព្រះវេទស្របតាមតម្រាវិន័យ ដោយបានផ្តល់កំណើតបុត្រាស្របតាមច្បាប់ពិសិដ្ឋ និងដោយបានបូជាយញ្ញ ស្របតាមលទ្ធភាពរបស់ខ្លួន អ្នកអាចតម្រង់ចិត្តខ្លួនសំដៅទៅរក (ការសម្រេច) ការរួចរំដោះចុងក្រោយបាន។

៣៧- អ្នកមានកំណើតពីរដង ដែលស្វែងរកការរួចរំដោះចុងក្រោយ ដោយមិនបានសិក្សាព្រះវេទ ដោយមិនបានផ្តល់កំណើតបុត្រា និងដោយមិនបានបូជាយញ្ញ ធ្លាក់ចុះក្រោម។

---

២ ប្រែ 'សមស្របជាព្រាហ្មណ៍ គឺ តាបស'។ កុល្ល. យល់ថា 'យាវាស' ជា 'តាបសនៅក្នុងព្រៃ'។ រាឃ. ប្រែពាក្យព្រាហ្មណ៍ថា 'អ្នកទាំងឡាយដែលចេះព្រហ្មញ្ញ'។

**៣១.** គោវ. និងកុល្ល. ប្រែពាក្យ *យុក្ត*ដែលតាំងចិត្តមាំ'(នារ., រាឃ.) ក្នុងន័យថា 'យកចិត្តទុកដាក់ប្រតិបត្តិយោគ'។ គោវ. និងកុល្ល. (ក៏យល់ដូចលោកមេធ. ដែរចំពោះកាព្យបន្ទាប់)និយាយថា បុរសអាចធ្វើ*មហាប្រស្ថាន* 'កំពូលនៃការចាកចេញ' ក្នុងដំណើរដែលបញ្ចប់ដោយសេចក្តីស្លាប់ នៅពេលគេមានជំងឺមិនអាចព្យាបាលបាន ឬជួបនូវគ្រោះមហាអកុសល និងថាពីព្រោះវិធីនេះមានបង្រៀននៅក្នុងសាស្ត្រ ហើយមិនផ្ទុយពីតម្រាវិន័យព្រះវេទ ដែលហាមឃាត់ការធ្វើអត្តឃាត។ ផ្ទើមចេញពីសេចក្តីប្រហាក់ប្រហែលគ្នានៅក្នុងគម្ពីរ អាប. ជំពូក២ លេខ២៣, ២ យ៉ាងណាមិញ គឺច្បាស់ណាស់ថា គេចាត់ទុកការស្លាប់ដោយស្មគ្រចិត្តដោយការអត់អាហារ ជាអំពើសមស្របសម្រាប់ការបញ្ចប់ជីវិតតាបស។ ការបដិបត្តិពីបុរាណកាល និងជាទូទៅ អាចអាស្រ័យការយល់ដឹងពីហេតុការណ៍ថា គណៈតាបសក៏ចាត់ទុកអំពើនេះថាជាអំពើគួរឱ្យសរសើរ។

**៣២.** 'ដោយវិធីមួយក្នុងចំណោមវិធីទាំងនោះ' គឺ 'ដោយពន្លិចខ្លួនឱ្យលង់ក្នុងទន្លេ ដោយទម្លាក់ខ្លួនពីលើភ្នំ ដោយដុតខ្លួន ឬដោយបង្អត់អាហារឱ្យស្លាប់'(មេធ.) ឬ 'ដោយវិធីមួយក្នុងចំណោមវិធីអនុវត្តតបៈធម៌ ដូចបាននិយាយខាងលើកាព្យលេខ ២៣'(គោវ., កុល្ល., នារ., នន្ទ.)។ មេធ. ថែមការពិភាក្សាមួយដ៏វែងអន្លាយ ដោយព្យាយាមបញ្ជាក់ថា 'ពិភពព្រហ្ម' ដែលតាបសសម្រេចបាន មិនមែនជាការរួចរដោះពិតប្រាកដទាំងស្រុងទេ។

**៣៣-៨៥.** អាប. ជំពូក២ លេខ២១, ២-១៧; គោត. ជំពូក៣ លេខ១១-២៥; វស. ជំពូក៦ លេខ១៩-២០; ជំពូក១០; ពោធ. ជំពូក២ លេខ១១, ១៦-២៦; ១៧, ១-១៨, ២៧; វិ. ជំពូក៩៦-៩៧; យញ្ញ. ជំពូក៣ លេខ៥៦-៦៥។

**៣៣.** លោកនារ. ប្រែពាក្យ *អាសង្គ*ការជាប់ជំពាក់'(គោវ., កុល្ល.) ក្នុងន័យថា 'ការមានកម្មសិទ្ធិ'។

៣៨- ដោយបានធ្វើ*ឥស្ថិ* ដ៏ពិសិដ្ឋសម្រាប់ព្រះបង្កើតសត្វលោក(ប្រគាបតិ) ដែល(ទ្រង់ផ្តល់)កម្មសិទ្ធិខ្លួនទាំងអស់ធ្វើជាអំណោយបូជាយញ្ញ ដោយបានរក្សាភ្លើងពិសិដ្ឋក្នុងខ្លួន ព្រាហ្មណ៍អាចចាកចេញពីផ្ទះខ្លួន (ធ្វើជាតាបស)។

៣៩- ពិភពដែលមានរស្មីត្រចះត្រចង់ ក្លាយជា (ចំណែករបស់) អ្នកដែលសូត្រធម៌និទានពីព្រហ្ម និងចាកចេញពីផ្ទះ (ធ្វើជាតាបស) បន្ទាប់ពីបានសន្យាផ្តល់សេចក្តីសុខដល់សព្វសត្វទាំងអស់។

៤០- ព្រោះថា អ្នកមានកំណើតពីរដង មិនបានបង្កគ្រោះភ័យតិចតួចបំផុតដល់សត្វលោក នឹងមិនទទួលផលអាក្រក់មួយ(ភាគណា)ទេ បន្ទាប់ពីគេបានរួចរំដោះពីរូបកាយរបស់ខ្លួន។

៤១- ដោយចាកចេញពីផ្ទះរបស់ខ្លួនទាំងស្រុង ដោយប្រើមធ្យោបាយសម្អាតកាយចិត្ត(បវិត្រ) ចូរអ្នកត្រាច់ចរដោយស្ងប់ស្ងាត់បំផុត និងមិនខ្វល់នឹងការសប្បាយ ដែលខ្លួនអាចទទួលបានទេ។

៤២- ចូរអ្នកត្រាច់ចរម្នាក់ឯងជានិច្ច ដោយមិនចាំបាច់មានគ្នីគ្នា ដើម្បីសម្រេចបាន (ការរួចរំដោះចុងក្រោយ) ដោយការយល់ដឹងទាំងស្រុងថា (មនុស្ស) នៅម្នាក់ឯង ដែលមិនលះបង់ និងមិនត្រូវគេបោះបង់ សម្រេចបានគោលដៅរបស់ខ្លួន។

៤៣- អ្នកមិនគួរមានភ្លើង កន្លែងស្នាក់នៅទេ អ្នកអាចទៅកាន់ភូមិដើម្បីរកអាហារបាន (អ្នកគួរតែ)មិនជាប់ជំពាក់នឹងអ្វីទាំងអស់ មានបំណងច្បាស់លាស់ដោយការធ្វើសមាធិ (និង)ការជញ្ជឹងគិតដល់ព្រហ្ម។

៤៤- អំបែងភាជន៍ (ជំនួសបាត) ការយកឫសឈើ (ធ្វើជម្រក) សម្លៀកបំពាក់រហែកគម្រើម ការរស់នៅតែឯង និងមិនជាប់ជំពាក់អ្វីទាំងអស់ ជាសញ្ញានៃអ្នកដែលបានសម្រេចការរួចរំដោះ។

៤៥- ចូរអ្នកកុំចង់ស្លាប់ ចូរអ្នកកុំចង់រស់ ចូរអ្នករង់ចាំ (ពេលវេលាកំណត់) ដូចជាអ្នកបម្រើ(រង់ចាំ) ប្រាក់ឈ្នួលរបស់ខ្លួន។

---

**៣៨.** ការពណ៌នាអំពីការរៀបចំពិធីសាសនា ក្នុងការបួសជាតាបស មានលម្អិតនៅក្នុងគម្ពីរពោធ. ជំពូក២ លេខ១៧។

**៤១.** *បរិវ្រាបកិតះ* 'ដោយផ្តល់នូវមធ្យោបាយសម្អាតកាយចិត្ត' គឺ 'មានដំបងរបស់ខ្លួន ផ្តាំងទឹករបស់ខ្លួនជាដើម'(គោវ., កុល្លូ., នន្ទ.) តាមលោកមេធ. យល់ថា 'ដោយព្យាយាមសូត្រធម៌បន្សុទ្ធកាយចិត្ត និងដែលជាមធ្យោបាយបន្សុទ្ធកាយចិត្ត ពោលគឺ មានដំបងជាដើម'ក៏បាន ឬ 'ដោយធ្វើតបៈ ដែលបន្សុទ្ធកាយចិត្ត'ក៏បាន។ នារ. ប្រែពាក្យនេះថា 'ដោយបានចាត់ទុកជាអំពើដ៏ឧត្តមបំផុតក្នុងជីវិតរបស់ខ្លួន ក្នុងនាមជាយាវាស ដែលត្រូវធ្វើការសម្អាតកាយចិត្ត ពោលគឺការធ្វើតបៈធម៌ និងការសូត្រព្រះវេទជាដើម' ហើយលោករាឃ. ថា 'ដោយមានទុនចំណេះដឹងធ្វើសន្តកម្មដ៏សម្បូរបែប ដែលបានទទួលពីគម្ពីរឧបនិស័ទ'។ នារ. ប្រែពាក្យ *មុនិះ* 'ស្ងប់ស្ងាត់ទាំងស្រុង'(គោវ., កុល្លូ.) ក្នុងន័យថា 'ដែលផ្តោតចិត្តសមាធិ'។ នន្ទ. បកស្រាយពាក្យ *សមុបោធេសុ* 'ដែលអាចផ្តល់ឱ្យគេបាន'(មេធ., គោវ., កុល្លូ.) ថា 'ដែលគេបានប្រមូលទុកក្នុងផ្ទះរបស់ខ្លួន' ហើយនារ. ថា 'ដែលគេបានសប្បាយដោយត្រឹមត្រូវ'។

**៤១.** មេធ. បកស្រាយពាក្យ *មុនិះ* 'ដោយធ្វើសមាធិ'(គោវ., កុល្លូ.) ដោយថា 'ដែលស្ងប់ស្ងាត់ទាំងស្រុង'។ ជំនួសពាក្យ *អសំកសុកះ* 'ប្រកាន់ខ្ជាប់នូវបំណងហ្មឹងម៉ាត់'(គោវ., កុល្លូ.) នារ., នន្ទ. និង K. ប្រើម មនុ អាន *អសំកយិកះ* 'មិនស្តុកទុករបស់ចាំបាច់នានា' ហើយរាឃ. សរសេរ *អសង្កសូកះ* 'គ្មានមន្ទិល'។ មេធ. ដែលអត្ថបទរបស់លោកសរសេរ *អសំកសុកះ* ឱ្យន័យពាក្យនេះ ដូចការបកស្រាយរបស់អ្នកនិពន្ធដទៃ ហើយទំនងជាអានដូចនឹងលោកនារ. និងនន្ទ. ថា *អសំកយិកះ*។

**៤៥.** អំណានត្រឹមត្រូវ គឺ *និរវេសំ* (មេធ., នារ., នន្ទ., អ្នកនិពន្ធផ្សេងទៀត) ជំនួសពាក្យ *និរទេសំ* (គោវ., K.) ឬ *និទេសំ* (កុល្លូ., រាឃ.)។ អំណានក្រោយនេះ តាមការកត់សម្គាល់របស់លោកនារ. អាចមានន័យថា 'ពាក្យបញ្ជា'។

៤៦- ចូរអ្នកអត់ធន់នឹងពាក្យស្តីបន្ទោស ចូរអ្នកកុំប្រមាថរូបកាយណាមួយឱ្យសោះ ហើយចូរអ្នកកុំធ្វើជាសត្រូវរបស់កាយ ដើម្បីបង្កការវិនាសដល់រូបកាយ។

៤៧- ចូរអ្នកអត់ធន់នឹងពាក្យស្តីបន្ទោស ចូរអ្នកកុំប្រមាថរូបកាយណាមួយឱ្យសោះ ហើយចូរអ្នកកុំធ្វើជាសត្រូវរបស់កាយ ដើម្បីបង្កការវិនាសដល់រូបកាយ។

៤៨- ក្នុងការទប់ទល់នឹងមនុស្សខឹង ចូរអ្នកកុំជះកំហឹងតប ចូរអ្នកឱ្យពរនៅពេលមានគេជេរប្រទេចអ្នកហើយ ចូរអ្នកកុំនិយាយពាក្យគ្មានការពិត ត្រាច់ចរតាមខ្លោងទ្វារប្រាំពីរ។

៤៩- ត្រេកអរជាមួយនឹងព្រលឹងវិញ្ញាណ ដោយអង្គុយ(ក្នុងជំហរជាយោគៈ) មិនទទួល(ជំនួយពីអ្នកក្រៅ) ទប់សេចក្តីរីករាយផ្លូវអារម្មណ៍ទាំងស្រុង ដោយនៅតែក្នុងបន្ទប់របស់ខ្លួនប៉ុណ្ណោះ អ្នកគួររស់នៅក្នុងពិភពនេះ ដោយចង់បានពរ(នៃការរួចរំដោះចុងក្រោយ)។

៥០- កុំ(បកស្រាយ)ហេតុអស្ចារ្យ និងបុព្វនិមិត្ត កុំប្រកាន់យកជំនាញហោរាសាស្ត្រ និងវិជ្ជាទាយបាតដៃ កុំផ្តល់ប្រឹក្សាយោបល់និងអធិប្បាយ(អំពីសាស្ត្រ) ចូរអ្នកទទួលវត្ថុទេយ្យទានបានជានិច្ច។

៥១- ចូរអ្នកកុំ (ដើម្បីសុំទាន) ដើរជិតផ្ទះដែលមានឥសី ព្រាហ្មណ៍ សត្វស្លាប ឆ្កែ ឬស្មូមផ្សេងៗ។

៥២- ចូរកាត់សក់ ក្រចក និងពុកចង្ការបស់ខ្លួនឱ្យខ្លី ដើរកាន់បាត ដំបង និងកំសៀវទឹក, ចូរអ្នកត្រាច់ចរជាប្រចាំដោយគ្រប់គ្រងខ្លួនឯង និងមិនបង្កការឈឺចាប់ដល់សត្វណាមួយឡើយ។

៥៣- ភាជន៍របស់អ្នកមិនគួរធ្វើពីលោហៈ ភាជន៍ប្រើប្រាស់គួរតែគ្មានការបែកបាក់ តាមបញ្ញត្តិគឺថា អ្នកគួរប្រើទឹកសម្អាតភាជន៍ ដូចជា(ពែង ដែលគេហៅថា)*ភមសៈ* នៅពេលមានពិធីយញ្ញ។

៥៤- ឃ្លោក ចានឈើ (ចាន)ដី ឬចានដែលធ្វើពីបន្ទះផ្តៅ *មនុ* បុត្ររបស់ព្រះស្វយំភូ បានប្រកាស(ថាជា)ភាជន៍(សមស្រប)សម្រាប់តាបសឥសី។

៥៥- ចូរអ្នកដើរសុំទាន(មួយថ្ងៃ)ម្តង ចូរអ្នកកុំចង់បាន(វត្ថុទាន)ច្រើនពេក ព្រោះតាបសដែលខំស្វែងរកទេយ្យទាន ជាប់ជំពាក់នឹងសេចក្តីរីករាយផ្លូវអារម្មណ៍ផងដែរ។

---

**៤៦.** មានន័យថា 'ចូរអ្នកប្រយ័ត្នមុននឹងអ្នកដាក់ជើងចុះ ក្រែងលោអ្នកបង្កអន្តរាយដល់សត្វតូចតាច សូមមើលកាព្យ៦៨' (គោវ., មេធ., រាឃ.) ឬ 'ក្រែងលោអ្នកដើរជាន់របស់មិនស្អាត'(កុល្ល.)។

**៤៨.** 'ខ្លោងទ្វារប្រាំពីរ' តាមលោកមេធ. និងគោវ. គឺ 'ធម្ម អាថ៌ និងកាម ដោយឡែកពីគ្នា ធម្មនិងអាថ៌, អាថ៌និងកាម និងចុងក្រោយផ្សំបញ្ចូលគ្នា' ធម្មាថកាម ហើយយោងតាមកុល្ល. និងមេធ. ថា 'ចិត្ត បញ្ញា និងញាណប្រាំ' និងតាមនារ. ថា 'ញាណប្រាំ ចិត្ត និងអហំការ ឬអត្តាទិដ្ឋ'។ កុល្ល. ធ្វើការបកស្រាយម្យ៉ាងទៀតថា 'លោកប្រាំពីរ' ហើយលោកមេធ. ផ្តល់ន័យទីបីថា 'ខ្យល់ជីវិតប្រាំពីរ ដែលស្ថិតក្នុងក្បាល'។ ន័យទូទៅមានសភាពដូចគ្នា គឺ 'អ្វីដែលសំដៅដល់បញ្ហាលោកិយ'។

**៥០.** យោងតាមនារ. និងរាឃ. ពាក្យ *អង្គវិទ្យា* 'វិជ្ជាទាយបាតដៃ'(មេធ., កុល្ល., នន្ទ.) មានន័យថា 'វិទ្យាសាស្ត្រស្តីពីវេយ្យាករណ៍ និងអង្គប្រាំទៀតរបស់ព្រះវេទ'។ គោវ. ប្រែ *នក្សត្រាង្គវិទ្យា* ជាពាក្យផ្សំគុណនាមកំណត់ ដោយឱ្យន័យថា 'ហោរាសាស្ត្រ'។ ពាក្យ *អនុសាសនៈ* 'ការឲ្យឱវាទ'(មេធ., គោវ., កុល្ល., រាឃ.) ហើយការឱ្យន័យតាមនារ. និងនន្ទ.គឺថា 'ការបង្រៀនព្រះវេទ'។ ព្រះវេទ 'ការអធិប្បាយអំពី(សាស្ត្រ)'(គោវ., កុល្ល.) និងតាមមេធ. និងនារ. ថា 'ការជជែកជំទាស់' ហើយតាមនន្ទ. និងរាឃ. ថា 'វិទ្យាសាស្ត្រវិចារវិទ្យា'។ កាព្យនេះ ដែលមាននៅក្នុងគម្ពីរវស. ជំពូក១០ លេខ ២១ ដែរនោះ មានសារសំខាន់ជាប្រវត្តិសាស្ត្រ ព្រោះវាស្តែងឱ្យឃើញថា កាលពីបុរាណ ក៏ដូចជាសម័យទំនើប តាបសបានដើរតាមលំអានការងារលោកិយ និងជាគ្រូអាចារ្យ ឬទីប្រឹក្សារបស់ប្រជាជន។

**៥៥.** ការបកស្រាយរបស់លោកគោវ. គឺ'ចូរអ្នកកុំចេញទៅដើរសុំញឹកញាប់ពេក' ជំនួសឱ្យ 'ចូរអ្នកកុំចង់បានទេយ្យទានចំនួនច្រើនពេក'។

៥៦- នៅពេលគ្មានផ្សែងចេញពី (ផ្ទះបាយ) ពេលអង្រែនៅស្ងៀមគ្មានចលនា ពេលរងើកភ្លើងរលត់ ពេលមនុស្សបញ្ចប់ការទទួលទានអាហាររបស់ពួកគេ ពេលអាហារសំណល់ក្នុងចានអស់ ចូរតាបសដើរសុំគេជានិច្ច។

៥៧- ចូរអ្នកកុំសោកស្តាយពេលអ្នកមិនបានទទួលអ្វី និងកុំរីករាយពេលអ្នកទទួលបាន (អ្វីៗ) ចូរអ្នក (ទទួល)ត្រឹមតែសម្រាប់ការចិញ្ចឹមជីវិតប៉ុណ្ណោះ ចូរអ្នកកុំខ្វល់ពី(គុណភាព)ប្រដាប់ផ្ទះបាយ។

៥៨- ចូរអ្នកកុំឱ្យតម្លៃ(អាហារ)ទាំងអស់ ដែលទទួលបានដោយសារការគោរពដ៏រាបសា(ព្រោះ)សូម្បីតាបស ដែលបានសម្រេចការរួចរំដោះចុងក្រោយក្តី ក៏នៅជាប់ជំពាក់នឹង(ច្រវ៉ាក់វដ្តសំសារ) ដោយការទទួល(អាហារ)ដែលបានការគោរពដ៏រាបសាដែរ។

៥៩- ដោយការទទួលទានតិច និងដោយឈរនិងអង្គុយម្នាក់ឯង ចូរអ្នកទប់ឥន្ទ្រីយារម្មណ៍របស់ខ្លួន ប្រសិនបើវាជាប់ជំពាក់នឹងវត្ថុកាម។

៦០- ដោយការខំទប់ឥន្ទ្រីយារម្មណ៍របស់ខ្លួន ដោយការបំផ្លាញក្តីស្រឡាញ់ និងស្អប់ និងដោយការមិនបង្កគ្រោះភ័យដល់សត្វលោក អ្នកសមនឹងទទួលបានភាពអមតៈ។

៦១- ចូរអ្នកពិចារណាអំពីដំណើរវិវត្តន៍របស់មនុស្សដែលកើតពីអំពើបាបរបស់ខ្លួន អំពីការធ្លាក់ចុះនរក និងអំពីការរងទារុណកម្មនៅក្នុងឋាន*យម*។

៦២- ពិចារណាអំពីការនៅបែកពីមនុស្សជាទីស្រឡាញ់របស់ខ្លួន ការសេពគប់ជាមួយមនុស្សគួរឱ្យស្អប់ អំពីការស្ថិតក្នុងអំណាចចាស់ជរាដោយវ័យ និងអំពីការរងទុក្ខដោយសារជំងឺ,

៦៣- ពិចារណាអំពីព្រលឹងចាកចេញពីរូបកាយនេះ និងការចាប់កំណើតជាថ្មីរបស់ព្រលឹង នៅក្នុងគភ៌ (មួយទៀត) និងអំពីការត្រាច់ចររបស់ព្រលឹងឆ្លងកាត់រាប់សិបពាន់លានអត្តិភាព,

៦៤- ពិចារណាអំពីទោសនៃការឈឺចាប់ដែលមាននៅក្នុង(ចិត្ត) ដែលកើតពីអកុសល និងការទទួលពរអមតៈ ដែលកើតពីការសម្រេចគោលបំណងថ្នាក់ខ្ពស់បំផុតរបស់ខ្លួន (បានទទួលតាមរយៈ) កុសលផ្លូវចិត្ត។

៦៥- ដោយចិត្តសមាធិដ៏ជ្រៅ ចូរអ្នកទទួលស្គាល់ធម្មជាតិដ៏សុខុមនៃកំពូលអាត្ម័ន និងវត្តមាននៃអាត្ម័ននៅក្នុងគ្រឿងវិញ្ញាណទាំងអស់ ទាំងថ្នាក់ខ្ពស់បំផុត និងថ្នាក់ទាបបំផុត។

៦៦- អ្នកអាចប្រកាន់ខ្ជាប់នូវលំដាប់ណាមួយ ចូរអ្នក ទោះបីមានការខ្វះ(ដោយចំណង់នៃសញ្ញាខាងក្រៅ) បំពេញករណីយកិច្ចរបស់ខ្លួន រក្សាចិត្តស្មើចំពោះសព្វសត្វទាំងអស់ (ព្រោះ)សញ្ញាខាងក្រៅ(នៃទម្លាប់សុខស្រួល) មិនមែនជាបុព្វហេតុនៃការទទួលបានបុណ្យកុសលទេ។

---

**៥៧.** *មាត្រា*ប្រដាប់ប្រើប្រាស់' មានដូចជា ដំបង កំសៀវទឹករបស់ខ្លួនជាដើម (មេធ., គោវ., កុល្លូ., រាឃ.) និងតាមនារ. និងនន្ទ. ថា 'មួយផ្នែក ឱ.ទា.មួយម៉ាត់' (កវណៈទិះ, នារ.) ឬ'មួយផ្នែក ល្មមនឹងពេញក្រពះខ្លួន'(ឧទរបូរណាវធិរ មាត្រា)។

**៦៥.** នន្ទ. លុបកាព្យនេះចោល។ 'បំណងខ្ពស់បំផុត' គឺ 'ការទទួលស្គាល់របស់ព្រហ្ម'(កុល្លូ.) និងសំណាងល្អក្នុងការសម្រេចបានបំណងនោះ ស្ថិតនៅលើអ្នកដែលបានសម្រេចបុណ្យកុសលដ៏ច្រើន។

**៦៦.** ជំនួសពាក្យ *ទូសិតោ 'បិ* 'ទោះបីសៅហ្មង(ដោយចំណងនៃសញ្ញាខាងក្រៅ)នៃទម្លាប់សុខក្តី'(កុល្លូ., នន្ទ., រាឃ.) លោកមេធ., គោវ., នារ. និង K. អាន *ភូសិតោ 'បិ* 'ទោះបីជាប់ជំពាក់នឹងកម្រងផ្កាក៏ដោយ'។

៦៧- ថ្វីបើផ្លែឈើ*កតក*(សម្បកភ្លឺថ្លា) ញុាំងឱ្យទឹកថ្លាក៏ដោយ ប៉ុន្តែ(ទឹក)មិនមែនថ្លា ដោយសារសម្គាល់លើឈ្មោះ(របស់ផ្លែឈើ)ទេ។

៦៨- ដើម្បីការពារសត្វមានជីវិត ចូរអ្នកដើរទាំងថ្ងៃ ទាំងយប់ សូម្បីមានការឈឺចាប់ដល់រូបកាយអ្នក ក៏ដោយ ដោយក្រឡេកមើលដីដោយប្រុងប្រយ័ត្ន។

៦៩- ដើម្បីលុបលាង(ការស្លាប់)របស់សត្វទាំងអស់ ដែលអ្នកបង្កឡើងដោយអចេតនា ទោះនៅពេលថ្ងៃក្តី ឬពេលយប់ក្តី តាបសគួរតែមុជទឹក និងធ្វើការទប់ដង្ហើមប្រាំមួយដង។

៧០- ការទប់ដង្ហើមបីដងក្តី ស្របតាមតម្រាវិធាន និងអមដោយ(ការសូត្រ)វ្យាហ្ឫតិះ និងពាក្យ ឱម អ្នកត្រូវតែចេះរបៀបធ្វើតបៈធម៌ដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់ព្រាហ្មណ៍គ្រប់រូប។

៧១- ដោយសារភាពមិនបរិសុទ្ធនៃរ៉ែលោហៈ ដែលឆេះរលាយហើយចេញពី(ចង្ក្រាន) ដូច្នេះគេកំចាត់ភាពសៅហ្មងនៃឥន្ទ្រីយ៍ តាមរយៈការទប់ដង្ហើម។

៧២- ចូរអ្នកកម្ចាត់បង់គ្រឿងសៅហ្មងដោយការទប់ដង្ហើម (ការបង្កើត)បាបកម្មដោយការជាប់ជំពាក់ចិត្ត ការប្រកាន់ខ្ជាប់នូវអារម្មណ៍ទាំងអស់ដោយការខំទប់(អារម្មណ៍និងគ្រឿងវិញ្ញាណរបស់ខ្លួន) និងលក្ខណៈសម្បត្តិទាំងអស់ ដែលគ្មាននៅក្នុងខ្លួនព្រះជាម្ចាស់ ដោយការធ្វើសមាធិ។

៧៣- តាមរយៈការបតិបត្តិសមាធិ ចូរអ្នកទទួលស្គាល់ការរីកចម្រើនផ្នែកព្រលឹងមួយៗ តាមប្រភេទនានា (ការវិវត្ត)ដ៏លំបាកសម្រាប់មនុស្សដែលគ្មានការអប់រំ។

៧៤- អ្នកដែលមានការយល់ដឹងច្បាស់ពិតប្រាកដ(ចាក់ឆ្លុះក្នុងធម្មជាតិលោកិយ) មិនជាប់ជំពាក់នឹងអំពើរបស់ខ្លួនទេ ប៉ុន្តែអ្នកដែលគ្មានការយល់ដឹងច្បាស់លាស់នោះ ធ្លាក់ចុះក្នុងវដ្តនៃការកើត និងស្លាប់។

---

**៦៩.** ចំពោះពាក្យ 'ការទប់ដង្ហើម' សូមមើល វស. ជំពូក២៥ លេខ១៣ និង Wilson*វិស្ណុបុរាណ* ជំពូក៥ ទំព័រ ២៣១ (ពិនិត្យផ្ទៀងផ្ទាត់ដោយសាស្ត្រាចារ្យ Hall)។

**៧១.** វស. ជំពូក២៥ លេខ៦; ពោធ. ជំពូក៤ លេខ១, ២៤។

**៧២.** ចំពោះពាក្យ *ធារណា*ផ្តោតចិត្ត' សូមមើលWilson*វិស្ណុបុរាណ* ជំពូក៥ ទំព័រ ២៣១ (ពិនិត្យផ្ទៀងផ្ទាត់ដោយលោក Hall) និង Jacob*វេទាន្តសារ* ទំព័រ ១០៩។

*អនិស្វាន គុណាន* 'លក្ខណៈសម្បត្តិទាំងអស់ដែលព្រះជាម្ចាស់គ្មាន'។ មេធ. បកស្រាយលក្ខណៈសម្បត្តិ ថាជា 'អំពើល្អ តណ្ហា និងភាពងងឹត' និងពាក្យគុណកិរិយា 'ដែលព្រះជាម្ចាស់គ្មាន' ថា 'ដែលស្ថិតលើវត្ថុអាស្រ័យមួយទៀត' និងបន្ថែមថា 'ការប្រកាន់(អភិមានៈ)អាត្ម័ន(បុរុស) ដែលមានលក្ខណៈសម្បត្តិ និងជាប់ជំពាក់តម្រេក ឬការឈឺចាប់ ហើយអំពើបែបនេះ គេត្រូវកម្ចាត់ចោលឱ្យបាន'។ គោវ. និង K. អះអាងថា លក្ខណៈសម្បត្តិទាំងឡាយ ដែលផ្ទុយពី 'កុសល ពុទ្ធិ ការគ្មានតម្រេក និងអំណាច'(Dawies *សាំខ្យា* ទំព័រ ៨១) គេអាចកំចាត់ចោលបានដោយ 'ការធ្វើសមាធិ' ដូចមានកំណត់នៅក្នុងយោគសាស្ត្រ។ ដូចគ្នានេះដែរ លោកនារ.(ព្រមទាំងនន្ទ.) ដែលអាន *អនៃស្វាន* និយាយថា លក្ខណៈសម្បត្តិ ដែលផ្ទុយពីពុទ្ធិ និងកម្លាំងពិតប្រាកដនិងជាការកែខៃតម្រេក និងភាពងងឹត ត្រូវកម្ចាត់ចោលដោយការធ្វើសមាធិ ដោយមិនចាំបាច់មានរូបភាពជាក់លាក់ទេ។ ម្យ៉ាងទៀត កុល្លូ. និងរាឃ. ប្រែសេចក្តីស្តីពីគោលការណ៍*វេទាន្ត* និងបកស្រាយលក្ខណៈសម្បត្តិទាំងឡាយថា 'ដូចជាមិនជាប់នឹងព្រះ ព្រហ្ម ពេលគឺជាទោសៈ លោភៈ និងឥច្ឆាជាដើម'។

៧៥- ដោយការមិនបង្កអន្តរាយដល់សត្វ ដោយការផ្តាច់ការជាប់ជំពាក់ចិត្ត(ពីវត្ថុកាមតម្រេក) ដោយការធ្វើពិធីសាសនាដែលមានកំណត់ក្នុងព្រះវេទ និងដោយការធ្វើតបៈធម៌ដ៏តឹងរ៉ឹង (មនុស្ស) សម្រេចបានសភាពនោះ(សូម្បី)ក្នុង(លោកិយនេះ)ក៏ដោយ។

៧៦- ៧៧ ចូរអ្នកបោះបង់ការអាស្រ័យនៅដែលមានធាតុផ្សំប្រាំ ដែលមានឆ្អឹងជាធ្នឹម ហើយដែលចងភ្ជាប់ដោយសរសៃពួរ(ជំនួសខ្សែពួរ) ដែលសាច់និងឈាមជាបាយអ ដែលបិទបាំងដោយស្បែក ដែលមានក្លិនអាក្រក់ពោរពេញដោយទឹកមូត្រនិងលាមក រងទារុណដោយរ័យជរានិងទុក្ខព្រួយ ជាសម្បុករោគ ត្រូវឃាយីដោយការឈឺចាប់ សោកសៅនឹងតម្រេកតណ្ហា ហើយបែកធ្លាយទៅ។

៧៨- អ្នកដែលចាកចោលរូបកាយនេះ (ដោយការចាំបាច់) ដូចដើមឈើ(ដែលត្រូវដាច់ចេញពី)ច្រាំងទន្លេ ឬ(ហើរដោយសេរី)ដូចបក្សីចាកចោលរុក្ខា បានរួចផុតពីទុក្ខសោកក្នុង(លោកិយនេះ ដែលគួរឱ្យខ្លាច) ឧបមាដូចជាខ្លាចត្រីឆ្លាម។

៧៩- ដោយធ្វើអំពើល្អ(ជាកុសលរបស់ខ្លួនផ្ទាល់)ចំពោះមិត្តសំឡាញ់ខ្លួន និង(ធ្វើ)អំពើអាក្រក់ចំពោះសត្រូវ អ្នកទទួលបានឋានព្រហ្មអមតៈ ដោយការធ្វើសមាធិ។

៨០- ដោយសម្បទា(ចិត្តរបស់ខ្លួន) ពេលដែលអ្នកមិនប្រកាន់ខ្ជាប់នឹងវត្ថុទាំងអស់ អ្នកទទួលបានសុភមង្គលជានិរន្តន៍ ទាំងក្នុងជាតិនេះនិងទាំងក្នុងជាតិក្រោយ។

៨១- អ្នកដែលបានលះបង់ការជាប់ជំពាក់បន្តិចម្តងៗតាមរបៀបនេះ និងរួចរំដោះពីសភាពគូនឹងគ្នា សង្ឃឹមនឹងបានឋានព្រហ្មតែម្យ៉ាង។

៨២- ទាំងអស់នេះ ដូចដែលបានប្រកាស(ខាងដើម) អាស្រ័យលើការធ្វើសមាធិ ព្រោះអ្នកដែលគ្មានការប៉ិនប្រសប់នឹងចំណេះដឹង ញ៉ាំងឱ្យអាត្ម័នមិនបានទទួលផលទាំងស្រុងធ្វើបត្តិពិធីសាសនា។

---

**៧៥.** 'ដោយពិធីសាសនា ដែលមានកំណត់ក្នុងព្រះវេទ' ជាពិធីប្រចាំថ្ងៃ(មេធ., គោវ., កុល្លូ.) ឬ 'ពិធីប្រចាំថ្ងៃ និងពិធីទាំងឡាយដែលកំណត់សម្រាប់ឱកាសជាក់លាក់ណាមួយ'(នារ., នន្ទ.)។ 'សភាពនោះ' គឺ 'ការប្រសប់ជាមួយព្រហ្ម'(គោវ., កុល្លូ., រាឃ.) ហើយតាមមេធ. ថា 'ដំណាក់នោះ គឺឋានព្រហ្ម'។ នារ. និងនន្ទ. អាន *តជ្ជ្យំ* 'ដំណាក់(ព្រហ្ម)ដ៏ខ្ពស់បំផុត'។

**៧៦-៧៧.** មៃត្រ. ឧប. ជំពូក៣ លេខ៤។

**៧៩.** 'ធ្វើអំពើល្អ(ជាកុសលផ្ទាល់ខ្លួន)' តាមគោវ. និងមេធ. ថា '(ផល)នៃអំពើល្អរបស់នរណាម្នាក់'។

**៨០.** 'នៅក្នុងភពនេះ' ពោលគឺ អ្នកក្លាយជា *គីវន្មុក្ត* អ្នកដែលបានរួចរំដោះក្នុងជាតិនេះ(នារ.)។

**៨១.** 'សភាពផ្ទុយគ្នា' ដូចជា ការស្រេកឃ្លាននិងការឆ្អែតឆ្អន់ជាដើម(គោវ.) ឬកិត្តិយស និងអ័ព្ទយស(កុល្លូ.)។

**៨២.** ខ្ញុំប្រែតាមលោកគោវ., នារ. និងនន្ទ. ដែល 'បកស្រាយកាព្យនេះក្នុងន័យថា មេរៀនទាំងអស់នៅក្នុងជំពូកខាងដើម ដែលមានបួនដំណាក់កាល អាស្រ័យលើការធ្វើសមាធិ ដែលអាចសម្រេចផលទីបំផុតយ៉ាងឆាប់រហ័សដែរ ព្រោះថា បើមនុស្សអាចធ្វើពិធីបញ្ញត្តិតាមសាសនាបានល្អយ៉ាងណាក៏ដោយ ក៏គេមិនអាចទទួលផលទាំងស្រុង ដោយគ្មានការចេះដឹង និងការធ្វើសមាធិផ្តោតទៅលើឋានព្រហ្មបានទេ។ កុល្លូ. ឱ្យន័យឃ្លានេះ ថា «ទាំងអស់នេះត្រូវបានប្រកាសរួចហើយ» សំដៅដល់ន័យកាព្យចុងក្រោយ ហើយថា «ការរួចរំដោះទាំងស្រុងពីការជាប់ជំពាក់ និងការបានឋានព្រហ្ម» អាស្រ័យលើការទទួលស្គាល់ការឯកភាពអាត្ម័នខ្លួនជាមួយនឹងឋានព្រហ្ម។ លោកយល់ពាក្យ *ក្រិយាផលំ* «ផលសម្រាប់ការធ្វើសមាធិ»' លោកមេធ. ផ្តើមការបកស្រាយដូចគ្នានឹងលោកកុល្លូ.ដែរ ប៉ុន្តែគាត់ប្រែ *ក្រិយាផលំ* ក្នុងន័យដូចគ្នានឹងគោវ., នារ. និងនន្ទ. ដែរ។ លោករាឃ. ប្រែ *យទ អេតទ អភិសព្ទិតំ* ថា 'អ្វីៗ ដែលអាចបញ្ជាក់ដោយពាក្យ'។

៨៣- ចូរអ្នកសូត្រ(អត្ថបទ)ព្រះវេទទាំងនោះជាប្រចាំ ដែលពាក់ព័ន្ធនឹងពិធីយញ្ញ (ពាក្យ)ឧទ្ទិសដល់អាទិទេព និង(ពាក្យ)ដែលគោរពដល់អាត្ម័ន និងដែលមានក្នុងផ្នែកបញ្ចប់នៃព្រះវេទ(វេទាន្ត)។

៨៤- នោះគឺជាទីពឹងរបស់មនុស្សល្ងង់ ហើយ(ទីពឹង)នោះក៏ជារបស់អ្នកដែលចេះដឹង(ន័យព្រះវេទ) នោះជា(ការការពារ) អ្នកទាំងឡាយដែលស្វែងរក (ពរឡើង) ឋានសួគ៌ និងដែលស្វែងរក (បរមសុខ)ជានិរន្តន៍។

៨៥- អ្នកមានកំណើតពីរដង ដែលក្លាយជាតាបស បន្ទាប់ពីបានធ្វើអំពើខាងលើជាបន្តបន្ទាប់ កម្ចាត់អស់បាបកម្មធ្ងន់ៗដូចរៀបរាប់ខាងក្រោម នឹងឡើងកាន់ឋានព្រហ្មដ៏ខ្ពស់បំផុត។

៨៦- ដូច្នេះ ច្បាប់(មានសុពលភាព)សម្រាប់តាបសដែលចេះគ្រប់គ្រងខ្លួន ត្រូវបានបកស្រាយជូនអ្នកទាំងឡាយ ឥឡូវនេះចូរស្ដាប់ករណីយកិច្ច(ពិសេស)របស់អ្នកដែលបោះបង់ (ពិធីដែលបញ្ញត្តិដោយ)ព្រះវេទ។

៨៧- សិស្ស យរាវាស ឥសី និងតាបស ទាំងអស់នេះ(បង្កើតបាន)លំដាប់ថ្នាក់បួនផ្សេងគ្នា ដែលរាប់ចាប់ពី(លំដាប់ថ្នាក់)យរាវាសឡើងទៅ។

៨៨- ប៉ុន្តែទាំងអស់ (ឬ)សូម្បីលំដាប់ថ្នាក់ណាក៏ដោយ ដែលបានប្រតិបត្តិតាមគោលការណ៍(ច្បាប់ពិសិដ្ឋ)ជាបន្តបន្ទាប់ ញ៉ាំងឱ្យព្រាហ្មណ៍ដែលអនុវត្ត(តម្រាវិធាន)ខាងដើមនេះ ឡើងទៅកាន់ទីខ្ពស់បំផុតបាន។

៨៩- ហើយអនុលោមតាមសិក្ខាបទព្រះវេទនិងស្មិតិ អ្នកគ្រប់គ្រងផ្ទះត្រូវបានប្រកាសថា ខ្ពង់ខ្ពស់ជាងអ្នកដទៃទាំងអស់ ព្រោះគាត់ឧបត្ថម្ភគាំទ្រដល់អ្នកទាំងបីផ្សេងទៀត។

៩០- ដូចជាទន្លេទាំងអស់ ទាំងធំទាំងតូច ស្វែងរកទីសម្រាកក្នុងមហាសាគរ បីដូចជាមនុស្សគ្រប់លំដាប់ថ្នាក់ ស្វែងរកការការពារពីយរាវាស។

---

**៨៣.** 'ដែលសំដៅពិធីយញ្ញ'គឺ 'ព្រាហ្មណ៍' (មេធ., គោវ., នន្ទ.) ឬ 'ព្រហ្មវេទ'(កុល្ល., នារ.) ឬ 'កាមកាណ្ឌ' ឧ.ទា. *ឥសេត្វា ឱគេ ត្វា* (វាគ. សំហ. ជំពូក១ លេខ១), រាឃ. ថា 'ពិធីនោះឧទ្ទិសចំពោះអាទិទេព' គឺ 'មន្ត្រី ដែលពិពណ៌នាអាទិទេពនានា'(មេធ., គោវ.) តួយ៉ាងគម្ពីរឫគ-វេទ ជំពូក៨ លេខ៤៤, ១៦(គោវ.)។ អនុប្រយោគទីបីនៃអត្ថបទនេះ គឺជាពាក្យនៅក្នុងគម្ពីរឧបនិស័ទ ប៉ុន្តែសូមមើល Goldstucker*វចនានុក្រមសំស្ក្រឹត* រកពាក្យ *អធ្យាត្ម*។

**៨៦.** គោវ. មានយោបល់ថា បុគ្គលដែលមានរៀបរាប់ឈ្មោះខាងលើ ជំពូក៤ លេខ២២ មានបញ្ជាក់នៅទីនេះ។ ប៉ុន្តែដោយមានសេចក្ដីបន្តបន្ទាប់ កាព្យលេខ៩៤, ៩៥ ហាក់ដូចជាសបញ្ជាក់ថា អត្ថបទចង់សំដៅដល់ព្រាហ្មណ៍ទាំងឡាយ ដែលបន្តរស់នៅក្នុងផ្ទះរបស់ខ្លួន ទោះបីមានបំណងចង់បានពុទ្ធិដ៏កំពូល និងបោះបង់កិច្ចការលោកិយទាំងអស់ក៏ដោយ សូមមើលជំពូក៤ លេខ២៥៧ផង។ គោវ. និងនារ. សន្មតថា ពួកគេនៅតែជាយរាវាសដដែល ចំណែកឯលោកកុល្ល. រាប់ពួកគេ ក្នុងក្រុមតាបសទាំងឡាយ។

**៨៧-៩៣.** អាប. ជំពូក២ លេខ២៣-២៤; គោត. ជំពូក៣ លេខ៣៦; វស. ជំពូក៨ លេខ១៤-១៦; ជំពូក១០ លេខ៣០; ពោធ. ជំពូក២ លេខ១១, ៩-៣៤; វិ. ជំពូក៥៩ លេខ២៧-២៩។

យោងតាមអ្នកនិពន្ធនានា ការពិភាក្សាតទៅនេះ សំដៅបង្ហាញ ទី១-ថាមានលំដាប់ថ្នាក់តែបួនប៉ុណ្ណោះ និងថា *វេទសំន្យាសិក* ស្ថិតក្នុងក្រុមនេះ និងមិនបង្កើតថ្នាក់ទីប្រាំទេ ឬស្ថិតក្រៅលំដាប់ថ្នាក់ទេ ទី២-ថា ព្រោះលំដាប់ថ្នាក់យរាវាស ជាថ្នាក់ពិសេស មានន័យថា មនុស្សអាចបន្តរស់នៅក្នុងផ្ទះរបស់ខ្លួន ដើម្បីការពារបុត្ររបស់ខ្លួនបាន។

៩១- ដោយសារអ្នកមានកំណើតពីរដងស្ថិតក្នុង(លំដាប់ថ្នាក់)ណាមួយក្នុងចំណោមលំដាប់ទាំងបួនសិក្ខាច្បាប់ដប់ខ គេត្រូវប្រតិបត្តិដោយយកចិត្តទុកដាក់ជានិច្ច។

៩២- ការពេញចិត្ត ការឱ្យអភ័យ ការគ្រប់គ្រងខ្លួន ការមិនយករបស់អ្នកដទៃធ្វើជារបស់ខ្លួនដោយ មិនត្រឹមត្រូវ (ការគោរពតាមតម្រា) សម្អាតកាយចិត្ត ការបង្ខំគ្រឿងវិញ្ញាណ គតិបណ្ឌិត ពុទ្ធិ (នៃអាត្ម័នដ៏កំពូល) សច្ចភាព និងការវៀរចាកកំហឹង (បង្កើតបានជា)សិក្ខាច្បាប់ដប់យ៉ាង។

៩៣- ព្រាហ្មណ៍ទាំងឡាយដែលសិក្សាសិក្ខាច្បាប់ទាំងដប់ដោយហ្មត់ចត់ ហើយបន្ទាប់ពីបានសិក្សាបដិបត្តិ វានឹងបានឡើងកាន់សភាពខ្ពស់បំផុត។

៩៤- អ្នកមានកំណើតពីរដងដែលដើរតាមសិក្ខាច្បាប់ដប់ ដោយចិត្តមូល និងបានសងបំណុល (បី) របស់ខ្លួន អាចក្លាយជាតាបសបន្ទាប់ពីសិក្សាវេទាន្ត ស្របតាមតម្រាបញ្ញត្តិ។

៩៥- ដោយបានបោះបង់(ការធ្វើ)ពិធីសាសនាទាំងអស់ ដោយលះបង់ទោស(នៃអំពើបាប)របស់ខ្លួន ដោយខិតខំទប់វិញ្ញាណ និងដោយបានសិក្សាព្រះវេទ អ្នកអាចរស់នៅតាមសម្រួលក្រោមការការពាររបស់បុត្រខ្លួន។

៩៦- ដូចនេះអ្នកដែលបានបោះបង់(ការធ្វើ)ពិធីសាសនាទាំងអស់ដែលផ្តោតលើវត្ថុបំណង(តែមួយ) របស់ខ្លួនផ្ទាល់ (ហើយ)រួចផុតពីចំណង់ កម្ចាត់បង់ទោសរបស់ខ្លួន ដោយការលះបង់នឹងឡើងកាន់សភាពខ្ពស់បំផុត។

៩៧- ដូច្នេះ ច្បាប់ពិសិដ្ឋបួនខសម្រាប់ព្រាហ្មណ៍ ដែលបន្ទាប់ពីស្លាប់(ទទួល)ផលមិនចេះសាបសូន្យត្រូវបានប្រកាសប្រាប់អ្នកទាំងឡាយ ឥឡូវនេះចូរសិក្សាពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ។

---

**៩២.** ពាក្យ *ធ្រិតិះ* 'ការពេញចិត្ត' តាមលោកនារ., នន្ទ. និងរាឃ. ថា 'ការប្រកាន់ខ្ជាប់នូវបំណង ឬដោយអនុវត្តតាមភារកិច្ច'។ ពាក្យ *ទមះ* 'ការគ្រប់គ្រងខ្លួន' តាមមេធ. និងនន្ទ. ថា 'ការដាក់ខ្លួន' ហើយតាមគោវ. និងនារ. ថា 'ធន់ទ្រាំនឹងការឈឺចាប់', តាមកុល្លូ. និងរាឃ. ថា 'ការគ្រប់គ្រងគ្រឿងវិញ្ញាណខាងក្នុង'។ ពាក្យ *ធីះ* 'គតិបណ្ឌិត' តាមមេធ. និងគោវ. ថា 'រួចផុតពីមន្ទិល និងការភាន់ច្រឡំ', តាមកុល្លូ. និងរាឃ. ថា 'ចំណេះដឹងអត្ថន័យពិតរបស់សាស្ត្រ'។ លោក នារ. និងនន្ទ. អាន *ហ្រីះ* 'ខ្មាស់បាប ឬខ្លាចបាប'។

**៩៤.** វស. ជំពូក១០ លេខ១០។

**៩៥.** 'ដោយបានសិក្សាព្រះវេទ' គឺ 'ឧបនិស័ទ'(កុល្លូ.) គោត., នារ., នន្ទ., រាឃ. និង K. អាន *អក្សស្យន*ការសិក្សា ព្រះវេទ' និងលោកមេធ. សរសេរអំណានដូចគ្នាក្នុងអត្ថបទនានា។

**៩៦.** 'វត្ថុបំណងផ្ទាល់ខ្លួន' គឺ 'ការរួចរដោះចុងក្រោយ'។

**៩៧.** អនុលោមតាមលោកមេធ. ពាក្យ 'ព្រាហ្មណ៍' មិនមែនមិនរាប់បញ្ចូលពួកអារ្យ៉ន៍ផ្សេងទៀតទេ ប៉ុន្តែតាមលោកគោវ., កុល្លូ. និងនារ. ពាក្យនេះមានន័យបញ្ជាក់ថា ភាពជាតាបស គឺអនុញ្ញាតចំពោះតែព្រាហ្មណ៍ប៉ុណ្ណោះ។

# ជំពូក ៧

១- ខ្ញុំនឹងថ្លែងអំពីករណីយកិច្ចរបស់ព្រះមហាក្សត្រិយ (និង) បង្ហាញថា តើព្រះមហាក្សត្រិយគួរប្រតិបត្តិខ្លួនយ៉ាងដូចម្តេច តើគេបង្កើតព្រះរាជារបៀបណា ហើយ (ព្រះអង្គអាចសម្រេច) ជោគជ័យ ខ្ពស់បំផុតបានដោយរបៀបណា។

២- មហាក្សត្រិយ ដែលបានទទួលពិធីរាជាភិសេកស្របតាមតម្រាច្បាប់ ដែលបញ្ញត្តិដោយព្រះវេទ ត្រូវការពារ(ពិភពលោក)ទាំងមូលឱ្យបានត្រឹមត្រូវ។

៣- ដោយហេតុថា សត្វលោកទាំងអស់បើសិនជាគ្មានស្តេច នឹងភ័យខ្លាចចែកផ្លូវទៅកាន់ទិសទាំងអស់ ព្រះជាម្ចាស់បានបង្កើតព្រះមហាក្សត្រិយសម្រាប់ការពារ (សត្វលោក) ទាំងអស់,

៤- (ក្នុងបំណងនេះ) ដោយទទួលបានចុណ្ណភាគអមតៈពីព្រះឥន្ទ្រ ព្រះពាយ ព្រះយមៈ ព្រះអាទិត្យ ព្រះអគ្គី ព្រះវរុណ ព្រះច័ន្ទ និងព្រះភោគទ្រព្យ(កុពេរ)។

៥- ដោយហេតុថាគេបានបង្កើតស្តេច ចេញពីចុណ្ណភាគនៃព្រះអាទិទេពទាំងអស់នោះ ហេតុនេះ ទ្រង់មានពន្លឺរស្មីល្បីល្បាញលើសអស់សត្វទាំងពួង;

៦- ហើយបីដូចព្រះអាទិត្យ ព្រះរាជាមានកែវភ្នែកមុត ចិត្តដាច់ ហើយគ្មាននរណាម្នាក់នៅលើផែនដីអាចសម្លឹងចំភ្នែកទ្រង់ទេ។

៧- ដោយសារអំណាច(អភិធម្មជាតិ)របស់ទ្រង់ព្រះអង្គជាព្រះអគ្គី និងព្រះពាយ ទ្រង់ជាព្រះអាទិត្យ និងព្រះច័ន្ទ ជាព្រះតំណាងយុត្តិធម៌ (ព្រះយមៈ) ព្រះកុពេរ ព្រះវរុណ ទ្រង់ជាកំពូលព្រះឥន្ទ្រ។

៨- សូម្បីស្តេចនៅជាកូនក្មេងក៏គេមិនត្រូវស្អប់ខ្ពើម (ដោយគំនិត)ថា ទ្រង់(គ្រាន់តែ)ជាមនុស្សប៉ុណ្ណោះទេ ព្រោះទ្រង់ជាកំពូលអាទិទេព ដែលមានទម្រង់ជាមនុស្ស។

៩- ភ្លើងឆេះរលាកតែមនុស្សម្នាក់ប៉ុណ្ណោះ បើសិនជាគេធ្វេសប្រហែសទៅប៉ះភ្លើង ភ្លើង (កំហឹង) របស់ព្រះរាជាឆេះគ្រួសារ(ទាំងមូល) រួមទាំងសត្វពាហនៈ និងគំនរទ្រព្យរបស់ទ្រង់។

១០- ដោយបានពិចារណាទាំងស្រុងនូវបំណង អំណាច(ទ្រង់) និងទីកន្លែង ពេលវេលា ផ្ទុយទៅវិញ ទ្រង់ប្រើរូបភាព(ផ្សេងៗ)ជាច្រើន ដើម្បីសម្រេចបានយុត្តិធម៌ទាំងស្រុង។

---

**ជំពូក ៧ លេខ២.** 'ពិធីប្រសិទ្ធី' ជា 'ពិធីបញ្ចូលសមាជិកថ្មី'(មេធ., គោវ., នារ., កុល្ល.) ឬ 'ពិធីបញ្ចូលសមាជិកថ្មី និងពិធីបែបនេះ' (រាឃ.) ឬ 'ពិធីប្រសិទ្ធីរាជាភិសេក'(នន្ទ.)។ មតិចុងក្រោយនេះ ទំនងជាមតិត្រឹមត្រូវ។

**៥.** អ្នកអធិប្បាយទាំងឡាយបកស្រាយ *តេជៈ*ភាពល្បីល្បាញ' ថាជា 'វីរកម្ម ឬតម្លៃ'(វីរិយ)។ ប៉ុន្តែកាព្យបន្ទាប់ បង្ហាញថាយ៉ាងហោចណាស់ ក៏ជាការលេងពាក្យមួយដែរ។

**១០.** យោងតាមអ្នកអធិប្បាយនានា កាព្យនេះមានន័យថាជាការព្រមានចំពោះអ្នកទាំងឡាយដែលមានជំនឿហួសហេតុក្នុងការនិយមព្រះរាជា។

១១- ទ្រង់ ដែលសព្វព្រះទ័យគង់លើផ្កា*បទ្មា* ជាទេពធីតា ជោគរាសី ដែលមានតម្លៃលើជ័យជម្នះ ដែលមានកំហឹងញាំងឱ្យស្លាប់ ត្រូវបានបង្កើតឡើងពីពន្លឺរស្មីនៃ(អាទិទេព)ទាំងអស់។

១២- (មនុស្ស) ដែលមិនចូលចិត្តទ្រង់ដោយសារភាពល្ងង់ខ្លៅហួសហេតុរបស់ខ្លួន ប្រាកដជាវិនាស ព្រោះថាព្រះរាជាសម្រេចព្រះទ័យភ្លាម ដើម្បីបំផ្លាញ(មនុស្ស)បែបនេះ។

១៣- ហេតុនេះ ចូរ(មនុស្ស)កុំបំពានច្បាប់ ដែលព្រះរាជាបញ្ញត្តិស្របតាមចំណូលចិត្តរបស់ទ្រង់ ព្រមទាំង(ព្រះរាជបញ្ជារបស់ទ្រង់) ដែលបង្កឱ្យឈឺចាប់ដល់អ្នកដែលពេញចិត្ត។

១៤- ដើម្បីប្រយោជន៍(របស់ព្រះរាជា) ព្រះជាម្ចាស់បានបង្កើតបុត្ររបស់ព្រះអង្គផ្ទាល់ ទណ្ឌកម្ម អ្នកការពារសត្វលោកទាំងអស់ (វត្តមានរបស់)ច្បាប់ ដែលមានទម្រង់ជាកិត្តិគុណរបស់ព្រហ្ម។

១៥- ដោយសេចក្ដីភ័យខ្លាចទ្រង់ សត្វលោកទាំងអស់ទាំងគ្មានចលនានិងទាំងមានចលនា អាចសប្បាយរីករាយ ហើយមិនអាចគេចពីករណីយកិច្ចរបស់ខ្លួនទេ។

១៦- ដោយបានពិចារណាទាំងស្រុងអំពីកាលនិងទីតាំង(ប្រព្រឹត្តបទល្មើស) ចំណុចខ្លាំង និងពុទ្ធិ (របស់ជនល្មើស)រួចហើយ ចូរទ្រង់ដាក់(ទោស)នោះដោយយុត្តិធម៌ចំពោះមនុស្សដែលប្រព្រឹត្តអំពើអយុត្តិធម៌។

១៧- ការដាក់ទោស (តាមតថភាព) ជាព្រះរាជា (និង)បុរស ដែលជាអ្នកគ្រប់គ្រងកិច្ចការ មេដឹកនាំ ហើយគេហៅថាអ្នកធានាឱ្យមនុស្សទាំងបួនថ្នាក់គោរពច្បាប់។

---

**១១.** '*បទ្មា* ទេពធីតាជោគរាសី' ត្រូវលោកនារ. និងនន្ទ. ប្រែថា 'ដែលកាន់ផ្កាឈូកក្នុងព្រះហត្ថព្រះនាង' ហើយតាមរាឃ. ថា 'ដែលមានផ្កាឈូកជាទីអាស្រ័យ'។ យោងតាមមេធ., គោវ. និងកុល្លូ. គេបន្ថែមវិសេសស័ព្ទ ដើម្បីបញ្ជាក់ពីភាពអស្ចារ្យនៃគំនិត។

**១៣.** មេធ. ផ្ដល់នូវវត្ថុយ៉ាងថា ប្រសិនបើព្រះរាជាបញ្ជាថា ក្នុងពេលរៀបពិធីអាពាហ៍ពិពាហ៍នៅក្នុងផ្ទះរបស់កុង្សីយ៍ ឬពិធីបុណ្យសំខាន់ៗ បុណ្យសាធារណៈ ត្រូវប្រារព្ធធ្វើនៅក្នុងក្រុង ថាមនុស្សម្នាទាំងឡាយត្រូវមានវត្តមានក្នុងឱកាសនោះ ឬថាក្នុងអំឡុងពេលជាច្រើនថ្ងៃនោះ គេមិនត្រូវសម្លាប់សត្វណាមួយទេ គេមិនត្រូវដាក់អន្ទាក់សត្វស្លាបទេ ហើយម្ចាស់បំណុលមិន អាចដាក់គុកកូនបំណុលទេ ពោលគឺអ្នកគ្រប់គ្នាត្រូវតែគោរពព្រះរាជបញ្ជា។ ដូចគ្នានឹងករណីថា ប្រសិនបើព្រះរាជាចេញ បញ្ជាចំពោះមនុស្សដែលមិនចូលចិត្តទ្រង់ថា អ្នកទាំងឡាយកុំរាប់អានពួកគេ ពេលនោះគ្មាននរណាម្នាក់ហ៊ានចូលផ្ទះ ពួកគេទេ។ លោកគោវ., កុល្លូ., និងរាឃ. ធ្វើការបកស្រាយដូចគ្នា ហើយពួកគេ ព្រមទាំងលោកមេធ. បន្ថែមថា វិធានច្បាប់នេះ សំដៅដល់បញ្ហាស្របច្បាប់ពាក់ព័ន្ធនឹងបញ្ហាលោកិយប៉ុណ្ណោះ។ លោកនារ. ហាក់ដូចជាប្រែកាព្យនេះផ្សេងទៅវិញ ក្នុងន័យ ដូចមាននៅក្នុងការបកប្រែរបស់ Sir W. Jones។

**១៤.** យញ្ញ. ជំពូក១ លេខ៣៥៣។

**១៥.** *ភោគាយ កល្បន្តេ*អាចឱ្យពួកគេរីករាយ'(មេធ.,គោវ., នារ., នន្ទ.,រាឃ.)តាមកុល្លូ.ថា'អាចញ៉ាំងឱ្យពួកគេរីករាយ'។ គោវ. ថា *ខេទនាទិភយេន វ្រិក្សាទិស្ថាវាណី អបិ ផលបុស្បាទិទ្វារេណោបភោគាថី សំបក្យន្តេ និយតកាលំ បុស្បាទិទាន វ្យស្តាំ នាតិក្រាមន្តិ*ដោយការភ័យខ្លាចក្នុងការកាត់ដាក់កំណាត់ និងវត្ថុគ្មានចលនា ដូចជាដើមឈើ សប្បាយនឹងផ្លែផ្ការបស់វាជាដើម (ពោលគឺ)វាមិនបំពានច្បាប់ ដែលវាត្រូវចេញផ្កាជាដើម តាមកាលកំណត់' និងសូមមើលកាព្យលេខ២៣ ខាងក្រោមផង។

**១៦.** គោត. ជំពូក១២ លេខ៥១; វស. ជំពូក១៩ លេខ៩; វិ. ជំពូក៣ លេខ៩១; យញ្ញ. ជំពូក១ លេខ៣៦៧។

**១៧.** 'នោះជាបុរស' គឺ 'បើធៀបជាមួយនឹងព្រះអង្គ អ្នកដទៃទាំងអស់ជាស្ត្រី(ដ៏ទន់ខ្សោយ)'(កុល្លូ.)។

១៨- ប្រសិនបើ(ការដាក់ទោស) ត្រូវបានអនុវត្តត្រឹមត្រូវ បន្ទាប់ពីមានការវិនិច្ឆ័យ(សមហេតុផល) វាញ៉ាំងឱ្យមនុស្សទាំងអស់សប្បាយចិត្ត ប៉ុន្តែបើការដាក់ទោសដោយគ្មានការវិនិច្ឆ័យ វានឹងធ្វើឱ្យវិនាសអ្វីៗទាំងអស់។

១៩- ប្រសិនបើព្រះរាជមិនបានដាក់ទោសដោយគ្មានការនឿយហត់ ចំពោះអ្នកដែលគួរទទួលទោស នោះអ្នកខ្លាំងនឹងជិះជាន់អ្នកទន់ខ្សោយ បីដូចជាត្រីនៅលើមុខកាំបិត;

២០- សត្វក្អែកនឹងស៊ីនំបូជាយញ្ញ ហើយឆ្កែនឹងលិឍអាហារបូជាយញ្ញ ហើយសិទ្ធិជាម្ចាស់មិននៅជាមួយនរណាមួយទេ វណ្ណៈថ្នាក់ក្រោមនឹង(ដណ្ដើមយកទីតាំងរបស់)វណ្ណៈថ្នាក់ខ្ពស់។

២១- ពិភពលោកទាំងមូលត្រូវរក្សាភាពរៀបរយ ដោយការដាក់ទោស ព្រោះថាមនុស្សដែលគ្មានទោសគឺពិបាករកបានណាស់ ហើយដោយការភ័យនឹងការដាក់ទោស ពិភពលោកទាំងមូលទទួលបានសេចក្ដីរីករាយ(តាមសភាពពិតរបស់វា)។

២២- ព្រះអាទិទេព ទានវៈ គន្ធវៈ រាក្សសៈ ទេវតាបក្សី និងទេវតាពស់ ក៏ផ្ដល់ភាពរីករាយ (ដោយសារទេវតាទាំងនេះ)ប៉ុណ្ណោះ ប្រសិនបើពួកគេមានការ(ភ័យខ្លាច)នឹងការដាក់ទោស។

២៣- វណ្ណៈទាំងអស់នឹងត្រូវរលាយ (ដោយសារការឡូកឡំគ្នា) របាំងទាំងអស់នឹងត្រូវរលាយដោយភាពច្របូកច្របល់ ហើយមនុស្សទាំងអស់នឹងប្រឆាំងគ្នា(ទៅវិញទៅមក) ដោយសារកំហុសក្នុងការដាក់ទោស។

២៤- ប៉ុន្តែទីណាមានការដាក់ទោសដោយភ្នែកខ្មៅលាយក្រហម ដែលកម្ចាត់ជនប្រព្រឹត្តអំពើបាប ទីនោះប្រជារាស្ត្របានសុខគ្មានការរំខាន ព្រោះព្រះរាជាដែលដាក់ទោសអំពើបាប មានព្រះតម្រិះត្រឹមត្រូវ។

២៥- ប្រជារាស្ត្រប្រកាសថា ព្រះរាជា ជាអ្នកអនុវត្តការដាក់ទោសដោយយុត្តិធម៌ ជាអ្នកមានសច្ចធម៌ ជាអ្នកមានការវិនិច្ឆ័យត្រឹមត្រូវ ជាអ្នកមានគតិបណ្ឌិត និងជាអ្នកដែលស្គាល់នូវ(តម្លៃ)គុណធម៌ សេចក្ដីរីករាយ និងទ្រព្យ។

២៦- ព្រះរាជា ដែលដាក់(ទោស)បានត្រឹមត្រូវ បានចម្រើនដោយ(មធ្យោបាយបង្កើតសុខ)បីយ៉ាង ប៉ុន្តែ ព្រះរាជាដែលសម្បូរកាមតម្រេក លំអៀង និងបោកប្រាស នឹងត្រូវវិនាសដោយសារការដាក់ទោស(ដ៏អយុត្តិធម៌របស់ទ្រង់)។

---

**១៩.** យញ្ញ. ជំពូក១ លេខ៣៥៥។

**២៣.** អ្នកអធិប្បាយស្រង់សេចក្ដីបរិយាយនៃកាព្យ ពីគម្ពីរយគុរ-វេទ 'ដោយសេចក្ដីភ័យខ្លាច ភ្លើងផ្ដល់នូវកម្ដៅ ដោយសេចក្ដីភ័យខ្លាច ព្រះអាទិត្យបញ្ចេញរស្មីដោយសេចក្ដីភ័យខ្លាចធ្វើឱ្យមានវដ្តរបស់ព្រះឥន្ទ្រ ព្រះពាយនិងសេចក្ដីស្លាប់ ជាទីប្រាំ'។

**២៥.** វិ. ជំពូក៣ លេខ៩៦។

**២៦.** គោត. ជំពូក១១ លេខ២។

**២៧.** *វិសមៈ*លំអៀង'(នារ.) ហើយតាមគោវ., កុល្លូ. និងរាឃ. ថា 'ទោសៈ'។

២៧- ការដាក់ទោស (ជា)ពន្លឺដ៏ថ្លៃថ្លាមួយ ហើយពិបាកនឹងដំណើរការដោយមនុស្សដែលមានចិត្តមិនប្រសើរ ពោលគឺវាធ្វើឱ្យអាប់ឱនព្រះរាជាដែលមិនបំពេញករណីយកិច្ចរបស់ទ្រង់ ព្រមទាំងញាតិសន្តានរបស់ទ្រង់ផង។

២៨- បន្ទាប់មកវាធ្វើឱ្យក្ដៅក្រហាយដល់ព្រះរាជវាំងទ្រង់ ដែនដីទ្រង់ ពិភពលោកទាំងមូល ព្រមទាំងសត្វមានជីវិតនិងគ្មានជីវិត បីដូចបណ្ឌិតនិងទេវតា ដែល(មិនអាច)ឡើងឋានសួគ៌បាន។

២៩- អ្នកដែលគ្មានជំនួយការ មនុស្សល្ងីល្ងើ មនុស្សល្មោភ មនុស្សដែលមានចិត្តមិនប្រសើរ និងមនុស្សដែលញៀននឹងកាមតម្រេក មិនអាចអនុវត្ត(ការដាក់ទោស)បានដោយត្រឹមត្រូវនោះទេ។

៣០- គឺមនុស្សដែលមានចិត្តបរិសុទ្ធ(និង)ស្មោះត្រង់នឹងពាក្យសន្យារបស់ខ្លួន ដែលអនុវត្តតាមគោលការណ៍ (ច្បាប់ពិសិដ្ឋ) ដែលមានជំនួយការល្អ និងមានគតិបណ្ឌិត ទើបធ្វើការដាក់ទោស បានដោយយុត្តិធម៌។

៣១- ចូរអ្នកដំណើរការការងាររបស់ខ្លួនដោយយុត្តិធម៌ ដាក់ទណ្ឌកម្មតឹងរ៉ឹងដល់សត្រូវរបស់ខ្លួន ធ្វើល្អចំពោះមិត្តសំឡាញ់ខ្លួនដោយគ្មានចិត្តវៀចវេរ ហើយមានចិត្តអនុគ្រោះចំពោះព្រាហ្មណ៍។

៣២- កេរ្តិ៍ឈ្មោះរបស់ព្រះរាជាដែលប្រព្រឹត្តដូច្នេះ សូម្បីបើទ្រង់រស់នៅដោយសារកម្លាំងអ្នកដទៃក៏ដោយ ក៏រីកសុះសាយទូទាំងពិភពលោក បីដូច ដំណក់ប្រេងនៅលើទឹក។

៣៣- ប៉ុន្តែកេរ្តិ៍ឈ្មោះរបស់ព្រះរាជាដែលប្រព្រឹត្តផ្ទុយពីនេះ និងដែលមិនបានឈ្នះខ្លួនឯង នឹងអាប់ឱនក្នុងចំណោមមនុស្ស បីដូចការទម្លាក់ប៊ឺសុទ្ធចូលក្នុងទឹក។

៣៤- ព្រះរាជាត្រូវបានបង្កើតឡើង(ដើម្បីធ្វើជា)អ្នកការពារវណ្ណៈ និងសណ្ដាប់ធ្នាប់ ដែលទាំងអស់គ្នាត្រូវបំពេញករណីយកិច្ចជាច្រើនរបស់ខ្លួន ស្របតាមឋានៈខ្លួន។

៣៥- អ្វីក៏ដោយដែលព្រះរាជា និងមន្ត្រីរបស់ទ្រង់ធ្វើ គឺដើម្បីការពារប្រជារាស្ត្ររបស់ទ្រង់ ដែលខ្ញុំនឹងថ្លែងប្រាប់អ្នកទាំងឡាយទាំងស្រុង តាមលំដាប់លំដោយ។

៣៦- បន្ទាប់ពីតើននាព្រឹកព្រលឹមអុល ចូរព្រះរាជាគោរពព្រាហ្មណ៍ ដែលចេះវិទ្យាសាស្ត្រពិសិដ្ឋបីផ្នែក និងចេះដឹង(ការងារគ្រប់គ្រងរដ្ឋ) និងប្រតិបត្តិតាមឱវាទរបស់ពួកគេ។

៣៧- រាល់ថ្ងៃ ចូរទ្រង់គោរពចាស់ព្រឹទ្ធាចារ្យព្រាហ្មណ៍ ដែលចេះព្រះវេទ និងមានចិត្តបរិសុទ្ធ ព្រោះថាព្រះរាជាដែលគោរពចាស់ព្រឹទ្ធាចារ្យជានិច្ច នឹងទទួលការសរសើរ សូម្បីពីពួករាក្សសៈក៏ដោយ។

---

**២៨.** 'ដោយមនុស្សដែលគ្មានចិត្តប្រសើរ' គឺ 'អ្នកដែលមិនបានចេះសាស្ត្រ'(គោវ., កុល្ល.)។

**៣០-៣១.** គោត. ជំពូក១១ លេខ៤; យញ្ញ. ជំពូក១ លេខ៣០៨-៣០៩, ៣៥៤។

**៣១.** ពាក្យ *បរិសុទ្ធ* គឺ 'សំដៅដល់ការមានទ្រព្យសម្បត្តិ' គឺ 'ដែលមិនលោភ'(មេធ., គោវ., កុល្ល., នារ., រាឃ.)។ ពាក្យ *សត្យសំធ* 'ស្មោះត្រង់នឹងពាក្យសន្យារបស់ខ្លួន'(គោវ., កុល្ល, រាឃ.) ហើយតាមលោកមេធ. ថា 'ដែលគិតគូរតែ ពីសច្ចធម៌តែម្យ៉ាង'។

**៣២.** វិ. ជំពូក៣ លេខ៩៦; យញ្ញ. ជំពូក១ លេខ៣៣៣។

**៣៣.** វិ. ជំពូក៣ លេខ៩៧។

**៣៧-៣៨.** វិ. ជំពូក៣ លេខ៧៦-៧៧។

៣៨- សូម្បីបើអ្នកជាមនុស្សសុភាពរាបសាហើយក៏ដោយ ចូរអ្នករៀនពីភាពរាបសាពីពួកគេជានិច្ច ព្រោះព្រះរាជាដែលសុភាពរាបសា មិនចេះសាបសូន្យទេ។

៣៩- ព្រះរាជាជាច្រើន បានវិនាសទាំងកម្មសិទ្ធិរបស់ខ្លួន ដោយសារកង្វះភាពរាបសា ដោយសារភាពរាបសា សូម្បីឥសីនៅក្នុងព្រៃក៏បានទទួលគ្រប់គ្រងអាណាចក្រ។

៤០- ព្រះរាជា*វេន* បានវិនាសដោយកង្វះភាពរមទម្យ ដូចជាព្រះរាជា*នាហុស, សុទាស,* បុត្រារបស់*មិគវេន, សុមុខ* និង *នេមិ*។

៤១- ប៉ុន្តែដោយសារភាពរមទម្យ*ប្រិថុ* និង*មនុ* បានទទួលអធិបតេយ្យ, *កុពេរ* ទទួលតំណែងឧបរាជ កាន់ឃ្លាំង និងបុត្រារបស់*គាធី*ទទួលឋានៈជាព្រាហ្មណ៍។

៤២- ចូរអ្នកសិក្សា(វិទ្យាសាស្ត្រពិសិដ្ឋ)បី គឺវិទ្យាសាស្ត្របឋមស្តីពីរដ្ឋាភិបាល វិទ្យាសាស្ត្រស្តីពីវិចារវិទ្យានិងចំណេះដឹងអំពីអាត្ម័ន(ដ៏កំពូល) តាមរយៈកាព្យទាំងអស់នៅក្នុងព្រះវេទទាំងបី និងតាមរយៈមនុស្ស (ទ្រឹស្តី)នៃការធ្វើពាណិជ្ជកម្ម និងអាជីពនានា។

៤៣- ទាំងថ្ងៃទាំងយប់ អ្នកត្រូវតែខិតខំហ្វឹកហាត់គ្រប់គ្រងចិត្តវិញ្ញាណខ្លួន ព្រោះមានតែអ្នក (ទេ) ដែលគ្រប់គ្រងចិត្តរបស់ខ្លួនឯងបាន ទើបអាចធ្វើឱ្យអ្នកក្រោមបង្គាប់របស់ខ្លួនស្តាប់ឱវាទ។

៤៤- ចូរអ្នកយកចិត្តទុកដាក់ជៀសវាងអបាយមុខដប់ដែលកើតចេញពីការងប់នឹងការសប្បាយ និងអបាយមុខប្រាំបីដែលកើតចេញពីទោសៈ ហើយ (អបាយមុខទាំងអស់នេះ) មានទីបញ្ចប់ទុក្ខសោក។

៤៥- ព្រោះថា ព្រះរាជាដែលជាប់ជំពាក់នឹងអបាយមុខ ការងប់នឹងការសប្បាយ ខាតបង់ទ្រព្យ និងគុណធម៌របស់ទ្រង់ ប៉ុន្តែ (ព្រះរាជាដែលសម្បូរទៅដោយ) ទោសៈ (បាត់បង់)ដល់អាយុជីវិតទ្រង់ក៏សឹងមាន។

៤៦- ការប្រមាញ់ ការលេងល្បែង ការដេកថ្ងៃ ការចាប់កំហុស ការល្មោភស្រី ការស្រវឹងខ្លួប (ការងប់នឹង)ការច្រៀង ការរាំរែកនឹងតន្ត្រី និងការដើរហើរដោយឥតប្រយោជន៍ ជាអំពើអបាយមុខដប់ដែលកើតចេញពីការងប់នឹងការសប្បាយ។

៤៧- ការនិទានរឿង អំពើហិង្សា អំពើក្បត់ ឥច្ឆា ការបង្ខូចកេរ្តិ៍ ការរិបអូសទ្រព្យសម្បត្តិ(មិនត្រឹមត្រូវ) ការជេរប្រមាថនិងការរំលោភបំពាន ជាប្រភេទនៃ(អំពើអបាយមុខ)ប្រាំបី ដែលបង្កើតឡើងដោយសេចក្តីខឹងក្រោធ។

---

**៤១.** ខ្ញុំអានតាមលោកមេធ., គោវ., នារ., រាឃ. និង K. *សុទៈ បៃគវន កៃវ* ជំនួស *សុទាសោ យវន កៃវ* (កុល្ល.)។ លោកនន្ទ. ប្រែ *វៃគវន* ថាជាកំហុសរបស់អ្នកប្រតិបត្តិធម៌ប៉ុណ្ណោះ។ ដូចលោកមេធ.កត់សម្គាល់ថា រឿងព្រេងដែលនិទានពីតម្លៃនានានៅទីនេះ គឺមាននៅក្នុងរឿងមហាភារតៈ។

**៤២.** បុត្ររបស់*គាធី* ពោលគឺ *វិស្វាមិត្រ* សូមមើល Muir អត្ថបទដើមភាសាសំស្ក្រឹត ជំពូក១ ទំព័រ៨៣។

**៤៣.** គោត. ជំពូក១១ លេខ៣; យញ្ញ. ជំពូក១ លេខ៣១០។ នារ. ប្រែ*អាន្វីក្សិកីម កាតមវិទ្យាំ* ក្នុងន័យថា 'និងវិទ្យាសាស្ត្រវិចារវិទ្យា ពោលគឺ វិទ្យា*ន្យាយ, សំខ្យ* ជាដើម ដែលមានប្រយោជន៍សម្រាប់ការរួចរំដោះចុងក្រោយ'។ មេធ. មិនច្បាស់ដែរប្រសិនបើ*អាន្វីក្សិកី* ត្រូវប្រែតាមន័យរបស់វា ប៉ុន្តែស្នើឱ្យសិក្សា 'វិទ្យាសាស្ត្រវិចារវិទ្យា ដែលមានប្រយោជន៍សម្រាប់អ្នក'។

**៤៥-៤៨.** វិ. ជំពូក៣ លេខ៥០-៥១។

៤៨- ពោលគឺសេចក្តីលោភ ដែលបណ្ឌិតទាំងអស់ប្រកាសថាជាឫសគល់នៃអបាយមុខទាំងពីរប្រភេទ ចូរព្រះអង្គយកព្រះទ័យទុកដាក់គ្រប់គ្រងឱ្យបាន អបាយមុខទាំងពីរកើតឡើងដោយហេតុនោះ។

៤៩- ការសេពសុរា ល្បែងអាប៉ោង ស្រី និងបរបាញ់ អបាយមុខទាំងបួន(ដែលបានរៀបរាប់ឈ្មោះ)ជាបន្តបន្ទាប់ ទ្រង់ត្រូវតែដឹងថាជាទោសដ៏គ្រោះថ្នាក់បំផុតដែលកើតពីការងប់នឹងសេចក្តីសប្បាយ។

៥០- ការបង្ករបួសស្នាមរូបកាយ ការជេរប្រមាថ និងការរិបអូសទ្រព្យសម្បត្តិគេ អំពើទាំងបីនេះទ្រង់ត្រូវដឹងថាជាទោសដ៏គ្រោះថ្នាក់បំផុត គឺកើតឡើងដោយសារសេចក្តីក្រោធ។

៥១- (ព្រះរាជា)ដែលគ្រប់គ្រងខ្លួនបានល្អ គួរតែដឹងថា ក្នុងអបាយមុខទាំងប្រាំពីរប្រភេទ ដែលអាចកើតមាននៅគ្រប់កន្លែង អបាយមុខនីមួយៗដែលបានរៀបរាប់ខាងដើម ជាការគួរខ្លាចជាង (អបាយមុខដែលបានរៀបរាប់ក្រោយៗ)។

៥២- (តាមការប្រៀបធៀប)រវាងអបាយមុខនិងសេចក្ដីស្លាប់ អបាយមុខត្រូវចាត់ទុកថាមានទោសធ្ងន់ជាង ហើយអ្នកងប់នឹងអបាយមុខនឹងធ្លាក់(នរក)ថ្នាក់ក្រោមបំផុត អ្នកដែលស្លាប់ដោយ មិនជំពាក់នឹងអបាយមុខ នឹងឡើងឋានសួគ៌។

៥៣- ចូរទ្រង់តែងតាំងកុងស៊ីយ៍ប្រាំពីរឬប្រាំបី ដែលបុព្វបុរសពួកគេធ្លាប់ជារាជការ ដែលចេះកាព្យ វិទ្យាសាស្ត្រ ជាវីរជនដែលមានជំនាញក្នុងការប្រើប្រាស់អាវុធ និងជាប់សែស្រឡាយ(អភិជន) និងដែលធ្លាប់មានពិសោធន៍។

៥៤- សូម្បីកិច្ចការមួយដ៏ងាយស្រួល(ពេលខ្លះ) ពិបាកនឹងសម្រេចបានដោយមនុស្សម្នាក់ ចុះសម្រាប់ព្រះរាជាម្នាក់នឹងជួប (ការលំបាកខ្លាំងយ៉ាងណាទៅ) ជាពិសេស (បើទ្រង់) គ្មានជំនួយការ (ដើម្បីគ្រប់គ្រង)អាណាចក្រដែលផ្ដល់នូវចំណូលយ៉ាងច្រើន។

៥៥- ចូរទ្រង់ពិគ្រោះជាមួយពួកគេរាល់ថ្ងៃអំពី(ធុរកិច្ច)ធម្មតាដែលពាក់ព័ន្ធនឹងសន្តិភាព និងសង្គ្រាម (បញ្ហាសំខាន់បួនគឺ)*ស្ថាន:*, ចំណូល, (វិធី)ការពារខ្លួន និងអាណាចក្ររបស់ទ្រង់ និងឧទ្ទិសផលចំណេញរបស់ទ្រង់ (ដោយការបរិច្ចាគដោយក្ដីស្រឡាញ់)។

---

**៤៩.** 'សេចក្ដីលោភ (លោភៈ) ជាឫសគល់នៃ(អបាយមុខ)ទាំងអស់ ព្រោះ(ព្រះរាជា)ធ្វើសកម្មភាពក្នុងករណីខ្លះ(ក្នុងចំណោមសកម្មភាពទាំងនេះ) ដោយការចង់បានថវិកា និងសកម្មភាពផ្សេងទៀតដោយសេចក្ដីលោភនឹងតម្រេក'(គោវ.)។

**៥២.** មេធ., នន្ទ. និង K. អាន *អាត្មន:* ជំនួសពាក្យ *អាត្មវ័* ហើយក្នុងករណីនោះ ការប្រែគឺ 'ចូរទ្រង់ដឹងថា នៅក្នុងអំពើអបាយមុខ...ដូចបានរៀបរាប់ឈ្មោះខាងដើម មានទោសធ្ងន់សម្រាប់ទ្រង់ (ជាង...)'។

**៥៤.** វិ. ជំពូក៣ លេខ៧១; យញ្ញ. ជំពូក១ លេខ៣១១។ ពាក្យ *លព្ធលក្សាន* 'ដែលមានជំនាញក្នុងការប្រើអាវុធ'(កុល្លូ., នារ.) ហើយតាមមេធ., គោវ., នន្ទ. និងរាឃ. ថា 'ដែលមិនខកខានបំពេញកិច្ចការរបស់ទ្រង់'។ ពាក្យ *បរីក្សិតាន* (មេធ., នារ.) ថា 'ដែលត្រូវបានពិសោធ' ពោលគឺ ដោយការបញ្ចុះបញ្ចូលដោយវិធីផ្សេងៗ(មេធ.) ឬ 'បើពួកគេមិនពុករលួយ(នារ.)' ឬ'ដែលមានអ្នកស៊ើបការណ៍តាមដានរួចហើយ'(គោវ.) ឬ 'ដែលមានស្វាមីភ័ក្តិ ដែលទាក់ទងរូប ព្រះអាទិទេព ជាដើម' (កុល្លូ., រាឃ.)។ នន្ទ. អាន *បរីក្សកាន* 'ដែលចេះដឹង(កិច្ចការរដ្ឋ)'។

**៥៥.** ការអានត្រឹមត្រូវ គឺ*កិមុ* 'លំបាកច្រើនប៉ុណ្ណាទៅ'(មេធ., គោវ. សូមមើលគម្ពីរមនុ, នារ., នន្ទ., រាឃ.,K.) ជំនួសពាក្យ *កឹ តុ* 'ប៉ុន្តែ' នៅក្នុងអត្ថបទបោះពុម្ព។

**៥៦.** យញ្ញ. ជំពូក១ លេខ៣១១ ពាក្យ *ស្ថាន:* តាមលោកគោវ., កុល្លូ., នារ., រាឃ. ថា 'ការងារយោធា ឃ្លាំងប្រាក់ ទីក្រុង

៥៦- (ទីមួយ)ដោយបានដឹងច្បាស់ទស្សនៈយោបល់របស់(កុងស៊ីយ៍)នីមួយៗ និង(បន្ទាប់មកទស្សនៈរួម)របស់ពួកគេទាំងអស់ ចូរទ្រង់ធ្វើអ្វីដែលមានប្រយោជន៍(បំផុត)សម្រាប់កិច្ចការរបស់ទ្រង់។

៥៧- ប៉ុន្តែដោយមានភាពខុសគ្នាខ្លាំងក្នុងចំណោមពួកគេទាំងអស់ ចូរព្រះរាជាពិគ្រោះយោបល់ជាមួយព្រាហ្មណ៍ ដែលមានចំណេះដឹងអំពីកិច្ចការសំខាន់ៗបំផុត ទាក់ទងនឹងវិធានការប្រាំមួយនៅក្នុងព្រះរាជគោលនយោបាយ។

៥៨- ចូរទ្រង់មានទំនុកចិត្តទាំងស្រុងប្រគល់កិច្ចការទាំងអស់ដល់(មន្ត្រី)នោះជានិច្ច ហើយដោយបានធ្វើការសម្រេចព្រះទ័យជាមួយមន្ត្រីនោះ បន្ទាប់មកចូរទ្រង់ចាប់ផ្តើមចាត់វិធានការ។

៥៩- ទ្រង់ក៏ត្រូវតែងតាំងមន្ត្រីផ្សេង មនុស្សដែលមានសុចរិត (ដែលមាន)គតិបណ្ឌិត ចិត្តរឹងប៉ឹង មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រមូលថវិកា និងត្រូវបានពិសោធន៍មើលដោយត្រឹមត្រូវ។

៦០- ការបំពេញព្រះរាជកិច្ចរបស់ទ្រង់ដ៏ត្រឹមត្រូវតម្រូវឱ្យមានមនុស្សដ៏ច្រើនដូចគ្នា ពោលគឺមនុស្សជាច្រើន ដែលមានជំនាញ និងបញ្ញាវាងវៃ គ្មានការខ្ជិលច្រអូស ចូរទ្រង់តែងតាំងពួកគេចុះ។

៦១- ក្នុងចំណោមពួកគេ ទ្រង់ប្រើអ្នកក្លាហាន មានជំនាញ ត្រកូលខ្ពស់ និងមានសេចក្តីស្មោះត្រង់ ឱ្យធ្វើ(ក្នុងការិយាល័យប្រមូល)ចំណូល (តួយ៉ាង)ក្នុងការងាររ៉ែ ផលិតកម្ម និងការងារកាន់ឃ្លាំង (ប៉ុន្តែ)ជនអៀនប្រៀន ប្រើឱ្យធ្វើការក្នុងព្រះរាជវាំងរបស់ទ្រង់។

៦២- ចូរទ្រង់តែងតាំងព្រះអគ្គរាជទូតដែលចេះតែងកាព្យគ្រប់វិទ្យាសាស្ត្រ ដែលវាងវៃយល់ដឹងពីពាក្យតម្រុយ ទឹកមុខ និងកាយវិការ ដែលជាមនុស្សស្មោះត្រង់ មានជំនាញ និងជាគ្រួសារអភិជន។

៦៣- អគ្គរាជទូត(បែបនេះ) ត្រូវបានទទួលទំនុកចិត្តពីព្រះរាជា(ដែល)មានព្រះទ័យស្មោះសរ ទៀងត្រង់ ប៉ិនប្រសប់ មានការចងចាំល្អ ដែលស្គាល់កាលនិងពេលដ៏គួរ(ដែលត្រូវចាត់វិធានការ) ដែលសង្ហារមានវោហារកោសល្យ និងគ្មានការភ័យខ្លាច។

៦៤- កងទ័ពពឹងផ្អែកលើពលទាហាន(ប្រចាំការ)ការគ្រប់គ្រង(អាណាប្រជារាស្ត្រ)ត្រឹមត្រូវ អាស្រ័យលើកងទ័ព រតនាគារនិងការគ្រប់គ្រងអាណាចក្រអាស្រ័យលើព្រះរាជា ហើយសន្តិភាពនិង(សង្គ្រាម)ពាក្យផ្ទុយនឹងសន្តិភាព អាស្រ័យលើអគ្គរាជទូត។

---

និងអាណាចក្រ' ហើយតាមលោកមេធ. ក៏ប្រែដូច្នេះ ឬថា 'ការបាត់បង់អាណាចក្ររបស់ទ្រង់' និងតាមលោកនន្ទ. គឺ 'ការបញ្ឈប់'(អាសនៈ)។

**៥៨.** យញ្ញ. ជំពូក១ លេខ៣១១។

**៦០.** នារ. សរសេរ *កុលោទ្គតាន* 'ដែលជាគ្រួសារអភិជន' ឯសំណៅផ្សេងសរសេរ *អវស្ថិតាន*មានចិត្តរឹងប៉ឹង'។

**៦២.** វិ. ជំពូក៣ លេខ១៨, ២១។ មេធ. ប្រែ *ករម័ន្ត*តាមន័យត្រង់ថា 'ការគ្រប់គ្រង' សំដៅដល់ 'រោងចក្រស្ត កន្លែងបិតស្រា ជាដើម' ហើយគោវ. និងកុល្ល. បន្ថែម 'ឃ្លាំងស្តុកគ្រាប់ធញ្ញជាតិ'។ លោកនារ. បកស្រាយពាក្យនេះ ថា 'កន្លែងផលិតគ្រឿងសម្ពាង និងអាវុធជាដើម'។ យ៉ាងណាមិញ គេមិនអាចមិននិយាយថា ពាក្យសមាស *អាការករមាន្តេ* អាចមានន័យថា 'សម្រាប់ការគ្រប់គ្រងរ៉ែ និងការផលិត'។ *អាការ* ជាញឹកញាប់មានន័យពីរ។

**៦៤.** *អនុរក្តះ* 'ព្រះទ័យស្មោះសរ'(មេធ., គោវ., រាឃ.) ហើយតាមកុល្ល. ថា 'ដែលមហាជនស្រឡាញ់រាប់អាន'។

៦៥- ព្រោះអគ្គរាជទូតតែងឯងអាចចងសម្ព័ន្ធមេត្រី(របស់ព្រះរាជា) និងអាចបំបែកសម្ព័ន្ធមេត្រីបាន។ អគ្គរាជទូត អាចធ្វើការងារ ដែលបំបែក ឬមិនបំបែក(ព្រះរាជា)បាន។

៦៦- ដោយសារកិច្ចការនេះ ចូរ(អគ្គរាជទូត)ថ្លឹងថ្លែងការបញ្ចេញទឹកមុខ កាយវិការ និងសកម្មភាពរបស់ (មហាក្សត្រិយបរទេស) តាមរយៈកាយវិការ និងសកម្មភាពរបស់(ទីប្រឹក្សាសម្ងាត់ទ្រង់) និង(ស្វែងរក)ផែនការរបស់ទ្រង់ ក្នុងចំណោមអ្នកបម្រើទ្រង់។

៦៧- ដោយបានដឹងច្បាស់ (ពីអគ្គរាជទូតទ្រង់) អំពីផែនការរបស់ស្តេចបរទេស ចូរ(ព្រះរាជា) ចាត់វិធានការបង្ការ ដែលមិនផ្តល់ផលអាក្រក់ដល់ខ្លួនទ្រង់។

៦៨- ចូរទ្រង់ស្នាក់អាស្រ័យនៅលើដែនដីដែលនៅកណ្តាលវាល និងមានអាកាសធាតុស្ងួត ដែលសម្បូរ ធញ្ញជាតិ ដែលមានពួកអារ្យ័នស្នាក់នៅច្រើន គ្មានជំងឺឆ្លង (ឬគ្មានរោគរាតត្បាត) និងជាកន្លែង ដ៏គួរឱ្យរស់នៅ ដែលមានរដ្ឋចំណុះស្តាប់បង្គាប់ ហើយជាកន្លែងដែលអាណាប្រជារាស្ត្ររបស់ទ្រង់ ងាយនឹងប្រកបរបរចិញ្ចឹមជីវិត។

៦៩- ចូរទ្រង់កសាងទីក្រុង(នៅទីនោះ) ដោយកសាងបន្ទាយដើម្បីសុវត្ថិភាពទ្រង់ ដែលការពារដោយវាលខ្សាច់ ឬបន្ទាយ ដែលសង់ពី(ថ្មនិង)ដី ឬបន្ទាយដែលព័ទ្ធដោយទឹក ឬដើមឈើ ឬបន្ទាយ (ដែលជាជុំរុំកងទ័ពប្រដាប់អាវុធ) ឬបន្ទាយភ្នំ។

៧០- ចូរទ្រង់ប្រឹងប្រែគ្រប់បែបយ៉ាងដើម្បីរក្សាបន្ទាយភ្នំ ព្រោះក្នុងចំណោមបន្ទាយទាំងអស់នោះ(ដូចបានរៀបរាប់) បន្ទាយភ្នំមានលក្ខណៈពិសេសច្រើន។

៧១- បន្ទាយបីប្រភេទដំបូង ជាតំបន់អាស្រ័យនៅរបស់សត្វសាហាវ សត្វព្រៃដែលរស់នៅក្នុងរូង និងសត្វទឹក ហើយបន្ទាយបីខាងក្រោយ ជាកន្លែងអាស្រ័យរបស់សត្វស្វា មនុស្ស និងអាទិទេព តាមទីនីមួយៗ។

---

**៦៦.** ជំនួស *កិឡ្វន្តេ យេន វា ន វា* ‵ដែលអាចបំបែក ឬមិនបំបែក(ព្រះរាជា)បាន′(កុល្ល., រាឃ.) តែលោកមេធ., នន្ទ. និង K. សរសេរថា *កិឡ្វន្តេ យេន មានវះ* ហើយលោកគោវ. សរសេរ *កិឡ្វន្តេ យេន ពាន្ធវះ* ‵ដែលបំបែកបំបាក់មនុស្ស ឬសាច់ញាតិបាន′។

**៦៧.** *និគុជឹងគិតកេស្ថិតែ* ‵តាមរយៈកាយវិការ និងសកម្មភាពរបស់(ទីប្រឹក្សា)សម្ងាត់របស់ព្រះរាជានោះ′(កុល្ល., រាឃ.) ហើយតាមមេធ. និងគោវ. ថា ‵ដោយសារកាយវិការនិងអំពើសម្ងាត់ផ្ទាល់របស់ទ្រង់′ ឬអាចថា ‵ខណៈដែលមានការខំទប់កាយវិការនិងទង្វើសំខាន់ៗរបស់ទ្រង់ផ្ទាល់′តែលោកនន្ទ.ថា‵តាមរយៈមនុស្សដែលលាក់កាយវិការនិងទង្វើផ្ទាល់របស់ខ្លួន′។

**៦៨.** មេធ., គោវ., នន្ទ. និងរាឃ. ប្រែកាព្យផ្សេងទៅវិញថា ‵ដោយបានដឹងច្បាប់ពីគ្រោងការណ៍របស់ស្តេចបរទេស (អគ្គរាជទូត)គួរចាត់វិធានការណាដែលមិននាំផលអាក្រក់ដល់ខ្លួនឯងផង (ចៅហ្វាយរបស់ខ្លួនផង)′។

**៦៩.** វិ. ជំពូក៣ លេខ៤-៥; យញ្ញ. ជំពូក១ លេខ៣២០។ ការឱ្យន័យទាំងស្រុងនៃពាក្យ *គាង្គលះ* ‵ដែលនៅកណ្តាលវាល និងអាកាសធាតុស្ងួត′ ហើយអនុលោមតាមកាព្យដែលគោវ., រាឃ. និងកុល្ល. ស្រង់សម្តី គឺ ‵ប្រទេសនោះគេហៅថា *គាង្គលៈ* ដែលមានទឹក និងស្មៅតិច ដែលមានខ្យល់ត្រជាក់ស្រួល កំដៅខ្លាំង ដែលសម្បូរធញ្ញជាតិនានា′។ *អនាវិល* ‵ដែល គ្មានជំងឺរាតត្បាត (ឬបញ្ហាបែបនេះ)′(កុល្ល. និងរាឃ.) ហើយតាមមេធ. ថា ‵ដែលប្រជារាស្ត្រគ្មានជម្លោះនឹងគ្នា′ តែតាម នារ. និង នន្ទ. ថា ‵ដែលគ្មានរឿងអាសោច ដូចជាភាពឡូកឡំនៃវណ្ណៈជាដើម′។

**៧០.** វិ. ជំពូក៣ លេខ៦។

៧២- ព្រោះសត្រូវមិនបង្កអន្តរាយដល់សត្វទាំងអស់នេះ (បើសិនពួកវា)មានបន្ទាយសម្រាប់ការពារខ្លួន សូម្បីបច្ចាមិត្ត (ក៏) មិនអាចបង្កអន្តរាយដល់ព្រះរាជាដែលបានស្នាក់អាស្រ័យក្នុងបន្ទាយរបស់ទ្រង់ដែរ។

៧៣- នាយធ្នូមួយ ដែលនៅក្នុងកំពែង ជាទីតាំងសមរភូមិប្រយុទ្ធសម្រាប់(សត្រូវ)មួយរយនាក់ ហើយនាយធ្នូមួយរយនាក់សម្រាប់សត្រូវមួយម៉ឺននាក់ ហេតុនេះសាស្ត្រៈបានបញ្ញត្តិថា (ព្រះរាជាគួរមាន)បន្ទាយ។

៧៤- ចូរផ្គត់ផ្គង់ដល់(បន្ទាយ)នោះនូវអាវុធ ថវិកា ធញ្ញជាតិ និងសត្វដឹកជញ្ជូន ព្រាហ្មណ៍ សិប្បករ យន្ត សម្ភារៈចាំបាច់ និងទឹក។

៧៥- ចូរទ្រង់ឲ្យគេសង់ព្រះរាជវាំងដ៏ធំនៅចំកណ្ដាលបន្ទាយ ដែលមានការការពារល្អ អាចស្នាក់នៅបានគ្រប់រដូវ ដ៏ត្រចះត្រចង់ (ដោយលាបកំបោរស) មានទឹក និងដើមឈើ។

៧៦- ដោយការតាំងសំណាក់នោះ ចូរទ្រង់រៀបការមហេសីដែលមានវណ្ណៈស្មើគ្នា ដែលមានសញ្ញានក្ខត្តឫក្ស(នៅលើខ្លួនព្រះនាង) និងមានកំណើតក្នុងមហាគ្រួសារ ដែលសម្បូរដោយមន្តស្នេហ៍ និង មានសម្ផស្ស និងលក្ខណៈសម្បត្តិល្អឥតហ្មង។

៧៧- ចូរទ្រង់តែងតាំងបុរោហិតក្នុងវាំងនិងអាចារ្យពិធីការ (ឫត្វិគ) ហើយពួកគេនឹងរៀបចំធ្វើពិធីសាសនាក្នុងវាំងទ្រង់ និងពិធី(យញ្ញ) ដែលតម្រូវឱ្យមានអគ្គីបី។

៧៨- ព្រះរាជានឹងបូជាយញ្ញ(ស្រោត)ផ្សេងៗ ដោយមានការបែងចែកមត៌កតាមសទ្ធាចិត្ត ហើយដើម្បីទទួលបានបុណ្យកុសល ទ្រង់គួរផ្ដល់សេចក្ដីរីករាយ និងទ្រព្យដល់ព្រាហ្មណ៍។

៧៩- ចូរព្រះអង្គជំរុញឱ្យ(មន្ត្រី)មនុស្សស្មោះត្រង់ប្រមូលចំណូលប្រចាំឆ្នាំនៅក្នុងអាណាចក្រទ្រង់ ចូរព្រះអង្គគោរពច្បាប់ពិសិដ្ឋក្នុង (ការទំនាក់ទំនងជាមួយ) ប្រជារាស្ត្រ និងប្រព្រឹត្តដូចជាបិតា រាប់អានចំពោះមនុស្សទាំងអស់។

៨០- ចូរព្រះអង្គតែងតាំងអ្នកគ្រប់គ្រងប៉ិនប្រសប់ សម្រាប់កាន់ការនានា ពួកគេនឹងត្រួតពិនិត្យទង្វើទាំងអស់របស់មនុស្ស ដែលធ្វើកិច្ចការថ្វាយទ្រង់។

---

**៧៥.** ពាក្យ*យន្ត្រៃ* ‹ដោយយន្ត› គឺ ‹ដោយកម្លាំងម៉ាស៊ីនទាញជាដើម›(នារ. ថា*ក្សេប្យាកិះ*) ឬដែលធ្វើពីដែកជាដើម›(រាឃ.)។

**៧៦.** អាប. ជំពូក២ លេខ២៥, ២-៣។ *សវវតុកំ* ‹ដែលអាចអាស្រ័យនៅបានគ្រប់រដូវ›(នារ., នន្ទ.) ហើយតាមមេធ., គោវ. , កុល្ល. និងរាឃ. ថា ‹ដែលមានបន្លែបង្កាគ្រប់រដូវ›។

**៧៨.** គោត. ជំពូក១១ លេខ១២-១៨; វស. ជំពូក១៩ លេខ៣-៦; ពោធ. ជំពូក១ លេខ១៨, ៧-៨; វិ. ជំពូក៣ លេខ៧០; យញ្ញ. ជំពូក១ លេខ៣១២-៣១៣។ មេធ., គោវ., រាឃ. និង K. អានតាមន័យថា *ឫត្វិគះ* ‹អាចារ្យពិធីការ› ចំណែកឯកុល្ល. ម្នាក់ប៉ុណ្ណោះ សរសេរជាឯកវចនៈ។

**៧៩.** អាប. ជំពូក២ លេខ២៦, ១; វិ. ជំពូក៣ លេខ៨១, ៨៤; យញ្ញ. ជំពូក១ លេខ៣១៤។ ‹សេចក្ដីរីករាយ› គឺ ‹កម្រងផ្កា ទឹកអប់ ក្រមួនជាដើម›(មេធ.) ឬ ‹ផ្ទះសម្បែងជាដើម›(គោវ., រាឃ.) ឬ ‹មាស សម្លៀកបំពាក់›(កុល្ល.) ឬ ‹ភរិយា លំនៅ សម្លៀកបំពាក់ជាដើម›(នារ.) ឬ ‹មេគោ និងក្របី›(នន្ទ.)។

**៨០.** យញ្ញ. ជំពូក១ លេខ៣២១។ ‹ចូរទ្រង់គោរពច្បាប់ពិសិដ្ឋក្នុង(ការទាក់ទងជាមួយ)ប្រជារាស្ត្រទ្រង់› គឺ ‹ចូរទ្រង់កុំដំឡើងពន្ធ និងអាករឱ្យលើសពីច្បាប់កំណត់›។

៨១- ចូរព្រះអង្គគោរពព្រាហ្មណ៍ទាំងឡាយ ដែលបានវិលត្រឡប់ពីផ្ទះគ្រូរបស់ពួកគេ(បន្ទាប់ពីការសិក្សាព្រះវេទ) ព្រោះថា (ថវិកាដែលត្រូវផ្ដល់)ឱ្យព្រាហ្មណ៍ ត្រូវបានប្រកាសថាជារតនៈមិនចេះសាបសូន្យសម្រាប់ព្រះរាជា។

៨២- ជារតនៈដែលចោរមិនអាចលួចនិងសត្រូវមិនអានប្លន់បាន ហើយមិនអាចបាត់ ដូច្នេះគំនរកុសលមិនចេះសាបសូន្យ ត្រូវព្រះរាជាសន្សំទុកជាមួយព្រាហ្មណ៍។

៨៣- ការឧទ្ទិសតាមរយៈមាត់របស់ព្រាហ្មណ៍ ដែលមិនធ្វើដោយងាយៗ មិនសាបសូន្យ និងមិនបាត់បង់ គឺថ្លៃថ្លាឧត្តុង្គឧត្តមជាង*អគ្និហោត្រ*។

៨៤- ការបរិច្ចាគចំពោះអ្នកដែលមិនមែនជាព្រាហ្មណ៍ (នឹងបាន)ផលធម្មតា ឯការបរិច្ចាគចំពោះអ្នកដែលទ្រង់ហៅថាព្រាហ្មណ៍ បានផលទ្វេដង ការបរិច្ចាគចំពោះព្រាហ្មណ៍ដែលមានការចេះដឹងច្រើន បានផលរាប់រយពាន់ដង; ការបរិច្ចាគចំពោះអ្នកដែលចេះព្រះវេទ និងអង្គ(វេទបារគ) បានផលរាប់ប្រមាណមិនបាន។

៨៥- ព្រោះយោងតាមលក្ខណៈសម្បត្តិពិសេសរបស់អ្នកទទួលនិងអាស្រ័យលើជំនឿ (របស់អ្នកឱ្យ) ការបរិច្ចាគនឹងហុចផលទោះតិចក្តី ច្រើនក្តី នៅក្នុងជាតិក្រោយ។

៨៦- ព្រះរាជាដែល ក្នុងពេលដែលទ្រង់ការពារប្រជារាស្រ្ត ត្រូវ(បច្ចាមិត្ត)ទន្ទ្រានឈ្លានពាន ទោះបីបច្ចាមិត្តនោះមានកម្លាំងស្មើ ឬលើស ឬខ្សោយជាងក្តី មិនត្រូវចាកចេញពីសមរភូមិទេ ចូរចងចាំករណីយកិច្ចរបស់ក្សត្រិយ។

៨៧- ការមិនដកថយពីសមរភូមិ ដើម្បីការពារប្រជារាស្រ្ត ដើម្បីគោរពព្រាហ្មណ៍ ជាមធ្យោបាយប្រសើរបំផុតសម្រាប់ក្សត្រិយ ដើម្បីជានាសុភមង្គល។

៨៨- ព្រះរាជាទាំងឡាយ ដែលខំរកវិធីសម្លាប់គ្នានៅក្នុងសមរភូមិ តយុទ្ធដោយការព្យាយាមអស់ពីកម្លាំងកាយចិត្ត និងមិនដកថយ នឹងឡើងឋានសួគ៌។

---

**៨៣.** យញ្ញ. ជំពូក១ លេខ៣១៤។

**៨៤.** វស. ជំពូក៣០ លេខ៧; យញ្ញ. ជំពូក១ លេខ៣១៥។ *ន វ្យថតេ* ‵មិនធ្លាក់(ដល់ដី)′(គោវ., នារ.) តែតាមកុល្ល. ថា ‵មិនសាបសូន្យ′។ មេធ. អាន *ក្សរតេ*ធ្លាក់ដល់(ដី)′ ហើយនារ.ចូលចិត្តអំណាននេះជាង។ នន្ទ. ប្រែ *ន វ្យធតេ* (ដូច្នេះ) ថា ‵មិនខូចដោយសក់ ឬសត្វល្អិតដែលធ្លាក់មកលើ′។ រាឃ. ប្រែពាក្យនេះ ដូច ក្រិស្ណបណ្ឌិត នៅក្នុងអត្ថបទរបស់គាត់ស្តីពី វស. ជំពូក៣០ លេខ៧ ក្នុងន័យថា ‵មិនបង្កឲ្យមានការឈឺចាប់′។

**៨៥.** គោត. ជំពូក៥ លេខ២០; វិ. ជំពូក៩៣ លេខ១-៤។ *សមំ ផលំ* ‵ផលធម្មតា′ គឺ‵ច្រើនដូចព្រះវេទបានទូន្មាន′(គោវ., កុល្ល., រាឃ.)។ មេធ. ប្រែពាក្យ *សមំ* ក្នុងន័យ ‵មធ្យម′ ហើយនារ. បកស្រាយថា ‵ផលស្មើនឹងសមានចិត្តស្តែងឡើង′។ ជំនួសពាក្យ *ប្រាធីតេ* ‵ចំពោះព្រាហ្មណ៍ចេះដឹងច្រើន′ មេធ., គោវ., នារ. និង K. អាន *អាចារ្យេ*ចំពោះគ្រូអាចារ្យ′ និងនន្ទ. ថា *ស្រោត្រិយេ*ចំពោះស្រោត្រិយ′។ ជាងនេះទៀត គោវ., K. និងនន្ទ. សរសេរ *សហស្រគុនំ* ឬ *សហស្រំ... ទានំ*បានផលច្រើនពាន់ដង′។

**៨៧-៨៩.** អាប. ជំពូក២ លេខ២៦, ២; គោត. ជំពូក១០ លេខ១៦; ពោធ. ជំពូក១ លេខ១៨, ៩; វិ. ជំពូក៣ លេខ៤៣-៤៥; យញ្ញ. ជំពូក១ លេខ៣២២-៣២៣។

៨៩- នៅពេលទ្រង់តយុទ្ធជាមួយបច្ចាមិត្តក្នុងសមរភូមិ ចូរទ្រង់ប្រយុទ្ធដោយកុំប្រើអាវុធជងឈើ កុំប្រើអាវុធចុងស្រួច អាវុធដែលមានថ្នាំពុល ឬចុងអាវុធដែលមានភ្លើង។

៩០- ចូរទ្រង់កុំប្រយុទ្ធជាមួយអ្នកដែលបានឡើងទីខ្ពស់ ជាមួយមនុស្សគម្រៀវ ជាមួយអ្នកដែលលើកដៃសំពះ(អង្វរករ) ជាមួយអ្នកដែលកំពុងរត់ប្រាសអាយុ ជាមួយអ្នកដែលអង្គុយ និងកុំប្រយុទ្ធជាមួយអ្នកដែលនិយាយថា 'ខ្ញុំចុះចាញ់ហើយ',

៩១- កុំប្រយុទ្ធជាមួយអ្នកដេក, អ្នកដែលបាត់អាវក្រោះ, អ្នកដែលអាក្រាត, អ្នកដែលគ្មានអាវុធ, អ្នកឈរមើលដែលមិនពាក់ព័ន្ធក្នុងការប្រយុទ្ធ និងអ្នកដែលកំពុងប្រយុទ្ធជាមួយ(សត្រូវ)ម្នាក់ទៀត,

៩២- កុំប្រយុទ្ធជាមួយអ្នកដែលខូចអាវុធ, អ្នកដែលរងទុក្ខ (ដោយបាត់បង់អ្នកជាទីស្រឡាញ់), អ្នកដែលត្រូវរបួសធ្ងន់, អ្នកដែលស្លុតក្នុងការភ័យខ្លាច, អ្នកដែលបានរត់ចោលជួរ, (ប៉ុន្តែក្នុងគ្រប់ករណីទាំងអស់ ចូរទ្រង់)ចងចាំករណីយកិច្ច(ជាអ្នកចម្បាំងដ៏មានកិត្តិយស)។

៩៣- ប៉ុន្តែ(ក្សត្រិយ) ដែលត្រូវស្លាប់ក្នុងសមរភូមិ នៅពេលទ្រង់ដកថយដោយការភ័យខ្លាចនឹងទទួលបាបកម្មទាំងអស់ម្ចាស់ទ្រង់ ទោះជាបាបកម្មអ្វីក៏ដោយ,

៩៤- ហើយ (អ្នក) ដែលត្រូវស្លាប់ក្នុងការប្រយុទ្ធ អាចបានទទួលផលគ្រប់យ៉ាងសម្រាប់ជាតិក្រោយគឺផលបុណ្យទាំងអស់ដែលម្ចាស់ខ្លួនមាន។

៩៥- រថចម្បាំង និងសេះ ដំរី ក្លស់ ថវិកា ធញ្ញជាតិ សត្វពាហនៈ ស្ត្រី ទំនិញគ្រប់ប្រភេទ (ដែលអាចលក់ដូរបាន) និងលោហៈធាតុមិនអាចកាត់ថ្លៃបាននានា ជាកម្មសិទ្ធិរបស់អ្នកដែលដណ្តើមបាន (ពីម្ចាស់កម្មសិទ្ធិ)។

៩៦- អត្ថបទព្រះវេទ (ប្រកាស)ថា (ទាហាន)នឹងបង្ហាញរបស់ជ័យភ័ណ្ឌថ្វាយស្តេច ហើយអ្វីដែលមិនអាចយកម្នាក់ឯងបាន ត្រូវព្រះរាជាបែងចែកដល់ទាហានទាំងអស់។

៩៧- (អំពើ)ដូច្នេះត្រូវបានប្រកាសថាគ្មានទោស តាមច្បាប់បុរាណសម្រាប់អ្នកចម្បាំង តាមរយៈច្បាប់នេះ ក្សត្រិយមិនត្រូវរត់ចោលសមរភូមិ នៅពេលប្រយុទ្ធជាមួយសត្រូវ។

---

**៩០.** ពោធ. ជំពូក១ លេខ១៨, ១០។ *កូតៃ*ដែលកប់(ក្នុងឈើ)'(មេធ., គោវ., កុល្ល., នារ., រាឃ.) ហើយតាមនន្ទ. ថា 'ដែលក្បត់'។

**៩១-៩៣.** អាប. ជំពូក២ លេខ១០, ១១; គោត. ជំពូក១០ លេខ១៨; ពោធ. ជំពូក១ លេខ១៨, ១១; យញ្ញ. ជំពូក១ លេខ៣២៥។

**៩១.** *ស្ថលារូឌំ* 'អ្នកដែល(កំពុងប្រយុទ្ធ)បានឡើងទៅកាន់ទីទួល'(នារ.) តាមមេធ., កុល្ល., និងរាឃ.ថា 'អ្នកដែលបានចុះពីលើមកដី' គឺ 'ខណៈដែលអ្នកប្រយុទ្ធកំពុងឈរលើរាជរថរបស់គេ'។

**៩២.** មេធ. សរសេរសំណេរ *ភគ្នំ* 'ដែលត្រូវខូច(អាវុធ?)' ចំពោះពាក្យ *នគ្នំ* 'ដែលអាក្រាត'។

**៩៤-៩៥.** យញ្ញ. ជំពូក១ លេខ៣២៤។

**៩៦-៩៧.** គោត. ជំពូក១០ លេខ២០-២៣។

**៩៧.** យោងតាមអ្នកអធិប្បាយនានា អត្ថបទវេទដែលនិយាយពាក់ព័ន្ធ គឺគម្ពីរ *ឯតរេយ-ព្រាហ្មណ៍* ជំពូក៣ លេខ២១។

៩៨- ចូរទ្រង់ព្យាយាមឱ្យបាននូវអ្វីដែលទ្រង់មិនទាន់ទទួលបាន ហើយអ្វីដែលបានទទួល ចូរទ្រង់រក្សាដោយប្រុងប្រយ័ត្ន។ ចូរទ្រង់ពង្រីកនូវអ្វីដែលទ្រង់មាន និងអ្វីដែលទ្រង់បានបង្កើនច្រើនហើយ ចូរទ្រង់ធ្វើអំណោយដល់អ្នកដែលគួរទទួល។

៩៩- ចូរទ្រង់ដឹងថា នេះគឺជាមធ្យោបាយបួន ដើម្បីជានាបានបំណង(ចង់បានអត្ថិភាព)របស់មនុស្ស ហើយចូរទ្រង់ប្រើប្រាស់មធ្យោបាយទាំងបួនឱ្យត្រឹមត្រូវ ដោយមិនចេះធុញទ្រាន់ឡើយ។

១០០- អ្វីដែលទ្រង់មិនទាន់បានទទួល(នៅឡើយ) ចូរទ្រង់ខំស្វែងរកឱ្យតាមរយៈកងទ័ពរបស់ទ្រង់។ អ្វីដែលទ្រង់បានទទួលហើយ ចូរទ្រង់ការពារដោយយកចិត្តទុកដាក់, អ្វីដែលទ្រង់បានការពារ ចូរទ្រង់ពង្រីក ដោយវិធីផ្សេងៗក្នុងការធ្វើឱ្យវាបានច្រើន ហើយអ្វីដែលទ្រង់បានពង្រីកបានច្រើន ចូរទ្រង់ធ្វើទានដោយសទ្ធាចិត្ត(ដល់អ្នកដែលគួរទទួល)។

១០១- ចូរទ្រង់ត្រៀមខ្លួនប្រយុទ្ធជានិច្ច ត្រូវបង្ហាញភាពក្លាហានរបស់ទ្រង់ជានិច្ច ហើយត្រូវលាក់ការណ៍សម្ងាត់របស់ទ្រង់ឱ្យបានជានិច្ច ហើយចូរទ្រង់ខំរកចំណុចខ្សោយរបស់បច្ចាមិត្តជាប្រចាំ។

១០២- ដោយសារទ្រង់ដែលត្រៀមប្រយុទ្ធជានិច្ច ពិភពលោកទាំងមូលនឹងមានការភ័យខ្លាច ដូច្នេះចូរទ្រង់ញ៉ាំងឱ្យសត្វលោកទាំងស្ថិតនៅក្រោមព្រះចេស្តានៃកងកម្លាំងរបស់ទ្រង់ឱ្យបាន។

១០៣- ចូរទ្រង់ធ្វើឱ្យដូចជាគ្មានការបោកបញ្ឆោត និងដោយគ្មានពុតត្បុត ហើយការពារខ្លួនដោយប្រុងប្រយ័ត្ន ចូរទ្រង់ស្វែងយល់ឱ្យបានពីអំពើក្បត់របស់សត្រូវទ្រង់ជានិច្ច។

១០៤- មិនត្រូវឱ្យសត្រូវរបស់ទ្រង់ដឹងពីចំណុចខ្សោយទ្រង់ទេ តែទ្រង់ត្រូវដឹងពីចំណុចខ្សោយរបស់សត្រូវទ្រង់ ដូចអណ្តើក (លាក់ខ្លួនក្នុងស្នូក) ដូច្នេះសូម្បីទ្រង់ត្រូវការពារសមាជិក (ក្នុងជួររដ្ឋាភិបាលទ្រង់កុំឱ្យមានអំពើក្បត់)ក៏ដោយ ចូរទ្រង់ការពារចំណុចខ្សោយផ្ទាល់របស់ទ្រង់។

១០៥- ចូរទ្រង់រៀបផែនការការងាររបស់ទ្រង់(ដោយចិត្តអត់ធ្មត់)ដូចសត្វក្រសារ, ចូរទ្រង់ពង្រឹងចំណុចខ្លាំងរបស់ទ្រង់ ឧបមាដូចជាសត្វតោ, ចូរទ្រង់ខំដណ្តើម(ចំណីទ្រង់)ឱ្យ ដូចជាឆ្កែចចក, ចូរទ្រង់ពង្រីកបន្ទាយឱ្យធំ ដូចសត្វទន្សាយស្លឹក។

១០៦- ដូចនេះ ពេលទ្រង់កំពុងជាប់ដៃក្នុងចម្បាំង ចូរទ្រង់បង្ក្រាបគូសត្រូវទាំងអស់ដែលទ្រង់អាចរកឃើញ ដោយឧបាយការផ្សះផ្សា និងវិធីផ្សេងៗ(បួនយ៉ាង)។

---

**៩៩.** យញ្ញ. ជំពូក១ លេខ៣១៦; វស. ជំពូក១៦ លេខ៦។

**១០១.** មេធ., គោវ., រាឃ., នន្ទ. និង K. អាននៅខាងចុងកាព្យនេះ ថា *បាត្រេសុ និក្សិបេត* 'ចូរទ្រង់ផ្តល់អំណោយដល់អ្នកទទួលដែលស័ក្តិសម' ហើយលោកកុល្ល. ក៏បានសរសេរដូច្នេះដែរ។

**១០២.** *និត្យំ ឧទ្យតទណ្ឌះ ស្យាត* 'ចូរទ្រង់ត្រៀមប្រយុទ្ធជានិច្ច'(នារ., នន្ទ.) ហើយតាមមេធ., គោវ. និងកុល្ល. ថា 'ចូរទ្រង់ត្រៀមកងទ័ព ឬសមយុទ្ធត្រៀមប្រយុទ្ធជានិច្ច'។

**១០៤.** ខ្ញុំអានតាមគោវ., នារ., នន្ទ., រាឃ. និង K. ថា *សុសំវូតះ* 'ដោយការពារខ្លួនយ៉ាងប្រុងប្រយ័ត្ន'។ មេធ. អាន *អតន្ទ្រិតះ* 'ដោយមិនចេះនឿយហត់'។

**១០៦.** ទីតាំងនៃអនុប្រយោគទីពីរ និងទីបួន តាមលោកមេធ., គោវ., នន្ទ. ថាត្រូវគេប្តូរគ្នា។

១០៧- បើសិនជាមិនអាចបញ្ឈប់សត្រូវដោយឧបាយបីដំបូង ដូច្នេះ ចូរទ្រង់ព្យាយាមដាក់ពួកគេ ក្រោមអំណាចដោយសន្សឹមៗ ដោយការប្រើកម្លាំងលើពួកគេតែម្យ៉ាង។

១០៨- ក្នុងចំណោមឧបាយទាំងបួន ការផ្សះផ្សានិងវិធីផ្សេងៗ អ្នកចេះដឹងតែងតែចាប់ផ្ដើមប្រើវិធីផ្សះផ្សា និង(ការប្រើ)កម្លាំង ដើម្បីវិបុលភាពរបស់អាណាចក្រ។

១០៩- ដោយហេតុថា មនុស្សចង្រៃបង្កើតរឿងចង្រៃ និងបំផ្លាញពោត ដូច្នេះហើយ ចូរព្រះរាជាការពារអាណាចក្ររបស់ទ្រង់ និងកម្ចាត់គូសត្រូវរបស់ទ្រង់។

១១០- ព្រះរាជាដែលជិះជាន់អាណាចក្រ ព្រមទាំងញាតិសន្តានរបស់ទ្រង់ទាំងកម្រោល នឹងមិនយូរទេ នឹងត្រូវគេដកហូតជីវិត និងអាណាចក្ររបស់ទ្រង់។

១១១- ព្រោះថាជីវិតរស់នៅរបស់សត្វលោក ត្រូវវិនាសដោយការធ្វើទារុណកម្មរូបកាយរបស់ពួកគេ ដូចគ្នានេះដែរ ជីវិតព្រះរាជាត្រូវវិនាស ដោយអំពើជិះជាន់របស់ទ្រង់ចំពោះអាណាចក្រខ្លួនឯង។

១១២- ក្នុងការគ្រប់គ្រងអាណាចក្ររបស់ទ្រង់ ចូរទ្រង់រមែងប្រតិបត្តិតម្រាវិធាន(ខាងក្រោម) ព្រោះព្រះរាជាដែលគ្រប់គ្រងអាណាចក្ររបស់ខ្លួនបានល្អ នឹងរុងរឿងដោយងាយ។

១១៣- ចូរទ្រង់ដាក់ទាហានមួយកង ដែលបញ្ជា(ដោយនាយទាហានដ៏គួរឱ្យទុកចិត្ត) នៅកណ្ដាលភូមិពីរ ភូមិបី ភូមិប្រាំ ឬភូមិរាប់រយ ដើម្បីការពារអាណាចក្រ។

១១៤- ចូរទ្រង់តែងតាំងមេភូមិ(នីមួយៗ) ព្រមទាំងអ្នកគ្រប់គ្រងដប់ភូមិ ម្ភៃភូមិ មួយរយភូមិ និងអ្នកគ្រប់គ្រងមួយពាន់ភូមិ។

១១៥- មេភូមិមួយត្រូវរាយការណ៍ផ្ទាល់ដល់មេដប់ភូមិ អំពីឧក្រិដ្ឋកម្មដែលបានកើតមាននៅក្នុងភូមិខ្លួន ហើយអ្នកគ្រប់គ្រងដប់ភូមិ (ត្រូវរាយការណ៍)ជូនអ្នកគ្រប់គ្រងម្ភៃភូមិ។

១១៦- ប៉ុន្តែអ្នកគ្រប់គ្រងម្ភៃភូមិ ត្រូវរាយការណ៍ (បញ្ហា) ទាំងអស់នេះ ជូនអ្នកគ្រប់គ្រងមួយរយភូមិ ហើយអ្នកគ្រប់គ្រងមួយរយភូមិ ត្រូវរាយការណ៍ដល់អ្នកគ្រប់គ្រងមួយពាន់ភូមិ។

១១៧- (របស់)ទាំងឡាយដែលអ្នកភូមិគួរថ្វាយព្រះរាជារាល់ថ្ងៃ មានដូចជាអាហារ ភេសជ្ជៈ និងប្រេង មេភូមិទទួលរបស់ទាំងនោះបាន។

---

**១១៤.** កុល្ល. និយាយថា 'នៅកណ្ដាលភូមិពីរ ភូមិបី ឬភូមិមួយរយ'។ នារ. កត់សម្គាល់ថា ការប្រើពាក្យពហុវចនៈ 'មួយរយ' គឺដើម្បីបង្ហាញចំនួនមិនច្បាស់លាស់។ យ៉ាងណាមិញ មិនអាចមិននិយាយថា នៅចំណុចនេះ ក៏ដូចជាក្នុងអត្ថបទសំស្ក្រឹតបុរាណ *សតានាំ* មានន័យថា 'មួយរយ'។ មេធ. បកស្រាយពាក្យ *សំគ្រហៈ* 'ការការពារ' ថា 'ពលទាហាន' ឬ 'រាជឃ្លាំង'។ គោវ. អះអាងយ៉ាងត្រឹមត្រូវថា ទាហានដែលលើកឡើងនៅទីនេះ គេហៅថា *ស្ថានកៈ* ជា*ថាណា* នៅគណ្ឌាសម័យទំនើប។
**១១៥-១២៤.** អាប. ជំពូក២ លេខ២៦, ៤-៥; វិ. ជំពូក៣ លេខ៧-១៥; យញ្ញ. ជំពូក១ លេខ៣៣៧។
**១១៦.** ការគ្រប់គ្រង តាមលោកមេធ., គោវ., កុល្ល. និងរាឃ គឺសំដៅដល់បទល្មើសដែលអ្នកទទួលខុសត្រូវរាយការណ៍មិនអាចដោះស្រាយបាន។នារ. គិតថាចំណុចនេះសំដៅដល់ការបដិសេធមិនបង់ចំណូលឬមានវិវាទចំពោះបញ្ហាបែបនេះ។
**១១៨.** មេភូមិ ប្រាកដជា *បាដីល* ទំនើប, *បត្តកីល* ឬ *គ្រាមគុត* នៃអក្សរចារឹក និងរបស់ដែលត្រូវថ្វាយទ្រង់ គឺ 'ត្រីសាច់'។ មន្ត្រីដទៃទៀតរាយការណ៍ចំពោះ *នៃប-សូពាស, សូពាស* ឬ *មហាល្កវីស, មាំលតទា* ជាដើម និងចំពោះ*វិសយបតិ, រាស្ត្របតិ, រាគស្ថាននិយ* នៅក្នុងសិលាចារឹកជាដើម។

១១៨- អ្នកគ្រប់គ្រងដប់ (ភូមិ) នឹងទទួលបានដីមួយ*កុលៈ* (ទំហំដីគ្រប់គ្រាន់សម្រាប់មួយគ្រួសារ), អ្នកគ្រប់គ្រងម្ភៃភូមិ បានប្រាំ*កុលៈ*, អ្នកគ្រប់គ្រងមួយរយភូមិ បាន(ចំណូល)មួយភូមិ, អ្នកគ្រប់គ្រង មួយពាន់ភូមិ (បានចំណូល)មួយក្រុង។

១១៩- កិច្ចការរបស់(មន្ត្រី)ទាំងអស់ដែលពាក់ព័ន្ធនឹងការងារភូមិ និងការងារដោយឡែករបស់ខ្លួន គុង្សីយ៍មួយរូបរបស់ព្រះមហាក្សត្រិយ នឹងធ្វើអធិការកិច្ច (អ្នកដែល) ស្មោះត្រង់ និងមិនខ្ជីខ្ជា,

១២០- ហើយនៅតាមក្រុងនីមួយៗ ចូរទ្រង់តែងតាំងអ្នកគ្រប់គ្រងកិច្ចការទូទៅ ដោយតម្លើងឋានៈ ហួសប្រមាណ (បីដូចជា)មួយភពក្នុងចំណោមហ្វូងតារា។

១២១- ចូរ(បុរស)នោះផ្ទុយទៅវិញត្រូវសួរសុខទុក្ខ(មន្ត្រី)ទាំងអស់ដោយផ្ទាល់ជានិច្ច ចូរគាត់ស្ទាបស្ទង់ឥរិយាបថពួកគេនៅក្នុងតំបន់នានា តាមរយៈចារបុរស(ដែលតែងតាំងប្រចាំ)តំបន់មួយៗ។

១២២- ព្រោះរាជការរបស់ព្រះរាជា ដែលត្រូវបានទទួលការតែងតាំងដើម្បីការពារ(ប្រជារាស្ត្រ) ជាទូទៅ គឺជាអ្នករាជការ ដែលរឹបអូសទ្រព្យរបស់អ្នកដទៃ ចូរទ្រង់ការពារប្រជារាស្ត្រប្រឆាំងនឹង(មនុស្ស) បែបនេះ។

១២៣- ចូរព្រះរាជាដកហូតទ្រព្យទាំងអស់របស់មន្ត្រីទាំងឡាយដែលមានចិត្តអាក្រក់ យកលុយពីគូក្តី និងនិរទេសពួកគេចេញពីនគរ។

១២៤- ចំពោះស្ត្រីដែលបម្រើការរាជកិច្ច និងចំពោះរាជបរិពារ ចូរទ្រង់កំណត់ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ ស្របតាមឋានៈ និងទំហំការងាររបស់ពួកគេ។

១២៥- មួយ *បនៈ* គឺជាប្រាក់ឈ្នួល(ប្រចាំថ្ងៃ)ការងារថ្នាក់ទាបបំផុត, ប្រាំមួយសម្រាប់ការងារថ្នាក់ខ្ពស់បំផុត ដូចជាសម្លៀកបំពាក់សម្រាប់រយៈពេលប្រាំមួយខែម្តង និងមួយ*ទោណៈ* នៃគ្រាប់ធញ្ញជាតិរៀងរាល់ខែ។

១២៦- ដោយបានពិចារណាត្រឹមត្រូវ(ពីអត្រានៃ)ការទិញ និងលក់ (ចម្ងាយ) ផ្លូវធ្វើដំណើរ (ចំណាយសម្រាប់)អាហារ និងគ្រឿងទេស តម្លៃជានាទំនិញជាដើម ចូរព្រះរាជាតម្រូវឱ្យឈ្មួញបង់ពន្ធ។

---

**១១៩.** *កុលំ* '(ដីសមល្មមសម្រាប់)មួយគ្រួសារ' គឺជាពាក្យបច្ចេកទេស ដែលមេធ.បកស្រាយដោយពាក្យ *យណ្ត* ដែលមានប្រើ 'នៅក្នុងស្រុកមួយចំនួន'។ គោវ., កុល្ល., នារ. និងរាឃ. អះអាងថា ជា 'ការភ្ជួរ'ពីរដង ពោលគឺត្រូវកសិកម្ម ដោយគោដប់ពីរ ចំណែកឯនន្ទ. ប្រែពាក្យនេះថា 'ចំណែករបស់អ្នកធ្វើស្រែម្នាក់'។

**១២០.** នារ. បកស្រាយ *ប្រិថក្ការយាណិ* កិច្ចការដោយឡែក' ថា 'ជម្លោះរវាងគ្នានឹងគ្នា' ហើយនន្ទ. ថា 'កិច្ចការនានារបស់អ្នកភូមិ'។ *ស្និគ្ធៈ* 'ស្វាមីភ័ក្តិ'(កុល្ល., រាឃ.) ហើយតាមមេធ. ថា 'មិនលំអៀង'។

**១២១.** *គ្រហំ* 'ភព'(កុល្ល., រាឃ.) ឬ 'ភពអង្គារ'(មេធ.) ឬ 'ព្រះអាទិត្យ'(គោវ.) ឬ 'ព្រះច័ន្ទ'(នារ.)។

**១២៦.** 'មួយ*បណ*' សូមមើលជំពូក៨ លេខ១៣៦ខាងក្រោម។ 'មួយ *ទ្រោណ*'គឺ 'បួន *អាឍកៈ*'(មេធ., កុល្ល., រាឃ.) ឬ 'ប្រាំរយដប់ពីរ *បលៈ*'(គោវ.) សូមមើលជំពូក៨ លេខ១៣៥ ខាងក្រោម។ គោវ., កុល្ល., នារ. និងរាឃ. អះអាងថា រាជការថ្នាក់ខ្ពស់បំផុត នឹងទទួលបានគ្រាប់ធញ្ញជាតិ និងសម្លៀកបំពាក់លើសថ្នាក់ទាបបំផុតចំនួនប្រាំមួយដង ហើយពួកគាត់បន្ថែមថា រាជការថ្នាក់កណ្តាល តាមពិតទទួលបានច្រើនជាងអ្នកទាបបំផុតចំនួនបីដង។

**១២៧.** 'អាហារនិងគ្រឿងទេស' គឺ 'អ្វីដែលមនុស្សប្រើប្រាស់ និងឈ្មួញលក់ដូរ'។ យោងតាមកុល្ល. និងនារ. *យោគ* មានន័យថា 'ចំណេញសុទ្ធ' និង*ក្សេម*តម្លៃសម្រាប់ធានាការប្លន់ទំនិញជាដើម'។ តាមមេធ., គោវ. និងរាឃ. ពាក្យផ្សំទាំងមូលសំដៅដល់តម្លៃក្រោយនេះ។

១២៧-បន្ទាប់ពីការពិចារណា (ត្រឹមត្រូវ) ព្រះរាជានឹងកំណត់ពន្ធអាករនៅក្នុងអាណាចក្ររបស់ទ្រង់តាមរបៀបមួយគឺថា ទាំងទ្រង់និងទាំងអ្នកដែលធ្វើកិច្ចការនេះទទួលរង្វាន់(សមស្របរបស់ខ្លួន)

១២៨-ព្រោះថាឈ្លើង កូនគោនិងឃ្មុំ ស៊ីអាហាររបស់ខ្លួនបន្តិចម្តងៗ ដូចគ្នានេះព្រះរាជាត្រូវហូតពន្ធប្រចាំឆ្នាំសមរម្យពីអាណាចក្ររបស់ទ្រង់។

១២៩-ព្រះរាជាអាចហូតមួយភាគហាសិប(តម្លៃបន្ថែមលើ) សត្វពាហនៈ និងមាស និងមួយភាគប៉ែតសិប, ហុកសិប ឬដប់ពីរ ចំពោះកសិផល។

១៣០-ទ្រង់ក៏អាចហូតចំណែកទីប្រាំមួយនៃដើមឈើ សាច់ ទឹកឃ្មុំ ប៊ឺសុទ្ធ គ្រឿងក្រអូបរុក្ខជាតិ (ឱសថ) សារជាតុសម្រាប់បង្កើតរសជាតិអាហារ ផ្កា ឫសឈើ និងផ្លែឈើ,

១៣១-នៃស្លឹកឈើ តិណទេស ស្មៅ (វត្ថុ)ដែលធ្វើពីផ្តៅ ស្បែក ភាជន៍ដី និង(ទំនិញ) ទាំងអស់ដែលធ្វើពីថ្ម។

១៣២- ទោះបីមានការខ្វះខាតខ្លាំងក៏ដោយ ក៏ព្រះរាជាមិនត្រូវយកពន្ធចំពោះស្រោត្រិយ ហើយមិនត្រូវឱ្យស្រោត្រិយដែលអាស្រ័យនៅក្នុងអាណាចក្ររបស់ទ្រង់ ស្លាប់ដោយការស្រេកឃ្លានទេ។

១៣៣- អាណាចក្ររបស់ព្រះរាជាអង្គនោះ ដែលនៅក្រោមអំណាចរបស់ទ្រង់ មានស្រោត្រិយស្រេកឃ្លាន មិនយូរមិនឆាប់នឹងរងនូវគ្រោះទុរ្ភិក្ស។

១៣៤- ដោយមានការចេះដឹងព្រះវេទពិតប្រាកដ និង(ភាពបរិសុទ្ធនៃ)ទង្វើរបស់គេ ព្រះរាជាត្រូវផ្តល់ឱ្យគេនូវមធ្យោបាយចិញ្ចឹមជីវិត ស្របតាមច្បាប់ពិសិដ្ឋ និងការពារគេតាមគ្រប់វិធី បីដូចជាបិតា(ការពារ)បុត្រារបស់ខ្លួនដោយស្របច្បាប់។

១៣៥- អំពើល្អទាំងឡាយ(ដូចជាព្រាហ្មណ៍)ស្ថិតក្រោមការការពាររបស់ព្រះរាជា ដូច្នេះព្រះរាជាមានព្រះជន្មយឺនយូរ បរិបូណ៌ដោយទ្រព្យធន ហើយអាណាចក្ររុងរឿង។

១៣៦- ចូរព្រះរាជាតម្រូវឱ្យអ្នកស្រុកទូទៅនៅក្នុងអាណាចក្ររបស់ទ្រង់ ដែលប្រកបរបរជួញដូរ ត្រូវបង់ចំណាយប្រចាំឆ្នាំខ្លះ ដែលគេហៅថាពន្ធ។

១៣៧- យន្តការី និងសិប្បករ ព្រមទាំងពួកសូទ្រៈដែលចិញ្ចឹមជីវិតដោយកម្លាំងបាយ ទ្រង់អាចឱ្យគេធ្វើការ(ថ្វាយទ្រង់)មួយថ្ងៃក្នុងមួយខែ។

---

**១៣០-១៣២.** អាប. ជំពូក២ លេខ២៦, ៩; គោត. ជំពូក១០ លេខ២៤-២៧; វស. ជំពូក១៩ លេខ២៦-២៧; ពោធ. ជំពូក១ លេខ១៨, ១, ១៣, ១៥; វិ. ជំពូក៣ លេខ២២-២៥, ២៩-៣០។

**១៣២.** មេធ. និងកុល្ល. បន្ថែម ՝ពីផលចំណេញ (យកលើទំនិញដប់ប្រាំពីរមុខដែលបានរៀបរាប់ឈ្មោះ)՛។

**១៣២.** អាប. ជំពូក២ លេខ២៦, ១០; ២៥, ១១; គោត. ជំពូក១០ លេខ៩; វស. ជំពូក១៩ លេខ២៣; វិ. ជំពូក៣ លេខ២៦, ៧៩។

**១៣៥-១៣៦.** យញ្ញ. ជំពូក៣ លេខ៤៤។

**១៣៧.** *ប្រិថក្តនំ*អ្នកស្រុកធម្មតា՛ គឺ ឈ្មួញតូចតាច លក់បន្លែ ស្លឹកឈើជាដើម(កុល្ល., រាឃ.) ឬលក់នំ(គោវ.)។

**១៣៨.** គោត. ជំពូក១០ លេខ៣១; វស. ជំពូក១៩ លេខ២៨; វិ. ជំពូក៣ លេខ៣២។

១៣៨- ចូរទ្រង់កុំធ្វើឱ្យបុព្វបុរសផ្ទាល់របស់ទ្រង់កើតទុក្ខ(ដោយការមិនយកពន្ធ) និងកុំធ្វើឱ្យបុព្វបុរសរបស់(មនុស្ស)រងទុក្ខ ដោយសេចក្ដីលោភហួសហេតុ ព្រោះដោយសារការធ្វើឱ្យបុព្វបុរសរបស់ទ្រង់ផ្ទាល់ (ឬរបស់ពួកគេ)រងទុក្ខ ទ្រង់ធ្វើឱ្យខ្លួនឯង ឬពួកគេរងទុក្ខវេទនា។

១៣៩- ចូរព្រះរាជា បន្ទាប់ពីបានពិចារណារាជកិច្ច(នីមួយៗ)ដោយយកចិត្តទុកដាក់ ត្រូវមានចិត្តដាច់ផងនិងទន់ភ្លន់ផង ព្រោះព្រះរាជាដែលមានចិត្តដាច់ផងនិងទន់ភ្លន់ផង នឹងបានទទួលការគោរពស្រឡាញ់ច្រើន។

១៤០- បើសិនជាទ្រង់នឿយណាយក្នុងការធ្វើអធិការកិច្ចការងាររបស់រាជការ ចូរទ្រង់ប្រទានតំណែង (យមរាជ) ជូននាយកុង្សីយ៍របស់ទ្រង់ (ដែលមាន)ចំណេះដឹងផ្នែកច្បាប់ មានគតិបណ្ឌិត ចេះគ្រប់គ្រងខ្លួនបានល្អ និងស្ថិតក្នុងគ្រួសារ(អភិជន)។

១៤១- ដូចនេះ ដោយបានចាត់ចែងកិច្ចការទាំងអស់នៅក្នុង (រដ្ឋាភិបាល) របស់ទ្រង់ ទ្រង់ត្រូវការពារប្រជារាស្ត្រដោយព្រះទ័យទុកដាក់ និងយ៉ាងខ្ជាប់ខ្ជួន។

១៤២- (ស្ដេច)ណា ដែលបណ្ដោយឱ្យប្រជារាស្ត្ររងគ្រោះដោយចោរឆក់ប្លន់ (ទស្យុ) នៅក្នុងអាណាចក្ររបស់ទ្រង់ ចំណែកឯអាណាប្រជារាស្ត្រស្រែករកជំនួយក្ដែងៗ ហើយទ្រង់និងរាជការទ្រង់ឈរមើល(ដោយស្ងាត់ស្ងៀម) គឺជាស្ដេចសុគត ហើយមិនមែនជា(ស្ដេច)រស់ទេ។

១៤៣-ករណីយកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់ក្សត្រិយ គឺត្រូវការពារអាណាប្រជារាស្ត្រទ្រង់ ព្រោះព្រះរាជាដែលចង់បានកុសលដូចបានរៀបរាប់ ត្រូវបំពេញករណីយកិច្ច(នោះ)។

១៤៤- បន្ទាប់ពីបានតើនពីព្រលឹម ធ្វើពិធីបន្សុទ្ធកាយចិត្តផ្ទាល់ខ្លួន ដោយព្រះទ័យស្ងប់ បូជាព្រះអគ្គីនិងបន្ទាប់ពីគោរពព្រាហ្មណ៍ ទ្រង់នឹងដើរចូលសាលសវនាការ ដែលមានសញ្ញានក្ខប្ញក្ស (សម្រាប់ការប្រថាប់)។

១៤៥- ក្នុងដំណើរយាងចូលកាន់ទីនោះ ទ្រង់បង្កភាពរីករាយដល់នាហ្មឺនសព្វមុខមន្ត្រីទាំងអស់(ដែលចូលគាល់ទ្រង់ ដោយព្រះទ័យករុណាស្វាគមន៍) ហើយបន្ទាប់មកឱ្យពួកគេចេញទៅ ទ្រង់នឹងពិគ្រោះកិច្ចការជាមួយកុង្សីយ៍របស់ទ្រង់។

១៤៦- ក្នុងដំណើរឡើងខ្នងភ្នំ ឬទីធ្លាមួយ (ហើយ)សម្រាក(នៅទីនោះ)ម្នាក់ឯង ឬនៅក្នុងព្រៃតែអង្គឯង ចូរទ្រង់ពិគ្រោះកិច្ចការជាមួយពួកគេដោយមិនចាំបាច់មានពិធីជំជុំទេ។

១៤៧- ព្រះរាជាដែលមិនឱ្យអ្នកដទៃដឹងពីផែនការសម្ងាត់របស់ទ្រង់ទេ (ទោះបី) មានបំណងដូចគ្នាក៏ដោយ (នឹង)សព្វព្រះទ័យរីករាយនឹងផែនដីទាំងមូល ថ្វីបើទ្រង់ខ្សត់ខ្សោយទ្រព្យក្ដី។

១៤៨- ក្នុងពេលពិគ្រោះការណ៍នោះ ចូរទ្រង់កុំឱ្យមានវត្តមានមនុស្សល្ងីល្ងើ មនុស្សគ មនុស្សខ្វាក់ និងមនុស្សថ្លង់ សត្វ បុរសចាស់ជរា ស្ត្រី មនុស្សព្រៃ អ្នកជំងឺ និងមនុស្សពិការអវយវៈ។

១៤៩- (មនុស្ស)គួរឱ្យស្អប់ទាំងអស់នេះ ព្រមទាំងសត្វ និងជាពិសេសស្ត្រី មានល្បិចលាក់ពុតការជំនុំការសម្ងាត់ ក្នុងហេតុផលនេះ ទ្រង់ត្រូវតែប្រយ័ត្នចំពោះពួកគេ។

១៥០- នៅពេលកម្លាំងកាយ និងព្រះទ័យទ្រង់ថយចុះនៅពេលថ្ងៃត្រង់ ឬកណ្ដាលយប់ ចូរទ្រង់ពិគ្រោះយោបល់តែអង្គឯងក៏បាន ឬជាមួយ(កុង្សីយ៍) របស់ទ្រង់ក៏បាន អំពីគុណធម៌ សេចក្ដីរីករាយ និង ទ្រព្យ

១៥១- ក្នុង(ការសម្រួល)សម្រេចបាន(គោលបំណង)ទាំងអស់ ដែលមានការខ្វែងព្រះទ័យគ្នាទៅវិញទៅមក អំពីការទុកដាក់ឲ្យព្រះបុត្រីរៀបអាពាហ៍ពិពាហ៍ និងអំពីការរក្សាព្រះបុត្រាទ្រង់(ឱ្យរួចផុតពីគ្រោះថ្នាក់),

---

**១៤១.** វិ. ជំពូក៣ លេខ៧៣-៧៤; យញ្ញ. ជំពូក២ លេខ១-៣។ មេធ. អាន *សាន្តំ* ʽដែលមានអារម្មណ៍ស្ងប់ស្ងាត់ʼ ចំពោះ *ប្រាជ្ញំ* ʽប្រជ្ញាʼ។

**១៤២-១៤៤.** អាប. ជំពូក២ លេខ១០, ៦; គោត. ជំពូក១០ លេខ៧-៨; វស. ជំពូក១៩ លេខ១; ពោធ. ជំពូក១ លេខ ១៨, ១; វិ. ជំពូក៣ លេខ១; យញ្ញ. ជំពូក១ លេខ៣៣៤-៣៣៥។

**១៤៧-១៤៨.** យញ្ញ. ជំពូក១ លេខ៣៤៣។

**១៤៧.** ពាក្យ *និហ្សលោកេ* ʽម្នាក់ឯងដាច់ពីគេʼ(នារ., កុល្ល., រាឃ.) តែតាមមេធ., គោវ. និងនន្ទ. ថា ʽគ្មានស្មៅជាដើមʼ។

**១៤៩.** ʽសត្វʼ គឺ ʽសេក, សាកាកែវ និងសត្វស្លាបចេះនិយាយផ្សេងទៀតʼ(កុល្ល., គោវ., រាឃ., នន្ទ.) ʽព្រោះសត្វប្រភេទនេះ ចេះលាតត្រដាងផែនការសម្ងាត់ʼ(មេធ.)។

១៥២- អំពីការបញ្ជូនអគ្គរាជទូត ការបញ្ចប់ភារកិច្ច (ដែលបានផ្ដើមធ្វើរួចហើយ) អំពីឥរិយាបថរបស់(ស្ត្រី) នៅក្នុងបន្ទប់ស្រីស្នំរបស់ទ្រង់ និងអំពីការធ្វើជាចារបុរសរបស់ទ្រង់។

១៥៣- អំពីរាជកិច្ចទាំងប្រាំបី និងវណ្ណៈទាំងប្រាំ(របស់ចារបុរស) អំពីសុឆន្ទៈ ឬភាពជាសត្រូវ និងការប្រព្រឹត្តរបស់អ្នកជុំវិញ ដែលទ្រង់ត្រូវតែប្រយ័ត្នប្រយែង។

១៥៤- អំពីការប្រព្រឹត្តរបស់ (ព្រះអង្គម្ចាស់) ថ្នាក់កណ្ដាល អំពីអំពើរបស់អ្នកដែលព្យាយាមចង់សោយរាជ្យ អំពីឥរិយាបថរបស់ (ព្រះមហាក្សត្រិយ) អព្យាក្រឹត និងរបស់សត្រូវ ចូរទ្រង់ព្យាយាមព្រះតម្រិះរឿយៗ។

---

**១៥៤.** ʽរាជកិច្ចប្រាំបីʼ តាមលោកមេធ. គឺមាន ʽការផ្សះផ្សា, ការបំបែកបំបាក់, ការប្រើកម្លាំង, ការឱ្យអំណោយʼក៏បាន ឬ ʽការងារកសិកម្ម, ជំនួញ, ការកសាងស្ពាន និងទំនប់ទឹក, ការសង់ឬជួសជុលបន្ទាយ, ការទាក់ដំរី, ការជីករ៉ែ, ការបោះទីតាំងនៅតំបន់រហោស្ថាន, ការកាប់ព្រៃឈើʼ ឬ ʽការប្រមូលចំណូល, ចំណាយ, ការបណ្ដេញបរិវារអាក្រក់, ការហាមឃាត់អំពើអាក្រក់ពាក់ព័ន្ធនឹងវណ្ណៈ និងសណ្ដាប់ធ្នាប់, ការសម្រេចចិត្តបញ្ហាលំបាកនៅក្នុងកិច្ចការផ្ទាល់របស់ខ្លួន, ការវិនិច្ឆ័យករណីផ្លូវច្បាប់, ការដាក់ទោស និងការដាក់ទណ្ឌកម្មជាដើមʼ។ លោកនន្ទ. ផ្ដល់នូវការបកស្រាយទីពីរ ដែលគេនិយាយថាជា*អន្តកៈ* (យមៈ) ការបកស្រាយទីបីរបស់គោវ., កុល្ល., នារ. និងរាឃ. ជាការស្រង់ចេញពី*នីតិសាស្ត្រ* របស់ឧសនៈ។ ʽវណ្ណៈប្រាំ(របស់ចារបុរស)ʼ គឺ ʽការបតិកៈ, អ្នកធម្មយាត្រា ឬជនពាល, តាបសដែលបានបំពានពាក្យសត្យរបស់ខ្លួន, អ្នកធ្វើកសិកម្មក្នុងគ្រាលំបាក, ពាណិជ្ជកររថោកទាប និងធម្មចារីក្លែងក្លាយʼ(មេធ., គោវ., កុល្ល., រាឃ.)។ នារ. និងនន្ទ. បកស្រាយ *បញ្ចវគៈ* ថាʽការប្រមូល(របស់ចាំបាច់សម្រាប់ការធ្វើការងារ)ʼ។ ចំពោះពាក្យʽអ្នកជុំវិញʼសូមមើលកាព្យខាងក្រោម។

**១៥៥-១៥៩.** វិ. ជំពូក៣ លេខ៣៨; យញ្ញ. ជំពូក១ លេខ៣១៤។

**១៥៥.** ʽព្រះអង្គម្ចាស់ថ្នាក់កណ្ដាលʼ ជាអង្គម្ចាស់ដែលមានដែនដីនៅចន្លោះដែនដីរបស់ព្រះរាជា ដែលចង់គ្រប់គ្រងដែនដី

១៥៥- អ្នកស្រុក(បួន)តំបន់នេះ(ប្រក្ធតិ) (និយាយដោយសង្ខេប) បង្កើតបានជាមូលដ្ឋានអ្នកជិតខាង ក្រៅពីនេះអ្នកស្រុកប្រាំបីតំបន់ទៀត ត្រូវគេរាប់(នៅក្នុងគោលការណ៍ គ្រប់គ្រងរដ្ឋ) ដូច្នេះ គេប្រកាសថាជារួមមានដប់ពីរ។

១៥៦- កុង្សីយ៍ អាណាចក្រ បន្ទាយ រតនាគារ និងកងទ័ពជា(សមាសធាតុសំខាន់) ប្រាំទៀត សម្រាប់ធ្វើជាមជ្ឈដ្ឋានជុំវិញ ព្រោះសមាសធាតុទាំងអស់នេះ មានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងសមាសធាតុប្រាំខាងដើម ហេតុនេះមជ្ឈដ្ឋានទាំងមូល (មាន) និយាយដោយសង្ខេប ចិតសិបពីរ (ផ្នែកសំខាន់)។

១៥៧- ចូរ(ព្រះរាជា)ចាត់ទុកអ្នកជិតខាងផ្ទាល់ និងបក្សពួករបស់សត្រូវ(ប្រភេទនេះ) របស់ទ្រង់ជាសត្រូវ ចាត់ទុកអ្នកជិតខាងផ្ទាល់របស់សត្រូវទ្រង់ជាមិត្ត និងចាត់ទុកជាអ្នកអព្យាក្រឹត(ចំពោះព្រះរាជា) ដែលនៅផុតពីអ្នកទាំងពីរនោះ។

១៥៨- ចូរទ្រង់យកឈ្នះលើពួកគេទាំងអស់ដោយឧបាយ(បួនយ៉ាង) ការផ្សះផ្សា និងឧបាយផ្សេងៗ ដោយប្រើឧបាយតែមួយក៏បាន ឬប្រើឧបាយច្រើនរួមគ្នាក៏បាន (ឬ)ដោយប្រើភាពក្លាហាន និងគោលនយោបាយ(តែម្យ៉ាង)ក៏បាន។

១៥៩- ចូរទ្រង់ពិចារណាជា ប្រចាំអំពីវិធានការប្រាំមួយនៅក្នុងព្រះរាជគោលនយោបាយ (គុណៈ ជាដើម) គឺការចងមិត្ត សង្គ្រាម ការធ្វើចលនាទ័ព ការបញ្ឈប់ ការដាក់ពង្រាយកងទ័ព និងការរកមធ្យោបាយការពារ។

១៦០- ដោយបានពិចារណារាជកិច្ច(ក្នុងដៃ)ដោយហ្មត់ចត់រួចហើយ ចូរទ្រង់សុខចិត្តអង្គុយស្ងៀម ឬធ្វើការចល័តទ័ព ការចងមិត្ត ឬសង្គ្រាម ការពង្រាយកម្លាំងរបស់ទ្រង់ ឬស្វែករកការការពារ (នៅពេលមានការចាំបាច់)។

១៦១- ប៉ុន្តែព្រះរាជាត្រូវតែដឹងថា ការចងមិត្ត និងសត្រូវមានពីរប្រភេទ (ដូចគ្នា)ការចល័តទ័ព និងការអង្គុយស្ងៀម មានពីរប្រភេទ និង(ឱកាសពីរប្រភេទ)សម្រាប់ការស្វែងរកការការពារ។

---

ទាំងអស់ និងដែនដីរបស់សត្រូវទ្រង់ ហើយថ្វីបើមិនអាចតតាំងបានទាំងពីរក៏ដោយ ក៏អាចមានគ្រោះថ្នាក់សម្រាប់ពួកគេបើសិនជាពួកគេធ្វើសង្គ្រាមជាមួយគ្នា; សូមមើលកាមន្ទកិ,*នីតិសាស្ត្រ* ជំពូក៨ លេខ១៨ ដែលអ្នកនិពន្ធដកស្រង់សេចក្តី។ 'សត្រូវ' អាចមានបីប្រភេទ 'កើតពីធម្មជាតិ', 'កើតពីមនុស្ស' (គឺអ្នកដែលមានហេតុផលពិសេសសម្រាប់បង្កភាពអមិត្ត) និង 'ដែនដីជិតខាងផ្ទាល់'(សូមមើលកាព្យលេខ១៥៨ខាងក្រោម)។

**១៥៦.** 'អ្នកស្រុកប្រាំបីតំបន់ទៀត' តាម*កាមន្ទកិ* ជំពូក៨ លេខ១៦-១៧ (ក).នៅខាងមុខហួសដែនដីរបស់សត្រូវ ១. មិត្ត ២. មិត្តរបស់សត្រូវ ៣.មិត្តរបស់មិត្ត ៤.មិត្តរបស់មិត្តសត្រូវ, (ខ)នៅខាងក្រោយ គឺ ១.អ្នកដែលវាយប្រហារខាងក្រោយ (បាស្ណិគ្រាហ) ២.អ្នកដែលទប់ស្កាត់អ្នកខាងក្រោយនេះ(អាក្រន្ទ), ៣. និង៤. អ្នកគាំទ្ររបស់អ្នកទាំងពីរនេះ។ អ្នកនិពន្ធទាំងអស់ លើកលែងមេធ. ទំនងជាដកស្រង់*កាមន្ទកិ* បានត្រឹមត្រូវ។ *កាមន្ទកិ* ជំពូក៨ លេខ២៤ បញ្ជាក់ថា លទ្ធិនេះ ស្របតាមផ្នែកសំខាន់នៃប្រព័ន្ធរដ្ឋ ដែលធ្វើឱ្យព្រះរាជាទាំងឡាយចាប់អារម្មណ៍ គឺដូចគ្នានឹង*មាន់ៈ*។

**១៦០-១៦១.** វិ. ជំពូក៣ លេខ៣៩; យញ្ញ. ជំពូក១ លេ៣៤៥-៣៤៦។

១៦២- ការចងមិត្ត ដែលផ្ដល់ប្រយោជន៍ក្នុងពេលបច្ចុប្បន្ន និងពេលអនាគត ទ្រង់ត្រូវតែដឹងអំពីការចងមិត្តពីរប្រភេទ(ជាដើម)ថា ពេលទ្រង់រួមដំណើរជាមួយ(សម្ព័ន្ធមិត្ត)និងឧបសគ្គ (ដែលសម្ព័ន្ធមិត្តបង្កើតឡើងតែឯង)។

១៦៣- សង្គ្រាមត្រូវគេប្រកាសថាមានពីរប្រភេទ(ជាដើម) គឺសង្គ្រាមដែលធ្វើក្នុងរដូវ ឬក្រៅរដូវ ដោយភាគីម្ខាង និងសម្រាប់បំណងផ្ទាល់ខ្លួន និង(សង្គ្រាមដែលធ្វើឡើងដើម្បីសងសឹក)ការខូចខាតចំពោះមិត្ត។

១៦៤- គេនិយាយថា ការចល័តទ័ព(ចូលប្រយុទ្ធ)មានពីរយ៉ាង (គឺការចល័តដែលធ្វើឡើង)ដោយភាគីម្ខាងពេលមានបញ្ហាបន្ទាន់បានកើតឡើងភ្លាមៗ និង(ការចល័តទ័ព)របស់អ្នកដែលចងសម្ព័ន្ធមិត្តជាមួយមិត្ត។

១៦៥- ការអង្គុយស្ងៀម គេនិយាយថាមានពីរប្រភេទ (គឺការអង្គុយក្នុងតំណែង) ដែលភាគីម្ខាងកំពុងទន់ខ្សោយដោយជោគវាសនាអាក្រក់ ឬដោយសារកម្មពីមុន និង (ការនៅស្ងៀម) ស្របតាមប្រយោជន៍របស់មិត្ត។

១៦៦- បើសិនជាទ័ពឈប់ (នៅកន្លែងមួយ) ហើយមេទ័ព(នៅកន្លែងមួយផ្សេង) ដើម្បីសម្រេចគោលបំណងមួយចំនួន អំពើនោះគេហៅ ស្របទៅតាមវិធានការនៃព្រះរាជគោលនយោបាយ ថាការបែងចែកកម្លាំងជាពីរផ្នែក។

១៦៧- ការស្វែងរកជម្រកគេប្រកាសថាមានពីរប្រភេទ (ទីមួយ)ក្នុងបំណងទទួលបានប្រៀប នៅពេលសត្រូវយាយីរំខានខ្លួន (ទីពីរ) ដើម្បីឱ្យគេដឹងថាក្នុងចំណោមគុណធម៌ទាំងឡាយ (មានអ្នកនៅក្រោមអាណាព្យាបាលរបស់ព្រះរាជាដ៏មានអំណាច)។

---

**១៦៣.** មេធ. ធ្វើការបកស្រាយម្យ៉ាងទៀតក្រៅពីការបកស្រាយខាងលើ គឺ 'ព្រះរាជាត្រូវដឹង ការចងមិត្តមានពីរប្រភេទ (ជាដើម)ថា ទីណា(សម្ព័ន្ធមិត្ត)ផ្ដល់នូវគ្រោះថ្នាក់ និងផ្លែផ្កានៃការរួបរួម និងឧបសគ្គ'(យានផលសហិតោ គច្ឆាវះ សមានផលភាគិតយ ភវិស្យតិ)។ នារ. គិតថា គុណស័ព្ទ *តទាត្វាយតិសំយុក្តះ* ក៏សំដៅដល់ករណីពីរផ្សេងគ្នា និងមានន័យថា 'ដែលផ្ដល់ផលភ្លាមៗក៏មាន ឬនៅពេលអនាគតក៏មាន'។ នន្ទ. សម្រេចយកយោបល់ចុងខាងក្រោយ ព្រមទាំងការបកស្រាយទីពីររបស់មេធ. នៅផ្នែកទីមួយនៃកាព្យនេះ។

**១៦៤.** ចំពោះសំនួនពាក្យ 'ក្នុងរដូវ' សូមមើលកាព្យលេខ១៨២ ខាងក្រោម។ មេធ. ប្រែ 'ក្រៅរដូវ'តាមអនុប្រយោគទីពីរ 'និង (ថាសង្គ្រាមដែលធ្វើឡើង)ខុសរដូវ (ដើម្បីសងការខូចខាតចំពោះមិត្ត)'។ លោកក៏ប្រើពាក្យផ្សេង *មិត្រេណាបក្ឫតេ* (ដែលគោវ. សម្រេចយកតាម) តាមការបកស្រាយខាងក្រោម 'និងសង្គ្រាមដែលធ្វើខុសរដូវ បើសិនជាសម្ព័ន្ធមិត្ត បានធ្វើឱ្យសត្រូវចុះខ្សោយ'។ គោវ. យល់ស្របតាមការបកស្រាយក្រោយនេះ លើកលែងតែថា គាត់ប្រែ *អកាលេ* តាមអនុប្រយោគទីមួយ។ អ្នកអធិប្បាយផ្សេងទៀត ធ្វើការបកស្រាយដូចមាននៅក្នុងអត្ថបទបកប្រែ។

**១៦៦.** *បូវក្ឫតេន*ដោយសារផលកម្មពីមុន' គឺ 'ដោយសារអំពើដែលបានប្រព្រឹត្តពីអត្តិភាពមុនៗ ឬដោយសារអំពើធ្វេសប្រហែសពីមុន'(មេធ., គោវ., កុល្ល.)។ នន្ទ. និងរាឃ. ធ្វើការបកស្រាយទីពីរប៉ុណ្ណោះ ហើយនារ. និយាយថា 'ដោយសត្រូវដែលខ្លួនបានបង្កើតពីមុន'។

**១៦៧.** អត្ថបទនេះពិតជានិយាយពីវិធី 'បំបែក'តែមួយរបៀបប៉ុណ្ណោះ។ ដូច្នេះលោកមេធ. គិតថា ដើម្បីឱ្យបានពីររបៀបតាមការតម្រូវ គេត្រូវយល់ថា គេអាចរកវិធានការសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួនក៏បានឬសម្រាប់ការពារអ្នកដទៃក៏បាន។ នារ.

១៦៨- ពេល(ព្រះរាជា)ដឹងថា ឧត្តមភាពរបស់ទ្រង់ស្ថិតស្ថេរមួយរយៈពេលនាអនាគត និងថានៅពេលបច្ចុប្បន្ន (ទ្រង់នឹងទទួល)ការខូចខាតតិចតួច ដូច្នេះចូរទ្រង់មានសំអាងលើវិធានការសន្តិវិធី។

១៦៩- ប៉ុន្តែពេលដែលទ្រង់ព្រះតម្រិះថា អាណាប្រជារាស្ត្រទាំងអស់របស់ទ្រង់មានការពេញចិត្តហួសហេតុ និង(ថាទ្រង់)ខ្លួនឯងត្រូវបានទទួលការសរសើរបំផុត(នៅក្នុងអំណាច) ដូចនេះចូរទ្រង់ធ្វើសង្គ្រាម។

១៧០- បើសិនជាទ្រង់ដឹងថាកងទ័ពរបស់ទ្រង់ផ្ទាល់មានអារម្មណ៍រីករាយពេញចិត្ត និងខ្លាំងក្លាហើយ(ទ័ព) របស់សត្រូវទ្រង់មានលក្ខណៈផ្ទុយទៅវិញ នោះចូរទ្រង់ចល័តទ័ពប្រឆាំងសត្រូវទ្រង់។

១៧១- ប៉ុន្តែប្រសិនបើទ្រង់ទន់ខ្សោយផ្នែកទ័ពសេះនិងសត្វដឹកជញ្ជូន និងទាហាន ដូចនេះចូរទ្រង់នៅស្ងៀមដោយប្រុងប្រយ័ត្ន ដោយព្យាយាមផ្សះផ្សាជាមួយសត្រូវទ្រង់សន្សឹមៗ។

១៧២- បើសិនជាព្រះរាជាដឹងថា សត្រូវខ្លាំងជាងគ្រប់ទិដ្ឋភាពទាំងអស់ ដូច្នេះចូរទ្រង់បំបែកកងទ័ពរបស់ទ្រង់ បន្ទាប់មកអនុវត្តឱ្យសម្រេចព្រះរាជបំណងរបស់ទ្រង់។

១៧៣- ប៉ុន្តែបើសិនជាទ្រង់ងាយស្រួលឱ្យកម្លាំងសត្រូវវាយប្រហារបាន ដូច្នេះចូរទ្រង់ប្រញាប់រកកន្លែងអាស្រ័យជាមួយព្រះរាជាណាមួយដ៏មានអំណាចពិតប្រាកដ។

១៧៤- (ស្តេច)ណាដែលបង្ខិតបង្ខំទាំងប្រជារាស្ត្រ(មិនស្មោះត្រង់)របស់ទ្រង់ និងទាំងទ័ពរបស់សត្រូវបាន ចូរទ្រង់គោរពបម្រើស្តេចអង្គនោះឱ្យដូចជាគុរុ។

១៧៥- សូម្បីនៅក្នុង(ស្ថានភាព)នោះ បើសិនជាទ្រង់យល់ថា អំពើឃោរឃៅនឹងកើតមានចេញពីការការពារបែបនេះ ចូរទ្រង់ចាត់វិធានការធ្វើសង្គ្រាម ដោយកុំស្ទាក់ស្ទើរឱ្យសោះ។

១៧៦- ដោយឧបាយ(ទាំងបួន) ព្រះរាជាប៉ិនប្រសប់ត្រូវតែចាត់ចែង(បញ្ហាទាំងឡាយ) ដើម្បីកុំឱ្យមានមិត្ត អ្នកអព្យាក្រឹត និងសត្រូវ មានឧត្តមភាពជាងទ្រង់។

១៧៧- ចូរទ្រង់ពិចារណាអំពីលទ្ធផលខាងមុខ និងលទ្ធផលភ្លាមៗនៃព្រះរាជកិច្ចទាំងអស់ ព្រមទាំងផលល្អ និងផលអាក្រក់(នៃអំពើ)ពីអតីតកាលទាំងអស់។

១៧៨- ព្រះរាជាដែលស្គាល់អំពើល្អនិងអាក្រក់ (ដែលកើតចេញពីអំពើរបស់ខ្លួន)នៅពេលអនាគត គឺប្រញាប់ប្រញាល់ធ្វើការសម្រេចចិត្តសម្រាប់ពេលបច្ចុប្បន្ន និងស្វែងយល់ពីលទ្ធផលនៃ(អំពើ)ពីអតីតកាល នឹងមិនចេះបរាជ័យឡើយ។

---

និយាយពីរបៀបទាំងពីរ ដោយសន្មតថា ក្នុងករណីមួយ ទ័ពឈប់នៅខាងមុខសត្រូវ ក្រោមមេបញ្ជាការមួយរូប រីឯព្រះរាជាចល័តកម្លាំងមួយផ្នែករបស់ព្រះអង្គ ហើយក្នុងករណីមួយទៀត អាចធ្វើតាមរបៀបផ្ទុយទៅវិញ។ គោវ. បន្ទាប់ការបកស្រាយដូចមាននៅក្នុងអត្ថបទបកប្រែនេះ ស្រង់ពី កាមន្ទកិ *នីតិសាស្ត្រ* ជំពូក១១ លេខ២៤ ដែលមានន័យផ្សេង 'លក្ខខណ្ឌពីរ' សម្រាប់ពាក្យ *ទ្វៃធិការៈ*។ ការបកស្រាយទាំងស្រុងនន្ទ. មាននៅក្នុងសេចក្តីដកស្រង់នេះ។

**១៧០.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ និងលោក K. ថា *ប្រហ្ឫស្តា* ជំនួសពាក្យក្នុងសៀវភៅ *ប្រក្ឫស្តា*។

**១៧៦.** ខ្ញុំអានតាមគោវ. និង K. ថា *ស យុទ្ធំ* ជំនួសពាក្យ *សុយុទ្ធំ* (មេធ., កុល្ល., រាឃ., នន្ទ.) 'ចូរទ្រង់ប្រយុទ្ធដោយក្លាហាន'។

១៧៩- ចូរទ្រង់ចាត់ចែងអ្វីៗតាមរបៀបដែលថា គ្មានមិត្ត គ្មានអ្នកកណ្ដាល ឬសត្រូវ អាចធ្វើឱ្យទ្រង់ខូចខាតបាន នោះជាលទ្ធផលនៃគតិបណ្ឌិតផ្នែកនយោបាយ។

១៨០- ប៉ុន្តែប្រសិនបើព្រះរាជាប្រើឧបាយមួយទប់ទល់នឹងអាណាចក្រសត្រូវ ពេលនោះចូរទ្រង់ធ្វើដំណើរសន្សឹមៗឆ្ពោះទៅកាន់រាជធានីសត្រូវរបស់ទ្រង់ តាមរបៀបដូចខាងក្រោម។

១៨១- ចូរព្រះរាជាចាត់ចែងចល័តទ័ពរបស់ទ្រង់ក្នុងដំណើរ*មារគសីសៈ* ខែល្អ ឬដល់ខែផល្គុណ និងចែត្រ ស្របតាម(ស្ថានភាព)កងទ័ពរបស់ទ្រង់។

១៨២- សូម្បីនៅពេលផ្សេងក៏ដោយ បើសិនទ្រង់មានជំនឿមុតមាំរំពឹងបានជោគជ័យ ឬពេលប្រទេសសត្រូវរបស់ទ្រង់កំពុងធ្លាក់ក្នុងគ្រោះមហន្តរាយ ទ្រង់អាចធ្វើដំណើរទៅវាយសត្រូវមុនបាន។

១៨៣- ក៏ប៉ុន្តែដោយបានចាត់ចែង (កិច្ចការទាំងអស់) បានត្រឹមត្រូវនៅក្នុង (អាណាចក្រដើម) របស់ទ្រង់ និងអ្វីៗដែលទាក់ទងនឹងឧបាយកល ដោយបានជានាមូលដ្ឋាន (សម្រាប់ប្រតិបត្តិការរបស់ទ្រង់) និងដោយបានបញ្ជូនចារបុរសរបស់ទ្រង់បានទាន់ពេលវេលា;

១៨៤- ដោយបានត្រួសត្រាយផ្លូវបីប្រភេទ និង(បានធ្វើឱ្យ)កងទ័ពប្រាំមួយផ្នែករបស់ទ្រង់(មានភាពស័ក្តិសិទ្ធិ)រួចហើយ ចូរទ្រង់បន្តចាត់ចែងតាមសម្រួលតាមរបៀបរៀបចំព្រះរាជកិច្ច សង្គ្រាមប្រឆាំងរាជធានីរបស់សត្រូវ។

១៨៥- ចូរទ្រង់ប្រយ័ត្នរវាំងយាមកាមមិត្ត ដែលធ្វើការជាសម្ងាត់ឱ្យសត្រូវ និងតាមដានអ្នករត់ចោលជួរដែលមកពី(ជុំរំសត្រូវ) ព្រោះមនុស្ស (បែបនេះគឺ) ជាសត្រូវដ៏គ្រោះថ្នាក់បំផុត។

១៨៦- ចូរទ្រង់ចល័តទ័ពតាមផ្លូវ ដោយរៀបទាហានទ្រង់ជាជួរដូចជាបង្គោលរបង (ជាជួរដ៏វែង) ឬដូចជាក្បួនរទេះ (គឺជាចំគ្នាជាកងៗ) ឬដូចជាជ្រូកព្រៃ (គឺជាចតុកោណព្នាយ) ឬដូចជា*មករ* (ជាត្រីកោណពីរដែលមានកំពូលរួមគ្នា) ឬដូចជាម្ជុល (គឺជាជួរដ៏វែង) ឬដូចជា*គរុឌ* (គឺបួនជ្រុងស្មើដែលមានស្លាបដ៏វែង)។

---

**១៨២.** រ៉ិ. ជំពូក៣ លេខ៤០; យញ្ញ. ជំពូក១ លេខ៣៤៧។ 'វេលាល្អ' គឺ 'ពេលសម្បូរចំណីសត្វ និងធញ្ញជាតិ ហើយផ្លូវស្ងួតល្អ'(គោវ., កុល្ល., រាឃ.)។ *មារគសីសៈ* គឺ ខែវិច្ឆិកា-ធ្នូ; *ផល្គុណ* គឺចន្លោះខែកុម្ភៈ-មីនា; *ចែត្រ* គឺខែមីនា-មេសា។

**១៨៤.** 'ដោយបានជានាមូលដ្ឋាន(សម្រាប់ប្រតិបត្តិការរបស់ទ្រង់' គឺ 'ដោយបានយកឈ្នះលើបរិវាររបស់សត្រូវទ្រង់ ដែលអាចជាបង្កអរិភាពជាមួយម្ចាស់របស់ពួកគេ'(មេធ., គោវ., កុល្ល., រាឃ.) ឬ 'ដោយបានបង្កើតជុំរុំនៅ ក្នុងដែនដែលទ្រង់មានចេតនាចង់វាយប្រហារ'(នារ.)។

**១៨៥.** 'ផ្លូវបីប្រភេទ' គឺ 'តាមដែនកណ្ដាលវាល តាមផ្លូវសើម ឬធ្វើដំណើរផ្លូវកាត់តាមផ្លូវទឹក និងតាមព្រៃ'(*គាង្គលានូបាតវិកៈ*) (មេធ., គោវ., កុល្ល., រាឃ., នន្ទ.)។ លោកនារ.ធ្វើការបកស្រាយដូចគ្នា ប៉ុន្តែបន្ថែមថា ការប្រែត្រឹមត្រូវជាង គឺ 'តាមភូមិ ព្រៃ និងភ្នំ'។ 'កងទ័ពប្រាំមួយផ្នែក' គឺមាន 'ទ័ពដំរី ទ័ពសេះ ទ័ពរទេះ ទ័ពថ្មើរជើង មេទ័ព និងពួកសាងសង់'(មេធ., គោវ., កុល្ល., រាឃ.)។ មេធ. បន្ថែមថា អ្នកខ្លះឱ្យឈ្មោះថាជាផ្នែកទីប្រាំគឺ 'រតនៈ' ហើយថា អ្នកខ្លះបកស្រាយពាក្យនេះថា 'ការបែងចែកជាប្រាំមួយផ្នែក ដូចមានបញ្ជាក់ដោយកាមន្ទិ'*នីតិសាស្ត្រ* ជំពូក១៦ លេខ២៦។ លោកនន្ទ. យល់ព្រមតាមមតិក្រោយនេះ។ នារ. រៀបរាប់បន្ថែមក្រៅពីទ័ពដំរី សេះ រទេះ និងទ័ពថ្មើរជើង អ្នកជិះដំរី និង *សាស្ត្រោបនាយក* ( ? )។

**១៨៧.** ការលម្អិតអំពីវិធីនានាក្នុងការរៀបចំកងទ័ព មាននៅក្នុង*កាមន្ទកិ* នីតិសាស្ត្រ ជំពូក១៩។

១៨៧- ផ្ដើមចេញពីជ្រុងណាដែលទ្រង់យល់ថាមានគ្រោះថ្នាក់ ត្រង់(ទិស)នោះ ចូរទ្រង់ពង្រាយទ័ព របស់ទ្រង់ ហើយចូរទ្រង់តាំងបន្ទាយឱ្យរៀបរយ ដូចជាផ្កាឈូកជានិច្ច។

១៨៨- ចូរទ្រង់បែងចែកអគ្គមេបញ្ជាការ មេទ័ព(ក្រោមចំណុះ) (និងនាយទាហានជាន់ខ្ពស់) កាន់ទី តាំងគ្រប់ទិស ហើយចូរទ្រង់ដុតភ្លើងនៅខាងមុខទិសណាដែលទ្រង់មានអារម្មណ៍គ្រោះថ្នាក់។

១៨៩- ចូរទ្រង់ដាក់ក្រុមទាហាននៅគ្រប់ទិសដែលទ្រង់អាចទុកព្រះទ័យបាន តាមមុខសញ្ញាដែលបាន រៀបចំ ដែលជំនាញទាំងផ្នែកជំនួយ និងវាយលុក ដោយគ្មានការភ័យខ្លាច និងស្មោះត្រង់។

១៩០- ចូរទ្រង់ចាត់ទាហានមួយចំនួនតូចចូលប្រយុទ្ធផ្ទាល់ ចូរទ្រង់ពង្រាយទាហានមួយចំនួនធំនៅឱ្យ ឆ្ងាយតាមការសព្វព្រះទ័យរបស់ទ្រង់ ឬចូរទ្រង់ឱ្យពួកគេប្រយុទ្ធ ដោយចាត់មួយក្រុម(តូច)នៅ កណ្ដាលក្បួន (ហើយមួយចំនួនធំ)នៅស្លាបវាយសន្ធប់។

១៩១- សូម្បីនៅលើគោក ចូរទ្រង់ប្រយុទ្ធនឹងទ័ពរទេះ ទ័ពសេះ នៅក្នុងទឹកនៅលើទូក និងដំរី នៅលើ (គោក) ដែលបិទបាំងដោយដើមឈើ និងគុម្ពោតព្រៃ ដែលមានធ្នូនៅលើភ្នំ មានដាវ ស្នា និង អាវុធ(ផ្សេងទៀត)។

១៩២- (ទាហានដែលកើតនៅ)កុរុក្សេត្រ, មត្សយៈ, បញ្ចាលៈ, និងអ្នកដែលកើតនៅសូរសេន ចូរទ្រង់ ឱ្យពួកគេប្រយុទ្ធក្នុងទ័ពជួរមុខ ព្រមទាំង(អ្នកដទៃដែលមាន)មានរាងខ្ពស់ស្ដើង។

១៩៣- បន្ទាប់ពីចាត់ចែងទាហានទ្រង់ហើយ ទ្រង់គួរលើកទឹកចិត្តពួកគេ(ដោយការនិយាយឆ្លើយឆ្លង) និងត្រួតមើលពួកគេដោយព្រះទ័យទុកដាក់; ទ្រង់ក៏គួរចេះសម្គាល់មារយាទរបស់(ទាហាន) ពេលពួកគេចូលប្រយុទ្ធជាមួយសត្រូវ។

១៩៤- ពេលទ្រង់បានហ៊ុំទ័ពសត្រូវទ្រង់(នៅក្នុងក្រុងមួយ) ចូរឱ្យគេនៅក្នុងជំរុំ រុកគួនអាណាចក្រគេ និងបន្តបំផ្លាញស្មៅ អាហារ ប្រេង និងទឹករបស់សត្រូវ។

១៩៥- ទន្ទឹមនឹងនេះដែរ ចូរទ្រង់បំផ្លាញស្រះត្រពាំងទឹក កំពែង និងប្រឡាយ ហើយចូរទ្រង់ប្រហារ សត្រូវ(កុំឱ្យដឹងខ្លួន) និងធ្វើឱ្យសត្រូវតក់ស្លុតនៅពេលយប់។

---

**១៨៨.** ការប្រែរបស់ខ្ញុំចំពោះអនុប្រយោគចុងក្រោយ យកតាមលោកគោវ., នារ. និងរាឃ.។ មេធ. និយាយថា ព្រះរាជាគួរ យាងចាកចេញពីក្រុងជាមួយកងទ័ពរៀបតាមក្បួនផ្កាឈូក ហើយលោកកុល្ល. និយាយពី 'ការក្លែងធ្វើជានៅក្នុងជុំរុំ' (*កបត និវេសនំ កុរយាត*)។ ក្បួនផ្កាឈូក មានការបញ្ជាក់ថា 'ត្រូវពង្រាយទ័ពស្មើគ្នាទៅគ្រប់ទិស និងមានរាងវង្វង់មូល ល្អឥតខ្ចោះ ចំណុចកណ្ដាលជាកន្លែងព្រះមហាក្សត្រិយប្រថាប់'។

**១៨៩.** មេធ. កត់សម្គាល់ថា ព្រោះមានមេទ័ពចំណុះ និងអគ្គមេបញ្ជាការតែពីរប៉ុណ្ណោះ ពួកគេមិនអាច 'នៅគ្រប់ទិសទាំង អស់'បាន ដូចការរៀបរាប់ក្នុងអត្ថបទទេ ហើយថា ដូច្នេះបរិវាររបស់ពួកគេ (នាយទាហានជាន់ខ្ពស់) ក៏ត្រូវរាប់បញ្ចូលដែរ។

**១៩០.** នារ. បកស្រាយ *គុល្មាន*ក្រុមទាហាន' ដោយពាក្យ *គុល្មទេសស្ថាន*(ទាហាន)ដែលឈរលាក់ខ្លួនក្នុងព្រៃ'(?)។

**១៩១.** *ស្ថលេ*នៅលើភ្នំ'(និមនោន្នតេ តាមលោករាឃ.) ហើយតាមមេធ., គោវ. និងកុល្ល. ថា 'នៅលើដីដែលគ្មានថ្ម គ្មាន ព្រៃ គ្មានវល្លិ៍ គ្មានបន្លា គ្មានរណ្ដៅជាដើម'។

**១៩៣.** *កុរុក្សេត្រ* គឺតំបន់មួយនៅជាប់នឹង*ដេលី; មត្សយៈ* ជាអ្នកស្រុកតំបន់ពៃរាត នៅខាងជើងបុរី*ជេពួរ* (មេធ. ថា *កត បុរេ*); *បញ្ចាលៈ* គឺអ្នកស្រុកកាន្យកុព្ជ (កនោគ); *សូរសេនៈ* គឺអ្នកស្រុកដែនដី នៅជិតមថុរា (គោវ. ថា *អហិឆត្រ*)។

១៩៦- ចូរទ្រង់ញុះញង់ឱ្យមានការប៉ះបោរចំពោះអ្នកដែលងាយនឹងធ្វើឱ្យមានការប៉ះបោរ ចូរឱ្យសត្រូវដឹងអំពីអំពើ(របស់សត្រូវ)ទ្រង់ ហើយពេលមានជោគវេលាល្អ ចូរទ្រង់ប្រយុទ្ធដោយគ្មានការភ័យខ្លាច ដោយព្យាយាមយកឈ្នះឱ្យបាន។

១៩៧- (យ៉ាងណាក៏ដោយ)ទ្រង់គួរតែព្យាយាមយកឈ្នះសត្រូវទ្រង់ដោយការផ្សះផ្សា ដោយការផ្តល់អំណោយ(ល្អៗ) និងដោយការបំបែកបំបាក់ ដោយប្រើឧបាយមួយៗដោយឡែកពីគ្នាក៏បាន ឬរួមគ្នាក៏បាន ព្យាយាមកុំប្រើការប្រយុទ្ធគ្នា (ប្រសិនបើអាចជៀសបាន)។

១៩៨- ព្រោះថាបើ (ព្រះអង្គម្ចាស់) ពីរប្រយុទ្ធគ្នា ជោគជ័យនិងបរាជ័យនៅក្នុងសមរភូមិ តាមបទពិសោធន៍ គឺមិនច្បាស់លាស់ទេ ហេតុនេះចូរទ្រង់ជៀសវាងការធ្វើសង្គ្រាម។

១៩៩- (ប៉ុន្តែ) បើសិនជាការប្រើឧបាយកលទាំងបីដែលបានរៀបរាប់ខាងលើ មិនបានជោគជ័យក្តី ដូចនេះចូរទ្រង់ ដោយការប្រឹងប្រែងដោយផ្ទាល់ ប្រយុទ្ធតាមរបៀបមួយដែលទ្រង់អាចយកឈ្នះសត្រូវរបស់ទ្រង់បានទាំងស្រុង។

២០០- ប្រសិនបើព្រះអង្គបានទទួលជោគជ័យ ចូរទ្រង់គោរពព្រះអាទិទេពតាមការសមគួរ និងគោរពព្រាហ្មណ៍ដោយត្រឹមត្រូវ ចូរទ្រង់ព្រះរាជទានការលើកលែង ហើយចូរទ្រង់ប្រកាសការសន្យាផ្តល់សុវត្ថិភាព។

២០១- ប៉ុន្តែដោយបានដឹងច្បាស់ទាំងស្រុងអំពីបំណងប្រាថ្នារបស់ (អ្នកចាញ់សង្គ្រាម) ទាំងអស់ ចូរទ្រង់ដាក់ឱ្យពួកគេនៅទីនោះជាញាតិរបស់ (មេដឹកនាំរាជបល្ល័ង្កដែលបរាជ័យ) ហើយចូរទ្រង់ដាក់នូវលក្ខខណ្ឌរបស់ទ្រង់។

២០២- ចូរទ្រង់ចេញព្រះរាជបញ្ញាអនុវត្ត(ទំនៀមទម្លាប់)ស្របច្បាប់របស់(អ្នកស្រុក) ស្របតាមបញ្ញត្តិប្រពៃណី ហើយចូរទ្រង់ថ្វាយនិងជូនព្រះរាជអំណោយមានតម្លៃថ្វាយ(ព្រះរាជាថ្មី) និងដល់មន្ត្រីសំខាន់ៗរបស់ទ្រង់។

២០៣- ការដកហូតកម្មសិទ្ធិសំខាន់ៗ ដែលបង្កឱ្យមានការមិនសប្បាយចិត្ត ហើយការបែងចែកទ្រព្យដែលបង្កភាពរីករាយ ជាអំពើគួរធ្វើទាំងពីរ (ប្រសិនបើអំពើនោះ) ត្រូវបានធ្វើឡើងស្របតាមពេលវេលាសមស្រប។

---

**២០១-២០៥.** វិ. ជំពូក៣ លេខ៤៧-៤៩; យញ្ញ. ជំពូក១ លេខ៣៤២, ៣៤៨-៣៥១។

**២០១.** 'អាទិទេព' គឺសំដៅដល់ប្រទេសដែលដណ្តើមបាន។ *បរិហារន* 'ការលើកលែង' គឺ 'ឱ្យរួចពន្ធសម្រាប់រយៈពេលមួយឆ្នាំ ឬពីរឆ្នាំ'(មេធ., នន្ទ.) តែតាមគោវ. ថា 'ការឱ្យទៅពួកស្រោត្រិយ និងអ្នកផ្សេងទៀត' (ស្រោត្រិយាទិគ តាវាស្យទានេសុមយៃត័ទ អនុគញាតំ ឥតិ អេវំ); តាមកុល្លូ. ថា 'ការឱ្យពួកអាទិទេព និងព្រាហ្មណ៍'; តាមនារ. ថា 'អគ្រហារ ឬភូមិនានាដែលជូនដល់ពួកព្រាហ្មណ៍'; តាមរាឃ. ថា 'ការឱ្យសម្លៀកបំពាក់ និងគ្រឿងអលង្ការ ដល់អ្នកស្រុកនោះ'។ ពាក្យ *បរិហារ* មានប្រើជារឿយៗនៅក្នុងសិលាចារឹក (សូមមើលឧ.ទា. ឯកសារ របាយការណ៍ស្តីពីឥណ្ឌា ភាគខាងលិច ភាគបួន ទំព័រ ១០៤) ហើយមានន័យលម្អិត បង្ហាញថា 'ការលើកលែងពន្ធ និងការទូទាត់ ព្រមទាំងអភ័យ ឯកសិទ្ធិផ្សេងទៀត'។ *បរិហារ* ទាំងនេះ ជារឿយៗត្រូវភ្ជាប់ជាមួយអំណោយទាំងអស់សម្រាប់ពួកព្រាហ្មណ៍ ឬវិហារ សាសនា។ តាមសេចក្តីរបស់យើង ទំនងជាសំដៅដល់ការលើកលែងពន្ធបណ្តោះអាសន្នជាទូទៅ។

២០៤- កិច្ចការទាំងអស់(នៅក្នុង)លោកិយនេះ អាស្រ័យលើច្បាប់នៃផលកម្មផង និងអាស្រ័យលើការព្យាយាមរបស់មនុស្សផង ប៉ុន្តែក្នុងចំណោមវិធីទាំងពីរនេះ ផលកម្មជាសភាពហួសវិស័យនឹងពិចារណាបាន ហើយចំពោះអំពើរបស់មនុស្ស គឺជារឿងមួយដែលអាចទៅរួច។

២០៥- ឬ(ព្រះរាជាដែលបានជ័យជម្នះ) ដែលចាត់ទុកមិត្ត មាស និងដីធ្លី (ថាជា)ផលបីយ៉ាងចេញពី(ការធ្វើការងារ) ដោយមានការយកចិត្តទុកដាក់ អាចសាងសន្តិភាពជាមួយ(សត្រូវទ្រង់) និងផ្តល់សន្តិភាពដល់(អាណាចក្ររបស់ទ្រង់)បាន។

២០៦- ដោយបានយកចិត្តទុកដាក់ដ៏សមគួរចំពោះព្រះរាជាដែលនៅក្នុងចំណោម(រដ្ឋជិតខាង) ដែលអាចវាយប្រហារទ្រង់ពីក្រោយ និងចំពោះអ្នកគាំទ្ររបស់ទ្រង់ដែលប្រឆាំង នឹងអ្នកខាងក្រោយនេះ ចូរ (អ្នកឈ្នះ) ជានាឱ្យនូវផ្លែផ្កានៃការងារពី(ស្តេចដែលទ្រង់វាយប្រហារ) ទោះបី (ទ្រង់អាចក្លាយជា)មិត្តក្តី ឬ(នៅ)ជាសត្រូវក្តី។

២០៧- ដោយការទទួលបានមាស និងដី មិនបានធ្វើឱ្យព្រះរាជាខ្លាំងណាស់ណាដូចការបានមិត្តរឹងមាំ(ដែល)សូម្បីនៅខ្សោយក៏ដោយ (ក៏អាចមាន)អំណាចខ្លាំងក្លាយបាននៅពេលអនាគត។

២០៨- គេគួរសរសើរលើកតម្កើងមិត្ត(សូម្បី)ទន់ខ្សោយ ដែលមានភាពត្រឹមត្រូវ (និង)កតវេទី ដែលមានប្រជារាស្ត្រពេញចិត្ត ដែលតស៊ូព្យាយាមក្នុងកិច្ចការរបស់ខ្លួន។

២០៩- បណ្ឌិតប្រកាសមនុស្សមួយប្រភេទ (ដែលជា)សត្រូវដ៏មានគ្រោះថ្នាក់បំផុត គឺសត្រូវដែលមានគតិបណ្ឌិត អម្បូរអភិជន អ្នកក្លាហាន ឆ្លាតវៃ ចិត្តទូលាយ ចេះដឹងគុណ និងមានចិត្តរឹងមាំ។

២១០- ឥរិយាបថដ៏សមសួនរបស់អារ្យ៉ន ពុទ្ធិរបស់មនុស្ស សេចក្តីក្លាហាន ចិត្តមេត្តាករុណា និងចិត្តទូលំទូលាយ គឺជាគុណធម៌របស់មនុស្សអព្យាក្រឹត (ដែលគេអាចចងមិត្តបាន)។

---

**២០៥.** យញ្ញ. ជំពូក១ លេខ៣៤៨។ 'អំពើ' គឺ 'ការស្វែងរកដោយយកចិត្តទុកដាក់' ដូច្នេះគេគួរតែខិតខំសម្រេចបំណងរបស់ខ្លួនឱ្យបាន តាមរយៈការព្យាយាមធ្វើការងារ(គោវ., កុល្ល.) ឬ 'អំពើដែលអាចកែកុនបាន'(*ប្រតិក្រិយា* តាមការបកស្រាយរបស់នារ.) ឬ 'ការខំប្រឹងប្រែង'(តាមរាឃ. ថា *បុរុសការៈ*)។ លោកនន្ទ. ប្រែអនុប្រយោគចុងក្រោយផ្សេងទៅវិញថា 'បើមានការខំប្រឹងប្រែងរបស់មនុស្ស អំពើនៃផលកម្មនឹងកើតឡើង'(*មានុសេ បុរុសការេ សតិ ទៃវស្យ វិទ្យតេ*)។

**២០៦.** យោងតាមលោកគោវ., កុល្ល. និងនារ. អត្ថន័យគឺថា បើសិនជាសត្រូវចង់សម្ព័ន្ធមិត្ត ផ្តល់សួយសារអាករ និងប្រគល់ទឹកដីមួយចំនួន ព្រះរាជាដែលបានជ័យជម្នះ ក៏អាចសាងសន្តិភាពជាមួយគេ ដោយមិនចាំបាច់មានការប្រយុទ្ធដាក់ស្តែង ហើយអាចត្រឡប់ទៅផ្ទះវិញបាន។ នៅក្នុងសំណៅដៃរបស់លោកមេធ. កាព្យនេះ និងកាព្យក្រោយៗរហូតដល់កាព្យលេខ២១១ ជាការតម្រូវ និងអធិប្បាយអំពីកាព្យ២១១ មួយផ្នែក។

**២០៧.** យោងតាមគោវ., កុល្ល. និងរាឃ. ន័យនៃកាព្យនេះ គឺថា ព្រះរាជាដែលមានជ័យជម្នះ គួរជានាការយាងត្រឡប់ទៅវិញ នៅមុនពេលទ្រង់បំពេញរាជកិច្ច។ ស្តេចដែលនៅពីក្រោយទ្រង់ផ្ទាល់ ដែលតាមនីតិហៅថា *បាស្ណិគ្រាហៈ* 'អ្នកជាន់កែង' អាចជាសត្រូវរបស់ទ្រង់ និងអាចឈ្លានពានដែលដីរបស់ទ្រង់ ក្នុងកំលុងពេលអវត្តមានរបស់ទ្រង់។ ហេតុនេះ ការសំខាន់សម្រាប់អ្នកឈ្នះ ត្រូវដោះស្រាយបញ្ហាជាមួយគេជាមុនក៏បាន ឬជានាឱ្យមានការគាំទ្រពីអ្នកប្រទេសជិតខាងបន្ទាប់ *បាស្ណិគ្រាហៈ* ដែលគេហៅតាមបច្ចេកទេសថា *អាក្រន្ទ* ហើយគេអាចពិនិត្យមើលពាក្យ *បាស្ណិគ្រាហៈ* នេះបាន។

**២០៨.** យញ្ញ. ជំពូក១ លេខ៣៥១។

**២១១.** ពាក្យ *ស្ថោលលក្ស្យ* (កុល្ល., នារ., រាឃ., នន្ទ.)ថា 'មហាសប្បុរស' ហើយតាមការបកស្រាយរបស់មេធ. និងគោវ. ដូចការបញ្ជាក់របស់កុល្ល. ថា 'ការមើលមិនបានច្បាស់'។ យ៉ាងណាមិញសំណៅរដ្ឋាភិបាលរបស់គោវ. ប្រើពាក្យផ្ទុយគ្នាគឺ

២១១- ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ចូរព្រះរាជាកុំមានការស្ទាក់ស្ទើរក្នុងការបោះបង់សូម្បីដល់ប្រទេស (ដ៏)ល្អ សម្បូរដីជាតិ និងងាយស្រួលសម្រាប់ជីវិតសត្វពាហនៈក៏ដោយ។

២១២- ចូរទ្រង់រក្សាទ្រព្យសម្បត្តិរបស់ទ្រង់សម្រាប់ពេលត្រូវការ ចូរទ្រង់រវាំងប្រយ័ត្នមហេសីទ្រង់ ក្នុងការចាយវាយទ្រព្យរបស់ទ្រង់ ហើយចូរទ្រង់រក្សាខ្លួនគ្រប់ព្រឹត្តិការណ៍ទាំងអស់ សូម្បី(ត្រូវបោះបង់)មហេសីទ្រង់ និងទ្រព្យសម្បត្តិរបស់ទ្រង់ក៏ដោយ។

២១៣- (ស្ដេច)ដ៏មានគតិបណ្ឌិតដែលចេះមើលឃើញថា សំណាងអាក្រក់គ្រប់ប្រភេទអាចកើតមានចំពោះទ្រង់យ៉ាងសាហាវក្នុងពេលតែមួយ គួរព្យាយាមប្រើឧបាយ(ទាំងបួន) ទោះជាប្រើរួមគ្នាក៏បាន ឬដោយឡែកពីគ្នាក៏បាន (ដើម្បីរក្សាខ្លួនទ្រង់)។

២១៤- ចូរទ្រង់ពិចារណាថ្លឹងថ្លែងអំពីបញ្ហាបីយ៉ាង គឺបុគ្គលដែលប្រើឧបាយនោះ អំពីកិច្ចការដែលត្រូវសម្រេចឱ្យបាននិងអំពីឧបាយរួមទាំងអស់ ហើយព្យាយាមសម្រេចព្រះរាជបំណងទ្រង់ឱ្យបាន។

២១៥- ហេតុនេះបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយកុង្សីយ៍របស់ទ្រង់អំពី(បញ្ហា)ទាំងអស់នេះ ក្រោយពីបានអនុវត្ត និងបន្ទាប់ពីស្រង់ទឹករួច ព្រះរាជាអាចយាងចូលកាន់បន្ទប់ស្រីស្នំ នៅពេលថ្ងៃត្រង់ ដើម្បីសោយក្រយា។

២១៦- នៅទីនោះ ទ្រង់អាចសោយព្រះក្រយា(ដែលព្រះរាជបម្រើ)ដ៏ស្មោះត្រង់ សុចរិត ស្គាល់កាលវេលា បានរៀបចំ(សម្រាប់ថ្វាយទ្រង់) ដែលត្រូវបានពិនិត្យត្រឹមត្រូវ (និងត្រូវធ្វើឱ្យសក្តិសិទ្ធិ) ដោយធម៌ពិសិដ្ឋ ដែលជួយកម្ចាត់ជាតិពុល។

២១៧- ចូរទ្រង់បញ្ចូលក្នុងអាហារទាំងអស់របស់ទ្រង់នូវឱសថ(ដែល)ជួយបន្សាបជាតិពុល ហើយចូរទ្រង់ប្រុងប្រយ័ត្នដោយពាក់ត្បូងដែលប្រឆាំងជាតិពុល។

២១៨- ស្ត្រីដែលគេបានពិនិត្យការតុបតែងស្លៀកពាក់បានស្អាតបាត នឹងយកចិត្តទុកដាក់បម្រើទឹកគ្រឿងក្រអូប និងបក់ផ្លិតថ្វាយទ្រង់។

២១៩- ក្នុងទំនងបែបនេះ ចូរទ្រង់ប្រយ័ត្នចំពោះរាជរថ សយនា អាសនៈ បន្ទប់ទឹក បង្គន់ និង គ្រឿងអលង្ការទាំងអស់របស់ទ្រង់។

---

*សូក្ស្មទវសិត្វំ*។ ការបកស្រាយរបស់លោកមេធ. មិនអាចន័យច្បាស់ទេ។

**២១៥.** 'បុគ្គលដែលប្រើឧបាយ' គឺ 'ព្រះអង្គផ្ទាល់'(គោវ., កុល្ល., នារ., រាឃ.) ហើយនន្ទ.ថា 'កុង្សីយ៍ ឬមន្ត្រីរបស់ទ្រង់'។ អាស្រិយ 'ចូរទ្រង់ពិចារណាថ្លឹងថ្លែង' (នារ., រាឃ. ថា *មនសា ពលាពទិ និស្កិត្យ*) ហើយតាមមេធ., គោវ., កុល្ល. 'ចូរទ្រង់ពឹង ផ្អែកលើ'

**២១៧-២២០.** វិ. ជំពូក៣ លេខ៨៥, ៨៧-៨៨; យញ្ញ. ជំពូក១ លេខ៣២៦។

**២១៨.** មេធ., គោវ., នារ. និងនន្ទ. អាន *នេគយេត* និងរាឃ. ថា *សោធយេត*ចូរទ្រង់សម្អាតកាយចិត្ត' ជំនួសពាក្យ *យោគយេត* តាមកុល្ល., K. ថា 'ចូរទ្រង់ចូលជ្រៀតជ្រែក'។ នារ. បកស្រាយ *និយតះ* (មេធ., នារ., រាឃ.) ឬ *ប្រយតះ* 'រវាំងប្រយ័ត្ន'។ លោកគោវ., កុល្ល., រាឃ. ថា *យត្នវាន*ដោយបរិសុទ្ធ'។

**២២៣.** យញ្ញ. ជំពូក១ លេខ៣២៩។ 'ក្នុងចំណោមអ្នកដែលធ្វើរបាយការណ៍សម្ងាត់' គឺ 'ក្នុងចំណោមរដ្ឋមន្ត្រី និងមន្ត្រីផ្សេងៗទៀត'(នារ.) ឬ 'ក្នុងចំណោមប្រជាពលរដ្ឋដែលបានក្លាយជា'(មេធ.)។

២២០- នៅពេលព្រះអង្គបានសោយព្រះក្រយាបូច ព្រះអង្គអាចបង្វែរការសប្បាយជាមួយមហេសីទៅ ជាមួយស្រីស្នំ ប៉ុន្តែនៅពេលផ្លាស់ប្តូរការសប្បាយនោះព្រះអង្គត្រូវតែគិតឡើងវិញអំពីរាជកិច្ច រាជការ តាមកាលដ៏គួរ។

២២១- ដោយពាក់អាវ(រាជការ) ចូរទ្រង់ពិនិត្យមើលទាហានប្រយុទ្ធ រាជរថ និងសត្វសម្រាប់ដឹកជញ្ជូនអាវុធ និងគ្រឿងប្រើប្រាស់ផ្សេងៗទាំងអស់របស់ទ្រង់ឡើងវិញ។

២២២- បន្ទាប់ពីបានធ្វើអធិដ្ឋានរបស់ទ្រង់ពេលរាត្រី ចូរទ្រង់យាងចូលរាជរោងរម្យស្តាប់ការរាយការណ៍សម្ងាត់នានា និងរបាយការណ៍របស់ចារកម្មទ្រង់ ដោយកាន់អាវុធផង។

២២៣- ប៉ុន្តែពេលយាងទៅកាន់បន្ទប់សម្ងាត់មួយទៀតនិងដេញមនុស្សទាំងអស់នេះចេញ ទ្រង់អាចចូលបន្ទប់ស្រីស្នំ ដែលចោមរោមដោយ(បរិពារ)ស្រីស្រឹង្គា ដើម្បីសោយព្រះក្រយាម្តងទៀត។

២២៤- បន្ទាប់ការសោយអ្វីម្យ៉ាងនៅទីនោះជាលើកទីពីរ និងមានសំឡេងតន្ត្រីដ៏ពីរោះផង ចូរទ្រង់ចូលសម្រាក និងតើនតាមពេលសមគួរ ឱ្យស្បើយពីការអស់ព្រះកាយពល។

២២៥- ព្រះរាជា ដែលមានព្រះរាជសុខភាពល្អ ប្រតិបត្តិតាមក្បួនតម្រាទាំងនេះ ប៉ុន្តែបើសិនជាទ្រង់មិនស្រួលព្រះទ័យ ទ្រង់អាចប្រគល់(រាជកិច្ច)ទាំងអស់នេះទៅរាជបម្រើរបស់ទ្រង់បាន។

---

**២២៥.** យញ្ញ. ជំពូក១ លេខ៣៣០។ 'អ្វីម្យ៉ាង' គឺ 'មិនច្រើនពេក'។

# ជំពូក ៨

១- ព្រះរាជាដែលចង់ស៊ើបអង្កេតករណីច្បាប់ ត្រូវតែយាងចូលតុលាការយុត្តិធម៌របស់ទ្រង់ ដោយបានរក្សាឱ្យនូវអាការថ្លៃថ្នូរជាមួយព្រាហ្មណ៍ និងអាមាត្យដ៏មានបទពិសោធន៍។

២- នៅទីនោះ ទោះជាចង់អង្គុយក៏បាន ឬឈរក៏បាន ដោយលើកព្រះហត្ថស្តាំរបស់ទ្រង់ ដោយមិនសំញែងព្រះពស្ត្រ និងអាភរណៈ ចូរទ្រង់ព្រះតម្រិះវិភាគសាច់រឿងរបស់គូក្តី,

៣- រាល់ថ្ងៃ(ដោយវិនិច្ឆ័យ)ករណីមួយហើយមួយទៀត(ករណីទាំងអស់) ដែលស្ថិតក្នុងមាតិកាសិទ្ធិទាំងដប់ប្រាំបី(នៃច្បាប់) ស្របតាមគោលការណ៍ដែលមាននៅមូលដ្ឋាន និងគោលការណ៍នៃច្បាប់ពិសិដ្ឋ។

៤- ក្នុងចំណោម(សិទ្ធិ)ទាំងនោះ ទីមួយ គឺការមិនទូទាត់បំណុល (នៅពេលបន្ទាប់) (២)ការកក់និងការសន្យាផ្តល់ប្រាក់ (៣)ការលក់ដោយមិនចាំបាច់មានម្ចាស់ (៤)ការបារម្ភក្នុងចំណោមអ្នកចូលហ៊ុន និង(៥)ការធ្វើអំណោយបន្ត,

៥- (៦)ការបង់ប្រាក់ឈ្នួល (៧)ការមិនអនុវត្តកិច្ចព្រមព្រៀង (៨)កតិកាភេទនៃការលក់ និងទិញ, (៩)វិវាទរវាងម្ចាស់(សត្វពាហនៈ) និងអ្នកបម្រើរបស់គាត់,

៦- (១០)វិវាទពាក់ព័ន្ធនឹងព្រំប្រទល់ (១១)អំពើបំពាន និង(១២)ការបរិហាកេរ្តិ៍ (១៣)ចោរកម្ម (១៤)អំពើប្លន់ និងអំពើហិង្សា (១៥)សហាយស្មន់,

៧- (១៦)ករណីយកិច្ចរបស់បុរសនិងភរិយា (១៧)ការចែក(មរតក) (១៨)ការលេងល្បែង និងការភ្នាល់ទាំងអស់ជាប្រធានបទដប់ប្រាំបីនៅក្នុងលោកិយនេះ ដែលមានចោទនៅក្នុងរឿងក្តី។

៨- អាស្រ័យលើច្បាប់ដ៏អមតៈ ចូរទ្រង់វិនិច្ឆ័យរឿងក្តីរបស់រាស្ត្រ ដែលភាគច្រើនពាក់ព័ន្ធនឹងមាតិកា ដូចបានជម្រាបជូនមកនេះ។

---

VIII. ១. វិ. ជំពូក៣ លេខ៧២; យញ្ញ. ជំពូក១ លេខ៣៥៩; ជំពូក២ លេខ១; គោត. ជំពូក១៣ លេខ២៦; វស. ជំពូក១៦ លេខ២។

២. 'ការឈរ' គឺ 'ក្នុងករណីសំខាន់'(មេធ., គោវ., កុល្ល., រាឃ.)។ 'ដោយលើកព្រះហស្តស្តាំរបស់ទ្រង់' គឺ 'ដោយទុកព្រះហស្តឱ្យនៅកណ្តាលវាល'(នារ., នន្ទ., រាឃ., គោវ.)។ ចំពោះអត្ថន័យនៃអំពើ សូមមើលជំពូក៤ លេខ៥៨ខាងលើ។

៣. គោត. ជំពូក១១ លេខ១៩-២៤; វស. ជំពូក១៦ លេខ៤-៥។ 'ការប្រើប្រាស់នៅមូលដ្ឋាន' គឺ 'ច្បាប់ទំនៀមទម្លាប់ដែលមិនផ្ទុយពីសាស្ត្រ'(មេធ., គោវ., កុល្ល., នារ.)។

៤. 'ការមិនសងបំណុល'(*ឫណស្យ អទានំ* តាមនារ., នន្ទ.) គេអាចប្រែថា 'ការសងបំណុល'(*ឫណស្យ អាទានំ*)។

៧. ពាក្យ *វ្យវហារស្ថិតោ* 'ដែលកើតមាននៅក្នុងរឿងក្តី'(គោវ.) ហើយតាមនារ. ថា 'ដែលមាននៅក្នុងការវិនិច្ឆ័យរឿងក្តី'។

៨. ពាក្យ 'ភាគច្រើន' ចង់បង្ហាញថាមានមាតិកាផ្សេងទៀត ដូចលោកនារទ បានប្រកាស(មេធ., គោវ., កុល្ល., នារ., រាឃ.)។ នន្ទ. លុបកាព្យនេះចោល។

៩- ប៉ុន្តែបើព្រះរាជាមិនចង់វិនិច្ឆ័យរឿងក្តីដោយផ្ទាល់ ដូច្នេះចូរទ្រង់តែងតាំងព្រាហ្មណ៍ដែលមានចំណេះដឹងច្រើន កាត់ក្តីនោះបាន។

១០- (បុរស)នោះត្រូវចូលមកកាន់តុលាការដ៏ឧត្តុង្គឧត្តមបំផុតនោះ ដោយមានជំនួយការបីរូប ហើយវិនិច្ឆ័យទាំងស្រុងនូវហេតុ(ទាំងអស់)នៅចំពោះព្រះភក្ត្រ(ព្រះរាជា) ដោយអង្គុយក៏បាន ឬឈរក៏បាន។

១១- កន្លែងដែលមានព្រាហ្មណ៍បីរូបជាអ្នកចេះតែងកាព្យវេទ និង(ចៅក្រម)ដ៏មានចំណេះដឹង ដែលព្រះរាជាបានតែងតាំង អង្គុយនោះ គេហៅថា តុលាការព្រហ្ម(មុខបួន)។

១២- ប៉ុន្តែកន្លែងដែលយុត្តិធម៌កើតមានអំពើអយុត្តិធម៌ ហើយចៅក្រមមិនបានកម្ចាត់អំពើនោះ ទីនោះ(ក៏នឹង)ត្រូវរងគ្រោះ(ដោយអំពើអយុត្តិធម៌នោះ)ដែរ។

១៣- គេមិនចាំបាច់ដើរចូលតុលាការនោះក៏បាន ឬគេមិនបាច់និយាយពីសច្ចធម៌ក៏បាន ហើយមនុស្សដែលមិននិយាយអ្វីក៏ដោយ ឬនិយាយមិនពិតក៏ដោយ នឹងមានបាបកម្ម។

១៤- ទីណាដែលយុត្តិធម៌ត្រូវបំផ្លាញដោយអំពើអយុត្តិធម៌ ឬសច្ចធម៌កើតឡើងដោយការបន្លំ ពេលដែលចៅក្រមវិនិច្ឆ័យក្តី ទីនោះក៏នឹងត្រូវបំផ្លាញដែរ។

១៥- 'យុត្តិធម៌ដែលត្រូវបានបំពាន នឹងរលាយ; យុត្តិធម៌ដែលត្រូវបានរក្សានឹងរក្សាគេវិញ ហេតុនេះគេមិនត្រូវបំពានយុត្តិធម៌ទេ បើគេបំពានវា យុត្តិធម៌នឹងបំផ្លាញយើងហើយ'។

១៦- ព្រោះ(គេនិយាយថា)យុត្តិធម៌ល្អផូរផង់បីដូចដំរីឈ្មោល(វ្រ្វស) និងថា(មនុស្ស) ដែលបំពានយុត្តិធម៌ (កុំរុតេលំ) អាទិទេពចាត់ទុក(អ្នកនោះជាមនុស្សគួរឱ្យស្អប់)ដូចសូទ្រៈ (វ្រ្វសល) ហេតុនេះចូរទ្រង់ប្រយ័ត្នកុំបំពានយុត្តិធម៌។

១៧- មិត្តដែលជាប់តាមខ្លួនមនុស្សយើងបន្ទាប់ពីស្លាប់ គឺមានតែយុត្តិធម៌ប៉ុណ្ណោះ ព្រោះអ្វីៗដទៃទៀតត្រូវសាបសូន្យទន្ទឹមគ្នានឹងពេលរូបកាយ(វិនាស)។

១៨- មួយភាគបួននៃ(ទោស)កើតពីការវិនិច្ឆ័យមិនយុត្តិធម៌ នឹងធ្លាក់មកលើអ្នកប្រព្រឹត្ត(បទឧក្រិដ្ឋ) មួយភាគបួនធ្លាក់លើសាក្សី(ក្លែងក្លាយ) មួយភាគបួនធ្លាក់លើចៅក្រមគ្រប់រូប មួយភាគបួនធ្លាក់លើព្រះរាជា។

១៩- ប៉ុន្តែទីណាដែលមានការដាក់ទោសចំពោះអ្នកដែលគួរត្រូវទោស ព្រះរាជាគ្មានទោស ហើយចៅក្រមបានរួចពី(អំពើបាប) ហើយទោសធ្លាក់លើអ្នកប្រព្រឹត្ត(បទឧក្រិដ្ឋតែឯងប៉ុណ្ណោះ)។

---

៩. វិ. ជំពូក៣ លេខ៧៣; យញ្ញ. ជំពូក២ លេខ៣; គោត. ជំពូក១៣ លេខ២៦; វស. ជំពូក១៦ លេខ២។

**១០.** មេធ. និយាយថា 'ដោយ(យ៉ាងហោច)មានជំនួយការបីរូប'។

**១៣.** 'មិនចាំបាច់ចូល' គឺ 'ក្នុងបំណងធ្វើការសម្រេចរឿងក្តី' (គោវ., កុល្លូ., រាឃ.)។ ប៉ុន្តែការលម្អិតបន្ថែមទៀត បង្ហាញថាកាព្យនេះជាភាសិតទូទៅមួយ ដែលជាសក្ខីកម្មផងដែរ។

**១៥.** ជំនួយការត្រូវតែជួយជាស់តឿនដល់ចៅក្រម ដែលបំពានច្បាប់(គោវ., កុល្លូ., រាឃ.)។ នន្ទ. អាន *វ:អ្នក'* ជំនួយពាក្យ *នៈ* 'យើង'។

**១៨.** គោត. ជំពូក១៣ លេខ១១; ពោធ. ជំពូក១ លេខ៩, ៨។ *សភាសទ:* 'ចៅក្រម' ហើយតាមលោកគោវ. ថា 'មន្ត្រីទាំង

២០- ព្រាហ្មណ៍ដែលរស់អាស្រ័យតែដោយសារឈ្មោះនៃវណ្ណៈខ្លួន(គាតិ) ឬអ្នកដែលគ្រាន់ហៅខ្លួនជាព្រាហ្មណ៍(ដោយសារដើមកំណើតរបស់ខ្លួនមិនច្បាស់លាស់) អាច តាមការសព្វព្រះទ័យរបស់ព្រះរាជា អនុវត្តច្បាប់ចំពោះរូបគេបាន ប៉ុន្តែកុំធ្វើចំពោះសូទ្រៈឱ្យសោះ។

២១- អាណាចក្ររបស់មហាក្សត្រិយ ដែលឈរមើលពួកសូទ្រៈដោះស្រាយបញ្ហាច្បាប់ នឹងលិចលង់(ធ្លាក់ចុះមិនលែង) បីដូចមេគោស្ថិតនៅទីស្នោគគ្រោក។

២២- អាណាចក្រណាដែលមានពួកសូទ្រៈដ៏ច្រើនដែលជាអ្នកមិនជឿថាមានអាទិទេព និងខ្វះខាត(អ្នកស្រុក)ដែលមានកំណើតពីរដង មិនយូរទេនឹងវិនាសទាំងស្រុង ដោយសារគ្រោះទុរ្ភិក្ស និងជំងឺដម្កាត់។

២៣- ដោយបានកាន់តំណែងយុត្តិធម៌ ដោយបានបិទបាំងកាយរបស់ខ្លួន និងបានគោរពអាទិទេពអ្នកការពារលោក ចូរទ្រង់ចាប់ផ្តើមការកាត់ក្តីដោយចិត្តមូល។

២៤- ដោយដឹងនូវអ្វីដែលជាឧបាយឬមិនមែនជាឧបាយ អ្វីដែលជាយុត្តិធម៌ពិតឬមិនយុត្តិធម៌ ចូរទ្រង់វិនិច្ឆ័យរឿងក្តីរបស់គូក្តី ស្របទៅតាមប្រព័ន្ធវណ្ណៈ។

២៥- ចូរទ្រង់រកឱ្យឃើញអារម្មណ៍ខាងក្នុងរបស់មនុស្ស ដោយសញ្ញាខាងក្រៅ ដោយសំឡេង ដោយពន្លឺពណ៌ ដោយការធ្វើចលនា រូបរាងខាងក្រៅ ភ្នែក និងកាយវិការរបស់ពួកគេ។

---

អស់នៅក្នុងតុលាការដែលពាក់ព័ន្ធនឹងការវិនិច្ឆ័យ'។ យ៉ាងណាមិញ ចៅក្រម និងជំនួយការរបស់គាត់ គឺជាមនុស្សក្នុងក្រុមនេះឯង។

**២០.** 'អ្នកដែលរស់អាស្រ័យដោយឈ្មោះវណ្ណៈរបស់ខ្លួនតែម្យ៉ាង' គឺ 'មនុស្សដែលមានដើមកំណើតជាព្រាហ្មណ៍ ដែលមិនបានសិក្សាផង និងមិនបានប្រតិបត្តិអំពើណាមួយដែលតម្រូវដោយច្បាប់ពិសិដ្ឋផង'(កុល្លូ., រាឃ.) ឬ 'អ្នកដែលមិនបានធ្វើពិធីចូលជាសមាជិកថ្មី'(នារ.)។ *ព្រាហ្មណព្រុវៈ* 'អ្នកដែលគ្រាន់តែហៅខ្លួនឯងជាព្រាហ្មណ៍ (សូម្បីដើមកំណើតរបស់ខ្លួនមានមន្ទិលក៏ដោយ' តាមលោកកុល្លូ., រាឃ.) ហើយតាមនារ. ថា 'ព្រាហ្មណ៍បានធ្វើពិធីចូលសមាជិកថ្មី តែមិនបានសិក្សា

ព្រះវេទ៎។ មេធ. និងគោវ. ប្រែពាក្យទាំងពីរនេះ សំដៅដល់បុគ្គលតែម្នាក់ ៉សូម្បីតែជាព្រាហ្មណ៍គួរឱ្យស្អប់ ដែលអាស្រ័យតែលើឈ្មោះវណ្ណៈរបស់ខ្លួន៎ ពោលគឺ មិនបានសិក្សាព្រះវេទ មិនបានប្រតិបត្តិពិធីសាសនាជាដើម។ អ្នកអធិប្បាយគូសបញ្ជាក់ថា ដោយសារតែការប្រើប្រាស់សូទ្រៈត្រូវបានហាមឃាត់ដាច់ណាត់ ទើបពួកក្សត្រិយ និងវៃស្យ អាចត្រូវគេប្រើក្នុងករណីចាំបាច់។

**២២.** *សូទ្រភូយិស្ឋំ* ៉ទីណាដែលមានពួកសូទ្រៈដ៏ច្រើន៎(គោវ., កុល្ល., រាឃ.) ហើយតាមមេធ. ថា ៉ទីណាដែលសូទ្រៈ ភាគច្រើនជាអ្នកសម្រេចរឿងក្តីផ្លូវច្បាប់៎តាមនន្ទ. ៉ទីណាដែលមានការប្រើពួកសូទ្រៈច្រើននៅក្នុងតំណែងជាន់ខ្ពស់៎។ នារ. បន្ថែមថា អ្នកសៅហ្មងម្នាក់ៗមានចំនួនកើនឡើងអាចបង្កភាពហិនហោចបាន។

**២៤.** មេធ. និងរាឃ. ធ្វើការបកស្រាយអនុប្រយោគគុណស័ព្ទបន្ថែមមួយទៀត ៉ដោយយល់ថា យុត្តិធម៌ពិតជានាបានគុណប្រយោជន៍ ហើយអយុត្តិធម៌បង្កើតគុណវិបត្តិ៎។ យោងតាមកុល្ល. គឺថា ៉ដោយដឹងនូវអ្វីដែលជាឧបាយ និងអ្វីដែលមិនមែនឧបាយ ប៉ុន្តែយកចិត្តទុកដាក់ចំពោះតែរឿងយុត្តិធម៌ និងអយុត្តិធម៌ប៉ុណ្ណោះ៎។ នារ. និងនន្ទ. នៅតែបកស្រាយដែលគេមិនអាចទទួលយកបាន។ គោវ. ដែលពិចារណាការបកស្រាយខាងលើថាជាការបកស្រាយត្រឹមត្រូវតែមួយគត់ បញ្ជាក់ថា ៉អ្វីដែលជាឧបាយ៎ ដោយ ៉អ្វីដែលធ្វើប្រជារាស្ត្រសប្បាយចិត្ត៎ និង ៉អ្វីដែលមិនមែនជាឧបាយ៎ ដោយ៉អ្វីដែលនឹងធ្វើឱ្យពួកគេខឹងសម្បារ៎ ហើយកុល្ល. និងរាឃ.ថា ៉អ្វីដែលនឹងការពារប្រជារាស្ត្រ៎ និង ៉អ្វីដែលនឹងបំផ្លាញពួកគេ៎។

**២៥-២៦.** យញ្ញ. ជំពូក២ លេខ១៥។

២៦- (ការដំណើរការ)របស់ចិត្តខាងក្នុង អាចឱ្យយើងយល់ដឹងបានតាមរយៈរូបរាងខាងក្រៅ ចលនា ដំណើរ កាយវិការ ពាក្យសម្តី និងចលនាភ្នែក និងទឹកមុខ។

២៧- ព្រះរាជាគួរការពារទ្រព្យមរតកនិងទ្រព្យ(ផ្សេងទៀត)របស់អនីតិជន រហូតដល់អនីតិជននោះបានត្រឡប់មក(ពីផ្ទះរបស់គ្រូខ្លួន)វិញ ឬរហូតដល់គេឆ្លងផុតពីអនីតិភាពរបស់គេ។

២៨- ដូចគ្នានេះដែរ យើងត្រូវតែយកចិត្តទុកដាក់ចំពោះស្ត្រីគ្មានកូន ស្ត្រីដែលគ្មានកូនប្រុស ស្ត្រីដែលគ្រួសារស្លាប់អស់ ចំពោះភរិយានិងស្ត្រីម៉េមាយដែលស្មោះត្រង់ចំពោះម្ចាស់ខ្លួន និងស្ត្រីដែលមានជំងឺ។

២៩- ព្រះរាជាត្រឹមត្រូវ ត្រូវតែដាក់ទោសដូចជាចោរ ចំពោះសាច់ញាតិទាំងឡាយដែលយកទ្រព្យសម្បត្តិរបស់ស្ត្រីបែបនោះ ទាំងក្នុងកំលុងពេលស្ត្រីទាំងនោះនៅរស់រានមានជីវិត។

៣០- ទ្រព្យសម្បត្តិដែលបានបាត់បង់ម្ចាស់ ព្រះរាជាត្រូវឱ្យគេរក្សាទុកក្នុងអំឡុងបីឆ្នាំ ហើយក្នុងអំឡុងបីឆ្នាំ ម្ចាស់ទ្រព្យអាចទាមទារយកវិញបាន បើផុត(រយៈពេលនោះ) ព្រះរាជាអាចយកទ្រព្យនោះបាន។

៣១- អ្នកដែលនិយាយថា ៉នេះជារបស់ខ្ញុំ៎ ត្រូវមានការវិនិច្ឆ័យស្របតាមតម្រាច្បាប់ បើសិនជាគេរៀបរាប់រូបរាងនិងចំនួន(របស់នោះ)ជាដើមបានត្រឹមត្រូវ (អ្នកនោះគឺជា)ម្ចាស់ (ហើយគួរ)ទទួលបានទ្រព្យនោះវិញ។

---

**២៥.** គោវ. លុបពាក្យ *ស្វរៈ* ៉សំឡេង៎ ហើយសរសេរ *មុខៈ* ៉ដោយពន្លឺពណ៌ផ្ទៃមុខ៎។ *ឥង្គិតៈ* ៉ចលនា៎ ដូចជា ៉ការញ័រ ការព្រឺស្បែកព្រឺរោមជាដើម៎(មេធ., គោវ., រាឃ.) ឬ៉ការសម្លឹងចុះក្រោមជាដើម៎(កុល្ល.) ឬ៉ការកម្រើដៃដោយអចេតនា៎ (នារ.)។ *អាការៈ* ទិដ្ឋភាពខាងក្រៅ៎ គឺ ៉សម្បុរស្លាំងជាដើម៎(គោវ.) ឬ ៉ការបែកញើស, ការព្រឺស្បែកព្រឺរោមជាដើម៎ (កុល្ល., នារ.)។ មេធ. និងរាឃ. ប្រែពាក្យ *អាការៈ* ថា ៉លក្ខណៈ៎សំឡេងជាដើម មិនមែនជាប្រភេទសញ្ញាដោយឡែកទេ។ *ចេស្តិតៈ* ៉កាយវិការ៎ គឺ ៉ការធ្វើចលនា កម្រើកដៃជាដើម៎(គោវ., កុល្ល., រាឃ.) ឬ ៉ការធ្វើចលនាដោយចេតនា៎(នារ.)។

**២៧-២៩.** គោត. ជំពូក១០ លេខ៨៤; វស. ជំពូក១៦ លេខ៨; វិ. ជំពូក៣ លេខ៦៥។

**២៧.** 'អនីតិភាព ចប់ត្រឹមវ័យគ្រប់ដប់ប្រាំមួយឆ្នាំ'(កុល្លុ., នារ.) សូមមើល *នារទ* ជំពូក៣ លេខ៣៧។ ពាក្យទីពីរ សំដៅដល់ករណីរបស់អ្នកដែលបញ្ចប់ការសិក្សាព្រះវេទរបស់ខ្លួនមុនវ័យដប់ប្រាំមួយឆ្នាំ(មេធ., កុល្លុ.) ឬ សូទ្រៈ (មេធ.)។

**២៨.** 'អ្នកដែលគ្រួសារស្លាប់អស់' គឺ 'ស្រីក្រមុំក្នុងលក្ខខណ្ឌនេះ'(គោវ.) ឬ 'អ្នកដែលបានបោះបង់គ្រួសាររបស់ខ្លួន ហើយក្លាយជាស្រីពេស្យា'(មេធ. ថា 'អ្នកផ្សេងទៀត')។ 'ភរិយាដែលស្មោះត្រង់ចំពោះម្ចាស់ខ្លួន' គឺ 'អ្នកដែលប្តីមិននៅ'(គោវ., រាឃ.)។ លក្ខខណ្ឌការពាររបស់ព្រះមហាក្សត្រិយ មានគ្រប់ករណីដែលសាច់ញាតិស្លាប់ក៏បាន ឬដែលមិនអាចផ្គត់ផ្គង់ស្ត្រីទាំងនោះក៏បាន ឬព្យាយាមជិះជាន់ពួកគេក៏បាន។

**៣០-៣៤.** អាប. ជំពូក២ លេខ២៨, ៧-៩; គោត. ជំពូក១០ លេខ៣៦-៣៨; វស. ជំពូក១៦ លេខ២០; យញ្ញ. ជំពូក២ លេខ៣៣។

**៣០.** 'ទ្រព្យដែលបានបាត់ម្ចាស់' តាមអ្នកអធិប្បាយមានន័យថា 'ទ្រព្យសម្បត្តិដែលរាជការបានរកឃើញ (នៅក្នុងព្រៃឬនៅកន្លែងណាមួយ លោកមេធ. ថា គេមិនបានស្គាល់ម្ចាស់ទ្រព្យ'។ គេនឹងប្រកាសប៉ាវគងទូងស្គរកទ្រព្យសម្បត្តិបែបនេះ (គោវ.,កុល្លុ.)។'អ្នកដទៃ'តាមការដកស្រង់របស់លោកមេធ.គឺថា បន្ទាប់ពីរយៈពេលបីឆ្នាំព្រះរាជាអាចប្រើប្រាស់ ទ្រព្យនោះជារបស់ទ្រង់បាន ប៉ុន្តែនៅតែរក្សាទុកទ្រព្យនោះដដែល ប្រសិនបើម្ចាស់បង្ហាញមុខ។ នន្ទ. គូសបញ្ជាក់ថា តម្រាសិក្ខា មិនសំដៅដល់ទ្រព្យរបស់ព្រាហ្មណ៍ទេ (សូមមើលសំណេរដែររបស់គោត.)។

៣២- ប៉ុន្តែបើអ្នកមិនដឹងពេលវេលានិងទីកន្លែងបាត់របស់ មិនដឹងពណ៌ ទម្រង់និងទំហំរបស់ពិតប្រាកដទេ អ្នកនោះនឹងសមទទួលពិន័យស្មើនឹងតម្លៃ(វត្ថុដែលទាមទារ)នោះ។

៣៣- ឥឡូវព្រះរាជា ដោយរំលឹកពីករណីយកិច្ចមនុស្សល្អ អាចទទួលបានមួយភាគប្រាំមួយនៃទ្រព្យដែលបាត់ និងបន្ទាប់ពីរកឃើញឬមួយភាគដប់ ឬយ៉ាងហោចមួយភាគដប់ពីរ។

៣៤- ទ្រព្យបាត់ និងបន្ទាប់ពីការរកឃើញ(ដោយរាជការរបស់ព្រះរាជា) នឹងរក្សាទុកនៅជាមួយមន្ត្រី (ពិសេស) ហើយអ្នកដែលព្រះរាជាអាចកាត់ទោសពីបទលួចទ្រព្យនោះ ទ្រង់គួរប្រទានទោសស្លាប់ឱ្យដំរីជាន់។

៣៥- ព្រះរាជាអាចដកហូតមួយភាគប្រាំមួយ ឬមួយភាគដប់ពីរពីអ្នកដែលនិយាយត្រូវអំពីកំណប់បាត់នោះ ថា 'នេះជារបស់ខ្ញុំ'។

៣៦- ប៉ុន្តែអ្នកដែលនិយាយមិនពិត នឹងត្រូវពិន័យមួយភាគប្រាំបីនៃទ្រព្យរបស់ខ្លួន ឬតាមការគណនា (នៃតម្លៃ)ទ្រព្យនោះ តាមចំណែកមួយតូចជាង(តម្លៃទ្រព្យនោះ)។

៣៧- បើសិនព្រាហ្មណ៍ដែលចេះដឹងច្រើន បានឃើញវត្ថុមានតម្លៃដែលគេទុកចោលពី (ពេល) មុន គាត់អាចយកវត្ថុនោះទាំងអស់បាន ព្រោះគាត់ជាម្ចាស់នៃអ្វីៗទាំងអស់។

៣៨- បើសិនព្រះរាជាប្រទះឃើញវត្ថុមានតម្លៃ ដែលគេកប់ចោលក្នុងដីពីមុន ចូរទ្រង់ឱ្យពាក់កណ្តាលទៅព្រាហ្មណ៍ និងយកពាក់កណ្តាល (ទៀត) ដាក់ក្នុងឃ្លាំងរបស់ទ្រង់។

៣៩- ព្រះរាជាទទួលបានពាក់កណ្តាលនូវវត្ថុដែលគរទុក និងលោហធាតុពីបុរាណ(កប់)ក្នុងដី ដោយហេតុផល(ទ្រង់ជាអ្នកផ្តល់)ការការពារ និងព្រោះថាទ្រង់ជាម្ចាស់ផែនដី។

**៣៣.** ចំនួនដែលព្រះរាជាត្រូវដកហូត តាមលោកមេធ. គឺអាស្រ័យលើរយៈពេលថែរក្សារបស់នោះ (លោករាឃ. ក៏យល់ដូច្នេះដែរ) ឬគុណនឹងពីរ (តាមការយល់របស់គោវ.) និងតាមព្រះទ័យករុណារបស់ព្រះរាជា ហើយយោងតាមកុល្ល. និងនារ. អាស្រ័យលើគុណធម៌របស់ម្ចាស់។ មេធ. ដាក់កាព្យនេះនៅក្រោយកាព្យលេខ៣៤។
**៣៥-៣៩.** គោត. ជំពូក១០ លេខ៤៣-៤៥; វស. ជំពូក៣ លេខ១៣-១៤; វិ. ជំពូក៣ លេខ៥៦-៦៤; យញ្ញ. ជំពូក២ លេខ៣៤-៣៥។
**៣៥.** ‵កំណប់គ្មានម្ចាស់′ គឺ ‵វត្ថុមានតម្លៃដែលកប់ចោលក្នុងដីជាសម្ងាត់′(មេធ.)។ ចំនួនដែលត្រូវដកយក អាស្រ័យលើ ‵ចិត្តបុណ្យ′របស់អ្នករកឃើញ(មេធ., គោវ., កុល្ល., រាឃ.) ឬស្ថិតលើវណ្ណៈរបស់គាត់(នារ.) ឬអាស្រ័យលើទីកន្លែង និងពេលវេលា វណ្ណៈជាដើម(គោវ.)។
**៣៦.** ចំនួនពិន័យអាស្រ័យលើព្រឹត្តិការណ៍ករណី ឬ ‵គុណធម៌′របស់អ្នករក្សាការពារប៉ុណ្ណោះ(គោវ., កុល្ល., រាឃ.)។
**៣៧.** មេធ., គោវ., នារ. ប្រែដូចលោកកុល្ល. ដោយគូសបញ្ជាក់ពាក្យ *បូរវបនិហិតំ* មិនសមទំនងថា ‵ទុកចោលពីដូនតារបស់គាត់′។ សេចក្តីប្រហែលគ្នានៅក្នុងគម្ពីរវិស្ណុ និងគម្ពីរដទៃ និយាយច្បាស់ពីចំណុចនេះ។
**៣៩.** ខ្ញុំប្រែអនុប្រយោគចុងក្រោយ ក្នុងន័យថា ‵(ហើយ)ព្រោះទ្រង់ជាម្ចាស់ផែនដី′ ដែលជាការទទួលស្គាល់គោលការណ៍ជាក់ស្តែងថា កម្មសិទ្ធិដីធ្លីទាំងអស់ជារបស់ព្រះរាជា។ មេធ. និយាយថា ‵ទ្រង់ជាម្ចាស់ផែនដី(ព្រះ*ភូមី*) ពោលគឺថា ចំណែកត្រូវថ្វាយទ្រង់ គឺពាក់ព័ន្ធដីរបស់ទ្រង់ (*តទីយាយា ភូវោ យល្លត្វំ*)′។

៤០- ទ្រព្យដែលចោរលួច ព្រះរាជាត្រូវរកមកឱ្យ(មនុស្ស)គ្រប់វណ្ណៈ ហើយព្រះរាជាដែលប្រើប្រាស់(ទ្រព្យ)ប្រភេទនេះដោយព្រះអង្គឯង នឹងមានទោសជាចោរ។
៤១- (ព្រះរាជា) ដែលចេះច្បាប់ពិសិដ្ឋ ត្រូវតែដឹកសួរច្បាប់ពាក់ព័ន្ធនឹងវណ្ណៈ (គាតិ) តំបន់ មុខរបរ និងគ្រួសារ (ហេតុនេះ)ហើយទើបដោះស្រាយករណីនីមួយៗតាមច្បាប់។
៤២- ព្រោះមនុស្សដែលប្រកបរបរពិសេសរបស់ខ្លួន និងប្រតិបត្តិតាមករណីយកិច្ចពិសេសរបស់ខ្លួន នឹងជាទីស្រឡាញ់របស់អ្នកផងទាំងពួង សូម្បីពួកគេរស់នៅឆ្ងាយក៏ដោយ។
៤៣- មិនមែនព្រះរាជា និងមិនមែនរាជការណាមួយរបស់ទ្រង់ផ្តើមធ្វើបណ្តឹង ឬបំបិទចោលក្តី ដែលអ្នកដទៃ(ណាមួយ)បានប្តឹង(នៅចំពោះមុខពួកគេ)ទេ។

---

**៤០.** អាប. ជំពូក២ លេខ២៦, ៨; គោត. ជំពូក១០ លេខ៤៦-៤៧; វិ. ជំពូក៣ លេខ៦៦-៦៧; យញ្ញ.ជំពូក២លេខ៣៦។ ពោលគឺ ‵បើទ្រង់បានរបស់នោះមកវិញ′(មេធ., គោវ., កុល្ល., នារ., រាឃ., នន្ទ.)។ មេធ. អាន *ចោរីហ្ធតំ* និងសរសេរអំណានមួយទៀត *ចោរហ្ធតំ* ដែលរាឃ. សរសេរ និងគិតថា អាចមានន័យថា ព្រះរាជាត្រូវតែលៃលករកទ្រព្យចោរលួចដែលមិនទាន់រកឃើញនោះ ដោយប្រពៃ។
**៤១.** អាប. ជំពូក២ លេខ១៥, ១; គោត. ជំពូក១១ លេខ២០; វស. ជំពូក១៩ លេខ៧; ពោធ. ជំពូក១ លេខ២, ១-៨; វិ. ជំពូក ៣ លេខ៣; យញ្ញ. ជំពូក១ លេខ៣៦០។ ពាក្យ *គាតិ* ‵វណ្ណៈ′ គឺ ‵ព្រាហ្មណ៍ជាដើម′(កុល្ល., នារ., រាឃ., នន្ទ.)។ ពាក្យ*គានបទ* ‵ច្បាប់ប្រចាំតំបន់ ឧទាហរណ៍ ដែនកុរុ, កាសី ឬ កាស្មីរ′(មេធ.) ឬ ‵តំបន់មួយចំនួន′(តាមគោវ., កុល្ល., រាឃ. ថា *ទេសៈ*) ឬ ‵របស់អ្នកស្រុកនៅដែនមួយ និងភូមិតែមួយ′(នារ.)។ មេធ. ក៏ផ្តល់ការបកស្រាយម្យ៉ាងទៀត ចំពោះពាក្យសមាស *គាតិគានបទាន*នៃវណ្ណៈនៅមូលដ្ឋាន′ ឬ ‵អ្នកស្រុកដើមនៃដែនដីនានា′។ *ស្រេណី* ‵សមាគមមុខរបរ′ គឺ ‵របស់ពាណិជ្ជករជាដើម′(មេធ., កុល្ល., នារ., រាឃ.) ឬ ‵របស់អ្នកលក់ដូរ និងអ្នកស្រែជាដើម′(គោវ.) ឬ ‵របស់អ្នកលក់ដូរនិងអ្នកសម្តែងជាដើម′(នន្ទ.)។ រាឃ. អាន *បរិបាលយេត* ‵ហើយការពារច្បាប់ពិសេសរបស់ក្រុមនីមួយៗ′។ ការពិតគេអាចយល់ថា ទំនៀមទម្លាប់មិនត្រូវផ្ទុយនឹងច្បាប់ពិសិដ្ឋទេ(មេធ., គោវ., កុល្ល., រាឃ.)។

**៤៣.** គោត. ជំពូក១៣ លេខ២៧។ `(មនុស្ស)ដទៃណាមួយ´ គឺ `ដើមបណ្តឹង´(មេធ.) `ដើមបណ្តឹង ឬចុងចោទ´(កុល្ល.) ឬ `គូក្តីណាក៏ដោយ´។ `អ្នកដទៃ´បកស្រាយកាព្យពាក់កណ្តាលទីពីរ យោងតាមលោកមេធ. គឺ `ហើយចូរទ្រង់ទទួលលុយដែលគេថ្វាយទ្រង់ តាមរបៀបមួយដើម្បីឈ្នះក្តី´។

# ច្បាប់រដ្ឋបវេណី និងព្រហ្មទណ្ឌ

CIVILANDCRIMINALLAW

៤៤- ឧបមាដូចអ្នកប្រមាញ់តាមរកកន្លែងលាក់ខ្លួនរបស់ក្តាន់(របួស) តាមស្នាមឈាម ដូច្នេះព្រះរាជាក៏គួររកឱ្យឃើញសិទ្ធិថាតើសិទ្ធិនឹងធ្លាក់ទៅខាងណា ដោយការពិចារណា(ទឹកមុខ)។

៤៥- នៅពេលចូលក្នុងដំណើរការវិនិច្ឆ័យក្តី ទ្រង់ត្រូវយកចិត្តទុកដាក់ទាំងស្រុងចំពោះការពិត ចំពោះកម្មវត្ថុ(វិវាទ) (និង)ពិចារណាក្នុងព្រះទ័យទ្រង់ បន្ទាប់មកចំពោះសាក្សី ទីកន្លែង ពេលវេលា និងទិដ្ឋភាពកើតហេតុ។

៤៦- អ្វីដែលមនុស្សល្អអាចអនុវត្តបាន គឺអ្នកមានកំណើតពីរដងនេះ ត្រូវមានភក្តីភាពចំពោះច្បាប់ ទ្រង់នឹងបង្កើតវាឡើងជាច្បាប់ ប្រសិនបើវាមិនផ្ទុយនឹង(ទំនៀមទម្លាប់)របស់ដែនដី គ្រួសារនិងវណ្ណៈ(គាតិ)។

៤៧- នៅពេលម្ចាស់បំណុលប្តឹង(នៅចំពោះព្រះភក្ត្រ) សុំឱ្យកូនបំណុលសងលុយវិញ ចូរទ្រង់តម្រូវឱ្យកូនបំណុលសងលុយតាមចំនួនដែលម្ចាស់បំណុលបង្ហាញភស្តុតាងគ្រប់គ្រាន់។

៤៨- ម្ចាស់បំណុលអាចទទួលបានទ្រព្យរបស់ខ្លួនវិញដោយមធ្យោបាយណាក៏ដោយ គាត់អាចបង្ខំកូនបំណុល ដោយមធ្យោបាយទាំងនោះ ដើម្បីឱ្យកូនបំណុលសងវិញ។

៤៩- ដោយការអន្ទងខាងផ្លូវសីលធម៌ ដោយការប្តឹងតាមផ្លូវច្បាប់ ដោយការប្រើឧបាយ ឬដោយប្រើនីតិវិធីតាមទំនៀមទម្លាប់ ម្ចាស់ជំនួយអាចទារទ្រព្យជំពាក់បាន ហើយទីប្រាំ ដោយវិធីបង្ខំ។

---

**៤៤.** លោកកុល្ល. និងរាឃ. ប្រែដូច្នេះ។ ប៉ុន្តែលោកមេធ. និងគោវ. ប្រែកាព្យនេះផ្សេងពីនេះបន្តិច `បីដូចអ្នកប្រមាញ់តាមដានស្នាមសត្វក្តាន់(របួស)´ជាដើម។

**៤៥.** `ការពិត´ គឺ `ដោយកុំឱ្យមានការបន្លំ´(កុល្ល., រាឃ.) ឬ `អ្វីដែលជាចំណែក(នៃរឿងក្តីនេះ) គឺផ្អែកលើការពិត´(នារ., នន្ទ.)។ *អាថ៌*កម្មវត្ថុវិវាទ´ គឺ `ប្រសិនបើវាគ្មានន័យសោះ ក្នុងករណីថា គេមិនត្រូវទទួលយកពាក្យត្អូញត្អែរ´(មេធ., គោវ., កុល្ល., រាឃ.)។ នារ. បកស្រាយ *អាថ៌* ថា `ចរិកាដែលបានពីការពិន័យ និងផ្សេងៗ´ ហើយនន្ទ. ថា `បំណង´។ `ព្រះអង្គឯង´ គឺ `ថា ទ្រង់នឹងឡើងឋានសួគ៌ ដោយការវិនិច្ឆ័យត្រឹមត្រូវ´(កុល្ល., រាឃ.)។ `ទីកន្លែង និងពេលវេលា´ គឺ `អ្វីៗដែលស៊ីគ្នានឹងទីកន្លែង និងពេលវេលា´(កុល្ល.) ឬ `ទីកន្លែង ឧទាហរណ៍ *ពនារៈ* និងពេលវេលា (ឧ.ទា. ក្នុងពេលគ្រោះទុរ្ភិក្ស) ជាកន្លែងនិងពេលកើតបទល្មើស និងអ្វីដែលអាចធ្វើឱ្យរឿងក្តីកាន់តែមានពន្លឺ ឬកាន់តែមានទម្ងន់´(មេធ., នន្ទ.) ឬ `ទំនៀមទម្លាប់របស់ប្រទេស និងអ្វីដែលសមស្របនឹងពេលវេលា´(នារ.) ឬ `ទីកន្លែងដែលកើតបទល្មើស និងអាយុរបស់ជនល្មើស´ (គោវ.)។ ពាក្យ *រូបំ* `ទិដ្ឋភាព´ គឺ `លក្ខណៈនៃកម្មវត្ថុ´(មេធ., នន្ទ.) ឬ `ចរិតលក្ខណៈរឿងក្តី´(កុល្ល.) ឬ `ទឹកមុខរបស់គូភាគី´ (មេធ., គោវ., នារ., រាឃ. និងអ្នកដទៃ)។

**៤៦.** លោកកុល្ល., នារ.,រាឃ.និងនន្ទ. បកស្រាយដូច្នេះ។ ប៉ុន្តែលោកមេធ. ប្រែកាព្យនេះផ្សេងថា `អ្វីដែលមនុស្សល្អ និងអ្នកមានកំណើតពីរដង បានប្រព្រឹត្ត... នោះទ្រង់នឹងបង្កើតវាជាច្បាប់សម្រាប់ប្រទេស គ្រួសារ និងវណ្ណៈ ប្រសិនបើវាមិនផ្ទុយ

(នឹងអត្ថបទស្រុតិ និងស្រ្មិតិ’។ គោវ. អាន *អនុរូបំ* ‘អនុលោមតាម’ ជំនួសពាក្យ *អរិរុំទំ* ‘មិនផ្ទុយ’ ហើយហាក់ដូចជា ស្រប នឹងលោកមេធ.។ លោកនិយាយថា ‘ដូច្នេះហើយចូរទ្រង់ដាក់ទណ្ឌកម្មគូក្តី ដែលប្រព្រឹត្តផ្ទុយក្នុងដំណើរការក្តី’ ហើយដូច ឃ្លានៅទីនេះ គេប្រើ‘អ្វីដែលមនុស្សប្រព្រឹត្ត’ (វិធាន)នេះ ត្រូវតែសំដៅដល់ការប្រព្រឹត្តល្អ។ ប៉ុន្តែវិធាន ដែលមាននៅក្នុង កាព្យ ៤១នេះ ត្រូវសំដៅដល់ច្បាប់ មិន(ពាក់ព័ន្ធនឹង)ការប្រព្រឹត្តល្អទេ។

**៤៩.** *វ្យវហារេណ* ‘ដោយការប្តឹង’(គោវ., កុល្ល., នារ.) ឬ‘ដោយការគំរាមប្តឹង’(នន្ទ.) ឬ‘ដោយឱ្យធ្វើការដោយបង្ខំ’(មេធ.)

៥០- ព្រះរាជាមិនត្រូវបន្ទោសម្ចាស់បំណុល ដែលទារសំណងទ្រព្យរបស់ខ្លួនដោយផ្ទាល់ពីកូន បំណុលខ្លួន ពីបទទារយកអ្វីដែលជារបស់ខ្លួននោះទេ។

៥១- ប៉ុន្តែដាក់ទោសអ្នកដែលបដិសេធសងបំណុលដែលមានភស្តុតាងច្បាស់លាស់ ទ្រង់គួរបញ្ជាឱ្យសងបំណុលនោះទៅម្ចាស់បំណុល និងពិន័យមួយចំនួនតូច ស្របតាមព្រឹត្តិការណ៍របស់ខ្លួន។

៥២- ចំពោះការបដិសេធរបស់កូនបំណុលមិនព្រមសងបំណុលតាមការតម្រូវរបស់តុលាការ អ្នកប្តឹងត្រូវហៅ(សាក្សី)ដែលមានវត្តមាន (ក្នុងពេលផ្តល់កម្ចី) ឬបង្ហាញភស្តុតាងផ្សេងៗ។

៥៣- (ដើមបណ្តឹង) ដែលហៅសាក្សី មិនមានវត្តមានក្នុងការខ្ចី ដែលប្រកែកនឹងពាក្យសម្តីរបស់ខ្លួន ឬមិនដឹងថា ពាក្យសម្តីរបស់ខ្លួនមានការបំភាន់ ឬមានន័យផ្ទុយ;

៥៤- ឬដោយបានអះអាងនូវអ្វីដែលគាត់ចង់ផ្តល់កសិណនោះ ក្រោយមកប្រែ (ខុសពីករណីរបស់ខ្លួន)ឬដែលត្រូវបានសួរអំពីហេតុការណ៍ដែលបានអះអាងត្រឹមត្រូវ មិនគោរពតាមពាក្យនោះ;

៥៥- ឬដែលនិយាយជាមួយសាក្សីក្នុងកន្លែងមិនសមគួរសម្រាប់ការសន្ទនាបែបនេះ ឬដែលបដិសេធមិនឆ្លើយសំណួរត្រឹមត្រូវ ឬដើរចេញពី(តុលាការ);

៥៦- ឬមានការបញ្ជាឱ្យនិយាយ តែមិនព្រមឆ្លើយ ឬមិនព្រមបញ្ជាក់នូវអ្វីដែលគាត់បានចោទ ឬដែលមិនដឹងនូវអ្វីដែលជា(ចំណុច)ទីមួយ ហើយអ្វីជាចំណុចទីពីរ មិនមាននៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។

៥៧- ព្រមទាំងអ្នកដែលនិយាយថា ‘ខ្ញុំមានសាក្សី’ និងដោយមានបញ្ជាឱ្យធ្វើសាក្សី មិនធ្វើសាក្សី ចៅក្រមត្រូវប្រកាស ដោយផ្អែកលើមូលដ្ឋាន(ដូចគ្នា)នេះ ថាមិនត្រឹមត្រូវទេ។

---

ឬ ‘ដោយការលក់ទ្រព្យដោយបង្ខំ’(រាឃ.)។ *អាចារិត* ‘ការប្តឹងតាមទំនៀមទម្លាប់’ គឺ ‘ដោយការសម្លាប់ភរិយា កូន និងសត្វពាហនៈរបស់នរណាម្នាក់ និងអង្គុយនៅមាត់ទ្វាររបស់កូនបំណុល’។ *ព្រិហស្បតិ* ដែលលោកកុល្ល. និងរាឃ. បានដកស្រង់ ឬ ‘ដោយតមអាហារ’(គោវ.) ឬ ‘ដោយម្ចាស់បំណុលបង្អត់អាហារខ្លួនឯងដល់ស្លាប់’(នារ.)។ ទំនៀមទម្លាប់នេះ ស្របគ្នានឹងពាក្យ *ប្រាយោបវេសន* ឬ *ធរណា* និង *ត្រគ* នៃពាក្យកាព្យ។

**៥០.** វិ. ជំពូក៦ លេខ១៩; យញ្ញ. ជំពូក២ លេខ៤០។

**៥១.** ‘ក្នុងករណីនេះ ការជួយខ្លួនឯងមិនត្រូវយកមកប្រើទេ’(មេធ.)។ ចំពោះចំនួនប្រាក់ពិន័យ សូមមើលកាព្យលេខ១៣៩ ខាងក្រោម។

**៥២.** ជំនួសពាក្យ *ទេស្យំ* ‘(សាក្សី) ដែលមានវត្តមាន(ក្នុងពេលធ្វើកម្ចី)’(K., រាឃ., កុល្ល.) ហើយមេធ., គោវ., នារ. និង នន្ទ. អាន *ទេសំ* ‘(ត្រូវតែបង្ហាញ)ទីកន្លែង’។

**៥៣-៥៦.** យញ្ញ. ជំពូក២ លេខ១៦។

**៥៣.** មេធ., គោវ., នារ. និងនន្ទ. អាន *អបទេសំ* 'កន្លែងមិនពិត ឬកន្លែងខុស' ជំនួសពាក្យ *អទេស្យំ* សាក្សីដែលគ្មានវត្តមាន'។ កុល្ល. អានតាមអត្ថបទបោះពុម្ព '*អទេស្យំ* ប៉ុន្តែការបកស្រាយរបស់គាត់ស្របគ្នានឹងអំណានផ្សេងទៀត។
**៥៤.** *ប្រណិហិតំ* 'អះអាងត្រឹមត្រូវ(ដោយខ្លួនគាត់)'(កុល្ល., នន្ទ.) គឺ 'មាននៅក្នុងបណ្ដឹង'(គោវ.) ហើយតាមរាឃ. និងនារ. 'ដែលបញ្ជាក់ត្រឹមត្រូវ'។
**៥៦.** 'អ្នកដែលមិនដឹងនូវអ្វីដែលជា(ចំណុច)ទីមួយ និងអ្វីជាចំណុចទីពីរ' គឺ 'អ្វីជាភស្តុតាង និងបញ្ហាអ្វីដែលត្រូវបញ្ជាក់'(កុល្ល., រាឃ.) ឬ 'អ្វីដែលគេគួរនិយាយទីមួយ និងអ្វីដែលគេគួរនិយាយបន្ទាប់'(នារ., នន្ទ.)។

៥៨- ប្រសិនបើដើមចោទមិននិយាយ គេអាចទទួលទោសការដាក់ទណ្ឌកម្មរូបកាយ ឬពិន័យស្របតាមច្បាប់ ហើយប្រសិនបើ(ចុងចោទ)មិនសារភាពក្នុងអំឡុងប្រាំមួយសប្ដាហ៍ គេនឹងចាញ់ក្ដីរបស់ខ្លួន។

៥៩- ក្នុងចំនួនទ្វេដងដែល(ចុងចោទ)បដិសេធខុសពីការពិត ឬដែល(ដើមចោទ) អះអាងខុសពីការពិត ព្រះរាជាគួរដាក់ពិន័យ(អ្នក)ទាំងនោះ ដែលហ៊ានបំពានយុត្តិធម៌។

៦០- (ចុងចោទ) ដែលត្រូវម្ចាស់បំណុលប្ដឹងឡើង(តុលាការ) (ហើយ)ត្រូវចោទសួរនោះ បដិសេធ(បំណុល) នឹងត្រូវកាត់ទោសពី(បទភូតកុហករបស់ខ្លួន) យ៉ាងហោចដោយមានសាក្សីបីនាក់(ដែលត្រូវឆ្លើយ)នៅចំពោះមុខព្រាហ្មណ៍ (ដែលទទួលការតែងតាំងពីព្រះមហាក្សត្រិយ)។

៦១- ខ្ញុំនឹងប្រកាសទាំងស្រុងនូវមនុស្សប្រភេទណាដែលអាចធ្វើជាសាក្សីក្នុងរឿងក្ដីរបស់ម្ចាស់បំណុល ហើយតើ(សាក្សី)នោះត្រូវផ្ដល់(ភស្តុតាង)ពិតប្រាកដតាមរបៀបណា។

៦២- ឃរាវាស មនុស្សដែលមានបញ្ញាភេទ និងអ្នកស្រុក(នៃប្រទេស ពួកគេជា)ក្សត្រិយ វៃស្យ ឬសូទ្រៈ មានសមត្ថភាពពេលអ្នកប្ដឹងកោះហៅ ដើម្បីផ្ដល់ភស្តុតាង មិនមែនអ្នកដែល (មានស្ថានភាពរបស់ខ្លួន)អ្វីក៏ដោយនោះទេ លើកលែងតែក្នុងករណីបន្ទាន់។

៦៣- មនុស្សគួរឱ្យទុកចិត្តនៃវណ្ណៈទាំង (បួន) អាចធ្វើជាសាក្សីក្នុងរឿងក្ដីបាន (អ្នក) ដែលដឹងពីករណីយកិច្ចទាំងស្រុងរបស់ខ្លួន ហើយគ្មានសេចក្ដីលោភលន់ ប៉ុន្តែចូរទ្រង់បដិសេធអ្នកទាំងឡាយដែលមាន(ចរិតលក្ខណៈ)ទទឹងរឹងរូស។

៦៤- មិនត្រូវអនុញ្ញាតឱ្យធ្វើជា (សាក្សី) ចំពោះអ្នកដែលមានផលប្រយោជន៍ក្នុងរឿងក្ដី មិនមែនជា(មិត្តភ័ក្ដិ)សិទ្ធិស្នាល មិនមែនជា(អ្នក)ដែលមានជំងឺ(ធ្ងន់ធ្ងរ) និងមិនមែនជា (អ្នក)ដែលមាន(បាបកម្មធ្ងន់ធ្ងរ)។

---

**៥៨.** 'បើសិនដើមចោទមិននិយាយ' គឺ'បន្ទាប់ពីដាក់ពាក្យបណ្ដឹង'(កុល្ល.)។ ទណ្ឌកម្មរូបកាយ ជាករណីធ្ងន់ធ្ងរ(កុល្ល.)។
**៥៩.** យញ្ញ. ជំពូក២ លេខ៥៩។
**៦០.** លោកគោវ., កុល្ល., រាឃ. និយាយដូច្នេះដែរ ប៉ុន្តែពាក្យចុងក្រោយក៏អាចមានន័យ'ក្នុងវត្តមានព្រះរាជានិងព្រាហ្មណ៍'។
**៦១-៧២.** អាប. ជំពូក២ លេខ២៩, ៧; គោត. ជំពូក១៣ លេខ១-៤; វស. ជំពូក១៦ លេខ២៨-៣០; ពោធ. ជំពូក១ លេខ១៩, ១៣; វិ. ជំពូក៣ លេខ៧-៩; យញ្ញ. ជំពូក២ លេខ៦៨-៧២។
**៦២.** មេធ. និងនារ. បញ្ជាក់សំនួនវោហារ 'មិនមែនអ្នក(ដែលអាចមានស្ថានភាពរបស់ខ្លួន)ណាក៏ដោយ' សំដៅដល់អ្នកស្មគ្រចិត្តផ្ដល់ភស្តុតាង ដោយមិនចាំបាច់មានការកោះហៅ។ 'ករណីបន្ទាន់' មានបញ្ជាក់នៅខាងក្រោម កាព្យ៦៩។
**៦៤.** 'អ្នកដែលមានផលប្រយោជន៍ក្នុងរឿងក្ដី'(នារ.) ហើយតាមលោកមេធ., គោវ., កុល្ល. និងរាឃ. ថា 'ដែលពាក់ព័ន្ធនឹងលុយកាក់ គឺម្ចាស់បំណុល ឬកូនបំណុលដែលជាភាគី' ឬយោងតាមនន្ទ. ថា 'អ្នកដែលបានទទួលប្រយោជន៍ពីភាគី

ម្ខាង’។ ពាក្យ *សហាយ* ‘គូកន’ គឺ ‘អ្នកជានាជាដើម’(មេធ.) ឬ ‘អ្នកបម្រើ’(កុល្ល., នារ.)។ *ទូស្តទោស* ‘អ្នកដែលធ្លាប់មានទោសពី មុន(ពីបទភូតកុហកតុលាការ)’(មេធ., គោវ., កុល្ល., នារ., រាឃ., នន្ទ.) ហើយតាមមេធ. ក៏អាចមានន័យថា ‘អ្នកដែលធ្លាប់បានត្រូវកាត់ទោស(ពីបទល្មើលធ្ងន់ធ្ងរណាក៏ដោយ)’។ អ្នកដែលមានជំងឺធ្ងន់ធ្ងរមិនត្រូវអនុញ្ញាតឱ្យធ្វើសាក្សីទេ ព្រោះមនុស្សបែបនេះងាយនឹងខឹង ឬភ្លេច ដូច្នេះអាចផ្តល់ភស្តុតាងមិនពិត(មេធ.)។ *ទូសិត* ‘ដែលមានស្នាម’ គឺការប្រព្រឹត្តឧក្រិដ្ឋកម្មប៉ះពាល់ជីវិត ឬបទល្មើសតូចៗជាច្រើន(មេធ., កុល្ល., រាឃ.) ហើយតាមលោកនារ. និងនន្ទ. ថា *អភិសស្ត្រ*អ្នកទាំងឡាយដែលជាប់ចោទបទឧក្រិដ្ឋបែបនេះ’។

៦៥- ព្រះរាជា យន្តការី និងអ្នកសម្តែង ស្រោត្រិយ សិស្សដែលសិក្សាព្រះវេទ និងតាបសដែលបានផ្តាច់ទំនាក់ទំនង(លោកិយនេះ) មិនអាចធ្វើជាសាក្សីបានទេ,

៦៦- ហើយអ្នកដែលចំណុះទាំងស្រុង អ្នកដែលមានកេរ្តិ៍ឈ្មោះអាក្រក់ ទស្យុ អ្នកដែលប្រកបរបរហោមឃាត់ មនុស្សចាស់ជរា កូនក្មេង មនុស្ស(ឯកោ) មនុស្សដែលមានវណ្ណៈទាបបំផុត និងអ្នកដែលគ្មានគ្រឿងវិញ្ញាណគ្រប់គ្រាន់ មិនអាចធ្វើជាសាក្សីបានដែរ,

៦៧- (មិនអាចធ្វើជាសាក្សីបាន)ចំពោះអ្នកដែលមានទុក្ខសោកហួសហេតុ អ្នកស្រវឹងខ្ទប មនុស្សឆ្កួត អ្នកដែលស្រេកឬឃ្លានពេក អ្នកដែលអស់កម្លាំង អ្នកដែលលោភលន់ អ្នកដែលក្រេវក្រោធ និងចោរ។

៦៨- ស្ត្រីគួរផ្តល់ភស្តុតាងឱ្យស្ត្រី និងសម្រាប់បុរសមានកំណើតពីរដង ហើយអ្នកមានកំណើតពីរដង (អាចផ្តល់កសិណឱ្យគ្នាបាន) សូទ្រៈល្អអាចផ្តល់កសិណដល់សូទ្រ ហើយមនុស្សដែលមានវណ្ណៈទាបបំផុត អាចផ្តល់កសិណដល់អ្នកដែលមានវណ្ណៈទាបបំផុត។

៦៩- ប៉ុន្តែបុគ្គលណាដែលដឹងដោយខ្លួនឯង(អំពីការប្រព្រឹត្ត)នៅក្នុងបន្ទប់ស្ងាត់(ក្នុងផ្ទះ) ឬក្នុងព្រៃ ឬ(អំពើឧក្រិដ្ឋដែលបណ្តាល)ឱ្យបាត់បង់ជីវិត អាចផ្តល់ភស្តុតាងរវាងគូភាគីបាន។

៧០- (ក្នុងករណីបែបនេះ)ស្ត្រី ក្មេង មនុស្សចាស់ជរា កូនសិស្ស សាច់ញាតិ ទាសករ ឬអ្នកបម្រើដែលស៊ីឈ្នួលគេ មិនអាចធ្វើជាសាក្សីគ្រប់លក្ខណៈសម្បត្តិ ដើម្បីផ្តល់ភស្តុតាងបានទេ។

៧១- ប៉ុន្តែ(ចៅក្រម)គួរពិចារណាអំពីភស្តុតាងរបស់កូនក្មេង មនុស្សចាស់ជរា និងអ្នកមានជំងឺដែល(ងាយនឹង)និយាយមិនពិតព្រោះតែគ្មានសេចក្តីស្មោះត្រង់ ដូចជាការបង្ហាញភស្តុតាងរបស់មនុស្សដែលមានចិត្តវិបល្លាស។

---

**៦៥.** *កុសីលវ* ‘អ្នកសំដែង’(នារ.) ឬ ‘អ្នករបាំ តន្ត្រីករ និងអ្នកចម្រៀង’(មេធ.) ឬ ‘ពួកតារាជាដើម’(គោវ., កុល្ល.) ឬ ‘អ្នកចម្រៀង’(នន្ទ.)។ *ស្រោត្រិយ* ឬ ព្រាហ្មណ៍ដែលសិក្សាព្រះវេទ មិនអាចឱ្យធ្វើជាសាក្សីបានទេ ព្រោះគាត់ត្រូវជាប់ជំពាក់នឹងការសិក្សារបស់គាត់ និងអគ្និហោត្រ(មេធ., កុល្ល., នារ., រាឃ., គោវ., នន្ទ.)។ កំណត់សម្គាល់ដដែលនេះក៏សម្រាប់អនុប្រយោគពីរចុងក្រោយដែរ។ *លិង្គស្ថ*សិស្ស’ តាមលោកនារ., គោវ., នន្ទ., មេធ. ក៏រាប់បញ្ចូលទាំង ‘តាបសឥសី’ ដែរ។
**៦៦.** ‘អ្នកដែលចំណុះទាំងស្រុង’ គឺ ‘ទាសករពីកំណើត’(មេធ., គោវ., កុល្ល., នារ., រាឃ.)។ *វិក្តវ្យ* ‘អ្នកដែលមានកេរ្តិ៍ឈ្មោះអាក្រក់’ ហើយតាមលោកមេធ. ក៏អាចមានន័យថា ‘អ្នកដែលមានរោគឃ្លង់ ឬជំងឺធ្ងន់ធ្ងរមួយចំនួនទៀត’។ *ទស្យុ* គឺ ‘អ្នកបម្រើយកប្រាក់ឈ្នួល’(មេធ., គោវ., រាឃ.) ឬ ‘បុរសដែលមានចិត្តឃោរឃៅ’(មេធ.) ឬ ‘មនុស្សកំហឹង’(កុល្ល.) ឬ ‘ឃាតក’(រាឃ.) ឬ ‘មនុស្សវណ្ណៈទាប’(នន្ទ.)។ យ៉ាងណាមិញ ពាក្យនេះសំដៅដល់កុលសម្ព័ន្ធមានកំណើតចោរប្លន់ ហើយទំនងរាប់ទាំងអ្នកទាំងអស់ដែលប្រហាក់ប្រហែលនេះ។ ‘អ្នកដែលប្រកបរបរហោមឃាត់’ គឺ ‘ព្រាហ្មណ៍ដែលបានក្លាយជាអ្នកចម្បាំង ឬឈ្មួញជាដើម’(មេធ.) ឬ ‘អ្នកសម្លាប់សត្វជាដើម’(នារ.)។

**៦៨.** វស. ជំពូក១៦ លេខ៣០។ ‘ស្ត្រីគួរផ្តល់ភស្តុតាងសម្រាប់ស្ត្រីតែក្នុងករណីរវាងស្ត្រីនិងស្ត្រី ឬក្នុងបញ្ហាពាក់ព័ន្ធផ្លូវភេទស្ត្រី ដែលគេសន្មតថាមានតែស្ត្រីទេទើបដឹង’(មេធ., គោវ., កុល្លូ.)។ ‘បុរសមានកំណើតពីរដងក្នុងប្រភេទដូចគ្នា’ ឬ ‘ក្នុងវណ្ណៈដូចគ្នា’(កុល្លូ., នារ., នន្ទ.) ឬ ‘ក្នុងវណ្ណៈ និងជាមនុស្សល្អដូចគ្នា’(គោវ.) ឬ ‘ក្នុងកន្លែងដូចគ្នា’ ឬ ‘ក្នុងវណ្ណៈ មុខរបរដូចគ្នាជាដើម’(មេធ.)។

**៦៩.** ‘ឬ (បទឧក្រិដ្ឋដែលបង្ក)ឱ្យបាត់បង់ជីវិត’ គឺ ‘ជាអំពើប្លន់ ឃាតកម្មជាដើម’(មេធ., គោវ., កុល្លូ.)។

**៧០.** វិធាននេះសំដៅដល់ករណីដែលមានរៀបរាប់ក្នុងកាព្យលេខ៦៩ (គោវ., កុល្លូ.) ឬ សំដៅដល់កាព្យចុងក្រោយ

## ច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌៈ នីតិវិធី

៧២- ក្នុងករណីអំពើហិង្សា ចោរកម្ម និងសហាយស្មន់ ការបង្ខូចកេរ្តិ៍ និងការជេរប្រមាថទាំងអស់ ទ្រង់មិនត្រូវពិនិត្យ(សមត្ថភាព)របស់សាក្សី(ឱ្យតឹងរ៉ឹងពេក)ទេ។

៧៣- ពេលមានវិវាទរឿងកសិណសាក្សី ព្រះរាជានឹងទទួល(ភស្តុតាង)តាមការពិត ប្រសិនបើ(ភាគីទំនាស់មាន) មានភស្តុតាងស្មើគ្នា (យកភស្តុតាង)របស់អ្នកដែលមានគុណសម្បត្តិល្អ ហើយបើខុសគ្នារវាង(សាក្សី)ដែលមានលក្ខណៈសម្បត្តិដូចគ្នា យកភស្តុតាងប្រសើរបំផុតក្នុងចំណោមអ្នកមានកំណើតពីរដង។

៧៤- ភស្តុតាងដែលស្របតាមអ្វីដែលបានឃើញឬបានឮជាក់ស្តែង អាចទទួលយកបាន ហើយសាក្សីដែលនិយាយពិតក្នុង(ករណី)ទាំងនោះ មិនគិតពីលក្ខណៈកុសលផ្លូវចិត្ត និងទ្រព្យទេ។

៧៥- សាក្សីដែលផ្តល់ភស្តុតាងក្នុងអង្គប្រជុំអ្នកមានកិត្តិយស(អារ្យ៉ន) អំពីអ្វីក៏ដោយ តែជាអ្វីដែលគាត់បានឃើញ ឬបានឮ នឹងធ្លាក់នរក និងបាត់ឱកាសឡើងឋានសួគ៌បន្ទាប់ពីស្លាប់។

៧៦- ពេលដែលមនុស្សម្នាក់(ដំបូង)មិនត្រូវបានគេតែងតាំងជាសាក្សី ឃើញឬឮអ្វីក៏ដោយ ហើយ(ក្រោយមក)ត្រូវគេដឹងរឿងនេះ គេត្រូវតែប្រកាសថាវា(ពិត)ដូចដែលគេបានឃើញ ឬបានឮ។

៧៧- មនុស្សម្នាក់ដែលគ្មានសេចក្តីលោភ គេអាច(ចាត់ទុកជា)សាក្សីបាន ប៉ុន្តែសូម្បីគ្មានស្ត្រីបរិសុទ្ធច្រើនក្តី ព្រោះការយល់ដឹងរបស់ស្ត្រីគឺអាចប្រែប្រួល ហើយសូម្បីគ្មានបុរសផ្សេងច្រើនដែលជាប់ពាក់ព័ន្ធអំពើបាបក្តី។

៧៨- អ្វីដែលសាក្សីប្រកាសតាមជាក់ស្តែង គេត្រូវតែទទួលយកដាក់ក្នុងការកាត់ក្តី ហើយ (ចម្លើយកសិណ)ផ្សេងពីនោះ ដែលមិនសមស្រប គឺគ្មានតម្លៃ(សម្រាប់)យុត្តិធម៌ទេ។

---

ប៉ុណ្ណោះ(នារ.)។

**៧៣.** វិ. ជំពូក៨ លេខ៣៩; យញ្ញ. ជំពូក២ លេខ៧៨, ៨០។ ‘ការល្អបំផុតគឺអ្នកមានកំណើតពីរដង’ គឺ ‘ព្រាហ្មណ៍’(គោវ., នារ.) ឬ ‘ជាពិសេសព្រាហ្មណ៍មានកិត្តិយស ដែលបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន’(កុល្លូ., រាឃ.)។

**៧៤-៧៥.** អាប. ជំពូក២ លេខ២៩, ៩-១០; គោត. ជំពូក១៣ លេខ៧; ពោធ. ជំពូក១ លេខ១៩, ១៤-១៥; វស. ជំពូក១៦ លេខ៣៦; វិ. ជំពូក៨ លេខ១៣-១៤។

**៧៤.** ‘មិនមែនទ្រព្យ’ គឺ ‘គាត់នឹងមិនត្រូវពិន័យទេ’។

**៧៥.** 'នៅក្នុងអង្គប្រជុំអ្នកមានកិត្តិយស' គឺ នៅក្នុងតុលាការ(មេធ.) ឬ 'នៅក្នុងអង្គប្រជុំរបស់ព្រាហ្មណ៍'(គោវ.)។ 'និងបានឱកាសឡើងឋានសួគ៌' គឺ អ្វីដែលគាត់បានខំសន្សំដោយការងារល្អ(មេធ., គោវ., កុល្ល., នន្ទ.) ឬ 'សូម្បីបន្ទាប់ពីឆ្លងកាត់នរក គេមិនអាចឡើងឋានសួគ៌បានទេ ព្រោះកុសលរបស់គេសាបសូន្យហើយ'(នារ.)។

**៧៦.** '(ដំបូង)មិនមានការតែងតាំង(ជាសាក្សី' គឺ 'មិនបានចូលធ្វើជាសាក្សីនៅក្នុងឯកសារ'(មេធ.) 'តែដោយចៃដន្យមានវត្តមានក្នុងសកម្មភាពនោះ'(កុល្ល., នារ., នន្ទ.)។

**៧៨.** 'តាមជាក់ស្តែង' គឺ 'មិនមែនគ្មានមេត្តា ក្នុងជំនឿទទួលបានកុសល ឬស្ថិតលើស្ត្រីទេ'(មេធ.) ឬ 'មិនមែនគ្មានការភ័យខ្លាចជាដើមទេ'(កុល្ល.) ឬ 'ដោយគ្មានការស្ទាក់ស្ទើរ ដោយភ្លាមៗ'(នារ.)។ គោវ. និងនន្ទ. បកស្រាយពាក្យនេះ 'ស្របតាមការពិត'។

៧៩- សាក្សីដែលបានចូលក្នុងតុលាការ ក្នុងវត្តមានដើមចោទនិងចុងចោទ ចូរចៅក្រមសាកសួរពួកគេដោយដាស់តឿនពួកគេយ៉ាងសុភាព តាមរបៀបដូចខាងក្រោមៈ

៨០- 'អ្វីដែលអ្នកដឹង មានពាក់ព័ន្ធទៅវិញទៅមកក្នុងបញ្ហានេះ រវាងមនុស្សពីរនាក់នៅចំពោះមុខយើងនេះ ចូរប្រកាសតាមការពិតទាំងអស់ ព្រោះអ្នកជាសាក្សីក្នុងរឿងក្តីនេះ។

៨១- 'សាក្សីដែលនិយាយការពិតក្នុងការផ្តល់កសិណរបស់ខ្លួន(បន្ទាប់ពីស្លាប់) បានទទួលពរទៅកាន់ឋានប្រសើរបំផុត ហើយនៅទីនេះ (ឋានកណ្តាល)បានកេរ្តិ៍ឈ្មោះគ្មានគូប្រៀប ហើយការផ្តល់កសិណបែបនេះនឹងបានទទួលការស្រឡាញ់ពីព្រហ្ម។

៨២- 'អ្នកដែលផ្តល់កសិណក្លែងក្លាយ នឹងត្រូវជាប់ខ្នោះច្រវាក់របស់*វរុណ* ដោយគ្មានជំនួយអស់អំឡុងមួយរយអត្តិភាព (ហេតុនេះ)ចូរមនុស្សទាំងឡាយ ផ្តល់កសិណពិត។

៨៣- 'ដោយសច្ចភាព សាក្សីនឹងត្រូវបរិសុទ្ធ តាមរយៈសច្ចភាពកុសលរបស់គេកើនច្រើនឡើង ហេតុនេះសាក្សីគ្រប់វណ្ណៈទាំងអស់ ត្រូវតែនិយាយការពិតកុំខាន។

៨៤- 'អាត្ម័នផ្ទាល់ ជាសាក្សីរបស់អាត្ម័ន ហើយអាត្ម័នជាជម្រករបស់អាត្ម័ន ហើយមិនពេញចិត្តអាត្ម័នរបស់ខ្លួនអ្នកផ្ទាល់ក្តី ក៏អាទិទេពជាកសិណរបស់មនុស្ស។

៨៥- 'តាមពិត អំពើអាក្រក់បញ្ចេញសំឡេងក្នុងបេះដូងរបស់ខ្លួនថា "គ្មាននរណាឃើញយើងទេ" ប៉ុន្តែព្រះអាទិទេពឃើញពួកគេយ៉ាងច្បាស់ ហើយបុរសនៅក្នុងទ្រូងរបស់ខ្លួនផ្ទាល់។

៨៦- 'មេឃ ដី ទឹក (ភេទឈ្មោលនៅក្នុង)បេះដូង ព្រះច័ន្ទ ព្រះអាទិត្យ ភ្លើង ព្រះយមៈ និងព្រះពាយ រាត្រី ពេលអស្តង្គតទាំងពីរ និងយុត្តិធម៌ ស្គាល់អំពើរបស់សព្វសត្វទាំងអស់។'

៨៧- (ចៅក្រម)ដែលមានភាពបរិសុទ្ធនឹងសួរ(សាក្សី)អ្នកមានកំណើតពីរដង ដែលមានភាពបរិសុទ្ធដែរ នៅមុនពេលថ្ងៃត្រង់ (និងឈរ)បែរមុខទៅទិសខាងជើងឬខាងកើត ដើម្បីផ្តល់កសិណពិតក្នុងនាម(រូបភាព)ព្រះអាទិទេព និងព្រាហ្មណ៍។

៨៨- ចូរចៅក្រមសួរព្រាហ្មណ៍(ដោយចាប់ផ្តើមថា) 'ចូរមានប្រសាសន៍' សួរក្សត្រិយ 'មានព្រះបន្ទូលការពិត' សួរវៃស្យ (ដោយដាស់តឿនគាត់)ដោយវាចារថា សត្វគោ ធញ្ញជាតិ និងមាសរបស់អ្នក សួរសូទ្រៈ(ដោយគម្រាមគេ)ដោយ(ទោសនៃ)បទឧក្រិដ្ឋនានា ដែលនាំឱ្យបាត់បង់វណ្ណៈ;

---

**៧៩.** គោត. ជំពូក១៣ លេខ៥។

**៨០-១០១.** អាប. ជំពូក២ លេខ២៩, ៩-១០; គោត. ជំពូក១៣ លេខ១៤-២២; វស. ជំពូក១៦ លេខ៣២-៣៤; ពោធ. ជំពូក១ លេខ១៩, ៩-១២; វិ. ជំពូក៨ លេខ១៩-៣៧; យញ្ញ. ជំពូក២ លេខ៧៣-៧៥។

**៨២.** `ខ្នោះប្រវាក់របស់ព្រះ*វរុណ*´ គឺ `ចំណងពស់ ឬរោគទឹកក្នុងស្បែកដ៏គួរឱ្យខ្លាច´(មេធ., កុល្ល.)។ លោកគោវ. សរសេរតែចំណងពស់ប៉ុណ្ណោះ ហើយលោករាឃ. និយាយថា កាព្យនេះគម្រាមពីការដាក់ទណ្ឌកម្មចុះនរក។ រោគទឹកក្នុងស្បែកជាជំងឺពិសេសដែលបង្កើតដោយព្រះវរុណ សូមមើលឫគ-វេទជំពូក៧ លេខ៨៩, ១ និងរឿងរបស់សុនហ្សផ *អែត. ព្រាហ្ម.* ជំពូក៧ លេខ១៥។ ខ្នោះប្រវាក់របស់វរុណ ជាទោសសម្រាប់ដាក់អ្នកភូតកុហក តាមគម្ពីរអេថរវេទ ជំពូក៤ លេខ១៦, ៦។

**៨៦.** `(ភេទឈ្មោលនៅក្នុង)បេះដូង´ គឺ `ធាតុឈ្មោល ឬព្រលឹង(បុរសៈ) ដែលស្ថិតក្នុងបេះដូងមនុស្ស ដែលដណ្តប់ដោយកាយជាប្រធាន´(មេធ.) ហើយដូចគ្នានឹងអ្នកអធិប្បាយផ្សេងទៀតដែរ។

**៨៨.** `(ដោយដាស់តឿនគាត់) ដោយបញ្ជាក់អំពីសត្វគោ ធញ្ញជាតិ ឬមាសរបស់គាត់´ គឺ `ដោយគម្រាមគាត់អំពីទោសនៃ

៨៩- (ដោយនិយាយ)`(បណ្ឌិត)តម្រូវឱ្យមាន(ទណ្ឌកម្ម)នៅកន្លែងណាក៏ដោយចំពោះអ្នកសម្លាប់ព្រាហ្មណ៍ ចំពោះអ្នកសម្លាប់ស្ត្រីនិងកុមារ ចំពោះអ្នកដែលក្បត់មិត្តសំឡាញ់ និងចំពោះមនុស្សអកតញ្ញូ អំពើទាំងនោះមាន(ចំណែក)របស់អ្នក ប្រសិនបើអ្នកនិយាយមិនពិត។

៩០- `(ផល)នៃអំពើល្អទាំងអស់ដែលអ្នក (មនុស្សល្អ) បានធ្វើតាំងពីការចាប់កំណើតរបស់អ្នក នឹងក្លាយ ជាចំណែករបស់សត្វឆ្កែ ប្រសិនបើសម្តីរបស់អ្នកខុសពីការពិត។

៩១- `ប្រសិនបើអ្នកគិតចំពោះខ្លួន ឱ មិត្តរបស់មនុស្សល្អអើយ "មានតែខ្ញុំម្នាក់ប៉ុណ្ណោះ"(ទើបដឹងថា) បណ្ឌិតដែលជាសាក្សីនៃអំពើល្អ និងអំពើឧក្រិដ្ឋទាំងអស់ ស្ថិតនៅក្នុងបេះដូងរបស់អ្នក។

៩២- `ប្រសិនបើអ្នកមិនផ្សេងពីព្រះអាទិទេពយមៈ បុត្ររបស់វិវស្វ័ត ដែលស្ថិតក្នុងបេះដូងរបស់អ្នក អ្នកមិនចាំបាច់ទៅកាន់ទន្លេគង្គា និង(ដែនដី)កុរុ នោះទេ។

៩៣- `ដោយអាក្រាត និងគ្មានអ្វីសោះ ញាំញីដោយសេចក្តីស្រេកឃ្លាន និងងងឹតពពឹមពពើម គឺគេនេះហើយដែលផ្តល់កសិណមិនពិត ដើរកាន់អំបែងដើរសុំអាហារ តាមមាត់ទ្វារផ្ទះសត្រូវខ្លួន។

៩៤- `ដោយធ្លាក់ក្នុងភពងងឹតទាំងស្រុង ពោលគឺបាបជននឹងចុះនរក ដោយសារនៅពេលគេសួរនៅសវនាការតុលាការ ឆ្លើយសំណួរមួយមិនពិត។

៩៥- `អ្នកដែលនៅក្នុងតុលាការ (យុត្តិធម៌) រៀបរាប់សកម្មភាពមិនពិត (ឬអះអាងហេតុការណ៍) ដែលខ្លួនមិនបានឃើញផ្ទាល់ភ្នែក បីដូចមនុស្សខ្វាក់ ដែលលេបត្រីទាំងឆ្អឹង។

៩៦- `ព្រះអាទិទេពស្គាល់តែអ្នកនោះច្បាស់ គ្មាននរណាក្រៅពីរូបគេទេនៅក្នុងលោកនេះ ដែលចិត្តដឹងរបស់គេ មិនខ្វះទំនុកចិត្ត ពេលគេផ្តល់កសិណ។

៩៧- `ឥឡូវឱសំឡាញ់ ចូររៀនអំពីការគណនាចំនួនជាក់លាក់ ថាតើគេបំផ្លាញញាតិប៉ុន្មាននាក់ ដោយសារការផ្តល់កសិណមិនពិត ក្នុងរឿងក្តីជាច្រើន។

៩៨- `គេធ្វើឱ្យសត្វគោក្របី(តូចៗ)ប្រាំក្បាលងាប់ ដោយការផ្តល់កសិណមិនពិត គេធ្វើឱ្យគោដប់ក្បាលងាប់ដោយការផ្តល់កសិណមិនពិត គេធ្វើឱ្យសេះមួយរយងាប់ ដោយការផ្តល់កសិណមិនពិត និងមនុស្សមួយពាន់ស្លាប់ ដោយការផ្តល់កសិណមិនពិត។

៩៩- 'ដោយការនិយាយមិនពិត ក្នុងរឿងក្តីពាក់ព័ន្ធរឿងមាស គេសម្លាប់អ្នកដែលកើត និងអ្នកមិនទាន់កើត ដោយការផ្តល់កសិណមិនពិតអំពីបញ្ហាដីធ្លី គេបង្កឱ្យស្លាប់អ្វីៗទាំងអស់ ដូច្នេះចូរដឹងអំពីការផ្តល់កសិណមិនពិតពាក់ព័ន្ធរឿងដីធ្លី។

---

បទល្មើសទាំងអស់ដែលត្រូវដាក់ មានសត្វគោជាដើម'(មេធ.) ឬ 'មានទោសពីបទលួចគោជាដើម'(គោវ., កុល្លូ., រាឃ.) ឬ 'ពីការបាត់បង់គោរបស់ខ្លួនជាដើម'(នារ.) ឬ 'ដោយតម្រូវឱ្យគាត់ស្នាបមេគោជាដើម'(នន្ទ.)។

*៩៧. ហន្តិ* 'បំផ្លាញ ឬសម្លាប់' គឺ 'ជាហេតុនាំឱ្យធ្លាក់នរក'(មេធ., គោវ., កុល្លូ., នារ.) ឬ 'ជាហេតុនាំឱ្យធ្លាក់ពីឋានសួគ៌ និងចាប់កំណើតក្នុងគភ៌របស់សត្វ'(រាឃ.)។ មេធ. និងកុល្លូ. (កាព្យលេខ៩៩) ផ្តល់ការបកស្រាយម្យ៉ាងទៀតថា 'បង្កឱ្យមានទោសធ្ងន់ ឧបមាដូចជាគេបានសម្លាប់ពួកវា'។

*៩៨.* 'មនុស្ស'គឺ 'ទាសករ'។

*៩៩.* 'អ្វីៗ' គឺ 'អ្វីៗដែលមានជីវិត'(គោវ., កុល្លូ.) ឬ 'សូម្បីច្រើនជាងមួយពាន់'(នារ., រាឃ.)។

១០០- 'ពួកគេប្រកាសថា (ការផ្តល់កសិណមិនពិត)ពាក់ព័ន្ធរឿងទឹក ការជាប់ជំពាក់នឹងរូបរបស់ស្ត្រី និងពាក់ព័ន្ធរឿងត្បូងទាំងអស់ ដែលមាននៅក្នុងទឹក ឬដែលមានថ្ម (អាក្រក់)ស្មើនឹងការកុហកពាក់ព័ន្ធរឿងដីធ្លី។

១០១- 'ដោយដឹងច្បាស់ពីអំពើអាក្រក់ទាំងអស់ (ដែលកើតចេញពី) ការភូតកុហកតុលាការ ចូរអ្នកប្រកាសបើកចំហអ្វីៗគ្រប់យ៉ាងតាម(ដែលអ្នកបាន)ឮ ឬបានឃើញ(រឿងនោះ)។'

១០២- ព្រាហ្មណ៍ ដែលមើលថែគោក្របី ដែលជាឈ្មួញ ដែលជាយន្តការី អ្នកសម្តែង (ឬអ្នកចម្រៀង) អ្នកបម្រើ ឬអ្នកចងការប្រាក់ (ចៅក្រម)នឹងចាត់ទុកដូចជាសូទ្រៈ។

១០៣- ក្នុង(ករណី)មួយចំនួន សូម្បីដឹងការពិតផ្សេងក្តីដែលផ្តល់(កសិណមិនពិត) ដោយហេតុផលនៃជំនឿមិនបាត់បង់ឋានសួគ៌ទេ ហើយ(កសិណ)បែបនេះ ពួកគេហៅថាពាក្យរបស់អាទិទេព។

១០៤- ពេលណាសេចក្តីស្លាប់របស់សូទ្រៈ វៃស្យ ក្សត្រិយ ឬរបស់ព្រាហ្មណ៍ កើតឡើងដោយសារការប្រកាសការពិត នោះគេអាចនិយាយមិនពិតបាន ព្រោះ(ការពោលពាក្យមិនពិត)ដូច្នេះ ប្រសើរជាងពាក្យពិត។

១០៥- (កសិណ)បែបនេះ ត្រូវថ្វាយការបូជា*សរស្វតី* នូវបាយឆ្អិន(ចរុ) ដែលជាអាហារពិសិដ្ឋសម្រាប់ទេពធីតាតំណាងពាក្យសម្តី (ដូច្នេះ)ដោយធ្វើតបះដ៏ប្រពៃបំផុត ដើម្បីលុបលាងទោសនៃការនិយាយមិនពិតនោះ។

១០៦- ឬ(កសិណ)បែបនេះអាចបូជាតាមតម្រាច្បាប់នូវបីសុទ្ធដល់ព្រះអគ្គី ដោយសូត្រពាក្យ*កូស្មាណ្ឌ* ឬ ឫគ ដ៏ពិសិដ្ឋចំពោះព្រះវរុណ ថា 'ឱ ព្រះវរុណ សូមស្រាយខ្សោះច្រវាក់ដ៏ខ្ពង់ខ្ពស់បំផុត' ឬកាព្យបីដែលត្រូវថ្លែងទៅកាន់ព្រះគង្គា។

១០៧- អ្នកដែលគ្មានជំងឺ មិនផ្តល់កសិណក្នុងរឿងក្តីខ្ចីប្រាក់ និងរឿងក្តីបែបនេះ ក្នុងពេលពីរសប្តាហ៍ (បន្ទាប់ពីមានដីកាកោះ) នឹងទទួលខុសត្រូវចំពោះបំណុលទាំងស្រុង ហើយ(ត្រូវបង់)មួយភាគដប់នៃបំណុលទាំងអស់ (ជាប្រាក់ពិន័យថ្វាយព្រះរាជា)។

---

**១០០.** 'ទឹក' គឺ 'អណ្តូង ស្រះត្រពាំងជាដើម'។ 'ត្បូងដែលមាននៅក្នុងទឹក' គឺ 'គជ់ ផ្កាថ្មជាដើម'។

នន្ទ. ដាក់កាព្យលេខ៩៩ នៅមុនកាព្យ១០០ ហើយកាព្យខ្លះទៀតត្រូវគេដាក់នៅចន្លោះ និងបន្ទាប់ពីកាព្យទាំងនេះ ប៉ុន្តែការភាន់ច្រឡំ ទំនងជាកើតមានដោយសារការភាន់របស់ស្មៀន ព្រោះគ្មានការអធិប្បាយទេ។

**១០១.** *អង្គសា* 'ដោយចំហ' តាមគោវ. និងកុល្ល. ថា 'តាមការពិត' ហើយតាមនារ. ថា 'យ៉ាងរហ័ស'។

**១០២.** វស. ជំពូក៣ លេខ១។

**១០៣-១០៤.** គោត.ជំពូក១៣ លេខ២៤-២៥; វស.ជំពូក១៦ លេខ៣៦; វិ.ជំពូក៨ លេខ១៥; យញ្ញ.ជំពូក២ លេខ៨៣។

**១០៣.** នន្ទ. លុបកាព្យនេះចោល។

**១០៥-១០៦.** ពោធ. ជំពូក១ លេខ១៩, ១៦; វិ. ជំពូក៨ លេខ១៦; យញ្ញ. ជំពូក២ លេខ៨៣។

**១០៦.** ពាក្យ *កូស្មាណ្ឌ* មាននៅក្នុង តៃត្ត. អារ. ជំពូក១០ លេខ៣-៥; កាព្យនេះសំដៅដល់ព្រះវរុណ គម្ពីរឫគវេទ ជំពូក១ លេខ២៤, ១៥ និងកាព្យបី ដែលសំដៅដល់ព្រះគង្គា ឫគវេទ ជំពូក១០ លេខ៩, ១-៣។

**១០៧.** យញ្ញ. ជំពូក២ លេខ៧៦។

១០៨- សាក្សី នឹងត្រូវសងបំណុលនិងប្រាក់ពិន័យ បើក្នុងអំឡុងប្រាំពីរថ្ងៃក្រោយពីបានផ្តល់កសិណ ជួបប្រទះ (សំណាងអាក្រក់ ដោយ)កើតជំងឺ ភ្លើងឆេះ ឬស្លាប់ញាតិសន្តាន។

១០៩- ប្រសិនបើ(ភាគី)ទាំងពីរ ជជែកយកឈ្នះអំពីបញ្ហាព្រោះតែគ្មានសាក្សីបញ្ជាក់ ហើយ(ចៅក្រម) មិនអាចបញ្ជាក់ការពិតបាន ចៅក្រមអាចរកការពិតតាមរយៈការស្បថសច្ចាក៏បាន។

១១០- ភាគីទាំងពីរត្រូវបានមហាបណ្ឌិតនិងអាទិទេពតម្រូវឱ្យស្បថ ដើម្បី(វិនិច្ឆ័យ) បញ្ហាដែលនៅមានមន្ទិលសង្ស័យ ហើយវសិស្ឋ ក៏បានពោលពាក្យសម្បថនៅចំពោះព្រះភក្ត្រព្រះរាជា(សុទា) បុត្ររបស់*បិយវន*។

១១១- ចូរអ្នកមានគតិបណ្ឌិតកុំពោលពាក្យស្បថមិនពិត សូម្បីក្នុងរឿងតូចតាចក៏ដោយ ព្រោះអ្នកដែលពោលពាក្យស្បថមិនពិត ត្រូវវិនាសក្នុងលោកិយនេះ និងជាតិក្រោយ។

១១២- ការពោលពាក្យស្បថ(មិនពិត)ចំពោះស្ត្រី ពាក់ព័ន្ធនឹងវត្ថុបំណងរបស់ខ្លួនក្នុងរឿងរៀបការ ដើម្បីបានស្មៅសម្រាប់មេគោឬប្រេង និងដើម្បីបង្ហាញការគាំទ្រចំពោះព្រាហ្មណ៍ មិនមែនជាបទឧក្រិដ្ឋ ដែលញ៉ាំងឱ្យបាត់បង់វណ្ណៈនោះទេ។

១១៣- ចូរ(ចៅក្រម)តម្រូវឱ្យព្រាហ្មណ៍ស្បថតាមពាក្យសត្យរបស់ខ្លួន ក្សត្រិយ(ស្បថ)ដោយសេនារទេះរបស់ទ្រង់ ឬសត្វដែលទ្រង់ជិះ និងដោយអាវុធរបស់ទ្រង់ វៃស្យ(ស្បថ)ដោយហ្វូងគោធញ្ញជាតិ និងមាសរបស់ខ្លួន ហើយសូទ្រៈ ដោយ(ការដាក់បណ្តាសារទោសត្រូវក្បាលរបស់ខ្លួន) នូវរាល់បទល្មើសធ្ងន់ធ្ងរ(បាតកៈ)។

១១៤- ឬ(ចៅក្រម)អាចឱ្យ(ភាគី)នោះកាន់ភ្លើង ឬជ្រមុជចូលក្នុងទឹក ឬវាយក្បាលប្រពន្ធនិងកូនរបស់ខ្លួនខ្លាំងៗ។

១១៥- អ្នកដែលមិនឆេះភ្លើង ដែលមិនបង្ហំងើបចេញពីទឹក(យ៉ាងរហ័ស) ដែលមិនជួបសំណាងអាក្រក់ភ្លាមៗ ត្រូវគេចាត់ទុកថាគ្មានទោស ដោយសារ(កម្លាំង)ការធ្វើសម្បថរបស់ខ្លួន។

---

**១០៨.** យញ្ញ. ជំពូក២ លេខ១១៣។

**១០៩.** គោត. ជំពូក១៣ លេខ១២-១៣; វិ. ជំពូក៩ លេខ២-៩។ យោងតាមមេធ. ពាក្យ *សបថ* 'សម្បថ' ត្រូវគេប្រើសម្រាប់*ទៃវ អនុមាន*កស្តុតាងបញ្ជាក់ដោយអាទិទេព' ដូច្នេះទើបរាប់បញ្ចូលការកាត់ក្តីបែបបុរាណ។
**១១០.** មេធ. និងគោវ. គូសបញ្ជាក់ថា បណ្ឌិតប្រាំពីរនាក់ បានបន្សុទ្ធខ្លួនដោយការស្បថ នៅពេលពួកគេចោទប្រកាន់គ្នាទៅវិញទៅមកអំពីការលួចផ្កាឈូក(មហ. ជំពូក១៣ លេខ៩៣, ១៣ និងថា ព្រះឥន្ទបានស្បថ ពេលព្រះអង្គជាប់ចោទពីបទប្រើឧបាយដាក់*អហល្យា* ភរិយារបស់គោតម។ វសិស្ថ ទីបញ្ចប់បានរួចផុតពីការចោទប្រកាន់ ដែលឥសីវិស្វាមិត្រ បានចោទគាត់ចំពោះព្រះកត្រ្តព្រះរាជា*សុទា* ថា គាត់ជារាក្សសៈ និងបានស៊ីកូនប្រុសមួយរយរបស់ខ្លួន(មេធ., គោវ., កុល្ល., នារ., រាឃ., នន្ទ.)។ សូមមើល សាយណៈ គម្ពីរឫគវេទ ជំពូក៧ លេខ១០៤ ហើយជាពិសេសកាព្យលេខ១៥ ដែលមាននិយាយពីការធ្វើសម្បថ។
**១១២.** គោត. ជំពូក២៣ លេខ២៩; វស. ជំពូក១៦ លេខ៣៥។ 'ប្រេង' គឺ 'សម្រាប់ការបូជាអគ្គិ'(មេធ., គោវ., កុល្ល., នារ.)។ នៅក្នុងអនុប្រយោគចុងក្រោយ ពិសិដ្ឋភាពនៃបំណងឱ្យអភ័យដល់បទឧក្រិដ្ឋ។
**១១៣.** ក្សត្រិយ និងវៃស្យៈ ត្រូវប៉ះអ្វីដូចបាននិយាយ ហើយថា 'សូមឱ្យវត្ថុនេះកុំប៉ះពាល់ដល់ខ្ញុំ!'(មេធ., គោវ., កុល្ល.)។
**១១៤.** កាព្យនេះ តាមការអះអាងរបស់អ្នកអធិប្បាយ គឺសំដៅដល់ការពិសោធន៍ពីរយ៉ាង ដែលរៀបរាប់ដោយគម្ពីរ វិ. ជំពូក

១១៦-ព្រោះដំបូងឡើយ ពេលប្អូនប្រុសបានចោទវត្ស ភ្លើង ជាចារបុរសក្នុងលោក មិនបានឆេះសក់(របស់គាត់) សូម្បីមួយសរសៃ ដោយហេតុនៃពាក្យសត្យរបស់ខ្លួនទេ។

១១៧-ពេលណាក៏ដោយឱ្យតែគេផ្តល់កសិណាមិនពិតនៅក្នុងតុលាការ ចូរ(ចៅក្រម)កែប្រែសាលក្រម ហើយអ្វីក៏ដោយដែលបានសម្រេច ត្រូវគេចាត់ទុកថាមិនបានសម្រេច។

១១៨-កសិណា(ដែលផ្តល់)ដោយចិត្តលោភ ការធ្វេសប្រហែស ការភ័យខ្លាច មិត្តភាព តណ្ហា កំហឹង អវិជ្ជា និងភាពនៅក្មេងខ្ចី ត្រូវគេប្រកាសថាគ្មានសុពលភាព។

១១៩-ខ្ញុំនឹងថ្លែងអះអាងអំពីការដាក់ទោសជាក់ស្តែងចំពោះអ្នកដែលផ្តល់កសិណាមិនពិត ដោយហេតុណាមួយក្នុងចំណោមហេតុទាំងឡាយនេះ។

១២០-(អ្នកដែលប្រព្រឹត្តអំពើភូតកុហកតុលាការ) ដោយចិត្តលោភ នឹងត្រូវពិន័យចំនួនមួយពាន់(បណៈ)(អ្នកដែលកុហកតុលាការ)ដោយការធ្វេសប្រហែសទទួលពិន័យតិចបំផុត (បើមនុស្សម្នាក់ភូតកុហកតុលាការ)ដោយការភ័យខ្លាច ការពិន័យជាមធ្យមពីរ ត្រូវបង់ជាប្រាក់ពិន័យ(បើគេភូតតុលាការ)ដោយសារមិត្តភាព ត្រូវពិន័យប្រាក់តាមការពិន័យកម្រិតទាបបំផុត គុណនឹងបួនដង។

១២១-(អ្នកដែលកុហកតុលាការ)ដោយតណ្ហា(នឹងបង់)ពិន័យកម្រិតទាបបំផុតគុណនឹងដប់ តែ(អ្នកកុហកតុលាការ)ដោយកំហឹង គុណនឹងបី ការពិន័យថ្នាក់បន្ទាប់ (ឬការពិន័យទីពីរ) ហើយ(អ្នកដែលកុហកតុលាការ)ដោយអវិជ្ជាត្រូវពិន័យពីរពាន់តែម្តង តែ(អ្នកដែលកុហកតុលាការ) ដោយភាពនៅក្មេងខ្ចី ត្រូវពិន័យមួយរយ(បណៈ)។

១២២-ពួកគេប្រកាសថា បណ្ឌិតបានរៀបចំការដាក់ពិន័យទាំងអស់នេះចំពោះការភូតកុហកតុលាការ ដើម្បីការពារការបរាជ័យក្នុងការរកយុត្តិធម៌ និងដើម្បីទប់ស្កាត់អយុត្តិធម៌។

១២៣-ប៉ុន្តែព្រះរាជាប្រកបដោយយុត្តិធម៌នឹងពិន័យ និងនិរទេស(មនុស្សនៃវណ្ណៈ)ក្រោមបី ដែលបានផ្តល់កសិណាមិនពិត ប៉ុន្តែព្រាហ្មណ៍ ទ្រង់(គ្រាន់តែ)និរទេសប៉ុណ្ណោះ។

១២៤- មនុ បុត្ររបស់ព្រះស្វយម្ភូ (ស្វយំភូ)បានរាប់ឈ្មោះដប់កន្លែងដែលអាចជាការដាក់ទណ្ឌកម្ម ក្នុងករណីវណ្ណៈ(ក្រោម)បី ប៉ុន្តែព្រាហ្មណ៍នឹងចាកចេញ(ពីប្រទេស)ដោយគ្មានរបួសអ្វីទេ។

---

១១-១២ និងយញ្ញ. ជំពូក២ លេខ១០៣-១០៩។ មេធ., គោវ. និងកុល្លូ. ពោលអះអាងថា ត្រូវធ្វើការពិសោធន៍តែក្នុងករណីសំខាន់ៗប៉ុណ្ណោះ សូមមើលវិ. ជំពូក៩ លេខ១០-១៤។

**១១៦.** *មៃត្រិយ* បងប្អូនធម៌របស់*វត្ស* ដែលក្រោយមកជាប់ចោទថាជាកូនរបស់ស្ត្រីសូទ្រៈ។ ដើម្បីបញ្ជាក់ពីការមិនពិតចំពោះពាក្យចោទប្រកាន់ វត្ស បានដើរឆ្លងកាត់ភ្លើង(មេធ., គោវ., កុល្លូ., នារ., រាឃ.)។ ខ្ញុំអាន *ស្បស:* ជំនួស ស្រ្សិសះ។

**១១៧.** វិ. ជំពូក៨ លេខ៤០។ 'ការដាក់ពិន័យត្រូវគេបន្ធូរបន្ថយ'(គោវ., កុល្លូ., នារ.)។

**១១៩-១២៣.** យញ្ញ. ជំពូក២ លេខ៨១។

**១២០.** ចំពោះការដាក់ទោសពិន័យបីប្រភេទ សូមមើលកាព្យ១៣៨ខាងក្រោម។

**១២៣.** *វិវាសយេត*ទ្រង់នឹងបណ្តេញចេញ(តែម្យ៉ាង)'(កុល្លូ., នារ., រាឃ., នន្ទ.) តាមលោកមេធ. ថា 'ទ្រង់នឹងដកហូតយកសម្លៀកបំពាក់ ឬផ្ទះសម្បែងរបស់គេ'។ គោវ. ធ្វើការបកស្រាយន័យទីមួយរបស់មេធ.ប៉ុណ្ណោះ។

**១២៤.** អាប. ជំពូក២ លេខ២៧, ៨, ១៧-១៩; គោត. ជំពូក១២ លេខ៤៦-៤៧; វិ. ជំពូក៥ លេខ២-៨។

១២៥- (ទាំងអស់នេះជា)អវយវៈ ក្បាលពោះ អណ្តាត ដៃពីរ និងទីប្រាំ គឺជើងពីរ ភ្នែក ប្រមុះ ត្រចៀកពីរ ប្រៀបដូចជារូបកាយ(ទាំងមូល)។

១២៦- ចូរ(ព្រះរាជា)ដោយបានដឹងច្បាស់ពីហេតុ ពេលវេលា និងទីកន្លែង(នៃបទល្មើស) និងដោយបានវិនិច្ឆ័យពីលទ្ធភាព (របស់ឧក្រិដ្ឋជន ដែលត្រូវទទួលទោស) និង(ចរិកលក្ខណៈនៃ)បទឧក្រិដ្ឋ អាចធ្វើការដាក់ទោសចំពោះអ្នកដែលសមនឹងទទួលទោស។

១២៧- ការដាក់ទោសមិនត្រឹមត្រូវ បំផ្លាញកិត្តិសព្ទក្នុងចំណោមមនុស្ស និងកេរ្តិ៍ឈ្មោះ(បន្ទាប់ពីស្លាប់) ហើយសូម្បីនៅក្នុងជាតិក្រោយ បាត់ឱកាសឡើងឋានសួគ៌ ដូច្នេះចូរទ្រង់ប្រុងប្រយ័ត្ន(អំពីការដាក់ទោស)នេះ។

១២៨- ព្រះរាជាដែលដាក់ទោសអ្នកដែលមិនសមនឹងទទួលទោស ហើយមិនដាក់ទោសអ្នកដែលសមទទួល នឹងនាំមកនូវភាពទុសយ៍ដាក់ខ្លួនទ្រង់ ហើយ(បន្ទាប់ពីសុគត)នឹងធ្លាក់នរក។

១២៩- ចូរទ្រង់ដាក់ទោសទីមួយ ដោយការស្តីបន្ទោស(ដ៏រាបសារ) បន្ទាប់មកដោយការតិះដៀល ទីបីដោយការពិន័យ បន្ទាប់ពីនោះគឺដោយការដាក់ទណ្ឌកម្មរូបកាយ។

១៣០- ប៉ុន្តែពេលទ្រង់មិនអាចបញ្ឈប់(ជនល្មើស)បែបនេះបាន សូម្បីដោយការដាក់ទណ្ឌកម្មរូបកាយក៏ដោយ បន្ទាប់មកចូរទ្រង់ដាក់ទោសគេ តាមទម្រង់ទោសទាំងបួន(រួមគ្នាតែម្តង)។

១៣១- ខ្ញុំនឹងប្រកាសទាំងស្រុងនូវឈ្មោះបច្ចេកទេស (អំពីបរិមាណជាក់លាក់នៃ) ទង់ដែង ប្រាក់ និងមាស ដែលគេប្រើជាទូទៅនៅលើផែនដី ក្នុងបំណងធ្វើកិច្ចពាណិជ្ជកម្មក្នុងចំណោមមនុស្ស។

១៣២- ផង់ធូលីដ៏តូច ដែលយើងឃើញនៅពេលព្រះអាទិត្យបញ្ចេញពន្លឺរស្មី ពួកគេប្រកាស (ថាជា) ចំនួនដ៏តូចបំផុត ហើយ(ត្រូវគេហៅថា)ត្រសរេណុ (ចុណ្ណភាគធូលីដែលអណ្តែតត្រសែត)។

១៣៣- ចូរដឹង(ថា)ប្រាំបីត្រសរេណុ (គឺស្មើ)នឹងខ្នាតមួយ*លិក្សា* (ពងចៃ) បីពងចៃ ស្មើនឹងគ្រាប់ស្ពៃខ្មៅមួយ(រាយសសប) ហើយចំនួនបីខ្នាតក្រោយនេះ ស្មើមួយគ្រាប់ស្ពៃសមួយ។

១៣៤- គ្រាប់ស្ពៃសប្រាំមួយស្មើនឹងគ្រាប់ពោត ដែលប៉ុនគ្រាប់ស្រូវសាឡីធុនមធ្យម និងគ្រាប់ពោតបីស្មើមួយក្ឫស្ណល (រត្តិកា ឬគុញ្ញ គ្រាប់បីរី) ហើយប្រាំក្ឫស្ណល ស្មើមួយមាសៈ (គ្រាប់សណ្តែក) ហើយដប់ប្រាំមួយគ្រាប់សណ្តែកស្មើមួយសុវណ្ណ។

១៣៥- បួនសុវណ្ណ ស្មើមួយបលៈ ហើយដប់បលៈ ស្មើមួយធរណៈ ហើយពីរក្ឫស្ណលៈ(នៃប្រាក់)រួមគ្នាត្រូវចាត់ទុកស្មើនឹងមួយមាសកៈប្រាក់។

**១២៦.** គោត. ជំពូក១២ លេខ៥១; យញ្ញ. ជំពូក១ លេខ៣៦៧។ អនុពន្ធ 'ហេតុនៃប្រព្រឹត្ត' តាមលោកគោវ. និងកុល្ល. រួមទាំង 'ការប្រព្រឹត្តបទល្មើសជារឿយៗ'។ នារ. ឱ្យន័យក្រោយនេះប៉ុណ្ណោះ។ នន្ទ. អាន អបរាធំ 'បទល្មើស'។ ជំនួសពាក្យសារាបរាធៅ លោកនន្ទ. អានសារាសារំ 'ចំណុចខ្លាំង ឬចំណុចខ្សោយ(របស់ជនល្មើស)'។

**១២៧-១២៨.** យញ្ញ. ជំពូក១ លេខ៣៥៦; វិ. ជំពូក១៩ លេខ៤៣។

**១២៩-១៣០.** យញ្ញ. ជំពូក១ លេខ៣៦៦។

**១៣១-១៣៨.** វិ. ជំពូក៤ លេខ១-១៤; យញ្ញ. ជំពូក១ លេខ៣៦១-៣៦៥។

**១៣៤.** អ្នកលក់មាស និងគ្រឿងអលង្ការ នៅតែប្រើខ្នាត ក្ឫស្ណល ឬ រត្តិកា (រត្តិ)ដដែល គឺវាស្មើនឹង ០.១២២ក្រាម ឬ ១.៨៧៥គ្រាប់ធញ្ញជាតិ

១៣៦-ប្រាំមួយមាសកៈស្មើមួយធរណៈប្រាក់ឬបុរាណៈ ប៉ុន្តែចូរដឹង(ថា)មួយកសៈទង់ដែង ស្មើមួយកាសបណៈ ឬបណៈ។

១៣៧-ចូរចាំ(ថា)ដប់ធរណៈប្រាក់ស្មើមួយសតមានៈ, បួនសុវណ្ណ ត្រូវ(ស្មើនឹង)ទម្ងន់និក្ស។

១៣៨-ពីររយហាសិបបណៈ ត្រូវចាត់ទុក(ជា)ការដាក់ពិន័យថ្នាក់ទីមួយ (ឬថ្នាក់ទាបបំផុត), ប្រាំរយត្រូវចាត់ទុកជាមធ្យោបាយ(ពិន័យថ្នាក់កណ្តាល) ប៉ុន្តែមួយពាន់ ជាពិន័យថ្នាក់ខ្ពស់បំផុត។

១៣៩-បំណុលដែលត្រូវដល់ពេលសង (ចុងចោទ) នឹងបង់ (ពិន័យ) ប្រាំក្នុងមួយរយ ប្រសិនបើគេបដិសេធ(និងត្រូវរកការពិតឃើញ) គឺគុណនឹងពីរចំនួននោះ នេះជាការបង្រៀនរបស់ព្រះមនុ។

១៤០- អ្នកឱ្យខ្ចី អាចកំណត់ថាជាការបង្កើនមូលធនរបស់ខ្លួន ព្រោះវសិស្ឋអនុញ្ញាតឱ្យយកការប្រាក់ប្រចាំខែចំនួនមួយភាគប៉ែតសិបក្នុងមួយរយ។

១៤១- ឬតោងចាំករណីយកិច្ចរបស់មនុស្ស គេអាចយកពីរក្នុងមួយ(ក្នុងមួយខែ) ព្រោះអ្នកដែលយកពីរក្នុងមួយរយនឹងមិនក្លាយជាជនប្រព្រឹត្តអំពើបាប ព្រោះការរកចំណេញទេ។

១៤២- គ្រាន់តែពីរ បី បួន និងប្រាំក្នុងមួយរយ(និងមិនលើសពីនេះ) គេអាចយកជាការប្រាក់ប្រចាំខែស្របតាមលំដាប់នៃវណ្ណៈ។

១៤៣-ប៉ុន្តែបើការសន្យាចែកផលចំណេញ (ជាប្រភេទកិច្ចសន្យាដែលចែកផលចំណេញ) គេនឹងមិនយកការប្រាក់ចំពោះកម្ចីទេ ហើយគេមិនអាចធ្វើបានទេ បន្ទាប់ពីធ្វើកិច្ចសន្យា (បែបនេះ) ជាការឱ្យ ឬលក់វាសម្រាប់រយៈពេលវែង។

**១៣៦.** មួយ ករសៈ = ១៦ មាសៈ = ៨០ ក្ឫស្ណលៈ។

**១៣៩.** វិ. ជំពូក៥ លេខ២០-២១; យញ្ញ. ជំពូក២ លេខ៤២។ យោងតាមនារ. ថា 'អ្នកខ្លះយល់ថា' មានតែក្នុងកាព្យប៉ុណ្ណោះ។

**១៤០.** គោត. ជំពូក១២ លេខ២៩; យញ្ញ. ជំពូក២ លេខ៣៧។ តម្រាវិធាននេះ មាននៅក្នុងវាសិស្ឋ ធម៌សាស្ត្រ ជំពូក២ លេខ៥១។ ចំនួនគឺដប់ប្រាំភាគរយក្នុងមួយឆ្នាំ។ យោងតាមកុល្លូ. (កាព្យលេខ១៤១), នារ., រាឃ. និងនន្ទ. ថា វិធាននេះសំដៅដល់បំណុល ដែលធានាដោយកិច្ចសន្យា ហើយការកែតម្រូវយោបល់នេះ មានបញ្ជាក់ដោយសេចក្តីប្រហែលគ្នានៃគម្ពីរយញ្ញ.។

**១៤១-១៤២.** វស. ជំពូក២ លេខ៤៨; វិ. ជំពូក៦ លេខ២; យញ្ញ. ជំពូក២ លេខ៣៧។ វិធាននេះ យោងតាមអ្នកអធិប្បាយដដែលថា សំដៅដល់កម្ចីដែលគ្មានការធានា។ ព្រាហ្មណ៍ ត្រូវបង់ពីរភាគរយក្នុងមួយខែ ក្សត្រិយបង់បីភាគរយ វៃស្យៈបង់បួនភាគរយ ហើយសូទ្រៈបង់ប្រាំភាគរយ។ មេធ. និងគោវ. គិតថា វិធាននេះសំដៅដល់ករណីដែលម្ចាស់បំណុលមិនអាចរស់បានដោយសារអត្រាការប្រាក់ទាបជាងនេះ។

**១៤៣.** គោត. ជំពូក១២ លេខ៣២; វិ. ជំពូក៦ លេខ៥។ 'កិច្ចសន្យាចែកផលចំណេញ' មាន 'ដីធ្លី សត្វគោក្របី ទាសករជាដើម'។ យោងតាមមេធ., គោវ. និងនារ. ថា អនុប្រយោគចុងក្រោយសំដៅដល់កិច្ចសន្យា ដែលមិនមានប្រើ។ ប៉ុន្តែលោកកុល្លូ. បដិសេធថា នេះផ្ទុយនឹងការអនុវត្តទូទៅរបស់សិស្ថៈ ហើយរាឃ. សំដៅដល់យញ្ញ. ជំពូក២ លេខ៥៨ ដែលមានបញ្ជាក់ច្បាស់ថា កិច្ចសន្យាចែកផលចំណេញ គឺមិនចេះខាតទេ ចំណែកឯកិច្ចសន្យាណាដែលខាត គឺពេលដែលបំណុលដើម ត្រូវបានគុណនឹងពីរ ដោយចំនួនការប្រាក់ដែលមិនបានបង់។

១៤៤- កិច្ចសន្យា(ដែលត្រូវរក្សាប៉ុណ្ណោះ) គឺគេមិនត្រូវប្រើកម្លាំង (ម្ចាស់បំណុល)បើធ្វើដូច្នេះ នឹងបាត់បង់ការប្រាក់របស់ខ្លួន(ទាំងស្រុង) ឬ(បើកិច្ចសន្យាត្រូវខកខានដោយការប្រើប្រាស់) គេនឹងបំពេញលក្ខខណ្ឌ(របស់ម្ចាស់) ដោយសងតម្លៃដើម (នៃកិច្ចសន្យានោះ) បើមិនដូច្នោះទេគេប្រព្រឹត្តចោរកម្មនៃកិច្ចសន្យា។

១៤៥- ទាំងកិច្ចសន្យា ទាំងប្រាក់ដែលបានផ្តល់ អាចលែងមានន័យ ដោយសារអស់សុពលភាព ហើយគេអាចទារវាមកវិញបានទាំងពីរ ទោះបីវាបានពន្យាពេលយ៉ាងយូរ(តាមអ្នកបង់ប្រាក់ជានា)ក្តី។

១៤៦- វត្ថុដែលគេប្រើដោយមានការយល់ព្រមជាមិត្តភាព មេគោ អូដ្ឋ សេះជំនិះ និង(សត្វតិរច្ឆាន) ដែលមានការបំពានកិច្ចសន្យា នឹងមិនត្រូវបាត់បង់(សម្រាប់ម្ចាស់)ឡើយ។

១៤៧- (តែជាទូទៅ) វត្ថុសង្ហារិមអ្វីក៏ដោយ ដែលម្ចាស់ឃើញនៅជាមួយអ្នកដទៃ ក្នុងអំឡុងដប់ឆ្នាំ ទោះក្នុងពេលបច្ចុប្បន្នគាត់មិននិយាយអ្វីសោះក៏ដោយ គាត់នឹងមិនអាចទារ(របស់)នោះ មកវិញបានទេ។

១៤៨- បើសិនជា(ម្ចាស់)មិនមែនជាមនុស្សឆ្កួត និងមិនមែនជាអនីតិជន ហើយប្រសិនបើ(សង្ហារិមរបស់គាត់)នៅជាមួយ(មនុស្សម្នាក់ទៀត)នៅចំពោះមុខគាត់ តាមច្បាប់របស់នោះលែងជារបស់គាត់ហើយ ហើយម្ចាស់ម្ខាងទៀតនឹងរក្សាទុកទ្រព្យនោះ។

១៤៩- កិច្ចសន្យា ព្រំប្រទល់ កម្មសិទ្ធិរបស់កូនក្មេង ការផ្ញើ(ជាចំហ) ការផ្ញើដោយមានបិទត្រាសៀលស្ត្រី កម្មសិទ្ធិរបស់ព្រះរាជា និងទ្រព្យរបស់ស្រោត្រិយ មិនត្រូវបាត់ដោយហេតុផលប្រើប្រាស់(របស់អ្នកផ្សេង)ទេ។

១៥០- មនុស្សឆ្កួតដែលប្រើកិច្ចសន្យាដោយគ្មានការអនុញ្ញាតពីម្ចាស់ នឹងបន្ទូរបន្ថយផលប្រយោជន៍របស់គេពាក់កណ្តាល សម្រាប់ជាការសងចំពោះការប្រើប្រាស់នោះ។

**១៤៤.** រិ. ជំពូក៦ លេខ៥; យញ្ញ. ជំពូក២ លេខ៥៩។ យោងតាមមេធ. ថា គឺសំដៅដល់សម្លៀកបំពាក់ជាដើម ហើយតាមកុល្លូ. និងរាឃ. ថា សម្លៀកបំពាក់ គ្រឿងអលង្ការជាដើម និងតាមនារ. ថា គ្រែជាដើម។ នារ. គិតថា សំនួនពាក្យ 'តម្លៃ' សំដៅដល់ផលចំណេញដែលបានពីការប្រើប្រាស់កិច្ចសន្យានោះ។

**១៤៥.** រិ. ជំពូក៦ លេខ៧-៨; យញ្ញ. ជំពូក២ លេខ៥៨។ យោងតាមមេធ. កិច្ចសន្យានៅទីនេះ គឺ 'កិច្ចសន្យាសម្រាប់រក្សាការប្រើប្រាស់ដោយបង្ខំ'។ *ឧបនិធិ* 'ការផ្ញើ' តាមលោកមេធ., គោវ., កុល្លូ. (យ៉ាងណាមិញ ដែលឱ្យន័យពាក្យនេះ សំដៅដល់ការផ្ញើដែរ) លោករាឃ. និងនន្ទ. ថា 'អ្វីៗដែលគេឱ្យម្នាក់ទៀតខ្ចីក្រៅពីមិត្តភាព' ហើយតាមនារ. ថា 'ការសន្យាបន្ថែមដែលធ្វើនៅពេលក្រោយ ដើម្បីជានាបានទាំងស្រុងចំពោះកម្មវិធីនោះ'។

**១៤៧-១៤៨.** គោត. ជំពូក១២ លេ៣៧; វស. ជំពូក១៦ លេខ១៦-១៧; យញ្ញ. ជំពូក២ លេខ២៤។

**១៤៩.** វស. ជំពូក១៦ លេខ១៨; គោត. ជំពូក១២ លេខ៣៨-៣៩; យញ្ញ. ជំពូក២ លេខ២៥។ 'ស្ត្រី' គឺ 'ទាសករស្រីបែបនេះជាដើម'។ រាឃ.បន្ថែមថា កូនចៅរបស់ពួកគេ មិនត្រូវបាត់បង់សម្រាប់ម្ចាស់នោះទេ។ ឧបនិធិ 'ការផ្ញើដោយមានត្រាសៀល'(គោវ., នារ. និងរាឃ.)។

**១៤៤.** តាមអ្នកអធិប្បាយថា នេះជាផលវិបាកដែលបណ្តាលមកពីការប្រើកិច្ចសន្យាជាសម្ងាត់ដោយគ្មានការអនុញ្ញាតក្នុងករណីធម្មតា រីឯការបាត់បង់ប្រយោជន៍ទាំងស្រុង កើតចេញពីការប្រើប្រាស់ដោយបង្ខំ ជាការបំពាន ខ ហាមឃាត់ពិសេស។

១៥១- ក្នុងការរកស៊ីលុយកាក់ ការប្រាក់ដែលត្រូវបង់មួយលើក (មិនត្រូវបន្តបន្ថែម) នឹងមិនត្រូវឱ្យលើសពីរដង(នៃប្រាក់ដើម) ហើយចំពោះធញ្ញជាតិ ផ្លែឈើ រោម ឬសក់សត្វ (និង)សត្វដឹកទំនិញ មិនត្រូវឱ្យច្រើនជាងប្រាំដង(ចំនួនដើម)ទេ។

១៥២- ការប្រាក់ដែលកើនលើសអត្រាកំណត់ស្របច្បាប់ ដែលផ្ទុយនឹង(ច្បាប់) មិនអាចឱ្យគេសងវិញបានទេ ហើយគេហៅថា (ការឱ្យប្រាក់ខ្ចី)យកការប្រាក់ហុតឈាម ហើយ(អ្នកឱ្យខ្ចីគ្មានសិទ្ធិ)យកលើសពីប្រាំភាគរយទេ។

១៥៣- ចូរគេកុំយកការប្រាក់ហួសពីមួយឆ្នាំ គេមិនគាំទ្រឱ្យធ្វើដូច្នេះទេ កុំបញ្ចូលការប្រាក់ ការប្រាក់តាមកាលកំណត់ ការប្រាក់កំណត់ជាក់លាក់ និងការប្រាក់ពលកម្ម។

១៥៤- អ្នកដែលមិនអាចសងបំណុល(តាមកាលកំណត់)បាន ចង់ធ្វើកុងត្រាថ្មី អាចធ្វើកិច្ចព្រមព្រៀងជាថ្មី បន្ទាប់ពីបង់ការប្រាក់តាមការកំណត់។

**១៥១.** គោត. ជំពូក១២ លេខ៣១, ៣៦; រិ. ជំពូក៦ លេខ១១-១៥; យញ្ញ. ជំពូក២ លេខ៣៩។ ការប្រាក់ក្នុងន័យនេះ ជាអ្វីដែលគេមិនបង់បន្ថែម ប៉ុន្តែត្រូវសងជាមួយនឹងប្រាក់ដើម។ តាមអ្នកអធិប្បាយថា ចំនួនដែលត្រូវសងទាំងស្រុង គឺ ការប្រាក់បូននឹងប្រាក់ដើម មិនត្រូវឱ្យលើសទ្វេដងនៃចំនួនឱ្យខ្ចីទេ ឬក្នុងករណីពិសេសដូចបានរៀបរាប់ គឺប្រាំដងក្នុងចំនួន។

**១៥២.** យោងតាមគោវ. និងនារ. កាព្យនេះផ្តល់សិទ្ធិឱ្យអ្នកខ្ចីឱ្យលុយ អាចយកការប្រាក់ប្រាំភាគរយពីអាប៊្រន មិនយកពីពួកសូទ្រៈតែប៉ុណ្ណោះ។

**១៥៣.** គោត. ជំពូក១២ លេខ៣០, ៣៤-៣៥។ 'ម្ចាស់បំណុល'អាចយកការប្រាក់សម្រាប់មួយឆ្នាំតាមការព្រមព្រៀងថា 'ពេលមួយ ពីរ ឬបីខែបានកន្លងផុតទៅ ការប្រាក់(ផ្អែកលើដើមទុន)នឹងត្រូវគណនា និងសងឱ្យខ្ញុំមួយលើក' ប៉ុន្តែគេមិនត្រូវយកការប្រាក់តាមការសន្យា ដែលកន្លងហួសទៅមួយឆ្នាំនោះទេ(កុល្លូ., រាឃ.)។ តាមគោវ. អនុប្រយោគនេះ មានន័យថា 'បើ(ម្ចាស់បំណុល)មិនបានលុយ(តាមការកំណត់)អស់ពីរ ឬបីឆ្នាំ ហើយបន្ទាប់មក(កូនបំណុល)សងម្ចាស់បំណុល

នឹងមិនយកការប្រាក់លើសពីមួយឆ្នាំទេ'។ នារ. និយាយថា '*អតិសាំវត្សរីម* (ហួសមួយឆ្នាំ)មានន័យថា (ការប្រាក់)ដែលបន្ទាប់ពីហួសកាលកំណត់មួយឆ្នាំ មិនចាំបាច់ទៀតទេ' គឺ 'លើសពីចំនួនទ្វេដង'(សូមមើលកាព្យលេខ១៥១)។ *អធ្វសាំ* 'ដែលគ្មានការអនុញ្ញាត' គឺ 'តាមគម្ពីរច្បាប់'(កុល្ល., រាឃ.) ឬ 'តាមគម្ពីរច្បាប់ និងតាមជីវិតប្រចាំថ្ងៃ'(នន្ទ.) ហើយតាមមេធ. និងគោវ. ថា *អនុបចិតាំ* 'ដែលមិនបានប្រមូល' គឺ 'ដែលត្រូវយកមួយ ពីរ ឬបីថ្ងៃ'។ នារ. យល់ស្របតាមយោបល់ក្រោយ នេះ។ *កាលវ្ឫទ្ធិះ* 'ការប្រាក់តាមកាលកំណត់' គឺ 'ការប្រាក់ប្រចាំខែ'(គោវ., នារ.) ឬ 'ការប្រាក់ដែលបំពានកាព្យ ១៥១'( កុល្ល., រាឃ.)។ *ការិតា* 'ការប្រាក់បន្ថែម' គឺ 'អត្រាការប្រាក់ខុសច្បាប់ ឬការប្រាក់ដែលបូកថែមលើប្រាក់ ដើមដែលកើនទ្វេដង មានការព្រមព្រៀងពីកូនបំណុល ក្នុងគ្រាអាសន្ន'(មេធ., គោវ., នារ., កុល្ល., រាឃ.)។ *កាយិកា* ការប្រាក់ពលកម្ម' ជា 'ការប្រាក់ដែលត្រូវសងដោយការធ្វើពលកម្មកម្លាំងបាយ ឬដោយប្រើកម្លាំងកាយរបស់សត្វ ឬទាសករដែលបានសន្យា'(មេធ.)។ លោកកុល្ល., រាឃ. និងនន្ទ. ផ្ដល់ការបកស្រាយន័យទីពីរ។ តាម 'អ្នកខ្លះ'ដែលលោកមេធ. និងនារ. ស្រង់សំដី ប្រភេទការប្រាក់បួនចុងក្រោយ មិនត្រូវបានហាមឃាត់ទេ។ លោកមេធ. និងគោវ. គិតថា ការប្រាក់ខ្លះ ឬទាំងអស់អាចធ្វើ ទៅបានសម្រាប់ឈ្មួញ។ សូមមើលការបកស្រាយពាក្យ គោត. ជំពូក១២ លេខ៣៤-៣៥ សេចក្ដីសម្គាល់ និង Colebrooke ជំពូក១ អត្ថបទសង្ខេប លេខ៣៥-៤៥។

**១៥៤.** *ករណៈ* 'ការព្រមព្រៀង' គឺ 'ការធានាជាលាយលក្ខណ៍អក្សរ'(កុល្ល., រាឃ.) ឬ 'លិខិតលាយលក្ខណ៍អក្សរដោដើម' (គោវ., នារ.)។ តាមអ្នកទាំងពីរក្រោយនេះ ក៏ដូចជាលោកមេធ.ដែរ ហាក់ដូចជាយល់ស្របគ្នាថា ករុណៈ អាចសំដៅដល់ការព្រមព្រៀងជាពាក្យសម្ដី នៅចំពោះមុខសាក្សីក៏បាន។

១៥៥- ប្រសិនបើគេមិនអាចសងលុយ (តាមការប្រាក់) គេអាចដាក់វាបញ្ចូលក្នុង(កិច្ចព្រមព្រៀង)ថ្មីបាន ហើយគេត្រូវសងការប្រាក់ច្រើនតាមការកំណត់នោះ។

១៥៦- អ្នកដែលបានធ្វើកិច្ចសន្យាដឹកទំនិញដោយរទេះកង់ដើម្បីយកលុយ និងយល់ព្រមដឹកទៅកាន់កន្លែង ឬពេលវេលាណាមួយជាក់លាក់ នឹងមិនបានទទួលផលនោះទេ ប្រសិនបើគេមិនរក្សាទីកន្លែង និងពេលវេលា(ដែលបានកំណត់)។

១៥៧- អត្រាអ្វីក៏ដោយក៏មនុស្សអាចកំណត់ អ្នកមានជំនាញក្នុងការធ្វើដំណើរតាមសមុទ្រ នឹងអាចគណនា(ប្រាក់ចំណេញ)ស្របតាមទីកន្លែង ពេលវេលា និងវត្ថុ(ដែលត្រូវដឹក) ការព្រមព្រៀងនោះ(មានអំណាចផ្លូវច្បាប់) ក្នុងករណីបែបនេះ ត្រូវតែសងជាចាំបាច់។

១៥៨- អ្នកដែលធ្វើជាអ្នកធានានៅក្នុង(លោក)នេះដើម្បីបង្ហាញខ្លួនរបស់(កូនបំណុល) និងមិនផ្ដល់ផលដល់គេនោះ នឹងសងបំណុលដែលមិនមែនជាទ្រព្យផ្ទាល់របស់ខ្លួន។

១៥៩- ប៉ុន្តែលុយដែលអ្នកធានាត្រូវសង ឬសន្យាដោយគ្មានបានប្រយោជន៍ ឬខាតបង់ក្នុងការធានា ឬដូចជាបង់ថ្លៃស្រា ឬអ្វីដែលនៅសល់មិនទាន់បានបង់ថ្លៃពិន័យ និងពន្ធឬអាករ ហើយកូនប្រុស(របស់ភាគីជំពាក់នោះ) នឹងមិនមានកាតព្វកិច្ចត្រូវសងទេ។

១៦០- វិធានដែលបាននិយាយមកនេះ នឹងអនុវត្តចំពោះករណីធានាក្នុងការបង្ហាញខ្លួន (ប៉ុណ្ណោះ) ប្រសិនបើអ្នកធានាសងនោះស្លាប់ (ចៅក្រម)អាចបង្ខំឱ្យទាយាទរបស់ខ្លួន សងបំណុលនោះ។

១៦១- តើមានអ្វីកើតឡើងបន្ទាប់ពីមរណភាពរបស់អ្នកធានាក្រៅពីការសង ដែលការងាររបស់គាត់ត្រូវបានដឹងឮទាំងស្រុង ម្ចាស់បំណុល(ក្នុងករណីខ្លះ)ក្រោយមក អាចទារបំណុលពី(ទាយាទ) នោះបានឬទេ?។

**១៥៥.** 'សង' គឺ សន្យាសងតាមការព្រមព្រៀងជាថ្មី។
**១៥៦.** ដូចលោកមេធ., គោវ., កុល្ល. និងរាឃ. ដែរ លើកលែងតែលោកនារ. និងនន្ទ. បកស្រាយ *ចក្រវ្ឫទ្ធិ* 'កិច្ចសន្យាដឹកទំនិញតាមរទេះកង់' ដោយ 'ការបូកការប្រាក់' ហើយលោកមេធ. នៅកាព្យលេខ១៥៧ បញ្ជាក់យោបល់នេះដែរ។
**១៥៧.** សំនួនវោហារ 'ក្នុងការធ្វើដំណើរតាមសមុទ្រ' រួមទាំងការធ្វើដំណើរតាមផ្លូវគោក(មេធ., គោវ., កុល្ល., រាឃ.) ឬ ការធ្វើដំណើរទាំងអស់(នារ.)។ អ្នកអធិប្បាយ ដែលបកស្រាយកាព្យខាងដើមសំដៅលើការបូកការប្រាក់ ពន្យល់កាព្យក្នុងន័យថា ឈ្មួញដែលជួញដូរតាមផ្លូវសមុទ្រ ត្រូវតែបងអត្រាការប្រាក់សម្រាប់ថវិកាដែលខ្ចីគេ ដែលអ្នកជំនាញអាចកំណត់បាន (សូមមើលយញ្ញ. ជំពូក២ លេខ៣៨)។ ការពិតអ្នកដទៃយល់តាម 'អត្រា'(វ្ឫទ្ធិ) ប្រាក់ឈ្នួលរបស់អ្នកដឹកជញ្ជូន ឬម្ចាស់នាវា។
**១៥៨-១៦០.** គោត. ជំពូក១២ លេខ៤២; វិ. ជំពូក៦ លេខ៤១; យញ្ញ. ជំពូក២ លេខ៤៧, ៥៣-៥៤។
**១៥៩.** 'ដែលសន្យាដោយឥតប្រយោជន៍' គឺ 'ដើរតួត្លុកជាដើម'(កុល្ល.) ឬ 'ធ្វើជាស្ពានចម្លងជាដើម'(នារ.) ឬ 'មិនមែនបំណងសាសនា តែសម្រាប់អ្នកចម្រៀងជាដើម'(នន្ទ.) ឬ 'ជាការកំប្លែង គឺធ្វើជាស្ពានចម្លងភក់ជាដើម'(រាឃ.) ឬ 'កម្រៃក្រៅជាដើម'(គោវ.)។
**១៦១.** 'ដែលគេដឹងកិច្ចការទាំងស្រុង'គឺ 'ហេតុដែលគេធ្វើជាអ្នកធានា(ឧ.ទា. សម្រាប់ការបង្ហាញខ្លួន ឬឥរិយាបថល្អ) ដែលបានដឹងទាំងស្រុង'(នារ., រាឃ.)។

១៦២- ប្រសិនបើអ្នកធានាបានទទួលថវិកា (ពីគាត់សម្រាប់អ្នកបង់ប្រាក់ធានា) និងមានថវិកាគ្រប់គ្រាន់ (ដើម្បីសង) ដូច្នេះ(ទាយាទរបស់គាត់)ដែលបានទទួលថវិកានោះ នឹងសងបំណុលក្រៅពីទ្រព្យរបស់គាត់ នោះជាវិធានដែលបានបញ្ញត្តិ។

១៦៣- កិច្ចសន្យាដែលធ្វើដោយបុគ្គលស្រវឹង ឬមនុស្សឆ្កួត ឬវិបល្លាសធ្ងន់ធ្ងរ (ដោយជំងឺជាដើម) ឬអ្នកនៅក្នុងបន្ទុកទាំងស្រុង ដោយកូនក្មេងឬមនុស្សជរាខ្លាំង ឬដោយ(ភាគី) ដែលគ្មានសិទ្ធិអំណាច គឺគ្មានសុពលភាពទេ។

១៦៤- កិច្ចព្រមព្រៀងណា ដែលធ្វើឡើងផ្ទុយនឹងច្បាប់ ឬផ្ទុយនឹងទម្លាប់បញ្ញត្តិ(របស់មនុស្សល្អ) មិនអាចមានអំណាចផ្លូវច្បាប់ទេ ទោះបីកិច្ចព្រមព្រៀងនោះធ្វើឡើងដោយ(តឹកតាងជាក់លាក់)ក្តី។

១៦៥- ការលក់ ឬការលក់បញ្ចាំដោយបន្លំ ការឱ្យឬការទទួលដោយបន្លំ និង(ការលក់ដូរ) ដែលគាត់រកឃើញថាមានការបន្លំ (ចៅក្រម)នឹងប្រកាសទុកជាមោឃៈ និងគ្មានសុពលភាព។

១៦៦- ប្រសិនបើកូនបំណុលស្លាប់ ហើយ(លុយដែលខ្ចីនោះ)ត្រូវធ្លាក់ទៅលើគ្រួសារ សាច់ញាតិ ដែលមិននៅក្រោមដំបូលតែមួយ សូម្បីពួកគេនៅបែកគ្នាក៏ដោយ ត្រូវតែសងបំណុលនោះ។

១៦៧- បើសូម្បីបុគ្គលដែលជាអ្នកនៅក្នុងបន្ទុកទាំងស្រុង ធ្វើកិច្ចសន្យាជាគុណប្រយោជន៍របស់គ្រួសារម្ចាស់(ផ្ទះ) ទោះបី(កំពុងរស់នៅ)ក្នុងប្រទេសខ្លួនក្តីឬនៅក្រៅប្រទេសក្តី នឹងមិនរំលាយកិច្ចសន្យានោះបានទេ។

១៦៨- អ្វីដែលគេឱ្យដោយបង្ខំ អ្វីដែលគេប្រើដោយបង្ខំ ព្រមទាំងអ្វីដែលបណ្តាលឱ្យមានការសរសេរដោយបង្ខំ និងកិច្ចពាណិជ្ជកម្មដទៃទាំងអស់ដែលធ្វើដោយបង្ខំ **មនុ**បានប្រកាសទុកជាមោឃៈ។

១៦៩- ទាំងបី គឺសាក្សី អ្នកធានា និងចៅក្រម ជាអ្នករងទុក្ខព្រោះរឿងអ្នកដទៃ ប៉ុន្តែបួន គឺព្រាហ្មណ៍មួយ អ្នកឱ្យលុយគេខ្ចីមួយ ឈ្មួញមួយនិងក្សត្រិយ៍មួយបានរុងរឿងខ្លួនឯង(ដោយសារអ្នកដទៃ)។

**១៦២.** *អលំធនះ* 'មានថវិកាគ្រប់គ្រាន់(សម្រាប់សង)' គឺ 'បានទទួលថវិកាស្មើនឹងកម្ចីតាមកិច្ចសន្យារបស់ខ្លួនសម្រាប់ការឈរធ្វើជាអ្នកធានា'(មេធ., គោវ., កុល្លូ., នារ.)។ តាមលោករាឃ. គុណស័ព្ទសំដៅដល់ទាយាទ និងមានន័យថា 'ប្រសិនបើគាត់មានថវិកាគ្រប់គ្រាន់ដើម្បីសង'។ នន្ទ. អាន *អលក្សិតះ* 'ប្រសិនបើគេរកមិនឃើញអ្នក ធានាដែលបានទទួលលុយទេ'(គឺ បានស្លាប់ ឬបាត់ខ្លួនជាដើម)។

**១៦៣.** យញ្ញ. ជំពូក២ លេខ៣២។

**១៦៤.** 'ការលក់ប្រពន្ធ និងកូន ដោយផ្តល់ទ្រព្យទាំងអស់របស់ខ្លួន ទោះបីជាគេមានការជំទាស់ក៏ដោយ'(មេធ.)។

**១៦៦.** វិ. ជំពូក៦ លេខ៣៩; យញ្ញ. ជំពូក២ លេខ៤៥។ តាមការគូសបញ្ជាក់របស់នន្ទ. អត្ថន័យគឺថា ប្រសិនបើបំណុលត្រូវបានចុះកិច្ចសន្យា ជាប្រយោជន៍របស់គ្រួសារទាំងមូល សមាជិកគ្រួសារនោះត្រូវចេញសងវិញ ទោះបីពួកគេអាចចែកផ្លូវគ្នាបន្ទាប់ពីនោះក៏ដោយ។

**១៦៧.** *អធ្យធីនះ* 'អ្នកនៅក្នុងបន្ទុកទាំងស្រុង' គឺ 'អ្នកបម្រើ'(នារ.) ឬ 'ទាសករ'(កុល្លូ.) ឬ '(ប្អូនប្រុស)ពៅគេ ឬអ្នកដែលមានឋានៈបែបនេះ'(រាឃ.)។ គោវ. អាន *វា* ជំនួសពាក្យ អបិ ហើយ(មេធ., កុល្លូ., រាឃ.) ប្រើ *វិចាលយេត* ឬ*វិចារយេត* (នន្ទ.), *វិលំពយេត* ហើយចំពោះអំណាននេះ ការបកប្រែអាចថា 'ឬអ្នកនៅក្នុងបន្ទុកទាំងស្រុង ដែលធ្វើ ខ សន្យាជាប្រយោជន៍គ្រួសារ ត្រូវរងចាំដល់ម្ចាស់ផ្ទះ(មកដល់)សូម្បីគាត់នៅក្នុងស្រុក ឬក្រៅស្រុកក៏ដោយ'។

**១៦៨.** វិ. ជំពូក៧ លេខ៦; យញ្ញ. ជំពូក២ លេខ៤៩។

**១៦៩.** *កុលំ* ចៅក្រម' (មេធ., គោវ., កុល្លូ.) ហើយតាមនារ., នន្ទ. និងរាឃ. ឱ្យន័យធម្មតាថា 'គ្រួសារ'។ លោកនារ. និង

១៧០- សូម្បីខ្សត់ខ្សោយយ៉ាងណាក្តី គ្មានស្តេចណាមិនទទួលអ្វីដែលមិនគួរទទួលទេ ហើយគ្មានស្តេចណា ទោះបីសម្បូណ៌ទ្រព្យសម្បត្តិយ៉ាងណា បដិសេធមិនទទួលអ្វីដែលទ្រង់គួរទទួលទេ ទោះជាទ្រព្យនោះតូចតាចប៉ុនណាក៏ដោយ។

១៧១- ដោយសារទ្រង់យកអ្វីដែលមិនគួរយក ឬទ្រង់បដិសេធមិនយកអ្វីដែលគួរទទួល ព្រះអង្គនឹងត្រូវចោទថាស្តេចខ្សោយ ហើយនឹងវិនាសនៅក្នុងលោកនេះ និងជាតិក្រោយ។

១៧២- ដោយការយកពន្ធរបស់ទ្រង់ ដោយការការពារភាពច្របូកច្របល់នៃវណ្ណៈ និងដោយការការពារអ្នកខ្សោយ អំណាចរបស់ស្តេចកើនឡើង ហើយព្រះអង្គរុងរឿងក្នុងជាតិនេះ និងជាតិក្រោយ។

១៧៣- ហេតុនេះ ចូរព្រះអង្គ ដូចព្រះយមៈ ដោយមិនគិតគូរពីការចូល និងមិនចូលចិត្តរបស់ទ្រង់ផ្ទាល់ ប្រព្រឹត្តដូចជាព្រះយមៈទាំងស្រុង ដោយខំទប់កំហឹង និងគ្រប់គ្រងខ្លួនព្រះអង្គ។

១៧៤- ប៉ុន្តែព្រះរាជាចិត្តអាក្រក់ដែលវិនិច្ឆ័យរឿងក្តីដោយអយុត្តិធម៌តាមភាពចំកួតរបស់ទ្រង់ នោះសត្រូវរបស់ទ្រង់នឹងបង្ខំឱ្យចុះពីអំណាចក្នុងពេលឆាប់ៗ។

១៧៥- ប្រសិនបើជម្នះបានសេចក្តីស្រឡាញ់និងស្អប់ ព្រះអង្គវិនិច្ឆ័យរឿងក្តីស្របតាមគតិច្បាប់ (ចិត្តរបស់)ប្រជារាស្ត្រទ្រង់ហូរមកកាន់ទ្រង់ បីដូចទឹកទន្លេទាំងឡាយ(ហូរ)ទៅកាន់សមុទ្រ។

១៧៦- (កូនបំណុល) ដែលប្តឹងព្រះរាជា ដែលម្ចាស់បំណុលរបស់ខ្លួនទាមទារសង(បំណុល)ដោយឯករាជ្យ(នៅក្នុងតុលាការ) នឹងត្រូវព្រះរាជាបង្ខំឱ្យបង់(ពិន័យ)មួយភាគបួន(នៃចំនួនសរុប) និងសងលុយ(បំណុល)ដែលត្រូវសងម្ចាស់បំណុលខ្លួនវិញ។

១៧៧- សូម្បីដោយការធ្វើពលកម្ម(ផ្ទាល់ខ្លួន)ក្តី បើកូនបំណុលធ្វើល្អ (ចំពោះអ្វីដែលគេជំពាក់)ចំពោះម្ចាស់បំណុលខ្លួន ប្រសិនបើគេមានវណ្ណៈដូចគ្នាឬវណ្ណៈទាបជាង ប៉ុន្តែ(កូនបំណុល) ដែលមានវណ្ណៈខ្ពស់ជាង នឹងសងបំណុលបន្តិចម្តងៗ(នៅពេលដែលគេមានប្រភព ចំណូល)។

នន្ទ. និយាយថា ញាតិសន្តានដែលមិនទាន់បែកបាក់ ត្រូវរងទុក្ខក្នុងការសងបំណុលរបស់ម្ចាស់ទ្រព្យរួមដែលចែកឋានទៅ ហើយលោករាឃ. បកស្រាយទុក្ខព្រួយរបស់គ្រួសារ ដែលបំផ្លាញឬបង្កើតឡើងដោយកូនអាក្រក់។ មេធ., គោវ. និងកុល្លូ. បញ្ជាក់ថា កម្មវត្ថុកាព្យនេះ គឺដើម្បីបណ្ដុះគំនិតថា គេមិនត្រូវបង្ខំមនុស្សឱ្យធ្វើសាក្សីជាដើម ដែលប្រឆាំងនឹងធន្ទះរបស់ខ្លួន ហើយថា ព្រាហ្មណ៍ជាដើម មិនត្រូវបង្ខំអ្នកដទៃ ឱ្យធ្វើកិច្ចការទាំងឡាយ ដើម្បីពួកគេបានប្រយោជន៍ ឧ.ទា. តាមផ្លូវច្បាប់ទេ។ (ដូចគ្នារាឃ. ដែរ) នារ. ប្រែកាព្យពាក់កណ្ដាលទីមួយថាជាការព្រមាន កុំធ្វើជាសាក្សី ឬអ្នកធានា ឬរក្សាកុំឱ្យមានការបែកបាក់។

**១៧០.** វស. ជំពូក១៩ លេខ១៤-១៥។

**១៧១.** "ព្រោះប្រសិនបើព្រះរាជាយកអ្វីដែលទ្រង់មិនគួរយកពីប្រជារាស្ត្ររបស់ទ្រង់ រាស្ត្រនឹងនិយាយថា "ទ្រង់ពិន័យយើងពីព្រោះព្រះអង្គមិនអាចយកឈ្នះលើប្រទេសចំណុះ ប្រទេសជិតខាង និងកុលសម្ព័ន្ធព្រៃ (ហើយទទួលថវិកាពីពួកគេ)ទេ"" (មេធ.)។

**១៧៦.** វិ. ជំពូក៦ លេខ១៩។ សូមមើលកាព្យលេខ៤៩-៥០ ខាងលើ។

**១៧៧.** អនុប្រយោគចុងក្រោយសំដៅដល់ព្រាហ្មណ៍(មេធ., កុល្លូ., រាឃ.)។

១៧៨- យោងតាមតម្រាវិធានទាំងនេះ ចូរព្រះរាជាវិនិច្ឆ័យដោយសមធម៌រវាងគូក្ដី ដែលមានវិវាទនឹងគ្នាលើបញ្ហាផ្សេងៗ ដែលផ្ដល់កសិណដោយសាក្សីនិងភស្តុតាង(ផ្សេងៗទៀត)។

១៧៩- មនុស្សដែលមានសតិល្អគួរធ្វើរបស់ (តែ) ជាមួយមនុស្សដែលមានប្រវត្តិគ្រួសារ (ល្អ) មានការប្រព្រឹត្តល្អ យល់ដឹងច្បាប់បានល្អប្រសើរ ប្រកាន់សេចក្ដីទៀងត្រង់ មានញាតិសន្តានច្រើន សម្បូណ៌ទ្រព្យធន និងមានសេចក្ដីថ្លៃថ្នូរ(ជាអារ្យា)។

១៨០- ដោយវិធីបែបណាក៏ដោយ មនុស្សម្នាក់នឹងផ្ញើអ្វីមួយក្នុងដៃមនុស្សម្នាក់ទៀត តាមរបៀបដូចគ្នា (ដែលម្ចាស់) គួរតែបានទទួលរបស់ដដែលនោះមកវិញ ព្រោះថាការប្រគល់(ត្រូវតែមាន)ការប្រគល់ត្រឡប់មកវិញ។

១៨១- អ្នកដែលមិនព្រមប្រគល់វត្ថុបញ្ញើនៅនឹងខ្លួន ជូនអ្នកផ្ញើតាមសំណើរបស់គេ ចៅក្រមអាចកាត់ក្ដីកំបាំងមុខរបស់អ្នកផ្ញើបាន(ដោយមិនចាំបាច់មានវត្តមានរបស់អ្នកផ្ញើ)។

១៨២- បើគ្មានកសិណសាក្សី ចូរ(ចៅក្រម)ការពិតត្រូវទុកមាសនៅជាមួយ(ចុងចោទ)នោះ ក្នុងហេតុផលឧបាយមួយចំនួន ឬឧបាយផ្សេងៗ ដោយមានចារបុរសដែលមានវ័យសមស្រប និងអាចបង្ហាញខ្លួន (ក្រោយពីទាមទារមាសនោះ)បានមកវិញ។

១៨៣- ប្រសិនបើ (ចុងចោទ) ប្រគល់របស់តាមរបៀបនិងរូបភាពដែលបង់ប្រាក់ជានានោះ គឺគ្មានអ្វី (ដូចការរៀបរាប់ថា)នៅក្នុងដៃរបស់ខ្លួនទេ ដូចអ្នកដទៃចោទគាត់នោះទេ។

១៨៤- ប៉ុន្តែបើគាត់មិនប្រគល់មាសនោះតាមការតម្រូវទៅឱ្យ (ចារបុរស) នោះ ដូច្នេះគាត់នឹងត្រូវបង្ខំឱ្យប្រគល់(វត្ថុបញ្ញើ)ទាំងពីរមកវិញ ហើយនេះជាតម្រាវិធានច្បាប់ដែលបានបញ្ញត្តិទុក។

១៨៥- បញ្ញើបើក ឬមិនសៀល មិនត្រូវប្រគល់ឱ្យញាតិជិតខាង (របស់អ្នកផ្ញើក្នុងកំលុងពេលរស់នៅរបស់អ្នកក្រោយ) ព្រោះប្រសិនបើ(អ្នកទទួលនោះ)ស្លាប់ ដោយមិនបានប្រគល់វត្ថុបញ្ញើ) វានឹងត្រូវបាត់ ប៉ុន្តែបើគាត់មិនស្លាប់ របស់ក៏មិនបាត់។

១៨៦- ប៉ុន្តែ(អ្នកទទួលបញ្ញើ) ដែលព្រមព្រៀងប្រគល់បញ្ញើឱ្យសាច់ញាតិជិតដិតរបស់(អ្នកផ្ញើ) ដែលបានស្លាប់ មិនត្រូវព្រះរាជាឬសាច់ញាតិរបស់ម្ចាស់បញ្ញើនោះ មករុកគួនរំខាន (រឿងបញ្ញើ) នោះទេ។

**១៧៨.** *ប្រត្យយ*កស្តុតាង(ដទៃទៀត)' គឺ 'ដោយការសន្និដ្ឋាន និងភស្តុតាងអាទិទេព'(មេធ.) ឬ 'ដោយការសន្និដ្ឋាន និងពាក្យសម្បថជាដើម'(គោវ.) ឬ 'ដោយពាក្យសម្បថ'(នារ., នន្ទ.)។

**១៨០.** យញ្ញ. ជំពូក២ លេខ៦៥។ សូមមើលកាព្យលេខ១៩៥ខាងក្រោម។ លោកនន្ទ. លុបចោលកាព្យលេខ១៨៤ ហើយដាក់កាព្យដទៃតាមលំដាប់ដូចជា ១៨០, ១៩៥, ១៨៨b, ១៨៥, ១៨៦, ១៨៩, ១៩៤, ១៨៧, ១៨៨a, ១៨១, ១៨២, ១៨៣, ១៩៦, ១៩០, ១៩១, ១៩២, ១៩៣។

**១៨១.** លំដាប់កាព្យសំដៅដល់ការសាកល្បងអ្នកទទួលរបស់បញ្ញើ តាមលោកគោវ. គឺកាព្យ១៨១, ១៨៣, ១៨៤, ១៨២ ហើយតាមនារ. គឺ ១៨១, ១៨៣, ១៨២, និង១៨៤។

**១៨៥.** *ប្រយុទន្តរ* 'ឱ្យទៅញាតិជិតដិត' គឺ 'ឱ្យទៅកូន បងប្អូន ឬប្រពន្ធរបស់ខ្លួន'(មេធ.)។

១៨៧- ហើយ(ក្នុងករណីមានការមន្ទិល) គេគួរតែព្យាយាមយកវត្ថុនោះដោយវិធីមិត្តភាព ដោយមិនប្រើឧបាយ(ប្តឹង) ឬបន្ទាប់ពីបានស៊ើបសួរអំពីការប្រព្រឹត្ត(របស់អ្នកទទួលបញ្ញើ) គេគួរដោះស្រាយ(បញ្ហានោះ)ដោយវិធីទន់ភ្លន់។

១៨៨- វិធានបែបនេះ គឺសំដៅទារយកមកវិញនូវវត្ថុបញ្ញើបើកទាំងអស់ ហើយក្នុងករណីបញ្ញើមានត្រាសៀល (អ្នកទទួលបញ្ញើ) នឹងមិនចាំបាច់(ពិនិត្យ)ទេ បើសិនជាគាត់មិនបានយកអ្វីមួយចេញ។

១៨៩- (បញ្ញើ)ដែលត្រូវចោរលួចឬត្រូវទឹកកួចយក ឬក៏ត្រូវភ្លើងឆេះ (អ្នកទទួលបញ្ញើ) នឹងមិនទទួលខុសត្រូវទេ លើកលែងតែគាត់បានចំណែកខ្លះនៃបញ្ញើ(សម្រាប់ខ្លួនគាត់)។

១៩០- អ្នកដែលយកវត្ថុបញ្ញើមកធ្វើជារបស់ខ្លួននិងអ្នក(ដែលសុំបញ្ញើ) ដោយមិនបានផ្ញើបញ្ញើ (ចៅក្រម) នឹងព្យាយាមប្រើគ្រប់មធ្យោបាយ និងដោយវិធីស្បថដូចមានចែងនៅក្នុងព្រះវេទ។

១៩១- អ្នកដែលមិនបានប្រគល់វត្ថុបញ្ញើ និងអ្នកដែលទារយកអ្វីដែលមិនបានផ្ញើ នឹងត្រូវទទួលទោសទាំងពីរ ដូចចោរ ឬ ត្រូវបង្ខំឱ្យបង់ពិន័យស្មើ (នឹងតម្លៃវត្ថុដែលរក្សា ឬទារនោះ)។

១៩២- ព្រះរាជាគួរតែបង្ខំអ្នកដែលមិនប្រគល់សងបញ្ញើបើកឱ្យគេវិញ ហើយដូចគ្នានឹងអ្នកដែលរក្សាទុកបញ្ញើបិទត្រាសៀល ឱ្យបង់ពិន័យស្មើ(នឹងតម្លៃបញ្ញើ)។

១៩៣- មនុស្សដែលចង់បានទ្រព្យរបស់អ្នកដទៃធ្វើជារបស់ខ្លួនដោយឧបាយបន្លំ នឹងត្រូវមានការដាក់ទោសជាសាធារណៈ តាម(ទម្រង់)ផ្សេងៗជាការធ្វើទណ្ឌកម្មលើរូបកាយ (ឬពិន័យជាទ្រព្យ) រួមគ្នាជាមួយអ្នកសមគំនិតរបស់គាត់ផង។

**១៨៧.** យោងតាមនារ. កាព្យនេះសំដៅដល់រឿងក្តី ពេលដែលមនុស្សម្នាក់មានជំនឿក្នុងការផ្ញើរបស់ជា មួយមនុស្សម្នាក់ទៀត តែមិនបានធ្វើដោយខ្លួនឯងទេ ហើយតាមលោកគោវ. និងកុល្លូ. សំដៅដល់ករណី ដែលមានការភាន់ច្រឡំ។ គោវ. និងកុល្លូ. គិតថា បុគ្គលដែលត្រូវដើរតួនេះ គឺព្រះរាជា ហើយពួកគេបកស្រាយ *អន្វិច្ឆេត* 'គេគួរព្យាយាមយកឱ្យបាន' ដោយថា 'គេគួរសម្រេច'។ ផ្ទុយទៅវិញ នារ. និងរាឃ.គិតថា អ្នកផ្ញើគួរតែដើរតួនេះ។ ការបកស្រាយខាងដើមទំនងជាប្រសើរជាង។

**១៨៩.** យញ្ញ. ជំពូក២ លេខ៦៦។

**១៩០.** 'ដោយគ្រប់មធ្យោបាយ' គឺ 'ដោយឧបាយទាំងបួន ចិត្តមេត្តាជាដើម'(គោវ., កុល្ល., រាឃ.) ឬ 'ដោយចារបុរសជាដើម'(នារ.) ឬ 'ដោយការវាយដំ ការដាក់គុកជាដើម'(មេធ.)។ 'ដោយពាក្យសម្បថដូចមានចែងនៅក្នុងព្រះវេទ' គឺ 'ដោយការពិសោធន៍ ដូចជាការកាន់ភ្លើង'(គោវ., កុល្ល., នារ.)។ លោកនារ. ស្រង់សេចក្តីមួយនៅក្នុងព្រះវេទ ដែលបញ្ញត្តិថា ជនជាប់ចោទត្រូវកាន់ដែកពូថៅក្តៅ។

**១៩១.** រ. ជំពូក៥ លេខ១៦៩-១៧១។ ការដាក់ទោសពីមុន ដែលមានការកាត់អវយវៈ និងការដាក់ទណ្ឌកម្មលើរូបកាយផ្សេងៗទៀត(មេធ.,នារ.,រាឃ.)ឬការដាក់ពិន័យជាដើម(គោវ.) នឹងត្រូវអនុវត្តចំពោះអ្នកផ្សេងក្រៅពីព្រាហ្មណ៍ ជាពិសេសក្នុងករណីធ្ងន់ធ្ងរ និងការប្រព្រឹត្តបទល្មើសដដែលៗច្រើនដង(មេធ., គោវ., កុល្ល., នារ., រាឃ.)។

**១៩២.** លោកមេធ., គោវ. និងកុល្ល. បញ្ជាក់ថា វិធាននេះអនុវត្តចំពោះបទល្មើសថ្នាក់ទី១។ លោកនារ. ប្រែ *អវិសេសណា* តាមរបៀបនេះ' សំដៅដល់ 'ដោយមិនញែកច្បាស់អំពីវណ្ណៈរបស់ជនល្មើសទេ'។ លោកមេធ. បកស្រាយ *ឧបនិធិ* 'បញ្ញើដែលមានត្រាសៀល' ដោយថា 'វត្ថុដែលគេឱ្យខ្ចីក្នុងលក្ខណៈមិត្តភាព'។

**១៩៣.** 'ដោយការធ្វើពុតក្លែងបន្លំ' គឺ 'ដោយគំរាមអ្នកដទៃ ដោយថាព្រះរាជាខ្ញាល់ ដោយសន្យាទារយករបស់នោះ តាមព្រះទ័យទ្រង់ ឬការស្រឡាញ់របស់ស្រីកំណាន់ជាដើម'(មេធ.)។ 'ដោយការធ្វើទណ្ឌកម្មរូបកាយតាមទម្រង់(ផ្សេងៗ)' គឺ 'ដោយកាត់ដៃ កាត់ជើង ឬកាត់ក្បាលរបស់គេជាដើម'(គោវ., កុល្ល., រាឃ.) ឬ 'ដោយកាត់ក្បាល ឬចាក់សម្លាប់ជនល្មើស ឬឱ្យដំរីជាន់ជនល្មើសដល់ស្លាប់ជាដើម'(មេធ.)។

១៩៤- ប្រសិនបើបញ្ញើដែលនរណាម្នាក់ផ្ញើ មានរៀបរាប់ល្អិតល្អន់ ឬបរិមាណ ដោយមាន(សាក្សី)មួយចំនួននោះ គេត្រូវតែដឹងថា (ការរៀបរាប់)ល្អិតល្អន់និងបរិមាណ ដែលអ្នកទទួលបញ្ញើមានការរាប់បន្លំ(វត្ថុបញ្ញើ) គឺអ្នកទទួលបញ្ញើត្រូវទទួលពិន័យ។

១៩៥- ប៉ុន្តែប្រសិនបើគេប្រគល់ឬទទួលអ្វីមួយដោយផ្ទាល់គេត្រូវតែប្រគល់សងរបស់នោះទៅវិញ ព្រោះបញ្ញើ(គឺត្រូវមាន)ការប្រគល់សងវិញ។

១៩៦- ដូច្នេះចូរព្រះរាជាវិនិច្ឆ័យ (ក្តី) ពាក់ព័ន្ធនឹងបញ្ញើ និងកម្ចីលក្ខណៈមិត្តភាព (សម្រាប់ការប្រើប្រាស់) ដោយមិនបង្ហាញនូវភាពហ្មឹងម៉ាត់(មិនសមល្មម)ចំពោះអ្នកទទួលបញ្ញើ។

១៩៧- ប្រសិនបើនរណាម្នាក់លក់ទ្រព្យរបស់មនុស្សម្នាក់ទៀតដោយមិនមានវត្តមានម្ចាស់ និងដោយគ្មានការយល់ព្រមពីម្ចាស់ទ្រព្យ (ចៅក្រម)នឹងមិនថាគេជាចោរទេ ទោះបីគេមិនអាចចាត់ទុកខ្លួនឯងថាជាចោរ ជាសាក្សី(ក្នុងករណីណា)ក៏ដោយ។

១៩៨- ប្រសិនបើ (ជនល្មើស) ជាញាតិខាងប្រុស (របស់ម្ចាស់ទ្រព្យ) គាត់នឹងត្រូវពិន័យប្រាំមួយរយបណៈ បើគាត់មិនមែនជាញាតិខាងប្រុស និងមិនមានការដោះសារអ្វីសោះ គាត់នឹងមានទោសពីបទចោរកម្ម។

១៩៩- ការឱ្យ ឬលក់ ដែលធ្វើឡើងដោយអ្នកផ្សេង មិនមែនជាម្ចាស់ ត្រូវតែចាត់ទុកជាមោឃៈ និងគ្មានសុពលភាព ស្របតាមវិធានច្បាប់នៅក្នុងដំណើរការវិនិច្ឆ័យ។

២០០- ទីណាដែលការកាន់កាប់ជាក់ស្តែង ប៉ុន្តែមិនមានទទួលសិទ្ធិកាន់កាប់ ពេលនោះសិទ្ធិកាន់កាប់ គឺជាភស្តុតាងកម្មសិទ្ធិ មិនមែនការកាន់កាប់ទេ នេះជាវិធានច្បាប់បញ្ញត្តិ។

---

**១៩៤.** ពោលគឺ គេត្រូវតែពិនិត្យសាក្សីពាក់ព័ន្ធនឹងរឿងនេះ និងភស្តុតាងរបស់គេឱ្យបានប្រាកដប្រជា។

**១៩៦.** សេចក្តីសន្និដ្ឋាននេះធ្វើឱ្យមានមន្ទិលខ្លះថាតើពាក្យ *ឧបនិធិ* ដែលមាននៅក្នុងកាព្យ១៨៥ និង១៩១ និងត្រូវគេប្រែថា 'បញ្ញើបិទត្រាសៀល' ស្របតាមមតិរបស់អ្នកអធិប្បាយភាគច្រើនបំផុត គឺក្នុងន័យនេះឯង។

**១៩៨.** 'ការដោះសាណាមួយ' ឧ.ទា. 'ថាគាត់បានទទួលវាជាអំណោយ ឬបានទិញវាពីកូន ឬសាច់ញាតិផ្សេងទៀតរបស់ម្ចាស់ទ្រព្យជាដើម'(គោវ., កុល្ល.)។ លោកនារ. អាន *អនវសេយ* និងទិញដោយមិនសមស្រប(នឹងពេលវេលាឬទីកន្លែង)'។
**១៩៩.** នន្ទ. លុបកាព្យនេះចោល និងដាក់បញ្ចូលប្រយោគ 'អ្នកដែលលក់របស់ដែលគ្មានសិទ្ធិកាន់កាប់ ដោយការមិនដឹង នឹងត្រូវទទួលទោសតាមវិធានច្បាប់ខាងលើ(គឺត្រូវពិន័យ) ប៉ុន្តែអ្នកលក់ដែលបានដឹងជាមុន នឹងត្រូវដាក់ទោសស្មើនឹងបទចោរកម្ម'។ នារ. មិនមានសរសេរពាក់ព័ន្ធកាព្យ១៩៩ទេ តែស្រង់សេចក្ដីផ្ដើមកាព្យនេះដែលគ្រាន់ប្រែថា(អនេន វិធិនេតិ)។
**២០០.** នន្ទ. ដាក់កាព្យនេះបន្ទាប់ពីកាព្យ ២០២។
**២០១-២០២.** វិ. ជំពូក៥ លេខ១៦៤-១៦៦; យញ្ញ. ជំពូក២ លេខ១៦៨-១៧០។
**២០០.** លោកមេធ., កុល្ល., នារ. និងរាឃ. បកស្រាយដូច្នេះ។ (តែលោកកុល្ល. ប្រែ *សោធិតៈ* 'ដែលឱ្យរួចទោស' ក្នុងន័យ *និស្ចិតៈ* 'ដែលបានកំណត់')។ ប៉ុន្តែលោកគោវ. ប្រែផ្នែកទីមួយផ្សេងទៅវិញ។ 'ប្រសិនបើគាត់(អ្នកលក់) មិនអាចកំណត់តម្លៃ ព្រោះគាត់បានចេញទៅប្រទេសមួយទៀត ដូចនេះព្រះរាជាមិនត្រូវដាក់ទោសអ្នកទិញទេ ដោយចាត់ទុកថា គ្មានទោស ដោយការលក់ជាចំហ ស្របតាមវិធានច្បាប់ដែលមាននៅក្នុងកាព្យខាងដើម' ហើយលោកនន្ទ. ក៏យល់ប្រហាក់ប្រហែលនេះដែរ។ ចំណុចខុសគ្នាគឺថា គោវ. ទំនងជាជំទាស់នឹងការបកស្រាយ *មូលំ* (នន្ទ. សរសេរ *មូល្យំ*) ថា '(អ្នកលក់)ដើម'។ យោងតាមលោកកុល្ល. អ្នកទិញបានតម្លៃពាក់កណ្ដាល ពីម្ចាស់ដើម។

២០១- អ្នកដែលទទួលសង្ហារិមនៅទីផ្សារនៅចំពោះមុខ(សាក្សី)មួយចំនួនទទួលសង្ហារិមនោះ ជាប់ជាមួយសិទ្ធិកាន់កាប់ស្របច្បាប់ច្បាស់លាស់ តាមរយៈការទិញ។

២០២- ប្រសិនបើ(អ្នកលក់)ខ្លួនឯងមិនអាចទទួលផលបាន (អ្នកទិញ)ដែលត្រូវរួចទោស ដោយសារការលក់ជាសាធារណៈ ត្រូវព្រះរាជាបណ្ដេញចេញដោយគ្មានការដាក់ទោស ប៉ុន្តែ(ម្ចាស់ដើម) ដែលបាត់សង្ហារិម នឹងទទួលបានវត្ថុនោះ(ពីអ្នកទិញមកវិញ)។

២០៣- ទំនិញមួយដែលជាប់ពាក់ព័ន្ធនឹងមនុស្សផ្សេងទៀត មិនត្រូវគេលក់(ដោយគ្មានមន្ទិល) និងមិនអាក្រក់(តាមជាក់ស្ដែង) និងមិនតិច(ជាងបរិមាណ ឬទម្ងន់ពិត) និងមិនជាអ្វីដែលមិននៅក្នុងដៃ ឬដែលនៅទីកំបាំង។

២០៤- បើបន្ទាប់ពីមានការបង្ហាញស្រីក្រមុំ គេប្រគល់ស្រីក្រមុំម្នាក់ទៀតឱ្យទៅកូនកំលោះ គាត់អាចរៀបការអ្នកទាំងពីរក្នុងតម្លៃដូចគ្នា នេះជាបញ្ញត្តិរបស់មនុ។

២០៥- អ្នកដែលប្រគល់(ស្រីក្រមុំតាមវិធីអាពាហ៍ពិពាហ៍) ដោយទីមួយបានប្រកាសជាចំហអំពីចំណុចខ្វះខាតរបស់នាង ទោះជានាងឆ្កួតឬមានជំងឺឃ្លង់ ឬបាត់បង់ព្រហ្មចារីរបស់នាងក៏ដោយ មិនអាចទទួលទោសទេ។

២០៦- បើអាចារ្យពិធីការ ដែលបានទទួលការអញ្ជើញឱ្យរៀបចំពិធីយញ្ញ បោះបង់ការងាររបស់ខ្លួននោះ អ្នកដែលសហការជាមួយគាត់ត្រូវផ្ដល់ប្រាក់ឈ្នួលមួយចំណែកដល់គាត់ ស្របតាមការងារ(ដែលត្រូវបំពេញ)។

២០៧- ក៏ប៉ុន្តែអ្នកដែលបោះបង់ការងាររបស់ខ្លួន បន្ទាប់ពីបានទទួលថ្លៃឈ្នួលរៀបចំពិធី នឹងទទួលបានចំណែករបស់ខ្លួនទាំងស្រុង ហើយត្រូវបំពេញ(កិច្ចការដែលនៅសល់ទាំងអស់) ដែលអាចារ្យម្នាក់ ទៀតមិនទាន់បានបំពេញ។

២០៨- ប៉ុន្តែបើថ្លៃឈ្នួល(ជាក់លាក់) ត្រូវបានកំណត់សម្រាប់ផ្នែកជាច្រើននៃពិធីបុណ្យមួយ តើអ្នក(ដែលបំពេញការងារតាមផ្នែក)ទទួលកម្រៃផ្នែកនោះ ឬតើពួកគេនឹងចែកតម្លៃនោះទាំងអស់?។

**២០៣.** យញ្ញ. ជំពូក២ លេខ២៤៥។ 'ដែលនៅទីកំបាំង' គឺ 'នៅក្នុងក្រណាត់'(មេធ., នារ.) ឬ 'នៅក្នុងដី'(នន្ទ.) ឬ 'ដែលលាបពណ៌'(គោវ., កុល្ល., រាឃ.)។

**២០៤.** វិធានច្បាប់នេះ ជារឿងមួយចម្លែកបន្តិច បន្ទាប់ពីអ្វីដែលមាននិយាយនៅក្នុងជំពូក៣ លេខ៥១-៥៤ ស្តីពីការលក់កូនស្រី ហើយវិធាននេះអះអាងថា ថ្វីបើមានការជំទាស់គ្រប់យ៉ាងក៏ដោយ ក៏នៅក្នុងសង្គមឥណ្ឌាបុរាណមានការជាវភរិយាជាញឹកញយដូចនៅក្នុងសម័យសព្វថ្ងៃដែរ។

**២០៧.** យញ្ញ. ជំពូក២ លេខ២៦៥។ 'បន្ទាប់ពីបានទទួលថ្លៃឈ្នួលរៀបចំពិធី' គឺ 'នៅក្នុងថ្ងៃធ្វើពិធីជាដើម'(មេធ., កុល្ល., គោវ.)។ យោងតាមលោកមេធ. ម្ចាស់ពិធីយញ្ញត្រូវបង់ថ្លៃឱ្យអ្នកជំនួស ហើយតាមអ្នកអធិប្បាយផ្សេងទៀតថា អាចារ្យដែលទទួលប្រាក់ឈ្នួល។

**២០៨.** មេធ. និយាយថា ថ្លៃឈ្នួលជាក់លាក់ មានកំណត់នៅក្នុង*រាឃ-សូយ* និងពិធីយញ្ញប្រហាក់ប្រហែល សូមមើល អាស្វ.ស្រោតសូត្រ ជំពូក៩ លេខ៣, ១៤-១៥, ៤, ៧-២០។

២០៩- អាចារ្យ *អធ្វរយុ* នឹងបានរទេះចម្បាំង ហើយអាចារ្យព្រាហ្មណ៍ សម្រាប់ពិធីបង្កាត់ភ្លើង (អគ្ន្យាធាន)បានសេះ អាចារ្យ*ហោត្រិ* នឹងបានសេះមួយដែរ ហើយអាចារ្យ*ឧទ្គាត្រិ* បានរទេះរុញ (ដែលគេជាវ)សម្រាប់មកយកប្រើក្នុងពិធី*សោម*។

២១០- អាចារ្យសំខាន់ (បួន) ក្នុងចំណោមអាចារ្យទាំងអស់ (ដប់ប្រាំមួយ) ដែលមានសិទ្ធិទទួលពាក់កណ្តាលនឹងបាន (ប្រាក់ឈ្នួល) មួយភាគ (បួន) បន្ទាប់ពីបានពាក់កណ្តាលចំណែកនោះ ការកំណត់សម្រាប់ចំណែកទីបី បានមួយភាគបីហើយអ្នកដែលមានសិទ្ធិសម្រាប់ចំណែកទីបួន បានមួយភាគបួន។

២១១- តាមការអនុវត្តគោលការណ៍ទាំងអស់នេះ ការចែកចំណែកគេត្រូវតែធ្វើក្នុងចំណោមមនុស្សទាំងឡាយ(ដូចខាងក្រោម)នោះ ដែលបំពេញការងាររបស់ខ្លួនរួមគ្នា។

២១២- បើការឱ្យ(ឬការសន្យាឱ្យ)ថវិកា គឺក្នុងន័យជំនឿរបស់មនុស្សម្នាក់ ចំពោះមនុស្សម្នាក់ទៀតដែលចង់បានថវិកា ការឱ្យនឹងគ្មានសុពលភាពទេ ប្រសិនបើ(ថវិកានោះ)បន្ទាប់មកមិនត្រូវបាន(ប្រើ)តាមរបៀបដូច(បានបញ្ជាក់)ទេ។

២១៣- ប៉ុន្តែបើ(អ្នកទទួល)ដោយការពេញចិត្ត ឬដោយការលោភលន់ ព្យាយាមអនុវត្ត(ការបំពេញពាក្យសន្យា) ព្រះរាជានឹងបង្ខំគាត់ឱ្យសងចំនួនមួយ*សុវណ្ណ* ជាលុបលាងទោសចំពោះបទលួចរបស់គាត់។

២១៤- ដូចនេះការដកហូតយកអំណោយដោយស្របច្បាប់ ត្រូវបានពន្យល់ទាំងស្រុងហើយតទៅនេះ ខ្ញុំនឹងថ្លែងរៀបរាប់អំពី(ច្បាប់ស្តីពី)ការមិនសងថ្លៃឈ្នួល។

**២០៩.** យោងតាមលោកមេធ. និងកុល្ល. អំណោយទាំងបីដែលបានរៀបរាប់ដំបូង គេត្រូវឲ្យតាមបញ្ញត្តិច្បាប់*សាខា* តាម*អគ្ន្យាធាន* គឺការបង្កាត់ភ្លើង។ ប៉ុន្តែលោកគោវ. និយាយថា អាចារ្យព្រាហ្មណ៍ទទួលបាន សេះមួយដ៏លឿននៅពេល *អគ្ន្យាធាន* ហើយលោកនារ. បន្ថែមថា *ហោត្រិ* ទទួលសេះក្នុង*ជ្យោតិស្តោម*។

**២១០.** អាចារ្យទាំងបួនថ្នាក់ ដែលមានមុខងាររបស់ខ្លួន មាននៅក្នុងស្នាដៃរបស់លោក Max Muller *ប្រវត្តិអក្សរសាស្ត្រសំស្ក្រឹត* ទំព័រ៤៦៨ គឺ៖ ១. ហោត្រិ, អធ្វរយុ, ព្រាហ្មណ៍, ឧទ្គាត្រិ, ២.មៃត្រាវរុណ, ប្រតិប្រស្ថាត្រិ, ព្រាហ្មណាច្ឆំសិន, ប្រស្តោត្រិ ៣.អច្ឆាវាក, នេស្ត្រិ, អគ្និធ្រ, ប្រតិហរត្រិ ៤. បោត្រិ, សុព្រហ្មន្យា, គ្រាវស្តុត, នេត្រិ។ លោកមេធ. រៀបរាប់ចំនួនសរុប នៅលេខ១១២ និងចំណែកដែលត្រូវបាន កាព្យលេខ៥៦, ២៨, ១៦, ១២ ហើយលោកគោវ., កុល្ល., នារ. និងរាឃ. ប្រាប់ចំនួនសរុប ១០០ និងចំណែកកាព្យលេខ៤៨, ២៤, ១៦, ៨។ ប៉ុន្តែនន្ទ. និយាយថា ចំនួនសរុបថ្លៃឈ្នួល ទោះជាមានចំនួនប៉ុន្មានក៏ដោយ គួរត្រូវចែកជា ២៥ចំណែក ហើយថ្នាក់ជាច្រើននឹងទទួលបាន១២, ៦, ៤, និង៣ តាមលំដាប់ចំណែកនីមួយៗ។ សូមមើល អាស្វ. ស្រោតសូត្រ ជំពូក៩ លេខ៤, ៣-៥។ វិធានច្បាប់នៅក្នុងកាព្យនេះ អនុវត្តចំពោះករណីធម្មតាទាំងអស់។

**២១១.** យញ្ញ. ជំពូក២ លេខ២៥៩, ២៦៥។ ម្នាក់ៗត្រូវទទួលស្របតាមបរិមាណការងារ ដែលខ្លួនបំពេញ។

**២១២.** ‘ក្នុងន័យជំនឿ’ គឺ ‘សម្រាប់ពិធីយញ្ញ ឬអាពាហ៍ពិពាហ៍’(មេធ.)។

**២១៣.** *សំសាធយេត*ព្យាយាមអនុវត្ត(ការបំពេញពាក្យសន្យា)’ គឺ ‘ដោយប្ដឹងនៅចំពោះព្រះភក្ត្រព្រះរាជា’(មេធ.) ឬ ‘ព្យាយាមទារលុយដោយបង្ខំ ឬបដិសេធប្រគល់លុយ’(កុល្ល., រាឃ., គោវ.)។

២១៥- (អ្នកបម្រើឬកម្មករ)ស៊ីឈ្នួល ដែលគ្មានជំងឺមិនប្រកាន់ខ្លួន តែមិនបំពេញការងាររបស់ខ្លួនតាមការព្រមព្រៀង នឹងត្រូវពិន័យប្រាំបីក្រិស្ណលៈ ហើយគេនឹងមិនផ្ដល់ប្រាក់ឈ្នួលឱ្យគាត់ទេ។

២១៦- ប៉ុន្តែ(បើគាត់)ឈឺពិតប្រាកដ (ហើយ)បន្ទាប់ពីជាមកវិញ បំពេញ(ការងាររបស់ខ្លួន)ស្របតាមការព្រមព្រៀងដំបូង គាត់នឹងបានទទួលប្រាក់ឈ្នួលរបស់ខ្លួន ទោះជាពេលកន្លងផុតយ៉ាងយូរជាខាងក្រោយក៏ដោយ។

២១៧- ប៉ុន្តែបើគាត់ ទោះជាពេលឈឺឬជាមិន(បានបំពេញឬ)ឱ្យ(អ្នកដទៃ)ជួយបំពេញការងាររបស់ខ្លួន តាមការព្រមព្រៀងរបស់ខ្លួនទេ ប្រាក់ឈ្នួលសម្រាប់ការងារនោះគេនឹងមិនផ្ដល់ឱ្យគាត់ទេ ទោះ(ថ្លៃឈ្នួល)នៅសល់តិចតួចក៏ដោយ។

២១៨- ដូចនេះច្បាប់ស្ដីពីការមិនផ្ដល់ប្រាក់ឈ្នួលត្រូវបានបញ្ជាក់ទាំងស្រុង ហើយបន្តទៅនេះខ្ញុំនឹងបកស្រាយច្បាប់ស្ដីពីអ្នកដែលបំពានកិច្ចសន្យា។

២១៩- ប្រសិនបើមនុស្សដែលស្ថិតក្នុងក្រុមមួយនៅក្នុងភូមិ ឬតំបន់មួយ ក្រោយពីបានស្បថព្រមព្រៀងជាមួយគ្នា បំពានការព្រមព្រៀងនោះដោយសេចក្ដីលោភលន់ (ព្រះរាជា)នឹងបណ្ដេញគាត់ចេញពីអាណាចក្ររបស់ទ្រង់,

២២០- ហើយបន្ទាប់ពីបានដាក់គុកអ្នកបំពានការព្រមព្រៀងនោះ ទ្រង់នឹងបង្ខំឱ្យគាត់បង់ប្រាំមួយនិស្កៈ(ម្នាក់)បួនសុវណ្ណ និងមួយ*សតមាន* ប្រាក់។

២២១- ព្រះរាជាដែលប្រកាន់ភាពត្រឹមត្រូវនឹងអនុវត្តច្បាប់ពិន័យនេះនៅក្នុងភូមិ និងវណ្ណៈ(គាតិ) ចំពោះអ្នកទាំងឡាយណាដែលបំពាន់កិច្ចសន្យា។

២២២- ប្រសិនបើនរណាម្នាក់នៅក្នុង(លោកិយ)នេះ បន្ទាប់ពីទិញឬលក់អ្វីមួយ ស្ដាយក្រោយ(ពីការតថ្លៃរបស់ខ្លួន) គាត់អាចប្រគល់ ឬយកមកវិញនូវចលនវត្ថុនោះក្នុងអំឡុងដប់ថ្ងៃ។

---

**២១៥.** អាប. ជំពូក២ លេខ២៨, ២-៣; វិ. ជំពូក៥ លេខ១៥៣-១៥៤; យញ្ញ. ជំពូក២ លេខ១៩៣។ ‘ប្រាំបីក្រិស្ណលៈ’ គឺ ‘នៃមាស, ប្រាក់ឬទង់ដែង ស្របតាមករណី’(មេធ., គោវ.) ឬ ‘នៃមាស’(កុល្ល.)។

**២១៦.** ខ្ញុំអានតាមលោកមេធ., គោវ., នារ., រាឃ. និង K. *សុទីរេយស្យ* សម្រាប់ពាក្យ *ស ទីរេយស្យ* (កុល្ល., នន្ទ.)។
**២១៩.** វិ. ជំពូក៥ លេខ១៦៨; យញ្ញ. ជំពូក២ លេខ១៩២។ ដោយ 'ក្រុមដែលស្នាក់នៅក្នុងភូមិ ឬតំបន់មួយ' តាមលោកមេធ. មានន័យថា សហគមន៍ភូមិ និងការចូលហ៊ុនរកស៊ីរបស់ឈ្មួញ ស្នូម ឬព្រះសង្ឃ ចតុរវេទីជាដើម ហើយគាត់បញ្ជាក់អំពីបទបញ្ញាជាទូទៅពាក់ព័ន្ធការឱ្យស្មោសត្វពាហនៈស៊ី តាមការព្រមព្រៀងមួយក្នុងចំណោមការព្រមព្រៀងនានាដែលត្រូវគោរពទាំងអស់គ្នា។
**២២០.** យោងតាមអ្នកដទៃដែលលោកមេធ.បានលើកឡើងថា ការប្រែគួរតែថា 'បួនសុវណ្ណ ឬប្រាំមួយនិស្ក ឬមួយសតមាន'។ លោកកុល្ល. និងរាឃ. ក៏គិតថា គេអាចប្រែថាប្រភេទពិន័យបីផ្សេងគ្នា ដែលគេអាចដាក់ពិន័យស្របតាមព្រឹត្តិការណ៍នៃរឿងក្ដី។
**២២២.** យញ្ញ. ជំពូក២ លេខ១៧៧។ យោងតាមលោកមេធ., គោវ., កុល្ល. វិធានច្បាប់នេះសំដៅដល់អ្វីដែលមិនខូចខាតដោយងាយៗ ដូចជាដីធ្លី ទង់ដែងជាដើម គឺមិនមែនជាផ្កា ផ្លែឈើ ប្រភេទនេះទេ ហើយតាមលោកនារ. គឺធញ្ញជាតិ និងគ្រាប់ពូជ 'ព្រោះនៅក្នុងស្មិតិដទៃដែលខុសសម័យកាលគ្នា មាននិយាយអំពីវត្ថុដទៃទៀត'(មើលយញ្ញ. អត្ថបទដដែល)។

២២៣-ប៉ុន្តែបន្ទាប់ពី(ផុតកំណត់)ដប់ថ្ងៃ គាត់មិនអាចឱ្យ និងមិនអាចទទួលវាមកវិញទេ ទាំងអ្នកដែលយកវាមកវិញ និងទាំងអ្នកដែលឱ្យវាទៅវិញ (លើកលែងតែមានការយល់ព្រម) នឹងត្រូវព្រះរាជាដាក់ពិន័យប្រាំមួយរយ(បណៈ)។

២២៤-ប៉ុន្តែព្រះរាជាផ្ទាល់នឹងដាក់ពិន័យ ៩៦បណៈ ចំពោះអ្នកដែលប្រគល់ស្រីក្រមុំដ៏មានមន្ទិល (ទៅឱ្យអ្នកចង់បានស្រីធ្វើប្រពន្ធ) ដោយមិនបានប្រាប់(គាត់អំពីវិការៈ)នោះទេ។

២២៥-ប៉ុន្តែបុរសដែលគ្មានចិត្តព្យាបាទ និយាយប្រាប់ស្រីក្រមុំថា 'នាងមិនក្រមុំទេ' នឹងត្រូវពិន័យចំនួនមួយរយ(បណៈ) ប្រសិនបើគាត់មិនអាចបង្ហាញភស្តុតាងអំពីវិការៈនោះ។

២២៦-ពាក្យអាពាហ៍ពិពាហ៍ត្រូវគេប្រើសំដៅតែទៅលើស្រីព្រហ្មចារី (ហើយ)គ្មានកន្លែងណាមួយក្នុងចំណោមបុរសសំដៅដល់ស្ត្រី ដែលបានបាត់ព្រហ្មចារីទេ ព្រោះ(ស្ត្រី)បែបនេះ ត្រូវគេដេញចេញពីពិធីសាសនា។

២២៧-ពាក្យអាពាហ៍ពិពាហ៍ ជាសក្ខីកម្មជាក់លាក់មួយ (ថា ស្រីក្រមុំទើបអាចធ្វើជា) ភរិយាស្របច្បាប់បាន ប៉ុន្តែអ្នកចេះដឹងគួរដឹងថា ពួកគេ (និងពិធីអាពាហ៍ពិពាហ៍) គឺបញ្ចប់ដោយជំហានទីប្រាំពីរ (របស់កូនក្រមុំ ដែលដើរជុំវិញភ្លើងពិសិដ្ឋ)។

២២៨-ប្រសិនបើនរណាមួយ(នៅក្នុងលោកិយ)នេះស្ដាយក្រោយចំពោះកិច្ចការមួយដែលបានចប់ទៅហើយ (ព្រះរាជា)នឹងតម្រូវឱ្យគាត់ដើរតាមគន្លងត្រឹមត្រូវ ស្របតាមវិធានច្បាប់ដែលមានចែងខាងលើ។

២២៩-ខ្ញុំនឹងប្រកាសតាមច្បាប់ពិតប្រាកដ(នូវវិធានស្ដីពី)វិវាទ(ដែលកើតឡើង)ពីការបំពានរបស់ម្ចាស់សត្វពាហនៈ និងអ្នកចិញ្ចឹមសត្វ។

២៣០-ក្នុងកំលុងពេលថ្ងៃ ការទទួលខុសត្រូវចំពោះសុវត្ថិភាព(របស់សត្វ) គឺស្ថិតលើអ្នកចិញ្ចឹមក្នុងកំលុងពេលយប់ ស្ថិតលើម្ចាស់ (ព្រោះថាសត្វទាំងឡាយនៅ)ក្នុងផ្ទះរបស់ម្ចាស់ ហើយផ្ទុយទៅវិញ (បើសត្វនោះនៅជាមួយ)អ្នកចិញ្ចឹមនឹងទទួលខុសត្រូវ(ចំពោះសត្វក្នុងកំលុងពេលយប់ផងដែរ)។

២៣១-អ្នកស៊ីឈ្នួលចិញ្ចឹមសត្វ ដែលទទួលបានទឹកដោះ អាចយកទឹកដោះតាមការព្រមព្រៀងរបស់ម្ចាស់(មេគោ)ល្អបំផុត អស់ទឹកដោះដប់ថ្ងៃ ហើយនោះជាថ្លៃឈ្នួលរបស់គាត់ បើគ្មានថ្លៃឈ្នួល(ផ្សេងទៀត)។

---

**២២៤-២២៥.** យញ្ញ. ជំពូក១ លេខ៦៦។
**២២៤.** ចំពោះការខូចខាត សូមមើលកាព្យ ២០៥ ខាងលើ។
**២២៦.** លោក K. លុបកាព្យនេះចោល។
**២២៧.** នន្ទ. លុបកាព្យនេះ និងកាព្យបន្ទាប់ចោល។ បន្ទាប់ពីឈានដល់ជំហានទីប្រាំពីរ អាពាហ៍ពិពាហ៍អាចរំលាយចោលបាន(មេធ., គោវ., កុល្ល., នារ.)។
**២២៨.** ពោលគឺ គាត់អាចរំលាយកិច្ចសន្យាផ្តល់ប្រាក់ឈ្នួលជាដើមបាន ក្នុងអំឡុងដប់ថ្ងៃបាន ប៉ុន្តែមិនអាចទេ បើផុតពីពេលដប់ថ្ងៃនេះ(គោវ., កុល្ល.)។
**២៣១.** លោកនន្ទ. លុបកាព្យនេះចោល។

២៣២- អ្នកចិញ្ចឹមតែឯងនឹងមើលថែ (កុំឱ្យបាត់បង់សត្វ)ដោយការដើរវង្វេង ដោយបំផ្លាញដោយដង្កូវ ដោយឆ្កែខាំសម្លាប់ ឬ(ដោយដើរធ្លាក់)ក្នុងរណ្តៅ ប្រសិនបើគាត់មិនបានខិតខំការពារ(សត្វ)ឱ្យបានត្រឹមត្រូវ។

២៣៣- ប៉ុន្តែចំពោះ(សត្វ)ដែលចោរបានលួច ទោះបីគាត់បានប្រកាសអាសន្នក៏ដោយ ក៏អ្នកចិញ្ចឹមនឹងមិនសងឡើយ ព្រោះគាត់ផ្តល់ដំណឹងដល់ម្ចាស់ខ្លួន តាមកាលទេសៈសមស្រប។

២៣៤- ប្រសិនបើសត្វងាប់ ចូរគាត់យកឱ្យម្ចាស់ខ្លួនមើលនូវត្រចៀក ស្បែក កន្ទុយ ប្លោកនោម សរសៃពួ និងទឹកប្រមាត់លឿងខាប់ ហើយចូរគាត់បង្ហាញពីស្លាកស្នាមជាក់លាក់របស់សត្វ។

២៣៥- ប៉ុន្តែបើពពែ ឬចៀម ត្រូវឆ្កែចចកឡោមព័ទ្ធ ហើយអ្នកចិញ្ចឹមមិនប្រញាប់ប្រញាល់(ជួយ)វាទេ គាត់ត្រូវទទួលខុសត្រូវចំពោះ(សត្វ)ណាដែលឆ្កែចចកវាយប្រហារសម្លាប់។

២៣៦- ប៉ុន្តែបើសត្វទាំងឡាយ ដែលនៅក្នុងហ្វូង(ត្រឹមត្រូវ) រកស្មៅស៊ីក្នុងព្រៃ ហើយឆ្កែចចក លោតខាំសត្វមួយក្នុងចំណោមសត្វទាំងឡាយ ដើម្បីសម្លាប់វា អ្នកចិញ្ចឹមនឹងគ្មានការទទួលខុសត្រូវទេក្នុងករណីនោះ។

២៣៧- គេគួររក្សាទុកទីធ្លាគ្រប់ទិសនៅក្នុងភូមិ ចំនួនមួយរយ*ធនុ* ឬបី*សំយា* (ទទឹងសម្រាប់វាលស្មៅ) ហើយទំហំបីដង(វាលនោះ)ជុំវិញក្រុងមួយ។

២៣៨- ប្រសិនបើសត្វពាហនៈបំផ្លាញកសិផលដែលគ្មានរបងតាមធម្មតា ព្រះរាជានឹងមិនដាក់ទោសអ្នកគង្វាលសត្វទេក្នុងករណីនោះ។

២៣៩- (ម្ចាស់វាល) នឹងធ្វើរបងកម្ពស់ដែលសត្វអូដ្ឋមិនអាចមើលឃើញ និងបិទគ្រប់ច្រកដែលឆ្កែ ឬជ្រូកព្រៃអាចរុញក្បាលចូលបាន។

២៤០- (ប្រសិនបើសត្វបុិលប៉ូច) នៅទីវាលដែលមានរបងក្បែរផ្លូវធំឬជិតភូមិ អ្នកចិញ្ចឹមនឹងត្រូវពិន័យមួយរយ (បណៈ) (ប៉ុន្តែសត្វ) ដែលអ្នកចិញ្ចឹមបណ្តែតបណ្តោយ (អ្នកឃ្វាលនៅតាមវាល) នឹងដឹកទៅឆ្ងាយ។

**២៣២.** វិ. ជំពូក៥ លេខ១៣៧-១៣៧; យញ្ញ. ជំពូក១ លេខ១៦៤-១៦៥។ 'ដោយដង្កូវ' គឺតាមលោកមេធ. ថាដោយដង្កូវមួយប្រភេទឈ្មោះ *អារោហិកៈ* ដែលចូលតាមប្រដាប់ភេទរបស់មេគោ ហើយសម្លាប់មេគោ។ លោករាឃ. និយាយថា 'ដោយពស់ចិកជាដើម'។ 'ដោយឆ្កែ' តាមលោកមេធ. ពាក្យនេះ គ្រាន់តែជាតួយ៉ាងសំដៅដល់សត្វព្រៃណាក៏បាន។
**២៣៤.** ខ្ញុំអានតាមមេធ. និងគោវ. *អាំកាំ ច* 'ស្លាកស្នាមពិសេសរបស់វា' ជំនួសពាក្យ *អង្គានិ* 'អវយវៈ(ផ្សេងៗ) របស់វា' (រាឃ., នន្ទ., K. និង អត្ថបទបោះពុម្ព)។ ដើម្បីវិនិច្ឆ័យបទអធិប្បាយ លោកកុល្លូ. ត្រូវសរសេរអំណានដូចគ្នានឹងលោក មេធ. និងគោវ.។
**២៣៥.** វិ. ជំពូក៥ លេខ១៣៧។
**២៣៧.** យញ្ញ. ជំពូក២ លេខ១៦៧។ *ធនុ*ន័យត្រង់គឺ 'ប្រវែងមួយធ្នូ'= បួនហត្ថ ឬ ប្រាំមួយហ្វីត។ *សំយា* ជាកំណាត់ឈើខ្លីសម្រាប់ប្រើក្នុងពិធីយញ្ញ។ ទំហំសំយា ជាមាត្រាសាស្ត្រ ដែលមាននៅក្នុងអាប. ជំពូក១ លេខ៩, ៦។
**២៤០-២៤២.** អាប. ជំពូក២ លេខ២៨, ៥; គោត. ជំពូក១២ លេខ១៩-២៦; វិ. ជំពូក៥ លេខ១៤០-១៥០; យញ្ញ. ជំពូក២ លេខ១៦១-១៦៣។

២៤១- (សម្រាប់ការខូចខាត)នៅតាមស្រែផ្សេងៗ(សត្វនីមួយ)នឹង(បង់ពិន័យ)មួយបណៈ និងមួយភាគបួន ហើយក្នុងករណីទាំងអស់(តម្លៃ)កសិផលដែលត្រូវបំផ្លាញ) នឹងត្រូវផ្តល់ឱ្យម្ចាស់ស្រែ នេះជាវិធានច្បាប់ដែលបានបញ្ញត្តិ។
២៤២- ប៉ុន្តែ*មនុ* បានប្រកាសថា គ្មានពិន័យណានឹងត្រូវបង់ចំពោះ(ការខូចខាតដែលបង្កឡើងដោយ) មេគោក្នុងកំលុងពេលដប់ថ្ងៃបន្ទាប់ពីកើតកូន ដោយគោឈ្មោលនិងដោយសត្វពាហនៈដ៏ពិសិដ្ឋសម្រាប់ព្រះអាទិទេព ទោះបីមានការយកចិត្តទុកដាក់មើលសត្វពីអ្នកចិញ្ចឹមឬអត់ក៏ដោយ។
២៤៣- ប្រសិនបើ(កសិផលត្រូវបំផ្លាញដោយ)កំហុសរបស់កសិករផ្ទាល់ ប្រាក់ពិន័យនឹងស្មើនឹងដប់ដងដូចចំណែក(របស់ព្រះរាជា) ប៉ុន្តែការពិន័យ(យក)តែពាក់កណ្តាលចំនួននោះប៉ុណ្ណោះ បើ(កំហុស)ជារបស់អ្នកបម្រើ ហើយកសិករមិនបានដឹងបញ្ហានេះ។
២៤៤- ព្រះរាជាដែលប្រកបដោយភាពត្រឹមត្រូវនឹងអនុវត្តវិធានច្បាប់ទាំងអស់នេះ ចំពោះ(ករណីទាំងអស់)ពាក់ព័ន្ធនឹងការរំលោភបំពានរបស់ម្ចាស់ សត្វ និងអ្នកចិញ្ចឹមរបស់ពួកគេ។
២៤៥- ប្រសិនបើមានវិវាទកើតឡើងរវាងភូមិពីរពាក់ព័ន្ធព្រំប្រទល់ ព្រះរាជានឹងដោះស្រាយបញ្ហាព្រំប្រទល់នៅខែ*ជ្យេស្ឋ* ពេលដែលគេអាចមើលឃើញទីតាំងសម្គាល់ទីកន្លែងបានច្បាស់បំផុត។
២៤៦- ចូរទ្រង់បោះព្រំប្រទល់ដោយដើមឈើ (ឧ.ទា.)ដើម*ន្យគ្រោធ, អស្វត្ថ, កឹសុកៈ*, ដើមកប្បាស់, *សាលៈ*, ដើមត្នោត និងដើមឈើមានជ័រដូចទឹកដោះ,
២៤៧- ដោយការចងបាច់កូនឈើតូចៗ ឫស្សីប្រភេទផ្សេងៗ *សមី* រុក្ខជាតិវល្លិ៍ និងដំបូក ប្របុស ព្រៃគុម្ពោតកុព្ចកៈ ធ្វើដូច្នេះនឹងងាយភ្លេចព្រំប្រទល់ទេ។
២៤៨- ស្រះ អណ្តូង អន្លង់ និងកន្លែងទឹកផុស ព្រមទាំងព្រះវិហារ ត្រូវគេកំណត់ថាជាកន្លែងចំណុចប្រសព្វព្រំប្រទល់,

---

**២៤១.** 'សត្វពាហនៈ' គឺ 'អ្នកចិញ្ចឹមនឹងបង់ឱ្យសត្វ'។ 'ក្នុងករណីទាំងអស់' គឺ 'ទោះបីអ្នកចិញ្ចឹមនៅជាមួយសត្វ ឬអត់ក៏ដោយ' (មេធ., គោវ., កុល្លូ., រាឃ.)។

**២៤២.** មេគោ តាមលោកនារ. ក្នុងកំលុងថ្ងៃដំបូងបន្ទាប់ពីកើតកូនដែលគេមិនអាចគ្រប់គ្រងបានទាំងស្រុង។ 'គោឈ្មោល' គឺ 'សត្វដែលមានសេរីភាព(មើលវិ. ជំពូក៨៦)'(នារ., កុល្លូ.) ដែលយើងអាចឃើញនៅក្បែរភូមិឥណ្ឌាជាច្រើន និងតាមក្រុងជាច្រើន។ 'សត្វដ៏ពិសិដ្ឋសម្រាប់ព្រះអាទិទេព' គឺ 'ជាសត្វសម្រាប់ពិធីយញ្ញ'ក៏បាន ឬ 'សត្វដែលគេទុកសម្រាប់ព្រះវិហារ'ក៏បាន(មេធ.)។ អ្នកអធិប្បាយផ្សេងទៀត ចូលចិត្តការបកស្រាយទីពីរជាង។

**២៤៣.** អាប. ជំពូក២ លេខ២៨, ១។ 'កំហុស(ផ្ទាល់)របស់កសិករ' គឺ 'បើគាត់បានបណ្តោយសត្វស៊ីកសិផលរបស់គាត់ ឬមិនបានសាបក្នុងស្រែតាមពេលវេលាសមស្របជាដើម'(មេធ., គោវ., កុល្លូ., នារ., រាឃ.)។

**២៤៥.** *ត្បែស្ត* គឺចន្លោះខែឧសភា-មិថុនា 'ពេលដែលស្មៅត្រូវហួតហែងដោយសារកំដៅ'(មេធ., កុល្លូ., រាឃ.)។

**២៤៦.** យញ្ញ. ជំពូក២ លេខ២៥១។ *ន្យគ្រោធ* គឺដើម*Ficus Indica*; *អស្វត្ថ* គឺដើម *Ficus Religiosa; កឹំសុកៈ* ដើម *Butea Frondosa; សាលៈ* ដើម*Shorea Robusta*។ 'ដើមឈើមានជ័រដូចទឹកដោះ' គឺ 'ដើម Arka (Calatropis Gigantea), Udumbara(Ficus Glomerata)ជាដើម'។

**២៤៧.** *សាមី* ដើម Acacia Suma; 'ដំបូក' គឺ សំដៅដល់គំនរដីដែលបច្ចុប្បន្នគេប្រើជាទូទៅធ្វើជាទីសម្គាល់ដីនៅស្រុកអង់គ្លេស។ ជំនួសពាក្យ កុព្ជកៈ លោកនន្ទ. ប្រើពាក្យ កុល្យកៈ។

២៤៩- ហើយដោយសារតែទ្រង់ជ្រាបថា ដោយសារការដែលមនុស្សមិនដឹងពីព្រំប្រទល់ ទើបកើតមានការរំលោភបំពានជាប្រចាំនៅក្នុងលោកិយនេះ ចូរទ្រង់ឱ្យគេធ្វើសញ្ញាបង្កប់ផ្សេងៗ សម្រាប់សម្គាល់ព្រំដី,

២៥០- ថ្មឆ្អឹង រោមមេគោ អង្កាម ផេះ អំបែងភាជន៍ អាចម៍គោស្ងួត ឥដ្ឋ កម្ទេចផេះផង់ ក្រួស និងខ្សាច់,

២៥១- ហើយអ្វីៗផ្សេងៗដែលមានទម្រង់ប្រហាក់ប្រហែលនេះនៅលើដី មិនងាយនឹងវិនាស សូម្បីពេលយូរក៏ដោយសូមទ្រង់ឱ្យគេកប់របស់ទាំងនោះនៅត្រង់ចំណុចប្រសព្វព្រំប្រទល់(ផ្សេងៗ)។

២៥២- ដោយសារសញ្ញាទាំងនេះ ដោយសារការកាន់កាប់បន្តបន្ទាប់រយៈពេលយូរ និងដោយមានជ្រោះទឹកហូរជាប្រចាំ ព្រះរាជានឹងដឹងច្បាស់ពីព្រំប្រទល់(ដី)របស់គូភាគីវិវាទពីរ។

២៥៣- ប្រសិនបើមានការសង្ស័យក្នុងការពិនិត្យទីសម្គាល់នោះ ការដោះស្រាយវិវាទរឿងព្រំប្រទល់នឹងអាស្រ័យលើកសិណសាក្សី។

២៥៤- សាក្សី(ដែលផ្តល់កសិណ)ពាក់ព័ន្ធព្រំប្រទល់ នឹងត្រូវគេសួរសំណួរពាក់ព័ន្ធទីសម្គាល់ដី ដោយវត្តមានអ្នកភូមិដ៏ច្រើនកុះករ ព្រមទាំងមានគូក្តីទាំងពីរផង។

២៥៥- ក្នុងពេលគេសួរ ពួកគាត់បញ្ជាក់ជាឯកច្ឆ័ន្ទ ដូច្នេះព្រះអង្គនឹងកត់ត្រាព្រំប្រទល់(ជាលាយលក្ខណ៍អក្សរ) រួមទាំងឈ្មោះរបស់ពួកគាត់ផង។

២៥៦- ចូរឱ្យពួកគេដែលកំពុងយកដីដាក់លើក្បាល ពាក់ឈុត(ផ្កាក្រហម) និងសម្លៀកបំពាក់ពណ៌ក្រហម ដោយម្នាក់ៗស្បថ ដោយយក(បុណ្យកុសល)នៃអំពើល្អរបស់ខ្លួនជាសំអាង កំណត់(ព្រំប្រទល់)ស្របតាមការពិត។

២៥៧- ប្រសិនបើពួកគេកំណត់(ព្រំប្រទល់)តាមរបៀបដូចបានបញ្ជាក់ពួកគេគ្មានទោស(ពីការធ្វើជា)សាក្សីដ៏ស្មោះត្រង់ទេ ប៉ុន្តែបើពួកគេកំណត់ព្រំប្រទល់មិនត្រឹមត្រូវ ពួកគេនឹងត្រូវគេបង្ខំឱ្យប្រាក់ពិន័យចំនួនពីររយ(បណៈ)។

២៥៨- ពេលរកកសិណសាក្សី(ពីភូមិទាំងពីរមិនបាន) មនុស្សក្នុងភូមិជិតខាងទាំងបួន ដែលមានចិត្តបរិសុទ្ធនឹងធ្វើ(ជាសាក្សី)សម្រេចពាក់ព័ន្ធរឿងព្រំប្រទល់នេះនៅចំពោះព្រះវត្តមានរបស់ព្រះរាជា។

**២៥១.** យោងតាមកុល្ល. ដែលផ្អែកលើអត្ថបទរបស់ព្រហស្បតិ វត្ថុទាំងអស់នេះ ត្រូវគេដាក់ក្នុងពាង។
**២៥៤.** យោងតាមអ្នកអធិប្បាយនានា កាព្យនេះសំដៅដល់វិវាទរវាងភូមិពីរ ហើយគូក្តីទាំងពីរជាបុគ្គលដែលភូមិនីមួយៗបានជ្រើសរើសធ្វើជាតំណាង ដើម្បីដំណើរការក្តី(សូមមើលកាព្យលេខ២៦១ខាងក្រោមផង)។
**២៥៥.** អ្នកអធិប្បាយទាំងអស់បកស្រាយ*និពទ្ធិយាត* ថា'ទ្រង់នឹងកត់ត្រាជាលាយលក្ខណ៍អក្សរ' ហើយដូចបានបញ្ជាក់ជាពិសេសថា ឈ្មោះរបស់សាក្សីត្រូវតែមាន ហើយការប្រែពាក្យនេះក្នុងន័យផ្សេង ទំនងជាមិនអាចទៅរួចទេ។ លោកមេធ. និយាយថា ប្រសិនបើសាក្សីមិនយល់ស្របតាម នោះគេត្រូវយកសំឡេងភាគច្រើន។
**២៥៦-២៦០.** យញ្ញ. ជំពូក២ លេខ១៥០-១៥២។
**២៥៨.** លោកកុល្ល. សុំឱ្យប្រែថា មនុស្សដែលមកពីភូមិជុំវិញទាំងបួន។ ភាពត្រឹមត្រូវនៃមតិត្រូវបានសបញ្ជាក់ដោយការពិតថា ការប្រគល់ដី តាមធម្មតាត្រូវមាន 'ព្រំប្រទល់បួន'(ចតុរាឃាតនានិ)នៃភូមិដែលផ្តល់ដីនោះ។ លោកមេធ. និងនន្ទ. សរសេរ *គ្រមសាមន្តាភសិនៈ* 'មនុស្សបួននាក់នៅក្នុងភូមិជាដើម'។

២៥៩- ពេលរកអ្នកជិតខាងដែលជាអ្នកស្រុកដើម (នៅក្នុងដែននោះ និងអាចធ្វើជា) សាក្សីរឿងព្រំប្រទល់មិនបាន (ព្រះរាជា) អាចស្តាប់កសិណ ដែលជារបស់អ្នកស្រុកតំបន់នៅព្រៃជាប់នោះ ក៏ដោយ,

២៦០- (ដូចជា)នាយព្រានព្រៃ អ្នកប្រមាញ់សត្វស្លាប អ្នកចិញ្ចឹមសត្វ អ្នកនេសាទ អ្នកដើរជីកមើមឈើ អ្នកចាប់ពស់ អ្នកដើរប្រមូលផលអនុផលព្រៃឈើ និងអ្នកដើរព្រៃដទៃទៀត។

២៦១- ព្រោះតាមការសាកសួរ ពួកគេប្រកាសអំពីទីសម្គាល់ចំណុចប្រសព្វព្រំប្រទល់ ដូច្នេះព្រះរាជានឹងឱ្យគេកំណត់ព្រំប្រទល់ដោយត្រឹមត្រូវរវាងភូមិទាំងពីរនោះបាន។

២៦២- ការវិនិច្ឆ័យទីសម្គាល់ព្រំដីស្រែ អណ្តូង ស្រះ សួន និងលំនៅឋាន អាស្រ័យលើ(កសិណសាក្សីរបស់)អ្នកជិតខាង។

២៦៣- បើអ្នកជិតខាងផ្តល់កសិណមិនពិត ពេលមនុស្សមានវិវាទរឿងទីសម្គាល់ព្រំដីនោះ ព្រះរាជានឹងឱ្យពួកគេម្នាក់ៗបង់ពិន័យពាក់កណ្តាលម្នាក់ជាប្រាក់ពិន័យ។

២៦៤- អ្នកដែលគំរាមកំហែងដោយផ្ទាល់ កាន់កាប់ផ្ទះ ស្រះ សួន ឬវាលណាមួយ នឹងត្រូវទទួលពិន័យប្រាំរយ(បណៈ) ហើយ(បើគេបានបំពាន)ដោយមិនបានដឹង ប្រាក់ពិន័យនឹងត្រូវបង់ត្រឹមពីររយ(បណៈ)។

២៦៥- ប្រសិនបើព្រំប្រទល់ មិនមានកសិណសាក្សីអាចកំណត់ដាក់លាក់បាន ចូរព្រះរាជាដែលប្រកបដោយព្រះទ័យត្រឹមត្រូវ មានព្រះតម្រិះចង់ផ្តល់ប្រយោជន៍ដល់ពួកគេ(ទាំងអស់) ចែកដី(របស់ទ្រង់)ផ្ទាល់ដល់(ពួកគេម្នាក់) នេះជាវិធានច្បាប់ដែលបានបញ្ញត្តិទុកមកដូច្នេះ។

២៦៦- ហេតុនេះច្បាប់សម្រាប់វិនិច្ឆ័យ(វិវាទ)ព្រំប្រទល់ ត្រូវបានប្រកាសទាំងស្រុងហើយ ជាបន្តទៅទៀត ខ្ញុំនឹងថ្លែងរៀបរាប់(ពីរបៀប)ធ្វើការវិនិច្ឆ័យ(ករណី)បង្ខូចកេរ្តិ៍ឈ្មោះ។

២៦៧- ក្សត្រិយដែលបានបង្ខូចកេរ្តិ៍ឈ្មោះព្រាហ្មណ៍ នឹងត្រូវទទួលពិន័យមួយរយ(បណៈ); វៃស្ស (ពិន័យ)មួយរយហាសិប ឬពីររយ; សូទ្រៈ នឹងទទួលទណ្ឌកម្មលើរូបកាយ។

២៦៨- ព្រាហ្មណ៍ នឹងត្រូវទទួលពិន័យហាសិប (បណៈ) ចំពោះការបង្ខូចកេរ្តិ៍ឈ្មោះក្សត្រិយ; ក្នុង (ករណីរបស់)វៃស្សៈ ប្រាក់ពិន័យត្រូវបង់គឺម្ភៃប្រាំ(បណៈ); ក្នុង(ករណីរបស់)សូទ្រៈ គឺម្ភៃ។

---

**២៥៩.** *មោលានាំ* 'អ្នកស្រុកដើម' គឺ 'ដូនតារបស់គាត់បានរស់ទីនោះតាំងពីមានការតាំងលំនៅក្នុងភូមិ'(មេធ., គោវ., កុល្ល. , រាឃ.)។

**២៦០.** 'អ្នកនៅក្នុងព្រៃផ្សេងទៀត' គឺ'អ្នកដែលដើរបេះផ្កា ផ្លែឈើនិងជ័រ'(មេធ., គោវ., កុល្ល.) ឬ 'សពរៈ ជាដើម'(នារ.)។

**២៦២.** វស. ជំពូក១៦ លេខ១៣-១៥; យញ្ញ. ជំពូក២ លេខ១៥៤។

**២៦៣.** យញ្ញ. ជំពូក១ លេខ១៥៣។

**២៦៥.** យញ្ញ. ជំពូក២ លេខ១៥៣។

**២៦៧-២៧៧.** អាប. ជំពូក២ លេខ២៧, ១៤; គោត. ជំពូក១២ លេខ១, ៨-១៤; វស. ជំពូក៩ លេខ៩; វិ. ជំពូក៥ លេខ ២៣-៣៩; យញ្ញ. ជំពូក២លេខ២០៤-២១១។

២៦៩- ចំពោះបទល្មើសរបស់មនុស្សដែលមានកំណើតពីរដង ទៅលើវណ្ណៈស្មើគ្នា(ប្រាក់ពិន័យក៏នឹងត្រូវបង់ចំនួនម្ភៃ(បណៈ); ចំពោះពាក្យសម្តីដែលគេមិនគួរនិយាយ បទល្មើស(និងប្រាក់ពិន័យនីមួយៗ នឹងកើន)ទ្វេដង។

២៧០- អ្នកមានកំណើតម្តង(សូទ្រៈ) ដែលប្រមាថអ្នកមានកំណើតពីរដង ដោយការជេរប្រមាថទាំងកម្រោល នឹងត្រូវគេកាត់អណ្តាតរបស់គាត់ចោល ព្រោះគាត់មានដើមកំណើតថ្នាក់ទាប។

២៧១- ប្រសិនបើគាត់ហៅចំឈ្មោះ និងវណ្ណៈ(គាតិ)របស់អ្នកមានកំណើតពីរ ដោយសម្តីព្រហើនកោងកាច គាត់នឹងត្រូវគេបុកច្រកដែកក្តៅដ៏ក្រហមឆ្អៅ ប្រវែងដប់ម្រាមដៃ រុកចូលមាត់របស់គាត់។

២៧២- ប្រសិនបើគាត់ទូន្មានព្រាហ្មណ៍អំពីករណីយកិច្ចរបស់ពួកគេដោយក្រអឺតក្រទម ព្រះរាជានឹងឱ្យគេចាក់ប្រេងក្តៅចូលមាត់ និងត្រចៀករបស់គាត់។

២៧៣- អ្នកដែលថ្លែងពាក្យមិនពិតដោយអំណួត អំពីការចេះដឹងរបស់(មិត្តរួមវណ្ណៈ) ប្រទេសរបស់ខ្លួន វណ្ណៈ(គាតិ)របស់ខ្លួន ឬពិធីសាសនាដែលធ្វើឱ្យកាយរបស់គាត់រួចផុតពីបាប នឹងត្រូវបង្ខំឱ្យបង់ពិន័យចំនួនពីររយ(បណៈ)។

២៧៤- អ្នកដែលហៅអ្នកផ្សេងថា អាភ្នែកមួយ អាពិការ ឬពាក្យផ្សេងៗបែបនេះ ទោះជាត្រឹមត្រូវតាមការពិតក៏ដោយ នឹងត្រូវទទួលពិន័យយ៉ាងហោច ចំនួនមួយ*កហាបណៈ*។

២៧៥- អ្នកដែលបង្ខូចកេរ្តិ៍ឈ្មោះម្តាយខ្លួន ឪពុកខ្លួន ភរិយាខ្លួន បងប្អូនប្រុស កូនប្រុស ឬគ្រូរបស់ខ្លួន និងអ្នកដែលមិនជៀស ទុកផ្លូវឱ្យគ្រូបាធ្យាយរបស់ខ្លួន នឹងត្រូវបង្ខំ ឱ្យបង់ពិន័យមួយបណៈ។

២៧៦- (ចំពោះការបំពានគ្នាទៅវិញទៅមក) រវាងព្រាហ្មណ៍និងក្សត្រិយ (ព្រះរាជា)ដែលមានការវិនិច្ឆ័យល្អ ត្រូវដាក់ពិន័យចំពោះព្រាហ្មណ៍នូវប្រាក់ពិន័យទាបបំផុត ប៉ុន្តែពិន័យក្សត្រិយកម្រិតមធ្យម។

២៧៧- វៃស្យៈ និងសូទ្រៈ ត្រូវទទួលពិន័យដាក់ស្តែងដូចគ្នាស្របតាមវណ្ណៈរៀងៗខ្លួនរបស់ពួកគេ ប៉ុន្តែគេមិនត្រូវកាត់អណ្តាត(របស់សូទ្រៈ)ទេ ពោលនេះជាដីកា។

---

**២៦៩.** 'សម្តីដែលគេមិនគួរនិយាយ' គឺ 'សម្តីស៊កសៀតធ្វើឱ្យខូចកិត្តិយសរបស់ញាតិស្ត្រីរបស់ម្ខាងទៀត ជាពិសេសម្តាយ និងបងប្អូនស្រី'(មេធ., គោវ., កុល្ល., រាឃ.) ដែលដូចជាអ្នកបួព៌ាប្រទេសដទៃដែរ ហិណ្ឌូគិតដូច្នេះហើយ។
**២៧០.** អនុប្រយោគចុងក្រោយ តាមអ្នកអធិប្បាយ សំដៅដល់ដើមកំណើតរបស់សូទ្រៈ ដែលកើតចេញពីជើងរបស់ព្រះព្រហ្ម សូមមើលជំពូក ១ លេខ៣១ ខាងលើ។ តាមលោកមេធ. សំនួនពាក្យ 'កើតម្តង' រាប់បញ្ចូលទាំងមនុស្ស ដែលមានកំណើតពីឪពុកវណ្ណៈខ្ពស់ និងម្តាយវណ្ណៈទាប។
**២៧១.** ពោលគឺ បើគាត់និយាយ '*អេ យគ្នទត្ត* ឬ 'ឯង រលាយទៅព្រាហ្មណ៍'។
**២៧៣.** 'ក្នុងចំណោមអ្នកមានវណ្ណៈស្មើគ្នា'(កុល្ល., រាឃ.) ព្រមទាំងលោកគោវ. ក៏អះអាងថា វិធានច្បាប់មិនអាចសំដៅដល់សូទ្រៈទេ ព្រោះការដាក់ទោសមានកម្រិតស្រាលពេក។ លោកមេធ. បកស្រាយពាក្យ *កម្ម* ថា 'មុខរបរ' និងពាក្យ *សារីរ៍* ថា '(វិការៈផ្នែក)រូបកាយ' ចំណែកឯអ្នកដទៃសំដៅដល់ *កម្ម សារីរ៍* ថា ការបដិសេធមិនឱ្យចូលជាសមាជិកថ្មី។
**២៧៥.** *អាក្សារយតិ* 'បង្ខូចកេរ្តិ៍ឈ្មោះ' គឺ 'ចោទប្រកាន់គេអំពីអំពើបាបធ្ងន់ធ្ងរ'(គោវ., កុល្ល., រាឃ.) ឬ 'ពីស្មន្ទការ'(នារ.) ឬ 'បង្កឱ្យមានវិវាទបែកបាក់រវាងពួកគេ និងអ្នកដទៃ'(មេធ.) ឬ 'ធ្វើឱ្យពួកគេខឹងសម្បារ'(នន្ទ.)។
**២៧៧.** គឺថា បើសូទ្រៈបង្ខូចកេរ្តិ៍ឈ្មោះរបស់វៃស្យៈ អណ្តាតរបស់សូទ្រៈនឹងមិនត្រូវគេកាត់ ប៉ុន្តែគាត់ត្រូវបង់ពិន័យកម្រិតមធ្យម។

២៧៨- ដូច្នេះវិធានច្បាប់សម្រាប់ដាក់ទណ្ឌកម្ម(អនុវត្តចំពោះករណី)បង្ខូចកេរ្តិ៍ឈ្មោះ ត្រូវបានប្រកាសយ៉ាងត្រឹមត្រូវ ជាបន្តខ្ញុំនឹងថ្លែងរៀបរាប់អំពីការវិនិច្ឆ័យ(ករណី)ការបង្ករបួសស្នាម។

២៧៩- មនុស្សវណ្ណៈទាប បង្ករបួសស្នាមចំពោះអវយវៈអ្វីក៏ដោយរបស់(មនុស្សវណ្ណៈបី)ខ្ពស់បំផុត ហើយអវយវៈនោះនឹងត្រូវគេកាត់ដាច់វិញ នេះជាការបង្រៀនរបស់មនុ។

២៨០- អ្នកដែលលើកដៃរបស់ខ្លួន ឬដំបង នឹងត្រូវកាត់ដៃគាត់នោះ អ្នកដែលទាត់ទាំងកំហឹងដោយជើងរបស់គាត់ នឹងត្រូវកាត់ជើងរបស់គាត់នោះ។

២៨១- មនុស្សវណ្ណៈទាប ដែលព្យាយាមអង្គុយលើកៅអីជាមួយគ្នានឹងមនុស្សវណ្ណៈខ្ពស់ នឹងត្រូវគេដុតដែកបោះលើភ្លៅរបស់គាត់ ហើយគេបណ្តេញចេញពីប្រទេស ឬ(ព្រះរាជា)នឹងឱ្យគេវះគូទរបស់គាត់យ៉ាងជ្រៅ។

២៨២- បើដោយភាពកោងកាច គាត់ស្តោះទឹកមាត់(ដាក់អ្នកខ្ពង់ខ្ពស់) ព្រះរាជានឹងឱ្យគេកាត់ភ្លៅទាំងពីររបស់គាត់ ហើយគាត់នោម(ដាក់អ្នកនោះ) កាត់លិង្គរបស់គាត់ចោល ហើយបើគាត់ផោមដាក់(អ្នកនោះ) គេនឹងកាត់រន្ធគូទរបស់គាត់។

២៨៣- បើគាត់ចាប់សក់(របស់អ្នកខ្ពង់ខ្ពស់) ចូរ(ព្រះរាជា)កាត់ដៃរបស់គាត់កុំស្ទាក់ស្ទើរ ដូចគ្នា(បើគាត់ប្រើជើង)កាត់ជើង, យកពុកចង្កាមកប៉ះ គឺកាត់ក ឬកាត់ពងស្វាស។

២៨៤- អ្នកដែលធ្វើឱ្យដាច់ស្បែក(របស់អ្នកវណ្ណៈស្មើគ្នា) ឬធ្វើឱ្យចេញឈាម(អ្នកនោះ) នឹងត្រូវទទួលពិន័យមួយរយៈ(បណៈ) អ្នកដែលមុតសាច់ដុំ ពិន័យប្រាំមួយនិស្កៈ អ្នកដែលធ្វើឱ្យបាក់ឆ្អឹង នឹងត្រូវគេបណ្តេញចេញពីប្រទេស។

២៨៥- ចំពោះការប្រើប្រាស់ដើមឈើផ្សេងៗ គេត្រូវតែពិន័យចំពោះអ្នកដែលបង្កឱ្យគេឈឺចាប់ នេះជាវិធានច្បាប់ដែលបានបញ្ញត្តិ។

២៨៦- បើការវាយប៉ះត្រូវមនុស្ស ឬសត្វ ដើម្បី(ធ្វើឱ្យគេ)ឈឺចាប់ (ថៅក្រម) នឹងដាក់ពិន័យដោយសមាមាត្រទៅនឹងកម្រិតនៃការឈឺចាប់(ដែលបានបង្កឡើង)។

---

**២៧៩-២៨០.** វិ. ជំពូក៥ លេខ១១៩; យញ្ញ. ជំពូក២ លេខ២១៥។

**២៨០.** *ប្រហារេត* 'ទាត់' គឺ 'លើកជើងរបស់គាត់ដើម្បីទាត់'(មេធ., នារ., នន្ទ.)។

**២៨១.** អាប. ជំពូក២ លេខ២៧, ១៥; គោត. ជំពូក១២ លេខ៧; វិ. ជំពូក៥ លេខ២០។ យោងតាមមេធ., គោវ., កុល្លូ., វិធានច្បាប់នេះសំដៅដល់ព្រាហ្មណ៍ និងសូទ្រៈ យោងតាមរាឃ. សំដៅដល់ព្រាហ្មណ៍និងអារ្យ៉ន ហើយតាមនារ. សំដៅដល់ក្សត្រិយ៍ វៃស្យ ឬសូទ្រៈ ដែលបំពានទៅលើព្រាហ្មណ៍។

**២៨២.** វិ. ជំពូក៥ លេខ២១-២២។

**២៨៤.** វិ. ជំពូក៥ លេខ៦៦-៧០; យញ្ញ. ជំពូក២ លេខ២១៨។ 'ដែលស្មើគ្នា'(មេធ., កុល្លូ., នន្ទ.)។ តាមលោករាឃ. វិធាននេះសំដៅដល់សូទ្រៈដែលបង្ករបួសដល់សូទ្រៈ។ តាមលោកនារ. កម្មសិទ្ធិរបស់ជនល្មើសចុងក្រោយ នឹងត្រូវរឹបអូស។

**២៨៥.** វិ. ជំពូក៥ លេខ៥៥-៥៩; យញ្ញ. ជំពូក២ លេខ២២៧-២២៨។ ពាក្យ 'ដើមឈើ' រួមទាំងរុក្ខជាតិទាំងអស់(មេធ., កុល្លូ.)។ តាមលោកគោវ. ការពិន័យចំពោះការបង្កការខូចខាតដើមឈើដែលផ្តល់ម្លប់ គឺមានចំនួនតិចតួចប៉ុណ្ណោះ ហើយក្នុងករណីរុក្ខជាតិមានផ្កា ពិន័យកម្រិតកណ្តាល ក្នុងករណីដើមឈើមានផ្លែ ពិន័យខ្ពស់(សូមមើលវិ. អត្ថបទដកស្រង់)។ មេធ. កត់សម្គាល់ថា ទីតាំងដើមឈើ តួយ៉ាងទោះវាជាសញ្ញាសម្គាល់ព្រំដីក៏បាន ឬឈរឱ្យម្លប់លើផ្លូវ ក្នុងអាស្រមឥសីជា

២៨៧- ប្រសិនបើអវយវៈត្រូវរបួស ការបង្ករបួសស្នាម ឬការធ្វើឱ្យហូរឈាម អ្នកបង្កនឹងត្រូវបង់ចំណាយព្យាបាល ឬចំណាយទាំងស្រុង(ទាំងពិន័យធម្មតា និងទាំងថ្លៃព្យាបាល) និងពិន័យ(ថ្វាយព្រះមហាក្សត្រិយ)។

២៨៨- អ្នកដែលបង្កឱ្យមានការខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃ ទោះជាដោយចេតនាក្តី ឬអចេតនាក្តី នឹងត្រូវផ្តល់សំណង(ម្ចាស់)វិញ ហើយបង់ពិន័យថ្វាយព្រះរាជាស្មើនឹង (ប្រាក់សំណងខូចខាត)។

២៨៩- ក្នុងករណី(ការបង្កការខូចខាតចំពោះ)ស្បែក ឬចំពោះគ្រឿងប្រដាប់ធ្វើពីស្បែក ពីឈើ ឬពីដីឥដ្ឋ ប្រាក់ពិន័យ(នឹងត្រូវគុណនឹង)ប្រាំដងនៃតម្លៃវត្ថុ ដូចគ្នាក្នុងករណី(ធ្វើឱ្យ)ផ្កា ឫសឈើ និងផ្លែឈើដែរ។

២៩០- ពួកគេប្រកាសពាក់ព័ន្ធនឹងការដឹកជញ្ជូន អ្នកបើកបរ និងម្ចាស់ដឹកជញ្ជូន (ថាមាន)ដប់ករណីដែលគេមិនអាចដាក់ចំពោះ (ការខូចខាតដែលបានកើតឡើង) ហើយក្នុងករណីផ្សេងពីនេះនឹងត្រូវបង់ប្រាក់ពិន័យតាមបញ្ញត្តិ។

២៩១- ពេលខ្សែកន្ត្រះដាច់នឹកពេលបាក់រទេះធ្លាក់ផ្លូវ ឬថយក្រោយពេលភ្លៅរទេះឬកង់រទេះបាក់,

២៩២- ពេលខ្សែព្រាត់ ខ្សែប្រឡៅក ឬខ្សែបង្ហៀរដាច់ និងពេល(អ្នកបើកបរ)បានស្រែកបញ្ជាឮៗថា 'ជៀសផ្លូវ' *មនុ* បានប្រកាស(ថាក្នុងករណីទាំងអស់នេះ) ការដាក់ទោសនឹងមិនកើតមានទេ។

២៩៣- ប៉ុន្តែបើរទេះធ្លាក់ចេញពី(ផ្លូវ)ដោយសារការខ្វះជំនាញរបស់អ្នកបើក ម្ចាស់នឹងត្រូវពិន័យចំនួនពីររយ(បណះ) បើមានការខូចខាតកើតឡើង។

២៩៤- ប្រសិនបើអ្នកបើកបរមានជំនាញ(តែធ្វេសប្រហែស)គេនឹងពិន័យតែអ្នកបើកបរប៉ុណ្ណោះហើយ បើអ្នកបើកបរគ្មានជំនាញ អ្នកទទួលខុសត្រូវដឹកជញ្ជូន(ក៏)នឹងត្រូវពិន័យម្នាក់ៗចំនួន មួយរយ (បណៈ)។

២៩៥- ប៉ុន្តែបើសត្វ ឬរទេះដឹកជញ្ជូន(ផ្សេង)ត្រូវបញ្ឈប់ដំណើររបស់គាត់ ហើយគាត់បង្កឱ្យស្លាប់ដល់សត្វមានជីវិត ប្រាកដណាស់ការដាក់ពិន័យត្រូវតែមាន។

---

ដើម ត្រូវគេលើកយកមកពិចារណា(សូមមើលយញ្ញ. អត្ថបទដកស្រង់)។

**២៨៦-២៨៧.** វិ. ជំពូក៥ លេខ៧៥-៧៦; យញ្ញ. ជំពូក២ លេខ២១៩, ២២២។

**២៨៧.** ជំនួសពាក្យ *វ្រណៈ* 'របួស'(កុល្លូ., នារ.) លោកមេធ., គោវ., រាឃ., នន្ទ. និង K. អាន *ប្រាណៈ*។ មេធ. បកស្រាយអំណានក្រោយថា 'បើកម្លាំងទ្រទ្រង់ជីវិតត្រូវរងរបួស' ហើយគោវ. និងរាឃ. ថា 'បើកម្លាំងដកដង្ហើមត្រូវរងរបួស ដោយការភ្ជាល់គ្នា'។ 'ឬទាំងអស់(ជា)ពិន័យ' គឺ បើមនុស្សដែលរងរបួស មិនទទួលសំណង។ លោកនារ.ថា 'ហើយនឹងបង់ពិន័យទាំងអស់ដូចបានរៀបរាប់ខាងដើម'។

**២៨៨.** 'ទ្រព្យ' គឺ 'វត្ថុនានាដែលមិនមានចែងច្បាស់ទេ'(មេធ., គោវ., កុល្លូ., រាឃ.)។

**២៩១-២៩៥.** យញ្ញ. ជំពូក២ លេខ២៩៨-២៩៩។

**២៩១.** 'ពេលរទេះធ្លាក់ផ្លូវ ឬថយក្រោយ' គឺ 'ធ្លាក់ពីផ្លូវដោយសារកំហុសរបស់រទេះ សត្វដែលជួបការភ័យខ្លាចជាដើម' (មេធ., គោវ., កុល្លូ., រាឃ.)។

**២៩៥.** ការអានបានពីរយ៉ាង គឺ *អវិចារិតៈ* 'ដោយគ្មានមន្ទិល' (ន័យត្រង់ 'ដែលគេមិនចាំបាច់គិត')និង *វិចារិតៈ* 'ត្រូវគេ

២៩៦- បើមនុស្សម្នាក់ត្រូវគេសម្លាប់ ពិរុទ្ធភាពរបស់គាត់ស្មើនឹង(កំហុសរបស់)ចោរដែរ ហើយចំពោះសត្វធំៗ ដូចជាមេគោ ដំរី អូដ្ឋ ឬសេះ មានពិរុទ្ធភាពពាក់កណ្តាលទោសនោះ។

២៩៧- ចំពោះការបង្ករបួសស្នាមដល់សត្វតូច ប្រាក់ពិន័យ (គឺត្រូវនឹង) ចំនួនពីររយ (បណៈ) ហើយប្រាក់ពិន័យចំពោះសត្វចតុប្បាទនិងសត្វស្លាបព្រៃដ៏ស្រស់ស្អាត គឺស្មើនឹងហាសិប(បណៈ)។

២៩៨- ចំពោះសត្វលាសត្វចៀមនិងពពែ ប្រាក់ពិន័យគឺចំនួនប្រាំ*មាសៈ* ប៉ុន្តែទោសសម្រាប់ការសម្លាប់ឆ្កែ ឬជ្រូក ត្រូវបង់ចំនួនមួយ*មាសៈ*។

២៩៩- ភរិយា កូនប្រុស ទាសករ កូនសិស្ស និងប្អូន(ប្រុស)បង្កើត ដែលបានប្រព្រឹត្តកំហុស ត្រូវគេវាយនឹងខ្សែព្រួរ ឬបន្ទះរំពាត់ឫស្សី,

៣០០- ប៉ុន្តែវាយតែលើខ្នង (ប៉ុណ្ណោះ) មិនវាយលើផ្នែកសំខាន់ៗទេ ហើយអ្នកដែលវាយពួកគេនោះត្រង់ចំណុចហាមឃាត់ នឹងមានទោសស្មើនឹងបទចោរដែរ។

៣០១- ដូច្នេះ ច្បាប់ទាំងមូលស្តីពីការបង្ករបួសស្នាម (និងការបង្កការឈឺចាប់) ត្រូវបានប្រកាសទាំងស្រុង ហើយពេលនេះខ្ញុំនឹងបកស្រាយវិធានច្បាប់សម្រាប់វិនិច្ឆ័យ(ករណី)បទចោរកម្ម។

៣០២- ចូរព្រះរាជាខិតខំឱ្យអស់ព្រះទ័យដើម្បីដាក់ទោសចោរ ព្រោះ បើទ្រង់ដាក់ទោសចោរ កិត្តិសព្ទរបស់ទ្រង់នឹងកើនឡើង ហើយអាណាចក្ររបស់ទ្រង់នឹងរុងរឿង។

៣០៣- តាមពិត ព្រះរាជាសមនឹងទទួលបានការគោរពក្នុងនាមជាអ្នកធានាសុវត្ថិភាព (ជូនប្រជារាស្ត្ររបស់ទ្រង់) ព្រោះការជួបជុំក្នុងពិធីយញ្ញ (សត្រ្តដែលទ្រង់ប្រារព្ធធ្វើតាមជាក់ស្តែង) អាស្រ័យលើឋិរវេលា តែសុវត្ថិភាព(របស់ប្រជារាស្ត្រទ្រង់ តំណាងនូវ)តម្លៃពិធីយញ្ញ។

៣០៤- ព្រះរាជាដែលការពារ (ប្រជារាស្ត្រទ្រង់បានត្រឹមត្រូវ) ទទួលបានបុណ្យកុសលគ្រប់យ៉ាង និងកុសលទីប្រាំមួយនៃព្រលឹងវិញ្ញាណពួកគេទាំងអស់ ប្រសិនបើទ្រង់មិនការពារពួកគេ អកុសលទីប្រាំមួយរបស់ពួកគេ(ក៏នឹងធ្លាក់មកលើទ្រង់)ផងដែរ។

៣០៥- កុសលអ្វីក៏ដោយ (ដែលមនុស្សបានទទួលដោយសារ) ការអានព្រះវេទ ដោយការបូជាយញ្ញ ដោយការបរិច្ចាគបំពេញកុសល (ឬដោយ) ការគោរពបូជា(គ្រូនិងព្រះអាទិទេព) ព្រះរាជាទទួលផលទីប្រាំមួយនោះ ដោយសារការការពារ(អាណាចក្ររបស់ទ្រង់)បានត្រឹមត្រូវ។

---

គិត(ឱ្យបានត្រឹមត្រូវ)'។ លោកមេធ.ផ្តល់ការបកស្រាយផ្សេងពីនេះ ដែលលោកកុល្លូ.ស្រង់ដាក់អត្ថបទបកប្រែថា 'មិនត្រូវបានគិត(ត្រឹមត្រូវ)'។ គាត់ក៏សរសេរអំណានទីពីរ ដែលលោកគោវ., រាឃ.,នារ. និងនន្ទ. ឯកភាព និងបកស្រាយថា 'ត្រូវគិត(ឱ្យបានត្រឹមត្រូវ)'។

**២៩៦.** 'ស្មើគ្នានឹងទោសរបស់ចោរ' គឺ 'គាត់ត្រូវតែបង់ប្រាក់ពិន័យខ្ពស់បំផុត ឬចំនួន១០០០បណៈ'(មេធ., គោវ., នារ., កុល្លូ., រាឃ., នន្ទ.)។

**២៩៧-២៩៨.** វិ. ជំពូក៥ លេខ៥០-៥៤។

**២៩៩-៣០០.** អាប. ជំពូក១ លេខ៨, ៣១; គោត.ជំពូក២ លេខ៤៣-៤៤។

**៣០០.** 'មិន(វាយ)លើផ្នែកសំខាន់ៗ' គឺ 'មិន(វាយ)លើទ្រូង ឬក្បាលជាដើម'(មេធ., កុល្លូ.)។

**៣០៣-៣១១.** អាប. ជំពូក២ លេខ២៥, ១៥; វស. ជំពូក លេខ៤២-៤៤; វិ. ជំពូក៥ លេខ១៩៦; យញ្ញ. ជំពូក១ លេខ៣៣៥-៣៣៦, ៣៥៨; សូមមើលជំពូក៩ លេខ២៥២ខាងក្រោមផង។

៣០៦- ព្រះរាជាដែលការពារសត្វលោកស្របតាមតម្រាច្បាប់ពិសិដ្ឋ និងដាក់ទណ្ឌកម្មរូបកាយតាមសមគួរ ធ្វើពិធីបូជាយញ្ញរាល់ថ្ងៃ ដែលចំណាយតម្លៃឈ្នួលរាប់រយពាន់។

៣០៧- ព្រះរាជាដែលមិនអាចផ្តល់ការការពារ (តែ)ទទួលយកចំណែកទ្រង់តាមរបៀប ជាពន្ធអាករ និងកម្រៃផ្សេងៗ ជាអំណោយនិងប្រាក់ពិន័យរាល់ថ្ងៃ (បន្ទាប់ពីចូលទិវង្គត)នឹងធ្លាក់នរកភ្លាម។

៣០៨- ពួកគេប្រកាសថា ព្រះរាជាដែលមិនអាចផ្តល់ការការពារ (តែ)ទទួលផលទីប្រាំមួយ គឺផលអាក្រក់ទាំងអស់របស់អាណាប្រជានុរាស្ត្ររបស់ទ្រង់ នឹងធ្លាក់មកលើទ្រង់។

៣០៩- ចូរដឹងថា ព្រះរាជាដែលមិនយកព្រះទ័យទុកដាក់ការគ្រប់គ្រង(តាមច្បាប់) ដែលជាអ្នកគ្មានជំនឿលើព្រះអាទិទេព និងលោភលន់ហួសហេតុ ដែលមិនការពារអាណាប្រជានុរាស្ត្ររបស់ទ្រង់ តែបំផ្លាញពួកគេ នឹងធ្លាក់ចុះក្រោម (បន្ទាប់ពីទទួលមរណភាព)។

៣១០- ចូរទ្រង់យកព្រះទ័យទុកដាក់គ្រប់គ្រងជនអាក្រក់ដោយវិធីបីយ៉ាង ដោយការចាប់ដាក់គុក ដោយការដាក់ខ្នោះច្រវាក់ និងដោយការធ្វើទណ្ឌកម្មរូបកាយ(តាមរបៀបផ្សេងៗ)។

៣១១- ព្រោះដោយសារការដាក់ទោសជនអាក្រក់ និងការអនុគ្រោះមនុស្សល្អ ព្រះរាជានឹងទទួលបានការសង្គ្រោះជាជនមានកំណើតមានពីរ ដោយការបូជាយញ្ញ។

៣១២- ព្រះរាជាដែលប្រាថ្នាចង់បានសុខុមាលភាពរបស់ផ្ទាល់ ត្រូវតែចេះឱ្យអភ័យជានិច្ច ចំពោះគូក្តី កូនក្មេង ចាស់ជរា និងអ្នកជំងឺ ដែលចោមរោមរិះគន់ទ្រង់។

៣១៣- ទ្រង់ដែលចេះឱ្យអភ័យដល់ (អ្នកទាំងឡាយ) ដែលបំពានធ្វើឱ្យទ្រង់ឈឺចាប់ នឹងទទួលរង្វាន់ឡើង ឋានសួគ៌ដោយសារអំពើនោះ ប៉ុន្តែទ្រង់ដែលមានមោទនភាពជាព្រះស្តេចរបស់ព្រះអង្គមិន ចេះឱ្យអភ័យដល់ពួកគេ នឹងធ្លាក់នរកដោយសារហេតុផលនោះ។

---

**៣០៧.** 'ចំណែកដូចដើម' គឺ 'ការទទួលចំណែក ឬផលទីប្រាំមួយ'(មេធ., គោវ., កុល្ល., នារ., រាឃ.) ឬ 'ចំណែកប្រសើរបំផុត ឬផ្លែឈើ ធញ្ញជាតិជាដើម ដែលត្រូវថ្វាយព្រះរាជា'។ 'ពន្ធ' គឺ *គង្ហាទាន* (មេធ.) ឬ ពន្ធដីធ្លីដែលបង់ជាថវិកា(នារ.) 'ពន្ធប្រចាំខែ ឬពន្ធដែលអ្នកភូមិបង់តាមខែកំណត់ជាក់លាក់'(គោវ., គោវ., រាឃ.)។ *សុល្កៈ* ជា 'កម្រៃ និងអាករ ដែលឈ្មួញ និងពាណិជ្ជករបង់'(មេធ., គោវ., កុល្ល., នារ., រាឃ.)។ ចំពោះ*ប្រតិភាគំ* គឺ 'អំណោយប្រចាំថ្ងៃជាផ្លែឈើ បន្លែបង្កាជាដើម' ដែលគេហៅថា *ដាលី* (មេធ., កុល្ល.) ហើយនារ. និងរាឃ. អាន *ប្រតិភោគំ* លោកគោវ.ថា *ភូតិភោគំ* ហើយនន្ទ. ថា *ប្រីតិភោគំ* ប៉ុន្តែការបកស្រាយសំណេរពីរដំបូង គឺដូចគ្នា។ យ៉ាងណាមិញ *ប្រីតិភោគ* គឺជា 'សមានចិត្ត' ដែលធម្មតាគេហៅថា *ប្រីតិទាន* ហើយត្រូវប្រមូលនៅក្នុងឱកាសសំខាន់ៗ។

**៣០៨.** មេធ. និងនារ. អាន *អរក្សិតារំ អត្តារំ* 'ព្រះរាជាដែលមិនផ្តល់ការការពារ (តែ)អនុគ្រោះ(ចំពោះប្រជារាស្ត្រទ្រង់) ហើយទទួលតង្វាយជាដើម។'

**៣០៩.** នន្ទ. អានពាក្យចុងកាព្យនេះថា *អសត្យំ ច ន្ទបំ ត្យជេត* 'ចូរទ្រង់កុំគាំទ្រព្រះរាជាដែលមិនយកព្រះទ័យទុកដាក់គោរពវិធានច្បាប់... និងគ្មានព្រះទ័យសច្ចធម៌'។ ឃ្លានេះ លោកមេធ. សរសេរថា *វិប្រលុម្បកំ* (ឬ *លោបកំ*) 'លោភលន់' តាមលោកនារ., នន្ទ. និងរាឃ. ថា 'ដែលទទួលទ្រព្យរបស់ព្រាហ្មណ៍ ឬធ្វើឱ្យពួកព្រាហ្មណ៍ឈឺចាប់'។

**៣១០.** 'មនុស្សអាក្រក់' គឺ 'ចោរ ព្រោះប្រធានបទ(និយាយចោរកម្ម'(មេធ.)។

**៣១០.** 'អ្នកមានកំណើតពីរដង' គឺ 'ព្រាហ្មណ៍'(មេធ., នារ.)។

៣១៤- ចោរកំពុងរត់យ៉ាងបះសក់សំដៅមករកព្រះរាជា ដោយសារភាពពីការលួចនោះ (ហើយនិយាយថា) 'សូមដាក់ទោសខ្ញុំ ចំពោះការដែលខ្ញុំបានធ្វើដូច្នេះ',

៣១៥- (ហើយទ្រង់ត្រូវតែ) លីដំបងលើស្មាទ្រង់ ឬព្រនង់ឈើខទិរៈ ឬលំពែងដែលមានចុងស្រួចសងខាង ឬដំបងដែក។

៣១៦- ទោះជាដាក់ទោស ឬឱ្យអភ័យក្តី ចោរនឹងបានរួចផុតពី(ទោស)ចោរកម្ម ប៉ុន្តែព្រះរាជា បើមិនដាក់ទោសចោរ កំហុសរបស់ចោរនឹងធ្លាក់មកលើទ្រង់ផ្ទាល់។

៣១៧- អ្នកសម្លាប់ព្រាហ្មណ៍ចេះដឹង ទម្លាក់កំហុសរបស់វាទៅលើអ្នកដែលស៊ីអាហាររបស់វា, ភរិយាផិតក្បត់(ទម្លាក់កំហុស)លើប្តី (ធ្វេសប្រហែស) របស់នាង, កូនសិស្សឬម្ចាស់បុណ្យយញ្ញ (ដែលប្រព្រឹត្តអំពើបាប) (ទម្លាក់កំហុស) លើគ្រូ (ឬអាចារ្យ) ដែលធ្វេសប្រហែស បីដូច (កំហុសរបស់)ចោរ ធ្លាក់លើព្រះរាជា(ដែលឱ្យអភ័យដល់ចោរ)។

៣១៨- ប៉ុន្តែមនុស្ស ដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ និងត្រូវព្រះរាជាដាក់ទោស នឹងឡើងឋានសួគ៌ ដោយភាពបរិសុទ្ធ បីដូចជាអ្នកដែលបានធ្វើអំពើល្អដែរ។

៣១៩- អ្នកដែលលួចខ្សែពួរ ឬផើងទឹកពីអណ្តូង ឬធ្វើឱ្យខូចខ្ទមសម្រាប់បែងចែក នឹងបង់ពិន័យចំនួនមួយមាសៈ ហើយសង(របស់ដែលយក ឬធ្វើឱ្យខូច)ទម្រង់ត្រឹមត្រូវរបស់វត្ថុ។

៣២០- សម្រាប់អ្នកដែលលួចធញ្ញជាតិលើសពីដប់*កុម្ភៈ* នឹងត្រូវទទួលទណ្ឌកម្មរូបកាយ ហើយក្នុងករណីផ្សេងពីនេះ គេនឹងត្រូវពិន័យគុណនឹងដប់មួយដង ហើយត្រូវសង(ម្ចាស់វិញ)តាមតម្លៃទ្រព្យរបស់គាត់។

៣២១- ដូច្នេះបើមានការដាក់ទណ្ឌកម្មរូបកាយ ចំពោះបទលួចរបស់ដែលមានតម្លៃលើសពីមួយរយ(បលៈ)ដែលលក់គិតតាមទម្ងន់(ឧ.ទា.)មាស ប្រាក់ជាដើម និងសម្លៀកបំពាក់ប្រណិតបំផុត។

---

**៣១៤-៣១៦.** អាប. ជំពូក១ លេខ២៥, ៤-៥; គោត. ជំពូក១២ លេខ៤៣-៤៥; វស. ជំពូក២០ លេខ៤១; ពោធ. ជំពូក២ លេខ១, ១៦-១៧; វិ. ជំពូក៥២ លេខ១-២; យញ្ញ. ជំពូក៣ លេខ២៥៧។

**៣១៤.** មេធ. និងនន្ទ. អានជំនួសពាក្យ *ធាវតា* 'ដែលកំពុងរត់' ប្រើពាក្យ *ធីមតា* (នឹងរត់មករកព្រះរាជា) 'ដោយមានការតាំងចិត្តហ្មឹងម៉ាត់'។ ប៉ុន្តែមេធ.សរសេរអំណានផ្សេងដែរ ដែលមានភាពត្រឹមត្រូវគម្ពីរ វស. អត្ថបទដដែល។ យោងតាមអ្នកអធិប្បាយ និងសេចក្ដីប្រហាក់ប្រហែល ចោរដែលមានចិត្តស្ដាយក្រោយ គឺសំដៅដល់ចោរដែលបានលួចមាសរបស់ព្រាហ្មណ៍។ សូមមើលជំពូក១១ លេខ១៩៩-២០១ ខាងក្រោម។

**៣១៧.** វស. ជំពូក១៩ លេខ៤៤។ លោកមេធ. ដាក់កាព្យលេខ៣១៧ បន្ទាប់ពីលេខ៣១៨ ប៉ុន្តែគត់សម្គាល់ថា លំដាប់កាព្យ គួរតែត្រឡប់។ លោកនិយាយថា អាចារ្យត្រូវតែចាកចេញពីម្ចាស់បុណ្យដែលមិនស្ដាប់បង្គាប់ ហើយកំហុសដោយម្ចាស់បុណ្យដែលបានប្រព្រឹត្តខុសទំនង នឹងធ្លាក់មកលើអាចារ្យទាំងអស់។

**៣១៩.** 'ធ្វើឲ្យខូច' គឺ'យកឈើដាប់ផើង'(នារ.)។ 'មួយមាសៈ' គឺ'នៃទង់ដែង'(មេធ.),'នៃមាស'(គោវ., កុល្ល., នារ., រាឃ.)។

**៣២០.** វិ. ជំពូក៥ លេខ១២។ 'មួយកុម្ភៈ ស្មើនឹង ២០ ឬ២២ ប្រស្ថ ក្នុង ៣២បលៈ'(គោវ., កុល្ល., រាឃ.) ឬ 'ត្រូវនឹង ២០០បលៈ'(នារ.)។ *វធៈ* 'ការដាក់ទណ្ឌកម្មរូបកាយ' គឺ 'ការវាយដំ, ការកាត់អវយវៈ ឬការដាក់ទោសប្រហារជីវិត ស្របទៅតាមលក្ខណៈសម្បត្តិរបស់បុគ្គលដែលត្រូវចោរប្លន់'(គោវ., កុល្ល., រាឃ.)។

**៣២១.** វិ. ជំពូក៥ លេខ១៣។ តាមលោកនារ. និងរាឃ. វត្ថុផ្សេងក្រៅពីមាសនិងប្រាក់ ត្រូវគេចាត់ជា*ធរិម*ដែលលក់តាម

៣២២- ចំពោះ(ការលួច)លើសពីហាសិប(បលៈ) ច្បាប់កំណត់ថា ត្រូវកាត់ដៃ(របស់ជនល្មើស) ប៉ុន្តែក្នុងករណីក្រៅពីនេះ ចូរទ្រង់ដាក់ពិន័យគុណនឹងដប់មួយដងនៃតម្លៃនោះ។

៣២៣- ចំពោះការលួចពីមនុស្សក្នុងគ្រួសារខ្ពង់ខ្ពស់ ហើយជាពិសេសស្ត្រី និងត្បូងមានតម្លៃបំផុត (ជនល្មើស សមទទួលទោសទណ្ឌកម្មរូបកាយ (ឬទោសប្រហារជីវិត)។

៣២៤- ចំពោះការលួចសត្វធំៗ អាវុធ ឬឱសថ ចូរព្រះរាជាកំណត់ការដាក់ទោស បន្ទាប់ពីវិនិច្ឆ័យច្បាស់ពីពេលវេលា និងបំណង(នៃការប្រព្រឹត្ត)។

៣២៥- ចំពោះ(ការលួច)មេគោដែលជាកម្មសិទ្ធិរបស់ព្រាហ្មណ៍ ចំពោះការចោះ(ច្រមុះរបស់)មេគោអារ និងចំពោះការលួចសត្វពាហនៈ(ផ្សេងទៀតដែលជារបស់ព្រាហ្មណ៍) នោះជនល្មើសនឹងទទួលទោសកាត់ជើងពាក់កណ្ដាលមួយរំពេច។

៣២៦- (ចំពោះការលួច) អំបោះ សំឡី ថ្នាំសម្រាប់ធ្វើជំបែ អាចម៍មេគោ ទឹករង្វ ទឹកដោះគោជូរ ទឹកដោះគោផ្អែម ទឹកដោះខាប់ ទឹក ឬស្មៅ,

៣២៧- ភាជន៍ដែលធ្វើពីឫស្សី ឬផ្ដៅ អំបិលប្រភេទផ្សេងៗ ភាជន៍ដី ដី និងផេះ,

៣២៨- ត្រី សត្វស្លាប ប្រេង ប៊ីសុទ្ធ សាច់ ទឹកឃ្មុំ និងវត្ថុផ្សេង ដែលបានពីសត្វព្រៃ,

៣២៩- ឬរបស់ផ្សេងៗប្រភេទនេះ ទឹកគ្រឿងស្រវឹង បាយឆ្អិន និងអាហារចម្អិនគ្រប់ប្រភេទ ពិន័យ(នឹងត្រូវស្មើពីរដងនៃតម្លៃ(វត្ថុដែលបានលួច)។

៣៣០- ចំពោះផ្កា ពោត ធញ្ញជាតិបៃតង ចុល្លព្រឹក្ស វល្លិ៍ ដើមឈើ និង(ធញ្ញជាតិ)ដែលនៅជាប់សំបក ប្រាក់ពិន័យ(គឺស្មើ)ប្រាំ*ក្ឫស្ណលៈ*។

---

ទម្ងន់'។ ប៉ុន្តែលោកមេធ., គោវ. និងកុល្ល. បកស្រាយដូចខាងលើ។

**៣២២.** វ. ជំពូក៥ លេខ៨១-៨២។ លោកនារ. គិតថា វិធានច្បាប់នេះសំដៅដល់ទង់ដែង និងលោហៈដែលមានតម្លៃតិច។ ប៉ុន្តែគេក៏លុបចោលភាពមិនសមហេតុសមផលបាន តាមរយៈការបកស្រាយពាក្យ *វធៈ* តាមកាព្យមុន ថា 'ការដាក់ទោសប្រហារជីវិត'។

**៣២៤-៣២៥.** វ. ជំពូក៥ លេខ៧៧-៧៨។

**៣២៤.** 'ចេតនាប្រើប្រាស់វត្ថុប្រព្រឹត្ត' គឺ'ទោះជាអាវុធត្រូវលួចបានក្នុងការប្រយុទ្ធ ឬលួចឱសថពីអ្នកជំងឺក្តី'(មេធ., គោវ., រាឃ.)។

**៣២៥.** ជំនួសពាក្យក្នុងអត្ថបទបោះពុម្ព 'ឃូរិកាយា ច ភេទនេ' លោកមេធ., នារ., រាឃ., នន្ទ. និង K. សរសេរ 'ស្ចូរិកាយា ច ភេទនេ' ដែលពិតជាសំណេរត្រឹមត្រូវ ពាក្យ *វុល្លត* ដែលមានការឱ្យន័យខុសពីទម្រង់ដើមអក្សរ 'ថៈ'។ លោកកុល្ល. និងរាឃ. បកស្រាយឃ្លានេះ តាមរបៀបខាងលើ ហើយគោវ. ដែលអាច 'នាសស្រិ]កាយា ច ភេទនេ' ស្របតាមពួកគេ។ ម្យ៉ាងទៀត លោកមេធ. និយាយថា ស្ថូរិកា គឺ'គោឈ្មោល'(ពលីវទេះ)ហើយឃ្លានេះត្រូវគេប្រែ 'សម្រាប់ការបេះប្រលេះទង (និងប្រើប្រាស់សម្រាប់បំណងរបស់នរណាម្នាក់) នូវគោ(របស់អ្នកផ្សេង)'។ លោកនារ. ចុងក្រោយអះអាងថា *ស្ថូរិកា* មានន័យថា'ឥវ៉ាន់ដែលទុកនៅលើគោ'រួចប្រែពាក្យនេះថា'ចំពោះការកាត់បើក ថង់ដែលនៅលើគោនិងដកយក វត្ថុក្នុងថង់នោះ'។

**៣២៦-៣៣១.** វ. ជំពូក៥ លេខ៨៣-៨៦។

**៣២៨.** 'វត្ថុផ្សេងៗ ដែលបានសត្វព្រៃ' គឺមាន 'ស្បែក ស្នែង *គោរោចនា* ជាដើម'(គោវ., នារ., កុល្ល., រាឃ.)។

**៣២៩.** 'វត្ថុផ្សេងៗរបៀបនេះ' គឺមាន 'ម្សៅអាសេនិកក្រហម សំណក្រហម ជាដើម'(គោវ., កុល្ល.) ឬ 'វត្ថុដែលអាចទទួលទានបានផ្សេងៗទៀត'(នន្ទ.)។

៣៣១- សម្រាប់ធញ្ញជាតិដែលបកសំបក បន្លែ មើមឈើ និងផ្លែឈើ ប្រាក់ពិន័យ(ត្រូវស្មើ)មួយរយ(បណៈ) បើគ្មានទំនាក់ទំនង(រវាងម្ចាស់និងចោរ) ហើយពិន័យហាសិប(បណៈ) បើមានទំនាក់ទំនងបែបនេះ។

៣៣២- បទល្មើស(តាមការរៀបរាប់នេះ) ដែលត្រូវបានប្រព្រឹត្តដោយមានវត្តមាន(របស់ម្ចាស់) និងដោយហិង្សា គឺជាបទប្លន់ ហើយបើ(អំពើនោះប្រព្រឹត្ត)ដោយគ្មានវត្តមានម្ចាស់ អំពើនោះជាបទលួច ឧបមាបីដូចជា(ការកាន់យករបស់)អ្វីមួយ ដែលម្ចាស់មិនឱ្យ។

៣៣៣- គឺនិយាយអំពីមនុស្សដែលអាចលួចរបស់អ្វីមួយដែលបានរៀបរាប់ខាងលើ នៅពេលពួកគេរៀបចំសម្រាប់(ប្រើប្រាស់) ចូរព្រះរាជាដាក់ពិន័យថ្នាក់ទីមួយ (ឬកម្រិតទាបបំផុត) ដូចគ្នាអ្នកដែលអាចលួចភ្លើង(ពិសិដ្ឋ)ចេញពីបន្ទប់(ដែលគេរក្សាភ្លើង)។

៣៣៤- ចោរប្រព្រឹត្តបទល្មើសបែបណាក៏ដោយដែលធ្វើឱ្យពិការដល់មនុស្ស ដូច្នោះព្រះរាជានឹងចាប់ខ្លួនគេ ដើម្បីកុំឱ្យមាន(ការប្រព្រឹត្តបទឧក្រិដ្ឋដដែលៗ)។

៣៣៥- ព្រះរាជាមិនត្រូវ មិនដាក់ទោសចំពោះឪពុក គ្រូ មិត្ត ម្តាយ ភរិយា កូនប្រុស អាចារ្យក្នុងគ្រួសារនោះទេ ប្រសិនបើពួកគេមិនបដិបត្តិតាមករណីយកិច្ចរបស់ពួកគេ។

៣៣៦- ចំណុចណាដែលមនុស្សធម្មតាម្នាក់ត្រូវទទួលពិន័យមួយកហាបណៈ គេនឹងពិន័យព្រះរាជា ចំនួនមួយពាន់ នេះជាវិធានច្បាប់ដែលបានបញ្ញត្តិ។

៣៣៧- ក្នុង(ករណី)បទចោរកម្ម ទោសរបស់សូទ្រៈ ត្រូវគុណនឹងប្រាំបី, ទោសវៃស្យៈ គុណនឹងដប់ប្រាំមួយ, ទោសរបស់ក្សត្រិយ គុណនឹងសាមសិបពីរដង។

---

**៣៣០.** គោវ. ជំពូក១២ លេខ១៨។ គោវ. អាន *អប្ជេសុ*សម្រាប់(ធញ្ញជាតិ)តូចៗដែលជាប់សំបក' ជំនួសពាក្យ *អន្យេសុ* 'ផ្សេងៗទៀត'។ 'ប្រាំក្ឫស្ណលៈ' គឺ 'នៃមាស'(មេធ.) 'នៃមាសឬប្រាក់'(គោវ., កុល្ល., រាឃ.)។

**៣៣១.** *និរន្វយេ*បើគ្មានការជាប់ពាក់ព័ន្ធ(រវាងអ្នកម្ចាស់ និងចោរ' តាមលោកមេធ.អាចថា 'បើគ្មានទំនាក់ទំនងទៅវិញទៅមកជាមិត្តភាពទេ' ឬ 'បើគ្មានទំនាក់ទំនងដូចជាលំនៅឋានក្នុងភូមិជាមួយ' ឬ 'បើគ្មានអ្នកមើលនៅក្នុងវាលស្រែ'។ គោវ. និង នារ. យល់ស្របតាមការបកស្រាយដំបូង លោកកុល្ល. និងរាឃ. យល់ស្របតាមការបកស្រាយទីពីរ ប៉ុន្តែសូមមើលកាព្យលេខ១៩៨ ខាងលើ។

**៣៣២.** យញ្ញ. ជំពូក២ លេខ២៧០។ មេធ. និងនារ. ដាក់កាព្យនេះ នៅកាព្យបន្ទាប់។

**៣៣៣.** 'រៀបចំសម្រាប់ប្រើប្រាស់' គឺ 'សម្រាប់ទទួលទាន'(មេធ., នារ.) ឬ 'អម្បោះនៅក្នុងខោអាវ'(មេធ., គោវ., កុល្ល., រាឃ.)។ 'ភ្លើង' អាចជាភ្លើងពិសិដ្ឋក៏បាន(មេធ., កុល្ល., នារ., រាឃ.) ឬភ្លើងធម្មតាក៏បាន(គោវ.)។ មេធ. និងនន្ទ. អាន *សតំ* 'មួយរយបណៈ' ជំនួសពាក្យ *អាឡំ* 'ការពិន័យកម្រិតទាបបំផុត' ដែលលោកមេធ. ក៏សរសេរតាមអំណានក្រោយនេះដែរ។

**៣៣៤.** *ប្រត្យាទេសាយ* 'ដើម្បីការពារកុំឱ្យមាន(ការប្រព្រឹត្តបទល្មើសដដែលៗ'(គោវ., កុល្ល., រាឃ., នន្ទ.) តាមលោកមេធ. និងនារ. គឺ 'ដើម្បីធ្វើឱ្យ(អ្នកផ្សេង)ញញើត'។

**៣៣៥.** យញ្ញ. ជំពូក១ លេខ៣៥៧។

**៣៣៦.** ព្រះរាជានឹងបោះលុយ សម្រាប់ជាប្រាក់ពិន័យចំពោះបទល្មើសដែលទ្រង់បានប្រព្រឹត្ត ចូលក្នុងទឹកឬប្រគល់វាឱ្យព្រាហ្មណ៍ (មេធ., គោវ., កុល្ល.) អនុលោមតាមជំពូក៩ លេខ២៤៥។

**៣៣៧-៣៣៨.** គោត. ជំពូក១២ លេខ១៥-១៧។

**៣៣៧.** 'ទោស' ការពិតមានន័យថា ជនល្មើសត្រូវបង់ពិន័យតាមសមាមាត្រ។

៣៣៨- ទោសរបស់ព្រាហ្មណ៍ គឺហុកសិបបួនដងឬមួយរយដង ឬ(សូម្បី)ហុកសិបគុណនឹងបួនដង ព្រោះ(ពួកគេម្នាក់ៗ)សុទ្ធតែដឹងពីលក្ខណៈនៃបទល្មើស។

៣៣៩- (ការដក)ឫស និងបេះផ្លែឈើពីដើម ការយកឈើសម្រាប់ភ្លើង(ពិធីយញ្ញ) និងការយកស្មៅសម្រាប់ចិញ្ចឹមមេគោ *មនុ*បានប្រកាសថា (មិនមែនជា)បទចោរកម្មទេ។

៣៤០- ព្រាហ្មណ៍ ដោយការស្វែងរកទ្រព្យពីមនុស្សដែលបាននូវអ្វីដែលខ្លួនមិនគួរបាន ទោះជាដោយការបូជាសម្រាប់គាត់ក្តី ឬដោយការបង្រៀនគាត់ក្តី គឺហាក់បីដូចជាចោរដែរ។

៣៤១- អ្នកមានកំណើតពីរដង ដែលកំពុងធ្វើដំណើរ ហើយអស់របស់របរប្រើប្រាស់ចាំបាច់របស់ខ្លួន នឹងមិនត្រូវពិន័យ ប្រសិនបើគាត់យកអំពៅពីរដើម ឬមើមឈើ(ដែលអាចបរិភោគបាន)ពីមើមពីចម្ការរបស់មនុស្សអ្នកផ្សេង។

៣៤២- អ្នកដែលចងខ្សែឬស្រាយខ្សែ(សត្វពាហនៈរបស់អ្នកដទៃ), អ្នកដែលយកទាសករ សេះឬរទេះនឹងមានទោសជាចោរ។

៣៤៣- ព្រះរាជាដែលដាក់ទោសចោរកម្ម ស្របតាមវិធានច្បាប់ទាំងនេះ នឹងបានទទួលកិត្តិនាមនៅក្នុងលោកិយនេះ និងបានពរជ័យរាប់មិនអស់នៅជាតិក្រោយ។

៣៨៤- ព្រះរាជា ដែលប្រាថ្នាចង់បានរាជបល្ល័ង្ករបស់ព្រះឥន្ទ្រ និងកិត្តិនាមដែលមិនចេះសាបសូន្យ មិនត្រូវធ្វេសប្រហែស សូម្បីតែម្តង (ក្នុងការដាក់ទោស)អ្នកដែលប្រព្រឹត្តអំពើហិង្សា។

៣៨៥- គេមិនត្រូវចាត់ទុកអ្នកដែលប្រព្រឹត្តអំពើហិង្សាជាជនល្មើសអាក្រក់បំផុតទេ (គឺគួរអាក្រក់)ជាងអ្នកបង្ខូចកេរ្តិ៍ ជាងចោរ និងជាងអ្នកដែលប្រើដំបងបង្ករបួសស្នាម(ដល់អ្នកដទៃ)ទៅទៀត។

៣៨៦- ប៉ុន្តែព្រះរាជា ដែលឱ្យអភ័យដល់អ្នកប្រព្រឹត្តអំពើហិង្សានឹងវិនាស និងបង្កឱ្យមានសេចក្តីស្អប់ខ្ពើមយ៉ាងឆាប់។

៣៨៧- មិនមែនដោយសារមិត្តភាព មិនមែនដោយសារលាភសក្ការៈមហាសាល ញ៉ាំងឱ្យព្រះរាជាត្រូវដោះលែងអ្នកប្រព្រឹត្តអំពើហិង្សា ដែលបង្កភេរវកម្មដល់សព្វសត្វនោះទេ។

៣៨៨- អ្នកមានកំណើតពីរដង អាចចាប់កាន់អាវុធ ពេល(ពួកគេ)ត្រូវបានឡោមព័ទ្ធ(ក្នុងការបំពេញ)ករណីយកិច្ចរបស់ខ្លួន ពេលសេចក្តីវិនាស(គំរាមកំហែង)ដល់វណ្ណៈដែលមានកំណើតពីរដងក្នុងគ្រា(សាហាវឃោរឃៅ),

---

**៣៣៩.** អាប. ជំពូក១ លេខ២៨, ៣; គោត. ជំពូក១២ លេខ២៨; យញ្ញ. ជំពូក២ លេខ១៦៦។ តាមលោកមេធ., គោវ., កុល្លូ., នារ. និងរាឃ. លក្ខខណ្ឌគឺថា វត្ថុដែលគេយក មិននៅក្នុងរបង។

**៣៤១.** គោត. ជំពូក១២ លេខ៤៩-៥០; សូមមើលជំពូក៩ លេខ២៧៩, ២៤១ ខាងក្រោម។

**៣៤២.** 'ចាប់យកទាសករជាដើម' គឺ'យកពួកគេធ្វើការរបស់ខ្លួន'(នារ.)។ អ្នកអធិប្បាយដទៃគិតថាជាបទចោរកម្មជាក់ស្តែង។

**៣៤៤.** *សាហសៈ* 'ហិង្សា' តាមលោកមេធ. គឺអំពើប្លន់ (សូមមើលកាព្យ៣៣២ ខាងលើផង) អំពើរំលោភ ការបង្កអគ្គីភ័យ ការធ្វើឱ្យហែកសម្លៀកបំពាក់ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយបង្ខំ។

**៣៤៨-៣៥១.** គោត. ជំពូក៧ លេខ២៥; វស. ជំពូក៣ លេខ១៥-១៨, ២៤; ពោធ. ជំពូក១ លេខ១៨-២៣; វិ. ជំពូក៥ លេខ១៨៩-១៩២។

**៣៤៨.** គឺ ពេលដែលចោរប្លន់ជាដើម មិនអនុញ្ញាតឱ្យអ្នកមានកំណើតពីរដង ធ្វើការបូជាយញ្ញ ឬ ដើម្បីបំពេញករណីយកិច្ច

៣៨៩- ក្នុងការការពារខ្លួនដោយផ្ទាល់ ក្នុងការព្យាយាមទាមទារថ្លៃសម្រាប់អាចារ្យពិធីការ និងដើម្បីការពារស្ត្រីនិងព្រាហ្មណ៍ អ្នកដែល(ស្ថិតក្រោមកាលៈទេសៈបែបនេះ) អាចសម្លាប់ដោយហេតុផលត្រឹមត្រូវ មិនមែនជាការប្រព្រឹត្តអំពើបាបទេ។

៣៩០- អ្នកអាចសម្លាប់ឃាតករដែលសំដៅមករកខ្លួន(ដោយបំណងឃាតកម្ម) ដោយគ្មានស្ទាក់ស្ទើរ ទោះបីជា(គាត់ជាគ្រូរបស់អ្នក) ជាកូនក្មេងក្តី ឬជាមនុស្សចាស់ក្តី ឬជាព្រាហ្មណ៍ដែលចេះតែងកាព្យបានជ្រៅជ្រះក្នុងព្រះវេទក្តី។

៣៩១- ដោយការសម្លាប់ឃាតករអ្នកសម្លាប់មិនមានទោសទេទោះជា(គាត់ធ្វើអំពើនោះ)ជាសាធារណៈក្តី ឬដោយស្ងាត់ក្តី ហើយក្នុងករណីនោះគឺ កំហឹងទល់នឹងកំហឹង។

៣៩២- អ្នកដែលប្រព្រឹត្តអំពើផិតក្បត់ជាមួយភរិយាអ្នកដទៃ ព្រះរាជាត្រូវឱ្យមានការដាក់ទោស ដែលបង្កឱ្យមានការភ័យខ្លាច ហើយបន្ទាប់មកនិរទេសខ្លួន។

៣៩៣- ព្រោះ (អំពើផិតក្បត់) បង្កឱ្យមានភាពច្របូកច្របល់វណ្ណៈក្នុងចំណោមបុរស អំពើនេះ(នាំឱ្យមាន)បាប ដែលកាត់ផ្តាច់ឫសកែវ និងបង្កសេចក្តីវិនាសគ្រប់បែបយ៉ាង។

៣៥៤- បុរសដែលដំបូងជាប់ចោទពីបទល្មើស(បែបនេះ) ដែលសន្ទនាជាសម្ងាត់ជាមួយប្រពន្ធអ្នកដទៃ នឹងបង់ពិន័យថ្នាក់ទីមួយ (ឬថ្នាក់ទាបបំផុត)។

៣៥៥- ប៉ុន្តែបុរសម្នាក់ ដែលគ្មានទំនាក់ទំនងមុនពេលត្រូវចោទ ដែលនិយាយជាមួយ(ស្ត្រីម្នាក់) ក្នុងហេតុផល(សមស្រប)មួយចំនួន នឹងគ្មានទោស ព្រោះគាត់គ្មានការប្រព្រឹត្តបំពានអ្វីទេ។

៣៥៦- អ្នកដែលនិយាយជាមួយប្រពន្ធអ្នកដទៃនៅឯ *ទីរថៈ* ខាងក្រៅភូមិ ក្នុងព្រៃ ឬនៅមាត់ប្រសព្វទន្លេ នឹងទទួល(ទោសពីបទ)សហាយស្មន់(សំគ្រហណៈ)។

៣៥៧- ការផ្ដល់អំណោយ(ឱ្យស្ត្រី) ការបន្លែងលេង(ជាមួយនាង) ការប៉ះពាល់គ្រឿងអលង្ការ និងសម្លៀកបំពាក់របស់នាង ការអង្គុយជាមួយនាងនៅលើគ្រែ អំពើ(ទាំងអស់នេះ) ត្រូវចាត់ទុកជាអំពើផិតក្បត់(សំគ្រហណៈ)។

---

ពិសិដ្ឋផ្សេងៗទៀត ឬនៅពេលមានការឈ្លានពានពីបរទេស(គោវ., កុល្ល., នារ., រាឃ.) ឬគ្រោះទុរ្ភិក្ស វណ្ណៈអ្នកមានកំណើតពីរដង ត្រូវគំរាមកំហែង ដោយសារភាពច្របូកច្របល់ខុសទំនង(សំការៈ)។

**៣៥០.** តាមលោកកុល្ល. លក្ខខណ្ឌគឺថា យើងមិនអាចជួយខ្លួនឯងបានដោយការរត់គេច តាមលោកនារ. យើងមិនត្រូវបង្កបួសស្នាមមនុស្សបែបនេះ 'ឱ្យធ្ងន់ធ្ងរហួសហេតុទេ'។

**៣៥១.** 'ដោយសម្ងាត់'គឺ 'ដោយមន្តគាថា ឬអាគមអូមអាម'(គោវ., នារ., នន្ទ.)។

**៣៥៣.** គឺ បើមានភាពឡូកឡំវណ្ណៈ គេមិនអាចធ្វើពិធីយញ្ញបានដោយត្រឹមត្រូវទេ ពីព្រោះអ្នកធ្វើពិធី មិនគ្រប់លក្ខណៈសម្រាប់ធ្វើពិធី។ ប្រសិនបើពិធីយញ្ញ មិនបានធ្វើដោយត្រឹមត្រូវ ភ្លៀងនឹងមិនធ្លាក់ទេ(សូមមើលជំពូក៣ លេខ៧៦) ហើយអ្វីៗនឹងវិនាស(មេធ., គោវ., កុល្ល., រាឃ.)។

**៣៥៤-៣៥៨.** អាប. ជំពូក២ លេខ២៦, ១៨-១៩; យញ្ញ. ជំពូក២ លេខ២៨៤។

**៣៥៥.** 'ទីរថៈ' គឺ 'ទីតាំងច្រាំងទន្លេ ដែលស្ត្រីចុះទៅដងទឹក'(មេធ., នារ., រាឃ.)។ ការដាក់ទោស ជាពិន័យកម្រិតខ្ពស់បំផុត(កុល្ល.)។ នន្ទ. ដាក់កាព្យនេះបន្ទាប់ពីកាព្យលេខ៣៥៧។

៣៥៨- ប្រសិនបើនរណាម្នាក់ប៉ះពាល់ស្ត្រីម្នាក់ ត្រង់កន្លែងមួយដែល(មិនគួរប៉ះពាល់) ឬ ដែលអាចប៉ះបានដោយខ្លួនឯងនៅកន្លែងបែបនោះ អំពើទាំងអស់(ដែលបានធ្វើ) ដោយមានការយល់ព្រមទៅវិញទៅមក ត្រូវប្រកាសថាជាការផិតក្បត់(សំគ្រហណៈ)។

៣៥៩- បុរសដែលមិនមែនជាព្រាហ្មណ៍ គួរទទួលទោសស្លាប់ ចំពោះបទផិតក្បត់(សំគ្រហណៈ) ព្រោះភរិយារបស់វណ្ណៈទាំងបួន យ៉ាងណាក៏ដោយត្រូវតែទទួលបានការការពារពិសេសជានិច្ច។

៣៦០- ស្មូម ករី អ្នកដែលបានធ្វើពិធីយញ្ញតាមព្រះវេទចូលជាសមាជិកថ្មី និងសិល្បករ មិនត្រូវគេហាមឃាត់មិនឱ្យនិយាយជាមួយស្ត្រីដែលរៀបការហើយនោះទេ។

៣៦១- ចូរបុរសកុំសន្ទនាជាមួយភរិយារបស់អ្នកដទៃ បន្ទាប់ពីខ្លួនត្រូវគេហាម(មិនឱ្យធ្វើដូច្នេះ) ប៉ុន្តែអ្នកដែលសន្ទនា(ជាមួយស្ត្រី) ទោះបីជាមានការហាមឃាត់ក៏ដោយនោះ នឹងត្រូវពិន័យចំនួនមួយសុវណ្ណ។

៣៦២- វិធានច្បាប់នេះ មិនអនុវត្តចំពោះភរិយារបស់តារាសម្ដែងនិងអ្នកចម្រៀងទេ និងមិនអនុវត្តចំពោះភរិយារបស់អ្នកដែលរស់នៅអាស្រ័យលើ(ភរិយា)របស់ខ្លួនទេ ព្រោះបុរសបែបនេះបញ្ជូន

កិរិយារបស់ខ្លួន(ឱ្យទៅអ្នកដទៃ) ឬដោយជួយលាក់បាំង អនុញ្ញាតឱ្យពួកគេរួមប្រព្រឹត្តអំពើឧក្រិដ្ឋ។

៣៦៣- ប៉ុន្តែអ្នកដែលសន្ទនាជាសម្ងាត់ជាមួយស្ត្រីបែបនេះ ឬជាស្ត្រីទាសករដែលមានម្ចាស់ និងជាមួយស្ត្រីរបស់ឥសី នឹងត្រូវបង្ខំឱ្យបង់ពិន័យតិចតួច។

៣៦៤- អ្នកដែលរំលោភស្រីក្រមុំដែលមិនសុខចិត្ត នឹងទទួលទណ្ឌកម្មរូបកាយភ្លាមៗ ប៉ុន្តែបុរសដែលរីករាយនឹងស្រីដែលមានចំណង់ នឹងមិនទទួលទណ្ឌកម្មរូបកាយទេ ប្រសិនបើ(វណ្ណៈរបស់ខ្លួន) ស្មើគ្នានឹងវណ្ណៈរបស់នាង។

---

**៣៥៨.** នន្ទ. និយាយថា 'បើបុរសប៉ះពាល់ស្ត្រីនៅកន្លែងស្ងាត់តែឯង'។ គោវ. ក៏សរសេរបកស្រាយដូច្នេះដែរ។

**៣៥៩.** យោងតាមលោកគោវ., កុល្ល., រាឃ. វិធានច្បាប់នេះសំដៅដល់ការផិតក្បត់ ដែលប្រព្រឹត្តដោយសូទ្រៈ ជាមួយព្រាហ្មណី (រាឃ.) ឬសំដៅដល់ការរំលោភព្រាហ្មណីពីសំណាក់បុរសសូទ្រៈ(គោវ., កុល្ល.)។ មេធ.ក៏គិតដូច្នេះថា បុរសសូទ្រៈប៉ុណ្ណោះត្រូវទទួលទោសប្រហារជីវិតពីបទផិតក្បត់ជាមួយស្ត្រីអារ្យ៉ន។ លោកនន្ទ. ទីបំផុតនិយាយថា គឺសំដៅដល់ក្សត្រិយ វៃស្យៈ និងសូទ្រៈ ដែលប្រមាថលើស្ត្រីដែលមានវណ្ណៈខ្ពស់ជាង។ ប៉ុន្តែទំនងជាការបកស្រាយត្រឹម ត្រូវពាក្យ *ប្រាណាន្តំ ទណ្ឌំ* 'ទោសស្លាប់' អាចជា 'ការដាក់ទោសដល់ស្លាប់ក៏មាន'។ ការប្រែនេះ យ៉ាងហោចណាស់ លុបបំបាត់បញ្ហាស្មុគ្រស្មាញទាំងអស់ ដែលបង្កើតឡើងដោយសេចក្តីប្រហាក់ប្រហែល និងកាព្យបន្តបន្ទាប់។

**៣៦១.** យញ្ញ. ជំពូក២ លេខ២៨៥។

**៣៦២.** ពោធ. ជំពូក២ លេខ៤, ៣។ ខ្ញុំប្រែ *ចារណ* តាមអ្នកអធិប្បាយនានាថា 'តារាសម្តែង និងអ្នកចម្រៀង' ប៉ុន្តែក៏អាចមាន វណ្ណៈដូចគ្នា ដែលគេបានដឹងច្បាស់នៅឥណ្ឌាប៉ែកខាងលិច។

**៣៦៣.** 'ស្ត្រីរបស់ឥសី' គឺ 'វក្សកា(?), សីលមិត្រា(?) ជាដើម'(មេធ.) ឬ 'នាងជីពុទ្ធសាសនា'(គោវ., កុល្ល., រាឃ.)។ នារ. និយាយថា 'ស្ត្រីស្នម'។ គួរឱ្យកត់សម្គាល់ថា យោងតាមសេចក្តីរបស់លោកគោវ. និងនារ. រហូតដល់ពោធាយនៈ ប៉ុន្តែមិនមាននៅក្នុងអត្ថបទរបស់យើងទេ 'អ្នកខ្លះ'អនុញ្ញាតឱ្យស្ត្រីធម្មតាធ្វើជាឥសីនីបាន។ ឥសីនី ទំនងជាមាននៅប្រទេសសម័យបុរាណ ជាទូទៅដូចឥឡូវនេះដែរ ហើយគេចាត់ទុកថាមានឈ្មោះអាក្រក់ដូចគ្នា។

**៣៦៤-៣៦៨.** យញ្ញ. ជំពូក២ លេខ២៨៨។

៣៦៥- អំពីស្រីក្រមុំដែលផ្តើមទាក់ទង(ប្រុស)ដែលមានវណ្ណៈខ្ពស់ ប្រុសនោះនឹងមិនទទួលពិន័យទេ ប៉ុន្តែស្រី ដែលចែងចង់ប្រុសដែលមានវណ្ណៈទាប ត្រូវបង្ខំប្រុស ឱ្យរស់នៅក្នុងការឃុំឃាំងក្នុងផ្ទះរបស់នាង។

៣៦៦- (បុរស)ក្នុងវណ្ណៈទាប ដែលរួមស្នេហាជាមួយស្រីក្រមុំដែលមានវណ្ណៈខ្ពស់បំផុត នឹងទទួលទណ្ឌកម្មរូបកាយ ហើយបុរសដែលចែចង់ស្រីក្រមុំ(វណ្ណៈ)ស្មើគ្នា នឹងចេញថ្លៃរៀបការ ប្រសិនបើឪពុករបស់នាងចង់ឱ្យមានការរៀបការនោះ។

៣៦៧- ប៉ុន្តែបើបុរសណាមានចិត្តព្រហើន បង្ខំបង្ខូចព្រហ្មចារីស្រីក្រមុំ ម្រាមដៃចំនួនពីររបស់បុរសនោះនឹងត្រូវគេកាត់ភ្លាម ហើយគាត់នឹងបង់ពិន័យចំនួនប្រាំមួយរយ(បណៈ)។

៣៦៨- បុរស(ដែលមាន)វណ្ណៈស្មើគ្នា ដែលធ្វើឱ្យខូចព្រហ្មចារីស្រីក្រមុំដែលសុខចិត្ត នឹងមិនទទួលទោសកាត់ម្រាមដៃទេ ប៉ុន្តែនឹងបង់ពិន័យចំនួនពីររយ(បណៈ) ដើម្បីធ្វើឱ្យគាត់រាងចាលកុំប្រព្រឹត្ត (បទល្មើសដដែលៗ)។

៣៦៩- ស្រីក្រមុំដែលធ្វើឱ្យព្រហ្មចារីស្រីក្រមុំ(ម្នាក់ទៀត) ត្រូវទទួលពិន័យចំនួនពីររយ(បណៈ) បង់ថ្លៃរៀបការរបស់នាងចំនួនទ្វេដង និងទទួលទណ្ឌកម្មដប់រំពាត់(ខ្សែតី)។

៣៧០- ប៉ុន្តែស្ត្រីដែលធ្វើឱ្យព្រហ្មចារីស្រីក្រមុំ នឹងត្រូវគេកោរសក់(ក្បាលនាង)ភ្លាម ឬកាត់ម្រាមដៃពីរ ហើយត្រូវបណ្ដើរឱ្យជិះសត្វលា (ដើរទូទាំងក្រុង)។

៣៧១- ប្រសិនបើភរិយា ដែលមានមោទនភាពចំពោះសាច់ញាតិខ្លួន ឬឧត្តមភាព(របស់ខ្លួនផ្ទាល់) រំលោភបំពានករណីយកិច្ច ដែលនាងជាប់ជំពាក់នឹងម្ចាស់ខ្លួន ព្រះរាជានឹងជំរុញឱ្យឆ្កែហែកហួរនាងនៅនឹងកន្លែងច្រើនលើកច្រើនសា។

៣៧២- ចូរទ្រង់ឱ្យគេនាំជនល្មើសប្រុសដេកលើគ្រែដែកក្ដៅក្រហមឆ្អៅ ហើយគេនឹងដាក់ឈើពីលើវា (រហូតដល់)ជនប្រព្រឹត្តអំពើបាបនោះត្រូវភ្លើងឆេះ(ដល់ស្លាប់)។

៣៧៣- ចំពោះបុរសម្នាក់ (ដែលធ្លាប់)ត្រូវកាត់ទោស ដែលត្រូវជាប់ចោទ(ម្ដងទៀត)ក្នុងមួយឆ្នាំ ការដាក់ពិន័យ(ត្រូវគុណទ្វេដង) ដូច្នេះ(ពិន័យ)ត្រូវគុណទ្វេដង សម្រាប់ការរួមសង្វាស (ច្រើនដង)រវាងវ្រាត្យានិងចណ្ឌាលី។

---

**៣៦៥.** 'អំពីស្រីក្រមុំ' គឺ 'ពីសាច់ញាតិ ឬអាណាព្យាបាលរបស់នាង'(មេធ.)។ យោងតាមលោកកុល្លូ. និងនារ. ក្មេងស្រី ត្រូវគេឃុំឃាំង តាមមេធ. ត្រូវបានការពារដោយសាច់ញាតិរបស់នាង។ ការឃុំឃាំងគឺមានរយៈពេលរហូតដល់នាងជាប់ចិត្ត។

**៣៦៦.** ន័យនៃអនុប្រយោគទីពីរ គឺថា បើឪពុកចង់បានអាពាហ៍ពិពាហ៍ ជនល្មើសត្រូវរៀបការជាមួយក្មេងស្រីនោះ បន្ទាប់ពីបង់ថ្លៃអាពាហ៍ពិពាហ៍(កុល្លូ., នារ.)។ ប្រសិនបើឪពុកមិនចង់ទទួលថ្លៃនោះទេ ជនល្មើសត្រូវបង់ថវិកាចំនួនស្មើគ្នានោះ ជាប្រាក់ពិន័យថ្វាយព្រះមហាក្សត្រ (មេធ., គោវ., រាឃ.)។

**៣៧០.** យោងតាមលោកមេធ. និងនារ. កាព្យនេះរៀបរាប់អំពីទណ្ឌកម្មបីប្រភេទផ្សេងគ្នា ហើយជនល្មើសព្រាហ្មណី ត្រូវគេកោរសក់, ក្សត្រិយា ត្រូវគេដាក់លើសត្វលាបណ្ដើរតាមផ្លូវ ចំណែកឯស្ត្រីវណ្ណៈផ្សេង ត្រូវបាត់ម្រាមដៃពីរ។ យោងតាម គោវ. , កុល្លូ. និងរាឃ. ការដាក់ទណ្ឌកម្មត្រូវបានកំណត់ទៅតាមព្រឹត្តិការណ៍។

**៣៧១-៣៧២.** គោត. ជំពូក២៣ លេខ១៤-១៥; វិ. ជំពូក៥ លេខ១៨។

**៣៧៣.** 'វ្រាត្យា' គឺ 'ភរិយារបស់អាវ្រ័ន ដែលមិនទាន់បានរៀបចំពិធី'(គោវ., កុល្លូ., រាឃ.) និងសូមមើលជំពូក២ លេខ៣៩

៣៧៤- សូទ្រៈ ដែលរួមសង្វាសជាមួយស្ត្រីវណ្ណៈដែលមានកំណើតពីរដង ដែលមានការការពារ ឬគ្មាន (នឹងត្រូវដាក់ទោសតាមរបៀបខាងក្រោម) ប្រសិនបើនាងមិនមានអ្នកហួងហែង ប្រុសមិនមានចំណែក(ល្មើស)ទេ ហើយបាត់ទ្រព្យទាំងអស់របស់ខ្លួន ប្រសិនបើនាងមានអ្នកហួងហែង ប្រុសនឹងបាត់បង់អ្វីៗទាំងអស់(រួមទាំងជីវិតរបស់ខ្លួនផង)។

៣៧៥- (ចំពោះការរួមសង្វាសជាមួយព្រាហ្មណីដែលមានអ្នកហួងហែង) វៃស្យៈនឹងបង់ពិន័យទ្រព្យរបស់ខ្លួនទាំងអស់ បន្ទាប់ពីជាប់គុករយៈពេលមួយឆ្នាំ ក្សត្រិយនឹងត្រូវពិន័យចំនួនមួយរយ (បណៈ) និងត្រូវកោរសក់លាបទឹកនោម(លា)។

៣៧៦- ប្រសិនបើវៃស្យៈ ឬក្សត្រិយ មានទំនាក់ទំនងជាមួយព្រាហ្មណីដែលគ្មានអ្នកហួងហែង ចូរទ្រង់ពិន័យវៃស្យៈ ចំនួនប្រាំរយ(បណៈ) និងក្សត្រិយចំនួនមួយរយ។

៣៧៧- ប៉ុន្តែទោះបីពិន័យអ្នកទាំងពីរដូច្នេះក្តី ប្រសិនបើពួកគេបំពានទៅលើព្រាហ្មណី(ដែលមិនត្រឹមតែមាន) អ្នកហួងហែង (តែជាភរិយារបស់បុរសខ្ពង់ខ្ពស់) នឹងត្រូវពិន័យដូចសូទ្រៈដែរ ឬត្រូវដុតក្នុងភ្លើងស្មៅស្ងួត។

៣៧៨- ព្រាហ្មណ៍ ដែលស្គាល់រូបកាយព្រាហ្មណីដែលមានអ្នកហួងហែង ដោយផ្ទុយពីឆន្ទៈរបស់នាងនឹងត្រូវពិន័យចំនួនមួយពាន់(បណៈ) ប៉ុន្តែគាត់នឹងត្រូវបង់ពិន័យចំនួនប្រាំរយ ប្រសិនបើគាត់មានទំនាក់ទំនងជាមួយស្ត្រីដែលសុខចិត្ត។

៣៧៩- ពិធីកោរសក់ (ក្បាល) ជាការបំបួសព្រាហ្មណ៍ (ជំនួសឱ្យ) ការដាក់ទោសប្រហារជីវិត ប៉ុន្តែ (បុរស)វណ្ណៈផ្សេង នឹងទទួលទោសប្រហារជីវិត។

៣៨០- ចូរទ្រង់កុំសម្លាប់ព្រាហ្មណ៍ ទោះបីគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ (ដែលអាចកើតមាន) ទាំងអស់ ហើយចូរទ្រង់និរទេស(ជនល្មើស)បែបនេះ ដោយឱ្យទ្រព្យទាំងអស់របស់គាត់(ទៅគាត់) និង (រូបកាយគាត់)គ្មានការឈឺចាប់។

៣៨១- នៅលើលោកនេះ គ្មានអំពើឧក្រិដ្ឋណាធ្ងន់ធ្ងរជាងការសម្លាប់ព្រាហ្មណ៍ទេ ដូច្នេះព្រះរាជាមិនត្រូវតែ សូម្បីតែមានគំនិតក្នុងចិត្ត កុំចង់សម្លាប់ព្រាហ្មណ៍ឱ្យសោះ។

៣៨២- ប្រសិនបើវៃស្យៈចូលទៅរកស្ត្រីវណ្ណៈក្សត្រិយ ដែលមានអ្នកហួងហែង ឬក្សត្រិយចូលទៅរកស្ត្រីវៃស្យៈ (ដែលមានអ្នកហួងហែង) ពួកគេទាំងពីរសមនឹងទទួលទោសដូចគ្នាក្នុងករណីស្ត្រីព្រាហ្មណ៍ដែលគ្មានអ្នកហួងហែង។

---

ខាងលើ ឬ 'ស្ត្រីដែលមិនទាន់រៀបការតាមកាលសមស្រប'(នារ. និងមេធ.) ដែលអ្នកក្រោយនេះក៏ចង់បកស្រាយ ម្យ៉ាងទៀត 'ស្ត្រីសាធារណៈ' ឬ 'ស្ត្រីទទួលប្រុសច្រើន'។ ប្រាក់ពិន័យដែលត្រូវបង់ គឺ ពីររយបណៈ(គោវ., កុល្លូ., រាឃ.)។

**៣៧៤.** អាប.ជំពូក២ លេខ២៦, ២០; ២៧, ៩; គោត. ជំពូក១២ លេខ២-៣; វស. ជំពូក២១ លេខ៥, ៥; ពោធ. ជំពូក២ លេខ៣, ៥២; យញ្ញ. ជំពូក២ លេខ២៨៦, ២៩៤។ 'មានអ្នកការពារ' គឺ'មានប្ដី ឬសាច់ញាតិរបស់នាង'(មេធ., កុល្លូ., រាឃ.)។

**៣៧៧.** អាប. ជំពូក២ លេខ២៦, ២០; វស. ជំពូក២១ លេខ២-៣; យញ្ញ. ជំពូក២ លេខ២៨៦។ 'ដូចជាសូទ្រៈ' សូមមើលកាព្យលេខ៣៧៤។

**៣៨២.** យោងតាមអ្នកអធិប្បាយនានា ប្រើវិធានកាព្យលេខ៣៧៦។

៣៨៣- ព្រាហ្មណ៍នឹងត្រូវគេបង្ខំឱ្យបង់ពិន័យចំនួនមួយពាន់(បណៈ) ប្រសិនបើគាត់រួមសង្វាសជាមួយ (ស្ត្រី)វណ្ណៈទាំងពីរដែលមានអ្នកហួងហែង ព្រោះ(ការប្រព្រឹត្តល្មើសចំពោះ)ស្ត្រីសូទ្រៈ(ដែលមានអ្នកហួងហែង) ពិន័យចំនួនមួយពាន់(បណៈ ត្រូវដាក់)ចំពោះក្សត្រិយ ឬវៃស្យៈ។

៣៨៤- ចំពោះ(ការរួមសង្វាសជាមួយ)ស្ត្រីក្សត្រិយដែលគ្មានអ្នកហួងហែង ពិន័យចំនួនប្រាំរយ(បណៈ ចំពោះ)វៃស្យៈ ប៉ុន្តែ(ចំពោះបទល្មើសដូចគ្នា) ក្សត្រិយនឹងត្រូវគេកោរព្រះកេសា លាបទឹកនោម (លា) ឬ(បង់)ពិន័យដូចគ្នា។

៣៨៥- ព្រាហ្មណ៍ដែលចូលទៅរកស្ត្រីត្រកូលក្សត្រិយ ឬ(វណ្ណៈ)វៃស្យៈ ដែលគ្មានអ្នកហួងហែង ឬស្ត្រីសូទ្រៈ នឹងត្រូវពិន័យចំនួនប្រាំរយ(បណៈ) ប៉ុន្តែ (ចំពោះការរួមសង្វាសជាមួយ)ស្ត្រីវណ្ណៈទាបបំផុត (ពិន័យ)មួយពាន់។

៣៨៦- ពោលគឺព្រះរាជានៅក្នុងក្រុងរបស់ទ្រង់ គ្មានចោរ គ្មានអ្នកផិតក្បត់ គ្មានប្រមាថ គ្មានអ្នកដែលមានទោសប្រព្រឹត្តហិង្សា និងគ្មានអ្នកបង្ករបួសស្នាម បានឡើងឋាន*សក្រ*(ឥន្ទ្រ)។

៣៨៧- ការបង្ក្រាបបទល្មើសទាំងប្រាំនេះនៅក្នុងការគ្រប់គ្រងរបស់ទ្រង់ ធានាបាននូវអធិបតេយ្យភាពដ៏ខ្ពង់ខ្ពស់ជាក្សត្រិយ ក្នុងចំណោមមហាក្សត្រិយនានា និងកិត្តិស័ព្ទនៅក្នុងលោក។

៣៨៨- ម្ចាស់ពិធីយញ្ញ ដែលបូជាអាចារ្យពិធីការ ហើយអាចារ្យពិធីការដែលលះបង់ដើម្បីម្ចាស់ពិធីយញ្ញ (ម្នាក់ៗដែល)អាចបំពេញការងាររបស់ខ្លួន និងមិនសៅហ្មង(ដោយបទឧក្រិដ្ឋធ្ងន់ធ្ងរ) ម្នាក់ៗត្រូវពិន័យចំនួនមួយរយ(បណៈ)។

៣៨៩- មិនមែនម្តាយ មិនមែនឪពុក មិនមែនប្រពន្ធ និងមិនមែនកូនប្រុស នឹងត្រូវបំបោះបង់ទេ ហើយអ្នកដែលបំបោះបង់ពួកគេ លើកលែងតែគ្មានទោសឧក្រិដ្ឋដែលតម្រូវឱ្យបាត់បង់វណ្ណៈ នឹងត្រូវព្រះរាជា ពិន័យចំនួនប្រាំមួយរយ(បណៈ)។

៣៩០- ប្រសិនបើបុរសមានកំណើតពីរដង ឈ្លោះគ្នាពីករណីយកិច្ចតាមលំដាប់ថ្នាក់ ព្រះរាជាដែលចង់បានសុខុមាលភាពផ្ទាល់ខ្លួន មិនត្រូវវិនិច្ឆ័យ(ដោយរហ័នពេក)ថាអ្វីជាច្បាប់នោះទេ។

៣៩១- ដោយបានបង្ហាញកិត្តិយសសមគួរដល់ពួកគេ ព្រះអង្គ ដោយមានជំនួយពីព្រាហ្មណ៍ទីមួយ និយាយលួងលោមពួកគេដោយ(វាចា)ទន់ភ្លន់ បន្ទាប់មកទើបទូន្មានពួកគេអំពីករណីយកិច្ចរបស់ខ្លួន។

---

**៣៨៥.** 'ស្ត្រីវណ្ណៈទាបបំផុត' គឺ 'ចណ្ឌាលី'(គោវ., កុល្ល., រាឃ.) ឬ 'ដែលជាកម្មសិទ្ធិរបស់វណ្ណៈបុរសបោកខោអាវ កម្មករស្បែក អ្នកសម្តែង អ្នកធ្វើកញ្ជើល្អី អ្នកនេសាទ *មេទ* ឬ កិល្លៈជាដើម'(នារ.)។

**៣៨៦.** វិ. ជំពូក៥ លេខ១៩៦។

**៣៨៨.** 'អាចារ្យពិធីការ' គឺ 'អ្នកដែលបានរៀបចំធ្វើពិធីឱ្យគ្រួសារខ្លួន តាំងពីច្រើនជំនាន់មកហើយ'(គោវ., នារ.)។

**៣៨៩.** វិ. ជំពូក៥ លេខ១៦៣; យញ្ញ. ជំពូក២ លេខ២៣៧។ 'នឹងមិនត្រូវគេបោះបង់ចោល' គឺ 'នឹងមិនត្រូវគេបដិសេធការបីបាច់ ឬការគោរពត្រឹមត្រូវទេ'(មេធ., គោវ., កុល្ល.)។

**៣៩០.** 'តាមលំដាប់' គឺ 'តាមលំដាប់ទាំងបួន'(នារ., រាឃ.) ឬ 'របស់ឃរាវាស'(គោវ., កុល្ល.)។ មេធ. និងនន្ទ. ប្រែ *អាស្រម* មិនមានន័យ 'តាមលំដាប់'ទេ ប៉ុន្តែជា 'អាស្រមបទ' និង 'បុរសមានកំណើតពីរដង' ក្នុងន័យថា 'តាបស'។ នារ.

៣៩២- ព្រាហ្មណ៍ ដែលមិនអញ្ជើញអ្នកជិតខាងបន្ទាប់របស់ខ្លួន និងអ្នកជិតខាងម្ខាងទៀត (ទោះជា) ទាំងពីរនាក់(ទើប)សមនឹងកិត្តិយស ឱ្យចូលរួមពិធីដែលមានព្រាហ្មណ៍ចំនួនម្ភៃចូលរួម ត្រូវបង់ពិន័យចំនួនមួយមាសៈ។

៣៩៣- ស្រោត្រិយ ដែលមិនទទួលស្រោត្រិយល្អក្នុងពិធីបុណ្យដ៏នក្ខត្តឫក្ស នឹងត្រូវបង់ឱ្យគាត់ទ្វេដងនៃ(តម្លៃ)អាហារ និងមួយមាសៈនៃមាស (ជាប្រាក់ពិន័យថ្វាយព្រះរាជា)។

៣៩៤- មនុស្សខ្វាក់ មនុស្សឡប់សតិ មនុស្សពិការ ដែលធ្វើចលនាដោយក្តារជំនួយចាស់ជរាវ័យជិតសិបឆ្នាំ និងអ្នកដែលផ្តល់ប្រយោជន៍ដល់ស្រោត្រិយ នឹងមិនត្រូវ(ព្រះរាជាណាមួយ)បង្ខំឱ្យបង់ពន្ធទេ។

៣៩៥- ចូរព្រះរាជាតែងតែរាប់អានដោយរាបសាចំពោះ ស្រោត្រិយ អ្នកជំងឺ ឬអ្នកជួបគ្រោះអាសន្នកូនក្មេងនិងមនុស្សចាស់ ឬមនុស្សទុរគត មនុស្សដែលមានកំណើតខ្ពស់ និងអ្នកមានកិត្តិយស (ពួកអារ្យ៉ន)។

៣៩៦- អ្នកបោកខោអាវនឹងបោកសម្អាត(ខោអាវរបស់អ្នកជួលខ្លួន) ដោយល្អលើក្តារឈើសាល្មលី ដ៏រលោងហើយគាត់មិនប្រគល់ខោអាវ (របស់មនុស្សម្នាក់) ឱ្យទៅមនុស្សផ្សេងនិងមិនឱ្យនរណាម្នាក់(ក្រៅពីម្ចាស់) ស្លៀកពាក់ខោអាវនោះទេ។

៣៩៧- អ្នកតម្បាញ (ដែលបានទទួលអំបោះ) ចំនួនដប់បលៈ នឹងប្រគល់(ក្រណាត់ទម្ងន់)មួយបលៈឡើង ហើយអ្នកដែលប្រព្រឹត្តផ្ទុយពីនេះ នឹងត្រូវគេបង្ខំឱ្យបង់ពិន័យចំនួនដប់ពីរ(បណៈ)។

៣៩៨- ចូរព្រះរាជាដកយកមួយភាគដប់ពីរនៃចំនួន ដែលមនុស្សដឹងពីការទូទាត់ថ្លៃនិងពន្ធ (និង) មានជំនាញក្នុង(ការប៉ាន់តម្លៃ)ទំនិញគ្រប់ប្រភេទ អាចកំណត់ជាតម្លៃទំនិញមួយៗដែលអាចលក់បាន។

---

បកស្រាយ *ន វិព្រូយាត* ៉នឹងមិនវិនិច្ឆ័យ(ដោយរហ័ន)ទេ៉ថា ៉នឹងមិនវិនិច្ឆ័យដោយព្រះអង្គឯងដោយខុសនោះទេ៉។

**៣៩២.** វិ. ជំពូក៥ លេខ៩៤; យញ្ញ. ជំពូក២ លេខ២៦៣។ ៉ពិធីបុណ្យ៉ គឺ ៉ពិធីអាពាហ៍ពិពាហ៍ជាដើម៉(មេធ.) ឬ ៉នៅឯពិធីដប់លៀងបាយល្ងាច៉(នន្ទ.)។ *អនុវេស្យ* ៉អ្នកជិតខាងបន្ទាប់របស់គាត់ តែមួយ៉(កុល្ល., នារ., រាឃ.) តាមលោកមេធ., គោវ. និងនន្ទ. គឺថា ៉អ្នកដែលរស់នៅខាងក្រោយផ្ទះរបស់គាត់៉ ចំណែកឯងអ្នកនៅទល់មុខ គឺ *ប្រាវិវេស្យ*។ ៉ម្ភៃ៉ គឺ ៉ចំនួនម្ភៃ ឬច្រើនជាងព្រាហ្មណ៍៉(គោវ.)។ ៉មួយមាសៈ៉ គឺ ៉គិតជាប្រាក់៉(គោវ., កុល្ល., រាឃ.) ឬ ៉គិតជាមាស៉(មេធ., នារ.)។

**៣៩៣.** ៉ស្រោត្រិយល្អ៉ គឺ ៉អ្នកជិតខាង៉(គោវ., កុល្ល., រាឃ.) ឬ ៉ដែលរស់នៅក្នុងភូមិជាមួយ៉(នារ.)។ មេធ.និយាយថា ៉អ្នកដែលមិនមែនជាអ្នកជិតខាង៉។

**៣៩៤.** អាប. ជំពូក២ លេខ២៦, ១០-១៥; វស. ជំពូក១៩ លេខ២៣-២៤។ ៉(មនុស្សពិការ)ដែលធ្វើចលនាដោយក្តារជំនួយ៉ គឺមិនមានឃើញទូទៅនៅតាមថ្នល់ទីក្រុងរបស់ឥណ្ឌាទេ។ ៉ដោយ(ព្រះរាជា)ណាមួយ៉ គឺ ៉ទោះជាដោយអ្នកដែលអស់ទ្រព្យក៏ដោយ៉។

**៣៩៦.** យញ្ញ. ជំពូក២ លេខ២៣៨។ សាល្មលី ឬឈើដើមសំឡី មានលក្ខណៈទន់ពីធម្មជាតិ(មេធ.)។

**៣៩៧.** យញ្ញ. ជំពូក២ លេខ១៧៩។ ជំនួសឱ្យ ៉ដប់ពីរ(បណៈ)៉(កុល្ល., រាឃ.) លោកមេធ. ស្នើថា ៉ដប់ពីរ(បលៈ)៉ លោកគោវ. ថា ៉ដប់ពីរ(ដងនៃតម្លៃអំបោះ)៉ ហើយនារ. ថា៉មួយភាគដប់ពីរ(នៃតម្លៃអំបោះ)៉។ នន្ទ. អាន *ទសផលំ* និង *ឯកផលាធិកំ* ហើយនិយាយថា អ្នកត្បាញ ត្រូវបង់ថ្វាយព្រះរាជានូវប្រាក់ចំណេញមួយភាគដប់មួយ នៃស្នាដៃផលិតបានរបស់ខ្លួន។

**៣៩៨.** យញ្ញ. ជំពូក២ លេខ២៦១។ ជំនួស ៉នៃ(ចំនួន)នោះ៉(មេធ., នារ.) លោកគោវ., កុល្ល. និងរាឃ. និយាយថា ៉នៃ

៣៩៩- ចូរព្រះរាជារឹបអូសទ្រព្យសម្បត្តិទាំងអស់របស់(ឈ្មួញ)ដែលមានបំណងនាំចេញទំនិញដែលព្រះរាជាមានសិទ្ធិផ្តាច់មុខ ឬ(នាំចេញទំនិញ)ហាមឃាត់។

៤០០- អ្នកដែលគេចពន្ធ (ឬការបង់ថ្លៃ) អ្នកដែលទិញ ឬលក់ដោយខុសកាល ឬអ្នកដែលថ្លែងសេចក្តីមិនពិត ក្នុងការរាប់ឈ្មោះ(ទំនិញរបស់ខ្លួន) នឹងត្រូវពិន័យប្រាំបីដង (នៃតម្លៃពន្ធ) ដែលគាត់ព្យាយាមគេច។

៤០១- ចូរ(ព្រះរាជា)កំណត់(អត្រាសម្រាប់)ការទិញ និងលក់ទំនិញនៅទីផ្សារទាំងអស់ បន្ទាប់ពីបានពិចារណា(ត្រឹមត្រូវ)ពីកន្លែងដែលទំនិញមក ទំនិញទៅ រយៈពេលរក្សាទំនិញ និងចំណេញ (ដែលអាចទទួលបាន) និងចំណាយដើមទុន(តាមការប៉ាន់ស្មាន)។

៤០២- គ្រាមួយក្នុងពេលប្រាំរាត្រី ឬជិតពីរសប្តាហ៍ម្តង ចូរព្រះរាជាកំណត់តម្លៃជាសាធារណៈសម្រាប់(ពាណិជ្ជករ)។

៤០៣- ខ្នាតទម្ងន់ និងរង្វាស់ទាំងអស់ត្រូវកំណត់ឱ្យបានត្រឹមត្រូវ ហើយក្នុងពេលប្រាំមួយខែម្តង ចូរព្រះអង្គពិនិត្យមើលខ្នាតទាំងនោះឡើងវិញ។

៤០៤- នៅត្រង់កំពង់ចម្លង រទេះ(ទទេ)តម្រូវឲ្យបង់មួយបណៈ ដឹកបុរសម្នាក់បង់កន្លះបណៈ សត្វមួយនិងស្ត្រីម្នាក់ បង់មួយភាគបួន(បណៈ) មនុស្សប្រុសម្នាក់ចុះ យកកន្លះមួយភាគបួន។

៤០៥- រទេះ(ដែលផ្ទុកទំនិញពេញដោយ)ភាជន៍ នឹងត្រូវបង់ថ្លៃកំពង់ស្របតាមតម្លៃ(ទំនិញ) កប៉ាល់ទទេ និងមនុស្សដែលគ្មានឥវ៉ាន់ យកបន្តិចបន្តួច។

៤០៦- ចំពោះដំណើរឆ្ងាយ ការជួលទូកត្រូវឱ្យមានសមាមាត្រទៅនឹងទីកន្លែង និងពេលវេលា តោងដឹងថា (វិធាន) នេះសំដៅដល់ការធ្វើដំណើរតាមច្រាំងទន្លេ ហើយតាមផ្លូវសមុទ្រគ្មានការកំណត់(បន្ទុក)ទេ។

៤០៧- ប៉ុន្តែស្ត្រីដែលមានផ្ទៃពោះពីរខែ ឬលើស តាបស ឥសីនៅក្នុងព្រៃ និងព្រាហ្មណ៍ដែលជាសិស្សសិក្សាព្រះវេទ នឹងមិនតម្រូវឱ្យបង់ថ្លៃចម្លងទេ។

---

ប្រាក់ចំណេញនោះ។

**៣៩៩.** យញ្ញ. ជំពូក២ លេខ២៦១។ លោកមេធ. ផ្តល់តួយ៉ាងសិទ្ធិផ្តាច់មុខ មានសត្វដំរី ហើយនៅកាស្មៀរ គឺរមៀត; នៅខាងកើត គឺក្រណាត់ប្រណិត និងរោមចៀម; នៅខាងលិច គឺសេះ; នៅខាងត្បូង គឺត្បូងមានតម្លៃ និងគជ់។ រមៀតនៅតែជាទំនិញផ្តាច់មុខរបស់ក្សត្រិយនៅកាស្មៀរដដែល។

**៤០០.** យញ្ញ.ជំពូក២ លេខ២៦២។ 'ក្នុងពេលមិនសមកាល' គឺ'នៅពេលយប់ជាដើម'(មេធ., គោវ., នារ., កុល្ល., រាឃ.)។

**៤០២.** យញ្ញ. ជំពូក២ លេខ២៥១។ លោកគោវ. និងកុល្ល. និយាយថា 'ចូរទ្រង់កំណត់តម្លៃ ដោយមាន (អ្នកជំនាញចូលរួម សូមមើលកាព្យលេខ៣៩៨ខាងក្រោម)។ ការប្រែនេះយកតាមលោករាឃ. ។ ទំហំរយៈពេល គឺអាស្រ័យទៅតាមទំនិញដែលមានតម្លៃខុសៗពីគ្នា។ លោកមេធ. លុបកាព្យ និងកាព្យបន្ទាប់។

**៤០៣.** វស. ជំពូក១៩ លេខ១៣។

**៤០៥.** 'កប៉ាល់ទទេ' គឺសម្រាប់ជាយានដឹកជញ្ជូនទំនិញ ក្រឡ ថង់ស្បែក កញ្ជើល្អីជាដើម។ *អបរិច្ឆទាះ* 'បុរសដែលគ្មានឥវ៉ាន់' គេអាចប្រែថា 'បុរសដែលគ្មានទាសាទាសី'។ លោកកុល្ល. និងរាឃ. និយាយថា 'អ្នកក្រ'។

**៤០៧.** វិ. ជំពូក៥ លេខ១៣២។ យោងតាមលោកមេធ. ព្រះសង្ឃក្រៅសាសនា ត្រូវតែបង់ ព្រោះពាក្យព្រាហ្មណ៍ (ដែលប្រើជាមួយសិស្ស) សំដៅដល់មនុស្សទាំងអស់ដូចបានរៀបរាប់។

៤០៨- អ្វីក៏ដោយឱ្យតែអាចខូចខាតនៅក្នុងទូក ដោយសារកំហុសរបស់អ្នកទូក នោះគឺជាទំនិញដែលអ្នកទូកត្រូវរក្សាឱ្យបានល្អទាំងអស់ (ម្នាក់ៗបង់)តាមចំណែករបស់ខ្លួន។

៤០៩- ការវិនិច្ឆ័យរឿងក្តី(របស់)អ្នកដំណើរ (នៅល្អតែ)ក្នុងករណី អ្នកទូកមានកំហុសធ្វេសប្រហែសនៅលើទឹកហើយក្នុងករណី(មានឧបទ្ទវហេតុ)ដែលកើតឡើងដោយឆន្ទៈព្រះអាទិទេព ព្រះអង្គមិនអាចដាក់ពិន័យ(លើពួកគេ)ទេ។

៤១០- (ព្រះរាជា)គួរតែបង្គាប់ឱ្យវៃស្យៈ ធ្វើជំនួញ ឱ្យប្រាក់គេខ្ចី បង្កបង្កើនផលឬចិញ្ចឹមសត្វពាហនៈ ហើយពួកសូទ្រៈ បម្រើពួកវណ្ណៈដែលមានកំណើតពីរដង។

៤១១- ព្រាហ្មណ៍(សម្បូណ៌ទ្រព្យ)មួយចំនួន នឹងមានចិត្តមេត្តាទំនុកបម្រុងទាំងក្សត្រិយ ទាំងវៃស្យៈ ប្រសិនបើពួកគេជួបគ្រោះអាសន្នក្នុងការចិញ្ចឹមជីវិតដោយជួលពួកគេឱ្យធ្វើការ(ដែលសមស្រប) តាម(វណ្ណៈ)របស់ពួកគេ។

៤១២- ប៉ុន្តែព្រាហ្មណ៍ ដោយសារតែខ្លួនមានអំណាច ដោយសារសេចក្ដីលោភ ចេះតែប្រើ(មនុស្ស ដែលមានកំណើតពីរដង) ដោយផ្ទុយពីឆន្ទៈរបស់ពួកគេធ្វើការងាររបស់ទាសករ នឹងត្រូវព្រះរាជាពិន័យចំនួនប្រាំមួយរយ(បណៈ)។

៤១៣- ប៉ុន្តែសូទ្រៈ ទោះជាត្រូវទិញឬមិនទិញក្ដី គេអាចបង្ខំឱ្យធ្វើការងារទាសករ ព្រោះសូទ្រៈត្រូវព្រះស្វយម្ភូ បង្កើតឡើងឱ្យធ្វើជាទាសកររបស់ព្រាហ្មណ៍។

៤១៤- សូទ្រៈ ទោះជាត្រូវម្ចាស់ខ្លួនឱ្យក្លាយជាអ្នកជាក៏ដោយ ក៏មិនត្រូវដោះលែងឱ្យរួចពីទាសភាពដែរ ព្រោះទាសភាពជាប់នឹងខ្លួនគាត់ពីកំណើត តើនរណាអាចដោះលែងឱ្យគាត់មានសេរីភាព?។

៤១៥- ទាសករ មានប្រាំពីរប្រភេទ (ពោលគឺ)អ្នកដែលជាឈ្លើយសឹកតាមការសន្មត អ្នកដែលបម្រើគេដើម្បីបានអាហារប្រចាំថ្ងៃ អ្នកដែលមានកំណើតនៅក្នុងផ្ទះនោះ អ្នកដែលគេទិញនិងអ្នកដែលគេឱ្យ អ្នកដែលទទួលមរតកពីដូនតា និងអ្នកដែលក្លាយជាទាសករដោយការជាប់ទោស។

---

**៤០៨.** 'អ្វីក៏ដោយ' គឺ 'ទំនិញ'(មេធ., នារ.) ឬ 'ឥវ៉ាន់'(គោវ., កុល្លូ., រាឃ.)។

**៤១១.** ពោលគឺ គាត់នឹងជួលក្សត្រិយក្រីក្រ ធ្វើជាអ្នកយាម ជួយវៃស្យៈ ធ្វើជាអ្នកមើលថែសត្វ(មេធ.)។ ប្រសិនបើគាត់ជួលពួកគេរបៀបនេះ គាត់មិនមានទោសទេ(គោវ., កុល្លូ.)។

**៤១៣.** 'ទោះជាបានទិញ ឬមិនបានទិញក្ដី' គឺ 'ទោះជារក្សាទុកដោយហេតុនៃការបម្រើ ឬអត់ក្ដី'(គោវ., កុល្លូ., រាឃ.) ឬ 'ទោះជាទិញ ឬជួលក៏ដោយ'(នារ.)។

**៤១៤.** មេធ. និយាយថា អនុប្រយោគចុងក្រោយ គឺ 'អាថ៌វាទ ព្រោះបន្តទៅទៀតនឹងមានបង្ហាញថា គេអាចលោះទាសករឱ្យក្លាយជាអ្នកជាបាន'។ លោកកុល្លូ. គិតថា សូទ្រៈដែលបានក្លាយជាអ្នកជា ត្រូវតែនៅបម្រើព្រាហ្មណ៍ ឬអារ្យ័នផ្សេងទៀតដដែល ដើម្បីបានបុណ្យកុសលផ្នែកព្រលឹងវិញ្ញាណ។

**៤១៥.** មេធ. បដិសេធសញ្ញាណដែលថា គេអាយកក្សត្រិយដែលជាឈ្លើយសឹក ធ្វើជាទាសករបាន ហើយគិតថា សូទ្រៈដែលត្រូវចាប់ខ្លួន ត្រូវតែក្នុងន័យនេះ ប៉ុន្តែសូមមើលយញ្ញ. ជំពូក២ លេខ១៨៣ ដែលមាននិយាយថា ក្សត្រិយអាចក្លាយជាទាសកររបស់ព្រាហ្មណ៍ និងវៃស្យៈរបស់ព្រាហ្មណ៍ និងក្សត្រិយ។ លោកនារ. បកស្រាយ *ធ្វជាហ្ឫតៈ* 'អ្នកដែលជាឈ្លើយតាមការសន្មត' ដោយថា 'អ្នកដែលបានក្លាយជាទាសករ ដោយការរៀបការជាមួយស្ត្រីទាសករ'។ 'ត្រូវក្លាយជាទាសករដោយសារការដាក់ទោស' គឺ 'ព្រោះគាត់មិនអាចសងបំណុល ឬពិន័យបាន'(មេធ., គោវ., កុល្លូ., រាឃ.) ឬ 'ក៏ព្រោះគាត់

៤១៦- ភរិយា កូនប្រុស និងទាសករ គេប្រកាសថា ទាំងបីនេះគ្មានកម្មសិទ្ធិទេ ហើយទ្រព្យដែលពួកគេរកបាន (គឺសម្រាប់)អ្នកដែលជាម្ចាស់របស់ពួកគេ។

៤១៧- ព្រាហ្មណ៍ អាចរឹបយកទំនិញរបស់ (ទាសករ) សូទ្ររបស់ខ្លួនបានដោយជំនឿចិត្ត ព្រោះថា (ទាសករ)នោះមិនអាចមានកម្មសិទ្ធិទេ ម្ចាស់របស់គេអាចកាន់កាប់ទ្រព្យនោះបាន។

៤១៨- (ព្រះរាជា) គួរតែប្រយ័ត្នក្នុងការបង្ខំវៃស្យៈ និងសូទ្រៈ ឱ្យធ្វើការឱ្យខ្លួន ព្រោះប្រសិនបើវណ្ណៈទាំងពីរនេះ ដើរចេញពីករណីយកិច្ចរបស់ខ្លួន ពួកគេនឹងធ្វើឱ្យពិភពលោកនេះ(ទាំងមូល) ធ្លាក់ក្នុងភាពច្របូកច្របល់។

៤១៩- ចូរឱ្យគេយកចិត្តទុកដាក់បំពេញការងាររបស់ខ្លួនប្រចាំថ្ងៃ សត្វដឹកទំនិញរបស់ខ្លួន និងរទេះ(សម្រាប់ប្រមូល)ផលរបស់ខ្លួន និងការចំណាយប្រាក់ ព្រលឹងដូនតារបស់ខ្លួន និងការសន្សំទ្រព្យរបស់ខ្លួន។

៤២០- ដូចនេះ ព្រះរាជាដែលត្រូវធ្វើសេចក្ដីសន្និដ្ឋានរឿងក្ដីផ្លូវច្បាប់ ដូចបានរៀបរាប់ខាងលើ និងលុបបំបាត់អំពើបាបទាំងអស់ នឹងបានទទួល(ពរ)ឡើងកាន់ឋានដ៏ខ្ពស់បំផុត។

---

ចាកចេញពីវិន័យសាសនា'(សូមមើល វិ. ជំពូក៥ លេខ១៥២)(នារ., នន្ទ.)។

**៤១៦.** តាមលោកមេធ., គោវ., កុល្ល., រាឃ. កាព្យនេះមានន័យត្រឹមតែថា មនុស្សទាំងអស់នេះមិនអាចចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនបានដោយឯករាជ្យទេ។ កំណត់សម្គាល់សង្ខេបរបស់នារ. (*អធិគច្ឆំតិ បរកមករណោទិនា*) ទំនងជាបង្ហាញថា គាត់ប្រែឃ្លានេះ សំដៅដល់កង្វះសមត្ថភាពរបស់ពួកគេ ក្នុងការរកលុយ ដោយការធ្វើការឱ្យអ្នកដទៃបាន។

**៤១៧.** 'ដោយទំនុកចិត្ត' តាមលោកមេធ., នារ. និងនន្ទ. ថា 'ដោយមិនបារម្ភថា គាត់ប្រព្រឹត្តអំពើបាបក្នុងការទទួលអំណោយពីសូទ្រៈទេ'។

**៤១៩.** *កម្មាន្ត* 'ការបំពេញការងាររបស់ខ្លួន'(កុល្ល., រាឃ.) តាមលោកមេធ., គោវ. និងនន្ទ. ថា 'ការងារ' គឺ 'កសិកម្មមុខនាទីប្រមូលចំណូលពន្ធ និងអាករជាដើម'(មេធ., គោវ.) ហើយតាមនារ. ថា 'ការងាររោងជាង ឧ.ទា.ធ្វើអាវុធជាដើម'។ ការបកស្រាយចុងក្រោយ ទំនងប្រសើរជាងគេ។

# ជំពូក ៩

១- ពេលនេះ ខ្ញុំនឹងថ្លែងអំពីច្បាប់អមតៈ សម្រាប់ស្វាមី និងភរិយា ដែលប្រកាន់ខ្ជាប់នូវគន្លងករណីយកិច្ច ទោះបីជាពួកគេរស់នៅជាមួយ ឬនៅបែកគ្នាក៏ដោយ។

២- ថ្ងៃ និងយប់ ស្ត្រីត្រូវតែរស់អាស្រ័យលើបុរស(ក្នុងគ្រួសារ)របស់ខ្លួន ហើយបើពួកគេមានតម្រេកផ្លូវភេទ ពួកគេត្រូវប្រព្រឹត្ត ស្របតាមការគ្រប់គ្រងរបស់ខ្លួន។

៣- ឪពុកនាងការពារ(នាង) កាលពីកុមារភាព ប្ដីនាងការពារ(នាង)ក្នុងពេលយុវភាព ហើយកូនប្រុសនាងការពារ(នាង)ពេលចាស់; ស្ត្រីមិនដែលមានពេលបានឯករាជ្យភាពទេ។

៤- អ្នកទទួលខុសត្រូវ គឺឪពុកដែលមិនឱ្យ(កូនស្រីខ្លួនរៀបការ)តាមកាលដ៏គួរ ហើយអ្នកទទួលខុសត្រូវគឺប្ដី ដែលមិនទៅរក(ប្រពន្ធខ្លួនតាមកាលដ៏ត្រឹមត្រូវ) និងអ្នកទទួលខុសត្រូវគឺកូនប្រុសដែលមិនការពារម្ដាយខ្លួន បន្ទាប់ពីប្ដីរបស់គាត់បានទទួលមរណភាព។

៥- ស្ត្រីជាពិសេសត្រូវមានការការពារទល់នឹងទំនោរអាក្រក់ ទោះជាមិនសូវសំខាន់ក៏ដោយ (ក៏ការប្រព្រឹត្តអាក្រក់ហាក់ដូចជាមាន) ព្រោះប្រសិនបើស្ត្រីមិនមានការការពារ ពួកស្ត្រីនឹងនាំទុក្ខព្រួយដល់គ្រួសារពីរ។

៦- ដោយពិចារណាថា ករណីយកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់វណ្ណៈទាំងអស់ សូម្បីស្វាមីទន់ខ្សោយ(ក៏ត្រូវ)ខិតខំការពារភរិយាខ្លួនដែរ។

៧- អ្នកដែលយកចិត្តទុកដាក់ការពារភរិយាខ្លួន ការពារ(ភាពបរិសុទ្ធរបស់)កូនខ្លួន ការពារអំពើល្អគ្រួសារខ្លួន ខ្លួនឯង និង(មធ្យោបាយទទួល)កុសលរបស់ខ្លួន។

---

ជំពូក ៩. លេខ១. យោងតាមលោកមេធ., គោវ. និងកុល្លូ. ករណីយកិច្ចរបស់ស្វាមី និងភរិយា មាននិយាយនៅក្នុងផ្នែកស្ដីពីច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ ព្រោះព្រះរាជាអាច ហើយសូម្បីត្រូវប្រតិបត្តិតាមការដាក់ទោស ប្រសិនបើនរណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ធ្វើបណ្ដឹង។ 'រស់នៅបែកគ្នា' គឺ 'ពេលប្ដីមិននៅ ឬស្លាប់'(នារ., រាឃ.)។
**២-៣.** គោត. ជំពូក១៨ លេខ១; វស. ជំពូក៥ លេខ១-២; ពោធ. ជំពូក២ លេខ៣, ៤៤-៤៥; វិ. ជំពូក៥ លេខ១-២; យញ្ញ. ជំពូក១ លេខ៨៥។
**២.** 'ត្រូវតែស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន' គឺ 'ពួកគេត្រូវកាត់បន្ថយការជាប់ជំពាក់ដ៏គ្រោះថ្នាក់របស់ខ្លួន'(អាត្មនោ វសេ ស្ថាប្យា យថា ន សត្យន្តេ) (នារ.)។
**៤.** យញ្ញ. ជំពូក១ លេខ៦៤។ 'តាមកាលដ៏គួរ'គឺនៅមុនពេលនាងដល់វ័យរៀបការ។ សូមមើលគោត. ជំពូក១៨ លេខ២១; វស. ជំពូក១៧ លេខ៦៧-៧១។ 'ប្ដី' សូមមើលពោធ. ជំពូក៤ លេខ១, ១៧-១៩ និងជំពូក៣ លេខ៤៥ ខាងលើ។ បន្ទាប់ពីកាព្យនេះ លោក K. បញ្ចូលកាព្យមួយទៀត ដែលអ្នកអធិប្បាយនានាមិនបាននិយាយ គឺ 'បើភរិយាត្រូវបានការពារ ដូច្នេះ(ភាពបរិសុទ្ធ)របស់កូន ត្រូវបានធានា ហើយបើ(ភាពបរិសុទ្ធិ)របស់កូន ត្រូវបានធានា ខ្លួនឯងក៏ផុតភ័យ។'
**៦.** យញ្ញ. ជំពូក១ លេខ៨១។ 'ប្ដីទន់ខ្សោយ' គឺ 'មនុស្សខ្វាក់ ពិការ ឬក្រីក្រជាដើម'(កុល្លូ., រាឃ.)។
**៧.** 'គ្រួសាររបស់ខ្លួន' គឺ 'ដូនតារបស់ខ្លួន' ព្រោះកូនប្រុសស្របច្បាប់ប៉ុណ្ណោះ ទើបអាចធ្វើពិធីស្រាទ្ធបាន(មេធ., គោវ., កុល្លូ.) ឬ 'សាច់ញាតិរបស់ខ្លួន' ព្រោះអំពើផិតក្បត់នាំមកនូវភាពអាម៉ាស់(មេធ., រាឃ.) ឬ 'ឋានៈរបស់គ្រួសារ'(នារ.) ឬ

៨- ប្ដី បន្ទាប់ពីភរិយាខ្លួនទទួលស្គាល់ ក្លាយជាទារក ហើយចាប់កំណើតជាថ្មីពីនាង ព្រោះថាភាពជាភរិយា គឺជាភរិយា(ជាយា) នោះប្ដីមានកំណើតម្ដងទៀតដោយភរិយា(ជាយតេ)។

៩- ដោយហេតុថាប្រុស ជាផ្នែកមួយរបស់ភរិយា ដូច្នេះកូនប្រុសកើតពីភរិយា ហេតុនេះចូរស្វាមីយកចិត្តទុកដាក់ការពារភរិយារបស់ខ្លួន ដើម្បីរក្សាភាពបរិសុទ្ធឱ្យកូនចៅខ្លួន។

១០- គ្មានប្រុសណាមួយអាចការពារស្ត្រីបានទាំងស្រុងដោយសារកម្លាំងនោះទេ ប៉ុន្តែស្ត្រីអាចទទួលបានការការពារ ដោយការប្រើឧបាយ(ដូចខាងក្រោម):

១១- ចូរ(ស្វាមី)ប្រើ(ភរិយា)របស់ខ្លួន ឱ្យរក្សាទុកដាក់និងចាយវាយទ្រព្យរបស់ខ្លួន ក្នុងការរៀបចំ(អ្វីៗ)ឱ្យស្អាតបាត ក្នុងការបំពេញករណីយកិច្ចសាសនា ក្នុងការរៀបចំអាហារឱ្យខ្លួន និងក្នុងការថែទាំផ្ទះសម្បែង។

១២- ស្ត្រី ដែលនៅក្នុងផ្ទះជាអ្នកបម្រើដ៏ស្លូត និងគួរឱ្យទុកចិត្ត មិនត្រូវបានការពារ(ដោយល្អ) ប៉ុន្តែអ្នកដែលស្មគ្រចិត្តការពារខ្លួនដោយខ្លួនឯង គឺទទួលបានការការពារដ៏ល្អ។

១៣- ការសេព(គ្រឿងស្រវឹង) ដោយសេពគប់ជាមួយមនុស្សអាក្រក់ ការនៅបែកពីស្វាមី ការដើរកំសាន្តទៅក្រៅប្រទេស ការដេក(ខុសកាល) និងស្នាក់នៅក្នុងផ្ទះប្រុសផ្សេង ជាបុព្វហេតុចំនួនប្រាំមួយនៃសេចក្ដីវិនាសសម្រាប់ស្ត្រី។

១៤- ស្ត្រីមិនយកចិត្តទុកដាក់បញ្ហាសម្ផស្ស មិនគិតគូរកែកុនវ័យរបស់ខ្លួន (ដោយគិតថា) '(គ្រប់គ្រាន់ហើយដែលថា) គាត់ជាបុរស' ស្ត្រីជាអ្នកផ្ដល់ភាពសង្ហា និងភាពអាក្រក់។

១៥- ដោយសារតណ្ហារបស់ស្ត្រីសម្រាប់បុរស ដោយសារអារម្មណ៍ប្រែប្រួលរបស់ស្ត្រី ដោយសារភាពគ្មានមេត្តាពីកំណើតរបស់ស្ត្រី ស្ត្រីគ្មានស្វាមីភក្តិចំពោះស្វាមីខ្លួនទេ ទោះជាមានការយកចិត្តទុកដាក់យ៉ាងណាក្តី ស្ត្រីអាចត្រូវបានការពារនៅក្នុង(លោកិយ)នេះ។

១៦- ដោយដឹងពីអារម្មណ៍របស់ពួកគេ ដែលព្រះជាម្ចាស់បានផ្តល់ឱ្យពួកគេពីកំណើត ដូច្នេះបុរស(គ្រប់រូប)ត្រូវតែខិតខំការពារស្ត្រីយ៉ាងខ្លាំងក្លាបំផុត។

១៧- (នៅពេលបង្កើតស្ត្រី) មនុ បានផ្តល់ឱ្យស្ត្រី(នូវការស្រឡាញ់)គ្រែ(របស់ពួកគេ) កៅអីនិងគ្រឿងតុបតែងខ្លួន បំណងប្រាថ្នាមិនបរិសុទ្ធ កំហឹង ភាពមិនទៀងត្រង់ ចិត្តច្រណែន និងការប្រព្រឹត្តអាក្រក់។

'កម្មសិទ្ធិរបស់ខ្លួន'(រាឃ.)។ 'ខ្លួនឯង' គឺ 'ព្រោះកូនស្របច្បាប់ប៉ុណ្ណោះ ទើបអាចធ្វើពិធីស្រាទ្ធបាន'(គោវ., កុល្លូ., រាឃ.) ឬ 'ព្រោះស្ត្រីក្បត់ប្តី ហើយស្វាមីរបស់នាង ទំនងជាចង់យកជីវិតខ្លួន'(មេធ.)។ '(មធ្យោបាយទទួល)កុសលរបស់ខ្លួន' គឺ 'ព្រោះស្វាមីរបស់ស្ត្រីក្បត់ប្តី មិនមានសិទ្ធិបង្កាត់ភ្លើងពិសិដ្ឋ'(គោវ., កុល្លូ., រាឃ.)។ នារ. និយាយថា 'ករណីយកិច្ចរបស់គាត់ (ក្នុងនាមជាអ្នកគ្រប់គ្រងផ្ទះ)'។

៨. យញ្ញ. ជំពូក១ លេខ៥៦។ គំនិតនេះ ត្រូវបានស្រង់ចេញពីព្រះវេទ។ សូមមើល ឌ.ទា. អៃតរេយ ព្រាហ្មណ៍ ជំពូក៧ លេខ១៣ តាមការយោងរបស់លោកកុល្លូ.។

**១៣.** 'ដោយសេពគប់មនុស្សអាក្រក់' គឺរាប់អានកិរិយាមិនស្មោះត្រង់ផ្សេងទៀត'(នារ.) ឬរាប់អានស្ត្រីក្បត់ប្តី'(រាឃ.)។

១៨- សម្រាប់ស្ត្រី គ្មានពិធី(ពិសិដ្ឋ) ត្រូវបាន(គេធ្វើឡើង)ដោយពាក្យពិសិដ្ឋ ដូច្នេះច្បាប់ត្រូវបានកំណត់ ហើយស្ត្រី(ដែល)គ្មានកម្លាំង និងគ្មាន(ចំណេះដឹង)អត្ថបទវេទ (គឺមិនបរិសុទ្ធដូចជា) ភាពក្លែងក្លាយ នេះជាវិធានច្បាប់កំណត់។

១៩- ហើយដើម្បីផលយ៉ាងនេះ គេក៏ច្រៀងពាក្យពិសិដ្ឋជាច្រើនដែលមាននៅក្នុងព្រះវេទ ដើម្បីឱ្យគេបានដឹងទាំងស្រុងអំពីអារម្មណ៍ពិត (របស់ស្ត្រី) ហើយ(ឥឡូវនេះ) ចូរស្តាប់ពាក្យទាំងឡាយសំដៅដល់ការលាង(បាប)របស់ពួកគេ។

២០- 'បើសិនជាម្តាយខ្ញុំដែលវង្វេងផ្លូវ និងគ្មានសេចក្តីស្មោះត្រង់ មានចេតនាខុសសីលធម៌ សូមឱ្យឪពុករបស់ខ្ញុំយកគ្រាប់ពូជនោះចេញពីខ្ញុំទៅ' នេះជាពាក្យដែលមានក្នុងគម្ពីរ។

២១- បើសិនជាស្ត្រីគិតអ្វីម្យ៉ាងក្នុងចិត្តរបស់ខ្លួន ដែលធ្វើឱ្យប្តីរបស់ខ្លួនឈឺចាប់ (អត្ថបទខាងលើ)ត្រូវបានប្រកាស(ថាជាមធ្យោបាយសម្រាប់)លុបបំបាត់ដំណើរផិតក្បត់បែបនេះទាំងស្រុង។

២២- បុរសទោះជាមានលក្ខណៈសម្បត្តិបែបណាក៏ដោយ ត្រូវរួមរស់ជាមួយស្ត្រី ស្របតាមច្បាប់ លក្ខណៈសម្បត្តិបែបនេះសូម្បីមាននៅក្នុងខ្លួនស្ត្រីក្តីក៏បីដូចជាទន្លេ(ប្រសព្វ)ជាមួយមហាសមុទ្រ។

២៣- អក្សមាលា ស្ត្រីដែលមានកំណើតថ្នាក់ទាបបំផុត ដែលត្រូវរួមរស់ជាមួយ*វសិស្ឋ* និង *សារង្គី* ដែលត្រូវរួមរស់'ជាមួយ *មន្ទបាល* សមនឹងបានកិត្តិយស។

២៤- ស្ត្រីទាំងនេះ និងស្ត្រីដែលមានកំណើតទាបដទៃទៀត បានទទួលភាពខ្ពង់ខ្ពស់នៅក្នុងលោកនេះ ដោយសារគុណសម្បត្តិល្អរបស់ស្វាមីខ្លួន។

**១៨.** ពិធីបុណ្យក្នុងន័យនេះ គឺជាពិធីបុណ្យកំណើតជាដើម។ សូមមើលជំពូក២ លេខ២៦ខាងលើ។ 'គ្មានកម្លាំង'(គោវ.) គឺ 'នៃភាពរឹងមាំ បញ្ញា កម្លាំងកាយជាដើម'(មេធ., នន្ទ.)។ កាព្យពាក់កណ្ដាលទីពីរមានទំនាក់ទំនងជិតស្និទ្ធ នឹងកាព្យសម្រង់គម្ពីរ ពោធ. ជំពូក២ លេខ៣, ៤៦ ហើយកាព្យក្រោយនេះទំនងជាមានការកែសម្រួលសេចក្ដីវេទ។

**២០.** កាព្យនេះជាមន្ត្រ ដែលមានការកែបន្ថិចបន្តួចនៅក្នុង*សង្ខាយន គួហ្យ-សូត្រ* ជំពូក៣ លេខ១៣ និងក្នុងផ្នែកចាតុ រមាស្យ ដែលជាការពិនិត្យសំណៅដៃ*កឋាក* គម្ពីរខ្មៅ យជុរ-វេទ។ យោងតាមស្នាដៃដើម មានរៀបរាប់ពាក្យ អន្យត្រករណ 'កូនប្រុសប្ដីប្រពន្ធ'។ ប៉ុន្តែកាថៈ រៀបរាប់ពីការប្រើប្រាស់របស់ម្ចាស់ពិធីនានា ដែលធ្វើការបូជាយញ្ញចាតុរមាស្យ។ លោក មេធ., គោវ. និងកុល្លូ. ទំនងជានិយាយសំដៅដល់ទំនៀមទម្លាប់របស់សាលាក្រោយនេះ ពេលពួកគេនិយាយថា គ្រប់ម្ចាស់ បុណ្យត្រូវសូត្រមន្ត្រ ហើយថា គេត្រូវសូត្រដដែលពី*វិនិយោគ* ឬការឧទ្ទិសក្នុងពិធីចាតុរមាស្យ និងពិធីអន្វស្ដកា-ស្រាទ្ធ។ លោកគោវ., កុល្លូ., រាឃ., នារ. និងនន្ទ. បកស្រាយ *រេតះ* 'គ្រាប់ពូជ' ថា *មាត្រិរតោរូបំ ស្កន្ទំ* និង *វ្ទ្ធតំ* 'សូមឱ្យគាត់យកចេញឱ្យឆ្ងាយ' ដោយថា *ភគតាំ* (ស្ទើករពោត តាមលោកនារ., នន្ទ.) 'សូមឱ្យគាត់ទទួលយកខ្លួនឯងចុះក៏បាន ឬដោយថា *សោធយតុ* 'សូមឲ្យគាត់បរិសុទ្ធ'(គោវ., កុល្លូ., រាឃ.)។ ចំណែកឯលោកមេធ. ដឹងរឿងការបកស្រាយចុងក្រោយនេះ។ ប៉ុន្តែលោកក៏ផ្ដល់ការបកស្រាយមួយទៀត *រេតះ បិតុះ សំពន្ធិ យទ រេតះ សុក្រម* និង *វ្ទ្ធតាំ អបនុទតុ* ដែលត្រូវន័យច្រើន សម្រាប់កាព្យខាងលើ។ *និទរសនំ* 'អត្ថបទដែលមានក្នុងគម្ពីរ' តាមលោកមេធ. ថា *ទ្ធស្ដាន្តះ* ឧទាហរណ៍' ហើយអ្នកអធិប្បាយផ្សេងទៀតបកស្រាយកាព្យនេះប្រហាក់ប្រហែលគ្នា។

**២២.** ពោលគឺ ឧបមាដូចជាទន្លេ នឹងប្រែ ក្រោយពីកពប្រសពជាមួយសមុទ្រ។ ចូរចាំក្នុងចិត្តថា យោងតាមករីផណ្ណា ទន្លេគឺដូចជាភរិយានៃមហាសមុទ្រ។

**២៣.** *អក្សមាលា* ឬ *អរុន្ធាតិ* គឺជាចណ្ឌាលី(គោវ., រាឃ.) ហើយធ្វើជាភរិយារបស់បណ្ឌិតវសិស្ឋ តាមការបញ្ជាក់របស់ស្រុតិ (រាឃ.) ដោយមានការអនុញ្ញាតពីឫសី។ សាច់រឿងមន្ទបាល មាននិទាននៅក្នុងមហាភារត ជំពូក១ លេខ៨៣៣៥ (អធ្យ.

២៥- ដូច្នេះសេចក្ដីប្រកាសគឺជាទម្លាប់តាមការនិយមទូទៅសុទ្ធសាធ (ដែលកំណត់អំពីទំនាក់ទំនង) រវាងស្វាមី និងភរិយា (តទៅនេះ)ចូរស្ដាប់ច្បាប់ស្ដីពីកូន ដែលជាបុព្វហេតុនៃសុភមង្គលនៅក្នុងលោកនេះ និងលោកខាងមុខ។

២៦- រវាងភរិយា (ស្ត្រិយះ) ដែល(វាសនាកំណត់)ត្រូវមានកូន ដែលនាំមកនូវពរជ័យជាច្រើន ដែលសមនឹងគោរពបូជា និងបញ្ចេញរស្មី(ក្នុង)លំនៅឋានរបស់ខ្លួន និងរវាងទេពធីតាក័ព្វសំណាង (ស្រិយះ) ដែលស្ថិតនៅក្នុងផ្ទះរបស់(បុរស) គ្មានភាពខុសគ្នាអ្វីទេ។

២៧- ការបង្កើតកូន ការចិញ្ចឹមកូនទាំងនោះ និងជីវិតប្រចាំថ្ងៃរបស់បុរស (ក្នុងចំណោមបញ្ហាទាំងអស់នេះ) ស្ត្រីជាបុព្វហេតុជាក់ស្ដែង។

២៨- កូនចៅ(ការប្រតិបត្តិ)ពិធីសាសនាត្រឹមត្រូវ ការបម្រើដ៏ស្មោះត្រង់ សេចក្ដីរីករាយជាប្ដីប្រពន្ធដ៏ខ្ពង់ខ្ពស់បំផុត និងពរជ័យពីឋានសួគ៌សម្រាប់ដូនតានិងខ្លួនឯង ស្ថិតនៅលើភរិយារបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ។

២៩- ស្ត្រី ដែលចេះគ្រប់គ្រងគំនិត ពាក្យសម្ដីនិងអំពើរបស់ខ្លួន មិនបំពានករណីយកិច្ចរបស់ខ្លួនចំពោះម្ចាស់ខ្លួន នៅជាមួយប្ដី(បន្ទាប់ពីស្លាប់)នៅឋានសួគ៌ ហើយនៅក្នុងលោកនេះ ត្រូវមនុស្សល្អហៅថា(ភរិយា *ស្វាធី*)ដ៏ស្មោះត្រង់។

៣០- ប៉ុន្តែចំពោះភាពមិនស្មោះត្រង់ចំពោះស្វាមីខ្លួន ភរិយាត្រូវតិទៀនក្នុងចំណោមបុរស ហើយ(នៅជាតិក្រោយ)នាងនឹងកើតក្នុងផ្ទៃពោះឆ្កែព្រៃ និងហែកហួរដោយជំងឺ ការទទួលទណ្ឌកម្មពីអំពើបាបរបស់ខ្លួន។

៣១- (ឥឡូវ)ចូរស្តាប់ការពិភាក្សាដ៏ពិសិដ្ឋដូចខាងក្រោមសម្រាប់បុរសទាំងអស់ ដែលមនុស្សល្អ (នាពេលបច្ចុប្បន្ន) និងមហាបណ្ឌិតពីបុរាណ បាននិយាយអំពីកូនប្រុស។

៣២- ពួកគាត់(ទាំងអស់)និយាយថា រឿងបុរស(របស់ស្ត្រី)ស្ថិតនៅលើម្ចាស់ ប៉ុន្តែតាម(ន័យរបស់ពាក្យ) ម្ចាស់ អត្ថបទដែលបានបង្ហាញមានភាពខុសគ្នា ហើយអត្ថបទខ្លះហៅថាអ្នកឱ្យកំណើត (កូន) ខ្លះប្រកាស(ថាម្ចាស់គឺជា)ម្ចាស់ដី។

៣៣- តាមប្រពៃណីពិសិដ្ឋ ស្ត្រីត្រូវគេប្រកាសថាជាដី បុរសត្រូវគេប្រកាសថាជាពូជ ហើយការបង្កើតសត្វលោកទាំងអស់(កើតឡើង)ដោយសារការផ្សំផ្គុំដីនឹងពូជ។

---

២២៩)។ លោកមេធ., គោវ. និង K. អាន*សាគ្គី*ជំនួសពាក្យ*សារគ្គី*។

**២៧.** ជំនួសពាក្យ *ប្រត្យហំ* 'ជីវិតរបស់បុរស)ប្រចាំថ្ងៃ' មេធ. និងនារ. អាន *ប្រត្យវចំ* '(ជីវិតរបស់បុរស)គ្រប់បែបយ៉ាង' ហើយលោកគោវ. ថា *ប្រីត្យវចំ* 'ការរួមសង្វាសមេត្រីរបស់បុរស' ព្រោះអ្នកដែលគ្មានប្រពន្ធ មិនអាចសប្បាយជាមួយអ្នកដទៃទេ(គោវ., កុល្លូ., រាឃ.)។ លោកមេធ. ក៏សរសេរម្យ៉ាងទៀតថា *ប្រត្យវជំ*។

**២៩.** ដូចគ្នាជំពូក៥ លេខ១៦៥។

**៣០.** វស. ជំពូក២១ លេខ១៤។ សូមមើលជំពូក៥ លេខ១៦៤ខាងលើផង។

**៣២.** អាប. ជំពូក២ លេខ១៣, ៦-៧; គោត. ជំពូក១៨ លេខ៩-១៤; វស. ជំពូក១៧ លេខ៦-៩, ៦៣-៦៤។ លោកគោវ., កុល្លូ., រាឃ. និងនន្ទ. បកស្រាយដូច្នេះ។ ប៉ុន្តែលោកមេធ., នារ. និង K. (ប្រិម មនុ) អាច*ភរតរី*ជំនួសពាក្យ *ភរតរី* ហើយតាមអំណាននេះ គេអាចប្រែកាព្យនេះថាៈ 'ពួកគេ(ទាំងអស់)ប្រកាសថា កូនប្រុស(ដែលកើតដោយស្របច្បាប់) ជារបស់

៣៤- ក្នុងករណីខ្លះ ពូជមានលក្ខណៈខុសគ្នា ហើយក្នុងករណីខ្លះសំដៅដល់គភ៌របស់ស្ត្រី ប៉ុន្តែពេលទាំងពីរនេះស្មើគ្នា កូននឹងបានទទួលការរាប់អានខ្ពស់បំផុត។

៣៥- បើប្រៀបធៀបពូជនិងប្រដាប់ទទួល(ពូជ) ពូជត្រូវគេប្រកាសថាមានសារៈសំខាន់ជាង ព្រោះកូនចៅរបស់សត្វលោកទាំងអស់ ត្រូវកំណត់តាមលក្ខណៈពូជ។

៣៦- ពូជប្រភេទណាក៏ដោយដែលសាបព្រោះក្នុងស្រែ ត្រៀមតាមរដូវកាលសមគួរ (រុក្ខជាតិ) ប្រភេទដូចគ្នា ដែលមានលក្ខណៈពូជពិសេស បង្កើតបានរុក្ខជាតិម្យ៉ាងប្រភេទនោះ។

៣៧- តាមពិត គេហៅផែនដីនេះថាជាមាតាដើមរបស់សត្វលោកទាំងអស់ ប៉ុន្តែពូជវិវត្ត មិនចម្រើនឡើងក្នុងកម្មសិទ្ធិរបស់មាតាទេ។

៣៨- នៅក្នុងលោកនេះ ពូជប្រភេទផ្សេងៗ ដែលសាបព្រោះលើដីស្របតាមកាល សូម្បីក្នុងស្រែតែមួយ កើតឡើងទៅតាមប្រភេទ(នីមួយៗ)របស់ខ្លួន។

៣៩- ស្រូវ(ហៅថា)*វ្រីហិ* និង(ស្រូវ)សាលិ សណ្តែកទ្រើង ល្ង សណ្តែករាជមាស ស្រូវបាឡេ គុយឆាយដើមធំ និងអំពៅ (ទាំងអស់)កើតឡើង ដោយសារពូជរបស់វា។

៤០- ពោលគឺ (រុក្ខជាតិ)មួយត្រូវបានបណ្តុះ និងរុក្ខជាតិមួយទៀតត្រូវគេបង្កើត គឺមិនអាចកើតឡើងទេ។ សាបព្រោះពូជបែបណា នឹងបានរុក្ខជាតិបែបនោះ។

៤១- ហេតុនេះមិនដែលមានបុរស ដែលមានការបណ្តុះបណ្តាលល្អដោយប្រយ័ត្នប្រយែង ដែលចេះព្រះវេទ និងអង្គវេទ និងចង់បានអាយុវែង រួមសង្វាសជាមួយភរិយាអ្នកដទៃទេ។

៤២- ចំពោះ(បញ្ហា) នេះ អ្នកដែលចេះសូត្រកំណាព្យពីមុនមួយចំនួន ដែលច្រៀងដោយវាយុ (ព្រះពាយ ដើម្បីបង្ហាញ)ថា បុរសម្នាក់មិនអាចសាបព្រោះពូជលើបុរសម្នាក់ទៀតបានទេ។

៤៣- ដោយហេតុថា ព្រួញដែល(អ្នកប្រមាញ់)បានបាញ់ចេញ បន្ទាប់មកត្រូវ(ក្តាន់)របួស ត្រង់កន្លែងរបួស(ដែលអ្នកប្រមាញ់ម្នាក់ទៀត បានបង្កើតឡើង) ត្រូវបាញ់ចេញដោយឥតប្រយោជន៍ ដូច្នេះពូជដែលសាបព្រោះលើពូជមួយទៀត ត្រូវបាត់ភ្លាម(សម្រាប់អ្នកសាប)។

---

ប្តី ប៉ុន្តែសម្រាប់អ្នកបង្កើត(កូន គឺភរិយារបស់មនុស្សម្នាក់ទៀត) នាំឱ្យមានវិវាទរវាងអត្ថបទដែលបានបង្ហាញ ហើយអ្នកខ្លះប្រកាសថា អ្នកបង្កើត (គឺជាម្ចាស់របស់កូន) អ្នកខ្លះទៀតថា (គាត់គឺជា)ម្ចាស់ដី។

**៣៤.** អ្នកអធិប្បាយគូសបញ្ជាក់ករណី*វ្យាស* និង *ឫស្យស្រិង្គ* ជាតួយ៉ាងបញ្ជាក់ការពិតនៃសំណើទីមួយ និងពី*ធូតរាស្ត្រ* និងក្សេត្រជៈដទៃទៀត ជាឧទាហរណ៍ពីរ។ 'ស្មើគ្នា' គឺ 'ជាម្ចាស់ដូចគ្នា និងក្នុងថ្នាក់ជាមួយគ្នា'(មេធ.)។

**៣៧.** 'វិត្ត មិនមែនជាកម្មសិទ្ធិរបស់គត់ទេ' គឺ 'បង្ហាញថាមិនមែនជាកម្មសិទ្ធិ ដូចជាដី'(មេធ., គោវ., កុល្ល.)។

**៣៩.** *វ្រីហិ*មានស្រូវ ដែលទុំក្នុងរយៈពេលហុកសិបថ្ងៃ(សស្តកា); សាលិ គឺ 'ស្រូវក្រហម ដែលទុំនៅរដូវរងារ'(គោវ., នារ.)។ មុទ្គ គឺ Phaseolus Mungo(mûg=សណ្តែកទ្រើង); មាសៈ គឺ សណ្តែករាជមាស(Phaseolus Radiatus)។

**៤១.** *វិញ្ញាណ*ចំណេះដឹងអំពីអង្គ'(កុល្ល.) តាមលោកមេធ. និងនារ. គឺ 'ចំណេះដឹងក្រៅសាសនា' ហើយតាមលោករាឃ. ថា 'ប្រពៃណី'។ លោកនន្ទ. ត្រឡប់លំដាប់លំដោយ ហើយនិយាយថា 'ការចេះដឹងក្រៅសាសនា និងដ៏ពិសិដ្ឋ'។

**៤៣.** ឬ តាមការបកស្រាយទីពីររបស់លោកមេធ. គឺ 'ដូចព្រួញរបស់អ្នកប្រមាញ់ ដែលរត់ទៅត្រូវក្តាន់ដែលមានរបួស ត្រូវបាញ់ ត្រូវខ្យល់ ហើយជាការឥតប្រយោជន៍'។

៤៤- (បណ្ឌិត) ដែលចេះហៅផែនដីនេះតាមបែបបុរាណ(ឬថិវី) ព្រមទាំងភរិយារបស់*ប្ធុ* ផង ពួកគេប្រកាសថាស្រែជារបស់អ្នកដែលបានកាប់ឆ្ការព្រៃឈើ និងជាសត្វក្តាន់របស់អ្នកដែលបាញ់ឱ្យរបួស(ទីមួយ)។

៤៥- គាត់គឺជាមនុស្សល្អឥតខ្ចោះតែម្នាក់គត់ ដែលមាន(មនុស្សបីនាក់នៅរួមរស់ជាមួយ) គឺភរិយារបស់ខ្លួន ខ្លួនឯងនិងកូនរបស់ខ្លួន ដូច(ព្រះវេទនិយាយថា) ហើយព្រាហ្មណ៍អ្នកចេះដឹង ថ្លែងរៀបរាប់(ភាសិត)នេះដូច្នេះថា 'គេនិយាយថា ប្តីត្រូវនៅជាមួយប្រពន្ធ'។

៤៦- ប្រពន្ធមិនអាចរួចផុតពីប្តី ដោយសារការទិញ និងការលែងលះទេ នេះជាច្បាប់ដែលយើងបានដឹងថា ព្រះជាម្ចាស់(ប្រជាបតិ)បានបង្កើតឡើងតាំងពីបុរាណ។

៤៧- ពេលមានការបែងចែក (មរតក) (ពេលគេអនុញ្ញាត)ឱ្យស្រីក្រមុំរៀបការ(និង)ពេល(បុរស) និយាយថា 'ខ្ញុំយល់ព្រម' ហើយគេធ្វើអំពើនីមួយៗក្នុងចំណោមអំពើទាំងបីម្តងប៉ុណ្ណោះ។

៤៨- ដូចជាមេគោ លាញី អូដ្ឋញី ក្មេងស្រីទាសករ ក្របីញី ពពែញី និងចៀមញី មិនមែនជាអ្នកបង្កើត(ឬម្ចាស់របស់វា)ដែលបានកូនទេ ដូច្នេះ(វាជា)ប្រពន្ធរបស់អ្នកដទៃ។

៤៩- អ្នកដែលគ្មានកម្មសិទ្ធិដីស្រែ ប៉ុន្តែមានគ្រាប់ពូជពោតសាបព្រោះនៅលើដីរបស់អ្នកដទៃ តាមពិត មិនបានទទួលផលធញ្ញជាតិ ដែលដុះលូតលាស់នោះទេ។

៥០- បើសិនជាគោឈ្មោល(របស់បុរសម្នាក់)ត្រូវផ្តល់កំណើតដល់កូនគោមួយរយជាមួយមេគោរបស់អ្នកដទៃ ពួកវាជាកម្មសិទ្ធិរបស់ម្ចាស់មេគោ ដូចនេះគោឈ្មោលនឹងចំណាយកម្លាំងឥតប្រយោជន៍។

៥១- ដូច្នេះបុរសដែលគ្មានកម្មសិទ្ធិអាពាហ៍ពិពាហ៍ជាមួយស្ត្រី ប៉ុន្តែសាបព្រោះពូជរបស់ខ្លួននៅលើដីរបស់អ្នកដទៃ ផ្តល់ប្រយោជន៍ឱ្យម្ចាស់របស់ស្ត្រីនោះ តែ អ្នកផ្តល់ពូជមិនបានផលអ្វីទាំងអស់។

---

**៤៤.** ៉ប្តីត្បិតផែនដី បន្ទាប់ពីព្រះរាជាជាច្រើនបានគ្រប់គ្រងព្រះនាងដែលជាកម្មសិទ្ធិរបស់*ប្ឫថុ* តែគេហៅព្រះនាង*ប្ឫថិវី* ឬ *ប្រឫថ្វី*បន្ទាប់ពីម្ចាស់ទីមួយរបស់នាង គឺ*ប្ឫថុ*(មេធ., នារ.)។

**៤៥.** តាមការបញ្ជាក់ភាសិតទីមួយ អ្នកអធិប្បាយលើកហេតុផលត្រង់សេចក្តីមួយនៃគម្ពីរវាគសនេយិ ព្រាហ្មណ៍ ហើយសូមមើលអាប. ជំពូក១ លេខ១៤, ១៦ ផង។

**៤៦.** អត្ថន័យគឺថា ភរិយាដែលត្រូវប្តីលក់ ឬបោះបង់ចោល មិនអាចក្លាយជាភរិយាស្របច្បាប់របស់បុរសម្នាក់ទៀត ដែលអាចដាវ ឬទទួលនាង បន្ទាប់ពីនាងត្រូវគេបោះបង់ចោល(មេធ.)។

**៤៧.** យញ្ញ. ជំពូក១ លេខ៦៥។ ៉ការបែងចែក(មរតក)៎ គឺ ៉អ្នកដែលបានធ្វើតាមច្បាប់ មិនមែនធ្វើដោយមិនត្រឹមត្រូវទេ៎ (គោវ., កុល្ល., រាឃ.)។ លោកមេធ. ធ្វើការបកស្រាយពីរបែបទៀត ១-៉បើសិនជាម្ចាស់ទ្រព្យរួមម្នាក់ក្នុងចំណោមម្ចាស់ទ្រព្យទាំងអស់ប្តឹង បន្ទាប់ពីខ្លួនបានទទួលទ្រព្យតិចពេក គាត់មានសិទ្ធិទទួលផ្នែកណាមួយ តាមការកែសម្រួលមិនមែនបដិសេធចោលការបែងចែកទាំងស្រុងទេ៎ ២-៉បើសិនជា បន្ទាប់ពីការបែងចែក ហាក់ដូចជាភាគីនៃម្ចាស់ទ្រព្យរួម គ្មានសមត្ថភាព ដោយសារវិការខាងផ្លូវកាយ ហើយមិនគួរទទួលបានចំណែកមួយ ដែលអ្នកផ្សេងមិនបានទទួល៎។ លោកនារ. សំដៅឃ្លានេះថា ៉ខ្ញុំនឹងផ្តល់៎ការសន្យាផ្ទាល់មាត់ ឱ្យក្មេងស្រីម្នាក់ ដោយមិនចាំបាច់មានពិធីច្រូចទឹកទេ។ ខ្ញុំអានតាមលោកមេធ., គោវ., រាឃ., នន្ទ. និង K. ថា *សកាំ សក្ឫត* ៉(អំពើ)ទាំងបីនោះត្រូវប្រព្រឹត្តម្តង ក្នុងចំណោមមនុស្សល្អ៎។ កម្មវត្ថុនៃកាព្យនេះ សំដៅបង្ហាញថា អាពាហ៍ពិពាហ៍មិនអាចរំលោយបាន ព្រោះក្មេងស្រីអាចរៀបការបានតែម្តងគត់(កុល្ល., នន្ទ.)។

**៥០.** វស. ជំពូក១៧ លេខ៨។

៥២- បើសិនជាគ្មានការព្រមព្រៀងអំពីផល រវាងម្ចាស់ស្រែនិងម្ចាស់ពូជទេ នោះផលប្រាកដជារបស់ម្ចាស់ស្រែ ពោលគឺកន្លែងទទួលពូជ មានសារៈសំខាន់ជាពូជ។

៥៣- ប៉ុន្តែបើមានកិច្ចសន្យាពិសេស (ស្រែ) គឺជាថ្នាលសម្រាប់ (អ្នក) សាបព្រោះ ដូច្នេះម្ចាស់ពូជនិងម្ចាស់ដី ជាអ្នកទទួលផលទាំងពីរនាក់ នៅក្នុងលោកនេះ។

៥៤- បើសិនជាពូជត្រូវទឹកហូរ ឬខ្យល់កួចចូលស្រែរបស់នរណាមួយ ហើយដុះ(នៅស្រែនោះ) (រុក្ខជាតិដែលដុះពី)ពូជនោះ ក៏ជារបស់ម្ចាស់ស្រែ ហើយម្ចាស់ពូជមិនបានទទួលផលអ្វីទេ។

៥៥- ចូរដឹងថា នេះជាច្បាប់ដែលនិយាយពីកូនរបស់មេគោ លាញី ក្មេងស្រីទាសករ អូដ្ឋញី ពពែញី និងចៀមញី ព្រមទាំងបក្សីញី និងក្របីញី។

៥៦- ដូច្នេះការប្រៀបធៀបសារសំខាន់រវាងពូជនិងផ្ទៃ ត្រូវបានប្រកាសជម្រាបជូនអ្នកទាំងឡាយ បន្តទៅទៀតខ្ញុំនឹងថ្លែងរៀបរាប់អំពីច្បាប់(សម្រាប់)ស្ត្រីក្នុងគ្រាអកុសល។

៥៧- ប្រពន្ធរបស់បងប្រុស គឺសម្រាប់ប្អូនប្រុសខ្លួន ប្រពន្ធរបស់គ្រូ ប៉ុន្តែប្រពន្ធរបស់ប្អូនប្រុស ត្រូវបានប្រកាសថាជាកូនប្រសាររបស់បងប្រុស។

៥៨- បងប្រុស ដែលចូលទៅរកប្រពន្ធរបស់ប្អូន ហើយប្អូន(ប្រុសដែលចូលទៅរក)ប្រពន្ធរបស់បង លើកលែងក្នុងគ្រាអកុសល ទាំងពីរនាក់ក្លាយជាមនុស្សក្រៅវណ្ណៈ ថ្វីត្បិតតែ(ពួកគេ) មានសិទ្ធិគ្រប់គ្រាន់ក៏ដោយ។

៥៩- បើគ្មានកូន(ជាមួយប្តីរបស់នាង) ស្ត្រីមានសិទ្ធិ អាចមានកូនតាមការប្រាថ្នា តាមរបៀបមួយត្រឹមត្រូវដូចបានរៀបរាប់ (ដោយរួមរស់ជាមួយ)ប្អូនថ្លៃក៏បាន ឬ(ជាមួយ)សបិណ្ឌផ្សេងទៀត(របស់ប្តី)ក៏បាន។

៦០- អ្នក(ដែល)ព្រមព្រៀងរួមរស(ជាមួយ)ស្ត្រីមេម៉ាយ នឹង(ចូលទៅរកនាង)នៅពេលយប់ ដោយលាបប៊ឺស្រស់ និងរក្សាភាពស្ងៀមស្ងាត់ (និង)ផ្តល់កំណើតកូនប្រុស គឺគ្មានវិធីផ្សេងទេ។

---

**៥៤.** ខ្ញុំអានតាមលោកគោវ., រាឃ. និង K.*ពីជី* 'ម្ចាស់ពូជ' ជំនួសពាក្យ *វក្តា* អ្នកសាបព្រោះពូជ'(មេធ., កុល្លូ., នន្ទ.)។

**៥៥.** 'ច្បាប់បែបនេះ' គឺជាអ្វីដែលមាននិយាយនៅក្នុងកាព្យលេខ៤៨-៥៤។

**៥៦.** 'ក្នុងពេលជួបគ្រោះអាក្រក់' គឺ 'ពេលគ្មានកូនប្រុស'។

**៥៧.** គុរុ នៅទីនេះ តាមលោករាឃ. គឺ 'ឳពុក'។ ព្រោះភរិយារបស់ប្អូនប្រុស ត្រូវគេហៅថាកូនស្រីធម៌របស់បងប្រុស ការបកស្រាយនេះទំនងជាត្រឹមត្រូវ។

**៥៨-៦៨.** គោត. ជំពូក១៨ លេខ៤-៨; វស. ជំពូក១៧ លេខ៥៦-៦១; ពោធ. ជំពូក២ លេខ៤, ៩-១០; យញ្ញ. ជំពូក១ លេខ៦៨-៦៩។

**៥៩.** ស្ត្រីអាចមានសិទ្ធិ ដោយសារប្តីរបស់ខ្លួន ឬបន្ទាប់ពីប្តីស្លាប់ ដោយសារសាច់ញាតិប្តី។ 'បើគ្មានកូន' គឺ 'គឺកូនប្រុស' (គោវ., រាឃ., នន្ទ.) ឬ 'របស់កូនប្រុស និងកូនស្រីតាមការព្រមព្រៀង'(មេធ.)។ បើសិនជាកូនប្រុសដែលកើតមកនោះមិនសមនឹងធ្វើពិធីស្រាទ្ធ គេអាចបង្កើតកូនទីពីរ(មេធ., កុល្លូ., នារ.)។

**៦០.** យោងតាមអ្នកអធិប្បាយនានា សំនួនពាក្យ 'មេម៉ាយ' គេគ្មានបំណងហាមឃាត់ការជ្រើសរើសរបស់ប្តីដែលមានជំងឺ ឬគ្មានសមត្ថភាពផ្លូវភេទ។

៦១- (បណ្ឌិត)មួយចំនួន ដែលចេះតែងកាព្យជាច្បាប់ ដោយពិចារណាពីបំណងជួបគ្នារបស់អ្នកទាំងពីរ ដែលមិនបានសម្រេច(ចំពោះកំណើតកូនទីមួយ) គិតថា កូនទីពីរ(ប្រុស) អាចត្រូវបង្កើតដោយស្របច្បាប់ជាមួយស្ត្រី(បែបនេះ)បាន។

៦២- ប៉ុន្តែពេលបំណងចង់រួមរស់ជាមួយស្ត្រីមេម៉ាយ បានសម្រេចស្របតាមច្បាប់ អ្នកទាំងពីររាប់អានគ្នាទៅវិញទៅមក បីដូចជាឳពុក និងកូនស្រីប្រសា។

៦៣- បើសិនជាអ្នកទាំងពីរ (នេះ) តម្រូវឱ្យមានការដើរចាកគន្លងច្បាប់ និងធ្វើតាមបំណងផ្លូវកាយ ពួកគេទាំងពីរនឹងក្លាយ ជាមនុស្សក្រៅវណ្ណៈ (ព្រោះបុរស) ដែលប្រព្រឹត្តបំផ្លាញព្រហ្មចារីនៅលើគ្រែរបស់កូនស្រីប្រសា ឬរបស់គុរុ។

៦៤- បុរសដែលមានកំណើតពីរដង មិនត្រូវតម្រូវឱ្យស្ត្រីមេម៉ាយ(រួមរស់ជាមួយ)ប្រុសណាមួយ(ក្រៅពីប្តីរបស់ខ្លួន)ទេ ព្រោះអ្នកដែលតម្រូវឱ្យ(នាង)រួមរស់ជាមួយបុរសម្នាក់ទៀត នឹងបំពានច្បាប់អមតៈ។

៦៥- នៅក្នុងអត្ថបទពិសិដ្ឋ ដែលនិយាយអំពីអាពាហ៍ពិពាហ៍ គ្មានកន្លែងណាមួយនិយាយពីការរៀបចំឱ្យជួប(ស្ត្រីមេម៉ាយ) និងគ្មាននិយាយពីការរៀបការជាថ្មីរបស់ស្ត្រីមេម៉ាយ ដូចមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ទេ។

៦៦- អ្នកចេះដឹងជាអ្នកមានកំណើតពីរដង ធ្វើការរិះគន់ការអនុវត្តនេះថាដូចជាសត្វជាតុ (សូម្បីកើតមាន)ក្នុងចំណោមមនុស្សក៏ដោយ ចំណែកឯ*វេន* បានកំណត់។

៦៧- នាយករាជបណ្ឌិត ដែលធ្លាប់កាន់កាប់ពិភពលោកទាំងមូល បានបង្កឱ្យមានភាពច្របូកច្របល់វណ្ណៈនោះបញ្ញារបស់លោក ត្រូវបានបំផ្លាញដោយកាមតម្រេក។

៦៨- តាំងពីពេលនោះមក មនុស្សល្អទិតៀន(បុរស)ដែល ដោយសារភាពចម្កួតរបស់ខ្លួន ផ្តល់សិទ្ធិឱ្យស្ត្រីដែលប្តីស្លាប់ទៅហើយ ឱ្យមានកូនជាមួយ(បុរសម្នាក់ទៀត)។

---

**៦១.** 'ពីព្រោះតែសិស្ស និយាយថា 'អ្នកដែលមានកូនប្រុសតែមួយ គ្មានកូនប្រុសទេ"(មេធ., គោវ., កុល្ល., រាឃ.)។

**៦២.** 'អ្នកទាំងពីរនេះ' គឺ 'បងប្រុស និងស្ត្រីដែលមានការព្រមព្រៀង'។

**៦៣.** 'អ្នកទាំងពីរនេះ' គឺ 'បងប្រុស ឬប្អូនប្រុស'។ ពាក្យ 'គន្លងច្បាប់' សូមមើលកាព្យលេខ៦០។ ចំពោះអនុប្រយោគចុងក្រោយ ប្រៀបធៀបកាព្យលេខ៥៧។

**៦៤-៦៨.** កាព្យទាំងនេះនិយាយផ្ទុយទាំងស្រុងពីច្បាប់ដែលមានរៀបរាប់នៅក្នុងកាព្យមុនៗ។ ប៉ុន្តែប្រាកដណាស់ វាជាការបន្ថែមនៅសម័យទំនើប។ តាមការបង្ហាញការយល់ឃើញដូចគ្នារបស់អាប. ជំពូក២ លេខ២៧, ២-៦ ហើយតាមពោធ. ជំពូក២ លេខ៣, ៣៤ ថាជាការសន្និដ្ឋានរបស់*ឱបគន្ធនិ* ។ ជាងនេះទៅទៀត ព្រហស្បតិ ស្រ្មិត បញ្ជាក់ច្បាស់ (Cole-brooke ជំពូក៤ ទំព័រ១៥៧)ថា សេចក្តីថ្លែងផ្ទុយគ្នា មាននៅក្នុងគម្ពីរមានវៈធម្មសាស្ត្រ ដែលគេស្គាល់ថាជាឈ្មោះអ្នកនិពន្ធគម្ពីរនេះ។

**៦៥.** ក្នុងអត្ថបទអធិប្បាយរបស់គាត់ត្រង់កាព្យលេខ៦៦ លោកមេធ.គូសបញ្ជាក់ថា នៅក្នុងអត្ថបទពិសិដ្ឋផ្សេងទៀត ឬគវេទ ជំពូក១០ លេខ៤០, ២ មាននិយាយពី*និយោគ*។

**៦៦.** តាមវីរកថា និងប្រពៃណីវេន បុរាណ គឺបិតាឬថុ និងមហាក្សត្រិយដែលគ្មានជំនឿលើអាទិទេព ដែលតម្រូវឱ្យគេធ្វើពិធីយញ្ញជូនទ្រង់ មិនមែនថ្វាយអាទិទេពទេ។ ដូច្នេះទ្រង់ ត្រូវពួកព្រាហ្មណ៍ កាប់ចិញ្ច្រាំនឹងកាំបិតកាត់ស្មៅកុសៈ។ ប៉ុន្តែរហូត

៦៩- ប្រសិនបើ(អនាគត)ប្តីរបស់ស្រីក្រមុំម្នាក់ស្លាប់ បន្ទាប់ពីបានសន្យាភ្ជាប់ពាក្យដោយផ្ទាល់មាត់ ប្អូនថ្លៃរបស់នាងនឹងរៀបការជាមួយនាង ស្របតាមវិធានច្បាប់តទៅ។

៧០- តាមវិធានច្បាប់ ដោយបានរៀបការជាមួយនាង (ដែលត្រូវតែជា)ស្លៀកពាក់រ៉ូបពណ៌ស និងមានបំណងបរិសុទ្ធ គាត់នឹងចូលទៅរកនាងមួយលើកៗ ក្នុងកាលដ៏សមស្រប រហូតដល់មានកូន។

៧១- ចូរបុរសដែលមានការប្រុងប្រយ័ត្ន បន្ទាប់ពីប្រគល់កូនស្រីខ្លួនទៅ(បុរស)ម្នាក់ កុំឱ្យនាងទៅបុរសម្នាក់ទៀត ព្រោះថាអ្នកដែលប្រគល់(កូនស្រីខ្លួន)ទៅឱ្យអ្នកដែលខ្លួនបានប្រគល់ពីមុន គឺជា (ទោស)និយាយមិនពិតពាក់ព័ន្ធរឿងមនុស្ស។

៧២- ថ្វីបើ (បុរសម្នាក់) អាចទទួលស្រីក្រមុំម្នាក់តាមទម្រង់ត្រឹមត្រូវ គាត់អាចបោះបង់(នាងបាន) ប្រសិនបើនាងមានភាពសៅហ្មង មានជំងឺឬអស់ព្រហ្មចារី ហើយ(បើសិនជានាងត្រូវគេប្រគល់)ដោយបំភាន់។

៧៣- ប្រសិនបើនរណាម្នាក់ប្រគល់កូនក្រមុំ ដែលមានមន្ទិល ដោយមិនបានប្រកាសប្រាប់ជាមុន (កូនកំលោះ) អាចបដិសេធ(កិច្ចសន្យា)នោះចំពោះអ្នកប្រគល់ដែលមានចិត្តមិនល្អ។

៧៤- បុរស ដែលមានធុរកិច្ច(ក្រៅប្រទេស)អាចចាកចេញបាន បន្ទាប់ពីបានធានាការចិញ្ចឹមជីវិតសម្រាប់ភរិយារបស់ខ្លួន សូម្បីប្រកបដោយគុណធម៌ក៏ដោយ ក៏អាចនាំឱ្យខូចការ បើសិនជានាងមានទុក្ខព្រួយ ដោយសារការខ្វះខាតក្នុងការចិញ្ចឹមជីវិត។

៧៥- ប្រសិនបើ(ប្ដី)បានធ្វើដំណើរ បន្ទាប់ពីផ្ដល់(ការចិញ្ចឹមជីវិតដល់នាង) ភរិយានឹងព្យាយាមជម្នះការចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ខ្លួន ប៉ុន្តែបើសិនជាប្ដីចាកចេញដោយមិនបានផ្ដល់(ឱ្យនាង) នាងអាចចិញ្ចឹមជីវិតដោយធ្វើការងារគ្មានទោសដោយដៃ។

៧៦- ប្រសិនបើប្ដីធ្វើដំណើរទៅក្រៅប្រទេសដើម្បីករណីយកិច្ចដ៏ពិសិដ្ឋណាមួយ (នាង)ត្រូវរង់ចាំគាត់រយៈពេលប្រាំបីឆ្នាំ បើសិនជា(គាត់ទៅ)ក្រេបយកចំណេះដឹង ឬរកកេរ្តិ៍ឈ្មោះ រយៈពេលរង់ចាំគឺចំនួនប្រាំមួយឆ្នាំ បើសិនជា(គាត់ទៅ)ដើម្បីការកំសាន្តសប្បាយ ពេលរងចាំ គឺបីឆ្នាំ។

---

មកដល់ពេលនេះ គ្មាននរណាមួយបានឃើញសេចក្ដីដទៃ ដែលនិយាយថា ទ្រង់បានដាក់ឱ្យអនុវត្ត*និយោគ*នោះទេ។ ទំនងជាការពោលអះអាងនៃគម្ពីរមានវ អាចសាយភាយដោយសារមានការនាំចូលពាក្យ*វេទ*ពោរពេញដោយចំណង់ ឬតម្រេក៎។

**៧០.** តាមការគូសបញ្ជាក់របស់អ្នកអធិប្បាយនានា ដូចនេះក្មេងដែលកើតពីស្ត្រីដែលបានរៀបការ គឺជារបស់អ្នកភ្ជាប់ពាក្យជាមួយនាង ដែលបានស្លាប់ទៅ។

**៧១.** យញ្ញ. ជំពូក១ លេខ៦៥; វិ. ជំពូក២៥ លេខ៩-១០។ បើនិយាយពីកំហុសដែលកើតមាន សូមមើលជំពូក៨ លេខ៩៨ខាងលើ។ លោកមេធ. និងនន្ទ. និយាយថា កាព្យនេះ គឺសំដៅហាមឃាត់អាពាហ៍ពិពាហ៍របស់ក្មេងស្រី ដែលស្លាប់គូដណ្ដឹង។ ប៉ុន្តែលោកកុល្ល. គិតថា កាព្យនេះសំដៅដល់ករណីទាំងអស់ ដែលមានការភ្ជាប់ពាក្យ ហើយថា វាឆ្លុះបញ្ចាំងច្បាស់នូវការសង្ស័យដែលកើតចេញពីការបកស្រាយចង្អៀតពេកនៅក្នុងជំពូក៨ លេខ២២៧។

**៧២.** ៉តាមទម្រង់ត្រឹមត្រូវ៎ គឺ ៉ដោយមានពិធីប្រួចទឹក និងមានវត្តមានព្រាហ្មណ៍៎(មេធ., កុល្ល., រាឃ.)។ ៉មានភាពសៅហ្មង៎ គឺ ៉ដោយមានស្នាមអាក្រក់លើរូបកាយ៎(មេធ., កុល្ល., រាឃ., នន្ទ.) ឬ ៉ដោយមានគ្រួសារអាក្រក់៎(នារ.)។

**៧៣.** សូមមើលជំពូក៨ លេខ២០៥, ២២៤ ខាងលើ។

**៧៤.** លោកនន្ទ. បញ្ចូលកាព្យលេខ៩៥-៩៦ បន្ទាប់ពីកាព្យនេះ។

**៧៦.** គោត. ជំពូក១៨ លេខ១៥, ១៧; វស. ជំពូក១៧ លេខ៧៥-៨០។ លោកកុល្ល., នារ. និងរាឃ. ប្រកាសថា បន្ទាប់ពី

៧៧- ចូរប្ដីទ្រាំនៅជាមួយប្រពន្ធដែលស្អប់ខ្លួន រយៈពេលមួយឆ្នាំ ប៉ុន្តែបន្ទាប់ពី(ផុត)រយៈពេលមួយឆ្នាំ ចូរប្ដីដកហូតកម្មសិទ្ធិរបស់នាង ហើយឈប់រួមសង្វាសជាមួយនាង។

៧៨- នាងដែលបង្ហាញការមិនគោរពចំពោះ (ស្វាមី) ដែលញៀននឹងកាមតម្រេក(ដ៏គ្មានសីលធម៌) ជាអ្នកស្រវឹងខ្ជប ឬមានជំងឺរុំារ៉ៃ នឹងត្រូវបោះបង់ចោលរយៈពេលបីខែ (ហើយ)ដកហូតគ្រឿងលម្អកាយរបស់នាង និងសង្ហារិម។

៧៩- ប៉ុន្តែស្រី ដែលបង្ហាញការមិនពេញចិត្តចំពោះ(ប្ដី)ចម្កួត ឬដែលគេបោះបង់ចោល មនុស្សកម្រៀវគ្មានកម្លាំងកំហែងជាបុរស ឬជាមនុស្សមានជំងឺ ដោយសារការជាប់ទោសឧក្រិដ្ឋ នឹងមិនត្រូវគេបោះបង់ចោល និងដកហូតទ្រព្យរបស់នាងទេ។

៨០- ស្រី ដែលសេពគ្រឿងស្រវឹង មានចរិតអាក្រក់ រឹងរូស មានជំងឺ បើុលប៉ើច ឬខ្ជះខ្ជាយ អាចឱ្យគេ(យកប្រពន្ធមួយទៀត)ជំនួស នៅពេលណាក៏បាន។

៨១- ប្រពន្ធអារ អាចឱ្យគេយកប្រពន្ធមួយទៀតក្នុងឆ្នាំទីប្រាំបី នាងដែលមានកូនស្លាប់ទាំងអស់ក្នុងឆ្នាំទីដប់ នាងដែលមានតែកូនស្រីក្នុងឆ្នាំទីដប់មួយ ប៉ុន្តែជាស្រីដែលចូលចិត្តឈ្លោះមិនចេះចប់។

៨២- ប៉ុន្តែប្រពន្ធឈឺ ដែលមានចិត្តល្អ(ដាក់ប្ដីរបស់ខ្លួន) និងជាចរិតល្អ អាចឱ្យគេយកប្រពន្ធមួយទៀត (ក្នុងករណី)ដែលមានការយល់ព្រមពីនាងផ្ទាល់ ហើយគេមិនត្រូវធ្វើឱ្យនាងអាម៉ាស់ទេ។

៨៣- ប្រពន្ធដែលត្រូវប្ដីយកស្រីមួយទៀត មានកំហឹងដើរចេញពីផ្ទះ(របស់ស្វាមីខ្លួន) ត្រូវគេឃុំឃាំងមួយរយៈពេលក៏បាន ឬត្រូវគេលែងរាប់រកក្នុងគ្រួសារ។

៨៤- ប៉ុន្តែស្រីដែលសេពគ្រឿងស្រវឹង សូម្បីមានការហាមឃាត់នៅពេលបុណ្យទានក៏ដោយ ឬចូលក្នុងចំណោមមហាជន ឬការជួបជុំសាធារណៈ នឹងត្រូវពិន័យចំនួនប្រាំមួយក្រិស្នលៈ។

៨៥- ប្រសិនបើបុរសមានកំណើតពីរ រៀបការជាមួយស្ត្រីក្នុងវណ្ណៈជាមួយខ្លួន និងវណ្ណៈទាបជាង មានវ័យច្រើនជាង មានកិត្តិយស ហើយគេត្រូវសង់លំនៅឋានសម្រាប់ភរិយាទាំងនោះ ស្របតាមលំដាប់វណ្ណៈ។

---

ផុតរយៈពេលខាងលើ ភរិយានឹងទៅរកស្វាមីខ្លួន។ លោកនន្ទ និយាថា 'អត្ថន័យគឺថា គ្មានបាបកម្មទេ បើនាងយកប្ដីមួយទៀត នៅពេលក្រោយមក'។ លោកមេធ. សន្និដ្ឋានថា នាងនឹងចិញ្ចឹមខ្លួនឯងដូចពីមុន ដោយមុខរបរគ្មានទោស និងរក្សាភាពបរិសុទ្ធដដែល។ លោកលើកឡើងនូវមតិរបស់អ្នកដទៃ ដែលថា នាងអាចយកប្ដីមួយទៀត ស្របតាមគោលការណ៍របស់នារទ និងបរាសរ ប៉ុន្តែបោះបង់ចោលមតិនេះវិញ។ 'ដើម្បីការកំសាន្ត' គឺ 'ដើម្បីបានស្ត្រីមួយទៀត ដែលគាត់ពេញចិត្តជាង'(មេធ., កុល្ល., រាឃ.)។

**៧៧.** 'ទ្រព្យសម្បត្តិរបស់នាង' គឺ 'អលង្ការ និងទ្រព្យដទៃទៀត ដែលប្ដីឲ្យទៅនាង'(កុល្ល., រាឃ., នន្ទ.) ឬ 'ទ្រព្យដោយឡែករបស់នាង ដែលប្ដីផ្ដល់ឱ្យនាង'(ស្រីធនៈ, នារ.)។ អ្នកអធិប្បាយបន្ថែមថា យ៉ាងណាក៏ដោយនាងត្រូវគេបីបាច់រក្សា។

**៧៨.** 'ញៀននឹងកាមតម្រេក(ដ៏គ្មានសីលធម៌)' គឺ 'ញៀននឹងល្បែងជាដើម'(កុល្ល., នារ.) ឬ 'ញៀននឹងលោភៈ'(រាឃ.)។

**៨០-៨១.** ពោធ. ជំពូក២ លេខ៤, ៦; ជំពូក១ លេខ៧៣។

**៨០.** 'មានជំងឺ' គឺ 'មានជំងឺឃ្លង់ ឬជំងឺរបៀបនេះ'(កុល្ល.) 'របុិលរប៉ូច' គឺ 'ដែលវាយដំ ឬធ្វើបាបកូន អ្នកបម្រើរបស់នាង ជាដើម'(មេធ., នារ., កុល្ល.)។

**៨៣.** 'របស់គ្រួសារ' គឺ 'របស់គ្រួសារផ្ទាល់របស់នាង និងរបស់ប្ដី'(មេធ.) ឬ 'របស់គ្រួសារនាងផ្ទាល់'(កុល្ល., នារ.)។

៨៦- ក្នុងចំណោម (បុរសមានកំណើតពីរដង) ទាំងអស់ ភរិយាដែលមានវណ្ណៈស្មើគ្នាប៉ុណ្ណោះ មិនមែនភរិយាដែលមានវណ្ណៈផ្សេងគ្នា នឹងចូលរួមជាប្ដីខ្លួនដោយផ្ទាល់ និងជួយប្ដី ក្នុងពិធីពិសិដ្ឋប្រចាំថ្ងៃរបស់ប្ដី។

៨៧- ប៉ុន្តែអ្នកដែលញ៉ាំងឱ្យអ្នកផ្សេងបំពេញ(ករណីយកិច្ច)នោះយ៉ាងល្ងង់ខ្លៅ ចំណែកឯភរិយារបស់ខ្លួនដែលមានវណ្ណៈស្មើគ្នានៅមានជីវិត ត្រូវចាស់បុរាណប្រកាស (ថាជា) មនុស្សគួរឱ្យស្អប់ ដូចជាចណ្ឌាល(ដែលកើតចេញពី)វណ្ណៈព្រាហ្មណ៍។

៨៨- ចំពោះបុរសសង្ហាដ៏ល្បីឈ្មោះដែលមានវណ្ណៈស្មើគ្នា គួរ (ឪពុក) ប្រគល់កូនស្រីរបស់ខ្លួន ស្របតាមវិធានច្បាប់បញ្ញត្តិ ទោះបីនាងមិនទាន់ដល់វ័យ(សមស្រប)ក៏ដោយ។

៨៩- (ប៉ុន្តែ)ស្រីក្រមុំ ទោះជាអាចរៀបការបាន គួរឈប់រស់នៅក្នុងផ្ទះ (របស់ឪពុក) រហូតដល់ស្លាប់ប្រសើរជាងឪពុកប្រគល់នាងឱ្យទៅបុរស ដែលគ្មានគុណសម្បត្តិល្អ។

៩០- ចូរស្រីក្រមុំរង់ចាំបីឆ្នាំ ទោះបីនាងអាចរៀបការបានក៏ដោយ ប៉ុន្តែបន្ទាប់ពីរយៈពេលនោះ ចូរនាងជ្រើសរើសកូនកំលោះដែលមាន(វណ្ណៈ និងឋានៈ)ស្មើគ្នា ដោយខ្លួនឯង។

៩១- ប្រសិនបើមិនបានរៀបការ នាងត្រូវស្វែងរកប្តីដោយខ្លួនឯង នាងគ្មានទោសទេ ហើយអ្នកដែលនាងរៀបការជាមួយក៏គ្មានទោសដែរ។

៩២- ស្រីក្រមុំ ដែលជ្រើសរើសសម្រាប់ខ្លួនឯង មិនយកតាមខ្លួននូវគ្រឿងលម្អណាមួយដែលឪពុក ឬម្តាយនាង ឬបងប្អូនប្រុសរបស់នាងបានប្រគល់ឱ្យទេ ហើយបើនាងយករបស់ទាំងនោះតាមខ្លួននាងគឺជាចោរ។

៩៣- ប៉ុន្តែអ្នកដែលទទួលស្រីក្រមុំដែលអាចរៀបការបាន នឹងមិនចេញថ្លៃការជូនឪពុករបស់នាងទេ ព្រោះ(ឪពុក)លែងមានសិទ្ធិគ្រប់គ្រងលើនាងទៀតហើយ ដោយសារការការពារ(លទ្ធផលស្រប ច្បាប់នៃការមាន)រដូវរបស់នាង។

---

**៨៦.** វិ. ជំពូក២៦ លេខ១; យញ្ញ. ជំពូក១ លេខ៨៨។ 'ចូលរួមដោយផ្ទាល់' គឺ 'រៀបចំនិងនាំយកអាហាររបស់គាត់ជាដើម' (មេធ., កុល្លូ., រាឃ.)។

**៨៧.** វិ. ជំពូក២៦ លេខ២។ ជំនួសឱ្យ 'ដោយចាស់បុរាណ'(កុល្លូ., រាឃ., នន្ទ.) លោកមេធ. និយាយថា 'តាំងពីសម័យបុរាណព្រេងនាង' ហើយនារ.ថា 'កាលពីបុរាណ'។ ចំពោះដើមកំណើតពាក្យ*ចណ្ឌាល* សូមមើលជំពូក១០ លេខ១២ ខាងក្រោម។

**៨៨-៩២.** គោត. ជំពូក១៨ លេខ២០-២៣; វស. ជំពូក១៧ លេខ៦៩-៧១; ពោធ. ជំពូក៤ លេខ១១-១៤; វិ. ជំពូក២៤ លេខ៤០-៤១; យញ្ញ. ជំពូក១ លេខ៦៤។

**៨៨.** 'ទោះជានាងមិនទាន់ដល់(វ័យសមស្រប)ក៏ដោយ' គឺ 'វ័យប្រាំបីឆ្នាំ'(កុល្លូ., នារ., រាឃ.) ឬ 'នៅមុនពេលនាងរូបកាយនាងសមស្របសម្រាប់ការរៀបការ'(មេធ., នន្ទ.)។ លោកមេធ. ជំទាស់នឹងមតិទីមួយដាច់ខាត 'ព្រោះបុរសដែលលោភលន់ចង់បានលុយ ក៏អាចឱ្យទារករៀបការបានដែរ'។

**៩២.** ខ្ញុំអានតាមលោកមេធ. និងនន្ទ. *ស្តេយំ ស្យាត* ជំនួសការអាន *ស្តេនា ស្យាត* 'នាងនឹងក្លាយជាចោរ'(កុល្លូ., រាឃ., K.)។ លោកមេធ. លើកឡើងអំណានមួយទៀត *ស្តេនះ ស្យាត* 'គាត់ គឺ កូនកំលោះ គឺជាចោរ'។

**៩៣.** លោកមេធ. និយាយថា កាព្យនេះ តាមអ្នកខ្លះគឺថា មិនមែនជារបស់មនុ ទេ(*កេចិទ អាហូ អមានវំ យំ ស្លោកះ*)។

៩៤- បុរស ដែលមានវ័យសាបសិបឆ្នាំ នឹងរៀបការជាមួយកូនក្រមុំវ័យដប់ពីរឆ្នាំ ដែលពេញចិត្តខ្លួន ឬ បុរសវ័យសាបសិបបួនឆ្នាំរៀបការជាមួយក្មេងស្រីវ័យប្រាំបីឆ្នាំ ហើយបើ(ផ្ទុយទៅវិញ ការបំពេញ) ករណីយកិច្ចរបស់ខ្លួន ត្រូវបានអាក់ខាន (គាត់ត្រូវតែរៀបការ)ឱ្យកាន់តែឆាប់។

៩៥- ប្តីទទួលភរិយារបស់ខ្លួនពីព្រះអាទិទេព (គាត់មិនមែនរៀបការនាង)តាមឆន្ទៈផ្ទាល់របស់ខ្លួនទេ ហើយត្រូវធ្វើអ្វីឱ្យស្របតាមព្រះអាទិទេព គាត់ត្រូវតែចិញ្ចឹមនាងជានិច្ច (ឱ្យតែនាងនៅមានស្វាមីភក្តិ)។

៩៦- ការធ្វើជាម្តាយ គឺជាស្ត្រីដែលព្រះបង្កើត ហើយការធ្វើជាឪពុកគឺបុរស ហេតុនេះពិធីសាសនា ក៏មានបញ្ញត្តិនៅក្នុងព្រះវេទ សម្រាប់ឱ្យ(ប្តី) និងប្រពន្ធ ប្រតិបត្តិ។

៩៧- បើ បន្ទាប់ពីបានបង់ថ្លៃរៀបអាពាហ៍ពិពាហ៍ឱ្យកូនក្រមុំ អ្នកបង់ថ្លៃនោះស្លាប់ទៅ នាងនឹងត្រូវគេឱ្យរៀបការជាមួយប្អូនរបស់គាត់ ក្នុងករណីនាងយល់ព្រម។

៩៨- សូម្បីតែសូទ្រៈមិនគួរទទួលថ្លៃរៀបការទេ ពេលគាត់ប្រគល់កូនស្រីរបស់ខ្លួនឱ្យគេ ព្រោះអ្នកដែលទទួលថ្លៃនេះ គឺលក់កូនស្រីខ្លួនដោយបិទបាំង(ការលក់ដូរក្នុងន័យម្យ៉ាងទៀត)។

៩៩- មនុស្សល្អមិនដែលធ្វើបែបនេះទេ តាំងពីបុរាណក៏ដូចជាសម័យទំនើប បន្ទាប់ពីសន្យាឱ្យ(កូនស្រី)ទៅបុរសម្នាក់ ពួកគេបានប្រគល់នាងទៅឱ្យបុរសម្នាក់ទៀត,

១០០- តាមពិតយើងក៏មិនធ្លាប់បានឮ សូម្បីតាំងពីការបង្កើតសត្វលោកដំបូង រឿងបែបនេះ ហាក់ដូចជាការលាក់បាំងការលក់កូនស្រី តាមតម្លៃកំណត់ ដែលគេហៅថាថ្លៃរៀបអាពាហ៍ពិពាហ៍។

១០១- `ចូរបន្តមានភក្តីភាពទៅវិញទៅមករហូតដល់ស្លាប់´ គេចាត់ទុកនេះជាសេចក្តីសង្ខេបនៃច្បាប់ដ៏ខ្ពង់ខ្ពស់បំផុតសម្រាប់ស្វាមីភរិយា។

១០២- ចូរបុរសនិងស្ត្រីដែលឯកភាពគ្នារៀបការ ស៊ូទ្រាំជាប្រចាំ ពោលគឺ(ពួកគេ)មិនអាចបែកផ្លូវគ្នា(ហើយ)មិនអាចរំលោភភក្តីភាពទៅវិញទៅមករបស់ខ្លួនទេ។

---

**៩៤.** មេធ. និងកុល្លូ. គូសបញ្ជាក់ថា កាព្យនេះគ្មានបំណងកំណត់នូវវិធានច្បាប់តឹងរ៉ឹង និងដ៏ត្រឹមត្រូវ ប៉ុន្តែគ្រាន់តែផ្តល់តួយ៉ាងបញ្ជាក់ពីវ័យសមស្របប៉ុណ្ណោះ។ `ប្រសិនបើ(ការបំពេញ)ករណីយកិច្ចរបស់ខ្លួន មិនមានបញ្ហាជាដើម´ គឺ `បើសិនជាគាត់បានបញ្ចប់ការសិក្សារបស់ខ្លួនមុន គាត់ត្រូវរៀបការភ្លាម ដើម្បីអាចបំពេញករណីយកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកគ្រប់គ្រងផ្ទះ´(កុល្លូ., មារ., រាឃ.)។

**៩៥.** `ពីព្រះអាទិទេព´ គឺ `ពីអ្នកទាំងឡាយដែលមានរៀបរាប់នៅក្នុងមន្ត្រ ដែលគេសូត្រនៅក្នុងពិធីអាពាហ៍ពិពាហ៍ ឧ.ទា. ពីព្រះភគ, អរ្យម័ន, សវិត្រិ ជាដើម´(កុល្លូ., រាឃ.) ឬ `ពីព្រះអគ្និ´(នារ.) ឬ `ពីព្រះសោម, គន្ធវៈ និងអគ្និ´(មេធ., នន្ទ.)។ លោកមេធ. អានវិន្ទេតានិច្ឆយា `នឹងរៀបការ ដោយមិនប្រាថ្នាចង់បានចំណែកខ្លួន´ ប៉ុន្តែលើកឡើងអំណានផ្សេង វិន្ទតេ នេច្ឆយា ដែរ។ យោងតាមលោកមេធ., កុល្លូ. និងរាឃ. ភរិយាស្មោះត្រង់ ត្រូវបានទំនុកបម្រុង ថ្វីបើនាងមិនស្រឡាញ់ស្វាមីខ្លួនក៏ដោយ។

**៩៧.** `បងប្អូនប្រុសរបស់ខ្លួន´ គឺ `បងប្អូនប្រុសបង្កើតរបស់ខ្លួន ដែលសូម្បីស្លាប់ក៏ដោយ´(នារ.)។ បើនិយាយពីថ្លៃអាពាហ៍ពិពាហ៍ និងការខ្វែងគំនិតគ្នារវាងកាព្យនេះ និងកាព្យបន្ទាប់ សូមមើលកំណត់សម្គាល់ជំពូក៨ លេខ២០៤។

**៩៩.** លោកនន្ទ. ដាក់កាព្យនេះបន្ទាប់ពីកាព្យក្រោយ។

១០៣- ដូចបានប្រកាសជូនអ្នកទាំងឡាយដូច្នេះ អំពីច្បាប់សម្រាប់ស្វាមី និងភរិយារបស់ខ្លួន ដែលមានទំនាក់ទំនងជិតស្និទ្ធជាសុភមង្គលប្តីប្រពន្ធ ហើយវិធីចិញ្ចឹមកូនក្នុងគ្រាក្រលំបាក ហើយពេលនេះ ចូរសិក្សាច្បាប់ស្តីពីការបែងចែកមរតក។

១០៤- បន្ទាប់ពីឪពុកម្តាយស្លាប់ទៅ បងប្អូនប្រុស ដោយចេះប្រជុំគ្នា បែងចែកចំណែកទ្រព្យរបស់ឪពុកម្តាយ ឱ្យស្មើៗគ្នាក្នុងចំណោមពួកគេ ព្រោះពួកគេគ្មានអំណាច (លើទ្រព្យនោះ) ទេ បើឪពុកម្តាយនៅមានជីវិត។

១០៥- (ឬ)កូនច្បងបំផុតប៉ុណ្ណោះ អាចទទួលទ្រព្យទាំងអស់របស់ឪពុកកូនផ្សេងទៀតនឹងរស់អាស្រ័យជាមួយគាត់ ដូចជា(ពួកគេរស់នៅ)ក្រោមការគ្រប់គ្រងរបស់ឪពុកខ្លួនដែរ។

១០៦- នៅពេលមានកំណើតកូនប្រុសទីមួយភ្លាម គេហៅថាឪពុករបស់កូនប្រុស ហើយគេឱ្យរួចបំណុលសម្រាប់ព្រលឹងដូនតា ហេតុនេះ(កូនប្រុស)នោះសមនឹង(ទទួល)ទ្រព្យទាំងអស់។

១០៧- កូនប្រុសនោះប៉ុណ្ណោះដែលជាអ្នកទទួលបំណុលឪពុក ហើយតាមរយៈកូនប្រុសនោះ ឪពុកអាចទទួលបានភាពអមតៈ ត្រូវបានចាប់កំណើតសម្រាប់ (ការអនុវត្ត) ច្បាប់ រួចពួកគេចាត់ទុកកូនដទៃទៀតទាំងអស់ជាកូនតាមសេចក្ដីប្រាថ្នា។

១០៨- ដោយសារឪពុក(ចិញ្ចឹម)កូនប្រុសខ្លួន ដូច្នេះចូរកូនច្បងគេចិញ្ចឹមប្អូនៗរបស់ខ្លួន ហើយចូរឱ្យពួកគេប្រព្រឹត្តចំពោះបងប្រុសបង្អស់របស់ខ្លួនតាមច្បាប់ ដូចកូនប្រុស(ប្រព្រឹត្តចំពោះឪពុកម្ដាយខ្លួនដែរ)។

១០៩- (កូនប្រុស)ច្បងគេធ្វើឱ្យគ្រួសាររុងរឿង ហើយផ្ទុយទៅវិញក៏អាចញ៉ាំងឱ្យគ្រួសារវិនាសបាន។ កូនច្បងគេ(ត្រូវគេចាត់ទុក)ក្នុងចំណោមបុរស ថាសក្តិសមនឹងមានកិត្តិយសបំផុត កូនច្បងគេមិនត្រូវមនុស្សល្អមិនគោរពនោះទេ។

១១០- បើសិនជាបងប្រុសបង្អស់ប្រព្រឹត្តសមគួរជាបងប្រុសគេ គាត់(ត្រូវតែទទួលបានការគោរព)បីដូចម្ដាយ និងឪពុក ប៉ុន្តែបើសិនជាគាត់ប្រព្រឹត្តមិនសមគួរបងប្រុសបង្អស់ គេមិនគួរផ្ដល់កិត្តិយសឱ្យគាត់ដូចញាតិសន្ដានប្រុសនោះទេ។

---

**១០៤.** គោត. ជំពូក២៨ លេខ១; ពោធ. ជំពូក២ លេខ៣, ៨; យញ្ញ. ជំពូក២ លេខ១១៧។ ទ្រព្យរបស់ឪពុក ត្រូវគេបែងចែក ក្រោយពីឪពុកទទួលមរណភាព ហើយទ្រព្យរបស់ម្ដាយ បន្ទាប់ពីម្ដាយស្លាប់(កុល្ល., នារ., រាឃ., នន្ទ.)។ ទ្រព្យរបស់ម្ដាយ ប្រគល់ឱ្យកូនប្រុស ក្នុងករណីគ្មានកូនស្រី(នារ.)។ ពាក្យ *អ៊ូធ្វំ*បន្ទាប់ពី' សបញ្ជាក់ថា វិធានច្បាប់នេះ ជួយជាប្រយោជន៍ ក្នុងករណីឪពុកក្លាយជាឫសី(រាឃ.)។ ការបែងចែកស្មើគ្នាត្រូវតែធ្វើឱ្យបាន ប្រសិនបើកូនច្បងមិនចង់ទទួលចំណែកបន្ថែម(កុល្ល.)។ អនុប្រយោគចុងក្រោយបង្ហាញថា ការបែងចែកទ្រព្យ អាចធ្វើឡើងដោយមានការអនុញ្ញាតពីឪពុកម្ដាយ ក្នុងអំឡុងពេលពួកគាត់នៅមានជីវិត(កុល្ល., នារ., រាឃ.)។

**១០៥.** គោត. ជំពូក២៨ លេខ៣; ពោធ. ជំពូក២ លេខ៣, ១៣។ ពោលគឺ ប្រសិនបើកូនប្រុសច្បងគេជាមនុស្សលល្អ (កុល្ល., រាឃ.) ឬ មានលក្ខណៈសម្បត្តិពិសេសឧត្តុង្គឧត្តម ចំណែកឯកូនដទៃមិនសូវទទួលបានការគោរពទេ(នារ.)។

**១០៦.** ចំពោះបំណុល សូមមើលវស. ជំពូក១១ លេខ៤៨។

**១០៧.** កាព្យនេះនិយាយសំដៅដល់អត្ថបទកាព្យ ដូចការដកស្រង់ វស.ជំពូក១៧ លេខ១; វិ. ជំពូក១៥ លេខ៤៥។

**១០៨.** គឺ បើសិនជាពួកគេមិនធ្វើការបែងចែក ហើយកូនច្បងគេទទួលទ្រព្យទាំងអស់(កុល្ល.)។ លោកនន្ទ. ដាក់កាព្យនេះក្រោយកាព្យបន្ទាប់។

**១១០.** 'ប្រព្រឹត្តដូចជាបងប្រុសបង្អស់(គួរធ្វើ)' គឺ 'ការពារ និងអប់រំប្អូនៗឱ្យបានត្រឹមត្រូវ'(មេធ., កុល្ល., នារ., រាឃ.)។ 'ដូច

១១១- ដូចនេះចូរពួកគេរស់នៅជាមួយគ្នាក៏បាន ឬរស់នៅផ្សេងគ្នាក៏បាន បើសិនជា (ម្នាក់ៗ) ចង់បានបុណ្យកុសលផ្នែកព្រលឹងវិញ្ញាណ ព្រោះ(ដោយសារការរស់នៅ)បែកគ្នា បុណ្យកុសល(របស់ពួកគេ)នឹងកើនឡើង ហេតុនេះការរស់នៅបែកគ្នា គឺជាអំពើកុសល។

១១២- ចំណែកបន្ថែម(ដក)ឱ្យបងបង្អស់ គឺស្មើមួយភាគដប់ពីរនៃ(ទ្រព្យរួម) និងចលនាទ្រព្យល្អៗទាំងអស់ សម្រាប់ពាក់កណ្ដាល ប៉ុន្តែសម្រាប់ប្អូនគេ បានមួយភាគបួន។

១១៣- ទាំងបងបង្អស់និងប្អូនបង្អស់ នឹងទទួលបានចំណែក(របស់ពួកខ្លួន)ស្របតាមវិធានច្បាប់ ដូចបានបញ្ជាក់ត្រឹមត្រូវ ហើយ(ម្នាក់ៗ)ក្រៅពីបងបង្អស់និងប្អូនបង្អស់ នឹងបានចំណែក(កំណត់)ពាក់កណ្ដាលនោះ។

១១៤-ក្នុងចំណោមទំនិញគ្រប់ប្រភេទ បងបង្អស់នឹងបាន(របស់)ល្អបំផុត ហើយ(សូម្បីកៅអីមួយ) ដែលនៅល្អ ព្រមទាំង(សត្វ)ល្អៗដប់។

១១៥-ប៉ុន្តែក្នុងចំណោម (បងប្អូនប្រុស) ដែលមានជំនាញស្មើគ្នាក្នុងមុខរបររបស់ខ្លួន គ្មានចំណែកបន្ថែម (ដែលមានសត្វល្អៗ)ក្នុងចំណោមសត្វដប់ទេ ហើយវត្ថុកំប៉ិកកំប៉ុកខ្លះត្រូវគេផ្តល់ឱ្យ តែបងបង្អស់ ជានិមិត្តរូបនៃការគោរពមួយ។

---

ជាញាតិសន្តានប្រុស' គឺ 'ដូចជាពូ ឬអ៊ំខាងម្តាយ ឬខាងឪពុក'(មេធ., កុល្ល., រាឃ.) សូមមើលកាព្យ២១៣ ខាងក្រោម។

**១១១.** គោត. ជំពូក២៨ លេខ៤។ 'គុណបុណ្យ(របស់ពួកគេ)កើនឡើង' គឺ 'ម្នាក់ៗត្រូវបង្កាត់ភ្លើងពិសិដ្ឋ បូជាអគ្និហោត្រដោយឡែកពីគ្នា មហាពិធីយញ្ញប្រាំជាដើម ដូច្នេះម្នាក់ៗមានគុណកុសលផ្សេងគ្នា'(មេធ., កុល្ល.)។

**១១២.** គោត. ជំពូក២៨ លេខ៥-៧; ពោធ. ជំពូក២ លេខ៣, ៩; វិ. ជំពូក១៨ លេខ៣៧; យញ្ញ. ជំពូក២ លេខ១១៤។ 'អ្នកផ្សេងពីនេះនឹងត្រូវគេចែកឱ្យស្មើៗគ្នា'។ សូមមើលកាព្យលេខ១១៦ (មេធ., កុល្ល., នារ., រាឃ.)។ លោកមេធ. និយាយថា 'អ្នកខ្លះ'ប្រកាសថា វិធានច្បាប់ស្តីពីការបែងចែកមិនស្មើគ្នា សំដៅដល់ពេលអតីតកាល ហើយគ្មានអំណាចសម្រាប់ *កលិយុគ* នេះទេ។ ប៉ុន្តែលោកច្រានចោលទស្សនៈនេះ។

**១១៣.** កម្មវត្ថុកាព្យនេះ ចង់បង្ហាញថា គ្មានភាពខុសគ្នារវាងកូនប្រុសនានា ពាក់ព័ន្ធរឿងអាយុបងគេ និងប្អូនគេទេ ទោះជាចំណែករបស់ពួកគេបានច្រើនយ៉ាងណាក៏ដោយ(កុល្ល., រាឃ.)។

**១១៤.** គោត.ជំពូក២៨ លេខ១១-១៣; ពោធ. ជំពូក២ លេខ៣, ៦។'(សូម្បីចលនទ្រព្យតែមួយ)ដែលនៅល្អ' គឺ 'សម្លៀកបំពាក់ឬគ្រឿងលម្អ'(មេធ.) ឬ 'អ្វីៗដែលលំអៀងដូចជារូបតាង'(នន្ទ.)។ 'សត្វល្អៗបំផុតដប់' យោងតាមគោត. ជំពូក២៨ លេខ១២ ថា លោកកុល្ល., នារ., រាឃ. មានប្រសាសន៍ដូច្នេះ គឺពួកគាត់អាន *ទសតះ បសូនាំ* ជំនួស *ទសតំ*។ លោក មេធ. ធ្វើការបកស្រាយដូចគ្នា ប៉ុន្តែប្រើវិធាននេះដែរសម្រាប់សម្លៀកបំពាក់ និងគ្រឿងលម្អ។ គាត់បន្ថែមថា 'អ្នកខ្លះទៀត' បកស្រាយអត្ថបទនេះ ស្របតាមវស. ជំពូក១៧ លេខ៤៣។ 'ហើយមួយភាគដប់(នៃសត្វគោ ក្របីនិងសេះ'។ លោកនន្ទ. ទំនងជាស្របតាមមតិរបស់លោកមេធ. ព្រោះគាត់និយាយថា គេនឹងចែកអ្វីៗជាដប់ចំណែក ហើយបងបង្អស់នឹងទទួលបានលើសមួយចំណែក។ អ្នកអធិប្បាយទាំងអស់យល់ស្របថា ចំណែកបន្ថែមនេះជារបស់បងប្រុសច្បងគេប៉ុណ្ណោះ បើសិនជាគាត់មានគុណសម្បត្តិល្អពិសេស ហើយអ្នកដទៃមានលក្ខណៈសម្បត្តិអន់ជាងគាត់។

**១១៥.** អាប. ជំពូក២ លេខ១៣, ១៣។ 'ការកាន់កាប់របស់ពួកគេ' គឺ 'សូត្រព្រះវេទជាដើម'(កុល្ល., រាឃ.)។ តាមលោកនារ. ឃ្លាថា 'គ្មានចំណែកបន្ថែម(មានសត្វល្អបំផុតក្នុងចំណោមដប់' បង្ហាញថា កាព្យលេខ១១៤ មិននិយាយពីចំណែកបន្ថែមទេ។ លោកនន្ទ. លុបចោលកាព្យនេះ។

១១៦-ដូច្នេះ បើសិនជាគេដកចំណែកបន្ថែមចេញ គេត្រូវតែចែកចំណែកស្មើគ្នា (ក្នុងចំណោមរបស់នៅសល់សម្រាប់ម្នាក់ៗ) ប៉ុន្តែបើសិនជាការដកបែបនេះ ការបែងចែកចំណែកក្នុងចំណោម ពួកគេ ត្រូវធ្វើតាមរបៀបតទៅ។

១១៧-ចូរកូនប្រុសបង្អស់យកមួយចំណែកលើស (បងប្រុស)បន្ទាប់បងបង្អស់ បានមួយចំណែកកន្លះ ប្អូនបន្ទាប់ បានមួយចំណែកម្នាក់ ពោលគឺច្បាប់កំណត់ដូច្នេះ។

១១៨-ប៉ុន្តែសម្រាប់(ប្អូនស្រី)ក្រមុំ បងប្អូនប្រុសម្នាក់ៗនឹងផ្តល់(ចំណែក) ក្រៅពីចំណែករបស់ខ្លួនម្នាក់ៗបានចំណែកមួយភាគបួន ហើយអ្នកដែលមិនព្រមផ្តល់(ចំណែកនោះ) នឹងក្លាយជាមនុស្សក្រៅវណ្ណៈ។

១១៩- ចូរគាត់កុំចែក (តម្លៃ) សត្វពពែ ឬចៀមតែមួយ ឬ (សត្វតិរច្ឆានមួយ)ដែលក្រចកគ្មានទ្រនាប់ ហើយតាមបញ្ញត្តិគឺ (ថា) ពពែឬចៀមតែមួយ (ដែលនៅសល់ពីការចែកស្មើៗគ្នាជារបស់)បងបង្អស់ប៉ុណ្ណោះ។

---

**១១៦.** គោត. ជំពូក២៨ លេខ៨។

**១១៧.** គោត. ជំពូក២៨ លេខ៩-១០; វស. ជំពូក១៧ លេខ៤២។ 'មួយចំណែកលើស' គឺ 'ពីរចំណែក'(មេធ., កុល្លូ., នារ., រាឃ., នន្ទ.)។ ប្អូននាក់ក្រោយគួសបញ្ជាក់ថា ការបែងចែកបែបនេះធ្វើឡើង នៅពេលដែលបងបង្អស់ និងបងទីពីរ មានឧត្តមភាពជាងអ្នកដទៃទៀត។

**១១៨.** វិ. ជំពូក១៨ លេខ៣៥; យញ្ញ. ជំពូក២ លេខ១២៤។ យោងតាមអ្នកអធិប្បាយ អត្ថន័យគឺថា បើសិនជាបុរសម្នាក់ចុះចោលកូន ដោយសារភរិយាមានវណ្ណៈខុសគ្នា បងប្អូនប្រុសគឺត្រូវផ្តល់បណ្ណាការរបស់ប្អូនស្រីវណ្ណៈដូចគ្នា ដែលមិនទាន់រៀបការ គឺ កូនប្រុសរបស់ព្រាហ្មណ៍ ជាមួយភរិយាព្រាហ្មណ៍ ឱ្យកូនស្រីរបស់អ្នកក្រោយ ហើយកូនរបស់ភរិយាក្សត្រិយឱ្យកូនស្រីរបស់អ្នកក្រោយនេះជាដើម។ ន័យនេះ មានបញ្ជាក់ច្បាស់ជាងនៅក្នុងអំណានរបស់លោកមេធ. *ស្វាត្យះ ស្វាត្យ តុកន្យាភ:*ប៉ុន្តែបងប្អូនប្រុសនឹងផ្តល់(ចំណែក)ដល់(ប្អូនស្រី)ក្រមុំ ម្នាក់ៗស្របតាមឋានៈរបស់ខ្លួនផ្ទាល់'។ លោកកុល្លូ. បន្ថែមថា ករណីយកិច្ចចិញ្ចឹមប្អូនស្រី ឧទាហរណ៍ទីមួយ គឺប្រគល់អំណាចដល់បងប្អូនប្រុសបង្កើត និងបងប្អូនប្រុសម្តាយឬឪពុកផ្សេងគ្នា។

បើនិយាយពីសំនួនពាក្យ 'ចំណែកមួយភាគបួន' លោកមេធ.និយាយថា បងប្អូនប្រុសនឹងទទួលបានបីភាគបួន ហើយបងប្អូនស្រី បានមួយភាគបួន ហើយថា បើមានបងប្អូនស្រីច្រើន ពួកគេនឹងទទួលបានមួយភាគបួននៃចំណែករបស់បងប្អូនប្រុសដែលមានវណ្ណៈស្មើគ្នា។ លោកកុល្លូ. យល់ស្របតាមការបកស្រាយផ្នែកទីមួយ តែបន្ថែមថា 'ដូច្នេះគេត្រូវយល់ថា ថ្វីបើមានបងប្អូនប្រុស និងស្រីដែលមានវណ្ណៈដូចគ្នាច្រើន ប៉ុន្តែកើតពីម្តាយផ្សេងគ្នា ចំណែកមួយភាគបួនត្រូវតែឱ្យទៅបងប្អូនស្រីបង្កើត'(គឺដោយបងប្អូនប្រុសបង្កើតរបស់ពួកគេ)។ លោកនារ. ថា 'ពួកគេនឹងឱ្យមួយភាគបួន នៃចំណែករបស់ពួកគេ និងយកបីចំណែក ហើយគេធ្វើការបែងចែកបែបនេះដូចគ្នា បើសិនជាមានបងប្អូនស្រីច្រើន។ ប៉ុន្តែបើសិនជាមានកូនប្រុសច្រើន និងកូនស្រីមួយ ពួកគេត្រូវដកពីចំណែកជាច្រើនរបស់ពួកគេ ជាថវិកាឱ្យច្រើនស្មើនឹងមួយភាគបួននៃចំណែករបស់បងប្អូនប្រុសម្នាក់ ហើយឱ្យទៅកូននោះ'។ លោកមេធ.ទិតៀនអ្នកអធិប្បាយទាំងអស់ ដែលគិតថា ចំណែកមួយភាគបួន គេមិនចាំបាច់ឱ្យទៅតាមជាក់ស្តែង ប៉ុន្តែគ្រាន់តែឱ្យមួយគ្រប់គ្រាន់សម្រាប់ចំណាយរៀបអាពាហ៍ពិពាហ៍ ប៉ុណ្ណោះ។

**១១៩.** ពោលគឺ គេមិនអាចលក់សត្វប្រភេទនេះទេ ហើយរបស់ផ្សេងទៀតត្រូវបែងចែក ហើយបងប្អូនប្រុសដទៃ មិនត្រូវផ្តល់តម្លៃខ្ពស់ ដោយផ្តល់វត្ថុផ្សេងដល់ពួកគេទេ(មេធ., កុល្លូ., នារ., រាឃ.)។

**១២០.** គឺ ក្សេត្រជៈ មិនបានចំណែកពិសេសទេ ដូចឪពុករបស់គាត់បានធ្វើនោះទេ។ លោកកុល្លូ. ទាញយោបល់ពីកាព្យនេះថា ទោះបីមានកាព្យលេខ១០៤ខាងលើក្តី ក៏បងប្អូនប្រុស(គឺកូនប្រុសរបស់សព) មានរៀបរាប់ឈ្មោះប៉ុណ្ណោះ ព្រមទាំងចៅប្រុសនឹងទទួលមរតក យោងតាមមនុ ដូចកូនប្រុស និងជាមួយកូនប្រុសដែរ។ សូមមើលកាព្យ១៨៦ខាងក្រោម។

១២០- ប្រសិនបើប្អូនប្រុសមានកូនប្រុសជាមួយប្រពន្ធរបស់បង ដូចនេះការបែងចែកត្រូវឱ្យស្មើគ្នា នេះជាច្បាប់បញ្ញត្តិ។

១២១- តំណាង (កូនប្រុសដែលកើតជាមួយភរិយា)មិនត្រូវបានសិទ្ធិរៀមច្បង(បងបង្អស់ បានចំណែកបន្ថែម) ហើយរៀមច្បង (ក្លាយជា)ឪពុកក្នុងការបង្កើតកូន(របស់ប្អូនប្រុសខ្លួន) ហេតុនេះគាត់នឹងផ្តល់មួយចំណែកដល់ (កូនប្រុស ដែលកើតពីភរិយារបស់បងប្រុស) ស្របតាមវិធានច្បាប់ (ដូចបញ្ជាក់ជូនខាងលើ)។

១២២- ប្រសិនបើនៅមានមន្ទិលសង្ស័យថាតើគួរបែងចែករបៀបណានោះ ក្នុងករណីកូនប្រុសប្អូន កើតពីភរិយារៀមច្បង និងកូនប្រុសរៀមច្បងរបស់ភរិយាប្អូន,

១២៣-(ដូច្នេះ កូនប្រុស)ដែលកើតពីភរិយាទីមួយ នឹងបានចំណែកបន្ថែមរបស់ខ្លួន ជា(គោឡើងកល្អបំផុត) ហើយគោឡើងកល្អបន្ទាប់(នឹងបានទៅ)អ្នកបន្ទាប់ ដែលជាកូនរបស់ម្តាយខ្លួន។

១២៤-ប៉ុន្តែ(កូនប្រុស)ច្បងបង្អស់ ដែលកើតពីភរិយាច្បងគេ នឹងទទួលបានមេគោដប់ប្រាំ គោឈ្មោលមួយ ដូចនេះកូនប្រុសផ្សេងអាចទទួលចំណែកស្របតាមវ័យចំណាស់របស់ម្តាយខ្លួន នេះជាវិធាន ច្បាប់បញ្ញត្តិ។

១២៥-ក្នុងចំណោមកូនប្រុសដែលកើតពីភរិយាវណ្ណៈស្មើគ្នា (និង)ដោយគ្មានខុសគ្នាពីវ័យរបស់ម្តាយផងនោះ គេប្រកាសថាភាពចំណាស់ គឺអាស្រ័យលើកំណើត។

---

**១២១.** លោកកុល្ល. បញ្ជាក់ដូច្នេះ ហើយលោកនន្ទ. យល់ស្របតាមកាព្យពាក់កណ្តាលទីមួយ ប៉ុន្តែផ្តល់ការបកស្រាយទីពីរថា 'ឪពុកជារៀមច្បង ក្នុងការបង្កើតកូនៗ ហេតុនេះគេត្រូវតែផ្តល់មួយចំណែកដល់(កូនប្រុសដែលកើតនឹងភរិយារបស់បងបង្អស់) ស្របតាមច្បាប់(បញ្ញត្តិខាងលើ)។' លោកនារ. ក៏យល់ផ្សេងដែរ។ '(កូនប្រុស)បន្តបន្ទាប់ តាមច្បាប់មិនបានទទួលឋានៈជារៀមច្បងទេ (ហើយក្នុងហេតុផលនេះ មិនអាចទទួលចំណែកបន្ថែមទេ ពោលគឺឪពុករបស់ខ្លួន (បងបង្អស់គឺ)រៀមច្បងក្នុងការបន្តត្រកូល ហេតុនេះគេនឹងផ្តល់មួយចំណែក(ដល់កូនបន្ទាប់របស់គាត់) ស្របតាមច្បាប់'។ លោករាឃ. បន្តទៀតថា 'រៀមច្បង (បងបង្អស់)តាមច្បាប់ មិនត្រូវចាត់ទុកដូចជាអ្នកជំនួសទេ (គឺមិនត្រូវគេ ដកចំណែកបន្ថែមទេ តែដោយសារ) ឪពុកជាមនុស្សសំខាន់ក្នុងការបង្កើត(កូន) គេគួរផ្តល់មួយចំណែកដល់ (កូនប្រុសរបស់ភរិយា) តាមច្បាប់ (ដែលអនុវត្តចំពោះឪពុកពិតរបស់ខ្លួន)'។ លោកមេធ. មានការបកស្រាយប្រហាក់ ប្រហែលគ្នាថា '(ការនិយាយ)ថា អ្នកជំនួស(គឺ ក្សេត្រជៈ) ស្មើនឹងរៀមច្បង គឺមិនស្របតាមច្បាប់ពិសិដ្ឋទេ ហើយឪពុក(គឺអ្នកផ្តល់កំណើត) ជារៀមច្បងក្នុងការផ្តល់កំណើតកូន ហេតុនេះគេត្រូវផ្តល់មួយចំណែក(ដល់ក្សេត្រជៈ) ស្របតាម(ច្បាប់ដែលបានបញ្ញត្តិខាងលើ)'។

**១២២.** ទស្សនៈដែលត្រូវសម្រេច គឺថា ប្រសិនបើរៀមច្បង ជាម្តាយជាមួយឬតាមកំណើតជាក់ស្តែង។ ភរិយារៀមច្បងបង្អស់ ការពិតជាស្ត្រីដែលបានរៀបការទីមួយ។

**១២៣.** គោត. ជំពូក២៨ លេខ១៤។

**១២៤.** គោត. ជំពូក២៨ លេខ១៥។ 'អាចបានចំណែក' គឺ 'អាចចែកមេគោ(ផ្សេងទៀត)'(មេធ., កុល្ល.) ឬ 'ម្នាក់ៗនឹងបានទទួលគោឈ្មោលមួយ គោល្អណាស់មួយ គោមិនសូវល្អអស្ចារ្យមួយ តាមលំដាប់ស្របតាមវ័យចំណាស់របស់ម្តាយខ្លួន' (នារ.)។

**១២៥.** ដូចកាព្យនេះ និងកាព្យបន្តបន្ទាប់ដែរ គឺជាវិធានដែលផ្ទុយនឹងកាព្យលេខ១២៣-១២៤។ អ្នកអធិប្បាយព្យាយាមកាព្យទាំងនេះតាមរបៀបនានា។ លោកមេធ. គិតថា កាព្យលេខ១២៣-១២៤ គឺអាចំរាទ ហើយគ្មានកម្លាំងផ្លូវច្បាប់ទេ។ លោករាឃ. បដិសេធយោបល់ដូចគ្នានេះ។ លោកនារ. និងនន្ទ. អះអាងថា វ័យចំណាស់អាស្រ័យលើអាពាហ៍ពិពាហ៍របស់

១២៦-ហើយបើនិយាយពី(អត្ថបទ)សាខាព្រាហ្មណ៍ គេកត់ត្រាថាកូនភ្លោះទីមួយ ត្រូវធ្វើការបន់ស្រន់(ព្រះឥន្ទ្រ)ម្តង នៅពេលចាប់កំណើតក្នុងគភ៌(ម្តាយរបស់ខ្លួន) ភាពរៀមច្បងត្រូវប្រកាស(អាស្រ័យលើ)កំណើតជាក់ស្តែង។

១២៧-អ្នកដែលគ្មានកូនប្រុស អាចយកកូនស្រីរបស់ខ្លួនធ្វើជាកូនស្រីតាមការកំណត់ តាមរបៀបដូចខាងក្រោម (បុត្រិកា ដោយនិយាយទៅកាន់ស្វាមីខ្លួន) 'កូន(ប្រុស) ដែលកើតពីរូបនាង នឹងធ្វើបុណ្យសពរបស់ខ្ញុំ'។

១២៨-យោងតាមវិធាននេះ ទក្សៈ ព្រះបង្កើតសត្វលោក ដំបូងបានបង្កើត(កូនស្រីរបស់ទ្រង់ទាំងអស់) កូនស្រីតាមការកំណត់ ដើម្បីបង្កើតពូជរបស់ទ្រង់។

១២៩- ទ្រង់បានប្រទានដប់ដល់ធម៌ ដប់បីសម្រាប់កស្សបៈ ម្ភៃដល់ព្រះរាជាសោមៈ ដោយផ្តល់កិត្តិយស (ពួកគេ)ដោយការគាប់ព្រះទ័យ។

១៣០-កូនប្រុស សូម្បីខ្លួនឯងក៏ដោយ (ដូច្នេះ)កូនស្រីគឺស្មើនឹងកូនប្រុស តើ(ទាយាទ)ផ្សេងទៀតអាចទទួលទ្រព្យរបៀបណា ចំណែកឯ(កូនស្រីតាមការកំណត់ដែល)ខ្លួនឯង នៅមានជីវិតនៅឡើយ យ៉ាងម៉េចដែរ?។

១៣១-ប៉ុន្តែអ្វីដែលជាទ្រព្យដោយឡែករបស់ម្តាយ គឺជាចំណែករបស់កូនស្រីដែលមិនទាន់រៀបការប៉ុណ្ណោះ ហើយកូនប្រុសរបស់កូនស្រី (តាមការកំណត់) នឹងទទួលទ្រព្យទាំងអស់របស់ (កូនស្រី ខាងម្តាយរបស់គាត់) ដែលគ្មានកូនប្រុស។

---

ម្តាយ មានសារៈសំខាន់សម្រាប់ច្បាប់មរតក (កាព្យលេខ១២៣-១២៤) ប៉ុន្តែថា វាគ្មានតម្លៃសម្រាប់ការគោរពវន្ទា ឬមានបុព្វសិទ្ធិផ្តាច់មុខក្នុងពិធីយញ្ញ(កាព្យលេខ១២៥-១២៦)ទេ។ លោកកុល្ល. ចុងក្រោយដោយផ្អែកលើយោបល់របស់លោកគោវ. គិតថា វិធានច្បាប់ផ្តល់នូវជម្រើស ហើយការអនុវត្តអាស្រ័យលើលក្ខណៈសម្បត្តិល្អ និងកង្វះខាតលក្ខណៈនេះ។ យ៉ាងណាមិញ អាចនិយាយបានថា យោងតាមទំនៀមទម្លាប់របស់អ្នកនិពន្ធហិណ្ឌូ មតិពីរផ្ទុយគ្នាគឺប្រកាន់ម្ខាងៗ ហើយក្នុងបំណងថា អ្នកចេះដឹងគួរស្វែងរកវិធីដោះស្រាយបញ្ហាលំបាក ដែលពួកគេជួបប្រទះ។

**១២៦.** អត្ថបទសាខាព្រាហ្មណ៍ មានការអញ្ជើញដែលសំដៅដល់ព្រះឥន្ទ្រ ឱ្យចូលរួមជាមួយព្រះសោមៈ។ សូមមើលអៃតរេយព្រាហ្មណ៍ ជំពូក៦ លេខ៣។ លោកនន្ទ. អាន *យមឃោស ចៃកគរកេ បិ*។

**១២៧.** គោត. ជំពូក២៨ លេខ១៨; វស. ជំពូក១៧ លេខ១៧; ពោធ. ជំពូក២ លេខ៣, ១៥; វិ. ជំពូក១៥ លេខ៥។

**១២៨.** រឿងកូនស្រីហាបសិប ហុកសិប ឬម្ភៃបួន របស់*ទក្ស:* មាននៅក្នុងមហាភារតៈ និងបុរាណៈ។ ម្ភៃប្រាំពីរដែលថ្វាយទៅស្តេចសោមៈ ព្រះច័ន្ទ គឺវិមានព្រះច័ន្ទ ឬ*នក្សត្រ*។

**១៣០.** ‘កូនប្រុស សូម្បីខ្លួនឯងក៏ដោយ’ សូមមើលកាព្យដកស្រង់ ពោធ.ជំពូក២ លេខ៣, ១៤។ អ្នកអធិប្បាយអះអាងថា ពាក្យ *ទុហិតា*កូនស្រី’ នៅទីនេះមានន័យ *បុត្រិកា*កូនស្រីតាមការព្រមព្រៀង’។ លោកមេធ. បន្ថែមថា យោងតាមកាព្យនេះ កូនស្រីតាមការព្រមព្រៀងដែលគ្មានកូនប្រុស ពេលឪពុកនាងស្លាប់ទៅ មិនបានទទួលមរតករបស់គាត់(?)ទេ។

**១៣១.** គោត. ជំពូក២៨ លេខ២៤; វិ. ជំពូក២៧ លេខ២១។ ការកែតម្រូវអត្ថបទបកប្រែពាក្យ *យោតកំ*ទ្រព្យដោយឡែក’ (មេធ.) យកតាមកាព្យលេខ២១៤ ខាងក្រោម ដើម្បីកំណត់ពីទ្រព្យដោយឡែករបស់បងប្រុស។ តាមលោកមេធ., កុល្ល. និងនារ. សុទ្ធតែឱ្យន័យ *ស្ត្រីធន* ហើយតាម ‘អ្នកផ្សេង’ ដែលលោកមេធ., នន្ទ. និងរាឃ.លើកឡើង គឺ *សោទាយិកំ* ឬ ទ្រព្យដែលបានពីគ្រួសាររបស់ឪពុក។ កុមារី ‘ក្មេងស្រីដែលមិនទាន់រៀបការ’(មេធ., កុល្ល.) តាមលោកនារ. គឺ ‘កូនស្រីដែលគ្មានកូនប្រុស’។ *ទោហិតៈ* ន័យត្រង់ ‘កូនប្រុសរបស់កូនស្រី’ តាមអ្នកអធិប្បាយគឺ ‘កូនប្រុសរបស់កូនស្រីតាម ការព្រមព្រៀង’

១៣២-កូនប្រុសរបស់កូនស្រី(តាមការកំណត់) តាមពិត(ក៏)នឹងទទួលទ្រព្យរបស់ឪពុកខ្លួន(ផ្ទាល់) ដែលគ្មានកូនប្រុស (ផ្សេង) (ដូច្នេះ) គាត់នឹងផ្តល់នំបុណ្យសពពីរសម្រាប់ឪពុករបស់ខ្លួនផ្ទាល់ និងសម្រាប់ជីតាខាងម្តាយរបស់ខ្លួន។

១៣៣- រវាងកូនប្រុសរបស់កូនប្រុស និងកូនប្រុសរបស់កូនស្រី(តាមការកំណត់) គ្មានភាពខុសគ្នា មិនពាក់ព័ន្ធបញ្ហាលោកិយ និងមិនពាក់ព័ន្ធករណីយកិច្ចពិសិដ្ឋទេ ព្រោះឪពុកនិងម្តាយរបស់ពួកគេទាំងពីរកើតចេញពីកាយរបស់បុរសតែមួយ។

១៣៤- ប៉ុន្តែបន្ទាប់ពីកូនស្រីកើតតាមការព្រមព្រៀង បើកូនប្រុសកើតពី(ឪពុករបស់នាង)ការបែងចែក (មរតក) ក្នុងករណីនេះ ត្រូវតែចែកស្មើគ្នា ព្រោះស្ត្រីគ្មានសិទ្ធិភាពជាច្បងទេ។

១៣៥- ប៉ុន្តែបើកូនស្រីតាមការព្រមព្រៀងស្លាប់ដោយចៃដន្យ ដោយគ្មាន(សល់)កូនប្រុស ប្ដីរបស់កូនស្រីតាមការព្រមព្រៀងនោះ អាចទទួលទ្រព្យនោះបាន ដោយគ្មានស្ទាក់ស្ទើរ។

១៣៦- តាមរយៈកូនប្រុសដែល(កូនស្រី) ទោះជាមិនតាមការព្រមព្រៀងក្ដី ឬតាមការព្រមព្រៀងក្ដី អាចមាន(ប្ដី)ដែលមានវណ្ណៈស្មើគ្នា ជីតាខាងម្ដាយរបស់គាត់ (មាន)កូនប្រុសរបស់កូនប្រុស ហើយគាត់នឹងជូននំបុណ្យសព និងទទួលទ្រព្យមរតក។

---

*បុត្រិកាបុត្រៈ*។ វិធានទីមួយ តាមលោកកុល្ល., នារ. និងនន្ទ. គឺជាភាសិតទូទៅ ដែលមិនសំដៅដល់ករណីរបស់បុត្រិកា ទេ។ វិធានទីពីរ តាមលោកនន្ទ. បង្ហាញថា កូនស្រីតាមការព្រមព្រៀង មិនបានទទួលទ្រព្យរបស់ឪពុកនាងដោយផ្ទាល់ទេ បើសិនជានាងគ្មានកូនប្រុស។

**១៣២.** លោកមេធ. លើកឡើងនូវសំណេរផ្សេង *អនុត្រស្យ ហរេទ យទិ*ប្រសិនបើកូនប្រុសរបស់កូនស្រី(តាមការព្រមព្រៀងទទួលបានទ្រព្យទាំងមូលរបស់(ជីតាខាងឪពុកខ្លួន)ជាដើម' ដែលមាននៅក្នុងអត្ថបទរបស់លោកគោវ. ប៉ុន្តែគិតថាខុស។

**១៣៣.** យញ្ញ. ជំពូក២ លេខ១២៨។ *លោកេ ធម៌តៈ* 'មិនពាក់ព័ន្ធកិច្ចការលោកិយ និងមិនពាក់ព័ន្ធករណីយកិច្ចពិសិដ្ឋ' (កុល្ល.) តាមលោករាឃ. និងនន្ទ. គឺថា 'និយាយពីករណីយកិច្ចពិសិដ្ឋ ស្របតាមច្បាប់'។

**១៣៥.** 'ទ្រព្យនោះ' គឺ 'អ្វីដែលកូនស្រីតាមការព្រមព្រៀងទទួលបានពីឪពុករបស់នាង ក្នុងអំឡុងពេលគាត់នៅរស់ក៏បាន ឬបន្ទាប់ពីគាត់ស្លាប់ក៏បាន'(នារ.)។ លោកកុល្ល. បន្ថែមថា កាព្យនេះសំដៅហាមឃាត់ឪពុក មិនឱ្យទទួលទ្រព្យមរតករបស់កូនស្រីដែលស្លាប់ទៅមុន តាមសំអាងថា នាងគឺដូចជាកូនប្រុស(សូមមើលកាព្យ១៨៥)។ លោកនន្ទ. និយាយថា អំខាងឪពុកជាដើម នឹងមិនទទួលទ្រព្យរបស់បុត្រិកាទេ។

**១៣៦.** លោកកុល្ល. បកស្រាយ *អក្ឫតា វាបិ* ថា '(កូនស្រី) ទោះជាមិនដោយការព្រមព្រៀង (ប៉ុន្តែប្រាកដជា ដោយការបម្រុងទុកខាងផ្លូវចិត្ត) ឬដោយការព្រមព្រៀងក៏ដោយ (ប្រាកដណាស់ គឺដោយការភ្ជាប់ពាក្យ យោងតាមកាព្យលេខ ២៧)'។ លោកបន្ថែមថា លោកគោវ. ប្រែពាក្យ *អក្ឫតា* តាមន័យធម្មតារបស់វា ហើយអះអាងថា កាព្យនេះអនុញ្ញាតឱ្យកូនប្រុសរបស់កូនស្រីដែលមិនដោយការព្រមព្រៀង អាចទទួលទ្រព្យមរតករបស់ជីតាខាងម្ដាយខ្លួនបាន។ លោកនារ.លើកឡើងនូវមតិក្រោយនេះ លោកក៏និយាយថា កូនប្រុសរបស់កូនស្រីដែលមិនដោយការព្រមព្រៀងទទួលមរតក បើគ្មានប្រពន្ធឬកូនស្រីរបស់ជីតារបស់ខ្លួន ហើយលោកនន្ទ., រាឃ. និងមេធ. ព្រមទាំងលោកកុល្ល. ធ្វើការបកស្រាយដែលមានការគាំទ្រដោយ គោត.ជំពូក២៨ លេខ២០ និងវិ. ជំពូក១៥ លេខ៦។ សេចក្ដីក្រោយនេះ បញ្ជាក់ច្បាស់ថា កូនស្រីរបស់បុរសដែលគ្មានកូនប្រុស គឺជាទូទៅ 'កូនស្រីតាមការព្រមព្រៀង'។

១៣៧- តាមរយៈកូនប្រុស គាត់ទទួលបានលោកទាំងឡាយ តាមកូនប្រុសរបស់កូនប្រុស គាត់ទទួលបានភាពអមតៈ ប៉ុន្តែតាមរយៈចៅប្រុសរបស់កូនប្រុសខ្លួន គាត់បានឡើងឋានព្រះអាទិត្យ។

១៣៨- ព្រោះកូនប្រុសដោះលែងឪពុករបស់ខ្លួន(ត្រាយតេ) ពីឋាននរកឈ្មោះ *បុត* ហេតុនេះគេហៅគាត់ថា*បុត្រ*អ្នកដោះលែងពីឋាន*បុត* ដោយព្រះស្វយម្ភូដោយផ្ទាល់។

១៣៩- ក្នុងចំណោមកូនប្រុសរបស់កូនប្រុស និងកូនប្រុសរបស់កូនស្រី គ្មានភាពខុសគ្នាទេនៅក្នុងលោកិយនេះ ព្រោះសូម្បីកូនប្រុសរបស់កូនស្រី ជួយសង្គ្រោះអ្នក(ដែលគ្មានកូនប្រុស) នៅក្នុងជាតិក្រោយ ដូចកូនប្រុសរបស់កូនប្រុសដែរ។

១៤០- ចូរកូនប្រុសរបស់កូនស្រីតាមការព្រមព្រៀង ទីមួយផ្ដល់នំបុណ្យសពដល់ម្ដាយរបស់ខ្លួន ទីពីរផ្ដល់ជូនឪពុករបស់ខ្លួន ទីបីជូនឪពុករបស់ឪពុកខ្លួន។

១៤១- ក្នុងចំណោមបុរស ដែលមានកូនប្រុស(ទត្រិម)ចិញ្ចឹម ដែលមានលក្ខណៈសម្បត្តិល្អគ្រប់យ៉ាង (កូនប្រុស)ដដែលនេះនឹងទទួលមរតក ទោះជាទិញពីគ្រួសារផ្សេងក៏ដោយ។

១៤២- កូនចិញ្ចឹម នឹងមិនយក(ឈ្មោះ)ត្រកូល និងទ្រព្យពីឪពុកបង្កើតរបស់ខ្លួន ហើយនំបុណ្យសព យកតាម (ឈ្មោះ) ត្រកូលនិងទ្រព្យ ការបូជាបុណ្យសពរបស់អ្នកដែលលែងមាន(កូនប្រុស ចិញ្ចឹម ដរាបណាដល់មានកូនប្រុស)។

---

**១៣៧.** វស. ជំពូក១៧ លេខ៥; វិ. ជំពូក១៥ លេខ៤៦; យញ្ញ. ជំពូក១ លេខ៧៨។ 'លោកទាំងឡាយ' គឺ 'ដប់ ដែលគេហៅថា វិសោក (រួចពីទុក្ខសោក) ទីមួយគឺ*ស្វគ*(មេធ.)។ 'ភាពអមតៈ គឺ ការរស់នៅបានយ៉ាងយូរ ក្នុង(លោក) តែមួយ' (មេធ., កុល្លូ.)។ 'ព្រះអាទិទ្យ' គឺ 'ហិរណ្យគរភ'(នារ.)។ កាព្យនេះបង្ហាញថា កូនប្រុស និងចៅប្រុសទទួលមរតក ទោះជាភរិយា និងអ្នកផ្សេងទៀត ឱ្យតែនៅរស់(កុល្លូ.)។

**១៣៨.** វិ. ជំពូក១៥ លេខ៤៤។

**១៣៩.** វិ. ជំពូក១៥ លេខ៤៧។ តាមលោកមេធ. និងកុល្លូ. *ទោហិត្រះ*កូនប្រុសរបស់កូនស្រី' ទីនេះក៏មានន័យថា 'កូនប្រុសរបស់កូនស្រីតាមការព្រមព្រៀង'។ លោកនន្ទ. អាន *បុត្រវ័ត*ដូចកូនប្រុស' ហើយគោវ. ថា *បូរវជាន*(និង)ជូនតា'។

**១៤០.** ពោធ. ជំពូក២ លេខ៣, ១៦។ លោកមេធ. សរសេរសំណេរផ្សេង *បិតុ តស្យ*ទីពីរជូនឪពុករបស់ខ្លួន' ដែលយ៉ាងណាមិញ គាត់ចាត់ទុកថាមិនល្អ។

**១៤១.** វស. ជំពូក១៥ លេខ៩-១០; ពោធ. បរិសិស្ត លេខ១៦។ លោកមេធ., កុល្លូ. និងរាឃ. បញ្ជាក់វិធាននេះ សំដៅដល់ករណីដែលបុរសមានកូនប្រុសស្របច្បាប់ និងកូនប្រុសចិញ្ចឹម ហើយគិតថា ក្នុងករណីបែបនេះ អ្នកក្រោយ ដែលមានគុណធម៌វិសេសវិសាល នឹងទទួលដូចក្សេត្រជៈ ដែរ(សូមមើលកាព្យលេខ១៤៦) គឺចំណែកទីប្រាំ ឬទីប្រាំមួយនៃទ្រព្យនោះ។ លោកមេធ.កត់សម្គាល់ថា អ្នកខ្លះគិតថា គាត់ត្រូវបានពាក់កណ្តាល ប៉ុន្តែថា មតិរបស់ពួកគេមិនសមស្របទេ ហើយទីបំផុតថា *ឧបាធ្យាយ* គឺ គ្រូបាធ្យាយរបស់ខ្លួន ចែកឱ្យកូនប្រុសចិញ្ចឹមតិចជាងក្សេត្រជៈ។ លោកកុល្លូ. និងរាឃ. អះអាងថា លោកគោវ.ប្រែកាព្យនេះក្នុងន័យថា កូនប្រុសចិញ្ចឹមមានគុណធម៌វិសេសវិសាល នឹងទទួលមរតក បើគ្មានកូនប្រុសស្របច្បាប់ និងកូនប្រុសរបស់ភរិយា ប៉ុន្តែថា ការបកស្រាយនេះ មិនអាចទទួលយកបានទេ បើនិយាយពីកាព្យលេខ១៦៥។ យ៉ាងណាមិញ លោករាឃ. លើកឡើងនូវមតិរបស់លោកគោវ.។ លោកនារ. និយាយថា 'គេបានប្រកាសថា កូនប្រុសចិញ្ចឹមទទួលមួយចំណែក ដូចកូនប្រុសសំខាន់ បើសិនជាគេមានគុណសម្បត្តិល្អខ្លាំង'។ លោកនន្ទ. អានចុងបន្ទាត់ទីពីរ *សំប្រាប្តោ ស្យ ន បុត្រកះ*'នឹងទទួលមរតក (ព្រោះថា)ឪពុកចិញ្ចឹមគ្មានកូនប្រុស។'

**១៤២.** លោកមេធ. លើកឡើងនូវការបកស្រាយមិនសមស្របមួយទៀត ដែលថា *ហរេត*'នឹងទទួល' គឺសំដៅដល់ *ហារយេ*

១៤៣- កូនប្រុសរបស់ភរិយា មិនដោយការព្រមព្រៀង(មានកូនជាមួយម្នាក់ទៀត) ហើយអ្នកដែល (ស្ត្រីកំណត់ជាស្រេច)ម្តាយរបស់កូនប្រុស មានបងប្អូនថ្លៃរបស់ខ្លួន ទាំងពីរនាក់មិនសមមានចំណែក (ម្នាក់ជា)កូនប្រុសរបស់អ្នកផិតក្បត់ប្តី ហើយម្នាក់ទៀត កើតឡើងដោយសារតម្រេកតណ្ហា(ប៉ុណ្ណោះ)។

១៤៤- សូម្បីតែជា (កូន) ប្រុសរបស់ស្ត្រី តាមការព្រមព្រៀង (ត្រឹមត្រូវ) មិនផ្តល់កំណើតតាមវិធាន (កំណត់ខាងលើ)ក៏ដោយ ក៏មិនសមនឹងទទួលទ្រព្យខាងឪពុកដែរ ព្រោះគាត់ត្រូវបានបង្កើតដោយអ្នកនៅក្រៅវណ្ណៈ។

១៤៥- កូនប្រុសដែលចាប់កំណើត (ស្របច្បាប់) ពីស្ត្រីតាមការព្រមព្រៀង នឹងទទួលមរតក ដូចកូនប្រុសស្របច្បាប់របស់សពដែរ ព្រោះពូជនោះ និងផលកើតឡើង តាមច្បាប់ គឺជារបស់ម្ចាស់ដី។

១៤៦- អ្នកដែលថែទាំងទ្រព្យរបស់បងប្អូនប្រុសរបស់ខ្លួនដែលទទួលមរណភាព និងរបស់ស្ត្រីមេម៉ាយរបស់ខ្លួន នឹងផ្តល់ទ្រព្យនោះដល់(កូនប្រុស)នោះ បន្ទាប់ពីចិញ្ចឹមកូនឱ្យបងប្អូនប្រុសខ្លួន។

១៤៧- ប្រសិនបើស្ត្រីមានការព្រមព្រៀង(ត្រឹមត្រូវ) មានកូនប្រុសជាមួយបងប្អូនប្រុសថ្លៃរបស់នាង ឬជាមួយ(សបិណ្ឌ)ម្នាក់ទៀត (កូនប្រុស)នោះ បើសិនជាគេចាប់កំណើតដោយសារតម្រេក ពួកគេប្រកាសថា មិនអាចទទួលមរតក និងកើតដោយឥតប្រយោជន៍។

១៤៨- វិធានច្បាប់(កំណត់ខាងលើ) ត្រូវគេយល់ថា (សម្រាប់)ការបែងចែកក្នុងចំណោមកូនប្រុសរបស់ស្ត្រីដែលមានវណ្ណៈដូចគ្នា តទៅទៀតនេះចូរស្តាប់ច្បាប់ស្តីពី អ្នកដែលត្រូវផ្តល់កំណើតដោយបុរសម្នាក់ ជាមួយភរិយាជាច្រើន ដែលមាន(វណ្ណៈ)ផ្សេងគ្នា។

១៤៩- ប្រសិនបើមានប្រពន្ធបួនជាព្រាហ្មណ៍ ក្នុងលំដាប់វណ្ណៈផ្ទាល់ វិធានច្បាប់សម្រាប់ការបែងចែក(ទ្រព្យ)ក្នុងចំណោមកូនប្រុសរបស់ពួកគេ មានដូចតទៅ៖

១៥០- (ទាសករ)ដែលកាប់គាស់ភ្ជួររាស់(ស្រែ) គោឈ្មោលដែលគេរក្សាបង្កាត់កូនមេគោ យានគ្រឿងលម្អ និងផ្ទះ នឹងត្រូវឱ្យជាចំណែកបន្ថែមដល់(កូនប្រុស)ព្រាហ្មណ៍ និងចំណែកប្រពៃបំផុត។

---

*តិ*'នឹងអាចឱ្យទទួល' ហើយសេចក្តីនៃកាព្យនេះគឺថា 'គាត់ត្រូវបានប្រយោជន៍ពី(ឪពុក)ទាំងពីរ ដូច*ទ្វាមុស្យាយណ*ដែរ'។

**១៤៤.** 'វិធានច្បាប់នេះ(មានចែងខាងលើ)' គឺមាននៅក្នុងកាព្យលេខ៦០។ លោកនន្ទ. លុបកាព្យនេះចោល។

**១៤៥.** លោកមេធ. និងកុល្ល. បញ្ជាក់ថា កម្មវត្ថុកាព្យនេះ គឺដើម្បីទូន្មានថា ក្សេត្រជៈ បើសិនជាមានគុណសម្បត្តិល្អ ក៏អាចទទួល (ផ្ទុយពីកាព្យលេខ១២០)ចំណែកបន្ថែមរបស់កូនប្រុសច្បង ព្រោះគេនិយាយថា គាត់ទទួល 'បានដូចកូនប្រុសស្របច្បាប់'។ លោកនារ. និយាយថា '(សំនួនពាក្យ)ដូចកូនប្រុសស្របច្បាប់ (ត្រូវគេប្រើ) ដើម្បីបង្កើត (ឋានៈមួយ) បានចំណែកស្មើ'។ លោកនន្ទ. លុបកាព្យនេះចោល។

**១៤៦.** 'វិធានច្បាប់នេះ សំដៅដល់ករណី ដែលមានការបែងចែកបងប្អូនប្រុសពីរនាក់ ចំណែកឯកាព្យលេខ១២០ សំដៅដល់អ្នកដែលរួមគ្នា'(មេធ., កុល្ល., រាឃ.)។ លោកនន្ទ. ដាក់កាព្យនេះ បន្ទាប់ពីកាព្យ១៤៧។

**១៤៩-១៥៦.** គោត. ជំពូក២៨ លេខ៣៥-៣៩; វស. ជំពូក១៧ លេខ៤៨-៥០; ពោធ. ជំពូក២ លេខ៣, ១០; វិ. ជំពូក១៨ លេខ១-៣៣, ៣៨-៤០; យញ្ញ. ជំពូក២ លេខ១២៥។

**១៥០.** 'គ្រឿងលម្អ' គឺ 'ចិញ្ចៀនដែលឪពុកធ្លាប់ពាក់ជាដើម'(មេធ., កុល្ល.)។ 'ផ្ទះ' គឺ 'លំនៅឋានសំខាន់'(មេធ., កុល្ល., រាឃ.)។ អេកាំសះ ច ប្រធានតះ 'ចំណែកមួយដ៏ល្អប្រពៃបំផុត'(មេធ., កុល្ល.) តាមនារ. និងនន្ទ. យល់ស្របថា 'និង ចំណែក

១៥១- ចូរកូនប្រុសរបស់(ភរិយា)ព្រាហ្មណ៍ យកបីចំណែកនៃទ្រព្យដែលនៅសល់ កូនប្រុសរបស់ក្សត្រិយាបានពីរចំណែក កូនប្រុសរបស់វៃស្យាបានមួយចំណែកកន្លះ ហើយកូនប្រុសរបស់សូទ្រាបានមួយចំណែក។

១៥២- ឬចូរអ្នកដែលចេះដឹងច្បាប់ ចែកដប់ចំណែកនៃទ្រព្យទាំងមូល ហើយបែងចែកវាដោយយុត្តិធម៌ស្របតាមវិធានច្បាប់ដូចតទៅ៖

១៥៣- (កូនប្រុស) ព្រាហ្មណ៍នឹងយកបួនចំណែក កូនប្រុសរបស់ (ភរិយា)ក្សត្រិយាយកបីចំណែក កូនប្រុសរបស់វៃស្យានឹងបានពីរចំណែក កូនប្រុសរបស់សូទ្រា អាចបានមួយចំណែក។

១៩៤- ទោះជា(ព្រាហ្មណ៍)មានកូនប្រុស ឬគ្មានកូនប្រុស(ជាមួយភរិយារបស់វណ្ណៈកំណើតពីរដង)ក៏ដោយ (ទាយាទ)តាមច្បាប់ ត្រូវតែផ្តល់ឱ្យកូនប្រុសរបស់(ភិរយា)សូទ្រា មិនលើសចំណែកទីដប់(នៃចំណែកទ្រព្យរបស់គាត់)។

១៩៥- កូនប្រុសរបស់ព្រាហ្មណ៍ ក្សត្រិយ និងវៃស្យ ជាមួយ(ភរិយា)សូទ្រៈ មិនបានទទួលចំណែកមរតកទេ ហើយអ្វីក៏ដោយដែលឪពុករបស់គេផ្តល់ឱ្យគេ នោះជាកម្មសិទ្ធិរបស់គេ។

១៩៦- កូនប្រុសទាំងអស់របស់បុរសមានកំណើតពីរដង ដែលកើតពីភរិយាវណ្ណៈដូចគ្នា នឹងចែកទ្រព្យស្មើៗគ្នា បន្ទាប់ពីកូនផ្សេងត្រូវឱ្យចំណែកបន្ថែមដល់កូនច្បងបង្អស់។

១៩៧- ចំពោះសូទ្រដែលត្រូវយកភរិយាក្នុងវណ្ណៈរបស់ខ្លួនផ្ទាល់ប៉ុណ្ណោះ (គឺ)មិនក្រៅពីនេះ កូនដែលកើតចេញពីនាង នឹងបានចំណែកស្មើៗគ្នា ទោះបីមានកូនប្រុសដល់មួយរយក៏ដោយ។

---

ដែលមានដ៏សំខាន់ គឺ ទ្រព្យល្អបំផុត'(ប្រធានតោ មុខ្យធនាទ ឧត្ក្រិស្ថាទ ឥតី អរថះ) ហើយតាមរាឃ. 'និងចំណែកមួយព្រោះគាត់ជាបុគ្គលសំខាន់'។ តាមលោកនារ. 'មួយចំណែក'នេះ ត្រូវស្មើនឹងតម្លៃមួយក្នុងចំណោមបីចំណែក ដែលមាននិយាយនៅក្នុងកាព្យបន្ទាប់។

**១៥១.** មេធ. និងកុល្ល. យល់ថា វិធានច្បាប់នេះមានប្រយោជន៍ បើសិនមានកូនប្រុសច្រើនជាងមួយក្នុងវណ្ណៈនីមួយៗ។

**១៥២.** តាមលោកនារ. វិធានច្បាប់នេះសំដៅដល់ករណី ដែលភរិយានីមួយៗមានកូនប្រុសច្រើន ចំណែកឯវិធានពីមុនត្រូវយកមកអនុវត្ត នៅពេលដែលភរិយានីមួយៗមានកូនប្រុសតែមួយប៉ុណ្ណោះ។ លោករាឃ. គិតថា វិធានទីមួយ នឹងត្រូវអនុវត្តនៅពេលកូនប្រុសរបស់ព្រាហ្មណី មានគុណសម្បត្តិល្អ ទីពីរនៅពេលកូននោះគ្មានគុណសម្បត្តិល្អ។

**១៥៣.** លោកមេធ. គូសបញ្ជាក់ថា តាមស្រ្មិតដទៃទៀត កូនប្រុសព្រាហ្មណ៍ប៉ុណ្ណោះទើបទទួលបានដីរបស់ឪពុកខ្លួន និងថា កូនប្រុសសូទ្រៈ មិនទទួលបានចំណែកដីទេ ប្រសិនបើមានទ្រព្យផ្សេង។

**១៥៤.** ហេតុនេះ បើគ្មានកូនប្រុសផ្សេង ទាយាទដទៃ សបិណ្ឌ(មេធ.) ឬមេម៉ាយ និងអ្នកផ្សេងទៀត(នារ.) នឹងទទួលចំណែកទ្រព្យដែលនៅសល់។ លោកនារ. បន្ថែមថា គេអាចទទួលបានច្រើនជាងចំណែកទីដប់ ប្រសិនបើឪពុករបស់គេប្រគល់វាឱ្យរូបគេ។

**១៥៥.** កូនប្រុសរបស់ភរិយាសូទ្រៈ គ្មានចំណែកទ្រព្យរបស់ឪពុកខ្លួនទេ ក្នុងករណីម្តាយមិនបានរៀបការស្របច្បាប់(មេធ., កុល្ល. និងអ្នកដទៃ) ឬក្នុងករណីរូបគេគ្មានគុណសម្បត្តិល្អ(កុល្ល., រាឃ.)។ តាមលោកមេធ. និងនារ. *ន រិក្ថភាគ*គ្មានចំណែកមរតកទេ' មានន័យថា 'មិនបានទទួលចំណែក(ធំជាង)ចំណែកមួយភាគដប់ទេ (លើកលែងករណីថា ឪពុកខ្លួនប្រគល់ច្រើនជាងនេះឱ្យខ្លួន)'។ ប៉ុន្តែទំនងជាអាចនិយាយបានថា កាព្យនេះមានបំណងសង្កត់ធ្ងន់រឿងភាសិតថា កូនប្រុសរបស់ភរិយាសូទ្រៈ មិនអាចទាមទារចំណែកកំណត់នៃមរតកពីឪពុករបស់ខ្លួន ដែលចែកទ្រព្យគាត់នោះទេ។

**១៥៦.** លោកមេធ., គោវ. និង K. អាន *វា* 'ឬ' ជំនួសពាក្យ *វេ* (គាតាះ) ប៉ុន្តែពាក្យនេះគ្មានន័យល្អទេ តាមការកត់

១៩៨- ក្នុងចំណោមកូនប្រុសដប់ពីររបស់បុរស ដែលកើតពីព្រះស្វយម្ភូ ដែលមនុរៀបរាប់ឈ្មោះ មានប្រាំមួយនាក់ជាញាតិសន្តានប្រុស និងទាយាទ ហើយប្រាំមួយមិនមែនជាទាយាទទេ (តែជា)ញាតិសន្តានប្រុស។

១៩៩- កូនប្រុសស្របច្បាប់របស់សព កូនប្រុសដែលកើតនឹងភរិយា កូនប្រុសចិញ្ចឹម កូនប្រុសសន្មតកូនប្រុសដែលកើតដោយអាថ៌កំបាំង និងកូនប្រុសដែលគេបោះបង់ចោល (គឺជា)ទាយាទប្រាំមួយ និងញាតិសន្តានប្រុស។

១៦០- កូនប្រុសរបស់ស្រីក្រមុំមិនបានរៀបការ កូនប្រុសដែលទទួលជាមួយភរិយា កូនប្រុសទិញ កូនប្រុសដែលកើតនឹងស្ត្រីរៀបការលើកទីពីរ កូនប្រុសប្រគល់ខ្លួនដោយខ្លួនឯង និងកូនប្រុសរបស់ស្ត្រីសូទ្រៈ (គឺជា)ប្រាំមួយអ្នក(ដែលមិនមែនជា)ទាយាទ (តែជា)ញាតិសន្តានប្រុស។

១៦១- លទ្ធផលអ្វីក៏ដោយដែលបុរសម្នាក់ទទួលបាន ក្នុងការព្យាយាមឆ្លងកាត់(ផ្ទៃ)ទឹក ដោយប្រើទូកគ្មានសុវត្ថិភាព បីដូចជាលទ្ធផលដែលគេទទួលបាន ក្នុងការព្យាយាមឆ្លងភពងងឹត(នៃជាតិក្រោយ)ដោយអ្នកជួយដ៏អាក្រក់(សម្រាប់)កូនប្រុស(ពិត)។

១៦២- ប្រសិនបើទាយាទពីររបស់បុរសម្នាក់ មួយជាកូនរបស់ខ្លួនស្របច្បាប់ និងមួយចាប់កំណើតជាមួយភរិយារបស់ខ្លួន កូនប្រុស (ម្នាក់ក្នុងចំណោមកូនទាំងពីរ) ដោយមិនគិតពីកូនផ្សេងនឹងទទួលបានទ្រព្យរបស់ឪពុក (បង្កើត) របស់ខ្លួន។

---

សម្គាល់របស់លោកមេធ.។

**១៥៨-១៥៩.** គោត. ជំពូក២៨ លេខ៣១-៣៣; វស. ជំពូក១៧ លេខ២៥, ៣៨; ពោធ. ជំពូក២ លេខ៣, ៣១-៣២។

**១៥៨.** គឺ ប្រាំមួយដំបូង ទទួលមរតកគ្រួសារ និងធ្វើការបុណ្យបូជាសព ប្រាំមួយខាងក្រោយមិនទទួលមរតកទេ ប៉ុន្តែធ្វើការបូជាទឹក ហើយរហូតដល់ចុងក្រោយគឺញាតិសន្តានប្រុស(កុល្ល., នារ., រាឃ., នន្ទ., 'មួយចំនួន')។ លោកមេធ., នារ. និងនន្ទ. ប្រែ *អទាយាទពាន្ធវ:* 'មិនមែនជាទាយាទ និងមិនមែនញាតិសន្តានប្រុស'។ ប៉ុន្តែលោកកុល្ល. បដិសេធ ដោយសមទំនងថា សេចក្តីស្របគ្នារបស់ពោធ. បង្ហាញថាការបកស្រាយនេះមិនត្រឹមត្រូវ។ លោកនារ. ចុងក្រោយប្រែ *ពន្ធុ ទាយាទា:* 'ទាយាទ និងញាតិសន្តានប្រុស' ថា 'ទាយាទរបស់ញាតិសន្តានប្រុស' គឺ 'អ្នកទទួលមរតកទ្រព្យរបស់ញាតិសន្តានប្រុសដូចជាអ៊ំខាងឪពុក ដែលគ្មានកូនប្រុស ភរិយាជាដើម'។ លោកនារ. និងនន្ទ. ព្រមទាំងលោកមេធ. ក្នុងអត្ថបទអធិប្បាយរបស់លោកត្រង់កាព្យលេខ១៦៦ បន្ថែមថា កូនប្រុសរបស់កូនស្រីតាមការព្រមព្រៀង មិនមានរៀបរាប់ទេ ព្រោះគេបានប្រកាសនៅខាងលើរួចហើយថាស្មើនឹងកូនប្រុសស្របច្បាប់។

**១៦១.** លោកមេធ. ធ្វើការបកស្រាយម្យ៉ាងទៀតចំពោះសំនួនពាក្យ *កុបុត្រៃ:*ដោយ(អ្នកជំនួស)កូនប្រុសពិតនោះ មិនល្អ' មានន័យថា 'កូនប្រុសរបស់ភរិយា ឬមេម៉ាយ ដែលមិនមានការព្រមព្រៀងត្រឹមត្រូវ'។

**១៦១.** តាមលោកមេធ. និងគោវ. (ស្រង់សម្តីដោយលោកកុល្ល. និងរាឃ.) វិធាននេះសំដៅដល់ករណីដែលកូនប្រុសស្របច្បាប់ និងកូនប្រុសរបស់ភរិយាដែលគ្មានការព្រមព្រៀង ទាំងពីរនាក់ទាមទារមរតក។ ប៉ុន្តែ 'អ្នកផ្សេង' (តាមការស្រង់សម្តីរបស់លោកមេធ., កុល្ល. និងរាឃ.) គិតថា វិធាននេះអនុវត្តចំពោះករណីដែលភរិយាទីមួយមានការព្រមព្រៀងពីស្វាមី ដើម្បីបង្កើតកូនប្រុសជាមួយប្អូនប្រុសរបស់គាត់ ហើយបន្ទាប់មកកូនប្រុសដែលកើតមក គឺស្របច្បាប់។ បញ្ហាលំបាកពាក់ព័ន្ធនឹងការបកស្រាយ ចំពោះកាព្យលេខ១៦៤ ត្រូវលោយបាត់ ដោយសារការសន្មតថា វិធានក្រោយអនុវត្តចំពោះករណីដែលឪពុកបង្កើតរបស់ក្សត្រជ: មានកូនប្រុស ចំណែកឯកាព្យលេខ១៦២ សន្មតថា គាត់គ្មានកូនប្រុស។ នារ. និងនន្ទ. និយាយថា ករណីដែលវិធាននេះពិចារណាហ្មត់ចត់ គឺថា បងប្អូនប្រុសពីរនាក់មិនអាចបែងចែកបាន ហើយនៅពេលម្នាក់ស្លាប់ ម្នាក់

១៦៣- កូនស្របច្បាប់របស់សពប៉ុណ្ណោះ(គឺជា)ម្ចាស់ទ្រព្យរបស់ឪពុក ប៉ុន្តែដើម្បីជៀសវាងភាពយង់ឃ្នង ចូរគេផ្តល់ការគាំទ្រដល់អ្នកដទៃទៀត។

១៦៤- ប៉ុន្តែពេលកូនស្របច្បាប់របស់សព បែងចែកទ្រព្យឪពុក គេនឹងឱ្យមួយភាគប្រាំមួយ ឬមួយភាគប្រាំនៃចំណែកទ្រព្យរបស់ឪពុកខ្លួន ដល់កូនប្រុសដែលចាប់កំណើតជាមួយភរិយា។

១៦៥- (ដូច្នេះ) កូនប្រុសស្របច្បាប់ និងកូនប្រុសរបស់ភរិយា មានចំណែកទ្រព្យរបស់ឪពុក ប៉ុន្តែដប់នាក់ទៀតជាសមាជិកគ្រួសារ នឹងទទួលស្របតាមលំដាប់របស់ពួកគេ (ម្នាក់ៗក្រោយនេះ បើគ្មានឈ្មោះខាងដើម)។

១៦៦- អ្នកដែលបុរសម្នាក់ផ្តល់កំណើតជាមួយភរិយារៀបការរបស់ខ្លួននោះ គឺជាកូនស្របច្បាប់របស់សព(ឱរស) ស្ថិតក្នុងលំដាប់ទីមួយ។

---

ទៀតដែលមានកូនប្រុស ជាមួយមេម៉ាយ គឺកូនប្រុសក្សេត្រជៈ។ បើនិយាយពីមរណភាពរបស់បងប្អូនទី២ ក្សេត្រជៈ មានសិទ្ធិទទួលបានតែចំណែករបស់ប្តីនៃម្តាយខ្លួន មិនអាចទារចំណែកទ្រព្យរបស់ឪពុកបង្កើតរបស់ខ្លួនបានទេ។ តាមការស្មានការបកប្រែគឺ 'ប្រសិនបើកូនប្រុសស្របច្បាប់(របស់បងប្អូនប្រុសម្នាក់) និងកូនប្រុសរបស់ភរិយា(ម្នាក់ទៀត) ទាមទារទ្រព្យដែល(មិនទាន់បែងចែក) ម្នាក់ៗនឹងទទួលបានចំណែករបស់ឪពុកខ្លួន'។

**១៦៣-១៦៥.** វិ. ជំពូក១៥ លេខ២៨-៣០; យញ្ញ. ជំពូក២ លេខ១៣២។

**១៦៣.** វិធាននេះសំដៅដល់ករណី ដែលបុរសម្នាក់បន្សល់អ្នកជំនួសកូនប្រុស និងកូនប្រុសស្របច្បាប់ជាច្រើននាក់(មេធ., កុល្លុ., នារ., រាឃ.)។ 'សម្រាប់អ្នកដទៃ' គឺ 'សម្រាប់អ្នកទាំងអស់ លើកលែងតែកូនប្រុសដែលចាប់កំណើតជាមួយភរិយា' (ដែលអ្នកក្រោយនេះ មានការលើកលែងដោយកាព្យលេខ១៦៤-១៦៥; លោកមេធ., កុល្លុ., រាឃ., នន្ទ.)។ 'អ្នកដែលមិនចិញ្ចឹមពួកគេ គឺប្រព្រឹត្តបាបកម្ម'(មេធ., កុល្លុ.) ប៉ុន្តែមិនចិញ្ចឹម បើពួកគេមានមធ្យោបាយផ្សេងសម្រាប់ចិញ្ចឹមជីវិត(នន្ទ)។

**១៦៤.** វិធាននេះសំដៅដល់ករណីដែលក្សេត្រជៈ ចាប់កំណើតមុនកូនប្រុសស្របច្បាប់ និងមិនទទួលទ្រព្យពីឪពុកបង្កើតរបស់ខ្លួនទេ(រាឃ.)។ សូមមើលកំណត់សម្គាល់របស់លោកកុល្លុ.ត្រង់កាព្យលេខ១៦២-១៦៣ ផង។ តាមលោកនារ. យ៉ាងណាមិញ កាព្យនេះសំដៅដល់ករណី ដែលបុរសទទួលមរណភាព ដោយបន្សល់ទុកប្រពន្ធមេម៉ាយច្រើន ហើយប្រពន្ធម្នាក់ត្រូវគេព្រមព្រៀងឱ្យមានកូនប្រុសជាមួយប្អូនថ្លៃរបស់ខ្លួន ចំណែកឯម្នាក់ទៀតក្រោយមក ឃើញថាមានផ្ទៃពោះ និងមានកូនប្រុសស្របច្បាប់។ 'ក្សេត្រជៈ ទទួលបានមួយភាគបី ប្រសិនបើគេមានគុណសម្បត្តិល្អ បានមួយភាគប្រាំមួយ'(មេធ., នារ., រាឃ., នន្ទ.)។

**១៦៥.** វស. ជំពូក១៧ លេខ៣៩។ គោត្រវិក្តាំសភាគិនះ 'ជាសមាជិករបស់គ្រួសារ (គឺមានសិទ្ធិនិងករណីយកិច្ចរបស់គ្រួសារ) និងទទួលមរតក'(មេធ., កុល្លុ., នន្ទ.) គេក៏អាចប្រែថា 'មានចំណែកទ្រព្យគ្រួសារ' ដូចការសន្និដ្ឋានរបស់នារ.។ ប៉ុន្តែសំណើរបស់គាត់ថា ទ្រព្យគ្រួសារនិយាយនៅទីនេះ គឺមិនរាប់បញ្ចូលទ្រព្យដែលជាកម្មសិទ្ធិផ្ទាល់របស់ឪពុកពួកគេទេ គឺមិនត្រឹមត្រូវពិតប្រាកដទេ។ ការបកស្រាយម្យ៉ាងទៀតរបស់លោកនារ. និងនន្ទ. ទំនងមិនអាចយកបានដូចគ្នា គឺ *អំសភាគិនះ* 'ពួកគេមានចំណែក' គឺមានន័យថា 'ពួកគេបានចំណែក (ដែលសមល្មមសម្រាប់ការចិញ្ចឹមជីវិតពួកគេ'។

**១៦៦.** អាប. ជំពូក២ លេខ១៨, ១; វស. ជំពូក១៧ លេខ១៣; ពោធ. ជំពូក២ លេខ៣, ១៤; វិ. ជំពូក១៥ លេខ២; យញ្ញ. ជំពូក២ លេខ១២៨។ ខ្ញុំអាន *ប្រាថមកល្បិកំ* តាមលោកមេធ., គោវ., នារ. និង K.។ លោករាឃ. សរសេរ *ប្រថមកល្បិកំ*។ លោកកុល្លុ. និងនារ. គិតថា ភរិយាត្រូវមានវណ្ណៈស្មើគ្នា ចំណែកឯលោកមេធ. និយាយថា *ស្វ* មានន័យ 'ខ្លួនផ្ទាល់' មិន'វណ្ណៈខ្លួនផ្ទាល់'ទេ។ លោកមេធ. លើកឡើងនូវមតិរបស់កុល្លុ. ដូចអ្នកដទៃដែរ។

១៦៧- អ្នកដែលចាប់កំណើតតាមច្បាប់ពិសេស(និយោគ)ជាមួយភរិយាតាមការព្រមព្រៀងរបស់បុរសដែលស្លាប់ របស់មនុស្សកម្រៀវឬរបស់បុរសមានជំងឺ ត្រូវគេហៅថាកូនប្រុសដែលចាប់កំណើតជាភរិយា(ក្សេត្រជៈ)។

១៦៨- (ក្មេងប្រុស)វណ្ណៈស្មើគ្នា ដែលម្តាយរបស់ខ្លួន ឬឪពុករបស់ខ្លួនផ្តល់កំណើតដោយការពេញចិត្ត (យល់ព្រមផ្តល់)ការបូជាទឹកក្នុងគ្រាអាសន្ន (ចំពោះបុរស)ដែលជាកូនប្រុសខ្លួន ត្រូវគេចាត់ទុកថាជាកូនចិញ្ចឹម(ទត្រិម)។

១៦៩- ប៉ុន្តែគាត់គឺជាកូនប្រុសដែលហៅថា (ក្ឫត្រិម) ដែល (បុរសម្នាក់) ញ៉ាំងឱ្យកូនប្រុសរបស់ខ្លួន (អ្នកដែលមានវណ្ណៈស្មើគ្នា) ស្គាល់ច្បាស់រវាងខុស និងត្រូវ (និង)មានគុណធម៌ជាកូន។

១៧០- បើសិនជា (កូន) កើតនៅក្នុងផ្ទះរបស់បុរសម្នាក់ ហើយគេមិនស្គាល់ឪពុកកូននេះ កូននេះជាកូនប្រុស ដែលចាប់កំណើតដោយអាថ៌កំបាំងនៅក្នុងផ្ទះ (គូឍោត្បន្ន) និងជារបស់អ្នកដែលភរិយារបស់កូនចាប់កំណើតនោះ។

១៧១- អ្នកដែល(បុរស) នោះទទួលកូនប្រុសខ្លួន (បន្ទាប់ពី) ឪពុកម្តាយខ្លួនឬខាងណាមួយបោះបង់ចោល ជាកូនប្រុសដែលគេបោះបង់ចោល(អបវិទ្ធ)។

---

**១៦៧.** វស. ជំពូក១៧ លេខ១៤; ពោធ. ជំពូក២ លេខ៣, ១៨; វិ. ជំពូក១៥ លេខ៣; យញ្ញ. ជំពូក១ លេខ៦៩, ជំពូក២ លេខ១២៧-១២៨។

**១៦៨.** វស. ជំពូក១៧ លេខ២៩; ពោធ. ជំពូក២ លេខ៣, ២០; វិ. ជំពូក១៥ លេខ១៨-១៩; យញ្ញ. ជំពូក២ លេខ១៣០។ សទ្ទសំ ‘ស្មើ(ដោយវណ្ណៈ)’(កុល្លូ., នារ., រាឃ., នន្ទ.) តាមលោកមេធ. គឺ ‘ស្មើដោយគុណធម៌ មិនមែនដោយវណ្ណៈទេ’។ ‘ម្តាយរបស់គាត់ ឬឪពុករបស់គាត់’ គឺ ‘បន្ទាប់ពីព្រមព្រៀងគ្នាទៅវិញទៅមក’(កុល្លូ.) ‘ម្តាយ ប្រសិនបើគ្មានឪពុក’(រាឃ.)។ លោកមេធ. និងនន្ទ. អាន *វា មាតា បិតា ច* ‘ម្តាយរបស់ខ្លួន និងឪពុករបស់ខ្លួន’ ប៉ុន្តែលោក មេធ. បន្ថែមថា *វា* ជាសំណេរត្រឹមត្រូវជាង។ ‘ដោយការពេញចិត្ត’ គឺ ‘មិនមែនដោយចិត្តច្រណែនទេ’(មេធ.) ឬ ‘មិនមែនដោយភ័យជាដើម’(កុល្លូ., នន្ទ.) ឬ ‘មិនដោយបង្ខំ ឬបន្លំទេ’(រាឃ.)។ ‘ក្នុងគ្រាអាសន្ន’ គឺ ‘បើសិនជាអ្នកចិញ្ចឹមគ្មាន កូនប្រុស’(កុល្លូ., រាឃ.) ឬ ‘បើសិនជាឪពុកម្តាយរបស់កូនចិញ្ចឹម ស្ថិតក្នុងគ្រាអាសន្ន’(នារ.)។

**១៦៩.** ពោធ. ជំពូក២ លេខ៣, ២១; យញ្ញ. ជំពូក២ លេខ១៣១។ លោកមេធ. បញ្ជាក់ឡើងវិញថា ‘ស្មើគ្នាដោយគុណសម្បត្តិ’។ ‘ដែលមាន(ភាពខុសគ្នារវាង)ត្រឹមត្រូវនិងខុស’ គឺ ‘ដោយធ្វើ ឬមិនធ្វើពិធីស្រាទ្ធ និងពិធីពិសិដ្ឋផ្សេងទៀត កុសល ឬបាប នឹងកើតឡើង’(កុល្លូ.) ឬ ‘ខ្ញុំ ពេលនេះ ជាកូនប្រុសរបស់អ្នកនេះ អ្នកនេះ ហើយបើខ្ញុំមិនបម្រើគាត់ ខ្ញុំនឹងទៅជាចណ្ឌាល’(រាឃ.) ឬ ‘មិនមែនជាក្មេងទេ’(មេធ., នារ., ‘អ្នកខ្លះ’)។ លោកនារ. បន្ថែមថា អ្នកខ្លះអាន *គុណទោសវិចាក្សនះ* ហើយជាគុណស័ព្ទសំដៅដល់អ្នកចិញ្ចឹម ដែលគេបំពានកុំឱ្យចិញ្ចឹមមនុស្សក្រៅវណ្ណៈ ឬមនុស្សប្រភេទនេះ។

**១៧០.** វស. ជំពូក១៧ លេខ២៤; ពោធ. ជំពូក២ លេខ៣, ២២; វិ. ជំពូក១៥ លេខ១៣-១៤; យញ្ញ. ជំពូក២ លេខ១២៩។ តាមអ្នកអធិប្បាយនានាលក្ខខណ្ឌគឺប្រាកដណាស់ថា ភរិយាបានរួមសង្វាសជាមួយបុរសវណ្ណៈថ្នាក់ក្រោម។ លោកនារ.និយាយថា ករណីពិភាក្សានេះ គឺថា ភរិយាបានរួមសង្វាសជាមួយបុរសជាច្រើនដែលមានវណ្ណៈស្មើគ្នា។

**១៧១.** វស. ជំពូក១៧ លេខ៣៧; ពោធ. ជំពូក២ លេខ៣, ២៣; វិ. ជំពូក១៥ លេខ២៤-២៥; យញ្ញ. ជំពូក២ លេខ១៣២។ ហេតុផលនៃការរត់ចោលអាចឪពុកម្តាយមានទុក្ខព្រួយហួសហេតុក៏បាន ឬអាចថាក្មេងនោះប្រព្រឹត្តកំហុសមួយចំនួន(មេធ.)។ ‘ដោយហេតុថាឪពុករបស់ក្មេងមានវណ្ណៈស្មើគ្នា’(នារ., នន្ទ.)។

១៧២- កូនប្រុសដែលចាប់កំណើតដោយអាថ៌កំបាំងនៅក្នុងផ្ទៃស្រីក្រមុំ នៅក្នុងផ្ទះឪពុករបស់នាង គេឱ្យឈ្មោះថាកូនប្រុសរបស់ស្រីឥតរៀបការ(កានិន ហើយប្រកាស)ថាជាកូនរបស់ស្រីឥតរៀបការ (ជាកូនរបស់) បុរសដែលរៀបការជាមួយនាង(នៅពេលក្រោយ)។

១៧៣- ទោះជាដោយដឹងក្តី ឬមិនដឹងក្តី បើបុរសម្នាក់រៀបការជាមួយ(ស្រីក្រមុំ)មានផ្ទៃពោះ កូននៅក្នុងផ្ទៃពោះរបស់នាង ជារបស់បុរសដែលរៀបការជាមួយនាង ហើយគេហៅ(កូនប្រុស) ដែលចាប់កំណើតនឹងស្រីក្រមុំ ថា(សហោធ)។

១៧៤- ប្រសិនបើបុរសម្នាក់ទិញ(ក្មេងប្រុសមួយ) ទោះជាមាន(គុណសម្បត្តិល្អ)ដូចគ្នា ឬមិនដូចគ្នាក្តី ពីឪពុកនិងម្តាយរបស់វាដើម្បីធ្វើជាកូនប្រុស(គេ)ហៅក្មេងនោះថា(កូនប្រុស)ទិញ (ក្រីតក)។

១៧៥- ប្រសិនបើស្ត្រីម្នាក់ដែលប្តីនាងបោះបង់ចោល ឬមេម៉ាយ សន្យារៀបការជាលើកទីពីរ ដោយការយល់ព្រមផ្ទាល់ពីនាង ហើយមាន (កូនប្រុសមួយ) គេហៅកូនប្រុសនេះថា កូនរបស់ស្ត្រីរៀបការលើកទីពីរ(បុនភវ)។

១៧៦- ប្រសិនបើនាង(នៅតែ)ជាស្រីក្រមុំ ឬអ្នកដែលត្រឡប់ទៅរក(ប្តីទីមួយរបស់នាង)វិញ បន្ទាប់ពីចាកចោលគាត់ នាងសមនឹងរៀបពិធីអាពាហ៍ពិពាហ៍លើកទីពីរ (ឬជាមួយប្តីដែលលែងលះលើកទីមួយ)។

១៧៧- ដោយបាត់បង់ឪពុកម្តាយ ឬត្រូវ(ពួកគាត់)បោះបង់ចោល អ្នកដែលប្រគល់ខ្លួនឱ្យ(បុរសម្នាក់) ដោយគ្មានហេតុផល(ត្រឹមត្រូវ) ជាកូនប្រុសដែលប្រគល់ខ្លួនដោយខ្លួនឯង(ស្វយំទត្ត)។

១៧៨- កូនប្រុសដែលព្រាហ្មណ៍ផ្តល់កំណើត ដោយតម្រេកតណ្ហាជាមួយស្ត្រីសូទ្រៈ គឺ(ទោះជា)មានជីវិត(បារយ័ន) ខ្មោច(សវ) ដូច្នេះគេហៅ*បារសវ*(ខ្មោចរស់)។

---

**១៧២.** វស. ជំពូក១៧ លេខ២២-២៣; ពោធ. ជំពូក២ លេខ៣, ២៤; វិ. ជំពូក១៥ លេខ១០-១១; យញ្ញ. ជំពូក២ លេខ១២៩។ 'ដោយហេតុថា សហាយមានវណ្ណៈស្មើគ្នា ឬខ្ពស់ជាង'(នារ.)។

**១៧៣.** វស. ជំពូក១៧ លេខ២៦-៣៧; ពោធ. ជំពូក២ លេខ៣, ២៥; វិ. ជំពូក១៥ លេខ១៥-១៦; យញ្ញ. ជំពូក២ លេខ១៣១។ ការអធិប្បាយរបស់លោកមេធ.ចំពោះកាព្យលេខ១៧៣-១៧៨ មិនមាននៅក្នុងសំណៅ I. O.។

**១៧៤.** វស. ជំពូក១៧ លេខ៣០-៣២; ពោធ. ជំពូក២ លេខ៣, ២៦; វិ. ជំពូក១៥ លេខ២០-២១; យញ្ញ. ជំពូក២ លេខ១៣១។ 'ស្មើគ្នា ឬមិនស្មើគ្នា' គឺ 'ដោយមានគុណសម្បត្តិល្អ មិនមែនដោយវណ្ណៈទេ'(កុល្លូ., រាឃ.) តាមលោកនារ. គឺ 'ដែលមានវណ្ណៈស្មើក៏បាន ឬទាបជាងក៏បាន'។

**១៧៥.** វស. ជំពូក១៧ លេខ១៨; ពោធ. ជំពូក២ លេខ៣, ២៧; វិ. ជំពូក១៥ លេខ៧-៩; យញ្ញ. ជំពូក២ លេខ១៣០។

**១៧៦.** វស. ជំពូក១៧ លេខ៧៤។ 'ដូចនេះស្ត្រីដែលរៀបការម្តងទៀត មិនមែនជាស្រីព្រហ្មចារី មិនសមនឹងធ្វើពិធីប្រសិទ្ធីទេ'(នារ.)។ រាឃ. ដោយផ្អែកលើយញ្ញ. ជំពូក២ លេខ១៣០ លើកឡើងនូវទស្សនៈផ្ទុយ ហើយគិតថា ពាក្យ *វា* 'ឬ' នៅចុងកាព្យពាក់កណ្តាលទីមួយ មានការបញ្ចូល 'ឬមិនព្រហ្មចារី'។

**១៧៧.** វស. ជំពូក១៧ លេខ៣៣-៣៥; ពោធ. ជំពូក២ លេខ៣, ២៨; វិ. ជំពូក១៥ លេខ២២-២៣; យញ្ញ. ជំពូក២ លេខ១៣១។

**១៧៨.** វស. ជំពូក១៧ លេខ៣៨; ពោធ. ជំពូក២ លេខ៣, ៣០; វិ. ជំពូក១៥ លេខ២៧។ 'ជាមួយស្ត្រីសូទ្រៈ' គឺ 'អ្នក

១៧៩- កូនប្រុស ដែលសូទ្រៈផ្តល់កំណើតជាមួយស្ត្រីទាសករ ឬ ស្ត្រីទាសកររបស់ទាសករខ្លួន បើឪពុកខ្លួនអនុញ្ញាត អាចទទួលចំណែក(មរតក) ពោលគឺច្បាប់ចែងដូច្នេះ។

១៨០- ទាំងដប់មួយនេះ កូនប្រុសដែលចាប់កំណើតជាមួយនឹងភរិយា និងអ្នកផ្សេងៗ ដូចបានរៀបរាប់ (ខាងលើ) បណ្ឌិតហៅថាអ្នកជំនួសកូនប្រុស ដើម្បី(ការពារ)ការមិនធ្វើពិធីបុណ្យ(សព)។

១៨១- កូនប្រុសទាំងឡាយដូចបានរៀបរាប់ មានទំនាក់ទំនង(ជាកូនស្របច្បាប់របស់សព) ដែលផ្តល់កំណើតដោយជនចម្លែក (តាមពិត)ជាកម្មសិទ្ធិរបស់បុរសដែលគ្រាប់ពូជកំណើត ប៉ុន្តែមិនមែនជាកម្មសិទ្ធិរបស់បុរស(ផ្សេងដែលជាអ្នកចិញ្ចឹម)ទេ។

១៨២- ប្រសិនបើក្នុងចំណោមបងប្អូនប្រុស ដែលកើតពី(ឪពុក)តែមួយ ម្នាក់មានកូនប្រុស មនុបានប្រកាសថា ពួកគេទាំងអស់សុទ្ធតែមានកូនប្រុស ដោយសារកូនប្រុសនោះ។

១៨៣- ប្រសិនបើក្នុងចំណោមភរិយាទាំងអស់របស់ប្តីម្នាក់ ម្នាក់មានកូនប្រុសមួយ មនុប្រកាសថា ពួកគេទាំងអស់(ជា)ម្តាយរបស់កូនប្រុស ដោយសារកូនប្រុសនោះ។

១៨៤- បើ(កូនប្រុស)ម្នាក់ៗមិនប្រសើរ ម្នាក់ដែលអន់ជាងម្នាក់ទៀត សមនឹងមានចំណែកមរតក ប៉ុន្តែបើមាន(ឋានៈ)ស្មើគ្នាច្រើន ពួកគេទាំងអស់នឹងមានចំណែកទ្រព្យ។

១៨៥- មិនមែនបងប្អូនប្រុស មិនមែនឪពុក (តែ) កូនប្រុសទទួលទ្រព្យឪពុក ប៉ុន្តែឪពុកនឹងទទួលមរតករបស់(កូនប្រុស) ដែលគ្មានកូនប្រុស និងបងប្អូនប្រុសរបស់គាត់។

---

ដែលរៀបការជួយគាត់'(កុល្ល.)។ ការឱ្យឈ្មោះ 'ខ្មោច' សបញ្ជាក់ថា ឪពុករបស់ខ្លួនទទួលផលមិនល្អ ពីការបូជារបស់ខ្លួន (កុល្ល., នារ., រាឃ.) ឬថា គាត់មានកំហុស(រាឃ.)។ ពាក្យ *ព្រាហ្មណៈ* តាមន័យរួមទាំងក្សត្រិយ(នារ.)។

**១៧៩.** យញ្ញ. ជំពូក២ លេខ១៣៣។ 'មួយចំណែក' គឺ 'ចំណែកមួយ ដែលស្មើនឹងចំណែករបស់ កូនប្រុសស្របច្បាប់' (កុល្ល.) ក្នុងករណីការបែងចែកក្នុងពេលឪពុកនៅមានជីវិត ហើយតាមយញ្ញ. គឺចំណែកពាក់កណ្តាល(មេធ.)។

**១៨០.** *ក្រិយាលោបាត*(ដើម្បីការពារ)ការមិនធ្វើពិធីបុណ្យ(សព)' តាមលោកមេធ. ថា '(ដើម្បីការពារ)ការមិនបំពេញករណីយកិច្ច(បង្កើតកូន)'។ លោកកុល្ល. ធ្វើការបកស្រាយដូច្នេះដែរ។ លោកនន្ទ. និយាយថា 'ពេលគ្មានភាពស្របច្បាប់ដោយសារកង្វះសកម្មភាពផ្តល់កំណើតកូន'។

**១៨១.** អាប. ជំពូក២ លេខ១៣, ៧; ពោធ. ជំពូក២ លេខ៣, ៣៤-៣៥។ ហេតុនេះ ពួកគេមិនត្រូវបានចិញ្ចឹម ប្រសិនបើមានកូនប្រុសស្របច្បាប់(មេធ.) ឬកូនស្រី តាមការព្រមព្រៀង(កុល្ល.)។

**១៨២.** វស. ជំពូក១៧ លេខ១០; វិ. ជំពូក១៥ លេខ៤២។ ហេតុនេះ ក្នុងករណីនេះគឺគ្មានកូនប្រុសជំនួស(កុល្ល., រាឃ.) ឬគ្មានក្សេត្រជៈ(នារ.)។ លោកកុល្ល. និងរាឃ. បន្ថែមថា បងប្អូនប្រុសនឹងទទួលទ្រព្យ និងធ្វើការបូជាបុណ្យសព បើគ្មានភរិយា កូនស្រីជាដើម(យញ្ញ. ជំពូក២ លេខ១៣៥)។

**១៨៣.** វស. ជំពូក១៧ លេខ២; វិ. ជំពូក១៥ លេខ៤១។ ហេតុនេះ ក្នុងករណីបែបនេះ គឺគ្មានការចិញ្ចឹម ឬគ្មានការជំនួស (កុល្ល., រាឃ.) ឬការព្រមព្រៀង(នារ.)ទេ។

**១៨៤.** '(កូនប្រុស)ប្រសើរម្នាក់ៗ' គឺម្នាក់ៗមុន ដែលមានឈ្មោះក្នុងចំណោមអ្នកទាំងដប់ពីរ'(កុល្ល., នារ., រាឃ., នន្ទ.)។ លោកកុល្ល. និងរាឃ. បន្ថែមថា ដូចកូនប្រុសរបស់ភរិយាសូទ្រៈដែលបានរៀបរាប់ឈ្មោះក្នុងចំណោមអ្នកទាំងដប់ពីរ និងមិនចាត់ទុកដូចជាកូនប្រុសរបស់ភរិយាក្សត្រិយ និងវៃស្យៈ ថាជាកូនប្រុសស្របច្បាប់ទេ គេទទួលមរតកបានក្នុងករណីគ្មានកូនប្រុសជំនួសផ្សេងទៀត។ 'ឋានៈស្មើគ្នាច្រើន' គឺ '*បុរភៅ* ជាច្រើនជាដើម'(កុល្ល., រាឃ.)។

**១៨៥.** កុល្ល. និងរាឃ. បញ្ចូលបន្ទាប់ពីឃ្លា 'ដែលគ្មានកូនប្រុស''គ្មានមេម៉ាយ និងកូនស្រី' និងពីមុខ 'បងប្អូនប្រុស''ដែលគ្មានឪពុកម្តាយ'។ លោកនារ. ដែល(ដូចគ្នានឹងលោកគោវ., នន្ទ. និង K.) អាន *ភេរ៉ាំ* ឬបងប្អូនប្រុស' និយាយថា ឪពុក

១៨៦- គេត្រូវបូជាទឹកដល់(បុព្វជន)ចំនួនបី ផ្តល់នំបុណ្យសពដល់បុព្វជនបី (អ្នកជំនាន់)ទីបួន ជាអ្នកធ្វើ(ការបូជា)ទាំងអស់នេះ អ្នកជំនាន់ទីប្រាំគ្មានពាក់ព័ន្ធនឹង(ការបូជាទាំងនេះ)ទេ។

១៨៧- ទ្រព្យគឺជារបស់ (សាច់ញាតិនៅក្នុងកម្រិតទាំងបី) ដែលស្ថិតក្នុងសែស្រឡាយជិតបំផុតនឹងសបិណ្ឌ(អ្នកដែលចែកឋានទៅ) បន្ទាប់មក*សកុល្យ* គឺជា(ទាយាទ) តមកទៀតគឺ គ្រូផ្នែកព្រលឹងវិញ្ញាណឬសិស្ស។

---

ទទួលមរតកទ្រព្យរបស់កូនប្រុសដែលមិនទាន់បែងចែក ដែលគ្មានកូនប្រុស ឬបងប្អូនប្រុស ដោយមានការអនុញ្ញាតរបស់ខ្លួន ហើយថាទ្រព្យរបស់កូនប្រុសដែលបានបែងចែក ធ្លាក់ទៅខាងភរិយារបស់គេ ហើយទាយាទដទៃដូច យញ្ញ. ជំពូក២ លេខ១៣៥-១៣៦ បានរៀបរាប់។ ការថែមថយទាំងអស់នេះ ទំនងជាមិនសូវសមស្របទេ ព្រោះមនុ មិនបាននិយាយពីសិទ្ធិទទួលទ្រព្យរបស់ភរិយា ឬកូនស្រី ដែលមិនតាមការព្រមព្រៀងទេ។ កាព្យនេះ អាចសំដៅតែទៅលើម្ចាស់ទ្រព្យរួម ដែលត្រូវបែងចែកប៉ុណ្ណោះ ឬសំដៅដល់ទ្រព្យដោយឡែករបស់អ្នកដែលមិនទាន់ទទួលការបែងចែក ហើយមតិរបស់មនុ ទំនងជាថា បើគ្មានកូនប្រុស ចៅប្រុស និងចៅទួតប្រុស ដែលមានសិទ្ធិ មានបញ្ជាក់ច្បាស់នៅ ក្នុងកាព្យលេខ ១៣៧ ឪពុកនឹងទទួលមរតក ហើយបន្ទាប់ពីគាត់ គឺបងប្អូនប្រុស។

**១៨៦.** 'ដល់បី' គឺ 'ដល់ឪពុក ជីតានិងតាទួត (កុល្ល., នារ., រាឃ., នន្ទ.)។ គេបូជានំដល់អ្នកទាំងបីដដែលនេះ (កុល្ល., រាឃ.)។ លោកកុល្ល. និងរាឃ. បញ្ជាក់ថា កម្មវត្ថុនៃកាព្យនេះ គឺឆ្លុះបញ្ចាំងពីសិទ្ធិរបស់ក្សេត្រជៈ និងកូនប្រុសជំនួយ ដទៃទៀត ក្នុងការទទួលទ្រព្យរបស់ជីតា និងសពជាដើម ដែលគ្មានកូន។ លោកកុល្ល. បន្ថែមថា សិទ្ធិរបស់កូនប្រុស និងចៅប្រុសរបស់កូនប្រុសស្របច្បាប់ មានបញ្ជាក់នៅក្នុងកាព្យលេខ ១៣៧។ យ៉ាងណាមិញ លោកនន្ទ.គិតថា កាព្យនេះបញ្ជាក់ពីសិទ្ធិរបស់ចៅប្រុស និងចៅទួតប្រុស ដែលត្រូវទទួលមរតកមុនបងប្អូនប្រុស និងអ្នកដទៃ'។

**១៨៧.** វស. ជំពូក១៧ លេខ៨១-៨២; គោត. ជំពូក២៧ លេខ៣៣; អាប. ជំពូក២ លេខ១៤, ២-៣។ ការបកប្រែខាងលើមិនស្របទាំងស្រុងនឹងការបកស្រាយរបស់អ្នកអធិប្បាយបួនរូប។ ផ្អែកលើមូលដ្ឋានទស្សនវិជ្ជា សម្រាប់ខ្ញុំទំនងជាមិនអាចនិយាយបានថា *អនន្តរៈ សបិណ្ឌាត* មិនអាចមានន័យផ្សេងក្រៅពី 'ជិតបំផុតនឹងសបិណ្ឌ' ហើយថាសបិណ្ឌនេះ គ្មាននរណាក្រៅពីអ្នកស្លាប់ទេ។ ជាងនេះទៅទៀត ដោយហេតុថាកាព្យលេខ១៨៦ មាននិយាយច្បាស់អំពីនិយមន័យ របស់ពាក្យ ដោយកំណត់ពីសែស្រឡាយទំនាក់ទំនងសបិណ្ឌ ត្រឹមបីកម្រិត ហើយកាព្យលេខ១៨៧ ពាក់កណ្ដាលទីពីរ ពាក្យ *សកុល្យ* 'អ្នកទាំងឡាយដែលស្ថិតក្នុងគ្រួសារតែមួយ' គឺជាទាយាទបន្ទាប់ ហើយប្រាកដណាស់ថា ពាក្យ'សែស្រឡាយជិតបំផុត' គឺ 'សបិណ្ឌ ឬញាតិជិតបំផុតក្នុងបីកម្រិត'។ ជាក់ស្ដែង ការប្រែស្នើឡើងនេះ មិនខុសគ្នាច្រើនពីការប្រែដែលលោកកុល្ល. ដកស្រង់ ហើយអ្នកដទៃ ដែលជាល្បិចប្រែតាមវេយ្យាករណ៍*សបិណ្ឌាត* សម្រាប់ *សបិណ្ឌមធ្យាត* ក្នុងចំណោមសបិណ្ឌ'។ ការបកស្រាយខាងលើ គឺត្រឹមត្រូវ បើតាមការបញ្ជាក់ដោយសេចក្ដីប្រហាក់ប្រហែលគ្នាបំផុតរបស់ពោធាយនជំពូក១ លេខ១១, ៩-១៣ ព្រះសូត្រទីមួយ ដែលទាក់ទងកាព្យលេខ១៨៦ ចំណែកឯបួននាក់ផ្សេងទៀត សង្កត់ន័យដូចគ្នានឹងកាព្យលេខ១៨៧ ដែរ។ នៅចំណុចនោះក៏មានពាក្យ *សកុល្យ* ដែល*ជីមូតវាហនៈ* ចង់ចង្អុលប្រាប់បច្ឆាជនបីប្រភេទក្រៅពីចៅទួតនិងបុព្វជនបីប្រភេទ ក្រៅពីជីតាទួត ចំណែកឯអ្នកផ្សេងទៀតបកស្រាយពាក្យនេះក្នុងន័យទូទៅថា 'សមាជិកគ្រួសារមួយ'។ យើងមិនអាចដឹងថាតើ មនុចង់និយាយអ្វីដែលជាន័យពិតប្រាកដរបស់ពាក្យនេះទេ។ ប៉ុន្តែតាម ដោយគាត់មិនបានកំណត់ន័យបច្ចេកទេស យើងអាចប្រែពាក្យដោយទុកចិត្តបំផុតតាមន័យនិរុត្តិសាស្ត្រ និងន័យទូលាយបំផុតរបស់ពាក្យនេះបានថា 'សមាជិក(ឆ្ងាយជាង)នៅក្នុងគ្រួសារ' ហើយអាចសន្មតថា គោលការណ៍សែជិតខាងសព ត្រូវកំណត់ថាជាការស្នងសម្បត្តិ។

ដោយគិតថា ការបកស្រាយរបស់អ្នកអធិប្បាយ លោកកុល្ល.មានប្រសាសន៍ថា 'តាមវិធានទូទៅនេះ គ្មានន័យអ្វីទេ បើសិនជាគេសំដៅដល់កូនប្រុសស្របច្បាប់ និងសបិណ្ឌ ផ្សេងទៀតទាំងអស់ ដែលបាននិយាយរួចហើយ ហេតុនេះកម្មវត្ថុរបស់វា គឺចង់ប្រៀនប្រដៅថា ភរិយា និងអ្នកផ្សេង ដែលមិនបានរៀបរាប់ នឹងបានទទួលមរតក។ សម្រាប់សបិណ្ឌ ដែលជាប់សែស្រឡាយជិតបំផុតក្នុងចំណោមសបិណ្ឌទាំងឡាយ ទោះជាប្រុសក្ដី ឬជាស្រីក្ដី នឹងមានកម្មសិទ្ធិលើទ្រព្យសព'។

១៨៨- ប៉ុន្តែបើគ្មាន (ទាយាទ) ទាំងអស់ ព្រាហ្មណ៍ (នឹង) ទទួលទ្រព្យនោះ (ជាអ្នកដែល) ចេះតែងកាព្យព្រះវេទបី ជាអ្នកបរិសុទ្ធ និងគ្រប់គ្រងខ្លួនឯងបាន នេះជាច្បាប់ គេមិនត្រូវបំពានទេ។

ហេតុនេះគាត់បន្តរៀបរាប់ឈ្មោះទាយាទ តាមលំដាប់ដូចតទៅ៖ ១-កូនប្រុសស្របច្បាប់ ដែលមានចំណែកជាមួយក្សេត្រជៈ (កាព្យ១៦៤) និងកូនប្រុសចិញ្ចឹមដែលមានគុណធម៌(កាព្យ១៤១) ២-កូនស្រីតាមការព្រមព្រៀង និងកូនប្រុសរបស់នាង ៣-ក្សេត្រជៈនិងកូនប្រុសជំនួសដប់នាក់ទៀត ដែលម្នាក់ៗគ្មានរៀបរាប់ឈ្មោះខាងដើម តាមបញ្ញត្តិថា កូនប្រុសរបស់ភរិយាសូទ្រៈទទួលទ្រព្យចំនួនមួយភាគដប់ប៉ុណ្ណោះ(កាព្យ១៥៤) ៤-មេម៉ាយ (ត្រង់ចំណុចនេះមានការស្រង់សេចក្ដីយ៉ាងច្រើន ហើយគេរិះគន់លោកមេធ. ដោយសារនៅក្នុងបទអធិប្បាយរបស់លោក ដែលភ្លេចពិនិត្យសំណៅដើម I.O. ដូចជាសេចក្ដីទាំងមូល លេខ១៨២-២០១ លោកបានបដិសេធសិទ្ធិទទួលមរតក) ៥-កូនស្រី ដែលមិនតាមការព្រមព្រៀង ៦-ឪពុក និងម្ដាយ ៧-បងប្អូនប្រុសបង្កើត ៨-កូនប្រុសរបស់បងប្អូនប្រុសបង្កើត ៩-យាយខាងឪពុក(កាព្យ២២៧) ១០-សបិណ្ឌ សែជិតដទៃទៀត (ក)សែស្រឡាយខាងជីតា (ខ)សែស្រឡាយខាងជីតាទួតជាដើម ១១-សមានោទកៈ ឬញាតិដែលជាប់ពាក់ព័ន្ធក្នុងការបូជាទឹក(កុល្ល. ដោយចាត់ទុក*សកុល្យ* ថាជា*សមានោទកៈ*) ១២-គ្រូ ១៣-កូនសិស្ស។ តាមលោកកុល្ល. ការបកប្រែ គឺ 'ទ្រព្យត្រូវបានទៅសែស្រឡាយជិតបំផុតក្នុងចំណោមសបិណ្ឌ(ប្រុសក៏បាន ស្រីក៏បាន) បន្ទាប់មក (បើគ្មានសបិណ្ឌ) *សមានោទកៈ* គឺជា(ទាយាទ) បន្ទាប់មកគ្រូ ហើយបន្ទាប់មកទៀត គឺកូនសិស្ស'។ លោករាឃ. យល់ស្របតាមការបកស្រាយនេះផ្នែកសារជាតុ ប៉ុន្តែដើម្បីបង្កើតជាវិធានច្បាប់ ភាគច្រើនឯកភាពតាមយញ្ញ. ជំពូក២ លេខ១៣៥-១៣៦ លោកបញ្ជាក់ថា ពន្ធុ ឬញាតិលោហិត ក៏មានបង្កប់ន័យដោយពាក្យ *សកុល្យ* ដែរ។ ការបកស្រាយពាក្យទីមួយរបស់លោកក៏ខុសគ្នាពីការបកស្រាយរបស់កុល្ល. ហើយស្របតាមគោលការណ៍វេយ្យាករណ៍ច្រើន គឺ 'អ្នកដែលជាប់សែស្រឡាយជិតបំផុតនឹងសបិណ្ឌ គឺ កូនប្រុសស្របច្បាប់ និងកូនប្រុសរបស់កូនស្រី(ដូចបានរៀបរាប់)ទីប្រាំ ភរិយា និងអ្នកដទៃទៀត (មានបញ្ជាក់នៅក្នុងយញ្ញ. ជំពូក២ លេខ១៣៥-១៣៦)'។ លោករាឃ. និងកុល្ល. បញ្ជាក់ច្បាប់ពីការសរសេររបស់យញ្ញ. ហើយបំលែងទៅជាអត្ថបទរបស់មនុ ដោយមិនត្រឹមត្រូវសោះ សម្រាប់គំនិតរបស់អ្នកក្រោយនេះ។ កំណត់សម្គាល់ដ៏ខ្លីផ្សេងគ្នារបស់លោកនារ. មិនបាននិយាយច្បាស់ទេ។ លោកបកស្រាយពាក្យទីមួយថា *អេសាំ មធ្យេ សបិណ្ឌានាំ អតោ ឋោ [យោ]មន្តរោ យថា បុត្រស្យ បិតា តស្យ តតបិតេត្យាទិ តស្យ តស្យ តទ្ធនំ*ក្នុងចំណោមសបិណ្ឌ ទាំងនោះ សែស្រឡាយជិតគាត់បំផុត គឺឪពុកដល់កូនប្រុសរបស់គាត់ ឪពុករបស់គាត់ដល់ខ្លួនគាត់ជាដើម ហើយទ្រព្យតែងតែ ជាកម្មសិទ្ធិរបស់គាត់ជានិច្ច'។ បន្ទាប់មក គាត់រៀបរាប់ បើគ្មានឪពុក ម្ដាយ និងកូនប្រុសរបស់ខ្លួន ជីតា សមានោទកៈ សគោត្រ និង 'ពន្ធុ ពោលគឺ អ៊ំខាងម្ដាយ និងអ្នកផ្សេងទៀត' ជាទាយាទស្នងមរតក ហើយបកស្រាយពាក្យ*សកុល្យ*ថា *ពន្ធុ*។

លោកនន្ទ. ដែលអត្ថបទរបស់លោកសរសេរ *សបិណ្ឌាហៈ* ដោយមិនត្រឹមត្រូវ អះអាងថា *បិណ្ឌ* (សបិណ្ឌ?) មានន័យថា 'អ្នកស្លាប់' ហើយបកស្រាយសែស្រឡាយទីមួយ ដោយនិយាយថា 'អ្នកដែលជាសបិណ្ឌ សែស្រឡាយជិតបំផុតនឹងអ្នកស្លាប់ មានសិទ្ធិទទួលទ្រព្យជានិច្ច ពោលគឺការសរសេរច្រើនសា(ពាក្យ *តស្យ*) បង្ហាញពីលំដាប់ស្នងមរតក'។ តាមប្រសាសន៍របស់គាត់ ពាក្យ *សកុល្យ* គឺ *សមានោទកៈ*។ លោកសរសេរ *សកុល្យាះ ស្យុះ*សកុល្យ គឺជាទាយាទ'។

**១៨៨.** គោត. ជំពូក២៨ លេខ៤១; វស. ជំពូក១៧ លេខ៨៤-៨៦; ពោធ. ជំពូក១ លេខ៣, ១៣, ១៤; វិ. ជំពូក១៧ លេខ១៣-១៤។ តាមលោកកុល្ល. ឃ្លា 'បើគ្មាន(ទាយាទ)ទាំងអស់' គឺ 'អ្នកទាំងឡាយដូចបានរៀបរាប់'(រាឃ.) ឬ 'គ្មានបុរស និងស្ត្រីទាំង អស់ដែលជាប់សែស្រឡាយសោះ(ជាមួយអ្នកស្លាប់)'(នន្ទ.) ចង្អុលបង្ហាញថា បុគ្គលដទៃដែលមិនបានរៀបរាប់ឈ្មោះ ដូចជាសិស្សរួមថ្នាក់ ក៏នឹងមានសិទ្ធិទទួលមរតកបាន។ 'ព្រាហ្មណ៍' ពោលគឺ 'ដូចជារស់នៅក្នុងភូមិជាមួយ' (នារ.)។ 'បរិសុទ្ធ' គឺ 'យកចិត្តទុកដាក់ចំពោះភាពបរិសុទ្ធខាងក្រៅ និងខាងក្នុង'(កុល្ល.) ឬថា 'ជាអ្នកដែលមានការប្រព្រឹត្តល្អ'(នារ.)។ តាមលោកកុល្ល. និងរាឃ. អត្ថន័យនៃអនុប្រយោគចុងក្រោយ គឺថា ព្រាហ្មណ៍ដែលទទួលទ្រព្យ នឹងធ្វើពិធីបូជាបុណ្យសព ហេតុនេះគឺគ្មានការបំពានច្បាប់ពាក់ព័ន្ធនឹងពិធីស្រាទ្ធនោះទេ។ លោកនារ.គូសបញ្ជាក់ថា វិធានច្បាប់នេះដូចមានកាព្យបញ្ជាក់បង្ហាញខាងក្រោម សំដៅតែទៅលើកម្មសិទ្ធិរបស់ព្រាហ្មណ៍ប៉ុណ្ណោះ។

១៨៩- ព្រះរាជាមិនត្រូវដកយកកម្មសិទ្ធិរបស់ព្រាហ្មណ៍នោះទេ នេះជាច្បាប់បញ្ញត្តិ ប៉ុន្តែ(កម្មសិទ្ធិរបស់មនុស្ស)វណ្ណៈផ្សេង ព្រះរាជាអាចដកយកបាន បើគ្មាន(ទាយាទ)ទាំងអស់។

១៩០- (បើមេម៉ាយ) របស់បុរសម្នាក់ដែលចែកឋានទៅដោយគ្មានកូន ចិញ្ចឹមកូនប្រុសម្នាក់ឱ្យគាត់ តាមរយៈសមាជិកគ្រួសារ (សគោត្រ) នាងនឹងប្រគល់ឱ្យ (កូនប្រុស) នោះ នូវទ្រព្យទាំងអស់ ដែលជាកម្មសិទ្ធិរបស់(អ្នកស្លាប់)។

១៩១- ប៉ុន្តែប្រសិនបើ(កូនប្រុស)ពីរនាក់ ដែលផ្តល់កំណើតដោយ (បុរស) ពីរនាក់ផ្សេងគ្នា ទាមទារយកទ្រព្យ(ដែលនៅក្នុងដៃ) របស់ម្តាយខ្លួន ម្នាក់ៗនឹងទទួលយកនូវអ្វីដែលជាកម្មសិទ្ធិរបស់ឪពុកខ្លួន គឺមិនរាប់បញ្ចូលទ្រព្យផ្សេងទេ។

១៩២- ប៉ុន្តែបើម្តាយនោះបានចែកឋានទៅ បងប្អូនប្រុសរួមផ្ទៃនិងបងប្អូនស្រីរួមផ្ទៃ នឹងទទួលបានចំណែកទ្រព្យរបស់ម្តាយស្មើៗគ្នា។

---

**១៨៩.** អាប. ជំពូក២ លេខ១៤, ៥; គោត. ជំពូក២៨ លេខ៤២; វស. ជំពូក១៧ លេខ៨៣; ពោធ. ជំពូក១ លេខ១៣, ១៥-១៦។ តាមលោកកុល្លូ. និងរាឃ. ការសរសេរច្រើនដងអំពីការហាមទទួលទ្រព្យរបស់ព្រាហ្មណ៍ សបញ្ជាក់ថា បើគេរកមិនឃើញមានអ្នកចេះដឹង និងព្រាហ្មណ៍ដែលមានគុណធម៌ទេ ព្រះរាជានឹងប្រទានទ្រព្យរបស់ព្រាហ្មណ៍ ដែលស្លាប់ទៅដោយគ្មានទាយាទនោះ ទៅឱ្យបុរសដែលគ្មានអ្វីសោះ តែមានឈ្មោះជាវណ្ណៈព្រាហ្មណ៍ក៏បាន។

**១៨៩.** តាមលោកកុល្លូ. និងរាឃ. កាព្យនេះសំដៅទៅលើករណី ដែលអ្នកមេម៉ាយ មានការយល់ព្រមត្រឹមត្រូវ ឱ្យមានកូនប្រុសជាមួយសាច់ញាតិរបស់ប្តីនាង ហើយអនុវត្តវិធានច្បាប់ដូចបានបញ្ជាក់ជូនក្នុងកាព្យលេខ១៤៦ ដែលក្នុងន័យនេះ គឺ 'ជាបញ្ញត្តិបញ្ជាក់អំពីអ្នកមេម៉ាយ'។ លោកកុល្លូ. បន្ថែមថា គោលបំណងក្នុងការបញ្ជាក់ម្តងហើយម្តងទៀត គឺចង់បង្ហាញថា មិនត្រឹមតែបងប្អូនប្រុសថ្លៃ ឬសបិណ្ឌ ដូចមានបញ្ជាក់នៅក្នុងកាព្យលេខ៥៩ ប៉ុណ្ណោះទេ តែថែមទាំងសាច់ញាតិឆ្ងាយសគោត្រ ក៏អាចផ្តល់កំណើតកូនប្រុស ឱ្យបុរសដែលស្លាប់ទៅដោយគ្មានកូននោះបាន។ ផ្ទុយទៅវិញ លោកនារ. គិតថា អនុលោមតាមកាព្យនេះ ក្មេងដែលអ្នកមេម៉ាយពពោះជាមួយសគោត្រ សូម្បីគ្មានការព្រមព្រៀងក៏ដោយ នឹងទទួលទ្រព្យរបស់ប្តីស្លាប់របស់អ្នកមេម៉ាយនោះ(សគោត្រាទ យទិ តន្តំ សំតានំ អាហរេទ អនិយុ ក្តាបិ ស្ត្រី តទា គោលកតេ´ បិ តស្យញាត្យន្តរាភវេ ក្សេត្របតិធនហារិត្វំ ឥតី អាថះ)។ គាត់បន្ថែមថា អ្នកខ្លះអនុវត្តវិធានច្បាប់នេះចំពោះស្ត្រីសូទ្រៈប៉ុណ្ណោះ ហើយថា តាមមតិយោបល់របស់អ្នកទាំងអស់នេះ គូធជៈ, កានីន និង សហោធៈ ក៏ត្រូវគេចាត់ទុកជាកូនប្រុស ក្នុងករណីរបស់សូទ្រៈប៉ុណ្ណោះ មិនមែនក្នុងករណីរបស់អារ្យ៉ៃនទេ។

**១៩១.** កុល្លូ. និងនន្ទ. គិតថា កាព្យនេះសំដៅដល់ករណីដែលស្ត្រីរៀបការប្តីអ្នកបន្តបន្ទាប់ នឹងមានកូនប្រុសមួយម្នាក់។ ប្រសិនបើប្តីទាំងពីរស្លាប់ទៅ ហើយទ្រព្យរបស់ប្តីស្ថិតក្នុងដៃរបស់ភរិយា នាងត្រូវប្រគល់ទ្រព្យទាំងអស់របស់ប្តីទី២របស់នាងទៅកូនប្រុសគាត់ និងទ្រព្យរបស់ប្តីទីពីរ ឱ្យទៅកូនប្រុសរបស់អ្នកក្រោយនេះ។ លោករាឃ. ធ្វើការបកស្រាយដូចគ្នា ប៉ុន្តែមានសំណើមួយថា 'បើ(កូនប្រុស)ទាំងពីរ ដែលផ្តល់កំណើតដោយបុរសពីរនាក់ផ្សេងគ្នា ទាមទារទ្រព្យដោយឡែករបស់ម្តាយពួកគេជាដើម'។ សម្រាប់ស្ត្រីដែលរៀបការពីរដង នឹងទទួលអំណោយអាពាហ៍ពិពាហ៍ និងអំណោយផ្សេងទៀតពីប្តីទាំងពីរ។ បន្ទាប់ពីនាងស្លាប់ កូនប្រុសម្នាក់ៗនឹងទទួលអ្វីដែលឪពុករបស់គេផ្តល់ឱ្យនាង។ លោកនារ. ចុងក្រោយអះអាងថា កាព្យនេះសំដៅដល់វិវាទរវាងកូនប្រុសស្របច្បាប់ និងគោលកៈ ឬបូនភវ ចំពោះទ្រព្យរបស់ឪពុករៀងខ្លួន ដែលស្ថិតក្នុងដៃរបស់ម្តាយពួកគេ។ លោកជដែករកខុសត្រូវពាក្យ *ស្រិយាះ* ជាមួយពាក្យ *ជាតោ*ដែលផ្តល់កំណើតដោយ(បុរស)ពីរនាក់ផ្សេងគ្នាជាមួយស្ត្រីម្នាក់'។

**១៩២.** លោកកុល្លូ. និងរាឃ. កំណត់វិធានច្បាប់នេះ តាមសេចក្តីរបស់ព្រហស្បតិ ត្រឹមកូនស្រីដែលមិនទាន់រៀបការ ហើយសន្និដ្ឋានថា កូនស្រីរៀបការរួច ទទួលបានត្រឹម 'និមិត្តរូបនៃការគោរព'។ អ្នកក្រោយនេះ តាមលោកកុល្លូ. គឺបាន 'មួយភាគ

១៩៣- សូម្បីអ្វីក៏ដោយដែលគេឱ្យទៅកូនស្រីរបស់ (កូនស្រី) ទាំងនោះ ហាក់ដូចជាក្រៅពីទ្រព្យរបស់ជីដូនខាងម្តាយរបស់ពួកគាត់ តាមការពេញចិត្ត។

១៩៤- អ្វី (ដែលប្រគល់ឱ្យ) នៅពីមុខភ្លើង (អាពាហ៍ពិពាហ៍) អ្វី(ដែលឱ្យ)នៅពេលដង្ហែកូនក្រមុំអ្វីដែលឱ្យជានិមិត្តរូបនៃសេចក្តីស្រឡាញ់ និងអ្វីដែលបានទទួលពីបងប្អូនប្រុស ម្តាយឬឪពុករបស់នាង គេហៅទ្រព្យនោះ ជាទ្រព្យប្រាំមួយភាគរបស់ស្ត្រី។

១៩៥- (ទ្រព្យបែបនេះ) ព្រមទាំងការឱ្យនៅពេលក្រោយ និងអ្វីដែលត្រូវប្រគល់ (ឱ្យនាង) ដោយប្តីជាទីស្រឡាញ់របស់នាង នឹងត្រូវធ្លាក់ក្នុងដៃកូនចៅរបស់នាង (សូម្បីតែ)នាងស្លាប់ក្នុងពេលប្តីរបស់នាងនៅរស់ក៏ដោយ។

១៩៦- តាមសេចក្តីបង្គាប់គឺថា ទ្រព្យ(របស់ស្រីរៀបការរួច) ស្របតាមពិធីព្រហ្ម ទេវ អាសៈ គាន្ធវៈ ឬពិធីប្រាជាបត្យ (នឹងក្លាយជារបស់)ប្តីនាងតែម្នាក់ប៉ុណ្ណោះ ប្រសិនបើនាងស្លាប់ទៅដោយគ្មានកូន។

១៩៧- ប៉ុន្តែដោយមានការរៀបរាប់ថា ទ្រព្យដែលត្រូវប្រគល់ឱ្យ(ភរិយា)ក្នុងពេលធ្វើពិធីអសុរៈ ឬ(ពិធីមួយក្នុងចំណោមពិធីរៀបការផ្សេងទៀតដែលគេគួរទិតៀន នឹងក្លាយជា)របស់ម្តាយនាង និងរបស់ឪពុកនាង ប្រសិនបើនាងស្លាប់ទៅដោយគ្មានកូន។

១៩៨- ទ្រព្យអ្វីក៏ដោយដែលឪពុករបស់នាងបានប្រគល់ឱ្យភរិយា (ភរិយាពីរដែលមានវណ្ណៈខុសគ្នា) គឺកូនស្រីរបស់(ភរិយា)ព្រាហ្មណី ឬកូន(របស់កូនស្រី)នោះ នឹងទទួលទ្រព្យនោះ។

---

ដប់នៃមួយចំណែក'។ សូមមើលកាព្យលេខ១១៨ ខាងលើ។ លោកនារ. និយាយថា ពាក្យ 'ទ្រព្យរបស់ម្តាយ' សំដៅទៅលើ 'ទ្រព្យផ្សេងទៀតក្រៅពីស្ត្រីធនៈ ឬទ្រព្យដោយឡែក' ហើយបន្ថែមសំនួនពាក្យថា *អបុត្រៈ*បងប្អូនស្រី' អ្នកដែលគ្មានកូនប្រុស។ យ៉ាងណាមិញ តាមការលើកឡើងរបស់លោកកុល្ល. និងរាឃ. គាត់ផ្តល់យោបល់មួយ ដែលបញ្ជាក់ថា ទ្រព្យជារបស់ 'មនុស្សមួយចំនួន'។

**១៩៣.** លោកកុល្ល. អះអាងថា គឺជាចៅស្រីដែលមិនទាន់រៀបការ។ លោកនារ. និយាយថា 'ពេលកូនស្រីរៀបការរួចនោះចែកឋានទៅ កូនស្រីរបស់ពួកគេនឹងទទួលបានចំណែកដែលម្តាយរបស់ខ្លួនបានទទួលជានិមិត្តរូបនៃការគោរពតាមឆន្ទៈរបស់អំខាងម្តាយរបស់ពួកគេ'។ លោករាឃ. ក៏គិតថា 'តាមការពេញចិត្ត' មានន័យថា 'តាមចិត្តមេត្តា(របស់ទាយាទ)'។ ប៉ុន្តែលោកនន្ទ. ទាញសេចក្តីសន្និដ្ឋានចេញពីពាក្យដដែលនេះ ថាជាការប្រគល់ឱ្យតាមការចាំបាច់ប៉ុណ្ណោះ។

**១៩៤.** វិ. ជំពូក១៧ លេខ១៧; យញ្ញ. ជំពូក២ លេខ១៤៣។ 'អ្វីដែលត្រូវឱ្យជានិមិត្តរូបនៃសេចក្តីស្រឡាញ់' គឺ 'ដោយប្តី' (នារ. ថា *រតិកាលិ*)។

**១៩៥.** យញ្ញ. ជំពូក២ លេខ១៤៤។ លោកកុល្ល. និងនារ. បញ្ជាក់ថា ទ្រព្យដោយឡែកទាំងពីររបស់ស្ត្រី មានរៀបរាប់នៅក្នុងកាព្យលេខ១៩៤ ហើយទ្រព្យដែលមានរាប់ឈ្មោះនៅក្នុងកាព្យលេខ១៩៥ ត្រូវធ្លាក់ទៅលើកូនរបស់នាង ពោលគឺ 'ទៅលើកូនប្រុសរបស់នាង និងអ្នកផ្សេងទៀត'(រាឃ.) ឬ 'ទៅលើកូនប្រុស ឬកូនស្រីរបស់នាង'(នន្ទ.)។ លោកនារ. កត់សម្គាល់ឃើញថា 'ការឱ្យនៅពេលក្រោយ' និង 'ការឱ្យតាមការពេញចិត្តរបស់ប្តី' មិនមែនជាស្ត្រីធន ឬជាទ្រព្យដោយឡែកទេ ហើយថា ដូចនេះប្រពន្ធគ្មានសិទ្ធិបែងចែកដោយសេរី ទៅឱ្យអ្នកទាំងពីរនោះទេ។

**១៩៦-១៩៧.** វិ. ជំពូក១៧ លេខ១៩-២០; យញ្ញ. ជំពូក២ លេខ១៤៥។

**១៩៦.** លោកនារ. បន្ថែមលើពាក្យ 'ទ្រព្យ' គឺ *ស្ត្រីធនាស្ត្រីធនរូបំ* ទោះជាទ្រព្យដោយឡែក ឬមិនដោយឡែកក៏បាន'។

**១៩៨.** ពោលគឺ ប្រសិនបើព្រាហ្មណ៍មានភរិយា ជាវណ្ណៈព្រាហ្មណ៍មួយ និងក្សត្រិយមួយ ទ្រព្យដែលគ្រួសាររបស់នាងឱ្យដោយរបៀបណាក៏ដោយ ទៅភរិយាជាក្សត្រិយ នឹងបានទៅកូនស្រីរបស់ភរិយាព្រាហ្មណ៍ ឬប្រសិនបើកូនស្រីរបស់ភរិយា

១៩៩- ស្ត្រីមិនត្រូវលាក់ទុក(ទ្រព្យរបស់)គ្រួសារខ្លួន ដែលជាទ្រព្យរួមសម្រាប់មនុស្សជាច្រើន និងមិនលាក់ទុកទ្រព្យ(ដោយឡែករបស់ប្តី)ខ្លួន ដោយគ្មានការអនុញ្ញាតនោះទេ។

២០០- គ្រឿងអលង្ការដែលស្ត្រីពាក់ក្នុងកំលុងពេលប្តីរបស់ខ្លួននៅរស់ ទាយាទរបស់ប្តីមិនទាន់បែងចែក ហើយអ្នកដែលបែងចែកទ្រព្យនោះ នឹងក្លាយជាចណ្ឌាល។

២០១- មនុស្សកម្រៀវនិងចណ្ឌាល (មនុស្ស)ងងឹតភ្នែក ឬថ្លង់ពីកំណើត ឆ្កួត មនុស្សឡប់សតិ និង មនុស្សគ ព្រមទាំងមនុស្សដែលខ្វះអវយវៈណាមួយ (នៃអំពើឬអារម្មណ៍) មិនទទួលបាន ចំណែកទេ។

២០២- ប៉ុន្តែគឺថា (បុរស) ដែលចេះ(ច្បាប់) គួរផ្តល់អាហារ និងខោអាវដល់ពួកគេទាំងអស់ ដោយមិន ខ្វះខាត ស្របតាមលទ្ធភាពរបស់ខ្លួន ហើយអ្នកដែលមិនបរិច្ចាគ នឹងក្លាយជាមនុស្ស ក្រៅវណ្ណៈ (ចណ្ឌាល)។

---

ព្រាហ្មណ៍នោះស្លាប់ ហើយបន្សល់ទុកកូនមួយ ត្រូវបានទៅអ្នកក្រោយនេះ។ ដូច្នេះគេមិនរាប់បញ្ចូលកូនប្រុសរបស់ភរិយាព្រាហ្មណ៍ទេ'(កុល្លូ., នារ.)។ លោកនារ. បញ្ជាក់យ៉ាងច្បាស់ថា ពាក្យ 'កូន' សំដៅតែកូនស្រីប៉ុណ្ណោះ។

**១៩៩.** លោកកុល្លូ. និងរាឃ. តាមការបកស្រាយនៅក្នុងការបកប្រែរបស់លោកខាងក្រោម ប្រែអនុប្រយោគទីមួយ សំដៅដល់ទ្រព្យគ្រួសាររួម និងទីពីរ សំដៅដល់ទ្រព្យដោយឡែករបស់ប្តី។ ប៉ុន្តែយោងតាមលោកនារ. និងនន្ទ. ការប្រែគួរតែថា 'ភរិយាមិនគួរទទួលបានអ្វី(សម្រាប់ចំណាយផ្ទាល់ខ្លួនទេ) ពី(ទ្រព្យរបស់ប្តីខ្លួន សម្រាប់ទ្រទ្រង់គ្រួសាររបស់ពួកគេដែលមានមនុស្សជាច្រើន ហើយមិនយកទ្រព្យផ្ទាល់របស់ពួកគេ (ដែលមិនមែនជា*ស្ត្រីធនៈ*) ដោយគ្មានការយល់ព្រមពីប្តីរបស់ខ្លួនទេ'។ ការបកស្រាយរបស់នារ. *និហារំ កុរ្យុះ*(មិនគួរ)ទទួលបានអ្វីទេ' ហាក់ដូចជាការបកស្រាយរបស់លោកកុល្លូ. និងរាឃ. ប្រសើរជាង។

**២០០.** វិ. ជំពូក១៧ លេខ២២។ 'ទាយាទរបស់គាត់' គឺ 'កូនប្រុស និងអ្នកដទៃទៀត'(កុល្លូ., នារ.)។ លោកនន្ទ. ដែលយល់ផ្សេងពីការបកស្រាយខាងលើ មានប្រសាសន៍ថា 'ដោយហេតុថាគ្រឿងអលង្ការជាកម្មសិទ្ធិរបស់ប្តី ព្រោះទ្រព្យនោះមិនមែនជា*ស្ត្រីធនៈ* គោលបំណងនៃសេចក្តីនេះ គឺហាមមិនឲ្យប្រគល់ទៅទាយាទ ខណៈដែលប្តីនៅមានជីវិត' (អលំ កាលស្យ ស្ត្រីធនេ នុទិស្តត្វាទ ភរត្តធនត្វេន ភរត្តភាវេ ទាយាទានាំ ប្រាប្ត្យបវាទារថោ យំ អារមភះ)។ ហេតុនេះ លោកនន្ទ. ទំនងជាអធិប្បាយ *បត្យោ ជាវតិ* ដោយពាក្យ *ភជេរេ* ដូចលោកនន្ទបណ្ឌិត បកស្រាយនៅក្នុងសេចក្តីប្រហាក់ប្រហែលគ្នានៃស្លែ (សូមមើលកំណត់សម្គាល់របស់សាស្ត្រាចារ្យ Jolly)។

**២០១-២០៣.** អាប.ជំពូក២ លេខ១៤, ១, ១៥; គោត. ជំពូក២៨ លេខ២៣, ៤០, ៤៣; វស. ជំពូក១៧ លេខ៥២-៥៣; ពោធ. ជំពូក២ លេខ៣, ៣៧-៤០; វិ. ជំពូក១៥ លេខ៣២-៣៧; យញ្ញ. ជំពូក២ លេខ១៤០-១៤១។

**២០១.** 'មនុស្សកម្រៀវ' គឺ 'ជាជំងឺដែលមើលមិនជា' ពាក្យ 'ចណ្ឌាល' គឺ 'អ្នកដែលមានទោសប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ (មហាបាតកៈ) នៅមុនពេលពួកគេធ្វើតបៈ' ពាក្យ 'ឆ្កួត' គឺសំដៅ 'អ្នកដែលមានជំងឺមិនអាចព្យាបាលបាន'(នារ.)។ 'អ្នកដែលខ្វះខាតអវយវៈណាមួយ គឺសម្រាប់ធ្វើសកម្មភាព'(នន្ទ.) ដូចជាមនុស្សពិការ (កុល្លូ., នន្ទ.) ដូចជាមនុស្សគ្មានដៃ (រាឃ.) ឬ 'សម្រាប់ដឹងអារម្មណ៍' ដូចជាមនុស្សដែលបាត់បង់កាយវិញ្ញាណ(នារ.)។

**២០២.** លោកមេធ. និងកុល្លូ. ប្រែ *អត្យន្តំ* 'ដោយមិនខ្វះខាត' ក្នុងន័យ 'សម្រាប់ការរស់នៅ'។ លោកនារ. ពន្យល់ពាក្យនេះដោយពាក្យ *អទទ័ត* ហើយបកស្រាយថា 'អ្នកដែលមិនបរិច្ចាគទាល់តែសោះ'។ លោកនន្ទ. អាន *អត្យង្គំ* 'គ្រឿងអលង្ការ' សម្រាប់ពាក្យ *អត្យន្តំ*ដោយមិនខ្វះខាត'។

២០៣- ប្រសិនបើមនុស្សកម្រៀវ និងអ្នកផ្សេងទៀត ដោយមិនដឹងហេតុផល ឬមានហេតុផលផ្សេង ចង់បានប្រពន្ធ នៅពេលមានកូន កូនរបស់ពួកគេសមនឹងមានចំណែក។

២០៤- ទ្រព្យអ្វីក៏ដោយ ដែល(កូនប្រុស)ច្បងបង្អស់ទទួលបាន (ដោយសារការប្រឹងប្រែងផ្ទាល់របស់ខ្លួន) បន្ទាប់ពីឪពុកទទួលមរណភាព មួយចំណែកនៃទ្រព្យនោះ (នឹងបានទៅ)ប្អូនប្រុសរបស់គាត់ ឱ្យតែពួកគេមានការរីកចម្រើនត្រឹមត្រូវក្នុងការសិក្សា។

២០៥- ប៉ុន្តែប្រសិនបើពួកគេទាំងអស់ ដែលមិនបានសិក្សា រកទ្រព្យបានដោយសារកម្លាំងពលកម្មរបស់ពួកគេ ការបែងចែកទ្រព្យត្រូវតែឱ្យស្មើៗគ្នា (ព្រោះទ្រព្យនោះ) មិនមែនជាទ្រព្យដែលឪពុករកបាន ពោលគឺនេះជាវិធានច្បាប់ដែលបានបញ្ញត្តិទុកមក។

---

**២០៣.** លោកមេធ. មានមតិថា អ្នកខ្លះក្នុងចំណោមមនុស្សទាំងឡាយ ដែលគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការទទួលមរតកទេ គឺ*ភតរេតះ ក្លីព* អ្នកដែលងងឹតភ្នែកពីកំណើត និងពិការ អាចរៀបការបាន ចំណែកឯពួកចណ្ឌាល មនុស្សឆ្កួត និងអ្នកផ្សេងទៀត មិនអាចរៀបការបានទេ។ ដូច្នេះ គេអាចប្រែអនុប្រយោគភ្ជាប់លក្ខខណ្ឌ ក្នុងន័យដូចបានជម្រាបជូនក្នុងការបកប្រែខាងលើ។ យ៉ាងណាមិញ លោកបន្ថែមថា វិធានច្បាប់ក៏អាចសំដៅដល់ករណីទាំងឡាយ ដែលកង្វះលក្ខណៈសម្បត្តិកើតឡើង បន្ទាប់ពីការរៀបអាពាហ៍ពិពាហ៍។ ការបកស្រាយរបស់លោកនារ. គឺដូចគ្នាផ្នែកសារជាតុ។ ប៉ុន្តែលោកគិតថា មនុស្សកម្រៀវ និងចណ្ឌាល មិនអាចធ្វើកិច្ចសន្យារៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានទេ ហើយថា សំនួនពាក្យ *ក្លិពាទយះ* តាមន័យត្រង់គឺ 'ទីមួយ គឺអ្នកដែលស្ថិតក្នុងចំណោមមនុស្សកម្រៀវ' សំដៅដល់ 'មនុស្សងងឹតភ្នែកពីកំណើតជាដើម'។ លោកក៏ព្រមទទួលស្គាល់សិទ្ធិរបស់កូនប្រុសក្សេត្រជៈរបស់មនុស្សកម្រៀវនិងចណ្ឌាល ដែលបានធ្វើកិច្ចសន្យារៀបអាពាហ៍ពិពាហ៍ នៅមុនពេលកើតមានកង្វះខាតលក្ខណៈសម្បត្តិរបស់ពួកគេ។ លោកកុល្ល. និយាយថា 'ដោយការប្រើពាក្យ "ដោយមិនដឹងហេតុផល ឬមានហេតុផលផ្សេង" ចង់បញ្ជាក់ថា មនុស្សកម្រៀវ និងអ្នកដទៃទៀត មិនសមនឹងរៀបការទេ'។ នៅក្នុងសេចក្តីនេះ លោកបកស្រាយពាក្យ 'កូន' ដោយពាក្យ *ក្សេត្រជៈ*។ លោករាឃ. និងនន្ទ. យល់ស្របតាមគាត់ ដោយយកគំនិតមួយក្រោយ។

**២០៤.** វិធានច្បាប់ តាមពិត សំដៅដល់គ្រួសារដែលនៅជុំគ្នាប៉ុណ្ណោះ(កុល្ល.)។ លោកមេធ. ទាញយោបល់ពីសំនួនពាក្យ *វិទ្យានុបាលិនះ* ឱ្យតែពួកគេមានការរីកចម្រើនក្នុងការសិក្សាបានល្អ'ក្នុងន័យថា 'មនុស្សដែលចិញ្ចឹមជីវិតដោយការសិក្សាមានយន្តការី និងអ្នកជំនាញ ដូចជាគ្រូពេទ្យ អ្នកសម្តែង អ្នកចម្រៀងជាដើម'។ លោកនារ. និងនន្ទ. សន្និដ្ឋានថា បងប្រុសបង្អស់ មិនអាចទាមទារនូវចំណែក ដោយផ្អែកលើព្រឹត្តិការណ៍ដូចគ្នានឹងករណីរបស់ប្អូនប្រុសពៅគេនោះទេ ដោយហេតុថា កាព្យនេះបញ្ជាក់តែពីបងប្រុសបង្អស់ប៉ុណ្ណោះ ហើយដោយសារកាព្យបន្ទាប់ប្រកាសថា របស់រកបានថ្មីរបស់សមាជិកណាមួយក្នុងចំណោមគ្រួសារដែលគ្មានការចេះដឹង អាចធ្វើការបែងចែកគ្នាបាន។

**២០៥.** គោត. ជំពូក៣៨ លេខ៣១។ វិធានច្បាប់នេះ សំដៅដល់របស់រកបានថ្មី ដោយការធ្វើពាណិជ្ជកម្ម(មេធ., កុល្ល., នារ.) ដោយកសិកម្ម(មេធ., កុល្ល., នន្ទ.) ឬដោយការបម្រើព្រះរាជា(មេធ.)។ 'ព្រោះថាការបែងចែកត្រូវតែស្មើគ្នា បងបង្អស់មិនទទួលបានចំណែកអនុគ្រោះទេ'(មេធ., កុល្ល., នន្ទ.)។ លោកមេធ. បន្ថែមថា ព្រោះសំនួនពាក្យ 'ព្រោះថាវាមិនមែនជាទ្រព្យដែលឪពុករកបាន' ផ្តល់ហេតុផលឱ្យមានការបែងចែកស្មើគ្នា ហើយវិធានដដែលបញ្ជាក់ច្បាស់ពីការបែងចែកទ្រព្យរបស់នរណាម្នាក់ ដែលបានចែកឋានទៅ ដោយគ្មានកូន។ លោកនន្ទ. ពន្យល់*អបិត្រ្យ ឥតិ* ថា *អបិត្រ្យៈ ឥតិ* ហើយបកស្រាយថា 'ព្រោះឪពុកមិនបានធ្វើ(ការបែងចែក)'។

២០៦- ទ្រព្យ(ដែលរកបាន)ដោយការសិក្សា គឺជាកម្មសិទ្ធិរបស់អ្នកដែលបានទទួលតែម្នាក់គត់ ដូចគ្នានឹងអំណោយរបស់មិត្ត ជាអំណោយដែលទទួលបាននៅថ្ងៃអាពាហ៍ពិពាហ៍ ឬជាវត្ថុសម្រាប់ដាក់ទឹកឃ្មុំ។

២០៧- ប៉ុន្តែប្រសិនបើបងប្អូនប្រុសម្នាក់ ដែលមានមុខរបរផ្ទាល់ខ្លួន អាច(ចិញ្ចឹមជីវិតខ្លួនឯងបាន) មិនចង់បាន(ចំណែកទ្រព្យគ្រួសារ)បងប្អូនប្រុសផ្សេងទៀតអាចទុកគេម្នាក់នោះដោយឡែក ដោយឱ្យទទួលបានបន្តិចបន្តួចនៃចំណែករបស់ខ្លួន ដើម្បីចិញ្ចឹមជីវិត។

២០៨- អ្វីដែល(ប្អូនប្រុស)ម្នាក់ទទួលបានដោយសារកម្លាំងពលកម្មរបស់ខ្លួន ដោយមិនប្រើទ្រព្យសម្បត្តិរបស់ឪពុក ទ្រព្យដែលរកបានដោយការប្រឹងប្រែងដោយផ្ទាល់តែម្នាក់ឯងនោះ គាត់នឹងមិនបែងចែកទេ លើកលែងតែគាត់មានចិត្តចង់ចែក(ជាមួយបងប្អូនប្រុសរបស់គាត់)។

---

**២០៦.** យញ្ញ. ជំពូក២ លេខ១១៨-១១៩។ 'ទ្រព្យដែលរកបានដោយការសិក្សា' គឺ 'ថ្លៃបង្រៀន ឬថវិកាដែលទទួលបានពីភាពស្ទាត់ជំនាញផ្នែកសិល្បៈ'(មេធ., នន្ទ.) តាមអត្ថបទរបស់កាត្យាយនៈ ដែលលោកកុល្លូ. និងរាឃ.បានដកស្រង់ (សូមមើល Colebrooke ជំពូក៥ កម្រងអត្ថបទលេខ៣៤៧) មានរាប់បញ្ចូលអំណោយរបស់កូនសិស្ស អំណោយសម្រាប់ការរៀបចំពិធីយញ្ញ ថ្លៃសម្រាប់ការដោះស្រាយប្រស្នាពិបាកៗពាក់ព័ន្ធនឹងការសម្រេចសេចក្តីផ្នែកសីលធម៌ ឬសម្រាប់ការបញ្ជាក់ការពិតនូវចំណុចសង្ស័យនៅក្នុងច្បាប់ រង្វាន់សម្រាប់ការបង្ហាញចំណេះដឹង ឬសម្រាប់ជ័យជម្នះ ក្នុងការប្រកួតប្រជែងចំណេះដឹង ឬសម្រាប់ការសូត្រព្រះវេទ ដោយសមត្ថភាពជំនាញដ៏វិសេសវិសាល។ តួយ៉ាងដីធ្លី ដែលគេផ្តល់ឱ្យជា *វិទ្យាធន* មានរៀបរាប់នៅក្នុងសិលាចារឹក សូមមើលឧទាហរណ៍សៀវភៅ*ស្វែងយល់ពីឥណ្ឌា* ជំពូក១២ ទំព័រ១៩៥B, ១. ៦។ 'អំណោយដែលទទួលបាននៅថ្ងៃរៀបអាពាហ៍ពិពាហ៍' គឺ 'អ្វីៗ(ដែលកូនកំលោះ)ទទួលបានពីសាច់ញាតិខាងភរិយារបស់ខ្លួន'(មេធ., នារ.) ឬ 'ពីមនុស្សដទៃទៀតក៏ដោយ'(មេធ., អ្នកខ្លះទៀត) ហើយតាមលោកនន្ទ. 'ស្ត្រីធន ដែលទទួលបាននៅពេលរៀបអាពាហ៍ពិពាហ៍'(?)។ លោកមេធ. ព្រមទាំងលោកកុល្លូ. និងលោកគោវ. ក៏បានបកស្រាយ 'អំណោយដែលបានទទួលដោយវត្ថុដាក់ទឹកឃ្មុំ' ថា 'ថ្លៃសម្រាប់រៀបចំពិធីយញ្ញ'។ ប៉ុន្តែតាមការបកស្រាយរបស់លោកកុល្លូ., នារ., រាឃ. និងនន្ទ. គឺ 'អំណោយណាក៏ដោយ ដែលទទួលបានក្នុងន័យជាការគោរព ដោយវត្ថុដាក់ទឹកឃ្មុំ' ឧទាហរណ៍ ថូប្រាក់(រាឃ.) ទំនងជាង។ ចំពោះមនុស្សដែលសមទទួលវត្ថុដាក់ទឹកឃ្មុំ សូមមើលជំពូក៣ លេខ១១៩-១២០ខាងលើ។ លោកកុល្លូ. គូសបញ្ជាក់ថា វិធានច្បាប់នេះ ជាការកម្រិតអ្នកទទួលដូចបានជម្រាបខាងលើ កាព្យលេខ២០៤។ លោករាឃ. បន្ថែមថា ដោយមានសេចក្តីប្រហាក់ប្រហែលរបស់យញ្ញ. បង្ហាញស្រាប់ ទ្រព្យរកបានបែបនេះក្លាយជា ទ្រព្យឯកជនរបស់អ្នកទទួលអំណោយ លើកលែងតែពួកគេទទួលបាន 'ដោយមិនធ្វើឱ្យអន្តរាយដល់ទ្រព្យឪពុក' សូមមើលកាព្យ២០៨ ខាងក្រោម។

**២០៧.** យញ្ញ. ជំពូក២ លេខ១១៦។ ការបកប្រែខាងលើ យកតាមការបកស្រាយទីពីររបស់លោកមេធ. និងសន្ទានុក្រមរបស់លោកកុល្លូ. និងនារ.។ តាមការបកស្រាយទីមួយរបស់លោកមេធ. ដែលលោកនន្ទ.យល់ស្របតាមដែរនោះ ការប្រែគឺស្របតាមការប្រែរបស់ Sir W. Jones ថា 'គាត់អាចហាមខ្លួនឯងមិនឱ្យទទួលចំណែករបស់ខ្លួន'។ តាមអ្នកអធិប្បាយទាំងអស់ ហេតុផលដែលគេឱ្យចំណែកបន្តិចបន្តួច គឺថា គេអាចការពារវិវាទដែលកើតឡើងនៅពេលអនាគតបាន។

**២០៨.** យញ្ញ. ជំពូក២ លេខ១១៨; វិ. ជំពូក១៨ លេខ៤២។ 'ដោយកម្លាំងពលកម្មរបស់ខ្លួន' គឺ 'ដោយការងារកសិកម្ម ជាដើម'(មេធ., កុល្លូ., នន្ទ.)ឬ 'ដោយមុខរបរណាមួយ ដោយគ្មានហេតុ'(ស្រមជន្យកមណា ដោយលោកនារ.)។ *អនុបឃ្ន័ន* 'ដោយគ្មានប្រើប្រាស់'(នន្ទ.) ឬ 'ដោយមិនអាស្រ័យលើ'(រាឃ.) ត្រូវលោកកុល្លូ. ធ្វើការបកស្រាយថា 'ដោយមិនធ្វើឱ្យខូចប្រយោជន៍ដល់' ហើយលោកនន្ទ. ធ្វើការបកស្រាយដូច្នេះដែរ។ លោកនារ. សង្កេតឃើញថា ការទទួលបានដោយគ្មានបញ្ចេញកម្លាំងពលកម្ម ឬដោយគ្មានហេតុ ត្រូវតែធ្វើការបែងចែក។ លោកនន្ទ. មានប្រសាសន៍ថា វិធានច្បាប់នៅក្នុងកាព្យ

២០៩- ក៏ប៉ុន្តែប្រសិនបើឪពុករកបានមកវិញនូវទ្រព្យដូនតាដែលបានបាត់បង់ទៅ គាត់នឹងមិនបែងចែកទ្រព្យនោះទេ លើកលែងតែគាត់មានចិត្តចង់ចែកទៅឱ្យកូនប្រុសរបស់គាត់ (ព្រោះវាជា)ទ្រព្យដែលរកបានដោយខ្លួនគាត់ផ្ទាល់។

២១០- ប្រសិនបើបងប្អូនប្រុស (ធ្លាប់)បែកខ្ញែកគ្នា ហើយរស់នៅជាមួយគ្នា (ឡើងវិញជាម្ចាស់ទ្រព្យរួម) ធ្វើការបែងចែកជាលើកទីពីរ ការបែងចែកក្នុងករណីនេះត្រូវស្មើគ្នា ហើយក្នុងករណីបែបនេះ គ្មានសិទ្ធិភាពជារៀមច្បងទេ។

២១១- ប្រសិនបើបងប្រុសបង្អស់ឬប្អូនប្រុសបង្អស់បាត់បង់ចំណែករបស់ខ្លួន ឬប្រសិនបើក្នុងចំណោមពួកគេមាននរណាមួយស្លាប់ ចំណែករបស់គេមិនត្រូវបាត់ (ចំពោះទាយាទបន្ទាប់ផ្ទាល់របស់គេ)។

២១២- បងប្អូនប្រុសផ្ទៃតែមួយរបស់គាត់ ដែលបានរស់នៅជុំគ្នា នឹងបែងចែកទ្រព្យស្មើគ្នា ហើយបងប្អូនប្រុសទាំងឡាយ ដែលបានមកជួបជុំគ្នាឡើងវិញ(ជាមួយគាត់) និងបងប្អូនស្រីផ្ទៃតែមួយ។

---

នេះ អាចសម្រួលតាមវិធានដែលមាននៅក្នុងកាព្យលេខ២០៥បាន ដោយសន្មតថា វិធានក្រោយនេះសន្មតជាមុនថា បងប្អូនប្រុសទាំងអស់មានសេចក្ដីព្យាយាមតាមសមត្ថភាពរបស់ពួកគេ (បូរវំ សវេសុ យថាសាមថ្យាំ ឥហមានេសុ ភ្រាតួសុ លព្ធស្យ សមវិភាគ ឧក្ត ឥតី អវិរោធោ ន្ុសំធេយះ)។

**២០៩.** យញ្ញ. ជំពូក២ លេខ១១៩; វិ. ជំពូក១៨ លេខ៤៣។ ការប្រែពាក្យ *បៃត្ួកំ* តាមន័យត្រង់ 'ខាងឪពុក' ដោយថា 'តាមដូនតា' គឺផ្អែកលើពាក្យសម្រាយរបស់លោកនារ. *ស្វបិត្ួសម្ពន្ធិ* ហើយតាមលោកមេធ. *បិត្ួបិមហាទិសំពន្ធិ*។ ការសម្រាយខាងក្រោយនេះ ក៏សំដៅដល់សេចក្ដីប្រហាក់ប្រហែលគ្នារបស់យញ្ញ. ថា *អនាប្ដំ*ត្រូវបាត់' តាមន័យត្រង់ គឺ 'មិនបានទទួល(ដោយឪពុករបស់ខ្លួន)'។ ការប្រែ *ស្វយមជិតំ* ថា 'ព្រោះវាជាទ្រព្យរកបានខ្លួនឯង' ស្របតាមប្រសាសន៍របស់លោកនន្ទ. *ស្វយមជិតត្វាទ ឥតី អំថះ*។ លោកនារ. បន្ថែម 'ដូច្នេះហើយទើបគេប្រកាសថា ទ្រព្យរបស់ឪពុក ដែលមិនមែនគាត់រកបាន ដោយមានហេតុផលច្រើនលើសលុប គេត្រូវបែងចែក តាមឆន្ទៈរបស់កូនប្រុស ហើយសេចក្ដីនេះ សំដៅដល់សេចក្ដីរបស់យញ្ញ. ជំពូក២ លេខ១២១ថា"គឺជីធ្លីរបស់ជីតាជាដើម"'។ លោកមេធ. ដែលការអធិប្បាយរបស់លោកត្រង់កាព្យនេះមានការច្របូកច្របល់ខ្លាំង ហាក់ដូចជាបានសន្និដ្ឋានថា មនុព្រមទទួលកម្មសិទ្ធិស្មើគ្នារបស់ឪពុក និងកូនប្រុសរបស់គាត់ លើកម្មសិទ្ធិរបស់ដូនតា (សូមមើល Colebrooke ជំពូក៥ កម្រងអត្ថបទលេខ៩១)។ ប៉ុន្តែលោកប្រឆាំងនឹងទ្រឹស្ដីថា កូនប្រុសអាចបង្ខំឱ្យឪពុក បែងចែកកម្មសិទ្ធិដូនតា ដោយមិនបំពានករណីយកិច្ចរបស់ពួកគេ។

**២១០.** វិ. ជំពូក១៨ លេខ៤១។

**២១១.** 'ត្រូវបាត់ចំណែករបស់ខ្លួន' គឺ 'ដោយសារគាត់បានក្លាយជាចណ្ឌាល ឬមនុស្សក្រៅវណ្ណៈជាដើម'(មេធ.) ឬ 'ដោយសារគាត់បានក្លាយជាឥសី'(កុល្ល., នន្ទ.) ឬ 'ដោយសារគាត់បាននិរទេសទៅនៅក្រៅប្រទេស'(នន្ទ.) ឬ 'ដោយសារគាត់បានក្លាយជាមនុស្សកម្រៀវ បន្ទាប់ពីការបែងចែក(ដំបូង)'នារ.)។ *ន លុប្យតេ*មិនត្រូវបាត់បង់ (ចំពោះទាយាទផ្ទាល់របស់គាត់)ទេ' ត្រូវលោកនារ. ពន្យល់ដូចតទៅ 'ចំណែករបស់គាត់ ដែលបានកំណត់រួចហើយពីមុនមក មិនត្រូវបាត់បង់ទេ ពោលគឺមិនត្រូវម្ចាស់ទ្រព្យរួមដែលរួបរួមគ្នាឡើងវិញ ធ្វើការបែងចែកទេ ធ្វើដូច្នេះធ្វើឱ្យបាត់ទ្រព្យ'(សូមមើលអត្ថបទរបស់ព្រហស្បតិ Colebrooke ជំពូក៥ អត្ថបទ៤០៧ លេខ២)។ 'អ្វីៗដែលពាក់ព័ន្ធនឹងចំណែក មានបង្ហាញនៅក្នុងកាព្យបន្តបន្ទាប់'(មេធ., នារ., រាឃ., នន្ទ.)។

**២១២.** វិ. ជំពូក១៧ លេខ១៧; គោត. ជំពូក២៨ លេខ២១; យញ្ញ. ជំពូក២ លេខ១៣៨។ អត្ថន័យកាព្យនេះ គឺ ១-តាមលោកមេធ. ដែលយោបល់របស់គាត់ហាក់ដូចជាមិនស្របគ្នានឹងការពន្យល់មិនច្បាស់លាស់របស់លោកកុល្ល. និងរាឃ. 'ចំណែករបស់បងប្អូនប្រុសនៃសពដែលនៅរួមរស់ជាមួយគ្នា ទីមួយបានទៅបងប្អូនប្រុសបង្កើតទាំងស្រុងដែលនៅជាមួយ

២១៣- បងប្រុសបង្អស់ ដែលអាចបន្លំប្អូនៗ ដោយសារចិត្តលោភ នឹងបាត់បង់(តំណែង)ជាបងប្រុសបង្អស់ នឹងមិនទទួលចំណែក(បន្ថែមរបស់កូនប្រុសច្បងបង្អស់)ទេ ហើយនឹងត្រូវព្រះរាជាដាក់ទោស។

២១៤- បងប្អូនប្រុសទាំងអស់ ដែលប្រព្រឹត្តអំពើហាមឃាត់ជាទម្លាប់ មិនសមនឹងមាន (ចំណែក) កម្មសិទ្ធិទេ ហើយបងបង្អស់នឹងមិនយក(អ្វីមួយ)ធ្វើជាទ្រព្យដោយឡែករបស់ខ្លួន ដោយមិនបានផ្តល់ឱ្យប្អូនប្រុសរបស់ខ្លួន(ស្មើៗគ្នា)នោះទេ។

២១៥- ប្រសិនបើសមាជិក(ដែលរស់នៅជាមួយឪពុករបស់ពួកគេ) ដោយមិនទាន់បានទទួលការបែងចែក រួមគ្នាទាមទារចំណែក ឪពុកនឹងមិនផ្តល់ឱ្យពួកគេស្មើៗគ្នា(ក្នុងការចែកទ្រព្យ)ទេ។

---

គ្នា និងបងប្អូនស្រីបង្កើតទាំងស្រុង ដែលមិនទាន់រៀបការ (អបុត្រៈ សំណេរដែថា អប្រត្តៈ) ពោលគឺបងប្អូនស្រីដែលបានរៀបការហើយ(*ប្រត្តាះ* សំណៅដែសរសេរថា *ប្រទត្តាះ*)មិនត្រូវបានរាប់បញ្ចូលទេ ដោយហេតុថាពួកគេមានគ្រួសារមួយទៀត បន្ទាប់មកដល់បងប្អូនបង្កើតទាំងស្រុងដែលមិននៅរួមរស់ជាមួយគ្នា ទីបំផុតរហូតដល់បងប្អូនពោះមួយ (ឪពុកផ្សេងគ្នា)ដែលរួមរស់ជាមួយគ្នា', ២-តាមលោកនារ. 'ចំណែករបស់បងប្អូនប្រុសដែលរួមរស់ជាមួយគ្នាឡើងវិញ ប្រគល់ទីមួយឱ្យបងប្អូនប្រុសបង្កើតទាំងស្រុងដែលរួមរស់ជាមួយគ្នាឡើងវិញ បន្ទាប់មកឱ្យបងប្អូនប្រុសពោះមួយ (ឪពុកផ្សេងគ្នា) ដែលរួមរស់ជាមួយគ្នាឡើងវិញ បន្តឱ្យទៅបងប្អូនស្រីបង្កើតទាំងស្រុង តទៅទៀតឱ្យកូនប្រុសរបស់បងប្អូនប្រុសប្រង្កើតទាំងស្រុង?] ហើយចុងក្រោយឱ្យទៅកូនប្រុសរបស់បងប្អូនពោះមួយ(? តទភាវេ ត្វសោទរាទ្យ អបិ)'។ លោកនន្ទ. ចាត់លំដាប់ថ្នាក់ទាយាទដូចគ្នានឹងលោកនារ.ដែរ ប៉ុន្តែបញ្ឈប់ត្រឹម 'បងប្អូនស្រីបង្កើតទាំងស្រុង'។ ការបកស្រាយរបស់លោកនារ. និង នន្ទ. ដែលយកតាមលំដាប់នៃការរៀបរាប់ដាក់លាក់នៅក្នុងអត្ថបទ ស្របតាមវិធានច្បាប់របស់ព្រហស្បតិ (មើល Colebrooke ជំពូក៥ កម្រងអត្ថបទ ៤០៧ លេខ៣) ដែលទំនងជាការបកស្រាយមួយពាក្យរបស់មនុ។ លោកកុល្ល., រាឃ. និង នារ. អះអាងថា ទាយាទ ដែលមានឈ្មោះនៅក្នុងកាព្យ ទទួលមរតកតែក្នុងករណីគ្មានកូនប្រុស ភរិយា កូនស្រី និងឪពុកម្តាយប៉ុណ្ណោះ។ លោកនារ. បន្តកត់សម្គាល់ថា អ្នកខ្លះយល់ថាកាព្យនេះ និងកាព្យបន្តបន្ទាប់ សំដៅដល់ការបែងចែកទ្រព្យរបស់អ្នកដែលទទួលមរណភាពទៅមុនការបែងចែក ចំណែកឯអ្នកខ្លះទៀតមានជំនឿថា វិធាននេះសំដៅដល់ទ្រព្យរបស់បងប្អូនប្រុសដែលរួមរស់ជាមួយគ្នាឡើងវិញប៉ុណ្ណោះ។

**២១៣.** 'នឹងបាត់បង់(ឋានៈ)ជាបងបង្អស់' គឺ 'នឹងមិនទទួលបានកិត្តិយស ឧទាហរណ៍ ក្នុងការគោរព ស្របតាមបងប្រុសបង្អស់'(មេធ., កុល្ល., នារ., រាឃ.)។ ការបញ្ចូលពាក្យ 'បន្ថែមឱ្យកូនប្រុសច្បងបង្អស់' ពីមុខ 'ចំណែក' គឺមាននៅក្នុងឯកសារដើមរបស់លោកមេធ. និងកុល្ល.។ 'នឹងត្រូវដាក់ទោស' គឺ 'ដោយការស្តីបន្ទោស(វាគ្គណ្ឌធិគ្គណ្ឌាភ្យាំ) ឬដោយការពិន័យ តាមករណីចាំបាច់'(មេធ.)។

**២១៤.** អាប. ជំពូក២ លេខ១៤, ១៥; គោត. ជំពូក២៧ លេខ៤០; ពោធ. ជំពូក២ លេខ៣, ៣៨។ 'ដែលប្រព្រឹត្តអំពើហាមឃាត់ជាទម្លាប់' គឺ 'ដែលញៀននឹងការប្រព្រឹត្តល្បែង សេពគ្រឿងស្រវឹង និងអបាយមុខជាដើម'(កុល្ល., រាឃ.) ឬ 'ដែលក្នុងនាមជាព្រាហ្មណ៍ ចិញ្ចឹមជីវិតតាមទម្រង់គួរឱ្យស្អប់ ដូចជាការថែទាំសត្វពាហនៈ ការបម្រើសូទ្រៈជាដើម'(នារ.)។ *ន... កុរីតា យោតុកំ* 'មិនត្រូវយកអ្វី ធ្វើជាទ្រព្យដោយឡែករបស់ខ្លួនទេ' តាមលោកនន្ទ. គឺថា 'នឹងមិនឱ្យចំណែកអាពាហ៍ពិពាហ៍ ទៅកូនស្រីរបស់ខ្លួន ដោយមិនទាន់បានធ្វើការបែងចែកទ្រព្យនោះទេ'។ យ៉ាងណាមិញ ការប្រែត្រឹមត្រូវ គឺការប្រែរបស់អ្នកអធិប្បាយផ្សេងទៀត ដែលថា បងប្រុសបង្អស់ មិនត្រូវយកអ្វីមួយចេញពីស្តុករួម សម្រាប់ខ្លួនឯង 'ដោយមិនបានផ្តល់ឱ្យអ្នកដទៃស្មើៗគ្នានោះទេ'(*កនិស្ឋេភ្យៈ តាវ៉េ អទាត្វា* តាមលោកនារ.)។

**២១៥.** យញ្ញ. ជំពូក២ លេខ១២០។ លោកមេធ. កត់សម្គាល់ថា វិធានច្បាប់នេះ ជាការកម្រិតអំណាចទូទៅរបស់ឪពុកក្នុងការបែងចែកមិនស្មើគ្នា(យញ្ញ. ជំពូក២ លេខ១១៦) ហើយគិតថា មិនចាំបាច់ទាល់តែបងប្អូនប្រុសទាំងអស់ត្រូវតែរួម

២១៦- ប៉ុន្តែកូនប្រុស ដែលកើតក្រោយការបែងចែក នឹងទទួលបានទ្រព្យរបស់ឪពុកខ្លួនប៉ុណ្ណោះ ឬប្រសិនបើកូនប្រុសណាមួយ (ក្នុងចំណោមកូនប្រុសដទៃទៀត) ត្រូវត្រឡប់ទៅរួមរស់ជាមួយ (ឪពុក) គេនឹងបានចំណែកជាមួយពួកគេវិញ។

២១៧- ម្តាយនឹងទទួលមរតករបស់កូនប្រុស (ដែលស្លាប់)ដោយគ្មានកូន ហើយបើសិនជាម្តាយស្លាប់ ជីដូនខាងឪពុកនឹងទទួលទ្រព្យនោះ។

២១៨- ហើយប្រសិនបើបំណុល និងទ្រព្យសម្បត្តិទាំងអស់ ត្រូវបានបែងចែកយ៉ាងត្រឹមត្រូវ ស្របតាមវិធានច្បាប់ បន្ទាប់មកគេរកឃើញថាមាន(ទ្រព្យ)ណាមួយ គេត្រូវតែបែងចែកវាឱ្យស្មើគ្នា។

២១៩- សម្លៀកបំពាក់ យានជំនិះ គ្រឿងអលង្ការ អាហារឆ្អិន ទឹក និង(ទាសករ)ស្រី ទ្រព្យសម្រាប់ការប្រើប្រាស់ក្នុងជំនឿសាសនា ឬពិធីយញ្ញ និងវាលស្មៅ គឺជាទ្រព្យដែលគេមិនអាចធ្វើការបែងចែកបានទេ។

---

រស់ជាមួយគ្នាដោយធ្វើការដូចគ្នានោះទេ។ តាមយោបល់របស់លោក ទាំងអស់គ្នាបានខិតខំប្រឹងប្រែងដើម្បីរកចរិកា គឺគ្រប់គ្រាន់ហើយ។ លោកនារ. និងនន្ទ. បង្ហាញទស្សនៈផ្ទុយយ៉ាងច្បាស់ថា (សហោត្ថានាំ សំភូយវាណិជ្យាទិនា វិត្តារជនំ លោកនារ.)។

**២១៦.** គោត. ជំពូក២៨ លេខ២៩; វិ. ជំពូក១៧ លេខ៣; យញ្ញ. ជំពូក២ លេខ១២២។

**២១៧.** វិ. ជំពូក១៧ លេខ៧; យញ្ញ. ជំពូក២ លេខ១៣៥។ លោកកុល្លូ., នារ. និងនន្ទ. ទាំងបីនាក់ អះអាងថា ម្តាយទទួលមរតក តែក្នុងករណីគ្មានកូនប្រុស(ចៅប្រុស និងចៅទួតប្រុស លោកនន្ទ.) មេម៉ាយ និងកូនស្រីប៉ុណ្ណោះ។ ប៉ុន្តែពួកគេមិនយល់ស្របនឹងលំដាប់នៃទាយាទបន្តបន្ទាប់ទេ។ លោកកុល្លូ. អះអាងថា ម្តាយនិងឪពុក ដែលមានសិទ្ធិដូចរៀបរាប់ខាងលើកាព្យលេខ១៨៥ ទទួលមរតកបន្តបន្ទាប់រួមគ្នា បន្ទាប់មកបងប្អូនប្រុស តមកទៀតកូនរបស់បងប្អូនប្រុស ហើយបន្ទាប់ពីពួកគេ គឺជីដូនខាងឪពុក។ លោកនារ. រៀបរាប់លំដាប់ដូចតទៅ៖ ១-ម្តាយ ២-ឪពុក ៣-បងប្អូនប្រុស ៤-កូនរបស់បងប្អូនប្រុស ៥-ជីដូនខាងម្តាយ។ លោកមេធ. និយាយថា កាព្យនេះ ត្រូវបានបកស្រាយពីមុនមកហើយ។ យ៉ាងណាមិញ ការបកស្រាយរបស់លោក ត្រូវបានបាត់ទៅហើយ។ សូមមើលកំណត់សម្គាល់កាព្យលេខ១៨៧។

**២១៨.** យញ្ញ. ជំពូក២ លេខ១២៦។ លោកមេធ., កុល្លូ. និងនារ. គូសបញ្ជាក់ថា នៅពេលបែងចែកទ្រព្យសម្បត្តិដែលរកឃើញក្រោយការបែងចែក បងប្រុសបង្អស់ តាមអត្ថបទនេះ មិនទទួលបានចំណែកអនុគ្រោះទេ។ លោកនារ.មានប្រសាសន៍បន្ថែមថា វិធានច្បាប់នេះ ក៏អនុវត្តចំពោះបំណុល ដែលរកឃើញបន្ទាប់ពីការបែងចែកផងដែរ។ លោកនារ. ដាក់បញ្ចូលកាព្យនេះ បន្ទាប់ពីកាព្យ ២១៩។

**២១៩.** គោត. ជំពូក២៨ លេខ៤៦-៤៧; វិ. ជំពូក១៨ លេខ៤៤។ ជំនួសពាក្យ *បត្រំ* យានជំនិះ′ គឺ ‵សេះ ឬរទេះ ដែលម្ចាស់ទ្រព្យរួមម្នាក់បានប្រើផ្តាច់មុខ ក្នុងអំឡុងពេលរស់នៅរួមគ្នា′(មេធ., កុល្លូ., នារ., រាឃ.) លោកនន្ទ. អាន *បាត្រំ* ‵ភាជន៍ភេសជ្ជៈ′។ *ស្ត្រិយះ* ‵(ទាសករ)ស្រី′ តាមលោកនារ. ថា ‵ភរិយា′។ ការបកប្រែរបស់ខ្ញុំ *យោគក្សេមំ* ដែលខ្ញុំប្រែតាមលោកមេធ., នារ. និងនន្ទ. ជាពាក្យសមាសក្នុងឃ្លាដែលជានបុំសកលិង្គ គឺ ‵ទ្រព្យសម្រាប់ការប្រើប្រាស់ក្នុងជំនឿសាសនា និងពិធីយញ្ញ′ ផ្អែកលើការបកស្រាយរបស់លោកវិជ្ញានេស្វរ (Colebrooke ជំពូក១ លេខ៤, ២៣) និងយកតាម លោកហរទត្ត និង នន្ទបណ្ឌិត ក្នុងសេចក្តីប្រហាក់ប្រហែលគ្នារបស់លោកគោត. និងវិ.។ ខ្ញុំពេញចិត្តការបកស្រាយផ្សេងទៀតទាំងអស់ជាពិសេសការពណ៌នាសេចក្តីរបស់លោគាក្សិ ដែលលោកវិជ្ញានេស្វរៈស្រង់សេចក្តី។ នៅក្នុងការគាំទ្រយោបល់ក៏បញ្ជាក់ថា អំណោយរបស់ព្រះរាជាដ៏ច្រើន ផ្តល់ឱ្យភូមិ ឬដីធ្លីដល់ព្រាហ្មណ៍ និងកូនចៅរបស់ពួកគេ សម្រាប់ការធ្វើពិធីមួយចំនួនឬសម្រាប់គោលបំណងសប្បុរសធម៌ ដូចជាការចែងស្បៀងអាហារប្រចាំថ្ងៃ (អន្នសត្ត្រ ឬ សទាវ្រត) និងថា ការកើតមានវិធានមួយនៅក្នុងស្ម្រិត ដោយប្រកាសថា ទ្រព្យដែលគេប្រគល់ឱ្យស្របតាមលក្ខខណ្ឌបែបនេះ មិនអាចលំអៀងបានទេ

២២០- ការបែងចែក(ទ្រព្យសម្បត្តិ) និងវិធានសម្រាប់ចែក(ចំណែក)ដល់កូនប្រុស(ជាច្រើននាក់) ហេតុនេះកូនប្រុសដែលចាប់កំណើតនឹងភរិយា និងអ្នកដទៃទៀត ត្រូវបានប្រកាស ប្រាប់លោកអ្នក តាមលំដាប់លំដោយ(ត្រឹមត្រូវ)រួចហើយ (ឥឡូវនេះ)ចូរស្តាប់ច្បាប់ស្តីពីការលេងល្បែង។

២២១- ការលេងល្បែង និងការភ្នាល់ ចូរព្រះរាជាបណ្តេញចេញឱ្យអស់ពីអាណាចក្ររបស់ទ្រង់ អបាយមុខទាំងពីរនេះបង្កឱ្យមានការបំផ្លាញអាណាចក្ររបស់ស្តេចនានា។

២២២- ការលេងល្បែងនិងការភ្នាល់ បង្កើតឱ្យមានចោរកម្មកាន់តែច្រើន ព្រះរាជាតែងតែព្យាយាមទប់ស្កាត់(អបាយមុខ)ទាំងពីរនេះ។

២២៣- បើសិនជាគេប្រើ(វត្ថុ)គ្មានជីវិត (ដើម្បីដាក់ភ្នាល់អាស្រ័យដោយវត្ថុនោះ) មនុស្សទាំងឡាយគេហៅថាការលេងល្បែង(ទ្យូតៈ) បើសិនជាគេប្រើសត្វមានជីវិត(ក្នុងបំណងដូចគ្នានេះ) គេត្រូវដឹងថានោះជាការភ្នាល់(សមាហ្វយ)។

២២៤- សូមព្រះរាជាដាក់ទណ្ឌកម្មរូបកាយចំពោះ(មនុស្ស)ទាំងអស់ដែលប្រព្រឹត្តល្បែង និងការភ្នាល់ ឬផ្តល់(ឱកាសឱ្យមានល្បែងស៊ីសង) ដូចគ្នានឹងសូទ្រៈដែលក្លែងសញ្ញាសម្គាល់ជា(បុរស)មានកំណើតពីរដង។

២២៥- អ្នកល្បែង អ្នករាំរែក និងអ្នកចម្រៀង មនុស្សកាចសាហាវ មនុស្សដែលមានជំនឿអញ្ញនិយម អ្នកដែលប្រកបមុខរបរហាមឃាត់ និងអ្នកលក់គ្រឿងស្រវឹង ចូរទ្រង់បណ្តេញចេញពីក្រុងរបស់ទ្រង់។

---

ពោលគឺមិនលើសពីការរំពឹងទុកទេ។ ផ្ទុយទៅវិញ អ្នកអធិប្បាយអំពីមនុ ផ្តល់ការបកស្រាយដូចតទៅ៖ ១-'មធ្យោបាយជានាការការពារ គឺ ក្រុមប្រឹក្សាព្រះមហាក្សត្រ អាចារ្យគ្រួសារ កុង្សីយ៍ ស្ត្រីចាស់ជរា(វ្ទ្ធា?) លំនៅឋាន និង*ចារៈ* ជាចារបុរស? ឬវាលស្មៅ(?) ជាដើម' (មេធ.) ២-'ក្រុមប្រឹក្សាមហាក្សត្រិយ អាចារ្យក្នុងគ្រួសារជាដើម'(កុល្ល. និងរាឃ. ដែលអ្នកក្រោយនេះ អាន*យោគក្សេមប្រចារំ*) ៣-'មធ្យោបាយទទួលផលចំណេញ គឺការឱ្យឬអំណោយជាដើម ដែលបានទទួលពីព្រះរាជា និងរកបានដោយខ្លួនឯង និងមធ្យោបាយការពារ'(ប្រាការ ច ឥស្កាទិះ? លោកនារ.) ៤-'ប្រភពប្រាក់ចំណេញ គឺបុគ្គលដែលខ្លួនធ្វើពលិកម្មចំពោះជាដើម ហើយប្រភពនៃការការពារ គឺអ្នកយាមទ្វារជាដើម និងប្រភពទទួលផលចំណេញ និងការការពារ គឺមេភូមិជាដើម'(នន្ទ.)។ *ប្រចារៈ*វាលស្មៅ' តាមលោកនារ.និងនន្ទ. មានន័យថា 'ផ្លូវឆ្ពោះទៅកាន់ស្រែ ច្បារដំណាំជាដើម'។

លោកមេធ., កុល្ល. និងនារ. បញ្ជាក់ថា វត្ថុបួនដំបូង ជាទូទៅត្រូវរក្សានៅក្នុងដៃរបស់ម្ចាស់ទ្រព្យរួម ដែលប្រើប្រាស់វា ឬសម្រាប់ការត្រៀមការប្រើប្រាស់របស់ពួកគេ ប៉ុន្តែវត្ថុទាំងនោះ ឬបរិមាណនៃតម្លៃពិសេសត្រូវគេលក់ ឬប្តូរយកទ្រព្យដទៃ។ ម្ចាស់ទ្រព្យរួមទាំងអស់ត្រូវប្រើប្រាស់អណ្តូងជាដើម(កុល្ល., នន្ទ.)។ ទាសករស្រី ត្រូវធ្វើការឱ្យម្ចាស់ទ្រព្យរួមទាំងអស់(កុល្ល.)។

**២២១-២២៩.** អាប. ជំពូក២ លេខ២៥, ១២-១៥; គោត. ជំពូក២៥ លេខ១៨; ពោធ. ជំពូក២ លេខ២, ១៦; យញ្ញ. ជំពូក២ លេខ១៩៩-២០៣។ នៅក្នុងសំណៅដៃ គ្មានការអធិប្បាយរបស់លោកមេធ.ពាក់ព័ន្ធនឹងកាព្យលេខ២២១-២២៧ទេ។

**២២៤.** យញ្ញ. ជំពូក២ លេខ៣០៤។ 'សញ្ញាសម្គាល់ជាបុរសមានកំណើតពីរដង' គឺ 'អំបោះយញ្ញ ជាដើម'(កុល្ល., នារ.)។ 'ដាក់ទណ្ឌកម្មរូបកាយ' គឺ'បញ្ជាឱ្យគេវាយដំពួកគេជាដើម'(នារ.) ឬ 'ឱ្យគេកាត់ដៃជើងរបស់ពួកគេជាដើម ស្របតាមស្ថានទម្ងន់ទោសនៃបទល្មើស'(កុល្ល., រាឃ.)។

**២២៥.** ជំនួស *ក្រូរាន*មនុស្សកាចសាហាវ' គឺ 'អ្នកទាំងឡាយ ដែលស្អប់អ្នកចេះដឹងព្រះវេទ'(កុល្ល.) តែលោកនារ. និងរាឃ. សរសេរ *ភេរក* ដែលអ្នកខាងដើមបកស្រាយថា 'មនុស្សដែលមានឥរិយាបថពាលហួសហេតុ' ហើយអ្នកខាងក្រោយ

២២៦- ប្រសិនបើ (មនុស្សដែលជា) ចោរអាថ៌កំបាំងបែបនេះ ស្នាក់នៅក្នុងអាណាចក្ររបស់ព្រះរាជា ពួកគេនឹងយាយីប្រជារាស្ត្រល្អរបស់ទ្រង់ជាប្រចាំ ដោយការប្រព្រឹត្តអំពើហាមឃាត់នានា។

២២៧- នៅក្នុងកល្បខាងដើម (អបាយមុខ)ល្បែងនេះត្រូវគេចាត់ទុកថាជាមហាសត្រូវ ហេតុនេះអ្នកមានគតិបណ្ឌិតមិនត្រូវប្រព្រឹត្តវាទេ សូម្បីដើម្បីការសប្បាយក៏ដោយ។

២២៨- ព្រះរាជាអាចដាក់ទោសស្របតាមឆន្ទានុសិទ្ធិរបស់ព្រះអង្គ ចំពោះមនុស្សទាំងឡាយដែលញៀននឹងអំពើអបាយមុខ ទោះដោយសម្ងាត់ក្ដី ឬដោយចំហក្ដី ។

២២៩- ប៉ុន្តែក្សត្រិយ វៃស្យ និងសូទ្រៈ ដែលមិនអាចបង់ប្រាក់ពិន័យបាន នឹងសងបំណុលនេះដោយការធ្វើពលកម្ម ហើយព្រាហ្មណ៍នឹងសងបំណុលដោយការសងបណ្ដាក់។

២៣០- ព្រះរាជាត្រូវដាក់ទោសស្ត្រី កុមារ មនុស្សដែលមានសតិមិនរៀបរយ អ្នកក្រ និងអ្នកជំងឺដោយវាយនឹងខ្សែតី រំពាត់ផ្ដៅ ឬខ្សែព្ជួរជាដើម។

២៣១- ក៏ប៉ុន្តែអ្នកដែលបានទទួលការតែងតាំង (ឱ្យចាត់ចែង) កិច្ចការសាធារណៈ ដែលត្រូវដុតដោយភ្លើងទ្រព្យ ធ្វើឱ្យខូចការងាររបស់គូក្ដី ព្រះរាជានឹងដកហូតទ្រព្យសម្បត្តិរបស់ពួកគេ។

២៣២- អ្នកក្លែងព្រះរាជបញ្ញត្តិ អ្នកដែលសូកកុង្សីយ៍របស់ទ្រង់ អ្នកដែលសម្លាប់ស្ត្រី កុមារ ឬព្រាហ្មណ៍ និងអ្នកដែលបម្រើសត្រូវរបស់ទ្រង់ ព្រះរាជានឹងដាក់ទោសប្រហារជីវិត។

---

យល់ស្របតាមការបកស្រាយរបស់លោកកុល្ល. *ក្រូរាន* ។ លោកនន្ទ. អាន *កៃលាន* សំដៅដល់ការលេងសប្បាយ' (កេលីសិលាន) ហើយលោក K. អាន *ចោរាន* 'ពួកចោរ'។ *សោណ្ឌិកាន* 'អ្នកបិតស្រា ឬអ្នកលក់គ្រឿងស្រវឹង' (កុល្ល., នារ.) ក៏អាចមានន័យថា 'មនុស្សស្រវឹងខ្លួប' តាមការបកស្រាយរបស់លោកនន្ទ.។

**២២៦.** ជំនួសឱ្យ 'ដែលជាចោរអាថ៌កំបាំង' (កុល្ល.) លោកនារ.និយាយថា 'និងចោរអាថ៌កំបាំង'។ *ពាធន្តេ* យាយី' (កុល្ល.) តាមលោកនារ., រាឃ. និងនន្ទ. ថា 'ធ្វើឱ្យខូច'។

**២២៧.** លោកនារ. បកស្រាយ *បុរាកល្បេ* នៅក្នុងកល្បមុន' ថា 'តាមសាច់រឿងពីបរមបុរាណ'ហើយលោករាឃ. និងនន្ទ. បង្ហាញពីការផ្សងព្រេងរបស់ស្ដេច *នល* និង *យុធស្ថិរ* ដែលត្រូវពណ៌នាបន្តិចបន្តួចនៅអត្ថបទ។

**២២៨.** រាឃ. និងនន្ទ. គូសបញ្ជាក់ថា (តាមកាព្យលេខ២២៤) មិនត្រឹមតែការដាក់ទណ្ឌកម្មរូបកាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគេអាចដាក់ពិន័យបាន។ សូមមើលកាព្យបន្ទាប់។

**២២៩.** យញ្ញ. ជំពូក២ លេខ៤៣។ របៀបនឹងវិធានច្បាប់ ដែលមាននៅក្នុងជំពូក៨ លេខ១៧៧។

**២៣០.** *សីផា* ' វាយនឹងរំពាត់' លោករាឃ.បកស្រាយថា 'រំពាត់ដែលមានប្រវែងប្រាំម្រាមដៃ' ឬ 'ឫសឈើដូចជាវល្លិ៍'។ លោកនារ. និងនន្ទ. បកស្រាយន័យមួយក្រោយ។ លោកមេធ., នារ. និងនន្ទ. អាន *ទរិទ្រានាថរោគិនាំ* 'អ្នកក្រីក្រ, អ្នកដែលគ្មានការការពារនិងអ្នកជំងឺ'។

**២៣១.** សូមមើលជំពូក៧ លេខ១២៤; វិ. ជំពូក៥ លេខ១៨០ ខាងលើ។ 'អ្នកដែលមានការព្រមព្រៀងជាដើម' គឺជាទេសាភិបាលជាដើម(មេធ.) ឬ ចៅក្រមជាដើម(នារ.)។

**២៣០.** 'ត្រូវដុតដោយភ្លើងទ្រព្យ' គឺជាការឧបមា ក្នុងន័យភ្លើងដុតឆ្នាំងដី ហើយក្នុងន័យថា ជាប្រភេទមនុស្សដែលស្ថិតក្រោមឥទ្ធិពលទ្រព្យ ងាយនឹងប្រែប្រួលទៅជាអាក្រក់បាន ឧបមាដូចឆ្នាំងដែលត្រូវកំដៅភ្លើង ប្រែពណ៌ដូច្នោះដែរ ឬប្រៀបដូចវៃសេសិកៈ ប្រែប្រួលតាមធម្មជាតិរបស់វា។ យោងតាមលោកមេធ. 'អ្នកដទៃ' អាន *យេ' និយុក្តា តុ* ហើយសំដៅ កាព្យនេះ ដល់បុគ្គលដែលមិនមែនជាមន្ត្រី ដែលធ្វើការផ្នែករដ្ឋបាល ឬតុលាការទេ។

**២៣២.** យញ្ញ. ជំពូក២ លេខ២៤០; វិ. ជំពូក៥ លេខ៩, ១១។

២៣៣- ពេលណាក៏ដោយគេត្រូវបញ្ចប់(ដំណើរការផ្លូវច្បាប់) ឬ(ការដាក់ទោស)ត្រូវធ្វើស្របតាមច្បាប់ ព្រះអង្គនឹងដាក់ទណ្ឌកម្ម ហើយមិនទុកជាអសារឥតការនោះទេ។

២៣៤- កុង្សីយ៍ឬចៅក្រមរបស់ទ្រង់ អាចដោះស្រាយបញ្ហាអ្វីក៏ដោយឱ្យមានកំហុសឆ្គង គឺព្រះរាជានឹងដោះស្រាយឡើងវិញដោយផ្ទាល់ ហើយពិន័យពួកគេចំនួនមួយពាន់(បណៈ)។

២៣៥- អ្នកសម្លាប់ព្រាហ្មណ៍ (អ្នកមានកំណើតពីរដង) ដែលសេព(គ្រឿងស្រវឹង គឺ)សុរា អ្នកដែលលួច (មាសរបស់ព្រាហ្មណ៍) និងអ្នកដែលបំពានលើគ្រែរបស់គុរុ ត្រូវគេវិនិច្ឆ័យម្នាក់ៗ និងទាំងអស់គ្នា ដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ (មហាបាតក)។

២៣៦- ប្រសិនបើពួកគេមិនធ្វើការលាងបាប ចូរទ្រង់ដាក់ទណ្ឌកម្មរូបកាយ និងពិន័យលើពួកគេទាំងបួន ស្របទៅតាមច្បាប់។

២៣៧- គេនឹងបោះសញ្ញាស្ត្រី (ដោយដែកក្តៅ)នៅលើថ្ងាសចំពោះការរំលោភបំពានគ្រែរបស់គុរុ, បោះសញ្ញាតៀមស្រា ចំពោះអ្នកសេព (គ្រឿងស្រវឹងគឺ) សុរា, បោះសញ្ញាជើងឆ្កែ ចំពោះអ្នកលួច (មាសរបស់ព្រាហ្មណ៍) និងបោះសញ្ញាសាកសពគ្មានក្បាល ចំពោះការសម្លាប់ព្រាហ្មណ៍។

២៣៨- ដោយហាមការចែករំលែកទាំងអស់នៅពេលទទួលទាន ហាមមិនឱ្យចូលពិធីយញ្ញទាំងអស់ ហាមមិនឱ្យធ្វើការអប់រំ និងការចងសម្ព័ន្ធញាតិខាងម្តាយ អ្នកថោកទាប និងហាមឃាត់ករណីយកិច្ចសាសនាទាំងអស់ ចូរឱ្យពួកគេដើរទេសលើដី(នេះ)។

---

**២៣៣.** មេធ. និងកុល្ល. បញ្ជាក់ការហាមឃាត់ថាសំដៅដល់ករណី ដែលត្រូវមានការវិនិច្ឆ័យត្រឹមត្រូវនៅក្នុងរាជវាំងរបស់ព្រះរាជា ចំណែកឯលោកនារ. គិតថា វិធាននេះសំដៅដល់រាជបញ្ញត្តិរបស់ព្រះមហាក្សត្រិយមុន។ នន្ទ. ធ្វើការបកស្រាយផ្សេង *នីតិ* និង *អនុសិស្តិ*។ លោកលើកហេតុផលកាព្យ*កាត្យាយន* ដែលអ្នកមុនចង់និយាយថា ‵រឿងហេតុ ឬបណ្តឹងដែលជំនួយការចៅក្រមប្រកាសថាត្រឹមត្រូវ ឬមិនត្រឹមត្រូវ′ ហើយអ្នកក្រោយថា ‵រឿងហេតុ ឬបណ្តឹង ដែលសាក្សីបានបញ្ជាក់′។

**២៣៤.** យញ្ញ. ជំពូក២ លេខ៣០៥។ មេធ. និងកុល្ល. គិតថា វិធានច្បាប់នេះសំដៅដល់ករណី ដែលថាមូលហេតុនៃការវិនិច្ឆ័យមិនយុត្តិធម៌គឺមិនមែនការសូកប៉ាន់ទេ ពីព្រោះការដាក់ទោសរបស់ចៅក្រមពុករលួយ ត្រូវបានរៀបរាប់នៅក្នុងកាព្យលេខ២៣១ ខាងលើ។ ប៉ុន្តែលោកនារ. និងរាឃ. គិតថា វិធាននេះសំដៅដល់ករណីស៊ីសំណូកផងដែរ និងថាការដាក់ពិន័យត្រូវតែខុសគ្នាទៅតាមចរិតលក្ខណៈរឿងក្តី ១000 បណៈ ជាទណ្ឌកម្មកម្រិតទាបបំផុត។

**២៣៥-២៤២.** ពោធ. ជំពូក១ លេខ១៨, ១៨; វិ. ជំពូក៥ លេខ៣-៧។

**២៣៥.** ជំនួសឱ្យឃ្លា ‵(អ្នកមានកំណើតពីរដង) ដែលសេពគ្រឿងស្រវឹងជាដើម′(កុល្ល., នារ.) លោកមេធ. និងនន្ទ. និយាយថា ‵ព្រាហ្មណ៍ដែល...′ ប៉ុន្តែសូមមើលជំពូក១១ លេខ៩៤ ខាងក្រោម។

**២៣៦.** មេធ. កត់សម្គាល់ថា ‵អ្នកដទៃ′បញ្ជាក់ថាវិធាននេះ បើនិយាយពីពាក្យ *អបិ*សូម្បី ដូចគ្នានឹង′ សំដៅដល់ *មហាបតកិន* ផងដែរ ពោលគឺសំដៅដល់អ្នកដែលសេពគប់ជាមួយនរណាមួយក្នុងចំណោមបួនក្រុមទៀត (សូមមើល ជំពូក១១ លេខ៥៥ ខាងក្រោម) ហើយលោករាឃ. ព្រមទាំងលោកនន្ទ. គាំទ្រការបកស្រាយនេះ។

**២៣៧.** ‵សញ្ញាតៀមសុរា′ គឺ ‵ពែងស្រា′។ វិធាននេះបន្តពីវិធានដែលមានចែងនៅក្នុងកាព្យលេខ២៤០ ថ្ងាសជាកន្លែងដែលមានសញ្ញានេះ។

**២៣៨.** មេធ. អាន *អសំយោជយាះ* ‵ហាមការសេពគប់ទាំងអស់′ ជំនួស *អសំយាជយាះ* ‵មិនឱ្យចូលពិធីយញ្ញទាំងអស់′។

២៣៩- គេត្រូវតែបណ្តេញ(មនុស្ស)ដែលត្រូវគេបោះសញ្ញា(មិនអាចលុបបាន)នេះចេញពីទំនាក់ទំនងញាតិខាងឪពុកនិងម្តាយរបស់ពួកគេ ហើយមិនទទួលបានសេចក្តីមេត្តា និងការគោរពទេនោះជាការបង្រៀនរបស់មនុ។

២៤០- ក៏ប៉ុន្តែ(មនុស្ស)គ្រប់វណ្ណៈទាំងអស់ ដែលធ្វើតបៈលាងបានតាមបញ្ញត្តិ មិនត្រូវព្រះរាជាបោះសញ្ញានៅលើថ្ងាសទេ ប៉ុន្តែនឹងត្រូវបង់ពិន័យកម្រិតខ្ពស់បំផុត។

២៤១- ចំពោះបទល្មើស(បែបនេះ) ពិន័យថ្នាក់កណ្តាលត្រូវអនុវត្តចំពោះព្រាហ្មណ៍ ឬអាចបំបរបង់គាត់ចេញពីអាណាចក្រ ដោយរក្សាទុកថវិកា និងប្រដាប់ប្រដាប្រើប្រាស់របស់គាត់។

២៤២- ប៉ុន្តែ(មនុស្ស)ក្នុងវណ្ណៈផ្សេងទៀត ដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋបែបនេះ គួរត្រូវដកហូតទ្រព្យទាំងអស់របស់ពួកគេ ប្រសិនបើ(ពួកគេបានប្រព្រឹត្តអំពើនោះ)ដោយចេតនា ពួកគេនឹងត្រូវបំបរបង់។

២៤៣- ព្រះរាជាប្រកបដោយគុណធម៌ មិនត្រូវដកហូតទ្រព្យរបស់អ្នកដែលមានទោសធ្ងន់ធ្ងរសម្រាប់ខ្លួនព្រះអង្គទេ ប៉ុន្តែប្រសិនបើទ្រង់ដកហូតដោយសេចក្តីលោភ ទ្រង់នឹងទទួលផលកម្មនៃទោស(របស់ជនល្មើសនោះ)។

២៤៤- បន្ទាប់ពីបានបោះប្រាក់ពិន័យចូលទៅក្នុងទឹក ចូរទ្រង់ឧទ្ទិសប្រាក់ពិន័យថ្វាយព្រះវរុណ ឬចូរទ្រង់ធ្វើអំណោយដល់អ្នកចេះដឹង និងព្រាហ្មណ៍ដែលមានគុណធម៌។

---

**២៤០.** 'វណ្ណៈទាំងអស់' គឺ 'វណ្ណៈអារ្យ៉ន់បី'។ លោកនារ. និងនន្ទ. អាន *បុរវ*វណ្ណៈដែលជម្រាបជូនខាងដើម'។ 'ការដាក់ទោសតាមអំពើចិត្តកម្រិតខ្ពស់បំផុត' សូមមើលជំពូក៨ លេខ១៣៨ ខាងលើ។

**២៤១.** យោងតាមលោកមេធ. អត្ថន័យនៃកាព្យនេះគឺ ព្រាហ្មណ៍ ដែលមានគុណសម្បត្តិល្អ ដែលប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ(កាព្យលេខ២៤២)ដោយអចេតនា នឹងត្រូវពិន័យថ្នាក់កណ្តាល និងត្រូវធ្វើការលាងបាបតាមបញ្ញត្តិកំណត់ ឬ ប្រសិនបើគាត់បដិសេធមិនព្រមធ្វើ គេត្រូវនិរទេសខ្លួន ដោយមិនចាំបាច់ដាក់ទោសពិន័យ។ លោកកុល្ល. និងនន្ទ. យល់ព្រមមួយផ្នែក ប៉ុន្តែគិតថា គេត្រូវដាក់ពិន័យជនល្មើស ប្រសិនបើគាត់បានប្រព្រឹត្តបទឧក្រិដ្ឋដោយចេតនា។

**២៤២.** ការប្រែនេះយកតាមលោកនារ. និងនន្ទ. ដែលគិតថា បុគ្គល ដែលធ្វើតបៈលាងបាប នឹងត្រូវដកហូត ទ្រព្យសម្បត្តិទាំងអស់របស់ពួកគេ ប្រសិនបើគេប្រព្រឹត្តអំពើល្មើសដោយអចេតនា និងត្រូវពិន័យ បន្ទាប់ពីបោះសញ្ញាសម្គាល់ ប្រសិនបើអំពើឧក្រិដ្ឋរបស់ពួកគេមានជាតុចេតនា។ ជាងនេះទៅទៀត លោកនារ. បន្ថែមថា 'កាព្យនេះសំដៅដល់ករណីស្រាលតាមបញ្ញត្តិគឺថា គាត់នឹងសម្លាប់ជនល្មើសក្នុងករណីធ្ងន់ធ្ងរ'។ លោកកុល្ល. និងរាឃ. គិតថា ការដកហូតទ្រព្យទាំងអស់ ត្រូវអនុវត្ត ជាពិសេសក្នុងករណីធ្ងន់ធ្ងរ ជំនួសឱ្យការដាក់ពិន័យចំនួន ១០០០ បណៈ ដែលបញ្ញត្តិនៅក្នុងកាព្យ២៤០ ហើយលោកមេធ. និយាយថា នេះជាយោបល់របស់ 'អ្នកខ្លះប៉ុណ្ណោះ'។ លោកមេធ., កុល្ល. និងរាឃ. បកស្រាយ *ប្រវាសនំ* 'នឹងត្រូវបំបរបង់' ដោយថា 'នឹងត្រូវដាក់ទោសរូបកាយ'។ ទោះជាគ្មានមតិដាច់ខាតក៏ដោយ *ប្រវាស* អាចមានន័យថា 'ធ្វើឱ្យបួសឬដាក់ទណ្ឌកម្មរូបកាយ' ហើយការប្រែន័យក្រោយនេះ ពាក់ព័ន្ធកាព្យលេខ២៣៨ និង២៤១ ហាក់ដូចជា មិនសមទេ បើធៀបនឹងជំពូក៨ លេខ២៨៤។ លោកមេធ. កត់សម្គាល់ថា សូទ្រៈ ដែលប្រព្រឹត្តល្មើសដោយអចេតនា នឹងត្រូវបោះសញ្ញា និងត្រូវដកហូតទ្រព្យទាំងអស់ ព្រមទាំងអាចដាក់ទោសប្រហារជីវិតជនល្មើសបាន។

**២៤៤.** យញ្ញ. ជំពូក២ លេខ៣០៧។

២៤៥- ព្រះវរុណជាព្រះតំណាងទណ្ឌកម្ម ព្រោះទ្រង់កាន់ដំបងអាជ្ញាខ្ពស់ជាងព្រះរាជានានា ហើយព្រាហ្មណ៍ដែលមានចំណេះដឹងព្រះវេទទាំងមូល គឺជាម្ចាស់នៃលោកិយទាំងមូល។

២៤៦- នៅក្នុង(ប្រទេស)ដែលព្រះរាជាជៀសវាងមិនយកទ្រព្យរបស់អ្នកប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរមនុស្សចាប់កំណើតតាមកាលកំណត់ (ហើយមាន)អាយុយឺនយូរ,

២៤៧- ហើយកសិផលរបស់កសិករនឹងកើនឡើង តាមការបង្កបង្កើនផល ហើយកូនក្មេងមិនស្លាប់ និង មិនខូចទម្រង់ នៅពេលចាប់កំណើត។

២៤៨- ប៉ុន្តែព្រះរាជានឹងដាក់ទណ្ឌកម្មផ្សេងៗចំពោះ(សូទ្រៈ)ដែលមានកំណើតថ្នាក់ទាប ដែលបង្កការឈឺចាប់ដោយចេតនាដល់ពួកព្រាហ្មណ៍ ដើម្បីធ្វើឱ្យមានការភ័យខ្លាច។

២៤៩- ប្រសិនបើព្រះរាជាដាក់ទោស(មនុស្ស)ស្មោះត្រង់ ទោសរបស់ទ្រង់ត្រូវចាត់ទុកថាធ្ងន់ធ្ងរ ពេលទ្រង់ឱ្យមនុស្សមានទោសមានសេរីភាព ក៏ប៉ុន្តែ (ទ្រង់មាន) គុណូបការ ពេលទ្រង់ដាក់ទោស (ដោយយុត្តិធម៌)។

២៥០- ដូច្នេះរបៀបសម្រេចរឿងក្តី(មាន)សិទ្ធិដប់ប្រាំបីរវាងភាគីគូក្តី ត្រូវបានប្រកាសលម្អិតរួចហើយ។

២៥១- ហេតុនេះព្រះរាជាបំពេញករណីយកិច្ចរបស់ទ្រង់ដោយត្រឹមត្រូវ ប្រកបដោយភាពយុត្តិធម៌ អាចស្វែងរកប្រៀបឈ្នះប្រទេសនានា ដែលព្រះអង្គមិនទាន់យកឈ្នះបាន ហើយនឹងការពារពួកគេឱ្យបានសមគួរ នៅពេលព្រះអង្គបានយកឈ្នះលើពួកគេហើយ។

២៥២- បន្ទាប់ពីបានគ្រប់គ្រងប្រទេសរបស់ទ្រង់បានត្រឹមត្រូវ និងកសាងបន្ទាយស្របតាមគោលការណ៍ គ្រប់គ្រង ព្រះអង្គប្រឹងប្រែងឱ្យអស់ពីសមត្ថភាពទ្រង់ដើម្បីជម្នះលើ (មនុស្សទាំងឡាយដែលមានពិសពុលបីដូចជា) បន្លា។

២៥៣- ដោយការការពារអ្នកទាំងឡាយដែលរស់នៅជាអារ្យ៉ន និងដោយការដកបន្លាចេញ ព្រះរាជាដែលមានចេតនាតែមួយក្នុងការការពារប្រជារាស្ត្ររបស់ព្រះអង្គ នឹងបានឡើងឋានសួគ៌។

---

**២៤០.** *វរុណៈ* គឺជាកំពូលមេដឹកនាំ(អធិរាជ)លើព្រះរាជាទាំងឡាយ។ សូមមើលតៃត្តិរិយ ព្រាហ្មណ៍ ជំពូក៣ លេខ១, ២, ៧។ ចំពោះឋានៈរបស់ព្រាហ្មណ៍ចេះដឹង សូមមើលជំពូក១ លេខ៩៨-១០១។

**២៤៦.** ជំនួស *ការលេន*តាមកាល(កំណត់ត្រឹមត្រូវ)' គឺ 'បន្ទាប់ពីរយៈពេលមានគត៌ទាំងស្រុង'(កុល្ល., នារ., រាឃ.) លោក នន្ទ. អាន *លោកេ តុ*ប៉ុន្តែនៅក្នុងប្រទេសនោះ'។

**២៤៨.** សូមមើលជំពូក៨ លេខ២៧៩-២៨៤ ខាងលើ។ ថ្វីបើអ្នកអធិប្បាយទាំងអស់ប្រែ *អវរជំ* ក្នុងន័យថា 'សូទ្រៈដែលមានកំណើតថោកទាប' ក៏ពាក្យនេះអាចមានន័យនិរុត្តសាស្ត្ររបស់វា 'មនុស្សដែលមានវណ្ណៈទាប'។ លោកមេធ. បកស្រាយ 'អ្នកដែលបង្កការឈឺចាប់' ថា 'អ្នកដែលយកទ្រព្យ ឬកិរិយារបស់ពួកគេ' ហើយនារ.ថា 'អ្នកដែលបង្កឱ្យមានទុក្ខសោកធ្ងន់ធ្ងរក្រៃលែង'។

**២៤៩.** សូមមើលជំពូក៍ លេខ១៩, ៣១០-៣១១, ៣១៧។

**២៥០.** 'កាព្យនេះជាការបញ្ចប់វគ្គ ស្តីពីសិទ្ធិដប់ប្រាំបីដែលមាននៅក្នុងច្បាប់'(មេធ.) 'ហើយពេលនេះជាការបន្ថែមលើករណីយកិច្ចរបស់ព្រះរាជា'(នារ.)។

**២៥២.** សូមមើលជំពូក៧ លេខ៦៩-៧០ខាងលើ។

**២៥៣-២៥៤.** សូមមើលជំពូក៨ លេខ៣០៧, ៣៨៦-៣៨៧ ខាងលើ។

## ករណីយកិច្ចរបស់ព្រះរាជា ( DUTIES OF A KING )

២៥៤- អាណាចក្ររបស់ព្រះរាជាដែលជាការទទួលខុសត្រូវរបស់ទ្រង់ បើទ្រង់មិនដាក់ទោសចោរ (នឹងត្រូវ) យាយីរំខាន ហើយទ្រង់(នឹង)បាត់បង់ឋានសួគ៌។

២៥៥- ក៏ប៉ុន្តែប្រសិនបើអាណាចក្ររបស់ព្រះអង្គមានសុវត្ថិភាព មានការការពារដោយកម្លាំងប្រដាប់អាវុធរបស់ទ្រង់ អាណាចក្រនោះនឹងរីកចម្រើនជាប្រចាំ ឧបមាដូចជាដើមឈើដែលមានការស្រោចទឹក(បានល្អ)។

២៥៦- ចូរព្រះរាជា ដែលមើលឃើញ(អ្វីៗ)តាមរយៈចារបុរសរបស់ទ្រង់ រកឃើញចោរពីប្រភេទ ដែលយកទ្រព្យអ្នកដទៃធ្វើជាកម្មសិទ្ធិរបស់ខ្លួន ទាំងអ្នកដែល(ធ្វើ)ដោយបើកចំហ និងទាំងអ្នកដែលធ្វើ(ដោយការបិទបាំង)។

២៥៧- ក្នុងចំណោមពួកគេ ជនពាលចេញមុខ (គឺជាអ្នក)ដែលរស់នៅដោយអាស្រ័យ(ការបោកប្រាស់ក្នុងការលក់)ទំនិញនានានៅលើទីផ្សារ ប៉ុន្តែជនពាលលាក់មុខ គឺជាចោរលួចគាស់ផ្ទះ ចោរប្លន់ក្នុងព្រៃជាដើម។

២៥៨- អ្នកទាំងឡាយណាដែលស៊ីសំណូក បោកប្រាស់និងជនពាល អ្នកល្បែង អ្នកទាំងឡាយដែលរស់នៅដោយការបង្រៀន (អំពីការធ្វើ) ពិធីនក្ខត្តឫក្សនានា មនុស្សលាក់ពុតឱ្យគេគោរពស្រឡាញ់ និងគ្រូទាយ,

២៥៩- មន្ត្រីជាន់ខ្ពស់ និងគ្រូពេទ្យ ដែលប្រព្រឹត្តមិនត្រឹមត្រូវ អ្នកដែលរស់នៅដោយការបង្ហាញភាពប៉ិនប្រសប់របស់ខ្លួនផ្នែកសិល្បៈ និងស្រីសោភិនីដ៏ឆ្លាតវៃ,

---

**២៥៨.** *ឱបាធិកាៈ*បោកប្រាស់’ តាមលោកមេធ.មានន័យថា ‘មនុស្សមានចរិតពាល ដែលសន្យាធ្វើល្អ តែលួចធ្វើអាក្រក់ចំពោះអ្នកដទៃ’ ឬ ‘ដូចជាយកលុយដោយល្បិចក្លែងក្លាយ’ ឬ ‘ដូចជាគម្រាមយកលុយ’។ លោកកុល្ល. និងរាឃ. ប្រកាន់យកការបកស្រាយចុងក្រោយ ចំណែកឯលោកនារ. និងនន្ទ. ប្រែពាក្យនេះក្នុងន័យថា ‘មនុស្សដែលបោកប្រាស់ ដោយការបន្លំខ្នាតទម្ងន់ និងរង្វាស់រង្វាល់’។ *វញ្ចកាៈ* ‘ជនពាល’ គឺ‘មនុស្សដែលសន្យាធ្វើធុរកិច្ចឱ្យអ្នកដទៃ ហើយមិនគោរពតាមពាក្យសម្ដីរបស់ខ្លួន’(មេធ.) ឬ ‘អ្នកច្នៃប្រឌិត ដែលចង់កែប្រែលោហធាតុមូលដ្ឋាន ឱ្យទៅជាលោហធាតុមានតម្លៃ’(រសំ វិទ្យំ [រសំវិទ្យយា] តាំរាទិ រាជតាទិរូបេណ ទរសយិត្វា សុវណ្ណទិកំ គូហ្ណន្តិ លោករាឃ., កុល្ល.) ឬ ‘អ្នកដែលយកលុយ ដោយពុតត្បុតក្លែងក្លាយ’(នារ.)។ *មង្គលាទេសវ្ត្តាៈ* ‘អ្នកទាំងឡាយដែលរស់នៅដោយការបង្រៀនអំពីការធ្វើ ឬដោយការធ្វើពិធីនក្ខត្តឫក្សឱ្យអ្នកដទៃ’(មេធ., កុល្ល., រាឃ.) តាមលោកនារ.មានន័យថា ‘អ្នកដែលរស់នៅអាស្រ័យសូត្រ ច្រៀងចម្រៀងពិសិដ្ឋ ថ្វាយអាទិទេព’(មង្គលស្តុតិបាឋៃ វ្ត្តំ ចារិតំ យេសាំ) ហើយលោកមេធ. លើកឡើងនូវការបកស្រាយប្រហាក់ប្រហែលគ្នា។ លោកមេធ. អាន *ភទ្រប្រេក្សណិកៃ សហ* ហើយប្រែកន្សោមពាក្យនេះថា ‘សុជាតិវិទូ’(ប្រាសំសិក បុរុសលក្សណាៈ)។ លោកនារ. បកស្រាយ *ឥក្សណិកាៈ* ‘អ្នកទាយជោគវាសនា’ ដោយថា ‘អ្នកសម្ដែង និងអ្នកលេងល្បិច’។
**២៥៩.** *មហាមន្ត្រ*មន្ត្រីជាន់ខ្ពស់’ គឺ ‘រាជបម្រើ ដូចជាអាមាត្យ និងព្រាហ្មណ៍បុរោហិតប្រចាំរាជវាំង’(មេធ.) ឬ ‘កុង្សីយ៍ ’(នារ.) ត្រូវលោកកុល្ល. និងរាឃ. ប្រែក្នុងន័យផ្សេងថា ‘ទម័កដំរី’។ *សិល្បោបចារយុក្តាៈ* ‘អ្នករស់នៅដោយការបង្ហាញភាពប៉ិនប្រសប់របស់ខ្លួនផ្នែកសិល្បៈ’ គឺ ‘ការកាត់ចំណិតអំពៅជាដើម’(មេធ., រាឃ.) ឬ ‘ជាងគំនូរ’(កុល្ល.)។ លោកនារ. និងនន្ទ. អាន *សិល្បោបការយុក្តាៈ* គឺ ‘សិល្បករ ដូចជាជាងគំនូរ និងអ្នកដែលសម្អាង(ឧបការៈ) ដូចជាអ្នកធ្វើសក់’(នារ.) ឬ ‘អ្នកធ្វើឆ័ត្រ និងផ្លិត’(នន្ទ.)។ លោកមេធ. មានប្រសាសន៍ថា *អសំយក្តារិណៈ*ដែលប្រព្រឹត្តមិនត្រឹមត្រូវ’ ត្រូវរាប់បញ្ចូលមនុស្សទាំងបួនវណ្ណៈ។

២៦០- អ្នកទាំងនេះនិងអ្នកដែលបង្ហាញខ្លួនជាទូទៅ ព្រមទាំងអ្នកទាំងឡាយដែលដើរក្លែងខ្លួន (ដូចជា)អ្នកមិនមែនជាអារ្យ៉ន ដែលពាក់សញ្ញារបស់ពួកអារ្យ៉ន ទ្រង់ត្រូវដឹងថាជាមនុស្សបន្លា (នៅក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់)។

២៦១- ដោយបានតាមដានពួកគេ ដោយមនុស្សស្មោះត្រង់ ដែលក្លែងខ្លួនពួកគេ (ធ្វើជា)ប្រកបមុខរបរដូចគ្នា និងដោយមធ្យោបាយចារបុរស ដោយស្លៀកពាក់ក្លែងរូបនានា ទ្រង់ត្រូវតែជំរុញឱ្យពួកគេ (ប្រព្រឹត្តបទល្មើស) ហើយនាំខ្លួនពួកគេ មកចូលក្នុងអំណាចរបស់ទ្រង់។

២៦២- ដូច្នេះបន្ទាប់ពីបានបង្កឱ្យឧក្រិដ្ឋកម្ម ដែលពួកគេបានប្រព្រឹត្តដោយសកម្មភាពជាច្រើន ដែលត្រូវប្រកាសថាស្របតាមហេតុការណ៍ពិត ព្រះរាជានឹងដាក់ទោសពួកគេយ៉ាងត្រឹមត្រូវ ស្របតាមកម្លាំងរបស់ពួកគេ និងអំពើឧក្រិដ្ឋរបស់ពួកគេ។

២៦៣- ចំពោះភាពឃោរឃៅរបស់ចោរដែលមានចិត្តបិសាច ដែលដើរក្រវែលជាសម្ងាត់នៅលើដីនេះ អាចត្រូវគេឃាត់ខ្លួន លើកលែងតែដោយការដាក់ទណ្ឌកម្ម។

២៦៤- អគារសភា អគារបែងចែកទឹកឬកន្លែងលក់នំ ផ្ទះបន តៀមស្រា និងហាងលក់អាហារផ្លូវ បំបែកដើមឈើល្បីៗ សាលមហោស្រព រោងល្ខោន និងរោងតន្ត្រី,

២៦៥- ឧទ្យានបុរាណ ព្រៃឈើ រោងសិប្បករ លំនៅដ្ឋានទទេ ចម្ការធម្មជាតិ និងចម្ការសិប្បនិមិត្ត,

២៦៦- កន្លែងទាំងអស់នេះនិងកន្លែងប្រភេទនេះ ព្រះរាជាតម្រូវឱ្យមានកងទាហានធ្វើការយាមកាមទាំងការបោះទីតាំង និងការដើរល្បាត និងមានចារបុរស ដើម្បីការពារចោរកម្ម។

២៦៧- ព្រះរាជាត្រូវតែតាមរកឱ្យឃើញ និងកម្ទេចពួកគេ ដោយប្រើមធ្យោបាយចោរក្លែងរូបដ៏ឆ្លាតវៃ ដែលសេពគប់ជាមួយ (ជនពាល) បែបនេះ ប្រកបរបរតាមពួកចោរ ហើយដឹងពីឧបាយកលផ្សេងៗរបស់ពួកគេ។

---

**២៦០.** លោកនារ. និងនន្ទ. អាន *វិជាតីយាន*បែបនេះ និង(ជនពាល)ជាច្រើនប្រភេទ' ហើយភ្ជាប់ទុតិយាវិភត្តិ ក្នុងកាព្យនេះជាមួយ*វិទិត្វា* នៅក្នុងកាព្យបន្ទាប់។ លោកកុល្ល. ប្រែ *វិជានីយាត*ចូរទ្រង់ដឹង(ថាជា)' នៅក្នុងន័យថា 'ចូរទ្រង់ស្វែងយល់(តាមរយៈចារបុរស)'។

**២៦១.** ការប្រែនេះយកតាមការបកស្រាយរបស់នារ. ដែលអាន *ប្រោត្សហ្យ* (ដូចជាមាននៅក្នុងស្នាដៃលោកគោវ., រាឃ. និងK.)ជំនួសពាក្យ *ប្រោត្សា ទ្យ* មាននៅក្នុងអត្ថបទបោះពុម្ព នៅក្នុងអត្ថបទរបស់លោកកុល្ល. ហើយទំនងជានៅក្នុងអត្ថបទរបស់លោកមេធ.ផងដែរ។ អំណាន *ប្រោត្សាទ្យ* 'បន្ទាប់ពីបំផ្លាញពួកគេ' គឺគេអាចជំទាស់បាន បើពិនិត្យមើល កាព្យបន្ទាប់។ លោករាឃ. បកស្រាយ *ប្រោត្សហ្យ* ផ្សេងទៅវិញ ហើយលោកថា 'ដោយបានទូន្មានពួកគេដោយកម្លាំង ដោយនិយាយថា "អ្នកឯងត្រូវតែបោះបង់ចោលជីវភាពនេះ ហើយរកលុយ ដោយការធ្វើកសិកម្ម ពាណិជ្ជកម្ម ជាដើម" ទ្រង់ជំរុញឱ្យប្រកាន់យកទម្រង់ចិញ្ចឹមជីវិតដ៏ស្មោះត្រង់ ដោយចំណង់ចង់បានប្រាក់'។ លោកនន្ទ. ហាក់ដូចជាអាន *ប្រោត្សារ្យ* (ប្រោត្សារ្យា តាមសំណៅដៃ)។ លោកកុល្ល. បកស្រាយ *អនេកសំស្ថានៃ* 'ដោយស្លៀកពាក់ក្លែងផ្សេងៗ'(នារ., នន្ទ.) ដោយថា 'បានស្នាក់នៅកន្លែងផ្សេងៗ'។ ការអធិប្បាយរបស់លោកមេធ. អំពីកាព្យលេខ២៦១ ផ្នែកចុងក្រោយ និងកាព្យ២៦២-២៧៤ មិនមាននៅក្នុងសំណៅដៃដើម។

**២៦៧.** ជំនួស*ឧត្សាទយេត*ទ្រង់នឹងបំផ្លាញពួកគេ'(កុល្ល., K..., អត្ថបទបោះពុម្ព) ហើយលោកគោវ., នារ., នន្ទ. និងរាឃ. អាន *ឧត្សាហយេត* គឺ 'ទ្រង់នឹងញុះញង់ឱ្យពួកគេប្រព្រឹត្ត (បទឧក្រិដ្ឋ តាមលោកនារ., រាឃ.)'។

២៦៨- ក្រោមលេស(ដោយផ្តល់ឱ្យពួកគេ)នូវចំណីឆ្ងាញ់នានា ដោយណែនាំពួកគេដល់ពួកព្រាហ្មណ៍ និងដោយការធ្វើពុត (បង្ហាញពួកគេ) អំពីភាពខ្លាំងក្លានៃកម្លាំង (ចារបុរស) ត្រូវតែនាំពួកគេមកជួប(មន្ត្រីយុត្តិធម៌)។

២៦៩- អ្នកទាំងឡាយក្នុងចំណោមអ្នកដែលមិនមក និងអ្នកទាំងឡាយដែល(ព្រះរាជា)សង្ស័យថាជាចោរពីមុន ព្រះរាជានឹងវាយប្រហារដោយកម្លាំង និងសម្លាប់រួមគ្នាជាមួយនឹងមិត្ត ញាតិលោហិត និងញាតិសម្ព័ន្ធរបស់ពួកគេ។

២៧០- ព្រះរាជាយុត្តិធម៌ មិនឱ្យគេប្រហារជីវិតចោរទេ (លើកលែងតែ) មានទំនិញចោរកម្មនៅក្នុង(ដៃរបស់វា) ហើយអ្នកដែល(មាន)ទំនិញចោរកម្ម និងឧបករណ៍(គាស់ផ្ទះ) ព្រះអង្គអាចឱ្យគេ សម្លាប់ចោរនោះដោយគ្មានស្ទាក់ស្ទើរ។

២៧១- ព្រមទាំងអ្នកទាំងឡាយ ដែលនៅក្នុងភូមិផ្តល់អាហារឱ្យចោរ ឬផ្តល់កន្លែងឱ្យចោរ (លាក់ឧបករណ៍របស់ពួកគេ) ព្រះអង្គនឹងជំរុញឱ្យមានការដាក់ទោសប្រហារជីវិត។

២៧២- អ្នកទាំងឡាយដែលទទួលការតែងតាំងឱ្យយាមខេត្ត និងដែនចំណុះរបស់ទ្រង់ ដែលត្រូវទទួលព្រះរាជាបញ្ជា(ឱ្យជួយ) ព្រះអង្គដាក់ទោសឱ្យបានឆាប់រហ័សដូចជាបទចោរកម្មដែរ (ប្រសិនបើពួកគេនៅតែ)អសកម្ម ក្នុងការប្រយុទ្ធជាមួយ(ចោរប្លន់)។

២៧៣- ជាងនេះទៀត ប្រសិនបើ(មនុស្សម្នាក់)ដែលចិញ្ចឹមជីវិតដោយ(ការអនុវត្ត)ច្បាប់ ប្រាស់ចាកពីនីតិច្បាប់ជាធរមាន (ព្រះរាជា)នឹងដាក់ទោសពិន័យរូបគេដោយសម្ងាត់ (ព្រោះគេ)បានបំពានករណីយកិច្ចរបស់ខ្លួន។

២៧៤- អ្នកទាំងឡាយដែលមិនផ្តល់ជំនួយតាមលទ្ធភាពរបស់ពួកគេ នៅពេលភូមិកើតមានអំពើលួចប្លន់ ទំនប់ទឹកត្រូវបានបំផ្លាញ ឬការប្លន់តាមផ្លូវធំ ត្រូវបំបរបង់ទាំងទ្រព្យ និងប្រដាប់ប្រដាប្រើប្រាស់របស់ពួកគេ។

---

**២៦៩.** *មូលប្រណិហិតាះ*ដែលសង្ស័យចំពោះចោរកម្មចាស់ ពីសំណាក់ព្រះរាជា'(កុល្ល., រាឃ.) ហើយតាមលោកនារ. ថា 'ដែលកុង្សីយ៍បានបញ្ជូនទៅជាដើម ឱ្យស្នាក់នៅអាណាចក្ររបស់ព្រះអង្គ'។ តាមលោកនន្ទ. ថា 'ដែលបានរកឃើញឫសគល់ គឺហេតុផល(ដំណើរការរបស់ចារបុរស)'។ យ៉ាងណាមិញ ការបកស្រាយទាំងបី នៅមានមន្ទិលសង្ស័យ។

**២៧១.** *ភាណ្ឌាវកាសទាះ*ដែលផ្តល់កន្លែងឱ្យពួកគេ (លាក់បាំង) ឧបករណ៍របស់ពួកគេ'(កុល្ល.) តាមលោកនារ. គឺថា 'ដែលផ្តល់ថវិការឱ្យពួកគេ (ទិញអាវុធជាដើម) និងផ្តល់ជម្រក'។

**២៧២.** អ្នកអធិប្បាយប្រែ *សាមន្តាន* 'ដែនចំណុះរបស់ទ្រង់' តាមន័យនិរុត្តសាស្ត្ររបស់ពាក្យ 'ប្រទេសជិតខាង'។ ប៉ុន្តែនៅទីនេះ ពិតជាមានន័យបច្ចេកទេសជម្នតាប៉ុណ្ណោះ។

**២៧៣.** តាមអ្នកអធិប្បាយ សំដៅដល់អាចារ្យពិធីការ និងព្រាហ្មណ៍បុរោហិតផ្សេងៗទៀត ដែលចិញ្ចឹមជីវិតអាស្រ័យដោយការទទួលទាន ផ្អែកលើកម្លាំងសទ្ធាលើជំនឿសាសនារបស់ពួកគេ។

**២៧៤.** រ៉ិ. ជំពូក៥ លេខ៧៤។ ជំនួយឱ្យ *ហិតាភង្គេ* 'ពេលដែលមានការបំផ្លាញទំនប់ទឹក'(កុល្ល., អត្ថបទបោះពុម្ព) លោករាឃ. អាន *ហិឝាភង្គេ* ហើយលោកគោវ. ព្រមទាំងលោកនន្ទ. ថា *ឥឝាភង្គេ* ដោយបកស្រាយដូចគ្នា។ លោកនារ. សរសេរ *តឝាគភង្គេ* ទំនងជាសរសេរខុសចំពោះ *ឥទាភង្គេ* ហើយអត្ថបទផ្សេងៗសរសេរ *ហិត្តាភង្គេ* ដោយបន្ថែម *ហិត្តា* 'ទំនប់កាត់ទន្លេ'។ លោក K. ចុងក្រោយអាន *សេតុភង្គេ*។

២៧៥- ព្រះអង្គនឹងដាក់ទោសប្រហារជីវិតនានា ដូចជាដាក់ទោសអ្នកដែលឃុបឃិតជាមួយសត្រូវរបស់ទ្រង់ និងអ្នកដែលប្លន់រតនវត្ថុរបស់ព្រះរាជា ព្រមទាំងអ្នកដែលព្យាយាមប្រឆាំងនឹង(រាជបញ្ជារបស់ទ្រង់)។

២៧៦- ក៏ប៉ុន្តែព្រះរាជានឹងកាត់ដៃចោរប្លន់ទាំងឡាយណា ដែលលួចចូលផ្ទះ ប្រព្រឹត្តចោរកម្ម នៅពេលរាត្រី ហើយឱ្យគេ ដោតពួកគេនៅលើបង្គោលចុងស្រួច។

២៧៧- ក្នុងពេលកាត់ទោសលើកដំបូង ចូរទ្រង់បញ្ជាឱ្យគេកាត់ម្រាមដៃពីររបស់ចោរឆក់កាបូប ពេលកាត់ទោសលើកទីពីរ កាត់ដៃម្ខាង និងជើងម្ខាង លើកទីបី គេនឹងទទួលទោសស្លាប់។

២៧៨- អ្នកទាំងឡាយ ដែលផ្តល់(ឱ្យចោរ)នូវភ្លើង អាហារ អាវុធ ឬជម្រក និងអ្នកទទួលផលចោរកម្ម មេដឹកនាំនឹងដាក់ទោសដូចបទចោរកម្មដែរ។

២៧៩- ព្រះអង្គនឹងសម្លាប់អ្នកដែលទម្លាយ(ទំនប់)ទឹក (ដោយជ្រមុជទឹករូបគេ)ក្នុងទឹក ឬដោយដាក់ទោសប្រហារជីវិតតាមទម្រង់សាមញ្ញផ្សេងទៀត ឬអាចឱ្យជនល្មើសជួសជុល(ការខូចខាត) ហើយត្រូវបង្ខំឱ្យពិន័យកម្រិតខ្ពស់បំផុត។

២៨០- ព្រះអង្គនឹងសម្លាប់ដោយគ្មានស្ទាក់ស្ទើរចំពោះអ្នកដែលគាស់ទម្លាយចូលឃ្លាំងទំនិញ (ស្តេច) ឃ្លាំងអាវុធឬវិហារ និងអ្នកដែលលួចដំរី សេះ ឬរទេះចម្បាំង។

២៨១- ក៏ប៉ុន្តែអ្នកដែលលួចយកទឹកចេញពីអាងសម័យបុរាណ ឬកាត់ផ្តាច់ការផ្គត់ផ្គង់ទឹក ត្រូវបង្ខំឱ្យបង់ពិន័យថ្នាក់ទីមួយ (ឬកម្រិតទាបបំផុត)។

២៨២- ប៉ុន្តែអ្នកដែលទម្លាក់វត្ថុកខ្វក់លើផ្លូវធំរបស់ព្រះរាជា លើកលែងតែក្នុងករណីចាំបាច់បំផុត នឹងត្រូវបង់ពិន័យពីរ កហាបណៈ ហើយត្រូវយកវត្ថុ(កខ្វក់នោះ)ចេញជាបន្ទាន់។

---

**២៧៦.** យញ្ញ. ជំពូក២ លេខ២៧៣។

**២៧៧.** វិ. ជំពូក៥ លេខ១៣៦; យញ្ញ. ជំពូក២ លេខ២៧៤។ 'ម្រាមដៃពីរ' គឺ 'មេដៃ និងចង្អុលដៃ'(កុល្ល., រាឃ., នារ.) ឬ 'ចង្អុលដៃ និងម្រាមកណ្តាល'(នន្ទ.)។

**២៧៨.** យញ្ញ. ជំពូក២ លេខ២៧៦។ 'អ្នកទាំងឡាយ ដែលផ្តល់ភ្លើងឱ្យ(ចោរ)' គឺ 'ដើម្បីឱ្យពួកគេអាចកំដៅខ្លួនឬសម្រាប់គោលបំណងប្រហាក់ប្រហែល'(មេធ.) ឬ 'ដើម្បីឱ្យពួកគេដាក់ភ្លើងនៅក្នុងផ្ទះ'(នារ.)។ *មោសស្យ សំនិធាត្រីន* 'អ្នកទទួលផលចោរកម្ម'(កុល្ល.) តាមលោកនារ.ថា 'អ្នកទាំងឡាយដែលប្រព្រឹត្តចោរកម្មនៅកន្លែងដែលពួកគេប្រព្រឹត្តបទឧក្រិដ្ឋ ឬអ្នកផ្តល់ជំនួយ និងអ្នកសមគំនិត'។ សំណៅល្អបំផុតរបស់លោកមេធ. មានពាក្យ *មោក្សស្យ* នៅក្នុងអត្ថបទផង និងនៅក្នុងបទអត្ថាធិប្បាយផង ហើយអ្នកផ្សេងទៀតសរសេរនៅក្នុងអត្ថបទ ចំណែកឯការបកស្រាយ គឺ *រក្សិតារះ* 'អ្នកការពារ ឬអ្នកសមគំនិត'។ លោកនន្ទ. ក៏អាននៅក្នុងអត្ថបទ *មោក្សស្យ* ហើយថា 'មោក្សស្យ មោសិតទ្រវ្យស្យ មោក្ស សាធនស្យេតិ វា'។ ហេតុនេះ ទំនងជាថា សំណៅអត្ថបទបុរាណពិតប្រាកដ គឺ *មោក្សស្យ*។

**២៧៩.** យញ្ញ. ជំពូក២ លេខ២៧៨។ 'ដោយការដាក់ទោសប្រហារជីវិតតាមទម្រង់សាមញ្ញផ្សេងទៀត' គឺ 'ដោយការកាត់ក្បាលរបស់គេ'(នារ., រាឃ.)។

**២៨០.** យញ្ញ. ជំពូក២ លេខ២៧៣។ កាព្យនេះ និងកាព្យបន្ទាប់ ត្រូវបានលុបចោលនៅក្នុងសំណៅដែររបស់លោកមេធ.។

**២៨១.** នារ. និយាយថា ជនល្មើសក៏ត្រូវប៉ះប៉ូវការខូចខាតដែលកើតឡើងដែរ។

**២៨២.** វិ. ជំពូក៥ លេខ១០៦-១០៧។ លោកមេធ. មានប្រសាសន៍ថា គេនឹងបង់ឱ្យចណ្ឌាលី គឺ អ្នកបោសសម្អាតឱ្យសម្អាតវត្ថុកខ្វក់នោះចេញ។

២៨៣- ប៉ុន្តែមនុស្សដែលមានការចាំបាច់បន្ទាន់ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ឬកូនក្មេង នឹងត្រូវទទួលការស្តីបន្ទោស និងសម្អាត(កន្លែង)នោះ នេះជាវិធានច្បាប់បញ្ញត្តិ។

២៨៤- គ្រូទេព្យទាំងអស់ ដែលប្រព្រឹត្តមិនត្រឹមត្រូវដាក់(អ្នកជំងឺរបស់ខ្លួន) នឹងត្រូវបង់ប្រាក់ពិន័យក្នុងករណីជាសត្វពិន័យថ្នាក់ទីមួយ(ឬថ្នាក់ទាបបំផុត) ក្នុងករណីជាមនុស្ស ពិន័យថ្នាក់កណ្ដាល។

២៨៥- អ្នកដែលបំផ្លាញស្ពាន ទង់(របស់ព្រះវិហារ ឬរាជវាំង) បង្គោល ឬរូប នឹងត្រូវជួសជុល(ការខូចខាត)ទាំងស្រុង និងបង់ប្រាក់ពិន័យប្រាំរយ(បណៈ)។

២៨៦- ចំពោះការធ្វើឱ្យខូចទំនិញដែលមិនខូច និងចំពោះការធ្វើឱ្យបែកស្នាមត្បូង ឬចំពោះការធ្វើឱ្យមានរន្ធដោយមិនត្រឹមត្រូវ ការពិន័យគឺកម្រិតទីមួយ (ឬកម្រិតទាបបំផុត)។

២៨៧- ប៉ុន្តែបុរសដែលប្រព្រឹត្តមិនស្មោះត្រង់ចំពោះ(អតិថិជន)ស្មោះត្រង់ ឬបោកប្រាស់តម្លៃរបស់ខ្លួននឹងត្រូវពិន័យកម្រិតទីមួយ ឬពិន័យកម្រិតកណ្ដាល។

២៨៨- ចូរព្រះអង្គសង់គុកទាំងអស់នៅជិតផ្លូវធំ ដែលគេអាចមើលឃើញជនល្មើសរងទុក្ខ និងខូចរូបកាយ។

២៨៩- ព្រះអង្គនឹងបំបរបង់ភ្លាម ចំពោះអ្នកដែលបំផ្លាញជញ្ជាំង(ទីក្រុង) ឬចាក់ដីលុបស្នាមភ្លោះ (ជុំវិញក្រុង) ឬធ្វើឱ្យបាក់ទ្វារ(ក្រុង)។

២៩០- ដាក់ពិន័យចំនួនពីររយ(បណៈ)ចំពោះការប្រើអាគមគាថាក្នុងបំណងបំផ្លាញជីវិត ចំពោះការធ្វើពិធីវេទមន្តបំផ្លាញ (ដែលអនុវត្តដោយមនុស្ស) ដែលមិនពាក់ព័ន្ធ (នឹងអ្នកដែលគេធ្វើអាគមដាក់) និងចំពោះអំពើអាបធ្មប់ផ្សេងៗ។

---

**២៨៤.** រ៉ិ. ជំពូក៥ លេខ១៧៥-១៧៧; យញ្ញ. ជំពូក២ លេខ២៤២។ លោកនារ. បន្ថែម 'ប៉ុន្តែកាព្យនេះសំដៅដល់ករណីដែលសេចក្ដីស្លាប់ មិន(បណ្ដាលមកពីការប្រព្រឹត្តមិនត្រឹមត្រូវ)ទេ ព្រោះប្រសិនបើករណីដូច្នោះមែន ការដាក់ទោសមានកម្រិតធ្ងន់ជាង'។

**២៨៥.** រ៉ិ. ជំពូក៥ លេខ១៧៤; យញ្ញ. ជំពូក២ លេខ២៩៧។ 'បង្គោល' គឺបង្គោលទង់នៅក្នុងភូមិ(នារ.) ឬ 'ដូចជាឈើនៅក្នុងអាងជាដើម'(កុល្ល.)។ 'រូប' គឺ 'រូបសំណាកមនុស្ស ប៉ុន្តែទោសស្លាប់ ចំពោះការបំផ្លាញរូបសំណាកព្រះអាទិទេពព្រោះ (កាព្យ២៨០ខាងលើ) បានរៀបរាប់អំពីការដាក់ទោសប្រហារជីវិតចំពោះការគាស់ទម្លាយចូលព្រះវិហារ'(នារ.)។ លោកកុល្ល. និងរាឃ. មានប្រសាសន៍ថា 'រូបធម្មតា ដែលធ្វើពីដីឥដ្ឋជាដើម'។

**២៨៦.** រ៉ិ. ជំពូក៥ លេខ១២៤; យញ្ញ. ជំពូក២ លេខ២៤៥-២៤៦។ លោកមេធ. គិតថា ប្រាក់ពិន័យត្រូវសមាមាត្រទៅនឹងតម្លៃត្បូងដែលខូច ហើយលោកកុល្ល. បន្ថែមថា ក្នុងគ្រប់ករណី ម្ចាស់វត្ថុខូចនោះនឹងទទួលសំណងវិញ។

**២៨៧.** លោកកុល្ល. និងនារ. មានប្រសាសន៍ដូច្នេះ។ ប៉ុន្តែលោកមេធ. ប្រែអនុប្រយោគទីមួយផ្សេងទៅវិញថា 'បុរសដែលផ្ដល់ (បរិមាណ)មិនស្មើនឹង(ទំនិញនោះ ត្រូវគេប្ដូរឱ្យ)បរិមាណដែលស្មើវិញ'។

**២៨៨.** លោកនន្ទ. អាន *កស្ដានិ*ដែលការប្រព្រឹត្តនោះមានទម្ងន់ធ្ងន់ធ្ងរ' ជំនួស *សភាណិ* 'ទាំងអស់'។

**២៩០.** តាមអ្នកអធិប្បាយនានា *អភិចារៈ* មានមន្តគាថា និងពិធីយញ្ញទាំងអស់ ដែលមានបង្រៀននៅក្នុងព្រះវេទក៏បាន ឬនៅក្នុងផ្លូវលោក ដែលមានចេតនាចង់បំផ្លាញជីវិតក៏បាន។ ពិធីវេទមន្ត ដែលធ្វើដើម្បីកម្ចាត់ គឺជាពិធីដែលចង់យកមនុស្សណាម្នាក់ មកដាក់ក្រោមអំណាចរបស់ខ្លួន។ របៀននេះត្រូវបានអនុញ្ញាត ប្រសិនបើអនុវត្តន៍ប្រឆាំងនឹងស្វាមី ឬសាច់ញាតិ(នារ.)។ *ក្ឫត្យាះ* 'អាបធ្មប់' គឺជាវេទមន្តបង្កើតជំងឺ ឬបង្កបរាជ័យការងាររបស់បច្ចាមិត្រ។ ប្រសិនបើ *អភិចារ* សម្រេចជោគជ័យ ការដាក់ទោសគឺបទមនុស្សឃាត(មេធ., កុល្ល.)។

២៩១- អ្នកដែលលក់ (ពូជពោតដែល) មិនមែនជាពោតពូជ អ្នកដែលប្រមូលយកគ្រាប់ពូជ(ដែលគេសាបព្រោះរួចហើយ) និងអ្នកដែលបំផ្លាញ (សញ្ញាសម្គាល់) ព្រំប្រទល់ នឹងត្រូវដាក់ទោសកាត់អវយវៈ។

២៩២- ប៉ុន្តែព្រះរាជានឹងបង្ខំឱ្យគេធ្វើទុក្ខទោសជាងមាស ដែលប្រព្រឹត្តមិនស្មោះត្រង់ ដោយការកាត់ធូតនឹងកាំបិតកោរ។

២៩៣- ចំពោះការលួចឧបករណ៍កសិកម្ម អាវុធ និងឱសថ ចូរព្រះរាជាដាក់ទោស ដោយគិតពីរយៈពេលនៃ(បទល្មើស) និងការប្រើប្រាស់(វត្ថុនោះ)។

២៩៤- ព្រះរាជា និងកុង្សីយ៍របស់ទ្រង់ រាជធានីរបស់ទ្រង់ អាណាចក្ររបស់ទ្រង់ កងទ័ពរបស់ទ្រង់ និងសម្ព័ន្ធមិត្តរបស់ទ្រង់ គឺជាធាតុសំខាន់ប្រាំពីរ (របស់ព្រះរាជាណាចក្រ) (ហេតុនេះ)គេនិយាយថាអាណាចក្រត្រូវមានអវយវៈ(អង្គ)ចំនួនប្រាំពីរ។

២៩៥- ប៉ុន្តែចូរព្រះអង្គជ្រាប(ថា)ក្នុងចំណោមអង្គទាំងប្រាំពីរនៃព្រះរាជាណាចក្រ(ដែលបានរៀបរាប់) តាមលំដាប់លំដោយអង្គនីមួយៗ (រៀបរាប់ឈ្មោះខាងដើម) មានសារសំខាន់ជាង និង(ការបំផ្លិតបំផ្លាញរបស់វា) ជាគ្រោះអាសន្នធ្ងន់ធ្ងរជាង។

២៩៦- ប៉ុន្តែនៅក្នុងព្រះរាជាណាចក្រមួយ ដែលអង្គសំខាន់ប្រាំពីរ ដែលលើកទ្រ បីដូចជាសសរស្តម្ភបី (របស់ឥសី) ពោលគឺគ្មាន (អង្គណាមួយ) សំខាន់ជាង (អង្គផ្សេង) ដោយហេតុផលនៃសារៈសំខាន់ផ្នែកគុណសម្បត្តិនៃអង្គនីមួយៗជាងអង្គផ្សេងទេ។

២៩៧- ព្រោះអង្គនីមួយៗមានលក្ខណៈសម្បត្តិពិសេស ដើម្បី(សម្រេច)វត្ថុបំណងជាក់លាក់ (ហេតុនេះហើយ) អង្គនីមួយៗ ត្រូវប្រកាសថាមានសារសំខាន់បំផុតសម្រាប់គោលបំណងពិសេសដែលអាស្រ័យដោយមធ្យោបាយរបស់វា។

២៩៨- តាមរយៈចារបុរស តាមរយៈការធ្វើពុតបង្ហាញកម្លាំង និងតាមរយៈការចាត់វិធានការ(នានា) ចូរព្រះរាជាដឹងឱ្យបានច្បាស់ជានិច្ចអំពីកម្លាំងរបស់ទ្រង់ផ្ទាល់ និងកម្លាំងរបស់សត្រូវទ្រង់,

---

**២៩១.**ជំនួស*ពិជោត្ក្រិស្ដំ*(កុល្ល.)ដែលត្រូវបកស្រាយថា'ដែលលក់គ្រាប់ពូជពោត ដោយដាក់(នៅខាងលើស្បោង ធញ្ញជាតិដែលគ្មានតម្លៃ)' ហើយការអានត្រឹមត្រូវហាក់ដូចជា *ពីជោត្ក្រុស្ដា*អ្នកដែលប្រមូលយកគ្រាប់ពូជ(ដែលគេសាបព្រោះរួច)'។ *ពិជោត្ក្រុស្ដា* មានតែនៅក្នុងបទអត្ថាធិប្បាយរបស់លោកនារ.ប៉ុណ្ណោះ ដែលបកស្រាយ *ពិជកាលេ មហាយតាកា មោត្តសការី* 'អ្នកដែល នៅពេលសាបព្រោះ បំផ្លាញ(ពូជ)ចោល ដោយចង់តម្លើងថ្លៃគ្រាប់ធញ្ញជាតិ'។ អ្នកអធិប្បាយដទៃ ទៀតទាំងអស់ លើកឡើងនូវអំណានដែលមិនសូវច្បាស់លាស់។

**២៩៣.** ហេតុនេះ ចោរលួចនង្គ័លនៅក្នុងរដូវភ្ជួររាស់ ឬលួចអាវុធនៅមុន ឬក្នុងអំឡុងពេលប្រយុទ្ធ គួរត្រូវដាក់ទោសឱ្យធ្ងន់ធ្ងរជាង ប្រសិនបើអំពើនោះត្រូវបានប្រព្រឹត្តនៅក្នុងពេលផ្សេងទៀត។

**២៩៤.** សូមមើលជំពូក៧ លេខ២៥៧; យញ្ញ. ជំពូក១ លេខ៣៥២ ខាងលើ។

**២៩៦.** តាមការកត់សម្គាល់របស់អ្នកអធិប្បាយនានា កាព្យនេះមានន័យចង់បង្ហាញថា គេមិនត្រូវសន្និដ្ឋានតាមកាព្យលេខ២៩៥ថា អង្គ ដែលការរៀបរាប់ឈ្មោះក្រោយ អាចត្រូវគេបំភ្លេចចោល។ តាមលោកនារ. ពាក្យប្រៀបធៀប មិនមែនចេញពីសសរស្តម្ភបីរបស់ឥសីទេ ប៉ុន្តែជាចំណុចល្អបីរបស់ផ្ទះជាដើម។

**២៩៨.** សូមមើលជំពូក៧ខាងលើ។ លោកមេធ., គោវ., នារ., នន្ទ. និង K.អាននៅចុងបន្ទាត់ *បរាត្មនោះ* ជំនួស*មហិបតិះ*។

២៩៩- ជាងនេះទៅទៀត គ្រោះវិបត្តិនិងអបាយមុខទាំងអស់ ចូរព្រះអង្គចាប់ផ្ដើមប្រតិបត្តិការរបស់ទ្រង់ បន្ទាប់ពីពេលព្រះអង្គបានពិចារណាទាំងស្រុងអំពីសារៈសំខាន់ពាក់ព័ន្ធរបស់វារួចហើយ។

៣០០- (ថ្វីត្បិតតែព្រះអង្គ) មានការធុញទ្រាន់ខ្លាំង (នឹងបរាជ័យម្ដងហើយម្ដងទៀត) ក៏ដោយ ចូរព្រះអង្គចាប់ផ្ដើមប្រតិបត្តិការរបស់ទ្រង់ម្ដងហើយម្ដងទៀត ព្រោះភ័ព្វសំណាងកើតមានដល់បុរស ណាដែលបានខិតខំប្រឹងប្រែងក្នុងកិច្ចការរបស់ខ្លួន។

៣០១- វិធីផ្សេងៗដែលព្រះរាជាប្រព្រឹត្ត(ឧបមាដូច)កាល*ក្រឹតត្រេតាទ្វាបរ* និង*កាលិ* ហេតុនេះព្រះរាជាត្រូវបានគេប្រដូចទៅនឹងអាយុកាលរបស់(ពិភពលោក)។

៣០២- ការផ្ទំ ទ្រង់តំណាងឱ្យកាលិ (ឬយុគដែក) ការតើនជាទ្វាបរ (ឬយុគស្ពាន់) ការរៀបចំធ្វើសកម្មភាព គឺជាត្រេតា (ឬយុគប្រាក់) ប៉ុន្តែការធ្វើសកម្មភាព(យ៉ាងសកម្ម)ជាក្រិត (ឬយុគមាស)។

៣០៣- ចូរព្រះរាជាប្រដែងយកឈ្នះសកម្មភាពស្វាហាប់របស់ព្រះឥន្ទ្រ ព្រះអាទិត្យ ព្រះពាយ ព្រះយម ព្រះវរុណ ព្រះច័ន្ទ ព្រះអគ្គី និងព្រះធរណី។

៣០៤- ដូចព្រះឥន្ទ្របញ្ចូនទឹកភ្លៀងដ៏បរិបូណ៌ក្នុងអំឡុងពេលបួនខែនារដូវវស្សា ហេតុដូច្នេះ ចូរព្រះរាជាសាបព្រោះប្រយោជន៍ដល់អាណាចក្ររបស់ទ្រង់ ឱ្យដូចគ្នានឹងមុខនាទីរបស់ព្រះឥន្ទ្រ។

៣០៥- ដូចព្រះអាទិត្យក្នុងអំឡុងប្រាំបីខែស្រូបទឹកដោយកាំរស្មីរបស់ទ្រង់ (ដោយគ្មាននរណាដឹង) ដូច្នេះចូរព្រះអង្គយកពន្ធរបស់ទ្រង់សន្សឹមៗពីអាណាចក្រទ្រង់ ព្រោះនេះជាមុខនាទីរបស់ទ្រង់ ដែលឧបមាដូចជាព្រះអាទិត្យ។

៣០៦- ដូចព្រះពាយយាង(ទៅកាន់គ្រប់ទិសតំបន់) ក្នុងរូបភាព (ជាខ្យល់សំខាន់សម្រាប់ជីវិត) សត្វលោកទាំងអស់ ហេតុនេះចូរព្រះអង្គយាងទៅ(គ្រប់កន្លែង)តាមរយៈចារបុរសរបស់ទ្រង់ ពោលគឺនេះជាមុខនាទីរបស់ទ្រង់ ឧបមាដូចព្រះពាយ។

៣០៧- ដូចព្រះយម គ្រប់គ្រងទាំងមិត្តនិងទាំងសត្រូវតាមពេលកំណត់ ដូច្នេះព្រះរាជាត្រូវតែគ្រប់គ្រងប្រជារាស្ត្រទាំងអស់ ពោលគឺ នេះជាមុខនាទីរបស់ទ្រង់ ដូចជាព្រះយមដែរ។

៣០៨- ដូច (អ្នកប្រព្រឹត្តអំពើបាប) ត្រូវគេឃើញជាប់ចំណងខ្សែរបស់ព្រះវរុណ ដូច្នេះចូរព្រះអង្គដាក់ទោសមនុស្សអាក្រក់ ព្រោះនេះជាមុខនាទីរបស់ទ្រង់ ដូចជាព្រះវរុណ។

---

**២៩៩.** 'គ្រោះវិបត្តិ និងអបាយមុខទាំងអស់' គឺ 'អ្នកដែលមានឥទ្ធិពលលើសត្រូវរបស់ទ្រង់ និងភាគីរបស់សត្រូវទ្រង់' (នារ.) ឬ 'អ្នកដែលមានឥទ្ធិពលលើភាគីទ្រង់ផ្ទាល់ផង និងភាគីសត្រូវផង'(កុល្លូ.)។ លោកនន្ទ. អានបន្ទាត់ទីពីរថា *គុរុលាឃវតោ ញាត្វា តតះ ក័មៈ សមាចរេត*។

**៣០២.** កាព្យនេះមានភាពស្របគ្នាឧបទេសទីបួនរបស់ព្រះឥន្ទ្រ ដែលថ្លែងទៅកាន់រោហិតា គម្ពីរអៃតរេយ-ព្រាហ្មណ៍ ជំពូក ៧ លេខ១៥។

**៣០៥.** ជំនួស *និត្យំ* 'សន្សឹមៗ' លោកនន្ទ. អាន *សំយក*ដោយសមគួរ'។

**៣០៨.** លោកនន្ទ. អានបន្ទាត់ទីមួយផ្សេងទៅវិញ *វរុណោនាបិ បាសៃ ច ពធ្យតេ វារុណៃរ នរះ*បីដូចព្រះវរុណ ចងមនុស្សនឹងច្រវាក់របស់វរុណដែរ'។ សំនួនពាក្យ 'ច្រវាក់របស់ព្រះវរុណ' ជាទូទៅសំដៅដល់ជំងឺលើសទឹក។

៣០៩- ទ្រង់ជាស្ដេច ដែលមាននាទីដូចជាព្រះច័ន្ទ បង្ហាញខ្លួនឱ្យប្រជារាស្ត្រទ្រង់(គោរពដោយក្ដីអំណរក្រៃលែង) ឧបមាដូចមនុស្សមានអារម្មណ៍នៅពេលមើលព្រះច័ន្ទពេញវង់។

៣១០- (ប្រសិនបើ)ទ្រង់ព្យាយាមប្រឆាំងនឹងឧក្រិដ្ឋជន និងមានថាមពលត្រចះត្រចង់ ហើយកម្ទាត់បរិវាខិលខូច ដូច្នេះគេនឹងប្រដូចលក្ខណៈរបស់ទ្រង់ (ដូចជា)លក្ខណៈរបស់ព្រះអគ្គីដែរ។

៣១១- ដូចព្រះធរណី ទ្រទ្រង់សត្វលោកទាំងអស់ដូចៗគ្នា ដូច្នេះ (ព្រះរាជា)ដែលទ្រទ្រង់អាណាប្រជានុរាស្ត្រទាំងអស់របស់ទ្រង់ (ជាអ្នកកាន់)នាទីដូចព្រះធរណី។

៣១២- ដោយប្រើលក្ខណៈទាំងនេះ និងមធ្យោបាយផ្សេងទៀត ព្រះរាជានឹងមិននឿយហត់ ក្នុងការគ្រប់គ្រងពួកចោរទាំងនៅក្នុងអាណាចក្រផ្ទាល់របស់ទ្រង់ និងនៅដែនដីផ្សេងទៀត។

៣១៣- ចូរទ្រង់ ទោះជាស្ថិតក្នុងទុក្ខព្រួយធ្ងន់ធ្ងរបំផុតក៏ដោយ ក៏មិនធ្វើឱ្យព្រាហ្មណ៍ខឹង ព្រោះថានៅពេលពួកព្រាហ្មណ៍ខឹង ពួកគេអាចបំផ្លាញព្រះអង្គភ្លាម ព្រមទាំងកងទ័ពរបស់ទ្រង់ និងយានជំនិះរបស់ទ្រង់។

៣១៤- តើអ្នកអាចគេចផុតពីការបំផ្លាញ ពេលណាព្រះអង្គធ្វើឱ្យ(មនុស្ស)ទាំងនោះខឹង តើនរណាបង្កើតភ្លើងឱ្យឆេះអ្វីៗទាំងអស់ តើនរណាបង្កើតទឹកសមុទ្រមកមិនអាចផឹកបាន ហើយតើនរណាបង្កើតព្រះច័ន្ទ ឱ្យមានដំណើររនោច និងខ្នើតឡើងវិញដូច្នេះ?។

៣១៥- តើនរណាអាចធ្វើឱ្យចម្រើន ខណៈដែលទ្រង់បំផ្លាញ(អ្នក)ទាំងឡាយ ដែលបានបង្កកំហឹង តើនរណាអាចបង្កើតពិភពលោកផ្សេង និងអ្នកការពារពិភពលោកផ្សេងទៀត ហើយអាចដកហូតឋានៈអាទិទេពរបស់ពួកទេវតាបាន?។

៣១៦- តើមនុស្សណាដែលស្រឡាញ់ជីវិត ចង់បំផ្លាញអ្នកទ្រទ្រង់ពិភពលោក (ទាំងបី) និងអាទិទេពដែលមានអត្ថិភាពរបស់ខ្លួនជានិច្ច និងអ្នកដែលមានទ្រព្យរបស់ខ្លួនជាព្រះវេទនោះ?។

---

**៣១០.** លោកនារ. បន្ថែម 'ដូចព្រះអគ្គី ក្នុងពេលពិសោធន៍ ធ្វើឲ្យមនុស្សអាក្រក់ត្រូវរបួស ដូច្នេះព្រះអង្គគួរបំផ្លាញ អ្នកជិតខាងដែលអាក្រក់ដូចគ្នាដែរ។'

**៣១២.** 'នៅក្នុង(ដែន)របស់អ្នកដទៃ' គឺ 'ចោរទាំងឡាយ ដែលរស់នៅក្នុងអាណាចក្រដទៃ ហើយមកលួចប្លន់នៅក្នុងដែនដីរបស់ទ្រង់ផ្ទាល់'(កុល្លូ., នារ.)។ លោកនារ. លុបចោលកាព្យនេះ និងកាព្យពីរបន្ទាប់ទៀត។

**៣១៣.** 'ចូរព្រះអង្គកុំធ្វើឱ្យព្រាហ្មណ៍ខឹង' គឺ 'ដោយដកយកកម្មសិទ្ធិរបស់ពួកគេ'(មេធ., នារ.) ឬ 'ដោយព្រហើនដាក់ពួកគេ'(មេធ.)។ 'ពួកគេអាចបំផ្លាញទ្រង់' គឺ 'ដោយពិធីវេទមន្ត និងការដាក់បណ្ដាសា'(កុល្លូ.)។

**៣១៤.** កាព្យនេះសំដៅដល់សាច់រឿងមួយចំនួន ដូចលោកមេធ.បាននិទានប្រាប់ស្រាប់ ហើយលោកនារ. គូសបញ្ជាក់នៅក្នុងវគ្គមហាភារត ឈ្មោះមោក្ស-ធ៌មៈ ជំពូក១២ លេខ៣៤៤, ៥៥, ៥៧-៥៨, ៦០-៦១។ ត្រង់ចំណុចនោះមាននិយាយថា ព្រះភ្រិគុបានធ្វើឱ្យភ្លើងឆេះត្របាក់អ្វីៗគ្រប់យ៉ាង ព្រះច័ន្ទក្លាយជា 'មានអារម្មណ៍បរិភោគ' ដោយសារបណ្ដាសារបស់ *ទក្ស:* ហើយ*វ៉ាឌមុខ* បានធ្វើឱ្យសមុទ្រ មានរសជាតិប្រៃ ដើម្បីជាការដាក់ទោសចំពោះការមិនស្ដាប់បង្គាប់របស់ទ្រង់។

**៣១៥.** កាព្យនេះក៏មាននិយាយទៅដល់រឿងមហាភារតៈផងដែរ។ ឥសីវិស្វាមិត្របានព្យាយាមបង្កើតពិភពលោកផ្សេងទៀត (មេធ.) គឺ *ពលខិល្យ* , ឋានព្រះឥន្ទមួយទៀត និងវាយុ ហើយឥសីខ្លះទៀតបានដកហូតឋានៈរបស់ពួកទេវតា។ បើយោងតាមចំណុចក្រោយនេះ លោករាឃ. ដកស្រង់សាច់រឿងមាណ្ឌវ្យ ដែលដាក់បណ្ដាសាព្រះមយៈ (មហាភារតៈ ជំពូក១ លេខ១០៨, ១៦) និងធ្វើឱ្យទ្រង់ចាប់កំណើតជាសូទ្រៈ។

**៣១៦.** សូមមើលជំពូក១ លេខ៩៣-៩៥។

៣១៧- ព្រាហ្មណ៍ ទោះជាគាត់ចេះដឹងក្តី ឬល្ងង់ខ្លៅក្តី ក៏មានទេវភាពច្រើន បីដូចជាព្រះអគ្គី ទោះជាគេយកទៅធ្វើពិធី(ដុតបូជា)ក្តី ឬមិនបូជាក្តី ក៏មានទេវភាពមហាសាល។

៣១៨- ភ្លើងដ៏ត្រចះត្រចង់ មិនកខ្វក់សូម្បីនៅក្នុងទីបញ្ចុះសព ហើយនៅពេលមានការបូជា (ខ្លាញ់) ក្នុងពិធីយញ្ញ ព្រះអគ្គីបង្កើនអានុភាពជាថ្មីទៀត។

៣១៩- ហេតុនេះ ថ្វីបើព្រាហ្មណ៍ដាក់ខ្លួនប្រកបការងារ(គ្រប់ប្រភេទ)ក៏ដោយ ក៏ពួកគេត្រូវតែទទួលបានកិត្តិយសគ្រប់ទិដ្ឋភាព ព្រោះថាព្រាហ្មណ៍(ម្នាក់ៗ) សុទ្ធតែមានភាពជាអាទិទេពដ៏វិសេសវិសាល។

៣២០- នៅពេលក្សត្រិយចាប់ផ្តើមជិះជាន់ព្រាហ្មណ៍តាមរបៀបណាមួយ ព្រាហ្មណ៍នឹងទប់ទល់ជាមួយពួកគេដោយត្រឹមត្រូវ ព្រោះក្សត្រិយចាប់កំណើតពីព្រាហ្មណ៍។

៣២១- ភ្លើងចាប់កំណើតពីទឹក ក្សត្រិយចាប់កំណើតពីព្រាហ្មណ៍ ដែកមានកំណើតពីថ្ម ហើយកម្លាំងទម្លុះចូលជាតុ(ទាំងបី) គ្មានអានុភាពទៅលើជាតុដែលបង្កើតវានោះទេ។

៣២២- ក្សត្រិយនឹងមិនចម្រើនបើគ្មានព្រាហ្មណ៍ ព្រាហ្មណ៍នឹងមិនចម្រើនទេបើគ្មានក្សត្រិយ ហើយព្រាហ្មណ៍និងក្សត្រិយនឹងចម្រើននៅក្នុង(លោកិយ)នេះ និងនៅក្នុងលោកបន្ទាប់ ដោយការរួបរួមគ្នាស្អិតរមួត។

៣២៣- ក៏ប៉ុន្តែ (ព្រះរាជាដែលស្គាល់នូវព្រះរាជបំណងរបស់ទ្រង់ជាប់ជាប្រចាំ) នឹងប្រើប្រាស់ទ្រព្យរបស់ទ្រង់ទាំងអស់ ដែលបានពីការពិន័យ សម្រាប់ពួកព្រាហ្មណ៍ ប្រទានអាណាចក្រទ្រង់ទៅឱ្យព្រះរាជបុត្ររបស់ទ្រង់ ហើយហ៊ានប្រឈមនឹងសេចក្តីស្លាប់នៅក្នុងសមរភូមិ។

៣២៤- ដូច្នេះព្រះរាជានឹងបញ្ជាឱ្យរាជការរបស់ទ្រង់ទាំងអស់ (ធ្វើការ)ដើម្បីប្រយោជន៍របស់ប្រជារាស្ត្រទ្រង់ តាមរយៈការប្រព្រឹត្តដោយផ្ទាល់ (និង)មានព្រះទ័យគិតគូរ(បំពេញ)រាជកិច្ចរបស់ទ្រង់ជានិច្ច។

៣២៥- ច្បាប់អមតៈស្តីពី ករណីយកិច្ចរបស់ព្រះរាជាត្រូវបានប្រកាសទាំងស្រុងមកយ៉ាងនេះ ហើយចូរដឹងថា វិធានច្បាប់ខាងក្រោម គឺសម្រាប់ករណីយកិច្ចរបស់ពួកវៃស្យ និងសូទ្រៈ។

---

**៣២១.** 'ភ្លើងមានកំណើតពីទឹក គឺគម្ពីរបុរាណិកៈថ្លែងដូច្នេះ'(នន្ទ.) '(ដើមកំណើតនោះគឺ)គេអាចមើលឃើញបាន ដោយសារការបដិសន្ធិ និងក្នុងកំណើតវណ្ណវាគ្និ(ក្រោមទឹក)'(រាឃ.)។ តាមលោករាឃ. ការថ្លែងថា ក្សត្រិយចាប់កំណើតពីព្រាហ្មណ៍ គឺផ្អែកលើខ្លឹមសារព្រះវេទ។ ប៉ុន្តែលោកនារ. គិតថា ចំណុចនេះសំដៅដល់សាច់រឿងគម្ពីរ*បុរាណ* ដែលថា ព្រាហ្មណ៍បានបង្កើតអំបូរក្សត្រិយ ចេញពីស្ត្រីក្សត្រិយា បន្ទាប់ពី*បរសុរាម*បំផ្លាញ*វំណ* ទីពីរ។

**៣២២.** គោត. ជំពូក១១ លេខ១៤; វស. ជំពូក១៩ លេខ៨។

**៣២៣.** លោកមេធ. មានប្រសាសន៍ថា អ្នកដទៃបកស្រាយសំនួនពាក្យនេះ 'ទ្រព្យរបស់ទ្រង់ទាំងអស់ ដែលបានពីការពិន័យ' ថា 'ទ្រព្យរបស់ទ្រង់ដែលមានទាំងអស់ លើកលែងតែសេះ និងរទេះចម្បាំង អាវុធ ដីធ្លី និងទាសករ' ប៉ុន្តែថា ការបកស្រាយនេះមិនសមស្របទេ។ លោកបន្ថែមថា ប្រសិនបើព្រះរាជាមិនស្លាប់នៅក្នុងសមរភូមិទេ ព្រះអង្គដុតឬលោតទឹកសម្លាប់ខ្លួនឯង។ លោកកុល្ល. និយាយថា ព្រះអង្គអាចសម្លាប់ខ្លួន ដោយការបង្អត់ព្រះក្រយា។ នៅសម័យក្រោយមក ព្រះរាជាបានប្រព្រឹត្តតាមវិធានច្បាប់នេះ។ សូមមើលឧទាហរណ៍ វិក្រមាង្កចរិត ជំពូក៤ លេខ៤៤-៦៨។

៣២៦- បន្ទាប់ពីវៃស្យបានទទួលពិធីប្រសិទ្ធី និងមានភរិយា គេតែងតែយកចិត្តទុកដាក់រឿងការងារដែលខ្លួនអាចចិញ្ចឹមជីវិតបាន និងគិតគូរ(ការងារ)មើលថែសត្វ។

៣២៧- ព្រោះពេលព្រះជាម្ចាស់ (ប្រជាបតិ) បានបង្កើតសត្វពាហនៈ ព្រះអង្គបានប្រទានវាឱ្យពួកវៃស្យ ឱ្យពួកព្រាហ្មណ៍ និងឱ្យព្រះរាជា ព្រះអង្គបានប្រគល់ឱ្យសត្វលោកទាំងអស់។

៣២៨- វៃស្យមិនដែល (នឹកសុំ) ពរនេះថា 'ខ្ញុំនឹងមិនចិញ្ចឹមសត្វទេ' ហើយបើវៃស្យមានបំណង(ចិញ្ចឹមសត្វ) មនុស្ស(វណ្ណៈ)ផ្សេងមិនត្រូវចិញ្ចឹមសត្វទេ។

៣២៩- (វៃស្យ)ត្រូវតែដឹងនូវតម្លៃសក្ការៈរបស់ត្បូង គជ់ ផ្កាថ្ម លោហធាតុ (ក្រណាត់)ដែលធ្វើពីអំបោះ គ្រឿងក្រអូប និងគ្រឿងទេស។

៣៣០- គេត្រូវតែចេះ(របៀប)សាបព្រោះគ្រាប់ពូជ និងគុណសម្បត្តិល្អនិងអាក្រក់របស់ស្រែ ហើយគេត្រូវតែចេះល្អិតល្អន់អំពីមាត្រាសាស្ត្រ និងខ្នាតទម្ងន់ទាំងអស់។

៣៣១- ជាងនេះទៅទៀត(ត្រូវដឹង)ឧត្តមភាពនិងវិការនៃទំនិញ គុណសម្បត្តិនិងគុណវិបត្តិ នៃប្រទេស (នានា) (ដឹងពី)ចំណេញនិងខាតក្នុងការរកស៊ីលក់ដូរ និងមធ្យោបាយចិញ្ចឹមសត្វពាហនៈដោយត្រឹមត្រូវ។

៣៣២- គេត្រូវតែដឹងពីប្រាក់ឈ្នួល(សមរម្យ)សម្រាប់អ្នកបម្រើ ចេះភាសានានារបស់មនុស្ស ស្គាល់របៀបរក្សាទុកទំនិញ និង(វិធានច្បាប់)សម្រាប់ការទិញ និងលក់។

## គ្រាអាសន្ន ចម្រុះវណ្ណៈ

៣៣៣- ចូរគេព្យាយាមប្រឹងប្រែងឱ្យពេញទំហឹង ដើម្បីបង្កើនទ្រព្យសម្បត្តិរបស់ខ្លួន ដោយវិធីត្រឹមត្រូវ ហើយចូរគេបរិច្ចាគអាហារដោយជំនឿស៊ប់ ដល់សត្វលោកទាំងអស់។

៣៣៤- ប៉ុន្តែចូរបម្រើព្រាហ្មណ៍(ដែលមាន)ការចេះដឹងព្រះវេទ ឃរាវាស និងមនុស្សដែលមានគុណធម៌ល្បីល្បាញ ជាករណីយកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់សូទ្រៈ ដែលនាំឱ្យមានបរមសុខ។

៣៣៥- (សូទ្រៈ ដែលមាន)ភាពបរិសុទ្ធ ជាអ្នកបម្រើអ្នកខ្ពង់ខ្ពស់ជាងខ្លួន មានសម្ដីសុភាពរាបសា និងមិនប្រកាន់ខ្លួន ហើយតែងតែស្វែងរកទីពឹងជាមួយនឹងព្រាហ្មណ៍ (នៅជាតិក្រោយរបស់ខ្លួន) នឹងបានវណ្ណៈខ្ពស់ជាងនេះ។

៣៣៦- ច្បាប់ដ៏ឧត្តមសម្រាប់ការប្រព្រឹត្តរបស់វណ្ណៈទាំងបួន (នៅពេលពួកគេ)មិនស្ថិតក្នុងភាពអាសន្ន ត្រូវបានប្រកាសជាផ្លូវការមកយ៉ាងដូច្នេះ ឥឡូវនេះចូរស្ដាប់តាមលំដាប់លំដោយ អំពី(ករណីយកិច្ចជាច្រើន)របស់ពួកគេក្នុងពេលមានអាសន្ន។

---

**៣២៦.** ចំពោះ 'ការងារដែលវៃស្យអាចចិញ្ចឹមជីវិតបាន' សូមមើលជំពូក១០ លេខ៧៧-៧៨ ខាងក្រោម។

**៣៣៣.** 'បើវៃស្យអ្នកមាន គ្មានចិត្តសប្បុរស ព្រះរាជានឹងដាក់ទោសគេ'(មេធ.)។

**៣៣៤-៣៣៦.** សូមមើលជំពូក១០ លេខ១២១-១២៩ ខាងក្រោម។

**៣៣៥.** ខ្ញុំអានតាមលោកមេធ., គោវ. និងនារ. *ព្រាហ្មណាបាស្រយោ និត្យំ*។

# ជំពូក ១០

១- ចូរអ្នកទាំងបីដែលមានកំណើតពីរដងបំពេញករណីយកិច្ចរបស់ពួកគេ(តាមបញ្ញត្តិ)សិក្សា(ព្រះវេទ) ប៉ុន្តែក្នុងចំណោមពួកគេ មានតែព្រាហ្មណ៍ប៉ុណ្ណោះទើបអាចបង្រៀនព្រះវេទបាន មិនមែនវណ្ណៈពីរផ្សេងទេ នេះជាវិធានច្បាប់ដែលបានកំណត់ទុករួចហើយ។

២- ព្រាហ្មណ៍ត្រូវស្គាល់មធ្យោបាយចិញ្ចឹមជីវិតតាមការបញ្ញត្តិរបស់ច្បាប់ សម្រាប់អ្នកទាំងអស់គ្នា ទូន្មានដល់អ្នកដទៃទៀត ហើយខ្លួនឯងក៏ត្រូវរស់នៅស្របទៅតាម(ច្បាប់)ដែរ។

៣- បើនិយាយភាពខ្ពង់ខ្ពស់ជាងគេរបស់ខ្លួន បើនិយាយពីឧត្តមភាពនៃដើមកំណើតរបស់ខ្លួន បើនិយាយពីការគោរពវិធានច្បាប់ដ៏តឹងរ៉ឹង(ណាមួយ) ហើយបើនិយាយអំពីការសង្គ្រោះរបស់ខ្លួន ព្រាហ្មណ៍គឺជាម្ចាស់នៃវណ្ណៈទាំងអស់។

៤- វណ្ណៈព្រាហ្មណ៍ ក្សត្រិយ និងវៃស្យ ជាអ្នកមានកំណើតពីរដង ប៉ុន្តែវណ្ណៈទីបួន សូទ្រៈ មានកំណើតម្តងប៉ុណ្ណោះ ដូច្នេះគ្មានវណ្ណៈទីប្រាំទេ។

៥- នៅក្នុងគ្រប់វណ្ណៈទាំងអស់ (ក្មេង)ទាំងឡាយណា ដែលចាប់កំណើតផ្ទាល់ជាមួយនឹងភរិយាដែលរៀបការ (មានវណ្ណៈស្មើគ្នា និងបានរៀបការទាំងនៅ)ក្រមុំព្រហ្មចារី ត្រូវគេចាត់ទុកថាមានវណ្ណៈស្មើគ្នា(ដូចឪពុករបស់ខ្លួនដែរ)។

---

**ជំពូក១០ លេខ១.** លោកមេធ. បន្ថែមមួយបន្ទាត់ទៀតនៅក្នុងការចាប់ផ្តើម 'ចាប់ពីពេលនេះតទៅ ខ្ញុំសូមប្រកាសថា វិធានច្បាប់សម្រាប់អនុវត្តទាំងឡាយ គេត្រូវតែសិក្សាឱ្យចេះដឹង'។ តាមលោកនារ. សំនួនពាក្យ *ស្វកម៌ស្ថា:* 'បំពេញករណីយកិច្ចរបស់ខ្លួនតាមការបញ្ញត្តិ' មានន័យ 'ប្រសិនបើពួកគេដើរតាមគន្លងការងាររបស់ខ្លួនដូចបានបញ្ញត្តិមកនេះ' ហើយបញ្ជាក់ថា អ្នកទាំងឡាយដែលប្រកបការងារហោមឃាត់ គួយ៉ាង រស់នៅដូចពួកសូទ្រៈ មិនសិក្សាព្រះវេទ។ អ្នកអធិប្បាយនានា ភ្លេចនិយាយទាំងស្រុងត្រង់ចំណុចនេះ យោងតាមជំពូក២ លេខ២៤១-២៤២ ព្រាហ្មណ៍អាចសិក្សាព្រះវេទ ពីគ្រូដែលមិនមែនជាព្រាហ្មណ៍បាន ដូច្នេះហើយថា វិធានច្បាប់នេះមិនដាច់ខាតនោះទេ។

**២.** គោត. ជំពូក១១ លេខ២៥; វស. ជំពូក១ លេខ៣៩-៤១។ លោកមេធ.គូសបញ្ជាក់ថា វិធានច្បាប់នេះជាការលើកលែងចំពោះជំពូក៤ លេខ៨០ ដែលនិយាយថា ព្រាហ្មណ៍នឹងមិនផ្តល់ឱវាទផ្នែកព្រលឹងវិញ្ញាណដល់ពួកសូទ្រៈទេ។

**៣.** សូមមើលជំពូក១ លេខ៩៣ ខាងលើ។ 'បើនិយាយអំពីភាពខ្ពង់ខ្ពស់ជាងគេរបស់គាត់' គឺ 'តាមរយៈគុណសម្បត្តិរបស់គាត់'(មេធ.) ឬ 'តាមរយៈពូជអំបូរ'(គោវ., កុល្ល., នារ., រាឃ.)។ *និយមស្យ ច ធារណាត*បើនិយាយពីការគោរពរបស់គេតាមវិធានច្បាប់ដ៏តឹងរ៉ឹង(ណាមួយ)' គឺ 'តាមវិធានច្បាប់ដែលបានបញ្ញត្តិសម្រាប់ស្នាតកៈ'(មេធ., គោវ., នារ., រាឃ.) ហើយតាមលោកកុល្ល.គឺថា 'បើនិយាយពីខ្លួនមានពុទ្ធិវិសេសវិសាលនៃព្រះវេទ'។ 'បើនិយាយពីការសង្គ្រោះ ពិសេសរបស់ខ្លួន' គឺ 'ដោយសារការប្រតិបត្តិពិសេស សម្រាប់រូបគាត់ ក្នុងការក្រេបទឹកជាដើម ឬដោយសារគាត់ត្រូវតែធ្វើពិធីចូលជាសមាជិកថ្មី ឱ្យបានមុនពួកក្សត្រិយ'(មេធ.)។ អ្នកអធិប្បាយផ្សេងទៀត លើកឡើងតែការបកស្រាយទីពីរប៉ុណ្ណោះ។ ពាក្យ 'ម្ចាស់' គឺ 'ទីប្រឹក្សានិងអ្នកទូន្មាន'។

**៤.** អាប. ជំពូក១ លេខ១, ៣; វស. ជំពូក២ លេខ១-២; ពោធ. ជំពូក១ លេខ១៦, ១; យញ្ញ. ជំពូក១ លេខ១០។

**៥.** អាប. ជំពូក២ លេខ១៣, ១; វិ. ជំពូក១៦ លេខ១; យញ្ញ. ជំពូក១ លេខ៩០។ 'ដោយផ្ទាល់' គឺ 'ដោយព្រាហ្មណ៍ ជាមួយព្រាហ្មណី ដោយក្សត្រិយជាមួយក្សត្រិយាជាដើម'(មេធ., គោវ., កុល្លូ.) តាមលោកនារ.ថា ក្នុងករណីនីមួយៗកូនកំលោះត្រូវតែមានអាយុច្រើនជាងភរិយា។ លោកបន្ថែម 'ហេតុនេះគេបានប្រកាសថា កូនប្រុសរបស់ស្ត្រីដែលមានអាយុ

៦- កូនប្រុស ដែលចាប់កំណើតជាមួយបុរសមានកំណើតពីរដង ជាមួយភរិយាដែលមានវណ្ណៈ ទាបបន្ទាប់ ពួកគេប្រកាសថា ប្រហែលគ្នា(នឹងឪពុករបស់ខ្លួន ប៉ុន្តែ)បន្ទោសលើម្តាយរបស់ពួកគេ។

៧- នេះជាច្បាប់អមតៈស្តីពី(កូន)ដែលចាប់កំណើតនឹងភរិយាដែលមានវណ្ណៈទាប(ជាស្វាមីរបស់ខ្លួន) ចូរដឹង(ថា) វិធានច្បាប់តទៅនេះ (អាចអនុវត្តបាន) ចំពោះអ្នកមានកំណើតនឹងស្ត្រីដែលមានវណ្ណៈកម្រិតទាបទីពីរ ឬទីបី។

៨- ផ្តើមពីព្រាហ្មណ៍ជាមួយនឹងកូនស្រីរបស់វៃស្យ បង្កើតបាន (កូនប្រុសមួយ) ហៅថា*អំពស្ឋ* ជាមួយកូនស្រីរបស់សូទ្រៈ ហៅថា *និសាទ* ដែលគេអាចហៅ*បារសវ* ក៏បាន។

៩- ផ្តើមពីក្សត្រិយ និងកូនស្រីរបស់សូទ្រៈ បង្កើតកូន ហៅថា *ឧគ្រ* ដោយប្រដូចទាំងក្សត្រិយផង និងសូទ្រៈផង ដែលមានឥរិយាបថរបស់គេសាហាវ និងចូលចិត្តអំពើឃោរឃៅ។

១០- កូនរបស់ព្រាហ្មណ៍កើតជាមួយ(ស្ត្រី)វណ្ណៈទាបបីថ្នាក់ កូនរបស់ក្សត្រិយកើតជាមួយ(ភរិយា) វណ្ណៈទាបពីរថ្នាក់និងកូនរបស់វៃស្យកើតជាមួយ(ភរិយា)វណ្ណៈ(ទាបជាងគាត់)មួយថ្នាក់គេហៅកូនទាំងប្រាំមួយ ថាមានវណ្ណៈថោកទាប(អបសទ)។

១១- ផ្តើមពីក្សត្រិយជាមួយនឹងកូនស្ត្រីព្រាហ្មណ៍ បង្កើតបាន (កូនប្រុស ហៅ) តាមវណ្ណៈរបស់ខ្លួន (ជាតិ)សូត; ពីវៃស្យជាមួយនឹងស្ត្រីវណ្ណៈក្សត្រិយ និងព្រាហ្មណ៍ បង្កើតបាន*មាគធ* និង*វៃទេហ*។

១២- ផ្តើមពីសូទ្រៈ ជាមួយនឹងស្ត្រីវៃស្យ ក្សត្រិយនិងព្រាហ្មណ៍ កើតបាន*អាយោគវក្សត្រី* និង*ចាណ្ឌាល* មនុស្សវណ្ណៈទាបបំផុត (ជាកូនប្រុសដែលមានដើមកំណើត)ច្របូកច្របល់វណ្ណៈ។

---

ច្រើនជាង(ប្តីខ្លួន) មិនមែនជាព្រាហ្មណ៍ទេ ទោះបីជានាងបានរៀបការស្របច្បាប់ក៏ដោយ និងអាចមានវណ្ណៈដូចគ្នា(នឹងប្តីរបស់នាង)ក៏ដោយ'។ អ្នកអធិប្បាយទាំងឡាយ ខិតខំអះអាងយ៉ាងលំបាកថា កូនប្រុសបម្រុង ដូចជា*សហោធ, កានីន* ជាដើមនិងកូនទាំងអស់ដែលកើតពីការរួមរស់ដោយខុសច្បាប់ គឺជាមនុស្សក្រៅវណ្ណៈ។ លោកមេធ. និងគោវ. ក៏យកបញ្ហានេះ ធៀបនឹងសាច់រឿងព្រះវេទរបស់*ជាពាលា សត្យកាម* (ខាន្ទោគ្យ ឧប. ជំពូក៤ លេខ៤) អ្នកដែលត្រូវបានចាប់កំណើតមិនដឹងថាម្តាយខ្លួនមួយណា ហើយយ៉ាងណាមិញគេយល់ថាជាព្រាហ្មណ៍។ ពួកគេមានមតិថា *ជាពាលា* ត្រូវបានរៀបការដោយស្របច្បាប់ ហើយបានភ្លេចឈ្មោះត្រកូលរបស់ស្វាមីខ្លួន ក្នុងអំឡុងពេលរឹករបស់ខ្លួន។

**៦-៥៦.** គោត. ជំពូក៤ លេខ១៦-២៨; វស. ជំពូក១៨; ពោធ. ជំពូក១ លេខ១៦, ៦-១៧, ១៥; វិ. ជំពូក១៦ លេខ២-១៥; យញ្ញ. ជំពូក១ លេខ៩១-៩៥។

**៦.** 'បន្ទោស' គឺ 'មិនរាប់បញ្ចូលវណ្ណៈរបស់ឪពុកទេ'(នារ.)។ ចំពោះសំនួនពាក្យ 'ប្រហែលគ្នា' ធៀបនឹងពាក្យរបស់ពោធ. 'សវណ៌'។ លោកនន្ទ. ដាក់កាព្យលេខ១៤ បន្ទាប់ពីកាព្យនេះផ្ទាល់ ហើយបន្ថែមថា ប្រសិនបើកាព្យក្រោយ ត្រូវដាក់មកក្រោម គឺមានកំហុសដោយសារអ្នកចម្លង។

**៧.** ចំពោះពាក្យ *បារសវ* សូមមើលជំពូក៩ លេខ១៧៨ ខាងលើ។ លោកគោវ. និងនារ. សង្កេតឃើញថា ឈ្មោះទីពីរ *បារសវ* ត្រូវគេបន្ថែម ដើម្បីធ្វើឱ្យពាក្យ *និសាទ* ប្លែកពីនិសាទ ដែលជា*ប្រតិលោម* និងចិញ្ចឹមជីវិតដោយការនេសាទត្រី។

**៨.** មេធ. មិនបកស្រាយកាព្យនេះទេ។

**១២.** នារ. និង K. អាន *អយោគវ*។ លោកមេធ. និងនន្ទ. អាន*ចណ្ឌាល*ជំនួសពាក្យ *ចាណ្ឌាល* (គោវ., កុល្ល.)។

១៣- ព្រោះគេប្រកាសថា អំពស្ឋ និងឧគ្រ (ដែលចាប់កំណើត)ដោយផ្ទាល់នឹង(ស្រី)ដែលមានវណ្ណៈទាបជាង(ស្វាមីខ្លួន)មួយថ្នាក់ (ជា)ក្សត្រិ និងវៃទេហក ទោះជាពួកគេកើតក្នុងវណ្ណៈផ្ទុយគ្នា (ពីម្ដាយដែលមានវណ្ណៈខ្ពស់ជាងឪពុកមួយថ្នាក់)ក៏ដោយ។

១៤- កូនប្រុសដែលមានកំណើតពីរដង កើតជាមួយនឹងភរិយាក្នុងវណ្ណៈទាបជាងបន្ទាប់ ដែលត្រូវបានរៀបរាប់តាមលំដាប់លំដោយ គេហៅឈ្មោះ អនន្តរ (ដែលមានវណ្ណៈទាបជាងបន្ទាប់) ពោលគឺកំហុសស្ថិតលើម្ដាយរបស់ពួកគេ។

១៥- ព្រាហ្មណ៍ផ្ដល់កំណើតជាមួយកូនស្រីរបស់ឧគ្រ បាន*អាវ្ឫត* ជាមួយកូនស្រីរបស់អំពស្ឋ បាន*អាភីរ* ប៉ុន្តែជាមួយស្ត្រីវណ្ណៈអយោគវ បាន*ធិគ្វណ*។

១៦- កើតពីសូទ្រៈ ក្នុងលំដាប់ផ្ទុយ (ជាមួយស្ត្រីដែលមានវណ្ណៈខ្ពស់ជាង) (កូនប្រុស *អបសទ*) កំណើតថ្នាក់ទាបបី គឺ អាយោគវ ក្សត្រិ និងចាណ្ឌាល ជាមនុស្សថ្នាក់ទាបបំផុត,

១៧- កើតពីវៃស្យ ក្នុងលំដាប់វណ្ណៈផ្ទុយ កើតបានមាគធ និងវៃទេហ ប៉ុន្តែពីក្សត្រិយ បានសូតៈប៉ុណ្ណោះ កូនទាំងនេះជាកូនដែលមានកំណើតថ្នាក់ទាបបីផ្សេងទៀត(អបសទ)។

១៨- កូនប្រុសរបស់និសាទ ដែលកើតពីស្ត្រីសូទ្រៈ ក្លាយជាបុក្កសៈ តាមវណ្ណៈ(ជាតិ) ប៉ុន្តែកូនប្រុសរបស់សូទ្រៈ ដែលកើតពីស្ត្រីនិសាទ ត្រូវគេប្រកាសថា *កុក្កុតក*។

១៩- ជាងនេះទៅទៀត កូនប្រុសរបស់ក្សត្រិ ដែលកើតពីស្ត្រីឧគ្រ ហៅថា *ស្វបាក* ប៉ុន្តែកូនដែលកើតពីវៃទេហក ជាមួយស្ត្រីអំពស្ឋ មានឈ្មោះថា*វេណៈ*។

២០- (កូនប្រុស) ទាំងឡាយ ដែលអ្នកមានកំណើតពីរដងផ្ដល់កំណើតនឹងភរិយាដែលមានវណ្ណៈស្មើគ្នា ប៉ុន្តែដែលមិនបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន ត្រូវបានដេញចេញពីសាវិត្រី គេត្រូវតែកំណត់ជាមុនដោយសាមញ្ញថា *វ្រាត្យ*។

---

**១៣.** អត្ថន័យគឺថា ក្សត្រិ និងវៃទេហក ទោះជា*ប្រតិលោម* ក៏ដោយ ក៏មានជំហរដូចគ្នាចំពោះពិធីពិសិដ្ឋ ប៉ុន្តែមិនមែនចំពោះការសិក្សាជាដើម ហើយសមដូចជាពាក្យ*អនុលោម* ពីរ(មេធ.)។ លោកគោវ. និងកុល្ល. សរសេរតែចំណុចទីពីរ ស្ដីពីសមភាពប៉ុណ្ណោះ។

**១៤.** អត្ថន័យគឺថា គេចាត់ទុកពួកគេស្ថិតក្នុងវណ្ណៈរបស់ម្ដាយ និងទទួលការប្រសិទ្ធិស្របតាមច្បាប់ ដែលបានបញ្ញត្តិសម្រាប់វណ្ណៈរបស់ម្ដាយ(មេធ., គោវ., កុល្ល., នារ., នន្ទ.)។ សូមមើលកាព្យ៤១ ខាងក្រោម។

**១៥.** *អាភីរៈ* ជាពាក្យ*អហិរ* ទំនើប។

**១៦-១៧.** លោកកុល្ល. គិតថា ប្រតិលោម ត្រូវបានរៀបរាប់លើសពីម្ដង 'ដើម្បីបង្ហាញថា ពួកគេមិនសមនឹងបំពេញករណីយកិច្ចរបស់កូនប្រុស'។ នន្ទ. ដាក់កាព្យពីរនេះមុនកាព្យលេខ១៥។

**១៨.** លោកនន្ទ. អាន *បុល្កស*ជំនួសពាក្យ *បុក្កស*។

**១៩.** លោកគោវ., នន្ទ. និង K. អាន *វេនៈ* ជំនួសពាក្យ *វេណៈ*។ លោករាឃ. បន្ថែមថា ឈ្មោះទំនើប គឺ*ពរុឌ* ជាឈ្មោះរបស់វណ្ណៈអ្នកធ្វើកញ្ជើល្អី។

**២០.** លោកគោវ. និងនន្ទ. អានបន្ទាត់ទីមួយផ្នែកចុងក្រោយ *សុតាន* សម្រាប់ពាក្យ *តុ យាន* (មេធ., កុល្ល., K.) 'ដែលមិនបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន' គឺ 'ដោយមិនបានធ្វើពិធីចូលជាសមាជិកថ្មីតាមកាលដ៏គួរ'។ សូមមើលជំពូក២ លេខ ៣៩ ខាងលើ។ លោកមេធ. សរសេរពាក្យផ្សេង *អព្រតាះ*កូនប្រុសទាំងឡាយដែលបុរសភ្លេចករណីយកិច្ច ពិសិដ្ឋរបស់ខ្លួន

២១- ប៉ុន្តែពីវ្រាត្យនៃ(វណ្ណៈ)ព្រាហ្មណ៍ បង្កើតបាន*ភូជ្ជកន្ទកៈ*ដ៏កំណាច ជា*អាវន្ត្យ វាទធាន បុស្បធ* និង *សែខៈ*។

២២- ពីវ្រាត្យនៃ(វណ្ណៈ)ក្សត្រិយ បានយល្ល មល្ល លិច្ឆិវិ នទ ករណ ខស និងទ្រាវិឌ។

២៣- ពីវ្រាត្យនៃ(វណ្ណៈ)វៃស្យ បង្កើតបានសុធនវ៉ៃ អាចារយ ការុស វិជន្មន មៃត្រ និងសាត្វត។

២៤- ការបង្កើតកូនប្រុស(ដែលមានដើមកំណើតរបស់ខ្លួនផ្ទាល់) ដោយសារផិតក្បត់(របស់មនុស្ស) ដែលមានវណ្ណៈ(ផ្សេងគ្នា) ដោយការរៀបការជាមួយស្ត្រីដែលមិនគួរនឹងរៀបការ និងដោយការធ្វេសប្រហែសមិនបំពេញករណីយកិច្ច និងការងារ បង្កើតឱ្យមានភាពច្របូកច្របល់នៃវណ្ណៈ។

២៥- (ឥឡូវនេះ) ខ្ញុំនឹងរៀបរាប់ទាំងស្រុងអំពី(កូនប្រុស) ដែលមានដើមកំណើតច្រឡូកច្រឡំ ដែលកើតពីអនុលោមនិងប្រតិលោម ហេតុនេះទើបមានជាប់ទំនាក់ទំនងទៅវិញទៅមក។

២៦- សូត, វៃទេហក, ចណ្ឌាល ជាមនុស្សថ្នាក់ទាបបំផុត នៅមាគធៈ គេមាន(ជាតិ)វណ្ណៈក្សត្តិ និងអាយោគវ,

---

ជាដើម'។ ប៉ុន្តែលោកបដិសេធការបកស្រាយនេះ។

**២១.** ខ្ញុំអានតាមលោកមេធ., គោវ., នារ. និងK. *ត្រិជ្ជកណ្ឋក* ជំនួស *ភូជកណ្ឋក*(អត្ថបទបោះពុម្ព) ឬ *ភូត្យកណ្ឋក* (នន្ទ.)។ សូមមើលគោត. ជំពូក៤ លេខ២០ ផង ត្រង់ចំណុចដែលមានសរសេរទម្រង់ *ត្រិជ្យកណ្ឋ*។ ចំពោះពាក្យ *អាវន្ត្យ* (*អាបញ្ញា* លោកនន្ទ.) ព្រមទាំងសូមមើលពោធ. ជំពូក១ លេខ២, ១៣ ផង។ ជំនួសឱ្យ *វាទធាន* លោកនន្ទ.សរសេរ *វាទធាន* និងលោកK. ថា *វាឌឃាន* ដែលមានស្នាមកែប្រែ។ លោកមេធ. អាន (តាមសំណៅដៃ *បុស្បសៃខរៈ*) *បុស្បសេខរ* ជំនួស *បុស្បធះ សៃខ អេវ ច*។ លោកគោវ. សរសេរ *បុស្បះសៃខកស្តថា* នៅក្នុងបទអធិប្បាយគឺ *បុស្បវសៃសខ*។ លោក K. ថា *បុស្ប... ខរ តថា* ហើយលោកនន្ទ. ថា *បុស្បសីពក អេវ ច*។ ហាក់ដូចជាថា តាមលោកមេធ. និងនន្ទ. មានកុលសម្ព័ន្ធតែបួនប៉ុណ្ណោះ ដែលកើតពី*វ្រាត្យ ព្រាហ្មណ៍*។ ក៏ប៉ុន្តែទម្រង់ឈ្មោះខាងចុង នៅមានមន្ទិលសង្ស័យ។ អ្នកអធិប្បាយគិតថា អំបូរទាំងអស់ដែលបានរៀបរាប់ គឺជាអ្នកជំនាន់ក្រោយបន្តពីវ្រាត្យ ព្រាហ្មណ៍ និងស្ត្រីក្នុងវណ្ណៈផ្ទាល់របស់គាត់។ លោកគោវ. កត់សម្គាល់ថា តាមនីតិសាស្ត្ររបស់លោក ឧសន បានឱ្យដឹងថា ព្រិជ្ជកណ្ឋ រស់នៅដោយសាររបរអាបធ្មប់ ពួកអាវន្ត្យ និងវាទធាន ធ្វើការងារចម្បាំង ហើយពួកវ្រាត្យ ដទៃទៀតទាំងអស់ ធ្វើជាចារបុរស។ ទំនងជាអាចនិយាយ បានថា ឈ្មោះទាំងអស់នេះ សបញ្ជាក់ពីសញ្ញាណដើមកំណើត ប៉ុន្តែអាវន្ត្យ អ្នកស្រុកមាល្វាខាងលិច និងវាទធាន ដែលមានរៀបរាប់ឈ្មោះនៅក្នុងចំណោមកុលសម្ព័ន្ធភាគខាងជើង មានប្រភពតែនៅក្នុងស្នាដៃដទៃទៀតប៉ុណ្ណោះ។

**២២.** ខ្ញុំអានតាមលោកមេធ. និងគោវ. *លិច្ឆិវិ*ជំនួស *និច្ឆិវិ* (អត្ថបទបោះពុម្ព)។ លោក K. សរសេរ *លិខវិ* (*ខ* ជាពាក្យដែលមានស្នាមកែប្រែ) ហើយនន្ទ. សរសេរ *លិច្ឆិខិ*។ ព្រោះស្រៈ 'អ' និង 'ិ'នៅក្នុងអត្ថបទនេះ ត្រូវផ្លាស់ប្តូរគ្នាជាប្រចាំ គេអាចចាត់ទុក*លិច្ឆិវិ*មានទម្រង់ជំនួសពាក្យ*លិច្ឆវិ*ហើយយើងអាចសន្និដ្ឋានថា មនុសំហិតា បានគិតថាអំបូរក្សត្រិយនៃនគរមគធៈ និងនេប៉ាល់ដ៏ល្បីល្បាញ ជាមតិមិនត្រឹមត្រូវមួយ។ លោកគោវ. មានប្រសាសន៍ថា យោងតាមលោកឧសន គឺថា ពួក*នទ* និង*ករណ* ជាចារបុរស ហើយពួក*ខស*និង*ទ្រាវិឌ* ជាអ្នកដឹកជញ្ជូនទឹក និងអ្នកចែកចាយទឹកសម្រាប់ប្រើប្រាស់។

**២៣.** លោក K. អាន *ចារុស* និងលោកនន្ទ. អាន *ការុជ* ជំនួសពាក្យ *ការុស* (មេធ., គោវ., កុល្ល.)។ ជំនួសពាក្យ *វិជន្មំ* លោកនន្ទ. សរសេរ *និជង្ឃ*។ លោកគោវ. បញ្ជាក់ថា យោងតាមឧសន ពួក*អាចារ្យ* និង *សាត្វត* ចិញ្ចឹមជីវិតដោយសារការគោរពបូជាព្រះអាទិទេព ឬធ្វើជាអាចារ្យតាមព្រះវិហារ (*អាចារ្យសាត្វតៈ ទេវបូជនំ*)។

**២៥.** ពាក្យ 'អនុលោម' សូមមើលកាព្យលេខ៨ ខាងលើ។

២៧- (ប្រតិលោម)ទាំងប្រាំមួយនេះ បង្កើតអំបូរ(វណ្ណៈ)ដូចគ្នា ជាមួយនឹងស្ត្រីក្នុង(វណ្ណៈ)ផ្ទាល់របស់ខ្លួន ពួកគេ(ក៏)បង្កើត(វណ្ណៈដូចគ្នា)ជាមួយនឹងស្ត្រីដែលមាន(ជាតិ)វណ្ណៈរបស់ម្តាយខ្លួន និងជាមួយស្ត្រីដែលមានវណ្ណៈខ្ពស់ជាង។

២៨- ដូច(ព្រាហ្មណ៍)ផ្តល់កំណើតកូនប្រុសជាមួយ(ស្ត្រីដែលមាន)វណ្ណៈពីរ ក្រៅពី(វណ្ណៈអ្នកមានកំណើតពីរដងចំនួនបី) ដូចខ្លួនដែរ (ប៉ុន្តែអន់ជាងតាមវណ្ណៈទាបរបស់ម្តាយ) និង(វណ្ណៈស្មើនឹងខ្លួន)ជាមួយស្ត្រីវណ្ណៈស្មើនឹងគាត់នេះជាលំដាប់វណ្ណៈក្នុងករណីមិនរាប់បញ្ចូល(អំបូរវាហ្យ)។

២៩- ក្រុមទាំងប្រាំមួយ(ដូចបានរៀបរាប់ខាងលើ) ក៏ផ្តល់កំណើតកូនគួរឱ្យស្អប់ច្រើនប្រភេទ ជាមួយស្ត្រីវណ្ណៈផ្សេង ថែមទាំងមានបាបធ្ងន់ជាង (ឪពុក) របស់ខ្លួន ហើយត្រូវគេបណ្តេញចេញពី (សហគមន៍អារ្យ៉ន, វាហ្យ)។

៣០- ដូចជាសូទ្រៈផ្តល់កំណើតជាមួយស្ត្រីព្រាហ្មណ៍ ដែលត្រូវគេបណ្តេញ(ចេញពីសហគមន៍អារ្យ៉ន) ដូច្នេះ(កូននេះផ្ទាល់)ដែលត្រូវគេបណ្តេញចេញ បង្កើតកូនជាមួយ(ស្ត្រី)វណ្ណៈបួន សមនឹងគេបណ្តេញចេញ(ច្រើន)ជាងខ្លួនគាត់ទៅទៀត។

---

**២៧.** លោកនារ. និងនន្ទ. យល់ដូច្នេះ ដែលលោកកុល្ល. យល់ស្របតាម លើកលែងត្រង់ចំណុចដែលលោកបន្ថែម 'ជាមួយនឹងវណ្ណៈខ្ពស់ជាង និង(ទាបជាង)'។ លោកមេធ. អានបន្ទាត់ទីពីរ *មាត្រិជាត្យាះ ប្រសូយន្តេ ប្រវាសុ ច យោនិសុ* ហើយបកស្រាយថា 'អ្នកទាំងឡាយ ដែលស្ថិតក្នុងវណ្ណៈរបស់ម្តាយ គឺ អនុលោម ដែលគេហៅ អនន្តរ(កាព្យលេខ១៤) ផ្តល់កំណើតកូនប្រុសដូចគ្នា ជាមួយស្ត្រីក្នុងវណ្ណៈរបស់ខ្លួនផ្ទាល់ ហើយ(កូនដែលមានវណ្ណៈទាបជាងច្រើន) កើតជាមួយនឹងស្ត្រីដែលមានវណ្ណៈខ្ពស់ជាង'។ លោកមានប្រសាសន៍ថា អ្នកដទៃអាន *មត្រិជាតៅ ប្រសូយន្តេ* និងនិយាយថា អត្ថន័យគឺ 'អនុលោម ផ្តល់កំណើតកូនប្រុសនៃអំបូរផ្ទាល់របស់ខ្លួន ជាមួយស្ត្រីដែលមានវណ្ណៈផ្ទាល់របស់ខ្លួន និងរបស់ម្តាយខ្លួន'។ លោកគោវ. អាន *មាត្រិជាតៅ ស្វយោន្យាំ តុ សទ្រិសំ ជនយន្តិ វៃ* ហេតុនេះបន្ទាត់នេះសំដៅដល់អនុលោម។ 'ប៉ុន្តែ (អនុលោម) ផ្តល់កំណើតកូនប្រុសដូចគ្នាជាមួយស្ត្រីដែលមានវណ្ណៈផ្ទាល់របស់ខ្លួន និងតាមវណ្ណៈរបស់ម្តាយខ្លួន'។ លោករាឃ. អានផ្សេងទៅវិញ។

**២៨.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ ហើយលោក K. អាន *ក្រមះ* ជំនួស *ក្រមាត*(សំណៅបោះពុម្ព)។ 'ដូច្នេះ លំដាប់នេះ គឺជាករណីនៃ(អំបូរ)ដែលត្រូវគេបណ្តេញចេញ' តាមលោកគោវ. និងកុល្ល. មានន័យថា វណ្ណៈមានភាពផ្សេងគ្នារវាងប្រតិលោម ដូចជាលំដាប់ដែលមានរវាងអនុលោម និងប្រតិលោម ដែលកើតចេញពីឪពុកអារ្យ៉ន គួរឱ្យគេគោរពជាងអ្នកដែលកើតពីឪពុកសូទ្រៈ។ លោកគោវ., កុល្ល. និងរាឃ. ជំទាស់នឹងយោបល់របស់លោកមេធ. ដែលថា *ប្រតិលោម* ដែលកើតពីឪពុក និងម្តាយអារ្យ៉ន ត្រូវគេចាត់ទុកជាអារ្យ៉ន ហើយសមជាអ្នកដែលអាចចូលជាអនុលោមបាន។ តាមលោកនារ. និង នន្ទ. ការប្រែគួរតែថា 'ព្រោះក្នុងចំណោមវណ្ណៈបី (បុរស)បង្កើត(កូនប្រុសប្រហែលនឹង)ខ្លួនគាត់ ជាមួយនឹងភរិយាពីរនាក់ (ពោលគឺ)ជាមួយនារី ដែលស្ថិតក្នុងវណ្ណៈផ្ទាល់របស់គាត់ និងនារី ដែលស្ថិតក្នុង វណ្ណៈទាបជាងមួយថ្នាក់ ដូច្នេះនេះជាលំដាប់ដែលអ្នកត្រូវគេបណ្តេញចេញ(ពីវណ្ណៈសំខាន់បួន)' ពោលគឺ ដូចគ្នានឹងអនុលោមដែរ ឧទាហរណ៍ ជាមួយនឹងមូរធាវសិក្ត ដែលផ្តល់កំណើតមូរធាវសិក្ត ជាមួយស្ត្រីមូរធាវសិក្ត និងស្ត្រីអាវន្ស្យ(នារ.) ហើយជាមួយប្រតិលោម ឧទាហរណ៍ ជាមួយ ក្សត្តិ ដែលផ្តល់កំណើតក្សត្តិ ទាំងជាមួយស្ត្រីក្នុងវណ្ណៈរបស់ខ្លួនផ្ទាល់ និងជាមួយចណ្ឌាលី(នន្ទ.)។ គេត្រូវបញ្ជាក់បន្ថែមថា លោកនន្ទ.អាន *អនន្តរ្យាំ* ជំនួស *អានន្តរ្យាត*។

៣១- ប៉ុន្តែមនុស្សដែលត្រូវបណ្តេញចេញ (ដោយពួកអារ្យ័នវាហ្យ) ដែលចូលទៅរកស្ត្រីវណ្ណៈខ្ពស់ជាង បង្កើតកូន(វណ្ណៈ)មួយដែលសមនឹងគេបណ្តេញចេញដែរ មនុស្សថ្នាក់ក្រោម(ហីន)នៅតែមានវណ្ណៈទាប សូម្បីដល់ថ្នាក់ទីដប់ប្រាំក៏ដោយ។

៣២- ទស្យុ ជាមួយ(ស្ត្រី)អាយោគវ បង្កើតកូនសៃរន្ធ្រ ដែលមានជំនាញក្នុងការរៀបចំខ្លួន និងរៀនពី(គ្រូរបស់ខ្លួន) ដែល(ទោះបី)មិនមែនជាទាសករក៏ដោយ ក៏រស់នៅដូចជាទាសករ (ឬ)ចិញ្ចឹមជីវិតដោយដាក់អន្ទាក់(សត្វ)។

---

**៣១.** ដើម្បីបង្ហាញថា គេបង្កើតឱ្យមានវណ្ណៈថ្នាក់ក្រោមដប់ប្រាំ អ្នកអធិប្បាយលើកឡើងនូវការបកប្រែកាព្យនេះ តាមរបៀបផ្សេងៗ ក្នុងចំណោមនោះខ្ញុំលើកយកតែការបកស្រាយរបស់លោក កុល្ល., នារ. និងរាឃ. ប៉ុណ្ណោះ។ លោកកុល្ល. គិតថាពាក្យ *វាហ្យ* និង *ហីន* អាចសំដៅដល់ក្រុមមនុស្សពីរប្រភេទក៏បាន ឬក្រុមតែមួយក៏បាន។ តាមការសន្មតខាងដើម គេពិតជា យល់ថា *វាហ្យ*គឺជាកូនប្រតិលោមរបស់សូទ្រៈ ពោលគឺ អាយោគវ, ក្សត្ត្រិ និងចណ្ឌាល ហើយពាក្យ *ហីន* កូន ប្រតិ-លោមរបស់ក្សត្រិយ និងវៃស្យ គឺសូត, មាគធ និងវៃទេហ។ អំបូរមួយក្នុងចំណោមអំបូរទាំងពីរនេះ បង្កើតឱ្យមានវណ្ណៈថ្នាក់ក្រោមចំនួនដប់ប្រាំ ដោយការសម្ព័ន្ធជាមួយស្ត្រីក្នុងវណ្ណៈចម្បងបួន និងវណ្ណៈរបស់ខ្លួន(កាព្យ ២៧) ពោលគឺ *អាយោគវ* ផ្តល់កំណើតប្រាំ ជាមួយព្រាហ្មណ៍ ក្សត្រិយ វៃស្យ សូទ្រ និងស្ត្រីអាយោគ ហើយក្សត្ត្រិ ក៏មានប្រាំ ជាមួយព្រាហ្មណ៍ ក្សត្រិយ វៃស្យ សូទ្រៈ និងស្ត្រីក្សត្ត្រិ ជាដើម។ ប៉ុន្តែប្រសិនបើគេឱ្យន័យពាក្យពីរ វាហ្យ និង ហីន សំដៅដល់អំបូរបុរសមួយប្រភេទប៉ុណ្ណោះ គេប្រាកដជាយល់ន័យពាក្យនេះ សំដៅដល់ប្រតិលោមចំនួនប្រាំមួយ គឺ*ចណ្ឌាល, ក្សត្ត្រិ, អាយោគវ, វៃទេហ, មាគធ* និង *សូទ្រៈ*។ គេពិតជាសន្និដ្ឋានថា កាព្យនេះសំដៅដល់ការរួមសម្ព័ន្ធក្នុងចំណោមអំបូរ ប្រតិលោមទាំងប្រាំមួយនេះប៉ុណ្ណោះ។ ដូច្នេះវណ្ណៈទាបបំផុតក្នុងចំណោមពួកគេ គឺចណ្ឌាល អាចបង្កើតជាមួយស្ត្រី ដែលស្ថិតក្នុងកុលសម្ព័ន្ធប្រតិលោម ខ្ពស់ជាងចំនួនប្រាំ បានកូនវណ្ណៈទាបជាងប្រាំ ហើយក្សត្ត្រិ ជាមួយស្ត្រីវណ្ណៈបួនខ្ពស់ជាងខ្លួន បង្កើតបានវណ្ណៈបួន; អាយោគវ ជាមួយស្ត្រីវណ្ណៈបីលើខ្លួន បង្កើតបានវណ្ណៈបី; វៃទេហ បង្កើតវណ្ណៈពីរ និងមាគធ បង្កើតបានមួយ។ ហេតុនេះ សរុប៥+៤+៣+២+១ស្មើដប់ប្រាំ។ លោករាឃ.យល់ស្របតាមការបកស្រាយនេះ។ ចំណែកឯលោកនារ. ឱ្យន័យពាក្យ វាហ្យ និង ហីន ថាជាអំបូរបុរសមួយប្រភេទ គឺប្រតិលោមបី ដែលកើតចេញពីសូទ្រៈ ហើយសន្និដ្ឋានថា កាព្យនេះសំដៅដល់ការរួមសម្ព័ន្ធរបស់អ្នកទាំងបីជាមួយស្ត្រីក្នុងវណ្ណៈធំទាំងបួន និងក្នុងវណ្ណៈរបស់ខ្លួន។ យោងតាមការគណនាដែលមាននៅក្នុងការបកស្រាយដំបូងរបស់លោកកុល្ល. ចំនួនសរុបនៃវណ្ណៈថ្នាក់ក្រោមៗបន្តទៀត អាចមានដល់សាបសិប។ ចំពោះខ្ញុំ យល់ថា ការបកស្រាយទីពីររបស់លោកកុល្ល. គឺល្អជាងគេ ទោះបីខ្ញុំមិនបានធ្វើការប្រៀបធៀប ដើម្បីបដិសេធថា គេអាចការពារការបកស្រាយទីមួយរបស់គាត់ ព្រមទាំងបំណកស្រាយរបស់លោកនារ.ផង។ អ្នកអធិប្បាយគូសបញ្ជាក់ថា គេប្រើពាក្យ វណ្ណៈ នៅទីនេះ ក្នុងន័យធៀបប៉ុណ្ណោះ ព្រោះដូចបានប្រកាសខាងលើនៅក្នុងកាព្យលេខ៤ ថា វណ្ណៈធំៗពិតប្រាកដ មានតែបួនប៉ុណ្ណោះ។

**៣២.** ខ្ញុំអានតាមលោកមេធ., គោវ., នារ., នន្ទ. និង K. ថា *សៃរន្ធ្រ* ជំនួសពាក្យ *សៃរន្ធ្រិ* (សំណៅបោះពុម្ព)។ 'ទស្យុ' គឺជា 'អំបូរកុលសម្ព័ន្ធមួយ ក្នុងចំណោមកុលសម្ព័ន្ធទាំងអស់នេះ ដូចមានរៀបរាប់ក្នុងកាព្យលេខ ៤៥ខាងក្រោម'(មេធ., គោវ., កុល្ល.) ឬ 'អំបូរមួយក្នុងចំណោមអំបូរប្រតិលោមចំនួនដប់ប្រាំ ដូចបានរៀបរាប់ខាងលើ'(នារ., នន្ទ.)។ ប្រសាធនោប ចារញ្ញំ 'ដែលមានជំនាញក្នុងការរៀបចំខ្លួន និងរៀនសូត្រពី(គ្រូរបស់ខ្លួន)' គឺ 'ក្នុងការរៀបចំសក់ ការស្អិតស្អាង លាបប្រេងជាដើម និងក្នុងការកក់សក់'(គោវ., នារ., នន្ទ.) តាមលោកកុល្ល. ដែលប្រែ *ប្រសាធនោបចារៈ* មិនមែនជា សន្ទានកិរិយាស័ព្ទ ទេ ប៉ុន្តែជាពាក្យសមាស *តត្បុរុសៈ*ដែលមានជំនាញក្នុងការបម្រើ (គ្រូរបស់ខ្លួន) នៅពេលគាត់ចូលបង្គន់'។ ការបកស្រាយរបស់លោកមេធ. មិនច្បាស់លាស់ទេ។ ចំពោះមុខរបរទីពីររបស់គាត់ 'ការដើរដាក់អន្ទាក់សត្វ' លោកមេធ., គោវ. និងកុល្ល. និយាយថា *សៃរន្ធ្រ* ពឹងផ្អែកលើរបរនេះ ដើម្បីចិញ្ចឹមជីវិតក្នុងគ្រាអាសន្ន ឬ ដើម្បីបានសាច់ សម្រាប់ការបូជាអាទិទេពនិងវិញ្ញាណក្ខន្ធ ឬតាមព្រះរាជបញ្ជារបស់ព្រះរាជា។ លោកនន្ទ. កត់សម្គាល់ថា 'ព្រោះទស្យុមានច្រើន សៃរន្ធ្រក៏មានច្រើន ហើយមានបង្ហាញទម្រង់ចិញ្ចឹមជីវិតផ្សេងៗទៀត'។

៣៣- វៃទេហ (ជាមួយស្ត្រីដូចគ្នា)បង្កើតមៃត្រយក ដ៏មានសំឡេងពីរោះ ដែលគោះរគាំងនៅពេលព្រឹកព្រលឹម អធិដ្ឋានសរសើរជាប្រចាំដល់(មហា)បុរសទាំងឡាយ។

៣៤- និសាទ (ជាមួយស្ត្រីដូចគ្នា) ផ្តល់កំណើតមាគ៌វ (ឬ)ទាស ដែលចិញ្ចឹមជីវិតដោយការធ្វើទូក(ហើយ) ដែលអ្នកស្រុកអារយ្យវត៌ ហៅថា កៃវត៌។

៣៥- អ្នកដែលមានកំណើតទាបទាំងបី ត្រូវចាប់កំណើតនីមួយៗជាមួយនឹងស្ត្រីអាយោគវ ដែលស្លៀកពាក់សម្លៀកបំពាក់របស់សាកសព មានចរិតឃោរឃៅ និងស៊ីអាហារមិនគួរបើ។

៣៦- ពីនិសាទ (ជាមួយស្ត្រីវណ្ណៈវៃទេហ) បង្កើតបាន*ការាវរ* ដែលធ្វើការផ្នែកស្បែក ហើយពីវៃទេហក (ជាមួយស្ត្រីវណ្ណៈការាវរ និងនិសាទ) បានអន្ទ្រ និងមេទ ដែលរស់នៅខាងក្រៅភូមិ។

៣៧- ពីចណ្ឌាល ជាមួយស្ត្រីវៃទេហ បង្កើតបាន*បាណ្ឌុសោបាក* ដែលរកស៊ីជាំអំពៅ ហើយពីនិសាទ (ជាមួយស្ត្រីដដែល) បាន*អាហិណ្ឌិក*។

៣៨- ប៉ុន្តែពីចណ្ឌាល ជាមួយស្ត្រីបុក្កស បង្កើតបាន*សោបាក* ដ៏មានបាប ដែលចិញ្ចឹមជីវិតដោយបន្តមុខរបរពីឪពុករបស់ខ្លួន ហើយត្រូវមនុស្សល្អស្អប់ខ្ពើមជានិច្ច។

៣៩- ស្ត្រីនិសាទជាមួយបុរសចណ្ឌាល បង្កើតបានកូនប្រុស(ហៅថា)*អន្ត្យាវសាយិន* ដែលធ្វើការនៅកន្លែងកប់ខ្មោច ហើយត្រូវពួកអ្នកដែលអារ្យ៉ុនដេញចេញ(ពីសហគមន៍អារ្យ៉ុន) ស្អប់ខ្ពើម។

៤០- អំបូរទាំងអស់ (ដែលមានកំណើត)ដោយច្របូកច្របល់(វណ្ណៈ និង) ត្រូវបានពិពណ៌នា ស្របទៅតាមឪពុកនិងម្តាយរបស់ពួកគេ អាចត្រូវគេស្គាល់ដោយសារមុខរបររបស់ពួកគេ ទោះជាពួកគេបិទបាំង ឬបង្ហាញដោយចំហដោយខ្លួនឯងក៏ដោយ។

---

**៣៤.** លោកគោវ. និង K. អាន *មាគធ* ជំនួស*មាគ៌វ*។ លោកគោវ. គិតថា ផ្នែកនេះបរិយាយពីប្រតិលោម ពាក្យ*និសាទ* នៅទីនេះ ជាប្រតិលោមនីសាទ ដែលលោកវ្យាស បានរៀបរាប់។

**៣៥.** ខ្ញុំយកតាមការអំណានរបស់លោកមេធ., គោវ., នារ., នន្ទ. និង K. ដែលអាន *ម្ឫតចស្រ្តក្ឫត្ស នាស្យាសុ*ដែលពាក់សម្លៀកបំពាក់របស់សាកសព មានចរិតឃោរឃៅ' ជំនួស *ម្ឫតវស្ត្រភ្ឫត្សុ នារីសុ*ស្ត្រី ដែលពាក់សម្លៀកបំពាក់របស់សាកសព'(សំណៅបោះពុម្ព)។ លោកកុល្លូ. ហាក់ដូចជាយកតាមអំណានខាងដើម ព្រោះគាត់ចម្លងតាមការបកស្រាយ *សុក្រូរាសុ* ឃោរឃៅខ្លាំង' តាមការបកស្រាយរបស់លោកគោវ.។ លោកមេធ. បកស្រាយ *អនាហ្យាសុ* 'ដែលពួកអារ្យ៉ុនមិនអាចប៉ះពាល់បាន'។

**៣៦.** តាមលោកមេធ. និងកុល្លូ. គឺក្នុងន័យដូច្នេះ។ ប៉ុន្តែលោកគោវ. និងរាឃ. យល់ន័យបន្ទាត់ទីពីរ 'ពីវៃទេហក' គឺ 'កើតពីស្ត្រីវណ្ណៈវៃទេហ'។ លោកនារ. ដែលនៅក្នុងកាព្យខាងដើម ប្រែពាក្យ *អេតេ ត្រយះ*អំបូរទាំងបីនោះ' ក្នុងន័យថា 'អំបូរបីបន្ទាប់ទៀត' ការពិតសន្មតថា ម្តាយរបស់ការាវរ, មេទ និងអន្ទ្រ គឺជាស្ត្រីអាយោគវ។ 'វណ្ណៈពីរក្រោយនេះ ជាប្រជាជាតិដ៏មានឈ្មោះល្បី ដែលរស់នៅតំបន់មេវាទ (មេទបាទ) នៅរាជបុតានភាគអាគ្នេយ៍ និងតំបន់ដេកកង់ ភាគខាងកើត។

**៣៨.** លោករាឃ. និងនន្ទ. អាន *ប៉ៅល្កស* ជំនួស *បុក្កស*។ មូលវ្យុសនវត្តិមាន តាមលោកគោវ., កុល្លូ., និងរាឃ. មានន័យថា 'ដែលចិញ្ចឹមជីវិតដោយការសម្លាប់ឧក្រិដ្ឋជន' ហើយតាមលោកនារ. និងនន្ទ. 'ដែលចិញ្ចឹមជីវិតដោយការដើរជីកមើមឈើ' គឺ 'ដើម្បីលក់វាធ្វើជាឱសថ' ឬ 'ដោយការព្យាបាលឫសដូចបាត'(នន្ទ.)។ លោកមេធ. លើកឡើងនូវការបកស្រាយទាំងពីរនេះ។ ការបកប្រែខាងលើ យកតាមទស្សនាវដ្តី Petersburg ។

៤១- កូនប្រុសប្រាំមួយ ដែលកើតពី (អារ្យ៉ន) ជាមួយស្ត្រីវណ្ណៈស្មើគ្នា និងវណ្ណៈទាបជាងបន្ទាប់ (អនន្តរ) ទទួលករណីយកិច្ចរបស់អ្នកមានកំណើតពីរដង ប៉ុន្តែអ្នកទាំងអស់ ដោយសារការបំពាន (ច្បាប់) គឺស្មើនឹងពួកសូទ្រៈ បើនិយាយពីករណីយកិច្ចរបស់ពួកគេ។

៤២- ដោយសារអំណាចនៃការធ្វើតបៈ និងគ្រាប់ពូជ (ដែលពួកគេបានចាប់កំណើត) (អំបូរ) ទាំងអស់នេះទទួលបាននៅជាតិនេះ ជាមនុស្សដែលមានឋានៈទាប ឬខ្ពស់ តាមជាតិកំណើតបន្តបន្ទាប់។

៤៣- ប៉ុន្តែដោយសារការមិនធ្វើពិធីពិសិដ្ឋ និងមិនពិគ្រោះយោបល់ជាមួយព្រាហ្មណ៍ កុលសម្ព័ន្ធបន្ទាប់ពីក្សត្រិយ បានធ្លាក់ចុះបន្តិចម្តងៗនៅក្នុងលោកិយនេះ រហូតដល់ឋានៈស្មើនឹងសូទ្រៈ។

៤៤- (គឺ)បៅល្ឌ្រស, ចោឌ, ទ្រវិឌ, កាម្ពោជ, យវន, សក, ប្រារទ, បហ្លវ, ចីន, កិរាត និង ទរទ។

៤៥- កុលសម្ព័ន្ធទាំងអស់នៅក្នុងពិភពលោកនេះ ដែលត្រូវគេបណ្តេញចេញពី(សហគមន៍)ចំពោះមនុស្សទាំងឡាយដែលកើតចេញពីព្រះឱស្ឋ ព្រះហស្ត ព្រះឱរូ និងព្រះបាទ (របស់ព្រះព្រហ្ម) ហៅថា *ទស្យុ* ទោះបីពួកគេនិយាយភាសា*ម្លេច្ឆ* (មនុស្សព្រៃ) ឬភាសារបស់អារ្យ៉នក៏ដោយ។

៤៦- អ្នកទាំងឡាយ ដែលត្រូវបានរៀបរាប់ថាជា(កូន *អបសទ*) របស់អារ្យ៉នដែលមានកំណើតឋានៈទាប ដោយសារការបំពាន(ច្បាប់ *អបធ្វំសជ*)នឹងចិញ្ចឹមជីវិតដោយមុខរបរដែលអ្នកមានកំណើតពីរដងបានរិះគន់។

---

**៤១.** មេធ. បន្ថែម 'ការនិយាយពីអនន្តរ សំដៅរាប់បញ្ចូលនូវអនុលោមទាំងអស់'។

**៤២.** 'ទាំងនេះ' គឺ 'អ្នកដែលកើតពីភរិយាវណ្ណៈស្មើគ្នា និងអនន្តរ'(គោវ., កុល្ល.)។ លោកមេធ. និងនារ. រាប់បញ្ចូលអនុលោមទាំងអស់ ហើយលោករាឃ.ថែមទាំងប្រតិលោម ដែលកើតពីឪពុកអារ្យ៉នផង។ យុគេ យុគេ 'នៅក្នុងជាតិកំណើតបន្តបន្ទាប់'(មេធ., នារ., នន្ទ.) ហើយតាមលោកកុល្ល. គឺ 'ក្នុងមួយសម័យកាលនៃពិភពលោក'។ លោកកុល្ល. ឱ្យន័យសាច់រឿងស្តីពី*វិស្វាមិត្រ* និង *ឫស្យស្រឹង្គ* ចំណែកឯលោកមេធ. សំដៅដល់ការពិភាក្សា ដូចមានក្នុងកាព្យ៦៤ ខាងក្រោម។

**៤៣.** មេធ. និងគោវ. អាន *ព្រាហ្មណាតិក្រមេណ* 'ដោយមិនគោរពចំពោះព្រាហ្មណ៍' ជំនួស *ព្រាហ្មណាទរសនេន* 'ដោយមិនពិគ្រោះយោបល់ជាមួយព្រាហ្មណ៍'(កុល្ល., នារ., នន្ទ., រាឃ., K.)។

**៤៤.** ជំនួស*បោល្ឌ្រស* (កុល្ល.) លោកមេធ., នារ., នន្ទ. និង K. អាន *បុណ្ឌ្រក* និងលោកគោវ. ថា *បៅណ្ឌ្រក*។ អំណានរបស់ខ្ញុំ *ចោឌ* ជាការកែពាក្យ *ចោមទ្រ* ដែលមាននៅក្នុងសំណៅដៃមួយចំនួនរបស់លោកមេធ. និងក្នុង K. ។ យើងឃើញមានពាក្យ *ចោល* យ៉ាងច្បាស់ នៅក្នុងស្នាដៃរបស់នន្ទ. ចំណែកឯសំណៅដៃខ្លះរបស់លោកមេធ. និង គោវ. អាន *ចាំដ្រ* ឬ *ចាំទ្រ* ហើយសំណៅបោះពុម្ពសរសេរ *ចៅឌ្រ*។ តាមយោបល់របស់ Sir W. Jones ថា ពាក្យ *ចៅឌ្រ* ជំនួសឱ្យ *ច ឱឌ្រ* គឺមិនសមទំនងទេ ព្រោះបរិវាស័ព្ទ 'និង' ជាពាក្យមិនចាំបាច់សម្រាប់បន្ទាប់ពីពាក្យទីមួយ។ ជំនួសពាក្យ *បហ្លវ* សំណៅដៃមួយចំនួនរបស់លោកមេធ. និងសំណៅបោះពុម្ពមួយចំនួនអាន *បហ្នវ* ។ លោកគោវ. សរសេរ *បល្លវ*។ សំណៅបោះពុម្ពសរសេរ *ខស* បន្ទាប់ពី *ទរទ*។ ប៉ុន្តែលោកមេធ., គោវ., នន្ទ. និង K. សរសេរ *តថា* នៅខាងចុងកាព្យ។ អ្នកអធិប្បាយនានាអះ អាងថា ឈ្មោះដែលរៀបរាប់នៅក្នុងតួយ៉ាងទីមួយ សម្គាល់ឈ្មោះប្រទេស ហើយបន្ទាប់មកសំដៅដល់អំបូរដែលរស់នៅក្នុងប្រទេសទាំងនោះ។

**៤៥.** 'អ្នកទាំងឡាយ ដែលកើតពីព្រះឱស្ឋ ជាដើម' ពោលគឺ សូមមើលវណ្ណៈទាំងបួន ក្នុងជំពូក១ កាព្យ៨៧ ខាងលើ។

**៤៦.** 'កូនរបស់អារ្យ៉ន ដែលមានកំណើតឋានៈទាប' សូមមើលកាព្យ ១៧ និង៤១ ខាងលើ ។

៤៧- ចំពោះសូតៈ (ទទួលការ)គ្រប់គ្រងសេះ និងរទេះចម្បាំង ចំពោះអម្ពស្ឋ ចេះផ្នែកសិល្បៈ សម្រុះសម្រួល ចំពោះវៃទេហក ចេះផ្នែកបម្រើស្ត្រី ចំពោះមាគធ ចេះការងារធ្វើជំនួញ;

៤៨- និសាទធ្វើការងារសម្លាប់ត្រី, អាយោគវធ្វើការងាររបស់ជាងឈើ, មេទ អន្ធ្រ ចុញ្ចុ និង មទ្គុ ជាអ្នកសម្លាប់សត្វព្រៃ;

៤៩- ចំពោះក្សត្តិ ឧគ្រ និងបុក្កស ចេះចាប់និងសម្លាប់(សត្វ)ដែលរស់នៅក្នុងរន្ធ ចំពោះធិគ្វណ ធ្វើរោមសត្វ ចំពោះវេន ដើរលេងវាយស្គរ។

៥០- នៅក្បែរដើមឈើល្បីឈ្មោះ និងកន្លែងកប់ខ្មោច នៅលើភ្នំនិងនៅក្នុងគុម្ពឈើ ចូរ(អំបូរមនុស្ស)ទាំងអស់នេះ ពឹងអាស្រ័យដោយចេះមើល(សញ្ញាមួយចំនួន) និងចិញ្ចឹមជីវិតដោយមុខរបរពិសេសសម្រាប់ខ្លួន។

៥១- ប៉ុន្តែការស្នាក់អាស្រ័យរបស់ចណ្ឌាល និងស្វបច នឹងនៅក្រៅភូមិ ពួកគេត្រូវតែធ្វើជា*អបបាត្រ* ហើយទ្រព្យរបស់ពួកគេ (គួរតែជា)សត្វឆ្កែ និងលា។

៥២- ការស្លៀកពាក់របស់ពួកគេ (គួរតែជា) សម្លៀកបំពាក់របស់សាកសព (ពួកគេនឹងទទួលទាន) អាហាររបស់ខ្លួនពីចានកំបែក ដែកខ្មៅ (គឺជា) គ្រឿងអលង្ការរបស់ពួកគេ ហើយពួកគេត្រូវតែដើរត្រាច់ចរពីកន្លែងមួយទៅកន្លែងមួយជានិច្ច។

៥៣- បុរសដែលបំពេញករណីយកិច្ចសាសនា នឹងស្វែងរកការរួមសង្វាសជាមួយពួកគេ ប្រតិបត្តិការរបស់ពួកគេ(គួរស្ថិត)ក្នុងចំណោមពួកគេ ហើយការរៀបអាពាហ៍ពិពាហ៍ជាមួយវណ្ណៈស្មើគ្នា។

៥៤- អាហាររបស់ពួកគេ គួរតែបានពីអ្នកដទៃ (មិនមែនពួកអារ្យ័ន) ឱ្យពួកគេក្នុងចានកំបែក ហើយពេលរាត្រី ពួកគេមិនត្រូវដើររហេតរហូតក្នុងភូមិ ស្រុកទេ។

---

**៤៧.** 'ការបម្រើស្ត្រី' គឺ 'ការិយាល័យគ្រប់គ្រងបន្ទប់ស្រីស្នំ'។

**៤៨.** ជំនួសពាក្យ *ចុញ្ចុ* (សំណៅបោះពុម្ព រាឃ.) លោកមេធ., គោវ. និងនារ. ទំនងជាអានថា *ចូចុ* ។ លោកនន្ទ. អាន *មំសុ* សម្រាប់ពាក្យ *មទ្គុ* ។ លោកនារ. និយាយថា ពាក្យទាំងពីរជាពាក្យវេវចនស័ព្ទនៃពាក្យ *យល្ល* និង *មល្ល* សូមមើលកាព្យ ២២ ខាងលើ។ ប៉ុន្តែលោកគោវ. ដកស្រង់កាព្យរបស់យម ដែលថា *ចូចុក* គឺជាកូនប្រុសរបស់វៃស្យ ជាមួយនឹងស្ត្រីក្សត្រិយា ហើយ*មទ្គុ* ជាកូនរបស់សូទ្រៈ និងស្ត្រីក្សត្រិយា។ សេចក្តីយោងរបស់លោកកុល្ល. និងរាឃ. ចំពោះស្នាដៃពោធ. គឺសំដៅដល់សំណៅដៃរបស់លោកពោធ. *ធម៌សូត្រ* ដែលមានការកែន្ដច្រឡំ។

**៤៩.** នន្ទ. លុបកាព្យនេះចោល។

**៥០.** នន្ទ. ដាក់កាព្យ លេខ៥០ បន្ទាប់ពីកាព្យ លេខ៥២។

**៥១.** មេធ. និងនារ. អាន *អវបាត្រាះ* ជំនួសពាក្យ *អបាបាត្រាះ* (កុល្ល., រាឃ., K. និងគោវ?) ហើយលោកមេធ. ធ្វើការបកស្រាយបីយ៉ាងចំពោះពាក្យនេះ គឺ ១-ភាជន៍ដែលពួកគេប្រើហើយ ត្រូវតែបោះចោល ២-ប្រសិនបើអាហារ ត្រូវគេឱ្យទៅពួកគេ គេមិនត្រូវដាក់អាហារនោះនៅក្នុងភាជន៍ដែលនៅក្នុងដៃរបស់ពួកគេទេ ប៉ុន្តែដាក់ក្នុងភាជន៍នៅលើដី ឬនៅក្នុងដៃអ្នកដទៃ ៣-ពួកគេត្រូវប្រើភាជន៍ខូច គឺភាជន៍បែក ដូចមាននិយាយនៅក្នុងកាព្យបន្ទាប់។ អ្នកអធិប្បាយផ្សេងទៀតសម្រេចយកការបកស្រាយទីមួយ ដែលជាការបកស្រាយត្រឹមត្រូវដោយគ្មានមន្ទិល។

**៥៣.** គោវ. និងនន្ទ. និយាយថា 'មនុស្សត្រឹមត្រូវ' ជំនួយឱ្យ 'មនុស្សដែលបំពេញករណីយកិច្ចសាសនា'។

**៥៤.** គោវ. និងនារ. ប្រែសេចក្តីផ្តើមកាព្យនេះផ្សេងទៅវិញថា 'អាហាររបស់ពួកគេ ត្រូវអ្នកផ្សេងឱ្យទៅពួកគេក្នុងភាជន៍បែក' គឺ 'ពួកគេមិនចំអិនអាហារសម្រាប់ខ្លួនឯង នៅក្នុងផ្ទះរបស់ខ្លួនទេ'។

៥៥- ពេលថ្ងៃពួកគេអាចដើររកការងារធ្វើ ដែលមានការសម្គាល់ពិសេសតាមព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ ហើយពួកគេនឹងសែងសាកសព(របស់មនុស្ស)ដែលគ្មានញាតិសន្តាន នេះជាវិធានច្បាប់ដែលបានបញ្ញត្តិទុកយ៉ាងនេះ។

៥៦- តាមបញ្ជារបស់ព្រះរាជា ពួកគេតែងតែប្រហារជីវិតឧក្រិដ្ឋជនស្របតាមច្បាប់ ហើយពួកគេនឹងយកសម្លៀកបំពាក់ គ្រែ និងអលង្ការ(របស់ឧក្រិដ្ឋជននោះ)មកធ្វើជារបស់ខ្លួន។

៥៧- មនុស្សដែលមានដើមកំណើតមិនបរិសុទ្ធ ដែលមិនស្ថិតក្នុងវណ្ណៈណាមួយ (ប៉ុន្តែដែលគេ) មិនស្គាល់ ដែល(ទោះជា)មិនមែនជាអារ្យ៉ែនក៏ដោយ ក៏មានលក្ខណៈខាងក្រៅជាអារ្យ៉ែន គេអាចដឹងបានដោយសារអំពើរបស់អ្នកនោះ។

៥៨- ឥរិយាបថមិនសមគួររបស់អារ្យ៉ែន ភាពឃោរឃៅ និងទម្លាប់ធ្វេសប្រហែសចំពោះករណីយកិច្ចដូចបានរៀបរាប់ បង្ហាញនូវសារជាតិដើមមិនបរិសុទ្ធរបស់មនុស្សនៅក្នុងលោកិយនេះ។

៥៩- មនុស្សដែលមានកំណើតឋានៈទាប ប្រៀបដូចលក្ខណៈរបស់ឪពុកឬម្តាយខ្លួន ឬទាំងពីរ គេមិនអាចបិទបាំងធម្មជាតិពិតរបស់ខ្លួនបានទេ។

៦០- សូម្បីបើមនុស្សដែលចាប់កំណើតក្នុងមហាគ្រួសារបានកើតពីការរួមសង្វាសខុសច្បាប់គេ ប្រាកដជាមានចំណែកកំហុសរបស់(ឪពុក)ខ្លួន ទោះជាពួកគេមានគ្រួសារតូច ឬធំក៏ដោយ។

៦១- ប៉ុន្តែអាណាចក្រដែលជាកន្លែងចាប់កំណើតរបស់កូនឥតខាន់ស្លា ដែលធ្វើឱ្យខូច (ភាពបរិសុទ្ធនៃ) វណ្ណៈ នឹងវិនាសទាំងអស់គ្នាជាមួយនឹងអ្នកស្រុករបស់ខ្លួនយ៉ាងឆាប់រហ័ស។

៦២- ដំណើរចាកលោកដោយមិនរំពឹងបានរង្វាន់ សម្រាប់ព្រាហ្មណ៍និងមេគោ ឬក្នុងការការពារស្ត្រី និងកុមារ ជានាបាននូវសុភមង្គលចំពោះអ្នកទាំងឡាយដែល(ពួកអារ្យ៉ែន)បណ្តេញចេញពីសហ-គមន៍ (វាហ្យ)។

៦៣- ការមិនបង្ករបួសស្នាមដល់(សត្វលោក) កាន់សច្ចធម៌ទៀងត្រង់ មិនយក(របស់ទ្រព្យអ្នកដទៃ) ដោយខុសច្បាប់ កាន់ភាពបរិសុទ្ធ និងគ្រប់គ្រងឥន្ទ្រីយ៍ខ្លួនបាន ព្រះមនុបានប្រកាសថា នេះជាសេចក្តីសង្ខេបអំពីច្បាប់សម្រាប់វណ្ណៈទាំងបួន។

៦៤- ប្រសិនបើ(ស្ត្រីនៃវណ្ណៈមួយ) បានកើតពីព្រាហ្មណ៍និងស្ត្រីសូទ្រៈ មាន(កូន)ជាមួយនឹងបុរសវណ្ណៈខ្ពស់បំផុត (អំបូរ)ថ្នាក់ទាបទទួលបានវណ្ណៈថ្នាក់ខ្ពស់បំផុតនៅក្នុងជំនាន់ទីប្រាំពីរ។

---

**៥៥.** 'ដោយមានសញ្ញាសម្គាល់ពិសេស'គឺ 'មានសញ្ញារន្ទះជាដើម ឬសញ្ញាពូថៅ ភឹង ជាដើម ដែលគេប្រើសម្រាប់សម្លាប់ឧក្រិដ្ឋជន និងលីដាក់លើស្មា'(មេធ.) ឬ 'ដោយសញ្ញាដំបងជាដើម'(គោវ.) ឬ 'ដោយអលង្ការដែក និងរោមក្ងោកជាដើម' (នារ.)។ លោករាឃ. គិតថា សញ្ញាទាំងនោះត្រូវគេបោះនៅលើថ្ងាស និងនៅលើខ្នង។ កាលពីបុរាណយូរលង់ អំបូរគុជរដែលចុះទន់ខ្សោយ ធ្លាប់ពាក់ស្នែងធ្វើជាសញ្ញាសម្គាល់ពិសេសរបស់ខ្លួន។

**៥៧-៥៩.** វស. ជំពូក១៨ លេខ៧; វិ. ជំពូក១៦ លេខ១៧។

**៦២.** វិ. ជំពូក១៦ លេខ១៨។

**៦៣.** គោត. ជំពូក៨ លេខ២៣; យញ្ញ. ជំពូក១ លេខ១២២ និងសូមមើលជំពូក៤ លេខ២៤៦, ជំពូក៥ លេខ១០៧។ នន្ទ. អាន*សាវណោ*សម្រាប់វណ្ណៈទាំងអស់' ជំនួសពាក្យ *ចាតុវណ្ណោ*សម្រាប់វណ្ណៈបួន'។

**៦៤.** អាប. ជំពូក២ លេខ១០-១១; គោត. ជំពូក៤ លេខ២២; យញ្ញ. ជំពូក១ លេខ៩៦។តាមលោកមេធ., គោវ., កុល្លូ.

៦៥- (ហេតុនេះ)សូទ្រៈទទួលបានឋានៈជាព្រាហ្មណ៍ ហើយ (តាមរបៀបដូចគ្នានេះ) ព្រាហ្មណ៍អាចធ្លាក់ដល់កម្រិតជាសូទ្រៈ ប៉ុន្តែចូរដឹងថា កូនរបស់ក្សត្រិយ ឬរបស់វៃស្យ ក៏ដូចគ្នាដែរ។

៦៦- ប្រសិនបើ(មានមន្ទិល) សង្ស័យកើតឡើងថា តើភាពខ្ពង់ខ្ពស់កើតឡើងដោយឪពុកជាអារ្យ័នផ្តល់កំណើតដោយចៃដន្យជាមួយស្ត្រីដែលមិនមែនជាអារ្យ័ន ឬការសង្ស័យចំពោះ (កូនប្រុស) របស់ស្ត្រីព្រាហ្មណ៍ជាមួយបុរសមិនមែនជាអារ្យ័ន,

៦៧- ការសម្រេចត្រូវកំណត់ថាៈ ៉អ្នកដែលចាប់កំណើតពីអារ្យ័នជាមួយស្ត្រីមិនមែនជាអារ្យ័នអាចក្លាយ(ទៅជា)អារ្យ័ន ដោយសារគុណធម៌របស់ខ្លួន អ្នកដែលមាន(ម្តាយ)អារ្យ័ន មានផ្ទៃពោះជាមួយឪពុកមិនមែនជាអារ្យ័ន (គឺនៅតែ)មិនមែនជាអារ្យ័ន៉។

---

និងរាឃ. អត្ថន័យគឺថា ប្រសិនបើកូនស្រីរបស់ព្រាហ្មណ៍ និងស្ត្រីសូទ្រៈ និងអ្នកជំនាន់ក្រោយរបស់នាង សុទ្ធតែបានរៀបការជាមួយព្រាហ្មណ៍ កូនរបស់ស្ត្រីជំនាន់ក្រោយទីប្រាំមួយបន្តពីគូស្វាមីភរិយាដើម នឹងក្លាយជាព្រាហ្មណ៍។ ចំពោះការបកស្រាយនេះស្របគ្នានឹងមតិរបស់ហរទត្ត ក្នុងសេចក្តីស្របគ្នារបស់គោតម តែលោកនារ. និងនន្ទ.ប្រែកាព្យនេះក្នុងន័យផ្សេងទៅវិញ។ ពួកគាត់និយាយថា ប្រសិនបើ*បារសវ* កូនប្រុសរបស់ព្រាហ្មណ៍ និងស្ត្រីសូទ្រៈ រៀបការជាមួយស្ត្រីបារសវ ដ៏ឧត្តុង្គឧត្តមបំផុត ដែលមានចរិតលក្ខណៈចិត្តគំនិតល្អ និងគុណធម៌ផ្សេងទៀត ហើយប្រសិនបើអ្នកជំនាន់ក្រោយរបស់គាត់ធ្វើដូច្នេះដែរ កូនដែលកើតក្នុងជំនាន់ទីប្រាំមួយ នឹងក្លាយជាព្រាហ្មណ៍។ លោកនន្ទ. ដកស្រង់សម្តីដើម្បីគាំទ្រយោបល់របស់គាត់ ពីពោធាយន ជំពូក១ លេខ១៦, ១៣-១៤ (មិនមាននៅក្នុងអត្ថបទបកប្រែគម្ពីរពិសិដ្ឋរបស់បូព៌ាប្រទេស ជំពូក២ ទំព័រ៩៧) *និសាទេន និសាទ្យាំ អា បញ្ចមាជ ជាតោ អបហន្តិ [ជាតោ បហន្តិ] សូទ្រតាំ / តំ ឧបនយេត សស្តំ យាជយេត* ៉(កូន) ដែលកើតពីនិសាទ ជាមួយស្ត្រីនិសាទី កាត់ផ្តាច់ខ្សែលោហិតសូទ្រៈ ក្នុងជំនាន់ទីប្រាំ ហើយគេអាចបញ្ចូលគាត់(ជាអ្នកជំនាន់ទីប្រាំ) គេអាចបូជាសម្រាប់ជំនាន់ទីប្រាំមួយ៉។ សេចក្តីរបស់ពោធាយននេះ អំណាចដែលគាំទ្រ ដោយសំណៅដៃថ្មីរបស់មទ្រ សបញ្ជាក់ច្បាស់ថា ពោធាយន អនុញ្ញាតឱ្យកូនប្រុសរបស់ព្រាហ្មណ៍ និងស្ត្រីសូទ្រៈ ទទួលបានការចិញ្ចឹមដល់កម្រិតអារ្យ័ន។ មិនមែនមិនអាចទេថា អត្ថន័យនៃកាព្យរបស់មនុ អាចមានន័យដូចគ្នា ហើយថា ការបកប្រែគួរថា ៉បើកូនរបស់ព្រាហ្មណ៍ និងស្ត្រីសូទ្រៈ ផ្តល់កំណើតកូនជាមួយបុរសវណ្ណៈព្រាហ្មណ៍ ឬស្ត្រីអំបូរបារសវ ដ៏ឧត្តុង្គឧត្តមបំផុតនោះ អំបូរ ថ្នាក់ក្រោម ទទួលបានវណ្ណៈខ្ពស់បំផុតក្នុងជំនាន់ទីប្រាំពីរ៉។ កម្មវត្ថុចម្បងនៃកាព្យនេះ ដែលមានការពិតថា *ស្រេយសា* ៉ដោយឧត្តុង្គឧត្តមបំផុត៉ សំដៅដល់ភេទប្រុស អាចមាននៅក្នុងការប្រើប្រាស់ភេទប្រុសរបស់ព្រះមនុ ជំនួសឱ្យភេទស្រីនៅក្នុងកាព្យលេខ ៣២ខាងលើ ដែលពាក្យ *អាយោគវេ* ត្រូវគេប្រើជំនួសពាក្យ *អាយោគវ្យាំ*។

**៦៥.** វិធីដែលព្រាហ្មណ៍ធ្លាក់ដល់កម្រិតជាសូទ្រៈ តាមលោកមេធ., គោវ. និងកុល្លូ. គឺមានដូចខាងក្រោម។ ប្រសិនបើកូនប្រុសរបស់ព្រាហ្មណ៍ និងស្ត្រីសូទ្រៈ ហើយអ្នកជំនាន់ក្រោយបន្ទាប់ពីគាត់ រៀបការជាមួយភរិយាសូទ្រៈ កូនចៅទីប្រាំពីរនឹងក្លាយជាសូទ្រៈពិតប្រាកដ។ លោកមេធ., គោវ. និងកុល្លូ. អះអាងថា កូនរបស់ព្រាហ្មណ៍ និងរបស់ស្ត្រីក្សត្រិយា បានឋានៈខ្ពស់ជាង ឬទាបជាង ក្នុងជំនាន់ទីបី ហើយកូនរបស់ព្រាហ្មណ៍ជាមួយនឹងស្ត្រីវៃស្យ ក្នុងជំនាន់ទីប្រាំ។ លោកមេធ. និង គោវ. បញ្ជាក់ច្បាស់ថា ៉ពួកគេ៉ គឺ អ្នកអធិប្បាយពីជំនាន់មុន ធ្វើការបកស្រាយដូច្នេះ។

**៦៦.** ៉ស្ត្រីមិនមែនជាអារ្យ័ន៉ គឺ ៉ស្ត្រីសូទ្រៈ៉(មេធ., គោវ., កុល្លូ., រាឃ., នន្ទ.) ឬ ៉កូនស្ត្រីរបស់*វ្រាត្យ* ជាដើម៉(នារ.)។ ៉ដោយចៃដន្យ៉ គឺ សូម្បីដោយកើតពីមនុស្សដែលគ្មានការរៀបការក៏ដោយ(មេធ., គោវ., កុល្លូ., រាឃ., នន្ទ.) ឬ ៉ដោយមិនបានដឹង៉(នារ.)។ ៉ស្ត្រីអារ្យ័ន៉ គឺ ៉ព្រាហ្មណី៉(មេធ., គោវ., កុល្លូ., រាឃ., នារ., នន្ទ.)។

**៦៧.** ៉អាចក្លាយ(ទៅជា)អារ្យ័ន ដោយសារគុណធម៌របស់ខ្លួន៉ គឺ ៉អាចក្លាយជាឋានៈឧត្តមបំផុត ឬគួរឱ្យសរសើរបំផុតដោយការបូជា*បាកយញ្ញ* ជាដើម ដែលតាម*ស្មិត* ដទៃទៀត អនុញ្ញាតចំពោះគេបាន៉(មេធ., គោវ., កុល្លូ., នារ.)។ ៉មិនដូចជាអារ្យ័ន៉ គឺ ៉មិនសមទទួលបានការសរសើរ ឬការគោរពទេ៉(គោវ., កុល្លូ.)។

៦៨- ច្បាប់បញ្ញត្តិថា អ្នកទាំងពីរមិនអាចទទួលពិធីពិសិដ្ឋទេ អ្នកទីមួយ(ដែលត្រូវគេបណ្តេញចេញ) ដោយផ្អែកលើដើមកំណើតថ្នាក់ទាបរបស់ខ្លួន អ្នកទីពីរ(ដោយសារការរួមសង្វាសរបស់ឪពុកម្តាយខ្លួន) គឺខុសវណ្ណៈគ្នា។

៦៩- ព្រោះគ្រាប់ពូជល្អ ដែលដុះនៅលើដីល្អ ឱ្យផលល្អឥតខ្ចោះ ដូច្នេះហើយកូនប្រុសរបស់អារ្យ៉ែនជាមួយនឹងស្ត្រីអារ្យ៉ែន គឺសមនឹងទទួលពិធីពិសិដ្ឋទាំងអស់។

៧០- បណ្ឌិតមួយចំនួនប្រកាសថា គ្រាប់ពូជមានសារៈសំខាន់ជាង ហើយបណ្ឌិតខ្លះថា ស្រែសំខាន់ជាង ហើយខ្លះទៀត(អះអាងថា) គ្រាប់ពូជនិងស្រែ (មានសារសំខាន់ដូចគ្នា) ប៉ុន្តែការវិនិច្ឆ័យតាមផ្លូវច្បាប់អំពីបញ្ហានេះ មានដូចតទៅៈ

៧១- គ្រាប់ពូជ ដែលសាបព្រោះលើដីគ្មានជីជាតិ នឹងវិនាសនៅលើដីនោះ ហើយដូចគ្នា ស្រែដ៏មាន(ជីជាតិ) ដែលមិនបានទទួលការសាបព្រោះគ្រាប់ពូជល្អ នឹងនៅតែគ្មានផលដដែល។

៧២- ដោយសារអំណាចនៃគ្រាប់ពូជ(កូនប្រុស)ដែលចាប់កំណើតពីសត្វ បានក្លាយជាបណ្ឌិត ដែលបានទទួលកិត្តិយសនិងការសរសើរ ហេតុនេះគ្រាប់ពូជត្រូវគេប្រកាសថាមានសារៈសំខាន់ជាង។

៧៣- ដោយបានពិចារណាពី (ករណីរបស់) អ្នកមិនមែនជាអារ្យ៉ែនដែលធ្វើហាក់ដូចជាពួកអារ្យ៉ែន និង (ករណីរបស់) អារ្យ៉ែន ដែលធ្វើហាក់ដូចជាមិនមែនអារ្យ៉ែន ព្រះបង្កើតសត្វលោកបានប្រកាសថា 'អ្នកទាំងពីរនោះ មិនស្មើគ្នាផង និងមិនដូចគ្នាផង'។

## មុខរបរតាមវណ្ណៈ

៧៤- ព្រាហ្មណ៍ ដែលតាំងចិត្តពឹងផ្អែកលើមធ្យោបាយ(គោរព)ព្រះព្រហ្ម ហើយប្រកាន់ខ្ជាប់ក្នុង(ការបំពេញករណីយកិច្ចរបស់ខ្លួន នឹងរស់នៅដោយការប្រតិបត្តិដ៏ត្រឹមត្រូវនូវអំពើប្រាំមួយយ៉ាង (ដូចមានរៀបរាប់) តាមលំដាប់លំដោយនៅខាងក្រោម។

៧៥- ការបង្រៀន ការសិក្សា ការធ្វើពលិកម្មសម្រាប់ខ្លួនឯង ការធ្វើពលិកម្មសម្រាប់អ្នកដទៃ ការធ្វើទាននិងការទទួលអំណោយ គឺជាអំពើប្រាំមួយ (ដែលជាបញ្ញត្តិ) សម្រាប់ព្រាហ្មណ៍។

---

**៦៩-៧២.** សូមមើលការពិភាក្សានៅក្នុងជំពូក ៩ លេខ៣៣-៤១ ខាងលើផង។

**៧១.** លោកគោវ., កុល្ល. និងនន្ទ. និយាយថា 'ស្រែ ដែលគ្មាន(ការសាបព្រោះ)ពូជ ទុកចោលសោះកក្រោះ'។ ការបកប្រែនេះយកតាមលោកមេធ.។ អ្នកអធិប្បាយសំដៅដល់សាច់រឿងរបស់ *មន្ទបាល* និង *ឫស្សស្រឹង្គ* សូមមើលជំពូក៩ លេខ២៣ ខាងលើ។

**៧២.** 'មិនស្មើគ្នា' គឺដោយសារពួកគេមានវណ្ណៈខុសគ្នា 'មិនដូចគ្នា' គឺ ព្រោះអ្នកទាំងពីរធ្វើនូវអំពើខុសគ្នា។ ហេតុនេះគ្មាននរណាមួយអាចធ្វើនូវអំពើណា ដែលគេមិនអនុញ្ញាតឱ្យខ្លួនធ្វើនោះទេ(គោវ., កុល្ល., រាឃ.។

**៧៤-៨០.** អាប. ជំពូក២ លេខ១០, ៤-៧; គោត. ជំពូក១០ លេខ១-៧, ៤៩; វស. ជំពូក២ លេខ១៣-១៩; ពោធ. ជំពូក ១ លេខ១៨, ១-៤; វិ. ជំពូក២ លេខ១-៧; យញ្ញ. ជំពូក១ លេខ១១៨-១១៩ និងសូមមើលជំពូក ១ លេខ៨៨-៩០ខាងលើផង។

**៧៤.** *ព្រហ្មយោនិស្ថាៈ*ដែលតាំងចិត្តពឹងផ្អែកលើមធ្យោបាយគោរពព្រះព្រហ្ម'(មេធ., គោវ., កុល្ល.) ហើយតាមលោកនារ. និងរាឃ. ថា 'ដែលមានជាតិកំណើតពីព្រះព្រហ្មដ៏បរិសុទ្ធ'។ តាមលោកនន្ទ. ថា 'អ្នកដែលប្រតិបត្តិតាមអ្វីបញ្ញត្តិចេញពីព្រះ

៧៦- ក៏ប៉ុន្តែក្នុងចំណោមអំពើទាំងប្រាំមួយ (បញ្ញត្តិ) សម្រាប់ព្រាហ្មណ៍ មានអំពើបីជាមធ្យោបាយសម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួន(រួមមាន)ការធ្វើពលិកម្មសម្រាប់អ្នកដទៃ ការបង្រៀននិងការទទួលអំណោយពីមនុស្សបរិសុទ្ធ។

៧៧- (ផ្អាកនិយាយ) អំពីព្រាហ្មណ៍ ងាកទៅនិយាយពីក្សត្រិយវិញ អំពើទាំងបី (ដែលជាភារៈរបស់ព្រាហ្មណ៍) ត្រូវហាមឃាត់ (គឺ) ការបង្រៀន ការធ្វើពលិកម្មសម្រាប់អ្នកដទៃ និងទីបីការទទួលអំណោយ។

៧៨- អំពើនេះក៏ជាការហាមឃាត់ចំពោះវៃស្យ ពោលគឺ នេះជាវិធានច្បាប់ដែលបានបញ្ញត្តិទុក ព្រោះព្រះមនុ ម្ចាស់បង្កើតសត្វលោក(ប្រជាបតិ) មិនបានបញ្ញត្តិអំពើទាំងនេះសម្រាប់ (មនុស្ស)ក្នុងវណ្ណៈទាំងពីរនេះទេ។

៧៩- ចំពោះការកាន់អាវុធប្រយុទ្ធ និងការគប់ប្រមាញ់ (ជាភារៈ ដែលបញ្ញត្តិ)សម្រាប់ក្សត្រិយ ធ្វើជាមធ្យោបាយចិញ្ចឹមជីវិត ហើយចំពោះការជួញដូរ (ការចិញ្ចឹម)សត្វធំៗ និងការធ្វើកសិកម្ម គឺសម្រាប់ពួកវៃស្យ ប៉ុន្តែករណីយកិច្ចរបស់ពួកគេ ត្រូវមានចិត្តសប្បុរសធម៌ សិក្សាព្រះវេទនិងធ្វើពិធីយញ្ញ។

៨០- ក្នុងចំណោមមុខរបរជាច្រើន មុខរបរដ៏ប្រពៃបំផុត គឺការបង្រៀនព្រះវេទសម្រាប់ព្រាហ្មណ៍ ការការពារ(ប្រជារាស្ត្រ)សម្រាប់ក្សត្រិយ និងការធ្វើជំនួញសម្រាប់វៃស្យ។

៨១- ប៉ុន្តែព្រាហ្មណ៍ ដែលមិនអាចចិញ្ចឹមជីវិតដោយមុខរបរពិសេសរបស់ខ្លួន ដូចបានជម្រាបជូននេះ អាចរស់នៅស្របតាមច្បាប់ដែលបញ្ញត្តិសម្រាប់ក្សត្រិយបាន ចំពោះក្សត្រិយអាចរស់នៅតាមបញ្ញត្តិសម្រាប់មនុស្សក្នុងវណ្ណៈបន្ទាប់ពីខ្លួនបាន។

៨២- ប្រសិនបើមានសំណួរចោទសួរថា 'តើធ្វើដូចម្តេចទៅប្រសិនបើគាត់មិនចិញ្ចឹមជីវិតខ្លួនឯងដោយ (មុខរបរទាំងអស់នេះ? ចម្លើយគឺថា)' គាត់អាចយកលំនាំតាមទម្រង់ចិញ្ចឹមជីវិតរបស់ពួកវៃស្យ ដោយធ្វើការក្នុងវិស័យកសិកម្ម និងចិញ្ចឹមសត្វបាន។

---

វេទ គឺ ច្បាប់ពិសិដ្ឋ' ឬ 'ដែលជាកន្លែងស្នាក់អាស្រ័យរបស់ព្រះវេទ'។

**៧៧.** នារ. អាន *ព្រាហ្មណាះ ក្សត្រិយំ ប្រតិ*សម្រាប់ក្សត្រិយ អំពើទាំងបីដែលជាភារៈសម្រាប់ព្រាហ្មណ៍ ត្រូវហាមឃាត់' ជំនួសឃ្លា *ព្រាហ្មណាត ក្សត្រិយំ ប្រតិ*។ លោកនន្ទ. ដែលអត្ថបទរបស់គាត់ត្រូវកែប្រែ ហាក់ដូចជាសរសេរដូចគ្នានឹងលោក នារ. ដែរ។

**៨០.** *វាត៌្តា* 'ការធ្វើជំនួញ'(នន្ទ.) តាមលោកកុល្ល. ថា 'ការធ្វើជំនួញ និងការចិញ្ចឹមសត្វ' ហើយតាមលោកគោវ. ថា 'ការធ្វើជំនួញ ការចិញ្ចឹមសត្វ និងកសិកម្ម'។ ប៉ុន្តែបរិបទនេះទំនងជាអាចសបញ្ជាក់បានថា ឃ្លានេះសំដៅដល់តែមុខរបរមួយប៉ុណ្ណោះ។

**៨១-៩៨.** អាប. ជំពូក១ លេខ២០, ១០-២១, ៤; គោត. ជំពូក២ លេខ១-២៦; វស. ជំពូក២ លេខ២២-៣៩; ពោធ. ជំពូក ២ លេខ៤, ១៦-២១; វិ. ជំពូក២ លេខ១៥; ជំពូក៥៤ លេខ១៨-២១; យញ្ញ. ជំពូក៣ លេខ៣៥-៤០។

**៨២.** នារ. គិតថា *ក្ញសិ* 'កសិកម្ម' នៅទីនេះ មានន័យថា *អស្វយំក្ញតា* 'ដែលព្រាហ្មណ៍មិនធ្វើដោយបុគ្គលខ្លួនឯង' ចំណែកឯ លោកគោវ. និងកុល្ល. សម្តែងនូវយោបល់ផ្ទុយទៅវិញ។ តាមយោបល់របស់ពួកគាត់ *អស្វយំក្ញតា ក្ញសិ* ត្រូវបានគេប្រើជាទូទៅ តាមកាលជាធម្មតា សូមមើលជំពូក៤ លេខ៤-៥ ខាងលើ។

៨៣- ប៉ុន្តែព្រាហ្មណ៍ ឬក្សត្រិយ ដែលចិញ្ចឹមជីវិតតាមទម្រង់ចិញ្ចឹមជីវិតរបស់វៃស្យ ត្រូវប្រុងប្រយ័ត្ន កុំប្រកបរបរកសិកម្មណា (ដែលអាចបង្ក) ភយន្តរាយដល់សត្វលោកច្រើន និងអាស្រ័យលើអ្នកដទៃ។

៨៤- (អ្នកខ្លះ)ប្រកាសថា ការងារកសិកម្មជាការងារឧត្តមដែរ (ប៉ុន្តែ) មធ្យោបាយចិញ្ចឹមជីវិតនោះត្រូវមនុស្សស្តីបន្ទោស (ព្រោះ) ឧបករណ៍ដែលធ្វើពីឈើ ដែលមានបំពាក់ចុងដែកស្រួច បង្កការឈឺចាប់ដល់ដី និង (សត្វលោក) ដែលរស់នៅក្នុងដី។

៨៥- ប៉ុន្តែអ្នកដែលជួបនូវការខ្វះខាតមធ្យោបាយចិញ្ចឹមជីវិត បោះបង់ចោលភាពដាច់ខាត ចំពោះករណីយកិច្ចរបស់ខ្លួនអាចលក់ទំនិញដែលពួកវៃស្យលក់ដើម្បីបង្កើនទ្រព្យរបស់ខ្លួនបាន (ប៉ុន្តែ) ដោយមានការលើកលែងខ្លះ (ដូចខាងក្រោម)។

៨៦- គេត្រូវជៀសវាង(ការលក់)គ្រឿងទេសគ្រប់ប្រភេទ អាហារចម្អិននិងគ្រាប់ល្ង ថ្ម អំបិល បសុសត្វ និងមនុស្ស,

៨៧- ក្រណាត់ជ្រលក់ពណ៌ទាំងអស់ ព្រមទាំងក្រណាត់ដែលធ្វើពីក្រចៅឬកប្បាស ឬក៏រោមសត្វ ទោះបីជាក្រណាត់នោះមិនមានជ្រលក់ពណ៌ក៏ដោយ មើមឈើ និងរុក្ខជាតិ( ឱសថ );

៨៨- ទឹក អាវុធ ថ្នាំពុល សាច់ សោម និងទឹកអប់គ្រប់ប្រភេទ ទឹកដោះស្រស់ ទឹកឃ្មុំ ទឹកដោះជូរ ប៊ឺសុទ្ធ ប្រេង ក្រមួន ស្ករ ស្មៅកុសៈ ;

៨៩- សត្វព្រៃទាំងអស់ សត្វដែលមានចង្កូម ឬភ្លុក សត្វស្លាប គ្រឿងស្រវឹង ដើមឆ្លះ ល័ក្ខ និងសត្វព្រៃដែលមានក្រចកមួយទាំងអស់។

៩០- ប៉ុន្តែអ្នកដែលចិញ្ចឹមជីវិតដោយការងារកសិកម្ម អាចលក់គ្រាប់ល្ងដែលមិនលាយ សម្រាប់គោលបំណងពិសិដ្ឋបាន ដោយហេតុថាគេបានដាំដុះវាដោយផ្ទាល់ និងមិនបានរក្សាទុកវាយូរទេ។

---

**៨៣.** `ពឹងផ្អែកលើអ្នកដទៃ´ ពោលគឺ `ពឹងផ្អែកលើគោគម្រៀងជាដើម´( គោវ., កុល្ល. )។ សិក្ខាបទនេះ ត្រូវបានទូន្មាននៅក្នុងជំពូក ៤ លេខ១៥៩-១៦០ ខាងលើថា ស្នាតកៈ គួរជៀងវាសនូវការពឹងពាក់អ្នកដទៃទាំងអស់។

**៨៤.** មេធ. គូសបញ្ជាក់ថា កាព្យនេះ សំដៅជំនាស់នឹងការបង្រៀនរបស់ វស. ជំពូក ២ លេខ៣២-៣៦។

**៨៦.** មេធ.និយាយថា `និងអាហារចម្អិន ដែលលាយនឹងគ្រាប់ល្ង´។ អ្នកអធិប្បាយដដែលគិតថា ដោយសារអំបិល ជាគ្រឿងទេសមួយប្រភេទ ជាពិសេសត្រូវគេហាមឃាត់ដែរ គេអាចលក់គ្រឿងទេសផ្សេងទៀត ដោយស្ម័គ្រចិត្ត។ ប៉ុន្តែលោក គោវ. និងកុល្ល. គូសបញ្ជាក់ថា មានការរៀបរាប់ឈ្មោះគ្រឿងទេសពិសេសៗ ព្រោះការធ្វើតបៈមានទម្ងន់ធ្ងន់ជាង។ លោកនារ. បកស្រាយ *រសាន* `គ្រឿងទេស´ ដោយថា `សារធាតុសាយចេញពីស្លឹកឈើ និងពីឈើជាដើម´។

**៨៨.** នារ. អាន *ក្សារំ* `សារធាតុក្បុង´ ជំនួសពាក្យ *ក្សីរំ* `ទឹកដោះគោស្រស់´ ប៉ុន្តែសរសេរអំណានក្រោយនេះ ហើយនន្ទ. ប្រើ *ក្សារំ* ជំនួស *ក្សៅទ្រំ* ។

**៨៩.** នារ. អាន *មជ្ជា* `ខួរឆ្អឹង´ ជំនួសពាក្យ *មទ្យំ* `ទឹកស្រវឹង´។ លោកមេធ. និយាយថា អ្នកខ្លះសរសេរ *អេកសផាន ពហូន* `សត្វព្រៃជាច្រើនដែលមានក្រចកមួយ´ និងអនុញ្ញាតឱ្យលក់សត្វតែមួយ។ លោកនន្ទ. សរសេរ *បសូន* `សត្វ´។

**៩០.** ពាក្យ *សុទ្ធាន* `ដែលលាយ´(មេធ., គោវ., កុល្ល., រាឃ.) តាមលោកនន្ទ. គឺ `ពណ៌ស´ ហើយតាមលោកនារ. ថា `ដែលមានគុណភាពល្អ´។ `ដោយហេតុថា គាត់មិនបានរក្សាវាអស់ពេលជាយូរមកហើយ´ គឺ `ប្រសិនបើគាត់មិនបានរក្សាវាក្នុងពេលដ៏យូរ បន្ទាប់ពីការប្រមូលផល ដើម្បីបង្កើនផលចំណេញរបស់ខ្លួនទេ´(មេធ., គោវ., កុល្ល., នារ.)។

៩១- ប្រសិនបើគេប្រើលូសម្រាប់គោលបំណងផ្សេងក្រៅពីអាហារ ការធ្វើប្រេងលាបនិងអំណោយសប្បុរស គេនឹងកើត(ជាតិក្រោយ) ជាដង្កូវ ហើយរួមទាំងដូនតារបស់ខ្លួនផងនឹងធ្លាក់ចូលក្នុងលាមកចំណីឆ្កែ។

៩២- ដោយ (ការលក់) សាច់ អំបិល និងល័ក្ខ ព្រាហ្មណ៍នឹងក្លាយជាចណ្ឌាលភ្លាម ដោយការលក់ទឹកដោះ គេក្លាយជា(ស្មើនឹង)សូទ្រៈ ក្នុងរយៈពេលបីថ្ងៃ។

៩៣- ប៉ុន្តែដោយការលក់ដោយចេតនានូវទំនិញ (ហាមឃាត់) ផ្សេងទៀតនៅក្នុងលោកិយនេះ ព្រាហ្មណ៍ នឹងមានលក្ខណៈដូចពួកវៃស្យ បន្ទាប់ពីប្រាំពីររាត្រី។

៩៤- គេអាចដោះដូរគ្រឿងទេសយកគ្រឿងទេសបាន ប៉ុន្តែមិនត្រូវយកអំបិលដូរយកគ្រឿងទេស(ផ្សេង)ទេ ហើយគេ (អាចដូរ) អាហារឆ្អិន យកអាហារឆ្អិន(ប្រភេទផ្សេងទៀត) និងដូរគ្រាប់លូពូជ យក គ្រាប់ធញ្ញជាតិក្នុងបរិមាណស្មើគ្នាបាន។

៩៥- ក្សត្រិយដែលបានធ្លាក់ខ្លួនក្នុងគ្រោះវិបត្តិ អាចចិញ្ចឹមជីវិតដោយ(មធ្យោបាយ)ទាំងអស់នេះបាន ប៉ុន្តែមិនត្រូវរក្សាទុកទម្រង់ចិញ្ចឹមជីវិតនេះថាជារបស់ខ្លួន អំណួត (សម្រាប់) ភាពប្រសើរឡើងរបស់ខ្លួននោះទេ។

៩៦- បុរសវណ្ណៈទាបដែលមានចិត្តលោភ ចង់រស់អាស្រ័យដោយមុខរបររបស់មនុស្សវណ្ណៈខ្ពស់ជាងព្រះរាជានឹងដកហូតទ្រព្យសម្បត្តិរបស់គេ ហើយបណ្តេញចេញពីនគរ។

៩៧- (ការបំពេញ) ករណីយកិច្ច (កំណត់) សម្រាប់ខ្លួនផ្ទាល់មិនបានពេញលេញ ប្រសើរជាងការបំពេញ ករណីយកិច្ចរបស់អ្នកដទៃបានពេញលេញ ព្រោះថាអ្នកដែលចិញ្ចឹមជីវិតស្របតាមច្បាប់សម្រាប់(វណ្ណៈ)មួយទៀត នឹងត្រូវគេដករបស់ខ្លួនទាំងអស់ភ្លាម។

៩៨- វៃស្យ ដែលមិនអាចចិញ្ចឹមជីវិតដោយករណីយកិច្ចរបស់ខ្លួនផ្ទាល់ អាចចិញ្ចឹមជីវិតខ្លួនតាមទម្រង់ជីវិតរបស់សូទ្រៈក៏បាន (តែ) ដោយជៀសវាងនូវអំពើហាមឃាត់ (សម្រាប់រូបគាត់) ហើយគេគួរតែបោះបង់វាចោល នៅពេលគេអាច (ធ្វើដូច្នេះ) បាន។

---

**៩១.** K. អាន *ក្ងមៀ ក្ងត្វា ស វិស្ថាយាំ* 'គេនឹងត្រូវធ្លាក់ក្នុងលាមក' ហើយលោកមេធ. ទំនងជាអាន *ស* 'គេ' សម្រាប់ពាក្យ *ស្វ* 'ឆ្កែ'។

**៩៣.** *កាមតះ* 'ដោយចេតនា' តាមលោកមេធ. និងនន្ទ. ថា 'មិនស្ថិតក្នុងគ្រាមានគ្រោះវិបត្តិ ប៉ុន្តែស្ថិតក្នុងពេលធម្មតា'។

**៩៤.** ខ្ញុំអានតាមលោកមេធ. និងនន្ទ. *ក្ងតាន្នំ ច ក្ងតាន្នេន* ជំនួស *ចាក្ងតាន្នេន*(គោវ., កុល្លូ., នារ.) 'សម្រាប់ធញ្ញជាតិដែលគ្មានសម្បក' ពីព្រោះស្រ្តិតផ្សេងទៀតទាំងអស់សុទ្ធតែមានវិធានខាងដើមនេះ។ K. អាន *វា ក្ងតាន្នេន* នេះជាការបង្ហាញពីការអានខុសព្យាង្គ *ចាអាំង* ដោយរបៀបណា។ នន្ទ. អាន *ន ត្វេវ លវណំ តិលេះ* 'ប៉ុន្តែមិនមែនអំបិល ដូរយកធញ្ញជាតិ លូទេ' ហើយលោកមេធ. សរសេរដូចក្នុងកាព្យនេះស្រាប់។

**៩៧.** នារ. លើកឡើងនូវគួយ៉ាងអំពីការបំពេញករណីយកិច្ចមិនបានត្រឹមត្រូវ ឬមិនបានពេញលេញរបស់ព្រាហ្មណ៍ដែលមានលក្ខណៈប្រសើរជាងការបំពេញករណីយកិច្ចរបស់វណ្ណៈផ្សេងបានពេញ គឺការទទួលទានពីមនុស្សមិនបរិសុទ្ធ។ នន្ទ. លុបកាព្យនេះចោល ដែលតាមពិតនៅត្រង់នេះមិនគួរមានទេ ហើយគួរមានក្នុងការពិភាក្សាផ្តើមកាព្យលេខ១០១។

**៩៨.** 'អំពើហាមសម្រាប់ខ្លួន' គឺ 'ការហូបអាហារសំណល់របស់អ្នកផ្សេងជាដើម'(គោវ., កុល្លូ., នារ.) ឬ 'ការបរិភោគអាហារហាមឃាត់ជាដើម'(នន្ទ.)។

៩៩- ប៉ុន្តែសូទ្រៈ ដែលមិនអាចរកការងារបម្រើអ្នកមានកំណើតពីរដង ដែលមានការគំរាមដល់ការបាត់បង់ជីវិតកូនប្រុសនិងភរិយារបស់ខ្លួន(ដោយសេចក្តីស្រេកឃ្លាន) អាចចិញ្ចឹមជីវិតដោយការធ្វើសិប្បកម្មបាន។

១០០- (ចូរអ្នកប្រកាន់យក)មុខរបរផ្នែកគ្រឿងយន្តទាំងឡាយ និងសិល្បៈអនុវត្តនានា ដោយការបម្រើ (ដ៏ប្រសើរបំផុត)ដល់អ្នកមានកំណើតពីរដង។

១០១- ព្រាហ្មណ៍ ដែលជួបនូវវិបត្តិ ដោយខ្វះមធ្យោបាយចិញ្ចឹមជីវិត និងរងទុក្ខ(ដោយសេចក្តីស្រេកឃ្លាន) (ប៉ុន្តែ) មិនចង់ប្រកាន់យកទម្រង់ចិញ្ចឹមជីវិតរបស់វៃស្យ និងតាំងចិត្តដើរតាមមាគ៌ារបស់ខ្លួនផ្ទាល់ អាចប្រព្រឹត្តតាមរបៀបដូចខាងក្រោម។

១០២- ព្រាហ្មណ៍ ដែលបាននិងកំពុងជួបគ្រោះវិបត្តិ អាចទទួល(អំណោយ)ពីនរណាក៏បាន ព្រោះតាមច្បាប់ គេមិនអាចអះអាងថា អ្វីដែលបរិសុទ្ធ ត្រូវបានធ្វើឱ្យខូចទាំងអស់នោះទេ។

១០៣- ដោយការបង្រៀន ដោយពលិកម្មចំពោះ និងដោយការទទួលអំណោយពី(មនុស្ស)គួរឱ្យស្អប់ ព្រាហ្មណ៍(ក្នុងគ្រាអាសន្ន)មិនប្រព្រឹត្តអំពើបាបទេ ព្រោះថាពួកគេមានភាពបរិសុទ្ធដូចជាភ្លើង និងទឹក។

១០៤- អ្នកដែល ក្នុងពេលមានការគំរាមកំហែងដល់ជីវិតរបស់ខ្លួន ទទួលយកអាហារពីនរណាមួយ ក៏ដោយ ក៏មិនប្រឡាក់ដោយអំពើបាប ដាងមេឃប្រឡាក់ភក់ទេ។

១០៥- អជីគត៌ ដែលរងនូវសេចក្តីស្រេកឃ្លាន ហៀបនឹងធ្វើឱ្យកូនប្រុស(ផ្ទាល់របស់ខ្លួន)បាត់បង់ជីវិត និងមិនប្រឡាក់ដោយអំពើបាបទេ ព្រោះគេ(គ្រាន់តែ)ស្វែងរកវិធីទប់ទល់ការដាច់ពោះស្លាប់។

១០៦- វាមទេវ ដែលដឹងខុសត្រូវបានល្អ មិនបានធ្វើឱ្យខ្លួនសៅហ្មងនៅពេលជួបនូវ(វិបត្តិអត់ឃ្លាន) គេចង់បរិភោគសាច់ឆ្កែ ដើម្បីសង្គ្រោះជីវិតរបស់ខ្លួន។

១០៧- ភរទ្វាជ អ្នកធ្វើមហាតបៈ បានទទួលយកមេគោជាច្រើនពីនាយជាងឈើព្វធុ នៅពេលគាត់កំពុងស្រេកឃ្លានជាមួយកូនប្រុសខ្លួន នៅក្នុងព្រៃយ៉ាងត្រម៉ង់ត្រមោច។

---

**៩៩-១០០.** វិ. ជំពូក៣ លេខ១៤; គោត. ជំពូក១០ លេខ៦០។

**១០១-១១៤.** គោត. ជំពូក៧ លេខ៤-៥, ២៣; អាប. ជំពូក១ លេខ១៨, ៥-៨, ១៤-១៥។

**១០២.** 'អ្វីក៏ដោយដែលបរិសុទ្ធ' គឺ 'ទន្លេគង្គាជាដើម'(មេធ., គោវ., កុល្ល.) ឬ 'អគ្គីជាដើម'(នារ., រាឃ.)។

**១០៣.** វស. ជំពូក២៧ លេខ៩។

**១០៥.** បើនិយាយរឿងរបស់ *អជីគត៌* សូមមើលគម្ពីរអៃតរេយ-ព្រាហ្មណ៍ ជំពូក៧ លេខ១៣-១៦។

**១០៧.** ខ្ញុំអានតាមលោកគោវ. និង សាយណ នៅក្នុងគម្ពីរឫគ-វេទ ជំពូក៦ លេខ៤៥, ៣១ ពាក្យ *ព្វធុ* ជំនួស *វ្ធុ* (កុល្ល., រាឃ., K.) និង *ព្វហត* (នារ., នន្ទ.)។ សំណៅកែតម្រូវរបស់លោកមេធ. សរសេរ *វ្ធុ* ប៉ុន្តែសំណេរបុរាណបំផុត គឺ *វ្ធ* នៅក្នុងអត្ថបទ និងនៅក្នុងបទអធិប្បាយ *ទ្វពុ* គឺ *ព្វធុ* ។ គ្មានអ្វីគួរឱ្យសង្ស័យទេ ពាក្យ *ព្វធុ* ជាសំណេរត្រឹមត្រូវ។ ព្រោះនៅក្នុងស្តុតិ៍ ចម្រៀងថ្វាយអាទិទេព ត្រូវបានស្រង់សេចក្តីថា តួអង្គត្រូវគេពណ៌នាថាជាជាងឈើរបស់*បណ្ឌិស* ហើយចិត្តសប្បុរសរបស់គាត់ ត្រូវបានគេកោតសរសើរយ៉ាងខ្លាំង។ ជាងនេះទៅទៀត សង្ខាយន ស្រោតសូត្រ (មើលវចនានុក្រម Petersburg ពាក្យ *ព្វធុ*) និយាយទៅដល់រឿងព្រេងទិនាទ ដូចព្រះមនុបានរៀបរាប់។

១០៨- ឥសីវិស្វាមិត្រ ដែលចេះដឹងច្បាស់នូវអ្វីដែលត្រូវ ឬអ្វីដែលខុសនោះ បានដើរចូលមកដល់នៅពេលគាត់កំពុងត្រូវវេទុក្ខដោយសេចក្តីស្រេកឃ្លាន (ដើម្បីបរិភោគ) ភ្លៅឆ្កែ ដែលទទួលបានពីដៃរបស់ចណ្ឌាល។

១០៩- បើ(ប្រៀបធៀប)ការទទួល (អំណោយពីមនុស្សវណ្ណៈទាប) ការបូជា(ចំពោះពួកគេ) និងការបង្រៀន (ពួកគេ) ការទទួលអំណោយនោះគឺជាអំពើដ៏អាក្រក់បំផុត និងជាអំពើដែលគេគួរទិតៀន(បំផុត)ចំពោះព្រាហ្មណ៍ (បើនិយាយផលនៃអំពើនោះ)នៅក្នុងជាតិក្រោយ។

១១០- (ចំពោះ)ការជួយដល់ការបូជាយញ្ញនិងការបង្រៀន គឺជា(អំពើពីរ)ដែលធ្វើឱ្យមនុស្សដែលបានទទួលពិធីពិសិដ្ឋ ប៉ុន្តែការទទួលអំណោយកើតឡើងក្នុងករណី(ដែលអ្នកឱ្យ)ជាសូទ្រៈវណ្ណៈថ្នាក់ទាបបំផុត។

១១១- ទោសដែលកើតពីការបូជាចំពោះការបង្រៀន(មនុស្សមិនសមគួរ) ត្រូវវិនាសទៅវិញ ដោយសារការសូត្រខ្សឹបៗ (នូវធម៌ពិសិដ្ឋ) និងដោយការបូជាអគ្គី ប៉ុន្តែទោសដែលកើតពីការទទួលអំណោយ(ពីពួកគេ) ដោយការបោះ(អំណោយនោះ)ចោល និងដោយការធ្វើតបៈ។

១១២- ព្រាហ្មណ៍ ដែលមិនអាចចិញ្ចឹមជីវិតខ្លួនបាន គួរតែបេះផ្លែ ឬធញ្ញជាតិពី(ចម្ការ ស្រែរបស់)ជនណាក៏បាន ការបេះផ្លែគឺប្រសើរជាងការទទួលអំណោយ ការបេះធញ្ញជាតិតែមួយមុខត្រូវគេប្រកាសថា នៅតែប្រសើរជាងច្រើន។

១១៣- ប្រសិនបើព្រាហ្មណ៍ ដែលជាស្នាតកៈ កំពុងរងនូវសេចក្តីស្រេកឃ្លាន ឬខ្វះខាត(គ្រឿងប្រដាប់ប្រើប្រាស់ដែលធ្វើពី)លោហធាតុធម្មតា ឬទ្រព្យរបស់អ្នកដទៃ ពួកគេអាចស្នើសុំពីព្រះរាជាបាន ប្រសិនបើទ្រង់គ្មានចិត្តមេត្តាទេ ចូរព្រាហ្មណ៍ដើរចេញទៅ។

---

**១០៨.** បើនិយាយពីរឿងព្រេងរបស់ឥសីវិស្វាមិត្រ សូមមើល មហាភារត ជំពូក១២ លេខ១៤២ វគ្គ ២៨។

**១១០.** នារ. និយាយថា ‵សូទ្រៈ (ឬ)មនុស្សវណ្ណៈទាបបំផុត គឺចណ្ឌាល′។

**១១១.** អាប. ជំពូក១ លេខ២៨, ១១; វស. ជំពូក២០ លេខ៤៥; វិ. ជំពូក៥៤ លេខ២៨។ ‵ដោយការធ្វើតបៈ′ គឺ ‵ដោយការធ្វើតបៈលាងបាប′ សូមមើលជំពូក១១ លេខ១៩៤ខាងក្រោម។

**១១៣.** *កុប្យំ* ‵(របស់របរប្រើប្រាស់ដែលធ្វើពី)លោហធាតុធម្មតា′ តាមលោកមេធ.ថា ‵ឆ្នាំង កំសៀវ ជើងម៉ាឈើជាដើម′ ហើយតាមលោកគោវ. ថា ‵ទ្រព្យទាំងអស់ដែលមានតម្លៃតិចតួច ដូចជាគ្រែ កៅអី′, តាមលោកកុល្ល., រាឃ., និងនន្ទ. ថា ‵គ្រាប់ធញ្ញជាតិ និងសម្លៀកបំពាក់ក៏បាន′។ ប៉ុន្តែលោកនារ. ប្រែពាក្យនេះក្នុងន័យធម្មតា‵លោហធាតុធម្មតា ដូចជាទង់ដែង និងស្ពាន់′។ ខ្ញុំប្រែប្រយោគចុងក្រោយ តាមការបកស្រាយទីមួយរបស់មេធ., គោវ., នារ. និងរាឃ. ដែលគិតថា ព្រាហ្មណ៍ទាំងអស់ គួរចាកចេញពីអាណាចក្ររបស់ព្រះរាជាណា ដែលមិនផ្គត់ផ្គង់ដល់ស្នាតកៈដែលកំពុងស្រេកឃ្លាន។ យ៉ាងណាមិញ លោកនន្ទ. និយាយថា ព្រះរាជាបែបនេះ ត្រូវគេបណ្តេញចេញ មិនឱ្យទទួលការអប់រំ និងមិនឱ្យចូលរួមពិធីយញ្ញ។ ការប្រែទីពីររបស់លោកមេធ. ដែលស្របគ្នានឹងយោបល់របស់នន្ទ. ថា ត្យាគៈ មានន័យ ធម្មហានិៈ ‵ការបាត់បង់គុណ ធម៌ផ្នែកព្រលឹងវិញ្ញាណ′។ លោកកុល្ល. ចុងក្រោយប្រែឃ្លានេះផ្សេងពីគេថា ‵ប៉ុន្តែអ្នកដែលមិនចង់បរិច្ចាគអ្វីមួយ ដែលគេចាត់ទុកថា ដោយសារសេចក្តីកំណាញ់របស់ខ្លួន ត្រូវឱ្យគេចេញដោយខ្លួនឯង គឺ មិនចាំបាច់មានគេស្នើសុំទេ′។ លោកកុល្ល. និងគោវ. អះអាងថា ‵ព្រះអង្គម្ចាស់′នៅទីនេះ គឺ ស្តេច ក្សត្រិយ ដែលមិនប្រតិបត្តិតាមសាស្ត្រ ឬស្តេចសូទ្រៈ (មើលកំណត់

សម្គាល់ នៅជំពូក៤ លេខ៣៣) ហើយថា កាព្យនេះនិរាករណ៍ការហាមឃាត់ ដែលមាននៅក្នុងជំពូក ៤ លេខ៨៤ ខាងលើ។

១១៤-(ការយកពី) ស្រែចម្ការដែលគ្មានម្ចាស់ មានទោសគួរឱ្យបន្ទោសតិចជាង (ការយកពី) ស្រែចម្ការដែលមានម្ចាស់ (បើនិយាយពី) មេគោ ពពែ ចៀម ធញ្ញជាតិ និងអាហារឆ្អិន (ការយកនូវ) របស់ខាងដើមដែលបានរៀបរាប់ មានទោសតិចជាងរបស់ខាងក្រោយៗ។

១១៥-ទម្រង់នៃការយកទ្រព្យគេដោយស្របច្បាប់ មានប្រាំពីរ (គឺ)ការទទួលមរតក ការរើសបាន ឬការបរិច្ចាគដោយមិត្តភាព ការជាវ របស់ជ័យកណ្ឌ ការឱ្យខ្ចីយកការប្រាក់ ការបំពេញការងារ និងការទទួលអំណោយពីមនុស្សល្អ។

១១៦-ការសិក្សា ជំនាញគ្រឿងយន្ត ការងារស៊ីឈ្នួល ការបម្រើ ការចិញ្ចឹមសត្វ ជំនួញ កសិកម្ម ការបំពេញចិត្ត (បន្តិចបន្តួច) ការដាក់ទាន និងការយកការប្រាក់ជាថវិកា ជាទម្រង់ចិញ្ចឹមជីវិតដប់យ៉ាង (ដែលអនុញ្ញាតសម្រាប់មនុស្សទាំងអស់ ក្នុងគ្រាអាសន្ន)។

១១៧-ព្រាហ្មណ៍និងក្សត្រិយ មិនត្រូវឱ្យ(លុយ)គេខ្ចីយកការប្រាក់ទេ ប៉ុន្តែដោយការអនុគ្រោះ របស់ខ្លួន (ព្រាហ្មណ៍ក្តី ក្សត្រិយក្តី) ក្នុងគ្រាអាសន្ន (ពេលដែលគាត់ត្រូវការថវិកា) សម្រាប់គោលបំណងពិសិដ្ឋ ឱ្យមនុស្សមានបាប ខ្ចីលុយ ដោយយកការប្រាក់តិចតួច។

១១៨-(ស្តេច) ក្សត្រិយ ដែលក្នុងគ្រាអាសន្ន អាចយកមួយភាគបួននៃ(កសិផល) គឺគ្មានទោសទេ ប្រសិនបើទ្រង់ខិតខំការពារប្រជារាស្ត្ររបស់ទ្រង់ ឱ្យអស់ពីលទ្ធភាពរបស់ទ្រង់។

១១៩-ករណីយកិច្ចពិសេសរបស់ទ្រង់ គឺការច្បាំងយកជ័យ ហើយទ្រង់មិនត្រូវរត់ទៅរកគ្រោះថ្នាក់ទេ ទ្រង់អាចឱ្យគេហូតពន្ធដោយស្របច្បាប់បាន។

---

**១១៤.** វស. ជំពូក១២ លេខ៣។

**១១៥.** គោត. ជំពូក១០ លេខ៣៩-៤២។ *លាភៈ* 'ការរើសបាន ឬការបរិច្ចាគដោយមិត្តភាព'(មេធ., គោវ., កុល្លូ.) តាមលោកនារ. និង នន្ទ. សំដៅដល់ការទទួលបាននូវវត្ថុមានតម្លៃប៉ុណ្ណោះ មិនមែនការទទួលអំណោយពីមិត្តភ័ក្តិ ពីឪពុកក្មេកនោះ ទេ។ *ជយ*ការច្បាំងជាញជ័យ' តាមលោកនន្ទ. ថា 'ការឈ្នះក្តី'។ អ្នកអធិប្បាយរូបនេះ ប្រែប្រយោគ 'ការឱ្យលុយខ្ចីយកការប្រាក់' ក្នុងន័យថា 'ការបង្រៀន' និង*កម្មយោគ*ការធ្វើពលកម្មដោយកម្លាំង' ក្នុងន័យ 'ការធ្វើពលិកម្ម សម្រាប់អ្នកដទៃ'។ អ្នកអធិប្បាយទាំងអស់ លើកលែងតែលោកនន្ទ. សុទ្ធតែគូសបញ្ជាក់ថា ទម្រង់នៃការធ្វើលទ្ធកម្មបីខាងដើម គឺស្របច្បាប់ សម្រាប់គ្រប់វណ្ណៈទាំងអស់ ទីបួនសម្រាប់ក្សត្រិយ ទីប្រាំនិងទីប្រាំមួយសម្រាប់វៃស្យ (ឬទីប្រាំសម្រាប់វៃស្យ ទីប្រាំមួយ សម្រាប់សូទ្រៈ តាមលោកនារ.) និងទីប្រាំពីរសម្រាប់ព្រាហ្មណ៍។

**១១៦.** 'ការសិក្សា' គឺ (ការបង្រៀន)ក្រៅពីវិទ្យាសាស្ត្រវេទ ឧទាហរណ៍តក្កវិជ្ជា ការដេញព្រលឹងខ្មោចបិសាច ឬការដាក់ស្នេហ៍ពិស(មេធ., កុល្លូ., នារ., រាឃ.)។ លោកគោវ. គិតថា 'ការបង្រៀនដើម្បីយកប្រាក់ឈ្នួលតាមការកំណត់' គឺអាចធ្វើទៅបាន អនុលោមតាមតម្រាច្បាប់នេះ។

**១១៧.** វស. ជំពូក២ លេខ៤០-៤៣។ គោវ., នារ. និង K. អាន *អល្បកំ* ជំនួស *អល្បិកាំ* ហើយតាមសំណេរផ្សេងទៀត អនុប្រយោគចុងក្រោយ គេអាចប្រែតាមលោកនារ. ថា '...(ទោះជាព្រាហ្មណ៍ ឬជាក្សត្រិយក្តី)... អាចឱ្យលុយបន្តិចបន្តួចទៅមនុស្សមានបាប ខ្ចីបាន'។

**១១៩.** ខ្ញុំអានតាមលោកគោវ. និង K.*ន ភយេ* ជំនួស *នាហវេ* (សំណៅបោះពុម្ព)។ អត្ថបទរបស់លោកមេធ. មានសរសេរពាក្យខាងក្រោយ ប៉ុន្តែអធិប្បាយ *ភយេ ឧបស្ថិតេ បាង្មុខោ យុទ្ធេ ន ស្យាត*នៅពេលគ្រោះថ្នាក់គំរាមកំហែង ទ្រង់មិនត្រូវ

ធ្វើសង្គ្រាមទេ៉ សបញ្ជាក់ថា សំណេររបស់គាត់ គឺ *ករយេ*។ សេចក្ដីសំអាងដដែលនេះ យើងអាចដកស្រង់ចេញពីបទអត្ថាធិប្បាយរបស់លោកកុល្ល. បាន។ លោកនន្ទ. ប្រែ *ន ករេវ* ទំនងជាច្រឡំនឹង *ន ករយេ*។

១២០- (គឺ)យកពីវៃស្យ មួយភាគប្រាំបី ជាពន្ធលើធញ្ញជាតិ មួយភាគដប់ពីរ(លើប្រាក់ចំណេញជាមាស និងសត្វ) ដែលយ៉ាងហោចណាស់មានចំនួនមួយ*កហាបណៈ* និងពីសូទ្រៈ សិប្បករ និង យន្តការី (នឹង)ផ្ដល់ប្រយោជន៍(ជូនស្ដេច) ដោយការធ្វើការងារ(ថ្វាយទ្រង់)។

១២១-ប្រសិនបើសូទ្រៈ (ដែលមិនអាចចិញ្ចឹមជីវិតដោយការបម្រើព្រាហ្មណ៍បាន) ចូរស្វែងរកការចិញ្ចឹមជីវិត គេអាចបម្រើក្សត្រិយ ឬគេក៏អាចរកវិធីចិញ្ចឹមខ្លួន ដោយចាំបម្រើវៃស្យសម្បូរទ្រព្យ។

១២២-ប៉ុន្តែចូរ(សូទ្រៈ)បម្រើព្រាហ្មណ៍ ដើម្បីបានឋានសួគ៌ផងឬសម្រាប់(ជាតិនេះផង និងជាតិក្រោយផង) ព្រោះអ្នកដែលជាអ្នកបម្រើព្រាហ្មណ៍ ត្រូវសម្រេចបំណងរបស់ខ្លួនទាំងអស់។

១២៣-ការបម្រើព្រាហ្មណ៍តែម្យ៉ាង ត្រូវគេប្រកាស(ថាជា) ការងារដ៏ឧត្ដម សម្រាប់សូទ្រៈ ព្រោះការងារផ្សេងក្រៅពីនេះ គេអាចធ្វើបាន នឹងមិនផ្ដល់ផ្លែផ្កាដល់រូបគេទេ។

១២៤- ពួកគេត្រូវតែចែកផលឱ្យគាត់ ក្រៅពី (ទ្រព្យ) គ្រួសារផ្ទាល់របស់ខ្លួន ជាការចិញ្ចឹមជីវិតសមស្របតាមលទ្ធភាពរបស់ខ្លួន ការប្រឹងប្រែងធ្វើការរបស់ខ្លួន និងចំនួនមនុស្សក្នុងបន្ទុកដែលខ្លួនមានកាតព្វកិច្ចទំនុកបម្រុង។

១២៥- អាហារសំណល់របស់ខ្លួន ត្រូវឱ្យទៅគេ ព្រមទាំងសម្លៀកបំពាក់ចាស់ៗរបស់ខ្លួន ធញ្ញជាតិដែលទុកចោល និងគ្រឿងសង្ហារិមចាស់ៗរបស់ខ្លួន។

---

**១២០.** តាមលោកមេធ. ជួរទីមួយសំដៅដល់ប្រាក់ចំណេញរបស់រាស្ត្រ ដែលរកស៊ីពោត ឬមាស។ ពីដំបូង ស្ដេចក្នុងគ្រាអាសន្ន អាចដកយកមួយភាគប្រាំបី និងយកពីអ្នកក្រោយ មួយភាគដប់ពីរ។ ជួរទីពីរ គូសបញ្ជាក់ថា សិប្បករដែលតាមជំពូក៧ លេខ៣៨ ក្នុងគ្រាធម្មតា ផ្ដល់មួយផ្នែកនៃការងារ ក្នុងខែនីមួយៗ អាចផ្ដល់ជាការធ្វើការងារថ្វាយស្ដេច។ តាមលោកគោវ. និងកុល្ល. អ្នកស្រែ (កូសិជីវិនាំ តាមលោកគោវ.) នឹងផ្ដល់ចំនួនបន្ថែមជាធញ្ញជាតិ (ឧបចយ) មួយភាគប្រាំបី (ជំនួសមួយភាគដប់ពីរ និងក្នុងគ្រាអាសន្ន ឱ្យមួយភាគបួន តាមកាព្យលេខ ១១៨ កុល្ល.) ជាចំនួនបន្ថែមជាមាសជាដើម ដែលមានតម្លៃជា កហាបណៈ មួយភាគដប់ពីរ ជំនួសឱ្យមួយភាគហាសិប ដូចមានបញ្ញត្តិក្នុងជំពូក៧ លេខ១៣០ ខាងលើ។ លោករាឃ. ជាសារធាតុ យល់ស្របតាមការបកស្រាយនេះ។ លោកនារ. និងនន្ទ. អានដូច្នេះថា *វឹសត្តារសាប ណាវំ* (ណាបរំ តាមលោកនន្ទ.) ហើយប្រែកាព្យនេះក្នុងន័យផ្សេង។ លោកនារ. និយាយថា ពន្ធយកលើធញ្ញជាតិ ត្រូវស្មើនឹងមួយ ភាគបួន ក្នុងករណីរបស់សូទ្រៈ និងមួយភាគប្រាំបី ក្នុងករណីជាវៃស្យ ថាពន្ធលើអ្វីៗផ្សេងទៀត យ៉ាងហោចណាស់ស្មើនឹងមួយកហាបណៈគិតជាម្លៃ ហើយថា សិប្បករ ដែលធ្វើការស៊ីឈ្នួល ត្រូវបង់អត្រាដូចគ្នា (វឹសតិការសាបនំ ឥតិ ធាន្យាដ ន្យេសុ វិញ្ញា គ្រាហ្យ ឥតី អវរះ បក្សះ/ សំករេ ត្វ អធិកំ អបិ គ្រាហ្យំ ឥតី អថ៌ះ / ធម្មោបករណោះ [កម្មោះ] ធម្មិភិរ [កម្មភិរ] វិស្វំ ឧបកុរ្វន្ត តន្តុវាយជយះ / សូទ្រោះ ការវោ វណ៌វាហ្យា នតចិត្រការាទ្យាះ / សិល្បិន ច រថការាទ្យាសតេ ៉បិ កម្ម ក្វត្វាក្វតិត្វេ ៉បិ វឹសតិកាសាបណលាភេ កាសាបណាវរំ សុល្កំ ទទ្យុរ ឥតិ សេសះ)។ តាមលោកនារ. ការប្រែគឺ ៉(ដូចជា)មួយភាគប្រាំបី ជាពន្ធ(ដែលត្រូវបង់)ដោយវៃស្យ លើធញ្ញជាតិ (និងលើអ្វីៗផ្សេងទៀត) យ៉ាងហោចណាស់ មួយកាសាបណៈក្នុងម្លៃ ហើយសិប្បករសូទ្រៈ និងយន្តការី ដែលផ្ដល់ប្រយោជន៍ (ដល់មនុស្ស) ដោយការធ្វើការងាររបស់ពួកគេ (នឹងបង់តាមអត្រាដូចគ្នា)៉។ លោកនារ. បន្ថែមថា អ្នកខ្លះអាន *ត្រឹសត្តាសាហណាវំ* ៉យ៉ាងហោចណាស់ មួយកាសាបណៈ ក្នុងសាបសិប៉។

**១២១-១២៩.** គោត. ជំពូក១០ លេខ៥០-៦៥; យញ្ញ. ជំពូក១ លេខ១២០-១២១។

**១២៦.** 'មិនអាចប្រព្រឹត្តបទល្មើស ដែលនាំឱ្យបាត់បង់វណ្ណៈ' គឺ 'ដោយការបរិភោគខ្ទឹមស និងផ្លែឈើហាមឃាត់ជាដើម' (គោវ., កុល្លូ.) ឬ 'ដោយ(ឃាម)ផ្ទះសត្តឃាត'(រាឃ.)។

១២៦- សូទ្រៈ មិនអាចប្រព្រឹត្តបទល្មើសដែលបង្កឱ្យបាត់បង់វណ្ណៈ (បាតកៈ) ហើយគេមិនសមនឹងទទួលពិធីពិសិដ្ឋទេ។ គាត់គ្មានសិទ្ធិ(អនុវត្ត)ច្បាប់ពិសិដ្ឋ (របស់ពួកអារ្យ៉ន ប៉ុន្តែ)គ្មានការហាមឃាត់ក្នុង (ការបំពេញភារកិច្ចរបស់ខ្លួន) តាមច្បាប់នោះទេ។

១២៧- (សូទ្រៈ) ដែលចង់បានបុណ្យកុសល និងស្គាល់ករណីយកិច្ច(របស់ខ្លួន) មិនប្រព្រឹត្តអំពើបាប ប៉ុន្តែបានទទួលពរ ប្រសិនបើពួកគេយកគ្រាប់តាមការអនុវត្តរបស់មនុស្សល្អ ដោយមិនចាំបាច់សូត្រធម៌ពិសិដ្ឋ។

១២៨- (សូទ្រៈ)ដែលរក្សាខ្លួនគេចឱ្យផុតពីការច្រណែន យកតម្រាប់តាមមនុស្សល្អកាន់តែច្រើន គាត់នឹងទទួលបានការលើកតម្កើងក្នុងជាតិនេះ និងជាតិក្រោយ ដោយគ្មានការចាប់ទោសកំហុស។

១២៩- សូទ្រៈមិនត្រូវធ្វើការប្រមូលទុកទ្រព្យសម្បត្តិទេ ថ្វីបើគេអាច(ធ្វើដូច្នេះ)ក៏ដោយ ព្រោះសូទ្រៈដែលមានទ្រព្យច្រើន បង្កការឈឺចាប់ដល់ព្រាហ្មណ៍។

១៣០- ករណីយកិច្ចសម្រាប់វណ្ណៈទាំងបួន ក្នុងគ្រាអាសន្ន ត្រូវបានប្រកាសមកយ៉ាងនេះ ហើយប្រសិនបើពួកគេប្រតិបត្តិវាបានល្អ ពួកគេនឹងសម្រេចនូវពរជ័យប្រសើរបំផុត។

១៣១- ដូច្នេះខ្ញុំបានប្រកាសជាផ្លូវការនូវវិធានច្បាប់ទាំងអស់សម្រាប់វណ្ណៈទាំងបួនរួចហើយ ជាបន្ត ខ្ញុំនឹងប្រកាសតម្រាវិធានដ៏ប្រពៃសម្រាប់ការធ្វើតបៈ។

---

**១២៧.** សូទ្រៈអាចធ្វើអំពើណាដែលសំខាន់ៗរបស់អារ្យ៉ន គេអាចយល់បានតាមរយៈសេចក្តីប្រហាក់ប្រហែលគ្នា ដូចបានដកស្រង់ខាងលើ។

**១២៩.** 'ផ្តល់នូវការឈឺចាប់ដល់ព្រាហ្មណ៍' គឺ 'ដោយមានមោទនភាព ហើយមិនបម្រើពួកគេ'(គោវ., កុល្លូ., រាឃ.)។

# ជំពូក ១១

# ការធ្វើតបៈ ការបរិច្ចាគ និងការបូជាយញ្ញ

១- បុរសដែលប្រាថ្នា(ចង់រៀបការដើម្បីបាន)កូន, បុរសដែលប្រាថ្នាចង់ធ្វើការបូជា ជាអ្នកដំណើរ, បុរសដែលតែងតែបានបរិច្ចាគទ្រព្យទាំងអស់របស់ខ្លួន, បុរសដែលសុំដើម្បីប្រយោជន៍គ្រូរបស់ខ្លួន ឪពុករបស់ខ្លួន ឬម្តាយរបស់ខ្លួន សិស្សសិក្សាព្រះវេទ និងមនុស្សឈឺ,

២- ព្រាហ្មណ៍ទាំងប្រាំបួនរូបនេះ គេគួរចាត់ទុកជាស្នាតកៈ ដែលដើរសុំ ដើម្បីបំពេញតាមច្បាប់ពិសិដ្ឋ គឺគេត្រូវផ្តល់អំណោយជូនមនុស្សកម្សត់បែបនេះ ស្របតាមការចេះដឹងរបស់ពួកគាត់។

៣- គេត្រូវផ្តល់អាហារ និងអំណោយជូនមនុស្សដ៏ឧត្តមបំផុត ក្នុងចំណោមអ្នកមានកំណើតពីរដងពោលគឺគេប្រកាសថា គេត្រូវផ្តល់អាហារដល់អ្នកដទៃ នៅក្រៅបរិវេណពិធីយញ្ញ។

៤- ប៉ុន្តែស្តេចត្រូវប្រទានតាមសមគួរ នូវគ្រឿងអលង្ការគ្រប់ប្រភេទ និងអំណោយនានា សម្រាប់ការបូជាដល់ព្រាហ្មណ៍ ដែលចេះដឹងព្រះវេទ។

៥- ប្រសិនបើបុរសដែលមានភរិយា រៀបការភរិយាទីពីរ ដោយបានសុំថវិកា (ដើម្បីចំណាយរៀបចំពិធីអាពាហ៍ពិពាហ៍ គាត់មិនបាន)ប្រយោជន៍ទេ តែបាននូវកាមតម្រេក ប៉ុន្តែផល (នៃការរៀបការលើកទីពីររបស់គាត់ ជារបស់)អ្នកបរិច្ចាគថវិកា។

---

**ជំពូក១១ លេខ១.** អាប. ជំពូក២ លេខ១០, ១-២; គោត. ជំពូក៥ លេខ២១; ពោធ. ជំពូក២ លេខ៥, ១៩។ 'អ្នកដែលតែងតែបានធ្វើការបរិច្ចាគទ្រព្យរបស់ខ្លួនជានិច្ច' គឺ 'ដោយការបូជា*វិស្វជិត*(មេធ., គោវ., កុល្ល., រាឃ.) ឬ '*ក្រតុស* ផ្សេងទៀត'(នារ.)។ 'ដើម្បីគ្រូរបស់ខ្លួន ឪពុករបស់ខ្លួន ឬម្ដាយរបស់ខ្លួន' គឺ 'ដើម្បីចិញ្ចឹមពួកគាត់'(គោវ., កុល្ល., រាឃ.) ឬ 'ដើម្បីផ្ដល់ថ្លៃបង្រៀនជូនគ្រូ'(រាឃ., នារ.)។ អ្នកអធិប្បាយព្យាយាមបង្ហាញការដាក់ឱ្យប្រើប្រាស់តម្រាវិធានផ្សេងៗ ដែលមាននៅក្នុងកាព្យលេខ ១-៤៣ មុនការពិភាក្សាអំពីការធ្វើតបៈ ដែលគួរដាក់បន្ទាប់ពីជំពូក១០ លេខ១៣១ភ្លាម ពោលអាចសន្មតថា កម្មវត្ថុគឺចង់បង្ហាញពីភាពចាំបាច់នៃការធ្វើតបៈ នៅពេលមានការរំលោភបំពានវិធានច្បាប់ទាំងនេះ ឬ ដោយគូសបញ្ជាក់ថា ព្រោះការបរិច្ចាគជាមធ្យោបាយសម្រាប់រំដោះអំពើបាប ហើយការរៀបរាប់អំពី*បាត្រ* ឬអ្នកសមនឹងទទួល គឺជាការចាំបាច់ដែរ។

**៣.** គោត. ជំពូក ៥ លេខ២២; ពោធ. ជំពូក២ លេខ៥, ២០។ ការប្រែនេះយកតាមលោកមេធ., គោវ. និងនារ.។ ការបកស្រាយដែលយកតាមលោកកុល្ល. គឺ 'គេត្រូវផ្ដល់ជូនព្រាហ្មណ៍ដ៏ឧត្ដុង្គឧត្ដមបំផុតនូវអាហារ ព្រមទាំងអំណោយនានា(នៅក្នុងបរិវេណធ្វើពិធីយញ្ញ)'។ លោកនន្ទ. អាន *ឯតេភ្យោ 'បិ* ជំនួ *ឯតេភ្យោ ហិ* ហើយគិតថា *ពហិវេទ* ត្រូវបកស្រាយដោយ *អបិ*ជូនមនុស្សដ៏ឧត្តមបំផុត ក្នុងចំណោមអ្នកមានកំណើតពីរដង ត្រូវគេផ្ដល់ សូម្បីនៅក្រៅពិធីយញ្ញក៏ដោយ'។ លោកនារ. ផ្ដល់ការបកស្រាយត្រឹមត្រូវអំពីកម្លាំងពាក្យ *ពហិវេទិ*ក្រៅពិធីយញ្ញ' លោកបន្ថែម *វេទ្យាំ តុ យាចិតំ ស៌វំ ឯវ ទេយំ*ប៉ុន្តែ នៅជិតអាស្រមព្រះអគ្គី គេត្រូវតែប្រគល់អ្វីៗជូនពួកគាត់ តាមការស្នើសុំ'។ ហេតុនេះ ន័យនៃកាព្យនេះគឺថា ស្នូមប្រាំបួននាក់ដូចមានរៀបរាប់នៅក្នុងកាព្យលេខ ១-២ តែងតែទទួលនូវអ្វីដែលពួកគាត់ស្នើសុំ និងស្នូមដទៃ សុំអាហារធម្មតា ប៉ុណ្ណោះ ប៉ុន្តែថា ប្រសិនបើពួកគាត់ សុំក្នុងពេលធ្វើពិធីយញ្ញ ទ្រព្យដទៃទៀតក៏ត្រូវផ្ដល់ជូនពួកគាត់ដែរ។

**៥.** អាប. ជំពូក២ លេខ១០, ៣។ កម្មវត្ថុនៃកាព្យនេះ ជាការហាមឃាត់ថា ទានទាំងឡាយត្រូវគេសុំ ឬជូនសម្រាប់គោលបំណងដូច្នេះ(គោវ., កុល្ល.)។ លោកមេធ., គោវ., នារ., រាឃ. និង K. លុបកាព្យនេះចោល។ កាព្យនេះទំនងជា មានការថែមថយ ដើម្បីបកស្រាយតម្រាវិធានខាងដើម។

៦- គេគួរតែផ្ដល់ទ្រព្យសម្បត្តិតាមលទ្ធភាពរបស់ខ្លួន ជូនព្រាហ្មណ៍ដែលចេះដឹងព្រះវេទ និងរស់នៅម្នាក់ឯង (ធ្វើដូច្នេះ) គេនឹងទទួលបានពរឡើងឋានសួគ៌ នៅជាតិក្រោយ។

៧- អ្នកដែលអាចធ្វើ (ការផ្គត់ផ្គង់) អាហារបានគ្រប់គ្រាន់ ដើម្បីចិញ្ចឹមអ្នកទាំងឡាយដែលនៅក្នុងបន្ទុករបស់ខ្លួន ក្នុងអំឡុងពេលបីឆ្នាំ ឬលើសពីនេះ គឺសមនឹងផឹកទឹកសោម។

៨- ប៉ុន្តែមនុស្សមានកំណើតពីរដង ដែលទោះជាមានទ្រព្យសម្បត្តិតិចក៏ដោយ នៅតែផឹកទឹកសោមបាន មិនបានទទួលប្រយោជន៍អ្វីពី(អំពើ)នោះទេ ថ្វីត្បិតគាត់ធ្លាប់ផឹកទឹកសោមពីមុនមកក្ដី។

៩- (ប្រសិនបើ) មនុស្សស្ដុកស្ដម្ភ(មានចិត្ត)សប្បុរសចំពោះមនុស្សផ្សេងៗ ខណៈដែលគ្រួសាររបស់គាត់កំពុងស្ថិតក្នុងស្ថានភាពមានវិបត្តិ នោះគុណធម៌ប្រឌិត មុនដំបូងនឹងជួយឱ្យគាត់ស្គាល់រសជាតិផ្អែម(នៃកិត្តិស័ព្ទ ប៉ុន្តែក្រោយមក) ធ្វើឱ្យគាត់លេបនូវថ្នាំពិស (នៃទណ្ឌកម្មនៅឋាននរក)។

១០- ប្រសិនបើ(មនុស្ស) ធ្វើអ្វីក៏ដោយដើម្បីសេចក្តីសុខរបស់ខ្លួនក្នុងជាតិមួយទៀត ដោយធ្វើឱ្យខូចប្រយោជន៍អ្នកដែលគាត់មានកាតព្វកិច្ចត្រូវទំនុកបម្រុង អំពើនោះផ្តល់នូវផលអាក្រក់សម្រាប់ខ្លួនគាត់ ទាំងខណៈពេលនៅមានជីវិត និងទាំងពេលចែកឋានទៅ។

១១- ប្រសិនបើការបូជាដែលធ្វើដោយអ្នកបូជា(មានកំណើតពីរដង) ជាពិសេសដោយព្រាហ្មណ៍ ត្រូវតែមិនបរិបូរណ៌ ដោយ(ការខ្វះ)លក្ខខណ្ឌមួយ ចំណែកឯព្រះរាជាត្រឹមត្រូវ គ្រងរាជ្យ,

១២- នោះរបស់(ដែលត្រូវការ)សម្រាប់ការបញ្ចប់ការបូជា អាចត្រូវគេចាត់ការ(បង្ខំ)គ្រួសារវៃស្យណាមួយដែលមានសត្វពាហនៈច្រើន (ប៉ុន្តែ)មិនចេះធ្វើការបូជា(សូម្បីបន្តិចបន្តួច) និងមិនដែលផឹកទឹកសោម;

១៣- (ឬ)អ្នកបូជាអាចយក(របស់ចំនួនពីរឬបីសម្រាប់ការបូជា)តាមសទ្ធារបស់ខ្លួន ពីផ្ទះរបស់សូទ្រៈ ព្រោះសូទ្រៈមិនរវល់រឿងបូជាទេ។

---

**៧.** វស. ជំពូក៨ លេខ១០; វិ. ជំពូក៥៩ លេខ៨; យញ្ញ. ជំពូក១ លេខ១២៤។ 'ផឹកទឹកសោម' គឺ 'ការធ្វើពិធីបូជាទឹកសោម ដើម្បីសម្រេចតាមសេចក្តីប្រាថ្នា'(មេធ., គោវ., កុល្ល., រាឃ.)។

**៨.** 'ទោះបីគាត់ធ្លាប់ផឹកទឹកសោមពីមុនក៏ដោយ' គឺ 'នៅឯពិធីយញ្ញបូជាទឹកសោម និត្យ(គឺប្រចាំឆ្នាំ សូមមើលជំពូក៤ លេខ ២៦, ជំពូក៦ លេខ១០)'(គោវ., កុល្ល., រាឃ.)។ អ្នកអធិប្បាយដដែល និងលោកមេធ. គូសបញ្ជាក់ថា កាព្យនេះ និងកាព្យពីមុន មិនហាមឃាត់ការធ្វើពិធីបូជាសោម និត្យទេ ប៉ុន្តែគេហៅពិធីនោះថា កាំយ។ អ្នកដែលធ្វើពិធីក្រោយនេះ ដោយគ្មានទ្រព្យចាំបាច់ ធ្វើឱ្យបាត់បុណ្យកុសលសម្រាប់អ្នកមុនផងដែរ។

**១១-១៥.** គោត. ជំពូក១៨ លេខ២៤-២៧។

**១១.** 'ខណៈដែលមានព្រះរាជាត្រឹមត្រូវគ្រងរាជ្យ' គឺ 'ព្រោះព្រះរាជាបែបនេះ នឹងមិនដាក់ទោសមនុស្ស ដែលប្រតិបត្តិតាមសាស្ត្រ'(មេធ., គោវ., កុល្ល., នារ.)។

**១២.** លោកនារ. និងនន្ទ. ពិចារណាថា 'ព្រះរាជា' គឺជា 'ភ្នាក់ងារ' ដែលគេយល់បានដោយសារកិរិយាស័ព្ទ 'អាចត្រូវយក'។ កិរិយាស័ព្ទក្រោយនេះអាស្រ័យលើសេចក្តីស្របគ្នាក្នុងរឿងមហាភារត ដែលបាទចុងក្រោយនៃកាព្យនេះ គឺ *យញ្ញាថំ បារថិវោ ហរេត*។ 'ការបូជា(បន្តិចបន្តួច)' គឺ 'បាកយញ្ញជាដើម'(កុល្ល.) ឬ 'មហាបូជាប្រាំ'(នារ.)។

១៤- ប្រសិនបើ(មនុស្សម្នាក់)មានគោមួយរយ មិនបង្កាត់ភ្លើងពិសិដ្ឋ ឬមនុស្សម្នាក់ដែលមានគោមួយពាន់ មិនផឹកទឹកសោម (អ្នកបូជា) អាចយកនូវ (អ្វីដែលគាត់ត្រូវការ) ពីផ្ទះរបស់មនុស្សទាំងពីរនោះដោយគ្មានការស្ទាក់ស្ទើរ ទោះបី (ពួកគេជាព្រាហ្មណ៍ក្តី ឬជាក្សត្រិយក្តី);

១៥- (ឬ)គាត់អាចយក(របស់នោះដោយបង្ខំ ឬការបន្លំ) ពីអ្នកដែលចេះតែទទួល មិនចេះឱ្យ ហើយដែលមិនព្រមឱ្យ ហេតុនេះកេរ្តិ៍ឈ្មោះរបស់(អ្នកទទួល)នឹងលាន់ឮកងរំពង ហើយកុសលរបស់គាត់នឹងកើនឡើង។

១៦- ដូចគ្នានឹងអ្នកដែលមិនបានបរិភោគអាហារប្រាំមួយមុខ (មួយពេល) អាចទទួលទាន(ម្ហូប)ទីប្រាំពីរពីមនុស្សដែលប្រហែសក្នុងការបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន (ទោះជាយ៉ាងណាក្តី) ដោយមិនបាច់ទុកថ្ងៃស្អែក,

១៧- ទោះជាយកពីក្តារបោកស្រូវក្តី ឬពីស្រែក្តី ឬពីផ្ទះក្តី ឬក៏ពីអ្វីដោយឱ្យតែគាត់រកឃើញ ប៉ុន្តែប្រសិនបើ(ម្ចាស់)សួរគាត់ គាត់ត្រូវតែឆ្លើយសារភាពប្រាប់គេពី(ការពិត និងមូលហេតុនៃអំពើនោះ)។

១៨- (ក្នុងកាលៈទេសៈបែបនេះ) ក្សត្រិយមិនត្រូវយកទ្រព្យរបស់ព្រាហ្មណ៍(មានគុណធម៌)ទេ ប៉ុន្តែអ្នកដែលកំពុងស្រេកឃ្លាន អាចយកធ្វើជារបស់ខ្លួនបាននូវទ្រព្យរបស់ទស្យុ ឬទ្រព្យរបស់អ្នកដែលមិនបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន។

១៩- អ្នកដែលយកទ្រព្យពីមនុស្សអាក្រក់ ហើយឱ្យវាទៅមនុស្សល្អ ធ្វើឱ្យខ្លួនក្លាយជាទូក ហើយចម្លងអ្នកទាំងពីរ(ឆ្លងសមុទ្រអកុសល)។

២០- ទ្រព្យរបស់អ្នកទាំងឡាយ ដែលធ្វើការបូជាដោយជំនឿស៊ុប បណ្ឌិតហៅទ្រព្យទេវតា ប៉ុន្តែទ្រព្យសម្បត្តិរបស់អ្នកដែលមិនធ្វើការបូជា ត្រូវហៅថាទ្រព្យរបស់*អាសុរ*។

២១- ចំពោះអ្នក(ដែលដោយមានហេតុផលដូចបានបញ្ជាក់ជូន យកទ្រព្យអ្នកដទៃធ្វើជារបស់ខ្លួន) ព្រះរាជាត្រឹមត្រូវនឹងមិនដាក់ទោសទេ ព្រោះ(ក្នុងករណីនោះ)ព្រាហ្មណ៍កំពុងឈឺចាប់ដោយការស្រេកឃ្លាន ដោយសារការមិនយកព្រះទ័យទុកដាក់របស់ក្សត្រិយ។

---

**១៤.** គោវ. គិតថា កាព្យនេះសំដៅដល់ក្សត្រិយប៉ុណ្ណោះ ចំណែកឯលោកមេធ., កុល្លូ., រាឃ. ថាកាព្យនេះសំដៅដល់ព្រាហ្មណ៍ផងដែរ។

**១៥.** គោវ., កុល្លូ. និងរាឃ. បកស្រាយ *អាទាននិត្យ*អ្នកដែលតែងតែយក' ថា 'ព្រាហ្មណ៍ដែលតែងតែទទួលអំណោយ' ចំណែកឯលោកមេធ. និងនារ. ឱ្យន័យពាក្យនេះ សំដៅដល់មនុស្សគ្រប់វណ្ណៈ ដែលប្រមូលសន្សំទ្រព្យសម្បត្តិទុកជានិច្ច។

**១៦-២៣.** គោត. ជំពូក១៨ លេខ២៨-៣២; យញ្ញ. ជំពូក៣ លេខ៤៣-៤៤។

**១៦.** 'ក្នុងពេលអាហារទីប្រាំពីរ' គឺ 'នៅថ្ងៃទីបួននៃការស្រេកឃ្លានរបស់គាត់'។

**១៨.** 'ទស្យុ' សូមមើលជំពូក១០ លេខ៤៥ ខាងលើ។ តាមលោកនារ. កាព្យនេះក៏សំដៅដល់ស្តេចដែរ។

**១៩.** 'ទាំងពីរ' គឺ 'អ្នកដែលគាត់យកទ្រព្យ ដោយការសង្គ្រោះបាបពីគេ (ឬ បញ្ហាការពារទ្រព្យរបស់គេ តាមលោកគោវ.) និងអ្នកទទួល'(កុល្លូ., គោវ.)។ លោកនន្ទ. លុបកាព្យ ១៩-២១។

**២១-២២.** សូមមើលជំពូក៧ លេខ១៣៤-១៣៥។

២២- ដោយបានដឹងប្រាកដអំពីចំនួនអ្នកនៅក្នុងបន្ទុកមនុស្សបែបនេះ និងដោយបានពិចារណាគ្រប់សព្វអំពីការចេះដឹងនិងការប្រព្រឹត្តរបស់គាត់ ព្រះរាជានឹងអនុញ្ញាតឱ្យគាត់ យកទ្រព្យនោះធ្វើជារបស់ខ្លួនផ្ទាល់ ដើម្បីចិញ្ចឹមជីវិតស្របតាមច្បាប់;

២៣- ហើយបន្ទាប់ពីចែកចំណែកឱ្យគាត់សម្រាប់ចិញ្ចឹមជីវិតរួចហើយ ព្រះរាជាត្រូវតែការពារគាត់គ្រប់វិធីទាំងអស់ ព្រោះទ្រង់នឹងទទួលបានពីមនុស្សដែលទ្រង់ការពារនេះ នូវចំណែកទីប្រាំមួយនៃកុសលផ្នែកព្រលឹងវិញ្ញាណរបស់គាត់។

២៤- ព្រាហ្មណ៍មិនត្រូវសុំទ្រព្យពីពួកសូទ្រៈសម្រាប់ការបូជាយញ្ញទេ ព្រោះអ្នកបូជាយញ្ញដែលបាន សុំ(ទ្រព្យពីមនុស្សបែបនេះ) បន្ទាប់ពីស្លាប់ នឹងកើត(ជាថ្មី)ជាចណ្ឌាល។

២៥- ព្រាហ្មណ៍ដែលបន្ទាប់ពីបានសុំទ្រព្យសម្រាប់ការបូជាយញ្ញមិនបានប្រើទ្រព្យទាំងអស់ (សម្រាប់គោលបំណងនោះ) ក្លាយជាសត្វត្មាតមួយប្រភេទឈ្មោះថា *ភាសៈ* ឬជាសត្វក្អែក អស់ពេលមួយរយឆ្នាំ។

២៦- មនុស្សមានបាប ដែលដោយសារចិត្តលោភ បំពានយកទ្រព្យរបស់ទេវតា ឬទ្រព្យរបស់ព្រាហ្មណ៍ នៅជាតិក្រោយ នឹងស៊ីអាហារសល់ពីសត្វត្មាត។

២៧- ក្នុងករណី គេមិនអាចធ្វើការបូជាទឹកសោម និងសត្វដូចបានបញ្ញត្តិទុក ចូរគេបូជា នៅពេលឆ្លងឆ្នាំដល់ឥសី វៃស្វានរី ដែលកំពុងធ្វើតបះ (សម្រាប់ការលះបង់)។

២៨- ប៉ុន្តែអ្នកមានកំណើតពីរដង ដែលមិនស្ថិតក្នុងគ្រាអាសន្ន បំពេញករណីយកិច្ចរបស់ខ្លួនស្របតាមច្បាប់សម្រាប់គ្រាអាសន្ន មិនបានទទួលកុសលសម្រាប់ខ្លួននៅជាតិក្រោយទេ នេះជាវាចារបស់(បណ្ឌិត)។

២៩- ដោយវិស្វ-ទេវ ដោយសាធ្យ និងដោយមហាបណ្ឌិតវណ្ណៈព្រាហ្មណ៍ ដែលមានការភ័យខ្លាចសេចក្តីវិនាសក្នុងគ្រាអាសន្ន ពួកគាត់បានបង្កើតតម្រាវិធាន(ពិសេស)សម្រាប់ជំនួស។

៣០- មនុស្សចិត្តអាក្រក់ ដែលអាចអនុវត្តតាមច្បាប់ទីមួយបាន រស់នៅតាមច្បាប់ទីពីរ មិនបានផលសម្រាប់ជាតិក្រោយទេ។

៣១- ព្រាហ្មណ៍ដែលចេះដឹងច្បាប់ មិនចាំបាច់រាយការណ៍ (បទល្មើស) ណាមួយថ្វាយព្រះរាជាទេ ដោយអំណាចផ្ទាល់របស់ទ្រង់ ព្រះរាជាអាចដាក់ទោសមនុស្សទាំងឡាយ ដែលធ្វើឱ្យទ្រង់អន្តរាយបាន។

---

**២៣.** សូមមើលជំពូក៨ លេខ៣០៤ ខាងលើ។

**២៤.** វិ. ជំពូក៥៩ លេខ១១; យញ្ញ. ជំពូក១ លេខ១២៧។

**២៥.** យញ្ញ. ជំពូក១ លេខ១២៧។ លោកមេធ., គោវ. និងនារ. និយាយថា 'ព្រាហ្មណ៍ដែល... មិនផ្តល់ទ្រព្យទាំងអស់នោះ (ជូនព្រាហ្មណ៍)'។

**២៦.** *បរ លោក*នៅភពមួយទៀត' តាមលោកគោវ. និងកុល្លូ. គឺ 'ក្នុងជាតិក្រោយរបស់ខ្លួន'។

**២៧.** វិ. ជំពូក៥៩ លេខ១០; យញ្ញ. ជំពូក១ លេខ១២៦។ *វៃស្វានរី ឥស្តិ* តាមលោកមេធ. គឺ ពិធីសាសនាដែលមានរៀបរាប់នៅក្នុងគម្ពីរ គ្ឫហ្យ-សូត្រ។ ចំពោះការបូជាស្រោតដូចបានរៀបរាប់នេះ សូមមើលជំពូក៤ លេខ២៥-២៦ខាងលើ។

**៣១.** កាព្យនេះ និងកាព្យបន្តបន្ទាប់ និរាករណ៍វិធានច្បាប់ដែលមានចែងក្នុងជំពូក ៩ លេខ២៩០ ខាងលើ។

៣២- អំណាចរបស់ខ្លួនផ្ទាល់ គឺធំធេងជាងអំណាចរបស់ព្រះរាជា ហេតុនេះព្រាហ្មណ៍អាចដាក់ទោសសត្រូវរបស់ខ្លួន ដោយអំណាចផ្ទាល់របស់ខ្លួនបាន។

៣៣- ចូរព្រាហ្មណ៍កុំមានការស្ទាក់ស្ទើរក្នុងការប្រើប្រាស់អត្ថបទពិសិដ្ឋ ដែលបង្ហាញដោយអថវ៌ន និងអង្គិរ តាមពិតសម្តីគឺជាអាវុធរបស់ព្រាហ្មណ៍ ដោយសារសម្តី គាត់អាចសម្លាប់សត្រូវខ្លួនបាន។

៣៤- ក្សត្រិយនឹងឆ្លងកាត់នូវជោគអាក្រក់ ដែលធ្លាក់មកលើទ្រង់ ដោយកម្លាំងនៃអាវុធរបស់ទ្រង់ វៃស្យ និងសូទ្រៈ ដោយកម្លាំងទ្រព្យរបស់ខ្លួន ប្រធានរបស់អ្នកមានកំណើតពីរដង ដោយការសូត្រធម៌ខ្សឹបៗ និងការបូជាអគ្គី។

៣៥- ព្រាហ្មណ៍ ត្រូវបានប្រកាសថា(ជា)អ្នកបង្កើត(លោក) អ្នកដាក់ទោស គ្រូ (ហេតុនេះ) ជាអ្នកបំពេញកុសលរបស់ (សត្វលោកទាំងអស់) ចូរមនុស្សទាំងឡាយកុំនិយាយអ្វីដែលមិនប្រសើរ និងកុំប្រើប្រាស់ពាក្យសម្តីឃោរឃៅដាក់ព្រាហ្មណ៍។

៣៦- ទាំងក្មេងស្រី ស្ត្រីវ័យក្មេង(ដែលបានរៀបការ) បុរសអ្នកចេះដឹងតិច មនុស្សភ្លើ មនុស្សដែលឈឺចាប់ធ្ងន់ធ្ងរ និងអ្នកដែលគ្មានពិសោធន៍ មិនអាចបូជាអគ្និហោត្របានទេ។

---

**៣២.** សូមមើលជំពូក៩ លេខ៣១៣-៣២១។

**៣៣.** 'ពាក្យពិសិដ្ឋ ដែលបង្ហាញដោយអថវ័ន និងអង្គិរៈ' គឺជាមន្តស្នេហ៍ និងមន្តគាថាដែលមាននៅក្នុងគម្ពីរអថ៌វ-វេទ។ នារ. អាន *អភិចារយេន*ដោយប្រើមន្តអាគមន៍' ជំនួស *អភិចារយេន* (មេធ., គោវ., កុល្ល., K.)។ នន្ទ. អាន *ស្រុតីរ អថ៌វាង្គិរសីះ កុរយាទ ឥតិ អភិចារតំ*។

**៣៤.** វស. ជំពូក២៦ លេខ១៦។

**៣៥.** ខ្ញុំអានតាមលោកមេធ., គោវ., នារ., រាឃ., នន្ទ. និង K. *មៃត្រោ* សម្រាប់ *មៃត្រី* និង *សុក្តាំ* សម្រាប់ *សុស្តាំ* (សំណៅបោះពុម្ព)។ អ្នកអធិប្បាយ យល់ផ្សេងគ្នាចំពោះការបកស្រាយបន្ទាត់ទីមួយ។ *វិធាតា* 'អ្នកបង្កើត'(លោក មេធ., នារ.) តាមលោកគោវ. និងកុល្ល. យល់ថា 'អ្នប្រតិបត្តិពិធីសាសនាតាមការបញ្ញត្តិ' តាមលោករាឃ. 'អាចធ្វើ មិនធ្វើ និងកែប្រែ' តាមលោកនន្ទ. 'អ្នកប្រតិបត្តិពិធីអាគម ជាដើម'។ *សាសិតា* 'អ្នកដាក់ទោស'(មេធ., កុល្ល., រាឃ.) គឺ 'អ្នកដាក់ដទៃ ព្រះរាជា' (មេធ.) ឬ 'កូនប្រុស សិស្សរបស់ខ្លួនជាដើម'(កុល្ល.) ត្រូវបានលោកនារ. ប្រែថា 'អ្នកអប់រំផ្នែកច្បាប់ពិសិដ្ឋ' ដោយនន្ទ. ថា 'មេគំនិត(សៃកមន្តអាគម)'។ *វក្តា* 'គ្រូ'(គោវ., នារ.) តាមលោកមេធ.ថា 'អ្នកផ្តល់ដំបូន្មានល្អៗ' តាមលោកកុល្ល. និងរាឃ. 'អ្នកបរិយាយច្បាប់ពិសិដ្ឋ'។ ការបកស្រាយរបស់លោកគោវ. និងកុល្ល. អនុញ្ញាតឱ្យ Sir W. Jones អនុម័តយកការប្រែថា 'អ្នកដែលប្រតិបត្តិករណីយកិច្ចរបស់ខ្លួន... ត្រូវគេហៅថាព្រាហ្មណ៍យ៉ាងត្រឹមត្រូវ'។ ដូចគ្នានឹងបន្ទាត់ទីពីរ លោកមេធ. ផ្តល់ការបកស្រាយពីរយ៉ាង។ ទីមួយ លោកប្រែថា 'ចំពោះគាត់ គឺ នៅពេលដែលគ្រាន់ប្រើមន្តអាគមចូល មនុស្សកុំនិយាយអ្វីដែលមិនសមរម្យ គឺគាត់មិនត្រូវដាក់ទោសគេ មិនត្រូវប្រើពាក្យសម្តីឆ្កាំឆ្គង គឺក្រើនរំលឹក ឬស្តីបន្ទោសគាត់យ៉ាងធ្ងន់ធ្ងរ'។ គោវ. និងកុល្ល. យលស្របតាមការបកស្រាយនេះ ប៉ុន្តែលុបចោលការបញ្ជាក់ 'ពេលដែលគាត់ប្រើមន្តអាគម'។ តាមការប្រែទីពីររបស់លោកមេធ. បន្ទាត់នេះមានដំបូន្មាន ដែលនិយាយអំពីមនុស្សគ្រប់វណ្ណៈទាំងអស់ មិនធ្វើឱ្យព្រាហ្មណ៍ ខឹងឬរំខានដល់ព្រាហ្មណ៍ទេ ហើយគំនិតនេះត្រូវលោករាឃ. និងនន្ទ. ដែលបកស្រាយ *អកុសលំ* ដែលមិនសមរម្យ' ដោយ *អនិស្តំ*អ្វីដែលគេមិនអាចទទួលយកបាន'។ អំណានរបស់លោកនារ. ទំនងជាយល់ផ្សេង ទៅវិញ។ លោកសរសេរ *កុរយាត* ជំនួស *ព្រូយាត* ហើយបកស្រាយឃ្លាទីមួយថា 'ចូរមនុស្សកុំធ្វើអ្វី ដែលមិនសមរម្យ ចំពោះព្រាហ្មណ៍' គឺអ្វីដែលមិនសមគួរ ដូចជាការបង្អប់បួសស្នាមរូបកាយ។ នៅក្នុងអនុប្រយោគទីពីរ លោកអាន *សុក្តំ* (សំណៅបោះពុម្ព) ដែលលោកបកស្រាយ *បរុសិតំ* 'ខូច' ប៉ុន្តែគាត់មិនបញ្ជាក់អត្ថបទផ្សេងរបស់គាត់ទេ។

**៣៦-៣៧.** អាប. ជំពូក២ លេខ១៥, ១៨-១៩; គោត. ជំពូក២ លេខ៤; វស. ជំពូក២ លេខ៦ សូមមើលជំពូក២ លេខ

៣៧- ព្រោះ(មនុស្ស)ដែលធ្វើការបូជាអគ្គីបែបនេះ ព្រមទាំងអ្នកដែលជាម្ចាស់ពិធី(អគ្និហោត្រ) នឹងធ្លាក់នរក ហេតុនេះអ្នកដែលបូជា(សម្រាប់អ្នកដទៃ) ត្រូវតែមានជំនាញក្នុង(ការធ្វើពិធី)វេតាន ហើយចេះព្រះវេទទាំងស្រុង។

៣៨- ព្រាហ្មណ៍ដែល ទោះជាមានទ្រព្យច្រើនក្តី ក៏មិនត្រូវផ្តល់ថ្លៃឈ្នួលសម្រាប់ការធ្វើពិធីអគ្និយាធេយជាសត្វសេះពិសិដ្ឋសម្រាប់ប្រជាបតិ គឺ(ស្មើគ្នានឹងអ្នក) ដែលមិនបានរក្សាភ្លើងពិសិដ្ឋ។

៣៩- ចូរអ្នកដែលមានជំនឿ និងគ្រប់គ្រងចិត្តវិញ្ញាណរបស់ខ្លួនបានធ្វើនូវអំពើបុណ្យផ្សេងៗទៀត ប៉ុន្តែចូរអ្នកកុំធ្វើការបូជា ដែលអ្នកផ្តល់ថ្លៃឈ្នួលតិចជាង(តាមការបញ្ញត្តិ)។

៤០- សរីរាង្គ(វិញ្ញាណ និងធ្វើសកម្មភាព) កិត្តិយស (ពរជ័យឡើង)ឋានសួគ៌ អាយុវែង កិត្តិស័ព្ទ កូនចៅ និងគោក្របី ត្រូវវិនាសដោយសារពិធីយញ្ញ ដែលមានការផ្តល់ថ្លៃឈ្នួលពិធីតិច(ពេក) ហេតុនេះមនុស្សដែលមានមធ្យោបាយតិចតួច មិនគួរធ្វើការបូជា(ស្រោត្រ)ទេ។

៤១- ព្រាហ្មណ៍ដែលជាអគ្និហោត្រិន មិនយកចិត្តទុកដាក់រក្សាអគ្គីពិសិដ្ឋ នឹងធ្វើតបៈលាងបាបនៅពេលយប់ ក្នុងអំឡុងពេលមួយខែ ព្រោះ(អំពើល្មើស)នោះគឺស្មើនឹងការធ្វើឃាតកូនប្រុស។

៤២- អ្នកទាំងឡាយណាដែលទទួលទ្រព្យពីសូទ្រៈ (ហើយប្រើប្រាស់ទ្រព្យនោះ)បូជាអគ្និហោត្រ ជាអាចារ្យរៀបចំពិធីផ្លូវការឱ្យសូទ្រៈ (ហេតុនេះ) ត្រូវទទួលការរិះគន់ក្នុងចំណោមអ្នកដែលសូត្រព្រះវេទ។

៤៣- ការយកជើងរបស់ខ្លួនជាន់ក្បាលមនុស្សភ្លើដែលបូជាភ្លើង(ដែលរក្សាដោយចំណាយរបស់សូទ្រៈអ្នកផ្តល់(ទ្រព្យ) តែងតែរួចផុតពីទុក្ខសោករបស់ខ្លួន(នៅក្នុងជាតិក្រោយ)។

៤៤- បុរសដែលលុបចោលកិច្ចតាមការបញ្ញត្តិ ឬធ្វើអំពើខុសឆ្គង ឬជាប់ជំពាក់នឹងកាមតម្រេក ត្រូវធ្វើតបៈលាងបាប។

---

១៧២; ជំពូក៥ លេខ១៥៥; ជំពូក៩ លេខ១៨។ ពិធី*វិតាន* ជាពិធីដែលគេរៀបចំធ្វើឡើងនៅក្នុង*វិតាន* អគ្គីពិសិដ្ឋបី។ ហេតុនេះអាចនិយាយថា អគ្និហោត្រនៅទីនេះ គឺជាស្រោត អគ្និហោត្រ។

**៣៨.** ការបកប្រែ*ប្រាជាបត្យ* 'ពិសិដ្ឋចំពោះប្រជាបតិ' យកតាមលោកគោវ., កុល្ល., នារ. និងរាឃ.។ លោកមេធ. និយាយថា គេអាចប្រើវិសេសស័ព្ទគ្រាន់តែសម្រាប់ការសរសើរប៉ុណ្ណោះ ឬអាចមានន័យថា សត្វជាសភាវៈមិនល្អក៏បាន និងមិនអាក្រក់ក៏បាន ឬថា ជាឃ្លាដែលបានមនុស្សបច្ចុប្បន្ន។ លោកនន្ទ. បកស្រាយថា 'ដើម្បីផ្តល់ជូនអាចារ្យព្រាហ្មណ៍'។

**៤០.** គោវ. និងកុល្ល. បកស្រាយចំណុចនេះ និងជំពូក៤ លេខ៩៤ខាងលើ *យសះ* 'កិត្តិយស' ដោយ 'កេរ្តិ៍ឈ្មោះល្អ ក្នុងពេលខ្លួននៅមានជីវិត' និង *កីរតិម*កិត្តិនាម' ដោយ 'កិត្តិនាមបន្ទាប់ពីស្លាប់'។ លោកនារ. ប្រែពាក្យខាងដើមថា 'ដែលអ្នកដទៃស្គាល់ចំពោះគុណធម៌របស់គេ' និងពាក្យក្រោយថា 'ដែលអ្នកដទៃកោតសរសើរ'។

**៤១.** គោត. ជំពូក២២ លេខ៣៤; វស. ជំពូក១ លេខ១៨; ជំពូក២១ លេខ២៧; វិ. ជំពូក៥៤ លេខ១៣។ នន្ទ. បកស្រាយ *វីរៈ* 'កូនប្រុស' (គោវ., កុល្ល., នារ., រាឃ.) ដោយក្សត្រិយ ហើយលោករាឃ. និយាយថា ពាក្យនេះអាចមានន័យថា 'អាទិទេព'ក៏បាន។

**៤២.** សូមមើលជំពូក១១ លេខ២២៤។

**៤៣.** លោកនន្ទ. អានបន្ទាត់ទី១ផ្សេងទៅវិញថា *បាបានាំ សតតំ តេសាំ អគ្នី សូទ្រស្យ ជុហ្វតាំ* ប៉ុន្តែន័យទូទៅនៅដដែល។

**៤៤-៤៦.** គោត. ជំពូក១៩; វស.ជំពូក២០ លេខ១-៣; ជំពូក២២; ពោធ. ជំពូក៣ លេខ១០; យញ្ញ.ជំពូក៣ លេខ២១៩, ២២៦។

៤៥- បណ្ឌិត (ទាំងអស់) បញ្ញត្តិពីអំពើបាប ដែលបានប្រព្រឹត្តដោយអចេតនា បណ្ឌិតខ្លះប្រកាសដោយផ្អែកលើកសិណនៃអត្ថបទបង្ហាញស្រាប់ (ថាគេអាចធ្វើបាន) សូម្បីជា(បទល្មើស)ដោយចេតនាក៏ដោយ។

៤៦- អំពើបាបដែលបានប្រព្រឹត្តដោយអចេតនា ត្រូវបានលុបលាងដោយការសូត្រអត្ថបទព្រះវេទ ប៉ុន្តែបាបដែល (មនុស្ស) ប្រព្រឹត្តដោយចេតនាភ្លីភ្លើរបស់ខ្លួន ដោយការធ្វើតបៈលាងបាប (តាមរបៀបពិសេស)ផ្សេងៗ។

៤៧- បុរសមានកំណើតពីរដង ដោយបានទទួលខុសត្រូវធ្វើតបៈ ព្រោះតាម(កម្រិតនៃ)ផលកម្មឬតាមកម្រិតនៃ(អំពើ) ដែលបានប្រព្រឹត្តកាលពីជាតិមុន មិនត្រូវរួមសង្វាសជាមួយបុរសល្អ នៅមុនពេលបានធ្វើតបៈលាងបាប។

៤៨- បុរសអាក្រក់មួយចំនួនទទួលទុក្ខផ្លាស់ប្តូររូប (ពីកំណើត) របស់ខ្លួន ដោយសារអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តក្នុងជាតិនេះ ហើយមួយចំនួនដោយសារអំពើទាំងឡាយ ដែលបានប្រព្រឹត្តកាលពីជាតិមុន។

៤៩- អ្នកដែលលួចមាស(របស់ព្រាហ្មណ៍) មានជំងឺក្រចក អ្នកផឹក(គ្រឿងស្រវឹងហៅ)សុរា ធ្មេញខ្មៅ; អ្នកសម្លាប់ព្រាហ្មណ៍ កើតរបេងសួត; អ្នកបំពានលើគ្រែរបស់គ្រូ កើតជំងឺស្បែក;

៥០- អ្នកនាំពាក្យ ឈឺច្រមុះស្អុយ; អ្នកនិយាយមួលបង្កាច់ មានដង្ហើមស្អុយ; អ្នកលួចធញ្ញជាតិ មានវិការអវៈយវៈ; អ្នកដែលធ្វើឱ្យខូច(ធញ្ញជាតិ) មានអវៈយវៈលើស;

៥១- អ្នកលួច(អាហារ)ឆ្អិន កើតជំងឺពិបាករំលាយអាហារ; អ្នកលួចពាក្យ(ព្រះវេទ) កើតជំងឺគ; អ្នកលួចខោអាវ កើតឃ្លង់ស; អ្នកលួចសេះ កើតជំងឺខ្វកជើង។

៥២- អ្នកលួចចង្កៀងនឹងខ្វាក់; អ្នកដែលពន្លត់ចង្កៀងនឹងមានភ្នែកម្ខាង; ការបង្ករបួសស្នាម (ដល់សត្វលោក) ត្រូវកើតជំងឺទូទៅច្រើន; អ្នកផិតក្បត់ (នឹងកើតជំងឺ)ហើមដៃជើង។

---

**៤៥.** អត្ថបទព្រះវេទ ដែលបញ្ញត្តអំពីការធ្វើតបៈចំពោះបទល្មើស ដែលបានប្រព្រឹត្តដោយចេតនា ត្រូវបានស្រង់សម្ដីដោយគោត. ជំពូក១៩ លេខ៧-១០។ អ្នកអធិប្បាយ ក៏លើកហេតុផលសំអាង អៃតរេយ-ព្រាហ្មណ៍ ជំពូក៧ លេខ២៨។

**៤៥.** *ទៃវាត*តាម(កម្រិត)នៃផលកម្ម' គឺ 'ដោយគិតពីការធ្វេសប្រហែស'(មេធ., នារ., កុល្លូ., រាឃ.)។ លោកមេធ. លើកឡើងនូវពាក្យផ្សេង *មោហាត* 'ដោយមាយារបស់ចិត្ត'។ 'ដោយ(អំពើ)ដែលបានប្រព្រឹត្តកាលពីជាតិមុន' គឺ 'ប្រសិនបើគេមានធ្មេញខ្មៅ ឬវិការរូបកាយផ្សេងទៀត ដោយសារតែបានប្រព្រឹត្តអំពើឧក្រិដ្ឋកាលពីជាតិមុន'។

**៤៨-៥៤.** វស. ជំពូក១ លេខ១៨; ជំពូក២០ លេខ៦; ជំពូក២១ លេខ៤៣-៤៤; វិ. ជំពូក៦៥; យញ្ញ. ជំពូក៣ លេខ២០៧-២១៥។

**៥១.** 'អ្នកលួចពាក្យ(ព្រះវេទ)' គឺ 'អ្នកដែលរៀនព្រះវេទ ដោយគ្មានការអនុញ្ញាត ដោយការស្តាប់បុរសដទៃ ដែលកំពុងសូត្រព្រះវេទ'(គោវ., កុល្លូ., រាឃ.) តាមលោកនារ. គឺ 'អ្នកលួចពាក្យគេ'។

**៥២.** គោវ., នារ., នន្ទ. និង K. លុបកាព្យនេះចោល ហើយលោករាឃ.និយាយថា នៅក្នុងសំណៅបោះពុម្ពខ្លះ មានពាក្យ *ក្វាបិ*។

៥៣- ហេតុនេះ ដោយសារផលនៃ(ទោស)ឧក្រិដ្ឋពីមុន កើតជាមនុស្សល្ងីល្ងើ គ ខ្វាក់ ថ្លង់ និងខូចទម្រង់កាយ ដែលទទួលនូវការស្អប់ខ្ពើមពីមនុស្សល្អ។

៥៤- ដូច្នេះគេត្រូវតែធ្វើតបៈលាងបាប ដើម្បីបន្សុទ្ធកម្ម ព្រោះអ្នកដែលបានលុបលាងបាបទាំងនោះទេ នឹងកើត(ជាតិក្រោយ)ដោយមានស្នាមមិនល្អ។

៥៥- ការសម្លាប់ព្រាហ្មណ៍ ការផឹក(គ្រឿងស្រវឹង ហៅថា)សុរា ការលួច(មាសរបស់ព្រាហ្មណ៍) ការផិតក្បត់ជាមួយភរិយារបស់គ្រូ និងការសេពគប់ជាមួយ(ជនល្មើស)បែបនេះ ពួកគេប្រកាសថា (ជា)អំពើបាបធ្ងន់ធ្ងរ(មហាបាតក)។

៥៦- ការក្លែងចាត់ទុកខ្លួនឯងថាមានកំណើតខ្ពស់ ការផ្តល់ព័ត៌មានមិនពិតថ្វាយព្រះរាជា(ស្តីពីអំពើឧក្រិដ្ឋ) និងការចោទប្រកាន់គ្រូរបស់ខ្លួនខុសពីការពិត (គឺជាបទល្មើស) ស្មើនឹងការសម្លាប់ព្រាហ្មណ៍។

៥៧- ការបំភ្លេចព្រះវេទ ការជេរប្រមាថព្រះវេទ ការផ្តល់កសិណមិនពិត ការសម្លាប់មិត្ត ការទទួលទានអាហារហាមឃាត់ ឬ(ការលេបសារធាតុ)ដែលមិនសមជាអាហារ ជា(បទល្មើស)ប្រាំមួយ ស្មើនឹងការផឹកសុរា។

៥៨- ការលួចបញ្ញើ ឬមនុស្ស សេះ និងប្រាក់ ដីធ្លី ពេជ្រ និងត្បូង(ផ្សេងទៀត) ត្រូវគេប្រកាសថា ស្មើនឹងការលួចមាស(របស់ព្រាហ្មណ៍)។

៥៩- ការរួមសង្វាសជាមួយបងប្អូនស្រីម្តាយតែមួយ ជាមួយស្រីក្រមុំ (មិនទាន់រៀបការ) ជាមួយស្ត្រីវណ្ណៈទាប ជាមួយភរិយារបស់មិត្ត ឬរបស់កូនប្រុស ពួកគេប្រកាសថាស្មើនឹងបទល្មើសបំពានគ្រែរបស់គុរុ។

---

**៥៣.** ខ្ញុំអានតាមលោកនារ., នន្ទ. និងK. *កម៌ារសេសេណា* ជំនួស *កម៌សេសេណា*(អត្ថបទបោះពុម្ព)។ ការបកស្រាយរបស់លោកមេធ., គោវ. និងកុល្លូ. ដូចមានក្នុងអំណានខាងដើម។

**៥៥-៧១.** អាប. ជំពូក១ លេខ២១, ៧-១៩; គោត. ជំពូក២១ លេខ១-១២; វស. ជំពូក១ លេខ១៩-២៣; ពោធ. ជំពូក២ លេខ២, ១-៨; ១២-១៣; ១៥-១៦; វិ. ជំពូក៣៤ លេខ១; ជំពូក៣៥-៣៨លេខ៦; ជំពូក៣៩-៦២; យញ្ញ. ជំពូក៣ លេខ២២៧-២៤២។

**៥៥.** សូមមើលជំពូក៩ លេខ ២៣៥ ខាងលើ។

**៥៦.** *គុរុស ចាលីកនិព៌ន្ទះ*ការចោទប្រកាន់គ្រូរបស់ខ្លួនដោយមិនពិត՛(មេធ., គោវ., កុល្លូ.) តាមលោកមេធ. ក៏អាចមានន័យថា ՝ការប្រព្រឹត្តខុសច្បាប់ជាមួយគ្រូ՛។ លោកនារ. និងនន្ទ. បកស្រាយថា ՝ការរឹងទទឹងក្នុងការធ្វើអ្វីដែលគ្រូមិនពេញចិត្ត՛។

**៥៧.** *គ៌ហិតានាទ្យ*អាហារហាមឃាត់ និង(សារធាតុ)មិនសមសម្រាប់អាហារ՛(គោវ., កុល្លូ., រាឃ.) តាមលោកមេធ. មានន័យថា ՝អាហារហាមឃាត់ និងអាហារដែលគេមិនគួរទទួលទាន՛ តាមលោកនារ. និងនន្ទ. ថា ՝អាហារដែលសៅហ្មងដោយការប៉ះពាល់របស់មនុស្ស ឬអ្វីដែលមិនបរិសុទ្ធ ហើយដូចជាដោយសារលក្ខណៈរបស់អាហារ មិនសមនឹងទទួលទានឧទាហរណ៍ដូចជាខ្ទឹមស՛។

**៥៩.** អ្នកអធិប្បាយគូសបញ្ជាក់ថា ទោះជាអំពើឧក្រិដ្ឋដូចបានរៀបរាប់ក្នុងកាព្យលេខ៥៦-៥៩ ត្រូវបញ្ជាក់ថាស្មើនឹងអំពើបាបធ្ងន់ធ្ងរ ការធ្វើតបៈមិនសុទ្ធតែដូចគ្នារហូតនោះទេ ប៉ុន្តែជារឿយៗមានស្ថានទម្ងន់ស្រាលជាង។

៦០- ការសម្លាប់គោច្រើន ការបូជាអ្នកដែលមិនសមនឹងបូជា ការផិតក្បត់ ការលក់ខ្លួន ការបោះបង់គ្រូម្តាយ ឬកូនប្រុសរបស់ខ្លួន ការបោះបង់ការសិក្សាព្រះវេទ(ប្រចាំថ្ងៃ) និងការធ្វេសប្រហែសមិនរក្សាភ្លើង(ពិសិដ្ឋក្នុងគ្រួសារ),

៦១- ការអនុញ្ញាតឱ្យប្អូនប្រុសខ្លួនរៀបការមុន ការរៀបការមុនបងប្រុសខ្លួន ការឱ្យកូនស្រី ឬការបូជាឱ្យ(បងប្អូនប្រុស)ក្តី,

៦២- ការធ្វើឱ្យខូចស្រីក្រមុំ ការចងការប្រាក់យកការប្រាក់ខ្ពស់ ការក្បត់ពាក្យសច្ចា ការលក់ផុងទឹកសួនច្បារ ភរិយារបស់ខ្លួន ឬកូនខ្លួន,

៦៣- ការរស់នៅដូចវ្រាត្យ ការបោះបង់ញាតិ ការបង្រៀន(ព្រះវេទ)ដើម្បីប្រាក់ឈ្នួល ការសិក្សា(ព្រះវេទ)ពីគ្រូបង្រៀនស៊ីឈ្នួល និងការលក់ទំនិញ ដែលមិនគួរលក់,

៦៤- ការគ្រប់គ្រងអណ្តូងរ៉ែ (ឬរោងចក្រ)គ្រប់ប្រភេទ ការធ្វើការងារគ្រឿងយន្តធំៗ ការធ្វើឱ្យរបួសរុក្ខជាតិ (មានជីវិត) ការចិញ្ចឹមជីវិតដោយ (ប្រាក់ចំណូល) របស់ភរិយាខ្លួន ដោយអំពើអាបធ្មប់ (ដោយការបូជាយញ្ញ) និងការងារមន្តអាគម (ជាចម្បង) ជាដើម,

## ការចាត់ថ្នាក់បទល្មើស

៦៥- ការកាប់រំលំដើមឈើស្រស់សម្រាប់ធ្វើអុស ការធ្វើអំពើសម្រាប់តែប្រយោជន៍ផ្ទាល់ខ្លួន ការទទួលទានអាហារហាមឃាត់,

---

**៦០.** ‛ការលក់ខ្លួន′ គឺ ‛ធ្វើជាទាសករដើម្បីលុយ′(មេធ.) តែនារ.ថា ‛សំដៅដល់ពួកអារ្យ័នប៉ុណ្ណោះ′។ លោកមេធ. សរសេរតាមអំណានមួយទៀត *បារទាយំ អវិក្រយះ* ‛ការផិតក្បត់ និងការលក់ទំនិញហាមឃាត់′។ លោកមេធ. និងនារ. និយាយថា ‛ការភ្លេចអត្ថបទពិសិដ្ឋ សម្រាប់ការសូត្រផ្ទាល់ខ្លួនរាល់ថ្ងៃ′ ហើយលោកមេធ. បន្ថែមថា ព្រោះបទល្មើសដដែល ត្រូវបាននិយាយនៅក្នុងកាព្យលេខ ៥៧ ខាងលើ ‛ការមិនយកចិត្តទុកដាក់ព្រះវេទ′ អាចត្រូវចាត់ទុកស្មើនឹងបទឧក្រិដ្ឋ មហាបាតកក៏បាន ឬឧបបាតក។ លោកនារ. ឲ្យន័យ ‛ភ្លើង′សំដៅដល់ភ្លើងស្រោតដ៏ពិសិដ្ឋបី។

**៦២.** ‛ការបំពានពាក្យសច្ចា′ គឺ ‛ពាក្យសច្ចាណាក៏ដោយដែលបានសន្យាដោយស្ម័គ្រចិត្ត′(មេធ., នារ.) តាមលោកគោវ., កុល្ល. និងរាឃ. ថា ‛ការបំពានពាក្យសច្ចាក្នុងការសិក្សា′។

**៦៣.** ‛ការរស់នៅដូចជាវ្រាត្យ′ សូមមើលជំពូក១០ លេខ២០។ ‛ការបោះបង់ញាតិ′ គឺ ‛មិនឧបត្ថម្ភគាត់នៅពេលមានទុក្ខលំបាក ទោះបីជាគាត់មានលុយគ្រប់គ្រាន់ធ្វើដូច្នេះបានក៏ដោយ′(មេធ.)។ លោកមេធ. ប្រែពាក្យ *ពាន្ធវ* ក្នុងន័យ ‛សាច់ញាតិខាងម្តាយ′ ហើយយល់ថា គឺរួមទាំងម្តាយ បងប្អូនស្រី ម្តាយមីងជាដើម ចំណែកឯអ្នកអធិប្បាយផ្សេងទៀត ប្រែពាក្យនេះក្នុងន័យទូលាយជាង។

**៦៤.** *មហាយន្ត្រប្រវត៌ន*ការធ្វើការងារគ្រឿងយន្តធំៗ′ ឧ.ទា. ‛ការសាងសង់ទំនប់ឆ្លងកាត់ទន្លេ ដើម្បីទប់ទឹក′(មេធ., គោវ., កុល្ល., រាឃ., K.) តាមលោកនារ. មានន័យថា ‛ធ្វើម៉ាស៊ីនសម្រាប់សម្លាប់សត្វធំៗ ដូចជាជ្រូកព្រៃ′ តាមលោកនន្ទ. ‛(ការធ្វើ)ម៉ាស៊ីនធំៗ ដូចជារោងចក្រស្កស′។ *ស្ត្រយាជីវ* ‛ការចិញ្ចឹមជីវិតដោយសារ(ចំណូលរបស់)ភរិយាខ្លួន គឺដោយឱ្យនាងចេញទៅធ្វើការ(នារ., នន្ទ.) ឬដោយបង្ខំឱ្យនាងធ្វើជាពេស្យា′(កុល្ល.) តាមលោកមេធ.ថា ‛ការចិញ្ចឹមជីវិតដោយសារ(ទ្រព្យដោយឡែករបស់) ភរិយាខ្លួន′ តាមលោករាឃ. ថា ‛ការរស់នៅពឹងផ្អែកលើ (ថវិកាដែលបានពីការលក់ភរិយាខ្លួន′។ លោកនន្ទ. អាន *ហឹស្រោសធិស្ត្រយុបាជីវៈ* ការចិញ្ចឹមជីវិតដោយពឹងលើ (ថវិកាដែលបានពីការលក់រុក្ខជាតិពុល ឬពឹងលើ (ចំណូលរបស់) ភរិយាខ្លួន′។

**៦៥.** ‛ការធ្វើអំពើដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ′ គឺ ‛ការធ្វើអាហារសម្រាប់តែខ្លួនឯងជាដើម′(មេធ., នារ., កុល្ល.,

៦៦- ការធ្វេសប្រហែសមិនរក្សាភ្លើងពិសិដ្ឋ ចោរកម្ម ការសងបំណុល(បី) ការសិក្សាគម្ពីរអាក្រក់ និងការអនុវត្ត (សិល្បៈ) រាំរែក និងចម្រៀង,

៦៧- ការលួចធញ្ញជាតិ លោហធាតុសំខាន់ៗ ឬសត្វពាហនៈ ការរួមសង្វាសជាមួយស្ត្រីដែលផឹកគ្រឿងស្រវឹង ការសម្លាប់ស្ត្រី សូទ្រៈ វៃស្យ ឬក្សត្រិយ និងការគ្មានជំនឿលើអាទិទេព (គឺសុទ្ធជា) បទល្មើសតូចតាច ដែលនាំឱ្យបាត់បង់វណ្ណៈ(ឧបបាតក)។

៦៨- ការផ្តល់ការឈឺចាប់ឱ្យព្រាហ្មណ៍(ដោយការវាយដំ) ការហិតនូវរបស់ដែលមិនគួរហិត ឬហិតគ្រឿងស្រវឹង ការឆបោក និងបទល្មើសខុសពីធម្មតាចំពោះមនុស្ស ត្រូវគេប្រកាសថាបណ្តាលឱ្យបាត់បង់វណ្ណៈ(ជាតិភ្រំស)។

៦៩- ការសម្លាប់សត្វលា សេះ អូដ្ឋ ក្តាន់ ដំរី ពពែ ចៀម ត្រី ពស់ ឬក្របី ត្រូវគេដឹងថាធ្វើឱ្យ (ជនល្មើស) ធ្លាក់ដល់វណ្ណៈចម្រុះ(សំការីការណៈ)។

៧០- ការទទួលអំណោយពីមនុស្សត្រូវបណ្តាសា ការធ្វើជំនួញ ការបម្រើសូទ្រៈ និងការនិយាយមិនពិតធ្វើឲ្យ(ជនល្មើស) មិនសមនឹងទទួលអំណោយ(អបាត្រ)។

៧១- ការសម្លាប់សត្វល្អិត ទោះតូច ឬធំ ឬសត្វបក្សី ការទទួលទានអ្វីដែលដាក់គ្រឿងស្រវឹង ការលួចផ្លែឈើ អុស ឬផ្កា (ជាបទល្មើស) ដែលនាំឱ្យមិនបរិសុទ្ធ(មលាវហ)។

៧២- (ឥឡូវនេះ)ចូររៀនទាំងស្រុងអំពីការធ្វើតបៈទាំងឡាយ ដែលបទល្មើសទាំងអស់ដូចបានរៀបរាប់ អាចលុបលាងទោសបាន។

៧៣- ចំពោះការធ្វើបន្សុទ្ធកម្មរបស់ខ្លួន អ្នកសម្លាប់ព្រាហ្មណ៍ត្រូវធ្វើខ្ទមនៅក្នុងព្រៃ ហើយស្នាក់នៅក្នុង(ខ្ទមនោះ)រយៈពេល ១២ឆ្នាំ ហើយចិញ្ចឹមជីវិតដោយទេយ្យទាន និងយកលលាដ៍ក្បាលខ្មោចធ្វើជាទង់ជ័យ;

---

នន្ទ., រាឃ.); សូមមើលជំពូក៣ លេខ១១៨ ខាងលើ។ ដោយ*និន្ទិតាន្ន*អាហារហាមឃាត់' លោកមេធ.យល់ដូចគ្នានឹងកាព្យ លេខ៥៧ខាងលើ; លោកកុល្ល. ថា 'អាហារហាមឃាត់ ដូចជាខ្ទឹមស'; លោកនារ., រាឃ. និងនន្ទ. ថា 'អាហារដែលផ្តល់ឱ្យ ដោយមនុស្សដែលមិនគួរទទួល ឧទាហរណ៍ដោយព្រះរាជា អ្នកល្បែងជាដើម'។ លោកមេធ. និងកុល្ល. បញ្ជាក់យ៉ាងច្បាស់ថា ប្រសិនបើគេបរិភោគអាហារបែបនេះម្តង និងដោយអចេតនា បទល្មើសស្មើនឹងឧបបាតក ប៉ុន្តែក្នុងករណីធ្ងន់ធ្ងរបំផុត ស្មើនឹងមហាបាតក។

**៦៦.** 'ចោរកម្ម' គឺ 'នូវវត្ថុមានតម្លៃ'(កុល្ល.) 'លើកលែងមាស និងរបស់ដទៃទៀត ដែលមានបញ្ញាក់ជាពិសេស' (មេធ., រាឃ.) ឧ.ទា. 'នូវសម្លៀកបំពាក់'(នារ.)។ ចំពោះបំណុលបី សូមមើល វស. ជំពូក១១ លេខ៤៥។ 'គម្ពីរអាក្រក់' គឺ 'សៀវភៅទាំងឡាយរបស់ចារវាក, និគ្រន្ថ (ជេន, មេធ.)' ឬ 'របស់ឥសីទូទៅ'(នារ.)។

**៦៧.** 'សត្វពាហនៈ' គឺលើសពីគោក្របី សូមមើលកាព្យលេខ ៦០ ខាងលើ។

**៦៨.** 'អ្វីដែលមិនគួរហិត' គឺ 'ខ្ទឹមស ខ្ទឹមបារាំង លាមកជាដើម'(មេធ., គោវ., កុល្ល., នារ.)។

**៧០.** 'មនុស្សត្រូវបណ្តាសា' គឺ អ្នកដែលមិនត្រូវទទួលអំណោយ សូមមើលជំពូក៤ លេខ ៨៤ខាងលើ។

**៧៣-៨៧.** អាប. ជំពូក១ លេខ២៤, ១០-២៥; ២៥, ១១-១២; ២៨, ២១-២៩, ១; គោត. ជំពូក២២ លេខ២-១០; វស. ជំពូក២០ លេខ២៥-២៨; ពោធ. ជំពូក២ លេខ១, ២-៦; វិ. ជំពូក២៥ លេខ៦; ជំពូក៥០ លេខ១-៦, ១៥; យញ្ញ. ជំពូក៣ លេខ២៤៣-២៥០។

**៧៣.** តាមលោកកុល្ល., នារ. និងរាឃ. គេត្រូវធ្វើតបៈនេះ ក្នុងករណីបានប្រព្រឹត្តមនុស្សឃាតដោយអចេតនា។

៧៤- ឬ ចូរគេ ដោយឆន្ទៈសុទ្ធសាធរបស់ខ្លួន ចង់ធ្វើជាផ្ទាំងស៊ីបរបស់អ្នកបាញ់ធ្នូ(ក្នុងសមរភូមិ) ដែលដឹងពី(គោលបំណងរបស់ខ្លួន) ឬ គេអាចលោតដាំដួងចូលភ្លើងដែលកំពុងឆេះយ៉ាងខ្លាំង;

៧៥- ឬគេអាចបូជាយញ្ញសេះ ស្វរជិត គោសវ អភិជិត វិស្វជិត ត្រិវ្ឫត ឬអគ្និស្តុត;

៧៦- ឬ ដើម្បីលុបលាង(ទោស)សម្លាប់ព្រាហ្មណ៍ គេអាចដើរមួយរយយោជន៍ ដោយសូត្រព្រះវេទមួយក្នុងចំណោមព្រះវេទទាំងឡាយ បរិភោគតិចតួច និងគ្រប់គ្រងឥន្ទ្រិយាអារម្មណ៍របស់ខ្លួន;

៧៧- ឬ គេអាចផ្តល់ឱ្យព្រាហ្មណ៍ដែលចេះដឹងព្រះវេទ នូវទ្រព្យទាំងអស់របស់ខ្លួន ច្រើនល្មមគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវិត(របស់អ្នកទទួល) ឬផ្ទះ ព្រមទាំងគ្រឿងសង្ហារិម;

៧៨- ឬ ចិញ្ចឹមជីវិតដោយអាស្រ័យលើអាហារយញ្ញ គេអាចដើរប្រាស់ទឹកតាមបណ្ដោយ (ទន្លេ) សរស្វតី ឬដោយកម្រិតអាហាររបស់ខ្លួន(ឱ្យច្រើន) គេអាចសូត្រព្រះវេទសំហិតាបីដង។

---

**៧៤.** *ទិសាំ* 'ដែលស្គាល់(បំណងរបស់ខ្លួន)'(មេធ., គោវ., កុល្ល.) តាមលោកមេធ.អាចមានន័យថា 'ដែលមានជំនាញខាងបាញ់ធ្នូ' ហើយលោកនន្ទ. ឯកភាពចំពោះការបកស្រាយនេះ។ លោកនារ. គិតថា អ្នកដែលសម្លាប់ព្រាហ្មណ៍ ដោយចេតនា ត្រូវតែធ្វើតបៈនេះ ហើយថាត្រូវបញ្ចប់ដោយសេចក្ដីស្លាប់របស់ខ្លួន។ តាម *ភវិស្យបុរាណ*ដែលលោកកុល្ល. និងរាឃ. ស្រង់សេចក្ដី ក្សត្រិយដែលបានសម្លាប់ព្រាហ្មណ៍ អ្នកដែលបាត់បង់ជីវិតដោយជនល្មើស ដែលគ្មានគុណសម្បត្តិល្អ សម្លាប់អ្នកចេះដឹងស្រោត្រិយ និងអ្នករក្សាភ្លើងរបស់ព្រះរាជាដ៏ឧត្ដមដែលធ្វើឱ្យព្រាហ្មណ៍ថោកទាបស្លាប់ដោយអចេតនា ត្រូវធ្វើតបៈទាំងពីរនេះ និងតបៈដែលមាននៅក្នុងកាព្យបន្ទាប់ ។

**៧៥.** តាម *ភវិស្យបុរាណ* លោកនារ. និងកុល្ល. ពាក្យ*ស្វជិត* ជាឈ្មោះពិធីយញ្ញមួយប្រភេទ ប៉ុន្តែលោកមេធ. (ក្នុងកាព្យ ៧៨) និងរាឃ. ប្រែពាក្យនេះជាគុណស័ព្ទ *គោសវ*។ ចំពោះ*គោសវ* សូមមើល*កាត្យាយន ស្រ. សូត្រ* ជំពូក២២ លេខ១១, ៣; ចំពោះពាក្យ *អភិជិត, អាស្វ. ស្រ. សូត្រ* ជំពូក៨ លេខ៥, ១៣។ តាមលោកគោវ. និងនារ. ពាក្យ *ត្រិវ្ឫត* ស្មើនឹងពាក្យ *ត្រិវ្ឫត្សោម* និងត្រូវឱ្យន័យផ្សេងគ្នា ប៉ុន្តែតាមលោកមេធ. និងរាឃ. *ត្រិវ្ឫតា* បញ្ជាក់ន័យឱ្យ*អគ្និស្តុត*។ ចំពោះពាក្យ *អគ្និស្តុត* សូមមើល អាស្វ. ស្រ. ស្រោត ជំពូក៩ លេខ២២-២៥។

**៧៦.** តាមលោកនារ., កុល្ល. និងរាឃ. (ពីនាក់ខាងក្រោយស្រង់សេចក្ដី *ភវិស្យបុរាណ* ជាប្រភពដ៏គួរឱ្យទុកចិត្តរបស់ពួកគាត់) តបៈនេះគ្រប់គ្រាន់លាងបាបអ្នកសម្លាប់ដោយអចេតនាចំពោះអ្នកដែលគ្មានអ្វីសោះ ក្រៅពីឈ្មោះជាព្រាហ្មណ៍។

**៧៧.** ខ្ញុំអានតាមលោកមេធ., គោវ. និង K. *ធនំ ហិ* ជំនួស *ធនំ វា* (នារ., នន្ទ., រាឃ. អត្ថបទបោះពុម្ព) 'ឬមានទ្រព្យច្រើនស្មើនឹង'។ ការបកស្រាយរបស់កុល្ល. ក៏គួសបញ្ជាក់តាមអំណានខាងដើម អត្ថន័យគឺថា 'ទ្រព្យសម្បត្តិទាំងស្រុង' ត្រូវតែគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់អ្នកទទួល។ ចំពោះ *ភវិស្យបុរាណ* ដែលលោកកុល្ល. និងរាឃ. ស្រង់សេចក្ដី បានឱ្យដឹងថា តបៈមានបញ្ញត្តចំពោះករណីដែលព្រាហ្មណ៍ចេះដឹង ជាអ្នកមានដែលមិនរក្សាភ្លើងពិសិដ្ឋ សម្លាប់ព្រាហ្មណ៍ថោកទាបទាំងស្រុងដោយអចេតនា។

**៧៨.** ចំពោះភវិស្យបុរាណ ដែលលោកកុល្ល. និងរាឃ.ស្រង់សេចក្ដី ព្រាហ្មណ៍ដែលគ្មានការចេះដឹង បានសម្លាប់ព្រាហ្មណ៍ថោកទាបដោយចេតនា ត្រូវធ្វើតបៈទីមួយ ស្រោត្រិយល្បីឈ្មោះខ្លាំង ដែលបានបង្កឱ្យបុរសដែលតាំងខ្លួនជាព្រាហ្មណ៍ស្លាប់ដោយអចេតនា ធ្វើតបៈទីពីរ។ លោកមេធ. និងគោវ. ភ្ជាប់គំនិតរបស់ខ្លួនពាក់ព័ន្ធនឹងករណីពិសេស ជាមួយនឹងការបកស្រាយព្រះសូត្រនេះ។ លោកគោវ. មិនទៅហួសពីគំនិតទូទៅទេ។ ប៉ុន្តែលោកមេធ. និយាយថា ការធ្វើតបៈតាមការរៀបរាប់នៅក្នុងកាព្យ ៧៣ និងទីមួយមានចែងនៅក្នុងកាព្យ ៧៤ គេអាចធ្វើដោយស្ម័គ្រចិត្ត ចំពោះការសម្លាប់ព្រាហ្មណ៍ធម្មតាដោយចេតនា។ ប្រសិនបើស្រោត្រិយ ឬអ្នកដែលកំពុងធ្វើពិធីស្រោត ត្រូវបានគេសម្លាប់ ជនល្មើសត្រូវតែដុតខ្លួនឯង។ ពិធីយញ្ញ នឹងលុបលាងទោសមនុស្សឃាតដែលបានប្រព្រឹត្តដោយអចេតនា ដោយសមាជិកដ៏ល្បីល្បាញបំផុតនៅក្នុងវណ្ណៈអារ្យ៉ន ដោយហេតុថា បុគ្គលដែលស្លាប់នោះ គឺជាព្រាហ្មណ៍តែឈ្មោះប៉ុណ្ណោះ។

៧៩- បន្ទាប់ពីបានកោរ(សក់របស់ខ្លួនអស់) គេអាចស្នាក់នៅឆ្ងាយពីភូមិ ឬនៅក្នុងទ្រុងគោ ឬក្នុងអាស្រម ឬក្រោមដើមឈើ ដោយសប្បាយនឹងធ្វើអំពើល្អដាក់មេគោ និងព្រាហ្មណ៍។

៨០- អ្នកដែលលះបង់ជីវិតដោយគ្មានចិត្តស្ទាក់ស្ទើរ ដើម្បីព្រាហ្មណ៍ឬមេគោ ត្រូវរួចរំដោះពី(ទោស) សម្លាប់ព្រាហ្មណ៍ ហើយ(ដូចគ្នានឹងអ្នក)ដែលសង្គ្រោះ(ជីវិត)មេគោ ឬព្រាហ្មណ៍។

៨១- ប្រសិនបើគាត់យ៉ាងហោចណាស់ប្រយុទ្ធ (ជាមួយចោរ) បីដង ក្នុងបំណងការពារទ្រព្យរបស់ព្រាហ្មណ៍ផង ឬដណ្ដើមយកមកវិញនូវទ្រព្យទាំងអស់របស់ព្រាហ្មណ៍ ឬប្រសិនបើគាត់បាត់បង់ជីវិតខ្លួនដើម្បីបុព្វហេតុបែបនេះ គាត់នឹងរួចរំដោះ(ពីទោសរបស់ខ្លួន)។

៨២- ដូច្នេះ អ្នកដែល(នៅតែ)គោរពពាក្យសត្យ ភាពបរិសុទ្ធរបស់ខ្លួនជានិច្ច និងមានការគ្រប់គ្រងចិត្ត រួចរំដោះ(ទោស)សម្លាប់ព្រាហ្មណ៍ បន្ទាប់ពីផុតរយៈពេល ១២ឆ្នាំ។

៨៣- ឬអ្នកដែល បន្ទាប់ពីសារភាពអំពើឧក្រិដ្ឋរបស់ខ្លួនក្នុងអង្គប្រជុំរបស់អាទិទេពផែនដី(ព្រាហ្មណ៍) និងអាទិទេពរបស់មនុស្ស(ក្សត្រិយ) ងូតទឹក(ជាមួយនឹងអាចារ្យ)នៅជិតនឹងពិធីបូជាសេះ (ក៏)បានរួចរំដោះពី(ទោស)ដែរ។

៨៤- ព្រាហ្មណ៍ត្រូវគេប្រកាស(ថាជា)ប្រភពនៃច្បាប់ពិសិដ្ឋ ហើយក្សត្រិយមានឋានៈខ្ពស់បំផុត ហេតុនេះអ្នកដែលបានសារភាព នូវអំពើបាបរបស់ខ្លួននៅចំពោះមុខមនុស្សបែបនេះ បានបរិសុទ្ធ។

៨៥- ដោយសារដើមកំណើតរបស់ខ្លួន ទើបព្រាហ្មណ៍ជាទេវតា ជាអាទិទេពក៏បាន ហើយ(ការបង្រៀនរបស់គាត់ជា) ប្រភពដ៏គួរឱ្យទុកចិត្តសម្រាប់មនុស្ស ព្រោះព្រះវេទជាមូលដ្ឋានសម្រាប់ការបង្រៀន។

៨៦- (ប្រសិនបើ) មានព្រាហ្មណ៍បីនាក់ក្នុងចំណោមព្រាហ្មណ៍ទាំងឡាយ ដែលចេះដឹងព្រះវេទប្រកាសពីរំលត់ទោសសម្រាប់បទល្មើស នោះ(អ្នកមានបាប)នឹងបាននូវភាពបរិសុទ្ធ ព្រោះពាក្យរបស់អ្នកចេះដឹងជាមធ្យោបាយសម្រាប់ធ្វើឱ្យបរិសុទ្ធ។

៨៧- ព្រាហ្មណ៍ដែលមានចិត្តស្ងប់រម្ងាប់ ប្រកាន់ខ្ជាប់នូវវិធាន(ដូចបានរៀបរាប់ខាងលើ) រួចរំដោះពីបាប ដែលបានសម្លាប់ព្រាហ្មណ៍ ដោយការគ្រប់គ្រងខ្លួនឯងបាន។

៨៨- ចំពោះការបំផ្លាញទារកក្នុងផ្ទៃ(របស់ព្រាហ្មណ៍ ដែលគេ)មិនដឹងភេទ ការសម្លាប់ក្សត្រិយឬវៃស្យដែល(ប្រតិបត្តិ ឬ)បានបូជាព្រះវេទ ឬស្ត្រី(ព្រាហ្មណ៍)ដែលបានងូតទឹក បន្ទាប់ពីភាពមិនស្អាតបណ្ដោះអាសន្ន(អាត្រេយី) គាត់ត្រូវតែធ្វើតបៈដូចគ្នា,

---

**៧៩.** លោកមេធ., កុល្លូ. និងគោវ. គិតថា វិធាននេះផ្ដល់នូវជម្រើសចំពោះទីស្នាក់អាស្រ័យ ក្នុងពេលធ្វើតបៈ ១២ឆ្នាំ (កាព្យ ៧៣)។ លោកនារ. និយាយថា កាព្យនេះមានវិធានទូទៅសម្រាប់ការធ្វើតបៈទាំងអស់។

**៨០.** ចំណុចនេះច្បាស់លាស់ នៅមុនពេលបញ្ចប់ការធ្វើតបៈរយៈពេល ១២ឆ្នាំ (គោវ., កុល្លូ., នារ.)។

**៨៣.** គោវ. អះអាងថា តបៈនេះស័ក្តិសិទ្ធិទៅបាន លុះត្រាតែជនល្មើសដាក់ចិត្តធ្វើតបៈរយៈពេល ១២ឆ្នាំ។ លោកកុល្លូ. និងរាឃ. គិតថា វាជាតបៈមួយដោយឡែក ពីព្រោះកម្មវត្ថុនៃការធ្វើតបៈ ១២ឆ្នាំ ត្រូវបានបញ្ចប់នៅក្នុងកាព្យខាងដើម ហើយដោយសារភវិស្សបុរាណ ចែងជាពិសេសអំពីការធ្វើតបៈសម្រាប់ព្រាហ្មណ៍ល្បីល្បាញ ដែលបង្កឱ្យព្រាហ្មណ៍ថោកទាបបាត់បង់ជីវិតដោយអចេតនា។ លោកមេធ. លើកឡើងនូវមតិទាំងពីរ ហើយអះអាងថា លោកមានជំនឿលើតបៈ ថាមានភាពស័ក្តិសិទ្ធិ ទោះក្នុងករណីណាក៏ដោយ។

៨៩- ដូចគ្នាដែរចំពោះការផ្ដល់កសិណមិនពិត(ក្នុងរឿងក្ដីសំខាន់)ចំពោះការបំពានគ្រូដោយចិត្តរំជួល ចំពោះការលួចបញ្ញើ និងចំពោះការសម្លាប់ភរិយា(ខ្លួន) ឬមិត្តរបស់ខ្លួន។

៩០- ការរួចរំដោះនេះ ត្រូវបានបញ្ញត្តិចំពោះការសម្លាប់ព្រាហ្មណ៍ដោយអចេតនា ប៉ុន្តែចំពោះការសម្លាប់ព្រាហ្មណ៍ដោយចេតនា គ្មានការតម្រូវឱ្យលាងបាបទេ។

៩១- អ្នកមានកំណើតពីរដង ដែលបានផឹក(គ្រឿងស្រវឹង សុរា ដោយចេតនា)ដោយសារចិត្តមោហៈនឹងផឹកស្រាវែងាស់នោះ ពេលដែលខ្លួនរបស់គាត់ត្រូវលោកទាំងស្រុងដោយស្រាពុះនោះ គាត់បានរួចរំដោះពីទោសរបស់ខ្លួន;

៩២- ឬគាត់អាចផឹកទឹកនោមមេគោ ទឹក ទឹកដោះគោ ប៊ឺសុទ្ធ ឬទឹកលាមកគោដែលដាំពុះ រហូតដល់គាត់ស្លាប់;

---

*៨៨-៨៩.* អាប. ជំពូក១ លេខ២៤, ៦-៩, ២៣; គោត. ជំពូក២២ លេខ១១-១៤; វស. ជំពូក២០ លេខ៣៤-៣៦; ពោធ. ជំពូក២ លេខ១, ១២; វិ. ជំពូក៥០ លេខ៧-១០; ជំពូក៥២ លេខ៤; យញ្ញ. ជំពូក៣ លេខ២៥១។

*៨៨.* មេធ. និងអ្នកអធិប្បាយជាច្រើនទៀត លើកឡើងនូវការបកស្រាយពាក្យ *អាត្រេយី* ក្រៅពីការប្រែខាងលើ ក៏ជាការភាន់ច្រឡំមួយថា 'ស្ត្រីកុលសម្ពន្ធអាត្រិ'។

*៨៩.* 'ការផ្តល់កសិណមិនពិត' គឺ 'ក្នុងករណីដែលមានពាក់ព័ន្ធនឹងអាយុជីវិតរបស់ជនជាប់ចោទ'(មេធ., គោវ., នារ.) ឬ 'ដែលយកមាស ដីធ្លីសំអាងជាដើម'(កុល្លូ., រាឃ.)។ 'ការបំពានលើគ្រូ' សូមមើលកាព្យលេខ ៥៦ ខាងលើ។ 'ការលួចបញ្ញើ' គឺ 'មាសរបស់ក្សត្រិយ ឬវៃស្យ ឬប្រាក់ និងទ្រព្យផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ព្រាហ្មណ៍'(កុល្លូ., នារ., រាឃ.) ឬទ្រព្យដែលជាកម្មសិទ្ធិរបស់ព្រាហ្មណ៍ក្រីក្រ(មេធ.)។ *ស្ត្រី* 'ភរិយារបស់ខ្លួន'(នារ., នន្ទ.) តាមលោកគោវ., កុល្លូ. និងរាឃ. ថា 'ភរិយាល្អរបស់ព្រាហ្មណ៍ដ៏មានកេរ្តិ៍ឈ្មោះ ដែលរក្សាភ្លើងពិសិដ្ឋ'។ លោកមេធ. (ចំពោះកាព្យ៨៨) ហាក់ដូចជាយល់ស្របតាមការបកស្រាយស្រដៀងគ្នា។ 'មិត្តរបស់ខ្លួន' គឺ 'ទោះជាគាត់មិនមែនជាព្រាហ្មណ៍ក៏ដោយ'(នារ.)។

*៩០.* កាព្យនេះដូចគ្នានឹងពោធ. ជំពូក២ លេខ១, ៦។ ការប្រែកាព្យនេះត្រឹមត្រូវ គឺថា មនុ ដូចជាអាប. ជំពូក១ លេខ ២៤,២៤ បានអះអាងថា ឃាតករសម្លាប់ព្រាហ្មណ៍ពិតប្រាកដ ដោយចេតនា មិនអាចរួចទោសក្នុង អំឡុងពេលឧក្រិដ្ឋជនមានជីវិតរស់នៅទេ ហើយបានទូន្មានថា ឃាតករត្រូវធ្វើតបះលាងបាបរហូតដល់បាត់បង់ជីវិតខ្លួន ឬរស់នៅតាមតម្រាច្បាប់ រយៈពេល ១២ ឆ្នាំ ក្នុងជីវិតធម្មតារបស់ខ្លួន។ នេះជាគោលការណ៍របស់មនុ តាមគោត. ជំពូក២១ លេខ៧។ ចំណែកឯលោកគោវ. និងនារ. យល់ស្របតាមការបកស្រាយនេះ លោកមេធ. អ្នកផ្សេងទៀត តាមការដកស្រង់របស់ គោវ., កុល្លូ., នន្ទ. និងរាឃ. ប្រើពាក្យ *ឥយំ* 'នេះ' សំដៅដល់កាព្យ ៧៣ ហើយអះអាងថា ក្នុងករណីឃាតកម្មដោយ ការតាំងចិត្ត គេត្រូវធ្វើ តបះលាងបាបធ្ងន់ធ្ងរជាង ដោយលើសពីពីរដង ឬបីដងនៃរយៈពេល ១២ឆ្នាំ។

*៩១-៩៨.* អាប. ជំពូក១ លេខ២៥, ៣, ១០; ២៧, ១០; គោត. ជំពូក២៣ លេខ១០-១២; វស. ជំពូក២០ លេខ១៩, ២២; ពោធ. ជំពូក២ លេខ១, ១៨-២២; វិ. ជំពូក៥១ លេខ១-៤; យញ្ញ. ជំពូក៣ លេខ២៥៣-២៥៤។

*៩១.* តបះនេះ និងតបះបន្ទាប់ ត្រូវបានបញ្ញត្តសម្រាប់បទល្មើសដោយចេតនា សូមមើលកាព្យលេខ ១៤៧ ខាងក្រោម។ តាមលោកមេធ., គោវ., កុល្លូ. និងរាឃ. (ពីនាក់ខាងក្រោយស្រង់សេចក្តី ភវិស្យបុរាណ) គ្រឿងស្រវឹងនៅទី គឺជាសុរាបៃស្តិកី ដែលបិតពីអង្ករសុទ្ធ។ តាមលោកនារ. ការធ្វើតបះដល់ស្លាប់ ត្រូវប្រកាន់យកដោយពួកអារ្យ៉ន ដែលបានផឹកសុរាបៃស្តិកី និងដោយព្រាហ្មណ៍ ដែលបានផឹកសុរាណាមួយក្នុងចំណោមស្រាទាំងបីប្រភេទ ដែលបានរៀបរាប់នៅក្នុងកាព្យ៩៥។ លោកនន្ទ. អាន *អមោហាត* ហើយបកស្រាយដោយពាក្យ *មតិបូវកំ*ដោយចេតនា'។

៩៣- ឬដើម្បីរួចរំដោះពី(ទោស)ផឹកសុរា គាត់អាចបរិភោគមួយពេល (ក្នុងមួយថ្ងៃ) រយៈពេលមួយឆ្នាំនៅពេលយប់នូវគ្រាប់បាយ ឬដុំខ្លាញ់ ដោយស្លៀកពាក់ខោអាវដែលធ្វើពីរោមមេគោ និងក្រងសក់របស់ខ្លួន និងកាន់(ពែងស្រា ធ្វើជា)ទង់ជ័យ។

៩៤- តាមពិត សុរា គឺជាសំណល់(មល)ធញ្ញជាតិដ៏គគ្រិច បាបក៏គេចាត់ទុកជា(មល)ដ៏គគ្រិចដែរ ហេតុនេះព្រាហ្មណ៍ ក្សត្រិយ និងវៃស្យ មិនត្រូវផឹកសុរាទេ។

៩៥- សុរា គេត្រូវតែដឹងថា មានបីប្រភេទ ដែលបិតចេញពីទឹករង្វ(គោឌី) ដែលបិតពីអង្ករសុទ្ធ និងដែលបិតពី(មាធ្វី)ផ្កាមធូក ដូច្នេះស្រា(ដែលមានឈ្មោះខាងលើ)គឺជាស្រាបីប្រភេទ ដែលហាមឃាត់ជាពិសេសចំពោះអ្នកមានកំណើតពីរដង។

៩៦- សុរា គ្រឿងស្រវឹង (ដទៃទៀតទាំងអស់) និងទឹករម្ងាស់ និងសាច់ជាអាហាររបស់ពួកយក្ស រាក្សសៈនិងបិសាច ហើយព្រាហ្មណ៍ដែលទទួលទាន (អាហារសំណល់ពី)ការបូជាឧទ្ទិសចំពោះព្រះអាទិទេព មិនត្រូវបរិភោគ(សារជាតុ)បែបនេះទេ។

៩៧- ព្រាហ្មណ៍ ដែលវង្វេងដោយការស្រវឹង អាចបំពានលើអ្វីដែលមិនបរិសុទ្ធ ឬសូត្រអត្ថបទព្រះវេទ (មិនត្រឹមត្រូវ) ឬប្រព្រឹត្តអំពើផ្សេងៗ ដែលមិនគួរប្រព្រឹត្ត។

៩៨- ពេលដែលព្រហ្ម(ព្រះវេទ)ដែលស្ថិតនៅក្នុងខ្លួនគាត់ ត្រូវលិចលង់ដោយគ្រឿងស្រវឹង(តែម្តង) ភាពជាព្រាហ្មណ៍របស់គាត់ បាត់អស់ពីក្នុងខ្លួនគាត់ ហើយគាត់ក្លាយជាសូទ្រៈ។

៩៩- ការលាងបាបផ្សេងៗសម្រាប់ការផឹក(គ្រឿងស្រវឹង គឺ)សុរា ត្រូវបានបកស្រាយពន្យល់មកយ៉ាងនេះ បន្តទៀតខ្ញុំនឹងប្រកាសពីការលាងបាបចំពោះការលួចមាស(របស់ព្រាហ្មណ៍)។

១០០- ព្រាហ្មណ៍ ដែលបានលួចមាស(របស់ព្រាហ្មណ៍) នឹងត្រូវចូលគាល់ព្រះរាជា ហើយសារភាពពីអំពើរបស់ខ្លួនថា 'ព្រះករុណា ចូរដាក់ទោសទូលព្រះបង្គំ!'។

១០១- ដោយបណ្តេញ(គាត់)ចេញពីសហគមន៍ (ដែលគាត់ត្រូវរ៉ាប់រង) ព្រះរាជាវាយគាត់ដោយផ្ទាល់ដល់ស្លាប់តែម្តង ចោរនឹងបានបរិសុទ្ធឬព្រាហ្មណ៍(អាចបរិសុទ្ធដោយខ្លួនឯង) ដោយការធ្វើតបៈដ៏តឹងរ៉ឹង។

---

**៩៣.** តាមលោកគោវ., កុល្ល., នន្ទ. និងរាឃ. តបៈនេះត្រូវបញ្ញត្តចំពោះការសេពសុរាបៃស្ដិកីដោយអចេតនា តាមអ្នកដទៃដែលលោកមេធ. និងរាឃ.ស្រង់សេចក្តី ចំពោះការផឹកសុរាគោឌី ឬមាធ្វី តាមលោកនារ. សម្រាប់ការផឹកដោយចេតនានូវទឹកដែលមានលាយមធុសុរា។ លោកមេធ. និយាយថា *ឥទំ ប្រាណាត្យយ ឱសធាចំ*នេះ(សំដៅដល់)ថ្នាំសម្លាប់ជីវិត'។

**៩៤.** កាព្យនេះ តាមការគូសបញ្ជាក់របស់អ្នកអធិប្បាយ បង្ហាញថា ភាពខុសគ្នារវាងគ្រឿងស្រវឹងដែលបិតពីធញ្ញជាតិសុទ្ធ សុរាបៃស្ដិកី និងស្រាពីប្រភេទទៀត ដែលមានរៀបរាប់នៅក្នុងកាព្យបន្ទាប់។ ប្រភេទទី១ប៉ុណ្ណោះ គឺជាបម្រាមសម្រាប់ពួកអារ្យ័នទាំងអស់ ពីរប្រភេទសម្រាប់ព្រាហ្មណ៍ សូមមើលគោត. ជំពូក២ លេខ២០ផង។

**៩៥.** *មាធ្វី* 'ដែលបិតពី(មោអា)ផ្កាមធូក' (កុល្ល.) តាមលោកមេធ.ថា 'ដែលបិតពីទឹកឃ្មុំ' តាមលោកនារ. 'ដែលបិតពីទំពាំងបាយជូក្តី ឬពីផ្កាមធូកក្តី ឬពីទឹកឃ្មុំក្តី'។

**១០០-១០១.** សូមមើលជំពូក៨ លេខ៣១៤-៣១៦ ខាងលើ។

**១០១.** នៅចុងកាព្យនេះ លោកគោវ., កុល្ល., នារ., រាឃ., នន្ទ. និងK. អាន *វា* ជំនួស *តុ* (មេធ. (?) សំណៅបោះពុម្ព) ដែលត្រូវបកស្រាយផ្សេងគ្នា។ តាមលោកនារ. និងនន្ទ. អាចមានន័យថា 'ប៉ុន្តែ'។ កុល្ល. គិតថា វាបង្ហាញច្បាស់ ខណៈដែលព្រាហ្មណ៍មិនដែលត្រូវព្រះរាជាសម្លាប់ អារ្យ័នផ្សេងទៀតក៏អាចធ្វើតបៈបាន។ តាមលោករាឃ. កាព្យនេះសំដៅដល់ការ

១០២- អ្នកដែលចង់រួចរំដោះពីទោសលួចមាស (របស់ព្រាហ្មណ៍) ដោយការធ្វើតបៈ គួរធ្វើតបៈ(តាមបញ្ញត្តិ)សម្រាប់អ្នកសម្លាប់ព្រាហ្មណ៍ (ដោយរស់) នៅក្នុងព្រៃ និងស្លៀកពាក់សម្បកឈើ។

១០៣- ដោយការធ្វើតបៈទាំងអស់នេះ បុរសមានកំណើតពីររួចរំដោះពីទោសលួច(មាស) ប៉ុន្តែគេអាចលាងបាបដូចគ្នាករណីផិតក្បត់ជាមួយភរិយាគុរុ ដោយការធ្វើតបៈដូចខាងក្រោម។

១០៤- អ្នកដែលបានបំពានគ្រែរបស់គុរុខ្លួន បន្ទាប់ពីសារភាពអំពើឧក្រិដ្ឋរបស់ខ្លួនរួច គួរតែដេកលើគ្រែដែកក្តៅ ឬឱបរូបសំណាកដែកក្តៅ(របស់ស្ត្រី) ដោយការស្លាប់ ទើបគាត់បានបរិសុទ្ធ;

១០៥- ឬដោយបានកាត់អវៈយវៈ និងលិង្គរបស់ខ្លួនដោយខ្លួនឯង និងដោយយកវាដាក់ក្នុងកំបង់ដៃរបស់ខ្លួន គាត់អាចដើរត្រង់សំដៅទៅតំបន់និរតី(ខាងលិចឈៀងខាងត្បូង) រហូតដល់គាត់ដួល (ស្លាប់);

១០៦- ឬដោយកាន់ជើងគ្រែ ស្លៀកសម្បកឈើនិងទុកឱ្យពុកចង្កាដុះវែង គាត់អាចធ្វើដោយចិត្ត សមាធិនូវក្ខចក្រ (ឬតបៈដ៏តឹងរ៉ឹង) នៅក្នុងព្រៃម្នាក់ឯង តាមការបង្ហាញរបស់ប្រជាបតិ ក្នុងអំឡុងពេលពេញមួយឆ្នាំ;

១០៧- ឬ ដោយគ្រប់គ្រងអវៈយវៈរបស់ខ្លួន គាត់អាចធ្វើតបៈពេលរាត្រី ក្នុងអំឡុងបីខែជាប់គ្នា (ដោយអាស្រ័យ)លើអាហារយញ្ញ ឬបបរាវសុទ្ធ ដើម្បីរំដោះ(ទោស)បំពានគ្រែរបស់គុរុ។

១០៨- ដោយការធ្វើតបៈទាំងអស់នេះ បុរសដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ(មហាបាត) អាចលុបលាងទោសរបស់ខ្លួនបាន ប៉ុន្តែអ្នកទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើសតូចតាចដែលបណ្តាលឱ្យបាត់បង់វណ្ណៈ (ឧបបាតក)អាចធ្វើតបៈបានដូចខាងក្រោម។

---

សូត្រគាយត្រី ដងដែលៗរហូតដល់ ៧០០,០០០ដង ហើយតាមនារ. សំដៅដល់ការធ្វើតបៈផ្សេងទៀត រហូតដល់ស្លាប់ក៏ដោយ។ ប៉ុន្តែលោកគោវ. ទំនងជាអះអាងត្រឹមត្រូវថា 'ការធ្វើតបៈតឹងរ៉ឹង' មានបញ្ញត្តនៅក្នុងកាព្យបន្ទាប់។

**១០២.** អាប. ជំពូក១ លេខ២៥, ១០; យញ្ញ. ជំពូក៣ លេខ២៥៨; វិ. ជំពូក៥២ លេខ៣។ តាមលោកនារ. កាព្យនេះសំដៅដល់បទល្មើស 'ដោយចេតនា' តាមលោកកុល្ល. និងរាឃ. សំដៅដល់ចោរលួចបន្តិចបន្តួច។

**១០៤-១០៧.** អាប. ជំពូក១ លេខ២៥, ១-២, ១០; ២៨, ១៥-១៨; គោត. ជំពូក២៣ លេខ៨-១២; វស. ជំពូក២០ លេខ១៣-១៤; ពោធ. ជំពូក២ លេខ១, ១៣-១៥; វិ. ជំពូក៣៤ លេខ២; ជំពូក៥៣ លេខ១; យញ្ញ. ជំពូក៣ លេខ២៥៩-២៦០។

**១០៤.** តាមលោកមេធ. ពាក្យ 'គុរុ' នៅទីនេះសំដៅដល់ 'គ្រូ ឬឪពុក' តាមលោកកុល្ល., នារ. និងរាឃ. 'ឪពុក' ហើយតាមនារ. ជាពិសេស មិនរាប់បញ្ចូលម្តាយចុងទេ។

**១០៤.** តាមលោកមេធ., កុល្ល., រាឃ. តបៈនេះជួយរំដោះបទស្មន់ ដែលបានប្រព្រឹត្តដោយការយល់ខុស តាមលោកនារ. វិធាននេះសំដៅដល់ករណី ដែលបទល្មើសត្រូវបានប្រព្រឹត្តចំពោះម្តាយចុង។ ចំពោះការធ្វើតបៈក្ឫច្ឆ្រ សូមមើលកាព្យ២១២ ខាងក្រោម។

**១០៧.** តាមលោកមេធ. និងរាឃ. វិធាននេះសំដៅដល់បទល្មើស ដែលបានប្រព្រឹត្តជាមួយភរិយារបស់ឪពុក ឬឪពុកមាខាងម្តាយ ឬគុរុរងផ្សេងទៀត ហើយតាមលោកកុល្ល. សំដៅដល់បទល្មើសចំពោះភរិយាមិនស្មោះត្រង់ ឬវណ្ណៈទាបរបស់ គុរុ។ ចំពោះការធ្វើតបៈពេលរាត្រី ឬចាន្ទ្រាយណៈ សូមមើលកាព្យ២១៧ ខាងក្រោម។

**១០៨.** នារ. ប្រែ *មហាបាតកិនៈ* 'អ្នកទាំងឡាយដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ' ក្នុងន័យ 'អ្នកដែលស្មើនឹងបាបជនធ្ងន់ធ្ងរ' គឺ ជនល្មើសដែលបានរៀបរាប់នៅក្នុងកាព្យលេខ ៥៦ខាងលើ។

១០៩- អ្នកដែលបានប្រព្រឹត្តបទល្មើសតូចតាច ដោយការសម្លាប់មេគោ (ឬគោឈ្មោល) នឹងផឹកទឹក(រង្វំ)នៃធញ្ញជាតិសុទ្ធក្នុងអំឡុងខែ(ទីមួយ) ដោយកោរសក់ក្បាលរបស់ខ្លួនទាំងអស់ និងពាក់ស្បែក(មេគោដែលគេសម្លាប់)នោះ គាត់ត្រូវរស់នៅក្នុងរោងមេគោ។

១១០- ក្នុងអំឡុងពីរខែ(បន្ទាប់) គាត់ត្រូវបរិភោគ(អាហារបន្តិចបន្តួច)ដោយគ្មានជាតិអំបិលក្លែងក្លាយនៅរាល់អាហារលើកទីបួន ហើយងូតទឹកនោមមេគោ ដោយគ្រប់គ្រងអវៈយវៈរបស់ខ្លួនជានិច្ច។

១១១-នៅពេលថ្ងៃដែលគាត់ដើរតាមមេគោ និងឈរឱ្យត្រង់ខ្លួន ស្រូបធុលី(ដែលហុយពីជើងគោ) នៅពេលយប់ បន្ទាប់ពីបម្រើនិងគោរពគោរួច គាត់ត្រូវរក្សា(ជំហរដដែល គឺ)វីរាសន។

១១២-ដោយគ្រប់គ្រងខ្លួនឯង និងទប់កំហឹង គាត់ត្រូវតែឈរនៅពេលគោឈរ ដើរតាមគោនៅពេលគោដើរ និងអង្គុយនៅពេលគោដេក។

១១៣-(នៅពេលមេគោ)ឈឺ ឬត្រូវគំរាមកំហែងដោយការប៉ងលួច ដោយខ្លាចាប់ជាដើម ឬដោយការធ្លាក់ ឬជាប់ផុងក្នុងភក់ល្បាប់ គាត់ត្រូវជួយមេគោនោះ តាមគ្រប់វិធីទាំងអស់ដែលអាចធ្វើបាន,

១១៤-ពេលឡើងកម្ដៅ ភ្លៀងឬរងា ឬពេលមានខ្យល់បោកបក់យ៉ាងខ្លាំង គាត់មិនត្រូវស្វែងរកជម្រកសម្រាប់ខ្លួនឯង ដោយមិនរកជម្រកឱ្យមេគោ(ជាមុន)តាមលទ្ធភាពរបស់ខ្លួនទេ។

១១៥-ចូរគាត់កុំនិយាយ(ស្ដី) ប្រសិនបើមេគោស៊ី(អ្វីៗ)នៅក្នុងរោងរបស់ខ្លួនផ្ទាល់ ឬរោង ឬស្រែ របស់អ្នកដទៃ ឬនៅទីលានបោកស្រូវ ឬប្រសិនបើកូនគោផឹក(ទឹកដោះគោ)។

១១៦-អ្នកសម្លាប់មេគោ ដែលបម្រើមេគោរបៀបនេះ បានរួចរំដោះពីទោស បន្ទាប់ពីពេលបីខែ ដែលបានធ្វើឱ្យមេគោស្លាប់។

១១៧-ប៉ុន្តែបន្ទាប់ពីគាត់បានបំពេញតបៈទាំងស្រុង គាត់ត្រូវផ្ដល់ជូន(ព្រាហ្មណ៍)ដែលចេះដឹងព្រះវេទនូវមេគោដប់ក្បាល និងគោឈ្មោលមួយ (ឬ)ប្រសិនបើគាត់គ្មាន(ទ្រព្យសម្បត្តិច្រើនដូច្នេះ)ទេ គាត់ត្រូវតែផ្ដល់ជូនព្រាហ្មណ៍នូវអ្វីទាំងអស់ដែលគាត់មាន។

១១៨-បុរសមានកំណើតពីរដង ដែលបានប្រព្រឹត្តបទល្មើសតូចតាច (ឧបបាតក) លើកលែងតែកូនសិក្សា ដែលបានបំពានពាក្យសច្ចារបស់ខ្លួន(អវកីរណិន) អាចធ្វើតបៈដូចគ្នានេះ ឬតបៈពេលរាត្រីក៏បាន ដើម្បីធ្វើឱ្យខ្លួនបានបរិសុទ្ធ។

---

**១០៩-១១៧.** អាប. ជំពូក១ លេខ២៦, ១; គោត. ជំពូក២២ លេខ១៨; វិ. ជំពូក៥០ លេខ១៦-២៤; យញ្ញ. ជំពូក២៦៣-២៦៤។

**១១១.** 'ក្នុង(ជំហរ គឺ)វីរាសន' គឺ 'ដោយអង្គុយ មិនផ្អែកជញ្ជាំងជាដើម'(កុល្លូ., នន្ទ.)។

**១១២.** យញ្ញ. ជំពូក៣ លេខ២៦៥។

**១១៨-១២៤.** អាប. ជំពូក១ លេខ២៦, ៨; គោត. ជំពូក២៥ លេខ១-៤; វស. ជំពូក២៣ លេខ១-៤; គោត. ជំពូក២ លេខ១, ៣០-៣៥; វិ. ជំពូក២៨ លេខ៤៩-៥០; យញ្ញ. ជំពូក៣ លេខ២៨០។

**១១៨.** តាមលោកនារ. និងនន្ទ. តបៈពេលរាត្រី គឺត្រូវតែអនុវត្ត ប្រសិនបើបទល្មើសនោះត្រូវបានប្រព្រឹត្តដោយអចេតនា។

១១៩-ប៉ុន្តែសិស្ស ដែលបានបំពានពាក្យសច្ចៈរបស់ខ្លួន នឹងបូជាសត្វលាភ្នែកមួយថ្វាយនិរ្ឫតិ នៅពេលរាត្រី ត្រង់ផ្លូវបំបែក ស្របតាមវិធានរបស់បាកយញ្ញ។

១២០-ដោយបានបូជាស្របតាមវិធានស្ដីពីការបូជាអគ្គី គាត់ទីបំផុតត្រូវបូជាប៊ឺសុទ្ធ(បួនតង្វាយ)ថ្វាយព្រះវាត ព្រះឥន្ទ ព្រះគ្រូ(របស់អាទិទេព គឺព្រហស្បតិ) និងព្រះអគ្គិ ដោយសូត្រកាព្យឫគ-វេទ ថា 'សូមឱ្យមរុត កើតមានដល់ទូលបង្គំ'ជាដើម។

១២១-អ្នកដែលចេះព្រះវេទ ប្រកាសថា ការហូរទឹកកាមដោយចេតនារបស់(យុវជន)មានកំណើតពីរដង ដែលប្រតិបត្តិពាក្យសត្យ (ក្នុងការសិក្សា ធ្វើ)បំពានពាក្យសត្យនោះ។

១២២- ពន្លឺទេវៈ ដែលព្រះវេទផ្តល់ឱ្យកូនសិស្ស ចូលទៅកាន់មរុត, បុរហូត (ព្រះឥន្ទ្រ) ព្រះគ្រូ (របស់អាទិទេព ព្រះព្រហស្បតិ) និងបាវក(អគ្គី) ប្រសិនបើគាត់បំពានពាក្យសត្យរបស់ខ្លួន។

១២៣- នៅពេលបានប្រព្រឹត្តអំពើបាបនេះ គេត្រូវទៅសុំទោសចំនួនប្រាំពីរផ្ទះ ដោយស្លៀកពាក់ស្បែកសត្វលា(ដែលគេបូជាយញ្ញ) ដោយប្រកាសពីអំពើរបស់ខ្លួន។

១២៤- ដោយទទួលទាន(អាហារ)មួយដងក្នុងមួយថ្ងៃ ដែលបានពីការដាក់ទាននៅទីនោះ និងងូតទឹកបី(សវន)ដង (ពេលព្រឹក ថ្ងៃត្រង់ និងពេលល្ងាច) គេបានបរិសុទ្ធបន្ទាប់ពី(ផុតរយៈពេល)មួយឆ្នាំ។

១២៥- ចំពោះការប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដែលបង្កឱ្យបាត់បង់វណ្ណៈ(ជាតិព្រំសករ) (ជនល្មើស) ត្រូវធ្វើសាំតបន ក្ឫច្ឆ្រ (ចំពោះការធ្វើអំពើនោះដោយអចេតនា) ធ្វើ(ក្ឫច្ឆ្រ) តាមការបង្ហាញរបស់ព្រះប្រជាបតិ។

១២៦- ដូចគ្នាការលាងបាបចំពោះអំពើដែលបន្ថយវណ្ណៈចម្រុះ (សំករ)និងចំពោះអំពើទាំងឡាយ ដែលធ្វើឱ្យមនុស្សមិនគួរទទួលអំណោយ(អបាត្រ) (គាត់ត្រូវធ្វើតបៈ)ពេលរាត្រីក្នុងអំឡុងពេលមួយខែចំពោះ(អំពើ)ដែលនាំឱ្យសៅហ្មង(មលិនីករណីយ) គាត់ត្រូវស្រុះខ្លួននឹងបបរាវ(ក្ដៅ)សុទ្ធក្នុងអំឡុងពេលបីថ្ងៃ។

---

**១១៩.** 'យោងតាមវិធានស្ដីពីបាកយញ្ញ' គឺ 'តាមបសុកល្ប ដែលមាននៅក្នុងព្រះសូត្ររបស់អាស្វលាយន និងគួហ្យ សូត្រផ្សេងទៀត' អាស្វ. គួ.សូត្រ ជំពូក១ លេខ១១(នារ.)។

**១២០.** កាព្យនេះ យើងឃើញមាននៅក្នុងគម្ពីរ តៃត្តិរីយ អារណ្យកៈ ជំពូក២ លេខ១៨, ៤។

**១២២.** ខ្ញុំអានតាមលោកមេធ., គោវ. និង K. ថា *មរុតះ* ជំនួស *មារុតំ* (នន្ទ. សំណៅបោះពុម្ព)។

**១២៥.** ចំពោះបទល្មើស ដែលគេហៅថា *ជាតិព្រំសករៈ* សូមមើលកាព្យលេខ៦៨ ខាងលើ។ សាំតបន ក្ឫច្ឆ្រ មានរៀបរាប់នៅក្នុងកាព្យលេខ២១៣ ខាងក្រោម។

**១២៦.** ចំពោះចំណាត់ថ្នាក់បទល្មើសទាំងបី សូមមើលលេខ៦៩-៧១ ខាងលើ។ តបៈដែលចិញ្ចឹមជីវិតដោយបបរាវសុទ្ធមានរៀបរាប់នៅក្នុងគម្ពីរ វិ. ជំពូក៦៨; ពោធ. ជំពូក៣ លេខ៦។

**១២៧-១៣១.** អាប. ជំពូក២៤, ១-៤; គោត. ជំពូក២២ លេខ១៤-១៦; វស. ជំពូក២០ លេខ៣១-៣៣; ពោធ. ជំពូក១ លេខ១៩, ១-២; ជំពូក២ លេខ៨-១០; វិ. ជំពូក៥០ លេខ១២-១៤; យញ្ញ. ជំពូក៣ លេខ២៦៦-២៦៧។

១២៧- មួយភាគបួន(នៃតបៈ)សម្រាប់ការសម្លាប់ព្រាហ្មណ៍ មានបញ្ញត្តិ(ជាការលាងបាប)សម្រាប់ការសម្លាប់ក្សត្រិយ (ដោយអចេតនា) មួយភាគប្រាំបីសម្រាប់ការសម្លាប់វៃស្យ ហើយចូរដឹងថា មួយភាគដប់ប្រាំមួយសម្រាប់ការសម្លាប់សូទ្រៈប្រកបដោយគុណធម៌។

១២៨- ប៉ុន្តែប្រសិនបើព្រាហ្មណ៍សម្លាប់ក្សត្រិយដោយអចេតនា គាត់ជូនមេគោមួយពាន់ និងគោឈ្មោលមួយ ដើម្បីធ្វើឱ្យខ្លួនបរិសុទ្ធ;

១២៩- ឬគាត់អាចធ្វើតបៈតាមបញ្ញត្តិសម្រាប់អ្នកសម្លាប់ព្រាហ្មណ៍ក្នុងអំឡុងពេលបីឆ្នាំ ដោយគ្រប់គ្រងខ្លួនឯង ពាក់សក់ក្រងរបស់ខ្លួន ដោយស្នាក់នៅឆ្ងាយពីភូមិ និងស្នាក់នៅក្រោមដើមឈើ។

១៣០-ព្រាហ្មណ៍ ដែលបានសម្លាប់វៃស្យប្រកបដោយគុណធម៌ ត្រូវធ្វើតបៈដូចគ្នាក្នុងអំឡុងពេលមួយឆ្នាំ ឬគាត់អាចផ្តល់មេគោមួយរយ និង(គោឈ្មោល)មួយ។

១៣១-អ្នកដែលបានសម្លាប់សូទ្រៈ ត្រូវធ្វើតបៈនោះទាំងស្រុងក្នុងរយៈពេលប្រាំមួយខែ ឬគាត់អាចផ្តល់មេគោសចំនួនដប់ក្បាល និងគោឈ្មោលមួយ ជូនព្រាហ្មណ៍។

១៣២-ដោយបានសម្លាប់សត្វឆ្មា ស្កា បក្សីខៀវអំបូរក្អែក កង្កែប ឆ្កែ ប្រកួត ទីទុយ ក្អែក គាត់ត្រូវធ្វើតបៈសម្រាប់ការសម្លាប់សូទ្រៈ;

---

**១២៧.** ពាក្យ 'ប្រកបដោយគុណធម៌' តាមអ្នកអធិប្បាយ គឺ 'ក្សត្រិយ' និង 'វៃស្យ' ហើយវិធាន(កាព្យលេខ៦៦) ដែលសំដៅដល់ការសម្លាប់សូទ្រៈ វៃស្យៈ និងក្សត្រិយ គឺជាឧបបាតកៈ ដែលត្រូវរួចរដោះដោយការធ្វើតបៈគោវ្រត រយៈពេលបីខែ ឬតបៈពេលរាត្រី សំដៅដល់ករណីរបស់មនុស្សដែលមិនបានរស់នៅស្របតាមច្បាប់ពិសិដ្ឋ។

**១២៨.** ខ្ញុំអានតាមលោកមេធ., គោវ., កុល្ល.(ការអធិប្បាយ), នន្ទ., K.*សុទ្ធ្យេធំ អាត្មនៈ* ជំនួស *សុចរិតព្រតៈ* (សំណៅបោះពុម្ព) ដែលសំណេរក្រោយនេះខុសទាំងស្រុង។

**១២៩.** យោងតាមលោកមេធ. និងរាឃ. កាព្យនេះគ្រាន់តែជាការសរសេរឡើងវិញនូវវិធានដែលមានចែងនៅក្នុងកាព្យលេខ១២៧ប៉ុណ្ណោះ។ ប៉ុន្តែអ្នកខ្លះ តាមការលើកឡើងរបស់គាត់ មានលោកគោវ., កុល្ល. និងនារ. គិតថា ការប្រតិបត្តិពិសេសបញ្ញត្តអំពីការធ្វើតបៈក្នុងអំឡុងពេល ១២ ឆ្នាំ ឧទាហរណ៍ការកាន់លលាដ៍ក្បាលខ្មោច ជំនួសទង់ដែលកាព្យនេះមិនបានបញ្ជាក់ច្បាស់ មិនចាំបាច់រក្សាទុកទេ។ លោកនន្ទ. អាន *ឡព្ទំ* 'ពីរឆ្នាំ' ជំនួស *ត្រ្យព្ទំ* ។

**១៣០.** ខ្ញុំអានតាមលោកគោវ., កុល្ល., នារ., រាឃ., នន្ទ. និង K.*ទទ្យាទ វៃកសតំ* ជំនួស *ទទ្យាទវៃ្រកសតំ* (មេធ. សំណៅបោះពុម្ព និងទំនងជាលើកឡើងដោយលោកនារ.)។ តាមលោកគោវ. និងកុល្ល. តបៈទាំងពីរនេះ ត្រូវធ្វើតាមជម្រើសក្នុងករណីវៃស្យប្រកបដោយគុណធម៌ ត្រូវគេសម្លាប់ដោយអចេតនា។ លោករាឃ. ហាក់ដូចជាមានមតិដូចគ្នា។ ប៉ុន្តែ លោកមេធ. និយាយថា តបៈទីមួយ ត្រូវធ្វើសម្រាប់ការសម្លាប់វៃស្យ ដែលមានកិត្តិស័ព្ទតិចជាងវៃស្យនៅ ក្នុងកាព្យលេខ ១២៧។ លោកនារ. ចុងក្រោយគិតថា កាព្យនេះសំដៅដល់វៃស្យ ដែលបានធ្វើពិធីយញ្ញ និងថា បរិវារស័ព្ទ *វា* យកកន្លែង កិរិយាភ្ជាប់ហេតុនេះមានបញ្ញត្តិតែតបៈមួយប៉ុណ្ណោះ។

**១៣០.** លោកគោវ. និងកុល្ល. អះអាងថា តបៈទាំងអស់នេះ ក៏ត្រូវធ្វើក្នុងករណីសម្លាប់ដោយអចេតនាផងដែរ។ លោកមេធ. បកស្រាយ *សិតាៈ* 'ស' មានន័យ 'មិនពណ៌សទេ តែ(គេហៅដូច្នេះ) ព្រោះមេគោហាក់ដូចជាភាពបរិសុទ្ធ(សារជាតុស) និងមានទឹកដោះច្រើន ហើយមានកូនគោជាច្រើនដើរតាម'។

**១៣២.** អាប. ជំពូក១ លេខ២៥, ១៣; គោត. ជំពូក២២ លេខ១៩; វស. ជំពូក២១ លេខ២៤; វិ. ជំពូក៥០ លេខ៣០-៣២; យញ្ញ. ជំពូក៣ លេខ២៧០។ លោកគោវ., កុល្ល., នន្ទ. បញ្ជាក់យ៉ាងច្បាស់ថា តបៈសម្រាប់ការសម្លាប់សូទ្រៈ ត្រូវតែធ្វើ (លោកនារ. អះអាងដូច្នេះដែរ) សម្រាប់ការសម្លាប់ដោយចេតនានូវសត្វណាមួយក្នុងចំណោមសត្វទាំងអស់នេះ ចំណែកឯលោកមេធ. គិតថា វិធាននេះបញ្ជាក់ច្បាស់ក្នុងករណីបើគេបានសម្លាប់សត្វទាំងអស់។ តបៈ តាមលោកគោវ., កុ

១៣៣- ឬគាត់អាចផឹកទឹកដោះគោក្នុងអំឡុងបីថ្ងៃ ឬដើរមួយរយយោជន៍ ឬងូតទឹកក្នុងទន្លេ ឬសូត្រសរសើរដល់ទឹកគង្គារ។

១៣៤- ចំពោះការសម្លាប់ពស់ ព្រាហ្មណ៍ត្រូវផ្តល់ចបជីកដែកខ្មៅ ចំបើងមួយគំនរ និងសំណមួយមាសដល់មនុស្សកម្រៀវ;

១៣៥- ចំពោះជ្រូកព្រៃ ឆ្នាំងប៊ឺសុទ្ធ, ចំពោះសត្វទទាឱ្យគ្រាប់ល្ងមួយទ្រោណៈ, ចំពោះសត្វសេក ឱ្យកូនគោអាយុពីរឆ្នាំ, ចំពោះសត្វក្រៀល ឱ្យ(កូនគោ)អាយុបីឆ្នាំ។

១៣៦- ប្រសិនបើគាត់បានសម្លាប់ហំសៈ, ពលាកៈ, ក្រសារ, ក្ងោក, ស្វា, ស្ទាំង ឬភាសៈ គាត់ត្រូវផ្តល់មេគោមួយជូនព្រាហ្មណ៍។

១៣៧- ចំពោះការសម្លាប់ព្រាហ្មណ៍ គាត់ត្រូវផ្តល់សម្លៀកបំពាក់, ចំពោះ (ការសម្លាប់) ដំរី ឱ្យគោឈ្មោលខ្មៅប្រាំ, ចំពោះ(ការសម្លាប់) ពពែ ឬចៀម ឱ្យគោភ្ជួរស្រែមួយ, ចំពោះការសម្លាប់សត្វលាឱ្យ(កូនគោ)អាយុមួយឆ្នាំ;

១៣៨- ប៉ុន្តែសម្រាប់ការសម្លាប់សត្វព្រៃស៊ីសាច់ជាអាហារ គេត្រូវផ្តល់មេគោមានទឹកដោះ, ចំពោះ (ការសម្លាប់)សត្វព្រៃដែលមិនស៊ីសាច់ជាអាហារ ឱ្យមេគោក្រមុំ, ចំពោះការសម្លាប់សត្វអូដ្ឋ ឱ្យមួយក្ឫស្ណលៈ។

១៣៩- ចំពោះការសម្លាប់ស្ត្រីផិតប្តីរបស់វណ្ណៈទាំងបួន គេត្រូវផ្តល់ថង់ស្បែក ធ្នូ ពពែឬចៀមតាមលំដាប់លំដោយ។

---

ល្ល., នារ. និងរាឃ. គឺមិនដូចការបញ្ជាក់នៅក្នុងកាព្យខាងដើមនោះទេ ប៉ុន្តែតបៈពេលរាត្រី(គោវ., កុល្ល., រាឃ.) ឬ គោវ្រត (គោវ., កុល្ល.) ឬ តប្ត ក្ឫច្រ្ឆ (នារ.)។

**១៣៣.** តាមលោកគោវ., កុល្ល., នារ., រាឃ. គេត្រូវតែធ្វើតបៈទាំងអស់នេះ ប្រសិនបើគេបានសម្លាប់សត្វដោយអចេតនា តាមលោកមេធ.ថា ពួកគេបម្រើដើម្បីលាងបាបអ្នកសម្លាប់សត្វតែមួយ។ ជម្រើសក្នុងចំណោមតបៈបួន តាមលោកកុល្ល. និងរាឃ. អាស្រ័យលើកម្លាំងរបស់ជនល្មើស តាមលោកគោវ. និងនារ. ថាអាស្រ័យលើវណ្ណៈរបស់ខ្លួន និងព្រឹត្តិការណ៍ផ្សេងៗទៀត។ 'មួយយោជន៍' គឺស្មើ ២,៥-៩ ម៉ាយ។ ចម្រៀងសរសើរ គឺមាននៅក្នុងគម្ពីរឫគវេទ ជំពូក១០ លេខ៩។

**១៣៤.** គោត. ជំពូក២២ លេខ២៣, ២៥; វិ. ជំពូក៥០ លេខ៣៤-៣៥; យញ្ញ. ជំពូក៣ លេខ២៧៣។ 'ព្រាហ្មណ៍ម្នាក់' គឺ 'សូម្បីព្រាហ្មណ៍ម្នាក់ក៏ដោយ'(នារ.)។ អ្នកទទួលអំណោយ គឺជាព្រាហ្មណ៍ក្នុងគ្រប់ករណីទាំងអស់។

**១៣៥.** គោត. ជំពូក២២ លេខ២៤; វិ. ជំពូក៥០ លេខ៣៦-៣៩; យញ្ញ. ជំពូក៣ លេខ២៧១-២៧៤។ *កុម្ភៈ* 'ឆ្នាំង' គឺ 'នៃ ២០០ បលៈ'(នារ.)។ មួយទ្រោណៈ គឺស្មើ បួនអាធាកៈ(មេធ.) ឬ ១២៨បលៈ(នារ.)។

**១៣៦.** វិ. ជំពូក៥០ លេខ៣៣; យញ្ញ. ជំពូក៣ លេខ២៧២។

**១៣៧.** វិ. ជំពូក៥០ លេខ២៥-២៨; យញ្ញ. ជំពូក៣ លេខ២៧១, ២៧៤។

**១៣៨.** វិ. ជំពូក៥០ លេខ២៩, ៤០-៤១; យញ្ញ. ជំពូក៣ លេខ២៧២-២៧៣។ 'មួយក្ឫស្ណលៈ' គឺ 'នៃមាស'(មេធ., គោវ., កុល្ល., នារ., នន្ទ., រាឃ.)។

**១៣៩.** គោត. ជំពូក២២ លេខ២៦; យញ្ញ. ជំពូក៣ លេខ២៦៨។ 'តាមលំដាប់' គឺតាមលំដាប់នៃវណ្ណៈ។ លោករាឃ. បន្ថែម 'ដោយអចេតនា'។

១៤០- បុរសមានកំណើតពីរដងដែលមិនអាចរួចផុតពីបាប ដោយការជូនអំណោយសម្រាប់សម្លាប់ពស់ និងសត្វដទៃទៀត(ដូចបានរៀបរាប់) ត្រូវធ្វើ(តបៈ)ក្ឫច្រ្ឆ សម្រាប់ករណីនីមួយៗ ដើម្បីបានរួចរំដោះពីទោសរបស់ខ្លួន។

១៤១- ប៉ុន្តែសម្រាប់ការធ្វើឱ្យវិនាសសត្វ(តូចៗ)ចំនួនមួយពាន់ ដែលមានឆ្អឹង ឬសត្វដែលគ្មានឆ្អឹងចំនួនមួយរទេះ គេត្រូវធ្វើតបៈ(តាមបញ្ញត្តិ) សម្រាប់ការសម្លាប់សូទ្រៈ។

១៤២- ប៉ុន្តែសម្រាប់ការសម្លាប់សត្វ(តូចៗ)ដែលមានឆ្អឹង គេត្រូវផ្តល់របស់បន្តិចបន្តួចជូនព្រាហ្មណ៍ ប្រសិនបើគេធ្វើឱ្យរបួស(សត្វ)គ្មានឆ្អឹងគេបានបរិសុទ្ធដោយសារការអត់ដង្ហើម(ប្រាណាយាម)

១៤៣- ចំពោះការកាត់ដើមឈើហូបផ្លែ ចុល្លព្រឹក្ស រុក្ខជាតិ វល្លិ៍ ឬដើមផ្កា គេត្រូវសូត្រឫក (វេទ?) មួយរយដង។

១៤៤- (ចំពោះការបំផ្លាញ) សត្វលោកប្រភេទណាក៏ដោយដើម្បីធ្វើជាអាហារ គ្រឿងទេស ផ្លែឈើ ឬ ផ្កា ការលាងបាបត្រូវទទួលទានប៊ឺសុទ្ធ។

១៤៥- ប្រសិនបើបុរសបំផ្លាញដោយគ្មានបំណងល្អនូវរុក្ខជាតិ ដែលកើតពីការដាំដុះ ឬក៏ដុះដោយឯកឯងនៅក្នុងព្រៃ គេត្រូវនៅជាមួយមេគោពេញមួយថ្ងៃ ដោយទទួលទានតែទឹកដោះគោប៉ុណ្ណោះ។

១៤៦- ទោសដែលបានបង្កដោយចេតនា ឬអចេតនា ដោយបង្ករបួសស្នាមដល់(សត្វលោក) អាចត្រូវរួចរំដោះ ដោយការធ្វើតបៈទាំងអស់នេះ (ឥឡូវ)តទៅនេះចូរស្តាប់អំពីវិធីលាង(បាប)ទាំងអស់ដែលកើតឡើងដោយសារការទទួលទាន(ឬផឹក) អាហារហាមឃាត់ ។

---

**១៤០.** យញ្ញ. ជំពូក៣ លេខ២៧៤; វស. ជំពូក២១ លេខ២៦។

**១៤១.** គោត. ជំពូក២២ លេខ២០-២១; អាប. ជំពូក១, លេខ២៦, ២; វស. ជំពូក២១ លេខ២៥; វិ. ជំពូក៥០ លេខ៤៦; យញ្ញ. ជំពូក៣ លេខ២៦៩។ ‘សត្វ(តូចៗ) ដែលមានឆ្អឹង’ គឺ ‘សត្វបង្គួយជីងចក់ជាដើម’(គោវ., កុល្ល., នារ.)។

**១៤២.** វិ. ជំពូក៥០ លេខ៤៧; យញ្ញ. ជំពូក៣ លេខ២៧៥; គោត. ជំពូក២២ លេខ២២។ វិធាននេះក្នុងករណីនីមួយៗសំដៅដល់ការបំផ្លាញសត្វតែមួយ(មេធ., គោវ., កុល្ល., រាឃ.) ឬ តិចជាងចំនួនដែលបានរៀបរាប់ក្នុងកាព្យខាងដើម (នារ.)។ ‘អ្វីមួយ’ គឺ មួយបណៈ(នារ.) ឬ ‘គ្រាប់ធញ្ញជាតិប្រាំបីក្តាប់’(នន្ទ.)។

**១៤៣.** វិ. ជំពូក៥០ លេខ៤៨យញ្ញ. ជំពូក៣ លេខ២៧៦។ តាមលោកកុល្ល. គេត្រូវធ្វើតបៈនេះ សម្រាប់បទល្មើសដែលប្រព្រឹត្តតែម្តង និងដោយអចេតនា ព្រោះ ‘ការកាត់ដើមឈើបៃតង’ ត្រូវបានប្រកាសក្នុងកាព្យលេខ៦៥ ខាងលើ ថាជាឧបបាតក ដែលយ៉ាងហោចណាស់ គេត្រូវធ្វើតបៈពេលរាត្រី។ ‘ឫកមួយរយដង’ គឺ ‘គាយត្រីជាដើម’(កុល្ល.) ឬ ‘គាយត្រីមួយដង’(នារ.)។

**១៤៤.** វិ. ជំពូក៥០ លេខ៤៩; យញ្ញ. ជំពូក៣ លេខ២៧៥។ *វស* ‘គ្រឿងទេស’ គឺ ‘ទឹករង្វ ទឹកដោះសល់ពីប៊ឺជាដើម’(មេធ., គោវ., កុល្ល.)។

**១៤៥.** វិ. ជំពូក៥០ លេខ៥០; យញ្ញ. ជំពូក៣ លេខ១៤៤។

**១៤៥.** អាប. ជំពូក១ លេខ២៥, ១០; គោត. ជំពូក២៣ លេខ២; វស. ជំពូក២០ លេខ១៩; ពោធ. ជំពូក២ លេខ១, ១៩; វិ. ជំពូក៥១ លេខ១, ៤; យញ្ញ. ជំពូក៣ លេខ២៥៥។ ‘វារុណី’ គឺ ‘ស្រា ដែលបិតពីទឹករង្វ ឬមោអា(គោឌី មាធ្វី ច)’ មិនមែនស្រាដែលបិតពីធញ្ញជាតិសុទ្ធទេ ពីព្រោះបតៈមួយទៀត គេត្រូវធ្វើតាមកាព្យលេខ៩៣ខាងលើ(មេធ., គោវ.)។ អ្នកអធិប្បាយផ្សេងទៀត យល់ស្របតាមការបកស្រាយនេះ ព្រមទាំងស្របតាមវិធានបន្ថែមថា *តប្ត គ្រូច្ឆ* ត្រូវតែធ្វើមុនពិធី

១៤៧- អ្នកដែលផឹក(គ្រឿងស្រវឹង ហៅថា)វារុណី ដោយអចេតនា បានបរិសុទ្ធ ដោយការធ្វើពិធីទទួលសិស្សថ្មី(ម្តងទៀត) (ទោះបីផឹក)ដោយចេតនាក្តី (តបៈ)ដែលវិនាសដល់ជីវិត គេមិនត្រូវធ្វើទេ នេះជាវិធានច្បាប់ដែលបានបញ្ញត្តិមកដូច្នេះ។

១៤៨- អ្នកដែលបានផឹកទឹក ដែលស្ថិតនៅក្នុងភាជន៍សម្រាប់ដាក់(គ្រឿងស្រវឹង ហៅថា)សុរា ឬ គ្រឿង ស្រវឹងផ្សេងៗទៀត ត្រូវផឹកតែទឹកដោះគោប្រាំយប់ប្រាំថ្ងៃ(ដោយគ្មានផឹកអ្វីផ្សេងឡើយ) ដែល រំងាស់លាយជាមួយនឹង(រុក្ខជាតិ)សង្ខបុស្បី។

១៤៩- អ្នកដែលបានប៉ះពាល់គ្រឿងស្រវឹង បានលះបង់វា ឬបានទទួលវា ស្របតាមតម្រាវិធាន ឬ បានផឹកទឹកដែលសល់ពីសូទ្រៈ ត្រូវផឹកទឹក ដែលរំងាស់ពីស្មៅកុសៈ រយៈពេលបីថ្ងៃ។

១៥០- ប៉ុន្តែពេលដែលព្រាហ្មណ៍បានទទួលទានទឹកសោម បានហិតលាមក ស្រូបក្លិនអ្នកផឹកសុរា គេបានបរិសុទ្ធដោយអត់ដង្ហើមបីដងនៅក្នុងទឹក និងបរិភោគប៊ឺសុទ្ធ។

១៥១- (បុរស)វណ្ណៈកំណើតពីរដងទាំងបី ដែលបានស្រូបលាមក ឬទឹកនោម ឬអ្វីដែលបានប៉ះពាល់នឹងសុរា ត្រូវធ្វើពិធីទទួលសមាជិកថ្មីម្តងទៀត។

១៥២- ពិធីកោរសក់ (ពាក់) ខ្សែចង្កេះពិសិដ្ឋ (កាន់) ឈើច្រត់ ដើរសុំទាន និងពាក្យសត្យ(ក្នុងពេលសិក្សា) ត្រូវលុបចោល ពេលធ្វើពិធីទទួលសមាជិកថ្មីលើកទី២ របស់បុរសមានកំណើតពីរដង។

១៥៣- ប៉ុន្តែអ្នកដែលបានបរិភោគអាហាររបស់បុរស នូវអាហារដែលគេមិនត្រូវបរិភោគ ឬអាហារសំណល់ពីស្ត្រី និងសូទ្រៈ ឬសាច់ហាមឃាត់ ត្រូវផឹកទឹក(បបររាវ)សុទ្ធ រយៈពេលប្រាំពីរ(ថ្ងៃនិង)យប់។

---

ទទួលសិស្សថ្មីជាលើកទីពីរ។ លោករាឃ. និងកុល្លូ. ក៏ស្រង់សេចក្តីភវិស្សបុរាណ ដែលផ្តល់ការបកស្រាយដូចគ្នា។ ការបកស្រាយផ្នែកទីពីរនៃកាព្យនេះ មានគ្រប់កន្លែងដែលត្រូវបកប្រែតាម លើកលែងការអធិប្បាយរបស់លោកមេធ. និងនន្ទ. ដែលប្រែថា '(ចំពោះការផឹក សូម្បីសុរាពីរប្រភេទ)ដោយចេតនាក៏ដោយ (តបៈនេះ)មិនត្រូវបានបញ្ញត្តិទេ (តែ)សេចក្តីស្លាប់គឺជាផលតែម្តង'។ តាមមតិរបស់ខ្ញុំ អ្នកអធិប្បាយនោះប្រែខុសទាំងស្រុង។ ខ្ញុំគិតថា *វារុណី* នៅទីនេះ ដូចនៅកន្លែងផ្សេងដែរ មានន័យថា សុរា និងថា ពាក់កណ្តាលទីមួយនៃកាព្យនេះ បញ្ញត្តិអំពីការធ្វើពិធីទទួលសមាជិកថ្មី ជាលើកទីពីរ បន្ទាប់ពីគេបានធ្វើតបៈ តាមការរៀបរាប់នៅក្នុងកាព្យលេខ៩៣ ចំណែកកុំឯបន្ទាត់ទីពីរ ទូន្មានថា ការផឹកសុរាដោយចេតនាអាចរួចរដោះដោយសេចក្តីស្លាប់ប៉ុណ្ណោះ។ ហេតុនេះ ខ្ញុំស្នើថា 'ប្រសិនបើបុរសម្នាក់ផឹក សុរាដោយអចេតនា គេបានបរិសុទ្ធដោយតែធ្វើពិធីទទួលសមាជិកថ្មីមួយដងទៀតប៉ុណ្ណោះ ប៉ុន្តែ(ទោសរបស់អ្នកផឹកសុរា) ដោយចេតនា មិនអាចរួចរដោះទេ ទោសនៅតែមាន ដរាបណាគេនៅមានជីវិត នេះជាវិធានច្បាប់ដែលបានបញ្ញត្តិ'។ ការកែតម្រូវ ការបកប្រែពាក្យ *អនិវេទសំប្រាណាន្តិកំ* ខ្ញុំយកតាមលោកគោត. ជំពូក២១ លេខ៧។

**១៤៨.** វស. ជំពូក២០ លេខ២១; វិ. ជំពូក៥១ លេខ២៣-២៤; ពោធ. ជំពូក២ លេខ១, ២២។

**១៤៩.** 'តាមវិធាននេះ' គឺ'ដោយសូត្រប្រសិទ្ធិ(ជូនអ្នកឱ្យ)'(គោវ., កុល្លូ., នារ., រាឃ.)ឬនៅឯពិធីយញ្ញសោត្រាមណី'(នន្ទ.)។

**១៥០.** គោត. ជំពូក២៣ លេខ៦; វិ. ជំពូក៥១ លេខ២៥។

**១៥១.** គោត. ជំពូក២៣ លេខ៣; វស. ជំពូក២០ លេខ២០; វិ. ជំពូក៥១ លេខ២; យញ្ញ. ជំពូក៣ លេខ២៣៥។

**១៥២.** វស. ជំពូក២០ លេខ៨; ពោធ. ជំពូក២ លេខ១, ២០; វិ. ជំពូក៥១ លេខ៥។ 'ពាក្យសត្យ' គឺ'ការបម្រើភ្លើង តមសាច់ ទឹកឃ្មុំជាដើម'(គោវ., កុល្លូ., រាឃ.) និង 'ពាក្យសច្ចាចំពោះព្រះវេទ'(នារ.)។

**១៥៣.** វស. ជំពូក១៤ លេខ៣៣; វិ. ជំពូក៥១ លេខ៥០, ៥៤, ៥៦។ សូមមើលជំពូក៤ លេខ២២២ ខាងលើ ដែលមាន

១៥៤- បុរសមានកំណើតពីរដង ដែលបានផឹក (អាហាររាវដែលក្លាយជា) ជូរផ្អូម ឬទឹកស្ងោរដ៏ខាប់ទោះ(សារធាតុទាំងនេះ)មិនមែនជាការហាមឃាត់(ជាពិសេស)ក៏ដោយ មានភាពមិនបរិសុទ្ធរហូតដល់រលាយអាហារនោះអស់។

១៥៥- បុរសមានកំណើតពីរដង ដែលបានស្រូបទឹកនោម ឬលាមករបស់ជ្រូកស្រុក លាអូដ្ឋឆ្កែព្រៃ ស្វា ឬមេគោ ត្រូវធ្វើតបៈលាងបាបពេលរាត្រី។

១៥៦- អ្នកដែលបានបរិភោគសាច់ងៀត ផ្សិតដែលដុះលើដី ឬ(សាច់)ដែលគេមិនដឹងលក្ខណៈរបស់វា (ឬ)ដូចជាត្រូវរក្សាទុកក្នុងផ្ទះអ្នកសម្លាប់សត្វ ត្រូវធ្វើតបៈនេះដូចគ្នា។

១៥៧- ការលាងបាបសម្រាប់ការបរិភោគ(សាច់របស់)មំសាសត្វ សាច់ជ្រូក អូដ្ឋ មាន់ឈ្មោល ក្អែក លា និងសាច់មនុស្ស គឺធ្វើ(តបៈ)តប្ត ក្ឫច្ឆ្រ។

១៥៨- ប្រសិនបើបុរសមានកំណើតពីរដង ដែលមិនបានត្រឡប់ពីផ្ទះគ្រូរបស់ខ្លួន មកផ្ទះវិញ បរិភោគអាហារ ធ្វើ(ពិធីសាទ្ធ)ប្រចាំខែ គេត្រូវសុំសីលក្នុងអំឡុងបីថ្ងៃ និងឈរក្នុងទឹកមួយថ្ងៃ។

១៥៩- ប៉ុន្តែកូនសិស្ស ដែលក្នុងឱកាសណាក៏ដោយ ទទួលទានទឹក ឬសាច់ ត្រូវធ្វើ(តបៈ)ក្ឫច្ឆ្រធម្មតា ហើយបន្ទាប់មកត្រូវបំពេញពាក្យសត្យក្នុងការសិក្សារបស់ខ្លួន។

---

បញ្ញត្តិអំពីតបៈមួយទៀតសម្រាប់ការទទួលទានអាហារដោយមិនដឹងអ្នកឲ្យ ដែលជាអាហារមិនត្រូវទទួលទាន។ តាមលោកកុល្លូ. គេអាចធ្វើតបៈពីរយ៉ាងតាមជម្រើស ប៉ុន្តែតាមលោកមេធ. និងនារ. ថា វិធាននេះ សំដៅដល់បទល្មើស ដែលបានប្រព្រឹត្តដោយចេតនា។

**១៥៥.** 'ទឹកស្មោរខាប់' គឺ 'ទឹកដែលគ្រូពេទ្យស្គាល់ ត្រូវគេស្មោរពីរុក្ខជាតិឱសថនានា'(មេធ.)។ រាឃ. និងនន្ទ. គិតថា *បីត្វាមេធ្យាន្យបី* សំដៅដល់ បីត្វាអមេធ្យានិ អបិ ហើយបកស្រាយ អមេធ្យ ថា 'ខ្ទឹមស ជាដើម'។

**១៥៦.** វិ. ជំពូក៥១ លេខ២៧, ៣៤។ គោវ. និងរាឃ. ប្រែ អញ្ញាតំ 'គេមិនស្គាល់លក្ខណៈ' គឺ 'ដោយអចេតនា'។ រាឃ. ប្រែ ភូមានិ 'ដែលដាំលើដី'ផ្សេងពីគេ ហើយប្រែ *កវកានិ* 'ផ្សិត' គឺ 'ផ្សិតដែលដុះលើដើមឈើ'។ ប៉ុន្តែលោកមេធ. និយាយថា 'ពាក្យភូមានិ ត្រូវគេប្រើ ដើម្បីរាប់បញ្ចូលផ្សិត ដែលដុះក្នុងរន្ធឈើ ដែលហាមឃាត់' ចំណែកឯលោកនារ. គិតថា តាមស្រ្មិតមួយទៀត មាននិយាយពីតបៈមួយទៀត គឺ *ប្រស្ឫតិយាវក* សម្រាប់ការបរិភោគអាហារក្រោយនេះ។

**១៥៧.** គោត. ជំពូក២៣ លេខ៤-៥; វស. ជំពូក២៣ លេខ៣០; វិ. ជំពូក៥១ លេខ៣-៤។ ចំពោះកាព្យនេះ និងកាព្យខាងដើម សូមមើលជំពូក ៥ លេខ១៩-២១ខាងលើ ដែលមានបញ្ញត្តអំពីតបៈផ្សេងទៀត។ កុល្លូ. និងរាឃ. គិតថា តម្រាវិធាននេះ សំដៅដល់បទល្មើស ដែលប្រព្រឹត្តម្តង ចំណែកឯកតបៈនៅក្នុងជំពូកទី៥ អនុវត្តចំពោះការភ្លេះភ្លោយម្តងទៀត។ ចំពោះ តប្ត ក្ឫច្ឆ្រ សូមមើលកាព្យ ២១៥ ខាងក្រោម។

**១៥៨.** វិ. ជំពូក៥១ លេខ៤៣-៤៤។ អ្នកអត្ថាធិប្បាយបញ្ជាក់ថា ពាក្យ *មាសិក*(ស្រាទ្ធ)ប្រចាំខែ' សំដៅដល់ពិធី *អេកោទ្ទិស្ត ស្រាទ្ធ*។ តាមលោកមេធ. 'អ្នកខ្លះទៀត'គិតថា ព្រោះកូនសិស្ស គេអនុញ្ញាតឱ្យបរិភោគស្រាទ្ធ តាមជំពូក២ លេខ១៨៩ អ្នកអញ្ជើញ ត្រូវធ្វើតបៈ។ តាមលោកមេធ. កូនសិស្សត្រូវឈរក្នុងទឹកនៅថ្ងៃទីបួន ប៉ុន្តែតាមលោកគោវ., កុល្លូ., នៅថ្ងៃសុំសីលបីថ្ងៃ តាមលោកនារ. ថានៅថ្ងៃទីមួយ។

**១៥៩.** វិ. ជំពូក៥១ លេខ៤៥; វស. ជំពូក២៣ លេខ១២; យញ្ញ. ជំពូក៣ លេខ២៨២។ ជំនួស ព្រហ្មចារី 'អ្នកសិក្សា' (មេធ., គោវ., នារ. និងនន្ទ. អាន វ្រតចារី 'បុរសដែលប្រតិបត្តិពាក្យសត្យ' ហើយលោកនារ.បកស្រាយថា 'អ្នកសិក្សា ឥសីមេម៉ាយ តាបស ជាដើម' ចំណែកឯអ្នកអធិប្បាយផ្សេងទៀតឱ្យន័យពាក្យនេះសំដៅដល់អ្នកសិក្សាប៉ុណ្ណោះ។

១៦០- អ្នកដែលបរិភោគអ្វីដែលសល់ពីសត្វឆ្មា ក្អែក កណ្តុរ ឬ(កណ្តុរប្រែង) ឆ្កែ ឬបង្គួយ ថ្លែន ឬ (អាហារ)មានចូលសក់ ឬសត្វល្អិត ត្រូវផឹក(ទឹកស្មោរ)រុក្ខជាតិព្រហ្មសុវចំលា។

១៦១- អ្នកដែលចង់បានភាពបរិសុទ្ធ មិនត្រូវទទួលទានអាហារហាមឃាត់ទេ ហើយត្រូវក្អួតចេញមកវិញនូវអ្វីដែលខ្លួនបានទទួលទានដោយអចេតនា ឬធ្វើការលាងបាបភ្លាម (ដោយវិធី) ធ្វើឱ្យបរិសុទ្ធនានា។

១៦២- វិធាននានាស្តីពីការធ្វើតបៈចំពោះការទទួលទានអាហារហាមឃាត់ ត្រូវបានប្រកាសមកយ៉ាងនេះ ហើយតទៅនេះចូរស្តាប់ច្បាប់ស្តីពីការធ្វើតបៈទាំងនោះ ដើម្បីរួចរំដោះពីទោសបទលួច។

១៦៣- នាយនៃអ្នកមានកំណើតពីរ បន្ទាប់ពីបានលួចដោយចេតនានូវទ្រព្យសម្បត្តិ (មានតម្លៃ) ធញ្ញជាតិ ឬអាហារឆ្អិន ពីផ្ទះរបស់បុរសរួមវណ្ណៈ ត្រូវបន្សុទ្ធ ដោយការធ្វើ(តបៈ)ក្ឫច្រ្ធ ពេញមួយឆ្នាំ។

១៦៤- តបៈពេលរាត្រី ត្រូវបានប្រកាសថាជាវិធីសម្រាប់រួចរំដោះចំពោះការលួចបុរសនិងស្ត្រី និង (ចំពោះការយកមកធ្វើជារបស់ខ្លួនដោយខុសច្បាប់នូវ)ស្រែ ផ្ទះ ឬ ទឹកអណ្តូង និងធុងទឹក។

១៦៥- អ្នកដែលបានលួចវត្ថុមានតម្លៃតូចៗ ពីផ្ទះរបស់បុរសផ្សេង បន្ទាប់ពីប្រគល់សង (វត្ថុលួចនោះ) វិញ ត្រូវធ្វើសាំតបន ក្ឫច្រ្ធ ដើម្បីការបន្សុទ្ធខ្លួន។

១៦៦- (ការលេប)ផលិតផលប្រាំរបស់មេគោ(បញ្ចគវ្យ) ជាវិធីលាងបាបសម្រាប់ការលួចរបស់ផ្សេងៗ ដែលអាចបរិភោគបាន យាន គ្រែ កៅអី ផ្កា មើមឈើ ឬផ្លែឈើ។

១៦៧- ការសុំសីលរយៈពេលបី(ថ្ងៃ និង)យប់ គឺជា(ការធ្វើតបៈសម្រាប់ការលួច)ស្មៅ ឈើ ដើមឈើ អាហារក្រៀម ទឹកងូត សម្លៀកបំពាក់ ស្បែក និងសាច់។

**១៦០.** វិ. ជំពូក៥១ លេខ៤៦; វស. ជំពូក២៣ លេខ១១។ ៉អាហារដែលមានចូលសត្វល្អិ ឬសក់៊ គឺ ៉ដោយមិនពោយដីដាក់វា៊(គោវ., កុល្ល., រាឃ.)។ លោកនារ. បន្ថែមក្នុងអំឡុងមួយថ្ងៃ។

**១៦១.** គោវ., ជំពូក២៣ លេខ២៦។ ៉មធ្យោបាយបន្សុទ្ធកម្ម៊ គឺ ៉ការធ្វើតបៈ៊(មេធ., គោវ., កុល្ល., រាឃ.) ឬ ៉ទឹកស្ងោរថ្នាំបញ្ចុះ៊(អ្នកដទៃ មេធ., នារ., នន្ទ.)។

**១៦៣.** វិ. ជំពូក៥២ លេខ៥។ តាមលោកមេធ. និងនារ. មានន័យថា អ្នកដទៃដែលលួចវត្ថុដូចគ្នា ពីបុរសរួមវណ្ណៈ ត្រូវធ្វើតបៈដូចគ្នា។ លោកមេធ., គោវ., កុល្ល., នន្ទ. និងនារ. គិតថា កាព្យនេះបញ្ជាក់ពីការកម្រិតតឹងរ៉ឹងបំផុតនៃការធ្វើតបៈ និងថា ក្នុងកាលៈទេសៈពិសេស គេអាចកាត់បន្ថយបាន។

**១៦៤.** វិ. ជំពូក៥២ លេខ៦។ ៉បុរស និងស្ត្រី៊ គឺ ៉ទាសករ៊(មេធ.)។ រាឃ. សរសេរផ្សេងថា តទាគានាំ ៉ឬធុងទឹក៊ ជំនួសជលានាំ ៉ទឹក៊។ លោកនារ. និងរាឃ. គិតថា តបៈនេះត្រូវធ្វើសម្រាប់បទល្មើសដែលបានប្រព្រឹត្តដោយអចេតនា។

**១៦៥.** វិ. ជំពូក៥២ លេខ៧។ ៉វត្ថុមានតម្លៃតូចតាច៊ គឺ ៉ភាជន៍ដី ភាជន៍ឈើ ឧ.ទា. ស្នូក ឬគ្រឿងប្រដាប់ដែក (ក្នុងផ្ទះបាយ) ដូចជាចបកាប់៊(មេធ.) ឬ ៉ប្រអប់ សំណជាដើម៊(គោវ., កុល្ល., រាឃ.) ឬ ៉ចំបើងជាងដើម៊(នារ.)។ K. លុបឃ្លា ៉បន្តាប់ពីប្រគល់សងគេវិញ៊ ហើយអាន *តត្បាបស្យ វិសុទ្ធយេ* ៉សម្រាប់រំដោះអំពើបាបនោះ៊។

**១៦៦.** វិ. ជំពូក៥២ លេខ៨។ លោកមេធ. និយាយថា ការធ្វើតបៈ មានរយៈពេលមួយថ្ងៃប៉ុណ្ណោះ។ លោកនារ. គិតថា *មហាសាំតបន* គឺបង្ហាញដោយបញ្ចគវ្យ ហើយថា វិធាននេះត្រឹមត្រូវក្នុងករណីបទល្មើសដោយអចេតនាប៉ុណ្ណោះ។ លោកនន្ទ. បន្ថែម ៉ដោយវិធាននេះ និងវិធានបន្ទាប់ ពាក្យ «បន្ទាប់ពីប្រគល់សងទ្រព្យវិញ» នៅតែមានអំណាចរបស់វាដដែល៊ ដូច្នេះសូមមើលកុល្ល. កាព្យលេខ១៦៥។

**១៦៧.** វិ. ជំពូក៥២ លេខ៩។ តាមលោកនារ. វិធាននេះសំដៅដល់បទល្មើសដោយអចេតនា។

១៦៨- ការចិញ្ចឹមជីវិតអាស្រ័យលើគ្រាប់ធញ្ញជាតិ(មិនចម្អិន)ក្នុងអំឡុងដប់ពីរថ្ងៃ (ជាតបៈសម្រាប់ការលួច)ត្បូង គជ់ ផ្កាថ្ម ទង់ដែង ប្រាក់ ដែក ស្ពាន់ ឬថ្ម។

១៦៩- (ចំពោះការលួច)សំឡី សូត្រ រោមសត្វ សត្វដែលមានក្រចកបែកជាពីរ ឬសត្វដែលមានក្រចកមិនបែកជាពីរ សត្វស្លាប ទឹកអប់ រុក្ខជាតិឱសថ ឬខ្សែ (តបៈគឺត្រូវចិញ្ចឹមជីវិត) ដោយទឹកដោះគោ ក្នុងអំឡុងបីថ្ងៃ។

១៧០- ដោយមធ្យោបាយធ្វើតបៈទាំងអស់នេះ បុរសមានកំណើតពីរដង អាចរួចរំដោះពីទោសលួច ប៉ុន្តែទោសបំពានលើស្ត្រី ដែលមិនគួរបំពាន(អគម្យា) គេអាចរួចពីបាបដោយការធ្វើតបៈ (ដូចខាងក្រោម)។

១៧១- អ្នកដែលបានរួមសង្វាស់ជាមួយបងប្អូនស្ត្រីម្តាយតែមួយ ជាមួយភរិយារបស់មិត្តសំឡាញ់ជាមួយស្រីក្រមុំមិនទាន់រៀបការ និងជាមួយស្ត្រីវណ្ណៈទាបបំផុត ត្រូវធ្វើតបៈតាមបញ្ញត្តិសម្រាប់ការបំពានគ្រែរបស់គុរុ។

១៧២- អ្នកដែលបានបំពានលើកូនស្រីរបស់បងប្អូនស្រីខាងឪពុករបស់ខ្លួន (ដែលសឹងតែស្មើនឹង) បងប្អូនស្រី (កូនស្រី)របស់បងប្អូនស្រីខាងម្តាយខ្លួន ឬបងប្អូនប្រុសបង្កើតខាងម្តាយខ្លួន ត្រូវធ្វើតបៈពេលរាត្រី។

១៧៣- បុរសឆ្លាតវៃមិនត្រូវចាត់ទុកភរិយាខ្លួនជាស្ត្រីណាមួយក្នុងចំណោមទាំងបី ពួកគេមិនត្រូវបានរៀបការ ព្រោះតែពួកគេជាសាច់ញាតិ(សបិណ្ឌ) អ្នកដែលរៀបការ(ស្ត្រីម្នាក់ក្នុងចំណោមស្ត្រីទាំងនោះ) នឹងធ្លាក់ចុះឱនថយ។

---

**១៦៨.** វិ. ជំពូក៥២ លេខ១០។ តាមលោកមេធ. តបៈនេះ អាចត្រូវគេបន្ថយរយៈពេល ស្របតាមព្រឹត្តិការណ៍ពិសេសនៃករណី។ លោកនារ. និយាយថា 'កាព្យសំដៅដល់ករណី ដែលការលួចមិនត្រូវបានប្រព្រឹត្តក្នុងគ្រាទុក្ខលំបាក'។

**១៦៩.** វិ. ជំពូក៥២ លេខ១១។ តាមលោកនារ. វិធាននេះ មានហេតុផលត្រឹមត្រូវ ប្រសិនបើការលួចត្រូវបានប្រព្រឹត្តក្នុងគ្រាទុក្ខលំបាក និងលួចក្នុងបរិមាណតិចតួចបំផុត។ គោវ. និងកុល្ល. សង្កេតឃើញកាព្យនេះ និងកាព្យខាងដើមថា វិសមភាពនៃការធ្វើតបៈ ដែលបញ្ញត្តិស្មើគ្នាសម្រាប់វត្ថុធំនិងតូច នឹងមិនមានទេ ប្រសិនបើព្រឹត្តិការណ៍ពិសេស ដូចជាភាពញឹកញយនៃបទល្មើស ពេលវេលានិងទីកន្លែង លក្ខណៈរបស់ម្ចាស់ជាដើម ត្រូវយកមកពិចារណា។

**១៧១.** គោត. ជំពូក២៣ លេខ១២-១៣, ៣២; វស. ជំពូក២០ លេខ១៥-១៦; ពោធ. ជំពូក២ លេខ១, ១៣; វិ. ជំពូក៣៤ លេខ២; ជំពូក៣៦ លេខ៧; ជំពូក៥៣ លេខ១; យញ្ញ. ជំពូក៣ លេខ២៣៣។ សូមមើលកាព្យ លេខ៥៩ ខាងលើ។ តាមលោកមេធ., គោវ., កុល្ល. និងរាឃ. តបៈដែលត្រូវធ្វើ គឺជាតបៈដែលមានរៀបរាប់នៅក្នុងកាព្យ លេខ ១០៦ខាងលើ ចំណែកឯការបូជាយញ្ញខ្លួនឯង មានបញ្ញត្តិសម្រាប់ការប្រព្រឹត្តបទល្មើសដដែលដោយចេតនាប៉ុណ្ណោះ។ លោកនារ. មានប្រសាសន៍អំពីការធ្វើតបៈរយៈពេលដប់ពីរឆ្នាំ។

**១៧២.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ និងលោក K. នៅក្នុងបន្ទាត់ទីពីរ *មាតុស ច ភ្រាតុរ អាប្តស្យ* (អាប្តាំ ច តាមនន្ទ.) ជំនួស *មាតុស ច ភ្រាតុស តនយាំ* (សំណៅបោះពុម្ព)។ តាមលោកកុល្ល. និងនារ. វិធាននេះសំដៅដល់បទល្មើសដែលបានប្រព្រឹត្តដោយការភាន់ច្រឡំ ហើយដូចនិយាយខាងដើម គឺតែម្តងប៉ុណ្ណោះ។

**១៧៣.** កាព្យនេះ ត្រូវបានបង្ហាញខុសពីទម្លាប់របស់អ្នកភាគខាងត្បូង តាមការបញ្ជាក់របស់ពោធ. ជំពូក ១ លេខ២, ៣។ 'នឹងធ្លាក់ចុះឱនថយ' គឺ 'ធ្លាក់នរក ឬមានកំណើតជាមនុស្សវណ្ណៈទាបបំផុត'(មេធ.)។ លោកគោវ. និងកុល្ល. ប្រកាន់យកការបកស្រាយខាងដើម ចំណែកឯលោកនារ. និយាយថា 'គេនឹងក្លាយជាមនុស្សក្រៅវណ្ណៈ'។

១៧៤- បុរសដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋកាចសាហាវ ឬឧក្រិដ្ឋខុសពីធម្មតា ជាមួយស្ត្រី ឬបានរួមភេទក្នុងទឹក ឬជាមួយស្ត្រីមានរដូវ ត្រូវធ្វើសាំតបន ក្ឫច្ឆ្រ។

១៧៥- បុរសមានកំណើតពីរដង ដែលប្រព្រឹត្តបទល្មើសមិនធម្មតាជាមួយបុរស ឬ រួមភេទជាមួយស្ត្រីក្នុងរទេះគោឈ្មោល ក្នុងទឹក ឬក្នុងពេលថ្ងៃ ត្រូវមុជទឹក ទាំងសម្លៀកបំពាក់។

១៧៦- ព្រាហ្មណ៍ ដែលបំពានលើស្ត្រីចណ្ឌាលដោយអចេតនា ឬ(ស្ត្រី)វណ្ណៈទាប ដែលទទួលទាន (អាហាររបស់មនុស្សបែបនេះ) និងទទួល(អំណោយពីពួកគេ) ក្លាយជាមនុស្សក្រៅវណ្ណៈ ប៉ុន្តែ(ប្រសិនបើគាត់ប្រព្រឹត្ត)ដោយចេតនា គាត់ក្លាយជាមនុស្សវណ្ណៈស្មើនឹងពួកគេ។

១៧៧- ភរិយាខិលខូចហួសប្រមាណ សូមស្វាមីរបស់នាងឃុំឃាំងឱ្យនៅក្នុងបន្ទប់មួយ និងបង្ខំឱ្យនាងធ្វើតបៈ តាមបញ្ញត្តិសម្រាប់មនុស្សប្រុសក្នុងករណីផិតក្បត់។

១៧៨- ប្រសិនបើរួមភេទជាមួយបុរស(វណ្ណៈ)ស្មើគ្នា នាង(ក្រោយមក)មានចិត្តមិនស្មោះត្រង់ម្តងទៀត ដូចនេះត្រូវធ្វើតបៈក្ឫច្រ្ឆ និងតបៈពេលរាត្រី សម្រាប់ធ្វើឱ្យនាងបរិសុទ្ធវិញ។

១៧៩- បាបដែលបុរសមានកំណើតពីរប្រព្រឹត្ត ដោយការដើរលេងសើចអស់មួយរាត្រីជាមួយវ្ឫសាលី គេត្រូវរំដោះបាបរយៈពេលបីឆ្នាំ ដោយការចិញ្ចឹមជីវិតលើការសុំទាន និងសូត្រ(ធម៌ពិសិដ្ឋ)រៀងរាល់ថ្ងៃ។

១៨០- អ្នកប្រព្រឹត្តអំពើបាបទាំងបួនប្រភេទ ត្រូវធ្វើការលាងបាប ដូចបានប្រកាសមកយ៉ាងនេះ ហើយឥឡូវនេះចូរស្តាប់អំពីការធ្វើតបៈសម្រាប់អ្នកដែលបានរួមសង្វាស់ជាមួយមនុស្សក្រៅវណ្ណៈ។

---

**១៧៤.** គោត. ជំពូក២២ លេខ៣៦; ជំពូក២៣ លេខ៣៤; វិ. ជំពូក៥៣ លេខ៤, ៧; យញ្ញ. ជំពូក៣ លេខ២៨៨។ អំពើឧក្រិដ្ឋដូចសត្វធាតុជាមួយនឹងមេគោ ត្រូវបានលើកលែង សូមមើល វិ. ជំពូក៥៣ លេខ៣។ លោកមេធ. លើកឡើងនូវឃ្លាផ្សេង *ជលេ ខេ ច* ជំនួស *ជលេ ចៃវ* ដែលស្របគ្នានឹងអត្ថបទរបស់វិស្ណុ។

**១៧៥.** វិ. ជំពូក៥៣ លេខ៤; យញ្ញ. ជំពូក៣ លេខ២៩១។ លោកនារ. មានប្រសាសន៍ថា កាព្យនេះសំដៅដល់បទល្មើសដោយអចេតនា។

**១៧៦.** វស. ជំពូក២៣ លេខ៤១; ពោធ. ជំពូក២ លេខ៤, ១៣-១៤; វិ. ជំពូក៥៣ លេខ៥-៦។ 'វណ្ណទាប១' គឺ*ម្លេច្ឆ* ឬមនុស្សព្រៃ សពជាដើម (មេធ., គោវ., កុល្ល.) ឬ 'សូតជាដើម'(នារ.) ឬ 'ជវន(គឺ មហោម្មេដ័ន ជាដើម)'(រាឃ.)។ ក្នុងករណីទីមួយ គេត្រូវធ្វើតបៈនេះសម្រាប់បតិតៈ ក្នុងករណីទីពីរ មិនមានបញ្ញត្តិអំពីការធ្វើតបៈទេ។

**១៧៧.** វស. ជំពូក២១ លេខ៨, ១២-១៣; វិ. ជំពូក៥៣ លេខ៨។ ការផិតក្បត់ គឺឧបបាតក យោងតាមកាព្យលេខ៦០ និងត្រូវលាងបាបដោយកាព្យលេខ១១៨ ដោយគោវ្រត ឬចន្ទ្រាយណ ដែលតបៈក្រោយនេះ ទំនងជាត្រឹមត្រូវត្រង់ចំណុចនេះ។ អ្នកអធិប្បាយបន្ថែមថា តបៈនេះត្រូវតែមានទម្ងន់ស្រាល ឬធ្ងន់ជាង ស្រមទៅតាមវណ្ណៈរបស់ជនល្មើសប្រុស។

**១៧៨.** ខ្ញុំអានតាមលោកគោវ., នារ. *ឧបមន្ត្រិតា* ជំនួស *ឧបយន្ត្រិតា* (សំណៅបោះពុម្ពរបស់ K., នន្ទ.)។ មេធ. ទំនងជាអាន *អនុមន្ត្រិតា*។

**១៧៩.** អាប. ជំពូក១ លេខ២៧, ១១; ពោធ. ជំពូក២ លេខ២១១; វិ. ជំពូក៥៣ លេខ៩។ 'វ្ឫសាលី' គឺ ចណ្ឌាល(មេធ., កុល្ល., រាឃ.)។ ប៉ុន្តែអ្នកផ្សេងតាមការលើកឡើងរបស់លោកមេធ., គោវ. និងនារ. គិតថា គឺសំដៅដល់ស្ត្រីសូទ្រៈ។ នន្ទ. ដាក់កាព្យនេះមុនកាព្យ ១៧៨។

១៨១- អ្នកដែលសេពគប់ជាមួយមនុស្សក្រៅវណ្ណៈ នឹងក្លាយជាមនុស្សក្រៅវណ្ណៈក្រោយមួយឆ្នាំ មិនដោយការបូជាយញ្ញឱ្យគេ ការបង្រៀនគេ ឬការចងមេត្រីរបស់ខ្លួនជាមួយញាតិខាងម្តាយ ប៉ុន្តែដោយការប្រើរទេះ ឬកៅអីតែមួយ ឬដោយការទទួលទានជាមួយគេ។

១៨២- អ្នកដែលសេពគប់ជាមួយនរណាម្នាក់ក្នុងចំណោមមនុស្សក្រៅវណ្ណៈ ត្រូវធ្វើតបៈតាមការបញ្ញត្តិសម្រាប់(អ្នកប្រព្រឹត្តអំពើបាប)នោះ ដើម្បីលាងបាបសម្រាប់ការរួមសង្វាស់(បែបនេះ)។

១៨៣- សបិណ្ឌ និងសមានោទក មនុស្សក្រៅវណ្ណៈ ត្រូវធ្វើ(ការបូជា)ទឹកដល់គាត់នៅក្រៅភូមិ ហាក់ដូចជាគាត់បានចែកឋានទៅហើយ នៅថ្ងៃគ្មានជោគល្អ នៅពេលរសៀល និងក្នុងវត្តសាច់ញាតិ អាចារ្យពិធីការ និងគ្រូ។

១៨៤- ទាសករស្រី ត្រូវយកជើងរបស់នាងក្រឡាប់ឆ្នាំងដែលមានទឹកពេញ ហាក់ដូចជាបូជាដល់អ្នកដែលបានចែកឋានទៅ (សបិណ្ឌរបស់គាត់)ព្រមទាំងអស់សមានោទក នឹងមិនបរិសុទ្ធអស់ពេលមួយថ្ងៃ មួយយប់;

១៨៥- ប៉ុន្តែតាំងពីពេលនោះមក គេហាមឃាត់មិនឱ្យសន្ទនាជាមួយគាត់ អង្គុយជាមួយគាត់ផ្តល់ចំណែកមរតកឱ្យគាត់ និងរួមសង្វាស់ជាមួយគាត់ តាមធម្មតាដូចបុរសនានាទេ;

១៨៦- ហើយ(ប្រសិនបើគាត់មានវ័យចំណាស់ជាងគេ) សិទ្ធិរៀមច្បងរបស់គាត់ត្រូវដកហូត ហើយចំណែកបន្ថែមដោយសារជាកូនប្រុសច្បងបង្អស់ ហើយប្អូនប្រុសបន្ទាប់ដែលបានកន្លែងរបស់គាត់ ដោយមានគុណធម៌ប្រសើរជាង នឹងបានចំណែករបស់បងប្រុសបង្អស់។

១៨៧- ប៉ុន្តែនៅពេលគាត់បានបំពេញតបៈរបស់ខ្លួន ពួកគេនឹងងូតទឹកជាមួយគាត់ក្នុងស្រះទឹកពិសិដ្ឋ និងបោកបំបែកឆ្នាំងថ្មីដែលមានទឹកពេញ។

---

**១៨១.** គោត. ជំពូក២១ លេខ៣; វស. ជំពូក១ លេខ២២; ពោធ. ជំពូក២ លេខ២, ៣៥; យញ្ញ. ជំពូក៣ លេខ២៦១; វិ. ជំពូក៣៥ លេខ៣-៥។ គោវ. និងនារ. បកស្រាយកាព្យផ្សេងថា 'អ្នកដែលសេពគប់ជាមួយមនុស្សក្រៅវណ្ណៈ ដោយការបូជាដល់គេ ឬដោយការចងសម្ព័ន្ធមេត្រីរបស់គេជាមួយញាតិខាងម្តាយ ក្លាយជាមនុស្សក្រៅវណ្ណៈ ក្រោយមួយឆ្នាំ ប៉ុន្តែមិនមែនដោយការប្រើរទេះ ឬកៅអីជាមួយគ្នា ឬទទួលទានជាមួយគេទេ'។ ក្នុងករណីក្រោយនេះ គឺត្រូវការពេលបួនឆ្នាំ។ សេចក្តីប្រហាក់ប្រហែលគ្នារបស់វិស្ណុ យ៉ាងណាមិញ សបញ្ជាក់យ៉ាងច្បាស់នូវអ្វីដែលចង់បញ្ជាក់ជូន។

**១៨២.** វិ. ជំពូក៥៤ លេខ១។

**១៨៣-១៨៦.** គោត. ជំពូក២០ លេខ៤-៧; វស. ជំពូក១៥ លេខ១២-១៦; ពោធ. ជំពូក២ លេខ១, ៣៦; យញ្ញ. ជំពូក៣ លេខ២៩៥។

**១៨៣.** 'ក្នុងវត្តមានរបស់សាច់ញាតិ ជាដើម' គឺ 'ក្នុងចំណោមអ្នកធ្វើពិធី មិនមែនក្នុងចំណោមអ្នកក្រៅវណ្ណៈទេ'(មេធ.)។

**៨៤.** 'ហាក់ដូចជាធ្វើសម្រាប់អ្នកដែលចែកឋានទៅ' គឺ 'ដោយនិយាយថា "នេះគឺសម្រាប់...."'(មេធ.) 'ដោយបែរទៅទិសខាងត្បូង'(គោវ., កុល្ល., នារ., នន្ទ., រាឃ.)។

**១៨៥.** ខ្ញុំចូលចិត្តសំណេររបស់លោក K.*និវរតេរ៍ តត តស្មាត* ។ តាមលោកមេធ. ថា 'អ្នកផ្សេង'បកស្រាយ *ទាយាទ្យ* 'ចំណែកនៃមរតក' ថា 'លុយ' ហើយគិតថា ថវិកាទាំងអស់សម្រាប់រូបគាត់ ត្រូវប្រគល់ទៅឱ្យទាយាទរបស់គាត់។

**១៨៧-១៨៨.** គោត. ជំពូក២០ លេខ១០-១៤; វស. ជំពូក១៥ លេខ១៧-២១; ពោធ. ជំពូក២ លេខ១, ៣៦; យញ្ញ. ជំពូក៣ លេខ២៩៦។

# ការដេញចេញពីសាសនា និងការឲ្យចូលក្នុងសាសនាវិញ

១៨៨- ប៉ុន្តែគាត់ត្រូវបោះឆ្នាំងនោះចូលក្នុងទឹក ដើរចូលក្នុងផ្ទះរបស់គាត់ ហើយបំពេញករណីយកិច្ចទាំងអស់របស់ខ្លួនចំពោះញាតិ។

១៨៩- សូមអ្នកប្រតិបត្តិតាមវិធានដដែលនេះ ក្នុងករណីមនុស្សស្រីក្រៅវណ្ណៈ ប៉ុន្តែគេត្រូវផ្តល់សម្លៀកបំពាក់ អាហារ និងភេសជ្ជៈ ដល់ពួកគេ ហើយពួកគេត្រូវនៅជិតផ្ទះ(គ្រួសារនោះ)។

១៩០- ចូរអ្នកកុំប្រកបធុរកិច្ចណាមួយជាមួយមនុស្សដែលមិនទាន់បានធ្វើខ្លួនឱ្យបរិសុទ្ធ ប៉ុន្តែចូរអ្នកត្រូវតែក្រើនរំលឹកអ្នកទាំងឡាយដែលបានលាងបាបនោះផង។

១៩១- ចូរអ្នកកុំរស់នៅជាមួយឃាតករសម្លាប់ក្មេង ជាមួយអ្នកដែលបានប្រែពីអាក្រក់មកធ្វើល្អវិញ និងជាមួយអ្នកសម្លាប់អ្នកសុំការការពារ ឬស្ត្រី ទោះជាពួកគេអាចធ្វើខ្លួនឱ្យបរិសុទ្ធ តាមច្បាប់ពិសិដ្ឋក៏ដោយ។

១៩២- បុរសមានកំណើតពីរដងទាំងឡាយ ដែលគេមិនអាចទូន្មានសាវិត្រីក្នុងពេល ដែលមានវិធានបញ្ញត្តិ គេត្រូវជំរុញឱ្យធ្វើ (តបៈ) ក្ឫច្រ្ឆ បី ហើយបន្ទាប់មក ធ្វើពិធីទទួលពួកគេជាថ្មីស្របតាមច្បាប់។

១៩៣- ចូរអ្នកប្រកាន់យកនូវ (ការលាងបាប) ដដែលនេះ នៅពេលបុរសមានកំណើតពីរដង ដែលប្រកបមុខរបរហោមឃាត់ ឬមិនយកចិត្តទុកដាក់ (សិក្សា) ព្រះវេទ ចង់ធ្វើតបៈ។

១៩៤- ប្រសិនបើព្រាហ្មណ៍មានទ្រព្យ ដោយសារអំពើដែលគួរឱ្យស្ដីបន្ទោស ពួកគេបានបរិសុទ្ធ ដោយការលះបង់ទ្រព្យ សូត្រធម៌ និង(ធ្វើ)តបៈដ៏តឹងរ៉ឹង។

១៩៥- ដោយការសូត្រសាវិត្រី ដោយចិត្តមូល ចំនួនបីពាន់ដង (រស់នៅ)រយៈពេលមួយខែនៅក្នុងរោងមេគោ (និង)ចិញ្ចឹមជីវិតអាស្រ័យលើទឹកដោះគោ (បុរស)បានរួចរំដោះពី(ទោសក្នុងការ)ទទួលអំណោយពីមនុស្សពាល។

១៩៦- ប៉ុន្តែពេលគេត្រឡប់មកពីរោងមេគោវិញ ដោយបានចុះស្គមដោយការអត់អាហាររបស់ខ្លួន និងគោរពយ៉ាងខ្ជាប់ខ្ជួន (ព្រាហ្មណ៍)នឹងសួរគេថា ‹សំឡាញ់ តើឯងចង់បានស្មើយើងទេ?›

---

**១៨៨.** គោវ., កុល្ល., រាឃ. និងអ្នកដទៃទៀត តាមការស្រង់សេចក្ដីរបស់លោកមេធ. មានន័យដូច្នេះ។ ប៉ុន្តែអ្នកអធិប្បាយក្រោយនេះ ឱ្យន័យ *ស តុ* ‹ប៉ុន្តែគេ› ថា សាច់ញាតិមួយ ហើយនារ. ទំនងជាយល់ស្របតាមគាត់។

**១៨៩.** យញ្ញ. ជំពូក៣ លេខ២៩៧។

**១៩០-១៩១.** វិ. ជំពូក៥៤ លេខ៣២-៣៣; យញ្ញ. ជំពូក៣ លេខ២៩៩។

**១៩២.** អាប. ជំពូក១ លេខ១, ២៣-២, ១០; វស. ជំពូក១១ លេខ៧៦-៧៩; វិ. ជំពូក៥៤ លេខ២៦។ ចំពោះពេលវេលាសម្រាប់ធ្វើពិធីទទួលសមាជិកថ្មី សូមមើលជំពូក២ លេខ៣៨ ខាងលើ។

**១៩៣.** វិ. ជំពូក៥៤ លេខ២៧។

**១៩៤.** វិ. ជំពូក៥៤ លេខ២៤, ២៨; យញ្ញ. ជំពូក៣ លេខ២៩០។ ‹ដោយអំពើដែលគួរឱ្យស្ដីបន្ទោស› គឺ ‹ដោយការទទួលអំណោយពីមនុស្សពាល និងអំពើប្រហាក់ប្រហែលនេះ›។

**១៩៥.** មេធ. កត់សម្គាល់ឃើញ សម្រាប់អ្នកខ្លះ គឺថា ជនល្មើសត្រូវសូត្រគាយត្រី រាល់ថ្ងៃ ឱ្យបានបីពាន់ដង តែអ្នកខ្លះថា បីពាន់ដងក្នុងមួយខែពេញ។

**១៩៦-១៩៧.** យញ្ញ. ជំពូក៣ លេខ៣០០។

១៩៧- ប្រសិនបើគេឆ្លើយប្រាប់ព្រាហ្មណ៍ថា ‹តាមពិត (ខ្ញុំនឹងមិនបំពានទៀតទេ)› គេនឹងដាក់ស្មៅឱ្យមេគោ ហើយប្រសិនបើមេគោគោរពដល់ទីកន្លែងនោះ (ដោយបរិភោគស្មៅនោះ) ព្រាហ្មណ៍នឹងអនុញ្ញាតឱ្យគេ(ចូលក្នុងសហគមន៍របស់ពួកគេ)វិញ។

១៩៨- អ្នកដែលបានបូជាចំពោះព្រាត្យ ឬបានធ្វើបុណ្យសពអ្នកដទៃ ឬពិធីវេទមន្ត(សំដៅបំផ្លាញជីវិត) ឬពិធីយញ្ញអហិន លុបលាង(ទោសរបស់ខ្លួន) ដោយការធ្វើ(តបៈ)ក្ឫច្រ្ឆបី។

១៩៩- បុរសមានកំណើតពីរដង ដែលបានផ្តាច់ទំនាក់ទំនងអ្នកសុំការការពារ ឬបានបកស្រាយព្រះវេទ (ដោយមិនត្រឹមត្រូវ) លុបលាងបទល្មើសរបស់ខ្លួន ប្រសិនបើគេចិញ្ចឹមជីវិតដោយស្រូវសាឡី ក្នុងអំឡុងមួយឆ្នាំ។

២០០- អ្នកដែលត្រូវបានឆ្កែ ឆ្កែព្រៃ ឬលា មំសាសត្វដ៏ស្លូត មនុស្ស សេះ អូដ្ឋ ឬជ្រូក(ស្រុក)ខាំ បាន បរិសុទ្ធដោយការអត់ដង្ហើមរបស់ខ្លួន (ប្រាណាយាម)។

២០១- ការបរិភោគរយៈពេលមួយខែនូវអាហារមួយភាគប្រាំមួយ(ប៉ុណ្ណោះ) ការសូត្រសំហិតា(នៃព្រះ វេទ)និង(ធ្វើ)ការបូជាសាកលរាល់ថ្ងៃ ជាមធ្យោបាយធ្វើឱ្យបរិសុទ្ធសម្រាប់អ្នកដែលត្រូវគេដេញ ចេញពីសង្គម ក្នុងពេលបរិភោគអាហារ(អបាង្កត្យ)។

---

**១៩៧.** សេចក្តីផ្តើមនៃកាព្យនេះ ត្រូវលោកនារ. និងនន្ទ. បកស្រាយផ្សេង គឺ 'ប្រសិនបើគេប្រាប់ការពិតដល់ព្រាហ្មណ៍ គឺ ចំពោះបទល្មើសរបស់ខ្លួន និងការធ្វើតបៈរបស់ខ្លួន'។ មេធ. ប្រែ *តីរថ* ក្នុងន័យធម្មតា 'កន្លែងងូតទឹក' ហើយភ្ជាប់ពាក្យនេះ ជាមួយ *ប្រតិគ្រហំ កុរយុះ* 'ពួកគេនឹងអនុញ្ញាតឱ្យចូលកន្លែងងូតទឹកវិញ'។ នារ. និយាយថា វាសំដៅដល់ *វ្យវហារវេត្តន* ។ ការប្រែយកតាមលោកគោវ., កុល្ល. និងរាឃ.។

**១៩៨.** អាប. ជំពូក១ លេខ២៦, ៧; វិ. ជំពូក៥៤ លេខ២៥; យញ្ញ. ជំពូក៣ ខ្សែ២៨៩។ ពាក្យ ព្រាត្យ សូមមើល ជំពូក ១០ លេខ២០។ 'ពិធីវេទមន្ត(សំដៅបំផ្លាញជីវិត)' គឺ 'ពិធីយញ្ញស្យេន ជាដើម'។ ពិធីយញ្ញអហីន ជាពិធីដែលមានរយៈ ពេលចន្លោះពី ២ថ្ងៃ និង១២ ថ្ងៃ សូមមើល Weber, *សិក្សាពីឥណ្ឌា* ជំពូក១០ លេខ៣៥៥។ លោកមេធ. គិតថា វិធាននេះ សំដៅដល់បុគ្គលដែលធ្វើការបូជាយញ្ញ(យជមាន) ចំណែកឯអ្នកផ្សេងទៀត តាមការលើកឡើងរបស់គាត់ អះអាងថា វិធាននេះគឺសម្រាប់អាចារ្យពិធីការផ្លូវការ។

**១៩៩.** យញ្ញ. ជំពូក៣ លេខ២៨៩។ *វេទំ វិប្លាវ្យ* 'ដោយបានបកស្រាយព្រះវេទ(មិនសមទំនង)' គឺ 'ដោយបានទូន្មាន មនុស្ស ដែលមិនគួរទទួលបានការទូន្មាន'(មេធ., គោវ., កុល្ល., នន្ទ.) តាមលោកនារ. គឺ 'ដោយបានបកស្រាយព្រះវេទ មិនសមទំនង ឬបានធ្វើឱ្យខូចន័យព្រះវេទ ដោយការលុបអនុស្វារ, វិសគ៌ជាដើម' ហើយតាមលោករាឃ. ថា 'ដោយបាន បំភ្លេចព្រះវេទដោយចេតនា'។

**២០០.** គោត. ជំពូក២៣ លេខ៧; វស. ជំពូក២៣ លេខ៣១; វិ. ជំពូក៥៤ លេខ១២; យញ្ញ. ជំពូក៣ លេខ២៧៧។ 'មំស សត្វដ៏ស្លូត' គឺ 'សត្វឆ្មា បង្គួយជាដើម'(មេធ., គោវ., កុល្ល., រាឃ.)។ នារ. អាន *អគ្រាំយេះ (គ្រាំយេះ) ក្រវ្យាទិះ* ហើយផ្ត ល់គួយ៉ាងថា 'ឆ្កែព្រៃ'។

**២០១.** ចំពោះពាក្យ អបាង្កត្យ ដែលកន្លែងផ្សេងហៅថា បង្កតិទូសណ 'អ្នកបង្ខូចព្រហ្មចារីមិត្ត' សូមមើលជំពូក៣ លេខ ១៥១ ខាងលើ។ នារ. កត់សម្គាល់ថា អ្នកដែលគ្មានវិធីលាងបាបផ្សេង ត្រូវធ្វើតបៈនេះប៉ុណ្ណោះ។ សាកល-ហោម ជាការ បូជា ដែលមានរៀបរាប់ដោយកាព្យប្រាំបី *វាជសនេយិ-សំហិតា* ជំពូក៨ លេខ១៣។

២០២- ព្រាហ្មណ៍ ដែលបានជិះដោយចេតនាលើរទេះដែលអូសដោយអូដ្ឋ ឬលា និងអ្នកដែលងូតទឹក ស្រាត បានបរិសុទ្ធដោយការទប់ដង្ហើមរបស់ខ្លួន(ប្រាណាយាម)។

២០៣- អ្នកដែលបានជួយសម្រាលភាពចាំបាច់នៃធម្មជាតិ ដោយត្រូវសម្ពាធយ៉ាងខ្លាំង ដោយគ្មាន (ប្រើ)ទឹកក្ដី ឬនៅក្នុងទឹកក្ដី បានបរិសុទ្ធដោយការងូតទឹកនៅខាងក្រៅ(ភូមិ) ទាំងសម្លៀកបំពាក់ និងដោយប៉ះមេគោ។

២០៤- ការតមអាហារ គឺជាតបៈសម្រាប់មិនធ្វើពិធីប្រចាំថ្ងៃ តាមការបញ្ញត្តិរបស់ព្រះវេទ និងសម្រាប់ការមិនយកចិត្តទុកដាក់ករណីយកិច្ចពិសេសរបស់ស្នាតក។

២០៥- អ្នកដែលបាននិយាយថា 'ហឹម' ដាក់ព្រាហ្មណ៍ ឬបានលើកឡើងអំពីភាពប្រសើររបស់ខ្លួន ដោយពាក្យ 'អ្នកឯង' ត្រូវងូតទឹក តមអាហារក្នុងផ្នែកនៃពេលថ្ងៃដែលនៅសល់ និងធ្វើឱ្យ(មនុស្សដែលត្រូវគេប្រមាថ)ស្ងប់ចិត្ត ដោយការគំនាប់គោរព។

២០៦- អ្នកដែលបានវាយ(ព្រាហ្មណ៍)សូម្បីដោយដើមស្មៅ ចងកគាត់ដោយក្រណាត់ ឬបានឈ្នះគាត់ដោយការឈ្លោះប្រកែក ត្រូវធ្វើឱ្យគាត់ស្ងប់ចិត្ត ដោយការក្រាបសំពះ។

២០៧- ប៉ុន្តែអ្នកដែលចង់ធ្វើឱ្យព្រាហ្មណ៍ឈឺចាប់ បានគំរាម(គាត់ដោយដំបងជាដើម) នៅតែធ្លាក់នរករយៈពេលមួយរយឆ្នាំ ហើយអ្នកដែលបានវាយព្រាហ្មណ៍(ដាក់ស្តែង) ធ្លាក់នរកមួយពាន់ឆ្នាំ។

២០៨- នឹងនៅក្នុងនរកស្មើនឹងចុណ្ណភាគធូលី ដែលកើតចេញពីឈាមរបស់ព្រាហ្មណ៍ គឺច្រើនពាន់ឆ្នាំស្មើនឹងគ្រាប់ឈាមនោះ។

២០៩- ចំពោះការគំរាមព្រាហ្មណ៍ (ជនល្មើស) នឹងធ្វើតបៈក្ឫច្ឆ្រ ចំពោះការវាយព្រាហ្មណ៍ ធ្វើអតិក្ឫច្ឆ្រ ចំពោះការធ្វើឱ្យឈាមព្រាហ្មណ៍ហូរ ធ្វើក្ឫច្ឆ្រ និងអតិក្ឫច្ឆ្រ។

២១០- ចំពោះការលាងបាបបទល្មើស ដែលគ្មានបញ្ញត្តិពីការរួចរំដោះ ចូរអ្នកកំណត់ពីការធ្វើតបៈបន្ទាប់ពីបានពិចារណាអំពីកម្លាំងនៃ(របស់ជនល្មើស) និង(លក្ខណៈនៃ)អំពើល្មើស។

---

**២០២.** វិ. ជំពូក៥៤ លេខ២២៣; យញ្ញ. ជំពូក៣ លេខ២៩១។ មេធ. និងកុល្ល. សង្កេតឃើញថា អ្នកដែលជិះលើខ្នងអូដ្ឋ ឬលា ត្រូវធ្វើប្រាណាយាមមួយ។

**២០៣.** វិ. ជំពូក៥៤ លេខ១០។ 'ក្រៅភូមិ' គឺ 'ក្នុងទន្លេ ឬប្រហាក់ប្រហែលនេះ'(មេធ., គោវ., កុល្ល., រាឃ.)។

**២០៤.** វិ. ជំពូក៥៤ លេខ២៥។ វិធានសម្រាប់ស្នាតក គឺអ្នកដែលមានរៀបរាប់នៅក្នុងជំពូកទី៤។ ពិធីប្រចាំថ្ងៃ ជាពិធីអគ្និហោត្រ ជាដើម។ ការតមអាហារ មានរយៈពេលមួយថ្ងៃ(មេធ., កុល្ល., នារ.)។

**២០៥.** យញ្ញ. ជំពូក៣ លេខ២៩២។ 'ភាពប្រសើររបស់គេគួរបញ្ជាក់ដោយពាក្យ "អ្នកឯង"'(មេធ.)។

**២០៦.** យញ្ញ. ជំពូក៣ លេខ២៩២។ សូមមើលជំពូក៤ លេខ១៦៦ខាងលើ។ គោវ. និងនារ. និយាយថា 'ព្រាហ្មណ៍ដែលគួរឱ្យគោរពជាងខ្លួនគាត់ទៅទៀត'។

**២០៧-២០៨.** សូមមើលជំពូក៤ លេខ១៦៥, ១៦៧-១៦៩ ដែលមានកំណែផ្សេងគ្នាចំពោះកាព្យទាំងនេះ។ ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ និងលោក K. ទ្វិជន្មនៈ 'នៃព្រាហ្មណ៍' ជំនួស មហីតលេ 'នៅលើដី'(សំណៅបោះពុម្ព)។

**២០៩.** វិ. ជំពូក៥៤ លេខ៣០; យញ្ញ. ជំពូក៣ លេខ២៩៣។ លោកមេធ. គូសបញ្ជាក់ថា អំពើល្មើសទាំងនេះ អាចត្រូវប្រព្រឹត្តដោយស្ម័គ្រចិត្ត ជំនួសឱ្យអំពើដែលបានរៀបរាប់នៅទីនេះ។

**២១០.** វិ. ជំពូក៥៤ លេខ៣៤; យញ្ញ. ជំពូក៣ លេខ២៩៤។

២១១- (ឥឡូវនេះ)ខ្ញុំនឹងរៀបរាប់ជូនលោកអ្នកអំពីវិធីទាំងឡាយ ដែលអាទិទេព បណ្ឌិត និងដូនតាបានអនុម័ត សម្រាប់ឱ្យមនុស្សយើងអាចរួចរំដោះពីអំពើបាបរបស់ខ្លួនបាន។

២១២- បុរសមានកំណើតពីរជង ដែលធ្វ(តបះក្ឫច្ឆ្រ) តាមការបង្ហាញរបស់ប្រជាបតិ ត្រូវទទួលទានតែពេលព្រឹក(ប៉ុណ្ណោះ)ក្នុងអំឡុងពេលបីថ្ងៃ ក្នុងអំឡុងបីថ្ងៃ(បន្ទាប់) ទទួលទានតែក្នុងពេលល្ងាច ក្នុងបីថ្ងៃបន្ទាប់ទៀត ទទួលទាន(អាហារដែលគេឱ្យ)ដោយមិនចាំបាច់សុំ ហើយត្រូវតមអាហារ ក្នុងរយៈពេលបីថ្ងៃទៀត។

២១៣- (ដោយចិញ្ចឹមជីវិតអាស្រ័យលើ)ទឹកមូត្រមេគោ អាចម៍មេគោ ទឹកដោះគោ ទឹកដោះគោជូ ប៊ីសុទ្ធ និងទឹកស្ងោរស្មៅកុសៈ និងតមអាហារមួយថ្ងៃ(មួយយប់) នេះជាតបះសាំតបន ក្ឫច្ឆ្រ។

២១៤- បុរសមានកំណើតពីរជង ដែលធ្វើ(តបះ)អតិក្ឫច្ឆ្រ ត្រូវតែបរិភោគអាហាររបស់ខ្លួន បីពេល បីថ្ងៃ តាមរបៀបដូចបានបញ្ញត្តខាងលើ (ប៉ុន្តែ)ក្នុងមួយពេលបរិភោគតែមួយម៉ាត់ពេញប៉ុណ្ណោះ និងតមអាហារក្នុងរយៈពេលបីថ្ងៃចុងក្រោយ។

២១៥- ព្រាហ្មណ៍ ដែលធ្វើ(តបះ)តប្តក្ឫច្ឆ្រ ត្រូវផឹកទឹកក្តៅ ទឹកដោះគោក្តៅ ប៊ីសុទ្ធក្តៅ និង(ស្រូប)ខ្យល់ក្តៅ ម្តងក្នុងរយៈពេលបីថ្ងៃ និងងូតទឹកម្តង ដោយសមាធិចិត្ត។

២១៦- ការតមអាហារសម្រាប់រយៈពេលដប់ពីរថ្ងៃ របស់បុរសដែលចេះគ្រប់គ្រងខ្លួនឯង និងមិនប្រព្រឹត្តកំហុស គេហៅថា បរាក ក្ឫច្ឆ្រ ដែលអាចរួចរដោះពីទោសទាំងអស់។

២១៧- ប្រសិនបើគេបន្ថយអាហារ (របស់ខ្លួនរាល់ថ្ងៃពី) មួយម៉ាត់នៅពេលងងឹត (មកកន្លះម៉ាត់) ហើយបង្កើន(វាតាមរបៀបដដែល)នៅពេលមេឃភ្លឺពាក់កណ្តាល និងងូតទឹក(រាល់ថ្ងៃ) តាមពេលបូជាបីដង (ពេលព្រឹក ថ្ងៃត្រង់ និងពេលល្ងាច) នេះជាតបះពេលរាត្រី (ចន្ទ្រាយណ)។

---

**២១២.** អាប. ជំពូក១ លេខ២៧, ៧; គោត. ជំពូក២៦ លេខ២-៥; វស. ជំពូក២១ លេខ២០; ពោធ. ជំពូក២ លេខ២, ៣៨; ជំពូក៤ លេខ៥, ៦-៧; វិ. ជំពូក៦៦ លេខ១០; យញ្ញ. ជំពូក៣ លេខ៣២០។ តាមលោកមេធ. អាហារដែលកវិយាយកមកជូន ដោយមិនចាំបាច់សុំ គឺជា ‘អាហារដែលគេឱ្យ មិនបាច់សុំដែរ’។

**២១៣.** ពោធ. ជំពូក៤ លេខ៥, ១៣; វិ. ជំពូក៦៦ លេខ១៩; យញ្ញ. ជំពូក៣ លេខ៣១៣។ ការធ្វើតបះនេះ មានវិធីពីរយ៉ាងគឺ អ្នកសារភាពទោសនោះអាចបរិភោគសារជាតុប្រាំមួយ ក្នុងមួយថ្ងៃ និងតមអាហារនៅថ្ងៃបន្ទាប់ក៏បាន ឬគេអាចទទួលទានសារជាតុមួយក្នុងចំណោមប្រាំមួយនោះក្នុងមួយថ្ងៃ ហើយតមអាហារនៅថ្ងៃទីប្រាំពីរ(មេធ., គោវ.)។ អ្នកអធិប្បាយផ្សេងទៀត ផ្តល់ការបកស្រាយទីមួយប៉ុណ្ណោះ។

**២១៤.** គោត. ជំពូក២៥ លេខ១៨-១៩; វស. ជំពូក២៤ លេខ១-២; ពោធ. ជំពូក២ លេខ២, ៤០; ជំពូក៤ លេខ៥, ៨; យញ្ញ. ជំពូក៣ លេខ៣២០។ ‘ខាងលើ’ គឺក្នុងកាព្យ ២១៣។

**២១៥.** វស. ជំពូក២១ លេខ១៨; ពោធ. ជំពូក២ លេខ២, ៣៧; ជំពូក៤ លេខ៥, ១០; វិ. ជំពូក៦៦ លេខ១១; យញ្ញ. ជំពូក៣ លេខ៣១៨។

**២១៦.** ពោធ. ជំពូក៤ លេខ៥, ១៥; វិ. ជំពូក៦៦ លេខ១៨; យញ្ញ. ជំពូក៣ លេខ២២១។ ‘ប្រព្រឹត្តកំហុស’ គឺ ‘ចំពោះវិធានទូទៅ ដែលគេត្រូវគោរពក្នុងពេលធ្វើតបះក្ឫច្ឆ្រ’ សូមមើលវស. ជំពូក២៤ លេខ៥ (មេធ., នារ.)។

**២១៧-២២៦.** គោត. ជំពូក២៧; វស. ជំពូក២៤ លេខ៤៥-៤៧; ជំពូក២៧ លេខ២១; ពោធ. ជំពូក៣ លេខ៨ជំពូក៤ លេខ១៧-២១; វិ. ជំពូក៦៧; យញ្ញ. ជំពូក៣ លេខ៣២៤-៣២៧។

**២១៧.** ទម្រង់តបះពេលរាត្រី ដែលបញ្ញត្តិក្នុងកាព្យនេះ ជាតបះបបីលិកាមធ្យ ឬតបះរាងស្រមោច ដែលការតមអាហារ ឬថ្ងៃស្គមកំប្រឹង នៅចំពាក់កណ្តាល។

២១៨- ចូរអ្នកប្រតិបត្តិតាមវិធានដដែល(គឺធ្វើចន្ទ្រាយណ) យវមធ្យម (មានរាងដូចគ្រាប់ស្រូវបាឡេ) ប៉ុន្តែចូរអ្នក(ក្នុងករណីនោះ)ចាប់ផ្តើមធ្វើតបៈពេលរាត្រី ដោយចិត្តមូល នៅថ្ងៃទីមួយខែរះពាក់កណ្តាល។

២១៩- អ្នកដែលធ្វើតបៈរាត្រីរបស់តាបស ត្រូវបរិភោគរាល់ថ្ងៃ ពេលថ្ងៃត្រង់(ក្នុងអំឡុងមួយខែ)ចំនួនប្រាំបីម៉ាត់ ដោយចេះគ្រប់គ្រងខ្លួនឯង និងទទួលទានអាហារយញ្ញ (ប៉ុណ្ណោះ)។

២២០- ប្រសិនបើព្រាហ្មណ៍បរិភោគបួនម៉ាត់ (រាល់ថ្ងៃក្នុងអំឡុងមួយខែ) នៅពេលព្រឹក និងបួនម៉ាត់បន្ទាប់ពីថ្ងៃលិច (នេះជា)តបៈរាត្រីសម្រាប់ក្មេង។

២២១- អ្នកដែលបរិភោគបីដងនូវអាហារយញ្ញចំនួនប្រាំបីមាត់ តាមរបៀបណាក៏ដោយក្នុងអំឡុងមួយខែ ស្នាក់នៅ(បន្ទាប់ពីស្លាប់)ក្នុងឋានព្រះច័ន្ទ។

២២២- រុទ្រ ដូចជាអាទិត្យ វសុស និងមរុត រួមជាមួយមហាបណ្ឌិត ដែលបានអនុវត្ត(ពិធី)នេះ ដើម្បីរួចរំដោះនូវអំពើអាក្រក់ទាំងអស់។

២២៣- ការដុតបូជា ដែលអមដោយ(ការសូត្រ)មហាវ្យាត្រិស (អ្នកសារភាពទោស) ត្រូវធ្វើរាល់ថ្ងៃ ដោយខ្លួនឯង ហើយគេត្រូវតែវៀរចាកកុំបង្កការឈឺចាប់ដល់(សត្វលោក) និយាយពាក្យពិត និងទប់ចិត្តខ្លួនកុំឱ្យមានកំហឹង និងភាពមិនស្មោះត្រង់។

២២៤- ចូរអ្នកងូតទឹកបីដងក្នុងមួយថ្ងៃ និងបីដងក្នុងមួយយប់ ទាំងសម្លៀកបំពាក់របស់ខ្លួន ចូរអ្នកកុំនិយាយទៅកាន់ស្ត្រី សូទ្រៈ និងមនុស្សក្រៅវណ្ណៈ។

២២៥- ចូរអ្នកឈរឱ្យផុត(ពេលថ្ងៃ) និងអង្គុយ(នៅពេលយប់) ឬប្រសិនបើអ្នកមិនអាចធ្វើ (ដូច្នោះបាន) ចូរអ្នកដេកលើដី(ទទេ) ហើយចូរអ្នករក្សាភាពបរិសុទ្ធ និងគោរពពាក្យសច្ច(ជាសិស្ស) និងគោរពគុរុរបស់ខ្លួន អាទិទេព និងព្រាហ្មណ៍។

២២៦- ចូរអ្នកសូត្រសាវិត្រីជាប្រចាំ និងធម៌សម្អាតកាយចិត្ត ស្របតាមលទ្ធភាពរបស់ខ្លួន (ចូរអ្នក) យកចិត្តទុកដាក់(ធ្វើដូច្នេះ) ក្នុងពេលធ្វើបំពេញពាក្យសច្ចៈ ដោយការធ្វើតបៈ។

---

**២១៨.** ជាការល្អ យើងគួរអានតាមលោកមេធ. និងគោវ. ក្នុងបន្ទាត់ទីពីរ *ចរេត* ជំនួស *ចរេ*។ គោវ. សរសេរ *ចរេ* នៅបន្ទាត់ទីមួយ។ លោកនន្ទ. អានពាក្យចុងក្រោយផ្សេងទៅវិញ (និយត) ចន្ទ្រាយណ អថាបរំ។

**២២១.** 'ដោយវិធីណាក៏ដោយ' គឺ 'ដោយមិនចាំបាច់គោរពតាមការកំណត់ពិសេសណាមួយ ត្រឹមចំនួនម៉ាត់ ដែលត្រូវបរិភោគក្នុងមួយថ្ងៃទេ'(នារ.)។

**២២៤.** មេធ. សង្កេតឃើញថា អ្នកសារភាពទោស យ៉ាងណាមិញ អាចនិយាយទៅកាន់សមាជិកគ្រួសារ ជាស្ត្រីរបស់ខ្លួនបាន ប្រសិនបើកាលៈទេសៈតម្រូវ។

**២២៥.** វ្រតី ស្យាត 'គោរពពាក្យសច្ច(ក្នុងនាមជាអ្នកសិក្សា)' គឺ 'ពាក់ខ្សែស្មៅមុញ្ជ កាន់ដំបងជាដើម'(គោវ., កុល្ល., នារ.) តាមលោកមេធ. ថា 'ចូរគេតាំងចិត្តតមនូវអ្វី ដែលមនុស្សល្អមិនហាមឃាត់'។

**២២៦.** 'ធម៌សម្អាតកាយចិត្ត' គឺ'អឃមស៌ណ,បាវមានីសជាដើម' សូមមើលវិ.ជំពូក៥៦។ 'ពាក្យសច្ចៈផ្សេងទៀត'គឺ'ក្ឫច្ឆ្រ'។

២២៧- ដោយវិធីលាងបាបទាំងអស់នេះ បុរសមានកំណើតពីរដង ត្រូវបានបរិសុទ្ធនូវអំពើបាបដែលខ្លួនដឹង ប៉ុន្តែចូរអ្នកធ្វើឱ្យបរិសុទ្ធនូវអំពើបាបដែលមិនបានដឹង ដោយ(ការសូត្រ)ធម៌ពិសិដ្ឋ និងដោយការធ្វើពិធីដុតបូជា។

២២៨- ដោយការសារភាព ការស្តាយក្រោយ ការធ្វើតបកម្ម និងការសូត្រ(ព្រះវេទ) អ្នកប្រព្រឹត្តអំពើបាបបានរួចរដោះពីទោស ហើយក្នុងករណីគ្មានវិធីផ្សេង អាចធ្វើដោយចិត្តសទ្ធាដាក់ទាន។

២២៩- តាមសមាមាត្រទម្ងន់ទោសដែលបុរសនោះបានប្រព្រឹត្ត គេត្រូវសារភាពដោយខ្លួនឯង សូម្បីគេបានរួចរំដោះពីទោស ចាប់ពីពេលនេះទៅ បីដូចជាពស់ចេញផុតពីសំណករបស់វា។

២៣០- តាមសមាមាត្រចិត្តស្អប់ខ្ពើមអំពើអាក្រក់របស់ខ្លួន សូម្បីដល់ពេលនេះកាយរបស់គេបានរួចរំដោះពីទោសនោះហើយ។

២៣១- អ្នកដែលបានប្រព្រឹត្តអំពើបាប និងបានដឹងកំហុសរបស់ខ្លួន រួចរំដោះពីអំពើបាបនោះ ប៉ុន្តែអ្នកបានបរិសុទ្ធដោយ(ការតាំងចិត្ត) ឈប់ធ្វើ (អំពើបាបប៉ុណ្ណោះ និងគិតថា) 'ខ្ញុំឈប់ធ្វើដូច្នេះទៀតហើយ'។

២៣២- បន្ទាប់ពីបានពិចារណាក្នុងចិត្តនូវផលដែលកើតមានពីអំពើរបស់ខ្លួនបន្ទាប់ពីស្លាប់យ៉ាងនេះ ចូរគេធ្វើល្អដោយកាយ វាចា និងចិត្តជានិច្ច។

២៣៣- អ្នកដែលបានប្រព្រឹត្តអំពើមានទោសដោយចេតនាក្តី ឬអចេតនាក្តី ចង់រួចរំដោះពី (ទោសនៃ) អំពើនោះ មិនត្រូវប្រព្រឹត្តអំពើអាក្រក់ជាលើកទីពីរទេ។

២៣៤- ប្រសិនបើចិត្តរបស់អ្នកមិនបានសុខចំពោះអំពើណាមួយចូរអ្នកចាប់ធ្វើតបកម្មជាថ្មី (តាមបញ្ញត្តិស្តីពីតបៈ)សម្រាប់អំពើនោះ រហូតដល់តបកម្មនោះធ្វើឱ្យ(មនសិការខ្លួន)រួចរំដោះទាំងស្រុង។

២៣៥- បណ្ឌិតតាមការបង្ហាញរបស់ព្រះវេទ បានប្រកាសពីពរជ័យទាំងអស់របស់អាទិទេព សម្រាប់ការធ្វើតបកម្មខាងដើម តបកម្មកណ្តាល និងតបកម្មខាងចុង។

---

**២២៧.** *វស*. ជំពូក២៥ លេខ៣។ តបៈតាមធម្មតា ត្រូវបានដាក់ចេញដោយបរិស័ទ សភារបស់ព្រាហ្មណ៍អ្នកចេះដឹង។ ក្នុងករណីអំពើបាបដ៏ពិសិដ្ឋ អ្នកចេះដឹងធ្វើការកំណត់អំពីតបៈ តាមរបៀបទូទៅ មិនថែងសម្រាប់ករណីពិសេសទេ។ តាមការបកស្រាយនេះ អ្នកអធិប្បាយជម្នះការលំបាក ដែលអាន *សោធយេត* 'ចូរអ្នកធ្វើឲ្យបរិសុទ្ធ'។ ប៉ុន្តែលោកនារ. អាន អនាវិស្កុតបាបាស តុ មន្ត្រៃ ហោមេ ច សោធនេះ 'ប៉ុន្តែអំពើបាបទាំងឡាយដែលគេមិនបានដឹង ដោយធម៌ពិសិដ្ឋ និងការបូជាអគ្គី (ត្រូវគេប្រកាសថាជា)មធ្យោបាយសម្រាប់ធ្វើឱ្យបរិសុទ្ធអំពើបាប'។

**២២៨.** *អាបទិ* 'ក្នុងករណីគ្មានវិធីផ្សេង' គឺ 'ប្រសិនបើជនល្មើសមិនអាចធ្វើតបៈ ឬសូត្រអត្ថបទព្រះវេទបាន'។

**២៣០.** 'កាយរបស់គេ' គឺ 'ព្រលឹងក្នុងកាយរបស់គេ'(មេធ., គោវ., កុល្ល., នន្ទ.) ឬ 'កាយដ៏ល្អិតសុខុម'(នារ.)។

**២៣១.** ជំនួសពាក្យ *នៃវំ* 'គ្មាន(ដូច្នេះទៀត)ទេ' លោកនារ. អាន *នៃនះ* '(ខ្ញុំនឹង)មិនធ្វើអំពើបាប(ទៀត)ទេ' ហើយសំណេររបស់ K. *នៃនំ* សំដៅដល់សំណេរដូចគ្នា។ គោវ., នន្ទ. និងសំណៅត្រឹមត្រូវបំផុតរបស់លោកមេធ. អាន *នៃតត កុយាត បុនរ ឥតិ*ហើយប្រែដូច្នេះថា 'ប៉ុន្តែគេបានបរិសុទ្ធដោយការឈប់ប្រព្រឹត្តអំពើបាប(ប៉ុណ្ណោះ) ហេតុនេះគេមិនត្រូវធ្វើអំពើបាបទៀតទេ'។

**២៣៥.** 'ត្រូវធ្វើតបកម្មផ្នែកខាងដើម ធ្វើតបកម្មផ្នែកកណ្តាល និងធ្វើតបកម្មផ្នែកខាងចុង' គឺ 'ត្រូវធ្វើ បន្តធ្វើ និងបញ្ចប់ដោយសារតបកម្មត្រូវបានធ្វើរួចហើយ'(មេធ., កុល្ល., នារ.)។

២៣៦- (ការស្វែងរក)ចំណេះដឹងពិសិដ្ឋ ជាតបកម្មរបស់ព្រាហ្មណ៍ ការការពារ(ប្រជាជន)ជាតបកម្មរបស់ក្សត្រិយ (ការប្រកប) ធុរកិច្ចប្រចាំថ្ងៃរបស់ខ្លួន ជាតបកម្មរបស់វៃស្យ ហើយការបម្រើជាតបកម្មរបស់ពួកសូទ្រ:។

២៣៧- បណ្ឌិតដែលចេះគ្រប់គ្រងខ្លួនឯង និងចិញ្ចឹមជីវិតដោយផ្លែឈើ មើមឈើ និងខ្យល់ ពិនិត្យមើលលោកទាំងបី ព្រមទាំង(សត្វលោក)ដែលមានចលនា និងគ្មានចលនារបស់លោកទាំងបី ដោយការធ្វើតបកម្មរបស់ខ្លួនតែម្យ៉ាង។

២៣៨- ឱសថ សុខភាពល្អ ការសិក្សា និងស្ថានភាពទេវៈផ្សេងៗ សម្រេចបានដោយការធ្វើតបកម្មតែម្យ៉ាង ព្រោះតបកម្មជាមធ្យោបាយសម្រាប់សម្រេចបានរបស់ទាំងនោះ។

២៣៩- អ្វីក៏ដោយដែលរឹងពិបាកទម្លុះទម្លាយបាន អ្វីក៏ដោយដែលពិបាកសម្រេចបាន អ្វីក៏ដោយដែលពិបាកឈោងចាប់បាន អ្វីក៏ដោយដែលពិបាកអនុវត្តបាន ទាំងអស់នេះ អាចសម្រេចទៅបានដោយការធ្វើតបកម្ម ពីព្រោះតបកម្ម(បាននូវអំណាច) ដែលពិបាកនឹងរកអ្វីប្រសើរជាងនេះ។

២៤០- អ្នកទាំងពីរដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ (មហាបាបតក) និងជនល្មើសផ្សេងទៀតទាំងអស់ បានរួចរំដោះពីទោសរបស់ខ្លួនយ៉ាងច្រើន ដោយវិធីធ្វើតបកម្មត្រឹមត្រូវ។

២៤១- សត្វល្អិត ពស់ ខ្មូត ឃ្មុំ សត្វស្លាប និងសត្វលោក ដែលគ្មានចលនា ឡើងឋានសួគ៌ ដោយសារអំណាចនៃតបកម្ម។

២៤២- អំពើបាបអ្វីក៏ដោយដែលមនុស្សប្រព្រឹត្តដោយចិត្ត ពាក្យសម្ដី ឬអំពើ បាបនោះគេអាចដុតកម្ទេចបានយ៉ាងឆាប់រហ័ស ដោយតបៈ ប្រសិនបើពួកគេរក្សាការធ្វើតបៈ ឱ្យកាន់តែចម្រើនឡើង។

២៤៣- អាទិទេពទទួលការបូជារបស់ព្រាហ្មណ៍ណាដែលបានធ្វើឱ្យខ្លួនបរិសុទ្ធ ដោយតបកម្ម និងប្រទាននូវអ្វីៗទាំងអស់តាមសេចក្ដីប្រថ្នារបស់គាត់។

២៤៤- ព្រះជាម្ចាស់ ប្រជាបតិ បានបង្កើតគោលការណ៍(ច្បាប់ពិសិដ្ឋ)ទាំងអស់នេះ ដោយការធ្វើតបៈរបស់ទ្រង់តែម្យ៉ាង ដូចគ្នានេះដែរបណ្ឌិតទាំងឡាយបានទទួល(ការបង្ហាញ)ព្រះវេទ តាមរយៈការធ្វើតបកម្មរបស់ខ្លួន។

២៤៥- អាទិទេពដែលដឹងថា ដើមកំណើតដ៏ពិសិដ្ឋនៃ (ចក្រវាល) ទាំងមូល គឺចេញពីតបកម្ម បានប្រកាសមកយ៉ាងនេះនូវអំណាចរបស់តបកម្ម ដែលគ្មានអ្វីប្រៀបប្រដូចបាន។

---

**២៣៨.** មេធ. បកស្រាយ *ឱសធានិ* 'ឱសថ' ថា 'ស្រាថ្នាំ'។ ជំនួសពាក្យ *អគទោ* (កុល្លូ., K., រាឃ.) លោកមេធ., គោវ., នារ. និងនន្ទ អាន *អគទាះ* ហើយបកស្រាយថា 'ឱសថ'(មេធ., នន្ទ.) 'ថ្នាំកែរោគ ឬស្នេហ៍ប្រឆាំងពិស'(គោវ., នារ.)។

**២៤១.** ជំនួសពាក្យ *កីតាស ច* 'សត្វល្អិត' លោកនារ. អាន *ស្វានស ច* 'សត្វឆ្កែ'។ គោវ. និងនន្ទ. និយាយថា កាព្យនេះសំដៅដល់ *កីតោខ្យាន* និង *កបោតាខ្យាន* ដែលបានប្រាប់នៅក្នុងឥតិហាសៈ (មហាភារតៈ ជំពូក១២)។

**២៤៥.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ និង K. នៅខាងចុងនៃកាព្យនេះ *ឧត្តរំ* ជំនួសពាក្យ *ឧត្តមំ* (សំណៅបោះពុម្ព)។

២៤៦- ការសិក្សាព្រះវេទរាល់ថ្ងៃ ការធ្វើមហាបូជាយញ្ញស្របតាមលទ្ធភាពរបស់ខ្លួន (និង) អត់ធន់ (សុខចិត្តរងទុក្ខ) កម្ចាត់បង់នូវទោសទាំងអស់ឱ្យបានឆាប់រហ័ស សូម្បីបាបនោះជាអំពើបាបធ្ងន់ធ្ងរក៏ដោយ។

២៤៧- បីដូចភ្លើងប្រើប្រាស់ប្រេងមួយខណៈសម្រាប់ផ្តល់ពន្លឺភ្លើងដូច្នេះក្តី អ្នកដែលចេះព្រះវេទ កម្ចាត់បង់ទោសទាំងអស់ ដោយភ្លើងនៃចំណេះដឹង។

២៤៨- តបៈចំពោះអំពើបាប (ដែលដឹងឮសាធារណៈ) ត្រូវបានប្រកាសមកយ៉ាងនេះ ស្របតាមច្បាប់ ហើយបន្តទៅនេះចូរសិក្សាអំពីតបៈសម្រាប់(អំពើបាប)ដែលស្ងាត់កំបាំង។

២៤៩- ការទប់ដង្ហើមដប់ប្រាំមួយខណៈ (ប្រាណាយាម) អមដោយ (ការសូត្រ) វ្យាហ្ឫតិស និងព្យាង្គឱម ធ្វើឱ្យបរិសុទ្ធ ប្រសិនបើគេសូត្រដដែលៗរាល់ថ្ងៃ ក្រោយពីមួយខែ ទោះជាឃាតករសម្លាប់ព្រាហ្មណ៍ចេះដឹងក៏ដោយ។

២៥០- សូម្បីអ្នកផឹក (គ្រឿងស្រវឹង ហៅថា) សុរា បានបរិសុទ្ធ ប្រសិនបើគេសូត្រខ្សឹបៗនូវចម្រៀងសរសើរព្រះ (ដែលបានឃើញ) ដោយព្រះកុត្ស 'ដោយភាពរុងរឿងរបស់ទ្រង់ សូមឱ្យយើងខ្ញុំបានរួចរំដោះពីទោស ឱ ព្រះអគ្និ'ជាដើម (ដែលបានឃើញ) ដោយវសិស្ឋ 'ដោយចម្រៀងសរសើរ របស់ពួកគេ វសិស្ឋ ភ្ញាក់ឡើងព្រលឹមអុស'ជាដើម មាហិត្រ(ចម្រៀង) និង(កាព្យ ហៅថា) សុទ្ធវតី។

២៥១- សូម្បីអ្នកដែលបានលួចមាស បានរួចរំដោះពីទោសភ្លាម ប្រសិនបើគេច្រៀង (ចម្រៀងសរសើរផ្តើមដោយពាក្យ) 'បងប្អូនប្រុសកណ្តាលរបស់អាចារ្យហោត្ឫពីបុរាណដ៏ស្រស់សោភា' និងសិវសំកល្ប។

---

**២៤៦.** វស. ជំពូក២៧ លេខ៧; យញ្ញ. ជំពូក៣ លេខ៣១១។

**២៤៧.** វស. ជំពូក២៧ លេខ១-២។

**២៤៨.** កុល្ល. និងរាឃ. អះអាងថា គោវ. លុបកាព្យនេះ ចំណែកឯលោកមេធ. មានសរសេរកាព្យនេះ។ យ៉ាងណាមិញ សំណៅរបស់លោកគោវ. ដែលយើងអាចរកបានបង្ហាញច្បាស់ តែគ្មានសេចក្តីអធិប្បាយទេ។ លោកមេធ. និយាយត្រឹមតែថា 'អ្នកខ្លះ'អានដូច្នេះ។ នារ. និងនន្ទ. លុបកាព្យនេះ។

**២៤៩.** វស. ជំពូក២៦ លេខ៤; វិ. ជំពូក៥៥ លេខ៥; ពោធ. ជំពូក៤ លេខ១, ២៩។ លោកនារ. បកស្រាយពាក្យនេះបានត្រឹមត្រូវ បំផុត គឺ 'អមដោយ(ការសូត្រ)វ្យាហ្ឫតិស និងព្យាង្គ ឱម' ហើយអះអាងថា ពាក្យទាំងនេះសបញ្ជាក់ពីភាពចាំបាច់នៃការសូត្រគាយត្រី ជាមួយនឹងអត្ថបទសិរៈ ក្នុងអំឡុងធ្វើប្រាណាយាម សូមមើលវស. ជំពូក២៥ លេខ១៣។

**២៥០.** វស. ជំពូក២៥ លេខ៥។ ចម្រៀងដែលបានឃើញដោយព្រះកុត្ស គឺ ឫគវេទ ជំពូក១ លេខ៩៧ ចម្រៀងដែលបានឃើញដោយវសិស្ឋ គឺ ឫគវេទ ជំពូក៧ លេខ៨០។ ចម្រៀងមហិត្រ គឺ ឫគវេទ ជំពូក១០ លេខ១៨៥។ សុទ្ធវតី គឺ ឫគវេទ ជំពូក៨ លេខ៨៤, ៧-៩។ មេធ., គោវ., នារ. និង K. អាន មាហេន្ទ្រំ ជំនួស មាហិត្រំ ហើយលោកនារ. បន្ថែមថា អ្នកខ្លះសរសេរសំណេរក្រោយ។ ចម្រៀងនេះ គេត្រូវសូត្រមួយខែដប់ប្រាំមួយដង(គោវ., កុល្ល., រាឃ.) ឬ ១០៨ដង ក្នុងមួយថ្ងៃ (នារ.)។

**២៥១.** វស. ជំពូក២៦ លេខ៦។ ចម្រៀងនេះ ឃើញមាននៅក្នុងឫគវេទ ជំពូក១ លេខ១៦៤; សិវសំកល្ប ជំពូក៥ វាជ. សំហ. ជំពូក៣៤ លេខ១។ 'ម្តង' គឺ 'ម្តងមួយថ្ងៃ ក្នុងអំឡុងមួយខែ'(គោវ., កុល្ល., នារ.)។

២៥២- អ្នកបំពានគ្រែរបស់គុរុ បានរួចរំដោះ(ពីបាប) ប្រសិនបើគេសូត្រដដែលៗនូវ(បទ) ហរិស្បាន្តីយ (ដែលផ្ដើមដោយ) ʽគ្មានទាំងភាពច្របូកច្របល់គ្មានទាំងគ្រោះអាក្រក់ʼ(និងដែលផ្ដើមដោយ) ʽដូច្នេះ តាមពិត ត្រូវតែយ៉ាងនេះʼ និងច្រៀងខ្សឹបៗបទសរសើរដល់ព្រះបុរុស។

២៥៣- អ្នកដែលប្រាថ្នាចង់លុបលាងបាប ទោះធំក្ដី តូចក្ដី ត្រូវសូត្រកាព្យឫគ-វេទរយៈពេលមួយឆ្នាំ ʽសូមឱ្យយើងខ្ញុំបានរួចរំដោះពីទោសៈរបស់ទ្រង់ ឱ ព្រះវរុណʼជាដើម ឬ ʽការប្រព្រឹត្តខុសអ្វីក៏ដោយ នៅទីនេះ ឱ ព្រះវរុណʼ ជាដើម។

២៥៤- បន្ទាប់ពីបានទទួលអំណោយដែលមិនគួរទទួល ឬបានទទួលទានអាហារហាមឃាត់ បុរសដែលសូត្រតរត្សមន្ទីយ(ឫគវេទ) បានបរិសុទ្ធ បន្ទាប់ពីរយៈពេលបីថ្ងៃ។

២៥៥- ប៉ុន្តែអ្នកដែលបានប្រព្រឹត្តអំពើបាបច្រើន បានបរិសុទ្ធ ប្រសិនបើគេសូត្រ(កាព្យចំនួនបួន) ក្នុងអំឡុងមួយខែ ដោយសរសើរដល់ព្រះសោម និងរុទ្រ និងកាព្យបី (ដែលផ្ដើមដោយ) ʽអរ្យម័ន, វរុណ និង មិត្រʼ ក្នុងពេលដែលខ្លួនកំពុងមុជទឹកក្នុងទន្លេ។

២៥៦- អ្នកប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវសូត្រកាព្យចំនួនប្រាំពីរ (ផ្ដើមដោយ) ʽព្រះឥន្ទ្រʼ អស់រយៈពេលកន្លះឆ្នាំ ប៉ុន្តែអ្នកដែលបានប្រព្រឹតអំពើមានទោសនៅក្នុងទឹក ត្រូវចិញ្ចឹមជីវិតដោយអាហារដែលបានដោយការស្នូម ក្នុងអំឡុងមួយខែ។

២៥៧- បុរសមានកំណើតពីរដង រួចរំដោះទោះទោសធំណាស់ក៏ដោយ ដោយការបូជាប៊ឹសុទ្ធ ដោយសូត្រធម៌ពិសិដ្ឋរបស់សាកល-ហោម ឬដោយសូត្រខ្សឹបៗនូវឫគ (ផ្ដើមដោយ) ʽស្វាមីភក្ដិʼ។

២៥៨- អ្នកដែលប្រឡាក់ដោយអំពើបាបធ្ងន់ធ្ងរ បានបរិសុទ្ធ ប្រសិនបើដោយចិត្តមូល គេនៅជាមួយមេគោអស់រយៈពេលមួយឆ្នាំ ដោយសូត្រ(បទ)បាវមានី និងចិញ្ចឹមជីវិតដោយការដើរសុំ។

២៥៩- ឬ ប្រសិនបើបរិសុទ្ធ (ដោយកាយ និងចិត្ត) គេសូត្រដដែលៗបីដងនូវសំហិតានៃព្រះវេទ នៅក្នុងព្រៃ ដែលស័ក្តិសិទ្ធិដោយ(តបៈ)បរាក គេបានរួចរំដោះពីអំពើឧក្រិដ្ឋទាំងអស់ ដែលនាំឱ្យបាត់វណ្ណៈ(បាតក)។

---

**២៥២.** វស. ជំពូក២៦ លេខ៧; យញ្ញ. ជំពូក៣ លេខ៣០៥។ ចម្រៀងបួន គឺ ឫគវេទ ជំពូក១០ លេខ៨៨; ជំពូក១០ លេខ១២៦; ជំពូក១០ លេខ១១៩និងជំពូក១០ លេខ៩០។

**២៥៣.** កាព្យពីរនេះ មាននៅក្នុងឫគវេទ ជំពូក១ ឡេខ២៤, ១៤ និងជំពូក៧ លេខ៨៩, ៥។

**២៥៤.** គោត.ជំពូក២៤ លេខ២-៣; ពោធ.ជំពូក៤ លេខ២,៤-៥។ កាព្យនេះមាននៅក្នុងឫគវេទ ជំពូក៩ លេខ៥៨,១-៤។

**២៥៥.** កាព្យនេះឃើញមាននៅក្នុងឫគវេទ ជំពូក៦ លេខ៧៤, ១-៤ និងជំពូក៤ លេខ២។

**២៥៦.** កាព្យនេះឃើញមាននៅក្នុងឫគវេទ ជំពូក១ លេខ១០៦, ១-៧។

**២៥៧.** មន្ត្រ សម្រាប់សាកល-ហោម គឺ វាជ. សំហ. ជំពូក៨ លេខ១៣។ កាព្យនេះ ឃើញមាននៅក្នុងឫគវេទ ជំពូក៦ លេខ៥១, ៨។ តាមលោកនារ. គេត្រូវសូត្រមន្ត្រនេះ ចំនួន១០៨ដង។

**២៥៨.** បទបាវមានី គឺ មណ្ឌលទីប្រាំបួននៃឫគ-វេទ។

**២៥៩.** ʽសំហិតាʼ គឺ មន្ត្រ និងព្រាហ្មណ៍ (កុល្ល., រាឃ.) ពាក្យខាងដើមប៉ុណ្ណោះ(នារ.)។ ʽបរាក តបៈʼ សូមមើលកាព្យ ២១៦ ខាងលើ។ កាព្យនេះទំនងសំដៅដល់*អនសន្នត្បាយណ*ដែលមានរៀបរាប់ទាំងស្រុងនៅក្នុង ពោធ. ជំពូក៣ លេខ៩។

២៦០- ប៉ុន្តែប្រសិនបើ(បុរស)តមអាហាររយៈពេលបីថ្ងៃ ដោយងូតទឹកបីដងក្នុងមួយថ្ងៃ និងសូត្រខ្សឹបៗ (ក្នុងទឹកនូវបទ ដែលបានឃើញដោយ)អឃមរសណ គេ(ដូចគ្នាដែរ)បានរួចរំដោះពីអំពើបាប ទាំងអស់ ដែលនាំឱ្យថ្លស់វណ្ណៈ។

២៦១- ដោយសារការបូជាយញ្ញសេះ ស្តេចនៃយញ្ញ ជួយរំដោះអំពើបាបទាំងអស់ សូម្បីបទ អឃម-រសណ ក៏ជួយលុបលាងទោសទាំងអស់បាន។

២៦២- ព្រាហ្មណ៍ ដែលនៅចងចាំគម្ពីរឫគ-វេទ មិនប្រឡាក់ដោយទោស ទោះបីជាគាត់បានធ្វើឱ្យវិនាស ដល់លោកទាំងបីនេះក៏ដោយ ទោះជាគាត់ទទួលទានអាហាររបស់នរណាក្តី។

២៦៣- អ្នកដែលមានចិត្តមូល សូត្រឫគសំហិតាបីដង ឬ (សូត្រ)យជុរ-វេទ ឬ(សូត្រ)សាម-វេទ អម ដោយអត្ថបទពិសិដ្ឋ (ឧបនិស័ទ) បានរួចរំដោះទាំងស្រុងពីអំពើបាបទាំងអស់។

២៦៤- បីដូចដុំដី ដែលធ្លាក់ចូលបឹងធំ ត្រូវរលាយយ៉ាងឆាប់ ហេតុនេះអំពើបាបទាំងអស់ ត្រូវស្រូបចូល ក្នុងព្រះវេទទាំងបី។

២៦៥- ឫគវេទ, យជុស(របៀបថ្លែង) ដែលខុសគ្នា (ពីខាងដើម) ចម្រៀងសាម័នច្រើនដង ត្រូវគេដឹង ថា (បង្កើតបាន)ព្រះវេទបី ហើយអ្នកដែលចេះព្រះវេទ (ត្រូវគេហៅថា)អ្នកចេះដឹងព្រះវេទ។

២៦៦- ព្រហ្មនមានព្យញ្ជនៈខាងដើមបី ដែល(ជាវិទ្យាសាស្ត្រពិសិដ្ឋ)បីវិស័យ ជាព្រះវេទបីទៀត ដែល ត្រូវរក្សានូវអាថ៌កំបាំង ហើយអ្នកដែលចេះវិទ្យាសាស្ត្រនេះ (គេហៅថា)អ្នកចេះដឹងព្រះវេទ។

---

**២៦០-២៦១.** គោត. ជំពូក២៤ លេខ១០-១២; វស. ជំពូក២៦ លេខ៨; ពោធ. ជំពូក៣ លេខ៥; ជំពូក៤ លេខ២, ១៥; វិ. ជំពូក៥៥ លេខ៧; យញ្ញ. ជំពូក៣ ខ្សែ៣០២។ *អឃមរសណ* ឃើញមាននៅក្នុងឫគ-វេទ ជំពូក១០ លេខ១៩០។

**២៦២.** វស. ជំពូក២៧ លេខ៣។

**២៦៣.** ពោធ. ជំពូក៤ លេខ៥, ២៩។

**២៦៤.** ខ្ញុំអានតាមលោគោវ., នន្ទ. និង K. ប្រ. មនុ 'ក្សិប្រំ' ជំនួស 'ក្សិប្តំ' (មេធ., K. វគ្គស្តីពីមនុ សំណៅបោះពុម្ព)។

**២៦៥.** មេធ.និងគោវ.អាន អាទ្យានិ 'នាយ' ជំនួស អន្យានិ 'ដែលផ្សេងគ្នា'។ មេធ. បកស្រាយពាក្យនេះថា 'ពាក្យដែលមាននៅក្នុងសំហិតា ដែលគ្មាននៅក្នុងព្រាហ្មណ៍ក្តី ឬពាក្យដែលសូត្រតាមសំហិតបាថ មិនមែនសូត្រតាមបទ ឬក្រមបាថក្តី'។ គោវ. ផ្តល់ការបកស្រាយទីមួយប៉ុណ្ណោះ។

**២៦១.** លោក K. លុបចោលកាព្យនេះ និងដាក់បញ្ចូលមកវិញពីរបន្ទាត់ គឺ៖

*អេស វោ ទិត['ភិហិត] សវះ ប្រាយស្ចិត្តវិណិរណ្យះ /*
*នៃស្រេយសំ ករមវិធី វិប្រស្បៃតំ និជោធត //*
*អតះ បរំ ប្រវក្សាមិ សំសារវិធី ឧត្តមំ /*

លោកនន្ទ. ដាក់ពីរបន្ទាត់ដំបូង បន្ទាប់ពីកាព្យលេខ២៦៦ តែដោយអានថា *ឥត្យេសា( ? )ភិហិតះ*។

# ជំពូក ១២

១- 'ឱ អ្នកគ្មានបាបអើយ ច្បាប់ពិសិដ្ឋទាំងមូល(សម្រាប់អនុវត្ត)ចំពោះវណ្ណៈទាំងបួន មេត្តាផ្តល់មក ឱ្យយើងខ្ញុំ(ឥឡូវនេះមក) ស្របតាមសច្ចធម៌ ការដាក់ទោសចុងក្រោយ ចូរកើតមានដល់អំពើ (របស់ពួកគេ)'។

២- សម្រាប់មហាបណ្ឌិត (ដែលបានថ្លែងពីគាត់ដូច្នេះ) ត្រិគុដ៏យុត្តិធម៌ ដែលកើតពីព្រះមនុ បាន ឆ្លើយថា 'ចូរស្ដាប់សេចក្ដីវិនិច្ឆ័យស្ដីពីទំនាក់ទំនងទាំងស្រុងនៃអំពើនេះចុះ'។

៣- អំពើដែលកើតពីចិត្ត ពីវាចា និងពីកាយ ផ្ដល់ផលល្អឬអាក្រក់របស់វាដោយសារអំពើនោះ បណ្ដាលឱ្យមានស្ថានភាព (ខុសៗគ្នា) របស់មនុស្ស ថ្នាក់ខ្ពស់បំផុត កណ្ដាល និងទាបបំផុត។

៤- ចូរចងចាំថា ចិត្តគឺជាដើមចម ចាប់ពីនេះទៅ សូម្បី(អំពើ)នោះមានពាក់ព័ន្ធនឹងកាយក្ដី (និង) ដែលមានបីប្រភេទ មានបីទីតាំង និងមានដប់មុខ។

៥- ចិត្តលោភចង់បានទ្រព្យអ្នកដទៃ ការគិតក្នុងចិត្តរបស់ខ្លួននូវអ្វីដែលមិនគួរប្រាថ្នា និងការប្រកាន់ មាំចំពោះ(ពាក្យប្រៀនប្រដៅ)មិនពិត ជាអំពើផ្លូវចិត្តបីប្រភេទ(ប្រកបដោយបាប)។

៦- ការបោកប្រាស(អ្នកដទៃ ដោយនិយាយ)មិនពិត ការធ្វើឱ្យខូចកុសលរបស់មនុស្សទាំងអស់ និងការនិយាយឥតបានការ ជាអំពើដោយវាចា(អាក្រក់)បួនប្រភេទ។

៧- ការយកអ្វីដែលគេមិនបានឱ្យ ការបង្កអន្តរាយ(ដល់សត្វលោក) ដោយមិនបានដាក់ទណ្ឌកម្ម តាមច្បាប់ និងការរួមសង្វាសដ៏ឧក្រិដ្ឋជាមួយភរិយារបស់បុរសដទៃ ត្រូវបានប្រកាសថាជាអំពើ ផ្លូវកាយ(ដ៏អាក្រក់)បីប្រភេទ។

៨- (មនុស្ស)ទទួល(ផល)នៃ(អំពើ)ផ្លូវចិត្តល្អ ឬអាក្រក់ នៅក្នុងចិត្តរបស់ខ្លួន (ផលនៃអំពើ) ផ្លូវ វាចា ក្នុងពាក្យសម្ដីរបស់ខ្លួន (ផលនៃ)អំពើផ្លូវកាយ ក្នុងកាយរបស់ខ្លួន។

៩- ដោយសារផលនៃអំពើបាប(ជាច្រើន)ដែលបានប្រព្រឹត្តដោយកាយរបស់ខ្លួន មនុស្សក្លាយជាវត្ថុ គ្មានជីវិត(ក្នុងជាតិក្រោយ) ដោយសារផលនៃ(អំពើបាប)ដែលបានប្រព្រឹត្តដោយវាចា កើតជា សត្វស្លាបឬសត្វតិរច្ឆានហើយដោយសារផលនៃ(អំពើបាប)ផ្លូវចិត្ត គេនឹងកើតជាថ្មីក្នុងវណ្ណៈទាប។

---

**ជំពូក១២ លេខ១.** រាយ. សរសេរ *តត្តវតះ បរំ* ផ្សេងទៅវិញ ហើយបកស្រាយបន្ទាត់ទីពីរ ថា 'មេត្តាផ្ដល់មកឱ្យយើងខ្ញុំ (ឥឡូវនេះមក) ការដាក់ទោសចុងក្រោយចូរកើតមានដល់អំពើរបស់ពួកគេ (និងការរួចរំដោះ)ដ៏កំពូល កើតចេញពីការ ទទួលស្គាល់សច្ចធម៌'។

**៤.** 'មានបីប្រភេទ' គឺ 'ល្អ កណ្ដាល ឬអាក្រក់'។ 'មានបីទីតាំង' គឺ 'ចិត្ត វាចា និងកាយ'។ 'មានដប់មុខ' គឺ 'មានរៀបរាប់នៅ ក្នុងកាព្យលេខ៥-៧'។ ចិត្តក្នុងទីនេះជាដើមចម ជាអវៈយវៈខាងក្នុង ដែលមានឥន្ទ្រីយ៍សំកល្ប 'ឆន្ទៈ'។

**៥.** 'ការគិតក្នុងចិត្តរបស់ខ្លួននូវអ្វីដែលមិនគួរប្រាថ្នា' តាមលោកមេធ. ថា 'ការគិត ឬចង់បានអ្វីមួយ ដែលអាចបង្កការឈឺ ចាប់ដល់អ្នកដទៃ ឬអ្វីដែលជាការហាមឃាត់'ក៏បាន។ លោកគោវ. និងនារ. ធ្វើការបកស្រាយន័យទីមួយ អ្នកអធិប្បាយ ផ្សេងទៀត ឱ្យន័យទីពីរ។ អ្នកខ្លះទៀត តាមការបញ្ជាក់របស់លោកមេធ. បកស្រាយ *វិតថាភិនិវេសំ* 'ការប្រកាន់មាំចំពោះ ពាក្យទូន្មានមិនពិត' (គឺ បដិសេធសភាពអនាគត ថាគ្មានប្រកពព្រះវេទជាដើម) ថា 'ទោសៈខ្លាំងក្លាជាប្រចាំ'។ តាមការ កត់សម្គាល់របស់ពួកគេចំពោះកាព្យនេះ និងកាព្យពីរបន្ទាប់ទៀត អ្នកអធិប្បាយគូសបញ្ជាក់ថា ភាពផ្ទុយគ្នានៃអំពើ មាន អំពើល្អផ្សេងៗពីគ្នា។

១០- គេហៅអ្នកនោះថា ត្រិទណ្ឌិន ដែលជាទីតាំងនៃចិត្តទាំងបីយ៉ាងមាំមួន គឺការគ្រប់គ្រងលើវាចារ (វាគ-ទណ្ឌ) ការគ្រប់គ្រងលើគំនិត(មនោទណ្ឌ) និងការគ្រប់គ្រងលើកាយ(កាយទណ្ឌ)។

១១- អ្នកដែលចេះគ្រប់គ្រងអង្គទាំងបី(លើខ្លួនឯង) ចំពោះសព្វសត្វទាំងអស់ នឹងយកឈ្នះលើ ចំណង់ និងទោសៈ រហូតដល់ធានាបានជោគជ័យទាំងស្រុង។

១២- ចិត្តដែលជំរុញអត្តា(រូបកាយ)នេះមានសកម្មភាព គេហៅក្សេត្រញ្ញ (អ្នកស្គាល់ស្រែ) ប៉ុន្តែចិត្ត ដែលធ្វើអំពើ ឈ្មោះត្រឹមត្រូវ គឺភូតាត្ម័ន (អត្តា ដែលមានជាតុផ្សំនានា)។

១៣- អត្តាខាងក្នុងមួយទៀត ដែលកើតព្រមជាមួយ(ក្សេត្រញ្ញ)មានរូបទាំងអស់ គឺជាជីវៈ ដែល(តាម រយៈក្សេត្រញ្ញ) ទើបមានសប្បាយ និងការឈឺចាប់ទាំងអស់ ក្នុងជាតិកំណើត(បន្តបន្ទាប់)។

១៤- ទាំងពីរនេះ មហាត្ម័ន និងក្សេត្រញ្ញ ដែលរួមផ្សំទាំងស្រុងជាមួយធាតុទាំងឡាយ ធ្វើឱ្យចិត្តសាយ ទៅដល់សព្វសត្វគ្រប់សណ្ឋាន។

---

**៥-៩.** យញ្ញ. ជំពូក៣ លេខ១៣១, ១១៤-១១៦។

**១០.** តាមធម្មតា តាបសដែលស្លៀកពាក់បន្ទះសំបកឈើ(ទណ្ឌ) ចងភ្ជាប់គ្នា គេហៅថា ទ្រិទណ្ឌិន។ យោងតាមកាព្យរបស់យើង សញ្ញាខាងក្រៅគ្មានន័យអ្វីទេ។ មនុស្សដែលស័ក្តិសមនឹងឈ្មោះទ្រិណ្ឌិន រក្សាការគ្រប់គ្រង(ទណ្ឌ)បីសម្រាប់ខ្លួនឯង។

**១១.** 'ជោគជ័យទាំងស្រុង' គឺ 'ការរួចរំដោះចុងក្រោយ'។

**១២.** 'អត្តា(រូបកាយ)នេះ' គឺ 'កាយ'(មេធ., គោវ., កុល្ល.) ឬ 'រូបកាយដែលមើលឃើញទាំងស្រុង រួមមានសំបកបី'(រាឃ., នារ.)។ 'ក្សេត្រញ្ញ(អ្នកមានចំណេះដឹងពីស្រែ)' គឺ 'ព្រលឹងរៀងខ្លួន(ជីវៈ)'(មេធ. ក្នុងកាព្យលេខ១៣ តាមលោក នារ.) ប្ររមាត្ម័ន(នន្ទ.) ហើយរាឃ. ដកស្រង់ការបកស្រាយពាក្យ 'ស្រែ'ពី ភគវទ្គីតា ជំពូក១៣ លេខ៥-៦។ 'ភូតាត្ម័ន(អត្តាដែលមានជាតុផ្សំនានា)' គឺ 'កាយ ដែលមានប្រតិកម្មធាតុផ្សំ ដូចជាធាតុជាដើម'(មេធ., គោវ., កុល្ល., រាឃ.) 'អត្តា ដែលមានទម្រង់ធាតុផ្សំ គ្មានវិញ្ញាណជាដើម'(នារ.) ឬ 'ជីវៈ'(នន្ទ.)។

**១៣.** តាមលោកមេធ.ថា 'អ្នកខ្លះ'យល់តាមពាក្យ ជីវៈ 'កាយដ៏ល្អិតសុខុម(លិង្គ សរីរៈ) ដែលប្រកបដោយមហ័ត មហាត្ម័ន' ព្រោះព្រលឹងរៀងៗខ្លួន ដែលធម្មតាគេហៅ ជីវៈ មានរៀបរាប់នៅក្នុងកាព្យលេខ១២ ក្រោមពាក្យក្សេត្រញ្ញ។ គាត់បន្ថែមថា 'អ្នកដទៃទៀត'បកស្រាយពាក្យ *ជីវៈ* ថា 'អវៈយវៈខាងក្នុង ដែលមានរូបជាចិត្ត បញ្ញា និងទិដ្ឋ'។ យោបល់ខាងដើម ជាគំនិតរបស់លោករាឃ. ចំណែកឯលោកគោវ. ដែលពន្យល់ពាក្យ *ជីវៈ* ថា *មនះ* 'ចិត្ត' ហើយលោកកុល្ល. ព្រមទាំងនារ. ដែលប្រែថា 'មហ័ត''មហាត្ម័ន ឬបញ្ញា' សំដៅដល់ន័យទីពីរ។ នន្ទ. និយាយថា 'ជីវសំញ្ញះ មានន័យ" អ្នកដែលស្គាល់ជីវៈទាំងស្រុង" គឺជាព្រះ'។ សហជះ 'នោះត្រូវបង្កើតដោយ' តាមលោកមេធ. និងគោវ. ថា 'នោះមានទំនាក់ទំនងរហូតដល់ពេលបែកធ្លាយ(ប្រលយ) ឬរហូតដល់បានសម្រេចការរួចរំដោះចុងក្រោយ'។

**១៤.** ពាក្យ *មហាន*មហាត្ម័ន' តាមលោកមេធ., គោវ., កុល្ល., នារ., រាឃ. សំដៅដល់ជីវៈ ដែលមានរៀបរាប់ក្នុងកាព្យខាងដើម ហេតុនេះម្នាក់ៗធ្វើការបកស្រាយទៅតាមទស្សនៈដែលបង្ហាញនៅក្នុងកាព្យលេខ១៣។ ភូតសំប្ធក្តោ 'ដែលផ្សំបញ្ចូលគ្នាជាមួយធាតុផ្សំទាំងស្រុង'(មេធ., គោវ., កុល្ល.) ឬ 'ដែលពាសដោយធាតុផ្សំ'(រាឃ.) តាមលោកនារ. គឺ 'ដែលផ្សំដោយភូតាត្ម័ន'។ ស្ថិតំ តំ វ្យាប្យ តិស្ថតះ 'សាយទូទៅដល់អ្នកអាស្រ័យនៅ' គឺ 'សាយ'(គោវ.) ឬ 'បិតនៅ'(កុល្ល.) ឬ 'បិទបាំងដោយមាយា'(នារ.) ក្នុងខ្លួន គឺ 'បរមាត្ម័ន អាត្ម័នដ៏កំពូល'(គោវ., កុល្ល., នារ.) 'ដែលស្ថិតនៅក្នុងសព្វសត្វទាំងអស់' (គោវ., នារ.) 'ជាសាក្សី'(កុល្ល., នារ.) លោកគោវ. បន្ថែម 'ឬ (សំនួនពាក្យ វ្យាប្យ តិស្ថតះ) "វាសាយភាយ" ត្រូវបានប្រើដោយ សារអាត្ម័នដ៏កំពូល សាយសព្វអ្វីៗទាំងអស់'។ ការបកស្រាយក្រោយនេះ ទំនងជាសំដៅដល់ការប្រែរបស់លោក មេធ. ដែលបកប្រែកាព្យនេះថា 'ទាំងពីរនេះ គឺ មហាត្ម័ន និងអ្នកស្គាល់ស្រែ ដែលផ្សំបញ្ចូលគ្នាទាំងស្រុង ស្ថិតនៅក្នុងខ្លួនគាត់ តាម

១៥- ផ្តើមពីកាយរបស់ខ្លួន បង្កើតរូបរាប់មិនអស់ ដែលជំរុញឱ្យសត្វគ្រប់សណ្ឋានធ្វើសកម្មភាពជាប្រចាំ។

១៦- កាយដ៏មាំមួនមួយទៀត ដែលកើតពីចុណ្ណភាគ(ជាតុផ្សំ)ប្រាំ និងសម្រាប់ទទួលទារុណកម្ម(នៅឋាននរក) ត្រូវបានឱ្យផលបន្ទាប់ពីស្លាប់ (ប្រសិនបើ)ជាមនុស្សអាក្រក់។

១៧- ពេលដែល(អ្នកធ្វើអំពើអាក្រក់) ដោយកាយនោះ ទទួលទារុណកម្មនៅទីនោះ ដោយព្រះយម (ផ្នែកសំខាន់នៃកាយ)ត្រូវផ្សំបញ្ចូលគ្នានូវធាតុនីមួយៗទៅតាមក្រុមរបស់វាជាមួយនឹងធាតុទាំងឡាយ(វាករកើត)។

---

ទម្រង់សត្វលោកផ្សេងៗ ដែលសាយភាយទៅគ្រប់(ទាំងអស់)៎។ លោកមេធ. ប្រកាសច្បាស់ថា តិស្ថតះ ត្រូវប្រែជា កិរិយាស័ព្ទសកម្ម (សរវេករមេត្វំ [សករមេត្វំ] តិស្ថតេរ អនេការថត្វាត)។ គាត់បកស្រាយ ៉គាត់៎ ថា ៉អាត្ម័នដ៏កំពូល៎ ហើយបន្ថែមថា សំនួនពាក្យ ៉ស្ថិតនៅ៎ ត្រូវបានបញ្ជាក់ភាពត្រឹមត្រូវ ព្រោះបរមាត្ម័ន ជាបុព្វហេតុនៃលោកទាំងមូល ហើយផលិតផលអាស្រ័យលើហេតុរបស់វា។ លោករាឃ. យល់ផ្សេងស្ទើរតែទាំងស្រុង ហើយនិយាយថា ៉ទាំងពីរ គឺមហាត្ម័ន (គឺបញ្ញា និងជាប់ទាក់ទងនឹងកាយដ៏ល្អិតសុខុម) និងអ្នកស្គាល់ស្រែ គឺ ព្រលឹងរៀងៗខ្លួន ដែលបិទបាំងដោយធាតុផ្សំប្រាំ (និង)សាយភាយទៅគ្រប់សត្វលោកទាំងឡាយ គឺកាយទាំងមូល និងស្ថិតនៅទីនោះ ក្នុងនាមជាអ្នកទទួល៎។ ចុងក្រោយ លោកនន្ទ. ធ្វើការបកស្រាយថា ៉ទាំងពីរ គឺ អាត្ម័ននីមួយៗ និងអាត្ម័នដ៏កំពូល ហើយនៅជាមួយធាតុផ្សំនានា គឺស្ថិតនៅក្នុងកាយ; មហាត្ម័ន គឺអាត្ម័នដ៏កំពូល និងអ្នកស្គាល់ស្រែ និងនៅក្នុងផ្នែកទាំងឡាយ គឺទូទៅ និងដ៏ល្អិតសុខុម; ធាតុដែលយើងមើលឃើញ គឺ ស្រែ(ក្សេត្រ) ដែលសាយភាយគ្រប់ធាតុទាំងអស់។ អត្ថន័យគឺថា ព្រលឹងនីមួយៗ សាយសព្វរាងកាយ ហើយអាត្ម័នដ៏កំពូល អាស្រ័យនៅនឹងព្រលឹងនីមួយៗ៎។

**១៥.** ៉ផ្តើមពីកាយរបស់ខ្លួន៎ គឺ ៉ពីធម្មជាតិ ឬទម្រង់នៃអាត្ម័នដ៏កំពូល(បរមាត្ម័ន មេធ., នារ.) ឬពីកាយរបស់ព្រហ្មដែលផ្តល់នូវគុណសម្បត្តិទាំងឡាយ៎(រាឃ.) ៉ឧបមាដូចជារលកកើតពីសមុទ្រ ឬផ្កាភ្លើងកើតពីភ្លើង តាមរបៀបដូចមានរៀបរាប់នៅក្នុងទស្សនវិជ្ជាវេទន្ត៎(គោវ., កុល្ល.)។ ៉អ្នកផ្សេងទៀត៎ តាមការរៀបរាប់របស់លោកមេធ. និងនន្ទ. បកស្រាយសំនួនពាក្យនេះ ថា ៉ពីឫសវិវត្តឡើង ឬរូប (ប្រក្ឫតិ) ដែលជាកាយរបស់អាត្ម័នដ៏កំពូល៎។ មូរតយះ ៉ទម្រង់៎ គឺ ៉ក្សេត្រញ្ញ៎(គោវ., កុល្ល., នារ.) ឬ ៉ព្រលឹង ដែលកំណត់ដោយកាយដ៏ល្អិតសុខុម៎(រាឃ.) ឬ ៉ភាគចំណែក ដែលជាហេតុកើតពីផលនៃរូប៎(នន្ទ.)។

**១៦.** *ត្រុវំ* ៉មាំមួន៎ គឺ ៉អាចធន់ទ្រាំនឹងទារុណកម្មពីអធិធម្មជាតិ៎(មេធ., កុល្ល., រាឃ.)។ លោកគោវ. និងនន្ទ. អាន *ទ្ធជំ*។

**១៧.** ការបកប្រែ យកលំនាំតាមលោកមេធ., គោវ. និងរាឃ. ដែលលោកនារ.ទំនងជាយល់ស្របតាមដែរ ហើយសន្មតថា សំណង់កាព្យនេះ មិនត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ទេ។ កុល្ល. និងនន្ទ. ដែលចង់បង្ហាញថា អត្ថបទរបស់មនុ មិនបានឃ្លាតចាកពីវិធានវេយ្យាករណ៍ធម្មតា សន្មតថា ប្រធាននៃអនុប្រយោគទាំងពីរ គឺ *ទុស្ក្ឫតិនោ ជីវះ* ៉ព្រលឹងដែលធ្វើអាក្រក់៎។ អ្នកខាងដើមនិយាយថា ៉ព្រលឹងធ្វើអាក្រក់ដ៏ល្អិតសុខុម ដោយបានទទួលនូវផលនៃកាយដែលកើតឡើង ជាអំពើទារុណកម្មរបស់ព្រះយម គឺត្រូវវិនាសទៅវិញរៀងៗខ្លួន រហូតរលាយបាត់រូបកាយទាំងមូល តាមផ្នែកនៃធាតុផ្សំសំខាន់ៗទាំងអស់៎ ហើយអត្ថន័យគឺថា ៉ពួកវានៅតែជាសង្ខតធាតុជាមួយគ្នាដដែល៎។ ការបកស្រាយរបស់លោកនន្ទ. មានលក្ខណៈងាយយល់ជាង។ តាមគំនិតរបស់គាត់ គេគួរប្រែថា ៉(ព្រលឹងនីមួយៗ) ដោយបានទទួលទារុណកម្មពីព្រះយម ដល់រូបកាយនោះ ត្រូវបែកធ្លាយ(ជាការបញ្ចប់នូវការឈឺចាប់របស់កាយ ដរាបណាកាយនោះអាស្រ័យនៅ) ក្នុងធាតុផ្សំ(ប្រាំ) ស្របតាមមុខងារការងាររបស់វា៎(វិភាគសះ តត្តម៌វិភាគានុរូបំ)។ ប៉ុន្តែសម្រាប់ខ្ញុំហាក់ដូចជាថា ការប៉ុនប៉ងកែកំហុសវេយ្យាករណ៍របស់អ្នកនិពន្ធ គឺគ្មានប្រយោជន៍ទេ។

១៨- ចិត្ត ដោយទទួលផលនៃកំហុសរបស់ខ្លួន ដែលកើតពីការប្រកាន់មាំចំពោះកាមតម្រេក និងដែលនាំឱ្យមានទុក្ខសោក អាចរួចផុតពីគ្រឿងសៅហ្មង ទាំងពីរនេះ ជាអំណាចទេព។

១៩- ទាំងពីររួមជាមួយគ្នា ពិសោធមើលដោយគ្មាននឿយហត់នូវគុណនិងទោសនៃ (ព្រលឹងនីមួយៗ) នោះ ដែលឡូកឡំជាមួយពរជ័យ ឬទុក្ខសោក ទាំងក្នុងជាតិនេះ ទាំងក្នុងជាតិបន្ទាប់។

២០- ប្រសិនបើ(ព្រលឹង)ភាគច្រើនធ្វើល្អនិងធ្វើអាក្រក់តិចតួច គេនឹងទទួលនូវពរជ័យនៅឋានសួគ៌ ដែលផ្សំដោយធាតុទាំងអស់នោះ។

២១- ប៉ុន្តែប្រសិនបើវាភាគច្រើនធ្វើអាក្រក់និងធ្វើល្អតិចតួច វារងទុក្ខដោយសារការវិនាសធាតុ ជាទារុណកម្មរបស់ព្រះយម។

២២- ព្រលឹងនីមួយៗ ដោយបានធន់ទ្រាំនូវទារុណកម្មទាំងឡាយរបស់ព្រះយម ផ្សំផ្គុំជាថ្មីនូវធាតុផ្សំទាំងប្រាំ តាមមុខងារនីមួយៗ ដោយគ្មានសៅហ្មងឡើយ។

---

**១៨.** ការបកប្រែនេះ យកតាមសំណេររបស់គោវ. (ការអធិប្បាយ) កុល្ល., នន្ទ. និងរាឃ. *អនុភូយាសុខោទរកាន* ។ មេធ., គោវ.(អត្ថបទ) និង K. អាន *អនុភូយ សុខោទរកាន* (បន្ទាប់ពីលាងបាប) ដែលសេចក្តីរីករាយជាផល’(មេធ.)។ ‘ចិត្ត’ គឺ ‘ព្រលឹងនីមួយៗ’(ក្សេត្រញ្ញ មេធ., គោវ., នន្ទ.)) ឬ ‘ព្រលឹងនីមួយៗ ដែលកំណត់ដោយកាយដ៏ល្អិតសុខុម’(កុល្ល., រាឃ.) តាមលោកនារ. សំដៅដល់ ‘មហាត្ម័ន’(មហាន)។ ‘អំណាចទេពទាំងពីរ’ គឺ ‘មហាត្ម័ន និងអាត្ម័នដ៏កំពូល’(មេធ., ‘អ្នកខ្លះ’ គោវ., កុល្ល.) តាមលោកមេធ. និងរាឃថា ‘មហាត្ម័ន និងក្សេត្រញ្ញ’(មានរៀបរាប់ក្នុងកាព្យលេខ១៤) តាមលោកនារ. និងនន្ទ. (កាព្យលេខ១៩) ‘ជីវៈ និងបរមាត្ម័ន ឬអាត្ម័នដ៏កំពូល’។ លោកមេធ. បន្ថែមថា អនុលោមតាមការបកស្រាយរបស់គាត់ កាព្យនេះហាក់ដូចជាថា ប្រសិបើខុសពីអត្តា ព្រោះគេសម្រេចគោលបំណង ហើយអ្នកសម្រេចគឺដូចគ្នា ប៉ុន្តែថាភាពផ្សេងគ្នាគ្រាន់តែជាន័យធៀបប៉ុណ្ណោះ។ ចំពោះសំនួនពាក្យ ‘វាចូល’ មានន័យថា ‘វាគ្មានអ្វីក្រៅពីនេះទេ’(គឺបន្ទាប់ពីការរំលាយរូបកាយ ដើម្បីទទួលទណ្ឌកម្ម នោះនៅតែជាក្សេត្រញ្ញ និងហាន)។ ពាក្យរបស់គាត់គឺ *អតះ ក្សេត្រញ្ញំ អក្សេតីតិ ប្រាប្តំ តច ច វិទ្ធំ ស អេវ ប្រាប្យ ប្រាបកៈ ច/ សត្យំ ឱបចារិកោ ភេទោ ភិប្រេតះ/ អក្សេតីតិ អយំ អាថ៌ះ/ អេតាវន្នាត្រសេ ភវតិ យទ ឧត ក្សេត្រញ្ញតយា ប្រាប្តាទិសំឃាត្មកេន មហាន ឥតិ វ្យបទិស្តេន ផលេសុ តាវន្នានត្រះ បរិសិស្យតេ/ លិង្គជីវៈ ច ក្សេត្រញ្ញះ//* លោករាឃ. អ្នកអធិប្បាយផ្សេងទៀត ដែលចម្លងន័យអាថ៌កំបាំងនៃកាព្យនេះ ប្រែ *អក្សេតិ* ‘វាចូល’ ថា *អនុគច្ឆតិ* ‘គាត់យកតាម’ និងបន្ថែមថា ‘ដើម្បីបង្កើតកាយថ្មី’(សរីរាន្តរារម្ភាយ)។ គាត់បន្តស្រង់សេចក្តី *សតបថ-ព្រាហ្មណ៍* ជំពូក១៤ លេខ៧, ២, ៥ ដើម្បីបង្ហាញថា តាមព្រះវេទ ព្រលឹងនីមួយៗ ដែលផ្សំជាមួយកាយដ៏ល្អិត សុខុម បង្កើតបានជាកាយមួយទៀត។

**១៩.** ‘ទាំងពីរ’ គឺ ‘មហាត្ម័ន និងអាត្ម័នដ៏កំពូល’(មហត្បរមាត្មានោ គោវ., កុល្ល.) តាមលោកមេធ. ដែលកែប្រែការបកស្រាយសម្រាប់កាព្យមុនៗ ថា មហាន និងបរមាត្ម័ន ហើយតាមរាឃ. ថា មហាន និងក្សេត្រញ្ញ។ បស្យតះ ‘ពិសោធមើល’ តាមលោករាឃ. មានន័យថា ‘ដោយវត្តមានរបស់វា ជាហេតុនាំឱ្យប្រព្រឹត្ត’។ ‘ទោស’ គឺ ‘ដែលនៅតែមានបន្ទាប់ពីរងទុក្ខ (ក្នុងឋាននរក តាមកុល្ល.)’។ នន្ទ. បកស្រាយបន្ទាត់ទីមួយផ្សេងពីគេ ‘ទាំងពីរ (កុសលនិងអកុសល) ឃ្លាំមើលចិត្ត (ក្សេត្រញ្ញ)ដែលងាយនឹងប្រព្រឹត្តល្អ និងអាក្រក់’។ ‘ដែលរួមជាមួយ’ គឺ ‘ជាមួយកុសល និងទោស’(មេធ., គោវ., កុល្ល., នន្ទ.) តាមយោបល់របស់លោករាឃ. សំដៅដល់ មហាន និងក្សេត្រញ្ញ។

**២០.** ‘ជាមួយនឹងធាតុផ្សំទាំងឡាយ’ គឺ ‘ជាមួយកាយទាំងមូល ដែលមានធាតុផ្សំប្រាំ ដូចរៀបរាប់ខាងលើ’។

**២១.** ‘ដែលវិនាសដោយធាតុទាំងឡាយ’ គឺ ‘បន្ទាប់ពីស្លាប់’(កុល្ល., នារ.)។

**២២.** មេធ. និង K. អាន *អក្សេតិ* សម្រាប់ *អប្យេតិ*។

២៣- ចូរ(មនុស្សយើង) ដោយបានទទួលស្គាល់ដោយបញ្ញារបស់ខ្លួននូវដំណើរវិវត្តន៍នៃព្រលឹងមួយៗ (ដែលអាស្រ័យ)លើអំពើកុសល និងអកុសល ចេះកែកុនចិត្តរបស់ខ្លួន(ដោយអំពើ)កុសល។

២៤- ស្គាល់សេចក្ដីល្អ (សត្វ) ការងារ (រជៈ) និងភាពងងឹត(តមៈ) ជាលក្ខណៈសម្បត្តិបីនៃអត្តា ដែលមហាត្ម័នតែងតែសាយភាយដល់គ្រប់អត្ថិភាពទាំងអស់។

២៥- ប្រសិនបើគុណសម្បត្តិមួយក្នុងចំណោមគុណសម្បត្តិទាំងអស់នេះ មានលក្ខណៈលុបទាំងស្រុង នៅក្នុងកាយ ដូច្នេះវាធ្វើឱ្យ(ព្រលឹង)ក្នុងកាយ ខុសគ្នាច្រើនតាមគុណសម្បត្តិនោះ។

២៦- សេចក្ដីល្អ ត្រូវប្រកាស(ថាជាទម្រង់)នៃពុទ្ធិ ភាពងងឹត(ជា)អវិជ្ជា សកម្មភាព(នៃ)ចិត្ត ស្រឡាញ់និងទោសៈនេះគឺធម្មជាតិនៃអង្គទាំងបី ដែលមាននៅគ្រប់កន្លែង និងតោងជាប់សភាវៈ ទាំងអស់។

២៧- ប្រសិនបើ(មនុស្ស)ពិសោធន៍ឃើញ(ចិត្តដឹង)នៅក្នុងព្រលឹង ពោរពេញដោយពរជ័យ សេចក្ដី ស្ងប់ដ៏ជ្រៅតាមសភាពពិតរបស់វា និងពន្លឺដ៏បរិសុទ្ធ ហេតុនេះចូរអ្នកចងចាំថា ក្នុងចំណោម គុណសម្បត្តិទាំងបី គឺមានសេចក្ដីល្អមួយ។

២៨- អ្វីដែលលាយឡំដោយការឈឺចាប់ និងមិនផ្ដល់ការគាប់ចិត្តចំពោះព្រលឹង យើងអាចដឹងបាន (តាមលក្ខណៈនៃ)អំពើដែលពិបាកនឹងគ្រប់គ្រងបាននិងដែលទាញព្រលឹងក្នុងកាយឱ្យកញ្ជ្រោល (វត្តកាម)។

២៩- អ្វីដែលលាយឡំដោយមាយា អ្វីដែលមានលក្ខណៈច្រឡំបល់មិនដឹងខុសត្រូវ អ្វីដែលមិនអាច យល់ដោយហេតុផល អ្វីដែលមិនដឹងទាំងស្រុង យើងត្រូវតែពិចារណា(តាមលក្ខណៈនៃ)ភាព ងងឹត។

---

**២៤.** យញ្ញ. ជំពូក៣ លេខ១៨២។ ៉នៃអត្តា៌ គឺ ៉នៃមហ័ត៌(កុល្ល., រាឃ., នារ., នន្ទ.) ពីរនាក់ក្រោយនេះ និយាយ *មហត្តត្វស្យ* ៉នៃគោលការណ៍(សាំខ្យ) ហៅថា មហ័ត៌។ ការពិភាក្សាវែងបន្តិចរបស់មេធ. បានលទ្ធផលដូចគ្នា។

**២៥.** ៉ក្នុងកាយ៌ គឺ ៉ក្នុងកាយដ៏ល្អិតសុខុម៌(រាឃ.)។ មេធ. និងគោវ. បន្ថែមក្នុងអនុប្រយោគទីមួយថា ៉ដោយសារអំពើដែលបានប្រព្រឹត្តពីជាតិមុន៌។

**២៥.** កុល្ល. ប្រែ អេត័ត ៉ដូច្នេះ៌ ក្នុងន័យថា ៉ដូចតទៅ៌។ នារ. និង្ននន្ទ. ប្រែបន្ទាត់ចុងក្រោយខុសពីគេបន្តិច ៉ធម្មជាតិនៃអង្គទាំងបីនេះ សាយសព្វដោយ(លក្ខណៈបីយ៉ាងដូចបានបញ្ជាក់ជូន និង)តោងជាប់នឹងសព្វសត្វទាំងអស់៌។

**២៧.** ៉(ចិត្តដឹង)ដែលពេញដោយពរជ័យ៌ គឺ ៉ដោយគ្មានហេតុពិសេសណាមួយ សម្រាប់ចិត្តដឹងនោះទេ៌(គោវ.)។ ខ្ញុំប្រែ *តត្រ* ដែលគោវ.និងកុល្ល.បកស្រាយដោយ តស្មិន និង និងរៀបរាប់ដោយ អាត្មនិ ក្នុងន័យ តេសុ ៉ក្នុងចំណោមអង្គទាំងបី៌។ រាឃ. និយាយ *តត្រេតិ ត្រិកិះ*។

**២៨.** មេធ. សរសេរ *អប្រតិបំ* ដែលលោកបកស្រាយ *អប្រត្យក្សំ* ៉មិនអាចដឹងបានដោយញាណ៌ ជំនួស អប្រតិឃំ ៉ពិបាកគ្រប់គ្រង៌។

**២៩.** ខ្ញុំយកតាមលោកគោវ., កុល្ល., នារ., រាឃ. និង K. ដែលអាន *អប្រក្ត-វិសយត្មកំ* ជំនួស *អប្រក្តំ វិសយាត្មាកំ* (នន្ទ. សំណៅបោះពុម្ព)។ អំណានរបស់លោកមេធ. មានការសង្ស័យ។ ៉អ្វីដែលនៅរួមជាមួយមាយា៌ គឺ ៉ដែលគេមិនអាចធ្វើការសម្រេចថាតើ(អ្វីនោះ)ពិត ឬមិនពិតនោះទេ៌(គោវ., កុល្ល., រាឃ.)។ *អប្រក្តវិសយាត្មកំ*អ្វីដែលមាន លក្ខណៈច្របូកច្របល់ដែលគេមិនអាចដឹងខុសត្រូវបាន៌(អស្ពុតវិសយាការស្វភាវំ លោកកុល្ល., រាឃ.) ឬ ៉អ្វីដែលមានទម្រង់ច្របូកច្របល់ ដែលគេមិនអាចដឹងខុសត្រូវបាន និងដែលមានចរិតលក្ខណៈធម្មជាតិមិនពិត៌(អស្បស្តវិសយាការាសត្យភាវំ លោកគោវ.) តាម

៣០- លើសពីនេះ ខ្ញុំនឹងរៀបរាប់ទាំងស្រុងអំពីផលដែលកើតពីលក្ខណៈទាំងបីនេះ មានផលឧត្ដុង្គ ឧត្ដមបំផុត ផលកណ្ដាល និងផលទាបបំផុត។

៣១- ការសិក្សាព្រះវេទ តបៈកម្មដ៏តឹងរ៉ឹង (ការស្វែងរក)ចំណេះដឹង ភាពបរិសុទ្ធ ការគ្រប់គ្រងឥន្ទ្រិយ៍ ការធ្វើអំពើកុសល និងភាវនាអំពីព្រលឹង (ជា)សញ្ញានៃលក្ខណៈអំពើល្អ។

៣២- ការរីករាយនឹងភារកិច្ច ការចង់បានភាពរឹងមាំ ការធ្វើអំពើបាប និងការបណ្ដោយជាប្រចាំឱ្យលង់ក្នុងកាមតម្រេក (ជា)សញ្ញានៃលក្ខណៈការងារ។

៣៣- សេចក្ដីលោភ ការងោកងុយ ការភ័យខ្លាច ភាពឃោរឃៅ ការមិនជឿលើអាទិទេព ការចិញ្ចឹមជីវិតគ្មានសីលធម៌ ទម្លាប់សុំការអនុគ្រោះ និងការមិនយកចិត្តទុកដាក់ ជាសញ្ញានៃលក្ខណៈងងឹត។

៣៤- ជាងនេះទៀត ចូរដឹងនូវការរៀបរាប់សង្ខេបអំពីលក្ខណៈបីតាមលំដាប់លំដោយនីមួយៗដូចខាងក្រោម ព្រោះវាស្ដែងឡើងក្នុងបី (ខណៈ បច្ចុប្បន្ន អតីត និងអនាគត)។

៣៥- ពេលដែល(មនុស្ស)បានធ្វើ កំពុងធ្វើ ឬហៀបនឹងធ្វើអំពើណាមួយ មានអារម្មណ៍ខ្មាស់អៀន អ្នកចេះដឹងអាចដឹងថា (អំពើ)បែបនោះជាសញ្ញានៃលក្ខណៈងងឹត។

៣៦- ក៏ប៉ុន្តែ ពេលដែល(មនុស្ស)ប្រាថ្នាចង់(បាន)កិត្តិនាមច្រើន ដោយអំពើមួយក្នុងលោកិយនេះ ហើយគ្មានអារម្មណ៍ឈឺចាប់ចំពោះបរាជ័យ ចូរដឹងថា វា(ជាសញ្ញានៃលក្ខណៈ)ការងារ។

៣៧- ប៉ុន្តែសកម្មភាពនោះ(ជា)សញ្ញានៃលក្ខណៈអំពើល្អ ដែលបេះដូងរបស់គេទាំងស្រុង ប្រាថ្នាចង់ដឹង ដែលគេគ្មានការខ្មាស់អៀននឹងប្រព្រឹត្ត និងដែលព្រលឹងរបស់គេរីករាយ។

៣៨- ការជាប់ជំពាក់នឹងកាមតម្រេក ត្រូវបានប្រកាសថាជាសញ្ញានៃភាពងងឹត (ការស្វែងរក)ទ្រព្យជា (សញ្ញានៃ)ការងារ (ការប្រាថ្នាចង់បាន) កុសលផ្លូវចិត្តជាសញ្ញានៃសេចក្ដីល្អ (លក្ខណៈនីមួយៗ)ដែលមានឈ្មោះខាងក្រោយ ប្រសើរជាងលក្ខណៈខាងដើម។

---

លោកនារ. 'ទីដែលមានភាពច្របូកច្របល់ ហើយព្រលឹងគ្មានពន្លឺ'(អប្រកាសោ វិសយ អាត្មា ច យត្រ)។

**៣១.** ពាក្យចុងក្រោយនៃកាព្យនេះ ដែលតាមការបកប្រែរបស់លោកមេធ. និងនារ. តាមន័យត្រង់មានន័យថា '(ជាផល) នៃអំពើល្អ (និង)សញ្ញានៃលក្ខណៈ(នោះ)'(សាត្ត្វិកំ សត្ត្វជន្សំ គុណាស្យ តស្សៃវ លក្សណំ ចិញ៌)។

**៣២.** អធៃរយំ 'ការចង់បានភាពមាំមួន' តាមលោកនារ. គឺ 'ការចង់បានអារម្មណ៍ពេញចិត្ត'។

**៣៣.** ភិន្នវ្ឫត្តិតា 'ដែលចិញ្ចឹមជីវិតគ្មានសីលធម៌' គឺ 'មិនរស់នៅតាមតម្រាសីលធម៌'; ប្រមាទះ 'ការមិនយកចិត្តទុកដាក់' គឺ 'ចំពោះករណីយកិច្ច'។

**៣៣.** ជំនួស *ត្រិសុ* 'ក្នុងបី(ខណៈ តាមលោកមេធ., គោវ., កុល្ល., រាឃ.) លោកនន្ទ.អានថា ន្ឫសុ'ក្នុងមនុស្ស'។ លោកនារ. ដែលអាន ត្រិសុ បកស្រាយដោយពាក្យ *ត្រយាណាំ* ថាត្រិសុ 'ក្នុងបី' គឺការសិក្សាព្រះវេទជាដើម, 'នៃគុណ គឺ នៃកុសលបីថ្នាក់' និង 'ក្នុងបី' គឺ 'ក្នុងលក្ខណៈដើមបី'។

**៣៦.** លោកនន្ទ. សរសេរ *ឫច្ឆតិ* ជំនួស *ឥច្ឆតិ*។ ខ្ញុំអានតាមលោកមេធ., គោវ., កុល្ល., នារ., រាឃ. និងនន្ទ. *ន ច សោចតិ* ជំនួស *ស ច សោចតិ*(សំណៅបោះពុម្ព)។ K. អាន *នៃវ* ។ 'និងគ្មានអារម្មណ៍ឈឺចាប់ចំពោះបរាជ័យ' គឺ 'ប្រសិនបើមិនបានសម្រេចនូវកិច្ចការរបស់ខ្លួនគេចាប់ផ្ដើមធ្វើកិច្ចការមួយ ប៉ុន្តែគេមិនឈប់ធ្វើការដោយសារការឈឺចាប់ទេ នេះជាអត្ថន័យ' (រាឃ.)។

**៣៧.** ជំនួស *យ័ត សរវេណ* (គោវ., កុល្ល.) លោកមេធ. និង K. អាន *យះ សរវេណ* ហើយលោកនន្ទ. ថា *សរ្វំ យេនេ* ដែលគេ ចង់ដឹងដោយពេញចិត្តទាំងស្រុង' គឺ 'អត្ថន័យព្រះវេទជាដើម'(កុល្ល., រាឃ.)។

៣៩- ខ្ញុំនឹងប្រកាសដោយសង្ខេបតាមលំដាប់លំដោយនូវដំណើរវិវត្តន៍ នៅក្នុងលោកិយនេះទាំងមូលដែល(មនុស្ស)មានលក្ខណៈណាមួយក្នុងចំណោមលក្ខណៈទាំងអស់នេះ។

៤០- អ្នកដែលមានសេចក្តីល្អឡើងដល់ឋានៈជាទេព អ្នកដែលមានសកម្មភាពជាសភាពមនុស្ស ហើយអ្នកដែលមានភាពងងឹត ធ្លាក់ទៅជាសភាពតិរច្ឆាន នេះជាដំណើរវិវត្តន៍បីយ៉ាង។

៤១- ប៉ុន្តែចូរស្គាល់នូវដំណើរវិវត្តន៍ទាំងបីនេះ ដែលអាស្រ័យលើលក្ខណៈ(បី) (ដើម្បីទទួលបានមកវិញនូវ)លក្ខណៈបី គឺទាប កណ្តាល និងខ្ពស់ ស្របទៅតាមលក្ខណៈពិសេសនៃអំពើ និងចំណេះដឹង(របស់មនុស្សម្នាក់ៗ)។

៤២- (សភាវៈ)គ្មានចលនា សត្វល្អិតទាំងតូចទាំងធំ ត្រី ពស់ និងអណ្តើក បសុសត្វ និងសត្វព្រៃ ជាឋានៈទាបបំផុត ដែលនាំទៅរក(លក្ខណៈ)ងងឹត។

៤៣- ដំរី សេះ សូទ្រៈ និងមនុស្សព្រៃដ៏គួរឲ្យស្អប់ តោ ខ្លា និងជ្រូកព្រៃ (ជា)សភាពកណ្តាល ដែលកើតពី(លក្ខណៈ)ងងឹត។

៤៤- *ចរណៈ*, *សុបរណៈ* និងមនុស្សលាក់ពុត រាក្សសៈនិងបិសាច (ស្ថិតក្នុង)ឋានៈខ្ពស់បំផុតក្នុងចំណោមលក្ខណៈទាំងឡាយ ដែលកើតពីភាពងងឹត។

៤៥- យល្ល, មល្ល, នតៈ, មនុស្សដែលចិញ្ចឹមជីវិតដោយមុខរបរគួរឱ្យស្អប់ និងអ្នកដែលញៀននឹងល្បែង និងគ្រឿងស្រវឹង (មាន)សភាពលក្ខណៈទាបបំផុត ដែលកើតពីការងារ។

៤៦- ស្តេចនិងក្សត្រិយ អាចារ្យក្នុងវាំងរបស់ព្រះរាជ និងអ្នកដែលចូលចិត្តធ្វើសង្គ្រាមច្បាំងគ្នា(បង្កើត)បានឋានៈកណ្តាលដែលកើតពីការងារ។

---

**៤០.** យញ្ញ. ជំពូក៣ លេខ១៣៧-១៣៩។

**៤១.** 'នៃចំណេះដឹង(របស់មនុស្សម្នាក់ៗ)' គឺ 'ប្រសិនបើគេបានប្រព្រឹត្តអំពើនោះដោយចេតនា ឬអត់'(មេធ.)។

**៤២.** '(សភាវៈ)ដែលគ្មានចលនា' គឺ 'ដើមឈើជាដើម'។ *បសវៈ* 'សត្វគោក្របី' គឺ 'មេគោជាដើម'(នារ.) ឬ 'ឆ្កែជាដើម'(រាឃ.)។ ជំនួស *សកច្ឆបាះ*(គោវ., កុល្ល., រាឃ.) 'និងអណ្តើក' លោកមេធ., នារ. និងនន្ទ. អាន *សរីស្ឫបាះ* 'អ្វីដែលវា' គឺ 'ខ្វាដំរីជាដើម'(នារ.)។ ជំនួស *ម្ឫគាចៃវ* (គោវ., កុល្ល., រាឃ.) 'និងសត្វព្រៃ(ឬក្តាន់)' លោកមេធ. និងនន្ទ. សរសេរ *ស្រិគាលា ច* 'និងឆ្កែព្រៃ'។

**៤៣.** *ម្លេច្ឆាះ* 'មនុស្សព្រៃ' គឺ 'សពរជាដើម'(នារ.)។

**៤៤.** *ចារណៈ* អាចសំដៅដល់វណ្ណៈរបស់មនុស្ស គឺ 'កវី អ្នកចម្រៀង មេអណ្តើកជាដើម'(មេធ.) ឬ 'អ្នករាំខ្សែ'(នារ.) ឬ 'នតៈ'(គោវ., កុល្ល.) ប៉ុន្តែតាមលោករាឃ. កាព្យនេះក៏អាចសំដៅដល់វណ្ណៈសត្វលោកតាមទេវកថា។ *សុបរណៈ* ជាទេពបក្សី ដូចមានរៀបរាប់នៅក្នុងជំពូក១ លេខ ៣៧ ខាងលើ។

**៤៥.** យល្ល, មល្ល គឺ 'ក្រុមដែលមានរៀបរាប់នៅជំពូក១០ លេខ២២ខាងលើ(កុល្ល., នារ.) ដែលជាអ្នកទទួលផល ដោយសារដំបង ឬអ្នកប្រយុទ្ធ និងអ្នកកំប្លែង'(មេធ., កុល្ល.)។ *នតៈ* គឺ 'អ្នកដែលបង្ហាញខ្លួននៅលើឆាក'(រង្គាវតារកៈ តាមលោកមេធ., កុល្ល.)។ ខ្ញុំអានតាមលោកមេធ., គោវ., នារ. និងនន្ទ. *បុរសា ច កុវ្ឫត្តយៈ* 'មនុស្សដែលចិញ្ចឹមជីវិតដោយមុខរបរគួរឱ្យស្អប់' ជំនួស *បុរសាះ សស្ត្រវ្ឫត្តយៈ* 'មនុស្សដែលចិញ្ចឹមជីវិតដោយការជួញអាវុធ'(កុល្ល. សំណៅបោះពុម្ព)។

**៤៦.** តាមការប៉ាន់ស្មានយ៉ាងតិច ដែលអាចារ្យក្នុងវាំង គឺឃើញមាននៅក្នុងកាព្យ ដែលបញ្ចតន្ត្រ ជំពូក២ លេខ៦៣ (សំណៅប៉ុំបៃ) ដកស្រង់សេចក្តី។ លោកនន្ទ. អាន *ទាន្យុទ្ធប្រធានា* 'មនុស្សមានចិត្តទូលំទូលាយ និងអ្នកដែលចូលចិត្តឈ្លោះប្រកែក'។

៤៧- គន្ធវៈ, គុហ្យក និងអ្នកបម្រើអាទិទេព ដូចជាអប្សរ (ទាំងអស់ស្ថិតក្នុង)លំដាប់ខ្ពស់បំផុតដែលកើតពីការងារ។

៤៨- ឥសី តាបស ព្រាហ្មណ៍ ពពួកទេពវេមានិក វិមានព្រះច័ន្ទ និងទៃត្យ (ជា)ថ្នាក់ទីមួយ (និងថ្នាក់ទាបបំផុត)នៃអត្ថភាព ដែលកើតពីសេចក្ដីល្អ។

៤៩- អ្នកបូជាយញ្ញ បណ្ឌិត ទេព ព្រះវេទ ពន្លឺឋានសួគ៌ ឆ្នាំ វិញ្ញាណក្ខន្ធ និងសាធ្យ (ជា)លំដាប់អត្ថិភាពទីពីរ ដែលកើតពីសេចក្ដីល្អ។

៥០- បណ្ឌិតប្រកាសថា ព្រហ្មា អ្នកបង្កើតចក្រវាឡ៍ ច្បាប់ មហាត្ម័ន និងសភាវៈមិនដឹង (គឺជា) លំដាប់សភាវៈខ្ពស់បំផុត ដែលកើតពីសេចក្ដីល្អ។

៥១- (ផល)នៃអំពើទាំងបីគឺយ៉ាងនេះ ប្រព័ន្ធវិវត្តន៍ទាំងមូល ដែលមានបីថ្នាក់ (ថ្នាក់នីមួយៗ)មានបីថ្នាក់បន្ទាប់ ហើយដែលសត្វលោកទាំងអស់ ត្រូវបានរៀបរាប់ទាំងស្រុងរួចហើយ។

៥២- ដោយសារការប្រកាន់ខ្ជាប់ចំពោះ(វត្ថុ)វិញ្ញាណ និងដោយសារការមិនបំពេញករណីយកិច្ចរបស់ខ្លួន មនុស្សភ្លើ មនុស្សវណ្ណៈទាបបំផុត ទៅកាន់កំណើតថោកទាបបំផុត។

៥៣- ទីចាប់កំណើតអ្វីនោះ ដែលព្រលឹងនីមួយៗចុះមកកាន់លោកិយនេះ និងដោយសារអំពើអ្វីនោះ បានដឹងនូវលក្ខណៈពិសេសរបស់វា ជាទូទៅ និងតាមលំដាប់លំដោយ។

៥៤- អ្នកណាដែលបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរ(មហាបាតក) ដោយរស់នៅអស់ពេលជាច្រើនឆ្នាំនៅឋាននរកដ៏គួរឱ្យខ្លាច ចាប់កំណើតបន្តបន្ទាប់ ក្រោយពីបញ្ចប់(រយៈពេលរងទណ្ឌកម្មនោះ)។

---

**៤៧.** *គុហ្យក* គឺ ‵ព្រលឹងអាក្រក់ ដែលធ្វើឲ្យក្មេងឈឺ′, *យក្ស* គឺ ‵អ្នកការពាររតនៈ′(នារ.)។ ទាំងពីរនេះ ជាអ្នកមានកំណើតពីទេព អ្នកបម្រើកុពេរ។ ‵អ្នកបម្រើទេព′ គឺ ‵វិទ្យាធរ ជាដើម′។

**៤៨.** លោកមេធ. លើកឡើងនូវមតិមួយដែលអ្នកដទៃអះអាង សំដៅដល់យតិ ‵តាបស′ ជាមនុស្សដែលរស់នៅលើភ្នំមេរុ។ ‵អាទិទេពវេមានិក′ គឺ ‵អ្នកដែលនៅកណ្ដាលខ្យល់ មានរទេះដ៏ធំជាយាន ដែលគេហៅថា វិមាន′។ ជំនួស *ទៃត្យាះ* លោក នារ. សរសេរម្យ៉ាងទៀតថា *សិទ្ធាះ*។

**៤៩.** ‵ព្រះវេទ′ គឺ ‵សម្លេងដែលដាក់តាមលំដាប់តៗគ្នា′(មេធ.) ឬ ‵អាទិទេពការពារ ឬការធ្វើឲ្យទៅជាបុគ្គលនៃព្រះវេទ ដូចមានរៀបរាប់នៅក្នុងឥតិហាស ដែលស្ថិតក្នុងជំណាក់ព្រហ្ម′(មេធ., អ្នកដទៃ, គោវ., កុល្លូ., នារ., រាឃ.)។ ចំពោះពាក្យពីរបន្ទាប់អ្នកអធិប្បាយឲ្យយោបល់មិនច្បាស់ថាតើជាសភាវៈនោះឬជារាជានុសិទ្ធិរបស់គេ(អធិស្ថាត្រី ទេវតា)។

**៥០.** *ព្រហ្មា* គឺ ‵ហិរណ្យគរភ′(គោវ., កុល្លូ., រាឃ.) ‵អ្នកបង្កើតចក្រវាឡ៍′ គឺ ‵មារីចិ និងអ្នកផ្សេងទៀត′ សូមមើលជំពូក ១ លេខ៣៥ ខាងលើ; ‵ច្បាប់′ គឺ ‵ជាអត្ថន័យព្រះវេទក៏បាន ឬច្បាប់ចាប់ភពក៏បាន′(មេធ.); ចំពោះអ្នកអធិប្បាយផ្សេងទៀតយកន័យខាងក្រោយប៉ុណ្ណោះ។ ‵មហាត្ម័ន′ គឺ ‵ទេវៈ ដែលជាមេលើគោលការណ៍(នៃទស្សនវិជ្ជាសាំខ្យ) គេហៅ មហាត្ម័ន ឬជាបញ្ញវន្ត′(តាមលោកគោវ., កុល្លូ., រាឃ.); ‵សភាវៈមិនដឹង′ គឺ ‵ទេព ដែលជាប្រធាននៃហេតុប្រែប្រួល ឬដើមចមនៃទស្សនវិជ្ជាសាំខ្យ′(គោវ., កុល្លូ., រាឃ.)។ លោកមេធ. ដែលពិភាក្សា និងច្រានចោលការបកស្រាយពាក្យ ពីរចុងក្រោយទាំងអស់ អះអាងថា ការបកស្រាយទាំងឡាយសំដៅដល់អាត្ម័នដ៏កំពូល(បរមាត្ម័ន)។ នារ. បកស្រាយពាក្យ ‵មិនដឹង′ ថា ‵អត្តា′។ លោកមេធ., គោវ. និង K. អាន *អវ្យក្ត អេវ ច* ជំនួស *អវ្យក្តំ អេវ ច*។

**៥១.** លោកមេធ. និង K. អាន *ឯស ធរមះ* ច្បាប់សម្រាប់អំពើទាំងបី គឺយ៉ាងនេះជាដើម′។ នន្ទ. ដាក់កាព្យលេខ៨១ ជាប់បន្ទាប់ពីកាព្យនេះ។

**៥២.** យញ្ញ. ជំពូក២ លេខ២១៩។ ‵មនុស្សភ្លើ′ គឺ ‵អ្នកដែលមិនបំពេញតបៈ′(គោវ., កុល្លូ.)។

៥៥- អ្នកសម្លាប់ព្រាហ្មណ៍ ចាប់កំណើតក្នុងពោះឆ្កែ ជ្រូក លា អូដ្ឋ មេគោ ពពែ ចៀម ក្ដាន់ បក្សី ចណ្ឌាល និងបុក្កស។

៥៦- ព្រាហ្មណ៍ដែលផឹក(គ្រឿងស្រវឹង គឺ)សុរា នឹងកើតក្នុង(ខ្លួន)សត្វល្អិតតូចនិងធំ សត្វខ្នាត សត្វស្លាប ដែលស៊ីលាមក និងសត្វតិរច្ឆានដ៏ចង្រៃ។

៥៧- ព្រាហ្មណ៍ ដែលលួច(មាសរបស់ព្រាហ្មណ៍ នឹងមានកំណើត)រាប់ពាន់ដង (ជាសត្វ)ពីងពាងពស់ និងសត្វបង្កួយ សត្វទឹក និងបិសាចដ៏ចង្រៃ។

៥៨- អ្នកបំពានគ្រែរបស់គុរុ (កើត)រាប់ពាន់ដង(ជារូប)ស្មៅ ចុល្លព្រឹក្សនិងវល្លិ៍ជាតិ ដូចជាមំស(សត្វ) និង(សត្វតិរច្ឆាន)ដែលមានចង្កូម និងសត្វដែលប្រព្រឹត្តអំពើអាក្រក់។

៥៩- មនុស្សដែលចូលចិត្តបង្កការឈឺចាប់ (ក្លាយជា)មំសា(សត្វ) អ្នកដែលទទួលទានអាហារហាមឃាត់ ចោរ (ជា)សត្វស៊ីសត្វជំពូកគ្នាឯង ហើយអ្នកដែលរួមសង្វាស់ជាមួយស្ត្រីវណ្ណៈទាបបំផុត(កើតជា) ប្រេត។

៦០- បុរសដែលបានសេពគប់ជាមួយមនុស្សក្រៅវណ្ណៈ អ្នកដែលបានលួចភរិយារបស់អ្នកដទៃ និងអ្នកដែលបានលួចទ្រព្យរបស់ព្រាហ្មណ៍ ក្លាយជាព្រហ្មរាក្សសៈ។

៦១- បុរសដែលមានចិត្តលោភបានលួចត្បូងគជ់ឬផ្កាថ្ម ឬវត្ថុមានតម្លៃណាមួយ នឹងកើតក្នុងចំណោមជាងមាស។

៦២- ចំពោះការលួចធញ្ញជាតិ(មនុស្ស)កើតជាកណ្តុរ ចំពោះអ្នកលួចលោហធាតុលឿង (កើតជា) ហំសៈ ចំពោះការលួចទឹក(កើតជា)ប្លវ ចំពោះការលួចទឹកឃ្មុំ(កើតជា)សត្វល្អិតមានទ្រនិច ចំពោះការលួចទឹកដោះគោ(កើតជា)ក្អែក ចំពោះការលួចគ្រឿងទេស(កើតជា)ឆ្កែ ចំពោះការលួចប្រឹសុទ្ធ(កើតជា)សត្វស្អា;

---

**៥៥.** យញ្ញ. ជំពូក៣ លេខ២០៧។ នន្ទ. អាន *បុល្កស* លោកមេធ. និងគោវ. អាន *បុក្កស* ជាមួយនឹង*ជិហ្វាមូលិយ* ដែលទំនងជាមានខ្យល់ *សិះ*។

**៥៦.** យញ្ញ. ជំពូក៣ លេខ២០៧។

**៥៥.** យញ្ញ. ជំពូក៣ លេខ២០៨។ 'សត្វទឹក' គឺ 'សត្វក្រពើជាដើម'(គោវ.)។ លោកគោវ. បកស្រាយពាក្យ *លូត*ពីងពាង' ថា 'ខ្នាដំរី'។ លោក K. លុបកាព្យនេះចោល។

**៥៥.** យញ្ញ. ជំពូក៣ លេខ២០៨។ អ្នកអធិប្បាយនានា បកស្រាយ 'មំស(សត្វ)' ថា 'សត្វត្មាតជាដើម','(សត្វព្រៃ)ដែលមានចង្កូម' ថា 'សត្វតោ ឬខ្លាជាដើម'។ 'អ្នកដែលធ្វើអំពើអាក្រក់' តាមលោកគោវ. គឺ 'មនុស្ស ដូចជាសពរ' ហើយតាមលោកកុល្ល. ថា 'សត្វ ដូចជាខ្លាជាដើម'។

**៥៩.** 'សត្វលោក ដែលស៊ីអំបូររបស់ខ្លួនផ្ទាល់' គឺ 'ត្រីជាដើម'។ លោកនន្ទ. ដាក់កាព្យ ៦០ មុនកាព្យ៥៩។

**៦០.** យញ្ញ. ជំពូក៣ លេខ២១២។ 'ព្រហ្មរាក្សស' ន័យត្រង់ 'រាក្សសជាព្រាហ្មណ៍' ជាព្រលឹងបិសាច។ លោក K. លុបកាព្យនេះចោល។

**៦១.** យញ្ញ. ជំពូក៣ លេខ២១៣។ តាមការបកស្រាយម្យ៉ាងទៀត ដែលលោកមេធ. គិតថាអាចទទួលយកបាន និងដែលអ្នកអធិប្បាយផ្សេងទៀត លើកឡើងនូវជម្រើសផ្សេង *ហេមកត្រ្ត*ជាងមាស' ថាជាឈ្មោះសត្វស្លាប។

**៦២.** យញ្ញ. ជំពូក៣ លេខ២១៤, ២១៥; វិ. ជំពូក៦៤ លេខ១៥-២០។ *សំ*គ្រឿងទេស' គឺ ទឹកអំពៅជាដើម(កុល្ល.) តាមលោកនារ. គឺ 'បារត'។

៦៣- ចំពោះការលួចសាច់ (កើត) ត្មាត ចំពោះការលួចខ្លាញ់ (កើត) ក្អែកទឹក ចំពោះការលួចប្រេង (កើត)សត្វស្លាប(ហៅថា)តៃលបក ចំពោះការលួចអំបិល(កើត)ចង្រិត ចំពោះការលួចទឹកដោះជូរ (កើត)បក្សី(ឈ្មោះ)ពលាកា។

៦៤- ចំពោះការលួចសូត្រ(កើត)សត្វទទា ចំពោះការលួចជោរនៃពស្ត្រ(កើត)កង្កែប ចំពោះការលួចសំពត់អំបោះ(កើត)សត្វក្រៀល ចំពោះការលួចមេគោ(កើត)សត្វប្រកួត ចំពោះការលួចទឹកអំពៅ (កើត)សត្វប្រជៀវ;

៦៥- ចំពោះការលួចទឹកអប់ប្រណិត(កើត)សត្វកណ្តុរទឹក ចំពោះការលួចបន្លែមានស្លឹក (កើត) សត្វក្ងោក ចំពោះការលួចអាហារឆ្អិនផ្សេងៗ(កើត)សត្វកាំប្រមា ចំពោះការលួចអាហារមិនចម្អិន (កើត) សត្វប្រមារោមខ្លី។

៦៦- ចំពោះការលួចភ្លើងគេនឹងកើតជាសត្វក្រសា ចំពោះការលួចគ្រឿងប្រើប្រាស់ក្នុងផ្ទះ (កើត) សត្វឪមាល់ ចំពោះការលួចសំពត់ជ្រលក់ពណ៌(កើត)សត្វទទាហ្វ្រង់កូលិន;

៦៧- ចំពោះការលួចសត្វក្តាន់ ឬដំរី (កើត)ឆ្កែចចក ចំពោះការលួចសេះ(កើត)ខ្លា ចំពោះការលួចផ្លែឈើនិងមើមឈើ(កើត)សត្វលា ចំពោះការលួចស្ត្រី(កើត)សត្វខ្លាឃ្មុំ ចំពោះការលួចទឹក (កើត) សត្វតាវៅខ្មៅស ចំពោះការលួចយាន(កើត)អូដ្ឋ ចំពោះការលួចបសុសត្វ (កើត) សត្វពពែឈ្មោល។

៦៨- បុរសដែលបានយកទ្រព្យរបស់អ្នកដទៃដោយបង្ខំ ឬដែលបានបរិភោគអាហារយញ្ញដែលមិនមែនជាចំណែករបស់ខ្លួន ប្រាកដជាកើតជាសត្វមិនខាន។

៦៩- ស្ត្រីក៏ដូចគ្នាដែលបានប្រព្រឹត្តចោរកម្មនឹងមានទោស ហើយពួកគេនឹងកើតជាសត្វញីដូចគ្នា (នឹងការចាប់កំណើតដែលបានរៀបរាប់ខាងលើ)។

---

**៦៣.** យញ្ញ. ជំពូក៣ លេខ២១១, ២១៥; វិ. ជំពូក៦៤ លេខ២១-២៥។ ខ្ញុំអានតាមលោកមេធ., គោវ. និងនន្ទ. *វសាំ* 'ខ្លាញ់' ជំនួសពាក្យ *វពាំ* (កុល្ល., សំណៅបោះពុម្ព) ដែលពាក្យក្រោយ លោកនារ.ក៏មានសរសេរ តែពន្យល់ដោយពាក្យ *មេទះ* ។ តៃលបក ទំនងជាសត្វកន្លាត។ ចីរីវាក 'ចង្រិន' ក៏អាចមានន័យថា 'សត្វរៃ'។ លោកនន្ទ. អាន *ចក្រវាក*សត្វទាព្រាហ្មណី'។

**៦៤.** យញ្ញ. ជំពូក៣ លេខ២១៥; វិ. ជំពូក៦៤ លេខ២៥-៣០។ ចំពោះពាក្យ *វាគ្គុទ* 'សត្វប្រជៀវ' សូមមើលកំណត់សម្គាល់ គោត. ជំពូក១៧ លេខ៣៤។ លោករាឃ. បញ្ជាក់ឡើងវិញនូវការបកស្រាយត្រង់ចំណុចនោះ ដូចលោកនិយាយថា វាជាសត្វស្លាប ដែលហើរនៅពេលយប់ លោកមេធ. និងនន្ទ. ហាក់ដូចជាសរសេរផ្សេងនៅខាងចុងកាព្យនេះ។ សំណៅរបស់អ្នកខាងដើម គឺ *កោពេ្លា គោធាមាំសាសុ វល្គុតិះ(?)* និងសំណៅរបស់អ្នកក្រោយ *គោធា គវ្យំ ទទោ សល្លំ(?)*។

**៦៥.** យញ្ញ. ជំពូក៣ លេខ២១៣; វិ. ជំពូក៦៤ លេខ៣១-៣៤។

**៦៦.** យញ្ញ. ជំពូក៣ លេខ២១៤-២១៥; វិ. ជំពូក៦៤ លេខ៣៥-៣៧។

**៦៧.** យញ្ញ. ជំពូក៣ លេខ២១៤; វិ. ជំពូក៦៤ លេខ៣៨-៤៣។

**៦៦.** យញ្ញ. ជំពូក៣ លេខ២១៧-២១៥; វិ. ជំពូក៦៤ លេខ៤៤។

**៦៩.** វិ. ជំពូក៦៤ លេខ៤៥។ 'តាមរបៀបដូចគ្នា' គឺ 'ដោយចេតនា'(គោវ., កុល្ល.)។

៧០- ប៉ុន្តែ(មនុស្សទាំងបួន)វណ្ណៈ ដែលបានចុះចាញ់ការងារត្រឹមត្រូវរបស់ខ្លួន ដោយសារសម្ពាធភាពចាំបាច់ នឹងកើតជាអ្នកបម្រើរបស់ទស្យុ បន្ទាប់ពីវិវត្តទៅជាកាយដ៏ចង្រៃ។

៧១- ព្រាហ្មណ៍ ដែលបានបោះបង់ចោលករណីយកិច្ចរបស់ខ្លួន(កើតជា)ប្រេតឧល្កាមុខ ដែលចិញ្ចឹមជីវិតដោយសារកំអួត ហើយក្សត្រិយ(កើតជា)ប្រេតកតបូតន ដែលស៊ីវត្ថុមិនស្អាតនិងសាកសព។

៧២- វៃស្យ ដែលបានបោះបង់ចោលករណីយកិច្ចរបស់ខ្លួន កើតជាប្រេតមៃត្រាក្សជ្យោតិក ដែលស៊ីខ្ទុះឈាម ហើយសូទ្រៈ (កើត)ប្រេតចៃលាសក (ដែលស៊ីខ្ទូត)។

៧៣- តាមសមាមាត្រដែលមនុស្សត្រេកត្រអាលក្នុងកាមតម្រេក ពួកគេនឹងទទួលនូវរសជាតិតាមសមាមាត្រដូចគ្នានោះដែរ។

៧៤- ដោយការប្រព្រឹត្តអំពើបាបរបស់ខ្លួនដដែលៗ មនុស្សដែលមានការយល់ដឹងតិច រងនូវការឈឺចាប់ក្នុងជាតិនេះ (ទាបជាង)ជាតិផ្សេងៗ;

៧៥- (ទារុណកម្ម)ដែលជាប់នៅក្នុងនរក តាមិស្រ និងនរកផ្សេងៗដ៏គួរឱ្យខ្លាច (ទណ្ឌកម្ម)ក្នុងព្រៃដែលមានដើមឈើមានស្លឹកជាផ្លែដាវជាដើម និង(ទណ្ឌកម្ម)ជាប់ចំណង និងហែកហួរ;

៧៦- និងទារុណកម្មនានា (ការឈឺចាប់) ដែលត្រូវក្អែកនិងទីទុយចឹកស៊ី ដែលត្រូវវិនាសដោយកម្តៅភ្លើងខ្សាច់ និង(ទារុណកម្ម)ដែលត្រូវគ្រាំក្នុងឆ្នាំងទឹកពុះ ដ៏សែនពិបាកនឹងទ្រាំ;

៧៧- និងការកើតក្នុងពោះសត្វចង្រៃ ដែលមានទុក្ខជាប្រចាំ និងឈឺចាប់ដោយសាររងានិងកម្តៅនិងការភ័យខ្លាចច្រើនប្រការ,

---

**៧០.** ខ្ញុំយកតាមលោកមេធ., គោវ., នារ., នន្ទ., រាឃ. និង K. ដែលអាន *ទស្យុ* ជំនួស *សត្រុស*របស់សត្រូវខ្លួន' (សំណៅបោះពុម្ព)។ គោវ. បកស្រាយ *ទស្យុ* ថា *សត្រុ* ហើយលោកកុល្ល.ធ្វើការបកស្រាយដូចគ្នា ចំណែកឯលោកមេធ. ថា 'ចោរលួចនិងចោរប្លន់' តាមលោកនារ. ថា 'កុលសម្ព័ន្ធព្រៃ ដូចជាសពរ'។ លោកនន្ទ. អាន *ប្រេតតាំ* (សំណៅបោះពុម្ព ប្រេនតាំ)សម្រាប់ *ប្រេស្យតាំ* និងបកស្រាយថា 'នឹងកើតជាបិសាច ក្នុងចំណោមពួកទស្យុ'។ អំណានរបស់គាត់ទំនងជាមានការកែសម្រួលទៅលើកាព្យបន្ទាប់។

**៧១.** *ឧល្កាមុខ* គឺ 'ដែលមានមាត់ឆេះភ្លើង'(មេធ.)។ លោកមេធ. ចូលចិត្តសរសេរ *កូតបូតន*ដែលមានច្រមុះស្អុយ' ជាង *កតបូតន* (កុល្ល., នារ., រាឃ., នន្ទ., K.)។ លោកគោវ. អាន *កឋបូតន* ។

**៧២.** *មៃត្រាក្សជ្យោតិក* តាមលោកមេធ., កុល្ល. និងរាឃ. ត្រូវបកស្រាយថាជាប្រេតមួយពួក ដែលមានភ្លើង ឬមើលឃើញទ្វារធំ។ លោកមេធ. ផ្តល់ការបកស្រាយម្យ៉ាងទៀត ដែលទំនងជាមានន័យថា 'ប្រេត' ហើយបន្ថែមថា 'អ្នកផ្សេង'បកស្រាយថា 'សត្វទីទុយ'។ *ចៃលាសក*(ប្រេត)ដែលស៊ីខ្ទូត'(គោវ.) តាមកុល្ល.ថា 'ដែលស៊ីចៃសាច់'។ *ចេលាសក* ជាអំណានរបស់លោកគោវ., នារ. និងនន្ទ.។

**៧៣.**ខ្ញុំយកតាមលោកមេធ. និងគោវ.ដែលបកស្រាយ *កុសលតា* តាមន័យត្រង់'ភាពឆ្លាត'(កុល្ល., រាឃ.)ថា ឯករលិភាវះ។

**៧៥-៧៦.** សូមមើលជំពូក៤ លេខ៨៨-៨៩ ខាងលើ; យញ្ញ. ជំពូក៣ លេខ២០៦, ២២១-២២៥។

**៧៦.** មេធ. អាន *ករម្ភវលុក តប្តាៈ*ហើយបកស្រាយ *ករម្ភៈ* ថា *ករមទៈ* (ករទមៈ?) 'ភក់និងខ្សាច់ក្តៅ(?)'។ ការប្រែយកតាមកំណត់សម្គាល់របស់លោកកុល្ល. និងរាឃ.។ មេធ., គោវ., រាឃ., នន្ទ., និង K. អាន *សុទុះសហាន*ពិបាកនឹងទ្រាំ' ដែលមានពន្យល់ខាងលើ ជំនួស *ទារុណាន*សែនទារុណ'(កុល្ល., សំណៅបោះពុម្ព)។

៧៨- (ការឈឺចាប់)ជាប្រចាំនៅក្នុងគភ៌ផ្សេងៗ និងជាកំណើតដ៏ឈឺចាប់ ការជាប់គុកច្រវាក់ដ៏សែនពិបាកទ្រាំ និងទុក្ខសោកធ្វើជាទាសកររបស់អ្នកដទៃ,

៧៩- និងការព្រាត់ប្រាស់ពីសាច់ញាតិនិងមនុស្សជាទីស្រឡាញ់របស់ខ្លួន និង(ឈឺចាប់)ដោយធ្វើដំណើរជាមួយមនុស្សអាក្រក់ (ការធ្វើពលកម្ម)រកទ្រព្យ និងការខាតបង់ ទ្រព្យក្នុងការគប់មិត្រ និង(កើតមាន)សត្រូវ។

៨០- វ័យជរាដែលគ្មានថ្នាំព្យាបាល ការឈឺចុកចាប់ដោយសារជំងឺការរងទុក្ខផ្សេងៗច្រើនអនេក ហើយ(ចុងក្រោយ)សេចក្ដីស្លាប់មិនជម្នះបាន។

៨១- ប៉ុន្តែដោយអារម្មណ៍ចិត្តបែបណា (មនុស្ស) ធ្វើអំពើមួយ ហើយគេទទួលផលនៃអំពើនោះ ក្នុងកាយ(អនាគត)ដែលមានលក្ខណៈដូចគ្នានៃផលនោះ។

៨២- ផលទាំងអស់ដែលកើតចេញពីអំពើ ត្រូវបានគូសបញ្ជាក់មកយ៉ាងនេះ (បន្តទៅទៀត) ចូរសិក្សាពីអំពើទាំងឡាយ ដែលនាំឲ្យបានសុខដ៏កំពូលកើតជាព្រាហ្មណ៍។

៨៣- ការសិក្សាព្រះវេទ (ការធ្វើ) តបកម្មតឹងរ៉ឹង (ការក្រេបយក)ចំណេះដឹងពិតប្រាកដ ការគ្រប់គ្រងឱ្យបាននូវឥន្ទ្រីយារម្មណ៍ ការតមមិនបង្កការឈឺចាប់ និងការបម្រើគ្រូ ជាមធ្យោបាយដ៏ប្រសើរបំផុត ដើម្បីបានសេចក្ដីសុខដ៏កំពូល។

៨៤- (ប្រសិនបើអ្នកសួរ) ថាតើក្នុងចំណោមអំពើកុសលទាំងអស់ ដែល(គេប្រព្រឹត្ត)ក្នុងលោកនេះដូចខាងក្រោម (មួយណា)ដែលមានប្រសិទ្ធភាពជាង(អំពើផ្សេងទៀត) ដើម្បីបានសេចក្ដីសុខដ៏កំពូលសម្រាប់មនុស្ស,

៨៥- (ចម្លើយគឺថា) ការចេះដឹងពីព្រលឹង ជាអំពើដ៏ប្រសើរបំផុតក្នុងចំណោមអំពើផ្សេងៗទាំងអស់ ព្រោះថាវាជាដើមចមនៃគ្រប់វិទ្យាសាស្ត្រទាំងអស់ ដោយហេតុថាភាពអមតៈគេបានទទួលដោយសារអំពើនោះ។

៨៦- ក្នុងចំណោមអំពើប្រាំមួយប្រភេទ(ដូចបានរៀបរាប់ខាងលើ ការធ្វើនូវ)អំពើតាមការប្រៀនប្រដៅនៅក្នុងព្រះវេទ ត្រូវបានគេអះអាងថា ជាអំពើដែលមានប្រសិទ្ធភាពបំផុត ដើម្បីបានសេចក្ដីនៅក្នុងលោកិយនេះ និងជាតិក្រោយ។

---

**៨១.** ឧ.ទា. ប្រសិនបើពេលមនុស្សធ្វើអំពើមួយ អារម្មណ៍របស់គាត់ជាសាត្វិក ឬ 'ពេញដោយគុណសម្បត្តិនៃសេចក្ដីល្អ' គាត់នឹងទទួលផលក្នុងកាយមួយដែលកើតពីគុណសម្បត្តិនោះ ឧ.ទា.លក្ខណៈជាទេព។

**៨៣.** យញ្ញ. ជំពូក៣ លេខ១៩០។

**៨៤.** មេធ. លុបកាព្យនេះចោល។

**៨៥.** យញ្ញ. ជំពូក១ លេខ១៩៩។ 'ការចេះដឹងពីព្រលឹង' គឺ មិនមែនការចេះដឹងពីក្សេត្រញ្ញទេ តែជាការចេះដឹងពីព្រលឹងដ៏កំពូលដូចបានទូន្មាននៅក្នុងគម្ពីរឧបនិស័ទ(មេធ., គោវ., កុល្លូ., នន្ទ.) ហើយតាមលោកនារ. គឺ 'ការធ្វើសមាធិ'(ធ្យានំ)។ លោកនន្ទ. អះអាងថា វិភត្តិទី៦ *សវេសាំ* 'ក្នុងចំណោមទាំងអស់' បញ្ជាក់ន័យវិភត្តិទី៥។ តាមប្រសាសន៍របស់គាត់ ការប្រែគួរថា 'គឺប្រពៃជាងអំពើផ្សេងទាំងអស់'។

**៨៦.** មេធ. ប្រែវិភត្តិទី៦ សណ្ណាំ 'ក្នុងចំណោមទាំងប្រាំមួយនោះ' ក្នុងន័យវិភត្តិទី៥ ហើយតាមយោបល់គាត់ ការប្រែគួរថា 'អំពើដូចបានទូន្មានៅក្នុងព្រះវេទ ត្រូវគេអះអាងថា ជាអំពើដែលមានភាពស័ក្តិសិទ្ធិជាង ដើម្បីបានសេចក្ដីសុខក្នុងលោកិយ

៨៧- ចំពោះការធ្វើអំពើតាមការរៀបរាប់របស់ព្រះវេទ (អំពើផ្សេងទៀត)ទាំងអស់ មានបញ្ចូលទាំងស្រុង (អំពើនីមួយៗ)តាមលំដាប់របស់វា មានវិធានជាច្រើនសម្រាប់ពិធីទាំងនោះ។

៨៨- អំពើនានាតាមបញ្ញត្តិរបស់ព្រះវេទមានពីរប្រភេទ ដូចជាផ្តល់នូវការបង្កើនសេចក្តីសុខ និងបន្ត(អត្ថិភាពលោកិយ *ប្រវ្ឫត្ត*) និងជួយផ្តល់បរមសុខដ៏កំពូល និងញ៉ាំងឱ្យបញ្ចប់(អត្ថិភាពលោកិយ *និវ្ឫត្ត*)។

៨៩- អំពើទាំងឡាយដែលជួយ(ឲ្យសម្រេច)សេចក្តីប្រាថ្នាក្នុងលោកិយនេះ ឬជាតិក្រោយ ហៅថាប្រវ្ឫត្ត (គឺជួយបន្តអត្ថិភាពលោកិយ) ប៉ុន្តែអំពើដែលធ្វើដោយគ្មានបំណងចង់(បានផល) ដែលផ្តើមដោយ(ការចង់បាន)ពុទ្ធិពិតប្រាកដ គេហៅថានិវ្ឫត្ត (ជាការបញ្ចប់អត្ថិភាពលោកិយ)។

៩០- អ្នកដែលធ្វើជារឿយៗនូវអំពើ ដែលនាំឱ្យមានកំណើតពេលអនាគត(ប្រវ្ឫត្ត) មានកំណើតស្មើនឹងទេព ប៉ុន្តែអ្នកដែលមានចេតនាធ្វើអំពើទាំងឡាយដែលនាំឱ្យបញ្ចប់(អត្ថិភាព និវ្ឫត្ត) ពិតជាអាចឆ្លងផុតពីធាតុផ្សំទាំងប្រាំ។

---

នេះ និងជាតិក្រោយ ជាងអំពើទាំងប្រាំមួយ(ដូចបានរៀបរាប់ខាងលើ)'។ គាត់ស្នើឡើងនូវការបកស្រាយពីរចំពោះ *កម៌ វៃទិកំ* ។ 'អំពើទាំងឡាយដូចមានទូន្មាននៅក្នុងព្រះវេទ' អាចប្រែថា 'ពិធីស្រោត ដូចជាជ្យោតិស្តោម'ក៏បាន ឬ 'ពិធីទាំងឡាយដែលមានរៀបរាប់បន្តនៅក្នុងកាព្យលេខ៨៨-៨៩ និវ្ឫត្ត' គឺ 'ពិធីដែលបំពេញជាករណីយកិច្ច ដោយគ្មានបំណងចង់បានរង្វាន់កុសលទេ'ក៏បាន។ នន្ទ. ទទួលយកការបកស្រាយទីមួយ ហើយលោកគោវ. ក៏ដូច្នោះដែរ តែប្រែវិភត្តិទី៦ ក្នុងន័យធម្មតា គឺ 'ក្នុងចំណោមទាំងប្រាំមួយនោះ'។ នារ. រើសយកការបកស្រាយទីពីររបស់លោកមេធ. ហើយនិយាយថា 'អំពើដូចបានទូន្មាននៅក្នុងព្រះវេទ' គឺ 'ពិធីយញ្ញជាដើម ដែលធ្វើដោយគ្មានចេតនា(ចង់បាន)រង្វាន់កុសល'ទេ ហើយអធិប្បាយវិភត្តិទី៦ ដូចលោកគោវ. ដែរ។ លោកកុល្លូ. ប្រើសំណង់ប្រយោគដូចគ្នា ថា កម៌ វៃទិកំ 'ការចេះដឹងអំពីព្រលឹងដ៏កំពូល'។ ការបកស្រាយទីពីររបស់លោកមេធ. ទំនងជាត្រឹមត្រូវបំផុត តាមកាព្យលេខ៨៩ និង៩០ ដែលមាន 'ការចេះដឹង' គឺ 'ការចេះដឹងអំពីព្រលឹងដ៏កំពូល'(សូមមើលកាព្យ៨៥) និងគេនិយាយថា ការធ្វើពិធី *និវ្ឫត្តំ កម៌* ឱ្យផលរួចរំដោះចុងក្រោយ។ ការបកស្រាយវិភត្តិទី៦ *សណ្ណាំ ឯតេសាំ* ថា 'ក្នុងចំណោមទាំងប្រាំមួយ' អាចមានហេតុផល ដោះសារបាន ប្រសិនបើ *វៃទិកំ កម៌* ត្រូវប្រែឱ្យស្របតាម *វេទាភ្យាសះ*ការសិក្សាព្រះវេទ (និងការគោរពតាមវិធានព្រះវេទ' ក្នុងកាព្យ៨៣។ ប៉ុន្តែការបកស្រាយសំណង់ប្រយោគរបស់លោកមេធ. ទំនងជាអាចត្រឹមត្រូវ។

**៨៧.** កុល្លូ. កែប្រែការបកស្រាយរបស់គាត់ *វៃទិកំ កម៌* បន្តិចបន្តួច រួចប្រែថា 'ការបូជាអាត្ម័នដ៏កំពូល'(*បរមាត្មោបាសនា*) និងដកស្រង់គម្ពីរព្ឫហទារណ្យក-ឧបនិស័ទ ជំពូក៤ លេខ៤, ២២ ដើម្បីគាំទ្រយោបល់របស់គាត់។ អ្នកអធិប្បាយដទៃ មិនឃើញមានការពិបាក្នុងការបង្ហាញថា ទាំង 'ពិធីស្រោត' ទាំង'និវ្ឫត្តាខ្យំ កម៌' មានដាក់ចំណុចទាំងប្រាំមួយ ដូចរៀបរាប់ក្នុងកាព្យ ៨៣ ខាងលើ។ ខ្ញុំអានតាម K. ក្នុងបន្ទាត់ទីមួយ *ហិ* ជំនួស *តុ* (មេធ., គោវ., កុល្លូ., នន្ទ.)។

**៨៨.** កុល្លូ. កែប្រែការបកស្រាយរបស់ខ្លួនចំពោះសំនួនពាក្យ 'អំពើដូចបានទូន្មាននៅក្នុងព្រះវេទ' ហើយប្រែវាក្នុងន័យថា 'ពិធីយញ្ញ ដូចជា *ជ្យោតិស្តោម* និងការបូជាបដិមា'។

**៨៩.** មេធ. បកស្រាយ *គ្នុនបុរវំ* 'ដែលផ្តើមដោយ(ការក្រេប)យកចំណេះដឹងពិតប្រាកដ' ក្នុងន័យថា 'ចំពោះចំណេះដឹងជាការសំខាន់'(*ញានំ អាទ្យំ មុខ្យំ យស្យ*)។

**៩០.** កុល្លូ. កត់សម្គាល់ថា សំនួនពាក្យ 'មានកំណើតស្មើនឹងទេព' ជាការផ្តល់តួយ៉ាងបង្ហាញពីផល ដែលសម្រេចបានដោយ *កាម្យានិ ករមាណិ*។ 'ឆ្លងផុតធាតុផ្សំទាំងប្រាំ' គឺ 'បោកចោលកាយដ៏ល្អិតសុខុម'(នារ.) ឬ 'បានការរួចរំដោះចុងក្រោយ'(មេធ., គោវ., កុល្លូ.)។

៩១- អ្នកដែលបូជាចំពោះតែអត្តា(ប៉ុណ្ណោះ) ដូចជាទទួលស្គាល់អត្តាក្នុងសព្វសត្វទាំងអស់ ហើយសព្វសត្វទាំងអស់នៅក្នុងអត្តា មាន(ឥស្សរភាព បីដូច)អត្តាធិបតី និងមានពន្លឺដោយឯកឯង។

៩២- បន្ទាប់ពីឈប់ធ្វើពិធីយញ្ញដូចបញ្ជាក់ជូនខាងលើ ព្រាហ្មណ៍គួរតែប្រឹងប្រែង (ស្វែងរក) ការចេះដឹងពីព្រលឹង ក្នុងការកម្ចាត់បង់នូវតណ្ហារបស់ខ្លួន និងក្នុងការសិក្សាព្រះវេទ។

៩៣- ដើម្បីឱ្យបានសម្រេចបំណងនៃអត្ថិភាព ជាពិសេសចំពោះព្រាហ្មណ៍ ពីព្រោះដោយការសម្រេចបំណងនោះ គ្មានអ្វីក្រៅពីនេះ បុរសមានកំណើតពីរដងបានសម្រេចបំណងទាំងអស់របស់ខ្លួន។

៩៤- ព្រះវេទជាភ្នែកអមតៈនៃបុព្វបុរស អាទិទេព និងមនុស្ស បទប្បញ្ញត្តិព្រះវេទ (គឺ)ហួសវិស័យនៃអំណាច(មនុស្ស)ផង និងហួសវិស័យនៃការយល់ដឹង(របស់មនុស្ស)ផង នេះជាការពិត។

៩៥- ប្រពៃណីទាំងអស់ (ស្ម្រិតិ) និងប្រព័ន្ធទស្សនវិជ្ជាដ៏គួរឱ្យស្អប់ ដែលមិនអាស្រ័យលើព្រះវេទ មិនផ្តល់ផលបន្ទាប់ពីស្លាប់ទេ ព្រោះគេប្រកាសថាវាជាមូលដ្ឋានលើភាពងងឹត។

---

**៩១.** *ឥស-ឧបនិស័ទ* លេខ៦។ ‘អ្នកដែលបូជាអត្តា(ប៉ុណ្ណោះ)’ គឺ ‘ដែលភ្ជាប់ខ្លួនទៅនឹងលក្ខណៈទេពទាំងអស់ គឺគិតថា “មិនមែនព្រះអគ្និ មិនមែនព្រះអាទិត្យ ជាទេពទេ គឺខ្ញុំនៅទីនេះជាទេព”(អាត្មានំ ឯវ សរវទេវតាមយត្វេន យោជយតេ/ មន្យតេ នាស្តិរ [នាគ្និរ] អាទិត្យោ វា ទេវតា/ អហំ ឥហិ ច ទេវតា មតិ [ឥហៃវ ទេវតា ឥតិ?] តាមលោកមេធ., នារ. និងទំនងជាលោកគោវ.ដែរ) ហើយតាមលោកកុល្លូ., រាឃ. និងនន្ទ. ថា ‘អ្នកដែលធ្វើពិធី*ជ្យោតិស្តោម* និង(ពិធីយញ្ញ នានា) ជាដើម តាមរបៀបព្រហ្មារបណ’។ អនុប្រយោគគុណស័ព្ទ តាមលោកមេធ. និងគោវ. គិតថា ‘ខ្ញុំមានអ្នកបង្កើតទាំងស្រុង ទាំងមានចលនា និងគ្មានចលនា’(វ្យវស្ថិតះ លោកគោវ.) ឬ ‘ខ្ញុំតាមពិតជាលោកទាំងមូល’(អហំ ឥវៃតជ្ជគ័ត តាមលោក មេធ.) និង ‘សត្វលោកទាំងអស់មាននៅក្នុងខ្លួនខ្ញុំ’(មយ្យ អវស្ថិតានិ តាមលោកគោវ. មយិស្ថិតានិ តាមលោកមេធ.)។ លោកកុល្លូ., រាឃ. និងនន្ទ. (ដែលអាន *សំបស្យ័ន*) បកស្រាយតាមគោលការណ៍វេទាន្តសុទ្ធសាធ។ អ្នកបូជា ត្រូវទទួលស្គាល់អត្តសញ្ញាណរបស់ខ្លួន ថាមានព្រលឹងដ៏កំពូល ហើយថា ដោយសារអត្តសញ្ញាណនេះ គេជាសភាវៈមួយ ដូចសព្វសត្វទាំងអស់ និងថាសព្វសត្វទាំងអស់ គឺតែមួយដូចគេដែរ។ ការប្រែពីរដងចំពោះពាក្យ *ស្វារាជ្យំ* គឺផ្អែកលើន័យពីររបស់កិរិយាស័ព្ទ *រាជ* ‘គ្រប់គ្រង’ និង ‘បញ្ចេញពន្លឺ’។ ពោលគឺ មានតែលោកមេធ. ទើបបញ្ជាក់យ៉ាងនេះ។ កុល្លូ. ឱ្យន័យ ទីពីរប៉ុណ្ណោះ ហើយប្រែឃ្លានេះក្នុងន័យផ្សេងបន្តិចថា ‘សម្រេចបានភាពជាពន្លឺដោយឯកឯង(ព្រហ្មន)’។ គោវ., នារ. និងនន្ទ. ប្រែន័យទីមួយតែម្យ៉ាងប៉ុណ្ណោះ។

**៩១.** ‘ដែលបានរៀបរាប់ខាងលើ’ គឺ ‘ដូចជាបាននូវសេចក្តីសុខដ៏កំពូល’(នន្ទ.) ឬ ‘អគ្និហោត្រ និងពិធីផ្សេងៗ’(មេធ., គោវ., កុល្លូ.)។ អ្នកអធិប្បាយបីរូបខាងក្រោយនេះ គូសបញ្ជាក់ថា កាព្យនេះ មិនចង់បង្ហាញពីការឈប់ធ្វើពិធីប្រចាំថ្ងៃ ដោយខុសពីធម្មតាទេ។

**៩៣.** នន្ទ. លុបកាព្យនេះចោល។ *ក្រិតក្ឫត្យះ*បានសម្រេចបំណងទាំងអស់របស់ខ្លួន’(មេធ.) ត្រូវលោកគោវ. ប្រែក្នុងន័យផ្សេងថា ‘បានធ្វើអ្វីទាំងអស់ ដែលខ្លួនគួរធ្វើ’(ក្ឫតករណីយះ)។

**៩៤.** ជំនួសពាក្យ *អសក្យំ* ‘ហួស(វិស័យ)អំណាចមនុស្ស’ គឺ ‘ដែលមនុស្សមិនធ្វើបាន’(គោវ., កុល្លូ.) លោកនារ. និងនន្ទ. អាន *អតរក្យំ*ហួស(វិស័យ)ហេតុផលរបស់មនុស្ស’(*តរកេណាន្យថាសម្ភវំ* តាមលោកនារ.; *ឥទ្វសំ ឥតី អធ្យវសាតុំ អសក្យំ អបោរុសេយត្វាត* តាមលោកនន្ទ.)។ *អប្រមេយំ* ‘ហួសវិស័យការយល់ដឹង(របស់មនុស្ស)’ តាមអ្នកអធិប្បាយនានា អាចមានន័យថា មនុស្សមិនអាចចេះព្រះវេទទាំងអស់ទេ គ្រប់ចំនួនអង្គធម៌ សាខារបស់ព្រះវេទ និងជម្រៅនៃអត្ថន័យព្រះវេទ ឬថា មនុស្សមិនត្រឹមតែ មិនអាចយល់ហេតុព្រះវេទទេ តែថែមទាំងត្រូវមានជំនួយវេយ្យាករណ៍ពី*មីមាំសា*ជាដើមផង។

**៩៥.** តួយ៉ាងបញ្ជាក់ពីប្រពៃណីក្លែងក្លាយ លោកមេធ. រៀបរាប់ថា ‘វិធាននានាដូចជា “បរមសុខនាឋានសួគ៌ សម្រេចបានដោយការបូជា*ចៃត្យ*” ដែលមាននៅក្នុង*សោក* និង*សិទ្ធាន្ត* ផ្សេងទៀតរបស់និរគ្រន្ថ (តិគម្ពរ ជេន)’។ ‘ប្រព័ន្ធទស្សនវិជ្ជាដ៏គួរឱ្យខ្ពើម’ ឧទាហរណ៍ ‘ប្រព័ន្ធទស្សនៈរបស់*ចារវាក*(កុល្លូ.)។ *ប្រេត្យ*បន្ទាប់ពីស្លាប់’(បរលោកេ តាមគោវ., កុល្លូ.) តាម

៩៦- (លទ្ធិ)ទាំងអស់នោះ ដែលខុសពី(ព្រះវេទ) ដែលកើតឡើង(រួច)វិនាសទៅវិញភ្លាម គឺគ្មានតម្លៃ និងមិនពិត ព្រោះវាមានកាលបរិច្ឆេទសម័យទំនើប។

៩៧- វណ្ណៈបួន លោកបី លំដាប់បួន អតីត បច្ចុប្បន្ន និងអនាគត ភាគច្រើនគេបានដឹងទាំងអស់ តាមរយៈព្រះវេទ។

៩៨- សំឡេង ផស្សៈ ពណ៌ រសជាតិ និងទីប្រាំ គឺក្លិន ត្រូវគេស្គាល់តាមរយៈព្រះវេទប៉ុណ្ណោះ ការបង្ហាញ(របស់វា) គឺតាមរយៈ(ពិធីវេទ ដែលជា) អំពើទីពីរ។

---

លោកមេធ. មានន័យថា *ប្រកសំ ប្របុ*បន្ទាប់ពីសម្រេចនូវភាពឧត្តម'។ លោកមេធ. លើកឡើងនូវការបកស្រាយដូចដែលអ្នកអធិប្បាយផ្សេងទៀតប្រកាន់យក និងបន្ថែមថា គេគួរអាន *ប្រេត*។

**៩៧.** នារ. និងរាឃ. បកស្រាយ *ប្រសិធ្យតិ*ត្រូវបានដឹង' ថា *ជាយតេ*ត្រូវបានបង្កើត'។ គោវ. និងកុល្ល. ចង្អុលទៅជំពូក៣ លេខ៧៦។

**៩៨.** ខ្ញុំអានតាមអ្នកអធិប្បាយទាំងអស់ *ប្រសិធ្យន្តិ* ជំនួស ប្រសូយន្តេ(សំណៅបោះពុម្ពរបស់ឥណ្ឌា)។ ពាក្យចុងក្រោយនៃកាព្យនេះ មានការសង្ស័យច្រើនបំផុត។ មេធ. អាន *ប្រសូតិ គុណកម៌តះ* និងលោកគោវ. ទំនងជាយល់ស្របតាមការប្រែដូចគ្នាដែរ ទោះជាអត្ថបទសំណេរ *បុណ* មានសរសេរ *ប្រភូតគុណកម៌តះ* ក៏ដោយ។ លោកកុល្ល. និងរាឃ. សរសេរ *ប្រសូតិគុណកម៌តះ* ហើយលោកនារ. ថា *ប្រសូតិគុណកម៌កិះ* ព្រមទាំងសំណេរផ្សេងទៀតរបស់លោកមេធ. *ប្រសូតិគុណ កម៌តះ* អាចស្របគ្នានឹងប្រភពដើម។ នៅក្នុងសេចក្តីសន្និដ្ឋាន កំណត់សម្គាល់របស់គាត់ចំពោះកាព្យនេះ លោកមេធ. បញ្ជាក់ថា មានសំណេរផ្សេងៗទៀតជាច្រើន ដែលលោកលុបចោល ព្រោះវាមិនមានប្រយោជន៍(*វៃចិត្រយបាឋាន្តរាណិ និស្ប្រយោជនត្វាន ន លិខ្យន្តេ*)។ ការបកស្រាយនៅតែមានភាពផ្សេងគ្នាពីអំណាននេះ។ ការបកប្រែយកតាមសំណេរ ប្រែ របស់លោកមេធ.។ តាមប្រសាសន៍របស់គាត់ កាព្យនេះមានន័យថា 'សំឡេង និងផ្សេងទៀត ត្រូវគេស្គាល់ថាគួរជាទីរីករាយ និងជាមធ្យោបាយទទួលបានសេចក្តីរីករាយ តាមរយៈព្រះវេទ ព្រោះគេយល់បានតាមទម្រង់ជាបទភ្លេងដ៏ពីរោះជាដើម នៅពេលធ្វើពិធីវេទ' ប៉ុន្តែថា 'ព្រះវេទមិនមែនជាមូលហេតុសម្ភាររបស់វាទេ ពិធីវេទដែលជាអំពើទីពីរ ស្របតាមការបង្កើតរបស់វាតែប៉ុណ្ណោះ'(សព្ទាទីនាំ ភោគ្យត្វេន សុខសាធនានាំ វេទាទ ឯវ ប្រសិទ្ធិះ/ វៃទិកកម៌ានស្ថានាទ គីតាទិសញ្ចាប បត្តិះ... ន បុនរ វេទ ឧបាទានការណំ... ឯត័ទ អាហប្រសូតិរ គុណកម៌តះ/ ប្រសូតិះ សព្ទាទីនាំ ឧត្បត្តិះ/ តទរថំ គុណកម៌ ផលារថតាត ប្រធានកម៌េ [ម] ច ចិត្រាទិសុ គុណធម៌ [កម៌េ] តី ឧក្តំ)។ កំណត់សម្គាល់ខ្លីជាសារជាតុរបស់គោវ. យល់ស្របតាមទស្សនៈនេះ (យេ ស្វគាទិវិប្រតា [សយា] ឧបភោគ្យត្វេនាភិមតាះ សព្ទាទយោ វិសយា តេ ភិមតវិសយោប ភោគោត្ប ត្បុរថំ យ័ទ ឧបការកំ កម៌ាគ្និហោត្រាទិកំ តទនុស្ថានទ្វារេណ វេទ័ទ ឯវ ប្រសិធ្យន្តិ)។ តាមលោកកុល្ល. អត្ថន័យពាក្យ សមាស គឺ 'តាមរយៈពិធីវេទ (ដែលមានប្រភពពី)លក្ខណៈទាំងបី (គឺសេចក្តីល្អជាដើម ដែល)ជាប្រភពនៃ(សំឡេងជាដើម) '។ រាឃ. លើកឡើងនូវការបកស្រាយពីរ គឺ '(ធាតុផ្សំដែលបង្កើតជា)សម្លេង ផស្សៈ ពណ៌ រសជាតិ និងទីប្រាំក្លិន ត្រូវគេដឹងតាមរយៈព្រះវេទ ស្របតាមដើមកំណើតរបស់វា លក្ខណៈរបស់វា និងអំពើរបស់វា'។ បន្ទាប់មក គាត់ឱ្យន័យពាក្យចុងក្រោយដែលសឹងតែដូចគ្នានឹងយោបល់របស់កុល្ល.។ នន្ទ. 'សម្លេងជាដើម រួមជាមួយប្រភពរបស់វា គឺអាកាសជាដើម តាមលក្ខណៈរបស់វា គឺផ្នែកតូចៗរបស់វា ឧ.ទា. *សដ្ឋ* (កំណត់សម្គាល់)ជាដើម និងតាមអំពើរបស់វា គឺការប្រកាន់ខ្ជាប់គ្រឿងអារម្មណ៍ជាដើម ត្រូវបានស្គាល់តាមរយៈព្រះវេទប៉ុណ្ណោះ'។ ចុងក្រោយលោកនារ. ប្រែអំណានរបស់គាត់ថា '(សំឡេងជាដើម) ត្រូវបានបង្កើតឡើងដោយព្រះវេទប៉ុណ្ណោះ ដែលមានលក្ខណៈជាបុព្វបទ *តសិ* មានន័យទីបី និង ករណីផ្សេងទៀត ដូចជាដើមកំណើត គឺ ហេតុនៃការករកើត លក្ខណៈ គឺភាពលើសលុបជាដើម គុណភាព គឺក្លិនក្រអូបជាដើម' (ប្រសូតិះ ជន្មហេតុះ/ គុណ ឧត្កតត្វាទិ/ ធម៌ះ សុរភិត្វាទិះ/ ត្វតិយាទិ តសិះ/ ឯតែរ ឧបលក្សិតាទ វេទាត ប្រសិធ្យន្តិ ជាយន្តេ)។

៩៩- ចំណេះដឹងអមតៈរបស់ព្រះវេទទ្រទ្រង់សត្វលោកទាំងអស់ ហេតុនេះខ្ញុំសូមអះអាងថា វាជាច្បាប់កំពូល ជាមធ្យោបាយ(សម្រាប់បាននូវសេចក្តីសុខ)ចំពោះសត្វលោកទាំងអស់។

១០០- បញ្ញារបស់ទ័ព អំណាចរបស់ព្រះរាជា តំណែងចៅក្រម និងអធិបតេយ្យភាពលើពិភពលោកទាំងមូល សក្តិសមសម្រាប់តែអ្នកដែលចេះវិទ្យាសាស្ត្រវេទប៉ុណ្ណោះ។

១០១- បើដូចភ្លើងដ៏ខ្លាំងក្លាឆេះព្រៃឈើទាំងអស់បាន យ៉ាងណាមិញអ្នកដែលចេះព្រះវេទ ដុតកម្ទេចអស់នូវគ្រឿងសៅហ្មងនៅក្នុងព្រលឹងរបស់ខ្លួនដែលកើតពីអំពើ(អាក្រក់)បានដូច្នោះដែរ។

១០២- ទោះជាស្ថិតក្នុងលំដាប់ណាក៏ដោយ (មនុស្ស)ដែលស្គាល់អត្ថន័យពិតនៃវិទ្យាសាស្ត្រវេទ អាចអាស្រ័យនៅបាន សូម្បីរស់នៅក្នុងលោកិយនេះក្តី ក៏គេសក្តិសមនឹងរួមរស់ជាមួយព្រហ្មបាន។

១០៣- (សូម្បី)អ្នកសិក្សាគម្ពីរ(ពិសិដ្ឋ)មានការភ្លេចភ្លាំងច្រើនក្តី ក៏មានកិត្តិនាមល្បីជាងមនុស្សល្ងង់ អ្នកទាំងឡាយដែលចេះចាំគម្ពីរពិសិដ្ឋល្បីល្បាញក្រៃលែងជាងសិស្ស(ដែលមានការភ្លេចច្រើន) អ្នកដែលមានការចេះដឹងពី(អត្ថន័យ) រឹតតែមានកិត្តិនាមល្បីជាងអ្នក (ដែលគ្រាន់តែ) ចេះចាំពាក្យប៉ុណ្ណោះ ហើយអ្នកដែលប្រតិបត្តិតាម(ការប្រៀនប្រដៅនៃគម្ពីរនោះ) គឺប្រសើរជាងអ្នក(ដែលគ្រាន់តែ)ចេះដឹង(អត្ថន័យវេទ)ទៅទៀត។

១០៤- ការធ្វើតបកម្មដ៏តឹងរ៉ឹង និងការសិក្សាដ៏ពិសិដ្ឋ ជាមធ្យោបាយប្រសើរបំផុត ដើម្បីឱ្យព្រាហ្មណ៍អាចទទួលបានសេចក្តីសុខដ៏កំពូល ហើយដោយសារតបកម្ម គេអាចលុបលាងទោសបាន ដោយសារការសិក្សាដ៏ពិសិដ្ឋ គេអាចបញ្ឈប់(ការកើត និង)ការស្លាប់បាន។

---

**៩៩.** នៅក្នុងការបកស្រាយបន្ទាត់ទីមួយ អ្នកអធិប្បាយចង្អុលទៅរកជំពូក៣លេខ៧៦ និងសេចក្តីវេទពាក់ព័ន្ធនានា។ គោវ. និងកុល្ល. បកស្រាយ *អស្យ ជន្តុះ* 'របស់សត្វលោកទាំងអស់' ថា 'របស់មនុស្សដែលបានធ្វើពិធីវេទ'។ នារ. ប្រែបន្ទាត់ទីពីរផ្សេងថា 'ដោយសារអំពើនោះ គឺ ព្រះវេទប៉ុណ្ណោះ ខ្ញុំចេះដឹងខ្ពស់បំផុត គឺ ការធ្វើសមាធិ ដែលជាមធ្យោបាយ គឺមធ្យោបាយសម្រាប់ការរួចរំដោះចុងក្រោយសម្រាប់សត្វលោកទាំងអស់'(យ័ទ អស្យ ជន្តុះ សាធនំ អបវគ៌សាធនំ / បរំ ធ្យានំ ធ្យេយាទិ/ត័ទ ឯតស្មាទ វេទ័ទ ឯវ មន្យេ ជានេ)។

**១០០.** មេធ. ដាក់កាព្យនេះក្រោយ។ លំដាប់តាមសំណៅដែនៅក្នុងកាព្យដទៃនៃសំហិតា ខុសគ្នាច្រើនពីលំដាប់កាព្យរបស់អ្នកអធិប្បាយដទៃ។ លំដាប់នោះគឺមាន៖ ១០៦, ១០៧, ១០៨, ១០០, ១០១, ១០២, ១០៣, ១០៤, ១០៥, ១០៩, ១១០, ១១១, ១១២, ១១៣, ១១៤, ១១៥, ១១៦, ១១៧, ១១៨, ១១៩, ១២០, ១២១, ១២២; បន្ទាប់មកទាំង អត្ថបទ ទាំងបទអធិប្បាយលេខ៩១, ៩២, ៩៣ ត្រូវសរសេរដដែលៗ តទៅទៀតសរសេរដល់កាព្យចុងក្រោយគឺ ១២៦។

**១០៣.** *អជ្ញេភ្យះ*ជាងអ្នកល្ងង់' គឺ 'មនុស្សល្ងង់ទាំងស្រុង'(មេធ., នារ.) 'ដែលមិនបានសិក្សាព្រះវេទ'(នន្ទ.) តាម លោកគោវ. និងកុល្ល. ថា 'អ្នកដែលបានសិក្សាតិចតួច'។ *គ្រន្ថិនះ* 'សិស្ស(ដែលមានការភ្លេចច្រើន)'(កុល្ល., នន្ទ.) តាម លោកមេធ. និងគោវ. ថា 'សិស្សដែលរៀនតែអត្ថបទប៉ុណ្ណោះ តែមិនយកចិត្តទុកដាក់ខ្លាំងចំពោះការសិក្សា' តាមលោកនារ. ថា 'បុរសដែលចេះតែអត្ថបទប៉ុណ្ណោះ'។ *ធារីណះ* 'អ្នកដែលចេះចាំ(អត្ថបទ)'(កុល្ល., នន្ទ.) តាមលោកមេធ. និងគោវ.ថា 'បុរសដែលមានសេចក្តីព្យាយាមក្នុងការសិក្សា' តាមលោកនារ. ថា 'អ្នកដែលចេះដឹងអត្ថន័យនៃអត្ថបទ'។ នារ. ប្រែ *ជ្ញានិន* 'អ្នកដែលចេះដឹង(អត្ថន័យអត្ថបទ)' ក្នុងន័យថា 'អ្នកដែលមានចំណេះដឹងអំពីព្រលឹង ឬអត្តា'។

**១០៤.** យញ្ញ. ជំពូក១ លេខ២០០។

១០៥- អ្នកដែលចង់បានភាពត្រឹមត្រូវតែតខ្វោះតាមច្បាប់ពិសិដ្ឋ ត្រូវតែមានការយល់ដឹងទាំងស្រុងនូវ (សក្ខីកម្ម)បីប្រភេទ គឺសញ្ញា ការពិចារណា និងគោលការណ៍(ពិសិដ្ឋ) ដែលមានប្រពៃណី(ពី) សាលាជាច្រើន។

១០៦- គ្មានអ្នកក្រៅពីនេះទេ គឺមានតែអ្នកដែលខិតខំរៀនតាមសម្ពីបណ្ឌិតនិងអង្គច្បាប់ ដោយវិធីពិចារណារកខុសត្រូវ មិនមែនស្អប់ខ្ពើមចំណេះដឹងព្រះវេទប៉ុណ្ណោះ។

១០៧- អំពើដែលនាំឱ្យបានសេចក្ដីដ៏កំពូល ត្រូវបានរៀបរាប់ទាំងស្រុង និងយ៉ាងច្បាស់លាស់មកយ៉ាងនេះ (តទៅនេះ) ព្រះមនុ នឹងប្រកាសអំពីផ្នែកពិសិដ្ឋនៃគោលការណ៍ទាំងអស់នេះ ដើម្បីទុកជាមេរៀន។

១០៨- ប្រសិនបើគេសួរថាតើធ្វើយ៉ាងណាដើម្បីទើបដឹងថាជា(ចំណុច)នៃច្បាប់ ដែលមិនបានបញ្ជាក់ជូនជាពិសេសនោះ (ចម្លើយគឺថា) ‘ចំណុចដែលព្រាហ្មណ៍(គឺ)សិស្ដៈថ្លែងអះអាង គឺអានុភាពច្បាប់’ ។

១០៩- គេត្រូវតែចាត់ទុកព្រាហ្មណ៍ទាំងនោះ ថាជាសិស្ដៈ ដែលតាមច្បាប់ពិសិដ្ឋ គឺបានសិក្សាព្រះវេទរួមទាំងសាខាវេទ ហើយអាចលើកហេតុផលសំអាង ដែលអាចឱ្យគេយល់ន័យបាន តាមអត្ថបទបង្ហាញនោះ។

---

**១០៥.** *សស្រ្តំ* ‘គោលការណ៍(ពិសិដ្ឋ)’ គឺ ‘ព្រះវេទ ដែលមានសាខាជាច្រើន’(គោវ., នារ.) ឬ ‘ព្រះវេទ និងស្មិតិ’(មេធ.) ឬ ‘ស្មិតិ’(កុល្ល.)។ នន្ទ. អាន *សិទ្ធី* ‘ការចេះដឹងទាំងស្រុង ឬ ការប្រតិបត្តិត្រឹមត្រូវ’ ជំនួស *សុទ្ធី* ។ សំណៅ*ឫណ* របស់លោកនារ. ចប់ត្រឹមកាព្យនេះ ផ្នែកផ្សេងទៀតត្រូវបាត់អស់ហើយ។

**១០៦.** ‘សម្ដីរបស់បណ្ឌិត’ គឺ ‘ព្រះវេទ’។ ‘អង្គច្បាប់’ គឺ ‘ស្មិតិ’។ ‘វិធីពិចារណាហេតុផល’ គឺ តាមលោកមេធ. និងកុល្ល. គឺ *មិមាំសា* របស់ជេមិនិ ហើយតាម ‘អ្នកផ្សេង’ ដែលលោកមេធ.ស្រង់សេចក្ដី សាលាទស្សនវិជ្ជាទាំងអស់ លើកលែងសាលាទាំងឡាយ ដូចជាសាលាពោធ, សាលានិគ្រ័ន្ថ និងសាលាលោកាយតិក បដិសេធប្រភពដ៏ត្រឹមត្រូវរបស់ព្រះវេទ។

**១០៨-១១៥.** អាប. ជំពូក២ លេខ២៩, ១៣-១៤; គោត. ជំពូក២៨ លេខ៤៨-៥១; វស. ជំពូក៣ លេខ២០; ពោធ. ជំពូក១ លេខ១, ៥-១៣, ១៦; យញ្ញ. ជំពូក១ លេខ៩-១០។

**១០៩.** ‘អនុលោមតាមច្បាប់ពិសិដ្ឋ’ គឺ ‘ខណៈដែលប្រតិបត្តិតាមតម្រាច្បាប់បញ្ញត្តិសម្រាប់សិស្ស’។ សំនួនពាក្យ *ស្រុតិប្រត្យក្សហេតវះ* ‘ដែលអាចលើកហេតុផលសំអាង ដែលគេអាចយល់ន័យអត្ថបទបង្ហាញនោះបាន’ គឺចេះបកស្រាយតាមបែបផ្សេងៗ។ តាមលោកមេធ. អាចមានន័យថា ‘អ្នកដែលចេះច្បាស់នូវអត្ថបទអាថ៌កំបាំង (លើកសំអាងតាមរយៈ)ការពិចារណា និងការលើកសេចក្ដីសំអាង’(សុត្រិប្រត្យក្សេ ហេតុ ច ស្រុតិប្រត្យក្សហេតុវះ) ឬ ‘អ្នកដែលអាចយល់ន័យអត្ថបទអាថ៌កំបាំងបាន គឺហេតុផលសម្រាប់បើកបង្ហាញឱ្យឃើញច្បាស់រវាងបុណ្យ និងបាប’(អថវា ស្រុតេះ ប្រត្យ ក្ស ស្រុតេះ/ ប្រត្យក្សសព្ទះ សោតេប្រត្យយេ ប្រត្យក្សតុល្យត្វាត ប្រយុត្តះ/ ស ច ហេតុ ធម៌ាធម៌បរិញ្ញានេ ការណំ យេសាំ ត ឯវំ ឧច្យន្តេ) ;តាមគោវ. ថា ‘ដែលចេះបង្រៀនមុខវិជ្ជា ដែលអាចយល់បាននៅក្នុងព្រះវេទ’ (វេទគោចរបទារថោបទេសការណភូតាះ); តាមកុល្ល. ថា ‘ដែលចេះបង្ហាញអត្ថបទអាថ៌កំបាំង ឱ្យគេអាចយល់បាន ដោយការសូត្រអត្ថបទអាថ៌កំបាំងនោះ’ ហើយតាមលោកនន្ទ. ថា ‘អ្នកដែលមានចំណេះដឹង និងចេះពណ៌នាច្បាប់ ឱ្យគេស្ដាប់ និងពិចារណាន័យបាន’(យេសាំ ស្រវណាំ ប្រត្យក្សំ ច ធម៌ញាណវចនយោ ហេតុ តេ)។ ‘សាខា’ គឺ ‘ឥតិហាស និងបុរាណ’(មេធ. សំដៅដល់មហាភារតះ, នន្ទ.) ឬ ‘អង្គ មីមាំសា គម្ពីរច្បាប់ គម្ពីរបុរាណជាដើម’(គោវ., កុល្ល.)។

១១០- ក្នុងអង្គជំនុំអ្វីក៏ដោយដែលមានគ្នាដប់នាក់ យ៉ាងតិចមានបីនាក់ដែលប្រកបមុខរបរ តាមបញ្ញត្តិសម្រាប់ខ្លួន គេប្រកាសថាស្របច្បាប់ តាម(អានុភាព)ច្បាប់ គឺអង្គជំនុំមួយដែលគ្មានទំនាស់។

១១១- មនុស្សបីនាក់ដែលម្នាក់ៗសុទ្ធតែចេះព្រះវេទមួយក្នុងចំណោមព្រះវេទសំខាន់ទាំងបី តក្កវិទូ មីមាំសក អ្នកដែលចេះនិរុត្ត អ្នកដែលចេះសូត្រ(គោលការណ៍)ច្បាប់ពិសិដ្ឋ និងបីនាក់ដែលស្ថិតក្នុងលំដាប់បីដំបូង នឹងបង្កើតបានជាអង្គជំនុំ(ស្របច្បាប់)ដែលយ៉ាងហោចមានសមាជិកដប់នាក់។

១១២- អ្នកដែលចេះឫគ-វេទ អ្នកដែលចេះយុជវេទ និងអ្នកដែលចេះសាម-វេទ អាចបង្កើតអង្គជំនុំមួយដែលយ៉ាងហោចមានសមាជិកបីនាក់(និងមានសមត្ថភាព)សម្រេចបញ្ហាសង្ស័យរបស់ច្បាប់បាន។

១១៣- សូម្បីមានព្រាហ្មណ៍តែម្នាក់ដែលចេះតែងកាព្យព្រះវេទ ប្រកាសជាច្បាប់ ក៏គេអាចចាត់ទុក(ថាមានអានុភាព)ច្បាប់ដ៏កំពូល តែមិនមែនថ្លែងច្បាប់ដោយមនុស្សល្ងង់ដ៏ច្រើនអនេកនោះទេ។

១១៤- សូម្បីបើព្រាហ្មណ៍មួយពាន់នាក់ ដែលមិនបានបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន មិនចេះព្រះវេទ និងចិញ្ចឹមជីវិតដោយសារឈ្មោះវណ្ណៈរបស់ខ្លួនប៉ុណ្ណោះ ជួបប្រជុំគ្នាក៏ដោយ ក៏ពួកគេមិនអាច(បង្កើត) ជាអង្គជំនុំ (សម្រាប់ដោះស្រាយច្បាប់ពិសិដ្ឋ)បានដែរ។

១១៥- បាបរបស់មនុស្សភ្លើ ការចាប់កំណើតដោយភាពងងឹត និងអ្នកដែលមិនចេះច្បាប់ទូន្មាន(តាមករណីយកិច្ចរបស់ខ្លួន) នឹងធ្លាក់ចុះរាប់រយដងតាមអ្វីដែលខ្លួនបានថ្លែង។

១១៦- អ្វីទាំងអស់ដែលឱ្យផលសក្តិសិទ្ធិដើម្បីបានសេចក្តីសុខដ៏កំពូល ត្រូវបានប្រកាសមកយ៉ាងនេះដល់អ្នកទាំងឡាយ គឺព្រាហ្មណ៍មិនគួរធ្លាក់ចុះពីអ្វីដែលខ្លួនបានសភាពដ៏ឧត្តមបំផុតនោះទេ។

១១៧- ដូចបានប្រកាសមកយ៉ាងនេះថា អាទិទេពគួរឲ្យគោរពសូមបង្ហាញខ្លួនឱ្យខ្ញុំឃើញមក ដោយសេចក្តីប្រាថ្នាផ្តល់ប្រយោជន៍ដល់មនុស្សជាតិ នេះជាអាថ៌កំបាំងដ៏ប្រពៃបំផុតនៃច្បាប់ពិសិដ្ឋ ត្រូវបានប្រកាសទាំងស្រុងដូច្នេះ។

---

**១១០.** មេធ. និងគោវ. អាន *វិចារយេត* ជំនួស *វិចាលយេត* (កុល្ល., នន្ទ.)។

**១១១.** 'មនុស្សបីនាក់ដែលស្ថិតក្នុងលំដាប់បីដំបូង' គឺ 'សិស្ស យរាវាសនិងឥសី'(គោវ., កុល្ល., នន្ទ.)។ មេធ. មានប្រសាសន៍ អ្នកខ្លះគិតថា 'សិស្ស យរាវាស និងតាបស' ព្រោះឥសីមិនត្រូវដើរចូលភូមិទេ ហើយដោយសារគោតម ក្នុងការរៀបរាប់អំពីវណ្ណៈ ដាក់តាបស នៅមុនតាឥសី ចំណែកឯអ្នកផ្សេងឱ្យន័យពាក្យនេះ សំដៅដល់លំដាប់បីខាងដើមរបស់មនុ។ សំណេរ *ត្រៃវិទ្យា* ដែលបទអធិប្បាយទាំងអស់ ទំនងជាសរសេរមិនបានត្រឹមត្រូវ។ គេគួរសរសេរ *ត្រៃវិទ្យំ,* តិស្វណាំ វិទ្យានាំសមាហារៈ; សូមមើលយញ្ញ. ជំពូក១ លេខ៩ ហើយប្រៀបធៀប *ចាតុរវិទ្យំ, ចាតុរវៃទ្យំ* របស់ពោធ. ជំពូក១ លេខ១, ១, ៨ និងវស. ជំពូក៣ លេខ២០។

**១១៤.** *អវ្រតានាំ*ដែលមិនបានបំពេញករណីយកិច្ចពិសិដ្ឋរបស់ខ្លួន' គឺ 'ដែលមិនបានបំពេញពាក្យសច្ចាក្នុងពេលសិក្សា' (គោវ., កុល្ល.)។

**១១៥.** នន្ទ. សរសេរ *យ័ទ* សម្រាប់ *យំ* ជំនួស *តមោភូតះ*ការចាប់ភពពីភាពងងឹត' តាមសំណេររបស់ធម៌-សូត្រ *តមោមូធាះ* 'ដែលឡូកឡំដោយភាពងងឹត ឬអវិជ្ជា'។

១១៨- ចូរ(ព្រាហ្មណ៍គ្រប់រូប) ដែលមានចិត្តមូល ទទួលស្គាល់អត្តា ថាមាននៅក្នុងសភាវៈទាំងអស់ ទាំងសភាវៈពិតនិងមិនពិត ព្រោះអ្នកដែលទទួលស្គាល់ចក្រវាលនៅក្នុងអត្តា មិនញ៉ាំងឱ្យចិត្តរបស់គេទទួលនូវភាពមិនត្រឹមត្រូវនោះទេ។

១១៩- អត្តាតែម្យ៉ាង មានទេពច្រើន ចក្រវាលស្ថិតនៅលើអត្តា ព្រោះអត្តាបង្កើតទំនាក់ទំនង (ព្រលឹង) ក្នុងកាយជាមួយនឹងអំពើ។

១២០- ចូរអ្នកភាវនាអំពីអាកាសឱ្យដូចជារន្ធក្នុងកាយ អំពីខ្យល់ឱ្យដូចជាដំណើរនៃចិត្ត និងផស្សៈ អំពីពន្លឺដ៏ប្រពៃបំផុតឱ្យដូចជាសរីរាង្គរំលាយអាហារ និងចក្ខុប្រសាទរបស់ខ្លួន អំពីទឹកឱ្យដូចជាវត្ថុរាវ (មានរូប) អំពីដីបីដូចជាផ្នែករឹង(នៃកាយរបស់ខ្លួន);

១២១- អំពីព្រះច័ន្ទ្របីដូចសរីរាង្គខាងក្នុង អំពីផ្នែកនៃផ្ទៃមេឃហាក់ដូចជាចិត្តញ្ញ អំពីព្រះវិស្ណុ ឱ្យដូចជា (អំណាចនៃ)ចលនា អំពីព្រះហរឱ្យដូចជាកម្លាំងរបស់ខ្លួន អំពីអគ្និ(ភ្លើង)ឱ្យដូចជាសម្តីរបស់ខ្លួន អំពី *មិត្រ*ឱ្យដូចជាការបន្ទោរបង់របស់ខ្លួន និងអំពីប្រជាបតិ ឱ្យដូចជាសរីរាង្គបង្កកំណើត។

១២២- ចូរអ្នកស្គាល់អង្គឈ្មោលដ៏កំពូល(បុរសជា)អ្នកគ្រប់គ្រងអំណាចលើសគេ តូចជាងតូច ភ្លឺដូចមាស និងអាចដឹងដោយបញ្ញា(សូម្បីនៅក្នុង)សភាពដេក (ដូចហួសវិស័យនឹងគិត)។

១២៣- អ្នកខ្លះហៅទ្រង់ព្រះអគ្និ (ភ្លើង) ខ្លះទៀតហៅមនុ ម្ចាស់នៃសត្វលោក ខ្លះថាព្រះឥន្ទ្រ ខ្លះទៀតថាខ្យល់ជីវិត ហើយខ្លះទៀតថា ព្រហ្មដែលគ្មានទីបំផុត។

១២៤- ទ្រង់សាយដល់សត្វលោកទាំងអស់ ក្នុងទម្រង់ទាំងប្រាំ និងធ្វើឱ្យសត្វលោកចម្រើនឡើង រួចបែកធ្លាយទៅវិញ ដោយសារកំណើត ហើយវិលចុះវិលឡើង ឧបមាដូចជាកង់(រទេះ)។

១២៥- ហេតុនេះទ្រង់ដែលទទួលស្គាល់អត្តា ដោយអត្តានៅក្នុងសត្វលោកទាំងអស់ មានព្រះទ័យលំឱនទៅសព្វសត្វទាំងអស់ស្មើៗគ្នា ហើយចូលទៅកាន់សភាពខ្ពស់បំផុត គឺព្រហ្ម។

---

**១១៨.** *សំបស្យេត* ‘ចូរ(ព្រាហ្មណ៍គ្រប់រូប)ទទួលស្គាល់ទាំងស្រុង’ គឺ ‘ចូរអ្នកស្គាល់ឱ្យបានច្បាស់នៅក្នុងចិត្ត’ (សាក្សា ត្កុរ យាត តាមមេធ., កុល្លូ.) ដោយការអនុវត្តធម្មទិដ្ឋ(ឧបាសនា តាមលោកមេធ.) ឬ ដោយការធ្វើសមាធិដ៏ជ្រៅ(កុល្លូ.) ឬ ‘ចូរអ្នកតាំងសច្ចា មានចិត្តតែមួយចង់បានចំណេះដឹង ដោយមិនរៀនមុខវិជ្ជាផ្សេងទៀតទាំងអស់’ (ញេយាន្តវិសយនិរាករណេន តទេកញ្ញេយនិស្ឋាំ អនុព្រូយាត តាមលោកមេធ.)។ *អាត្មានិ* ‘ក្នុងអត្តា’ គឺ ‘ក្នុងអាត្ម័នដ៏កំពូល’(កុល្លូ., នន្ទ.) ឬ ‘ក្នុងអត្តានីមួយៗរបស់ខ្លួន’(គោវ.)។ លោកមេធ. កត់សម្គាល់ថា ‘វិវាទក្នុងការសិក្សាពាក់ព័ន្ធនឹងអត្ថន័យនៃពាក្យ *អាត្ម័ន* និងថាក្រៅពីការបកស្រាយទាំងពីរ ដែលបានជម្រាបជូនរួចហើយនេះ ទំនងជាមានអ្នកខ្លះនិយាយថា ‘អត្តារូបកាយ’’ គឺ ‘ផល និងហេតុ’ ឬ ‘បញ្ញា និងគ្មានបញ្ញា’(នន្ទ.) តាមគោវ. គឺថា ‘អ្វីដែលមានទម្រង់ទំហំស្របជាក់លាក់ និងទម្រង់ផ្ទុយរបស់វា’ (មុរតំ ឫចិវ្យាទិ យច្ចាមូរតំ អាកាសាទិ)។ លោកមេធ. លើកឡើងនូវការបកស្រាយពីរផ្សេងទៀត ១. ‘អ្វីដែលទាំងមានអត្ថិភាព និងទាំងគ្មានអត្ថិភាព គឺប្រែជាមានអត្ថិភាព និងវិនាសទៅវិញ’ ២. ‘អ្វីដែលដូចជាស្នែងរបស់សត្វទន្សាយស្លឹក មិនធ្លាប់មានឡើយ និងថាអ្វីដែលដូចជាអាកាស គ្មានទីបំផុត’។ ពាក្យ *សមាហិតះ* ‘ប្រមូលអារម្មណ៍ខ្លួនឯង’ តាមលោក មេធ. គិត គឺជាន័យបច្ចេកទេស ហើយសំដៅដល់សមាធិ ដូចមានរៀបរាប់នៅក្នុងប្រព័ន្ធយោគៈ និងវេទាន្ត។

**១១៩.** នៅក្នុងកាព្យនេះ លោកគេក៏បកស្រាយ *អាត្មា* ថា *បរមាត្មា* ដែរ។

**១២០.** មេធ. បកស្រាយពាក្យ *ស្នេហ*នៅលើវត្ថុរាវ(មានរូប)’ ថា ‘នៅលើសារធាតុស្អិតអន្ទិល’ ឧ.ទា. ‘ខួរក្បាលជាដើម’។

**១២៤.** ទម្រង់ទាំងប្រាំ គឺជាតុធំៗទាំងប្រាំ ដែលបង្កើតរូបកាយទាំងអស់(គោវ., កុល្លូ., នន្ទ.)។

**១២៥.** ជំនួស *បរំបទំ* ‘សភាពខ្ពស់បំផុត’ លោកនន្ទ. អាន *សនាតនំ* ‘(ព្រហ្ម)គ្មានទីបំផុត’។

១២៦- អ្នកមានកំណើតពីរដង ដែលសូត្រគោលការណ៍ទាំងអស់ដែលព្រះមនុបានបើកបង្ហាញ តែងតែមានគុណធម៌ក្នុងការប្រព្រឹត្ត និងឈានទៅកាន់សភាពណាមួយតាមសេចក្តីប្រាថ្នា។

១២៧- ត

---

**១១៨.** តតតតតតតតតតតត

# សេចក្តីសង្ខេប

ដោយសារពាក្យណែនាំរបស់បណ្ណាធិការ ខ្ញុំសូមបន្ថែមសេចក្តីសង្ខេបលម្អិត ឬសេចក្តីប្រៀបធៀប ពីធម៌-សូត្រ និងស្រ្មិតិចំនួនប្រាំមួយ ព្រមទាំងកាព្យដូចគ្នាទាំងមូល ឬដោយផ្នែក ដែលស្រង់ពីគម្ពីរ មហាភារតៈ, បរាសរ, មានវៈ ស្រាទ្ធកល្ប, ឧបនិស័ទ និងស្នាដៃផ្សេងៗមួយចំនួនទៀត។ ខ្ញុំមានជំនឿ ចិត្តថា សូម្បីមានសេចក្តីសំអាងដល់ស្រ្មិតិនានា ដូចមាននៅក្នុងកំណត់សម្គាល់ចំពោះការបកប្រែក្តី ក៏ ការបន្ថែមនេះ មិនមានប្រយោជន៍អ្វីដែរ។ គោលការណ៍ដែលខ្ញុំបានសំអាងនោះ ជាគោលការណ៍ផ្សេង មួយ ហើយសេចក្តីសង្ខេបនេះ បង្ហាញកាន់តែច្បាស់ថាតើតម្រាវិធានមួយណានៅក្នុងស្នាដៃរបស់មនុ ត្រូវបានបង្ហាញនៅក្នុងគម្ពីរបុរាណៗ និងវិធានណាដែលគ្មាន។ ខ្ញុំអាចបង្ហាញត្រួសៗថា កាព្យណាខ្លះ ដែលខ្ញុំសរសេរប្រាប់ប្រភពផ្សេង។ យោងតាមអ្វីដែលបានរៀបរាប់មកហើយនៅក្នុងសេចក្តីណែនាំ ចំណុចទាំងពីរមានសារៈសំខាន់ខ្លះដែរ។ ខ្ញុំសូមប្រើប្រាស់ឱកាសនេះ ដើម្បីបញ្ជាក់ពីការលុបចោលខ្លះ និងដើម្បីកែសម្រួលកំហុសអក្ខរាវិរុទ្ធ ដែលមាននៅក្នុងសេចក្តីដកស្រង់ ត្រង់ចំណុចកំណត់សម្គាល់ ត្រង់កំណត់សម្គាល់ និងសេចក្តីបន្ថែមណាដែលផ្សេងគ្នា ចំណុចខាងក្រោយជាចំណុចសំអាងតែ ម្យ៉ាង។ ការបន្ថែមសញ្ញាផ្កាយ ( * )ត្រង់សេចក្តីដកស្រង់ មានន័យថា សេចក្តីមាននៅក្នុងកាព្យ ហើយ ថាដូច្នេះវាមានទំនាក់ទំនងផ្ទាល់ជាមួយស្លោករបស់មនុ។ សេចក្តីដកស្រង់ពីគម្ពីរមហាភារតៈ គឺជា កាព្យ មានប្រភពតែមួយ។ ហេតុនេះ គ្មានការថែមសញ្ញាផ្កាយទេ។

# ឧបសម្ព័ន្ធ







Dasaavataara of Lord Vishnu
Vamana
Parasurama
Narasimha
rama
Varaha
Krishna
Kurma
Budha
Vishnu Nijarupam
Kalki
Matcha





© www.astrogems.com


















© www.astrogems.com
















simon_ram









**បណ្ឌិតសភាចារ្យ ខ្លុត ធីតា**

១-មុខងារ : បណ្ឌិតសភាចារ្យ **ខ្លុត ធីតា** កើតនៅឆ្នាំ១៩៥៦ ភូមិសំណាយ ឃុំត្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់
. ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទទួលបន្ទុកការងារធម្មការនិងសាសនា
. ប្រធានរាជបណ្ឌិត្យសភាកម្ពុជា
. សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា
. សមាជិកក្រុមជាតិវចនានុក្រមខ្មែរ
. សាស្ត្រាចារ្យទស្សនវិជ្ជា និងច្បាប់

២-ស្នាដៃនិពន្ធនិងបោះពុម្ព : (១)-ឆ្នាំ១៩៩៥ : ទស្សនៈអហិង្សារបស់ព្រះពុទ្ធសាសនា និងសិទ្ធិមនុស្ស (២)-ឆ្នាំ១៩៩៦ : អហិង្សាព្រះពុទ្ធសាសនា និងលទ្ធិប្រជាធិបតេយ្យ (៣)-ឆ្នាំ១៩៩៦ : ព្រះពុទ្ធសាសនា និងការអភិវឌ្ឍសង្គមខ្មែរ (៤)-ឆ្នាំ១៩៩៦-២០០៥ : អត្ថបទស្តីពី ព្រះពុទ្ធសាសនាសម្រាប់ ទស្សនាវដ្តី អក្សរសាស្ត្រ-មនុស្សសាស្ត្រ (៥)-ឆ្នាំ១៩៩៦-១៩៩៨ : ព្រះពុទ្ធសាសនាក្នុងជីវិតខ្មែរ (ភាគ១ ភាគ២) (៦)-ឆ្នាំ១៩៩៨-១៩៩៩ : ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ (៧)-ឆ្នាំ១៩៩៩ : ស្វែងយល់ពីជំនឿសាសនាលើសកលលោក (៨)-ឆ្នាំ២០០០ : ព្រះសមណគោត្តម (៩)-ឆ្នាំ២០០២ : ទិដ្ឋភាពទូទៅនៃគំនិតខ្មែរ ឆ្នាំ១៩៩៩ លើកទី២ (១០)-ឆ្នាំ១៩៩៩ : បកប្រែនិងបោះពុម្ពសៀវភៅ ១០០ សំណួរ ១០០ចម្លើយ សាសនានៅប្រទេសចិន (១១)-ឆ្នាំ២០០០-២០០៦ : ទស្សនាវដ្តីកម្ពុជសុរិយានៅពុទ្ធសាសនបណ្ឌិត្យស្នាដៃខ្មែរចំពោះព្រះពុទ្ធសាសនា (១២)-ឆ្នាំ២០០២ : មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជាសកលលោក បោះពុម្ពបាន ៣ លើកជាបន្តបន្ទាប់ (១៣)-ឆ្នាំ២០០២ : ការស្វែងយល់អំពីការជឿព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ(ឆ្លុះបញ្ចាំងតាមរយៈទស្សនវិជ្ជា) (១៤)-ឆ្នាំ២០០២ : ប្រៀបធៀបទស្សនវិជ្ជាព្រះពុទ្ធសាសនា និងនៅសង្គមខ្មែរ(ទស្សនវិជ្ជាច្បាប់) (១៥)-ឆ្នាំ២០០៥ : ទស្សនវិជ្ជាឥណ្ឌា និងតក្កវិជ្ជា (១៦)-ឆ្នាំ២០០៦ : អក្សរសិល្ប៍ខ្មែរសតវត្សទី២០ (១៧)-ឆ្នាំ២០០៧ : ជឿនិទាន និងចំណេះដឹងជនជាតិភាគតិច នៅក្នុងប្រទេសកម្ពុជា ក្រុមវិទ្យាស្ថានមនុស្សនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា (១៨)-ឆ្នាំ២០០៥ : ទំនាក់ទំនងសីលធម៌ និងច្បាប់នៅក្នុងសង្គមខ្មែរ បោះពុម្ពលើកទី១ (១៩)-ឆ្នាំ២០០៧ : តើព្រះពុទ្ធបង្រៀនប្រជាជនអ្វីខ្លះ ? (២០)-ឆ្នាំ២០០៧ : ស្វែងយល់ពីទស្សនវិជ្ជា (២១)-ឆ្នាំ២០០៨ : ស្វែងយល់ពីអំពីចំណីអាហារ បោះពុម្ពលើកទី១ ទី២ និងទី៣ (២២)-ឆ្នាំ២០០៨ : អរិយទ្រព្យដ៏ប្រសើររបស់មនុស្ស បោះពុម្ពលើកទី១ (២៣)-ឆ្នាំ២០០៨ : ទស្សនវិជ្ជាសម័យអង្គរ (២៤)-ឆ្នាំ២០០២ : មូលដ្ឋានគ្រឹះនៃសីលវិទ្យាសកលលោក បោះពុម្ពលើកទី១ ទី២ ទី៣ និងទី៤ (២៥)-ឆ្នាំ២០០៩ : គតិបណ្ឌិតសម្រាប់ពុទ្ធសាសនិក បោះពុម្ពលើកទី១ និងទី២ (២៦)-ឆ្នាំ២០១១ : ទស្សនវិជ្ជាសម័យថ្មីមុន លាវ៉ូក ខុងជឺ និងបារាំង បោះពុម្ពលើកទី១ (២៧)-ឆ្នាំ២០១៣ : ព្រះពុទ្ធសាសនានិងភាពរីកសាសនានៅក្នុងសង្គមខ្មែរក្រោយឆ្នាំ មករា ១៩៧៩ (១៩៧៩-បច្ចុប្បន្ន) បោះពុម្ពលើកទី១ ទី២ និងទី៣ (២៨)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា បោះពុម្ពលើកទី១ (២៩)-ឆ្នាំ២០១៣ : ព្រះពុទ្ធបដិមានៅកម្ពុជា បោះពុម្ពលើកទី១ ជាក្រុម (៣០)-ឆ្នាំ២០១៣ : សាសនាសកល បោះពុម្ពលើកទី១ ទី២ (៣១)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាច្បាប់ (៣២)-ឆ្នាំ២០១៦ : ប្រវត្តិទស្សនវិជ្ជាថ្មី និងច្បាប់នៅប្រទេសមួយចំនួនលើពិភពលោក (៣៣)-ឆ្នាំ២០១៦ : គម្ពីរពិសិដ្ឋរបស់បុព្វប្រទេស (ច្បាប់មនុ) (៣៤)-ឆ្នាំ២០១៦ : ជំនាញវិទូនីតិវិស័យច្បាប់និងសីលធម៌ នៅលើសកលលោក (៣៥)-ឆ្នាំ២០១៦ : ព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរសម័យនគរភ្នំ (បុរាណ)ដល់សម័យសាធារណរដ្ឋ(លន់ នល់) (៣៦)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាសីលធម៌ខ្មែរ (ភាគទី១ និងភាគទី២) (៣៧)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាឥណ្ឌា (៣៨)-ឆ្នាំ២០១៦ : ប្រសិទ្ធភាពនៃសីលវិន័យ និងសិក្ខាបទសាសនានៅក្នុងសង្គមខ្មែរបច្ចុប្បន្ន (៣៩)-ឆ្នាំ២០១៦ : ស្វែងយល់ទស្សនវិជ្ជាពិភពលោក (៤០)-ឆ្នាំ២០១៦ : ទស្សនវិជ្ជាចិន (៤១)-ឆ្នាំ២០១៦ : សង្ខេបព្រះត្រៃបិដក ភាគទី១ ភាគទី២ (ព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម) (៤២)-ឆ្នាំ២០០០ : សាកល្បងពិចារណាការគិតរបស់ខ្មែររយៈពេលជាង ២០ សតវត្សរ៍ (៤៣)-ឆ្នាំ២០១៣ : ព្រះពុទ្ធសាសនាសម័យបុរាណ បោះពុម្ពលើកទី១ (៤៤)-ឆ្នាំ២០០២ : ឫសគល់នៃទស្សនវិជ្ជាខ្មែរ (៤៥)-ឆ្នាំ២០១៣ : ទស្សនវិជ្ជាច្បាប់ និងសាសនា (៤៦)-ឆ្នាំ២០១៦ : សីលធម៌ព្រះពុទ្ធសាសនា

៣-ត្រៀមបោះពុម្ពសៀវភៅមិនទាន់ហើយ ឆ្នាំ ២០១១-២០១៧

- ផ្តើមនិពន្ធ ឆ្នាំ ២០១១ : សង្ខេបព្រះត្រៃបិដក លើកទី២ (រៀបចំជាក្រុម)
- ផ្តើមនិពន្ធ ឆ្នាំ ២០១១ : ទស្សនវិជ្ជាខ្មែរ (ភាគទី១ ភាគទី២ និងភាគទី៣)
- ផ្តើមនិពន្ធ ឆ្នាំ ២០១១ : ចំណីអាហារ បោះពុម្ពលើកទី២ (ភាគទី១ ភាគទី២ និងភាគទី៣)ចំនួន២៥០០ទំព័រ A5)
- ផ្តើមនិពន្ធ ឆ្នាំ ២០១៣ : បកប្រែ វចនានុក្រមទស្សនវិជ្ជា ចំនួន៤០០០ ទំព័រ A4 (រៀបចំជាក្រុម)
- ផ្តើមនិពន្ធ ឆ្នាំ ២០១៣ : បកប្រែ ទស្សនវិជ្ជាភាសា ចំនួន ៣៥០ ទំព័រ A5


បកប្រែ និងបោះពុម្ពដោយ បណ្ឌិតសភាចារ្យ ខ្លុត ធីតា ប្រធានរាជបណ្ឌិត្យសភាកម្ពុជា និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោបណ្ឌិតសភាចារ្យ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពលើកទី២ ចំនួន ៥០០ ក្បាល

1[st] EDITION

គ.ស.២០១៦



រក្សាសិទ្ធិ


15 USD